ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ទស្សនវិជ្ជាព្រះពុទ្ធសាសនា

# PHILOSOPHY OF BUDDHISM



# សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ

## UNIVERSITY OF HENG SAMRIN THBONGKHMUM

# សៀវភៅ ទស្សនវិជ្ជាព្រះពុទ្ធសាសនា

PHILOSOPHY OF BUDDHISM

**សម្រាប់និស្សិតឆ្នាំទី៣ ឯកទេស ទស្សនវិជ្ជា**

**អ្នកនិពន្ធ និងចងក្រង** **គ្រូឧទ្ទេស ម៉ឺន សុផល្លា**

**គណៈកម្មការត្រួតពិនិត្យ** **លោក សេក ប៊ុនសង**

**លោក ហុក ឈានឃី**

រក្សាសិទ្ធិគ្រប់យ៉ាងដោយគ្រឹះស្ថាន

សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ

បោះពុម្ព ២០២១

អាសយដ្ឋាន: ផ្លូវជាតិលេខ៧៣ ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

ទូរសព្ទ: (៨៥៥) ១២ ៧៣ ៤២ ៣៣ (៨៥៥) ១២ ៧៩ ៧៨ ៧៩

website: www.uhst.edu.kh

ទស្សនវិជ្ជាព្រះពុទ្ធសាសនា

សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ

សហសត

UHST

UNIVERSITY OF HENG SAMRIN THBONGKHMUM

# អារម្ភកថា

ការរៀបចំនិពន្ធ និងចងក្រងសៀវភៅ **ទស្សនវិជ្ជាព្រះពុទ្ធសាសនា** គឺជាចេតនាចង់ឲ្យមនុស្សទូទៅមានការចាប់អារម្មណ៍ និងមានសេចក្តីពេញចិត្ត ក្នុងការឈ្វេងយល់អំពីពុទ្ធសាសនា ដើម្បីស្គាល់ព្រះពុទ្ធសាសនាពិតប្រាកដមែនទែន មិនមែនស្គាល់តាមរយៈពិធីកម្មនៃសាសនា ឬប្រពៃណីអ្នកកាន់សាសនាឡើយ ការស្គាល់ព្រះពុទ្ធសាសនាពិតប្រាកដគឺ តាមរយៈការសិក្សារៀនសូត្រ ការឈ្វេងយល់ ការតាមដានចំពោះសេចក្តីពិតនៅក្នុងព្រះពុទ្ធសាសនា សេចក្តីពិតនៅទីនេះ គឺសំដៅដល់ពាក្យឧបទេស របស់ព្រះសម្មាសម្ពុទ្ធ ដែលមាននៅក្នុងគម្ពីរនានារបស់ព្រះពុទ្ធសាសនា ព្រោះខ្លឹមសារពិតគឺនៅក្នុងគម្ពីរ ដែលជាមូលដ្ឋាននៃការទទួលស្គាល់ជាផ្លូវការរបស់ព្រះពុទ្ធសាសនា បន្ទាប់ពីសិក្សានៅក្នុងគម្ពីរពិតប្រាកដនោះហើយ គឺត្រូវតែធ្វើសេចក្តីពិចារណានិងវិភាគទៅលើខ្លឹមសារ នៃគម្ពីរនោះដោយឈរលើគោលការណ៍សច្ចភាព និងភាពពិសេសនៃពាក្យពេចន៍នោះ។

សៀវភៅ **ទស្សនវិជ្ជាព្រះពុទ្ធសាសនា** នេះនាំឲ្យអ្នកសិក្សាទាំងឡាយ បានស្គាល់ព្រះពុទ្ធសាសនាពិតប្រាកដគឺចង្អុលបង្ហាញនូវព្រះពុទ្ធដីកាទៅតាមលំដាប់ជាច្រើនដែលខ្លឹមសារទាំងនោះ គឺសុទ្ធតែមានគុណតម្លៃចំពោះជីវិត និងសង្គម គ្រប់ពាក្យពេចន៍ទាំងឡាយសុទ្ធតែមានអំណាច ទៅលើគ្រប់សកម្មភាពរបស់មនុស្ស គឺអភិវឌ្ឍន៍ទៅលើចិត្តគំនិតរបស់មនុស្ស ការធ្វើការសកម្មភាពការងាររបស់មនុស្ស ឱ្យរស់នៅក្នុងឧត្តមភាពនៃជីវិត ជាជីវិតដែលមានខ្លួនជាទីពឹងដោយខ្លួនឯង។

មេរៀននៅក្នុងព្រះពុទ្ធព្រះសាសនា គឺសុទ្ធតែជាបច្ចេកទេសនៃការប្រតិបត្តិ របស់មនុស្សលោកនៅក្នុងរាល់កម្មភាពរបស់មនុស្សក្នុងសង្គម ដែលត្រូវបានបង្រៀនដោយព្រះសម្មាសម្ពុទ្ធ ដោយការសិក្សាមើលឃើញថា ព្រះពុទ្ធសាសនាពោរពេញទៅដោយទស្សនវិជ្ជាវិទ្យាសាស្ត្រសង្គម និងទស្សនវិជ្ជាវិទ្យាសាស្ត្រ និងទស្សនវិជ្ជាធម្មជាតិ ដែលត្រូវបានព្រះសម្មាសម្ពុទ្ធបើកបង្ហាញដោយបញ្ញាដ៏ពិសិដ្ឋ ប្រកបដោយហេតុ ផល យ៉ាងប្រាកដ។ ដោយសារតែអ្នកសិក្សាជាច្រើនបានមើលឃើញថា ពុទ្ធវចនៈរបស់ព្រះសម្ពុទ្ធ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍទៅលើផ្នែកជាច្រើនមានដូចជា៖ វិស័យនយោបាយ វិស័យច្បាប់ វិស័យគ្រប់គ្រង វិស័យសេដ្ឋកិច្ច ទ្រឹស្តីស្តីសីលធម៌ ទ្រឹស្តីធម្មជាតិ ធម្មជាតិជីវិតរបស់មនុស្សលោក និងបរិស្ថានទូទៅ និងគុណតម្លៃជាច្រើនទៀត ព្រោះហេតុនេះហើយ ទើបក្រសួងអប់រំយុវជន និងកីឡា បានអនុញ្ញាតិឲ្យគ្រឹះស្ថានសិក្សាបញ្ចូលមុខវិជ្ជាទស្សនវិជ្ជាពុទ្ធសាសនា នៅក្នុងទៅកម្មវិធីសិក្សាជាច្រើន ដើម្បីបណ្តុះបណ្តាលតាំងពីថ្នាក់បឋមរហូតដល់ដល់ឧត្តមសិក្សា ដើម្បីជាចំណែកនៃការបណ្តុះនិស្ស័យល្អ និងនិស្ស័យសុចរិត និស្ស័យយុត្តិធម៌ ជាដើម មិនត្រឹមតែប៉ុណ្ណោះ រហូតអប់រំមនុស្សឲ្យព្យាយាមលះបង់នូវកិលេស និងអកុសលធម៌ជាច្រើនទៀតឲ្យស្រាលស្តើងពីក្នុងសន្តានចិត្ត រហូតក្លាយទៅជាមនុស្សដែលមានចិត្តល្អបរិសុទ្ធ។

គំនិតផ្ដើមនៃការសរសេរសៀវភៅនេះ និងផ្ដល់ឲ្យនូវថាមពលចិត្តគំនិត និងរាងកាយមនុស្ស ឲ្យតាំងនៅក្នុងសេចក្ដីបរិសុទ្ធ សុចរិត យុត្តិធម៌ សាមគ្គីធម៌ និងគុណតម្លៃគ្រប់យ៉ាង។

## ឧទ្ទិសស្នាដៃ

ដោយអំណាចនៃសេចក្ដីព្យាយាម ក្នុងការនិពន្ធ និងចងក្រងសៀវភៅដែលមានចំណងជើងថា **ទស្សនវិជ្ជាព្រះពុទ្ធសាសនា** ដែលបានចំណាយពេលវេលា កម្លាំងកាយ វាចា ចិត្ត អស់រយៈពេលជាច្រើនខែមកនេះ ដែលពោរពេញទៅដោយចិត្តសោមនស្ស និងឆន្ទៈប្រកបដោយកុសលក្នុងការចែករំលែកមេរៀនដ៏ពិសិដ្ឋរបស់ព្រះសម្មាសម្ពុទ្ធជាសាធារណៈនេះ គឺមានចេតនាក្នុងការចង់ឲ្យមនុស្សគ្រប់រូប បានសិក្សារៀនសូត្រ អំពីភាពត្រឹមត្រូវនៃព្រះធម៌ដែលព្រះពុទ្ធបានបង្រៀនមកហើយ។ ការនិពន្ធ និងចងក្រងនេះ គឺជាការចូលរួមចំណែកក្នុងការផ្សព្វផ្សាយ មេរៀនល្អៗដល់សាធារណជន ជាពិសេសគឺ យុវជន យុវជនារី ដែលជាសិស្ស និស្សិតដែលកំពុងតែសិក្សាទៅតាមជំនាញរបស់ខ្លួន ជាពិសេសគឺអ្នកសិក្សាជំនាញ ទស្សនវិជ្ជា ព្រោះសៀវភៅនេះគឺចងក្រង និងនិពន្ធឡើងដើម្បីសម្រួលដល់និស្សិតថ្នាក់ទស្សនវិជ្ជានេះតែម្ដង ព្រោះនៅក្នុងមុខវិជ្ជាសិក្សាជាច្រើននោះ ក៏មានមុខវិជ្ជា **ទស្សនវិជ្ជាព្រះពុទ្ធសាសនា** នេះមួយមុខដែរ សម្រាប់ឆមាសណាមួយដែលតម្រូវឲ្យសិក្សារៀនសូត្រ ដូច្នេះសៀវភៅនេះ និងបានជាសៀវភៅគោលសម្រាប់សម្រួលដល់ការសិក្សាស្រាវជ្រាវរបស់ប្អូនៗ និងអ្នកសិក្សាទីទៃៗផ្សេងទៀត។

សៀវភៅមុខវិជ្ជា **ទស្សនវិជ្ជាព្រះពុទ្ធសាសនា** ដែលនឹងនិពន្ធ និងចងក្រង ឡើងនេះសូមឧទ្ទិសស្នាដៃប្រកបដោយកុសលចេតនាថ្វាយ និងគោរពជូនចំពោះ៖

- អតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រយានីគ្រប់ៗជំនាន់
- អតីតសម្ដេចព្រះសង្ឃនាយក សម្ដេចព្រះសង្ឃនាយករង និងព្រះមហាថេរគ្រប់ៗព្រះអង្គ
- អតីតព្រះថេរានុត្ថេរៈគ្រប់ៗព្រះអង្គ សម្ដេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ វីរជន វីរនារីគ្រប់ៗរូប
- បុព្វការីជនញាតិមិត្តសាលោហិតទាំងឡាយទាំង៧សន្តាន និងក្នុងសង្សារវដ្ត
- ចំពោះពពួកសត្វទាំងឡាយគ្រប់ជាតិកំណើត និងគ្រប់ទីស្ថានទាំងឡាយ

សូមព្រះរាជវិបាកវិញ្ញាណថ្មី និងវិបាកវិញ្ញាណថ្មី លោកអ្នកសប្បុរសទាំងឡាយបានទៅកើតបដិសន្ធិក្នុងទីបរមសុខ កុំបីឃ្លៀងឃ្លាតឡើយ។

ជាពិសេសគឺសូមឧទ្ទិសស្នាដៃនេះចំពោះ៖

- ចំពោះប្រជាពលរដ្ឋខ្មែរគ្រប់រូប និងសិស្ស និស្សិត និងអ្នកសិក្សាទាំងឡាយ ដើម្បីបានជាឯកសារសម្រាប់សិក្សារៀនសូត្រ ឈ្វេងយល់ អំពីព្រះពុទ្ធសាសនាឲ្យរឹតតែមានវិសាលភាព និងសម្រាប់ផ្សព្វផ្សាយនូវសៀវភៅនេះទៅដល់មនុស្សគ្រប់ស្រទាប់វណ្ណៈ ដែលជាអ្នកសិក្សារៀនសូត្រ។

សូមឲ្យសៀវភៅនេះ បានជាមគ្គុទ្ទេសន៍ដ៏ឧត្តម សម្រាប់មនុស្សគ្រប់រូបក្នុងការសិក្សារៀនសូត្រឲ្យបាន ត្រឹមត្រូវ ដើម្បីធ្វើយ៉ាងណាឲ្យការជីវិតរស់នៅប្រកបដោយឧត្តមភាព និងវិបុលសុខដែលកើតចេញមកពីការ សិក្សាព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ។

## សេចក្តីថ្លែងអំណរព្រះគុណ និងអរគុណ

ទូលព្រះបង្គំ ខ្ញុំករុណាខ្ញុំបាទ ក្នុងនាមអ្នកនិពន្ធ និងចងក្រងនូវសៀវភៅ **ទស្សនវិជ្ជាព្រះពុទ្ធសាសនា** ដើម្បីចូលរួមចែករំលែកចំណេះដឹងដល់និស្សិត និងអ្នកសិក្សាទាំងឡាយ តាមរយៈការបង្រៀន ការពន្យល់ និង ចង្អុលបង្ហាញអំពីដំណើរ នៃការប្រព្រឹត្តទៅនូវព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលជាមេរៀនដ៏ឧត្តម សម្រាប់ មនុស្សជាតិ យកទៅអនុវត្ត (ប្រតិបត្តិ) ក្នុងជីវិតរាល់សកម្មភាពប្រចាំថ្ងៃ ដើម្បីកើតសុខ កើតសួស្តី និងកើត សុភមង្គលក្នុងជីវិត ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ក៏ដោយសារតែប្រទេសមានសន្តិភាព ព្រោះហេតុនៃ សន្តិភាពនេះហើយ ទើបធ្វើឲ្យការអភិវឌ្ឍទៅលើវិស័យនានាជាច្រើន ជាពិសេសគឺ វិស័យអប់រំ ដែលជាវិស័យ ដ៏មានសក្តានុពលបំផុត សម្រាប់កែច្នៃមនុស្សឲ្យមានពុទ្ធិ មានបញ្ញាទូលំទូលាយ រួចផុតពីអនអក្ខរជន ទន្ទឹង ទៅនឹងសុខសន្តិភាព ដែលជារតនៈមហាសាលរបស់មនុស្សជាតិនេះ ក្នុងនាមទូលព្រះបង្គំ ខ្ញុំករុណាខ្ញុំបាទ ដែលជាអ្នកនិពន្ធ និងចងក្រង សៀវភៅ **ទស្សនវិជ្ជាព្រះពុទ្ធសាសនា**នេះ សូមថ្លែងអំណរព្រះគុណ និងគុណ គោរពជូនចំពោះ ៖

- ទូលព្រះបង្គំខ្ញុំ សូមក្រាបថ្វាយបង្គំ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** សូមថ្លែងព្រះអំណរព្រះករុណាទិគុណ សម្តេចជាអង្គម្ចាស់ជីវិតលើត្បូង ដែលបានបំពេញព្រះរាជបេសកកម្ម ក្នុងការគ្រប់គ្រង និងគង់ជាម្លប់ដល់ ប្រទេសជាតិ កូនចៅ ជាពិសេសប្រទានវរោកាសដល់កូនចៅ ជាប្រជានុរាស្ត្រ បានសិក្សារៀនសូត្ររហូតមាន ឱកាសអាចសរសេរសៀវភៅ **ទស្សនវិជ្ជាព្រះពុទ្ធសាសនា**បាន និងបានក្លាយជាគ្រូបង្រៀននៅគ្រឹះស្ថានឧត្តម សិក្សាសាធារណៈដល់សព្វថ្ងៃ។ ទូលព្រះបង្គំសូមថ្វាយព្រះពរ សូមព្រះអង្គទ្រង់ចម្រើនព្រះជន្មាយុទីឃាយុ យឺនយូរជាងរយព្រះវស្សា។

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជានិច្ចកាលតែងតែយក ចិត្តទុកដាក់ខ្ពស់បំផុតចំពោះវិស័យអប់រំ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- ក្រសួងអប់រំយុវជន និងកីឡា ដឹកនាំដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា។

- **មូលនិធិស្រាវជ្រាវគំនិតច្នៃប្រឌិត និងនវានុវត្តន៍** ដែលបានបង្កើតកម្មវិធីនេះឡើង ដើម្បីផ្តល់ឱកាសដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ដែលមានឆន្ទៈស្រាប់អាចបញ្ចេញស្នាដៃរបស់ខ្លួន ក្នុងការនិពន្ធ និងចងក្រងសៀវភៅផ្សេងៗ ទៅតាមជំនាញរបស់ខ្លួន ដែលកំពុងតែប្រតិបត្តិការនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈបាននាពេលបច្ចុប្បន្ន ជាកម្មវិធីដ៏ឧត្តុង្គឧត្តមបំផុត។

- ឯកឧត្តម **ពិន វណ្ណារ៉ូ** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ។

- ឧបាសក **ម៉ឺន ម៉ន** និងឧបាសិកា **សួន ចេង** លោកទាំងពីរគឺជាអ្នកមានគុណូបការដ៏ធំធេងសម្រាប់ជីវិតរបស់ខ្ញុំតាំងពីនៅក្នុងផ្ទៃរហូតតរៀងមកដល់សព្វថ្ងៃនេះ។

- លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ គុណគ្រូឧបជ្ឈាយាចារ្យ គ្រប់រូបទាំងអស់ ដែលបានចូលមកក្នុងជីវិតរបស់ខ្ញុំតាមរយៈការផ្តល់ចំណេះដឹង ការបង្ហាត់បង្រៀនសព្វបែបយ៉ាង ធ្វើឲ្យខ្ញុំចាកចេញផុតពីភាពជាអនក្ខរជន ទទួលបាននូវតម្លៃចំណេះដឹងជាច្រើនសម្រាប់ជីវិតរស់នៅក្នុងសង្គម រហូតបានចូលរួមអភិវឌ្ឍន៍ជាតិ។

ជាទីបញ្ចប់ សូមគោរពដឹងគុណនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត គោរពជូនចំពោះសម្តេច ឯកឧត្តម លោក លោកស្រី លោកអ្នកមានគុណទាំងពីរ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សូមបានសម្រេចបំណងនូវពុទ្ធពរទាំងឡាយ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# គោលបំណង

គោលបំណងនៃការចងក្រង និងនិពន្ធចំពោះសៀវភៅមុខវិជ្ជា **ទស្សនវិជ្ជាព្រះពុទ្ធសាសនា** នេះមានចំណុចផ្តោតដូចខាងក្រោម ៖

១. នាំឲ្យមនុស្សទូទៅបានស្គាល់ដំណើរប្រវត្តិរឿងរ៉ាវសម្មាសម្ពុទ្ធព្រះពុទ្ធ

២. នាំឲ្យមនុស្សទាំងឡាយ បានស្គាល់ព្រះពុទ្ធដីកាដែលជាមេរៀនព្រះសម្មាសម្ពុទ្ធបានបង្រៀន

៣. នាំឲ្យមនុស្សទាំងឡាយស្គាល់ពីវិធីប្រតិបត្តិ និងផលនៃការប្រតិបត្តិ

ថ្វីត្បិតតែក្នុងប្រទេសកម្ពុជាយើង ប្រជាជនភាគច្រើនជាពុទ្ធសាសនិកតាំងពីកំណើតមក ប៉ុន្តែក្នុងចំណោមប្រជាជនដ៏ច្រើននោះ នៅមានប្រជាជនមួយភាគធំ មិនទាន់បានដឹងថា ព្រះពុទ្ធសាសនាជាអ្វី? ព្រះពុទ្ធបានបង្រៀនអ្វី?ព្រះពុទ្ធសាសនាពិតនៅត្រង់ណា? ប្រជាជនភាគច្រើនយល់ដឹងត្រឹមតែសម្មស្សខាងក្រៅដែលជាប្រពៃណីធ្លាប់បានមើលឃើញការអនុវត្តតៗគ្នា មកតាំងពីដូនតាមកតែប៉ុណ្ណោះ។ យោងព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ បែងចែកមនុស្សជាប្រាំពួក ដែលជាអ្នកចូលព្រៃរកឈើ បុគ្គលមួយពួកចូលព្រៃក៏រកក្រម៉ឈើ ក៏គិតថា នេះជាឈើ។ បុគ្គលមួយពួកទៀតចូលទៅក្នុងព្រៃដើម្បីរកឈើ ក៏បានសកសំបកឈើ ហើយក៏គិតថា នេះជាឈើ។ បុគ្គលមួយពួកទៀត ចូលទៅក្នុងព្រៃដើម្បីរកឈើ ក៏ទៅកាប់យកមែកឈើក៏សម្គាល់ថានេះជាឈើ។ បុគ្គលមួយក្រុមទៀតក៏ចូលទៅក្នុងព្រៃដើម្បីរកឈើដែរ ក៏បានទៅកាប់យកស្រាយឈើ ហើយក៏សម្គាល់ថានេះជាឈើ។ បុគ្គលមួយពួកទៀត ក៏ចូលទៅក្នុងព្រៃរកឈើដែរ ក៏បានទៅកាប់ដើមឈើហើយក៏បកសំបកចោលកាប់ស្រាយឈើចោល ហើយយកតែខ្លឹមឈើដែលនៅក្នុងហើយក៏ត្រឡប់មកផ្ទះវិញ។ បុគ្គលទាំង៥ពួកនេះ យើងឃើញថា ព្រះសម្មាសម្ពុទ្ធទ្រង់លើកឡើងដើម្បីធ្វើការប្រៀបធៀប ទៅនឹងអ្នកប្រតិបត្តិធម៌ដែលព្រះអង្គបានបង្រៀន គឺមានលក្ខណៈសម្បត្តិដូចជាអ្នកចូលព្រៃរកឈើដូច្នេះដែរ។

យោងព្រះពុទ្ធបំណងនេះហើយ ទើបការនិពន្ធ និងចងក្រង សៀវភៅដែលមានចំណងជើងថា **ទស្សនវិជ្ជាពុទ្ធសាសនា** បង្ហាញនូវអ្វីដែលជាសច្ចភាព បង្ហាញខ្លឹម ឲ្យអ្នកសិក្សាទាំងឡាយចូលទៅឲ្យដល់ពីពុទ្ធបំណងដែលព្រះអង្គបានបង្ហាញ ដើម្បីស្វែងរកសច្ចធម៌របស់ព្រះសម្មាសម្ពុទ្ធ យើងមិនអាចប្រតិបត្តិបែបក្រម៉ឈើ បែបសំបកឈើ បែបមែកឈើ បែបស្រាយឈើនោះឡើយ គឺត្រូវចូលទៅដល់ខ្លឹមនៃឈើតែម្តង ក្នុងន័យថា ត្រូវប្រតិបត្តិឲ្យត្រូវតាមធម៌ពិត ធម៌មែន ព្រះសទ្ធម្ម មិនមែនសទ្ធម្មបដិរូប គឺធម៌ប្លម ឬធម៌ក្លែងក្លាយឡើយ។ ការអនុវត្តធម៌ប្លម ធម៌ក្លែងក្លាយ នេះហើយទើបធ្វើឲ្យអ្នកប្រតិបត្តិជាច្រើន តែងតែខកបំណង ខាតពេលវេលា ហើយក៏ចាប់ផ្តើមពោលទោសចំពោះព្រះពុទ្ធ ចំពោះព្រះធម៌ ថាមិនសក្តិសិទ្ធិ មិនបានផល តាមទង្វើរបស់ខ្លួន តាមពិតមកពីខ្លួនឯងអ្នកប្រតិបត្តិខុសផ្លូវ ដើរមិនដឹងទិសតំបន់ បែរទៅជាបន្ទោសនូវអំពើរបស់ខ្លួនដែលសេពគប់នឹងព្រះពុទ្ធសាសនាទៅវិញ តាមពិតគឺយើងដើរលើផ្លូវប្រកបដោយទិដ្ឋិរបស់ខ្លួនតែប៉ុណ្ណោះ ឬសេពគប់តែមនុស្សដែលបង្ហាញតែធម៌ប្លមតែប៉ុណ្ណោះ នេះជាលទ្ធផលនៃការមិនយល់ដឹង។ ដើម្បីសម្រេចប្រយោជន៍គឺគប្បីសិក្សាតាមមជ្ឈិមាបដិបទា គឺផ្លូវដែលព្រះពុទ្ធបង្ហាញ នោះអ្នកនឹងទទួលផលតាមគាប់ចិត្ត។

# មាតិកាអត្ថបទ


**អារម្ភកថា** ---------- i

**ឧទ្ទិសកថា** ---------- ii

**សេចក្តីថ្លែងអំណរគុណ** ---------- iii

**គោលបំណង** ---------- v

**មាតិកាអត្ថបទ** ---------- vi

## ជំពូក១

## ពុទ្ធប្បវត្តិ

**១.១. សេចក្តីផ្តើម** ---------- ១

**១.២. ពុទ្ធប្បវត្តិសង្ខេប** ---------- ២

១.២.១. និយមន័យ ---------- ២

១.២.២. ការចុះចាប់បដិសន្ធិរបស់ព្រះពោធិសត្វ ---------- ២

១.២.៣. ការប្រសូត្ររបស់ព្រះពោធិសត្វ ---------- ៣

១.២.៤. រាជាភិសេករបស់ព្រះពោធិសត្វ ---------- ៤

១.២.៥. ការយាងចេញសាងបព្វជ្ជា (សាងផ្នួស) ព្រះពោធិសត្វ ---------- ៤

១.២.៦. ការបំពេញទុក្ករកិរិយារបស់ព្រះពោធិសត្វ ---------- ៦

១.២.៧. ការត្រាស់ដឹងរបស់ព្រះពោធិសត្វ ---------- ៦

១.២.៨. ការបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធ ---------- ៧

**១.៣. ព្រះរតនត្រៃ** ---------- ៨

១.៣.១. និយមន័យ រតនត្រៃ ---------- ៨

១.៣.២. ពុទ្ធគុណ គឺជាសេចក្តីល្អរបស់ព្រះសម្មាសម្ពុទ្ធមាន ១០ ---------- ៨

១.៣.៣. ព្រះធម្មគុណ ៦ គុណរបស់ព្រះធម៌ ---------- ១០

១.៣.៤. គុណព្រះសង្ឃមាន៩ ---------- ១១

## ជំពូក២

## ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ

**២.១. ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធសំខាន់ៗមួយចំនួន** ---------- ១៣

២.១.១. សីល៥ ---------- ១៣

២.១.២. អង្គនីមួយៗរបស់សិក្ខាបទទាំង៥ ---------- ២២

២.១.៣. កុសលកម្មបថ១០ ---------------------------------------------------------------------------- ២៧
២.១.៤. អកុសលកម្មបថ១០ ------------------------------------------------------------------------២៨
២.១.៥. មគ្គប្រកបដោយអង្គ៨------------------------------------------------------------------------៣០
២.១.៦. បារមី១០------------------------------------------------------------------------------------៣៤

## ជំពូក៣

## ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញនូវហេតុដែលនាំឲ្យវិនាស១២ប្រភេទ

**៣.១. ប្រធាននៃសេចក្តីវិនាស១២ប្រការ ------------------------------------------------------------ ៥០**
៣.១.១. ហេតុដែលនាំឱ្យវិនាសទី១------------------------------------------------------------- ៥០
៣.១.២. ហេតុដែលនាំឱ្យវិនាសទី២ -------------------------------------------------------------៥២
៣.១.៣. ហេតុដែលនាំឱ្យវិនាសទី៣------------------------------------------------------------- ៥៤
៣.១.៤. ហេតុដែលនាំឱ្យវិនាសទី៤------------------------------------------------------------- ៥៨
៣.១.៥. ហេតុដែលនាំឱ្យវិនាសទី៥------------------------------------------------------------- ៥៩
៣.១.៦. ហេតុដែលនាំឱ្យវិនាសទី៦------------------------------------------------------------- ៦១
៣.១.៧. ហេតុដែលនាំឱ្យវិនាសទី៧ -------------------------------------------------------------៦៣
៣.១.៨. ហេតុដែលនាំឱ្យវិនាសទី៨------------------------------------------------------------- ៦៤
៣.១.៩. ហេតុដែលនាំឱ្យវិនាសទី៩------------------------------------------------------------- ៦៥
៣.១.១០. ហេតុដែលនាំឱ្យវិនាសទី១០ --------------------------------------------------------- ៦៥
៣.១.១១. ហេតុដែលនាំឱ្យវិនាសទី១១ --------------------------------------------------------- ៦៦
៣.១.១២. ហេតុដែលនាំឱ្យវិនាសទី១២---------------------------------------------------------- ៦៦
**៣.២. ការបណ្តុះនិស្ស័យស្មោះត្រង់ ------------------------------------------------------------------- ៦៦**
**៣.៣. ធម៌ដែលនាំឲ្យកើតមានសិរីសួស្តី និងសុកមង្គលនៃការគ្រប់គ្រងផ្ទះមាន៤------------------------ ៧៣**

## ជំពូក៤

## ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញនូវហេតុនាំឲ្យកើតមង្គល៣៨

**៤.១. សេចក្តីផ្តើមនៃមង្គល៣៨ប្រការ ----------------------------------------------------------------- ៨១**
៤.១.១. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី១ (មាន៣ហេតុ)------------------------------------- ៨១
៤.១.២. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី២ (មាន៣ហេតុ) ------------------------------------- ៨៦
៤.១.៣. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៣ (មាន៤ហេតុ) -------------------------------------៨៧
៤.១.៤. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៤ (មាន៤ហេតុ) ------------------------------------- ៨៨

៤.១.៥. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៥ (មាន៤ហេតុ) ------------------------------------ ៨៨
៤.១.៦. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៦ (មាន៣ហេតុ ------------------------------------ ៨៩
៤.១.៧. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៧ (មាន៥ហេតុ)------------------------------------ ៩០
៤.១.៨. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៨ (មាន៤ហេតុ) ------------------------------------ ៩១
៤.១.៩. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៩ (មាន៤ហេតុ) ------------------------------------ ៩២
៤.១.១០. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី១០ (មាន៤ហេតុ)-------------------------------- ៩៣

## ជំពូក៥

## ព្រះសម្មាសម្ពុទ្ធបង្ហាញពីតួនាទីបុគ្គលក្នុងសង្គម

**៥.១. តួនាទីរបស់បុគ្គលដែលត្រូវប្រតិបត្តិមាន ---------------------------------------------------------------- ៩៥**
៥.១.១. តួនាទីមាតាបិតាចំពោះកូន---------------------------------------------------------- ៩៥
៥.១.២. តួនាទីកូនចំពោះមាតាបិតា ------------------------------------------------------- ១០៣
៥.១.៣. តួនាទីភរិយាចំពោះស្វាមី---------------------------------------------------------- ១០៤
៥.១.៤. តួនាទីស្វាមីចំពោះភរិយា ---------------------------------------------------------- ១០៦
៥.១.៥. តួនាទីសិស្សចំពោះគ្រូ ------------------------------------------------------------ ១០៨
៥.១.៦. តួនាទីគ្រូចំពោះសិស្ស ------------------------------------------------------------ ១០៩
៥.១.៧. តួនាទីថៅហ្វាយនាយចំពោះបុគ្គលិក ------------------------------------------------ ១០៩
៥.១.៨. តួនាទីបុគ្គលិកចំពោះថៅហ្វាយនាយ------------------------------------------------ ១០៩
៥.១.៩. តួនាទីសមណៈព្រាហ្មណ៍ចំពោះបរិស័ទ---------------------------------------------- ១០៩
៥.១.១០. តួនាទីបរិស័ទចំពោះសមណៈព្រាហ្មណ៍ -------------------------------------------- ១០៩
៥.១.១១. កល្យាណមិត្ត ------------------------------------------------------------------ ១០៩
៥.១.១២. បាបមិត្ត----------------------------------------------------------------------- ១១០
៥.១.១៣. អាបាយមុខ ជាប្រធាននៃសេចក្តីវិនាសភោគៈ -------------------------------------- ១១១

## ជំពូក៦

## ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញ

## អំពីលក្ខណៈសម្បត្តិអ្នកដឹកនាំ ទសពិធរាជធម៌

**៦.១. ទសពិធរាជ១០ប្រការ------------------------------------------------------------------------ ១១៣**
៦.១.១. និយមន័យទាន --------------------------------------------------------------- ១១៣
៦.១.២. ទានៈ------------------------------------------------------------------------ ១១៤

៦.១.៣. សីលៈ ---------- ១១៥

៦.១.៤. បរិច្ចាគៈ ---------- ១១៦

៦.១.៥. អាជ្ជវៈ ---------- ១១៧

៦.១.៦. មទ្ទវៈ ---------- ១១៨

៦.១.៧. តបៈ ---------- ១១៩

៦.១.៨. អក្កោធៈ ---------- ១២១

៦.១.៩. ខន្តិ ---------- ១២៦

៦.១.១០. អវិហឹសា ---------- ១២៧

៦.១.១១. អវិរោធនៈ ---------- ១២៨

**៦.២. ព្រហ្មវិហារធម៌៤ ---------- ១៣០**

៦.២.១. មេត្តា ---------- ១៣១

៦.២.២. ករុណា ---------- ១៣៣

៦.២.៣. មុទិតា ---------- ១៣៣

៦.២.៤. ឧបេក្ខា ---------- ១៣៣

**៦.៣. អគតិធម៌៤ ---------- ១៣៥**


# ជំពូក៧

# ហេតុដែលនាំឲ្យសម្រេចប្រយោជន៍លោកិយ


**៧.១. ហេតុដែលនាំឲ្យសម្រេចប្រយោជន៍លោកិយ ---------- ១៣៨**

៧.១.១. ឧដ្ឋានសម្បទា (ប្រឹងប្រែងឧស្សាហ៍ព្យាយាម បំពេញកិច្ចការទាំងឡាយ) ------ ១៣៨

៧.១.២. អារក្ខសម្បទា ---------- ១៤១

៧.១.៣. លក្ខណមិត្តតា ---------- ១៤១

៧.១.៤. សមជីវិតា ---------- ១៤៣

**៧.២. ហេតុដែលនាំឲ្យសម្រេចប្រយោជន៍លោកិយ៤ប្រការ (ឥទ្ធិបាទធម៌) ---------- ១៤៥**

៧.២.១. ឆន្ទៈ ---------- ១៤៥

៧.២.២. វិរិយៈ ---------- ១៤៥

៧.២.៣. ចិត្តៈ ---------- ១៤៥

៧.២.៤. វិមំសា ---------- ១៤៥

**៧.៣. គោលការណ៍ដែលគួរព្យកគ្រប់ពេលវេលា (សារាណីយធម៌) ---------- ១៤៦**

៧.៣.១. មេត្តាកាយកម្ម------------------------------------------------------------------------------------------១៤៦
៧.៣.២. មេត្តាវចីកម្ម ------------------------------------------------------------------------------------------១៤៦
៧.៣.៣. មេត្តាមនោកម្ម ------------------------------------------------------------------------------------------ ១៤៧
៧.៣.៤. សីលសាមញ្ញតា------------------------------------------------------------------------------------------១៤៨
៧.៣.៥. សាធារណភោគី------------------------------------------------------------------------------------------១៤៨
៧.៣.៦. ទិដ្ឋិ (សម្មាទិដ្ឋិ) ------------------------------------------------------------------------------------------១៤៨
**៧.៤. កល្យាណធម៌៥ប្រការ (ធម៌ល្អសម្រាប់ជីវិត)------------------------------------------------------------------១៥០**
៧.៤.១. មេត្តា ------------------------------------------------------------------------------------------១៥០
៧.៤.២. សម្មាអាជីវៈ------------------------------------------------------------------------------------------១៥០
៧.៤.៣. សទារសន្តោសៈ------------------------------------------------------------------------------------------១៥១
៧.៤.៤. សច្ចៈ ------------------------------------------------------------------------------------------១៥១
៧.៤.៥. សតិ ------------------------------------------------------------------------------------------១៥១
**៧.៥. ហេតុដែលនាំឲ្យអាយុខ្លីមាន៥------------------------------------------------------------------------------------------១៥១**
**៧.៦. ហេតុដែលនាំឲ្យមានអាយុវែងមាន៥------------------------------------------------------------------------------------------១៥៥**
**៧.៧. ព្រះសម្មាសម្ពុទ្ធបង្ហាញពីសេរីភាព១០ប្រការ ------------------------------------------------------------------------------------------១៥៧**

## ជំពូក៨

## សប្បុរិសធម៌៧ប្រការ

**៨.១. ព្រះសម្មាពុទ្ធ ទ្រង់បង្ហាញលក្ខណៈសម្បត្តិរបស់បុគ្គលអ្នកជោគជ័យក្នុងជីវិត --------------------១៦៤**
៨.១.១. ធម្មញ្ញុតា ជាមនុស្សស្គាល់ហេតុ ឬជាអ្នកដឹងធម៌------------------------------------------១៦៤
៨.១.២. អត្ថញ្ញុតា ជាមនុស្សស្គាល់ប្រយោជន៍ ឬស្គាល់សេចក្តី ------------------------------------------១៦៤
៨.១.៣. អត្តញ្ញុតា ជាមនុស្សស្គាល់ខ្លួនឯង------------------------------------------------------------------១៦៤
៨.១.៤.មត្តញ្ញុតា ជាមនុស្សស្គាល់ប្រមាណ ------------------------------------------------------------------១៦៥
៨.១.៥. កាលញ្ញុតា ជាមនុស្សកាលវេលា------------------------------------------------------------------១៦៥
៨.១.៦. បរិសញ្ញុតា ជាមនុស្សស្គាល់សមត្ថភាពមនុស្ស ------------------------------------------១៦៦
៨.១.៧. បុគ្គលញ្ញុតា ជាមនុស្សស្គាល់លក្ខណៈបុគ្គល------------------------------------------១៦៦
**៨.២. បុញ្ញកិរិយាវត្ថុ១០ប្រការ ------------------------------------------------------------------------------------------១៦៧**

# ជំពូក៩

# ឱវាទបាតិមោក្ខ

**៩.១. វិន័យនាំមកនៅសន្តិភាព ---------------------------------------------------------------------------------------១៧០**

៩.១.១. សព្វបាបស្ស អករណំ ការមិនធ្វើនូវអំពើបាបទាំងពួង ------------------------------ ១៧០

៩.១.២. កុសលស្សូបសម្បទា ការបំពេញកុសលឲ្យបរិបូណ៌ -------------------------------- ១៧០

៩.១.៣. សចិត្តបរិយោទបនំ ការញ៉ាំងចិត្តរបស់ខ្លួនឲ្យផូរផង -------------------------------- ១៧១

៩.១.៤. ខន្តិ បរមំ តបោ តីតិក្ខា សេចក្តីអត់ធន់ជាតបៈធម៌ដ៏ឧត្តម ------------------------ ១៧១

៩.១.៥. និព្វានំ បរមំ វទន្តិ ពុទ្ធា ព្រះនិព្វានជាធម៌ដ៏ឧត្តម---------------------------------- ១៧២

៩.១.៦. ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វហេឋយន្តោ បុគ្គលដែលសម្លាប់សត្វដ៏ទៃ មិនឈ្មោះថាបព្វជិត បុគ្គលដែលបៀតសត្វដទៃមិនឈ្មោះថាសមណៈឡើយ------------------------ ១៧៤

៩.១.៧. អនុបវាទោ អនូបឃាតោ ការមិនពោលតិះដៀល និងការមិនបៀតបៀនអ្នកដទៃ ១៧៥

៩.១.៨. បាតិមោក្ខេ ច សំវរោ ការសង្រួមក្នុងបាតិមោក្ខ--------------------------------------- ១៧៦

៩.១.៩. មត្តញ្ញុតា ច ភត្តស្មឹ ភាវៈជាអ្នកដឹងប្រមាណក្នុងភត្ត----------------------------------- ១៧៨

៩.១.១០. បន្តញ្ច សយនាសនំ ទីដេក ទីអង្គុយដ៏ស្ងាត់ ----------------------------------------១៨០

៩.១.១១. អធិចិត្តេ ច អាយោគោ ការបំពេញព្យាយាមក្នុងអធិចិត្ត---------------------------១៨០

# ជំពូក ១០

# ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញអំពីរឿងពិតនៃជីវិត អរិយសច្ចៈ

**១០.១. អរិយសច្ចៈ៤ប្រការ --------------------------------------------------------------------------------- ១៨៣**

១០.២. បដិច្ចសមុប្បាទធម៌--------------------------------------------------------------------------១៩១

១០.៣. សាមញ្ញលក្ខណៈធម៌៣ប្រភេទ ---------------------------------------------------------------១៩៨

១០.៤. សមាធិ និងបស្សនា -------------------------------------------------------------------------- ២១៤

១០.៤.១. និយមន័យសមាធិ ------------------------------------------------------------------------- ២១៤

១០.៤.២. វិបស្សនា -----------------------------------------------------------------------------------២៣០

១០.៤.៣. សារប្រយោជន៍សមាធិ--------------------------------------------------------------------- ២៥២

# ជំពូក ១១

# ឈ្វេងយល់អំពីបុណ្យសំខាន់ៗក្នុងព្រះពុទ្ធសាសនា

**១១.១. ឈ្វេងអំពីបុណ្យមាឃបូជា ---------------------------------------------------------------------------២៥៦**

**១១.២. ឈ្វេងអំពីបុណ្យវិសាបូជា -----------------------------------------------------------------------------២៥៩**

១១.៣. ឈ្វេងយល់អំពីបុណ្យកឋិន------------------------------------------------------------------------២៦០
១១.៤. ឈ្វេងយល់អំពីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ------------------------------------------------------- ២៦៣
១១.៥. ឈ្វេងយល់អំពីការបំបួសនាគ ---------------------------------------------------------------------២៦៥
១១.៦. ឈ្វេងយល់ការចូលវស្សា និងការចេញវស្សា ------------------------------------------------------- ២៧០
១១.៧. ឈ្វេងយល់អំពីតួនាទីវត្តអារាមព្រះពុទ្ធសាសនា ------------------------------------------------- ២៧១
១១.៨. ឈ្វេងយល់អំពីកិច្ចដើម្បីបានងារជាឧបាសក និងឧបាសិកាក្នុងព្រះពុទ្ធសាសនា-------------- ២៧៤
១១.៩. ឈ្វេងយល់អំពីគម្ពីរព្រះត្រៃបិដក------------------------------------------------------------------ ២៧៦
១១.១០. ឈ្វេងយល់អំពីព្រះពុទ្ធបដិមា នៅប្រទេសកម្ពុជា ---------------------------------------------- ២៧៨
១១.១១. ឈ្វេងយល់អំពីពិធីបុណ្យចូលឆ្នាំខ្មែរ ---------------------------------------------------------------២៨០
សន្និដ្ឋានរួម-----------------------------------------------------------------------------------------------------២៨៥
អនុសាសន៍ ------------------------------------------------------------------------------------------------------ ២៨៧
គន្ថនិទ្ទេស-------------------------------------------------------------------------------------------------------២៨៩

# ជំពូក១

# ពុទ្ធប្បវត្តិ

## ១.១. សេចក្តីផ្តើម

ដើម្បីចាប់ផ្តើមក្នុងការសិក្សាចំពោះព្រះពុទ្ធសាសនា គឺយើងទាំងឡាយ គប្បីសិក្សាអំពីប្រវត្តិព្រះសម្មាសម្ពុទ្ធជាខាងដើមសិន ថាតើព្រះពុទ្ធជានរណា? ជាកូនចៅរបស់ណា? មានទីកន្លែងនៅទីណា? មានប្រវត្តិយ៉ាងដូចម្តេច? ព្រោះការសិក្សាអំពីប្រវត្តិគឺជារឿងដែលសំខាន់បំផុត ដើម្បីងាយស្រួលក្នុងការតាមដានទៅលើរឿងរ៉ាវផ្សេងៗ សកម្មភាពផ្សេងៗនៃព្រះបរមសាស្ត្រាចារ្យ។ ប្រវត្តិរបស់ព្រះសម្មាសម្ពុទ្ធគឺបានបង្ហាញយ៉ាងច្បាស់នូវចរិយាធម៌ ដែលព្រះអង្គបាបង្ហាញដោយគ្មានលាក់បាំង តាំងពីអតីតកាល រហូតដល់ដំណាក់កាលដែលព្រះអង្គមានព្រះវត្តមាន នៅចំពោះមុខមនុស្សទូទៅជាសាធារណៈ អ្វីដែលព្រះអង្គបានបង្ហាញនោះគឺចាប់តាំងពីការប្រសូត្រមកម្ល៉េះ គ្រាន់តែប្រសូត្រហើយភ្លាម ក៏ព្រះអង្គបានបង្ហាញអំពីសេចក្តីពិតរបស់អង្គថា អាត្មាអញជាកំពូលនៃមនុស្សលោកជាចម្បងជាងគេក្នុងលោកប្រសើរជាងគេក្នុងលោក នេះជាជាតិចុងក្រោយបំផុតរបស់អាត្មាអញហើយ អំណើះតទៅអាត្មាអញលែងកើតទៀតហើយ។ ចាប់ពីពេលនោះ ប្រវត្តិរបស់ព្រះសាស្ត្រាចារ្យ ត្រូវបានប្រជាជនឥណ្ឌាសម័យនោះ បានស្គាល់ស្ទើតែគ្រប់ច្រកល្ហក រហូតមានអ្នកខ្លះចេញបួសតាមព្រះអង្គជាបន្តបន្ទាប់។ សម្រាប់ប្រជាជនខ្មែរយើងវិញ មានអ្នកកាន់ព្រះពុទ្ធសាសនាជាច្រើន ដែលមិនបានដឹងអំពីប្រវត្តិរបស់ព្រះសម្មាសម្ពុទ្ធទេ អ្នកខ្លះទៀតដឹងព្រាលៗ អ្នកខ្លះទៀតក៏ដឹងបានសមរម្យ អ្នកខ្លះទៀតក៏ដឹងច្រើនតាមការសិក្សារៀនសូត្រ ហើយការដឹងអំពីប្រវត្តិរបស់ព្រះសម្មាសម្ពុទ្ធនេះ គឺជាចំណុចចាប់ដំបូង បន្ទាប់មកទើបឈានចូលទៅដល់ការសិក្សាអំពីព្រះពុទ្ធដីកានានាជាច្រើន ដែលព្រះអង្គទ្រង់បង្រៀនមកដោយច្រើន។ ការស្គាល់ព្រះសម្មាសម្ពុទ្ធច្បាស់ដោយបញ្ញា គឺធ្វើឲ្យសទ្ធារបស់យើងរឹងមាំ សទ្ធារបស់យើងជឿជាក់ សទ្ធារបស់យើងមិនចេះប្រែប្រួលពាសវាលពាសកាល ព្រោះបានដឹងអំពីលក្ខណៈសម្បត្តិរបស់ព្រះអង្គរួចហើយ។ ព្រះអង្គគឺជាមនុស្សលោក មានទីកន្លែងច្បាស់លាស់ មានព្រះមាតាព្រះបិតា មានព្រះមហេសី មានព្រះរាជបុត្រ មានព្រះញាតិវង្សានុវង្ស មានអាណាប្រជានុរាស្ត្រសុខចិត្តលះបង់ព្រះរាជសម្បត្តិ លះបង់ព្រះនគរ លះបង់ព្រះអគ្គមហេសី លះបង់ព្រះបិតា លះបង់ព្រះញាតិវង្សានុវង្សដើម្បីបំពេញកិច្ចជាអ្នកបួស ដើម្បីស្វែងរកត្រាស់ដឹង ដើម្បីស្វែងរកនូវសច្ចៈធម៌ គឺសេចក្តីពិត និងមាគ៌ាដើម្បីរលាស់ខ្លួនចេញចាក់អំពី សេចក្តីទុក្ខគឺព្រះនិព្វានព្រះអង្គបានព្យាយាមប្រតិបត្តិយ៉ាងតឹងតែងបំផុត ដើម្បីរកឲ្យឃើញនូវសេចក្តីទុក្ខ ឫសគល់នៃសេចក្តីទុក្ខ ហេតុដែលនាំឲ្យកើតទុក្ខ កន្លែងរំលត់ទុក្ខ និងមធ្យោបាយប្រតិបត្តិដើម្បីចេញចាកទុក្ខ ទីបំផុតព្រះអង្គបានរកឃើញនូវអរិយសច្ចធម៌ ដោយខ្លួនព្រះអង្គផ្ទាល់។ ដូច្នេះការសិក្សាអំពីប្រវត្តិរឿងរ៉ាវរបស់ព្រះសម្មាសម្ពុទ្ធ គឺប្រសើរខ្លាំងណាស់ ក្នុងនាមជាពុទ្ធបរិស័ទ មិនត្រឹមតែដឹងអំពីសកម្មភាពរបស់ព្រះអង្គតែប៉ុណ្ណោះទេ តែក៏ទទួលបាននូវបទពិសោធល្អៗ ដំណើរល្អៗ សម្រាប់អនុវត្តក្នុងជីវិតយ៉ាងពិសេសទៀតផង។

## ១.២. ពុទ្ធប្បវត្តិសង្ខេប

### ១.២.១. និយមន័យ

ពុទ្ធ ៖ មានន័យថា ព្រះអង្គជាអ្នកភ្ញាក់រឭក ព្រះអង្គជាបុគ្គលរីក ព្រះអង្គជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច។

ន័យថា ព្រះអង្គជាអ្នកភ្ញាក់រឭកនោះគឺ ភ្ញាក់រឭកពីការដេកលក់ក្នុងអនុស័យ៧យ៉ាងមាន៖ ដេកលក់ក្នុងសេចក្តីត្រេកត្រអាលទៅរកបញ្ចកាមគុណ១ ដេកលក់ក្នុងសេចក្តីត្រេកត្រអាលក្នុងភព១ ដេកលក់ក្នុងបដិឃៈសេចក្តីថ្នាំងថ្នាក់១ ដេកលក់ក្នុងទិដ្ឋិសេចក្តីប្រកាន់១ ដេកលក់ក្នុងទិដ្ឋិសេចក្តីយល់ខុស១ ដេកលក់ក្នុងវិចិកិច្ឆាគឺសេចក្តីសង្ស័យស្ទាក់ស្ទើមិនចេះអស់មិនចេះហើយ១ ដេកលក់ក្នុងអវិជ្ជា គឺសេចក្តីល្ងង់ខ្លៅមិនឃើញច្បាស់នូវអរិយសច្ចៈ១។ ធម៌ដែលជាអកុសលទាំងនេះ ព្រះសាស្តាទ្រង់បានកម្ចាត់ចោលអស់ហើយចាប់ពីព្រះអង្គទ្រង់បាននូវអនុត្តរសម្មាសម្ពោធិញ្ញាណ។

ន័យថាព្រះអង្គជាបុគ្គលរីកគឺព្រះអង្គរីកចេញអំពីអវិជ្ជាសេចក្តីល្ងង់ កាលសត្វទាំងឡាយកំពុងអន្ទោលទៅក្នុងក្នុងវដ្តសង្សារ មិនទាន់បានត្រាស់ដឹងនៅឡើយ អវិជ្ជារមែងរឹតរុំព័ទ្ធជិតមិនឲ្យមានពន្លឺ គឺបញ្ញារីកសាយឡើងបាន និងមិនឲ្យឃើញនូវធម៌ពិតឡើយ ដូចជាកូនមាន់មិនទាន់ញាស់ សំបកពងនៅកំពុង រុំស្រោប រមែងមិនឃើញនូវបន្លឺព្រះអាទិត្យ លុះតែកូនមាន់នោះខំប្រឹងយកចំពុះ និងចុងក្រចកចឹកទម្លុះ សំបកពងនោះចេញទើបឃើញពន្លឺព្រះអាទិត្យ។

ន័យថា ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌នោះគឺ ទុក្ខសច្ចៈ ទុក្ខ១២កង មានជាតិទុក្ខជាដើម១។ សមុយទសច្ចៈ ហេតុដែលនាំឲ្យកើតទុក្ខ គឺតណ្ហាទាំង៣ កាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា១។ និរោធសច្ចៈ សេចក្តីរំលត់កងទុក្ខទាំងឡាយ១។ មគ្គសច្ចៈ អរិយមគ្គទាំង៨ ជាឧបាយសម្លាប់នូវសេចក្តីទុក្ខ[1]។

### ១.២.២. ការចុះចាប់បដិសន្ធិរបស់ព្រះពោធិសត្វ

ព្រះបាទសុទ្ធោទនជាត្រកូលគោត្តមហើយជាស្តេចសក្យនៅក្រុង កបិលវត្ថុ មានអគ្គមហេសី១ព្រះអង្គមានរូបល្អបរិបូណ៌ ដោយលក្ខណៈនាមថាជា ព្រះមាយាទេវី ជាត្រកូលកោឡិ (កោលិយ)។ រាត្រីមួយនោះព្រះនាងទ្រង់ផ្ទំលក់សុបិនឃើញដំរីសមួយមានភ្លុក៦ ចុះមកពីលើអាកាសចូលទៅក្នុងផ្ទៃព្រះនាងតាមឆ្អឹងជំនីខាងស្តាំ ដែលពិតនោះ គឺនឹងជាព្រះពុទ្ធ ក្នុងខាងមុខនោះឯង ចុះចាក់ឋានតុសិត ក្នុងវេលាយប់នោះមកកាន់យកបដិសន្ធិក្នុងផ្ទៃព្រះមាយាទេវី ព្រះនាងមាយាទេវីលុះព្រឹកឡើងស្អែកឡើង ព្រះបាទសុទ្ធោទន ឲ្យហៅថាព្រាហ្មណ៍ជាច្រើនមកទាយសុបិន ព្រាហ្មណ៍ក៏បានទាយថា រាជទេវីនឹងមានបុត្តមួយព្រះអង្គប្រកប ដោយលក្ខណៈគ្រប់យ៉ាង ហើយទាយតទៅទៀតថា បើប្រសិនណាជាព្រះរាជឱរសនេះនៅក្នុងនគរនឹងបានជាស្តេចមហាចក្រពត្តិបើចេញពីនគរទៅនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គស្រោចស្រង់សត្វលោក។

---

[1] ឈឹម ទូច ប្រស្នាត្រៃគុណ ពុទ្ធសាសនបណ្ឌិត្យ គ.ស១៩៩៩ ទំព័រ ៦២

### ១.២.៣. ការប្រសូត្ររបស់ព្រះពោធិសត្វ

លុះជិតថ្ងៃខែនឹងប្រសូត្របុត្រនោះព្រះនាង មាយាទេវី ក៏ក្នុកវាជហឫទ័យចង់ទៅយាងទៅសួរ ព្រះវរបិតាមាតានៅក្រុងទេវទហៈនាងគង់លើកមាស មានសេនាយោធាមាត្យជាច្រើន ហែរហមតាមក្រោយទៅ លុះដល់ដើមរាំង១ ដែលនៅចុះព្រំដែនទាំងពីរគឺ កបិវត្ថុ និងទេវទហៈ ហើយដែលគេហៅថា ព្រៃលុម្ពិនី នាងក៏ចង់ឈប់នៅទីនោះ ហើយយាងចុះទៅឈរក្រោមរាំង លើកព្រះហស្តឈោងចាប់មែកឈើនោះ មែកនោះក៏ទន់ទាប់មកដល់ដៃនាង ក៏ប្រសូត្ររាជបុត្រមកក្នុងវេលានោះឥតមានឈឺចាប់អ្វីឡើយ។

ព្រះរាជឱរសប្រសូត្រមកឥតមានប្រឡាក់មន្ទិលសៅហ្មងឡើយ តែវេលានោះ មានទវខ្សែទឹក២ធ្លាក់ចុះមកពីអាកាស ស្រោចស្រង់ឲ្យមួយអន្លើ និងព្រះមាតា។

ព្រះពោធិសត្វ នៅវេលាដែលប្រសូត្រចាកឧទរព្រះមាតាមក មានមហាព្រហ្ម៤នាក់ យកបណ្ដាញមាសមកទទួល រួចមហារាជទាំង៤ (ចតុលោកបាល) យកស្បែកឈ្លូសមកទទួលតទៅទៀត រួចពីនោះទើបមនុស្សទាំងឡាយយកសំពត់កោសេយ្យភ័ស្ដមកទទួលទៅ តមកទៀត ព្រះបរមពោធិសត្វក៏ឈរលើផែនដីហើយឈាន៧ជំហានទៅកាន់ទិសខាងកើត មានព្រហ្មមួយអង្គបាំងក្លស់ថ្វាយ ហើយសុយាមទេវបុត្រ កាន់សេះតាមក្រោយ លុះឆ្លោះព្រះនេត្រគ្រប់ទិសទាំង១០ហើយ ក៏បន្លឺវាចាភេទថាដូចនេះ ៖

" អញជាកំពូលនៃលោក ជាបុគ្គលប្រសើរជាងគេក្នុងលោក ជាច្បងគេទាំងអស់ក្នុងលោក នេះហើយជាកំណើតក្រោយគេបំផុតរបស់អញ អំណើះតទៅមុខទៅ អញគ្មានកើតទៀតឡើយ"។

រួចពីវេលានោះ គេបានយាងព្រះនាង មាយា ឲ្យយាងត្រឡប់ចូលទៅកាន់នគរកបិលវត្ថុវិញ មួយអន្លើដោយព្រះរាជបុត្រ ហើយយកព្រះរាជបុត្រទៅថ្វាយដល់ព្រះវររាជបិតា លុះកន្លងទៅ៧ថ្ងៃ ព្រះនាងមាយាទេវីក៏ចូលវិលាល័យទៅ ហើយទៅចាប់បដិសន្ធិនៅស្ថានត្រៃត្រឹង ឯព្រះរាជបុត្រនោះស្ដេចបានប្រគល់ឲ្យនាងមហាបជាបតិគោតមីជាម្ដាយមីរក្សា។

អំពីកាឡទេវិល តាបសចូលទៅថ្វាយព្រះពរ សម័យមួយនោះ កាឡទេវិលតាបសចូលទៅក្នុងវាំងហើយសូមព្រះរាជបុត្រមើល ព្រះបាទសុទ្ធោទនទ្រង់ត្រាស់បង្គាប់ឲ្យយកព្រះរាជបុត្តមក ហើយឲ្យថ្វាយបង្គំតាបសនោះ ប៉ុន្តែវេលានោះ ព្រះរាជកុមាមិនថ្វាយបង្គំ ក៏លើជើងទាំងពីរជាន់លើផ្នួងសក់មុនីនោះវិញ តាបសក៏ក្រោកចេញពីកន្លែង ហើយសំពះទៅបរមពោធិសត្វ រួចពីសំពះទើបញញឹមៗ ហើយយំតទៅទៀតព្រះបាទសុទ្ធោទន ទ្រង់មានសេចក្ដីសង្ស័យ ទើបសួរទៅតាបសអំពីហេតុដែលញញឹម និងយំ តាបសក៏ក្រាបទូលវិញថា បានជាអាត្មាភាពញញឹមវិញ ព្រោះឃើញថាអយ្យបុត្រនេះ តទៅមុខនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គស្រោចស្រង់សត្វលោក ហើយឯអាត្មាភាពយំនោះ ព្រោះស្ដាយដោយខ្លួនអាត្មាភាពឯង មិនអាចនឹងរស់នៅបានទាន់កាល ដែលបានត្រាស់ដឹងនោះ តែតាបសនោះចង់ឲ្យនាលកជាក្មួយទៅចូលបួស ឯនាលកទៅមុខទៅ នឹងបានចូលក្នុងពុទ្ធសាសនាហើយ បានសម្រេចនិរាណ៌ (និព្វាន)ក្រោយនោះបន្តិច។

នៅថ្ងៃទី៥ ក្រោយប្រសូត មានពិធីជ្រើសរើសនាមថ្វាយ ព្រះបរមពោធិសត្វ វេលានោះព្រះបាទសុទ្ធោ-

ទនៈ ទ្រង់ចាត់ឲ្យហៅថា ព្រាហ្មណ៍៣៨នាក់ដែលឈ្លាសក្នុងសិប្បសាស្ត្រមករើសនាមថ្វាយ ហើយព្រាហ្មណ៍ទាំងនោះក៏ថ្វាយព្រះនាមថា សិទ្ធាថ៌ (សិទ្ធត្ថ) លុះបានពិនិត្យមើលលក្ខណៈនៃរូបរបស់អយ្យបុត្រស្រេចហើយ ព្រាហ្មណ៍៧នាក់លើកម្រាមដៃពីរគ្រប់គ្នា ហើយទាយថា ប្រសិនព្រះរាជកុមារនេះនៅក្នុងនគរនឹងបានជាស្តេចចក្រពត្តិ បើចេញពីនគរនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គ ប៉ុន្តែឯព្រាហ្មណ៍ទី៨ គឺកោណ្ឌិត្យព្រាហ្មណ៍លើកម្រាមដៃតែមួយ ហើយទាយថា ព្រះអយ្យបុត្រនេះ ប្រាកដជាបានត្រាស់ជាព្រះពុទ្ធ១ព្រះអង្គដោយពិត។

នៅវេលាដែលព្រាហ្មណ៍ទាំងនោះថ្វាយព្រះនាមទំនាយនោះហើយព្រះបាទសុទ្ធោទនទ្រង់សួរទៅកាន់ព្រាហ្មណ៍ទាំងនោះថា ក្នុងស្ថានភាពដូចម្តេចខ្លះ ដែលកូនអញនឹងចេញចាកពីនគរទៅបួសនោះ? ព្រាហ្មណ៍ឆ្លើយថា នៅវេលាដែលបានឃើញនូវបុព្វនិមិត្តទាំង៤យ៉ាង ទ្រង់សួរទៀតថា និមិត្តទាំងនោះមានប្រការដូចម្តេចខ្លះ? ព្រាហ្មណ៍ឆ្លើយថា គឺឃើញមនុស្សជរា មនុស្សព្យាធិ មនុស្សមរណៈ និងភិក្ខុ (ភេទអ្នកបួស) វេលានោះទ្រង់ក៏ចាត់ការឲ្យប្រយ័ត្នយ៉ាងមាំ ដើម្បីកុំឲ្យព្រះអយ្យបុត្រឃើញរូបទាំងនោះឡើយ។

ទ្រង់ប្រសូត្រនៅថ្ងៃ សុក្រ ពេញបូណ៌មី ខែពិសាខ ឆ្នាំច នាលុម្ពិនីវ័នឧទ្យាន ដែលស្ថិតនៅក្នុងអាណាខេត្តប្រទេសនេប៉ាល់ ជិតព្រំប្រទស់នេប៉ាល់ និងឥណ្ឌាបច្ចុប្បន្ន[2]។

### ១.២.៤. រាជាភិសេករបស់ព្រះពោធិសត្វ

លុះព្រះពោធិសត្វ ព្រះជន្មបាន១៦ឆ្នាំ ព្រះវររាជបិតា បានសាងប្រាសាទ៣ថ្វាយ គង់គ្រប់រដូវ (រដូវ១ប្រាសាទ១) ទ្រង់ក៏ក្រសាលសប្បាយ ក្នុងប្រាសាទទាំង៣ មួយអន្លើនឹងស្រីស្នំបួនម៉ឺនជាបរិវារ (នាដកី) ទ្រង់មានព្រះអគ្គមហេសីមួយអង្គជាព្រះមាតារបស់រាហុល។

ដោយចេះតែក្រសាលសប្បាយ ឥតមានទុក្ខព្រួយបារម្ភគិតអ្វីសោះនោះ ពួកសក្យរិះគន់ថ្កោលទោសថា សិទ្ធថ៌ នេះមិនបានរៀនសិល្បធ្នូសោះ ប្រសិនបើមានចម្បាំងមកដល់ និងធ្វើដូចម្តេចទៅ លុះព្រះអយ្យបុត្របានជ្រាបនូវសេចក្តីនោះយ៉ាងដូច្នេះហើយ ទ្រង់បានឲ្យដើរប៉ាវគង ទូងភេរី ឲ្យដំណឹងដល់ពួកសក្យទាំងអស់ថា ក្នុង៧ថ្ងៃទៀត ទ្រង់នឹងចេញសម្តែងវិធីឲ្យឃើញចេស្តាពល់គ្នា លុះដល់ថ្ងៃដែលកំណត់ហើយ ទ្រង់ក៏ស្តេចចេញទៅបាញ់ធ្នូស្ទាត់ពូកែជាងពួកខ្មាន់ទាំងអស់។

ទ្រង់បានទទួលរាជាភិសេក ជាមួយនឹងព្រះនាងពិម្ពាយសោធរា ដែលមានព្រះជន្មតំណាល់គ្នា សោយរាជ្យជាធំលើសក្យវង្ស គ្រប់គ្រងក្រុងបិលវត្ថុ តំណាងព្រះបាទសុទ្ធោទនជាព្រះវររាជបិតានៅថ្ងៃអាទិត្យ ពេញបូណ៌មី ខែកត្តិក ឆ្នាំឆ្លូវ ទ្រង់សោយរាជ្យបាន១៣ឆ្នាំ។

### ១.២.៥. ការយាងចេញសាងបព្វជ្ជា (សាងផ្នួស) ព្រះពោធិសត្វ

ក្នុងថ្ងៃមួយនោះព្រះបរមពោធិសត្វ ទ្រង់គង់ព្រះរាជយានរថ ស្តេចទៅក្រសាលក្នុងឧទ្យាន វេលានោះមានទេវបុត្រមួយអង្គព្រះអង្គនិម្មិតឲ្យឃើញថា រូបមនុស្សចាស់ លុះទ្រង់ជ្រាប់បានដោយនាយ សារថី ទូលថា

---

[2] ពុទ្ធសាសនា ២៥០០ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៤៥ ទំព័រ ១

សេចក្តីជរានេះ នឹងមានដល់គ្រប់រូបមនុស្សជាតិ នោះទ្រង់ក៏ឲ្យត្រឡប់ព្រះរាជរថវិលត្រឡប់ចូលទៅក្នុងព្រះបរមរាជវាំងវិញ។

លើកទី២ ទ្រង់បានឃើញមនុស្សមានជំងឺ

លើកទី៣ ទ្រង់បានឃើញមនុស្សស្លាប់

លើកទី៤ ទ្រង់បានឃើញមនុស្សដែលជាភេទអ្នកបួស (ភិក្ខុ)។ នៅក្នុងវេលានោះ ទ្រង់ភ្ញាក់ព្រះរាជហឫទ័យបម្រុងនឹងចេញចាកលោកសន្និវាស ប៉ុន្តែសម័យនោះ ទ្រង់យាងហួសទៅដល់ឧទ្យានហើយស្រង់ជម្រះព្រះអង្គនៅទីនោះ លុះស្រង់ជម្រះព្រះអង្គរួចហើយ ទើបព្រះវិស្វកម៌ន និម្មិតជាជាងខ្មាន់ព្រះកេសយកគ្រឿងអលង្ការយ៉ាងល្អមកថ្វាយក្នុងវេលានោះៗ មានរាជទូតពីព្រះវររាជបិតាមកក្រាបបង្គំទូលថា ព្រះរាជបុត្រព្រះអង្គទើបនឹងប្រសូត្រថ្វាយព្រះនាមជា រាហុលកុមារ ហើយក៏ទ្រង់ត្រឡប់ចូលមកក្នុងព្រះបរមរាជវាំងវិញ។

ដោយព្រះអង្គមានសេចក្តីខ្ពើម រអើមលោកសន្និវាសនេះ ពេកណាស់ទ្រង់តើនចាក់ក្រឡាព្រះបន្ទំ ហើយហៅថា ឆន្នក ជានាយរក្សាសេះ បង្គាប់ឲ្យរៀបចងអានសេះកណ្ឋក ជារាជយានរបស់ព្រះអង្គ ប៉ុន្តែមុននឹងស្តេចចេញទៅ ទ្រង់មានព្រះរាជហឫទ័យ ចង់ឃើញព្រះរាជបុត្រសិន។

លុះយាងចូលទៅក្នុងបន្ទប់ព្រះអគ្គមហេសី ទ្រង់ក៏បានឃើញព្រះរាជទេវី ដោយអំណាចពន្លឺយ៉ាងតិចកំពុងតែផ្ទំលើក្រឡាព្រះបន្ទំ ដែលដេរដាសដោយផ្កាក្រអូបជាច្រើន ដាក់ព្រះហស្តគងទៅលើព្រះសិរព្រះរាជបុត្រ ទ្រង់ព្រះតម្រិះថា បើទ្រង់នឹងចាប់ត្រកងរាជបុត្រឡើង សមព្រះរាជទេវី នឹងភ្ញាក់ដឹងស្មារតីមិនខាន់នោះទេ ព្រះអង្គថយមកវិញ។

ឯ កណ្ឋកៈ ជាសេះយានព្រះអង្គមានសម្បុរសល្អយ៉ាងសមឈរចាំនៅក្រៅ ទេវតាទាំងឡាយបិទផ្ទប់សម្រែកសេះ មិនឲ្យលាន់ឮហើយយកដៃទ្រដើងសេះ ចាំនៅទីនោះ ដើម្បីមិនឲ្យបណ្តាជនទាំងឡាយភ្ញាក់ដឹងដល់ម្នាក់ឡើយ។

លុះពេលកណ្តាលអាធ្រាត្រព្រះអង្គក៏ទ្រង់ឡើងលើសេះព្រះរាជយានឯឆន្នកៈក៏តោងកន្ទុយសេះនោះចេញទៅលុះដល់មាត់ទ្វារក្រៅ វេលានោះទេវតាដែលចាំទ្វារនោះ បើទ្វារថ្វាយព្រះអង្គឲ្យចេញផុតទៅយប់នោះព្រះអង្គយាងកាត់នគរបីបានចម្ងាយ៣០យោជន៍ដល់ស្ទឹងអនោមាសេះនោះក៏ផ្លោះរំលង១ ជំហានផុតទៅ។

លុះដល់ស្ទឹងត្រើយម្ខាង ក៏ចុះពីខ្នងសេះ ដោះអស់គ្រឿងប្រដាប់មានមកុដជាដើម ប្រគល់ឲ្យទៅឆន្នកៈ ហើយកាត់ព្រះកេសាដោយព្រះខ័ន សក់ព្រះអង្គនៅសល់ប្រវែង២ធ្នាប់ ហើយគួចត្របាញ់វិលឯងទៅខាងស្តាំ ឯពុកចង្កាមានស្ថានមានដូចគ្នា មិនបាច់ឲ្យព្រះអង្គកាត់ ឬកោរទៀតឡើយ រួចពីនោះព្រះអង្គក៏បោះព្រះកេសា និងផ្នួងសក់នឹងឆ្នូតនេះ អណ្តែតទៅលើអាកាសបើមិនបានត្រាស់ដឹងទេ សូមឲ្យធ្លាក់មកលើផែនដីវិញ វេលានោះ ឯសក់នឹងឆ្នូតនោះ ក៏អណ្តែតទៅលើអាកាសកម្ពស់មួយយោជន៍ លុះព្រះឥន្ទបានឃើញក៏យកប្រអប់១ ដ៏មានតម្លៃមកទទួលហើយយកទៅតម្កល់ក្នុងចូលាមណិចេតិយ នៅស្ថានសួគ៌ត្រៃត្រឹង។

ទ្រង់ចេញសាងព្រះផ្នួស ក្នុងថ្ងៃព្រហស្បតិ៍ ពេញបូណ៌មី ខែអស្សុជឆ្នាំថោះ នាឆ្នេរស្ទឹងអនោមា។

### ១.២.៦. ការបំពេញទុក្ករកិរិយារបស់ព្រះពោធិសត្វ

ក្រោយដែលទ្រង់បានរៀនវិជ្ជាអំពីសំណាក់តាបស អាឡារកាលាម នៅវេសាលី និងតាបស ឧទ្រករាមបុត្រ នៅរាជគ្រឹះហើយ ហើយមិនបានគាប់ព្រះរាជហឫទ័យ នោះទ្រង់ក៏ប្ដេជ្ញានឹងល្បងប្រព្រឹត្តទុក្ករកិរិយា តែមួយព្រះអង្គឯងមើល មហាបធាន វេលានោះទ្រង់យាងទៅស្ថិតនៅឧរុវេឡា មួយអន្លើយនឹងបញ្ចវគ្គិយ៥រូប ហើយទ្រង់បង្អត់អាហារខ្លួនព្រះអង្គឯងកំណត់៦ឆ្នាំ លុះដល់ដួលបាត់ស្មារតីដូចស្លាប់ ព្រះអង្គមានអាការៈរាងកាយនោះ ស្គមនៅតែឆ្អឹង តែមិនបានសម្រេចនូវពោធិញាណ។ ព្រះអង្គទ្រង់យល់ឃើញថា ការដែលបង្អត់អាហារខ្លួនព្រះអង្គ មិនជាការមានប្រយោជន៍ ទ្រង់ក៏យាងបិណ្ឌបាតយកចង្ហាន់ឆាន់វិញ វេលានោះបញ្ចវគ្គិយអស់សង្ឃឹមលែងទុកចិត្តលើព្រះអង្គក៏នាំគ្នាទៅនៅទីមួយចម្ងាយ១៨យោជន៍ពីព្រះអង្គហៅថា ឥសិបតន។

### ១.២.៧. ការត្រាស់ដឹងរបស់ព្រះពោធិសត្វ

មាននារីម្នាក់នៅប្រទេសឧរុវេឡា នាមនាង សុជាតា បានតាំងចិត្តប្ដេជ្ញា ថានឹងយកចង្ហាន់ទៅថ្វាយដើមនិគ្រោធ១រាល់ឆ្នាំ។

ក្នុងឆ្នាំទី៦ ដែលព្រះអង្គទ្រង់ចង្រ្កមនៅក្នុងព្រៃនោះ នាង សុជាតា បានរៀបធ្វើអាហារយ៉ាងឆ្ងាញ់លាយដោយទឹកដោះគោ (បាយាស) ដើម្បីយកទៅថ្វាយដើមនិគ្រោធ (ជ្រៃ) នៅថ្ងៃពេញបូណ៌មីខែពិសាខនាងបានប្រើបាវម្នាក់ឈ្មោះនាង បូណ៌ា ឲ្យទៅរៀបចំកន្លែងនៅដើមឈើនោះមុន លុះស្ត្រីបម្រើនោះបានដើរទៅដល់ ក៏ឃើញព្រះបរមពោធិសត្វ អង្គុយនៅទៀបគល់និគ្រោធនោះឆ្លុះរស្មីពណ៌មាសជុំវិញព្រះអង្គស្ត្រីនោះក៏រត់ទៅឲ្យដំណឹងជាថៅហ្វាយនោះវិញ ថាទេវតាដើមនិគ្រោធបញ្ចេញកាយឲ្យឃើញ អង្គុយនៅក្រោមដើមឈើនោះ។

នាងសុជាតា ក៏ដាក់បាយនោះក្នុងភាជន៍មាស វេចសំពត់ពីក្រៅ ហើយទូលលើក្បាលដើរទៅ លុះទៅដល់នាងក៏ប្រគេនបាយនោះដាក់ភាជន៍មាសលើព្រះហស្តព្រះបរមពោធិសត្វ ហើយត្រឡប់ទៅផ្ទះវិញ វេលានោះព្រះពោធិសត្វ ក៏ក្រោកឡើង យកភាជន៍នោះទៅដាក់នៅមាត់ស្ទឹង នេរញ្ជរា ហើយចុះទៅជម្រះព្រះកាយក្នុងស្ទឹងនោះ លុះទ្រង់ស្រង់ស្រេចទ្រង់ក៏ពូតបាយ ៤៩ពំនូត ហើយឆាន់ចង្ហាន់នេះហើយ ដែលព្រះអង្គឆាន់តែម្ដង លុះផុតកំណត់៤៩ថ្ងៃដែលទ្រង់គង់នៅក្រោមដើមពោធិមណ្ឌល នៅវេលាដែលបានសម្រេចពោធិញាណហើយ មិនមានឆាន់ចង្ហាន់ទៀតឡើយ។

លុះព្រះអង្គទ្រង់ឆាន់ស្រេចបរិបូណ៌ ទ្រង់ក៏បោះភាជន៍មាសនោះទៅក្នុងស្ទឹង ហើយបញ្ចេញវចីភេទថា ប្រសិនបើខ្លួនអញនឹងបានត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃនេះ សូមឲ្យភាជន៍នេះអណ្ដែតច្រាសទឹក បើមិនបានត្រាស់ដឹងទេសូមឲ្យភាជន៍នេះ អណ្ដែតបណ្ដោយតាមខ្សែទឹកទៅ ក្នុងវេលានោះភាជន៍បានអណ្ដែតច្រាសទឹកបានចម្ងាយ៨០ហត្ថា ហើយលិចទៅក្នុងទឹកទៅ ទៅចូលក្នុងវិមាននាគរាជកាឡ តម្រួតលើភាជន៍ដែលសម្រាប់ព្រះពុទ្ធមុនៗ។

អំពីដើមឈើដែលព្រះអង្គបានសម្រេចពោធិញាណ ក្នុងថ្ងៃនោះ នៅវេលាឆាន់ចង្ហាន់ហើយ ព្រះបរម

ពោធិសត្វយាងចូលក្នុងព្រៃសាល (ព្រៃរាំង) លុះពេលល្ងាចទ្រង់យាងតម្រង់ទៅដើមពោធិ តាមផ្លូវទៅនោះព្រះអង្គបានទទួលស្បូង៨ចាប់ពីអ្នកច្រូតស្បូងឈ្មោះ ស្វស្តិក (សោត្ថិយ) ថ្វាយព្រះអង្គ យកស្បូវនោះទៅក្រាលជាកម្រាលក្រោមដើមពោធិ ហើយគង់ឆ្ពោះព្រះភក្ត្រទៅទិសខាងកើត។

ក្នុងវេលានោះ ស្តេចមារជិះលើខ្នងដំរីឈ្មោះ គិរីមេខល នៅមុខកងទ័ពមកតយុទ្ធនឹងព្រះអង្គ ហើយធ្វើឲ្យកើតជាខ្យល់ព្យុះយ៉ាងខ្លាំង ហើយបង្អុរភ្លៀងទឹក ភ្លៀងថ្ម អាវុធ ធ្យូង ធ្លាក់មកជាភ្ញីផ្កា នៅទៀបព្រះបាទព្រះអង្គ ឯផេះនឹងខ្សាច់ត្រឡប់កើតជាម្សៅក្រិស្នាថ្វាយព្រះអង្គទៅវិញ ឯចំណែកភក់ក្លាយទៅជាទឹកអប់យ៉ាងក្រអូប លុះក្រុងមារធ្វើឲ្យងងឹត សព្វទិសានុទិស រស្មីព្រះអង្គក៏កំចាត់បង់នូវសេចក្តីងងឹតនោះចេញ។

លុះឃើញដូចនេះ ក្រុងមារក៏ចូលមកជិតព្រះអង្គ កំហែងហើយបន្លឺនូវសម្រែកថាដូចនេះ សទ្ធាចំបៀសចេញពីកន្លែងនេះៗ មិនមែនជារបស់ឯងទេ គឺជារបស់អញ ប៉ុន្តែក្នុងលោកនោះ ព្រះបរមពោធិសត្វទ្រង់បញ្ជាក់ទៅក្រុងមារវិញ ដោយអាងផលទានដែលទ្រង់បានធ្វើកាលពីជាតិមុខៗ ដោយក្រុងមារកំហែងឲ្យទ្រង់រកសាក្សី នោះព្រះអង្គក៏លូកព្រះសហ្គទៅចាប់ប្រថពីអាចជាសាក្សីវេលានោះ ឯផែនដីនៅវេលាដែលព្រះអង្គអាងដូច្នេះហើយ ក៏បន្លឺនូវសម្រែកឡើងបញ្ជាក់ទៅឲ្យក្រុងមារ ក្រុងមារលុះឮសម្រែកដូច្នេះ ក៏បាក់ទ័ពទៅមួយអន្លើនឹងមានសេនាជាច្រើន ឯអស់ទាំងទេវតា ដែលភៀសខ្លួនរត់ម៉ត់អស់ទៅដោយខ្លាចអំណាចក្រុងមារនោះ ក៏ត្រឡប់មកនៅជុំវិញព្រះអង្គដដែល។

វេលាថ្ងៃនោះ នៅមិនទាន់អស្តង្គត់នៅឡើយ ដែលព្រះពោធិសត្វទ្រង់ផ្ចាញ់ទ័ពក្រុងមារបាន ក្នុងបឋមយាមទ្រង់បានជ្រាប់ច្បាស់នូវជាតិរបស់ព្រះអង្គក្នុងកាលជាអតីត (បុព្វេនិវាសញាណ) ក្នុងយាមទី២ ទ្រង់បាននូវព្រះនេត្រទិព្វ (ទិព្វចក្ខុ) ក្នុងយាមទី៣ ទ្រង់បានជ្រាប់ច្បាស់នូវធម៌ដូចជាច្រវាក់ជាបច្ច័យតៗគ្នា (បដិច្ចសមុប្បាទញាណ) លុះព្រលឹមស្វាងឡើងទ្រង់បានជ្រាប់ច្បាស់ទាំងអស់ក្នុងលោក (សព្វញ្ញុតញ្ញាណ) ហើយទ្រង់ក៏សរសើរជ័យរបស់ព្រះអង្គដោយឧទានកថាថា៖

" ខ្លួនអញវិលស្លាប់ វិលកើតជាអនេកជាតិ ខំស្វែងរកខ្លួនជាងដែលសង់ផ្ទះ គឺតណ្ហាមិនបានឃើញសោះឡើយ ខន្ធ៥ ជាគ្រឿងនាំមកនូវសេចក្តីទុក្ខរឿយៗ ម្នាលជាងសង់ផ្ទះ ឥឡូវនេះ អញឃើញច្បាស់ហើយ ឯងនឹងសង់ផ្ទះអញទៀតមិនបានឡើយ អស់ទាំងផ្ដាន និងមេដំបូលក៏បាក់បែកអស់ហើយ ចិត្តដែលដក់នូវព្រះនិព្វាន លាយនឹងរំលាយនូវតណ្ហាបានហើយ[3]។

ទ្រង់បានត្រាស់ដឹងជាសព្វញ្ញុពុទ្ធប្រាកដឡើងក្នុងលោក នៅថ្ងៃពុធ ពេញបូណ៌មី ខែពិសាខ ឆ្នាំរកមិនពុទ្ធសករាជ ៤៥ឆ្នាំ ក្រោមដើមពោធិមួយដើម។

### ១.២.៨. ការបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធ

បន្ទាប់ពីដាក់អាយុសង្ខាររួចហើយព្រះអង្គទ្រង់និមន្តទៅបិណ្ឌបាតគ្រប់ទិសទីហើយនៅទីបំផុតព្រះ-

[3] កម្ពុជសុរិយា ភាគ១/២៧ គ.ស១៩២៦ ទំព័រ១៦១

អង្គទ្រង់យាងទៅដល់នគរកុសិនារា ស្រាប់តែទ្រង់ប្រឈួនយ៉ាងខ្លាំង ក្រោយពេលព្រះអង្គបានសោយផ្សិតខ នឹងក្បាលជ្រូកដែលប្រគេនដោយនាយចុន្ទៈ។

ពេលនោះ ព្រះអង្គទ្រង់ព្យាយាមយាងចូលទៅដល់ព្រៃសាលវ័ន ហើយទ្រង់ត្រាស់ឱ្យព្រះអានន្ទរៀប កន្លែងថ្វាយព្រះអង្គផ្ទុំឱ្យបានឆាប់ព្រះអង្គទ្រង់ផ្ទុំផ្អៀងទៅខាងស្តាំដោយព្រះបាទឆ្វេងត្រួតលើព្រះបាទស្តាំ។

លុះពេលបច្ឆិមរាត្រីចូលមកដល់ ព្រះអង្គទ្រង់ត្រាស់ដល់ភិក្ខុទាំងឡាយថា៖ «អ្វីៗដែលកើតមាន ហើយ ផ្តុំឡើងហើយ តែងមានសភាវធម៌ និងរលត់ទៅវិញជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងប្រយោជន៍ឲ្យ សម្រេចដោយកិរិយាមិនប្រមាថចុះ» ព្រះពុទ្ធទ្រង់មានពុទ្ធដីកាតែប៉ុណ្ណេះ ក៏ទ្រង់រលត់ខន្ធក្នុងពេលនោះទៅ ព្រះពុទ្ធទ្រង់ចូលបរិនិព្វាននៅថ្ងៃអង្គារ ១៥កើតពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ ក្នុងព្រះជន្ម ៨០ឆ្នាំគត់។

ស្តេចយាងចូលកាន់និព្វាន នៅថ្ងៃអង្គរ ពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ មុនព.ស១ថ្ងៃក្រោមដើម សាលព្រឹក្សទាំងគូ នៅខាងលិចក្រុងកុសិនារា[4]។

## ១.៣. ព្រះរតនត្រៃ

### គុណព្រះរតនត្រៃទាំង៣

### ១.៣.១. និយមន័យ រតនត្រៃ

រតនត្រៃឬរតនត្រ័យរតនៈបីយ៉ាងគឺព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ ហៅថា ពុទ្ធរតនៈ ធម្មរតនៈ សង្ឃរតនៈ ឬព្រះពុទ្ធរ័ត្ន ព្រះធម៌រ័ត្ន ព្រះសង្ឃរ័ត្នក៏បាន។

រតនៈវត្ថុ ឬរបស់ដែលញ៉ាំចិត្តឲ្យរីករាយ កែវ ពេជ្រ ត្បូងគ្រប់ប្រភេទ សូម្បីមាស ប្រាក់ ក៏ហៅថា រតនៈ ដែរ ឬហៅថា រតនវត្ថុក៏បាន វត្ថុ ធម្មជាតិដ៏ប្រសើរវិសេស ឬមនុស្សប្រសើរវិសេស[5]។ល។

### ១.៣.២. ពុទ្ធគុណ គឺជាសេចក្តីល្អរបស់ព្រះសម្មាសម្ពុទ្ធមាន ១០ យ៉ាងគឺ៖

១ អរហំ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺ កិលេសព្រមទាំងវាសនា គឺកាយយោគ និងវចីបយោគ។

បញ្ជាក់ ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា ″អហរំ″

ក.″អរហំ″ព្រះអង្គជាអ្នកឆ្ងាយ»គឺព្រះអង្គឆ្ងាយស្រឡះអំពីកិលេសគឺមន្ទិល មាន រាគៈ ទោសៈ មោហៈ និងឆ្ងាយអំពីអគតិធម៌ទាំង៤ប្រការគឺ ទោសាសគតិ មោហាគតិ ភយាគតិ និងឆន្ទាគតិ ។ល។ ដែលថាព្រះ អង្គថា ទ្រង់ឆ្ងាយចាក់កិលេសទាំងនោះ នឹងថាកិលេសទាំងនោះ រត់គេចចេញពីព្រះអង្គក៏មិនមែន ឬនឹងថា ព្រះអង្គរត់គេចចេញអំពីកិលេសទាំងនោះក៏មិនមែនដែរ ព្រោះកិលេសជាអរូបធម៌ មិនមានសណ្ឋានទ្រង់ ទ្រាយឡើយ គឺព្រះអង្គគ្រាន់តែដុសខាត់ព្រះទ័យឲ្យស្អាត់តែប៉ុណ្ណោះ កិលេសទាំងនោះ ក៏សូន្យបាត់ទៅឯងៗ ដូចជាទីងងឹតត្រូវនឹងពន្លឺប្រទីប។

ម្យ៉ាងទៀត ព្រះអង្គមិនមែនគ្រាន់តែឆ្ងាយចាកកិលេសទាំងឡាយប៉ុណ្ណោះឡើយ ទ្រង់ឆ្ងាយចាកទាំង

---

[4] ពុទ្ធសាសនា ២៥០០ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៤៥ ទំព័រ៧

[5] ជួន ណាត វចនានុក្រមខ្មែរ ភាគទី១ ភាគទី២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យព.ស២៥១២ គ.ស១៩៦៨ ទំព័រ៩៧៩

វាសនា គឺស្នាមគំនួសដែលធ្លាប់ប្រព្រឹត្តពីបុព្វជាតិមកទាំង២ប្រការគឺ កាយបយោគៈ ទម្លាប់កាយ ឬក្រមាច់កាយ១ វចីបយោគៈ ទម្លាប់វាចា ឬក្រមាច់វាចា១។

ខ. "អរហំ" «ព្រះអង្គជាអ្នកគួរ» គឺគួរទទួលនូវគ្រឿងសក្ការបូជារបស់មនុស្ស និងទេវតាជាដើម វិសេសជាងបុគ្គលឯទៀតទាំងអស់។

គ. «អរហំ» «ព្រះអង្គជាអ្នកមិនមានទីកំបាំង» ព្រះអង្គមិនមានឱកាសស្ងាត់កំបាំងនឹងធ្វើបាប គឺថា ព្រះអង្គមិនពួនសំងំធ្វើបាបក្នុងទីកំបាំង។

២ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។

បញ្ជាក់ សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង ដោយប្រពៃ ចំពោះអង្គឯង។

ពាក្យថា «ព្រះអង្គត្រាស់ដឹង» នោះគឺ ត្រាស់ដឹងនូវធម៌ «ចត្តារិ សច្ចានិ សម្មាសម្ពុទ្ធោ» ព្រះអង្គត្រាស់ដឹងនូវធម៌ពិត ៤ប្រការគឺ ទុក្ខ១ សមុទយ១ និរោធ១ មគ្គ១ ដែលហៅថា «អរិយសច្ច» ប្រែថាធម៌ពិតរបស់ពិតរបស់ព្រះអរិយ ធម៌ពិតនាំឲ្យឆ្ងាយចាកសឹកសត្រូវ ធម៌ពិតញ៉ាំងភាពជាព្រះអរិយឲ្យសម្រេច ធម៌ពិតដ៏ប្រសើរ។

ពាក្យថា «ដោយប្រពៃ» ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងនូវធម៌ឯណា ឬធម៌ណាដែលព្រះអង្គត្រាស់ដឹងហើយ ធម៌នោះៗ មិនវិបរិតប្រែប្រួល គឺមិនមានល្មៀងឃ្លាតចាកការដឹងរបស់ព្រះអង្គ ព្រោះព្រះអង្គជ្រាប់ដោយការជាក់លាក់ មិនបានស្មាន ឬមិនបានត្រិះរិះប្រកបយកឡើយ។

ពាក្យថា «ចំពោះព្រះអង្គ» បានសេចក្តីថា ព្រះបរមសាស្តាចារ្យទ្រង់ត្រាស់ដឹងធម៌ទាំងពួងគ្មានចន្លោះចំពោះព្រះអង្គយ៉ាងនេះ មិនមែនត្រាស់ដឹងដោយសារបុគ្គលណាប្រៀនប្រដៅឡើយ ឬណែនាំពន្យល់ឲ្យព្រះអង្គត្រាស់ដឹង គឺទ្រង់ត្រាស់ដឹងតែដោយកម្លាំងប្រាជ្ញារបស់ព្រះអង្គឯង ហេតុនោះហើយ ទើបទ្រង់ព្រះអង្គទ្រង់ព្រះនាមថា «សម្មាសម្ពុទ្ធោ» ព្រះអង្គទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ។

៣ វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គ បរិបូណ៌ដោយវិជ្ជា៣ និងវិជ្ជា៨ និងចរណៈ១៥។

៤ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណោះល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន។

៥ លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក។

៦ អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន។

៧ បុរិសទម្មសារថិ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន។

៨ សត្ថា ទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ។

៩ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង

១០ ភគវា ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គខ្ជាក់ចោលនូវត្រៃភព គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ការរឭកដល់គុណរបស់ព្រះសម្មាសម្ពុទ្ធ ដែលហៅថា ពុទ្ធានុស្សាតិ មិនមែនសំដៅការលើកយកពាក្យណាមួយ មកទន្ទេញស្វាធ្យាយ ទាំងដែលមិនដឹងថា តើពាក្យនីមួយៗ នោះមានន័យយ៉ាងណានោះទេ តាមពិតទៅការរឭកដល់គុណរបស់ព្រះសម្ពុទ្ធ គឺនៅត្រង់ការយល់ ហើយពិចារណាតាមសមត្ថភាពនៃសទ្ធា និងបញ្ញារហូតកើតសេចក្តីស្ងប់ចិត្ត ឃ្លាតឆ្ងាយពីបាបទាំងពួង នេះហៅថា ពុទ្ធានុស្សតិ ដែលប្រែថា ការរលឹករឿយៗដល់ព្រះសម្មាសម្ពុទ្ធ មិនមែននៅត្រង់ការទន្ទេញ ពុទ្ធានុស្សតិ ឬអរហំ ទាំងដែលមិនបានយល់ដល់ពុទ្ធគុណនោះឡើយ។

ព្រះនាមរបស់ព្រះសម្មាសម្ពុទ្ធ អាចក្លាយជាទីតាំងនៃសេចក្តីស្ងប់ចិត្ត និងធ្វើឲ្យអ្នកនឹងឃើញមានសេចក្តីរីករាយ ជ្រះថ្លាកើតបុណ្យកុសលផ្សេងៗ យ៉ាងណាមិញ មនុស្សយើងក៏គួរតែរៀនតាមព្រះអង្គ ត្រង់ដែលថាពេលដែលគេនឹកដល់យើងកាលណាក៏កើតសេចក្តីសុខកាយសប្បាយចិត្ត មិនក្តៅក្រហាយចិត្ត[6]។

**១.៣.៣. ព្រះធម្មគុណ ៦ (គុណរបស់ព្រះធម៌)**

ព្រះធម្មគុណ ៦ (គុណរបស់ព្រះធម៌ - virtues or attributes of the Dhamma)

១.ស្វាក្ខាតោ ភគវតា ធម្មោ (ព្រះធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ដោយប្រពៃហើយ គឺត្រាស់ទុកជាការពិតស្មោះ ថែមទាំងជាការលំអខាងដើម កណ្តាល និងខាងចុង ព្រមទាំងអត្ថព្រមទាំងព្យញ្ជនៈប្រកាសគោលការណ៍គ្រងជីវិតដ៏ប្រសើរ បរិសុទ្ធិបរិបូណ៌ទាំស្រុង។

**២. សន្ទិដ្ឋិកោ** (អ្នកប្រតិបត្តិនឹងត្រូវឃើញ ច្បាស់ដោយខ្លួនឯង គឺអ្នកណាប្រតិបត្តិ អ្នកនោះនឹងសម្រេង អ្នកនោះរមែងមើល ឃើញច្បាស់ដោយខ្លួនឯង មិនចាំបាច់ជឿ តាមពាក្យរបស់អ្នកដទៃ អ្នកណាមិនប្រតិ បត្តិក៏មិនសម្រេច អ្នកដទៃប្រាប់ក៏មិនបាន - Sandiṭṭhiko : to be seen for oneself)

**៣. អកាលិកោ**[7] (មិនប្រកបដោយកាល គឺមិនឋិតនៅលើពេលវេលា ព្រមពេលណា សម្រេចបានពេលនោះ សម្រេចបានពេលណា ឃើញផលពេលនោះ ម្យ៉ាងទៀតថា សេចក្តីពិតយ៉ាងណាក៏ជាយ៉ាងនោះ មិនកំណត់កាល - Akāliko : not delayed; timeless)

**៤. ឯហិបស្សិកោ** គួរហៅចូលមកឲ្យមើល គឺអញ្ជើញឲ្យមកមើល និងពិសោធន៍ ឬនឹងធ្វើការត្រួតពិនិត្យ ព្រោះជារបស់ពិត និងល្អពិត - Ehipassiko : inviting to come and see; inviting inspection)

**៥. ឱបនយិកោ** (គួរបង្អោនចូលមក គឺ គួរចូលមកទុកចិត្ត ឬបង្អោនចិត្តចូលឲ្យ ដល់ដោយការប្រតិបត្តិឲ្យកើតមានក្នុងចិត្ត ឬឲ្យសម្រេចដល់ប្រការយ៉ាងនោះ មានន័យថា អញ្ជើញឲ្យសាកល្បងប្រតិបត្តិ ម្យ៉ាងទៀតថាជាប្រការដែលនាំអ្នកប្រ តិបត្តិឲ្យចូលដល់គោលដៅ គឺព្រះនិព្វាន។

**៦. បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** (វិញ្ញូជនត្រូវដឹងចំពោះខ្លួន គឺ ជាវិស័យនៃវិញ្ញូជននឹងត្រូវ ដឹងបានថាជារបស់ចំពោះខ្លួនត្រូវធ្វើ ទើបសោយបានចំពោះតែខ្លួនឯង ធ្វើជំនួសអ្នកដទៃមិនបាន យកពីគ្នាមិនបាន និងដឹងបានច្បាស់នៅក្នុងចិត្តរបស់ខ្លួននេះឯង។

គុណខទី១មានន័យទូលាយរួមទាំងបរិយត្តិធម៌ គឺពាក្យប្រៀនប្រដៅផង ចំណែខទី២ ដល់ទី៦ សំដៅ

---

[6] http://5000-years.org/kh/read/2286

[7] ឈឹម ទូច ប្រស្នាត្រៃគុណ ពុទ្ធសាសនបណ្ឌិត្យ គ.ស១៩៩៩ ទំព័រ ១១០

ដល់គុណនៃលោកុត្តរធម៌ នឹងឃើញបានក្នុងទីផ្សេងៗ ថា ខទី២ ដល់ទី៦ លោកសម្តែងទុកជាគុណបទនៃព្រះនិព្វានក៏មាន។

**១.៣.៤. គុណព្រះសង្ឃមាន៩**

ពាក្យថា ព្រះសង្ឃ ក្នុងទីនេះមានសេចក្តីដូចម្តេច?

ពាក្យថា « ព្រះសង្ឃ » សំដៅយកបព្វជិតពុទ្ធសាសនិក ជាសាវ័កនៃព្រះមានព្រះភាគ បានដល់ព្រះអរិយសង្ឃ ជាអ្នកសម្រេចគុណវិសេសមានសោតាបត្តិមគ្គជាដើមផង ព្រះសម្មតិសង្ឃផង។ ព្រះសង្ឃជាពុទ្ធសាវ័កនេះ លោកជាអ្នកទ្រទ្រង់នូវគុណសម្បត្តិដែលលោក គួរជាទីគោរពនមស្សការនៃមហាជន។

**គុណព្រះសង្ឃទី១**

« សុបដិបន្នោ » ប្រែថាលោកប្រតិបត្តិល្អហើយ សំដៅយកសេចក្តីប្រតិបត្តិដ៏ត្រឹមត្រូវរបស់លោក តាមអង្គនៃអដ្ឋង្គិកមគ្គ (ផ្លូវមានអង្គ៨ប្រការ) ឬហៅថា មជ្ឈិមបដិបទាជាបដិបទាមិនធូរពេក មិនតឹងពេក មិនចូលទៅក្នុងកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ លោកជាអ្នកប្រតិបត្តិល្អឈានទៅមុខមិនថយក្រោយ ជាអ្នកប្រតិបត្តិស្របតាមព្រះដ៏មានព្រះភាគ។

**គុណព្រះសង្ឃទី២**

« ឧជុបដិបន្នោ » មានសេចក្តីថា លោកប្រតិបត្តិត្រង់ហើយ សំដៅយកសេចក្តីប្រតិបត្តិរបស់លោក ឆ្ពោះត្រង់ព្រះនិព្វានមិនមែនជាសេចក្តីប្រតិបត្តិ ដើម្បីគ្រាន់តែប្រលោមលោក ឬញ៉ាំងលោកឲ្យភាន់ច្រលំឡើយ គឺលោកជាអ្នកប្រតិបត្តិ មិនវៀចទៅតាមគាមធម៌ឬដោយលាភសក្ការៈមិនមាន មាយាសាថេយ្យជាអ្នកប្រតិបត្តិត្រង់តាមគន្លង នៃព្រះសម្មាសម្ពុទ្ធនិងព្រះសង្ឃជាពុទ្ធសាវ័កដូចគ្នា ដែលប្រតិបត្តិត្រង់រហូតទាំងក្នុងចំពោះ មុខនិងទីកំបាំងមុខ។

**គុណព្រះសង្ឃទី៣**

« ញាយបដិបន្នោ » មានសេចក្តីថា លោកប្រតិបត្តិដើម្បីព្រះនិព្វាន សំដៅយកសេចក្តីប្រតិបត្តិរបស់លោកដើម្បី មគ្គផលព្រះនិព្វាន ដែលគួរដឹងច្បាស់ដោយខ្លួនឯង។

ពាក្យថា«ញាយៈ» ប្រែបានច្រើនយ៉ាង ដូចជាផលដែលគប្បីដឹង បដិបទាជាគ្រឿងដឹងច្បាស់ធម៌ដែលបុគ្គលគប្បីដឹងគឺមគ្គផលនិព្វាន ឧបាយជាគ្រឿងចេញចាកទុក្ខ និងគុណវិសេសដែលគប្បីដឹងបានជាដើម។

ម្យ៉ាងទៀតពាក្យថា «ញាយប្បដិបន្នៈ» សំដៅយកលោកអ្នកប្រតិបត្តិតាមធម្មាធិបតេយ្យ និងលោកាធិបតេយ្យ។

**គុណព្រះសង្ឃទី៤**

« សាមីចិប្បដិបន្នោ » សេចក្តីថា លោកប្រតិបត្តិហើយដ៏សមគួរ សំដៅយកសេចក្តីប្រតិបត្តិ ដែលគួរគោរពកោតក្រែងជាសេចក្តីប្រតិបត្តិដ៏សមគួរ ដែលអាចឲ្យបរិស័ទគោរពរាប់អានដោយស្មោះត្រង់ មិនមែនជាសេចក្តីប្រតិបត្តិឡើងចុះ តាមលោកធម៌ដែលប៉ះពាល់ត្រូវនោះឡើយ។

### គុណព្រះសង្ឃទី៥

« អាហុនេយ្យោ » មានសេចក្ដីថា លោកជាអ្នកគួរដល់សក្ការបូជាសំដៅយកសណ្ដាប់ធ្នាប់ល្អ គួរជាទីគោរពបូជានៃមហាជន ដែលអាចនាំគ្រឿងសក្ការៈអំពីចម្ងាយចូលមកបូជា។

### គុណព្រះសង្ឃទី៦

« បាហុនេយ្យោ » មានសេចក្ដីថា លោកជាអ្នកគួរដល់បុគ្គល ជាអ្នកទទួលសំដៅយក លោកមានគុណសម្បត្តិ សេចក្ដីល្អគ្រប់ត្រៃទ្វារ បរិបូណ៌ដោយសេចក្ដីសង្រួមដោយលោកមានឋានៈដ៏សមគួរ ទុកដូចជាភ្ញៀវពិសេស ដែលមកកាន់សំណាក់បុគ្គលណាមួយហើយអ្នកម្ចាស់ទីកន្លែង អាចទទួលគោរពរាប់អានដោយសេចក្ដីត្រេកអរ។ ព្រះសង្ឃជាពុទ្ធសាវ័កនេះ ទុកដូចជាភ្ញៀវជាន់ខ្ពស់ជាបុគ្គលដែលគួរមហាជន ទទួលដោយសេចក្ដីត្រេកអរពន់ពេក។

### គុណព្រះសង្ឃទី៧

« ទក្ខិណេយ្យោ » មានសេចក្ដីថា លោកជាអ្នកគួរដល់ការធ្វើបុណ្យ សំដៅយកសេចក្ដីបរិសុទ្ធរបស់លោក ដែលលោកឋិតនៅក្នុងកុសលធម៌ជានិច្ច គួរមហាជនលើកតម្កើងថា ជាបដិគ្គាហកបុគ្គលយ៉ាងខ្ពង់ខ្ពស់ គួរទទួលបច្ច័យ ៤ របស់ទាយកទាយិកា អ្នកប្រាថ្នាបុណ្យ។

### គុណព្រះសង្ឃទី៨

« អញ្ជលិករណីយោ » មានសេចក្ដីថា លោកជាអ្នកគួរយកអញ្ជលិកម្ម (លើកដៃសំពះ) សំដៅយកសេចក្ដីសង្រួមឥន្ទ្រីយ៍របស់លោក ដែលនៅប្រចាំទ្វារទាំងឡាយបីរបស់លោកគ្រប់ទិវារាត្រី គួរឲ្យមហាជនស្ងើចសរសើរ ថ្វាយបង្គំប្រណម្យដៃដោយគោរពដើម្បីជាទិដ្ឋានុគតិនៃសាធុជនតទៅ។

### គុណព្រះសង្ឃទី៩

« អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស » មានសេចក្ដីថា ព្រះសង្ឃជាបុញ្ញក្ខេត្តរបស់សត្វលោក មិនមានបុញ្ញក្ខេត្តណាក្រៃលែងជាង សំដៅយកសេចក្ដីបរិសុទ្ធបរិបូណ៌គ្រប់យ៉ាង ដែលមានក្នុងខន្ធសន្តានរបស់លោក ប្រៀបដូចជាស្រែដែលមានដីជាតិល្អ កាលបើបុគ្គលបានសាបព្រោះក្នុងស្រែនោះ ក៏អាចឲ្យផលបរិបូណ៌ព្រះសង្ឃជាបុគ្គលបរិសុទ្ធផូរផង់ដោយ សីល សមាធិ បញ្ញា ឈ្មោះថាទុកជាស្រែបុណ្យដ៏ប្រសើរបំផុតរបស់សត្វលោកដូច្នោះដែរ។

# ជំពូក២

# ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ

## ២.១. ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធសំខាន់ៗមួយចំនួន

### ២.១.១. សីល៥

និយមន័យសីល

សីលមានន័យដូចម្តេច?

សីលគឺការតាំងចេតនាថា អាត្មាអញនឹងមិនធ្វើនូវអំពើអាក្រក់ ព្រោះបើធ្វើអំពើអាក្រក់ អាត្មាអញនឹងបានទទួលនូវវិបាកជាទុក្ខ។ វេរមណីសីល គឺការនៅឆ្ងាយអំពីការធ្វើអំពើអាក្រក់។ អវីតិក្កមសីល ក្នុងករណីនេះ គឺអ្នករក្សាសីលមិនប្រព្រឹត្តល្មើសទាំងខាងកាយ និងវាចា។

សីលមានន័យថា ត្រជាក់ ប្រសើរបំផុត ទង្វើ ប្រក្រតី និងប្រក្រតីភាពតាមធម្មជាតិរបស់ទុក្ខ និងសុខម្យ៉ាងទៀតសីលមានន័យថា ក្បាល សន្តិភាព។

បើសិនជាបុគ្គលម្នាក់ពុំមានក្បាល បុគ្គលនោះក៏មិនអាចបោសធូលី គឺកិលេសអំពីឥន្ទ្រិយរបស់គេបានឡើយព្រោះអាការៈបែបនេះហៅថាស្លាប់ ដូច្នេះសីលរបស់ភិក្ខុគឺជាក្បាលនោងឯង ពេលដែលបាត់ក្បាលភិក្ខុនោះ ក៏បាត់បង់នូវគុណគឺសេចក្តីល្អទាំងពួង នេះគឺន័យរបស់ពាក្យសីល ដែលប្រែថាក្បាល។

សីលមានន័យថាត្រជាក់

ឧបមាដូចជាខ្លឹមចន្ទ ដែលមានជាតិត្រជាក់ អាចជួយបំបាត់អាការៈគ្រុនក្តៅរបស់រាងកាយបានយ៉ាងណា សីលក៏អាចជួយបំបាត់អាការៈគ្រុនក្តៅរបស់ចិត្ត ដែលកើតពីការភ័យខ្លាច បន្ទាប់ពីបានធ្វើឲ្យសីលដាច់ហើយ ព្រមទាំងនាំឲ្យកើតនូវប្រាមោទ្យបានយ៉ាងដូច្នោះដែរ នេះជាន័យរបស់ពាក្យសីលដែលប្រែថាត្រជាក់។

សីលមានន័យថា សន្តិ

បើបុគ្គលមានសីល បុគ្គលនោះនឹងមានការប្រព្រឹត្តស្ងប់រៀបរយ បុគ្គលនោះនឹងមិនបង្កការភ័យខ្លាចឲ្យកើតឡើងឡើយ នេះគឺជាន័យរបស់ពាក្យសីល ដែលប្រែថា សន្តិ[8]។

#### ១. វៀរចាកការបៀតបៀន និងសម្លាប់សត្វទូទៅ

ការមិនសម្លាប់បៀតបៀនជីវិតអ្នកដទៃ៖

ចៀសវាងដាច់ខាតពីការកាប់សម្លាប់ ជិះជាន់ បៀតបៀនជីវិតអ្នកដទៃ។ ជីវិតយើងគ្រប់រូបកើតមកតែងតែប្រាថ្នាចង់រស់នៅក្នុងភាពសុខសាន្តនិងការជួបជុំគ្រួសារ។ គ្មានអ្នកណាម្នាក់ចង់ឲ្យមនុស្សដែលខ្លួនស្រឡាញ់ ត្រូវបាត់បង់ជីវិត និរាសព្រាត់ប្រាស់ពីខ្លួន ដោយសារការជិះជាន់ ការបៀតបៀន ការគម្រាមកំហែង និងកាប់សម្លាប់ពីអ្នកដទៃនោះទេ។

---

[8] ហេង មណីចិន្តា គម្ពីរវិមុត្តិមគ្គ ព.ស ២៥៥៤ ទំព័រ ៧

បាណាតិបាត ដែលបុគ្គលសេពថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីនរក ប្រព្រឹត្តទៅដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅដើម្បីប្រេតវិស័យផលនៃបាណាតិបាត ដែលស្រាលជាងផលទាំងអស់រមែងប្រព្រឹត្តទៅ ដើម្បីមានអាយុខ្លី ដល់បុគ្គលអ្នកកើតជាមនុស្ស។

សិក្ខាបទនេះ គឺជាច្បាប់យ៉ាងសំខាន់ដែលបង្ហាញអំពីគុណតម្លៃនៃជីវិត មិនថាជីវិតមនុស្ស ឬជីវិតសត្វទេ ពីព្រោះបុគ្គលគ្រប់រូបគឺសុទ្ធសឹងតែស្រឡាញ់ជីវិតរបស់ខ្លួន។

**ទោសនៃការប្រព្រឹត្តបាណាតិបាតមាន៖**

. សម្លាប់សត្វល្អិត តូចៗ ដូចជាស្រមោចខ្មៅឈ្មោះថា មានទោសតិច។

សម្លាប់ដូច្នោះ តែធំជាងមានទោសច្រើនជាង

សម្លាប់សត្វប្រភេទជាប់ទាក់ទងដោយបក្សីធំជាងនោះ មានទោសច្រើនជាងនោះ សម្លាប់ប្រភេទសត្វសកុណាធំជាងនោះ មានទោសច្រើនជាងនោះ។

សម្លាប់សត្វទន្សងមានទោសច្រើនជាងនោះ។

សម្លាប់សត្វទន្សាយមានទោសច្រើនជាងនោះ។

សម្លាប់សត្វម្រឹគមានទោសច្រើនជាងនោះ។

សម្លាប់សត្វគោមានទោសច្រើនជាងនោះ។

សម្លាប់សត្វសេះមានទោសច្រើនជាងនោះ។

សម្លាប់សត្វដំរីមានទោសច្រើនជាងនោះ។

សម្លាប់មនុស្សទ្រុស្តសីលមានច្រើនជាងនោះ។

សម្លាប់មនុស្សអ្នកមានប្រក្រតីប្រព្រឹត្តដូចគោមានទោសច្រើនជាងនោះ។

សម្លាប់មនុស្សអ្នកដល់នូវត្រៃសរណគមន៍មានទោសច្រើនជាងនោះ។

សម្លាប់មនុស្សអ្នកតាំងនៅក្នុងសីល៥មានទោសច្រើនជាងនោះ។

សម្លាប់សាមណេរមានទោសច្រើនជាងនោះ។

សម្លាប់ភិក្ខុជាបុថុជ្ជនមានទោសច្រើនជាងនោះ។

សម្លាប់សោតាបន្នមានទោសច្រើនជាងនោះ។

សម្លាប់សកទាមីមានទោសច្រើនជាងនោះ។

សម្លាប់អនាគាមីមានទោសច្រើនជាងនោះ។

សម្លាប់ព្រះអរហន្តព្រីខីណាស្រពមានទោសច្រើនជាងនោះ។

**សេចក្តីពន្យល់៖**

បាណាតិបាតានេះ ឈ្មោះថាមានទោសតិច ព្រោះសត្វតិរច្ឆានជាដើម ដែលប្រាសចាកគុណ ជាសត្វដែលមានជីវិតតូចៗ។ ឈ្មោះថា មានទោសច្រើន ព្រោះសត្វមានជីវិតធំ។ ព្រោះហេតុអ្វី? ព្រោះមានប្រយោគធំសូម្បីកាលមានប្រយោគប៉ុណ្ណោះបាណាតិបាត ឈ្មោះថា មានទោសច្រើន ព្រោះមានវត្ថុធំជាច្រើន។ បណ្តាមនុស្សជាដើម ជាអ្នកមានគុណធម៌ ព្រោះអ្នកមានគុណធម៌តិច បាណាតិបាត មានទោសតិច ព្រោះអ្នកមានគុណធម៌ច្រើនមានទោសច្រើន តែកាលរាងកាយ និងគុណធម៌ស្មើគ្នា បាណាតិបាត ឈ្មោះថា ទោសតិច ព្រោះកិលេស និងសេចក្តីទន់ខ្សោយ មានទោសច្រើន ព្រោះកិលេស និងសេចក្តីព្យាយាមខ្លាំងក្លា។

ម្យ៉ាងទៀត ក្នុងរឿងបាណាតិបាតនេះ ការដែលបាណាតិបាតមានទោសច្រើន ព្រោះមានប្រយោគ និងវត្ថុធំជាដើម គប្បីជ្រាបដោយមានចេតនាកើតឡើង ព្រោះបច្ច័យទាំងនោះ មានកម្លាំង។ ប្រយោគដែលបានព្រោះចេតនា ដែលជាគូឲ្យសម្រេច ក៏ញុំាងកិច្ចរបស់ខ្លួនឲ្យសម្រេច ដោយអំណាចប្រយោគតាមដែលខ្លួនប្រាថ្នាឲ្យសម្រេចដោយឆាប់រហ័ស និងដោយសេវនៈ ដោយជវនៈទាំងឡាយ ដែលប្រព្រឹត្តទៅច្រើនដង គ្រាខ្លះកាលប្រយោគស្មើគ្នាទាំងទាំងក្នុងសត្វដែលមានជីវិតតូច និងធំសូម្បីមានចេតនារបស់អ្នកសម្លាប់សត្វធំមានកម្លាំងជាង និងកើតឡើងព្រោះដូច្នោះ សូម្បីវត្ថុជារបស់ធំទើបជាហេតុនៃចេតនាមានកម្លាំងជាង ដូច្នេះទាំង២យ៉ាងនេះ ទើបជាបាណាតិបាតមានទោសច្រើន ដោយសភាវដែលចេតនាមានកម្លាំងខ្លាំងនោះឯង។ ម្យ៉ាងទៀតកាលសត្វនឹងត្រូវស្លាប់មានគុណធម៌ច្រើន បាណាតិបាតនោះមានទោសច្រើន គប្បីឃើញថា សូម្បីចេតនាមិនជាឧបការៈដល់ការញុំាងខេត្តពិសេសឲ្យសម្រេច ជាចេតនាមានកម្លាំង និងខ្លាំងក្លាជាង នឹងកើតឡើងដូចដូចចេតនាជាឧបការៈ ដែលប្រព្រឹត្តទៅហើយក្នុងក្នុងសត្វ និងសម្លាប់នោះ ព្រោះហេតុនោះ កាលបច្ច័យទាំងឡាយ មានប្រយោគ និងវត្ថុជាដើមមិនធំ គប្បីជ្រាបសេចក្ដីដែលបានបាណាតិបាតមានទោសច្រើន ដោយអំណាចចេតនាមានកម្លាំង ព្រោះបច្ច័យទាំងឡាយមានភាព ជាអ្នកមានគុណធម៌ច្រើនជាងជាដើមនោះឯង។

**ផលនៃការមិនប្រព្រឹត្តធ្វើនូវបាណាតិបាតមាន ២៣ យ៉ាងគឺ ៖**

១. បរិបូណ៌ដោយអវយវៈ តូច ធំ (មានរាងកាយល្អ សមទ្រង់មិនវិកលវិការ)។
២. ប្រកបដោយរាងកាយខ្ពស់ ហើយសមទ្រង់។
៣. ជាមនុស្សសម្បូណ៌ដោយការវាងវៃ។
៤. ភាពជាមនុស្សមានជើងតាំងនៅស៊ប់ល្អ។
៥. ភាពជាមនុស្សមានសេចក្ដីជ្រះរុងរឿងផង។
៦. ភាពជាមនុស្សទន់ភ្លន់គួរសមផង។
៧. ភាពជាមនុស្សស្អាតល្អផង។
៨. ភាពជាមនុស្សប្រទះនឹងសេចក្ដីច្រើន។
៩. ភាពជាមនុស្សក្លៀវក្លា (ក្នុងបរិបស័ទ) ផង។
១០. ភាពជាមនុស្សមានកម្លាំងច្រើនណាស់ផង។
១១. ភាពជាមនុស្សមានវាចាពីរោះក្បោះក្បាយផង។
១២. ភាពជាមនុស្ស ដែលគេស្រឡាញ់ពេញចិត្តរបស់សត្វទាំងឡាយ។
១៣. ភាពជាមនុស្សមានបរិស័ទមិនបែកបាក់ពីខ្លួនផង។
១៤. ភាពជាមនុស្សមិនខ្លាចតក់ស្លុតភ័យខ្លាចអ្វីផង។
១៥. ពួកសឹកសត្រូវប្រទូស្តមិនបានផង។
១៦. ជាមនុស្សមិនស្លាប់ ដោយសេចក្ដីព្យាយាមរបស់អ្នកដទៃ។
១៧. ជាមនុស្សមានបរិវារច្រើនគ្មានទីបំផុត។
១៨. ភាពជាមនុស្សមានសម្បុរដូចមាស(សុវណ្ណតា)ភាពជាមនុស្សមានរូបល្អស្រស់ផង(សុរូបតា)។
១៩. ជាមនុស្សមានទ្រង់ទ្រាយល្អផង។

២០. ភាពជាមនុស្សមានជំងឺតិចផង។

២១. ភាពជាមនុស្សមិនខូចចិត្តដោយសោកឡើយ។

២២. មិនព្រាត់ប្រាសនិរាសចោលសត្វ និងសង្ខារដែលជាទីស្រឡាញ់ និងជាទីពេញចិត្តផង។

២៣. ភាពជាមនុស្សមានអាយុវែងទៅតាមកាល[9]។

**២. វៀរចាកការកាន់របស់ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា**

មិនលួចឆក់ទ្រព្យអ្នកដទៃ៖

ត្រូវវៀរចាកពីការលួចឆក់ទ្រព្យសម្បត្តិ មាស ប្រាក់ដែលមានម្ចាស់ថែរក្សា។ មិនត្រូវសម្លុតគម្រាមកំហែង ឬបង្ខិតបង្ខំដើម្បីអូសយកដីផ្ទះសម្បែងរបស់គេនោះទេ។ ម្យ៉ាងទៀត ជាជាតិសាសន៍ថ្លៃថ្នូរ មិនត្រូវប្រើកលល្បិចដើម្បីឈ្លានពានវាតទីទឹកដីជាតិសាសន៍ដទៃនោះដែរព្រោះវាជាហេតុនាំឲ្យកើតសង្គ្រាម ដែលនាំមកនូវវិនាសកម្មដល់មនុស្សជាតិ។

ក្នុងសិក្ខាបទនេះដែរ គឺសំដៅអប់រំមនុស្សមិនឲ្យបៀតបៀន លួច ឆក់ប្លន់ទ្រព្យសម្បត្តិគ្នាទេ បើទោះបីជាទ្រព្យសម្បត្តិនោះមានតិច ឬច្រើនក្តីក៏ដោយ ពីព្រោះថា ធម្មតាមនុស្សគ្រប់រូបមុននឹងបានទ្រព្យសម្បត្តិឯណានីមួយជាកម្មសិទ្ធិរបស់គេ គឺម្នាក់ៗបានប្រឹងប្រែងបញ្ចេញកម្លាំងពលកម្ម បញ្ញាស្មារតីគ្រប់បែបយ៉ាង។ ដូច្នេះនៅពេលដែលបានទ្រព្យមកហើយ គឺគេពិតជាស្រឡាញ់ទ្រព្យសម្បត្តិដែលខ្លួនរកបានមកនោះ។

អទិន្នាទាន ដែលបុគ្គលសេពថ្មីកហើយ រមែងប្រព្រឹត្តទៅដើម្បីប្រេតវិស័យ ផលនៃអទិន្នាទានដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តដើម្បីសេចក្តីវិនាសនៃភោគៈដល់បុគ្គលអ្នកកើតជាមនុស្ស។

សារប្រយោជន៍នៃការរក្សាសីលទី២នេះថា បើមនុស្សទាំងអស់បាននាំគ្នារក្សាសិក្ខាបទនេះ គឺសង្គមរបស់គេនឹងមានទំនុកទុកចិត្តរវាងគ្នានឹងគ្នាឬផ្តល់សុខសន្តិភាពឲ្យគ្នាដោយមិនចាំបាច់ភ័យព្រួយថា មានអ្នកណាមកគំរាមកំហែងលួចឆក់ប្លន់ទ្រព្យរបស់ខ្លួនឡើយ ហើយនៅក្នុងផ្ទះក៏សឹងតែមិនចាំបាច់ចាក់សោការពារក៏បាន។

**៣. វៀរចាកការប្រព្រឹត្តខុសចំពោះប្រពន្ធប្តីរបស់អ្នកដទៃ**

មិនប្រព្រឹត្តខុសក្នុងកាមទៅលើកូននិងប្រពន្ធរបស់អ្នកទៃ៖

ហាមប្រព្រឹត្តខុសក្នុងផ្លូវកាមលើសាច់ញាតិអ្នកដទៃ។ យើងស្រលាញ់ហួងហែងកូន ប្រពន្ធ ប្តីសាច់ញាតិ និងមនុស្សដែលយើងស្រលាញ់យ៉ាងណា អ្នកដទៃគេក៏ស្រលាញ់ហួងហែងកូនប្រពន្ធ ប្តី សាច់ញាតិ និងមនុស្សដែលគេស្រលាញ់យ៉ាងនោះដែរ។ទាំងយើងទាំងគេតែងតែប្រាថ្នាចង់ឲ្យស្វាមីភរិយាបុត្រា បុត្រី រស់នៅដោយសុភមង្គល មិនចង់ឲ្យអ្នកណាម្នាក់មកប្រព្រឹត្តអំពើផ្តាំផ្តង រំលោភបំពានលើក្រុមគ្រួសារខ្លួននោះទេ។

កាមេសុមិច្ឆាចារាវេរមណី»គឺសំដៅអប់រំអំពីគុណធម៌របស់មនុស្សម្នាក់ៗដែលមានធម្មសញ្ញាខ្ពង់ខ្ពស់ប្រសើរជាងសត្វ ឬមានការយល់ដឹងពីការប្រព្រឹត្តរបស់ខ្លួនថាអ្វីខុស អ្វីត្រូវជាដើម ពិសេសគឺមិនប្រព្រឹត្តរំលោភបំពានរាងកាយអ្នកដទៃ រួមមានប្រពន្ធ កូន ចៅ ប្តីសីរបស់គេជាដើម។

[9] ហ៊ាត ណាហំ សីលត្ថទីបនី ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា ព.ស ២៥៥៧ គ.ស ២០១៣ ទំព័រ ១៤០

នៅក្នុងពិភពលោក រួមមានទាំង ប្រទេសកម្ពុជាផង សព្វថ្ងៃនេះបានកើតមានអំពើប្រព្រឹត្តខុសក្នុងសីលទី៣នេះយ៉ាងខ្លាំង រហូតដល់បុគ្គលខ្លះវង្វេងវង្វាន់មិនដឹងខុសត្រូវ ដូចជាឪពុករំលោភបំពានកូនស្រីខ្លួនឯងបង្កើត មានអំពើជួញដូរស្ត្រី ឬកុមារី អំពើជះទឹកអាស៊ីដដាក់គ្នា មានបញ្ហាកើតជំងឺតម្កាត់ព្យាបាលមិនជាដូចជាជំងឺអេដស៍ ។ល។ បញ្ហាទាំងអស់នេះ ក៏ដោយសារតែមនុស្សទាំងនោះមិនរក្សា និងឲ្យតម្លៃសិក្ខាបទឬសីលទី៣នោះឯង។

ការដាច់មិនគោរពសិក្ខាបទទី៣នេះ គឺធ្វើឲ្យមនុស្ស ទាំងប្រុសស្រីរងទុក្ខលំបាកខ្លាំងណាស់ ឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្តៈ «ប្ដីប្រពន្ធយើងមានហើយ យើងមានចិត្តអនុគ្រោះដល់គ្នាទៅវិញទៅមកទៅ មិនមានចិត្តវៀចវេរ ទៅមានថ្មី នឹងធ្វើឲ្យសង្គមក្រុមគ្រួសារយើងហ្នឹងបានសេចក្ដីសុខ ហើយយើងនឹងផ្ដល់នូវចំណែកសេចក្ដីសុខយ៉ាងធំទៀតដល់សង្គមក្រុមគ្រួសារដែលនៅជុំវិញខ្លួនយើង ដែលយើងមិនបៀតបៀនមិនប្រព្រឹត្តខុសក្នុងភរិយាគេ ស្វាមីគេ ក្នុងកូនប្រុសកូនស្រីគេ។ តាំងចេតនាវៀរចាកការប្រព្រឹត្តខុសនៅក្នុងកាម»។

ផ្ទុយទៅវិញ កាមេសុមិច្ឆាចារ ដែលបុគ្គលសេពថ្មឹកហើយ ផលនៃកាមេសុមិច្ឆាចារដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីសត្រូវនិងពៀរដល់បុគ្គលអ្នកកើតជាមនុស្ស។

៤. វៀរចាកការនិយាយមិនពិត មិនភូតកុហកអ្នកដទៃ ត្រូវប្រកាន់ខ្ជាប់នូវពាក្យសច្ចៈ ដោយចៀសវាងការកុហកបោកប្រាស់អ្នកដទៃ។ ការនិយាយកុហកជាហេតុនាំមកនូវការបាត់បង់តម្លៃរបស់ខ្លួន។ កុហកគេម្ដងគេលែងជឿមួយជីវិត។ ពេលអ្នកកុហកបោកប្រាស់គេ គេអាចនឹងអធ្យាស្រ័យឲ្យអ្នក តែគេនឹងមិនភ្លេចពីទង្វើបោកប្រាស់ និងពាក្យកុហករបស់អ្នកទេ។ ការកុហកអាចនាំឲ្យមនុស្សកើតការសង្ស័យគ្នាគ្រប់ពេលវេលា។

«មុសាវាទា វេរមណី» គឺចង់អប់រំមនុស្សឲ្យរក្សាសំដីត្រូវ ឬវាចាត្រូវ ដោយមិនពោលពាក្យកុហកញុះញង់ ស៊កសៀតផ្ដែផ្ដា ចាក់ដោត ទ្រគោះបោះបោកដាក់អ្នកដទៃ ឬមិនពោលពាក្យរាយមាយ ឡេះឡោះឥតប្រយោជន៍ជាដើម។

ទោសនៃមុសាវាទពិតជាកើតមានប្រាកដចំពោះអ្នក ដែលនិយមចូលចិត្តនិយាយពាក្យភូតកុហក បើធ្ងន់ទោសនេះឱ្យផលមិនរំលងជាតិ តែបើតិចតួចក៏គង់ហុចផលឱ្យក្នុងបរលោក។

ការរក្សាសិក្ខាបទទី៤នេះ គឺនឹងនាំមកនូវសុខសន្តិភាពដល់មនុស្សផងគ្នា ពីព្រោះមនុស្សគ្រប់រូប មិនថាក្មេង ចាស់ ប្រុសស្រីទេ គឺចង់បានតែសម្ដីល្អ សម្ដីស្មោះត្រង់។ ដូច្នោះប្រសិនបើមានបុគ្គលណាមួយមិនគោរព រក្សាសីលទី៤នេះទេ ដោយប្រើពាក្យមិនសមរម្យទៅលើអ្នកដទៃ គឺអ្នកដែលទទួលរងនូវពាក្យនេះនឹងមិនសប្បាយចិត្តទេ ហើយអាចនឹងឈានទៅរកការប្រើអំពើហិង្សា។

តើអ្នកនិយាយពាក្យមិនពិតនឹងត្រូវទទួលផលបែបណា?

មុសាវាទប្រែថា និយាយកុហកពាក្យវៀចវេរបានដល់ពាក្យមិនពិតត្រង់ដូច មិនឃើញថាឃើញ មិនល្អថាល្អ មិនដឹងថាដឹង មិនយកថាយកជាដើម។ ពាក្យទាំងអស់នេះបើទោះជាអ្នកស្ដាប់គេជឿក្ដី មិនជឿក្ដីក៏ហៅថា កុហកទាំងអស់។ ពាក្យមុសាវាទនេះ ធ្វើឱ្យអ្នកដទៃវិនាសជីវិត វិនាសទ្រព្យសម្បត្តិក៏មាន។ មុសាវាទកាលបើចេញនិយាយទៅហើយ តែងឱ្យផលអាក្រក់ដោយប្រការផ្សេងៗជាអាទិ៍គឺ កាលណាអ្នកស្ដាប់គេដឹង

ថា មនុស្សណានិយាយភូតកុហកហើយ ទុកជាថ្ងៃក្រោយនិយាយពិតត្រង់ក៏គេលែងជឿ លែងទុកចិត្ត ទៅជាពាក្យសម្តីឥតន័យ អត់ខ្លឹមសារ ។

តាមពិត ពាក្យកុហកសូម្បីនិយាយដោះខ្លួនឱ្យរួចចាកភ័យ ឬក៏និយាយបង្រួបបង្រួមអ្នកដទៃ ឲ្យ-សាមគ្គីគ្នាឲ្យឯកភាពគ្នា ក៏មិនត្រូវនិយាយគឺត្រូវតែនិយាយពាក្យណាដែលពិតត្រង់ ព្រោះសំនួនវោហារដែលត្រូវលើកយកមកនិយាយឲ្យគេស្តាប់នោះ មានច្រើនបែបណាស់ ល្មមលើកយកមកប្រើបានដែរ ហើយគឺមិនខ្វះពាក្យនិយាយទេ ដោយហោចទៅ ទុកជាភូតលេងក៏មិនត្រូវនិយាយដ្បិតនាំឲ្យធ្លាប់មាត់ និងនាំឲ្យអ្នកស្តាប់ស្និទ្ធស្នាលនាំគ្នានិយាយភូតលេងតៗគ្នា។

ពាក្យភូតកុហកបើមានកម្លាំងច្រើន អាចនាំឱ្យមានទោសក្នុងជាតិនេះ តែបើមានកម្លាំងតិចក៏គង់ឲ្យទោសក្នុងជាតិខាងមុខ លោកសម្តែងថា អ្នកណានិយាយភូតកុហក អ្នកនោះទៅកើតក្នុងជាតិណាៗតែងជាមនុស្សវៀចមាត់ ធែបមាត់ មិនគួរជាទីរាប់អាននៃអ្នកដទៃ និងច្រើនតែមានអ្នកដទៃបោកបញ្ឆោត ចោទបង្កាច់បង្ខូច ដោយពាក្យមិនពិតផ្សេងៗ។

ដោយពាក្យភូតកុហក មានផលអាក្រក់ក្នុងលោកនេះ និងលោកខាងមុខដូចពោលមកនេះ ទើបលោកហៅថា បាបជាអំពើលាមក អាក្រក់ មិនគួរនិយាយ។ អ្នកប្រាជ្ញទាំងឡាយលោកឃើញទោសនៃពាក្យកុហកដូចពោលមកនោះ ទើបលោកមិនពោលភូតកុហកសោះ គឺលោកពោលពាក្យសច្ចៈតែម្យ៉ាងគត់ ទោះជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ។

មុសាវាទ ដែលបុគ្គលសេពថ្មឹកហើយ ផលនៃមុសាវាទ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បី គេពោលបង្កាច់ ដោយពាក្យមិនពិតដល់បុគ្គលអ្នកកើតជាមនុស្ស។

៥. វៀរចាកការផឹកគ្រឿងស្រវឹង និងប្រើប្រាស់គ្រឿងញៀន

មិនសេពគ្រឿងញៀន និងគ្រឿងស្រវឹង៖

ហាមផឹកទឹកស្រវឹងនិងសេពគ្រឿងញៀន។ ការទទួលគ្រឿងស្រវឹង និងជក់គ្រឿងញៀន ជាហេតុនាំឲ្យស្មារតីប្រែប្រួលដែលអាចបណ្តាលឲ្យ ប្រព្រឹត្តអំពើអកុសល និងទង្វើមិនគប្បីផ្សេងៗ។ ម្យ៉ាងទៀតគ្រឿងញៀនក្តីឬគ្រឿងស្រវឹងក្តី អាចបណ្តាលឲ្យបញ្ញា និងការចងចាំធ្លាក់ចុះ ហើយក៏អាចឲ្យបាត់បង់នូវសតិសម្បជញ្ញៈទៀងផង។

«សុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណី» គឺអប់រំមនុស្សអំពីទុក្ខទោសនៃការប្រព្រឹត្តគ្រឿងស្រវឹង គ្រឿងញៀនផងទាំងឡាយ។ នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន គេឃើញមានបញ្ហាគ្រោះថ្នាក់ជាច្រើនដល់អាយុជីវិត និងសុខភាពមនុស្ស ដែលបណ្តាលមកការសេពគ្រឿងស្រវឹង គ្រឿងញៀននេះ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ទាំងអ្នកប្រើប្រាស់ ទាំងអ្នកលក់ទំនិញ និងទាំងថ្នាក់ដឹកនាំប្រទេសគ្រប់ជាន់ថ្នាក់ នៅមើលស្រាលពីបញ្ហានេះនៅឡើយ។

អ្នកគប្បីប្រកាន់ខ្ជាប់ ឲ្យបាននូវសីលធម៌ទាំងប្រាំប្រការនេះ ដោយចៀសវាងការប្រព្រឹត្តអំពើបាបណាមួយទៅលើអ្នកដទៃ។ រស់នៅ ដោយមិនសម្លាប់ មិនបៀតបៀន មិនឈ្នានីស មិនជិះជាន់គ្នា មិនប្រាថ្នាទ្រព្យអ្នកដទៃ មិនប្រព្រឹត្តអំពើថោកទាបលើកូនប្រពន្ធអ្នកផងទាំងពួង មិនកុហកបោកប្រាស់ បោកបញ្ឆោតគេនោះសហគមន៍មួយ ប្រទេសជាតិមួយ រហូតដល់ពិភពលោកទាំងមូល ច្បាស់ជាមិនមានជម្លោះ មិនបង្កចលាចលឬសង្គ្រាមឡើយ។

រឿងអ្នកប្រមឹក (ទោសនៃការសេពគប់ជនពាល និងផឹកសុរា)

ពីអតីតសម័យ ក្នុងក្រុងពារាណសី មានមាណពម្នាក់ជាកូនអ្នករក្សានិច្ចសីល ។ មាណពនោះចូលចិត្តដើរជាមួយនឹងអ្នកលេងទាំងឡាយ ដែលមានវ័យស្រករគ្នា ។ អ្នកលេងទាំងឡាយ តែងបបួលមាណព ឲ្យផឹកស្រា តែមិនព្រមសោះថ្ងៃមួយគិតគ្នាថា បើមាណពនោះមិនផឹកស្រា មុខជាមិនចេញថ្លៃឲ្យពួកយើងទេ ហើយក៏រិះរកមធ្យោបាយ ដើម្បីឲ្យមាណពនោះផឹក ទើបបបួលទៅលេងឧទ្យានក្នុងថ្ងៃមហោស្រព ខ្ចប់ទឹកស្រាដែលមានរសដ៏ក្លៀវក្លា (មេស្រា) ដោយស្លឹកគ្របកឈូកទៅផង ហើយធ្វើកិច្ចឲ្យបុរសដទៃ នាំមកឲ្យពោលថា អ្នកទាំងឡាយ ចូរឲ្យផឹកទឹកដោះ ដល់មាណពក្នុងកាលជាទីផឹកទឹក ហើយនាំមកនូវទឹកមានរសផ្អែម។ អ្នកលេងទាំងនោះ ក៏ចោះទំលាយកញ្ចប់គ្របកឈូកខាងក្រោមហើយលើកយកមកផឹក ធ្វើអាការះហាក់ដូចជាផឹកទឹកផ្អែម។ (នេះឧបាយអ្នកលេងបញ្ឆោតមាណព ឲ្យលុះក្នុងតម្រាមនុស្សពាល)។

មាណពមានចំណង់ជាខ្លាំង ដាច់ចិត្តសុំទឹកនោះ ស្មានជាមានរសផ្អែមយកមកផឹក នាំស៊ីសាច់ផងក៏ស្រវឹងមួយរំពេច។ កាលស្រវឹងស៊ប់ហើយ មានភ្នែកពីរបើកប្រិមៗ ទ្រេតចុះទ្រេតឡើង ផ្លូវមួយដើរជ្រេងតែម្នាក់ឯង មិនកោតក្រែងដល់ជនដទៃ ស្មានថាខ្លួនជាមនុស្សគាប់ប្រសើរគ្រាន់បើជាងគេ ស្រែកបន្ទរថា នែភឿនទាំងឡាយខ្ញុំមិនដឹងថា ទឹកនោះឆ្ងាញ់ដល់ម្លឹងសោះ ចុះហេតុអីបានជាអ្នកទាំងឡាយមិនប្រាប់ខ្ញុំផង ហែអ្នកដ៏ចម្រើនទាំងឡាយអើយ ចូរនាំយកទឹកនោះមកទៀត។ ពួកអ្នកលេងក៏ឲ្យតាមពាក្យសុំ។

សេចក្តីស្រេកក្នុងស្រា រិតតែមានខ្លាំងឡើងៗ ដល់មាណពនោះ ត្រង់នេះឯង បុរាណពោលថាដុះមេ។ មាណពចេះតែសសោះអន្ទងទទូចសុំជារឿយៗ ដរាបដល់ពួកអ្នកលេងពោលថា ស្រាអស់រលីងហើយមាណពដោះចិញ្ចៀនឲ្យអ្នកលេងទាំងនោះ យកទៅលក់ទិញស្រាមកផឹកស្រវឹងឯតែជាមួយគ្នា វិលទៅដេកឯផ្ទះវិញ។ បិតានិយាយប្រដៅអស់ចំណះ ក៏មិនព្រមស្តាប់សោះ ហើយលាមាណពទៅកាន់សាលវិនិច្ឆ័យ ប្តឹងក្រសួងតុលាការថាអាប្រមឹកនេះ មិនមែនកូនខ្ញុំទេ សូមលោកជាចៅក្រមបណ្តេញវាចេញចុះ។ បុរសនោះ ត្រូវឪពុកនិងក្រសួងតុលាការបណ្តេញចោលហើយ ដោយស្រវឹងជោគជាមិនអាចធ្វើការអ្វីកើត ក៏កាន់អំបែងកំបែកដើរតាមច្រកល្ហកផ្ទះសុំបាយ ដរាបដល់ដេកដួលស្លាប់ នាសំយាបផ្ទះអ្នកដទៃ។

នេះទោសផឹកស្រាវិនាសទាំងទ្រព្យទាំងជីវិត និងប្រយោជន៍បរលោក អសោចអស់ទាំងកេរ្តិ៍ឈ្មោះវង្សត្រកូល ខូចពូជអំបូរអស់។

**ទោសនៃការផឹកស្រា ៦ យ៉ាង (សម្តែងដោយព្រះសម្មាសម្ពុទ្ធ)**

១- សន្ទិដ្ឋិកា ធនជានីៈ នាំឲ្យវិនាសទ្រព្យសម្បត្តិ ( ខាតបង់ទ្រព្យសម្បត្តិ )

ហេតុអ្វីបានជាការសេពនូវសុរានាំឲ្យវិនាសទ្រព្យសម្បត្តិ?

បានជាថាការសេពគ្រឿងស្រវឹងនាំឲ្យវិនាសទ្រព្យសម្បត្តិព្រោះជាបឋមគឺយកប្រាក់ទៅទិញរបស់ដែលមិនគួរទិញ បន្ទាប់មកទៀត ពេលបានញ៉ាំងជាតិស្រវឹងឲ្យចូលទៅក្នុងខ្លួនហើយ ធ្វើឲ្យបាត់បង់ស្មារតី ពេលនោះគ្រប់ខ្លួនឯងលែងបាន ចាប់ផ្តើមចាយវាយខ្ជះខ្ជាយ ឥតស្តាយ ឥតសន្សំសំចៃ មានប៉ុណ្ណាចាយប៉ុណ្ណឹង ឥតមានការស្មារតីពិចារណាពីការលំបាកក្នុងការស្វែងរកទ្រព្យសម្បត្តិឡើង ក្នុងនោះផងដែរបុគ្គលដែលជោកជាំដោយគ្រឿងស្រវឹងហើយ មិនអាចចាំបាននូវទ្រព្យសម្បត្តិរបស់ខ្លួនថា មានប៉ុណ្ណេះ ឬមានប៉ុណ្ណោះឡើយ អាចធ្វើបាត់បង់ទ្រព្យដោយខ្លួនឯង ឬត្រូវបានគេបន្លំយក ឬចាយវាយខុសទំនង ប៉ុណ្ណេះជាដើម ឈ្មោះថាធ្វើទ្រព្យរបស់ខ្លួនឲ្យវិនាសទាន់ហន់ វិនាសស្រស់ៗឃើញផ្ទាល់ភ្នែកតែម្តង។

២- កលហប្បវឌ្ឍនំៈ បង្កឲ្យកើតមានជម្លោះ និងអំពើហិង្សាផ្សេងៗ

ហេតុអ្វីបានគេថា ការសេគគ្រឿងស្រវឹងបង្កឲ្យមានជម្លោះ ឬហិង្សា?

បានជាគេថាការសេពគ្រឿងស្រវឹង ជាហេតុបង្កនាំឲ្យមានជម្លោះព្រោះ មនុស្សភាគច្រើនកាលពីនៅមិនទាន់ជាតិស្រវឹងចូលទៅក្នុងខ្លួនគឺនៅមានស្មារតី មានការពិចារណា មានការគិតគូរបានច្រើន និងគិតគូរបានវែងឆ្ងាយ គ្រប់គ្រងខ្លួនឯងលែងបាន តែពេលណាដែលគ្រឿងស្រវឹងចូលទៅបំផ្លាញស្មារតីឲ្យវង្វេងហើយ ទោះមនុស្សនោះពីដើមជាអ្នកស្លូត ជាអ្នកត្រឹមត្រូវ ជាអ្នកត្រង់ ជាអ្នកស្រគត់ស្រគុំ ជាអ្នកទន់ភ្លន់ ជាអ្នកត្រឹមត្រូវប៉ុណ្ណោះក៏ដោយ ក៏ធ្វើឲ្យជននោះមានការប្រែប្រួលចរិតភ្លាមមួយរំពេច ទៅជាមនុស្សក្អេងក្អាង ជាមនុស្សកោងកាច់ ជាមនុស្សក្លាហាន ជាអ្នកអង់អាច ជាអ្នកប្រើនូវហិង្សា ហ៊ានធ្វើនូវអំពើដែលប្រាសចាកសីលធម៌ បាត់បង់នូវភាពត្រឹមត្រូវ មានសេចក្ដីក្រោធខឹងច្រើន ឆាប់ខឹង ឆាប់ឆេវឆាវ ឆាប់ប្រទ្បេត ឆាប់មោហ៍ម៉ៅ ឆាប់ប្រកាន់ទោសអូសដំណើរច្រើន ទោះអំពើដែលមិនគួរនឹងឲ្យមានរឿងក៏ធ្វើឲ្យមានជម្លោះបាន បើប៉ះមនុស្សដែលមានចរិតអន់ ចរិតយ៉ាប់ស្រាប់ផង ក៏នឹងរឹតតែបង្កជម្លោះ បង្កវិវាទរឹតតែច្រើនហួសប្រមាណ នាំទុក្ខ នាំភ័យ អន្តរាយរឹតតែច្រើនដល់គ្រួសារ ដល់មនុស្សនៅជុំវិញខ្លួន និងដល់សង្គមទាំងមូល នាំឲ្យសង្គមកើតមាននូវអសន្តិសុខ បាត់បង់តម្លៃជាមនុស្ស ប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិ។ ជាពិសេស គឺអំពើហិង្សាក្នុងគ្រួសារ វាយដំទាត់ធាក់ សំដីអសុរោះ ការជេរប្រមាថ ការតិះដៀល ការប្រមាថមាកងាយ ធ្វើឲ្យប៉ះពាល់សមាជិកគ្រួសារមានកូនជាដើម ធ្វើឲ្យពួកគេរស់នៅខ្វះភាពកក់ក្ដៅ រស់នៅដោយការភ័យខ្លាច ក្នុងនោះផងដែរ ធ្វើឲ្យពួកគេចំទ្បងបាននូវរូបភាពអាក្រក់ៗជាច្រើនអំពីគ្រួសាររបស់ពួកគេ ហើយពួកគេនឹងប្រើប្រាស់វាទៅលើអ្នកដទៃណាម្នាក់ នៅពេលដែលពួកគេអាចប្រើវាបាន ព្រោះហេតុដូច្នោះទើបលោកថាការសេពគ្រឿងស្រវឹងគឺនាំឲ្យបង្កជម្លោះច្រើនយ៉ាង។

៣- រោគានំ អាយតនំៈ ជាហេតុនាំឲ្យកើតរោគច្រើនយ៉ាង ( ខូចសុខភាព )

ហេតុអ្វីបានជាគេថា ការសេពគ្រឿងស្រវឹង នាំឲ្យកើតរោគច្រើន?

បើយើងនិយាយអំពីរោគ គឺនរណាក៏មានរោគដែរនៅលើភពផែនដីនេះ កាលណាមានរូបគឺមានរោគ ព្រោះរាងកាយជាសម្បុកនៃរោគស្រាប់ទៅហើយ គ្មាននរណាម្នាក់អាចចៀសវាងផុត ពីរោគាព្យាធិបានឡើង រោគាតែងតែមានជាធម្មតា សម្រាប់មនុស្សសត្វគ្រប់រូបទាំងអស់ ដោយគ្មានអនុគ្រោះចំពោះជនណាម្នាក់ឡើយ ហើយរោគគឺមានច្រើនអនេកកប្បការរកំណត់មិនបាន ទាំងជំងឺកាច ទាំងជំងឺស្លូត គឺមានគ្រប់ប្រភេទទាំងអស់សម្រាប់រាងកាយនេះ។

ទន្ទឹមនឹងនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់បានបង្ហាញថា ការសេពគឿងស្រវឹងនាំឲ្យមានជំងៃច្រើន ជាការពិតបើសង្កេតឃើញតាមទិដ្ឋភាពជាក់ស្ដែង គឺឃើញថាមនុស្សដែលចូលចិត្តសេពសុរា កើតមានរោគជាច្រើនគឺរោគបាត់បង់ស្មារតី ស្មារតីលែងប្រក្រតី ហើមមុខហើមមាត់ ហើយខ្លួនប្រាណ រោគថ្លើម រោគថ្លើម រោគក្នុងពោះវៀនធំ រោគក្នុងពោះវៀនតូច រោគក្នុងភ្នែក រោគក្អួតចង្អោរ រោគញៀន រោគគេងមិនលក់ រោគស្ងួត រោគបណ្ដាលឲ្យឆ្កួត និងរោគជាច្រើនទៀតដែលកើតឡើង ដោយសាតែឥទ្ធិពលរបស់សុរា និងមេរ៉ៃពេលដែលបុគ្គលបានលេបវាចូលទៅក្នុងខ្លួនហើយ។ បើងសង្កេតនាពេលបច្ចុប្បន្ននេះ រោគដែលយើងឃើញជាក់ស្ដែងនោះគឺ ពេលណាដែលបុគ្គលបានប្រើប្រាស់ទឹកស្រវឹងហើយ តែងតែបង្កនូវគ្រោះថ្នាក់ចរា ចរណ៍យ៉ាងច្រើន

លើសលប់ នៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះ ធ្វើឲ្យមនុស្សបាត់បង់ជីវិត រងរបួស និងខូចខាងទ្រព្យសម្បត្តិជាច្រើន។

៤- អកិត្តិសញ្ជាននីៈ បណ្តាលឲ្យខូចកេរ្តិ៍ឈ្មោះ និងការរិះគន់ផ្សេងៗ

ហេតុអ្វីបានគេថា ការសេពនូវគ្រឿងស្រវឹងបណ្តាលឲ្យខូចកេរ្តិ៍ឈ្មោះ ?

យើងសង្កេតឃើញតាមសភាពជាក់ ការខូចកេរ្តិ៍ឈ្មោះ អាប់ឱនកេរ្តិ៍ឈ្មោះ ការផ្សាយកេរ្តិ៍ឈ្មោះមិនល្អទៅក្នុងសង្គមគឺវាបណ្តាលមកពីឫសគល់ជាច្រើន ដែលកើតមាននៅក្នុងសង្គមនាពេលបច្ចុប្បន្ន ក៏ដូចជាកាលពីអតីតកាលដែរ អ្នកខ្លះខូចកេរ្តិ៍ឈ្មោះដោយសារឿងបែបនេះ អ្នកខូចកេរ្តិ៍ឈ្មោះដោយសារឿងបែបនោះ អាស្រ័យតាមអំពើដែលសាមីខ្លួនបានប្រព្រឹត្ត ទៅលើមនុស្ស សត្វ ឬវត្ថុអ្វីមួយ។

ប៉ុន្តែដោយឡែកនៅក្នុងនេះ ព្រះសម្មាសម្ពុទ្ធទ្រង់បានបង្ហាញយ៉ាងច្បាស់ច្បង់ថា ការសេពគ្រឿងស្រវឹងនាំឲ្យខូចកេរ្តិ៍ឈ្មោះ ធ្វើឲ្យកេរ្តិ៍ផ្សាយទៅក្នុងសង្គមមនុស្សលោកមិនល្អ ដែលបណ្តាលមកពីសុរា និងមេរ័យ ជាការពិត មនុស្សដែលស្គាល់ខ្លួនឯង ស្គាល់តម្លៃខ្លួនឯង ស្គាល់អ្វីសមរម្យ មិនសមរម្យ អ្វីខុស អ្វីត្រូវ ការចេះខ្មាសអៀន គឺមានសម្រាប់តែមនុស្សដែលមានស្មារតីល្អ គ្រប់គ្រងខ្លួនបានល្អ មានសមត្ថភាពក្នុងការពិចារណារកហេតុផល ទើបមនុស្សចេះមានការខ្មាសអៀន។ ប៉ុន្តែពេលដែលមនុស្សណាម្នាក់បានធ្វើខ្លួនឲ្យជោកជាំដោយទឹកស្រវឹងហើយ ជននោះលែងស្គាល់ខ្លួនឯង លែងគ្រប់គ្រងខ្លួនឯងបានហើយ លែងមានស្មារតីចេះខ្មាសអៀនហើយ ស្មារតីក៏អន់ថយ រាងកាយក៏ទន់ទប់ខ្លួនមិនជាប់ ភ្នែកក៏ស្រវាំង ហើយវានឹងបណ្តាលឲ្យធ្វើនូវអំពើផ្តេសផ្តាសដូចជាស្រែកឡូឡា ស្រែកជេរ ស្រែកច្រៀង និយាយច្រើនលែងដឹងខុសត្រូវ ដើរជម្រុលជម្រក ដួលត្រឡាប់ត្រលួស ស្រាតខោ ដោះអាវ របូតអាវ របូតខោ របូតសំពត់ ប្រាស់ខ្លួនដេកទៅលើទីសមម្យលើលាមកសត្វ សត្វលិតមាត់ កាយវិការច្រឡើសបើស ហ៊ានជុតផ្ទះសម្បែង ជេរប្រទេចអ្នកជិតខាង ប៉ុណ្ណោះជាដើមគឺបានន័យថាសុរា និងមេរ័យពិតជាបង្កឲ្យកើតមាននូវភាពមិនចេះអៀនខ្មាសយ៉ាងពិតប្រាកដមែន។ ក្នុងករណីយមួយចំនួនទៀត ពេលស្រវឹងហើយ ហ៊ានប្រព្រឹត្តអំពើសម្លាប់ អំពើហិង្សា ការលួចឆក់ប្លន់ ការចាប់រំលោភ ប្រមាថអ្នកមានគុណ ជាដើម។

៥- ហិរិកោបិននិធំសនីៈ នាំឲ្យលេចកេរ្តិ៍ខ្មាស ឬបាត់បង់នូវកេរ្តិ៍ខ្មាស

ហេតុអ្វីបានជាគេថា ការសេពនូវសុរា និងមេរ័យនាំឲ្យបញ្ចេញកេរ្តិ៍ខ្មាស ដោយគ្មានភាពខ្មាសអៀន ?

បើយើងសង្កេតឲ្យជាក់ប្រាកដ ដោយឈរលើគោលការណ៍វិចារណញ្ញាណសីលធម៌ឃើញថា មានតែមនុស្សបីប្រភេទទេ ដែលជាប្រក្រតីមានការបង្ហាញនូវកេរ្តិ៍ខ្មាស ដោយមិនញញើតនោះមានដូចជាគឺៈ

១ - មនុស្សឆ្កួត ពីកំណើត ឬឆ្កួតដោយសាបញ្ហាជីវិតណាមួយ

២ - មនុស្សឆ្កួតដោយសាតែប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងច្រើនហួសប្រមាណ

៣ - មនុស្សឆ្កួតដោយសាតែអមនុស្សចូល ដែលគេនិយមហៅថា មនុស្សខ្មោចចូល

មនុស្សទាំងបីប្រភេទនេះ ជាទូទៅគឺគ្មានសេចក្តីអៀនខ្មាសទេ ពួកគេអាចដើរស្រាតខោ ដោះអាវ នៅតាមទីសាធារណៈ ដោយមិនមានខ្វល់ខ្វាយអ្វីអំពីអ្នកនៅជុំវិញខ្លួនឡើយ គឺត្រូវដេកៗ មិនរើសទីកន្លែង ត្រូវស្រាតក៏ស្រាត ត្រូវអ្វីគឺធ្វើនោះ ជារួមគឺពួកគាត់គ្រប់គ្រងខ្លួនឯងមិនបានទេ ហើយមិនខ្វល់ថា មានអ្នកសើចអ្នកយំ ឬប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អ្នកណាម្នាក់ឡើយ ជាពិសេសគឺមនុស្សឆ្កួតពីកំណើត និងមនុស្សឆ្កួតដោយសាការប្រើប្រាស់ទឹកស្រវឹង ច្រើនហួសប្រមាណពេក ធ្វើឲ្យប្រព័ន្ធប្រាសាទរបស់គាត់ត្រូវបានបំផ្លាញ

ចោលដោយសារជាតុពុលនៅក្នុងសុរា និងមេរ័យបំផ្លាញចោលអស់ ដូច្នេះពួកគាត់មិនខ្វល់អំពីអ្វីទាំងកុំថាឡើយត្រូវស្គាល់ឪពុកម្ដាយ បងប្អូន ផ្ទះសម្បែង សូម្បីតែគាត់ខ្លួនឯងមិនថាជាអ្វីផង។

៦- បញ្ញាយ ទុព្វលីករណី: នាំឲ្យចុះខ្សោយប្រាជ្ញាស្មារតី។

ហេតុអ្វីបានជាគេថា ការសេពសុរា និងមេរ័យធ្វើឲ្យបញ្ញាចុះខ្សោយ ចុះអន់ថយ?

ជាការពិត បើនិយាយពីរឿងបញ្ញា គឺពិតមានគ្រឿងផ្សំច្រើនណាស់ ក្នុងនោះមានដូចជា កត្តាដែលបានផ្ដល់ឲ្យមកដល់មនុស្សម្នាក់ៗពីធម្មជាតិ (គុណភាពខួរក្បាល) កត្តាខ្លួនឯង កត្តាសង្គម កត្តាសេពគប់ជាដើមប៉ុណ្ណេះជាហេតុធ្វើឲ្យបុគ្គលមានបញ្ញា ទៅតាមសមត្ថភាពរៀងៗខ្លួន ព្រោះមនុស្សមិនមានសមត្ថភាពដូចគ្នាទាំងអស់នោះទេ សូម្បីតែកើតចេញមកពីផ្ទៃ នៃម្ដាយតែមួយដូចគ្នាក៏ដោយ។

តាមសភាពជាក់ស្ដែង បើយើងសង្កេតតាមព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ទ្រង់បានបញ្ជាក់ថា ការសេពនូវគ្រឿងស្រវឹងគឺធ្វើឲ្យបញ្ញាចុះអន់ថយ បញ្ញាខ្សោយ ជាការពិតខួររបស់មនុស្សគឺជាធម្មជាតិមួយដែលត្រូវយកចិត្តទុកដាក់ការពារ ថែទាំរក្សាខ្ពស់បំផុតក្នុងចំណោមអវយវៈនៃរាងកាយទាំងមូល ក្បាលជាប្រភពនៃការទទួលទិន្នន័យ និងចែករំលែកទិន្នន័យ បើកន្លែងទទួលទិន្នន័យត្រូវបានបំផ្លាញដោយមេរោគ ធ្វើឲ្យធ្វើឲ្យកន្លែងទទួលទិន្នន័យចុះខ្សោយហើយ អ៊ីចឹងទាំងការទទួលព័ត៌មាន ទាំងរក្សាទុកព័ត៌មាន ទាំងការពិចារណាចម្រាញ់ទៅលើព័ត៌មាន ទាំងការឆ្លុះបញ្ចាំងទៅលើព័ត៌មានក៏ខ្សោយ បើប្រព័ន្ធទាំងនោះខ្សោយហើយ ការបញ្ចេញព័ត៌មានក៏ខ្សោយទៅតាមហ្នឹងដែរ ក្នុងន័យថា បើខួរក្បាលត្រូវជាតិពុលនៃសុរា និងមេរ័យ និងគ្រឿងដទៃទៀតចូលទៅបំផ្លាញឲ្យខូចបង់ហើយ ដូច្នេះបញ្ញាដែលជាគ្រឿងបញ្ចេញនូវភាពល្អប្រសើរ ក៏ត្រូវខូចបង់ទៅតាមហ្នឹងដែរ។ មនុស្សណាក៏ដោយ ឲ្យតែជាតិពុលនៃសុរា និងមេរ័យចូលទៅក្នុងខ្លួនហើយ សមត្ថភាពនៃការគិតគឺប្រែប្រួល និងខ្សោយបំផុតក្នុងពេលភ្លាមនោះឯង តែបើជននោះនូវតែព្យាយាមប្រើប្រាស់គ្រឿងស្រវឹងបន្តទៀត វានឹងធ្វើឲ្យខួរក្បាលរឹតតែខ្សោយជាលំដាប់ ព្រោះខួរក្បាលត្រូវបានបំផ្លាញនូវគុណភាពរបស់វាឥតឈប់ឈរ ដូច្នេះការទទួល និងការចងចាំគឺរឹតតែថយចុះជាលំដាប់។

ការផឹកនូវសុរានិងមេរ័យ ដែលបុគ្គលសេពថ្មីកហើយ ផលនៃការផឹកនូវសុរា និងមេរ័យ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅដើម្បីភាពជាអ្នកឆ្កួតដល់បុគ្គលអ្នកកើតជាមនុស្ស។

**ទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីលមាន៥យ៉ាងគឺះ**

១ - បុគ្គលទ្រុស្តសីល វិបត្តិចាកសីលនេះ តែងតែដល់នូវសេចក្ដីវិនាសនៃសម្បត្តិយ៉ាងធំ មានសេចក្ដីប្រមាទជាហេតុ។

២ - កិត្តិសពន្ទអាក្រក់របស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងផ្សាយទោសព្វទិស។

៣ - បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ចូលទៅរកបរិស័ទណាៗ ទោះខត្តិយបរិស័ទក្ដី ព្រាហ្មណ៍បរិស័ទក្ដី គហបតីបរិស័ទក្ដី សមណបរិស័ទក្ដី រមែងមិនក្លៀវក្លា មានមុខឱនចុះ ។

៤ - បុគ្គលទ្រុស្តសីល វិបត្តិចាកសីល តែងវង្វេងធ្វើមរណកាល។

៥ - បុគ្គលទ្រុស្តសីល វិបត្តិចាកសីល លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក[10]។

---

[10] សុត្តន្តបិដក ទីឃនិកាយ បាជិកវគ្គ ភាគ១៩ ព.ស ២៥០៣ទំព័រ ១៧៧

## ២.១.២. អង្គនីមួយៗនៃរបស់សិក្ខាបទទាំង៥

បុគ្គលនឹងឈ្មោះថាប្រព្រឹត្តកន្លង(ដាច់)សីល៥ណាមួយ លុះត្រាតែប្រព្រឹត្តកន្លងគ្រប់អង្គនៃសិក្ខាបទនោះៗទើបឈ្មោះថាដាច់សីល។ អង្គនៃសិក្ខាបទប្រាំនោះមានដូចខាងក្រោមនេះ៖

១- បាណាតិបាត វេរមណី វៀរចាកការសម្លាប់សត្វ។

បាណាតិបាត មានអង្គ៥ គឺ៖

១- បាណោ សត្វមានជីវិត

២- បាណសញ្ញិតា សេចក្តីដឹងថា សត្វមានជីវិត

៣- វធកចិត្តំ ចិត្តគិតនឹងសម្លាប់

៤- ឧបក្កមោ ព្យាយាមនឹងសម្លាប់

៥- តេនមរណំ សត្វស្លាប់ដោយការព្យាយាមនោះ

**ហេតុដែលមិនត្រូវទោសមាន ៦យ៉ាងគឺ៖**

មិនក្លែង១ មិនដឹង១ មិនប្រាថ្នានឹងសម្លាប់១ មនុស្សឆ្កួត១ មនុស្សមានចិត្តរវើរវាយ១ ជាមនុស្សមានទុក្ខវេទនាគ្របសង្កត់១។

២- អទិន្នាទានា វេរមណី វៀរចាកការកាន់យករបស់ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា (វៀរចាកលួចទ្រព្យគេ)។

**អទិន្នាទាន មានអង្គ៥ គឺ៖**

១- បរបរិគ្គហិតំ ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា។

២- បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថា ទ្រព្យមានម្ចាស់គេហួងហែងរក្សា។

៣- ថេយ្យចិត្តំ ចិត្តគិតនឹងលួច។

៤- ឧបក្កមោ ព្យាយាមនឹងលួច។

៥- តេនហរណំ លួចបានមកដោយការព្យាយាមនោះ។

**បរិយាយអំពីអវហារ ការលួចមានសេចក្តីដូចតទៅ៖**

សកម្មភាពនៃការលួច៥យ៉ាង

១. អ្នកលួចបានចោទប្រកាន់យកទ្រព្យគេមានស្រែ ចម្ការ ជាដើមតែម្ចាស់ទ្រព្យគេកាត់អាល័យ ខ្លួនឯងអ្នកលួចក៏ដាក់ធុរៈ ថាអញមិនឲ្យវិញទេ ដាច់ខូចអទិន្នាទានសិក្ខាបទ។

២. អ្នកលួចបាននាំយកទៅនូវភណ្ឌៈរបស់អ្នកដទៃ ដោយមានចិត្តគិតនឹងលួច (ថេយ្យចិត្ត) ញាំងវត្ថុដែលនៅលើក្បាលលើកលើស្មា លើចង្កេះឲ្យឃ្លាតចាកទីឋានប៉ុនចម្រៀកសក់ក៏ដាច់ខូចអទិន្នាទានសិក្ខាបទ។

៣. អ្នកលួចបានយកទ្រព្យគេ ដែលផ្ញើទុកនឹងខ្លួនដល់ម្ចាស់គេមកទារ មិនឲ្យទៅគេ តែម្ចាស់គេដាច់អាល័យក៏ដាច់ខូច អទិន្នាទានសិក្ខាបទ។

៤. អ្នកលួចបានយកទ្រព្យគេ យកទាំងម្ចាស់ទ្រព្យទៅផង តែនាំទៅឲ្យផុតជំហានជាគម្រប់ពីរ ក៏ដាច់ខូច អទិន្នាទានសិក្ខាបទ។

៥. អ្នកលួចបានយកទ្រព្យគេដែលនៅលើគោក នាំយកទៅឲ្យឃ្លាតចាកទីប៉ុនចម្រៀកសក់ ក៏ដាច់ខូច អទិន្នាទានសិក្ខាបទ។

**អ្នកលួច៥យ៉ាងទៀតគឺ**

១. អ្នកលួចបានចោទខ្ញុំកំដរ និងសត្វចិញ្ចឹមរបស់គេ ដាច់ខូច អទិន្នាទានសិក្ខា។

២. អ្នកលួចបានជួយនាំទៅនូវខ្ញុំកំដរនិងសត្វចិញ្ចឹមរបស់គេ ហើយមានចិត្តគិតនឹងលួច (ថេយ្យចិត្ត) ក៏លួចយកទៅតែម្តង ដាច់ខូចអទិន្នាទានសិក្ខាបទ។

៣. អ្នកលួចបានប្រវ័ញ្ចយកខ្ញុំកំដរ និងសត្វចិញ្ចឹមរបស់គេ ដែលគេផ្ញើទុកនឹងខ្លួន ដាច់ខូចអទិន្នាទានសិក្ខា។

៤. អ្នកលួចមានថេយ្យចិត្ត (ចិត្តគិតនឹងលួច) ធ្វើឥរិយាបថនៃខ្ញុំកំដរ និងសត្វចិញ្ចឹមរបស់គេ ឲ្យកម្រើកដាច់ខូច អទិន្នាទានសិក្ខាបទ។

៥. អ្នកលួចមានថេយ្យចិត្ត (ចិត្តគិតនឹងលួច) ធ្វើខ្ញុំកំដរ និងសត្វចិញ្ចឹមរបស់គេឲ្យឃ្លាតចាកទី ដាច់ខូច អទិន្នាទានសិក្ខាបទ។

**អ្នកលួច៥យ៉ាងទៀតគឺ**

១. អ្នកលួចកាន់យកដោយដៃខ្លួនឯង ដាច់ខូច អទិន្នាទានសិក្ខាបទ។

២. អ្នកលួចបានប្រើបង្គាប់អ្នកដទៃឲ្យលួចទ្រព្យគេ បើអ្នកដទៃលួចបានមកតាមបង្គាប់នោះ ដាច់ខូច អទិន្នាទានសិក្ខាបទ។

៣. អ្នកលួចបានទ្រព្យគេ ដោយបោះរំលងទីមានរបង និងទ្វារជាដើម ឬរត់រំលងគយព្រះរាជធានី ដាច់ខូច អទិន្នាទានសិក្ខាបទ។

៤. អ្នកលួចញុំាងប្រយោជន៍ឲ្យសម្រេចជាមុន អំពីកិរិយាលួច គឺបង្គាប់អ្នកដទៃថា អ្នកណាលួចរបស់នៃជនឯណោះបាន ក្នុងកាលណាចូរលួច ក្នុងកាលនោះចុះ ប្រសិនបើអ្នកដទៃលួចបានមែនខ្លួនអ្នកបង្គាប់ ដាច់ខូច អទិន្នាទានសិក្ខាបទ។

៥. អ្នកលួចបានលួចទ្រព្យគេសម្រេចដោយការដាក់ធុរៈ ដូចលួច ចោទប្រកាន់យកដីជាដើម ឬរបស់ផ្ញើទុកនឹងខ្លួន ពុំនោះសោត របស់ដែលខ្លួនបានខ្ចីគេមក បើខ្លួនដាក់ធុរៈថា អញមិនឲ្យ ឯម្ចាស់ទ្រព្យក៏គេដាច់អាល័យ ដាច់ខូចអទិន្នាទានសិក្ខាបទ។

**អ្នកលួច៥យ៉ាងទៀតគឺះ**

១. ប្រកបក្នុងខាងដើម

២. អ្នកលួចបានលួចទ្រព្យគេ ដោយព្យាយាមខ្លួនឯង មានបង្ខិតបង្គោលព្រំចូលទៅក្នុងទីស្រែចម្ការជាដើម ចំនួនទីប៉ុនចុងសក់ ដាច់ខូច អទិន្នាទានសិក្ខាបទ។

៣. អ្នកលួចបបួលគ្នាទៅលួចទ្រព្យគេ បើអ្នកណាមួយលួចបានមកក៏ដាច់ខូច អទិន្នាទានសិក្ខាបទ។

៤. អ្នកលួចប្រើអ្នកដទៃឲ្យទៅលួចទ្រព្យគេ ដោយកំណត់កាល មានវេលាព្រឹកជាដើម បើអ្នកដទៃលួចបានមែនត្រូវតាមកំណត់ កាលដែលប្រើបង្គាប់នោះ ដាច់ខូចអទិន្នាទានសិក្ខាបទ។

៥. ការធ្វើនិមិត្តអ្នកលួចគិតនឹងលួចទ្រព្យគេ ដោយធ្វើនិម្មិត្តកម្ម មានកិរិយាប៉ព្រិចភ្នែក និងកិរិយាញាក់មុខជាដើម ដើម្បីឲ្យសញ្ញាដល់អ្នកដែលខ្លួនប្រើឲ្យទៅលួច បើអ្នកនោះលួចបានមកតាមសញ្ញានោះមែន ដាច់ខូចអទិន្នាទានសិក្ខាបទ។

**អ្នកលួច៥យ៉ាងទៀតគឺ**

១. អ្នកលួចបានលបកាត់ជញ្ជាំងជាដើម ហើយលបចូលលួចរបស់គេក្តី បោកប្រាស់យករបស់គេក្តី ដោយរង្វាស់រង្វាល់ខ្វះ ឬលើស និងកហាបណៈក្លែងក្លាយជាដើម ដាច់ខូចអទិន្នាទានសិក្ខាបទ។

២. អ្នកលួចកំហែងសង្កត់សង្កិន ប្លន់ ឬឆក់ដណ្តើមយកទ្រព្យរបស់អ្នកដទៃ ដាច់ខូចអទិន្នាទានសិក្ខាបទ។

៣. អ្នកលួចទ្រព្យដោយកិរិយាកំណត់ទុក កិរិយាកំណត់ទុកក្នុងទីនេះមាន២ យ៉ាងគឺ កំណត់យកទ្រព្យ១ កំណត់ឱកាស១។

៤. ការបិទបាំងទុកហើយលួច។

៥. ការផ្លាស់ប្តូរស្លាកហើយកាន់យកទៅ។

**ទោសនៃការប្រព្រឹត្តល្មើលអទិន្នាទានមានច្រើនប្រភេទគឺៈ**

១. ការកាន់យកទ្រព្យរបស់បុគ្គលទ្រុស្តសីល ឈ្មោះថា មានទោសតិច។

២. ការកាន់យកទ្រព្យរបស់បុគ្គលប្រព្រឹត្តដូចជាគោ ឈ្មោះថា មានទោសច្រើនជាងនោះ។

៣. ការកាន់យកទ្រព្យរបស់បុគ្គលអ្នកដល់នូវត្រៃសរណគមន៍ ឈ្មោះថា មានទោសច្រើនជាងនោះ។

៤. ការកាន់យកទ្រព្យរបស់បុគ្គលអ្នកមានសីល៥មានទោសច្រើនជាងនោះ។

៥. ការកាន់យកទ្រព្យរបស់សាមណេរ ឈ្មោះថា មានទោសច្រើនជាងនោះ។

៦. ការកានក់យកទ្រព្យរបស់ភិក្ខុជាបុថុជ្ជន ឈ្មោះថា មានទោសច្រើនជាងនោះ។

៧. ការកាន់យកទ្រព្យរបស់សោតបន្ន ឈ្មោះថា មានទោសច្រើនជាងនោះ។

៨. ការកាន់យកទ្រព្យរបស់សកទាមី ឈ្មោះថា មានទោសច្រើនជាងនោះ។

៩. ការកាន់យកទ្រព្យរបស់ព្រះអនាគាមី ឈ្មោះថា មានទោសច្រើន។

១០. ការកាន់យកទ្រព្យរបស់ព្រះខីណាស្រព ឈ្មោះថា មានទោសច្រើនក្រៃលែងបំផុត។

ទោសអទិន្នាទាន ៖ អទិន្នាទានឈ្មោះថា មានទោសតិច ព្រោះរបស់អ្នកដទៃអាក្រក់ (តម្លៃតិច) ឈ្មោះថាមានទោសច្រើន ព្រោះរបស់អ្នកដទៃប្រណិត (តម្លៃច្រើន) ព្រោះហេតុអ្វី? ព្រោះវត្ថុប្រណិត ព្រោះវត្ថុប្រណិត មានទោសតិច ព្រោះរបស់អ្នកដទៃតិច ឈ្មោះថា មានទោសច្រើន ព្រោះរបស់អ្នកដទៃច្រើន ក៏ដូចគ្នាយ៉ាងនេះ។ ព្រោះហេតុអ្វី ? ព្រោះវត្ថុធំ និងព្រោះប្រយោគធំ តែកាលមានវត្ថុស្មើគ្នា អទិន្នាទាន ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុរបស់បុគ្គលអ្នកមានគុណធម៌ខ្ពស់ ឈ្មោះថា មានទោសតិច ព្រោះវត្ថុរបស់អ្នកមានគុណធម៌ទាបជាងអ្នកមានគុណធម៌ខ្ពស់នោះៗ ដោយសំដៅយកគុណធម៌ខ្ពស់នោះៗជាកេណ្ឌ តែកាលបើវត្ថុ និងគុណធម៌មិនប៉ុនគ្នា អទិន្នាទាន ឈ្មោះថា មានទោសតិច ព្រោះកិលេស និងប្រយោគទន់ខ្សោយ ឈ្មោះថា មានទោសច្រើន ព្រោះកិលេស និងប្រយោគជារបស់ខ្លាំងក្លា។

**ផលនៃការមិនប្រព្រឹត្តល្មើសអទិន្នាទានមាន១១យ៉ាងគឺ**

១. ភាពជាអ្នកមានទ្រព្យច្រើនផង

២. ជាមនុស្សមានរបស់របរ និងធញ្ញាហារសម្បូណ៌កុះករ

៣. ជាមនុស្សរកទ្រព្យបានដោយមិនទើសទាល់ដល់ទីបំផុត

៤. ភោគទ្រព្យមិនទាន់កើត ក៏កើតឡើងបាន។

៥. ភោគទ្រព្យកើតឡើងហើយ ក៏តាំងនៅខ្ជាប់ខ្ជួរមិនខូចខាត។

៦. រកទ្រព្យរបស់ដែលប្រាថ្នាបានឆាប់រហ័ស (មិនលំបាក)

៧. មានទ្រព្យសម្បត្តិមិនខ្ចាត់ខ្ចាយអន្តរាយដោយរាជភ័យ ចោរភ័យ (ភ័យអំពីចោរ) ឧទកភ័យ (ភ័យដោយសារទឹក) អគ្គិភ័យ (ភ័យដោយសារភ្លើង) ញាតិ (ភ័យដោយសារញាតិ) ឆបោកឡើយ។

៨. រកទ្រព្យបានមកហើយ មិនបានខ្ជះខ្ជាយសាយភាយទៅផ្តេសផ្តាសឡើយ។

៩. សមរម្យជាអ្នកបាននូវលោកុត្តរទ្រព្យទៀតផង។

១០. ភាពជាអ្នកមិនធ្លាប់ដឹង មិនធ្លាប់ឮដោយគ្រាន់តែពាក្យថាគ្មាន (នោះឡើយ)។

១១. ទៅនៅកន្លែងណាក៏ជួបប្រទះតែនឹងសុខ។

**ហេតុមិនត្រូវទោសក្នុងអទិន្នាទាន ៧ យ៉ាងគឺ៖**

១. កាន់យកដោយប្រឡំ សម្គាល់ថាជារបស់ខ្លួន

២. កាន់ដោយសេចក្តីស្និទ្ធស្នាលនឹងគ្នា។

៣. កាន់យកដោយរបស់ខ្ចី

៤. កាន់យករបស់ពួកប្រេតហួងហែងរក្សា

៥. កាន់យករបស់សត្វតិរច្ឆានហួងហែងរក្សា

៦. កាន់យកដោយសម្គាល់ថា ជារបស់រើសបាន

៧. ជាមនុស្សឆ្កួត។

**៣- កាមេសុមិច្ឆាចារា វេរមណី វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។**

កាមេសុមិច្ឆារៈ មានអង្គ៤ គឺ៖

១- អគមនីយដ្ឋានំ ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា។

២- តស្មឹសេវនចិត្តំ គិតនឹងសេពមេថុនធម្មនឹងស្ត្រីនោះ។

៣- ឧបក្កមោ ព្យាយាមនឹងសេពមេថុនធម្ម។

៤- មគ្គេនមគ្គបដិបាទនំ ញ៉ាំងមគ្គ និងមគ្គឲ្យដល់គ្នា។

**៤- មុសាវាទា វេរមណី វៀរចាកការពោលពាក្យមិនពិត គឺពាក្យកុហក។**

មុសាវាទ មានអង្គ៤ គឺ៖

១-អតថំវត្ថុ វត្ថុមិនពិត។

២- វិសំវាទនចិត្តំ ចិត្តគិតនឹងពោលឲ្យខុស។

៣- តជ្ជោវាយាមោ ព្យាយាមនឹងពោលឲ្យខុស។

៤- បរស្សតទត្ថវិជាននំ ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្តីនោះ។

**៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី វៀរចាកការសេពនូវទឹកស្រវឹងគឺសុរា និងមេរ័យ។**

សុរាមេរយៈ មានអង្គ៤ គឺ៖

១- មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរា និងមេរ័យ។

២- បាតុកម្យតាចិត្តំ ចិត្តគិតបម្រុងនឹងផឹក។

៣- តជ្ជោវាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ។

៤- តស្សបានំ បានផឹកនូវទឹកស្រវឹងនោះឲ្យកន្លងបំពង់កចូលទៅ។

បើមនុស្សក្នុងទីណា សង្គមណា ប្រទេសណា សម្បូណ៌ទៅដោយអ្នកមានសីល៥ ទីនោះ សង្គមនោះ ប្រទេសនោះ នឹងពោរពេញទៅដោយសន្តិសុខ និងសន្តិភាព។

## ២.១.៣. កុសលកម្មបថ១០

និយមន័យកុសលកម្មបថ

ពាក្យថា កម្មបថ មានន័យថា គន្លង ឬផ្លូវ នៃអំពើ។ គន្លងនៃអំពើដែលគេធ្វើ មាន២ចំណែកគឺ ចំណែកខាងអកុសល១ និងចំណែកខាងកុសល១។

កុសលកម្មបថមានគន្លង ១០ គឺ

ផ្លូវកាយមាន៣ ហៅថា **កាយកម្ម៣**, ផ្លូវវាចាមាន៤ ហៅថា **វចីកម្ម៤**, និងផ្លូវចិត្តមាន៣ ហៅថា **មនោកម្ម៣** រួមត្រូវជា១០ហៅថា **កម្មបថ១០**។ មនុស្សទាំងឡាយ និងអ្នករក្សាសីលត្រូវតែយល់ដឹងហើយប្រុងប្រយ័ត្នចំពោះកម្មបថ ព្រោះថាកាលបើដាច់កម្មបថត្រង់ប្រការណាមួយ ជីវិតនឹងមានបញ្ហា សីលរបស់អ្នកនោះក៏នឹងត្រូវដ្ដះដ្ឋាយទៅដែរ។

### ២.១.២.១. កាយសុចរិត៣

ក. កាយកម្ម៣ សកម្មភាពដែលស្ដែងឡើងតាមរយៈកាយ

១ បាណាតិបាតា វេរមណី ចេតនាវៀរចាកការ ធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់ សត្វ។

២ អទិន្នាទានា វេរមណី ចេតនាវៀរចាកការ កាន់យកនូវវត្ថុដែលគេមិនឲ្យដោយកាយ ឬដោយវាចា។

៣ កាមេសុមិច្ឆាចារា វេរមណី ចេតនាវៀរចាកការ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

### ២.១.២.២. វចីសុរិត៤

ខ. វចីកម្ម៤ (សកម្មភាពដែលស្ដែងចេញតាមរយៈពាក្យសំដី

១ មុសាវាទា វេរមណី ចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យកុហក។

២ បិសុណាយ វាចាយ វេរមណី ចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យញុះញង់ស៊កសៀតបំបែកបំបាក់អ្នកដទៃ។

បិសុណាវាចា មានអង្គ៤គឺៈ

១- ភិន្ទិតព្វោបរោ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក។

២- ភេទនបុរេក្ខាតោ គិតនឹងញុះញង់បំបែកបំបាក់អ្នកដទៃនោះ។

៣- តជ្ជោវាយាមោ ព្យាយាមបំបែកបំបាក់អ្នកដទៃនោះ ។

៤- តស្សតទត្ថវិជ្ជាទនំ ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវដំណើរដែលញុះញង់នោះ។

**៣- ផរុសាយ វាចាយ វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម។

ផរុសវាចា មានអង្គ៣គឺៈ

១ អក្កោសិតព្វោបរោ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីជេរប្រទេច។

២ កុប្បិតចិត្តំ ចិត្តខឹងរន្ធត់។

៣ អក្កោសនា បានជេរប្រទេច។

៤ សម្ផប្បលាបា វេរមណី ចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យរាយមាយឥតប្រយោជន៍។

សម្ផប្បលាប មានអង្គ២គឺៈ

១ ភារតយុទ្ធសិតាហរណាទិនិរត្ថកថា ពាក្យឥតប្រយោជន៍មានរឿងចម្បាំងនៃភារត និងរឿងរាពណ៍លួចនាងសេតាយកទៅជាដើម។

២ តថារូបីកថាកថនំ បានពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នេះ។

២.១.២.៣. មនោសុចរិត៣

គ. មនោកម្ម៣ (អំពីដែលជាចលនារបស់ចិត្ត សកម្មភាពរបស់ចិត្ត)

១ អនភិជ្ឈា មិនមានចិត្តគិតសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ។

អភិជ្ឈា មានអង្គ២គឺៈ

១ បរភណ្ឌំ ទ្រព្យជារបស់អ្នកដទៃ ។

២ អត្តនោ បរិណាមនំ គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះ ឲ្យមកជាទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេងៗ។

២អព្យាបាទោមិនមានចិត្តចងគំនុំគុំគួនគិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្តីវិនាសឡើយ។

**ព្យាបាទ មានអង្គ២គឺៈ**

១ បរសត្តោ អ្នកដទៃក្រៅពីខ្លួន ។

២ តស្សតំតំវិនាសចិន្តា គិតចងគំនុំគុំគួននឹងអ្នកនោះ ដល់នូវសេចក្តីវិនាសដោយហេតុនោះ។

៣ សម្មាទិដ្ឋិ គំនិតយល់ឃើញត្រូវពិត ហើយប្រកាន់ឡើងថាត្រូវមែន។

**មិច្ឆាទិដ្ឋិ មានអង្គ២គឺៈ**

១ វត្ថុនោចគហិតាការវិបរិតតោ ចិត្តប្រែប្រួលដោយអាការៈខុស អំពីព្រះរតនត្រ័យជាដើម។

២ យថាចនំគណ្ហាគិតថាភាវេនតស្សុបដ្ឋានំ គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះថាជាត្រូវវិញ។

៣. អានិសង្សនៃការប្រព្រឹត្តសុចរិតមាន៥យ៉ាងគឺ

១. អត្តាបិ អត្តានំ នឧបដ្ឋតិ ខ្លួនមិនតិះដៀលខ្លួនឯង

២. អនុវិច្ច វិញ្ញូ បសំសន្តិ ពួកអ្នកប្រាជ្ញពិចារណាហើយតែងតែសរសើរ

៣. កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កិត្តិស័ព្ទពីរោះខ្ទរខ្ទាយទៅ

៤. អសម្មូឡ្ហោ កាលំ ករោតិ ពេលស្លាប់ទៅមិនវង្វេងស្មារតី

៥. បរម្មារណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ក្រោយពីស្លាប់ទៅនឹងទៅក្នុងកើតក្នុងសុគតិភព។

## ២.១.៤. អកុសលកម្មបថ១០

និយមន័យ អកុសលកម្មបថ

អកុសលកម្មបថ មានន័យថា គន្លង ឬផ្លូវនៃអំពើជាអកុសល ហៅថា អកុសលកម្មបថ។

**អកុសលកម្មបថ១០គន្លង** ឬផ្លូវនៃអំពើជាអកុសល ហៅថា អកុសលកម្មបថ មាន១០យ៉ាងគឺ កាយកម្ម អំពើដែល សម្រេចដោយកាយ មាន៣យ៉ាង វចីកម្ម អំពើដែលសំរេចដោយវាចាមាន៤យ៉ាង មនោកម្ម អំពើដែលសម្រេចដោយចិត្តមាន៣ យ៉ាង រួមត្រូវជា១០យ៉ាង។

### ២.១.៣.១. កាយទុច្ចរិត៣

កាយកម្មមាន ៣យ៉ាង

១ បាណាតិបាតោ កិរិយាសម្លាប់សត្វដោយកាយរបស់ខ្លួនឬប្រើគេឲ្យសម្លាប់ដោយវាចា។

២ អទិន្នាទានំ កិរិយាលាក់ឆក់លួច ដណ្តើមទ្រព្យគេ ដោយកាយរបស់ខ្លួនឬប្រើឲ្យគេ លួចលាក់ ឆក់ដណ្តើមដោយវាចា។

៣ កាមេសុ មិច្ឆាចារា កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវនៈនិងស្ត្រីឬបុរស ដែលមានគេហួងហែងរក្សា។

### ២.១.៣.២. វចីទុច្ចរិត៤

វចីកម្ម៤យ៉ាង

១ មុសាវាទោ កិរិយាពោលនូវពាក្យកុហក។

២ បិសុណាវាចា កិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ។

៣ ផរុសវាចា កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃ

៤ សម្ផប្បលាបោ កិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍។

### ២.១.៣.៣. មនោទុច្ចរិត៣

មនោកម្ម៣យ៉ាង

១ អភិជ្ឈា ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឲ្យបានជារបស់ខ្លួន។

២ ព្យាបាទោ ចិត្តចងគំនុំគុំកួនប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្តីវិនាស។

៣ មិច្ឆាទិដ្ឋិ គំនិតយល់ខុស ហើយប្រកាន់ឡើងថាត្រូវ។

អង្គនៃកុសលកម្មបថ

បិសុណាវាចា មានអង្គ៤

១ ភិន្ទិតព្វោ បរោ អ្នកដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក។

២ ភេទនបុរេក្ខារតា គិតនឹងញុះញង់បំបែកអ្នកដទៃ។

៣ តជ្ជោ វាយាមោ ព្យាយាមនឹងញុះញង់បំបែកអ្នកដទៃនោះ។

៤ តស្ស ទត្ថវិជាននំ ញុំាងអ្នកនោះឲ្យដឹងច្បាស់នូវដំណើរដែលខ្លួនញុះញង់នោះ។

**ផរុសវាចា មានអង្គ៣**

១ អក្កោសិតព្វោ បរោ អ្នកដទៃមានរូបគឺខ្លួនគប្បីជេរប្រទេច។

២ កុប្បិតចិត្តំ ចិត្តខឹងរន្ធត់។

៣ អក្កោសនា បានជេរប្រទេចគេ។

**សម្ផប្បលាបៈ មានអង្គ២**

១ ភារតយុទ្ធសិតាហរណាទិនិរត្ថកថា ពាក្យឥតប្រយោជន៍ មានរឿងចំបាំងនៃមហាភាតរនិងរឿងរាពណ៍លួចនាំនាងសិតាទៅតាមជាដើម។

២ -តថារូបកថាកថនំ បានពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នោះ។

**អភិជ្ឈា មានអង្គ២**

១ បរភណ្ឌំ ទ្រព្យជារបស់អ្នកទៃ។

២ អត្តនោ បរិណាមនំ គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះ ឲ្យបានមកជា ទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេងៗ។

**ព្យាបាទៈ មានអង្គ២**

១ បរសត្តោ អ្នកដទៃក្រៅពីខ្លួន។

២ តស្ស តំ វិនាសចិន្តា គិតគំកួនប្រុងនឹងឲ្យអ្នកនោះដល់នូវសេចក្តី វិនាសដោយហេតុនោះៗ។

**មិច្ឆាទិដ្ឋិ មានអង្គ២**

១ វត្ថុនោ ច គហិតាការវិបរិតតា ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម។

២ យថា ច នំ គណ្ហាតិ តថាភាវេន តស្សូបដ្ឋានំ គំនិតដែលយល់ខុសនោះឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះថាជាត្រូវវិញ។

អកុសលកម្មបថ ១០ប្រការ ដូចបានពោលមកហើយនេះ ទោះត្រង់បទណាក្តី បើលុះព្រមដោយអង្គនោះៗ ទើបត្រូវទោសដល់អ្នកប្រព្រឹត្តខុស អ្នកនោះនឹងបាននូវសេចក្តីទុក្ខ សេចក្តីវិនាស ក្នុងលោកនេះ និងបរលោកនាយ បើទុកជាមិនទាន់ឲ្យផល ឲ្យឃើញច្បាស់ក្នុងលោកនេះ លុះដល់ទៅក្នុងបរលោកនាយ ក៏គង់នឹងឲ្យផលដល់អ្នកនោះពុំខានឡើយ បើមិនទាន់ព្រមដោយអង្គនោះៗ គឺថាបើនៅខ្វះអង្គណាមួយនោះ ក៏មិនទាន់បានឈ្មោះ ថាមានទោសក្នុងអកុសលកម្មបថ ដល់អ្នកដែលប្រព្រឹត្តនៅឡើយ។

**៣. ទោសនៃការប្រព្រឹត្តទុច្ចរិត៥យ៉ាងគឺ**

១. អត្តាបិ អត្តានំ ឧបវទតិ ខ្លួនតិះដៀលខ្លួនឯង

២. អនុវិច្ច វិញ្ញូ គរហន្តិ ពួកអ្នកប្រាជ្ញពិចារណាហើយតិះដៀលបាន

៣. បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កិតិស័ព្ទដ៏អាក្រក់ផ្សព្វផ្សាយទៅ

៤. សម្មុឡ្ហោ កាលំ ករោតិ ពេលស្លាប់វង្វេងស្មារតី

៥. បរម្មារណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ក្រោយពីស្លាប់ និងទៅកើតជាប្រេត តិរច្ឆានអសុរកាយ នរក។

## ២.១.៥. មគ្គប្រកបដោយអង្គ៨

បណ្តាបុគ្គលទាំងឡាយដែលកើតមកលើលោកនេះ រមែងមានការប្រព្រឹត្តផ្សេងៗគ្នា គឺខ្លះប្រព្រឹត្តតាមធម៌ ខ្លះទៀតមិនប្រព្រឹត្តតាមធម៌ ឬខ្លះប្រព្រឹត្តតាមដែរ ប៉ុន្តែនៅស្ទាកគំនិត មិនមានសន្ទុះល្បឿនទៅមុខទៀត ដោយគិតឃើញថា ការអនុវត្តតាមសាសនធម៌នេះ តែត្រឹមប៉ុណ្ណោះឯង គ្មានគុណជាតិអ្វីឲ្យវិសេស លើសជាងការប្រព្រឹត្តបែបនេះទៅទៀតនោះទេ អ្នកប្រព្រឹត្តធម៌បែបនេះឈ្មោះថា មិនញុំាងប្រយោជន៍របស់ខ្លួនឲ្យបាន

លូតលាស់ជាសាធារណៈទូទៅ ឲ្យដល់មនុស្សជាតិគ្រប់គ្នាទេ។ ជនខ្លះទៀត ប្រព្រឹត្តតាមធម៌ពិតៗ ទាំងប្រាថ្នាឲ្យកើតប្រយោជន៍ដល់មនុស្សជាតិគ្រប់ប្រាណ បានស្បើយចាកទុក្ខបំភ្លឺភ្នែកមនុស្សក្នុងលោក ឲ្យស្គាល់គុណទោស ខុស ត្រូវ បុណ្យ បាប ប្រេត នរក ហើយនឹងសេចក្តីចម្រើន និងមិនចម្រើន តែងចួបប្រទះឃើញផលានិសង្ស ដែលកើតមកអំពីការប្រព្រឹត្តស្មោះត្រង់ ចំពោះធម៌ដែលដែលពិតប្រាកដនោះ ឬក៏បានបង្ហាញពន្យល់គ្នីគ្នាឲ្យចេះដឹង យល់ចូលចិត្ត ស្តាប់បានថា ការប្រពឹត្តបែបនេះ បែបនោះ ជាគុណ ជាទោស មិនស្ទាក់ស្ទើរគំនិតក្នុងការអនុវត្តទៅតាមធម៌ពិតប្រាកដនោះឡើយ ទាំងដឹងច្បាស់ថា អាត្មាប្រព្រឹត្តតាមធម៌នេះ ឈ្មោះថាប្រព្រឹត្តធម៌ត្រូវ បើគុណជាតិ ឬរសអ្វីមួយ ដែលកើតពីការប្រព្រឹត្តតាមធម៌ពិត ហើយឲ្យសុខជាកម្រៃ លែងកើត ចាស់ ឈឺ ស្លាប់ រកទីបំផុតទុក្ខចប់ចុង ដើម្បីឃើញពុំខានឡើយ លុះទ្រង់មិនទញ់ព្រះទ័យដូច្នេះហើយ ក៏លាតាបសទាំងពីររូបឆ្ពោះទៅឧរុវេលប្រទេស ខំព្យាយាមប្រព្រឹត្តតាមធម៌អស់៦វស្សា ត្រាតែបានត្រាស់ជាអរហំសម្មាសម្ពុទ្ធប្រាកដឡើងក្នុងលោក ដោយបុណ្យបារមីធម៌ ដែលព្រះអង្គបានសន្សំទុកដោយល្អ រមែងនាំមកប្រគល់ឲ្យចំពោះព្រះអង្គឥតមានល្អៀង ថែមទាំងព្រះអង្គផ្សាយធម៌វិន័យទុកឲ្យយើងប្រតិបត្តិតាមធម៌ពិតនោះ ជាប្រយោជន៍ផ្លូវលោក និងផ្លូវធម៌រាល់គ្នាទៀត។

ហេតុដូច្នេះ ក្នុងឋានៈជាមនុស្សជាតិទាំងឡាយ គួរប្រព្រឹត្តធម៌ឲ្យប្រពៃ ជាផ្លូវមជ្ឈិមាបដិបទា គឺអដ្ឋង្គិកមគ្គ ផ្លូវមានអង្គ៨ ជាដំរាយដែលបណ្ឌិតទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើមធ្លាប់បានប្រព្រឹត្តតាមជាផ្លូវញ៉ាំមារ និងសេនារបស់មារ ឲ្យវង្វេងភ័ន្តភាំង។

ដូចមានពុទ្ធភាសិតបញ្ជាក់យ៉ាងដូច្នោះថា៖

"អ្នករាល់គ្នា ត្រូវដើរទៅតាមផ្លូវមានអង្គ៨នោះចុះ ជាផ្លូវដែលញ៉ាំងមារ និងសេនារបស់មារឲ្យវង្វេង ព្រោះថា បើអ្នករាល់គ្នាដើរតាមផ្លូវហ្នឹងហើយ និងធ្វើនូវព្រះនិព្វានជាទីបំផុតទុក្ខបាន"។

បណ្តាផ្លូវដែលពួកមនុស្សសត្វដើរទៅមកដោយជើងឬយានជំនិះសព្វថ្ងៃ បើទុកជាផ្លូវនោះល្អស្រួល ក៏គង់មានឧបស័គ្គអន្តរាយទាំងឡាយមានចោរ បន្លា គ្រួសជាដើមក៏មាន ឯផ្លូវដែលព្រះបរមសាស្តា ទ្រង់ត្រាស់បង្ហាញដល់មនុស្សលោកទាំងឡាយ ធ្វើដំណើរទៅនោះ ហៅថា មជ្ឈិមាបដិបទា ផ្លូវប្រតិបត្តិយ៉ាងកណ្តាល មិនតឹងពេក មិនធូរពេក មិនលើពេក មិនក្រោមពេក ដូចជាខ្សែដូរ្យតន្ត្រីដែលគេរឹតឲ្យល្មម មានសូរស័ព្ទសំឡេងពីរោះ មុខគួរឲ្យចាប់ចិត្តដល់អ្នកស្តាប់ មិនមែនដូចផ្លូវធម្មតានោះទេ មជ្ឈិមាបដិបទា ដំណើរផ្លូវនៃសេចក្តីប្រតិបត្តិយ៉ាងធម្យមនោះ អាចញ៉ាំងមនុស្ស ទេព្តាក្នុងត្រៃភពឲ្យភ្លឺភ្នែកយល់ច្បាស់ប្រាសចាកអវិជ្ជាសេចក្តីងងឹតល្ងង់ខ្លៅបាន ផ្លូវដែលប្រកបដោយអង្គ៨នោះគឺ៖

**២.១.៥.១. សម្មាទិដ្ឋិ (ការយល់ត្រូវ ការយល់ចំ)**

សម្មាទិដ្ឋិ សេចក្តីយល់ត្រូវ ចែកចេញជាពីរប្រការគឺ ប្រការទី១ គឺយល់ត្រូវក្នុងផ្លូវលោក ប្រការទី២ យល់ត្រូវក្នុងផ្លូវធម៌។ ឯការយល់ត្រូវក្នុងផ្លូវលោកនោះគឺ ការយល់ថា កើតមកជាពលរដ្ឋក្នុងប្រទេសនីមួយៗ ត្រូវគោរពកោតខ្លាចច្បាប់សម្រាប់ប្រទេស ឬសម្រាប់ផែនដី យល់ថាគួរតែស្រឡាញ់គ្នា ព្រួតកម្លាំងគ្នាកសាង

ប្រទេសជាតិឲ្យថ្កុំថ្កើងរុងរឿង យល់ថា គួរតែដឹកនាំចម្លងជាតិដូចគ្នាឲ្យចេះដឹង នឹងយល់ឃើញថា ត្រូវគោរព សាសនា មហាក្សត្រ ជាប្រមុខរបស់ជាតិឲ្យពេញទី។ យល់ថាត្រូវថា ឪពុកម្តាយមានគុណ សេចក្តីព្យាយាម មានផល ធ្វើសេចក្តីល្អ ពិតជានឹងទទួលបានសេចក្តីល្អ ធ្វើទង្វើអាក្រក់ពិតជានឹងទទួលបានផលអាក្រក់ ស្រប តាមទង្វើរបស់ខ្លួន ដាំបណ្តុះពូជយ៉ាងណា នឹងទទួលបានផ្លែផ្កាជាពូជនោះ។ ការយល់ឃើញយ៉ាងនេះ ហៅ ថាយល់ឃើញត្រូវក្នុងផ្លូវលោក គួរប្រជាជាតិទាំងឡាយ សន្សំការយល់ឃើញបែបនេះ ឲ្យកើតមានក្នុងសន្តាន ឲ្យបានគ្រប់គ្នាឡើង។

ឯការយល់ត្រូវក្នុងផ្លូវធម៌នោះ គឺការយល់ឃើញថា មនុស្សសត្វទាំងឡាយដែលកើតមកក្នុងសង្សារ វដ្តនេះ តែងមានជរា ព្យាធិ និងសេចក្តីស្លាប់ទៅវិញជាធម្មតា និងជីវិតរបស់មនុស្សសត្វទាំងឡាយដែលមាន វត្តមាននៅក្នុងលោកនេះ តែងតែមានសេចក្តីមិនទៀងជាប្រក្រតី សេចក្តីទុក្ខជាប្រក្រតី និងសភាពមិនែមជា របស់ខ្លួនជាប្រក្រតី កាលដែលស្លាប់ទៅមានតែបុណ្យបាបទេ ដែលជាប់ទៅជាមួយនឹងខ្លួន ដូច្នេះអាត្មាអញ មិនត្រូវប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្តឡើយ។

បើយើងនិយាយឲ្យជ្រាលជ្រៅជាងនេះគឺ ប្រាជ្ញាយល់ឃើញត្រូវ ប្រាជ្ញាដឹងក្នុងអរិយសច្ចៈទាំង៤គឺៈ

១. ទុក្ខ ធម្មជាតិដែលនាំឲ្យលំបាកព្រួយមានជាតិ ជរា ព្យាធិ និងមរណៈជាដើម។

២. ទុក្ខសមុទយ ហេតុបណ្តាលឲ្យកើតទុក្ខបានដល់តណ្ហា

៣. ទុក្ខនិរោធ ព្រះនិព្វានរំលត់តណ្ហា អវិជ្ជា និងឧបាទានដោយសមុច្ឆេទ

៤. ទុក្ខនិរោធគាមនីបដិបទា មគ្គមគ៌ានាំឲ្យទៅកាន់ទីរំលត់ទុក្ខ

**២.១.៥.២. សម្មាសង្កប្បៈ (ការត្រិះរិះត្រូវ ត្រិះរិះតែរឿងដែលល្អ)**

សេចក្តីត្រិះរិះត្រូវ បានដល់ការត្រិះរិះត្រូវមាន៣យ៉ាងគឺៈ

សេចក្តីត្រិះរិះក្នុងការចេញចាកកាម

សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ

សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន

**២.១.៥.៣. សម្មាវាចា (ការពោលពាក្យពេចន៍ត្រូវ និយាយតែរឿងដែលមានខ្លឹមសារ)**

សម្មាវាចា ពាក្យសំដីត្រូវត្រឹម គឺពាក្យសំដីនិយាយត្រឹមត្រូវតាមច្បាប់ មិននិយាយផ្តេសផ្តាស ដែលរក គោលចារឹកគ្មាននោះទេមួយវិញទៀងសំដីដែលត្រូវនិយាយទៅរកមនុស្សជាតិដូចគ្នាត្រូវតែពោលជាសុភាសិត វាចាពាក្យជាសុភាសិត មិនត្រូវពោលពាក្យជាទុព្ភាសិតវាចាពាក្យទុព្ភាសិតឡើយ ព្រោះទុព្ភាសិតវាចា មិនហុច ផលប្រយោជន៍ដល់អ្នកស្តាប់ ឬឲ្យបានចម្រើនជាតិថ្លៃថ្នូរទេ សុភាសិតវាចា ទើបបានចម្រើនដល់អ្នកស្តាប់ បានរស់រានមានជីវិតដល់ទៅដល់អនាគត ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជាក់យ៉ាងដូច្នេះថា សច្ចំ វេ អមតា វាចា ពាក្យពិតជាពាក្យមិនចេះស្លាប់។

ដូច្នេះក្នុងឋានៈជាមនុស្សជាតិដែលមានសម្បទាគ្រប់គ្រាន់ជាមនុស្សជាតិគួរតែពេញចិត្តនាំគ្នានិយាយតែពាក្យណា ដែលមានប្រយោជន៍ក្នុងផ្លូវធម៌ និងផ្លូវលោកដើម្បីជាប្រយោជន៍ដល់មនុស្សជាតិដូចគ្នា គឺត្រូវនិយាយឲ្យចម្រើនដល់សីលធម៌ ដល់សុជីវធម៌ ដល់សាមគ្គី ដល់យុត្តិធម៌ ដល់សុចរិតធម៌ និងវឌ្ឍនធម៌ក្នុងប្រទេសជាតិរបស់ខ្លួនតទៅ។

សម្មាវាចា សំដីត្រូវត្រង់ បានដល់វៀរចាក់នូវសំដីអាក្រក់៤យ៉ាងគឺ

១. វៀរចាកកិរិយាពោលកុហក

២. វៀរចាកកិរិយាពោលនូវសំដីញុះញង់

៣. វៀរចាក់ការពោលពាក្យសំដីទ្រគោះបោះបោក

៤. វៀរចាកកិរិយាពោលនូវពាក្យសំដីដែលមិនជាប្រយោជន៍ ពាក្យឥតបានការ

**២.១.៥.៤. សម្មាកម្មន្ត (ការងារត្រូវ ការងារមិនមានទោស ការងារសុចរិត)**

ការងារត្រូវគឺបានដល់កិរិយាវៀរនៅអំពើដែលមិនត្រូវបីប្រការគឺៈ

១. វៀរចាកកិរិយាបំបាត់ប្រាណសត្វ

២. វៀរចាកនូវការកាន់យករបស់ដែលគេមិនបានឲ្យ

៣. ការវៀរចាកការប្រព្រឹត្តក្នុងកាមទាំងឡាយ (ប្តីប្រពន្ធជាដើមរបស់អ្នកដទៃ)

**២.១.៥.៥. សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ ប្រកបមុខរបរសុចរិត មុខរបរស្របច្បាប់)**

ការចិញ្ចឹមជីវិតត្រូវសម្រាប់គ្រហស្ថ បានដល់ការវៀរចាកជំនួញខុស កិរិយាលះបង់បំបាត់ដោយជញ្ជីងជាដើម ការធ្វើជាសាក្សីកោង ការល្មោភសំណូក ហើយប្រកបអាជីវកម្ម ដោយវណិជ្ជកម្ម ដែលនាំឲ្យសេដ្ឋជាតិកិច្ចជាតិចម្រើន ដោយវិជ្ជាជីវៈដ៏យុត្តិធម៌ ដោយកសិកម្ម ជាឧត្តមកម្ម និងគោរក្ខកម្ម។ សម្រាប់បព្វជិត បានដល់ការលះបង់មិច្ឆាជីវៈដោយអានេសន បាបធម៌ មានទូតកម្ម វេជ្ជកម្មជាដើម ការត្រាចទៅកាន់អគោចរដ្ឋាន ហើយចិញ្ចឹមជីវិតដោយភិក្ខាចរិយាធម៌ដ៏ស្មើ ឬបច្ច័យដែលកើតឡើងតាមធម៌។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានលើកឡើងអំពីដំណើររឿងរបស់ព្រះអង្គយ៉ាងដូច្នេះថាៈ

ម្នាលភិក្ខុទាំងឡាយ កាលតថាគត (អាស្រ័យ) នូវជាតិពីមុន ភពពីមុន កើតជាមនុស្សក្នុងកាលពីមុន បានលះបង់នូវមិច្ឆាជីវៈ (ការចិញ្ចឹមជីវិតខុស) ចិញ្ចឹមជីវិតដោយសម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ជាអ្នកបានវៀរចាកការបញ្ឆោតបន្លំដោយជញ្ជីងបញ្ឆោតដោយមាសបញ្ឆោតដោយរង្វាស់រង្វាល់បង្អុសបំភាន់ បញ្ឆោតបោកប្រាសនឹងបន្លំ ដោយរបស់ប្លម វៀរចាកកិរិយាកាត់នូវអវយវៈ មានដៃ ជើងជាដើម សម្លាប់ ចង ធ្វើមនុស្សឲ្យវង្វេងផ្លូវ ប្លន់ កំហែងយកទ្រព្យ។ តថាគតនោះ ព្រោះបានធ្វើ សន្សំ កសាងកុសលកម្មនោះ លុះបែកធ្លាយរាងកាយបន្ទាប់ពីសេចក្តីស្លាប់ ក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក[11]។

[11] សុត្តន្តបិដក ភាគ១៩ ទំព័រ៦១

**២.១.៥.៦. សម្មាវាយាមៈ (ការព្យាយាមត្រូវ ព្យាយាមដែលនាំនៅប្រយោជន៍ឧត្តម)**

ព្យាយាមត្រូវបានដល់សម្បធាន៤ គឺការបង្កើតឆន្ទៈព្យាយាម ប្រារព្ធវិរិយៈ តាំងបធានផ្គងចិត្ត

ព្យាយាមដើម្បីមិនឲ្យអកុសលធម៌លាមកដែលមិនទាន់កើតឡើង កុំឲ្យកើតឡើងបាន។

ព្យាយាមលះបង់បាប់អកុសលដែលកើតឡើងហើយ ឲ្យរលាយសាបសូន្យទៅវិញ

ព្យាយាមដើមញុំាងកុសលដែលមិនទាន់កើតឡើង បណ្តុះឲ្យកើតឡើងក្នុងសន្តាន

ព្យាយាមការពារកុសលដែលបានកើតឡើងហើយ ឲ្យតាំងនៅរីកចម្រើន មាននិរន្តរភាព

**២.១.៥.៧. សម្មាសតិ (ការតម្កល់ស្មារតីត្រូវ មានស្មារតីភ្ញាក់រឭកគ្រប់ដង្ហើមចេញចូល)**

ការរឭកត្រូវ បានដល់សតិប្បដ្ឋាន៤គឺះ

កិរិយាតម្កល់សតិខ្ជាប់ខ្ជួនពិចារណារឿងក្នុងកាយ

កិរិយាតម្កល់សតិខ្ជាប់ខ្ជួនពិចារណារឿយៗក្នុងវេទនា

កិរិយាតម្កល់សតិខ្ជាប់ខ្ជួនពិចារណារឿយៗក្នុងចិត្ត

កិរិយាតម្កល់សតិខ្ជាប់ខ្ជួនពិចារណារឿយៗក្នុងធម៌

**២.១.៥.៨. សម្មាសមាធិ (ការតម្កល់ចិត្តត្រូវ តម្កល់ចិត្តឲ្យត្រូវចំពោះរឿងដែលត្រូវធ្វើ)**

សម្មាសមាធិ ការតាំងចិត្តខ្ជាប់ខ្ជួនត្រូវនោះ គឺយើងគួរតាំងចិត្តឲ្យមាំមួន គោរពធម៌ ស្រឡាញ់ធម៌ ខំបណ្តុះធម៌ ជាពាក្យប្រៀនប្រដៅទាំងផ្លូវធម៌ និងផ្លូវលោកឲ្យពិតប្រាកដ ពុំគួរធ្វើចិត្តឲ្យឃ្លេងឃ្លោង ឃ្លាតចាកការតាំងចិត្តត្រូវនោះឡើយ ព្រោះការតាំងចិត្តត្រូវជាគុណនាំមកនូវប្រយោជន៍សេចក្តីសុខ ចម្រើនក្នុងផ្លូវលោក និងផ្លូវធម៌ដោយពិត[12]។

សម្មាទិដ្ឋិ សម្មាសង្កប្បៈ សង្គ្រោះចូលក្នុងបញ្ញាសិក្ខា សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សង្គ្រោះចូលក្នុងសីលសិក្ខា សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សង្គ្រោះចូលទៅក្នុងចិត្តសិក្ខា[13]។

## ២.១.៦. បារមី១០

និយមន័យពាក្យថា បារមី

និយមន័យ «**បារមី**» គឺជាពាក្យបាលីមកពីពាក្យ «**បារ**» មានន័យថា ត្រើយម្ខាង ឬត្រើយខាងនាយ និងពាក្យ «**មី**» មានន័យថា គុណជាតិដ៏ប្រសើរដែលគួរបំពេញ ឬផ្លូវដ៏ខ្ពង់ខ្ពស់ដែលគួរដើរ ដូចក្នុងគម្ពីរនេមក្ខារដីកា ខែថា គុណជាតិដែលនាំឲ្យដល់ត្រើយនៃព្រះនិព្វាន ឬញុំាងសត្វឲ្យបានដល់ត្រើយនៃព្រះនិព្វាន ឈ្មោះថា «**បារមី**» (និយមតាមស័ព្ទពាក្យថា «**បារមី**» មកពីពាក្យ «**បរម**» + «**ណ្យ**» = «**បារមី**»)។

ដូច្នេះ «**បារមី**» មានន័យថា គុណជាតិដ៏ប្រសើរដែលបុគ្គលត្រូវបំពេញ ឬជាគ្រឿងសម្រាប់ញុំាងសត្វឲ្យដល់ត្រើយបរមសុខគឺ ព្រះនិព្វាន។ តាមពាក្យសាមញ្ញ ការសាងបារមីគឺការអប់រំខ្លួនឲ្យបានបរិសុទ្ធទាំងផ្លូវ **កាយ**

[12] កម្ពុជាសុរិយា ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ ពុទ្ធសាសនបណ្ឌិត្យ ភាគ ២៧/២ គ.ស១៩៥៥ ទំព័រ៤៨៤

[13] កម្ពុជសុរិយា ភាគ៥៧ ២០០៣ គ.ស ទំព័រ២៩

**វាចា ចិត្ត សតិ** និង **បញ្ញា** ដើម្បីធ្វើខ្លួនឲ្យមានគុណធម៌យ៉ាងល្អប្រសើរប្រចាំជីវិត។

**និយមន័យពាក្យថា ព្រះពោធិសត្វ ឬពោធិសត្ត**

«**ព្រះពោធិសត្វ**» គឺជាបុគ្គលម្នាក់ដែលតាំងចិត្តប្រាថ្នាឲ្យបានត្រាស់ដឹងជា ព្រះពុទ្ធ ដោយការខិតខំព្យាយាមសាងបុណ្យបារមីយ៉ាងស្វិតស្វាញជាទីបំផុត។ ពាក្យថា «**ពោធិសត្វ**» សំដៅយកបុគ្គល និងមហាសត្វទាំងឡាយដែលប្រកបដោយចិត្តបុណ្យដ៏ទូលំទូលាយ ព្រមទាំងមានបញ្ញាដ៏ជ្រាលជ្រៅ។ «**ពោធិ**» ជាពាក្យបាលីមានន័យថា បញ្ញាជាគ្រឿងត្រាស់ដឹង។ «**សត្ត**» ពាក្យបាលី ឬ «**សត្វ**» ពាក្យសំស្ក្រឹត មានន័យថា បុគ្គលដែលជាប់ជំពាក់ក្នុងអារម្មណ៍ ឬបំណងណាមួយ។ ដូច្នេះពាក្យថា «**ពោធិសត្វ**» មានន័យថា «បុគ្គលដែលមានចិត្តជាប់ជំពាក់ក្នុងការត្រាស់ដឹង ឬជាបុគ្គលដែលសាងចិត្តដើម្បីត្រាស់ដឹង»។

**ក្នុងន័យនេះ គម្ពីរមហាវគ្គដីកា ទីឃនិកាយ សម្តែងថា៖**

បញ្ញាណាចាក់ធ្លុះនូវធម៌ដែលគួរដឹងតាមសភាពពិត ហេតុនោះឈ្មោះថា «**ពោធិ**»។ បុគ្គលនោះឯងឈ្មោះថា «**ពោធិសត្វ**» ព្រោះជាអ្នកអនុគ្រោះនូវសត្វ។ ហេតុនោះ ទើបលោកហៅថា បណ្ឌិតសត្វ ពុជ្ឈនកសត្វ គឺជាអ្នកប្រកបដោយ «**ពោធិចិត្ត**»។

**តើបុគ្គលបែបណាទើបអាចសាងខ្លួនជាពោធិសត្វបាន?**

មនុស្ស សត្វ បុរស ស្ត្រីទូទៅក្នុងលោកសុទ្ធតែជាអ្នកមានភ័ព្វវាសនាសាងខ្លួនជាពោធិសត្វបាន ដោយការកសាង ពុទ្ធការកធម៌ ធម៌ធ្វើឲ្យបានត្រាស់ជាព្រះពុទ្ធ ស្ត្រីក៏អាចប្រាថ្នាជាព្រះពោធិសត្វបានដែរ ប៉ុន្តែនិយតពោធិសត្វត្រូវស្ថិតនៅក្នុងភាពជាបុរស ហើយអាចចាក់ធ្លុះសព្វញ្ញុតញ្ញាណជាព្រះពុទ្ធ នាអនាគតកាលបានឲ្យតែបុគ្គលនោះមានឆន្ទៈ បំណង ឬការប៉ងប្រាថ្នា យ៉ាងមុតមាំក្នុងគោលដៅជីវិត។ ជនណាក៏ដោយក៏អាចប្រាថ្នា និងសាងខ្លួនជាពោធិសត្វបានដូចគ្នា ព្រោះមនុស្សម្នាក់ៗដែលកើតមកតែងតែមានសភាវៈពីរនៅក្នុងខ្លួន គឺសភាវៈល្អ និងសភាវៈអាក្រក់ សភាវៈល្អនេះហើយដែលមានពូជធម្មជាតិរបស់ព្រះពុទ្ធ ហើយអាចរីកដុះដាលឲ្យមានបំណងដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធ។ ក្នុងចំណុចនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា ៖

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ

ការស្តាប់ធម៌របស់សប្បុរស បានដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ។

ទោះបីមនុស្ស សត្វ បានជួបប្រទះនូវការក្រទាំងបួនប្រការនេះក្តី ក៏ការបានចាប់កំណើតជាមនុស្សចាត់ទុកជាភ័ព្វវាសនាដ៏ខ្ពង់ខ្ពស់ណាស់ ព្រោះភពនៃមនុស្សយើងនេះជាកន្លែងនៃព្រះពុទ្ធគ្រប់ៗព្រះអង្គបានឧប្បត្តិឡើងដើម្បីសាងបារមីឆ្ពោះទៅកាន់ «**ពុទ្ធភូមិ**»។

ព្រះពោធិសត្វអាចមានច្រើនអង្គ នៅក្នុងរយៈពេលជាមួយគ្នា តែកម្រិតនៃការសាងបារមីខុសៗគ្នា។ ដូច្នេះហើយបានជាពោធិសត្វទាំងអស់នោះ ពុំអាចត្រាស់ជាព្រះពុទ្ធក្នុងពេលជំណាលគ្នាឡើយ។ ព្រះពោធិសត្វគ្រប់ៗជាតិ តែងតែមានឆន្ទៈយ៉ាងមាំមួនក្នុងពោធិចិត្ត គឺចិត្តដែលជាប់ជំពាក់ក្នុងការត្រាស់ដឹង (មានបំណងត្រាស់ដឹងជាព្រះពុទ្ធ) និងតែងតែអនុវត្តយ៉ាងហ្មត់ចត់ជាទីបំផុតគ្រប់ៗជាតិនូវសីលធម៌ និងក្រឹត្យវិន័យប្រចាំជីវិតដែលហៅថា «**ពុទ្ធការកធម៌**» ឬ ហៅថា «**បារមីធម៌**»។

និយមន័យ «**បារមី**» គឺជាពាក្យបាលីមកពីពាក្យ «**បារ**» មានន័យថា ត្រើយម្ខាង ឬត្រើយខាងនាយ និងពាក្យ «**មី**» មានន័យថា គុណជាតិដ៏ប្រសើរដែលគួរបំពេញ ឬផ្លូវដ៏ខ្ពង់ខ្ពស់ដែលគួរដើរ ដូចក្នុងគម្ពីរ

នមក្ការដើកាខែថា គុណជាតិដែលនាំឲ្យដល់ត្រើយនៃព្រះនិព្វាន ឬញុំាងសត្វឲ្យបានដល់ត្រើយនៃព្រះនិព្វាន ឈ្មោះថា «**បារមី**» (និយមតាមស័ព្ទពាក្យថា «**បារមី**» មកពីពាក្យ «**បរម**» + «**ណ្យ**» = «**បារមី**»)។ ដូច្នេះ «**បារមី**» មានន័យថា គុណជាតិដ៏ប្រសើរដែលបុគ្គលត្រូវបំពេញ ឬជាគ្រឿងសម្រាប់ញុំាងសត្វឲ្យដល់ត្រើយបរមសុខគឺ ព្រះនិព្វាន។ តាមពាក្យសាមញ្ញ ការសាងបារមីគឺការអប់រំខ្លួនឲ្យបានបរិសុទ្ធទាំងផ្លូវ **កាយ វាចា ចិត្ត សតិ** និង **បញ្ញា** ដើម្បីធ្វើខ្លួនឲ្យមានគុណធម៌យ៉ាងល្អប្រសើរប្រចាំជីវិត។

**តើចាប់ពីពេលណាទៅដែលបុគ្គលអាចសន្មតខ្លួនថាជាព្រះពោធិសត្វបាន ?**

គេអាចចាត់ទុកមនុស្សម្នាក់ ឬសត្វនាមួយជាព្រះពោធិសត្វបានគឺនៅពេលដែលសតិរបស់មនុស្សនោះ ឬសត្វនោះឈានទៅដល់កម្រិតមួយដ៏ខ្ពស់ដែលពុំអាចដកទឹកចិត្តចេញ ពីឆន្ទៈពោធិចិត្តបាន គឺសេចក្តីប្រាថ្នាតែមួយក្នុងបំណងត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។

ការសាងខ្លួនជាព្រះពោធិសត្វត្រូវឆ្លងកាត់បីដំណាក់កាលដ៏សំខាន់ៗដូចតទៅ ៖

**ដំណាក់កាលទី១** បុគ្គលចិញ្ចឹមចិត្តឲ្យក្លាយជាពោធិចិត្តហើយ តែនៅពុំអាចហ្វឹកហ្វឺនចិត្តឲ្យជាព្រះពោធិសត្វបាន ហាក់ដូចជាបុគ្គលម្នាក់ព្យាយាមយកគ្រាប់ពូជល្វមកផ្សាំក្នុងសួន តែពុំទាន់បានដុះជាដើមល្វ បុគ្គលនោះនៅតែខំព្យាយាមបន្តកប់គ្រាប់ល្វនៅក្នុងសួននោះទៀត (អាចប្រៀបបាននឹងរយៈពេលដែលព្រះពោធិសត្វតាំងមនោបណិធាន)។

**ដំណាក់កាលទី២** ក្រោយពីការតាំង ចិត្តបានជាច្រើនម៉ឺនសែនជាតិហើយ សតិរបស់បុគ្គលនោះចាប់ផ្តើមប្រារព្ធចិត្តជាព្រះពោធិសត្វ ហើយចិត្តរបស់បុគ្គលនោះតែងតែរិះគិតជានិច្ចចង់ត្រាស់ជាព្រះពុទ្ធ រហូតដល់មានកម្រិតខ្ពស់បំផុត ដោយដកចិត្តចេញវិញ លែងបានដូចដើមល្វមានពន្លកដុះចេញជាដើម ទង ស្លឹក ទន់ខ្ចី (អាចប្រៀបបាននឹងរយៈពេលដែលព្រះពោធិសត្វតាំងវចីបណិធាន)។

**ដំណាក់កាលទី៣** លុះបានប្រារព្ធចិត្តជាព្រះពោធិសត្វច្រើនកប្បហើយ បុគ្គលក៏ធ្វើសច្ចាប្រណិធានដោយប្តេជ្ញាចំពោះព្រះភ័ក្ត្រនៃព្រះសម្មាសម្ពុទ្ធថា ៖

ដោយអំណាចបុញ្ញកម្ម ដែលខ្ញុំព្រះអង្គបានបំពេញមានប្រមាណប៉ុណ្ណោះ សូមឲ្យខ្ញុំព្រះអង្គបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគតកាល។

ដំណាក់កាលទី៣នេះ ហាក់ដូចជាដើមល្វរឹងមាំជារុក្ខជាតិ តែពុំទាន់មានផ្លែផ្កា (អាចប្រៀបបាននឹងរយៈពេលដែលព្រះពោធិសត្វបំពេញបារមីបន្តរហូតបានត្រាស់បន្ទាប់ពីបានទទួលការព្យាករពីព្រះសម្មាសម្ពុទ្ធរួចហើយ)។

កាលណាព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករណ៍ បុគ្គលណាមួយថា នឹងបានត្រាស់ជាព្រះពុទ្ធ ពេលនោះហើយបុគ្គលនោះមានឈ្មោះថា«**និយតពោធិសត្វ**»(បុគ្គលទៀងនឹងបានត្រាស់ជាព្រះពុទ្ធ)។និយតពោធិសត្វគ្រប់ៗជាតិតែងតែធ្វើសច្ចាប្រណិធានដើម្បីនឹងបានត្រាស់ ជាព្រះពុទ្ធដោយព្យាយាមបំពេញពុទ្ធការកធម៌គឺ «**ទសបារមី**»។

ព្រះពោធិសត្វ គ្រប់ព្រះអង្គ បន្ទាប់ពីបានទទួលព្យាករណ៍ពីព្រះសម្មាសម្ពុទ្ធអង្គណាមួយរួចហើយ ក្នុងលក្ខណៈជានិយតពោធិសត្វត្រូវបំពេញនូវ**ទសបារមី** (បារមី១០) ដែលជាពុទ្ធការកធម៌បន្តទៅទៀត រហូតដល់បានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ដូចមានគាថាថា ៖

នោះមានដូចតទៅ ៖ ទានបារមី សីលបារមី នេក្ខម្មបារមី បញ្ញាបារមី វិរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី ឧបេក្ខាបារមី។

**២.១.៦.១. ទានបារមី**

**(ការលះបង់ទ្រព្យសម្បត្តិជួយអ្នកដទៃ គឺជាគុណជាតិដ៏ឧត្តម)**

«**ទាន**» មានន័យថា «ទេយ្យវត្ថុដែលបុគ្គលគប្បីឲ្យ» ការធ្វើទាន គឺជាការចែករំលែកនូវភោគសម្បត្តិ វិជ្ជាសម្បត្តិ កម្លាំងកាយ កម្លាំងចិត្ត ឬពេលវេលាសម្រាប់ជួយសម្រាលការស្រេកឃ្លាន និងរំដោះទុក្ខភ័យរបស់អ្នកដទៃ។ ពោលដោយសង្ខេប ការធ្វើទានជាមធ្យោបាយមួយដ៏ប្រសើរ ក្នុងការពត់ចិត្តឲ្យចេះ ស្រលាញ់ អាណិត និងគិតពីសុខទុក្ខអ្នកដទៃ។ ជាទូទៅ ទានបារមីដែលព្រះពោធិសត្វបានបំពេញមក គួរកត់សម្គាល់ថាមានលក្ខណៈខុសៗគ្នា៤យ៉ាងដូចខាងក្រោម ៖

ការផ្តល់សម្ភារៈផ្សេងៗ ដើម្បីសម្រាល ឬរំដោះទុក្ខអ្នកដទៃ ទាន មានចំណីអាហារ ប្រដាប់ប្រដាប្រើប្រាស់ និងទ្រព្យសម្បត្តិនានាជាដើម ហៅថា «**សង្គហទាន**»។

ទាន ដែលពុទ្ធវិស័ទ តែងតែប្រគេនចំពោះព្រះសង្ឃ និងអ្នកមានគុណធម៌ខ្ពស់ ឬទានដែលព្រះពោធិសត្វ លោកថ្វាយ ប្រគេនព្រះសម្មាសម្ពុទ្ធ ឬតាបស មានភោជនីយាហារ ផ្កាភ្ញី ស្បង់ ចីវរ សេនាសនៈជាដើម លោកហៅថា «បូជាទាន» គឺទានដែលប្រព្រឹត្តទៅដោយក្តីគោរព ជាមួយចិត្តបរិសុទ្ធផូរផង់។ **បូជាទាន** មានកម្រិត និងអានិសង្សខ្ពស់ជាងសង្គហទាន។

ការអនុគ្រោះ មិនខឹងគុំកួនតបតនឹងអ្នកប្រព្រឹត្តកំហុសលើយើង និងការលើកលែងទោស ឬផ្តល់សេរីភាពដល់មនុស្ស ឬសត្វដែលពុំមានសេរីភាព ឧទាហរណ៍ ការដោះលែងអ្នកទោស ឈ្លើយសង្គ្រាម ទាសករ អ្នកជំពាក់បំណុល និងលើកលែងទោសកំហុសរបស់សត្រូវជាដើម លោកហៅថា «**អភយទាន**»។ ព្រះពោធិសត្វ ឬអ្នកដឹកនាំមានព្រះរាជាជាដើម តែងអនុវត្តនូវអភយទាននេះ។ យើងទាំងអស់គ្នាក៏អាចប្រព្រឹត្តនូវធម៌អភយទាននេះក្នុងជីវិត ប្រចាំថ្ងៃរបស់យើងបានដែរ។

ការអប់រំណែនាំអ្នកដទៃឲ្យចេះប្រកបវិជ្ជាជីវៈ ដោយសម្មាអាជីវោ (វិជ្ជាជីវៈត្រឹមត្រូវ) ដើរតាមគន្លងសុចរិតធម៌ដោយការសម្តែងធម៌ទេសនា បង្រៀនសីលធម៌ សុវជីវធម៌ផ្សេងៗ ជាពន្លឺចង្អុលបង្ហាញផ្លូវទៅរកសុភមង្គលក្នុងកុសលធម៌ លោកហៅថា «**ធម្មទាន**» ធម្មទាននេះជាទានដ៏ប្រសើរលើសទាននានាក្នុងលោក ដែលព្រះពោធិសត្វបានបំពេញ។

**ការឲ្យវត្ថុ១០យ៉ាង**

ការអធិប្បាយនៃទានដោយព្រះមហាភិក្ខុនារទៈដែលសំអាងលើអដ្ឋកថានៃគម្ពីរចរិយាបិដក បរិយាយថា ព្រះពោធិសត្វលោកតែងឲ្យវត្ថុ១០ប្រការគឺ ៖

**១. អន្នទាន** គឺឲ្យបាយ ឬភោជនាហារដល់ស្មូមទាំងឡាយដោយសេចក្តីត្រិះរិះរបស់ព្រះអង្គថា អាត្មាអញនឹងញុំាងសម្បត្តិ៥យ៉ាង គឺអាយុវែង១ ពណ៌សម្បុរល្អចាំនៅ១ សេចក្តីសុខកាយសប្បាយចិត្ត១ កម្លាំងកាយ១ប្រាជ្ញាស្មារតី១ និងសម្បត្តិដ៏ប្រសើរគឺលោកុត្តរផលដែលបុគ្គលគប្បីត្រេកអរឲ្យសម្រេចដល់សត្វលោកទាំងពួង ដោយផលនៃទានដែលអាត្មាអញបានឲ្យនេះ។

២. **បានទាន** គឺឲ្យទឹកក្តៅ ឬទឹកត្រជាក់ដល់អ្នកសូមទាំងឡាយដើម្បីបំបាត់នូវសេចក្តីឃ្លាន គឺកាមកិលេសនៃសត្វទាំងឡាយ។

៣. **វត្ថុទាន** គឺឲ្យសំពត់សម្រាប់ស្លៀកដណ្តប់ដល់យាចកទាំងឡាយដើម្បីរក្សានូវពណ៌ សម្បុរឲ្យល្អដូចជាពណ៌នៃមាសផង ដើម្បីអភិបាលនូវសេចក្តីខ្មាសបាប និងសេចក្តីតក់ស្លុតចំពោះបាប និងគ្រឿងប្រដាប់សម្រាប់ស្លៀកពាក់នៃសត្វទាំងឡាយផង។

៤. **យានទាន** គឺឲ្យគ្រឿងជិះគ្រឿងសែង ឬឲ្យស្ពានដល់បដិគ្គាហកៈទាំងឡាយដើម្បីសម្រេចនូវឥទ្ធិឫទ្ធិផង ដើម្បីសម្រួលឲ្យបាននូវសេចក្តីសុខក្នុងព្រះនិព្វានផង។

៥. **គន្ធទាន** គឺឲ្យគ្រឿងក្រអូបជាទានដើម្បីសម្រេចកេរ្តិ៍ឈ្មោះក្រអូបអំពីសីលគុណ។

៦. **មាលាវិលេបនទាន** គឺឲ្យផ្កាកម្រង និងគ្រឿងងូត គ្រឿងលុបលាបផ្សេងៗជាទាន ដើម្បីសម្រេចនូវសុន្ទរាសីនៃព្រះពុទ្ធគុណ ។

៧. **អាសនទាន** គឺឲ្យស្ពានសម្រាប់អង្គុយជាទាន ដើម្បីសម្រេចនូវពោធិមណ្ឌលាសនៈ គឺញាណដ៏ផូរផង់ជាទីត្រាស់ដឹង ឈ្មោះថា «**ពោធិ**»។

៨. **សេយ្យទាន** គឺឲ្យនូវទីស្ពានសម្រាប់ដេកជាទាន ដើម្បីសម្រេចសម្រាន្តនូវទីស្ពានក្រឡាព្រះបន្ទំឈ្មោះថា «**តថាគតសេយ្យាសនៈ**»។

៩. **អាវាសថទាន** គឺឲ្យលំនៅជាទាន ដើម្បីសម្រេចនូវតេជានុភាពនៃខ្លួនព្រះអង្គឲ្យបានជាទីពឹងទីជ្រកនៃសត្វលោក។

១០. **បទីបេយ្យទាន** គឺ ឲ្យនូវគ្រឿងសម្រាប់បំភ្លឺមានពន្លឺគោម និងពន្លឺចង្កៀងជាដើមជាទាន ដើម្បីសម្រេចនូវចក្ខុ៥យ៉ាងមានទិព្វចក្ខុជាដើម។

យោងតាមគម្ពីរអដ្ឋសាលិនីអដ្ឋកថាធម្មសង្គណីព្រះពោធិសត្វបានប្រព្រឹត្តនូវទាន៦ប្រការទៀតគឺ

១. **រូបទាន** ជាការបូជានូវវត្ថុដែលមានពណ៌ទាំងឡាយ មានកម្រងផ្កា និងសំពត់ដែលមានពណ៌ល្អជាដើម ដល់ព្រះពុទ្ធរតនៈដើម្បីឲ្យបានសម្រេចឆព្វណ្ណរង្សី។

២. **សទ្ទទាន** ឲ្យសំឡេងជាទាន គឺការបូជាតូរ្យតន្ត្រីដល់ព្រះរតនត្រ័យ និងប្រគេនប្រេង និងទឹកអំពៅជាថ្នាំធ្វើឲ្យមានសំឡេងពីរោះចំពោះធម្មកថិកទាំងឡាយ និងឃោសនាឲ្យគេមកប្រជុំស្តាប់ធម៌ និងសម្តែងធម៌ទេសនាឲ្យអ្នកទាំងពួងស្តាប់ជាដើម ដើម្បីឲ្យមានសំឡេងពីរោះក្បោះក្បាយ ដូចជាសំឡេងមហាព្រហ្ម។

៣. **គន្ធទាន** ឲ្យក្លិនជាទាន គឺបូជានូវគ្រឿងក្រអូប មានឫសក្រអូបជាដើម ដែលជាទីគាប់ចិត្តដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដើម្បីឲ្យបានសម្រេចនូវសីលាទិគុណ។

៤. **រសទាន** ឲ្យរសជាទាន គឺបូជានូវវត្ថុដែលមានរសឆ្ងាញ់ មានរសមើម និងផ្កាជាដើមដល់ពុទ្ធាទិវត្ថុដើម្បីឲ្យបានសម្រេចនូវគុណវិសេស គ្រាន់ជាទីស្នេហាស្រលាញ់ដល់សត្តនិករក្នុងត្រៃភព។

៥. **ផោដ្ឋព្វទាន** ឲ្យនូវវត្ថុ ផ្សព្វផ្សាយនូវកាយជាទាន គឺបូជានូវទិសេនសនៈទាំងឡាយ មានគ្រែជាដើម ដល់ព្រះរតនត្រ័យដើម្បីសេចក្តីសុខក្សេមក្សាន្តជាសព្វញ្ញុពុទ្ធ។

៦. **ភេសជ្ជទាន** ឲ្យនូវថ្នាំរម្ងាប់រោគជាទាន គឺបូជានូវវត្ថុ៣មុខគឺ សប្បិ និងនវនីត១ ទឹកអង្គបាន១ ភត្ត ១៤ប្រការ១ ដល់ព្រះរតនៈទាំង៣ដើម្បីឃាត់នូវជាតិ ជរា ព្យាធិ មរណៈ ទុក្ខ មិនឲ្យកើតមានដល់ព្រះអង្គឡើយ។

ម្យ៉ាងទៀត ព្រះពោធិសត្វព្រះអង្គតែងឲ្យនូវទានឯទៀត១០ប្រការគឺ ៖

១. **ទាសានំកុជ្ជិស្សទាន** គឺកិរិយាលះបង់នូវបាវព្រាវ ខ្ញុំកំដរឲ្យរួចជាអ្នកជា នេះជាទានដើម្បីដោះស្រាយនូវព្រះអង្គមិនឲ្យជាខ្ញុំនៃកិលេស តណ្ហា។

២. **អនវជ្ជខិឌ្ឌារតីហេតុទាន** គឺឲ្យនូវវត្ថុសម្រាប់លេង ដែលមិនមានទោសទៅជាទាន ដើម្បីសេចក្តីត្រេកអរចំពោះព្រះសទ្ធម្មរបស់ព្រះអង្គ។

៣. **បុត្តទាន** គឺឲ្យនូវកូនប្រុសស្រីទៅជាទានដល់ជនទាំងឡាយដើម្បីកិរិយានាំចូល ទៅជិតកាន់ភាវៈនៃកូននោះ ជាកូននៃព្រះអង្គក្នុងជាតិជាអរិយបុគ្គល។

៤. **ទារទាន** គឺឲ្យនូវប្រពន្ធជាទានដល់ជនទាំងឡាយ ដើម្បីកិរិយាបាននូវភាវៈនៃព្រះអង្គជាម្ចាស់នៃសត្វលោកទាំងពួង។

៥. **រជ្ជទាន** គឺឲ្យនូវរាជសម្បត្តិជាទាន ដើម្បីបាននូវភាវៈនៃព្រះអង្គជាស្តេច ព្រោះព្រះអង្គត្រាស់ដឹងនូវធម៌។

៦. **ហត្ថទាន** គឺឲ្យនូវព្រះហស្តជាទាន ដើម្បីឲ្យមានព្រះសទ្ធម្មក្នុងព្រះហស្ត ជាប្រយោជន៍ដល់សត្វទាំងឡាយ និងបានរើខ្លួនចេញចាកអន្លង់ទាំង៤ មានបញ្ចពិធកាមគុណជាដើម។ អន្លង់ទាំង៤គឺ៖**កាមោឃៈ** អន្លង់គឺកាម១ **ភវោឃៈ** អន្លង់គឺភព១ **ទិដ្ឋោឃៈ** អន្លង់គឺទិដ្ឋិ១ **អវិជ្ជោឃៈ** អន្លង់គឺអវិជ្ជា១។

៧. **កណ្ណនាសាទិទាន** គឺ ឲ្យនូវចំណែករាងកាយ មានត្រចៀក និងច្រមុះជាដើមទៅជាទាន ដើម្បីបានចំពោះនូវឥន្ទ្រិយជាកុសលមានសទ្ធិន្ទ្រិយជាដើម។

៨. **ចក្ខុទាន** គឺ ឲ្យនូវព្រះនេត្រទៅជាទាន ដើម្បីបានចំពោះនូវសមន្តចក្ខុ។ ព្រះបរមពោធិសត្វព្រះអង្គតែងស្វែងរកនូវប្រយោជន៍ និងសេចក្តីសុខឲ្យដល់សត្វទាំងឡាយគ្រប់កាលទាំងពួង។ ម្យ៉ាងទៀត សត្វលោកទាំងឡាយ គប្បីចូលទៅជិត រស់នៅក្នុងកិច្ចទាំងឡាយដ៏ឧត្តមមានកិរិយាឃើញ និងឮ និងរលឹករឿយៗ និងធ្វើការបម្រើជាដើម ចំពោះព្រះអង្គ ។

៩. **មំសលោហិតទាន** គឺកិរិយាឲ្យនូវសាច់ និងឈាមទៅជាទានព្រោះព្រះអង្គមានបំណងថា សូមឲ្យអាត្មាមានសរីរៈរាងកាយបរិបូណ៌។

១០. **ឧត្តមង្គទាន** គឺកិរិយាបូជានូវអង្គដ៏ឧត្តម គឺព្រះសិសៈរបស់ព្រះអង្គទៅជាទាន ព្រោះព្រះអង្គគិតថា សូមឲ្យអាត្មាអញបានជាបុគ្គលឧត្តមខ្ពង់ខ្ពស់ជាងសត្វលោកទាំងពួង ដូចការបំពេញទានរបស់ព្រះពោធិសត្វអរិយមេត្តេយ្យ មានលក្ខណៈសំខាន់មួយគឺ កាត់សីសៈបូជាព្រះពុទ្ធសិរីមត្តៈ មិនមានបំណងចង់បានការដឹងគុណ ឬផលប្រយោជន៍ពីបដិគ្គាហកៈ ក្នុងលោកនេះឡើយ។ (អ្នកទទួលទាន)

ការបំពេញទានរបស់ព្រះពោធិសត្វមានពុទ្ធភូមិជាអារម្មណ៍ គឺព្រះទ័យជាប់ជំពាក់ក្នុងសព្វញ្ញុតញ្ញាណពោលគឺការបានសម្រេចជាព្រះសម្មាសម្ពុទ្ធ។ ទានបារមីរបស់ព្រះពោធិសត្វ មានលក្ខណៈលះបង់ខ្ពស់ដែលមនុស្សធម្មតាមិនអាចធ្វើឲ្យដូចបាន លុះត្រាបុគ្គលខំព្យាយាមបំពេញទានបន្តិចម្តងៗ ចាប់ពីវត្ថុតូចតាចឡើងទៅ។ ការធ្វើទាននេះ ព្រះពោធិសត្វមានព្រះទ័យក្លាហាន មិនញាប់ញ័រ ភិតភ័យ តក់ស្លុត ឬស្តាយក្រោយឡើយ។

ក្នុងការរក្សាទានបារមីនេះ ព្រះពោធិសត្វហ៊ានលះបង់ជាទាននូវអ្វីៗទាំងអស់ ដោយប្រកាន់ជំហរ៣កម្រិតដូចខាងក្រោម ៖

**កម្រិតទី១ ទានបារមី:** ព្រះពោធិសត្វពុំរារែកក្នុងការលះបង់នូវទ្រព្យសម្បត្តិ គ្រឿងប្រើប្រាស់របស់ព្រះអង្គធ្វើជាទានលុះអស់រលីង ហាក់ដូចជាទឹកដែលហូរចេញអស់ពីក្អមដែលផ្កាប់យ៉ាងណាមិញ ការលះបង់របស់ព្រះពោធិសត្វមានរួមទាំងភរិយា និងបុត្រជាទានផងដែរ ទាននេះឈ្មោះថា «**ទានបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរគឺព្រះនិព្វាន»។

**កម្រិតទី២ ទានឧបបារមី:** ក្នុងការធ្វើទាន ព្រះពោធិសត្វប្រព្រឹត្តនូវកិរិយាលះបង់អវយវៈ មានអង្គតូចអង្គធំរបស់ព្រះអង្គជាទាន ទាននេះឈ្មោះថា «**ទានឧបបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»។

**កម្រិតទី៣ ទានបរមត្ថបារមី:** សូម្បីការលះបង់ដល់ជីវិតរបស់ព្រះអង្គក្តី ព្រះអង្គហ៊ានបរិច្ចាគជិវិតព្រះអង្គផ្ទាល់ធ្វើជាទាន។ ទាននេះហៅថា «**ទានបរមត្ថបារមី**» ដែលជា «គុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។

សរុបមក ការធ្វើទានរបស់ព្រះពោធិសត្វ ទាំងអាមិសទានក្តី ធម្មទានក្តី មានលក្ខណៈខុសពីមនុស្សយើងធម្មតា ព្រោះការធ្វើទានរបស់ព្រះអង្គ មាននូវសព្វញ្ញុតញ្ញាណជាអារម្មណ៍ គឺដើម្បីបានចាក់ធ្លុះត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។ ក្នុងការសាងទានបារមីនេះ ព្រះពោធិសត្វតែសច្ចាប្រណិធានថា «គ្រប់អនាគតជាតិតទៅ អាត្មាអញសូមឲ្យមានចិត្តល្អជានិច្ច ហើយធ្វើខ្លួនឲ្យបានជាប្រយោជន៍ដល់សត្វលោកទូទៅ !»។

### ២.១.៦.២. សីលបារមី

(**ការវៀរចាកនូវអំពើអាក្រក់ទាំងឡាយ គឺជាគុណជាតិដ៏ឧត្តម**)

«**សីល**» មានន័យថា «កិរិយាប្រព្រឹត្តនៅជាប្រក្រតី ឬសេចក្តីរក្សាកាយ វាចា ចិត្តឲ្យល្អ» ព្រះពោធិសត្វបំពេញនូវបារមីទី២ គឺសីលដែលជាទីតាំងនៃកុសលធម៌ទាំងឡាយមាន សីល៥ សីល៨ សីល១០ ឬអធិសីលតាមកម្រិតដែលអាចរក្សាបាន។ បុគ្គលអាចសាងសីលបារមីក្នុងឋានៈជាឧបាសកក្តី ឧបាសិកាក្តី តែសីលដែលមានកម្រិត ខ្ពស់ជាងគេ គឺការរក្សាសីលក្នុងភេទផ្នួស «ការរក្សាសីល គឺជាវិធីបង្ហាត់ចិត្តឲ្យបានបរិសុទ្ធបន្តិចម្តងៗ» ជាពិសេសនិច្ចសីល (សីល៥) ជាវិន័យដ៏សំខាន់បំផុតសម្រាប់ត្រួតនគរទាំងបីរបស់យើងគឺ កាយ វាចា និងចិត្ត ឲ្យប្រព្រឹត្តទៅក្នុងកុសលកម្ម។

ការរក្សាសីលរបស់ព្រះពោធិសត្វតាមការកត់សម្គាល់មានលក្ខណៈពិសេស ដូចខាងក្រោម ៖

«***រក្សាសីល***» គឺដើម្បីជៀសវាងអំពើអកុសលកម្មដែលមិនមែនជាគុណធម៌។ អ្នករក្សាសីលត្រូវសច្ចាចំពោះព្រះពុទ្ធបដិមា ព្រះសង្ឃ ឬអាចារ្យថានឹងលះបង់នូវបាបកម្មដែលមានចែងក្នុងសិក្ខាបទទាំងឡាយ ហើយឧទ្ទិសខ្លួនថ្វាយចំពោះព្រះរតនត្រ័យជានិច្ច ហើយហ្វឹកហាត់ព្យាយាមបំពេញក្នុងកុសលទាំងឡាយមាន សមាធិ ភាវនា និងវិបស្សនា ជាដើម។ ក្នុងន័យនេះ ការរក្សាសីលគឺជាការហ្វឹកហាត់ ត្រួតចិត្តដើម្បីឲ្យមានសេចក្តីស្ងប់។

«***រក្សាសីល***» គឺដើម្បីជាប្រយោជន៍ដល់សត្វលោកទូទៅ។ ការរក្សាសីលនេះ មានកម្រិតខ្ពស់ជាងគេដោយអធិដ្ឋានចិត្តជួយដោះទុក្ខអ្នកដទៃ មានការណែនាំគេឲ្យរក្សាសីលជាដើម ហើយត្រូវផ្សាយមេត្តាករុណាធម៌ចំពោះសព្វសត្វលោកដែលរងទុក្ខជាទូទៅ។

«***រក្សាសីល***» ឲ្យបានហ្មត់ចត់ស្អាត មិនឲ្យដាច់វិនាសទៅបាន ប្រកបដោយចតុប្បារិសុទ្ធិសីល ឬសីល

៨ សីល៥ ឲ្យបានបរិបូណ៌ប្រពៃមានសទ្ធា សតិ វិរិយៈ និងបញ្ញា ជាគ្រឹះមូលដ្ឋាន។

ការរក្សាសីលនេះ ព្រះពោធិសត្វតែងតែប្រព្រឹត្ត និងរក្សាសីលដោយប្រកាន់ជំហរពាកម្រិតដូចគឺ

**កម្រិតទី១ សីលបារមីៈ** ព្រះពោធិសត្វពុំរារែកក្នុងការប្រព្រឹត្តនូវការរក្សាសីល ទោះបីត្រូវលះបង់នូវរាជសម្បត្តិក្ដី ទ្រព្យសម្បត្តិក្ដី ឬលះបង់នូវភរិយា និងបុត្រយ៉ាងណាក្ដី គឺព្រះអង្គមិនធ្វើឲ្យបាត់បង់នូវសីលរបស់ព្រះអង្គឡើយ។ សីលនេះឈ្មោះថា «**សីលបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»។

**កម្រិតទី២ សីលឧបបារមីៈ** ក្នុងការកសាង និងរក្សាសីល ព្រះពោធិសត្វហ៊ានលះបង់នូវអវយវៈ អង្គតូច អង្គធំរបស់ព្រះអង្គយ៉ាងណា គឺព្រះអង្គមិនធ្វើឲ្យបាត់បង់នូវសីលរបស់ព្រះអង្គឡើយ។ សីលនេះឈ្មោះថា **សីលឧបបារមី** ដែលជា គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន។

**កម្រិតទី៣ សីលបរមត្ថបារមីៈ** សូម្បីការលះបង់ដល់ជីវិតរបស់ព្រះអង្គ ព្រះអង្គហ៊ានបរិច្ចាគជិវិតព្រះអង្គផ្ទាល់ ដើម្បីរក្សា និងកសាងនូវសីលបារមីរបស់ព្រះអង្គយ៉ាងខ្ជាប់ខ្ជួន ដោយការតាំងចិត្តប្ដូរផ្ដាច់ ការពារសីលគឺព្រះអង្គមិនធ្វើឲ្យបាត់បង់នូវសីលរបស់ព្រះអង្គ ឡើយ។ សីលនេះឈ្មោះថា «**សីលបរមត្ថបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។

### ២.១.៦.៣. នេក្ខម្មបារមី

### (ការចាកចេញពីផ្ទះទៅបួស គឺជាគុណជាតិដ៏ឧត្ដម)

«**នេក្ខម្មបារមី**» គឺការចេញសាងផ្នួស មានន័យថា «កិរិយាចេញទៅដើម្បីគុណធំ ឬថាបព្វជ្ជា គឺផ្នួស ឬកិរិយាចេញសាងផ្នួស» ។

ព្រះពោធិសត្វ តែងហ្វឹកហ្វឺនចិត្តព្រះអង្គក្នុងការលះបង់នូវទ្រព្យសម្បត្តិ យសស័ក្តិ គ្រួសារ និងកាមគុណ គឺការត្រេកត្រអាលក្នុងវត្ថុកាមដែលជាគ្រឿងជាប់ជំពាក់ក្នុងលោក ។ ការលះបង់នូវវត្ថុកាម និងកិលេសកាម ជាការលះបង់ដ៏ប្រសើរបំផុត ដើម្បីឈានទៅសម្រេចនូវពុទ្ធភូមិ ។ ព្រះពោធិសត្វបានលះបង់គ្រឿងជាប់ជំពាក់ទាំងនេះច្រើនអសង្ខេយ្យជាតិ ដោយការចេញសាងបព្វជ្ជា ជាតាបស ឬជាភិក្ខុសាមណេរ ក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌នេះ ជាតិខ្លះព្រះពោធិសត្វក៏សម្រេចដល់ទៅ ឈាន អភិញ្ញា សមាបត្តិក៏មានដូចជារឿងតេមិយកុមារចេញសាងបព្វជ្ជាជាដើម ។

ព្រះពោធិសត្វ តែងប្រព្រឹត្តព្រហ្មចរិយធម៌យ៉ាងហ្មត់ចត់ប្រកាន់ជំហរពាកម្រិតដូចខាងក្រោមគឺ

**កម្រិតទី១ នេក្ខម្មបារមីៈ** ព្រះពោធិសត្វ តែងប្រព្រឹត្តនូវនេក្ខម្មបារមី ដោយព្រះអង្គមានការលះបង់នូវរាជសម្បត្តិ ទ្រព្យសម្បត្តិ យសសក្តិ គ្រួសារ និងកាមគុណ គឺការត្រេកត្រអាលក្នុងវត្ថុកាមដែលជាគ្រឿងជាប់ជំពាក់ក្នុងលោក ដោយការចេញសាងបព្វជ្ជា ជាតាបស ឬជាភិក្ខុ សាមណេរជាដើម។ នេក្ខម្មនេះឈ្មោះថា **នេក្ខម្មបារមី** ដែលជា គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន។

**កម្រិតទី២ នេក្ខម្មឧបបារមីៈ** ក្នុងការប្រតិបត្តិ និងរក្សាបារមី ព្រះពោធិសត្វហ៊ានលះបង់នូវអវយវៈ អង្គតូច អង្គធំរបស់ព្រះអង្គយ៉ាងណា គឺព្រះអង្គតាំងចិត្តមុតមាំ ដើម្បីរក្សានូវនេក្ខម្មៈរបស់ព្រះអង្គ។ នេក្ខម្មៈ

នេះឈ្មោះថា «**នេក្ខម្មឧបបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»។

**កម្រិតទី៣ នេក្ខម្មបរមត្ថបារមី:** សូម្បីការលះបង់ដល់ជីវិតរបស់ព្រះអង្គ ព្រះអង្គហ៊ានបរិច្ចាគជីវិតព្រះអង្គផ្ទាល់ ដើម្បីរក្សានូវការកសាងនេក្ខម្មៈរបស់ព្រះអង្គដោយការតាំងចិត្ត ប្តូរផ្តាច់ការពារព្រះផ្នួស គឺព្រះអង្គមិនធ្វើឲ្យបាត់បង់នូវនេក្ខម្មៈរបស់ព្រះអង្គឡើយ នេក្ខម្មៈនេះ ឈ្មោះថា «**នេក្ខម្មបរមត្ថបារមី**» ដែលជា «**នេក្ខម្មឧបបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។

ក្នុងការសាងនេក្ខម្មបារមីនេះ ព្រះពោធិសត្វតែងសច្ចាប្រណិធានថា «គ្រប់ អនាគតជាតិទៅ អាត្មាអញសូមកុំឲ្យជាអ្នកមានចិត្តអាត្មានិយម សូមឲ្យក្លាយជាអ្នកអាចលះបង់នូវការត្រេកត្រអាលសប្បាយផ្ទាល់ខ្លួន និងជាអ្នកសាងប្រយោជន៍ដល់សត្វលោកទូទៅ !»។

### ២.១.៦.៤. បញ្ញាបារមី

### (ការបាននូវប្រាជ្ញាស្មារតី គឺជាគុណជាតិដ៏ឧត្តម)

«**បញ្ញា**» មានន័យថា «ធម្មជាតិដឹងដោយបការៈ ឬសេចក្តីយល់ឃើញជាក់ច្បាស់» «**បញ្ញាបារមី**» គឺជាគុណធម៌ដែលដឹងច្បាស់នូវសេចក្តីពិតអាចកម្ចាត់នូវការល្ងិតល្ងង់ ការភ័ន្តច្រឡំ ឬការសង្ស័យ។ បុគ្គលណាដែលអាចត្រួតត្រា កាយ វាចា និងចិត្ត បានតាមវិន័យ សីលធម៌ទាំងបីដំពូកខាងលើ មានឈ្មោះថា ជាអ្នករក្សាសីល ឬជាអ្នកដែលប្រកបដោយសីលធម៌ប្រចាំជីវិត គឺជាអ្នកបំពេញសីលបារមី នេះគឺជាសេចក្តីសុខពិតដែលអ្នកប្រាជ្ញតែងនិយមស្វែងរកសម្រាប់ ប្រយោជន៍ខ្លួនឯងផង និងសម្រាប់សង្គមមនុស្សជាតិផង។ កាលបើបុគ្គលណាមួយមានសេចក្តីស្ងប់ក្នុងចិត្តហើយ បុគ្គលនោះអាចសាងបញ្ញាបារមីបាន។

ប្រភពនៃការបណ្តុះបញ្ញាមានបី ៖

១. បញ្ញាអាចកើតឡើងបានដោយករព្យាយាមសិក្សារៀនសូត្រ ស្តាប់ពីសំណាក់បណ្ឌិតសប្បុរស។ បញ្ញានោះឈ្មោះថា «**សុតមយបញ្ញា**» គឺបញ្ញាកើតពីការស្តាប់ ការសិក្សារៀនសូត្រ។ បញ្ញាកើតឡើងបានដោយករខិតខំព្យាយាមសិក្សាក្បួនខ្នាត និងស្តាប់ឲ្យយល់ពីទស្សនៈ និងគតិបណ្ឌិតរបស់គ្រូអាចារ្យ ។

២. ការបានស្តាប់ហើយធ្វើទុកក្នុងចិត្តដោយត្រូវទំនងត្រិះរិះពិចារណា សព្វគ្រប់ក៏កើតមានបញ្ញាឡើង បញ្ញានេះឈ្មោះថា «**ចិន្តមយបញ្ញា**» គឺបញ្ញាកើតពីការត្រិះរិះពិចារណារកហេតុផល ។ បញ្ញាអាចធ្វើឲ្យបុគ្គលយល់ច្បាស់ក្នុងចិត្តនូវបញ្ហាអ្វីមួយដែល ត្រូវដោះស្រាយ។ បញ្ញាអាចញ៉ាំងបុគ្គលឲ្យយល់ត្រូវ គិតត្រូវ និងធ្វើត្រូវ ជាគតិប្រចាំជីវិត។

៣. បញ្ញាកើតពីករាហ្វឹកហាត់ចិត្តឲ្យស្ថិតនៅក្នុងអារម្មណ៍តែមួយ មិនឲ្យរវើរវាយ បញ្ញានេះឈ្មោះថា «**ភាវនាមយបញ្ញា**»។ បញ្ញាជាពន្លឺដែលនាំឲ្យបុគ្គលចេញចាកផុតពីផ្លូវវង្វេងក្នុង លោកិយនេះ។ បញ្ញាអាចកើនចម្រើនបានដោយបុគ្គលខំសន្សំកុសលដែលជាចំណែកនៃញាណ សម្បយុត្ត គឺធ្វើនូវកុសលប្រកបដោយបញ្ញាជារឿយៗ ទើបជាឧបនិស្ស័យនាំឲ្យបុគ្គលនោះកើតមកសម្បូរដោយបញ្ញា។

បុគ្គល អ្នកសាងបញ្ញា គឺជាការចម្រើននូវគតិបណ្ឌិតឲ្យបានប្រសើរ ដោយតែងតែយកបញ្ញានោះ មកជួយរំដោះទុក្ខវេទនារបស់សត្វលោកទាំងពួង។ បញ្ញាអាចប្រៀបបានទៅនឹងពន្លឺព្រះអាទិត្យ បើព្រះអាទិត្យរះឡើងកាលណា រស្មីនៃព្រះអាទិត្យនោះ តែងតែញ៉ាំងភាពខ្មៅងងឹតនៃរាត្រីឲ្យវិនាសអស់ពីលោកនេះទៅយ៉ាងណា បុគ្គលអ្នកមានបញ្ញាតែងតែបំភ្លឺ អប់រំ ណែនាំសត្វលោកគ្រប់គ្នាដែលកំពុងទទួលរងនូវភាពងងឹតគឺអវិជ្ជាដែលជាសត្រូវនៃបញ្ញា។ «**អវិជ្ជា**» គឺសេចក្តីល្ងង់ខ្លៅ ប្រៀបដូចជាភាពងងឹត រីឯ «**បញ្ញា**» ប្រៀបដូចជាពន្លឺ។

ការសាងបញ្ញាបារមី គឺជាការសាងពន្លឺដើម្បីបំបាត់អវិជ្ជា។ បុគ្គលត្រូវសន្សំបញ្ញាបន្តិចម្តងៗ គ្រប់ៗជាតិ ទើបសម្រេចដល់បញ្ញាដ៏កំពូលគឺ «**សព្វញ្ញុតញ្ញាណ**»។

ក្នុងការរក្សាបញ្ញាបារមីនេះ ព្រះពោធិសត្វតែងតែប្រព្រឹត្ត និងរក្សាបញ្ញាបារមីដោយប្រកាន់ជំហរ៣ កម្រិតដូចខាងក្រោមគឺ ៖

**កម្រិតទី១ បញ្ញាបារមីៈ** ក្នុងការសាងនូវបញ្ញា គឺព្រះពោធិសត្វតែងតែលះបង់នូវកម្លាំងកាយ កម្លាំងចិត្ត ខិតខំធ្វើការសិក្សាឈ្វេងយល់ពីគ្រប់ទីកន្លែង និងសាកសួរអ្នកប្រាជ្ញគ្រប់ជាតិ ដើម្បីទទួលបាននូវបញ្ញា ទោះបីត្រូវលះបង់នូវទ្រព្យសម្បត្តិ រាជសម្បត្តិ យសសក្តិ និងគ្រួសារដ៏ដោយ ព្រះអង្គខំធ្វើនូវប្រយោជន៍ធំ និងប្រយោជន៍តូចរបស់សត្វលោកទាំងឡាយឲ្យសម្រេច កិរិយានោះឯងហៅថា «**បញ្ញាបារមី**» ដែលជា «**នេក្ខម្មឧបបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»។

**កម្រិតទី២ បញ្ញាឧបបារមីៈ** ការសាងបញ្ញា និងការរក្សាបញ្ញារបស់ព្រះពោធិសត្វ ព្រះអង្គហ៊ានលះបង់នូវអវយវៈ អង្គតូច អង្គធំ យ៉ាងណា គឺព្រះអង្គតាំងចិត្តមុតមាំ ដើម្បីរក្សានូវបញ្ញា គឺមិនឲ្យលត់សាបសូន្យនូវបញ្ញារបស់ព្រះអង្គឡើយ។ ក្នុងការសាងបញ្ញាព្រះអង្គខំធ្វើនូវប្រយោជន៍ធំ និងប្រយោជន៍ឲ្យបានសម្រេចដល់សត្វលោកទាំងឡាយ។ ព្រះហឫទ័យយ៉ាងមុតមាំនេះឈ្មោះថា «**បញ្ញាឧបបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»។

**កម្រិតទី៣ បញ្ញាបរមត្ថបារមីៈ** សូម្បីការលះបង់ដល់ជីវិតរបស់ព្រះអង្គ ព្រះអង្គហ៊ានបរិច្ចាគជិវិតព្រះអង្គផ្ទាល់ ដើម្បីរក្សានូវការសាងបញ្ញារបស់ព្រះអង្គដោយព្រះអង្គខំប្រឹងប្រែង រហូតដល់ប្តូរជិវិត ដើម្បីបំពេញនូវកិច្ចដល់ជនទាំងឡាយឲ្យបានសម្រេច។ គឺព្រះអង្គមិនធ្វើឲ្យបាត់បង់នូវបញ្ញារបស់ព្រះអង្គឡើយ។ ព្រះហឫទ័យដ៏អង់អាចមុតមាំនេះហើយដែលមានឈ្មោះថា «**បញ្ញាបរមត្ថបារមី**» ដែលជា «**នេក្ខម្មឧបបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។

### ២.១.៦.៥. វិរិយបារមី

### (សេចក្តីព្យាយាមដោយល្អចំពោះការងារ គឺជាគុណជាតិដ៏ឧត្តម)

«***វិរិយៈ***» មានន័យថា «សេចក្តីតស៊ូព្យាយាម សេចក្តីប្រឹងប្រែង» ជាទូទៅវិរិយៈ មានន័យថា ការខំប្រឹងប្រែង ព្យាយាមតស៊ូដោយកម្លាំងកាយ (ជាធំ) ចិត្ត និងប្រាជ្ញា ដើម្បីឲ្យបានសម្រេចនូវគោលបំណងអ្វីមួយដែលយើងបានកំណត់ទុកជាមុន។ និស្សិតដែលបានខំព្យាយាមសិក្សាអស់ពីសមត្ថភាព ទោះបីជួបប្រទះការលំបាកគ្រប់បែបយ៉ាងក្តី ដើម្បីទទួលបានជោគជ័យក្នុងការសិក្សារបស់ខ្លួនជាដើម ជាឧទាហរណ៍ជាក់ស្តែងនៃការប្រតិបត្តិវិរិយធម៌ និស្សិតនោះត្រូវបានចាត់ទុកជាអ្នកបានបំពេញនូវវិរិយធម៌ដ៏ប្រសើរ ទើបសម្រេចបាននូវគោលបំណងចម្បងរបស់ខ្លួន។

ការប្រារព្ធវិរិយធម៌នេះ យើងអាចប្រៀបធៀបនឹងនារីដែលរចនាកម្រងផ្កា ដោយរៀបផ្កាមួយទងម្តងៗ ក៏អាចក្លាយជាកម្រងផ្កាដ៏ល្អប្រណីតបាន។ នេះក៏មិនខុសគ្នាពីនារីដែលត្បាញសំពត់សូត្រនាងតែងបញ្ចូលសូត្រ ក្នុងត្រល់មួយសរសៃម្តងៗ លុះក្លាយជាសំពត់សូត្រដ៏ល្អប្រណីត ចម្រុះដោយពណ៌ផ្សេងៗគ្នា។ សត្វចាបចៀបកប្បាសតែងតែយកស្មៅ ឬវល្លិតូចៗ មួយម្តងៗ សាងជាសម្បុកដ៏ល្អបាន។ រីឯបុព្វបុរសយើងក៏បានសាងប្រាសាទនគរវត្តដ៏ល្អខ្ពស់ស្កឹមស្កៃ ល្បីល្បាញលើលោក ដោយយកដុំថ្មមួយដុំម្តងៗ មកតម្កល់លើគ្នា ក្នុង

ការសាងសង់អស់ពេលដ៏យូររបស់សត្វស្វា។ ឧទាហរណ៍ទាំងនេះបញ្ជាក់អំពីការអនុវត្តនៃវិរិយធម៌ក្នុងជីវិតរបស់សត្វលោក

ចំពោះវិរិយបារមីជា គុណធម៌មួយដ៏ខ្ពស់ មានន័យទូលំទូលាយណាស់ ដែលព្រះពោធិសត្វ តែងប្រារព្ធព្យាយាមឲ្យបានសម្រេចនូវគោលបំណងក្នុងជីវិត ទោះបីមានឧបសគ្គដ៏ធំមហិមាមកជំទាស់យ៉ាងណាក្តី។ក្នុងការប្រតិបត្តិដើម្បីសាងវិរិយបារមីនេះព្រះពោធិសត្វគ្រប់រូប តែងប្រាថ្នាឲ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ដើម្បីឲ្យបានរួចផុតចាកទុក្ខក្នុងវដ្តសង្សារផង និងដើម្បីជួយចម្លងសត្វលោកទាំងពួង ឲ្យឆ្លងផុតចាកទុក្ខទៅកាន់ព្រះនិព្វានផង។

ដូច្នេះ ដើម្បីសាងវិរិយបារមី ព្រះពោធិសត្វពីជាតិមួយទៅជាតិមួយ លោកបានសាងកុសលធម៌ និងផុសខាត់សម្អាតកម្ទិលចេញពីព្រះអង្គអស់។ ព្រះអង្គមិនបណ្តោយឲ្យពេលវេលា និងអាយុរបស់ព្រះអង្គសោត់បាត់ទៅដោយគ្មានប្រយោជន៍ឡើយ។ លោកមិនបានបណ្តោយឲ្យខ្លួនលោកវង្វេង ដោយការធ្វេសប្រហែលដូចជាអ្នកដេកលក់ងប់ងល់នារាត្រីជ្រៅ ឬអ្នកវង្វេងលង់ខ្លួនក្នុងជ្រោះនៃក្តីសប្បាយ និងត្រេកត្រអាលដោយកាមគុណ ដែលជានីវរណធម៌ ជាធម៌រាំងពុំឲ្យបុគ្គលសម្រេចនូវទិសដៅក្នុងជីវិតឡើយ។

ក្នុងការរក្សាវិរិយបារមីនេះ ព្រះពោធិសត្វតែងសាងវិរិយបារមីដោយម៉ត់ចត់ គឺប្រកាន់ជំហរ៣កម្រិតដូចខាងក្រោមគឺ ៖

**កម្រិតទី១ វិរិយបារមីៈ** ទោះបីការសាងវិរិយបារមីត្រូវជួបឧបសគ្គដល់ការលះបង់ទ្រព្យសម្បត្តិ យសសក្តិ ឬប្រពន្ធកូនក្តី ព្រះអង្គគឺពុំលះបង់វិរិយបារមីប្រែប្រួលពីគោលដៅដែលលោកបានប្រកាន់ យកយ៉ាងមុតមាំនោះឡើយ។ វិរិយនេះមានឈ្មោះថា «**វិរិយបារមី**» ដែលជា «**នេក្ខម្មឧបបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»។

**កម្រិតទី២ វិរិយឧបបារមីៈ** ទោះបីព្រះពោធិសត្វត្រូវលះបង់នូវអង្គកាយ គឺអវយវៈអង្គតូច អង្គធំ មានដៃ និងជើងជាដើម ព្រះអង្គមិនស្តាយឡើយ ហើយព្យាយាមចម្រើនវិរិយធម៌ឲ្យបានសម្រេច នេះឈ្មោះថា «**វិរិយឧបារមី**» ដែលជា «**នេក្ខម្មឧបបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន» ព្រោះសេចក្តីព្យាយាម។

**កម្រិតទី៣ វិរិយបរមត្ថបារមីៈ** ព្រះពោធិសត្វ ព្យាយាមសាងវិរិយបារមី ដោយមិនព្រមលះបង់នូវការព្យាយាមរបស់ព្រះអង្គឡើយ ទោះបីព្រះអង្គត្រូវប្រឈមមុខចំពោះឧបសគ្គដែលមានគ្រោះថ្នាក់ដល់ ជីវិតក្តី ព្រះអង្គនៅតែតស៊ូយ៉ាងស្វិតស្វាញ ទាំងកម្លាំងកាយ (ជាធំ) កម្លាំងចិត្ត និងបញ្ញា ដោយមិនបោះបង់នូវទិសដៅដែលព្រះអង្គប្រាថ្នាទុកពីមុនមក។ នេះឈ្មោះថា «**វិរិយបរមត្ថបារមី**» ដែលជា «**នេក្ខម្មឧបបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»។

ក្នុងការសាងបន្តនូវវិរិយបារមីរាល់ៗជាតិ ព្រះពោធិសត្វរមែងធ្វើសច្ចាប្រណិធានចំពោះខ្លួនលោកថា «គ្រប់ អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាឲ្យមានកម្លាំងពលំខ្លាំងក្លា ហើយព្យាយាមតស៊ូយ៉ាងស្វិតស្វាញរហូតអាត្មាអញបានសម្រេចនូវគោលដៅ របស់អាត្មាអញ ! សូមឲ្យអាត្មាអញមានចិត្តអង់អាចជម្នះគ្រប់គ្រោះថ្នាក់ និងឧបសគ្គទាំងឡាយ ! សូមឲ្យអាត្មាអញមានលទ្ធភាពបម្រើសត្វលោកទាំងឡាយឲ្យអស់ពី សតម្កភាព»។

### ២.១.៦.៦. ខន្តិបារមី

(**សេចក្តីអំណត់អត់ធន់ដោយល្អ គឺជាគុណជាតិដ៏ឧត្តម**)

«**ខន្តិ**» គឺជាអំណត់អត់ធន់ ជាគុណធម៌ខាងផ្លូវចិត្តក្នុងការគាំទ្រទុក្ខវេទនាគ្រប់បែបយ៉ាង ដោយយកធម៌ជាគោលដើម្បីសាងបារមីឆ្ពោះទៅកាន់ពុទ្ធភូមិ។ ការខំសាងខន្តិបារមីនេះ អាចញ៉ាំងឲ្យបុគ្គលរំងាប់បាននូវការព្រួយបារម្ភ ការតូចចិត្ត និងអាចធ្វើឲ្យចិត្តបាននឹងធឹង ហើយរកសុខក្នុងឧទ័យបាន។ **ខន្តិ** ជាសភាវៈផ្ទុយពីទោសៈ គឺកំហឹង កំហឹងនេះជាប្រភពនៃអំពើសាហាវយង់ឃ្នងនៃការកាប់សម្លាប់ និងសង្គ្រាមនានា។ ការសាងខន្តិបារមីមានលក្ខណៈសំខាន់គួរឲ្យកត់សម្គាល់ដូចខាងក្រោម ៖

១. ខន្តិបារមី ដោយមិនប្រព្រឹត្តតបវិញនឹងអំពើអាក្រក់ដែលគេរំលោភបំពានលើ ព្រះពោធិសត្វ។

ព្រះពោធិសត្វតែងតែខំអត់សង្កត់ចិត្តនូវរាល់អំពើផ្តាំផ្តងទាំងឡាយ របស់មនុស្ស សត្វ ដោយចិត្តករុណាដ៏ធំ ទូលាយ។

២. កាយ វាចា ចិត្ត របស់ព្រះពោធិសត្វតែងតែប្រព្រឹត្តទៅដោយអាការៈមិនក្រោធ ខឹង ប្រទ្បោត ឆេវឆាវជាប្រក្រតី។

៣. ព្រះពោធិសត្វ តែងតែចាត់ទុកអ្នកដែលប្រព្រឹត្តអំពើផ្តាំផ្តងលើលោក ដូចជាអ្នកទាំងនោះ ជាបងប្អូនជាប់សាច់ឈាមជាមួយលោក ហើយលោកតែងតែអត់ឱន នូវសេចក្តីល្មើសរបស់អ្នកទាំងនោះ ដោយធម៌មេត្តាករុណារបស់លោក។

៤. ក្នុងការសាងខន្តិ បារមីនេះ ព្រះពោធិសត្វមិនខឹងតបរករឿងហេតុទប់ទល់ជាមួយអ្នកដែលប្រមាថមើល ងាយ ខឹងតិះដៀលព្រះអង្គដោយគ្មានកំហុស ឬដោយរំលោភក្តី។ នេះមិនមានន័យថា ព្រះពោធិសត្វមិនមានវាចាតបតនោះឡើយ គឺព្រះពោធិសត្វមានការនិយាយស្តីតបវិញ តែដោយពាក្យពីរោះ និងទឹកចិត្តមិនប្រកាន់ទោសនោះឯង។

ក្នុងការរក្សាខន្តិបារមីនេះ ព្រះពោធិសត្វហ៊ានលះបង់នូវអ្វីៗទាំងអស់ តែមិនឲ្យដាច់នូវសន្តិធម៌នេះឡើយ ដោយប្រកាន់ជំហរពាកម្រិតដូចខាងក្រោមគឺ ៖

**កម្រិតទី១ ខន្តិបារមីៈ** ព្រះពោធិសត្វមានខន្តីចំពោះគ្រប់សត្វដែលធ្វើការផ្តាំផ្តងលើ ព្រះអង្គ ដោយចង់បានទ្រព្យសម្បត្តិ ប្រពន្ធ កូនរបស់ព្រះអង្គក្តី ព្រះអង្គមិនមានចិត្តបៀតបៀន ឬខឹង ក្រោធចំពោះបុគ្គលទាំងនោះឡើយ គឺព្រះអង្គរក្សានូវ «**ខន្តិបារមី**» ដែលដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។

**កម្រិតទី២ ខន្តិឧបបារមីៈ** ទោះបី មានការបៀតបៀនពីសំណាក់បុគ្គល ឬសត្វដទៃដែលចង់បាន ឬធ្វើឲ្យបាត់បង់ និងខូចខាតដល់រាងកាយអវយវៈ អង្គតូច អង្គធំក្តី ព្រះអង្គមិនមានការខឹងក្រោធ ចំពោះសត្វលោកទាំងនោះឡើយ គឺព្រះអង្គរក្សានូវ «**ខន្តិឧបបារមី**» ដែលជា «គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។

**កម្រិតទី៣ ខន្តិបរមត្ថបារមីៈ**ទោះបី មានការបៀតបៀនពីបុគ្គលដទៃ សូម្បីដល់ជីវិតរបស់ព្រះអង្គក្តី ព្រះអង្គមិនមានការតក់ស្លុត និងការប្រទូស្តតបតវិញឡើយ គឺព្រះអង្គរក្សានូវ «**ខន្តិបរមត្ថបារមី**» ដែលជា « គុណជាតិសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។

ក្នុងការសាងនូវខន្តិបារមីរាល់ៗជាតិ ព្រះពោធិសត្វរមែងធ្វើសច្ចាប្រណិធានចំពោះខ្លួនលោកថា «គ្រប់អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាឲ្យបានជាអ្នកមានអំណត់អត់ធន់ជានិច្ច ! ហើយអាចអត់ទ្រាំចំពោះ

ពាក្យទ្រគោះបោះបោក និងកំហុសអ្នកទដៃដែលមានចំពោះអាត្មាអញ ! អាត្មាអញសូមឲ្យបានជាអ្នកដែលចេះអត់ឱនដល់សត្វលោកទាំងឡាយ ហើយយល់ឃើញនូវចំណុចដ៏ល្អៗរបស់សត្វលោកទាំងនោះ ជាជាងរកកំហុសរបស់គេ ដូចនៅក្នុងរឿងខន្តិវាទីតាបស ព្រះពោធិសត្វមិនបានខឹងតបត សូម្បីបន្តិចបន្តួចសោះ ចំពោះស្តេចកលាពុ ដែលបៀតបៀនព្រះអង្គឡើយ។

**២.១.៦.៧. សច្ចបារមី** (**ពាក្យពិតពាក្យត្រង់ គឺជាគុណជាតិដ៏ឧត្តម**)

«**សច្ច**» មានន័យថា «ការពិតប្រាកដ សេចក្តីទៀងត្រង់» **សច្ច** គឺជាកិរិយាប្រព្រឹត្តទៅក្នុងវាចា មិនព្រមពោលនូវពាក្យមិនពិត។ **សច្ចបារមី** ជាគុណជាតិ ឬធម៌ដ៏ប្រសើរមួយរបស់អរិយបុគ្គលដែលលោកតែងអនុវត្តក្នុងជីវិត ដើម្បីឲ្យបានត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ។ ការសាងសច្ចបារមីនេះ ព្រះពោធិសត្វលោកបានទទួលនូវគុណសម្បត្តិដ៏ខ្ពង់ខ្ពស់បំផុត គឺព្រះនិព្វាន។ បារមីនេះគឺសំដៅការប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវសច្ចធម៌ គឺរក្សាពាក្យពិតគ្រប់សកម្មភាពអ្វីៗទាំងអស់ក្នុងជីវិត ទោះបីព្រះពោធិសត្វត្រូវប្រឈមមុខចំពោះគ្រោះថ្នាក់ដ៏ធំដល់ជីវិត ក៏លោកពុំលះបង់នូវសច្ចធម៌ឡើយ។ ក្នុងការសាងសច្ចបារមីនេះ ក៏ដូចជាបារមីដទៃទៀតដែរ គឺព្រះពោធិសត្វព្រះអង្គប្រកាន់ខ្ជាប់នូវកិរិយា «មិនពោលនូវពាក្យខុសពីការពិត» ដោយលោកប្រកាន់ជំហរពាកម្រិតដូចខាងក្រោមគឺ ៖

**កម្រិតទី១ សច្ចបារមី** ព្រះពោធិសត្វព្រះអង្គស៊ូលះបង់នូវទ្រព្យសម្បត្តិ រាជសម្បត្តិ យសស័ក្តិគ្រប់បែបយ៉ាង រួមទាំងបុត្រ និងភរិយា ដើម្បីរក្សា «**សច្ចធម៌**» ដែលជា «គុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។

**កម្រិតទី២ សច្ចឧបារមី**ព្រះពោធិសត្វលោកស៊ូលះបង់អវយវៈ គឺអង្គតូច អង្គធំនៃរាងកាយរបស់ព្រះអង្គក្នុងការរក្សាសច្ចធម៌ដើម្បីសាង «**សច្ចឧបបារមី**» ដែលជា «គុណជាតិដ៏ប្រសើរសម្រាប់ដឹកនាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។

**កម្រិតទី៣ សច្ចបរមត្ថបារមី** ព្រះពោធិសត្វស៊ូលះបង់ជីវិតក្នុងការរក្សាសច្ចធម៌ដើម្បីសាង «**សច្ចបរមត្ថបារមី**» ដែលជា «គុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។ ក្នុងរឿង**ព្រះវិធូរបណ្ឌិត** ព្រះពោធិសត្វបានឲ្យដំបូន្មានព្រះរាជាថា ក្នុងព្រះឋានៈជាស្តេចផែនដី ព្រះអង្គត្រូវតែគោរពនូវសច្ចធម៌ ទោះបីព្រះអង្គត្រូវលះបង់រាជសម្បត្តិ នគរ ឬព្រះជន្មក៏ដោយ។

ក្នុងការកសាងបារមីនេះ ព្រះពោធិសត្វគ្រប់ៗជាតិតែងតែធ្វើសច្ចាប្រណិធានរបៀបនេះថា «គ្រប់ អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាឲ្យប្រកាន់ខ្ជាប់នូវពាក្យពិត ! ក្នុងកិរិយាប្រព្រឹត្តទៅនៃជីវិត អាត្មាអញសូមកុំឲ្យវៀចវេរពីការពិត ដើម្បីផ្តល់នូវសេចក្តីសុខដល់មនុស្សសត្វទូទៅ!

**២.១.៦.៨. អធិដ្ឋានបារមី**

(**ការតាំងចិត្តដ៏មុតមាំចំពោះការងារ គឺជាគុណជាតិដ៏ឧត្តម**)

«**អធិដ្ឋាន**» មានន័យថា «កិរិយាតាំងចិត្តទទួលកិច្ចដែលគួរគាប់កាន់យក»។ **អធិដ្ឋាន** គឺ ជាកិច្ចដែលសមាទានប្រកាន់យកយ៉ាងមុតមាំនូវគោលដៅអ្វីមួយ ហើយមិនរើរុះផ្លាស់ប្តូរ ប្រែប្រួល ដោយសារជួបប្រទះការលំបាក ឬឧបសគ្គណាមួយ។ ព្រះពោធិសត្វកាន់យកដោយឈ្លាសវៃនូវឧបាយនៃករុណាចិត្ត ហើយមានចិត្ត និងចេតសិកតែងប្រព្រឹត្តទៅតាមអាការៈនៃសេចក្តីអធិដ្ឋាននោះ។ អំពើនេះហៅថា ការសាង «**អធិដ្ឋាន**

**បារមី**» ដែលជា «គុណជាតិដ៏សម្រាប់ចម្លងសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន» ព្រោះសេចក្ដីតាំងចិត្តព្យាយាមមុតមាំ។ ដើម្បីរក្សាឲ្យបានគង់វង្សនូវអធិដ្ឋានបារមីនេះ ព្រះពោធិសត្វតែងប្រកាន់ខ្ជាប់នូវជំហរ៣កម្រិតដូចខាងក្រោម គឺ ៖

**កម្រិតទី១ អធិដ្ឋានបារមី** ទោះបីការតាំងចិត្ត អធិដ្ឋានបារមីនេះ ត្រូវជួបឧបសគ្គរហូតដល់ការលះបង់នូវទ្រព្យសម្បត្តិ កូន ប្រពន្ធក៏ដោយ ព្រះពោធិសត្វពុំរើរុះ ប្រែប្រួលពីគោលដៅដែលលោកបានប្រកាន់យកយ៉ាងមុតមាំនោះឡើយ ដោយព្រះអង្គរក្សានូវ «**អធិដ្ឋាន**» ដែលជា «គុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន» ព្រោះសេចក្តីតាំងចិត្តដ៏មាំនេះ។

**កម្រិតទី២ អធិដ្ឋានឧបបារមី** ទោះបីការតាំងចិត្តអធិដ្ឋានបារមីនេះ ជួបនូវការលំបាក ឬឧបសគ្គដែលព្រះពោធិសត្វត្រូវឆ្លងកាត់នោះ ដោយព្រះអង្គត្រូវលះបង់នូវអវយវៈ គឺអង្គតូច អង្គធំនៃរាងកាយរបស់ព្រះអង្គក៏ដោយក្ដី ដើម្បីប្រកាន់យកនូវធម៌ជាកុសលនោះ ព្រះអង្គមិនរើរុះពីសេចក្ដីសម្រេចចិត្តដ៏មុតមាំរបស់ព្រះអង្គឡើយ។ នេះហៅថា «**អធិដ្ឋានឧបបារមី**» ដែលជា «គុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន» ដោយសារការតាំងចិត្តដ៏មុតមាំនេះ។

**កម្រិតទី៣ អធិដ្ឋានបរមត្ថបារមី** ក្នុងការតាំងចិត្តដែលជាកិរិយា សមាទាននូវកុសលធម៌ (គោលបំណងសាងកុសលធម៌) ណាមួយហើយនោះ ព្រះពោធិសត្វមិនអាចរលាស់ចោលឡើយ ទោះបីព្រះអង្គត្រូវប្រឈមមុខនឹងការលះបង់ជីវិតផ្ទាល់របស់ខ្លួនក្ដី។ សេចក្ដីមិនកម្រើកដោយខ្លាចបាត់បង់ជីវិតនេះហើយហៅថា «**អធិដ្ឋានបរមត្ថបារមី**» ដែលជា «គុណជាតិដ៏ប្រសើរសម្រាប់នាំសត្វលោកទៅកាន់ត្រើយបរមសុខ គឺព្រះនិព្វាន»។ ក្នុងការសាងអធិដ្ឋានបារមីនេះ ព្រះពោធិសត្វត្រូវផ្អែកលើការព្យាយាមទាំងកម្លាំងកាយ និងកម្លាំងចិត្តជាមូលដ្ឋានចម្បង។ ព្រះពោធិសត្វតែងធ្វើសេចក្ដីសច្ចាប្រណិធានដូច្នេះថា «គ្រប់ អនាគតជាតិតទៅ អាត្មាអញសូមឲ្យចិត្តមុតមាំប្ដូរផ្ដាច់ក្នុងការសម្រេចបំណងកុសលធម៌ ! សូមឲ្យអាត្មាអញមានចិត្តរឹងមាំដូចដែកតែសភាវៈទន់ភ្លន់ដូចផ្កា និងជាអ្នកកាន់សីលធម៌ខ្ពស់ជានិច្ច !»។

### ២.១.៦.៩. មេត្តាបារមី

### (ការផ្ដល់ឲ្យនូវការរាប់អាន អាណិតអាសូរដោយចិត្តបរិសុទ្ធ ចំពោះសព្វសត្វទូទៅគឺជាគុណជាតិដ៏ឧត្ដម)

«**មេត្តាបារមី**» គឺជាមេត្តាមហាសាល ដោយផ្ដល់សេចក្ដីស្រឡាញ់ដល់សត្វទាំងអស់ដោយគ្មានព្រំដែន ដោយពុំរើសអើងពីជាតិសាសន៍ និងប្រភពកំណើតជាដើម។ មេត្តាធម៌ជាសេចក្ដីស្រឡាញ់បរិសុទ្ធ ផុសចេញពីបេះដូង ដោយមានសេចក្ដីប្រាថ្នាឲ្យសត្វលោកទូទៅមានសេចក្ដីសុខជានិច្ចនៅ ក្នុងជីវិត ។ ព្រះពោធិសត្វពុំដែលមានចិត្តព្យាបាទដល់អ្នកដទៃឡើយ ទោះបីជាសត្រូវរបស់ព្រះអង្គក៏ដោយ។ ក្នុងការសាងមេត្តាបារមីនេះ ព្រះពោធិសត្វតែងប្រកាន់យកបញ្ញាឈ្លាសវៀងវៃ ជាឧបាយដោយមានមេត្តាធម៌ ដ៏ជ្រាលជ្រៅចំពោះសត្វលោកជាមូលដ្ឋាន។ ការកសាងមេត្តាបារមីនេះមានបីកម្រិតដែរគឺ ៖

**កម្រិតទី១ មេត្តាបារមី** ទោះបី ព្រះពោធិសត្វត្រូវលះបង់ដល់បុត្រ និងភរិយាក៏ដោយក៏លោកនៅតែរក្សាឲ្យជាប់នូវមេត្តាធម៌ គឺកិរិយាមិនបានញុំាងការចម្រើន និងសេចក្ដីសុខរបស់សត្វទាំងឡាយឲ្យវិនាសដោយសារការបៀតបៀន ឬសម្លាប់កូន ប្រពន្ធរបស់ព្រះអង្គឡើយ។ សេចក្ដីមិនព្យាបាទតបតដល់អ្នកបៀត

បៀនព្រះអង្គនេះហើយឈ្មោះថា «**មេត្តាបារមី**» ដែលជា «គុណជាតិដែលធ្វើឲ្យសត្វលោកបានឆ្លងទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»។

**កម្រិតទី២ មេត្តាឧបបារមី** ទោះបីព្រះពោធិសត្វត្រូវលះបង់អវយវៈ គឺអង្គតូច អង្គធំនៃរាងកាយរបស់ព្រះអង្គ ដោយការបៀតបៀនរបស់អ្នកដទៃក៏ដោយ ព្រះអង្គមិនមានចិត្តចង់ព្យាបាទដល់អ្នកទាំងនោះឡើយ ។ ការមិនចងពៀរនេះហើយឲ្យឈ្មោះថា «**មេត្តាឧបបារមី**» ដែលជា «គុណជាតិដែលធ្វើឲ្យសត្វលោកបានឆ្លងទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»។

**កម្រិតទី៣ បរមត្ថមេត្តាបារមី** ទោះបី ព្រះពោធិសត្វត្រូវលះបង់ជីវិតរបស់ព្រះអង្គ ដោយការប្រមាថបៀតបៀនធ្វើបាបពីសំណាក់អ្នកដទៃក្តី ក៏ព្រះអង្គមិនប្រព្រឹត្តនូវអំពើតបត ឲ្យអ្នកនោះទទួលការវិនាសខាតបង់នូវប្រយោជន៍ឡើយ ។ ការមិនតបតចងពៀរព្យាបាទចំពោះជននោះវិញ នេះឈ្មោះហៅថា «**បរតម្ថមេត្តាបារមី**» ដែលជា «គុណជាតិដែលធ្វើឲ្យសត្វលោកបានឆ្លងទៅកាន់ត្រើយដ៏ប្រសើរបំផុត គឺព្រះនិព្វាន»។

ក្នុងការកសាងបារមីនេះ ព្រះពោធិសត្វគ្រប់ៗជាតិតែងតែធ្វើសច្ចាប្រណិធានរបៀបនេះថា «គ្រប់អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាឲ្យមានចិត្តល្អ មានករុណាធម៌ និងជាទីស្រឡាញ់រាប់អានរបស់មនុស្សទូទៅ ! អាត្មាអញសូមឲ្យមានទឹកចិត្តស្រឡាញ់ និងតម្កល់សត្វលោកទាំងឡាយឲ្យដូចជា ម្តាយ ឪពុក បង ប្អូនរបស់អាត្មាអញដូចៗគ្នាទាំងអស់ !»។

ដើម្បីជាសក្ខីភាពបញ្ជាក់ពីការកសាងមេត្តាបារមី សូមលោកអ្នកមេត្តាសិក្សារឿង **ពលបាលកុមារជាតក** និងរឿង**ព្រះសុវណ្ណសាមកុមារ** ជាដើម។

### ២.១.៦.១០. ឧបេក្ខាបារមី

(**មានប្រាជ្ញាយល់ត្រូវគឺខុសដឹងថាខុសត្រូវដឹងថាត្រូវ ស្រឡាញ់សេចក្តីបរិសុទ្ធ ស្រឡាញ់យុត្តិធម៌ មិនមានចិត្តលម្អៀង គឺជាគុណជាតិដ៏ឧត្តម**)

«**ឧបេក្ខា**» មានន័យថា «សភាពជាកណ្តាល»។ ឧបេក្ខា ជាកិរិយាកម្ចាត់បង់នូវសេចក្តីត្រេកអរ និងការមិនថ្នាំងថ្នាក់ មិនខឹង ហើយប្រព្រឹត្តទៅស្មើចំពោះសត្វ និងសង្ខារទាំងឡាយ ដោយតម្កល់ចិត្តជាកណ្តាលគ្មានលំអៀង។ ក្នុងកសាងឧបេក្ខាបារមីនេះ ព្រះពោធិសត្វតែងហាត់ពត់ចិត្តឲ្យមានតុល្យភាព (កណ្តាល) ដោយមានឧបេក្ខាចិត្តជាឧបាយ។ នេះបានសេចក្តីថា គ្មានប្រការអ្វីដែលអាចញុំាងព្រះពោធិសត្វធ្វើឲ្យលោកមានចិត្ត អបអរ រំភើបញាប់ញ័រ ឬភ័យខ្លាចដ៏តិចតួចឡើយ។ ក្នុងស្ថានភាពនៃចិត្តជាឧបេក្ខា ព្រះពោធិសត្វពុំមានការរំភើបញាប់ញ័រចំពោះ**អដ្ឋលោកធម៌** (ធម៌ក្នុងលោកទាំង៨) មាន៖ ១. មានភាព ២. អត់លាភ ៣. មានយស ៤. អត់យស ៥. សរសើរ ៦. និន្ទា ៧. សុខ ៨. ទុក្ខ។

ក្នុងកាលៈទេសៈណាក៏ដោយ នៅពេលដែលលោកធម៌ទាំង៨ប្រការនេះកើតឡើង ព្រះពោធិសត្វលោកគង់ស្ថិតនៅក្នុងសភាពនឹងដដែល ហាក់ដូចជាថ្មដែលត្រូវខ្យល់បក់បោកនៅនឹងថ្កល់យ៉ាងនោះដែរ។ ការបំពេញឧបេក្ខាបារមីត្រូវចែកចេញជាបីកម្រិត ដូចបារមីដទៃទៀតដែរគឺ ៖

**កម្រិតទី១ ឧបេក្ខាបារមី** ចិត្ត នៃព្រះពោធិសត្វតាំងនៅជាកណ្តាលជានិច្ចចំពោះលោកធម៌ដែលកើតមានឡើង ហើយដល់សត្វលោកទាំងឡាយ ទោះបីអ្នកនោះមានឧបការគុណក្តី អ្នកមិនមានឧបការគុណក្តី មានបុត្រ និងភរិយារបស់លោកជាដើម ។ កិរិយាតាំងនៅជាកណ្តាលចំពោះលោកធម៌នេះឈ្មោះថា «**ឧបេក្ខា**

**បារមី**» ដែលជា «គុណជាតិសម្រាប់ដឹកនាំសត្វលោកឆ្ពោះទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន» ព្រោះការតាំងចិត្តជាកណ្ដាលនេះ។

**កម្រិតទី២ ឧបេក្ខាឧបបារមី** ព្រះពោធិសត្វ តែងតាំងចិត្តជាមធ្យម កណ្ដាលជានិច្ចចំពោះលោកធម៌ ដែលកើតឡើងដល់សត្វលោកទាំងឡាយ ទោះបីអ្នកនោះមានឧបការគុណធំក្ដី អ្នកមានឧបការគុណតូចក្ដី ទោះបីព្រះពោធិសត្វត្រូវលះបង់ឬបូជា(បូជនីយកម្ម)នូវអវយវៈអង្គតូច ឬអង្គធំរបស់ព្រះអង្គក្ដី ព្រះពោធិសត្វដែលលោកតាំងចិត្តក្នុងឧបេក្ខាបារមីបានហើយនោះដោយ ព្រះអង្គបានកាត់ព្រះទ័យលែងជាប់ជំពាក់នឹងអដ្ឋលោកធម៌ (គឺធម៌ទាំង៨ប្រការក្នុងលោក)។ កិរិយាដែលព្រះពោធិសត្វប្រព្រឹត្តនេះគឺជាការសាង «**ឧបេក្ខាឧបបារមី**» ដែលជា «គុណជាតិសម្រាប់ដឹកនាំសត្វលោកឆ្ពោះទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»[14]។

**កម្រិតទី៣ ឧបេក្ខាបរមត្ថបារមី** ព្រះពោធិសត្វតែតម្កល់សន្តានចិត្តយ៉ាងមធ្យម ជាកណ្ដាលជានិច្ចចំពោះសត្វលោក និងសង្ខារទាំងឡាយ ទោះបីសត្វទាំងនោះមានឧបករគុណស្រាលក្ដី ឬធ្ងន់ក្ដី ដែលអាចប៉ះពាល់ដល់ជីវិតរបស់ព្រះអង្គក្ដី ព្រះអង្គនៅរក្សាព្រះទ័យរបស់ព្រះអង្គដដែល ដោយពុំមានការរំភើប ញាប់ញ័រដ៏តិចតួចឡើយ ។ កិរិយាដែលព្រះពោធិសត្វប្រព្រឹត្តនេះ គឺជាការសាង «**ឧបេក្ខាបរមត្ថបារមី**» ដែលជា «គុណជាតិសម្រាប់ដឹកនាំសត្វលោកឆ្ពោះទៅកាន់ត្រើយដ៏ប្រសើរ គឺព្រះនិព្វាន»។

ក្នុងការសាងឧបេក្ខាបារមីនេះព្រះពោធិសត្វគ្រប់ៗជាតិតែងតែធ្វើសច្ចាប្រណិធានរបៀបនេះថា «គ្រប់អនាគតជាតិតទៅ អាត្មាអញសូមប្រាថ្នាជាអ្នកមានសភាវៈនឹងធឹង ស្ងប់ស្ងៀម និងប្រកបដោយសន្តិភាព! អាត្មាអញ សូមឲ្យមានតុល្យភាពក្នុងចិត្តជានិច្ច! អាត្មាអញសូមឲ្យបានប្រកបនូវឧបេក្ខាដ៏បរិសុទ្ធបំផុត! អាត្មាអញសូមប្រាថ្នាឲ្យបានបម្រើសត្វលោក ដោយចិត្តបរិសុទ្ធ ហើយសូមឲ្យមានចិត្តបរិសុទ្ធ ដើម្បីបម្រើសត្វលោក!»។

[14] https://choukhmer.wordpress.com/khmer-civilisation/the-lives-of-pothisat/chapter-5/

# ជំពូក៣

# ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញនូវហេតុដែលនាំឲ្យវិនាស១២ប្រភេទ

## ៣.១. ប្រធាននៃសេចក្តីវិនាស១២ប្រការ

នៅក្នុងព្រះពុទ្ធសាសនា មានគោលវិធីដ៏ច្រើនលើសលប់ ដែលត្រូវបានត្រាស់ដឹង និងសម្តែងចេញដោយព្រះសម្មាសម្ពុទ្ធ និងព្រះអគ្គសាវកទាំងឡាយ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ គោលវិធីទាំងនោះមានរហូតដល់ទៅ ៨៤០០០ធម្មក្ខន្ធ ដែលគោលវិធីទាំងនោះសុទ្ធតែបង្ហាញអំពីមធ្យោបាយដែលប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់ជនច្រើនគ្នា ដើម្បីប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីសេចក្តីចម្រើនដល់ជនច្រើនគ្នា។

រាល់គោលវិធីទាំងនោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បង្ហាញទាំងធម៌ដែលគួរសេព ឬគួរប្រតិបត្តិ ហៅថាកុសលធម៌ និងធម៌ដែលមិនគួរសេព ឬមិនគួរប្រតិបត្តិ ហៅថា អកុសលធម៌។ នៅក្នុងចំណែកនៃធម៌ទាំងនេះ ព្រះអង្គបានបង្ហាញហេតុ និងអានិសង្ស បង្ហាញហេតុ និងទោសគ្រប់មាតិកាទាំងអស់ ដោយពឹងផ្អែកទៅលើសកម្មភាពរបស់មនុស្សលោកដែលធ្វើនៅកម្មនោះៗ។

ជាបន្ទាល់ស្រាប់ នៅក្នុងសេចក្តីវិនាសទាំង១២ប្រភេទនេះ គឺព្រះពុទ្ធអង្គទ្រង់បានបញ្ជាក់អំពីហេតុ និងដំណើរ ដែលប្រព្រឹត្តទៅដើម្បីឈានដល់សេចក្តីវិនាស គឺព្រះអង្គបានបញ្ជាក់ម្តងមួយមាតិកាៗ យ៉ាងច្បាស់លាស់ និងជាក់លាក់បំផុត ដើម្បីបង្រៀនមនុស្សលោក ដែលមានស្មារតីគ្រប់គ្រាន់ មានសតិជាប្រក្រតី ឲ្យមើលឃើញនូវហេតុនោះៗ ហើយការពារខ្លួនឲ្យផុត និងគេចឲ្យឆ្ងាយកុំសេពនូវហេតុនោះៗ។ ក្នុងចំណែកប្រធាននៃសេចក្តីវិនាសទាំងនោះ គឺផ្តើមចេញពីបុគ្គលដែលប្រទុស្ត និងច្បាប់ (ធម៌) កាលណាដែលបុគ្គលប្រទុស្តនឹងច្បាប់(ធម៌)នេះហើយដំណើរដែលនាំទៅកាន់សេចក្តីវិនាស គឺនៅមានគ្រប់ច្រកនៃអំពើទាំងឡាយដែលជននោះធ្វើ។

### ៣.១.១. ហេតុដែលនាំឲ្យវិនាសទី១

**បុគ្គលអ្នកទ្រុស្តធម៌ ស្អប់ធម៌**

**និយមន័យធម៌ និងបុគ្គលអ្នកស្អប់ធម៌ទ្រុស្តធម៌**

ទ្រុស្តធម៌ => វិនាស

**ធម៌មានន័យ ៤ យ៉ាង៖**

១. សភាវៈទ្រទ្រង់សត្វលោក(ល្អ និងមិនល្អ) ឲ្យមានជីវិតក្នុង វដ្តសង្សារ (ធម៌=ទ្រទ្រង់ ទំនុកបម្រុង)

២. ដំបូន្មាន ការអប់រំ ការស្តីប្រដៅ (ក្នុងន័យល្អ ដើម្បីលះនូវ អកុសល អំពើអាក្រក់ទាំងពួង)

៣. វិន័យ ច្បាប់ ដែលកំណត់ដោយពួកគណៈ ឬអង្គភាព ឬប្រទេស

៤. ធម៌ដែលព្រះពុទ្ធ បានបញ្ញត្តិ (ព្រះធម៌ ក្នុងពុទ្ធសាសនា)។

ក្នុងន័យធម៌ទាំងបួនខាងលើ សុទ្ធសឹងតែជា គ្រឿងដែលនាំឲ្យអ្នកបដិបត្តិ បាននូវសេចក្តីចម្រើន។

ដូច្នេះ ប្រសិនបើ ស្អប់ធម៌ មានន័យថា ស្អប់សេចក្តីចម្រើន ហើយក៏មានន័យថា ប្រាថ្នានូវសេចក្តីវិនាសជាប្រាកដ។

**ការស្អប់ធម៌ ៣ យ៉ាង៖**

១. ស្អប់ធម៌ដោយកាយ ៣ យ៉ាង៖

ក. ការបៀតបៀនគ្រូអាចារ្យដែលបាន អប់រំ

ខ. ការបៀតបៀន គម្ពីរធម៌ (ព្រះត្រៃបិដក) និងបំផ្លិចបំផ្លាញ

គ. ការមិនបដិបត្តិតាមធម៌ទាំងឡាយនោះ

**២. ស្អប់ធម៌ដោយវាចា ៣ យ៉ាង៖ (ការពោលពាក្យមិនប្រសើរ)**

ក. មិនមានសំដីដែលប្រសើរ = មិនមានវិចីសុច្ចរិត ៤ ឬ ៥

ពោលពាក្យកុហក ពោលពាក្យឥតប្រយោជន៍ ពោលពាក្យមិនពីរោះ និងគ្រោធ ពោលពាក្យមិនប្រកបដោយមេត្តាចិត្ត ពោលពាក្យខុសកាល ខុសកាលវេលា។

ខ. ត្មិះតិះដៀលធម៌ (សប្បុរស) ហើយកាច់បង្ខូចធម៌ខុសពីការពិត

គ. ការមិនចេះសូត្រធម៌ និងមិនចេះណែនាំអ្នកដទៃឲ្យស្រលាញ់ធម៌ និងចងចាំធម៌

**៣. ស្អប់ធម៌ដោយចិត្ត ៣ យ៉ាង៖**

ក. មិនមានចេតនាលើកតម្កើងធម៌ = មិនប្រថ្នាឲ្យធម៌បានប្រសើរ

ខ. ការមិនត្រិះរិះអំពីធម៌ក្នុងធម៌

គ. មិនតាំងចិត្តសិក្សាធម៌ ឬដំបូន្មានទាំងឡាយ។

ការស្អប់ធម៌ = ស្អប់បញ្ញា = ល្ងង់ = យល់ខុស = មានវិបត្តិ ៤ យ៉ាង៖

១. សីលវិបត្តិ = ទ្រុស្តសីល មិនមានការបដិបត្តិតាមសីលទាំងឡាយ

២. អាចារៈ វិបត្តិ = អន់មារយាទ ខ្វះមារយាទ

៣. ទិដ្ឋិវិបត្តិ = ល្ងង់ ធ្វើខុសវិន័យ យល់ខុស

៤. អជីវវិបត្តិ = ការចិញ្ចឹមជីវិតខុស។

ពាក្យថា "ធម៌" មានអត្ថន័យច្រើនណាស់ ប៉ុន្តែនៅទីនេះ ក្នុងន័យទូលាយ ធម៌ មានន័យថា ការបង្រៀន ឬសភាវៈពិត។ នៅក្នុងន័យចង្អៀត ធម៌ គឺជាការបង្រៀនរបស់ព្រះពុទ្ធ។ សូមកុំច្រឡំការបង្រៀនរបស់ព្រះពុទ្ធ និងធម៌សម្រាប់សូត្រពេលបុណ្យទាននានា។ ដោយសារនៅទីនេះ ធម៌ ផ្តោតជាពិសេសទៅលើសេចក្តីពិត ច្បាប់ធម្មជាតិ ឬវិទ្យាសាស្រ្ត ដូច្នេះមនុស្សដែលស្រឡាញ់សេចក្តីពិត អនុវត្តតាមច្បាប់វិទ្យាសាស្ត្រនឹងចេះស្វែងរកទិន្នន័យឬព័ត៌មានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់សម័យសម្រាប់ធ្វើការសម្រេចចិត្តប្រកបដោយគតិបណ្ឌិតឬបញ្ញាញាណ។ ពួកគេរស់នៅមានសេរីភាព រួចផុតពីសេចក្តីបង្រៀនក្លែងក្លាយទាំងឡាយ ដែលជាអន្ទាក់ សំណាញ់ ឬរនាំងហ៊ុំព័ទ្ធបិទបាំងពួកគេ មិនឲ្យមើលឃើញការពិត។ មនុស្សជឿលើសេចក្តីពិតតាមបែបវិទ្យាសាស្ត្រនឹងរស់នៅប្រកបដោយសេចក្តីសុខស្ងប់ គ្មានការរវល់អំពល់ទុក្ខ ឬភ័យព្រួយបង្កឡើងដោយ

ការបន្លាច ឬការអូសទាញឲ្យជឿទៅលើសេចក្តីជំនឿឥតហេតុផល ឬអរូបិយជំនឿទាំងឡាយ ដូចជាជំនឿថា មានមនុស្ស សត្វ ឬហេតុការណ៍អស្ចារ្យ ឋាននរក ឋានសួគ៌ ខ្មោច ប្រេត អតីតជាតិ អនាគតជាតិ ទេវតា ព្រហ្ម ឬអាទិទេពជាដើម។ ជារួម មនុស្សជឿសេចក្តីពិត មិនងាយសម្រេចចិត្តជឿតាមសម្តីពន្យល់ ឬសេចក្តីបង្រៀនណាមួយ ដែលមិនទាន់បានសិក្សាស្រាវជ្រាវពិសោធន៍ល្អិតល្អន់ ដោយអ្នកវិទ្យាសាស្រ្តនោះឡើយ។

ចំណែកមនុស្ស ដែលមិនស្វែងយល់សេចក្តីពិត ពួកគេនឹងធ្លាក់ចូលក្នុងសេចក្តីបង្រៀនក្លែងក្លាយ ដែលនាំទៅដល់ការខាតបង់ពេលវេលា ទ្រព្យសម្បត្តិ និងជីវិតក៏អាចមាន។ មនុស្សនៅក្នុងក្រុមនេះនឹងធ្វើខ្លួនងាយឲ្យមនុស្សដទៃបោកបញ្ឆោត បំភ័យ ឬអូសទាញឲ្យធ្វើអំពើផ្សេងៗ ដែលគ្មានភាពប្រាកដនិយម ដូចជាត្រូវគេបោកឲ្យជឿលើការសាក់លើខ្លួនប្រាណ ការទិញកន្សែងយ័ន្ត ការទិញថ្នាំបុរាណធ្វើពីឫសឈើ ឬសត្វងាប់ ការស្រោចទឹកលើករាសី ការទស្សន៍ទាយមើលអនាគត ពិធីសែនព្រេន ជំនឿហោះហើរដើរលើអាកាស ឬការវិនិយោគទុនបោកប្រាស។ មនុស្សក្រុមនេះ នឹងងាយត្រូវគេបញ្ឆោតឲ្យចំណាយពេលវេលា ទ្រព្យសម្បត្តិ ឬជីវិតទៅលើគោលលទ្ធិមួយ។ ពួកគេនឹងក្លាយទៅជាមនុស្សយន្ត ធ្លាក់ចូលក្នុងការបញ្ជារបស់ជនបោកប្រាស់ ដែលរង់ចាំឱកាសកេងប្រវ័ញ្ចយកប្រយោជន៍ ទៅបម្រើបុគ្គលផ្ទាល់ខ្លួន ឬបក្សពួករបស់គេ។ មនុស្សមិនស្រឡាញ់ការពិត ឬសេចក្តីបង្រៀនតាមបែបវិទ្យាសាស្រ្ត និងសម្រេចចិត្តយ៉ាងងាយដោយមិនបានគិតពិចារណាឲ្យបានត្រឹមត្រូវតាមបែបវិទ្យាសាស្រ្ត។

### ៣.១.២. ហេតុដែលនាំឲ្យវិនាសទី២

### ទី ២ - សេពគប់នឹងជនជាអសប្បុរស

ដើម្បីយល់ច្បាស់អត្ថន័យនៅក្នុងគោលការណ៍មួយនេះ យើងត្រូវសិក្សាពាក្យសប្បុរស និងអសប្បុរស ឲ្យបានល្អិតល្អន់ ជាមុនសិន។ ពាក្យថា សប្បុរស គឺបុរស (មនុស្សប្រុសក្តី ស្រីក្តី) ជាអ្នកស្ងប់ មិនធ្វើអំពើអាក្រក់ដោយកាយ វាចា ឬចិត្ត។ សប្បុរសជន ជាមនុស្សប្រព្រឹត្តល្អ ត្រឹមត្រូវតាមច្បាប់រដ្ឋនិងច្បាប់សាសនា។ សប្បុរសជន ជាមនុស្សរស់នៅចុះសម្រុងនឹងមនុស្សដទៃនៅក្នុងសហគមន៍ ឬសង្គមជាតិទាំងមូល ពួកសប្បុរសជនគោរពសិទ្ធិមនុស្សយ៉ាងខ្ជាប់ខ្ជួន និងមានមេត្តាករុណាដល់សត្វ និងរុក្ខជាតិនៅលើផែនដី។ សប្បុរសជនមិនគិតតែប្រយោជន៍ផ្ទាល់ខ្លួន ឬប្រយោជន៍របស់ក្រុមបក្សខ្លួននោះទេ។ ពួកគេចេះជួយឧបត្ថម្ភមនុស្សដទៃដែលជាជនល្ងិតល្ងង់ឲ្យមានប្រាជ្ញា ជួយជនរងទុក្ខឲ្យមានសេរីភាព ជួយជនក្រីក្រស្រេកឃ្លានឲ្យទទួលបានអាហារបរិភោគ ជួយជនខ្វះទីជម្រកឲ្យមានគេហដ្ឋានត្រឹមត្រូវ បង្រៀនមនុស្សខ្វះទ្រព្យសម្បត្តិឲ្យចេះប្រកបអាជីពត្រឹមត្រូវសម្រាប់ជួយយឹតយោងខ្លួននិង គ្រួសារ។ លើសពីនោះទៀត សប្បុរសជនប្រដៅបង្រៀនកូនចៅរបស់ពួកគេ ឲ្យចេះគោរពមនុស្សដទៃដោយគ្មានការរើសអើង វណ្ណៈ ឬសាសនា។ ពួកគេចេះគោរពសេចក្តីសម្រេចចិត្តរបស់មនុស្សដទៃ ស្តាប់យោបល់ល្អរបស់មនុស្សផ្សេងទៀត ដើម្បីកែលម្អខ្លួនគេឲ្យកាន់តែប្រសើរ។ ការសម្រេចចិត្តរបស់សប្បុរសជន គឺធ្វើឡើងបន្ទាប់ពីពួកគេបានសិក្សាស្រាវជ្រាវរាវរកព័ត៌មានត្រឹមត្រូវ និងប្រឹក្សាយោបល់ជាមួយមនុស្សមានបទពិសោធន៍ច្រើន ឬជនជាបណ្ឌិត។ ការប្រតិបត្តិជីវិតតាមមាគ៌ារបស់សប្បុរសជន នឹងធ្វើឲ្យមនុស្សរស់នៅយ៉ាងសុខស្ងប់ ចម្រុងចម្រើន និងសន្តិភាពនៅក្នុងសង្គម។ ហេតុដូច្នេះ ហើយទើបបុរាណាចារ្យប្រដៅឲ្យមនុស្សជំនាន់ក្រោយសេពគប់រាប់រកមនុស្សជាសប្បុរសជន។

ផ្ទុយពីសប្បុរសជន មនុស្សជាអសប្បុរសជនខ្វះខាតគុណសម្បត្តិទាំងឡាយ ដែលសប្បុរសជនមាន ដូចបានរៀបរាប់ខាងលើស្រាប់។ ពិនិត្យមើលពីជ្រុងជ្រោយទ្រព្យសម្បត្តិ ទោះបីអសប្បុរសជនមានទ្រព្យច្រើន

សន្ទឹកយ៉ាងណា ក៏មនុស្សនៅក្នុងក្រុមនេះ មិនអើពើចែករំលែកទ្រព្យរបស់ខ្លួនធ្វើជាប្រយោជន៍ដល់មនុស្សដទៃដូចជាការចែកទានដោយផ្ទាល់ដល់ជនក្រីក្រឬការបង្កើតមូលនិធិសម្រាប់ជួយសិស្សនិស្សិតក្រីក្រ កសាងសាលារៀន មន្ទីរពេទ្យ ឬផ្លូវថ្នល់ ដែលជាប្រយោជន៍ដល់សហគមន៍ទាំងមូលនោះទេ។ កុំថាឡើយដល់ទៅការចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួនដល់មនុស្សដទៃ អសប្បុរសជន មិនរវល់អើពើចំណាយពេលវេលាស្ម័គ្រចិត្តជួយកិច្ចការសង្គម ដូចជាការជួយបង្ហាត់បង្រៀនជនល្ងិតល្ងង់ ការជួយកិច្ចការវត្តអារាម សាលារៀន ឬមន្ទីរពេទ្យជាដើម។ អសប្បុរសជនសម្រេចចិត្តធ្វើអ្វីមួយ តែងឈរលើមូលដ្ឋានទាញយកប្រយោជន៍មកដល់ខ្លួនឬបក្សពួករបស់ខ្លួនជាមុន។ អសប្បុរសជនទាញយកគ្រប់ហេតុផលដើម្បីបន្តអំពើរើសអើងវណ្ណៈ ជំនឿសាសនា និងពណ៌សម្បុរស្បែករបស់មនុស្សដទៃ ដែលមិនមែននៅក្នុងវណ្ណៈរបស់ពួកគេដើម្បីជាភស្តុតាងសម្រាប់អះអាងចំណុចទាំងពីរខាងលើនេះ សូមយើងនាំគ្នាពិនិត្យមើលសង្គមមនុស្ស នៅប្រទេសឥណ្ឌានៅសម័យព្រះពុទ្ធ ថាតើសប្បុរសជន និងអសប្បុរសជន បានគិតពិចារណា និងធ្វើសកម្មភាពអ្វីខ្លះសម្រាប់ខ្លួនគេនិង បក្សពួករបស់គេ។ នៅប្រទេសឥណ្ឌា មនុស្សត្រូវបានបែងចែកចេញជា៤វណ្ណៈធំៗ ពោលគឺ វណ្ណៈព្រាហ្មណ៍ វណ្ណៈក្សត្រ វណ្ណៈវេស្សៈ និង វណ្ណៈសូទ្រៈ។ ជាទូទៅមនុស្សវណ្ណៈព្រាហ្មណ៍ ទាញយកហេតុផលថាពួកគេជាមនុស្សកើតមកពីមាត់មនុស្សទេពឈ្មោះ "មនុ" ឬកើតមកពីព្រះឱស្ឋរបស់ព្រះព្រហ្ម ដែលធ្វើឲ្យពួកគេជាមនុស្សខ្ពង់ខ្ពស់ជាងមនុស្សមកពីវណ្ណៈដទៃ។ ពួកមនុស្សវណ្ណៈព្រាហ្មណ៍បានបង្កើតគម្ពីរ មនុ សស្រ្តៈ ដើម្បីបោកប្រាស់ កេងប្រវ័ញ្ច ជិះជាន់មនុស្សនៅវណ្ណៈក្រោមៗ ជាពិសេសមនុស្សចណ្ឌាល (ជនក្រៅវណ្ណៈ) ដោយគ្មានសុភវិនិច្ឆ័យឡើយ។ ទោះបីមកដល់បច្ចុប្បន្ននេះ រដ្ឋាភិបាលឥណ្ឌាមានច្បាប់រដ្ឋធម្មនុញ្ញ ដែលការពារសិទ្ធិរបស់ជនក្រៅវណ្ណៈទាំងឡាយក៏ដោយ ក៏មនុស្សនៅវណ្ណៈព្រាហ្មណ៍ និងវណ្ណៈក្សត្រ បន្តជិះជាន់កេងប្រវ័ញ្ច និង រើសអើងមនុស្សវណ្ណៈវេស្សៈ សូទ្រៈ និងជនក្រៅវណ្ណៈ (ចណ្ឌាល) ជានិច្ច។ រឿងនិទានអំពីជីវិតរបស់តួអង្គព្រះពុទ្ធ បានឆ្លុះបញ្ចាំងឲ្យឃើញការរើសអើងវណ្ណៈដ៏តឹងតែង នៅក្នុងសង្គមឥណ្ឌានាសម័យបុរាណ។មាតាបិតារបស់ព្រះពុទ្ធគឺជាមនុស្សនៅក្នុងវណ្ណៈក្សត្រ(ម្ចាស់ដី) ដែលតែងប្រមូលភោគផលកសិកម្មពីប្រជាកសិករនៅក្នុង វណ្ណៈសូទ្រៈ និងមនុស្សក្រៅវណ្ណៈ។ អំពើជិះជាន់ កេងប្រវ័ញ្ច និងរើសអើងវណ្ណៈ បានបន្តពីមួយជំនាន់ទៅមួយជំនាន់ទៀត ដោយគ្មានការកែប្រែ ដោយសារពួកមនុស្សនៅវណ្ណៈខាងលើ (វណ្ណៈព្រាហ្មណ៍ និងវណ្ណៈក្សត្រ) បានចូលដៃឃុបឃិតគ្នាបង្កើតជាគម្ពីរសាសនាច្រើនរាប់មិនអស់ សម្រាប់បិទបាំងគំនិតអាក្រក់របស់ពួកគេ និងសម្រាប់បំបាក់ផ្នត់គំនិតមនុស្សដទៃទៀត ឲ្យទ្រាំទទួលយកគម្ពីរសាសនាទាំងនោះព្រោះជាបំណងរបស់ព្រះអាទិទេព។ គម្ពីរសាសនា និងពិធីសាសនាច្រើនស្មុគស្មាញទាំងនោះបានក្លាយទៅជា ឧបករណ៍សម្រាប់គាបសង្កត់ផ្នត់គំនិតមនុស្សនៅវណ្ណៈក្រោមៗ ឲ្យបន្តទ្រាំទ្រទទួលយកស្ថានភាពជីវិតរបស់ខ្លួនដោយគ្មានការពិចារណា ឬងើបប្រឆាំងនឹងអំពើអយុត្តិធម៌សោះ។ ពួកអសប្បុរសជននៅវណ្ណៈខាងលើបន្តពន្យល់ពួកមនុស្សនៅវណ្ណៈក្រោមថា មូលហេតុដែលធ្វើឲ្យពួកខ្លួនមានទ្រព្យសម្បត្តិច្រើន រស់នៅសុខស្រួល មានបាវបម្រើច្រើននៅជាតិនេះ គឺមកពីពួកខ្លួនបានធ្វើបុណ្យច្រើនពីជាតិមុនៗ ហើយមូលហេតុ ដែលធ្វើឲ្យពួកមនុស្សនៅវណ្ណៈក្រោមៗក្លាយជាជនក្រីក្រដូច្នេះ គឺមកពីពួកគេបានធ្វើកម្មអាក្រក់ ឬថាមិនបានធ្វើបុណ្យច្រើនពីជាតិមុនៗ។ ដូច្នេះ ពួកគេត្រូវស៊ូទ្រាំខាំមាត់សង្កត់ចិត្តទទួលយកស្ថានភាពក្រីក្រ នៅក្នុងជាតិនេះ ហើយខំធ្វើបុណ្យដាក់ទានឲ្យបានច្រើន ដើម្បីអាចកើតមកម្តងទៀតនៅជាតិក្រោយ ជាសេដ្ឋីមានបាវបម្រើច្រើន ដូចពួកវណ្ណៈព្រាហ្មណ៍ និងវណ្ណៈក្សត្រ។ ការបកស្រាយបង្វែទិសរបៀបនេះទទួលបានផលហួត

មករាប់រយជំនាន់មនុស្សនៅវណ្ណៈក្រោមមិនហ៊ានងើបឡើងប្រឆាំងនឹងមនុស្សនៅវណ្ណៈខាងលើ ដើម្បីទាមទារយកសិទ្ធិសេរីភាពរបស់ខ្លួនទេ។ មកដល់សម័យកាលព្រះពុទ្ធ មនុស្សជាច្រើនបានជួបប្រាស្រ័យទាក់ទងគ្នាដើម្បីដោះដូរទំនិញព្រមទាំងគំនិតថ្មីៗ និងបច្ចេកវិទ្យាទំនើបៗ ដែលធ្វើឲ្យមនុស្សជាច្រើនចាប់ផ្តើមសួរដេញដោលអំពីទ្រឹស្តីទាំងឡាយ ដែលមានចែងនៅក្នុងគម្ពីរវេទរបស់ពួកព្រាហ្មណ៍ថា តើវាមានភាពប្រាកដនិយមក្នុងកម្រិតណា។ ព្រះពុទ្ធក៏ជាទស្សនវិទូម្នាក់ ក្នុងចំណោមទស្សនវិទូទាំងឡាយ ដែលបានមើលឃើញអំពើអយុត្តិធម៌នៅក្នុងសង្គមឥណ្ឌានៅសម័យនោះ។ ព្រះអង្គបានដេញដោល និងបដិសេធទ្រឹស្តីទាំងឡាយដែលបានចែងនៅក្នុងគម្ពីរវេទ ដែលព្រះអង្គបានរៀនសូត្រជាមួយគ្រូតាំងពីកុមារភាពមក។ ព្រះអង្គបានតស៊ូស្វិតស្វាញប្រឆាំងនឹងការបែងចែក និងរើសអើងវណ្ណៈ។ បិតារបស់ព្រះអង្គក៏ជាមនុស្សនៅក្នុងក្រុមរើសអើងវណ្ណៈដែរ។ សេចក្តីបង្រៀនរបស់ព្រះពុទ្ធ បានធ្វើឲ្យមនុស្សនៅក្នុងវណ្ណៈក្រោមពេញចិត្ត និង យកទៅអនុវត្តតាម ក៏ប៉ុន្តែសេចក្តីបង្រៀននោះ បានធ្វើឲ្យមនុស្សនៅវណ្ណៈខាងលើខឹងសម្បាយ៉ាងខ្លាំង។ បដិវត្តន៍ខាងគំនិតរបស់ព្រះពុទ្ធ បានហុចផលយ៉ាងសម្បើម ដោយមានមនុស្សជាច្រើនបានងាកទៅប្រតិបត្តិតាមសេចក្តីបង្រៀនរបស់ព្រះអង្គ ដែលធ្វើឲ្យសង្គមមានយុត្តិធម៌ មនុស្សមានសិទ្ធិសេរីភាព។ មនុស្សចាប់ផ្តើមយល់អំពីតម្លៃនៃពាក្យថា មេត្តា ករុណា ចំពោះគ្នាទៅវិញទៅមក។ ប្រជាជនចាប់ផ្តើមបោះបង់ពិធីខាងសាសនាដែលពួកព្រាហ្មណ៍ បានបង្ខំឲ្យធ្វើរាប់ពាន់ឆ្នាំកន្លងទៅ។ នេះគឺជាឧទាហរណ៍បញ្ជាក់អំពីផលប្រយោជន៍ នៃការសេពគប់មិត្តជាសប្បុរសជន និងផលអាក្រក់បានពីការសេពគប់មិត្តជាអសប្បុរសជន។

### ៣.១.៣. ហេតុដែលនាំឲ្យវិនាសទី៣

#### កិរិយាដេក និយាយ ខ្ជិល ខឹងច្រើន

នៅក្នុងគោលការណ៍នេះ មានកិរិយាខាងរាងកាយសំខាន់ៗចំនួន៤ ដែលយើងគួរពិចារណា និងទាញយកភស្តុតាងមកអះអាងការពារគំនិតនីមួយៗឲ្យបានច្បាស់លាស់។ មនុស្ស និងសត្វគ្រប់រូបតែងមាន និងប្រើប្រាស់កិរិយាទាំង៤នេះប្រចាំថ្ងៃ ដើម្បីឲ្យរាងកាយប្រព្រឹត្តទៅប្រកបដោយតុល្យភាព និងសុខភាព។ យើងសូមផ្តោតយកតែមនុស្សហើយសុំមិនលើកជីវិតសត្វមកបរិយាយនៅទីនេះទេ។

កិរិយាទី១ គឺការដេក។ ជាទូទៅ មនុស្សត្រូវចំណាយពេល ៨ម៉ោង សម្រាប់ដេកសម្រាក ដើម្បីឲ្យខួរក្បាលត្រជាក់ផង និងទុកពេលឲ្យរាងកាយបញ្ចេញចោលសារជាតិគីមីពុល ដែលសល់នៅក្នុងខ្លួន និងខួរក្បាលផង។ លើសពីនោះទៀត ក្នុងពេលដេកលង់លក់ ខួរក្បាលមនុស្សចាប់ផ្តើមរៀបចំព័ត៌មានដែលទទួលបានកាលពីពេលភ្ញាក់ដឹងខ្លួន (ព័ត៌មានទទួលបានតាមរយៈភ្នែក ត្រចៀក អណ្តាត ច្រមុះ ស្បែក និងចិត្ត) ឲ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវ។ ព័ត៌មានណាដែលគ្មានប្រយោជន៍ ខួរក្បាលមនុស្សនឹងបោះបង់ចោលដើម្បីទុកលំហសម្រាប់រក្សាទុកព័ត៌មានដែលមានប្រយោជន៍។ ចំពោះព័ត៌មានដែលមានប្រយោជន៍វិញ ជាពិសេសព័ត៌មានទាក់ទងនឹងទីកន្លែងមានម្ហូបចំណី សុវត្ថិភាព និងវិធីការពារខ្លួនឲ្យរួចផុតពីគ្រោះថ្នាក់ជាដើម ត្រូវបានខួរក្បាលយកទៅតម្រៀបទុកតាមលំដាប់លំដោយ សម្រាប់មនុស្សយកមកប្រើប្រាស់ នៅពេលខាងមុខ។ បន្ទាប់ពីដេកលក់បាន៧ ឬ៨ម៉ោង មនុស្សម្នាក់ៗនឹងភ្ញាក់ឡើងប្រកបដោយអារម្មណ៍ភ្លឺថ្លា គិតដោះស្រាយបញ្ហាអ្វីមួយបានលឿន ព្រមទាំងមានប្រតិកម្មតបនឹងស្ថានភាពអាសន្នមួយយ៉ាងរហ័សរហួនផងដែរ។ មនុស្សដែលដេកមិនគ្រប់គ្រាន់ច្បាស់ជាមានប្រតិកម្មយឺតៗ អាចបង្កគ្រោះថ្នាក់នៅពេលបើកបរ ឬបញ្ជាគ្រឿងយន្ត

ចំណែកសិស្សានុសិស្ស ដែលដេកមិនគ្រប់គ្រាន់វិញ ក៏ពិបាកនឹងចងចាំមេរៀន ដែលបានរៀនកាលពីថ្ងៃម្សិលមិញដែរ។

ដូច្នេះ ការដេកគឺពិតជារឿងសំខាន់ណាស់សម្រាប់មនុស្សគ្រប់រូប ទោះបីមនុស្សខ្លះត្រូវការពេលវេលាត្រឹម ៣ ទៅ ៤ ម៉ោងក៏អាចដេកលក់គ្រប់គ្រាន់ក៏ដោយ។ សេចក្តីបង្រៀននៅក្នុងគោលការណ៍ទី ៣ នេះ គឺ កុំចំណាយពេលដេកលើសពីសេចក្តីត្រូវការរបស់រាងកាយ។ ការចំណាយពេល៩ ឬ១០ម៉ោង សម្រាប់ដេកពួនគឺពិតជាបង្ខិនពេលវេលាសំខាន់លើសពី ១ ភាគ ៣ ក្នុងមួយថ្ងៃសម្រាប់ធ្វើការងារជាប្រយោជន៍ដល់ខ្លួនឯងដល់គ្រួសារ និង សង្គម។ បើយើងពិចារណាពីជ្រុងជ្រោយសុខភាព ការដេកច្រើនក៏នឹងបង្កឲ្យសាច់ដុំចុះខ្សោយ ឆ្អឹងងាយផុយស្រួយ តម្រងនោម និងសួតពិបាកធ្វើការ។ ការដេកច្រើនពេកក៏នឹងបង្កឲ្យស្បែកខ្នងរលាក ហើយក្រពះក៏ពិបាករំលាយអាហារ ដែលបង្កទៅជារោគទល់លាមកក៏មាន។ មានរោគជាច្រើនបង្កឡើង ដោយសារតែការដេកច្រើនហួសសេចក្តីត្រូវការរបស់រាងកាយ។ ដូច្នេះ យើងមិនត្រូវដំអក់ទម្រន់មិនក្រោកពីគ្រែ ឬទីដេកនៅពេលដល់ម៉ោងត្រូវភ្ញាក់នោះទេ វៀរលែងតែករណីមានជំងឺ។ ការពិសារគ្រឿងញៀនស្រវឹងក៏នឹងបង្កឲ្យមនុស្សម្នាក់ៗត្រូវចំណាយពេលវេលាសម្រាប់ដេកពួនលើសពីសេចក្តីត្រូវការរបស់រាងកាយដែរ។ ហេតុនេះយើងក៏ត្រូវជៀសវាងគ្រឿងញៀន ឬស្រវឹងទាំងឡាយ ដែលបង្កបញ្ហាដល់សុខភាពខួរក្បាលសួត ថ្លើម និងតម្រងនោម។

កិរិយាទី២គឺការនិយាយច្រើនហួសហេតុដែលមនុស្សគ្រប់រូបគួរកាត់បន្ថយ។ ជាទូទៅ មនុស្សនិយាយប្រាស្រ័យទាក់ទងគ្នាជាប់ជាប្រចាំដើម្បីចែករំលែកព័ត៌មានចំណេះដឹង វិធីធ្វើការងារ និងជួញដូរ។ ការនិយាយគឺជាអំពើដែលរាងកាយមនុស្សប្រើសម្ពាធខ្យល់ បញ្ចេញពីសួត ដើម្បីបញ្ជាប្រអប់សំឡេងឲ្យមានចេញជាសំឡេងស្រែកខ្សឹបឬនិយាយ។យើងឃើញថា មនុស្សម្នាក់ៗត្រូវប្រើថាមពលយ៉ាងច្រើនដើម្បីនិយាយទាក់ទងគ្នា។ បើមនុស្សនិយាយតិច គាត់ក៏នឹងចំណាយថាមពលតិច បើគាត់និយាយច្រើន គាត់ក៏ចំណាយថាពលច្រើនដែរ។ ពេលយើងដឹងការពិតដូច្នេះហើយ យើងត្រូវកាត់បន្ថយការនិយាយឲ្យបានតិចតាមអាចធ្វើបានដើម្បីសន្សំថាមពល ទុកប្រើប្រាស់នៅក្នុងកាយវិការដទៃទៀត។ មនុស្សមួយដែលចំនួនប្រកបអាជីពខ្លះៗដែលទាមទារការនិយាយច្រើន ដូចជាគ្រូបង្រៀន ភិក្ខុ មេធាវី ឬតំណាងរាស្ត្រ។ ការនិយាយរបស់ពួកគាត់ភាគច្រើន ជាការនាំប្រយោជន៍ដល់មនុស្សច្រើននាក់។ ប៉ុន្តែពួកគាត់ក៏ខាតបង់ថាមពលច្រើនណាស់ដែរនៅពេលនិយាយម្តងៗ។ ប៉ុន្តែ មនុស្សខ្លះបែរជាចង់បញ្ចេញសំដីពេយរាយព្រោកប្រាជ្ញឥតប្រយោជន៍ តាមតៀមស្រា ឬវត្តអារាម ដោយគ្មានគោលដៅពិតប្រាកដ ព្រោះពួកនេះមានអំនួតខ្ពស់ និងចង់ឲ្យមនុស្សដទៃកោតក្រែងខ្លួនថាជាអ្នកចេះដឹងច្រើន។ ការនិយាយបែបនេះគឺជាការបង់ខាតថាមពលរបស់ខ្លួន បើជ្រុលជានិយាយដើមអាក្រក់ ឬបង្ខូចកិត្តិយសរបស់មនុស្សដទៃវិញ ជនព្រោកប្រាជ្ញឥតបានការទាំងនោះច្បាស់ជានឹងត្រូវគេជេរស្តីឬវាយប្រហារឲ្យឈឺសាច់ជាមិនខាន។ បើនៅក្នុងវង់ជជែកវិញ មនុស្សនិយាយច្រើនមិនទុកឱកាសឲ្យដៃគូបញ្ចេញគំនិតរបស់គេទេ។ នេះគឺពិតជាការខាតបង់ដ៏ធំមួយ ព្រោះថាមនុស្សម្នាក់ៗតែងមានគំនិតល្អរៀងៗខ្លួន គ្រាន់តែគេមិនចង់បញ្ចេញឲ្យក្រុមពិភាក្សាដឹងព្រោះគាត់គ្មានឱកាស។ ដូច្នេះមនុស្សនិយាយច្រើនគួរតែទុកឲ្យកាសស្តាប់យោបល់របស់មនុស្សដទៃ កុំគិតថាមានតែខ្លួនទេទើបមានយោបល់ល្អ ឬចេះដឹងច្រើនជាងគេ។ ម្យ៉ាងទៀតការនិយាយច្រើននឹងនាំឲ្យបែកធ្លាយការណ៍សម្ងាត់ដែលនាំឲ្យជនបង្កប់លួចយកព័ត៌មានទៅប្រើសម្រាប់ធ្វើអំពើអាក្រក់ដល់ខ្លួនឬប្រទេសរបស់ខ្លួន។

កិរិយាទី ៣ គឺភាពកំជិលដែលមនុស្សម្នាក់ៗត្រូវជៀសវាង។ គ្មានជនណាម្នាក់អាចអួតអាងថា ខ្លួនគេគ្មានភាពកំជិលនៅក្នុងខ្លួននោះឡើយ។ មនុស្សម្នាក់ៗ តែងមានភាពកំជិលនេះជាប់មកតាំងពីកំណើត។ យើងខិតខំបង្កើតរបៀបធ្វើការងារ និងបង្កើតឧបករណ៍បច្ចេកវិជ្ជាផ្សេងៗ ដើម្បីធ្វើកិច្ចការមួយបានសម្រេចដោយប្រើពេលវេលាតិច ដើម្បីសន្សំពេលយកទៅសម្រាកលំហែកម្សាន្ត ពោលគឺភាពកំជិល។ មនុស្សខ្លះបានជួល ឬប្រើមនុស្សផ្សេងទៀតឲ្យធ្វើការងារជំនួសខ្លួនក៏មាន។ ក្រុមមនុស្សមានអំណាចប្រើប្រាស់មនុស្សនៅក្រោមបង្គាប់ឲ្យធ្វើការងាររាប់ពាន់ប្រភេទជំនួសខ្លួន។ ពួកម្ចាស់ដីប្រើកូនឈ្នួលធ្វើការងារកសិកម្មយ៉ាងលំបាក និងផ្តល់ប្រាក់ឈ្នួលបន្តិចបន្តួចឬមិនឲ្យសោះក៏មាន។ នោះហើយជាភាពកំជិលរបស់មនុស្ស។ រីឯអ្នកវិទ្យាសាស្ត្រក៏បានស្វះស្វែងរកវិធីធ្វើការងារឬបង្កើតឧបករណ៍សម្រាប់ធ្វើការងារឲ្យបានច្រើន ដោយប្រើពេលវេលា និងថាមពលតិចបំផុត។ ឧទាហរណ៍ មនុស្សជំនាន់ដើមត្រូវធ្វើស្រែដោយប្រើសត្វជាជំនួយព្រោះខ្ជិលប្រើកម្លាំងរបស់ខ្លួន ហើយក្រោយមកមនុស្សក៏បានបង្កើតគ្រឿងយន្តជំនួសសត្វវិញ ព្រោះវាជួយឲ្យពួកគេសម្រេចគោលដៅឆាប់។ យើងលើកយកភាពកំជិលបែបទីមួយមកបង្ហាញសិនថា ភាពកំជិលមិនមែនសុទ្ធតែអាក្រក់ទាំងអស់នោះទេ។ យើងឲ្យឈ្មោះភាពកំជិលប្រភេទនេះថា "ទុកពេលស្វែងរកគំនិតល្អផ្សេងទៀត ដើម្បីធ្វើការងារមួយឲ្យបានឆាប់និងប្រសើរជាងមុន"។ ភាពកំជិលបែបនេះ គឺមានប្រយោជន៍ច្រើនជាងការធ្វើការងារតាមវិធីដដែលៗ តាមក្បួនចាស់ តាមទម្លាប់ ដែលចំណាយពេល ឬកម្លាំងច្រើន និងបានផលតិច។

ចំណែកឯភាពកំជិល ដែលយើងត្រូវវៀរចាកឲ្យឆ្ងាយនោះគឺ ជាភាពកំជិលដែលមនុស្សម្នាក់មិនអនុវត្តតាមវិធីធ្វើការងារដ៏ប្រសើរ ដែលគេបានណែនាំ និងមិនរវល់គិតគូររកវិធីធ្វើការងារថ្មី ដើម្បីសម្រេចគម្រោងណាមួយឡើយ។ ឧទាហរណ៍ទី ១ កសិករម្នាក់ត្រូវភ្ជួរស្រែមួយហិកតាឲ្យចប់ក្នុងរយៈពេល១០ថ្ងៃ។ ប្រសិនបើគាត់មានតែគោ ឬក្របីមួយនឹម និងនង្គ័លតែមួយ ជាធម្មតាគាត់ត្រូវក្រោកពីព្រលឹមដើម្បីភ្ជួរស្រែឲ្យបានយូរក្នុងមួយថ្ងៃៗ។ ប៉ុន្តែគាត់បែជាខ្ជិលក្រោកពីព្រលឹម ហើយរង់ចាំថ្ងៃរះផុតព្រៃ ឬរង់ចាំជិតថ្ងៃត្រង់ទើបចេញទៅស្រែ ។ គាត់មិនអាចនឹងសម្រេចទិសដៅរបស់គាត់បានឡើយ។ ជម្រើសទី២ គាត់អាចជួលមនុស្សដទៃឲ្យមកជួយការងារនោះ ពេលនោះគាត់នៅតែអាចសម្រេចទិសដៅបាន។ ប៉ុន្តែគាត់ខ្ជិលចំណាយប្រាក់ ឬគ្មានប្រាក់សម្រាប់ចំណាយ ពេលនោះគម្រោងរបស់គាត់នឹងមិនអាចសម្រេចតាមទិសដៅដាក់ចុះឡើយ។

ឧទាហរណ៍ទី ២ និស្សិតម្នាក់ត្រូវសរសេរនិក្ខេបបទកម្រាស់ ២០០ទំព័រ ដើម្បីការពារគំនិតរបស់គាត់សម្រាប់បញ្ចប់ថ្នាក់បរិញ្ញាប័ត្រ។ គាត់ត្រូវបញ្ចប់គម្រោងនោះក្នុងរយៈពេល១២ខែ ដោយរាប់បញ្ចូលទាំងការរៀបចំគម្រោង ការចុះស្រាវជ្រាវយកទិន្នន័យ ការវិភាគទិន្នន័យ និងការសរសេរនិក្ខេបបទផងដែរ។ និស្សិតម្នាក់នោះខ្ជិលធ្វើកិច្ចការទាំងនោះ និងរង់ចាំជិតដល់ឆ្នាំបញ្ចប់សឹមចាប់ផ្តើមធ្វើការងារនោះ។ ពេលវេលាចេះតែរំកិលទៅមុខគ្មានរង់ចាំនិស្សិតកំជិលនោះទេ។ នៅចុងឆ្នាំគាត់គ្មានទាំងគម្រោង ទាំងទិន្នន័យសម្រាប់សរសេរ ហើយក៏គ្មានឯកសារសម្រាប់បញ្ជាក់ថាគាត់បានធ្វើកិច្ចការទាំងនោះ។ ឧទាហរណ៍ទី ៣ ភិក្ខុមួយអង្គត្រូវរៀនគម្ពីរព្រះត្រៃបិដកទាំង១១០ ក្បាល និងគម្ពីរផ្សេងៗរបស់ពុទ្ធសាសនា និងរបស់សាសនាផ្សេងៗទៀត ឲ្យចេះចាំយ៉ាងស្ទាត់សម្រាប់យកទៅការពារគំនិត នៅពេលតស៊ូមតិ (សង្គាយនា) ជាមួយនឹងភិក្ខុដទៃនៅថ្ងៃប្រគួតប្រឡងបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ។ ភិក្ខុមួយអង្គនោះអានតែគម្ពីរព្រះត្រៃបិដកជាភាសាខ្មែរ និងខ្ជិលអានសៀវភៅផ្សេងទៀត។ ថ្ងៃប្រគួតបានឈានមកដល់ ការជជែកដេញដោលបានឈានឡើងដល់កម្រិតជ្រៅ និងលំបាកយ៉ាងខ្លាំង។ ភិក្ខុជាដៃគូប្រគួតបានចោទសួរភិក្ខុកំជិលយ៉ាងចាស់ដៃ និងបានធ្វើឲ្យភិក្ខុកំជិលចាញ់

ដែអាម៉ាស់មុខ ខឹងចិត្តទៅសម្ងំសូត្ររៀនបន្ថែម សម្រាប់ឡើងទៅប្រយុទ្ធនៅពេលក្រោយទៀត។ ឧទាហរណ៍ទី៤ បុរសម្នាក់ចង់ក្លាយជាមនុស្សមានទ្រព្យសម្បត្តិច្រើន ប៉ុន្តែគាត់ខ្ជិលទៅប្រកបអាជីវកម្ម ឬធ្វើការងារបម្រើក្រុមហ៊ុនដទៃ។ គាត់គិតថាបើគាត់ទៅកាស៊ីណូ គាត់អាចនឹងឈ្នះល្បែងបានប្រាក់ច្រើនសន្ធឹកក្នុងពេលឆាប់ៗ បើមិនដូច្នោះទេ គាត់អាចនឹងទិញឆ្នោត ដែលអាចឲ្យគាត់ត្រូវបានប្រាក់រាប់លានដុល្លា។ បុរសម្នាក់នោះបន្តទៅកាស៊ីណូដើម្បីលេងល្បែងគ្មានលោះថ្ងៃ។ ថ្ងៃខ្លះក៏ឈ្នះ ថ្ងៃខ្លះក៏ចាញ់។ ជាសរុបគាត់ចាញ់ល្បែងអស់ប្រាក់រាប់ម៉ឺនដុល្លា ត្រូវបញ្ចាំផ្ទះដើម្បីយកប្រាក់ទៅលេងល្បែងទៀត។ គាត់ក៏បានចំណាយប្រាក់សន្ធឹកណាស់ដែរដើម្បីទិញលេខឆ្នោត។ ទីបំផុតផ្ទះក៏អស់ការងារក៏គ្មាន ព្រមទាំងជំពាក់ប្រាក់អ្នកដទៃយ៉ាងច្រើនទៀតផង។ នេះជាលទ្ធផលនៃភាពកំជិល ដែលមនុស្សគ្រប់រូបគួរវៀរចាកឲ្យឆ្ងាយ។

**ទោសនៃ កោសជ សេចក្តីខ្ជិលច្រអូស**

ខ្ជិលធ្វើការងារគ្មានធនធាន
ខ្ជិលគោរពខាតវិស្សាសៈ
ខ្ជិលដកដង្ហើមប្រាសជីវិត
ខ្ជិលនិយាយពុំចេះវោហារ
ខ្ជិលស្តាប់សព្ទសូរប្រែជាថ្លង់
ខ្ជិលធ្វើបុណ្យទានគង់ក្រប្រាណ
ខ្ជិលសូត្ររៀនធម៌ធ្លាក់នរក
ខ្ជិលងូតគង្គារគង់ក្រហាយ
ខ្ជិលថែរក្សាពុំឋិតថេរ
ខ្ជិលពុំចង់មាននឹងបានក្រ
ខ្ជិលមើលយូរទៅគង់ពិលខ្វាក់
ខ្ជិលពុំភាវនាគ្មានស្មារតី
ខ្ជិលរៀនក្រមច្បាប់ត្រូវផ្តន្ទា
ខ្ជិលរៀននព្វន្ធពុំចេះកត់
ខ្ជិលរៀនវិន័យត្រូវអាបត្តិ
ខ្ជិលបោសជម្រះពុំស្អាតឋាន
ខ្ជិលចងធ្វើម្តេចនឹងបានជាប់
ខ្ជិលប្រើមេត្តាឆ្ងាយក្តីស្ងួន
ខ្ជិលហៅថាធ្វើម្តេចនឹងស្គាល់នាម
ខ្ជិលដេញធ្វើម្តេចនឹងព្រាត់ខ្វាត់
ខ្ជិលលាងធ្វើម្តេចនឹងបានជ្រះ
ខ្ជិលរក្សាសីលកើតវេរា
ខ្ជិលឲ្យធ្វើម្តេចគេនឹងអរ
ខ្ជិលចរចាល្អនាំសៅហ្មង

ខ្ជិលពុំគិតរៀនគ្មានយសសក្តិ
ខ្ជិលស្ម័គ្រព្រះពុទ្ធគ្មានចេស្តា។
ខ្ជិលគិតពុំបានថ្លាបញ្ញា
ខ្ជិលដើរយាត្រាខ្វិនពុំខាន។
ខ្ជិលចង់គង់តែនឹងខានបាន
ខ្ជិលរកកំសាន្តខានសប្បាយ។
ខ្ជិលលក់ទំនិញគ្មានលុយចាយ
ខ្ជិលសម្អាតកាយគ្មានក្លិនល្អ។
ខ្ជិលសរសេរពុំចេះអក្សរ
ខ្ជិលល្អគង់តែបានអប្រិយ។
ខ្ជិលថ្នាក់ថ្នមបែកក្តីបេតី
ខ្ជិលរកឧន្តីគ្មានអំណត់។
ខ្ជិលរកទ្រព្យាគង់កំសត់
ខ្ជិលច្រត់គង់ភ្លាត់ដួលមិនខាន។
ខ្ជិលស្កាត់ធ្វើម្តេចនឹងជួបប្រាណ
ខ្ជិលច្រានធ្វើម្តេចរលំប្រាណ។
ខ្ជិលរាប់ធ្វើម្តេចដឹងចំនួន
ខ្ជិលពួនធ្វើម្តេចនឹងបានបាត់។
ខ្ជិលស្មៀមធ្វើម្តេចនឹងបានស្ងាត់
ខ្ជិលណាត់ធ្វើម្តេចត្រូវវេលា។
ខ្ជិលធ្វើការហោសខាតភាសា
ខ្ជិលទារធ្វើម្តេចគេនឹងសង។
ខ្ជិលតទំនិញខាតទ្រព្យផង
ខ្ជិលប៉ងម្តេចនឹងដូចប្រាថ្នា។

ខ្ជិលទន្ទេញធ្វើម្ដេចនឹងចាំ ខ្ជិលដាំធ្វើម្ដេចបានផ្លែផ្កា
ខ្ជិលខាតធ្វើម្ដេចបានជ្រះថ្លា ខ្ជិលស្អប់តណ្ហាទៅអបាយ[15]។

ម្យ៉ាងទៀត ធម៌ជាចំណែកនៃសេចក្ដីវិនាសសាបសូន្យ ប្រាំបីប្រការនោះបានដល់ហេតុខ្ជិលរបស់បុគ្គលប្រាំបីប្រការគឺ៖

១ - គិតថា អាត្មាអញនឹងធ្វើការ គួរតែសម្រាកសិន ហើយដេក។

២ - គិតថា អាត្មាអញបានធ្វើការរួចហើយ គួរឈប់ឲ្យសប្បាយ ហើយដេក។

៣ - គិតថា អាត្មាអញនឹងដើរទៅផ្លូវឆ្ងាយ គួរតែសម្រាកសិន ហើយដេក។

៤ - គិតថា អាត្មាអញដល់ទីកន្លែងហើយ គួរតែឈប់ឲ្យសប្បាយ ហើយដេក។

៥ - គិតថា អាត្មាអញបរិភោគអាហារតិចពេក ធ្វើការមិនកើតទេ ហើយដេក។

៦- គិតថា អាត្មាអញបរិភោគអាហារច្រើនពេក គួរតែឈប់សម្រាក ឲ្យអាហាររលាយរលួយស្រួលបួលសិន ហើយដេក។

៧ - គិតថា អាត្មាអញមិនសូវស្រួលខ្លួនទេ ចេះតែរកកល់ឈឺ គួរតែសម្រាកសិន ហើយដេក។

៨ - គិតថា អាត្មាអញទើបតែងើបពីឈឺថ្មីៗ គួរតែបង្អង់ធ្វើការងារសិន ហើយដេក[16]។

កិរិយាទី ៤ ការខឹងសម្បារ ដែលមនុស្សត្រូវកាត់បន្ថយឲ្យបានតិចបំផុត។ មនុស្សគ្រប់គ្នាតែងមានអារម្មណ៍ខឹងសម្បា ទោះបីជាជនសាមញ្ញ ឬអ្នកចេះដឹងខ្ពស់ក្លាយជាអរហន្តក៏ដោយ គ្រាន់តែកម្រិតនៃកំហឹងមានខុសគ្នាទៅតាមកម្រិតនៃភាពចេះដឹង និងការចេះខន្តី ឬសណ្ដោស។ កំហឹងគឺជាអារម្មណ៍ឆេះក្ដៅ ពុះកញ្ជ្រោលឡើងនៅក្នុងក្បាលរបស់បុគ្គលម្នាក់ នៅពេលស្ថានភាពមួយមិនកើតឡើង តាមការរំពឹងទុក ឬមនុស្សម្នាក់បង្កបញ្ហា ឬមិនធ្វើការងារឲ្យសមនឹងចិត្តចង់បានរបស់បុគ្គលទីមួយនោះ។ មនុស្សដែលមានខន្តី និងយល់ស្ថានការណ៍ ព្រមទាំងទុក្ខលំបាករបស់ជនដទៃ ក៏ចេះបន្ធូរអារម្មណ៍ខឹងបានឆាប់ និងមិនជះកំហឹងទៅលើជនទីពីរ។ មនុស្សគ្មានខន្តី មិនស្វែងយល់ស្ថានការណ៍របស់ជនដទៃ នឹងបន្តរក្សាកំហឹងឲ្យឆេះធំនៅក្នុងក្បាលរបស់ខ្លួន រួចហើយជះកំហឹងនោះទៅលើជនទីពីរ និងមនុស្សនៅក្បែរខ្លួនដូចជាកូន ចៅ ប្ដី ឬមនុស្សនៅក្រោមបង្គាប់។ សូម្បីរបស់មានតម្លៃ និងជាទីស្រឡាញ់របស់ខ្លួនក៏មនុស្សមិនចេះទប់កំហឹងនោះនឹងវាយបំបែកឲ្យខ្ទេច។ គ្មាននរណាម្នាក់ចង់រស់នៅក្បែរមនុស្សមិនចេះទប់កំហឹងសោះឡើយ ព្រោះកំហឹងរបស់បុគ្គលនោះនឹងឆ្លងដល់ខ្លួនមិនខាន។ កំហឹងដែលមិនមានការទប់ស្កាត់ត្រឹមត្រូវ គឺជាភាពចង្រៃដល់សីលធម៌ ( moral hazard )។

ការបកស្រាយខាងលើបានបង្ហាញឲ្យឃើញថា ការដេកច្រើន ការនិយាយច្រើន ភាពកំជិល និងកំហឹងគ្មានការគ្រប់គ្រងគឺជាមូលហេតុនាំមកនូវក្ដីវិនាសទី៣។ ហេតុនេះ បុគ្គលគ្រប់រូបគួរជៀសវាងឬកាត់បន្ថយការបញ្ចេញអារម្មណ៍ទាំងនោះ ឲ្យបានតិចបំផុតតាមអាចធ្វើបានដើម្បីអាចរស់នៅសុខចម្រើន និងចុះសម្រុងជាមួយមនុស្សដទៃនៅក្នុងគ្រួសារ និងសហគមន៍។ មានវិធីប្រកបដោយប្រសិទ្ធភាពជាច្រើនដែលមនុស្សគ្រប់

[15] កម្ពុជាសុរិយា ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ ពុទ្ធសាសនបណ្ឌិត្យ ភាគ ៤២/១ គ.ស១៩៧០ ទំព័រ៤៥៨

[16] កម្ពុជសុរិយា ភាគ ៣២/១ គ.ស១៩៦០ ទំព័រ ៥១០

រូបគួររៀន និងប្រតិបត្តិតាមដើម្បីជួយខ្លួនឯងឲ្យជៀសវាងការដេកទ្រមក់ ការនិយាយច្រើន ភាពកំជិល និងកំហឹងឥតគម្រូបរបស់ខ្លួន។

### ៣.១.៤. ហេតុដែលនាំឲ្យវិនាសទី៤

### មិនចិញ្ចឹមមាតាបិតា

តាមច្បាប់ធម្មជាតិ មេបាសត្វប្រភេទខ្លះ បង្កើតកូនដើម្បីបន្តពូជពង្សរួចហើយ ក៏បន្តរកចំណីមកបញ្ចុកកូនរហូតដល់កូនធំធាត់អាចស្វែងរកចំណីដោយខ្លួនឯង។ មេបាសត្វខ្លះ ថែមទាំងបង្រៀនកូនឲ្យចេះរកចំណីអាហារ និងជួយការពារកូនឲ្យរួចផុតពីសត្វដទៃ ដែលអាចចាប់កូនធ្វើជាចំណី។ នៅពេលកូនធំធាត់ដឹងក្តី ពួកគេបន្តជីវិតដោយខ្លួនឯង និងដើរតួនាទីជាមេបាដើម្បីបន្តពូជពង្សសត្វប្រភេទនោះបន្តទៀត។ អ្នកវិទ្យាសាស្ត្រនៅមិនទាន់រកឃើញកូនសត្វប្រភេទណាមួយ វិលត្រឡប់យកចំណីមកជួយមេបារបស់ខ្លួនទេ វៀរលែងតែមនុស្សប៉ុណ្ណោះ។ មនុស្សក៏ជាពូជសត្វម្យ៉ាងដែរ ប៉ុន្តែមនុស្សជាសត្វមានភាសាពិសេសសម្រាប់ឆ្លើយឆ្លងគ្នា សម្រាប់បង្រៀនឬផ្ទេរចំណេះដឹង និងបច្ចេកវិជ្ជាទៅមនុស្សជំនាន់មួយទៀត។ មនុស្សប្រើប្រាស់ភាសាពន្យល់គ្នាឲ្យចេះជួយបែងចែកចំណីអាហារ ជួយធ្វើការងារ និងការពារគ្នាតាមលទ្ធភាពដែលពួកគេមាន។

មនុស្សរស់នៅក្នុងកុលសម្ព័ន្ធ សហគមន៍ ឬប្រទេសជាមួយគ្នាបានបង្កើតច្បាប់ទម្លាប់សម្រាប់មនុស្សនៅក្នុងកុលសម្ព័ន្ធ សហគមន៍ ឬប្រទេសនោះ។ មនុស្សបានបង្កើតច្បាប់សម្រាប់គ្រប់គ្រងកុលសម្ព័ន្ធឬរដ្ឋ និងច្បាប់សាសនាដើម្បីឲ្យមនុស្សរស់នៅចុះសម្រុង និងចេះជួយគ្នាដើម្បីឲ្យពូជមនុស្សអាចរស់នៅប្រកបដោយសេចក្តីសុខ។ ការសិក្សាស្រាវជ្រាវបានបង្ហាញឲ្យឃើញថា ភាគច្រើននៃច្បាប់សាសនា បានបង្រៀនមនុស្សជាកូនចៅ ទទួលយកភារៈចិញ្ចឹមឪពុកម្តាយដោយស្ម័គ្រចិត្ត និងពេញចិត្ត។ ឧទាហរណ៍ នៅក្នុងគម្ពីរព្រះត្រៃបិដក នៃពុទ្ធសាសនានិកាយថេរវាទ មានសេចក្តីបង្រៀនថា កូនមានតួនាទីចំពោះឪពុកម្តាយស្របតាមប្រការ ៥ យ៉ាង គឺ ១- ជួយចិញ្ចឹមបីបាច់ ២- ជួយធ្វើការងារជំនួស ៣- ជួយការពារនិងរក្សាវង្សត្រកូល ៤- ប្រតិបត្តិខ្លួនឱ្យត្រឹមត្រូវសមជាអ្នកទទួលនិងគ្រប់គ្រងមរតកពីពួកគាត់ និង៥- ធ្វើបុណ្យទានជូនពួកគាត់ពេលពួកគាត់លាចាកលោកនេះ។ ប៉ុន្តែមានមនុស្សមួយចំនួនមិនអនុវត្តតាមច្បាប់សាសនាទាំងនោះទេ ពោលគឺមិនខ្វល់ជួយចិញ្ចឹមឪពុកម្តាយរបស់ខ្លួន ទោះបីពួកគេមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក៏ដោយ។

យើងសង្កេតឃើញថា ច្បាប់សាសនាគ្មានវិធីអ្វីដើម្បីចាប់បង្ខំពួកកូនទាំងនោះ ឲ្យអនុវត្តតាមច្បាប់ទាំងនោះទេ ក្រៅតែវិធីពីរយ៉ាង ពោលគឺ ទី១ ការលើកទឹកចិត្តថាវាជាកិច្ចការដែលព្រះអាទិទេពដាក់ចុះ ឬទេវតានឹងជួយរក្សាពួកខ្លួនឲ្យមានសុវត្ថិភាព និងវិធីទី២ គឺការនិយាយបំភិតបំភ័យដើម្បីបន្លាចឲ្យពួកកូនទាំងនោះទទួលយកនិងធ្វើតាម។ យើងមិនត្រូវបន្ទោសពួកកូនៗថា ពួកគេមិនចិញ្ចឹមឪពុកម្តាយឲ្យបានត្រឹមត្រូវ ដោយយើងមិនបានសិក្សា មើលអំពីលទ្ធភាពរបស់ពួកកូនៗទាំងនោះ ក្នុងការបំពេញកិច្ចការទាំងនោះឡើយ។ ប្រសិនបើពួកកូនទាំងនោះគ្មានលទ្ធភាពធ្វើកិច្ចការទាំងនោះទេ តើអ្នកណាជាអ្នកជួយពួកគេ? យើងត្រូវពិនិត្យមើលឲ្យហួសពីការទទួលខុសត្រូវរបស់ពួកកូនៗ និងត្រូវសួរថា តើសហគមន៍ទាំងមូលមានតួនាទីអ្វីខ្លះដែលអាចជួយមនុស្សចាស់នៅក្នុងភូមិ និងជួយបានក្នុងកម្រិតណា ? តើភិក្ខុសង្ឃអាចដើរតួជាអ្នកដឹកនាំប្រជាជនជាពុទ្ធបរិស័ទចំណុះជើងវត្ត ឲ្យចូលរួមគ្នាជួយពួកមនុស្សចាស់ទាំងនោះបានក្នុងកម្រិតណា? តើប្រទេសទាំងមូលអាចបង្កើតច្បាប់ការពារមនុស្សចាស់បានក្នុងកម្រិតណា រាប់ទាំងការគោរពសិទ្ធិមនុស្ស និងសិទ្ធិទទួលបានការឧបត្ថម្ភត្រឹមត្រូវពីរដ្ឋាភិបាល ទាំងផ្នែកចំណីអាហារ ទីជម្រកការថែទាំសុខភាព និងសុខុមា-

លភាព? ប្រសិនបើសហគមន៍ វត្តអារាម និងរដ្ឋាភិបាលរួមគ្នាជួយមនុស្សចាស់ទាំងឡាយ ពេលនោះបន្ទុកក្នុងការចិញ្ចឹមបីបាច់ឪពុកម្ដាយ នឹងមិនសូវជាធ្ងន់ពេកសម្រាប់ពួកកូនៗដើម្បីទទួលយកនោះឡើយ។

### ៣.១.៥. ហេតុដែលនាំឲ្យវិនាសទី៥

### ភូតកុហក បោកបញ្ឆោត

នៅក្នុងគោលការណ៍នេះ យើងត្រូវបែងចែកជាពីរផ្នែកឲ្យដាច់ស្រឡះ ដើម្បីឲ្យយើងអាចបកស្រាយ និងរកភស្តុតាង អំណះអំណាងមកការពារចំណុចនីមួយៗឲ្យបានពេញលេញ និងងាយយល់។ ផ្នែកទី១ គឺពាក្យថា ភូតឬកុហក។ តើសំដីកុហកផ្ដល់ប្រយោជន៍ ឬគុណវិបត្តិអ្វីដល់មនុស្សជាអ្នកនិយាយ និងមនុស្សជាអ្នកស្ដាប់ ? ជាទូទៅ គ្មានមនុស្សណាម្នាក់អាចអួតអាងថា មិនធ្លាប់និយាយកុហកសោះក្នុងមួយជីវិត។ មានពេលខ្លះសំដីកុហកអាចផ្ដល់ប្រយោជន៍ដល់អ្នកនិយាយ និងគ្មានមនុស្សណាមកចាប់ទោសអូសដំណើរអ្វីទេ ប្រសិនបើគេប្រើវាសម្រាប់ដោះទាល់ ឬការពារសុវត្ថិភាពរបស់ខ្លួន ឬសុវត្ថិភាពមនុស្សដទៃ។ ឧទាហរណ៍ មានជនចំឡែកម្នាក់មកសុំស្នាក់នៅក្នុងវត្តមួយ នៅក្នុងបំណងស៊ើបអង្កេតមើលស្ថានភាពរបស់ប្រជាជនក្នុងភូមិ ដូចជាចង់ដឹងថាតើគ្រួសារណាមានទ្រព្យច្រើនជាងគេ ឬថាតើមានការយាមកាមត្រឹមត្រូវ ឬអត់។ ប្រសិនបើជនចំឡែកសួរភិក្ខុមួយអង្គនៅក្នុងវត្ត នូវសំណួរទាំងឡាយប្រភេទនេះ តើភិក្ខុអង្គនោះត្រូវឆ្លើយយ៉ាងណា? បើឆ្លើយតាមការពិត ជនចំឡែកនឹងប្រើប្រាស់ព័ត៌មាននោះក្នុងផ្លូវអាក្រក់ ដូចជាការមកលួច ឬប្លន់ទ្រព្យប្រជាជនជាដើម។ បើមិនឆ្លើយតាមការពិតទេ ភិក្ខុនឹងមានកំហុសថាបានពោលពាក្យមុសា។ ដូច្នេះភិក្ខុអង្គនោះត្រូវថ្លឹងមើលថា តើក្នុងចំណោមអំពើទាំងពីរនោះ អំពើមួយណានឹងនាំទៅដល់ផលវិបត្តិតិចជាងគេ។ ប្រសិនបើមិនអាចគេចវេស មិនឆ្លើយតបចំពោះសំណួរទាំងនោះបានទេ ភិក្ខុអង្គនោះអាចនឹងជ្រើសយកការមិនផ្ដល់ព័ត៌មានពិត ឬអាចឆ្លើយថាមិនដឹងជាការស្រេច។ អំពើរបស់ភិក្ខុនោះជួយការពារទ្រព្យសម្បត្តិ ឬអាយុជីវិតរបស់ប្រជាជន ដែលជាប្រយោជន៍ប្រសើរជាងការនិយាយព័ត៌មានពិតក្នុងបំណងរក្សាសីល "មិនពោលពាក្យមុសាវាទ"។ ប៉ុន្តែការពោលពាក្យកុហកមួយចំនួននឹងនាំផលអវិជ្ជមានដល់ខ្លួនផង និងដល់មនុស្សដទៃផងដែរ។ ឧទាហរណ៍ ភិក្ខុមួយអង្គពោលពាក្យអួតអាងថា អាចព្យាបាលជម្ងឺច្រើនមុខជូនអ្នកស្រុក ដោយលោកគ្រាន់តែប្រើថ្នាំឫសឈើមួយឆ្នាំងប៉ុណ្ណោះ។ ជម្ងឺអេដស៍គឺជាជម្ងឺមួយក្នុងចំណោមជម្ងឺដែលភិក្ខុអង្គនោះអួតថាអាចព្យាបាលឲ្យជាសះស្បើយ។ មានគ្រួសារមួយ ដែលមានកូនប្រុសម្នាក់កើតជម្ងឺអេដស៍ ដែលបុគ្គលិកពេទ្យគ្មានវិធីព្យាបាលឲ្យជាសះស្បើយទេ គឺមានតែការចំណាយប្រាក់សម្រាប់ទិញថ្នាំលេប ដើម្បីបង្រ្កាបកុំឲ្យចំនួនវីរុសកើនឡើងច្រើនពេក ដែលអាចឈានទៅដល់សម្លាប់បុរសវ័យក្មេងនោះ។ ឪពុកម្ដាយយុវជននោះមិនជឿពាក្យណែនាំរបស់ពេទ្យ ក៏នាំកូនទៅជួបភិក្ខុពូកែអួតអាងអង្គនោះដើម្បីសុំឲ្យលោកជួយព្យាបាល។ ការពិតគឺគ្មានថ្នាំឫឈើណាអាចសម្លាប់មេរោគអេដស៍បានឡើយ។ ដោយក្ដីអំនួត មោទនភាព និងខ្លាចខ្មាស់ប្រជាជនផងប្រសិនបើភិក្ខុអង្គនោះពោលពាក្យពិត "អាត្មាមិនអាចព្យាបាលរោគអេដស៍" ជាជាងការពោលពាក្យពិតភិក្ខុអង្គនោះកុហកថា លោកអាចព្យាបាលយុវជនឲ្យជាសះស្បើយពីរោគអេដស៍។ ទីបំផុតឪពុកម្ដាយក៏អស់ប្រាក់ យុវជននោះក៏ស្លាប់ព្រោះមិនបានទទួលថ្នាំពេទ្យត្រឹមត្រូវដើម្បីសម្លាប់មេរោគអេដស៍។ នេះគឺជាការពោលពាក្យកុហកដែលបង្កឲ្យមនុស្សដទៃបាត់បង់ទ្រព្យ គ្រោះថ្នាក់ និងស្លាប់បាត់បង់ជីវិត។

ផ្នែកទី២ គឺការបោកបញ្ឆោត។ ពាក្យថា បោកបញ្ឆោត គឺជាសំដីដែលមនុស្សទី ១ និយាយលួងលោមមនុស្សទី២ ឲ្យធ្វើអំពើមួយដែលនឹងមិននាំផលល្អដល់មនុស្សទី១ទេ ប៉ុន្តែមនុស្សទី ២ បែរជាបានផលទៅ

វិញ។ ឧទាហរណ៍ មនុស្សសាមញ្ញម្នាក់បានពោលពាក្យបញ្ឆោតប្រជាជនទូទៅថា រូបខ្លួនគឺជាព្រះសិរីអារ្យមេត្រីចុះមកចាប់ជាតិ ដើម្បីជួយសង្គ្រោះមនុស្សលោក។ បុរសម្នាក់នោះ មានក្រុមបក្សរបស់ខ្លួនជាច្រើន ព្រមទាំងមានមនុស្សមានអំណាចជួយការពាររូបគេផងដែរ។ ជនបោកប្រាស់នោះ បានបញ្ឆោតមនុស្សជាច្រើនឲ្យជឿ និងចំណាយប្រាក់ជាច្រើនដើម្បីទិញដំរគ្រីស្គាល់របស់ខ្លួន ដោយនិយាយថា ដំរនោះនឹងក្លាយទៅជាដុំពេជ្រនៅពេលអនាគត។ លើសពីនោះទៀត ជនបោកប្រាស់ម្នាក់នោះនៅបានបោកប្រជាជនជាច្រើន ឲ្យចំណាយប្រាក់សង់វិមានធំស្កឹមស្កៃនៅលើដីវត្តរបស់ខ្លួន ព្រោះនៅពេលដល់ពេលកំណត់ជនបោកប្រាស់នោះនឹងហោះឡើងទៅឋានសួគ៌ ហើយមនុស្សណាដែលរស់នៅក្នុងវិមាននៅក្នុងដីវត្តនោះ អាចនឹងតោងជើងជនបោកប្រាស់នោះហោះឡើងទៅឋានសួគ៌ជាមួយដែរ។ ទីបំផុតអំពើបោកប្រាស់ ក៏ត្រូវបានបើកបង្ហាញឲ្យដឹងជាសាធារណៈជនបោកប្រាស់ក៏បានសារភាពនូវអំពើបោកប្រាស់របស់ខ្លួន។ មេបោកប្រាស់នេះសមនឹងទទួលពិន័យយ៉ាងធ្ងន់ធ្ងរស្របនឹងច្បាប់ជាធរមាន ប៉ុន្តែដោយសារតែមានខ្សែ ឬខ្នងបង្អែកធំ ជនបោកប្រាស់ក៏បានដោះលែងឲ្យរួចខ្លួន បន្ទាប់ពីបានពោលពាក្យសុំទោសបែបលាក់កំណួចរបស់ខ្លួន។ ចំណែកប្រជាជនរាប់ពាន់នាក់ដែលត្រូវជនបោកប្រាស់បញ្ឆោតឲ្យចំណាយប្រាក់រាប់ម៉ឺននោះវិញ បានត្រឹមតែខឹងមួម៉ៅក្តៅក្រហាយ និងជេរប្រទេចដាក់បណ្តាសាមនុស្សគម្រក់នោះប៉ុណ្ណោះ ព្រោះមិនអាចធ្វើអ្វីកើត និងឈឺចិត្តមិនគួរនឹងល្ងង់ខ្លៅត្រូវគេបោកប្រាស់យ៉ាងងាយដូច្នេះសោះ។ ទីបំផុតលោភៈ និងមោហៈ បានត្រឹមនាំមកនូវទោសៈដាក់ខ្លួនប៉ុណ្ណោះ។ ដូច្នេះសូមប្រជាជនទាំងអស់ប្រុងប្រយ័ត្នខ្លួន មិនត្រូវធ្លាក់ខ្លួនចាញ់ពាក្យល្បួងលួងលោមរបស់ជនពាលឡើយ ទោះជនពាលជាភិក្ខុសង្ឃ ឬជនសាមញ្ញក៏ដោយ។

### ៣.១.៦. ហេតុដែលនាំឲ្យវិនាសទី៦

**លាក់អាហារឆ្ងាញ់ និង ធនធាន**

នៅក្នុងគោលការណ៍នេះ ក៏មានពីរផ្នែកដែលយើងត្រូវបកស្រាយដាច់ដោយឡែកពីគ្នា។

ផ្នែកទី ១ ការលាក់អាហារឆ្ងាញ់មិនចែករំលែកជាមួយនឹងមនុស្សដទៃ។ តាមច្បាប់ធម្មជាតិ សត្វមួយចំនួនធំស្វែងរកចំណីអាហារ សម្រាប់ចិញ្ចឹមជីវិតត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ព្រោះពួកគេមិនដែលខ្វល់ខ្វាយកើបប្រមូលអាហារមកទុកសម្រាប់ថ្ងៃស្អែកទេ។ បើថ្ងៃស្អែកឡើងរកមិនបានអាហារ ពួកវាក៏នឹងស្វែងរកអាហារនៅថ្ងៃស្អែកទៀត។ មានសត្វបក្សីប្រភេទខ្លះ ត្រូវហើរផ្លាស់ទីចម្ងាយរាប់ពាន់គីឡូម៉ែត្រដើម្បីស្វែងរកចំណី ដោយចំណាយពេលហើរច្រើនថ្ងៃ ទើបទៅដល់គោលដៅក៏មាន។ សត្វខ្លះក៏រស់នៅក្នុងជីវិតក្រាំងមិនស៊ីអាហាររយៈពេលច្រើនខែ ឧទាហរណ៍ កង្កែបក្រាំងនៅខែប្រាំង ឬសត្វខ្លាឃ្មុំនៅដំបន់ប៉ូលខាងជើង។ ប៉ុន្តែក៏មានសត្វមួយចំនួន ចេះគិតគូរយកចំណីទៅជីកកប់លាក់ទុក សម្រាប់ពេលក្រោយផងដែរ ឧទាហរណ៍ សត្វក្អែកប្រភេទខ្លះយកចំណីទៅជីកកប់នៅទីតាំងច្រើនកន្លែង ដើម្បីកុំឲ្យក្អែកដទៃទៀតរកឃើញ ហើយក៏មានសត្វក្អែកខ្លះលួចតាមសង្កេតមើលសកម្មភាពជីកកប់លាក់ចំណីនោះ ដើម្បីទៅលួចយកចំណីនោះមកស៊ីក៏មានដែរ។ ពួកសត្វស្វាមួយចំនួនក៏មានវិធីលួចលាក់ចំណីមិនឲ្យស្វាដទៃរកឃើញផងដែរ។ រីឯមនុស្សក៏ជាសត្វដែលត្រូវការចំណីដើម្បីបន្តជីវិតដូចសត្វដទៃ ដូច្នេះ មនុស្សក៏មានល្បិចកលជីកកប់ចំណីលាក់ទុកសម្រាប់យកមកបរិភោគនៅថ្ងៃក្រោយដែរ។ ល្បិចនេះ គឺដុះឡើងក្នុងខួរក្បាលមនុស្សចាប់តាំងពីពេលពូជមនុស្ស ដំបូងៗដែលដើរស្វែងរកចំណីយ៉ាងលំបាកលំបិន។ សូម្បីមកដល់សម័យទំនើបនេះ ដែលងាយរកចំណីក៏ដោយ ក៏នៅមានមនុស្សមួយចំនួន បន្តកើបប្រមូលចំណីលាក់ទុកសម្រាប់ខ្លួនឯង ឬក្រុមគ្រួសាររបស់ខ្លួនដែរ។ ឧទាហរណ៍ជាក់ស្តែង

មនុស្សខ្លះទៅវត្តអារាម ដើម្បីប្រមូលយកចំណីមកផ្ទះវិញ ដោយមិនខ្វីខ្វល់ទុកចំណីខ្លះសម្រាប់មនុស្សដទៃឡើយ។ ភិក្ខុខ្លះក៏មានលាក់អាហារទុក មិនចែកឲ្យកូនសិស្សនៅក្នុងវត្តអារាមអាចទទួលទាន ហើយមានពេលខ្លះអាហារនោះក៏ហួសថ្ងៃកំណត់អាចទទួលទានបាន ឬ ផ្អូមស្អុយខូចមិនអាចបរិភោគបានក៏យកចេញមកប្រគល់ឲ្យកូនសិស្ស។ ទាំងនោះគឺជាអំពើដ៏ថោកទាបដែលមនុស្សមិនគួរនឹងបន្តធ្វើតទៅទៀតសោះ។ បើថ្ងៃនេះយើងមានចំណីអាហារទទួលទាន ហើយយើងចែករំលែកឲ្យមនុស្សដទៃបានបរិភោគដូចយើង ពួកគេក៏សប្បាយរីករាយជាមួយនឹងយើង។ ថ្ងៃក្រោយនៅពេលពួកគេមានចំណីឆ្ងាញ់ ពួកគេនឹកឃើញអំពើល្អរបស់យើង ពេលនោះពួកគេក៏នឹងចែកចំណីឆ្ងាញ់ជាមួយយើងដែរ។

ផ្នែកទី២ ពាក្យថា "ធនធាន" មានអត្ថន័យទូលំទូលាយដែលអាចរាប់បញ្ចូលទាំងចំណីអាហារ ប្រាក់កាស់ ចំណេះដឹង និងបច្ចេកវិជ្ជា។ នៅទីនេះយើងសូមលើកយកអត្ថន័យរបស់ "ធនធាន" ដែលមានន័យត្រឹមតែជាទ្រព្យសម្បត្តិដូចជាលុយកាក់ ឬមាសប្រាក់ប៉ុណ្ណោះ។ បើមនុស្សម្នាក់លាក់បំពួនចំណីអាហារមិនចែករំលែកជាមួយមនុស្សដទៃ មនុស្សម្នាក់នោះ ក៏មានវិធីលាក់បំពួនទ្រព្យរបស់ខ្លួន មិនចែករំលែកជាមួយអ្នកផ្សេងដែរ។ លុយកាក់ ឬមាសប្រាក់ គឺជាវត្ថុងាយស្រួលសម្រាប់យកទៅលាក់ទុក ជាងចំណីអាហារឆ្ងាយណាស់។ សព្វថ្ងៃមនុស្សមានទ្រព្យច្រើន បានយកទ្រព្យទាំងនោះទៅផ្ញើទុកនៅឯធនាគារ ដែលមានសុវត្ថិភាពជាងការលាក់ទុកនៅឯផ្ទះ។ ពេលអ្នកជិតខាង ឬមិត្តភក្តិម្នាក់មកពឹងពរសុំ ឬខ្ចីបុល ជនកំណាញ់នោះក៏ពោលថា គ្មានប្រាក់សេសសល់នៅផ្ទះសម្រាប់ឲ្យខ្ចីបុលទេ។ នៅពេលចូលដល់វ័យចំណាស់ មនុស្សកំណាញ់នោះបន្តប្រើល្បិចចុងក្រោយ ដើម្បីដឹកកប់ទ្រព្យសម្បត្តិរបស់ខ្លួន សម្រាប់បើកយកមកចាយនៅជាតិក្រោយទៀត។ មានសេចក្តីបង្រៀនគួរឲ្យអស់សំណើចមួយថា ពេលស្លាប់មនុស្សមិនអាចយកទ្រព្យទៅតាមខ្លួនបានទេ សូម្បីកាក់ក្រហមមួយសេនក៏យកតាមមិនបានផង។ ប៉ុន្តែពួកគេអាចដាក់ផ្ញើទ្រព្យទាំងនោះ ចូលគណនីរបស់ខ្លួននៅឯធនាគារឋានសួគ៌ ដោយការធ្វើបុណ្យដាក់ទានតាមរយៈភិក្ខុសង្ឃក្នុងពុទ្ធសាសនាជាអ្នកមានសីល។ បើយើងពិចារណាឲ្យល្អិតល្អន់បន្តិច ការធ្វើបុណ្យដាក់ទានតាមភិក្ខុសង្ឃនោះ ក៏នឹងគ្មានវិធីអ្វីអាចផ្ទៀងផ្ទាត់មើលឃើញថា ប្រាក់កាស់ដែលបុគ្គលនោះបានធ្វើបុណ្យទាននោះ ត្រូវបានវេរផ្ទេរចូលក្នុងគណនី នៃធនាគាររបស់គាត់នៅឯឋានសួគ៌ ឬឋាននរកខ្មោចឯណាដែរ។ សេចក្តីបង្រៀនទាំងនោះ គ្រាន់តែជាសិល្បៈលួងលោមមនុស្សឲ្យរៀនលះបង់ទ្រព្យសម្បត្តិ ធ្វើទានដល់មនុស្សក្រីក្រ ដើម្បីឲ្យពួកមនុស្សទាំងនោះបានចំណីបរិភោគគ្រប់គ្រាន់ដូចមនុស្សដទៃ។ តើមាននរណាម្នាក់ហ៊ានចេញមុខមកអះអាងបញ្ជាក់ថា ប្រាក់ដែលគាត់បានធ្វើបុណ្យរាប់សិបឆ្នាំមកហើយនោះ ត្រូវបានភិក្ខុសង្ឃផ្ទេរចូលគណនីរបស់គាត់នៅក្នុងធនាគារ នៅឯឋានសួគ៌ជាន់ទី១០ឬទី៣៣ ដែលមានអាសយដ្ឋានយ៉ាងនេះ ឬយ៉ាងនោះ ហើយមានអ្នកធ្វើការងារនៅធនាគារទីនោះ នឹងប្រើវិធីយ៉ាងណាដើម្បីផ្ទៀងផ្ទាត់ថារូបគាត់ជាម្ចាស់គណនីនោះ។ តើមានអ្នកស្លាប់ប៉ុន្មាននាក់ ដែលបានចេញមុខមកអះអាងបញ្ជាក់ថា គាត់បានបើកលុយកាក់របស់គាត់យកទៅចាយរួចហើយ? អ្វីៗទាំងអស់ដែលមនុស្សបង្កើតឬទាញចេញពីផែនដី ដើម្បីប្រើប្រាស់ក្នុងពេលរស់នៅមានជីវិតនៅលើផែនដី វត្ថុទាំងនោះនឹងត្រឡប់ទៅដីវិញតាមច្បាប់ធម្មជាតិ។ ទោះបីមនុស្សច្រើនជំនាន់ បានបង្កើតច្បាប់សាសនាជាច្រើន ឬអាទិទេពស្នេកស្នះដើម្បីអួតអាងបញ្ជាក់ថា វត្ថុទាំងនោះនឹងត្រូវបានបញ្ជូនទៅកាន់ភពផ្សេង ឬថាមនុស្សនឹងវិលមកកើតលើផែនដីជាថ្មីក៏ដោយ ក៏ជាសត្យានុម័តរឿងនោះគ្មានកើតឡើងសោះឡើយ។ វាគឺជាការបោកប្រាស់បំភ័ន្តភ្នែក និងជាឡប់ឡែ សម្រាប់បន្ធូរទុក្ខព្រួយរបស់មនុស្សងាយជឿតាមការពាក្យបោកប្រាស់ប៉ុណ្ណោះ។ ជាសេចក្តី

សន្និដ្ឋានរួម ប្រសិនបើមនុស្សម្នាក់មានចំណីឆ្ងាញ់នៅថ្ងៃម៉ោងនេះ ឬថ្ងៃនេះ សូមបែងចែកឲ្យមនុស្សដទៃបរិភោគផង ព្រោះចំណីឆ្ងាញ់នោះនឹងស្អុយខូច ទៅជាសម្រាមនៅម៉ោងក្រោយ ឬថ្ងៃស្អែក ឬសប្ដាហ៍ក្រោយ។ ប្រសិនបើបុគ្គលម្នាក់មានទ្រព្យច្រើនចាយមិនអស់ សូមចែកជាទាន បង្កើតជាមូលនិធិជួយជនក្រីក្រ ឬបង្កើតកម្មវិធី ឬគម្រោងផ្សេងៗសម្រាប់ជួយអភិវឌ្ឍសហគមន៍ឬប្រទេស ព្រោះថានៅពេលបុគ្គលនោះស្លាប់បាត់បង់ជីវិត គាត់នឹងក្លាយទៅជាផេះផង់សូន្យចាកអ្វីៗទាំងអស់ សូមកុំសង្ឃឹមថានឹងបានមកកើតជាថ្មី ឬទៅកើតជាទេវតា ឬទៅជួបព្រះអាទិទេពណាមួយឲ្យសោះ។ ទ្រព្យសម្បត្តិដែលគាត់ខំសន្សំ ឬលាក់ទុកទាំងប៉ុន្មាននឹងត្រូវធ្លាក់ចូលទៅក្នុងកណ្ដាប់ដៃមនុស្ស ដែលនៅរស់យកទៅប្រើប្រាស់បន្តទៀត។

### ៣.១.៧. ហេតុដែលនាំឲ្យវិនាសទី៧

### ប្រកាន់ជាតិ ត្រកូល ទ្រព្យ ឋានៈ និងមិនរាប់សាច់ញាតិរបស់ខ្លួន

មុននឹងអាចយល់គំនិតបង្កប់នៅក្នុងគោលការណ៍នេះ យើងត្រូវពិនិត្យមើលសង្គមឥណ្ឌានៅសម័យកាលព្រះពុទ្ធ និងសម័យបច្ចុប្បន្ននេះ ដើម្បីវាយតម្លៃមើលថាតើពួកមនុស្សទាំងនោះបន្តប្រព្រឹត្តតាមទំនៀមទម្លាប់ចាស់គំរិលរាប់ពាន់ឆ្នាំរបស់ពួកគេ ឬមានការកែប្រែក្នុងកម្រិតណា។ យើងបានសិក្សា និង ដឹងរួចហើយថា សង្គមមនុស្សនៅប្រទេសឥណ្ឌាត្រូវបានបែងចែកជា៤ក្រុម ឬវណ្ណៈដាច់ស្រឡះពីគ្នា។ លើសពីនោះទៀតមានមនុស្សមួយក្រុមពិសេសទៀតគឺពួកចណ្ឌាល ដែលជាមនុស្សនៅក្រៅវណ្ណៈទាំង៤ខាងលើ។ មានខជាច្រើននៅក្នុងគម្ពីរ មនុ ដែលពួកមនុស្សនៅក្នុងវណ្ណៈព្រាហ្មណ៍បានតាក់តែងឡើង ដើម្បីគ្រប់គ្រងមនុស្សនៅក្នុងវណ្ណៈដទៃទៀត។ ពួកព្រាហ្មណ៍អះអាងថា ពួកគេជាមនុស្សពិសេសដែលព្រះអាទិទេពចាត់ឲ្យរៀនគម្ពីរវេទ និងគម្ពីរផ្សេងទៀត សម្រាប់រៀបចំពិធីយញ្ញសម្រាប់បូជាអាទិទេព។ ពួកនេះប្រកាន់យ៉ាងតឹងរឹងថា គ្មានមនុស្សណាផ្សេងនៅក្នុងវណ្ណៈផ្សេងទៀតអាចអាន ឬរៀនគម្ពីរវេទ ឬគម្ពីរមនុបានឡើយ ហើយក៏គ្មានមនុស្សវណ្ណៈផ្សេងណា អាចរៀបចំធ្វើពិធីបូជាណាមួយបានដែរ។ មនុស្សស្ទើរតែទូទាំងប្រទេសឥណ្ឌានៅបន្តជឿថាត្រកូលរបស់ពួកគេ ប្រសើរជាងត្រកូលរបស់មនុស្សនៅវណ្ណៈក្រោម។ ការរើសអើងមនុស្សដោយអាងលើកំណើតនៅក្នុងវណ្ណៈខ្ពស់ ឬត្រកូលល្អ បានឆ្លុះបញ្ចាំងឲ្យឃើញអំពើអយុត្តិធម៌ ដែលស៊ីចាក់ជ្រៅចូលដល់ភូមិស្រុកនៅទីកន្លែងឆ្ងាយដាច់ស្រយាល។ មនុស្សនៅក្នុងវណ្ណៈក្រោមគ្មានទ្រព្យសម្បត្តិ ឬដីធ្លីសម្រាប់ប្រកបរបរកសិកម្ម ឬគ្មានចំណេះវិជ្ជាសម្រាប់បម្រើក្នុងសេវាសង្គមណាមួយ ក្រៅពីការដើររើសប្រមូលខ្មោចមនុស្ស ឬខ្មោចសត្វយកទៅដុតចោល ឬកើបលាមកពីបង្គន់របស់មនុស្សនៅវណ្ណៈខាងលើ យកទៅចាក់ចោលនៅទីឆ្ងាយ ដើម្បីជាការដោះដូរយកដុំបាយ ឬអាហារសេសសល់។ ទោះបីមនុស្សនៅវណ្ណៈក្រោមបានរៀនសូត្រចេះដឹងច្រើន និងមានមុខងារខ្ពស់យ៉ាងណា ក៏មនុស្សកំប៉ិកកំប៉ុកនៅក្នុងវណ្ណៈខាងលើបន្តរើសអើង មាក់ងាយមនុស្សម្នាក់នោះ គ្មានថ្ងៃបញ្ចប់សោះឡើយ។ ឧទាហរណ៍ **លោកបណ្ឌិត អាំបិដការ** ដែលជាមនុស្សមកពីវណ្ណៈចណ្ឌាល ដែលបានទទួលរងការមើលងាយមើលថោកគ្រប់ពេលវេលាពីសំណាក់សិស្ស ឬគ្រូដែលជាមនុស្សនៅវណ្ណៈខាងលើ។ នៅសាលារៀន លោកមិនអាចចូលអង្គុយក្នុងថ្នាក់ជាមួយសិស្សផ្សេងទៀត មិនអាចបរិភោគទឹកដោយខ្លួនឯង ព្រោះត្រូវតែមានមនុស្សវណ្ណៈខាងលើម្នាក់ ចាក់ទឹកចេញពីក្អមមកពីទីខ្ពស់ឲ្យ ព្រោះពួកមនុស្សទាំងនោះប្រកាន់មាំថា មនុស្សចណ្ឌាលមិនអាចប៉ះពាល់ទឹករបស់ពួកគេឡើយ។ ការរើសអើងនេះបន្តកើតមានរហូតដល់សកលវិទ្យាល័យដែលលោកទៅបង្រៀន នៅសភាជាតិឥណ្ឌា ដែលលោកគឺជាប្រធានគណៈកម្មការព្រាងច្បាប់រដ្ឋធម្មនុញ្ញហើយក៏ដោយ។ សូម្បីច្បាប់រដ្ឋធម្មនុញ្ញឥណ្ឌា ដែលទទួលបាន

ការបោះឆ្នោតអនុម័តដោយសំឡេងភាគច្រើនក៏ដោយ ក៏មនុស្សនៅវណ្ណៈខាងលើ មិនទទួលយកច្បាប់នោះទៅអនុវត្តភ្លាមៗដែរ ព្រោះគេគិតថា មិនមែនជាច្បាប់ដែលផ្តល់ប្រយោជន៍ដល់ពួកគេ។ នេះជាភស្តុតាងបញ្ជាក់ឲ្យឃើញអំពើរើសអើងដែលបានកើតឡើង និងកំពុងកើតឡើងនៅក្នុងសង្គមឥណ្ឌា។ សព្វថ្ងៃមនុស្សនៅក្នុងវណ្ណៈក្រោមបំផុត កំពុងងើបឡើងតស៊ូប្រឆាំងដោយចំហ ចំពោះការគ្រប់គ្រងប្រកបដោយភាពអយុត្តិធម៌ និងការរើសអើងរបស់មន្ត្រីមកពីវណ្ណៈព្រាហ្មណ៍ និងវណ្ណៈក្សត្រ (ម្ចាស់ដី)។ មនុស្សចណ្ឌាលមួយចំនួនបានផ្លាស់ប្តូរជំនឿពីសាសនាព្រាហ្មណ៍ទៅកាន់សាសនាព្រះពុទ្ធវិញ ព្រោះពុទ្ធសាសនាគ្មានការរើសអើងវណ្ណៈ គ្មានការប្រកាន់ជាតិ ត្រកូល ឋានៈឡើយ។ ពួកមនុស្សចណ្ឌាលមានសេរីភាពដើរហើរ និងចូលបម្រើក្នុងក្រសួងជាច្រើនដោយគ្មានខ្លាចការរើសអើង។ ប៉ុន្តែយើងនៅតែសង្កេតឃើញមានករណីរើសអើង ករណីមនុស្សវណ្ណៈខាងលើ ចាប់រំលោភស្ត្រីជាមនុស្សគ្មានវណ្ណៈ ករណីរដ្ឋាភិបាលមិនរៀបចំខ្វង់ថវិកាសម្រាប់អភិវឌ្ឍដំបន់ដែលមានមនុស្សចណ្ឌាលរស់នៅច្រើន។

ទោះបីនៅប្រទេសកម្ពុជា គ្មានប្រពៃណីប្រកាន់វណ្ណៈដ៏ធ្ងួតលីលា ដូចនៅប្រទេសឥណ្ឌាក៏ដោយ ក៏យើងសង្កេតឃើញក្រុមមេដឹកនាំប្រទេស និងអ្នកជំនួញ ដែលមានប្រាក់រាប់លានដុល្លារើសអើងប្រជាជនក្រីក្រ ឬបុគ្គលិកតូចតាច។ យើងក៏ឃើញមានករណីបងប្អូនឈប់រាប់រកគ្នា ដោយសារតែឋានៈមិនដូចគ្នា ឬទ្រព្យសម្បត្តិមិនច្រើនដូចគ្នា ឧទាហរណ៍ បងប្រុសជាមនុស្សមានប្រាក់រាប់លានដុល្លា ចំណែកប្អូនប្រុសជាជនក្រីក្ររកស៊ីរត់ម៉ូតូឌុប។ បងប្រុសមិនហ៊ានប្រាប់ញាតិមិត្តខាងភរិយាខ្លួនថា មានប្អូនប្រុសម្នាក់ជាអ្នករត់ម៉ូតូឌុបទេ ព្រោះខ្លាចអាម៉ាស់មុខខ្លួន។ នេះគឺជាអំពើរើសអើងដ៏លាមក ដែលកំពុងកើតមាននៅប្រទេសកម្ពុជាសព្វថ្ងៃ។ យើងជាជនជាតិខ្មែរ មិនត្រូវបន្តទំនៀមទម្លាប់រើសអើងដ៏ថោកទាបនេះទៀតទេ ប្រសិនបើយើងមានមោទនភាពជាខ្មែរ ជាប្រទេសធ្លាប់មានវប្បធម៌រុងរឿង និងជាអារ្យប្រទេស។

## ៣.១.៨. ហេតុដែលនាំឲ្យវិនាសទី៨

## ប្រព្រឹត្តល្បែង ៣ ប្រការ

ពាក្យថាល្បែង ៣ ប្រការគឺរាប់បញ្ចូលនូវល្បែងស្រី ល្បែងស្រា និងល្បែងប៉ោវបៀ។ ពាក្យថាល្បែងស្រីគឺសំដៅការចំណាយពេលវេលាទៅលើការដើរហើរជាមួយស្រីកំណាន់ ឬស្រីរកស៊ីផ្លូវភេទ នាំឲ្យបង់ខាតពេលវេលា ប្រាក់កាស់ និងទឹកចិត្ត លើសពីនោះទៀតបុគ្គលនោះអាចនឹងឆ្លងរោគសង្គមដូចជារោគស្វាយ ប្រមេះ ឬអេដស៍ជាដើម។ បើយើងស្រាវជ្រាវរកមើល គំនិតដើមរបស់គោលការណ៍នេះ យើងអាចទាញសេចក្តីសន្និដ្ឋានថា គោលគំនិតដើមគឺការប្រដៅបង្រៀនមនុស្សប្រុស ជាអ្នកប្រតិបត្តិព្រហ្មចរិយធម៌ឲ្យជៀសវាងអំពើទាំងឡាយ ដែលនាំឲ្យពួកគេមិនអាចសម្រេចគោលដៅមោក្ខធម៌។ ប៉ុន្តែមនុស្សប្រុសជាអ្នកគ្រប់គ្រងផ្ទះសម្បែង ក៏អាចយកគោលការណ៍នេះទៅអនុវត្ត សម្រាប់ដឹកនាំជីវិតរបស់ពួកគេឲ្យបានជាប្រយោជន៍ដែរ។ ចំណែកស្ត្រីជាអ្នកប្រតិបត្តិព្រហ្មចរិយធម៌ និងស្ត្រីជាមេផ្ទះក៏អាចគោលការណ៍នេះសម្រាប់ដឹកនាំជីវិតបានដូចគ្នា ដោយគ្រាន់តែប្តូរពីពាក្យថា ល្បែងស្រី ទៅជាល្បែងប្រុស ជាការស្រេច។ សម្រាប់ស្ត្រីជាមេផ្ទះ ពួកគាត់ត្រូវមានភក្តីចំពោះស្វាមី និងគ្រួសារ ដោយមិនត្រូវបណ្តោយចិត្ត និងខ្លួនប្រាណទៅជាឧបករណ៍បម្រើភេទរបស់បុរសដទៃឡើយ។

ពាក្យថាល្បែងស្រា គឺការចំណាយពេលវេលា និងប្រាក់កាស់ទៅលើគ្រឿងស្រវឹង និងគ្រឿងញៀនគ្រប់ប្រភេទ។

ត្រេកអរចំពោះភរិយាខ្លួនជាការប្រពៃ ប៉ុន្តែការលេងល្បែងស្រី រមែងជួបផលអវិជ្ជមានជាច្រើនដូចជា ខូចខាតទ្រព្យដែលមានស្រាប់ ខានបានរកទ្រព្យថ្មី មានបញ្ហាទាស់ទែងគ្នាជារឿយៗ ដើរលេងចោលទ្រព្យសម្បត្តិ ខានថែទាំគ្រួសារ (អាចជាហេតុធ្វើឲ្យប្រពន្ធផិតក្បត់ក៏មាន) ខូចកិត្តិយសខ្លួន និង វង្សត្រកូល មានរឿងអាស្រូវច្រើនមិនចេះចប់ សុខភាពចុះថយជាលំដាប់ ប្រឈមមុខនឹងការឆ្លងជំងឺផ្សេងៗ ជាពិសេសរោគសង្គម និងកាមរោគ។

អ្នកលេងល្បែងស្រា នាំមកនូវគុណវិបត្តិយ៉ាងច្រើនដូចជា វិនាសទ្រព្យសម្បត្តិដែលមានស្រាប់ ខាតពេលមិនបានរកទ្រព្យថ្មី និងខានប្រកបការងារផ្សេងៗ មានរឿងរ៉ាវច្រើន បង្កការឈ្លោះទាស់ទែង និងអំពើហិង្សាញឹកញាប់ និយាយស្តីគ្មានសតិ គ្មានសុជីវធម៌ បាត់បង់សីលធម៌ ខូចភាពថ្លៃថ្នូរ អាចឲ្យគេមើលងាយដល់កូនប្រពន្ធនិងវង្សត្រកូល) មិនបានថែគ្រួសារ ខ្សោយប្រាជ្ញា និងខ្សោយសុខភាពជាលំដាប់។ ល្បែងភ្នាល់គ្រប់យ៉ាង ក៏ធ្វើឲ្យស្រកស្រុតស្រយុតរបូតទ្រព្យសម្បត្តិ យ៉ាងលឿនរហូតលក់កេរមរតក និងប្រព្រឹត្តខុសផ្សេងៗទៀត ដូចជាសំណូកសូកប៉ាន់ ពុករលួយ និងចោរកម្ម នាំឲ្យមានទំនាស់បែកបាក់គ្រួសារ ខូចកេរ្តិ៍ឈ្មោះ ធ្វើឲ្យអ្នកជទែអស់ទំនុកចិត្ត (គេមើលងាយដល់កូនចៅ)។ ហេតុនេះ ល្បែងស្រី ល្បែងស្រា និងល្បែងស៊ីសងល្បែងមួយណាក៏ជាប្រមុខនៃក្តីវិនាសទី៨។

### ៣.១.៩. ហេតុដែលនាំឲ្យវិនាសទី៩

#### បុរសមិនត្រេកអរនឹងប្រពន្ធខ្លួន

ការរួមភេទគឺជាកាតព្វកិច្ចរបស់មនុស្ស សត្វនិងរុក្ខជាតិដើម្បីបន្តពូជពង្សមនុស្ស សត្វនិងរុក្ខជាតិនោះនៅលើផែនដី។ ចំពោះមនុស្ស ការរួមភេទដើរតួលើសពីការបន្តពូជពង្សទៀត។ សត្វ និងរុក្ខជាតិមានពេលវេលារបស់ពួកគេក្នុងការរួមភេទដើម្បីបន្តពូជពង្សរបស់គេ។ ប៉ុន្តែចំពោះមនុស្ស លើសពីតួនាទីបន្តពូជពង្សមនុស្សរួមភេទដើម្បីជាការកម្សាន្តសប្បាយ ឬពង្រឹងចំណងមិត្តភាពរវាងស្វាមីនិងភរិយា ដើម្បីទាក់ទាញឱពុកម្តាយឲ្យចូលរួមក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនៗរបស់ពួកគេ ។ ជាធម្មជាតិ មនុស្សប្រុសក៏ដូចជាសត្វឈ្មោលដែរ ពួកគេរមែងចង់រួមភេទជាមួយនឹងមនុស្សស្រីច្រើនរូប ព្រោះចំណង់ក្នុងការបន្តពូជរបស់ខ្លួនផង និងការកម្សាន្តសប្បាយផង។ ការរស់នៅជាគូស្វាមីភរិយាមួយទល់នឹងមួយ គឺជារឿងរបស់មនុស្សសម័យទំនើបនៅក្នុងវប្បធម៌របស់មនុស្សមួយភាគធំ។ នៅក្នុងវប្បធម៌នៃជនជាតិខ្លះៗ មនុស្សប្រុសបាន និងកំពុងជ្រើសយកមនុស្សស្រីច្រើនរូបធ្វើជាភរិយា ឧទាហរណ៍ នៅក្នុងវប្បធម៌របស់ជនជាតិដែលកាន់សាសនាអ៊ិស្លាម ឬពួកអ្នកកាន់សាសនាគ្រិស្តនៃនិកាយម៉័រម៉ឺន ឬនិកាយស្មបន្ទាល់ព្រះយេហូវ៉ាជាដើម។ ចំពោះមនុស្សប្រុសដែលរស់នៅក្នុងបណ្តាប្រទេស ដែលមានច្បាប់ហាមឃាត់ឲ្យមានតែប្តី ឬប្រពន្ធមួយ ថ្វីត្បិតតែពួកគេមិនយកប្រពន្ធច្រើនមែន ប៉ុន្តែ ពួកគេបែរជាអាចទៅរួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទ ដើម្បីកម្សាន្តសប្បាយ។ ការធ្វើដូច្នោះ នឹងនាំឲ្យមនុស្សប្រុសទាំងនោះបង់ខាតទ្រព្យសម្បត្តិ និងពេលវេលា ថែមទាំងកើតជំងឺឆ្លងតាមផ្លូវភេទដូចជាជំងឺស្វាយ ប្រមេះ ឬអេដស៍ជាដើម។ ដូច្នេះហើយ ទើបព្រះពុទ្ធទ្រង់ទូន្មានថា បុរសដែលមិនត្រេកអរនឹងប្រពន្ធខ្លួន គឺជាប្រមុខនៃក្តិវិនាសទី៩។

### ៣.១.១០. ហេតុដែលនាំឲ្យវិនាសទី១០

#### បុរសចាស់យកស្រីក្មេងធ្វើជាភរិយា

មនុស្សចាស់ដែលសម្រេចចិត្តជ្រើសរើសយកមនុស្ស ដែលមានអាយុក្មេងជាងខ្លួន ធ្វើជាគូកំណាន់តែងជួបប្រទះទុក្ខទោមនស្ស។ ឧទាហរណ៍ ប្រសិនបើមនុស្សប្រុសចាស់ម្នាក់ សម្រេចចិត្តជ្រើសរើសយកស្ត្រីវ័យក្មេងម្នាក់មកធ្វើជាភរិយា បុរសចាស់នោះ ច្បាស់ជាចំណាយពេលវេលាច្រើន ដើម្បីផ្គាប់ចិត្តភរិយាក្មេង។ នៅក្នុងបរិបទដូចគ្នា ស្ត្រីចាស់ម្នាក់ដែលសម្រេចចិត្តជ្រើសរើសយកមនុស្សប្រុសវ័យក្មេងម្នាក់ ធ្វើជាស្វាមី ក៏នឹងជួបទុក្ខទោមនស្សច្រើនមិនខុសគ្នាដែរ។ ទោះជាយ៉ាងណាក៏ដោយ មិនមែនការសម្រេចចិត្តបែបនេះសុទ្ធតែជារឿងមិនល្អទាំងអស់នោះឡើយ។ប្រសិនបើគូស្នេហ៍ទាំងពីរជាមនុស្សមានចិត្តស្មោះ និងសណ្ដោសចំពោះគ្នាពិតប្រាកដមែន នោះពួកគេនឹងមានសុភមង្គលអស់មួយជីវិត។ មានឧទាហរណ៍ច្រើនណាស់សម្រាប់ឆ្លុះបញ្ចាំង និងទូន្មានមនុស្សជំនាន់ក្រោយ ឲ្យចេះសម្រេចចិត្តត្រឹមត្រូវទាក់ទងនឹងការជ្រើសរើសគូកំណាន់ខុសវ័យគ្នានេះ។ ដូច្នេះ ទើបមានពាក្យទូន្មានថា បុរស ឬស្ត្រីវ័យចំណាស់ដែលសម្រេចចិត្តជ្រើសយកស្ត្រី ឬបុរសវ័យក្មេងធ្វើជាភរិយា ឬស្វាមី គឺជាប្រមុខនៃក្ដីវិនាសទី១០។

### ៣.១.១១. ហេតុដែលនាំឲ្យវិនាសទី១១

### ការជ្រើសរើសយកស្ត្រី ឬបុរសដែលជាមនុស្សខ្ជះខ្ជាយធ្វើជាគូកំណាន់

ការសម្រេចចិត្តជ្រើសរើសមនុស្សម្នាក់ធ្វើជាមិត្តភក្តិគឺជារឿងសំខាន់។ លើសពីនោះទៀត ការសម្រេចចិត្តជ្រើសរើសមនុស្សប្រុស ឬស្រីម្នាក់ ធ្វើជាស្វាមី ឬភរិយា ពិតជារឿងសំខាន់យ៉ាងខ្លាំងនៅក្នុងជីវិតរបស់គ្រហស្ថ។ ប្រសិនបើជ្រើសរើសខុស បុគ្គលនោះនឹងជួបប្រទះទុក្ខលំបាកទាំងផ្លូវចិត្ត និងផ្លូវកាយ។

ឧទាហរណ៍ ប្រសិនបើបុគ្គលម្នាក់ជ្រើសគូកំណាន់ចិត្តដែលជាមនុស្សល្ងង់ខ្លៅ បុគ្គលនោះនឹងវលាយបង់ទាំងទ្រព្យសម្បត្តិ និងកិត្តិយស។ ប្រពៃណីខ្មែរ និងប្រពៃណីជនជាតិមួយចំនួននៅលើពិភពលោក បានបណ្ដោយឲ្យឪពុកម្ដាយ ឬចាស់ព្រឹទ្ធាចារ្យ ជាអ្នកសម្រេចចិត្តជំនួសយុវជនក្នុងការជ្រើសរើសគូស្រករ។ ការធ្វើដូច្នេះ មិនមែនសុទ្ធតែបានផលល្អគ្រប់ពេលនោះទេ។ដូច្នេះ ជនជាបណ្ឌិតគួរជៀសវាងការសម្រេចចិត្តខុសក្នុងការជ្រើសយកមនុស្សប្រុស ឬមនុស្សស្រីម្នាក់មកធ្វើជាគូគាប់។ នេះគឺជាប្រមុខនៃក្ដីវិនាសទី១១។

### ៣.១.១២. ហេតុដែលនាំឲ្យវិនាសទី១២

### ជនកើតក្នុងត្រកូលក្សត្រក្រសម្បត្តិប្រាថ្នាចង់ធ្វើជាស្ដេច

បុគ្គលដែលកើតនៅក្នុងត្រកូលក្សត្រ (ឬអ្នកដឹកនាំ) មានចិត្តលោភលន់ ចង់បានអំណាច និងគំនរទ្រព្យសម្បត្តិ[17]។ ជនទាំងនោះគ្មានចំណេះវិជ្ជា គ្មានសមត្ថភាព និងទ្រព្យសម្បត្តិ ប៉ុន្តែបែរជាមានចិត្តចង់ឡើងគ្រងរាជសម្បត្តិ។ ប្រវត្តិសាស្ត្របានបង្ហាញឲ្យឃើញថា ជនទាំងនោះមួយចំនួនបានបង្កើតក្រុមបក្ស និងបង្កចលនាតស៊ូបដិវត្ត ដើម្បីផ្ដួលរំលំស្ដេចកំពុងគ្រងរាជសម្បត្តិ។ នៅពេលបានអំណាចនៅក្នុងកណ្ដាប់ដៃ ជនទាំងនោះមិនគិតគូរដល់ការកសាងជាតិ កសាងសមត្ថភាព និងអប់រំកែលម្អប្រជារាស្ត្រឲ្យបានសេចក្ដីសុខចម្រើនទេ។ ជាលទ្ធផលប្រទេសជាតិធ្លាក់ចូលក្នុងភាពអន្តរាយ វលាយទ្រព្យសម្បត្តិ ប្រជារាស្ត្រធ្លាក់ក្នុងទុរ្ភិក្សក្រីក្រ ស្រេកឃ្លាន ទីបំផុតសង្គ្រាមកាប់សម្លាប់គ្នាបានកើតឡើងបន្តបន្ទាប់គ្មានទីបញ្ចប់។

## ៣.២. ការបណ្ដុះនិស្ស័យស្មោះត្រង់

បណ្ដុះនិស្ស័យស្មោះត្រង់

---

[17] សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត តតិយភាគ ភាគ៥៤ ទំព័រទី ៣៦

សេចក្តីស្មោះត្រង់ជាមកុដសិរីផ្តល់ឲ្យនូវកេរ្តិ៍ឈ្មោះ ជាកំពូលនៃការជឿ ការស្តាប់ការទុកចិត្ត របស់មនុស្សដទៃ ជាគុណធម៌ខាងដើមនិងទីបំផុតនៃសេចក្តីល្អទាំងឡាយ ជាមគ្គុទ្ទេសដ៏ប្រសើរ ដែលយើងគួររកទុកដើម្បីនាំផ្លូវយើងទៅកាន់សេចក្តីល្អ ដ៏ទៃទៀតតាមដែលត្រូវការ។ អ្នកណាពាក់មកុដគឺការស្មោះត្រង់នេះ ហើយអ្នកនោះឈ្មោះថាជាអ្នកមានថ្វីដៃដែលជាជំនឿស្តាប់ទុកក្នុងចិត្តនៃមនុស្សដទៃ ប្រកាសកេរ្តិ៍ឈ្មោះរបស់ខ្លួនឱ្យគឹកកងទូទៅក្នុងលោកមិនឈប់។ មានសុភាសិតដែលប្រសូត្រចេញពីព្រះឱស្ឋព្រះសម្មាសម្ពុទ្ធថា **សច្ចំ វេ អមតា វាចា** សេចក្តីស្មោះត្រង់ជារបស់មិនស្លាប់។

សេចក្តីស្មោះត្រង់ ជាធម៌គួរនិយាយរឿយៗ គួរប្រដៅញយៗ គួរនាំគ្នាអប់រំឱ្យបានញឹកញាប់ ត្រូវសន្សំទុកនៅក្នុងសន្តានជានិច្ច កុំបណ្តែតបណ្តោយ ព្រោះមនុស្សវៀចវេរ នៅមានក្នុងលោកនៅឡើយ។ សូម្បីតែនៅក្នុងផ្ទះរបស់មនុស្សសូមទាន ក៏គង់ត្រូវសេចក្តីវៀចវេរដឹកនាំឱ្យវង្វេងលេងកល់មាយា លបបើករពងល្បែង ដោយប្រើផ្លូវពីរដែរគឺវៀច និងត្រង់លាយគ្នា នៅមុខថ្វាយបង្គំ នៅក្រោយឡក មុខត្រង់ចិត្តវៀច។

អ្នកដែលមន្ទិលដឹកនាំ ឱ្យក្លាយទៅជាមនុស្សវៀច តែងវង្វេងភ្លើតភ្លើន ក្នុងកម្មរបស់មនុស្សវៀច មិនយល់ឃើញដល់ការធ្វើខ្លួនឱ្យជាទីស្រឡាញ់ជាទីទុកចិត្តជាទីជឿ ជាទីរាប់អាន នៃមនុស្សដទៃជាសំខាន់ឡើយ ឃើញតែការវៀចវេរ ការទុច្ចរិត ការខុសសន្យា ការមិនសងបំណុល ការពោលកុហក ការប្រហើនកោងកាច និងការលលួចតែម្យ៉ាង ថាជារបស់សំខាន់ និងឃើញតែប្រយោជន៍ចំពោះខ្លួនតែប៉ុណ្ណោះ។

ការវៀចវេរជាហេតុឲ្យងងិតមានការវៀចង លំអៀងក្លែងក្លាយ ប្រែប្រួលត្រឡប់ត្រឡិន នៃអធ្យាស្រ័យ និងដំណើរប្រព្រឹត្តទៅរបស់បុគ្គលជាលក្ខណៈ មានអាការងងិតងងល់បិតបាំងខូចភ្នែក បែកចិត្តលាក់លៀមលលួច នៅក្នុងសន្តានជាគ្រឿងចំណាំឱ្យស្គាល់ថា ជាមនុស្សពាល។

សម្រាប់អ្នកស្មោះត្រង់វិញឃើញថា ការឱ្យគេជឿទុកចិត្ត រាប់អាន ជាជីវិតដ៏ប្រសើរ មនុស្សស្មោះត្រង់តែងធ្វើត្រឹមត្រូវតាមធម៌ រក្សាពាក្យសន្យា មិនពោលកុហកបោកប្រាស់ ប្រកាន់ខ្ជាប់នូវសច្ចធម៌ គ្រប់ត្រៃទ្វារ និងការនិយាយអ្វី ក៏មានមនុស្សស្តាប់ មនុស្សជឿ មានភាពកក់ក្តៅ មិនក្តៅក្រហាយចិត្ត។ មនុស្សវៀចវេរប្រតិបត្តិសេចក្តីស្មោះបានដោយលំបាក មនុស្សស្មោះត្រង់ទើបប្រតិបត្តិបានដោយងាយ តែប្រតិបត្តិសេចក្តីវៀចវេរបានដោយកម្រ លុះតែអ្នកវៀចវេរទើបប្រតិបត្តិបានដោយងាយ។

ការស្មោះត្រង់ជាហេតុធ្វើឱ្យរុងរឿង មានការស្មោះត្រង់ទៀងទាត់ ជាក់លាក់ពិតៗនៃអធ្យាស្រ័យ និងសេចក្តីប្រព្រឹត្ត របស់បុគ្គលជាលក្ខណៈ មានការផ្សាយរស្មីភ្លឺរុងរឿង ប្រាស់ចាក់មន្ទិលទោស និងការពិរុទ្ធគ្រប់យ៉ាងជាដួងរស្មីភ្លឺថ្លាជុំវិញ ធ្វើឱ្យទឹកមុខមនុស្សស្មោះត្រង់ ស្អាតផូរផង់អស់គ្រឿងសៅហ្មង ជារបស់បរិសុទ្ធក្នុងខ្លួនឯង។ មនុស្សស្មោះត្រង់កាន់យកសច្ចធម៌ជាទីតាំង រក្សាសេចក្តីទៀងត្រង់ជាធំ មិនក្លែងមិនសម្តែងខ្លួនឲ្យល្អលើសការពិត រក្សាខ្លួន និងការងាររបស់ខ្លួនគ្រប់យ៉ាងឲ្យដូចគ្នាដោយសេចក្តីស្មោះត្រង់ជាគោល។ ដូចមានពុទ្ធភាសិតលើកឡើងថា **សាធុ រូបោ ច បាសំសោ ទ្វារត្តយេន សច្ចវា** សេចក្តីស្មោះត្រង់ដែលបំណងយកក្នុងទីនេះ មិនមែនសំដៅយកតែការប្រព្រឹត្តទៀងត្រង់ តាមផ្លូវវាចា១ទេ គឺត្រូវប្រកបដោយសេចក្តីស្មោះត្រង់គ្រប់ទ្វារទាំងអស់ ឲ្យដូចគ្នាទាំងខាងក្រៅទាំងខាងក្នុង។ សេចក្តីស្មោះត្រង់មានលក្ខណៈដែលប្រាកដក្នុងរូបបុគ្គលនោះ៦ ប្រការគឺ ស្មោះត្រង់ចំពោះខ្លួនឯង ស្មោះត្រង់ចំពោះវាចា ស្មោះត្រង់ចំពោះការងារ ស្មោះត្រង់ចំពោះនាទី ស្មោះត្រង់ចំពោះបុគ្គល នឹងស្មោះត្រង់ចំពោះគណៈ។

**១ ស្មោះត្រង់ចំពោះខ្លួនឯង**

ការចង់បានល្អ ចង់បានសុខ ជាកំពូលបំណងរបស់មនុស្សគ្រប់គ្នា គ្មាននរណាសូម្បីត្រឹមតែម្នាក់ ចង់បានទុក្ខ ចង់បានអាក្រក់ឡើយ តែបើចង់បានឲ្យដូចប្រាថ្នា ត្រូវតែជាមនុស្សស្មោះត្រង់ចំពោះខ្លួនឯង ប្រព្រឹត្តល្អឲ្យត្រង់គ្នា និងគោលបំណងរបស់ខ្លួនឯង គឺធ្វើល្អវៀរអាក្រក់ ដើម្បីឲ្យខ្លួនបានល្អ បានសុខផុតពីទុក្ខ ធ្វើអំពើល្អដែលខ្លួនបំណងនោះឲ្យបានល្អបំផុត លះបង់អំពើអាក្រក់ឲ្យដាច់ស្រឡះ និងវៀរអំពើអាក្រក់ឲ្យឆ្ងាយក្រៃលែងកំសាវ៉ាក្នុងកាលប្រព្រឹត្ត សេចក្ដីល្អយ៉ាងណា ត្រូវប្រព្រឹត្តធ្វើយ៉ាងនោះ កុំភូតភរ នៅចំពោះមុខគេប្រព្រឹត្តយ៉ាងណា សូម្បីកំបាំងមុខគេ ក៏ត្រូវប្រព្រឹត្តយ៉ាងនោះ កុំសង្ស័យក្នុងកាលដែលមិនបានទទួលផលនៃសេចក្ដីល្អ ដែលខ្លួនបានប្រព្រឹត្តកុំខ្លាច ឬញាប់ញ័រក្នុងកាលដែលអ្នក ដទៃពោលចាក់រុក ឬឡកឡឺយឲ្យ សូម្បីមានពួកច្រើនដឹកនាំទៅ ដើម្បីឱ្យខូចបង់សេចក្ដីល្អរបស់ខ្លួន និងរក្សាខ្លួនឱ្យគង់វង្សនៅល្អជានិច្ច។ បើធ្វើបានដូច្នោះ បានឈ្មោះថា ជាមនុស្សរឹងប៉ឹងខ្ជាប់ខ្ជួនក្នុងសេចក្ដីល្អ មានសេចក្ដីស្មោះត្រង់ចំពោះខ្លួនឯង អាចនឹងប្រព្រឹត្តសេចក្ដីល្អបានយូរអង្វែង។

មនុស្សវៀចវេរចំពោះខ្លួនឯង សូម្បីចង់ល្អក៏មិនអាចប្រព្រឹត្តសេចក្ដីល្អឱ្យពេញលេញបាន ព្រោះថាចង់ល្អតែចូលចិត្តធ្វើការងារលើបលៗលេងៗល្បិចៗ តិចៗ មិនជាដុំកំភួន ខ្ជិលច្រអូសចំពោះការងារធ្ងន់និងការធំៗដែលជាដុំកំភួន ខ្ជិលច្រអូសចំពោះការងារតូចតាច ដែលមានតម្លៃច្រើន ដោយឃើញថា ជាការងារថោកទាបជាការងារសម្រាប់ថ្នាក់កម្មករ ជាការងារដែលនាំឱ្យអាប់មុខ។ កាលចង់បានល្អតែមិនបានផលល្អភ្លាមៗហើយក៏កើតខ្សោយកម្លាំងចិត្តលែងធ្វើការងារអ្វីឱ្យជាធំដុំតទៅទៀត ប៉ុនតែខាង កុហកបញ្ឆោតខ្លួនឯង មានការខ្ជិលច្រអូសជាត្រីមុខ សម្គាល់ការខ្ជិលច្រអូសថាជាការប្រសើរ ចិត្តមិនស៊ូ ចូលចិត្តអាងលេស អាងហេតុបន្តិចបន្តួចថា ព្រឹកពេក ល្ងាចពេក ក្ដៅពេក ត្រជាក់ពេកជាដើម ចាំស្អែកសឹមធ្វើ តែលុះព្រឹកឡើងក៏មិនធ្វើ ឬសូម្បីធ្វើខ្លះ ក៏គ្រាន់តែជាអាការលើបលល្បិចល្បើមប៉ុណ្ណោះ។ ជាមនុស្សត្រឡប់ត្រឡិនធ្វើមិនពិតប្រាកដតាមសេចក្ដីល្អ ជាមនុស្សមានពុតត្បុតធ្វើល្អតែនៅចំពោះមុខគេ ជាមនុស្សសាថេយ្យអួតអាងធ្វើដោយបំណងនឹងបង្អួតគេជាមនុស្សធ្វើល្អយកមុខ គឺបើសេចក្ដីល្អនោះជាការជួយអនុគ្រោះមនុស្សដទៃ និងជាកិច្ចដែលត្រូវធ្វើទាំងចំពោះមុខ និងក្នុងទីកំបាំងមុខ ក៏បែជាធ្វើត្រឹមត្រូវត្រឹមតែចំពោះមុខ ទាំងជាមនុស្សកុហកលោក គឺធ្វើល្អដោយបំណងឱ្យមនុស្សជាច្រើន ច្រឡំរាប់អានខ្លួនថាជាមនស្សល្អ កាលគេទៅអស់ហើយ ក៏លែងធ្វើសេចក្ដីល្អនោះវិញ នេះជាអាការលោក់កំនួច មនុស្សវៀចវេរចំពោះខ្លួនឯងទាំងអស់។

មនុស្សគ្រប់គ្នាចូរមានការស្មោះត្រង់ចំពោះខ្លួនឯងកុំកុហកបញ្ឆោតខ្លួនឯង កុំជាមនុស្សត្រឡប់ត្រឡិន កុំជាមនុស្សបោកប្រាស់ កុំជាមនុស្សសាថេយ្យ កុំជាមនុស្សធ្វើល្អយកមុខ កុំជាមនុស្សវង្វេងលោក និងកុំជាមនុស្សទោរទន់តាមសំដីដែលគេដឹកនាំឱ្យខូចសេចក្ដីល្អឡើយ ចូរអាស្រ័យតែផលរបស់សេចក្ដីល្អ សន្សំតែសេចក្ដីល្អ អភិរម្យតែក្នុងសេចក្ដីល្អ និងចូលប្រកបតែសេចក្ដីល្អឱ្យខ្ជាប់ខ្ជួន កុំអាស្រ័យនៃសេចក្ដីល្អហើយទម្លាយខ្លួនឯង ដោយការវៀចវេរឡើយ បើមិនដូច្នោះទេ នឹងត្រូវគេតិះដៀលថាគ្រាន់តែជាស្រមោលរបស់មនុស្សន។ ព្រោះមនុស្សវៀចវេរ សូម្បីមានសាច់ស្បែកជារូបរាង គេអាចឃើញប្រាកដ ដោយភ្នែកបាន ក៏រាប់ថាត្រឹមតែជាស្រមោលមនុស្សតែប៉ុណ្ណោះ។

**ប្រការដែលស្មោះត្រង់ចំពោះខ្លួនឯងនោះមានបីចំណុចគឺ**

ស្មោះត្រង់ដោយកាយ ស្មោះត្រង់ដោយវាចា និងស្មោះត្រង់ដោយចិត្ត។

នៅក្នុងអត្ថន័យនេះយើងអាចលើកយកពុទ្ធភាសិតដែល**ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា៖**

**១. យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ។**

អ្នកណាគប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់១ពាន់ៗដង គឺមួយលាន ចំណែកអ្នកណាឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះឈ្មោះថា ជាមនុស្សខ្ពង់ខ្ពស់ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ។

**២. អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា អត្តទន្តស្ស បោសស្ស និច្ចំ សញ្ញតចារិនោ**

**នេវ ទេវោ ន គន្ធព្វោ ន មារោ សហ ព្រហ្មុនា ជិតំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ។**

ខ្លួនឯងដែលឈ្នះហើយប្រសើរជាងចំណែកពួកសត្វក្រៅពីនេះដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុរសមានខ្លួនទូន្មានល្អហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្មមិនគប្បីធ្វើនូវជ័យជំនះ របស់សត្វមានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ។

**២. ស្មោះត្រង់ចំពោះវាចា**

លក្ខណៈនៃការស្មោះត្រង់ចំពោះវាចានេះ គេអាចដឹងបានត្រង់ការរក្សាវាចាឱ្យនិយាយតែតាមរឿងពិត និង ធ្វើឱ្យពិតតាមពាក្យនិយាយ គឺរក្សាសំដីឱ្យនិយាយតែតាមសភាពពិតក្នុងការដឹកនាំគ្នាដោយវាចា នឹងរក្សាឱ្យតាមវាចាដែលនិយាយដឹកនាំគ្នានោះ។

វិស័យអ្នកស្មោះត្រង់ចំពោះវាចានោះ សូម្បីនៅក្នុងទីកណ្តាលអាវុធច្រូងច្រាង ក៏មិនចរចាយ៉ាងដទៃក្រៅពីវាចាសច្ចៈរបស់ខ្លួនដែរ មានលក្ខណៈស្មោះត្រង់ចំពោះវាចាពិតៗ ឥតមាននរណាអាចទម្លាយបាន ទើបគួរចាត់មនុស្សបែបនេះ ថាជាអ្នករឹងជំហរក្នុងវាចារបស់ខ្លួនគ្រប់ពេលវេលា។

មនុស្សស្មោះត្រង់ចំពោះវាចា ជាអ្នកមានមារយាទរៀបរយ ឱនលំទោន ធ្វើអ្វីក៏ជារបៀប មានសច្ចធម៌ជាឫសកែវ នេះជាលក្ខណៈនៃមនុស្សដែលពេញជាមនុស្ស បើផ្ទុយពីនេះវិញ ក៏ជាលក្ខណៈម្រឹគក្នុងព្រៃ។ មនុស្សវៀចវេរស្វែងរកសេចក្តីល្អដើម្បីខ្លួន ដោយការប្រចុបប្រចែងញុះញង់ជានិច្ច មិនជួយគិតមិនជួយពិចារ-ណាជួយតែប្រចុបប្រចែងប៉ុណ្ណោះ គឺចេះតែហៃអើ ទាំងក្នុងកាលដែលគេធ្វើខុស ទាំងក្នុងកាលដែលគេធ្វើត្រូវ សរសើរគេទាំងក្នុងទីចំពោះមុខ លុះកំបាំងមុខក៏និន្ទា ចូលចិត្តសរសើរមនុស្សដែលគួរតិះដៀល និង តិះដៀលមនុស្សដែលគួរសរសើរ។ ឯមនុស្សស្មោះត្រង់វិញ តែងស្វែងរកសេចក្តីល្អដើម្បីខ្លួនដោយវាចាស្អាត ប្រាសចាកទោសជាគ្រឿងសៅហ្មងរបស់វាចា និងដោយការងារសុចរិតជាគ្រឿងបរិសុទ្ធរបស់កាយកម្ម។

លក្ខណៈនៃសេចក្តីស្មោះត្រង់ ចំពោះវាចាដែលត្រូវរក្សាឲ្យបានត្រឹមត្រូវ**មានបីសណ្ឋានគឺ**

១. សំបថៈ ការឲ្យសំដីហ្មតចត់របស់ខ្លួនដល់អ្នកដទៃ ជាលក្ខណៈនៃសំបថៈ។ បើសំដីពោលហ្មត់ចត់ដល់នរណាក៏ពោលដោយសុទ្ធចិត្តពិតៗ ដូចជាឲ្យពាក្យសច្ចាប្រណិធានថា (នឹងមិនធ្វើឬធ្វើ) ដូច្នេះហើយ ក៏មិនគិតបិទបាំងទុក ខំរក្សាឲ្យប្រព្រឹត្តទៅតាមសំបថនោះ ហៅថា រក្សាសំបថ។ មនុស្សទាំងឡាយគប្បីថែរក្សាសំបថទុកឱ្យស្មើនិងជីវិត បើទុកជាត្រូវខូចបាត់បង់ជីវិតក៏កុំឲ្យខូចបង់សច្ចៈ។

២. ប្តេជ្ញា អ្នកឱ្យពាក្យទទួលព្រមដល់អ្នកដទៃថា នឹងធ្វើ ឬ នឹងមិនធ្វើ ជាលក្ខណៈនៃការប្តេជ្ញា ដែលយើងឲ្យដល់អ្នកដទៃនោះទោះឲ្យក្នុងផ្លូវជានាអះអាងថា នឹងធ្វើក្តី ទោះនៅក្នុងផ្លូវលះរៀវថា នឹងមិនធ្វើក្តី ក៏រួមហៅថា ប្តេជ្ញា ដូចគ្នាទាំងអស់ ការឲ្យប្តេជ្ញាចំពោះគេយ៉ាងណាហើយខំរក្សាឲ្យប្រព្រឹត្តទៅយ៉ាងនោះ ហៅថា រក្សាពាក្យប្តេជ្ញា។

៣. សន្យា ការឲ្យពាក្យយល់ព្រមដល់គ្នានិងគ្នា នៃលក្ខណៈនៃពាក្យសន្យា ការឲ្យពាក្យយល់ព្រមនោះ សូម្បីយើងធ្វើទៅដើម្បីឃុំគ្រងដើម្បីផ្លូវច្បាប់ទម្លាប់ដែលហៅថា នីតិក្រមក្តី ធ្វើទៅដើម្បីប្រយោជន៍ដទៃទៀតក្តី គង់ហៅថា សន្យាទាំងអស់។

ស្មោះត្រង់ដោយវាចា គឺការពោលតែកថាទាំងឡាយណា ដែលជាបទប្រកបដោយប្រយោជន៍ដូចមានព្រះពុទ្ធដីកាជាទឡ្ហីករណ៍ដូចខាងក្រោម៖

១. សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ។

២. សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ។

បើគាថាសូម្បីមួយពាន់ ជាគាថាប្រកបដោយបទ ឥតប្រយោជន៍ គាថានោះពុំប្រសើរឡើយអ្នកណាស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែមួយបទក៏ឈ្មោះថាប្រសើរជាង។

យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ។

អ្នកណាគប្បីពោលគាថាមួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយនោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន បទនៃធម៌នោះ សូម្បីមួយបទក៏ឈ្មោះថាប្រសើរជាង ។

**៣. ស្មោះត្រង់ចំពោះការងារ**

ការមាននិស្ស័យស្រឡាញ់ការងារធ្វើអ្វីតាំងចិត្តឲ្យពិតៗមានសសម្បត្តិនៃសេចក្តីព្យាយាមទាំងបីប្រការគឺការព្យាយាមការឧស្សាហ៍និងការភ្ញាក់ព្រកហ្មត់ចត់ ដែលជាគ្រឿងលើកកម្លាំងចិត្ត ឲ្យរឹងប៉ឹងខ្ជាប់ខ្ជួនក្លាហានប្រាចាកកុសិតភាពនិងការច្រអូសមិនពត់ នេះចាត់ជាលក្ខណៈនៃសេចក្តីស្មោះត្រង់ចំពោះការងារ។ និស្ស័យស្មោះត្រង់ចំពោះការងារនេះ មានសេចក្តីស្រឡាញ់ការងារយ៉ាងអស់ពីចិត្ត មានការយកចិត្តទុកដាក់ ពិតៗមានការទទួលភារៈ ហាក់ដូចជាចង់ប្រណាំងប្រជែង មានការតាំងចិត្តធ្វើយ៉ាងម៉ឺងម៉ាត់ និងមានការយកចិត្តទុកដាក់ ពិនិត្យពិច័យយ៉ាងហ្មត់ចត់ជា លក្ខណៈ។

មនុស្សគ្រប់គ្នាត្រូវបណ្តុះនិស្ស័យស្រឡាញ់ការងារ កុំធុញទ្រាន់ចំពោះការងារ កុំនឿយណាយចំពោះសេចក្តីលំបាក កុំរុញរាចំពោះឧបសគ្គ ចូរប្រតិបត្តិតាមច្បាប់ដូចខាងក្រោមនេះ៖

១. ផ្តង់ដៃប្រកបការងារ ធ្វើកិច្ចនាទីតាមធុរៈរបស់ខ្លួន កុំនៅស្ងៀម កុំជាមនុស្សទម្រន់ ព្រោះចិត្តដែលទម្រន់គឺជាកំពែងដែលរាំងខាំងសេចក្តីល្អគ្រប់ផ្លូវ។

២. ត្រូវបណ្តុះឆន្ទៈ ឲ្យរួមគ្នាក្នុងកាលធ្វើកិច្ចការអ្វីមួយ និងចម្រុះសេចក្តីព្យាយាមទាំងអស់ ក្នុងកិច្ចការនោះតែម្យ៉ាង កុំរាយមាយ និងចម្រុះសេចក្តីព្យាយាមទាំងអស់ក្នុងកិច្ចនោះតែម្យ៉ាង។

៣. ត្រូវតាំងខ្លួនទុកដូចជាអ្នក ដែលចង់ប្រជ្រៀតគេចូលទៅក្នុងចន្លោះ ទ្វារដែលមានពួកមនុស្សខ្ជាន់ខ្ជាប់ដូច្នោះ គឺត្រូវប្រឹងប្រែងធ្វើការងារ មិនខ្ជិលច្រអូសនៅស្ងៀមដោយហេតុណានីមួយឡើយ។

៤. បើជួបរបស់ណាដែលជានាទីរបស់ខ្លួនហើយ គប្បីតាំងចិត្តធ្វើរបស់នោះឲ្យបានពេញទី ពេញចិត្តកុំប្រមាថ គប្បីប្រញាប់ប្រញាល់ប្រកបកិច្ចការងារនោះឲ្យទាន់ពេលវេលា ប្រយ័ត្នកុំឲ្យហួសកាលវេលាតាំងធ្វើឲ្យបានល្អបំផុត។

៥. ប្រព្រឹត្តឱ្យខ្ជាប់ខ្ជួនក្នុងកិច្ចការងារដែលខ្លួនប្រកប មិនត្រូវរើុះដោះដៃភ្លាមៗនោះទេ ត្រូវអត់ធន់ព្យាយាមប្រកបដោយការយកចិត្តទុកខ្ពស់ ចំពោះការងារនោះៗដោយមានការប្រុងប្រយ័ត្ន កុំឲ្យប្រែប្រួលនឹងធ្វើអ្វី ត្រូវធ្វើឲ្យបានពិតៗ។

**៤. ស្មោះត្រង់ចំពោះមុខក្រសួង**

មុខក្រសួងបានដល់ករណីយកិច្ច ចំណែកខ្លួន និងករណីយកិច្ចដែលខ្លួនបានទទួលយល់ព្រម ធ្វើជាមួយអ្នកដទៃ ឬធ្វើដោយទំនើងចិត្តខ្លួនឯងព្រមទាំងការងាររបស់ញាតិមិត្ត ពួក គណៈ ដែលគួរជួយដោយសាមគ្គីធម៌ ដែលខ្លួនត្រូវទទួលខុសត្រូវតាមឋានៈរបស់ខ្លួនផង ដូចយ៉ាងខ្លួនជាឪពុកម្តាយរបស់គេ ជាបុត្តធីតារបស់លោក ឬជាអ្នកគ្រប់គ្រងគេ ជាអ្នកនៅក្រោមការគ្រប់គ្រងរបស់លោក កាលបើការងារនោះដំណើរទៅដោយរៀបរយល្អ ក៏ជាសេចក្តីល្អរបស់យើងបើវិនាសអន្តរាយខូចខាតទៅ ក៏ជាសេចក្តីរបស់យើង។

អ្នកស្មោះត្រង់ចំពោះមុខក្រសួង រមែងប៉ុនប៉ងដើម្បីធ្វើកិច្ចការ ក្នុងមុខក្រសួងដោយសេចក្តីទៀងត្រង់ និងដោយមានការអត់ធ្មត់ ប្រកាន់ពេលវេលាថា ជាតួគោលច្បាប់ទម្លាប់ដែលគេតាំងឡើងដោយប្រាសចាកអគតិ។

**៥. ស្មោះត្រង់ចំពោះបុគ្គល**

ការស្មោះត្រង់ចំពោះបុគ្គល ជាអាការសំខាន់បំផុត ក្នុងកិច្ចទំនាក់ទំនងជាមួយមនុស្សដទៃ នាំកើតសេចក្តីស្រឡាញ់ស្និទ្ធស្នាលទុកចិត្តគ្នាទៅវិញទៅមក។ អ្នកណាមិនស្មោះត្រង់ចំពោះអ្នកដទៃ អ្នកនោះរមែងមិនជាអ្នកទុកចិត្តនៃអ្នកដទៃទម្លាយខ្លួនឯងឲ្យសាបសូន្យខូចកិត្តិយស មិនមាននរណានឹងរាប់អានជឿទុកចិត្តសូម្បីធ្វើការទាក់ទងជាមួយនឹងនរណា ក៏គេមិនទុកចិត្ត មានតែគេរង្កៀសសង្ស័យ មិនប្រាថ្នានិងសមាគមរួមជាមួយទៅវិញ ដូច្នេះ យើងទើបត្រូវតែស្មោះត្រង់ចំពោះគ្នានិងគ្នា។

សេចក្តីស្មោះត្រង់ថ្នាក់នេះមានបីប្រភេទ ហៅឈ្មោះតាមអាការថា ស្មោះត្រង់ចំពោះមិត្ត១ គោរពកោតក្រែង១ និងកតញ្ញូកតវេទី១។

១. ស្មោះត្រង់ចំពោះមិត្ត គឺជាមនុស្សប្រព្រឹត្តត្រង់មិនវៀចវេរចំពោះមិត្តភក្តិ។

២. គោរពកោតក្រែង ការស្រឡាញ់គោរពកោតក្រែងចំពោះ នាយចៅហ្វាយ ឬប្រមុខរបស់ខ្លួន មិនគិតវៀចវេរទុយ៌សចំពោះលោកដូចជា គោរពចំពោះខ្លួនឯង មានទឹកចិត្តកោតក្រែងពិតៗធ្វើខ្លួនឲ្យជាកម្លាំងក្នុងកិច្ចការសារពើៗ។

៣. កតញ្ញូកតវេទី ភាពជាអ្នកដឹងគុណ ឬឧបការៈដែលលោកធ្វើចំពោះខ្លួន ហើយមិនលុបគុណលោក និងប្រកាសគុណរបស់លោក ដែលមានចំពោះខ្លួនឲ្យប្រាកដដល់អ្នកដទៃ មិនបំបាត់គុណលោកតបស្នងសងគុណលោកនិងគោរពរាប់អានតំកល់លោកក្នុងតំណែងជាអ្នកមានឧបការៈ នេះជាលក្ខណៈនៃកតញ្ញូកតវេទី។ មនុស្សកតញ្ញូឃើញគុណថាជាគុណ ឃើញទោសថាជាទោស គោរពកោតក្រែងចំពោះលោក អ្នកមានគុណ និងគោរពរាប់អើពើជឿស្តាប់លោក និងរឭកតែសេចក្តីល្អរបស់លោកអំពីមុនមក ទាំងក្នុងទីចំពោះមុខ និងទាំងក្នុងទីកំបាំងមុខ។

អទ្ធា ឯសោ សតំ ធម្មោ យោ មិត្តោ មិត្តមាបទេ ន ចជេ ជិតស្សាបិ ហេតុ ធម្មមនុស្សរំ។

មិត្តណាកាលឮកឃើញនូវធម៌ ហើយមិនលះបង់មិត្តក្នុងកាលដែលមានសេចក្ដីអន្តរាយ ព្រោះហេតុនៃជីវិត ធម៌របស់មិត្តនោះ ឈ្មោះថា ជាធម៌របស់សប្បុរសដោយពិត។ (នៅក្នុងបិដកលេខ៦១ ទំព័រ៩៩ ក្នុងរឿងចុល្លហំសជាតក រាជហង្សឈ្មោះធតរដ្ឋ ហង្សសេនាបតីឈ្មោះថាសុមុខៈ។

**៦. ស្មោះត្រង់ចំពោះគណៈ**

ធម្មតាមនុស្សយើងតែងត្រូវការ នៅរួមគ្នាជាមួយពួកគណៈ មានគ្រប់គ្រង និងមានច្បាប់ទម្លាប់ របៀបសម្រាប់ឱ្យធ្វើនិងហាមឃាត់ ដើម្បីការពារនូវការបៀតបៀនគ្នានិងគ្នា ទើបនូវរួមគ្នាបានដោយសេចក្ដីស្ងប់ ស្ងៀម។ បើមនុស្សក្នុងពួកគណៈទាំងនោះទាំងអ្នកតូចទាំងអ្នកធំ មិនមានសេចក្ដីស្រឡាញ់ចំពោះពួកគណៈ មិនមានសេចក្ដីស្មោះត្រង់គោរពកោតក្រែង មិនកតញ្ញូនិងសេចក្ដីសុចរិត មិនប្រតិបត្តិ តាមច្បាប់ទម្លាប់ ឬក៏ងាកចិត្តចេញពីគ្នានិងគ្នា ពួកគណៈនោះនិងតាំងនៅមិនបាន ព្រោះពួកគណៈឬជាតិ អាចតាំងនៅខ្ជាប់ខ្ជួន និងចំរើនទៅបាន ក៏ព្រោះសេចក្ដីស្មោះរបស់មនុស្សក្នុងពួកគណៈឬពលរដ្ឋនោះៗ[18]។

**ស្មោះត្រង់ចំពោះគណៈនេះមាន៦ចំណុចសំខាន់គឺ**

១. គោរពចំពោះព្រះរាជបញ្ញត្តិ ជឿស្ដាប់កោតក្រែងរាប់អាន ស្មោះត្រង់ចំពោះគ្នា តាមភាពជាអ្នកធំអ្នកតូច មិនល្មើសលើគ្នា ខំយកចិត្តទុកដាក់ម៉ឺងម៉ាត់ចំពោះតួនាទីរបស់ខ្លួន។

២. មានសេចក្ដីសាមគ្គីព្រមព្រៀងគ្នាជាពួកមួយ ជួយអនុគ្រោះគ្នា រួមកាយរួមចិត្តគ្នាតែមួយ។

៣. ស្រឡាញ់ពួកគណៈ មានចិត្តប្រាថ្នាសេចក្ដីសុខ សេចក្ដីចម្រើនដូចបងប្អូននាំគ្នាជួយការពារសិទ្ធិពួកគណៈ រក្សាសម្បត្តិរបស់ពួកគណៈ រក្សាផលប្រយោជន៍របស់ពួកគណៈ ដូចជា សាសនា ភាសា អក្សរសាស្ត្រ ប្រពៃណីទំនៀមទម្លាប់ជាដើម។

៤. ធ្វើខ្លួនឱ្យប្រព្រឹត្តទៅតែក្នុងផ្លូវដែលត្រូវធម៌ មិនធ្វើសេចក្ដីក្ដៅក្រហាយ និងសេចក្ដីវិនាសឲ្យកើតឡើងដល់ខ្លួន និងពួកគណៈ។

៥. ជាមនុស្សមិនឃើញតែប្រយោជន៍ផ្ទាល់ខ្លួន គិតដល់ប្រយោជន៍របស់ពួកគណៈជាធំ មិនប្រកាន់ទិដ្ឋិរឹងត្អឹងមានៈរេចៈទោរទន់តាមគ្នា តាំងចិត្តប្រកបដោយមេត្តាចំពោះគ្នា និងគ្នាទាំងក្នុងពេលនិយាយ ទាំងក្នុងពេលធ្វើ និងព្រមទទួលខុសត្រូវដោយព្រមនៅក្នុងពួកគណៈ។

៦. វៀរចាកការប្រកាន់ពួកគណៈមិនជាមនុស្សនិស្ស័យចង្អៀតគឺជាមនុស្សមាននិស្ស័យទូលាយដោយប្រកាន់យ៉ាងខ្ជាប់ខ្ជួនថា អ្នកដែលនៅក្នុងដែនពសុធាទាំងអស់ សុទ្ធតែជាពួកជាមួយគ្នា។

យោងតាមកិច្ចការស្រាវជ្រាវនេះ យើងអាចសង្កេត និងស្វែងយល់បានថា **ការបណ្តុះនិស្ស័យស្មោះត្រង់** គឺជាគ្រប់ពូជគុណធម៌ដ៏ប្រសើរខ្ពស់បំផុត ដែលមនុស្សគ្រប់គ្នា គប្បីសន្សំឱ្យរឿយៗទុកនៅក្នុងសន្តានរបស់ខ្លួន។ ព្រោះថាគ្រប់និស្ស័យទាំងអស់ សុទ្ធតែកើតឡើងដោយការចម្រើនរបស់មនុស្ស រៀងៗខ្លួនទោះជានិស្ស័យល្អក្តី និស្ស័យអាក្រក់ក្តី វាមិនមែនកើតឡើងឯកឯងនោះទេ គឺវាកើតឡើងពីកត្តាខ្លួនឯង និងកត្តាសង្គម និងមជ្ឈដ្ឋានផ្សេងៗ ដែលបុគ្គលរស់នៅ។

[18] ប៊ុឹង ប៉ម ការបណ្តុះនិស្ស័យ ព.ស ២៥៥៤ គ.ស ២០១០ ទំព័រ ១១១-១៣៩

និស្ស័យស្មោះត្រង់លើកដំកើងសេចក្តីល្អឱ្យអណ្តែតឡើង ទម្លាយអាក្រក់ឱ្យហិចហោច តែផ្ទុយទៅវិញ បើបុគ្គលបណ្តុះនិស្ស័យអាក្រក់កាន់តែច្រើន ការលើកដំកើងសេចក្តីអាក្រក់ឲ្យអណ្តែកឡើង ហើយទម្លាយនូវសេចក្តីល្អឲ្យអន្តរាយគ្មានសល់។ និស្ស័យវៀចវេរ និង និស្ស័យស្មោះត្រង់ វាមានសមុដ្ឋានរបស់គឺ និស្ស័យវៀចវេរ កើតឡើងពីការគិតអាក្រក់ញយៗរបស់បុគ្គលដោយផ្ទាល់ និងមួយទៀត គឺកើតឡើងដោយការសេពគប់និងជនទុច្ចរិតឬជនអសប្បុរស ជនពាល ដែលបុគ្គលទាំងនេះតែងតែបង្រៀន បង្ហាត់ ឬទូន្មាននិយាយញយៗតែអំពើអាក្រក់មានកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត។ ចំណែកនិស្ស័យស្មោះត្រង់ក៏ដូចគ្នា គឺកើតចេញពីការគិតល្អៗការគិតត្រង់ការគិតមានមេត្តា ការគិតប្រកបដោយប្រយោជន៍របស់បុគ្គល ក្នុងជីវិតប្រចាំថ្ងៃ មួយវិញទៀតគឺឡើងពីការសេពគប់ជនសុចរិត ជនសប្បុរស ជនជាបណ្ឌិត ព្រោះជនទាំងនេះជាទូទៅមានសន្តានចិត្តប្រកបដោយបញ្ញា ដូច្នេះមុនពេលនិយាយ កំពុងនិយាយ និង និយាយរួចហើយ មុនពេលធ្វើ កំពុងធ្វើនិងធ្វើរួចហើយសុទ្ធតែប្រកបដោយប្រយោជន៍ និងធ្វើឲ្យមនុស្សកែចរិតពីធម្មជាតិបានខ្លះ ជាពិសេសគឺអាចកែទម្លាប់អាក្រក់របស់បុគ្គល ដែលចូលទៅគប់រកបានយ៉ាងល្អប្រសើរ។

គ្រប់គ្នានៅក្នុងលោកនេះទោះជាជាតិសាសន៍អ្វីក៏ដោយ សុទ្ធតែប្រាថ្នាជួប ប្រាថ្នារស់នៅជាមួយគ្នាទោះជា លក្ខណៈមិត្តភក្រ្តក្តី ស្វាមីភរិយាក្តី ក្រុមការងារក្តី សហគមន៍ក្តី ក្រសួងស្ថាប័ណ្ណនានាក្តី សុទ្ធតែជ្រើសរើសដោយដាច់ខាតចំពោះតែបុគ្គលដែលមាននិស្ស័យស្មោះត្រង់សច្ចៈ ស្លូតបូត ទន់ភ្លន់ មិនមានះ មិនប្រកាន់ទិដ្ឋិរឹងត្អឹងចំពោះការងារនិងចំពោះខ្លួនឯង។

ដូច្នេះសូមលោកអ្នកទាំងឡាយ! ព្យាយាមឲ្យបានតឹងរឹងបំផុតចំពោះខ្លួនឯង ក្នុងការបណ្តុះនិស្ស័យស្មោះ ឲ្យកើតមានចំពោះខ្លួនឯងឲ្យតោងតែបាន ដោយប្រកាន់ខ្ជាប់នូវសីលធម៌ និងគុណធម៌ គ្រប់ពេលវេលា ព្រោះថា ស្មោះត្រង់នឹងតាំងនៅដោយសេចក្តីស្មោះត្រង់ ស្លាប់នៅក្នុងសេចក្តីស្មោះត្រង់ ល្អជាងរស់នៅក្នុងសេចក្តីវៀចវេរ។

បើការបណ្តុះនិស្ស័យស្មោះត្រង់បានហើយ នឹងនាំមកនូវនៅប្រយោជន៍ សេចក្តីសុខ សន្តិភាព ការជឿទុកចិត្តគ្នា ធ្វើឲ្យការរស់នៅ និងសង្គមទាំងមូលមានស្ថេរភាព និរន្តភាព សេចក្តីថ្លៃថ្នូរ។

## ៣.៣. ធម៌ដែលនាំឲ្យកើតមានសិរីសួស្តី និងសុភមង្គលនៃការគ្រប់គ្រងផ្ទះមាន៤ប្រការគឺះ

ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញអំពីអំពីលក្ខណៈសម្បត្តិ នៃអ្នកគ្រប់គ្រងផ្ទះដែលត្រឹមត្រូវ គប្បីអនុវត្តតាមគោលវិធីដែលមានសេចក្តីយ៉ាងដូច្នេះថាៈ

" បុគ្គលដែលមានសទ្ធាគ្រប់គ្រងផ្ទះ ត្រូវមានធម៌៤ប្រការគឺ ៖ សច្ចៈ សេចក្តីពិតត្រង់ ឬពាក្យពិតត្រង់១ ទមៈ ទូន្មានចិត្ត គ្រប់គ្រងចិត្តបានល្អ១ ឋិតិ សេចក្តីអត់ធន់ អត់ធ្មត់១ ចាគៈ ការវិច្ឆាគ ការលះបង់ដើម្បីជួយអ្នកដទៃ១ រមែងមិនសោយសោក មិនក្តៅក្រហល់ក្រហាល មានស្តាយក្រោយក្នុងលោកនេះ និងលោកខាងមុខដោយពិត "។

ទី១ - សច្ចៈ សេចក្តីពិត គឺមិននិយាយបំផ្លើសឲ្យលើស ឬឲ្យថយចុះពីសភាវៈពិត បើឃើញថាឃើញ ខុសថាខុស ត្រូវថាត្រូវ ឮថាឮ ដូច្នេះជាដើមហៅថា សច្ចៈ សេចក្តីពិត។ ក្នុងនាមជាអ្នកគ្រប់គ្រងផ្ទះ មិនមែន

រស់នៅតែម្នាក់ឯងនោះទេ គឺមានសមាជិកគ្រួសារផង អ្នកនៅជុំវិញផ្ទះរបស់ខ្លួនផង មានញាតិទាំងឡាយផង ដើម្បីឲ្យគ្រួសារមានឧត្តមភាព និងសុភមង្គល បុគ្គលគ្រប់រូបគប្បីប្រកាន់ខ្ជាប់នូវគុណតម្លៃគឺសេចក្តីស្មោះត្រង់ ព្រោះសេចក្តីស្មោះត្រង់គឺជាថាមពលដ៏មានឥទ្ធិពលបំផុត ដែលមនុស្សគ្រប់រូបត្រូវការចង់បាន សេចក្តីស្មោះត្រង់ជាមន្តដ៏សក្តិសិទ្ធសម្រាប់ធ្វើសេចក្តីសុខកើតឡើងក្នុងគ្រួសារ សម្រាប់ចងមិត្តភាពឲ្យរឹងមាំ សម្រាប់រក្សាការងារឲ្យឋិតថេរ សម្រាប់រក្សានូវស្នាមញញឹមឲ្យគង់វង់ សម្រាប់ញ៉ាំងសេចក្តីចម្រើនកើតឡើង សម្រាប់ញ៉ាំងភាពស្និទ្ធឲ្យតាំងនៅជានិរន្តរ៍ សម្រាប់ញ៉ាំងមនុស្សឲ្យមានទុកចិត្តចំពោះគ្នា និងគ្នា សម្រាប់ញ៉ាំងមនុស្សឲ្យនឹករឭកគ្នា ធ្វើឲ្យមនុស្សមានភាពកក់ក្តៅ ធ្វើឲ្យមនុស្សសេចក្តីជឿជាក់ចំពោះគ្នា និងគ្នា សច្ចៈ គឺសេចក្តីពិតត្រង់ជាអាវុធដ៏មានឥទ្ធិពលសម្រាប់បំផ្លាញនូវសេចក្តីសង្ស័យ រវាងបុគ្គល និងបុគ្គល រវាងក្រុម និងក្រុម រវាងសហគមន៍ និងសហគមន៍មួយទៀត សេចក្តីស្មោះត្រង់នាំឲ្យមានសន្តិភាពផ្នែកផ្លូវចិត្ត ផ្លូវកាយ និងវាចា ទាំងសាមីខ្លួនផ្ទាល់ និងមនុស្សនៅជុំវិញខ្លួន។

សេចក្តីស្មោះត្រង់នេះព្រះសម្មាសម្ពុទ្ធទ្រង់លើកឡើងនូវឧទាហរណ៍យ៉ាងដូច្នេះថា៖

មានសេចក្តីដំណាលថា មានមាណពម្នាក់ ឈ្មោះ កាបទិកៈ មានក្បាលកោរ មានអាយុ១៦ឆ្នាំ ពីកំណើត ចេះចប់គម្ពីរត្រៃវេទ ព្រមទាំងគម្ពីរឃណ្ឌុ និងគម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទ និងគឺសិក្ខា និងនិរុត្តិ ដែលមានគម្ពីរឥតហាសៈជាគំរប់៥ ជាអ្នកស្គាល់នូវបទ និងវេយ្យាករណ៍ ជាអ្នកមិនអន់ថយ គឺស្ទាត់ជំនាញក្នុងកោកាយតសាស្ត្រ និងមហាបុរិសលក្ខណៈព្យាករណ៍សាស្ត្រ បានសួររកធម៌ដែលនាំឲ្យកើត សច្ចៈចំពោះព្រះមានព្រះភាគៗ ព្រះមានព្រះមានព្រះភាគទ្រង់ឆ្លើយថា ម្នាលមាណព សច្ចៈ គឺសេចក្តីពិតត្រង់ កើតឡើងដោយអាស្រ័យសេចក្តីព្យាយាមៗ កើតឡើងដោយអាស្រ័យការប្រឹងប្រែងៗ កើតឡើងដោយអាស្រ័យឆន្ទៈសេចក្តីពេញចិត្តៗ កើតឡើងដោយអាស្រ័យសេចក្តីចូលចិត្តធម៌ក្នុងគំនិតៗ កើតឡើងដោយាការពិចារណានូវអត្ថៗ កើតឡើងដោយការចេះចាំនូវធម៌ៗ កើតឡើងដោយអាស្រ័យការស្តាប់ធម៌ៗ កើតឡើងដោយការផ្ទង់ត្រចៀកប្រុងស្តាប់ៗ កើតឡើងដោយការចូលទៅអង្គុយជិតៗ កើតឡើងដោយអាស្រ័យការចូលទៅរកៗ កើតឡើងដោយអាស្រ័យសទ្ធាសេចក្តីជឿជាក់ បើបុគ្គលណាគ្មានសទ្ធាសេចក្តីជឿជាក់ហើយ ការចូលទៅរកក៏មិនមានបើការចូលទៅរកមិនមានហើយ ការចូលទៅអង្គុយជិតក៏មិនមាន បើការចូលទៅអង្គុយជិតមិនមានហើយ ការផ្ទង់ត្រចៀកប្រុងស្តាប់ក៏មិនមាន បើការផ្ទង់ត្រចៀកប្រុងស្តាប់មិនមានហើយ ការស្តាប់ធម៌ក៏មិនមាន បើការស្តាប់ធម៌មិនមានហើយ ការចេះចាំនូវធម៌ក៏មិនមាន បើការចេះចាំនូវធម៌មិនមានហើយ ការពិចារណានូវអត្ថក៏មិនមាន បើការពិចារណានូវអត្ថមិនមានហើយ សេចក្តីចូលចិត្តធម៌ក្នុងគំនិតក៏មិនមាន បើសេចក្តីចូលចិត្តធម៌ក្នុងគំនិតមិនមានហើយ ឆន្ទៈសេចក្តីពេញចិត្តក្នុងធម៌ក៏មិនមាន បើឆន្ទៈសេចក្តីពេញចិត្តមិនមានហើយ ការប្រឹងប្រែងក៏មិនមាន បើការប្រឹងប្រែងមិនមានហើយ ការពិចារណាក៏មិនមាន បើការពិចារណាមិនមានហើយ សច្ចៈ សេចក្តីពិតត្រង់ក៏មិនមាន។ បើសច្ចៈ សេចក្តីពិតត្រង់មិនមានហើយ បុគ្គលនោះលែងស្គាល់ខុសត្រូវ គុណ ទោស បុណ្យបាប តែងតែលុះក្នុងអំណាចនៃលោភៈ ទោសៈ មោហៈ ការដែលមិនពិតហ៊ានថាពិត

សេចក្តីខុសហ៊ានថាត្រូវ គិតឃើញតែប្រយោជន៍ផ្ទាល់ខ្លួន មិនឃើញសេចក្តីទុក្ខរបស់អ្នកដទៃ មនុស្សបែបនេះនឹងលុះក្នុងតម្រានៃសេចក្តីវិនាសមិនខានឡើយ។

ដូចជាមាតាបិតា និងកូនប្រុសស្រី ឬស្វាមី និងភរិយា ឬក៏គ្រូឧបជ្ឈាយ៍យាចារ្យ និងសិស្សានុសិស្ស បើគ្មានសច្ចៈពិតត្រង់នឹងគ្នាទៅវិញទៅមកទេ សេចក្តីវិនាសតែងតែឡើងប្រាកដដល់ជនទាំងនោះ ព្រោះសច្ចធម៌ជាគុណជាតិដ៏ប្រសើរបំផុត។

ព្រោះហេតុនោះបានជាព្រះសម្មាសម្ពុទ្ធជាអគ្គបុគ្គលទ្រង់សរសើរសច្ចៈធម៌ថា ៖

" សច្ចៈជាធម៌ដ៏ឧត្តមក្នុងលោក សច្ចៈជាប្រធានក្នុងលោក បុណ្យទាំងអស់រមែងមានក្នុងសច្ចៈ"។

ទី២ - ទមៈ ការទូន្មានចិត្ត ឬការទូន្មានខ្លួន បានដល់ការហាត់ពត់ដុសខាត់កាយ វាចា ចិត្តរបស់ខ្លួនឲ្យមានសណ្តាប់ធ្នាប់សមរម្យល្អ។ ក្នុងទីនេះសំដៅយក់សីល៥ ដែលហៅថា និច្ចសីលបានដល់សិក្ខាបទដែលគួរប្រព្រឹត្តកាន់រក្សាដោយទៀងទាត់អស់កាលជានិច្ច ពុំកំណត់កាលពេលវេលា ន័យខ្លះទៀតលោកហៅថា បុរាណសីល គឺសណ្តាប់ធ្នាប់របស់បុព្វបុរសដែលធ្លាប់រក្សាមកក្នុងកាលពីព្រេងនាយ មុនពុទ្ធសម័យ ន័យខ្លះទៀតលោកហៅថា កុរុធម៌ គឺជាប្រវេណីធម៌ ឬជាអរិយធម៌របស់អ្នកកុរុដែលធ្លាប់ប្រព្រឹត្តកាន់មកតាមសណ្តាប់គោត្រត្រកូល។ ព្រះសម្មាសម្ពុទ្ធកាលនៅជាពោធិសត្វ បានជាព្រះរាជក្នុងនគរឥន្ទបត្រ ដែនកុរុ ព្រះអង្គបានរក្សាសីល៥ជាប់ទៀតទាត់ជាដរាបព្រោះហេតុនោះ សីលទាំង៥នេះ ទើបលោកហៅថា កុរុធម៌ក្នុងកាលណោះលុះព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក ក៏ទ្រង់សំដែងសើរើរៀបបន្ថែមឡើងជាថ្មី ដើម្បីអនុគ្រោះសត្វលោកឲ្យមានសន្តិភាពឲ្យមានអរិយធម៌ច្បាប់សម្រាប់ទូន្មានខ្លួន មានត្រណមឲ្យកើតជាប្រយោជន៍ដល់មនុស្សលោកទូទៅ។

ត្រណមក្នុងសិក្ខាបទរបស់និច្ចសីលមានៈ

សិក្ខាបទទី១ ហាមអំពីការសម្លាប់សត្វទូទៅ ពាក្យថាសត្វៗនេះ សំដៅយកទាំងមនុស្ស ទាំងតិរច្ឆានដែលមានជីវិត ពុំកំណត់ថាប្រុសស្រី ឬក្មេងចាស់ ទោះបីពួកសត្វល្អិតតូចៗ ឬសត្វនៅក្នុងគភ៌ក្តី ក្នុងអណ្ឌក្តីក៏ឈ្មោះថាសត្វ រាប់ចូលក្នុងត្រណម ដែលត្រូវតមទាំងអស់។

សិក្ខាបទនេះ ព្រះអង្គទ្រង់បញ្ញត្តិឡើងដើម្បី ជាប្រយោជន៍ និងបណ្តុះធម៌មេត្តា ករុណា ចំពោះពួកសត្វ ធ្វើពួកសត្វទាំងសាកលពុំឲ្យមានពៀរដល់គ្នា និងគ្នា។

សិក្ខាបទទី២ ហាមអំពីការលួចទ្រព្យ ដែលម្ចាស់គេពុំបានឲ្យ។ ពាក្យថាទ្រព្យនេះ សំដៅយកទ្រព្យមានវិញ្ញាណ និងទ្រព្យឥតវិញ្ញាណ ទោះបីទ្រព្យនោះថ្លៃ ថោក ច្រើន តិច ក្តីមិនត្រូវយកខ្លួនទៅប្រព្រឹត្តឡើងត្រូវវៀរឲ្យដាច់ស្រឡះអំពីជីវិតរស់នៅ។

សិក្ខាបទនេះ ព្រះអង្គបញ្ញត្តិតាំងឡើងដើម្បី បណ្តុះសម្មាអាជីវៈ ការចិញ្ចឹមជីវិតដោយប្រពៃ ពុំឲ្យមានការបៀតបៀនគ្នា ឲ្យមានសេចក្តីស្មោះត្រង់ ជឿចិត្ត ស្រឡាញ់រាប់អានរាក់ទាក់រកគ្នាទូទៅ។

សិក្ខាបទទី៣ ហាមអំពីការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។ ពាក្យថា កាមនេះ សំដៅយកកិលេសដែលស្រឡាញ់គួចកាន់ ឬប្រាថ្នាក្នុងផ្លូវបវេណី ដែលពុំត្រូវប្រាថ្នា ពុំត្រូវប្រព្រឹត្ត ជាហេតុឲ្យសៅហ្មងមានគំនុំនឹងគ្នាក្នុងវាងត្រកូលទួទៅ។

**បុរសមិនគួរសេពគប់ស្ត្រី ២០ ពួកគឺ:**

១. ស្ត្រីដែលមាតាគ្រប់គ្រងរក្សា។

២.ស្ត្រីដែលបិតាគ្រប់គ្រងរក្សា។

៣. ស្ត្រីដែលមាតា និងបិតាគ្រប់គ្រងរក្សា។

៤. ស្ត្រីដែលបងប្អូនប្រុសគ្រប់គ្រងរក្សា។

៥. ស្ត្រីដែលបងប្អូនជាស្ត្រីគ្រប់គ្រងរក្សា។

៦. ស្ត្រីដែលញាតិគ្រប់គ្រងរក្សា។

៧. ស្ត្រីដែលបុគ្គលមានគោត្រជាមួយគ្នា ឬមានជាតិវង្សជាមួយគ្នាគ្រប់គ្រងរក្សា។

៨. ស្ត្រីដែលបព្វជិតអ្នកប្រព្រឹត្តធម៌ត្រូវគ្នាពួកណាមួយគ្រប់គ្រងរក្សា។

៩. ស្ត្រីដែលប្រកបដោយការរក្សា គឺស្ត្រីដែលមានស្វាមីហើយ ឬមានគេប្រកាន់ទុកហើយ។

១០. ស្ត្រីដែលប្រកបដោយអាជ្ញា គឺស្ត្រីដែលព្រះរាជាដាក់រាជអាជ្ញា មិនឲ្យប្រព្រឹត្តតាមអំពើចិត្ត ឬមិនឲ្យបុរសណាមួយទៅប្រព្រឹត្តកន្លង។

១១. ស្ត្រីដែលគេទិញ ឬលោះដោយទ្រព្យ ទោះបីតិចក្តីច្រើនក្តី យកមកធ្វើជាភរិយា ឬត្រឹមតែលោះមកប៉ុណ្ណោះ មិនដល់ធ្វើជាភរិយាក៏ដោយ។

១២. ស្ត្រីដែលរត់តាមគេ ទៅនៅធ្វើជាភរិយារបស់បុរសដទៃ ដោយសេចក្តីពេញចិត្តរបស់ខ្លួន ហើយបុរសក៏ទទួលយល់ព្រមផង។

១៣. ស្ត្រីដែលទៅនៅធ្វើជាភរិយារបស់បុរសដទៃព្រោះតែភោគៈ គឺស្ត្រីដែលបានភោគៈយ៉ាងហោចត្រឹមតែអង្រៃ និងត្បាល់ជាដើម អំពីបុរសណាមួយក៏ទៅនៅធ្វើជាភរិយារបស់បុរសនោះ។

១៤. ស្ត្រីដែលទៅនៅធ្វើជាភរិយារបស់បុរសដទៃព្រោះតែសំពត់ គឺស្ត្រីដែលជាអ្នកកំសត់ទុគត៌ ដែលគ្រាន់តែបុរសណាមួយ ឲ្យសំពត់ស្លៀក ឬដណ្តប់ប៉ុណ្ណោះ ក៏សុខចិត្តចូលទៅនៅធ្វើជា ភរិយារបស់គេទៅ។

១៥. ស្ត្រីដែលគេផ្គោបដៃជាមួយនឹងបុរសជ្រលក់ទៅក្នុងពាងទឹក ឬផ្តិលទឹក ហើយគេពោលថា "អ្នកនាងទាំងឡាយចូរច្រឡំគ្នាចូរកុំបែកគ្នាដូចជាទឹកនេះ" គឺស្ត្រីដែលគេផ្សំផ្គុំឲ្យជាភរិយា បុរសដោយវិធីបែបនេះ។

១៦. ស្ត្រីដែលគេជួយដាក់ទ្រនូលចុះពីលើក្បាល គឺស្ត្រីអ្នករកអុសជាដើម ដែលបុរសណាមួយ ជួយដាក់ទ្រនូលពីលើក្បាល ហើយនាំយកទៅធ្វើជាភរិយា។

១៧. ស្ត្រីដែលជាទាសីគេផង ជាភរិយាគេផង គឺស្ត្រីដែលជាទាសី របស់បុរសណាមួយ ហើយបុរសនោះយកធ្វើជាភរិយា។

១៨.ស្ត្រីដែលជាកូនឈ្នួលគេផង ជាភរិយាគេផង គឺស្ត្រីដែលចូលទៅនៅ ធ្វើការស៊ីឈ្នួលឲ្យបុរសណាមួយហើយបុរសនោះទៅសម្រេចយរាវាសធម៌ធម៌អ្នកគ្រប់គ្រងផ្ទះជាមួយលែងត្រូវការដោយភរិយារបស់ខ្លួន។

១៩. ស្ត្រីដែលសេនានាំមកដោយទង់ជ័យ គឺស្ត្រីដែលសេនាដំឡើងទង់ជ័យ លើកទ័ពទៅច្បាំងដណ្តើមយក ដែនរបស់ ស្តេចដទៃ កៀរយកបានមកហើយមានបុរសណាមួយយកធ្វើជាភរិយា។

២០. ស្ត្រីដែលមានបុរសទៅភពប្រសព្វ តែមួយស្របក់ៗ គឺស្ត្រីដែលជាសហាយស្មន់របស់បុរសណាមួយ។

ស្ត្រីទាំង ២០ ចំពូកដូចពោលមកនេះ សុទ្ធតែជាស្ត្រីដែលបុរស មិនគួរគប្បីទៅសេពគប់រកជាសេចក្តីស្នេហាឡើយ បើទៅសេពគប់ហើយចាត់ថា មានកំហុសបែកធ្លាយកម្មបថ ឬខុសច្បាប់ ប្រុស។

សិក្ខាបទនេះ ព្រះអង្គបញ្ញត្តិតាំងឡើយដើម្បី បណ្តុះសំវរៈ គឺការសង្រួម និងទាសសន្តោសៈ គឺសេចក្តីត្រេកអរចំពោះតែភរិយារបស់ខ្លួន។

សិក្ខាបទទី៤ ហាមអំពីការកុហក គឺនិយាយបំភ័ន្តអ្នកស្តាប់ ឲ្យចូលចិត្តខុស ឲ្យយល់ខុស មិនចំពោះតែនិយាយដោយវាចាទេ សូម្បីគ្រាន់តែធ្វើសញ្ញាដោយកាយ ការរាប់ចូលក្នុងមុសាវាទដូចគ្នាទោះបីអ្នកនិយាយកុហកដើម្បីសើចលេង ក៏ឈ្មោះថាជាពាក្យនៅក្នុងគ្រណាមនៅក្នុងសិក្ខាបទដែរ។

ក្នុងសិក្ខាបទនេះ ព្រះអង្គទ្រង់បញ្ញត្តិតាំងឡើង ដើម្បីបណ្តុះសច្ចធម៌នៅក្នុងសន្តាន ឲ្យមានការទៀងទាត់ស្មោះត្រង់ដល់គ្នា និងគ្នាពុំឲ្យមានការវិវាទចាប់ចោទប្រកាន់គ្នា។

សិក្ខាបទទី៥ ហាមអំពីការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ។ ពាក្យថា សុរា នេះជាឈ្មោះទឹកដែលកើតមកអំពីគ្រឿងត្រាំផ្លែឈើ ឬធញ្ញជាតិផ្សេងៗ ដែលគេត្រាំទុកយូរទាល់តែទឹកនោះជូរផ្អូមខ្លាំង ក្លាយរសជាតិជាទឹកស្រវឹងក្តី គេយកធញ្ញជាតិស្ងោររម្ងាស់បិទយកដំណក់ទឹកញើសនោះក្តី ធ្វើដោយបែបផ្សេងៗក្រៅពីនេះក្តី ទាំងនេះហៅថាសុរា។

ចំណែកមេរ័យ គឺជាទឹកត្រាំដែលគេដាក់មេជាតិស្រវឹង ត្រាំទុកឲ្យចេញរសជាតិ ដូចទឹកត្នោតជូរជាដើម។ សុរា និងមេរ័យនេះជាទឹកស្រវឹង ជាទីតាំងនៃសេចក្តីប្រមាទ ទោះបីខ្លាំងឬខ្សោយ ក៏រាប់ចូលក្នុងគ្រណាមរបស់សិក្ខាបទនេះទាំងអស់។

សិក្ខាបទនេះ ព្រះអង្គទ្រង់បញ្ញត្តិឡើង ដើម្បីបណ្តុះអប្បមាទធម៌ សតិសំវរៈ ឲ្យដុះលូតលាស់ល្អនៅក្នុងសន្តានពុំឲ្យមានការប្រមាទក្នុងកិច្ចទាំងពួង។

បុគ្គលណាវៀរចាកជាពុទ្ធបញ្ញត្តិប្រតិបត្តិតាមគ្រណាមក្នុងសិក្ខាបទទាំង៥ប្រការនេះបាន បុគ្គលនោះឈ្មោះថាជាអ្នកមានសីល។

សីលនេះជាទឹកឱសថវិសេសផុត ឱសថក្នុងលោកអាចលាងជម្រះនូវមន្ទិល គឺសេចក្តីសោកអពមង្គលដែលជុះក្រាំងជាប់នឹងដួចចិត្តរបស់សត្វក្នុងលោកបាន។

ព្រះសម្មាសម្ពុទ្ធទ្រង់សរសើរអំពីតម្លៃនៃសីលធម៌យ៉ាងវិសេសដូច្នេះថា៖

" ទឹកមហានទីគង្គាក្តី យមុនាក្តី សរភូក្តី សរស្សតីក្តី អចិរវតីក្តី មហីក្តី សុទ្ធតែនទីយ៉ាងធំៗ ក៏មិនអាចដើម្បីនឹងជម្រះនូវមន្ទិលរបស់សត្វទាំងឡាយក្នុងលោកនេះបានឡើយ មានតែទឹកគឺសីលនេះឯង ទើបអាចជម្រះនូវមន្ទិលរបស់សត្វទាំងឡាយបាន "។

ខ្យល់ទាំងឡាយដែលប្រកបដោយទឹកក្តី ខ្លឹមចន្ទក្រហមក្តី កែវមុក្តាហារក្តី កែវមណីក្តី រស្មីនៃព្រះចន្ទដ៏ស្រទន់ក្តី ពុំអាចនឹងរម្ងាប់បាននូវសេចក្តីក្រហលក្រហាយ របស់សត្វទាំងឡាយក្នុងលោកនេះបានឡើយ មានតែសីលដ៏ប្រសើរដែលបុគ្គលរក្សាហើយដោយប្រពៃជាគុណត្រជាក់យ៉ាងក្រៃលែងនេះទើបអាចរម្ងាប់បាន។

" សម្បត្តិក្នុងស្ថានមនុស្សក្តី ក្នុងស្ថានទេវតាក្តី កាលបើបុគ្គលដែលមានសីលបរិបូណ៌ ត្រូវការចង់បានហើយ សម្បត្តិទាំងនោះមិនជាក្រីក្រសោះឡើយ "។

"ម្នាលភិក្ខុទាំងឡាយសេចក្តីប្រាថ្នាដែលតាំងនៅក្នុងចិត្ត របស់បុគ្គលអ្នកមានសីល រមែងបានសម្រេចដូចបំណង " ហេតុនេះ មនុស្សទាំងឡាយគួរតែសិក្សានូវសីល ឈ្វេងយល់អំពីសីល ឲ្យដឹងច្បាស់នូវសីលមានសេចក្តីស្រឡាញ់ចំពោះសីល សប្បុរសទាំងឡាយគួររក្សាសីលនេះគ្រប់រូបចុះ។

ទី៣ - ឋិតិ សេចក្តីអត់ធន់ សេចក្តីអត់ធន់នេះលោកចែកចេញជាបីយ៉ាងគឺ៖

១ - អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើត លោភៈ

ឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុនាំឲ្យកើតលោភៈនោះ បានខាងការអត់ទ្រាំនឹងចំណង់ផ្សេងៗ ដែលកើតក្នុងទ្វារទាំង៦មាន៖

អត់ធន់ចំពោះបាតុភូតដែលកើតឡើងប្រាកដតាម ភ្នែក

អត់ធន់ចំពោះបាតុភូតដែលកើតឡើងប្រាកដតាម ត្រចៀក

អត់ធន់ចំពោះបាតុភូតដែលកើតឡើងប្រាកដតាម ច្រមុះ

អត់ធន់ចំពោះបាតុភូតដែលកើតឡើងប្រាកដតាម អណ្តាត

អត់ធន់ចំពោះបាតុភូតដែលកើតឡើងប្រាកដតាម កាយ

អត់ធន់ចំពោះបាតុភូតដែលកើតឡើងប្រាកដតាម ចិត្ត

២ - អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើត ទោសៈ

៣ - អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើត មោហៈ។

ពាក្យថា អត់ទ្រាំ មិនប្រព្រឹត្តទុច្ចរិតតាមចំណង់ ឬសេចក្តីស្រេកឃ្លាននោះៗ បុគ្គលពួកខ្លះ ព្រោះតែមិនចេះអត់ទ្រាំនឹងចំណង់ ឬសេចក្តីស្រេកឃ្លាន បានជាហ៊ានលួច ឆក់ ដណ្តើមបំបាត់កេងប្រវ័ញ្ចទ្រព្យសម្បត្តិរបស់គេ កាលបើប្រព្រឹត្តខុសទុច្ចរិតដូច្នោះ រមែងជួបប្រទះនូវសេចក្តីទុក្ខព្រួយ ដែលជាផលរបស់ទុច្ចរិតនោះៗ មានត្រូវទោសជាប់គុកច្រវាក់ជាដើម។ បុគ្គលណាជាមនុស្សមិនសូវរវេះរវាមពេក ចេះអត់ទ្រាំបាន បុគ្គលនោះឯងតែងប្រកបដោយសុខភាព និងអនាម័យដ៏ល្អ។ ឋិតិ សេចក្តីអត់ធន់បែបនេះ ហៅថាអត់ធន់ចំពោះសេចក្តី

ទុក្ខដែលជាហេតុនាំឲ្យកើតលោភៈ សូម្បីអត់ធន់ចំពោះសេចក្ដីទុក្ខ ដែលជាហេតុឲ្យកើតរាគៈក៏គួរសង្គ្រោះចូលក្នុងបិតនេះដែរ។

ឯសេចក្ដីអត់ធន់ចំពោះសេចក្ដីទុក្ខ ដែលជាហេតុនាំឲ្យកើតទោសៈនោះ បានខាងសេចក្ដីអត់ចំពោះពាក្យដែលបុគ្គលដទៃស្ដីថា រិះគន់ ឬត្មះតិះដៀល ឬអត់ធន់នឹងអំពើដែលបុគ្គលដទៃបៀតបៀន ដែលជាប្រកពរបស់ ទោសៈ ធម្មតាមនុស្សកើតមកក្នុងលោកនេះ ដែលថាមិនឲ្យគេស្ដីថា មិនឲ្យគេរិះគន់ ឬតិះដៀលសោះនោះគ្មានទេ អំបាលព្រះអាទិត្យ និងព្រះចន្ទដែលផ្លុះបំភ្លឺលោកជាប្រក្រតី ម្ដេចគង់មានគេតិះដៀលដែរចុះបើមនុស្សក្នុងលោកនិងរកនរណាឲ្យជាមនុស្សឥតគេតិះដៀលនោះពុំមានឡើយ ទុកជាព្រះសាស្ដាបរមគ្រូជាម្ចាស់ ដែលប្រកបដោយមហាករុណាទិគុណ ម្ដេចគង់មានគេតិះដៀល។ បើយល់ជាក់យ៉ាងនេះហើយ គួរឲ្យមានការអត់ធន់ កុំខឹងក្រោធ។ បុរាណណាចារ្យលោកសម្ដែងប្រាប់ឧបាយ គឺយោបល់ជាគ្រឿងរំលត់សេចក្ដីក្រោធខឹងថា ៖ ទុកជាមានភ្នែកភ្លឺ ក៏ត្រូវធ្វើដូចជាងងឹត បើមានត្រចៀកស្ដាប់ឮ ក៏ត្រូវធ្វើដូចជាថ្លង់ ដូច្នេះទើបអត់ធន់សេចក្ដីក្រោធខឹងនោះបាន។

អត់ធន់ចំពោះបាតុភូតដែលកើតឡើងប្រាកដ ដូចជាក្ដៅត្រជាក់ស្រេកឃ្លានការហត់នឿយ ការឈ្លោះប្រកែក ការប្រណាំប្រដែងដែលគ្មានតម្លៃសីលធម៌ជាដើម។

អត់ធន់ចំពោះបាតុភូតដែលកើតឡើងប្រាកដ សុខ ទុក្ខ សរសើរ និន្ទា បានយស អត់យស មានលាភអត់លាភ ជាដើម។

ឯសេចក្ដីអត់ធន់ចំពោះសេចក្ដីទុក្ខ ជាហេតុនាំឲ្យកើតមោហៈនោះ បានខាងសេចក្ដីអត់ធន់នឹងទុក្ខវេទនាផ្សេងៗដែលកើតឡើងក្នុងកាយ និងចិត្ត មិនលុះក្នុងអំណាចទុក្ខវេទនាហើយទៅប្រព្រឹត្តទុច្ចរិតឡើយ។

សូម្បីការដែលអត់ទ្រាំនឹងទុក្ខវេទនា ក្នុងវេលាឈឺថ្កាត់នោះសោត ក៏ជាហេតុជួយឧបត្ថម្ភឲ្យមានសតិសម្បជញ្ញៈ គឺការភ្ញាក់រឭនឹងសេចក្ដីដឹងខ្លួន ដែលគុណវិសេសគួរឲ្យមានគ្រប់កាលទាំងពួង ពុំនោះសោត ក្នុងវេលាមានព្យាធិដែលជាហេតុឲ្យដល់មរណៈក៏គួរតែមានសេចក្ដីអត់ធន់យ៉ាងមាំមួន។ ដោយជាស់តឿនខ្លួនឯងរឿយៗថាអាត្មាអញមានជំងឺតម្កាត់ជាធម្មតា និងចៀសវាងជំងឺតម្កាត់ពុំបានឡើយ ដូច្នោះនោះ ក៏ដើម្បីឲ្យប្រុងខ្លួនអំពីកាលដែលនៅជានៅឡើយ បើចាំទៅនឹករឭកនៅពេលដែលឈឺមកដល់ មុខជាកម្រនឹងនឹកឃើញណាស់ព្រោះវេលាដែលឈឺនោះតែងមានសេចក្ដីទុក្ខព្រួយលំបាកច្រើនយ៉ាងណាស់ កាលបើអត់ទ្រាំទុក្ខវេទនាពុំបាន សតិសម្បជញ្ញៈ ក៏នឹងទ្រេតទ្រោតទៅពុំតាំងនៅខ្ជាប់ឡើយ ដូចជនពួកខ្លះ ដែលបានហាត់ចិត្តទុកអំពីកាលដែលនៅជានោះ លុះវេលាដែលមានជំងឺយ៉ាងធ្ងន់មកដល់ ក៏ច្រើនតែមានចិត្តរវើរវាយផ្សេងៗ ដរាបដល់ធ្វើអំពើទុច្ចរិតមានសម្លាប់សត្វជាដើមដើម្បីបូជាគ្រោះដោយចង់រស់តែខ្លួនឯង ពុំគិតអាណិតសត្វដទៃក៏មាន។

ព្រោះហេតុដូច្នោះការដែលបង្ហាត់ចិត្តបង្ហាត់ស្មារតី ដើម្បីឲ្យកើតសេចក្ដីអត់ធន់នោះ ជាកិច្ចដែលយើងត្រូវការគ្រប់ៗប្រាណ សម្រាប់តយុទ្ធនឹងសត្រូវ គឺព្យាធិទុក្ខ ក្នុងវេលាដែលជិតដល់នឹងមរណៈទុក្ខនោះ។

ចំណែកអ្នកដែលមានសេចក្តីប្រាថ្នា រៀនរកនូវភោគទ្រព្យ វិទ្យាសាស្ត្រ ក្បេតសាស្ត្រ និងពាណិជ្ជកម្ម កសិកម្មជាដើមបើមានសេចក្តីអត់ធន់នូវការស្រេកឃ្លានមានក្រ ក្តៅត្រជាក់ជាដើមហើយ វិជ្ជានឹងភោគទ្រព្យក៏រមែងសម្រេចដល់បុគ្គលនោះ ដោយមុហុត្តកាល បុគ្គលនោះនឹងធ្វើខ្លួនឲ្យទៅជាមនុស្សរីកចម្រើនលោកបាន។

ទី៤ - ចាគ ប្រែថា ការលះ គឺលះនូវមច្ឆរិយ គឺសេចក្តីកំណាញ់[19]។

ចាគ និងទាន ពាក្យទាំងពីរនេះ បើសំដៅយកសេចក្តីឃើញថាផ្សេងៗគ្នា តែបើដោយលក្ខណៈស្រដៀងគ្នា ចំពោះពាក្យថា ចាគៈមានអត្ថន័យ៤យ៉ាងគឺៈ

១ - ចាគៈ ការលះវត្ថុណាមួយឲ្យចំពោះអ្នកទទួល ដើម្បីលះបង់សង្កិននូវលោភៈ និងសេចក្តីកំណាញ់ឲ្យស្រាលស្តើងចាកសន្តាន គឺចំណាយទ្រព្យដើម្បីទុកជាអលង្ការ ឬជាកល្យាណវត្តរបស់ចិត្ត ពុំបណ្តោយឲ្យចិត្តជ្រលក់ជាប់នៅក្នុងកិលេស។

២-ចាគៈ ការលះឲ្យដែលមិនជាប់ជំពាក់ដោយតណ្ហា គឺឲ្យដោយមានបំណងចំពោះនិរាមិសសុខគឺឲ្យដោយមានបំណងដើម្បីបង់នូវសេចក្តីសុខជាលោកិយនេះ ដើម្បីធ្វើចិត្តឲ្យបរិសុទ្ធ បើឱកាសឲ្យបញ្ញារបស់ខ្លួនមានកម្លាំងលូតលាស់ចម្រើនឡើងផង ដើម្បីជាប្រជយោជន៍ និងសេចក្តីថ្កុំថ្កើង ជាតម្រាប់ដល់មនុស្សជំនាន់ក្រោយផង ដូចជាការសាងសង់របស់អ្វីមួយឲ្យទៅជារបស់សាធារណៈ សម្រាប់មនុស្សទូទៅ នៅក្នុង សង្គម។

៣ - ចាគៈ ការលះឲ្យវត្ថុដ៏ប្រសើរក្រៃលែង លើសវិស័យរបស់មនុស្សសាមញ្ញក្នុងលោក គួរឲ្យស្ងើចដែលរាប់បញ្ចូលថាជាការបរិចាគដ៏ខ្ពង់ខ្ពស់បំផុត កម្រអ្នកផងយកតម្រាប់តាមបាន ដូចយ៉ាងមហាបរិច្ចាគរបស់ព្រះពោធិសត្វ។

៤ - ចាគៈ ការលះកាត់អាល័យក្នុងជីវិត និងសេចក្តីសុខទុក្ខក្នុងទ្រព្យសម្បត្តិរបស់ខ្លួនម្នាក់ឯង ដើម្បីស្វះស្វែងរកឧបាយ ជួយជ្រោងជ្រែងប្រជាករក្នុងលោក ឲ្យលះបង់ទ្រព្យសម្បត្តិ ដើម្បីរាយរាយចែកចាយឲ្យក្លាយទៅជាប្រយោជន៍ ផ្តល់សេចក្តីសុខចម្រើនរុងរឿងដល់មហាជនទុកជាកេរតំណែលតទៅ។

ចំណែកឯពាក្យថា ទានៈ ក៏ចែកចេញជា៤យ៉ាងដែរគឺៈ

១ - ទានៈ ការឲ្យវត្ថុណាមួយដែលនៅជាប់ជំពាក់ដោយមច្ឆរិយៈ (សេចក្តីកំណាញ់) ឬឲ្យដោយស្ទាក់ស្ទើរពុំជ្រះស្រឡះ ឬក៏ឲ្យតាមទំនៀមទម្លាប់របស់ត្រកូល ពុំមែនជាកិច្ចអស្ចារ្យ ចំឡែកជាងត្រកូលដែលធ្លាប់ធ្វើមក។

២ - ទានៈ ការឲ្យដែលជាប់ដោយជាប់តណ្ហា គឺបុគ្គលឲ្យទានប្រាថ្នាយកសិរីសួស្តី និងផលប្រយោជន៍មកខ្លួនវិញ ចំពោះសាមិសសុខក្នុងលោកនេះ ឬលោកខាងមុខ។

៣ - ទានៈ ការឲ្យពុំសមគួរ គឺបុគ្គលណាមានសម្បត្តិច្រើន មានវត្ថុថ្លៃថ្លាច្រើន លុះក្នុងការចាត់ចែងទានក៏ចាត់ចែងដោយរលីបរលោប ស្តួចស្តើង និងវត្ថុថោកទាបតាមធម្មតា ទានរបស់បុគ្គលនោះ ឈ្មោះថាជាទានពុំសមតាមសក្តិតាមកម្លាំងនៃទ្រព្យដែលខ្លួនមាន។

៤ - ទានៈការឲ្យចំពោះមុខអ្នកទទួលផ្ទាល់ ដែលជាបុគ្គលខ្សត់ខ្សោយដោយគុណធម៌ និងភោគទ្រព្យ ឬខ្ពង់ខ្ពស់ដោយគុណធម៌ និងភោគទ្រព្យ។

---

[19] កម្ពុជាសុរិយា ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ ពុទ្ធសាសនបណ្ឌិត្យ ភាគ ២៧/២ គ.ស១៩៥៥ ទំព័រ៨០៣

ពាក្យថា ចាគៈ និងទានៈ មានសេចក្តីផ្សេងគ្នាយ៉ាងដូច្នេះឯង។ ម្យ៉ាងទៀត ចាគៈ និងទានៈនេះ បើពោលតាមលក្ខណៈរួបរួមក៏គឺការឲ្យ ការចែករំលែកភោគទ្រព្យចំពោះសត្វ ឬបុគ្គលដទៃប៉ុណ្ណោះឯង តែបើបញ្ចូលតាមហេតុផលវិញ ចាគៈ ជាឈ្មោះចេតនាដែលជាចេតសិកសម្រាប់លះ ទានៈ ជាឈ្មោះបរិក្ខារវត្ថុដែលត្រូវគេឲ្យ ចាគៈចាត់ជាហេតុ ទានចាត់ជាផល អាស្រ័យគ្នាដូចព្រះអាទិត្យ និងពន្លឺនៃព្រះអាទិត្យ ម្យ៉ាងទៀត ចាគៈទុកដូចដើម ឬទងនៃរុក្ខជាតិ ទានៈ ដូចជាផ្កាផ្លែដែលលេចចេញចាកដើម ឬទង។

ជារួមមកវិញ បុគ្គលអ្នកគ្រប់គ្រងផ្ទះ ប្រកបដោយធម៌៤ប្រការនេះគឺ សច្ចៈ សេចក្តីត្រង់១ ទមៈ ចេះទូន្មានចិត្ត១ ឋិតិ ចេះមានសេចក្តីអត់ធន់១ និងចាគៈ ចេះលះបង់បរិច្ចាគៈ១ ជនដែលគ្រប់គ្រងផ្ទះមានលក្ខណៈសម្បត្តិយ៉ាងដូច្នេះ ជនជាម្ចាស់ផ្ទះ និងសមាជិកនៅក្នុងផ្ទះ និងជននៅជុំវិញនៃផ្ទះ និងមនុស្សរស់នៅក្នុងភូមិស្រុកជាមួយគ្នា នឹងកើតឡើងនូវសេចក្តីសុខ សុភមង្គល ជាក់ប្រាកដមិនខាន់ឡើយ។

# ជំពូក៤

# ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញនូវហេតុនាំឲ្យកើតមង្គល៣៨

## សេចក្តីផ្តើមនៃមង្គល៣៨ប្រការ

នៅក្នុងលោកនេះ មានមនុស្សច្រើនប្រភេទណាស់ ដែលតាំងខ្លួនធ្វើជាអ្នកចេះដឹង មិនត្រឹមតែប៉ុណ្ណោះ តាំងខ្លួនថាអាចឲ្យសេចក្តីសុខដល់អ្នកទៃ ជួយឲ្យអ្នកដទៃបាននូវមង្គល ដោយអំណាចបុណ្យបារមីរបស់ខ្លួន និងអ្នកខ្លះទៀត បានបង្រៀនមនុស្សឲ្យចេះបួងសួង សែនព្រេន បន់ស្រន់ ដើម្បីឲ្យទទួលបាននូវមង្គល។ គាប់ជួនមនុស្សជាច្រើនមានសេចក្តីលោភលន់ ល្ងង់ខ្លៅ គ្មានប្រាជ្ញា ការពិចារណាខ្សោយ ខ្វះការស្វែងរកហេតុផលពិត ក៏បានបណ្តែតបណ្តោយចិត្តឲ្យចាប់យកការអួសទាញនោះៗ ដោយពួកគេគិតថា ពួកគេនឹងទទួលបាននូវអ្វីដែលពួកគេប្រាថ្នាចង់បាន តែផ្ទុយទៅវិញ ពួកគេមិនត្រឹមតែមិនអាចទទួលបាននូវអ្វីដែលពួកគេចង់បាននោះទេ គឺថែមទាំងញ៉ាំញី ជាន់ពន្លេចពួកគេឲ្យរឹតតែធ្លាក់ជ្រៅទៅៗក្នុងសេចក្តីទុក្ខ និងភាពមិនប្រាកដប្រជាក្នុងជីវិត។

មនុស្សមានជំងឺខំស្វែងរកឱសថសម្រាប់ព្យាបាល ដើម្បីឲ្យជាសះស្បើយពីរោគនោះ តែផ្ទុយទៅវិញ ដោយសារតែស្វែងរកគ្រូពេទ្យអ្នកផ្សំថ្នាំខុស មិនចេះពីវិធីព្យាបាល មិនត្រឹមតែបានធូរស្រាលទេ គឺធ្វើឲ្យអ្នកជំងឺរឹតតែមានសភាពធ្ងន់ធ្ងរ ពិបាកក្នុងកែកុនឲ្យធូរស្បើយបាន យ៉ាងណាមិញ អ្នកស្វែងរកសេចក្ដីសុខ ឬមង្គលក៏ដូចគ្នា ខ្លួនឯងក៏មិនដឹង មិនស្គាល់វិធីប្រតិបត្តិដើម្បីទទួលបានសេចក្ដីសុខ ឬមង្គលស្រាប់ទៅហើយ ស្រាប់តែទៅជួបអ្នកល្ងង់អប្បឥតប្រាជ្ញាតាំងខ្លួនធ្វើជាគ្រូ ឬអ្នកចេះដឹង នាំទៅដោយខុសផ្លូវបន្ថែមទៀត ត្រូវខុសលើខុស បើមានហេតុដូច្នេះ ពួកគេមិនត្រឹមតែមិនអាចទទួលបានមង្គលសម្រាប់ជីវិតតែប៉ុណ្ណោះទេ គឺធ្វើឲ្យពួកគេមានវិបត្តិក្នុងជីវិតយ៉ាងធ្ងន់ធ្ងរបន្ថែមទៀត។

ព្រោះហេតុយ៉ាងនេះហើយ ទើបព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បានមើលឃើញពីភាពអវិជ្ជាក្នុងស្វែងរកមង្គល ឬសេចក្ដីសុខដោយមិនត្រឹមត្រូវតាមគន្លងនេះហើយ ទើបទ្រង់បានបង្រៀនមនុស្សលោក ឲ្យស្គាល់ច្បាស់ពីដំណើរហេតុដែលនោះឲ្យទទួលបានមង្គលពិតប្រាកដក្នុងជីវិត ដែលមានភាពសុក្រឹត និងសច្ចភាពដល់មនុស្សលោកឲ្យបានដឹង ស្គាល់ដោយខ្លួនឯង ដោយទ្រង់សង្កត់ធ្ងន់ថា មង្គលពិតប្រាកដមិនមែនបានមកពីអ្វីខាងក្រៅខ្លួននោះឡើយ តែមង្គលដែលពិតប្រាកដគឺកើតចេញពីការប្រតិបត្តិរបស់បុគ្គលម្នាក់ៗ គោលវិធីនៃការហេតុដែលនាំឲ្យទទួលបាននូវមង្គលពិតប្រាកដនោះ មានសេចក្ដីតាមលំដាប់លំដោយដូចខាងក្រោម៖

### ៤.១.១. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី១ (មាន៣ហេតុ)

**១. អសេវនា ច ពាលានំ**[20] កុំសេពគប់ពួកជនពាល ពាក្យថា ពាល នេះ មានប្រភពដើមថា ទ្វិ ពីរ និង លុ កាត់ ផ្លាស់ ទ្វិ ជា ពា ផ្លាស់ លុ ជា ល ផ្សំជា ពាល ប្រែថា អ្នកកាត់ប្រយោជន៍ពីរ គឺប្រយោជន៍ខ្លួនឯង និងប្រយោជន៍អ្នកដទៃឬប្រយោជន៍បច្ចុប្បន្ននិងប្រយោជន៍បរលោក។ពាលបើជាគុណនាមប្រែថាក្មេងទន់ ល្ងង់។

**អសប្បុរស ប្រកបដោយធម៌មាន ៤ យ៉ាងគឺ**

បុគ្គលនោះមិនបានពិចារណា ស្ទាបស្ទង់មើល ហើយពោលសរសើរ បុគ្គលដែលគួរតិះដៀល១

មិនបានពិចារណា ស្ទាបស្ទង់មើល ហើយពោលតិះដៀលបុគ្គលគួរសរសើរ១

មិនបានពិចារណា ស្ទាបស្ទង់មើល ហើយកើតសេចក្ដីជ្រះថ្លាក្នុងហេតុដែលមិនគួរជ្រះថ្លា១

មិនបានពិចារណា ស្ទាបស្ទង់មើល ហើយកើតសេចក្ដីមិនជ្រះថ្លាក្នុងហេតុដែលគួរជ្រះថ្លា១[21]។

ព្រះសម្មាសម្ពុទ្ធបានបង្រៀនថា បុគ្គលពាលមាន៣ជំពូកគឺ ៖

ក. បុគ្គលល្ងង់ខ្លៅ គ្មានគំនិតប្រាជ្ញា ហើយមិនគិតកសាងសមត្ថភាព និងគំនិតប្រាជ្ញា ជាបុគ្គលរីករាយក្នុងភាពល្ងង់ខ្លៅ មិនស្ដាប់ដំបូន្មានលោកអ្នកប្រាជ្ញ ឬចាស់ព្រឹទ្ធាចារ្យ ចាត់ទុកជាបុគ្គលពាលជំពូកមួយ ដោយហេតុធ្វើខ្លួនឱ្យជាបុគ្គលមិនមានប្រយោជន៍ ឬធ្វើខ្លួនឱ្យបាត់បង់ឱកាសក្នុងការសាងគុណតម្លៃ ក្នុងពេលដែលខ្លួនមានឱកាសកើតជាមនុស្ស។

---

[20] សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ ធម្មបទគាថា ឧទាន បឋមភាគ ៥២ ទំព័រ១៥

[21] សុត្តន្តបិដក ភាគ ៤២ ទំព័រ ៥

ខ. បុគ្គលស្វែងរកក្ដីសុខ ឬប្រយោជន៍ខ្លួនឯងដោយការធ្វើឱ្យខូចប្រយោជន៍អ្នកដទៃ ខូចក្ដីសុខអ្នកដទៃ ឬស្វែងរក ក្ដីសុខឱ្យខ្លួនឯងដោយការបៀតបៀតក្ដីសុខអ្នកដទៃ។

គ. បុគ្គលធ្វើឱ្យខូចប្រយោជន៍អ្នកដទៃផង ខ្លួនឯងផង។

ព្រះពុទ្ធបង្រៀនថា ដើម្បីញុំាងជីវលោកឱ្យបានប្រសើរ បុគ្គលគ្រប់រូបត្រូវតែមានទំនាក់ទំនងល្អជាមួយមនុស្សផងគ្នា ប៉ុន្តែការសេពគប់ត្រូវតែធ្វើឡើងដោយបញ្ញា ត្បិតថា បើសេពគប់ជាមួយមនុស្សប្រភេទណា យើងនឹងក្លាយជាមនុស្សប្រភេទនោះដែរ។ បុគ្គលពាលទាំង៣ជំពូកនេះ ជាប្រភេទមនុស្សគួរឱ្យខ្លាចជាងអ្វីៗទាំងអស់ ហើយមិនគប្បីសេពគប់ជាដាច់ខាត ព្រោះការសេពគប់ជាមួយបុគ្គលប្រភេទនេះ ក្រៅពីធ្វើឱ្យយើងវិនាសប្រយោជន៍ អសោចកេរ្តិ៍ឈ្មោះ អស់ទ្រព្យសម្បត្តិ ខាតពេលវេលា គំនិតប្រាជ្ញាទៅ ថែមទាំងនាំឱ្យយើងក្លាយជាបុគ្គលពាលជាមួយគេផងទៀត។ ព្រះពុទ្ធបានបង្រៀនថា ប្រសិនបើក្នុងលោកនេះ មានតែមនុស្សពីរនាក់ គឺម្នាក់ជារូបអ្នក ហើយម្នាក់ទៀតជាបុគ្គលពាល ក៏មិនគប្បីទៅសេពគប់ជាមួយបុគ្គលនោះឡើយ ហើយគប្បីនៅតែម្នាក់ឯងដោយរឹងមាំចុះ។ ការចេះប្រុងប្រយ័ត្ន ហើយចៀសវាងបាននូវការសេពគប់បុគ្គលពាលយ៉ាងណានេះ ជាមង្គលដ៏ឧត្តម។

**២. បណ្ឌិតានញ្ចសេវនា** គួរសេពគប់ពួកជនបណ្ឌិត ពាក្យថា បណ្ឌិត មានប្រភពដើមថា បឌិ ចេញមកជា បណ្ឌា ប្រែថា ប្រាជ្ញារក្សាខ្លួនឱ្យគេចចៀសវាងផុតចាកទុច្ចរិត ផ្សំជាមួយនឹង ឥក (បច្ច័យ) សម្រេចរួចជា បណ្ឌិត ប្រែថា អ្នកមានប្រាជ្ញារក្សាខ្លួនឱ្យគេចចៀសវាងផុតចាកទុច្ចរិត គឺអ្នកកាន់សុចរិតខ្ជាប់ខ្លួន ប្រែឲ្យខ្លីថា អ្នកប្រាជ្ញ គឺអ្នកមានគំនិតប្រាជ្ញាយល់ខុសត្រូវ ព្រមទាំងប្រព្រឹត្តកាន់សុចរិតយុត្តិធម៌ខ្ជាប់ខ្លួនផង[22]។

បណ្ឌិត គឺលោក អ្នកដែលមានចំណេះវិជ្ជាជ្រាលជ្រៅ ហើយមានគុណធម៌ខ្ពង់ខ្ពស់ និងសីលធម៌ថ្លៃថ្នូរ មិនបំផ្លាញប្រយោជន៍និងក្ដីសុខរបស់ខ្លួន និងមិនធ្វើឱ្យអ្នកដទៃខូចប្រយោជន៍ ឬខូចក្ដីសុខ មិនធ្វើឲ្យគេឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត។ម្យ៉ាងទៀត បុគ្គលដែលជាបណ្ឌិតតែងប្រកបដោយគុណធម៌ពីរយ៉ាងគឺៈ ជាបុគ្គលខ្មាសអៀនមិនហ៊ានធ្វើអំពើអាក្រក់ ហិរិ និងខ្លាចក្ដីអាក្រក់ មិនហ៊ានធ្វើអំពើអាក្រក់ទាំងឡាយ ទាំងក្នុងទីកំបាំង និងទីចំហរ ឱត្តប្បៈ។ ព្រះពុទ្ធបង្រៀនថា ដើម្បីបានក្ដីចម្រើនទាំងគំនិតប្រាជ្ញា ទាំងក្នុងសេដ្ឋកិច្ចជីវភាព និងដើម្បីបានជាប្រយោជន៍ទាំងឡាយ ពួកបុគ្គលគប្បីខ្នះខ្នែងស្វែងរកការសេពគប់ជាមួយបណ្ឌិត។ ដូច្នេះ កិរិយាសេពគប់នូវបុគ្គលដែលមានគតិបណ្ឌិត ជាមង្គលដ៏ឧត្តម។

ពាក្យថា បណ្ឌិត បានសេចក្ដីថា អ្នកប្រព្រឹត្តទៅដោយបញ្ញា ដោយញាណគតិ អ្នកប្រកបដោយបញ្ញាស្អាត អ្នកប្រាជ្ញ អ្នកមានប្រាជ្ញា អ្នកចេះដឹង អ្នកចេះសំដែងសេចក្ដីច្បាស់លាស់ អ្នកចេះវែកញែកបើកបង្ហាញសំដែងពន្យល់ ឲ្យងាយយល់នូវអាថ៌ធម៌ អ្នកឈ្លាស អ្នកប៉ិនប្រសប់ អ្នកវាងវៃមានប្រាជ្ញារឹងប៉ឹង អ្នកមាន

[22] កម្ពុជសុរិយា ៤៣/១/ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ គ.ស ១៩៧១ ទំព័រ ៥២

ប្រាជ្ញាខ្ជាប់ខ្ជួន អ្នកមានប្រាជ្ញាកាប់ឆ្កា អ្នកចេះលៃលក អ្នកមានញាណ អ្នកមានមតិល្អ អ្នកមានឧត្តមគតិ អ្នកចេះច្នៃខ្លួន អប់រំខ្លួនដោយសុចរិត។

**បណ្ឌិតចែកដោយន័យជាដំណើរមក ដោយសង្ខេបមាន៤០គឺ៖**

១ - បណ្ឌិតព្រោះរៀនស្ទាត់ខាងសិល្បៈមានសិល្បៈធ្នូជាដើម (សិប្បិបណ្ឌិត)

២- បណ្ឌិតព្រោះរៀនចេះអក្សរសាស្ត្រ ធម្មសាស្ត្រ បរិយត្តិជាដើម (ឧគ្គណ្ហនបណ្ឌិត)

៣ - បណ្ឌិតព្រោះចេះចាំច្រើន រៀនសូត្រស្តាប់ច្រើន (ពហុសច្ចបណ្ឌិត)

៤ - បណ្ឌិតព្រោះចូលសេពបណ្ឌិត រៀនស្តាប់ជាមួយ (បណ្ឌិតូបសំសេវបណ្ឌិត)

៥ - បណ្ឌិតព្រោះស្តាប់អ្នកប្រាជ្ញសំដែងរឿយៗ (សុតបណ្ឌិត)

៦ - បណ្ឌិតព្រោះការគិតត្រិះរិះ រាវរក ពិនិត្យ ពិសោធន៍ ល្បង (ចិន្តបណ្ឌិត)

៧ - បណ្ឌិតព្រោះចម្រើននូវគន្ធជាតុ អាយតនៈ ឥន្ទ្រិយ សច្ចៈ (ភាវនាបណ្ឌិត)

៨ - បណ្ឌិតព្រោះមានបញ្ញាពីកំណើត ដែលកើតអំពីធ្លាប់អប់រំ (សជាតិបណ្ឌិត)

៩ - បណ្ឌិតព្រោះចេះដោះខ្លួនឲ្យរួចអំពីឧបសគ្គ កណ្តាប់ដៃសត្រូវ (អត្តវិមោចនបណ្ឌិត)

១០ - បណ្ឌិតព្រោះឈ្លាសក្នុងឧបាយសព្វផ្លូវ (ឧបាយកោសល្លបណ្ឌិត)

១១ - បណ្ឌិតព្រោះស្គាល់ហេតុតូចធំ គួរមិនគួរ (ការណាការណេជាននបណ្ឌិត)

១២ - បណ្ឌិតព្រោះចេះស្គាល់វត្តទំនៀមលោក ប្រើឫកពាសមតាម (លោកវត្តជាននបណ្ឌិត)

១៣ - បណ្ឌិតព្រោះប្រសប់លៃទុកដាក់ខ្លួនតាមកាលៈទេសៈ (កាលវិចក្ខណបណ្ឌិត)

១៤ - បណ្ឌិតព្រោះវាងវៃក្នុងការដោះស្រាយបញ្ហា (បញ្ហាវិស្សជ្ជនបណ្ឌិត)

១៥ - បណ្ឌិតព្រោះចេះតម្កើងខ្លួនដោយសន្សំទ្រព្យឲ្យមាន (ធនសន្និចយបណ្ឌិត)

១៦ - បណ្ឌិតព្រោះគ្រប់គ្រងផ្ទះ តាមប្រយោជន៍ទាន់ភ្នែក) (ឃរាវាសបណ្ឌិត)

១៧ - បណ្ឌិតព្រោះចេះអាធ្យាស្រ័យ បុគ្គល បរិស័ទ (អជ្ឈាសយគ្គហាណបណ្ឌិត)

១៨ - បណ្ឌិតព្រោះដឹងគុណគេ ហើយធ្វើតបវិញ (កតញ្ញូកតវេទិបណ្ឌិត)

១៩ - បណ្ឌិតព្រោះចេះសង្គ្រោះដោយទាន សំដីល្អ ប្រាសចាកអកុសល (សង្គហបណ្ឌិត)

២១ - បណ្ឌិតព្រោះចេះថែទាំខ្លួនដោយល្អ ប្រាសចាកអកុសល (អត្តប្បដិជគ្គនបណ្ឌិត)

២១ - បណ្ឌិតព្រោះចេះតម្កល់ខ្លួនក្នុងគុណដ៏សមគួរ (បដិរូបនិវេសនបណ្ឌិត)

២២ - បណ្ឌិតព្រោះមានកល្យាណកម្ម អំពើល្អជាទីគាប់ចិត្ត (កល្យាណបណ្ឌិត)

២៣ - បណ្ឌិតព្រោះព្យាយាមកម្ចាត់មន្ទិលដោយបំពេញកុសល (មលនិទ្ធមបណ្ឌិត)

២៤ - បណ្ឌិតព្រោះចេះសន្សំបុណ្យបន្តិចម្តងៗ (បុញ្ញឧច្ចយបណ្ឌិត)

២៥ - បណ្ឌិតព្រោះលះកំណាញ់បំពេញទាន (បរិច្ចាគបណ្ឌិត)

២៦ - បណ្ឌិតព្រោះមានសីល ៥ ៨ ១០ និងសីល៤ (សីលបណ្ឌិត)

២៧ - បណ្ឌិតព្រោះមានបញ្ញាដឹងនូវទុក្ខ ហេតុទុក្ខ ការរលត់ទុក្ខ ហេតុរលត់ទុក្ខ (បញ្ញាបណ្ឌិត)

២៨ - បណ្ឌិតព្រោះត្រាស់ដឹងនូវសច្ចៈ ហើយឲ្យគេត្រាស់ដឹងផង (ពុទ្ធិបណ្ឌិត)

២៩ - បណ្ឌិតព្រោះត្រាស់ដឹងនូវសច្ចៈតាមក្រោយ (អនុពុទ្ធិបណ្ឌិត)

៣០ - បណ្ឌិតព្រោះចេះអត់ធន់នឹងសភាវធម៌ ធម្មជាតិ អន្តរាយ (ខន្តិបណ្ឌិត)

៣១ - បណ្ឌិតព្រោះព្យាយាមកម្ចាត់កិលេស អកុសលលាមក (វីរិយបណ្ឌិត)

៣២ - បណ្ឌិតព្រោះមិនមានពៀរភ័យរវាងខ្លួន និងអ្នកដទៃ (អវេរបណ្ឌិត)

៣៣ - បណ្ឌិតព្រោះការប្រព្រឹត្តស្មើដោយកាយ វាចា ចិត្ត (សមចរិយាបណ្ឌិត)

៣៤ - បណ្ឌិតព្រោះការដឹងនូវលោក ព្រោះស្ងៀមចាកអកុសល (មោនបណ្ឌិត)

៣៥ - បណ្ឌិតព្រោះពិចារណាឃើញត្រកូលវ័យជាដើម វៀរចាកអកុសល (បច្ចវេក្ខណបណ្ឌិត)

៣៦ - បណ្ឌិតព្រោះមានបញ្ញាចក្ខុកាន់យកនូវប្រយោជន៍ទាំងពីរ (អត្ថគ្គហណបណ្ឌិត)

៣៧ - បណ្ឌិតព្រោះធ្វើប្រយោជន៍ឲ្យខ្លួនឯងផង អ្នកដទៃផង (អត្តបរហិតបណ្ឌិត)

៣៨ - បណ្ឌិតព្រោះធ្វើខ្លួនឲ្យបានស្រួលឲ្យសុខសាន្ត (សុខីករណបណ្ឌិត)

៣៩ - បណ្ឌិតព្រោះច្នៃខ្លួនឲ្យបានល្អចម្រើន ចេះ (អត្តវិសោធនបណ្ឌិត)

៤០ - បណ្ឌិតព្រោះការឃើញទោសកាមគុណារម្មណ៍[23]។

បណ្ឌិតទាំងនេះ មានសទិសភាពតែមួយ មានលក្ខណៈ៣គឺ ការធ្វើល្អ ការនិយាយស្ដីល្អ ការគិតល្អ បំព្រួញមកនៅត្រឹមតែបីគឺ៖

១ - សយម្ភូបណ្ឌិត បណ្ឌិតចេះ ដឹងឯង ដោយផលបារមីធម៌

២ - អនុបណ្ឌិត បណ្ឌិតចេះដឹង តាមសយម្ភូបណ្ឌិត

៣ - ពីជបណ្ឌិត បណ្ឌិតដែលមានពូជជាតិបណ្ឌិតក្នុងខ្លួន

ក្នុងលោកនេះបុគ្គលដែលបានកើតមកជាមនុស្សហើយ បានជាបណ្ឌិតតែម្ដង កម្រមានណាស់ ប៉ុន្តែ ប៉ុន្តែបុគ្គលដែលមិនក្លាយជាបណ្ឌិតសោះនោះក៏មិនមានទេ បើទុកជាបុគ្គលនោះ កាន់អំពើពាលយ៉ាងណាក៏ដោយ ក៏គង់អាចច្នៃខ្លួនបាន ដោយការសេពគប់បណ្ឌិត ព្យាយាមជាដើម ព្រោះក្នុងសន្តានរបស់គេ តែងតែមានពូជជាតិបណ្ឌិតឋិតនៅ ដូចជាធាតុថ្លាតែងតែមានក្នុងទឹកជ្រាំ ឬដូចជាតិរសផ្អែមតែងតែមាននៅក្នុងផ្លែស្វាយខ្ចី ឬក៏ដូចពូជឈូកនៅក្នុងស្រះរីងទឹកក្នុងគិម្ហរដូវ។ ដូច្នេះមនុស្សឈ្មោះថា បណ្ឌិត ដោយពូជជាតិបណ្ឌិត ពូជជាតិបណ្ឌិតនេះនឹងដុះដាលឡើង ដោយការរៀន ដោយការសេពគប់បណ្ឌិតកល្យាណមិត្ត ដោយព្យាយាមជាដើម ដូចពូជឈូកនៅក្នុងស្រះ តែងតែដុះនៅពេលមានទឹកក្នុងវស្សានរដូវ ដូច្នោះ បើពុំដូច្នោះទេ មិនលូតលាស់ ដើម្បីបណ្ឌិតភាពឡើយ ដូចពូជឈូកមិនដុះក្នុងស្រះឥតទឹកដូច្នោះ។

[23] កម្ពុជសុរិយា ភាគ៣១/១ គ.ស១៩៥៩ ទំព័រ ៩

បុគ្គលជាពីជបណ្ឌិតអាចដើម្បីសាងខ្លួនឲ្យជាសយម្ភូបណ្ឌិតឬអនុបណ្ឌិតបានដោយព្យាយាម បណ្តុះបណ្តាលពូជបណ្ឌិត ដោយឧដ្ឋាន អប្បមាទ សញ្ញម ទម ដោយការសេពគប់សប្បុរស ដោយការអប់រំខ្លួនក្នុងរោងរៀន(សាលារៀន)វិជ្ជាស្ថានវិទ្យាល័យដោយនៅក្នុងសំណាក់អាចារ្យចេះច្រើនមានការពិសោធច្រើន មានសីលាចារ្យសមរម្យ ស្រគត់ស្រគំ ដោយការស្តាប់ គិត ដោយការលះបង់ចិត្ត គំនិត ចរិត អធ្យាស្រ័យអាក្រក់ ដោយឧបាយបន្តិចម្តងៗ ដោយភាពទៀងត្រង់ ទន់ភ្លន់សុភាព ប្រដៅងាយ ដោយទាន សីល ព្រហ្មវិហារ។

ពិជបណ្ឌិតកាលបានអប់រំខ្លួនយ៉ាងដូច្នេះហើយ បានឈ្មោះថាបណ្តុះពូជបណ្ឌិតឲ្យដុះតាមលំដាប់យូរៗទៅ មានបញ្ញាចាស់ក្លា មានកម្លាំងភ្លឺថ្លា អាចមើលឃើញច្បាស់ នូវត្រៃលោក ដូចគំនរភ្លើងគគីរ ៣ភ្នក់ធំ នូវលោកដែលកើលនឹងត្រៃលក្ខណ៍ នូវភ្លើងទុក្ខ ភ្លើងកិលេស នៅសង្សារវដ្តឥតចុងឥតដើម នៅក្នុងភ័យក្នុងសង្សារសាគរដ៏ធំធេងជ្រៅស្រឡូងឃើញយរាវាសធម៌ពោរពេញដោយសេចក្តីសាំញ៉ាំ។ ឃើញទោសរបស់កាមជាមេអសន្តិសុខ ព្យាបាទ វិហិង្សា ជាមេភ្លើង ប្រល័យលោក ដុតរោលលោក ឲ្យខ្លោមក្រៀមក្រំសៅហ្មងសោកសៅ ហើយធុញទ្រាន់នឹងលោក និងការកើត ចាស់ ឈឺ ស្លាប់ ឃើញច្បាស់នូវអានិសង្សនេក្ខម្មថា ក្សេម ឥតកង្វល់ លះបង់ភេទគ្រហស្ថទាំងអស់ ថ្វាយជីវិតបួសក្នុងព្រះពុទ្ធសាសនាប្រាសចាកឧបករណ៍ក្នុងផ្ទះ[24]។

បណ្ឌិតចេញអាល័យរបស់គ្រហស្ថ គឺកាមគុណហើយ ក៏ផ្តង់ចិត្តបោះគោលលើព្រះនិព្វាន ដែលឥតអាល័យឲ្យជាអារម្មណ៍ខាងដើមឲ្យជាទីសម្រាប់ដើរទៅនៃចិត្ត លោកតាំងយក សំវរៈ មត្តញ្ញុតា សទ្ធា វិរិយៈ ជាសេនាឯក ហើយតតាំងញ៉ាំញីមារ លះបង់ឲ្យជ្រះស្រឡះនូវធម៌ខ្មៅ គឺអកុសលធម៌ទាំងអស់ ដែលជាធម៌នាំឲ្យចិត្តខ្មៅ ឲ្យសៅហ្មងល្អក់កករ នាំសត្វទៅកាន់កន្លែងខ្មៅ កំណើតខ្មៅ ឥតសិរីសុខចម្រើន ដែលជាធម៌មានឫស៣គឺ លោភៈ ទោសៈ មោហៈ ចែកទៅមានទុច្ចរិត៣ ជាដើម។ តមកលោកព្យាយាមចម្រើនធម៌ស គឺកុសលធម៌ទាំងអស់ មានសុចរិត៣ជាដើម ដែលជាធម៌ស្អាត់បរិសុទ្ធម៉ដ្ឋចត់ផូរផង់ ឥតទោស ជាធម៌នាំចិត្តឲ្យស ឲ្យភ្លឺថ្លា នាំសត្វទៅកាន់កន្លែងស្អាត កំណើតស្អាត នាំសត្វទៅកាន់និព្វាន ដែលជាកន្លែងស្អាតចាកតណ្ហា មន្ទិល ទុក្ខគ្រប់ប្រការ លុះលោកបានចម្រើនធម៌សហើយ លោកត្រូវការចង់បាននូវអភិរតិ សេចក្តីត្រេកអរដែលកន្លងលែងនូវសេចក្តីត្រេកអរជារបស់មនុស្ស ទេវតាទាំងអស់ ក្នុងវិវេកគឺអមតនិព្វានដែលស្ងប់ស្ងាត់សូន្យចាកឧបធិគឺលេសទាំងឡាយ។

**៣. បូជា ច បូជនីយានំ** កិរិយាបូជាដល់បុគ្គលដែលគួរបូជា។

បូជា គឺការឱ្យ ការគោរពប្រតិបត្តិមានពីរយ៉ាងគឺះ

ក. បូជាដោយការឱ្យសម្ភារៈផ្សេងៗ (អាមិសបូជា)។

ខ. បូជាដោយការគោរពត្រង់ត្រាប់ ស្តាប់គំនិត យោបល់ និងអនុវត្តតាម (បដិបត្តិបូជា)។

---

[24] កម្ពុជសុរិយា ភាគ៣១/ គ.ស ១៩៥៩ ទំព័រ ១០

ការបូជា ជាការប្រសើរ ប៉ុន្តែ បើបូជាដល់បុគ្គលពាលគ្មានគុណធម៌ គ្មានសីលធម៌ ក្រៅពីមិនបានផលល្អដល់ខ្លួនឯង និងសង្គមទេ ក៏នៅរមែងបាននូវក្តីអន្តរាយ ក្តៅក្រហាយដោយសារបុគ្គលពាលនោះថែមទៀតផង ជាពិសេសនឹងក្លាយជាអ្នកលើកតម្កើងសភាវៈអាក្រក់។ ហេតុនេះ ការបូជាត្រូវតែធ្វើឡើងដោយបញ្ញា គឺធ្វើចំពោះបុគ្គលដែលគួរគោរពបូជា គឺជាបុគ្គលដែលមានគុណធម៌ខ្ពស់ មានសីលធម៌ដ៏ប្រពៃ តែងធ្វើនូវសេចក្តីសុខចម្រើន ដល់សង្គមមនុស្សជានិច្ច។ បូជនីបុគ្គលទាំងនេះ មានជាអាទិ៍ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មាតាបិតា គ្រូអាចារ្យ និងអ្នកដែលមានគុណូបការៈចំពោះខ្លួន ឬចំពោះសង្គមជាតិជាដើម។ ដូច្នេះការគោរពបូជាដល់បូជនីយបុគ្គលទាំងនេះ ជាមង្គលដ៏ឧត្តម។

### ៤.១.២. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី២ (មាន៣ហេតុ)

**៤. បដិរូបទេស វាសោច** កិរិយារស់នៅក្នុងប្រទេសដ៏សមគួរ។ ប្រទេសដ៏សមគួរ គឺប្រទេសដែលមានសុខសន្តិភាព គ្មានសង្គ្រាមកាប់សម្លាប់គ្នា និងបរិបូណ៌ដោយធម៌វិន័យ ច្បាប់ទម្លាប់ល្អប្រពៃ និងសម្បូរដោយអ្នកប្រាជ្ញ រាជបណ្ឌិត្យ អ្នកមានគុណធម៌ និងសីលធម៌ថ្លៃថ្នូរ ប្រព្រឹត្តប្រតិបត្តិច្បាប់រដ្ឋ និងធម៌វិន័យត្រឹមត្រូវ ជាប្រទេសដែលមានអ្នកដឹកនាំ និងមន្ត្រីប្រកបដោយធម៌ ដឹកនាំសង្គមជាតិដោយការគោរពច្បាប់ ដោយយុត្តិធម៌ និងជាហេតុនាំឱ្យមានក្តីចម្រើនរុងរឿង។ ការរស់នៅក្នុងប្រទេសបែបនេះជាការប្រពៃ ព្រោះជាគ្រឹះក្នុងការអភិវឌ្ឍគំនិតប្រាជ្ញាជាដើម។ កិរិយារស់នៅក្នុងប្រទេសដ៏សមគួរបែបនេះ ជាមង្គលដ៏ឧត្តម។

**៥. បុព្វេ កតបុញ្ញតា** ភាវៈនៃអ្នកបានធ្វើបុណ្យទុកហើយក្នុងកាលមុន។ ធម្មតាអ្នកដែលបានយល់ច្បាស់នូវផលល្អ នៃអំពើសុចរិត និងផលអាក្រក់នៃអំពើទុច្ចរិត តែងប្រញាប់ប្រញាល់វៀរចាកអំពើអាក្រក់គ្រប់យ៉ាង ហើយរួតរះធ្វើបុណ្យរាល់ៗជាតិ ព្រោះអំពើល្អតែងផ្តល់ផលជាសុខ។ ន័យនេះក៏បានដល់ការកសាង ឬការខិតខំប្រឹងប្រែងកសាងសមត្ថភាព និងលក្ខណៈសម្បត្តិគ្រប់យ៉ាង ដូចជាការត្រៀមធនធានទុកជាមុន លុះពេលត្រូវការក៏អាចយកសមត្ថភាព លក្ខណៈសម្បត្តិ និងធនធាននោះប្រើការបានប្រកបដោយប្រសិទ្ធភាព។ ដូច្នេះការខិតខំលះបង់បាននូវអំពើអាក្រក់ហើយព្យាយាមធ្វើឲ្យបាននូវអំពើល្អក្នុងកាលមុន ជាមង្គលដ៏ឧត្តម។

**៦. អត្តសម្មាបណីធិ ច** កិរិយាតម្កល់ខ្លួនទុកដោយប្រពៃ។ តម្កល់ខ្លួន មានន័យថា ការធ្វើខ្លួននៅក្នុងប្រភេទណាមួយ។ ប្រការនេះ បានដល់កិរិយាចេះពិចារណាឲ្យយល់ច្បាស់លាស់ថា អំពើល្អពិតជាផ្តល់ផលល្អ ឯអំពើអាក្រក់ពិតជាផ្តល់ផលអាក្រក់ ហើយក៏កើតមានសទ្ធាជឿកម្មផលយ៉ាងមុតមាំ ព្រមទាំងញ៉ាំងខ្លួនឲ្យព្យាយាមធ្វើតែអំពើល្អ មានធ្វើទាន និងរក្សាសីលជាដើម។ កិរិយាយល់ច្បាស់អំពីវិបាកនៃកម្ម ហើយប្រញាប់តម្កល់ខ្លួនក្នុងទានសីល ភាវនា សមាធិ ឲ្យនៅតែក្នុងសេចក្តីព្យាយាម មិនខ្ជីលច្រអូស តាំងខ្លួនឲ្យនៅក្នុងសតិឲ្យនៅឆ្ងាយពីការធ្វេសប្រហែស ឬមិនយកខ្លួនទៅជាប់ពាក់ព័ន្ធនឹងអំពើអាក្រក់ណាមួយ យ៉ាងនេះ ជាមង្គលដ៏ឧត្តម។

### ៤.១.៣. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៣ (មាន៤ហេតុ)

- ភាវៈជាបុគ្គលបានស្តាប់បានរៀនសូត្រចេះដឹងច្រើន ( ពាហុសច្ច )
- សេចក្តីឆ្លៀវឆ្លាតប៉ិនប្រសប់ក្នុងសិល្បៈទាំងពួង ( សិប្បៈ )

- វិន័យដែលបុគ្គលបានសិក្សាហើយដោយប្រពៃ ( វិនយោ ចសុសិក្ខិតោ )

- វាចាដែលបុគ្គលពោលដោយប្រពៃ ( សុភាសិតា ច យា វាចា )ទាំងបួននេះជាមង្គលដ៏ឧត្តម។

**៧. ពាហុសច្ចំ** ភាវៈជាបុគ្គលបានស្តាប់បានរៀនសូត្រចេះដឹងច្រើន។ ប្រការនេះ បានដល់ការ ស្តាប់ ការអាន និងសិក្សារៀនសូត្រចំណេះវិជ្ជាទាំងផ្លូវលោក និងផ្លូវធម៌ ស្តាប់ឱវាទរបស់បណ្ឌិតទាំងឡាយ និងដំបូន្មានរបស់ព្រឹទ្ធាចារ្យ មាតា បិតា គ្រូ និងរៀមច្បងជាដើម។ ដើម្បីក្លាយជាបុគ្គលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ មានសមត្ថភាព និងមានគំនិតប្រាជ្ញាភ្លឺត្រចះត្រចង់ ដែលជាហេតុញ៉ាំងប្រយោជន៍ និងសេចក្តីសុខចម្រើនដល់ខ្លួនឯង និងអ្នកដទៃយ៉ាងពិតប្រាកដ។ ការខិតខំស្តាប់ អាន និងសិក្សារៀនសូត្រឱ្យបានចេះដឹងជ្រៅជ្រះយ៉ាងនេះ ជាមង្គលដ៏ឧត្តម។

**៨. សិប្បៈ** សេចក្តីឆ្លៀវឆ្លាតប៉ិនប្រសប់ក្នុងសិល្បៈទាំងពួង។ ប្រការនេះបានដល់ការចេះដឹង និងការប៉ិនប្រសប់ ស្ទាត់ជំនាញក្នុងសិប្បកម្ម បច្ចេកទេសទាំងឡាយ យ៉ាងហោចណាស់ឱ្យស្ទាត់ជំនាញនូវមុខវិជ្ជាណា ដែលខ្លួនបានសិក្សា (ឬនៅក្នុងមុខតំណែងដែលខ្លួនប្រកបធ្វើ) ដែលនាំមកនូវប្រយោជន៍ និងសេចក្តីសុខចម្រើនដល់ខ្លួនឯង និងអ្នកដទៃ។ ដូច្នេះ កិរិយាឆ្លៀវឆ្លាត ឆ្លាសវៃ ប៉ិនប្រសប់ក្នុងសិប្បកម្ម ហត្ថកម្មទាំងពួង ជាមង្គលដ៏ឧត្តម។

**៩. វិនយោ ច សុសិក្ខិតោ** វិន័យដែលបុគ្គលបានសិក្សាហើយដោយប្រពៃ។ វិន័យ គឺជាច្បាប់ទម្លាប់របស់ប្រទេស និងរបស់ព្រះពុទ្ធសាសនា សម្រាប់គ្រហស្ថបានដល់សីល៥ សីល៨ និងច្បាប់របស់រដ្ឋជាដើម។ សម្រាប់បព្វជិត បានដល់វិន័យរបស់អ្នកបួស និងច្បាប់របស់រដ្ឋជាដើម។ បុគ្គលដែលមានចំណេះវិជ្ជា មានទ្រព្យសម្បត្តិយសសក្តិ មានត្រកូលខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ ប្រសិនបើគេជាបុគ្គលអនាចារ គ្មានវិន័យ គ្មានសីលធម៌រស់នៅ ដោយការបំពានលើច្បាប់នោះ គេនឹងមិនទទួលបានការគោរពកោតសរសើរឡើយ ប្រសិនបើទទួលបានវិញ គឺបានតែពួកមនុស្សអែបអប រណេបរណបប៉ុណ្ណោះ ហើយមិនយូរប៉ុន្មានគេនឹងទទួលបាននូវក្តីវិនាសជាមិនខាន។ ហេតុនេះ កិរិយារៀនវិន័យ និងច្បាប់រដ្ឋ និងព្យាយាម ប្រព្រឹត្តប្រតិបត្តិឲ្យបានត្រឹមត្រូវជាមង្គលដ៏ឧត្តម។

**១០. សុភាសិតា ច យា វាចា** វាចាដែលបុគ្គលពោលដោយប្រពៃ។ មនុស្សតែងប្រើការនិយាយជាមធ្យោបាយទំនាក់ទំនងនិងផ្តល់ព័ត៌មានដល់គ្នានិងគ្នាប៉ុន្តែ ព្រះពុទ្ធបានបង្រៀនយើងឲ្យចេះជ្រើសរើស ពាក្យសម្តីសម្រាប់និយាយស្តីឱ្យដូចជាកសិករជ្រើសរើសគ្រាប់ពូជសម្រាប់ដាំដុះសាបព្រោះយ៉ាងនោះដែរហើយព្រះអង្គតែងបានបង្រៀនយើង កុំឱ្យពោលពាក្យណាដែលធ្វើឱ្យអ្នកដទៃឈឺចាប់ ខូចប្រយោជន៍ បែកបាក់សាមគ្គី ឬពាក្យរោយរាយឥតប្រយោជន៍។ពាក្យល្អពីរោះមានប្រយោជន៍ សូម្បីតែមួយឃ្លា មួយប្រយោគ ក៏ប្រសើរជាងពាក្យរោយរាយឥតប្រយោជន៍រាប់ពាន់ប្រយោគដែរ។ ពាក្យដ៏ប្រពៃសំដៅដល់ **កថាវត្ថុ** គឺពាក្យដែលបុគ្គលគប្បីពោល១០យ៉ាង គឺពោលអំពីការមិនលោភលន់១ អំពីការសន្តោស១ អំពីការស្ងប់ស្ងាត់កាយ និងចិត្ត១ អំពីការនៅមិនច្របូកច្របល់ដោយពួកក្រុម១ អំពីការព្យាយាម១ អំពីសីល១ អំពីសមាធិ១ អំពីបញ្ញា១ អំពីព្រះនិព្វាន១ និងអំពីធម៌រំលត់ទុក្ខ១។ កិរិយាពោលនូវពាក្យដ៏ប្រពៃយ៉ាងនេះ ជាមង្គលដ៏ឧត្តម។

### ៤.១.៤. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៤ (មាន៤ហេតុ)

**១១-១២. មាតាបិតុ ឧបដ្ឋានំ** កិរិយាបម្រើ ឬទំនុកបម្រុងមាតានិងបិតា។ កូនប្រុស-ស្រីមានកាតព្វកិច្ចត្រូវចិញ្ចឹមមាតាបិតា ធ្វើការងារជំនួសគាត់ រក្សាវង្សត្រកូលឲ្យគង់វង្ស និងខ្ពង់ខ្ពស់ ធ្វើខ្លួនឲ្យសមរម្យជាអ្នក

ទទួលមរតកពីគាត់ ធ្វើបុណ្យជូនគាត់ជាដើម ព្រោះថា កូនដែលដឹងគុណមាតាបិតា ហើយប្រព្រឹត្តប្រតិបត្តិគោរពមាតាបិតាដូចពោលមកនេះ រមែងមិនច្យុតឡើយ។ ដូច្នេះ កិរិយាបម្រើ ទំនុកបម្រុងមាតាបិតា ជាមង្គលដ៏ឧត្តម។

**១៣. បុត្តទារស្ស សង្គហោ** កិរិយាសង្គ្រោះបុត្រនិងភរិយា។ មាតាបិតាដែលបានបំពេញកាតព្វកិច្ច៥ប្រការចំពោះកូន គឺហាមឃាត់កូនកុំឲ្យប្រព្រឹត្តអំពើអាក្រក់១ ណែនាំកូនឱ្យធ្វើតែអំពើល្អ (ទាំងការគិត ទាំងសកម្មភាព និងពាក្យសម្តី) ជាអំពើមានតែប្រយោជន៍ មិននាំផលក្តៅក្រហាយ១ ទំនុកបម្រុងកូនឲ្យបានរៀនសូត្រឲ្យមានចំណេះដឹង មានសមត្ថភាពអាចរស់នៅដោយថ្លៃថ្នូរ១ ទុកដាក់កូនឲ្យមានគូស្រករត្រឹមត្រូវ១ និងចែកទ្រព្យសម្បត្តិឲ្យកូនបានសមរម្យ១ឈ្មោះថាជាមាតាបិតាសង្គ្រោះបុត្រយ៉ាងល្អ។ ឯស្វាមីដែលបានបំពេញកាតព្វកិច្ច៥ប្រការចំពោះភរិយាគឺ និយាយពាក្យផ្អែមល្ហែមនឹងភរិយា១ មិនមើលងាយភរិយា១ មិនក្បត់ភរិយា១ ផ្គត់ផ្គង់ភរិយា១ និងផ្តល់សិទ្ធិក្នុងផ្ទះឱ្យភរិយា១ ឈ្មោះថាស្វាមីសង្គ្រោះភរិយា។ បុរសដែលបានធ្វើកិច្ចនេះដោយពេញលេញ និងទៀងទាត់ឈ្មោះថា ជាអ្នកបានកសាងគ្រឹះសុភមង្គលទាំងក្នុងគ្រួសារ និងសម្រាប់សង្គមជាតិ។ ដូច្នេះ កិរិយាព្យាយាមប្រព្រឹត្តឱ្យបានល្អក្នុងការសង្គ្រោះបុត្រ និងភរិយា ជាមង្គលដ៏ឧត្តម។

**១៤. អនាកុលា ច កម្មន្តា** ការងារទាំងឡាយដែលមិនច្របូកច្របល់។ នេះបានដល់ការចេះបែងចែកប្រភេទការងារឱ្យដាច់ដោយឡែកពីគ្នា និងបំពេញស្រេចរួចរាល់មិនទុកចោលកណ្តាលទី។ អ្នកដែលធ្វើការមិនច្របូកច្របល់គឺជាអ្នកដែលមានសេចក្តីព្យាយាម ម៉ឺងម៉ាត់ដែលអាចឱ្យសម្រេចបានរាល់ការងារបានយ៉ាងល្អ។ ធ្វើបានយ៉ាងនេះ ពិតជានាំមកសេចក្តីចម្រើនជាលំដាប់។ ដូច្នេះ ការងារទាំងឡាយដែលមិនច្របូកច្របល់ ជាមង្គលដ៏ឧត្តម។

### ៤.១.៥. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៥ (មាន៤ហេតុ)

**១៥. ទានំ** កិរិយាបរិច្ចាគទាន។ ទាន គឺការឱ្យហើយគោលដៅ និងបំណងនៃការឱ្យនេះ គឺមិនមែនក្នុងបំណងដើម្បីទទួលបានការតបពីគេមកវិញឡើយ។ បុគ្គលដែលបានឲ្យរបស់អ្វីម្យ៉ាង ទៅបុគ្គលណាហើយរំពឹងចង់បានការតបស្នងដោយប្រការណាមួយ បុគ្គលនោះមិនមែនជាអ្នកធ្វើទានទេ គឺជាអ្នកធ្វើវិនិយោគ។ ការធ្វើទាន គឺដើម្បីកាត់បន្ថយនូវគម្លាតគ្នារវាងអ្នកមាន និងអ្នកក្រ និងជាការលើកស្ទួយវប្បធម៌ចែករំលែក ក៏ជាវិធីដើម្បីកុំឲ្យមនុស្សគិតតែពីការបាន ដែលជាហេតុបង្កឲ្យមានទំនាស់ផ្សេងៗដោយសារ ដណ្តើមផលប្រយោជន៍។ ធ្វើទានបានដល់ការធ្វើអំណោយពីរយ៉ាងគឺ ការឲ្យសម្ភារៈសម្រាប់ទ្រទ្រង់ជីវិតដូចជា សម្លៀកបំពាក់ចំណីអាហារ ផ្ទះសម្បែង និងថ្នាំព្យាបាលរោគជាដើមហៅថា អាមិសទាន គឺការឱ្យវត្ថុ សម្ភារៈ១ និងការឱ្យចំណេះវិជ្ជាគំនិតយោបល់ល្អ ដើម្បីគេបានស្គាល់ខុសត្រូវ ស្គាល់ផ្លូវ ទៅរកប្រយោជន៍ និងភាពជោគជ័យល្អអាក្រក់ បុណ្យបាបជាដើមហៅថា ធម្មទាន គឺការឲ្យចំណេះវិជ្ជា គំនិតប្រាជ្ញា១។ កិរិយាដែលបានធ្វើនូវទានទាំងពីរប្រការនេះ ជាមង្គលដ៏ឧត្តម។

**១៦. ធម្មចរិយា** កិរិយាប្រព្រឹត្តធម៌ដ៏ប្រសើរ។ បានដល់ធម៌១០យ៉ាងគឺ កិរិយាមិនសម្លាប់១ កិរិយាមិនលួចប្លន់១ កិរិយាមិនប្រព្រឹត្តល្មើសក្នុងកាមតណ្ហា១ កិរិយាមិនកុហកឆបោកកេងប្រវ័ញ្ច១ កិរិយាមិនពោលពាក្យញុះញង់អុជអាលបំបែកបំបាក់១កិរិយាមិនពោលពាក្យអាក្រក់អសុរោះ១កិរិយាមិនពោលពាក្យរោយរាយឥតប្រយោជន៍១ កិរិយាមិនលោភលន់លើទ្រព្យអ្នកដទៃ១ កិរិយាមិនគុំគួនព្យាបាទអ្នកដទៃ១ និងកិរិយាយល់ត្រឹមត្រូវ គឺយល់ថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ និងយល់តាមសភាវៈពិតនៃធម្មជាតិ និងលោកិយ១។

កិរិយាដែលចេះពិចារណាឱ្យបានជាក់ច្បាស់ ហើយប្រព្រឹត្តឱ្យបានត្រឹមត្រូវតាមធម៌ទាំង១០ប្រការនេះ ជាមង្គលដ៏ឧត្តម។

**១៧. ញាតកានញ្ច សង្គហោ** កិរិយាសង្គ្រោះញាតិទាំងឡាយ។ ដែលហៅថាញាតិ បានដល់បងប្អូនជាញាតិសន្តានទាំងពីរខាង គឺតាំងពីដូនតាជំនាន់ទី៧ខាងមាតាចុះមក និងតាំងពីដូនតាទី៧ខាងបិតាចុះមក (ដែលហៅថា ញាតិប្រាំពីរសន្តាន)។ មនុស្សល្អតែងស្រឡាញ់រាប់អាន និងសង្គ្រោះ យឹតយោង លើកស្ទួយផ្ទុងផ្ដើមឲ្យញាតិសន្តានរបស់ខ្លួនឲ្យបានសិក្សាអប់រំ មានមុខរបរការងារសុចរិត និងជួយដាស់តឿនដឹកនាំឲ្យពួកគេដើរលើផ្លូវល្អ ផ្លូវត្រឹមត្រូវយ៉ាងប្រពៃ ចូរប្រយ័ត្នប្រយែងក្រែងក្លាយជាជនអគតិ គឺលម្អៀង ប្រព្រឹត្តប្រាសចាកច្បាប់ និងគុណធម៌ (ដោយសារតែការយោគយល់ថា ជាសាច់ញាតិ)។ ដូច្នេះ ការចេះស្រឡាញ់រាប់អាន និងសង្គ្រោះញាតិសន្តានរបស់ខ្លួនដោយប្រពៃ ជាមង្គលដ៏ឧត្តម។

**១៨. អនវជ្ជានិ កម្មានិ** កិរិយាប្រកបការងារទាំងឡាយដែលមិនមានទោស។ ការងារទាំងឡាយដែលផ្ទុយនឹងអំពើអាក្រក់ ទុច្ចរិត អយុត្តិធម៌ទាំងឡាយ លោកហៅថា ការងារបរិសុទ្ធ ឬសម្មាអាជីវៈ។ ការងារដែលមិនមានទោសដូចជា ការចិញ្ចឹមមាតា បិតា គ្រូអាចារ្យ ចាស់ព្រឹទ្ធាចារ្យ កុមារកំព្រា ជនពិការ អ្នកកម្សត់ទុគ៌តការកសាងសម្បត្តិសាធារណៈមាន ស្ពាន ថ្នល់ សាលារៀនជាដើម និងការចែកចាយសៀវភៅធម៌អាថ៌ ក្បួនច្បាប់ ឬពន្យល់ផ្សព្វផ្សាយនូវចំណេះវិជ្ជាដ៏ល្អ នូវធម៌ដ៏ប្រពៃដល់អ្នកដទៃដើម្បីឲ្យគេបានយល់ស្គាល់ខុសត្រូវល្អអាក្រក់ ហើយព្យាយាមប្រព្រឹត្តតែអំពើល្អជាដើម។ ទាំងនេះ គឺជាការងារមិនមានទោស។ ការប្រព្រឹត្តតែការងារមិនមានទោស ជាមង្គលដ៏ឧត្តម។

### ៤.១.៦. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៦ (មាន៣ហេតុ)

**១៩. អារតី វិរតីបាបា** កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប។ ការមិនត្រេកអរក្នុងបាបបានដល់ចិត្តដែលមិនត្រេកអរនៅពេលដឹង ឮ ឬឃើញ គេគិត ឬកំពុងធ្វើអំពើអាក្រក់អំពើបាបទាំងឡាយមានការប្រព្រឹត្តខុសក្នុងកាម ការកុហកកេងប្រវ័ញ្ច ឆបោក និងធ្វើអំពើទាំងឡាយជាអបាយមុខ ឬមានការកាប់សម្លាប់ជីវិត ធ្វើទុក្ខបុកម្នេញ បៀតបៀតក្ដីសុខដល់គ្នានឹងគ្នាជាដើមផង ថែមទាំងមានក្ដីសង្វេគតក់ស្លុតចំពោះអំពើទាំងនោះទៀតផង។ឯការវៀរចាកបាបបានដល់ការចៀសវាងមិនប្រព្រឹត្តធ្វើនូវអំពើបាបទាំងឡាយដូចដែលបានពោលមកហើយជាដើម ព្រោះមានសទ្ធាជឿជាក់ថា ធ្វើល្អពិតជាបានល្អ ធ្វើអាក្រក់ពិតជាបានអាក្រក់។ ដូច្នេះ កិរិយាដែលមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាបយ៉ាងនេះ ជាមង្គលដ៏ឧត្តម។

**២០. មជ្ជបានា ច សញ្ញមោ** សេចក្ដីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង។ នេះបានដល់ការតមសុរា និងមេរ័យគ្រប់ប្រភេទ ព្រោះបានយល់ច្បាស់នូវផលអាក្រក់ នៃការផឹកទឹកស្រវឹងនេះដូចជា អស់ប្រាក់កាស ខាតពេលវេលា ខូចសុខភាព ធ្វើឲ្យខ្សោយគំនិតប្រាជ្ញា និងជួនកាល បណ្ដាលឱ្យមានកិរិយាថោកទាប និងឈ្លោះទាស់ទែងគ្នាទៀតផង។ ដូច្នេះការពិចារណាឲ្យឃើញច្បាស់នូវទោសនៃសុរា ហើយតាំងចិត្តព្យាយាមចៀសវាងឱ្យបាន នូវការផឹកទឹកស្រវឹងគ្រប់ប្រភេទ ជាមង្គលដ៏ឧត្តម។

**២១. អប្បមាទោ ច ធម្មេសុ** ការមិនប្រមាទក្នុងធម៌ទាំងឡាយ។ នេះបានដល់ការមិនធ្វេសប្រហែសភ្លេចខ្លួន ព្រោះថា ការបណ្ដោយខ្លួនឱ្យលង់លក់ទៅក្នុងអំពើអកុសល និងអបាយមុខមានស្រី ស្រា និងល្បែងស៊ីសងជាដើម គឺជាមូលហេតុនៃសេចក្ដីវិនាសអន្តរាយគ្រប់យ៉ាង។ បុគ្គលមិនប្រមាទរមែងមិនភ្លេចខ្លួន ហើយតែងភ្ញាក់រឭកយល់ត្រូវជានិច្ច ដែលជាកត្តានាំមកនូវសេចក្ដីចម្រើនដល់ខ្លួនឯង និងសង្គម សមដូចពុទ្ធភាសិត

ថា **អប្បមាទោ អមតំបទំ ការមិនប្រមាទ ជាផ្លូវនៃក្ដីមិនស្លាប់**។ ដូច្នេះ ការមិនប្រមាទ ហើយភ្ញាក់រឭកព្យាយាម ធ្វើតែអំពើល្អ សុចរិត យុត្តិធម៌ ជាមង្គលដ៏ឧត្ដម។

### ៤.១.៧. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៧ (មាន៥ហេតុ)

**២២. គារវោ ច** កិរិយាគោរពចំពោះបុគ្គលដែលគួរគោរព។ ការគោរពត្រូវប្រកបដោយអង្គបី គឺដោយកាយ គឺឱនលំទោនលើកដៃសំពះ១ ដោយវាចា គឺពោលពាក្យទន់ភ្លន់សុភាពរាបសា១ និងដោយចិត្ត គឺមិនប្រមាថ១។ ឯបុគ្គលដ៏ជាទីគោរពនោះ គឺបានដល់បុគ្គលដែលមានគុណធម៌ខ្ពង់ខ្ពស់ទាំងឡាយមានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មាតា បិតា គ្រូអាចារ្យជាដើម១ បុគ្គលដែលមានជាតិត្រកូលនិងគុណធម៌ខ្ពង់ខ្ពស់ដូចជាលោកជាអ្នកប្រាជ្ញនិងអ្នកដឹកនាំរដ្ឋ មានមន្ត្រី រាជការ ដែលមានភាពសុចរិតទៀងត្រង់ តាំងនៅក្នុងច្បាប់ជាដើម១ និងបុគ្គលដែលមានអាយុច្រើនដូចជារៀមច្បងនិងចាស់ព្រឹទ្ធាចារ្យ ជាដើម១។ ការធ្វើនូវសេចក្ដីគោរពចំពោះ គារវបុគ្គលទាំងនេះ ជាមង្គលដ៏ឧត្ដម។

**២៣. និវាតោ ច** កិរិយាប្រព្រឹត្តបន្ទាបខ្លួន។ នេះបានដល់ការខិតខំជម្រុះនូវគំនិតដែលសម្គាល់ខ្លួនឯងជាតិសាសន៍ខ្លួនជាតិត្រកូលខ្លួន ពូជអម្បូរខ្លួនថាប្រសើរជាងគេ។ ព្រោះថា គំនិតនេះ នឹងនាំឱ្យកើតអស្មិមានៈក្នុងខ្លួន ហើយមើលងាយអ្នកដទៃ ដែលជាមូលហេតុឱ្យមានការប្រជែងវាសនា និងជាហេតុនៃសេចក្ដីវិនាសអន្តរាយគ្រប់យ៉ាង។ បុគ្គលទោះមានឋានៈ យសសក្តិ ទ្រព្យសម្បត្តិ ចំណេះវិជ្ជាយ៉ាងណាក្ដី បើជាបុគ្គលក្រអឺតក្រទម មិនសង្រួមទេនោះ នឹងមិនទទួលបានការគោរពរាប់អាន និងកោតសរសើរឡើយ ប៉ុន្តែបើបែរជាបានវិញ គឺបានតែពីសម្នាក់ពួកជនប្លម ប្រចុបប្រចែង និងជនពាលតែប៉ុណ្ណោះ។ ដរាបណាគំនិតប្រកាន់ពូជសាសន៍ ជាតិ ត្រកូល និងអស្មិមានៈបានត្រូវលះបង់អស់ហើយ ហើយប្រព្រឹត្តធ្វើតែអំពើល្អ ព្រោះក្ដីមិនប្រមាថដរាបនោះ សេចក្ដីសុខចម្រើននឹងកើតមានជាមិនខាន។ ដូច្នេះ ការប្រព្រឹត្តបន្ទាបខ្លួន ជាមង្គលដ៏ឧត្ដម។

**២៤. សន្តុដ្ឋី ច** សេចក្ដីសន្តោសត្រេកអរចំពោះរបស់ដែលមាន។ នេះបានដល់សភាពនៃចិត្តដែលត្រេកអរ ទៅតាមមានតាមបាន គឺទៅតាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួនដែលមាន។ ព្រះពុទ្ធបានបង្រៀនមនុស្សឱ្យចេះខិតខំប្រឹងប្រែងព្យាយាម បំពេញការងារឲ្យយ៉ាងអស់ពីសមត្ថភាព និងសក្ដានុពលរបស់ខ្លួន ប៉ុន្តែ ការដែលបានសម្រេចសមតាមបំណងប៉ុណ្ណា ក៏គោងចេះឱ្យតម្លៃ និងពេញចិត្តរបស់ទាំងនោះ ព្រោះថា ក្នុងលោកនេះ ប្រសិនបើមនុស្សប្រាថ្នាអ្វីបានហ្នឹងនោះ ពិភពលោកមុខជាមិនបានគង់វង្សមកដល់ថ្ងៃនេះទេ។ ម្យ៉ាងសោតរឿងពិតក្នុងលោក តែងតែមានការមិនសមបំណងជារឿយៗ ហេតុនេះ ដើម្បីរស់នៅដោយចុះសម្រុង និងមានក្ដីសុខនោះ គឺត្រូវចេះទទួលស្គាល់ការពិត និងស្កប់ស្កល់ចំពោះអ្វីដែលបានមកពីការខិតខំរបស់ខ្លួន។ បុគ្គលដែលមានសន្តានចិត្តសន្តោស រមែងមិនភ្លើតភ្លើន លោភលន់ ភ្លេចខ្លួន រហូតមើលងាយ ឬច្រណែននឹងអ្នកដទៃ នៅពេលដែលខ្លួនមានលាភ យសសក្តិ ទ្រព្យសម្បត្តិក្ដី ឬធ្លាក់ខ្លួនក្រខ្សត់បាត់យសសក្តិក្ដី។ ដូច្នេះ ការព្យាយាមអប់រំចិត្តខ្លួនឲ្យបានជាចិត្តសន្តោសយ៉ាងនេះ ជាមង្គលដ៏ឧត្ដម។

**២៥. កតញ្ញុតា** ភាពជាអ្នកដឹងឧបការគុណ ដែលអ្នកដទៃធ្វើហើយដល់ខ្លួន។ បុគ្គលបែបនេះឈ្មោះថាកតញ្ញូបុគ្គល។ បុគ្គលកតញ្ញូដែលបានតបស្នងឧបការគុណគេវិញឈ្មោះថា កតញ្ញូកតវេទីបុគ្គល។ ឯបុគ្គលដែលបានធ្វើឧបការគុណ គឺសេចក្ដីល្អគ្រប់យ៉ាងដល់អ្នកដទៃ ឈ្មោះថា បុព្វការី។ មាតាបិតា ជាបុព្វការីរបស់កូនព្រោះលោកបានបង្កើត ព្រោះលោកបានបង្ហាត់បង្រៀនបុត្រ។ ព្រះសម្មាសម្ពុទ្ធ ជាបុព្វការីរបស់ពុទ្ធបរិស័ទ និងមនុស្ស សត្វទាំងឡាយ ព្រោះព្រះអង្គបានព្យាយាមរកឃើញនូវមាគ៌ារំដោះទុក្ខ គឺអដ្ឋង្គិកមគ្គ ដើម្បីមនុស្ស

សត្វ ទេព្តាទាំងអស់។ល។ បើមិនមានបុព្វការីជនមានមាតាបិតាជាដើមទេនោះ សង្គមមនុស្សក៏មិនអាចស្ថិតស្ថេរីកចម្រើនបានឡើយ គោងប្រយ័ត្នបុគ្គលខ្លះដឹងថា យើងជាមនុស្សមិនបំភ្លេចគុណ និងតែងតបស្នងគុណគេវិញជាប្រក្រតីនោះ ក៏បានឆ្លៀតឱកាសបង្កហេតុ ហើយធ្វើជាមកជួយយកអាសាយើង ដើម្បីឱ្យយើងជំពាក់គុណគេ (ទើបគេឱ្យយើង ធ្វើអ្វីម្យ៉ាងដែលនាំមកនូវផលអាក្រក់ណាមួយ)។ ដូច្នេះ ការខិតខំកសាងខ្លួនឱ្យបានជា កតញ្ញូកតវេទីបុគ្គលផង ទាំងបុព្វការីបុគ្គលផង ជាមង្គលដ៏ឧត្តម។

**២៦. កាលេន ធម្មស្សវនំ** កិរិយាស្តាប់នូវធម៌តាមកាល។ ធម៌ ជាផែនទីសម្រាប់ស្វែងរកកំណប់ គឺផលប្រយោជន៍ និងក្តីសុខក្នុងជីវិត។ ប្រការនេះបានដល់ការខិតខំឆ្លៀតពេលដ៏មមាញឹក នៃជីវិតប្រចាំថ្ងៃ ទៅស្តាប់ព្រះធម៌ យ៉ាងហោចណាស់មួយអាទិត្យបានម្តង ព្រោះថាធម៌ គឺជាគុណជាតិបំភ្លឺបង្ហាញប្រាប់ឱ្យស្គាល់ខុសស្គាល់ត្រូវ គុណទោស ល្អអាក្រក់ បុណ្យបាបយ៉ាងសត្យានុម័ត ដែលអាចយកទៅប្រព្រឹត្តបានសេចក្តីសុខខ្លួនឯង និងសង្គមជាតិ (ចំពោះទស្សនៈដែលថា ចាំដល់ចាស់ ឬពេលចូលនិវត្តន៍ពីការងារ សឹមស្តាប់ធម៌នោះ ជាទស្សនៈមិនត្រឹមត្រូវឡើយ)។ ដរាបណាមានអ្នកប្រព្រឹត្តប្រតិបត្តិធម៌ គឺសេចក្តីល្អកាន់តែច្រើន ដរាបនោះ សង្គមជាតិ និងពិភពលោកកាន់តែរីកចម្រើន និងសុខសាន្ត។ ដូច្នេះ ការព្យាយាមស្តាប់ធម៌តាមកាល ជាមង្គលដ៏ឧត្តម។

### ៤.១.៨. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៨ (មាន៤ហេតុ)

**២៧. ខន្តិ ច** សេចក្តីអត់ធ្មត់។ ខន្តី គឺសភាពនៃចិត្តស្ងៀមស្ងាត់ស្ងប់ម្ងាប់នឹងនរ ទោះត្រូវរងនូវអំពើអាក្រក់បែបណាមួយដូចជារងការប្រមាថ ឬភាពអយុត្តិធម៌ជាដើម។ តាមធម្មតាក្នុងស្ថានភាពបែបនេះ អ្នកដែលគ្មានខន្តី រមែងមានសេចក្តីក្រោធខឹងក្តៅក្រហាយជាប្រាកដ ហើយតែងតបទៅវិញដោយអំពើហិង្សា ឬពាក្យទ្រគោះដោយប្រការណាមួយមិនខាន ដែលជាហេតុនាំមកនូវជម្លោះគ្រប់ប្រភេទ។ ចំណែកឯអ្នកមានខន្តីធម៌វិញ ពេលរងនូវអំពើអាក្រក់បែបណា រមែងមិនក្រោធខឹង មិនក្តៅក្រហាយផ្តេសផ្តាសឡើយ ហើយតែងមានប្រតិកម្មទៅវិញ ដោយអហិង្សាប្រកបដោយវិចារណញ្ញាណយ៉ាងថ្លៃថ្នូរបំផុត ដែលជាហេតុនាំមកនូវសុខសន្តិភាពយ៉ាងប្រពៃ ប្រការនេះគួរតែមិនមែនមានន័យថា ទោះជាត្រូវរងគ្រោះអយុត្តិធម៌យ៉ាងណា ក៏មិនអើពើឡើយ។ តាមពិត បើឃើញថាគួរតែឆ្លើយតបនោះគឺគោងតែឆ្លើយតប ប៉ុន្តែធ្វើដោយចិត្តស្ងប់មិនមែនធ្វើតាមកំហឹង។ ដូច្នេះ ការព្យាយាមកសាងអប់រំខ្លួនឱ្យមានសន្តានចិត្តប្រកបដោយខន្តី គឺសេចក្តីអត់ធន់ដ៏ប្រពៃហើយជាមង្គលដ៏ឧត្តម។

**២៨. សោវចស្សតា**ភាវៈនៃបុគ្គលដែលទូន្មានប្រៀនប្រដៅបានដោយងាយ។មនុស្សប្រដៅដោយងាយ គឺជាអ្នកដែលធ្លាប់ទទួលយកនូវដំបូន្មានឪពុកម្តាយ គ្រូអាចារ្យ ចាស់ព្រឹទ្ធាចារ្យ និងមតិយោបល់របស់បណ្ឌិតទាំងឡាយ ព្រោះភាពខ្លួនជាអ្នកឈ្លាសវៃមានការចេះដឹងច្រើន ធ្លាប់ពិចារណាឃើញនូវហេតុផលច្បាស់លាស់ ថែមទាំងជាបុគ្គលមានចិត្តបើកទូលាយ បន្ទាបខ្លួនមិនប្រកាន់មានះ តែទោះយ៉ាងណាគោងតែធ្វើដោយបញ្ញា **ប្រយ័ត្នត្រូវជនពាលបញ្ចុះបញ្ចូល អូសទាញឱ្យលុះក្នុងគំនិតគិតខុស**។ ឯអ្នកដែលមិនលុះតាមដំបូន្មានមាតាបិតា និងបណ្ឌិតជាដើម ក៏ព្រោះតែភាពនៃខ្លួនជាអ្នកមិនឆ្លៀសវៃ មិនមានការចេះដឹង ម្ល៉ោះហើយក៏មានការងឹតងងល់ក្នុងអស្មិមានះយ៉ាងធ្ងន់ធរ។ មានតែការខិតខំរៀនសូត្រ និងស្តាប់ធម៌ទេសនាជាដើមទេ ទើបអាចធ្វើខ្លួនឱ្យទៅជាបុគ្គលងាយប្រដៅបាន។ ដូច្នេះ ការខិតខំកសាងខ្លួនឱ្យបានក្លាយជាបុគ្គលដែលគេងាយប្រដៅ ជាមង្គលដ៏ឧត្តម។

**២៩. សមណានញ្ច ទស្សនំ** កិរិយាបានឃើញ បានជួបនូវសាមណៈទាំងឡាយដែលមានឥន្ទ្រីយ៍ស្ងប់ រម្ងាប់ហើយ។ សមណៈ គឺជាបព្វជិតដែលលះបង់ផ្ទះទៅបួស ហើយខិតខំប្រព្រឹត្តប្រតិបត្តិធម៌ធ្វើកាយ វាចា ចិត្តឱ្យស្ងប់ស្ងាត់ ចាកកិលេស គឺលោភៈ ទោសៈ មោហៈ មានឥរិយាបថស្ងប់ស្ងាត់ស្រគត់ស្រគំគួរជាទីគោរព ជ្រះថ្លានៃជនទាំង ពួង។ លើសពីនេះទៅទៀត សមណៈទាំងឡាយ លោកតែងឲ្យនូវដំបូន្មានដ៏ប្រពៃ ជាមាគ៌ា សម្រាប់ប្រព្រឹត្តប្រតិបត្តិឱ្យបានសុខចម្រើនក្នុងជាតិនេះនិងជាតិខាងមុខ។ ដូច្នេះ ការបានជួបនឹងសាមណៈ ទាំងឡាយ ជាមង្គលដ៏ឧត្តម។

**៣០. កាលេនធម្មសាកច្ឆា** កិរិយាសន្ទនាសាកសួរនូវធម៌តាមកាល។ នេះបានដល់ការចេះបែងចែក ពេលវេលាមានឱកាសសម្រាប់ជួបជុំគ្នាញឹកញាប់ ដើម្បីពិក្សាផ្លាស់ប្តូរយោបល់គ្នា អំពីធម៌វិន័យក្រោមអធិបតី ភាព នៃលោកអ្នកចេះដឹងជ្រៅជ្រះ ដែលជាអ្នកមានគុណធម៌ និងសីលធម៌ខ្ពង់ខ្ពស់ ដើម្បីអាចបំបាត់នូវចម្ងល់ គ្រប់យ៉ាងបាន។ មួយសោត ដើម្បីពិភាក្សាដោះស្រាយនូវបញ្ហានានា និងស្វែងរកនូវការចុះសម្រុងគ្នា។ ទង្វើ បែបនេះ ក៏ជាការសាបព្រោះនូវវប្បធម៌អហឹង្សា និងសន្តិភាពផងដែរ។ ធ្វើយ៉ាងនេះ គឺពិតជាបានបង្កើតនូវការ ចេះដឹងរបស់ខ្លួន ឲ្យបានទូលំទូលាយច្បាស់លាស់ជាបន្តបន្ទាប់ដែលអាចយកទៅប្រព្រឹត្តប្រតិបត្តិបានត្រឹមត្រូវ និងកើតផលប្រយោជន៍ដល់ខ្លួនឯង និងសង្គមជាតិពិតប្រាកដ។ ដូច្នេះ កិរិយាចូលរួមក្នុងការសន្ទនាសាកសួរ ធម៌តាមកាលជាមង្គលដ៏ឧត្តម។

### ៤.១.៩. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី៩ (មាន៤ហេតុ)

**៣១. តបោ ច** សេចក្តីព្យាយាមដុតនូវបាបធម៌។ បាបធម៌បានដល់លោភៈ គឺការជាប់ចិត្តលោភលន់ ហួសហេតុទៅលើសម្ភារៈគ្រប់យ៉ាង១ ទោសៈ គឺចិត្តប្រទូសរ៉ាយ ស្អប់ ក្រោធខឹងគ្រប់យ៉ាង១ និងមោហៈ គឺក្តី ងងឹតងងល់ វង្វេងវង្វាន់ មានកាប់សម្លាប់ លួចប្លន់ និងកុហកឆបោក កេងប្រវ័ញ្ចជាដើម។ រីឯតបៈធម៌ បាន ដល់ការព្យាយាមដុតបំផ្លាញនូវកិលេសទាំងបីខាងលើផង និងព្យាយាមកសាងនូវអំពើល្អគ្រប់យ៉ាង មានទាន សីល ភាវនា សាងផ្លូវថ្នល់សាលារៀនជាដើមផង ដែលសុទ្ធតែមានប្រយោជន៍ដល់ខ្លួនឯងនិងសង្គមជាតិ យ៉ាងពិតប្រាកដ។ ដូច្នេះ សេចក្តីព្យាយាម ដុតនូវបាបធម៌ ជាមង្គលដ៏ឧត្តម។

**៣២. ព្រហ្មចរិយញ្ច** កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ។ នេះបានដល់កិរិយាព្យាយាមប្រព្រឹត្តសីលធម៌ដ៏ ប្រសើរ ទាំង ៨ យ៉ាងគឺ៖ មិនសម្លាប់ជីវិតសត្វ១ មិនលួចប្លន់១ មិនប្រព្រឹត្តស្នេហា១ មិនភូតកុហក១ មិនផឹក ទឹកស្រវឹង១ មិនបរិភោគពេលសៀលនិងយប់១ មិនរាំច្រៀង លេងភ្លេង និងមិនតុបតែងកាយដោយគ្រឿង អលង្ការ១ មិនប្រើប្រាស់សម្ភារៈអង្គុយនិងដេកក្នុងទីដ៏ប្រសើរពេក១។ នេះគឺជាការប្រព្រឹត្តសង្រួមកាយ វាចា ចិត្តយ៉ាងប្រពៃ ដែលមានប្រយោជន៍ដល់ខ្លួនឯង ព្រោះបានធ្វើចិត្តឲ្យបានស្ងប់ស្ងាត់និងមានប្រយោជន៍ដល់ សង្គមជាតិ ព្រោះមិនបានរំខាននិងបៀតបៀនសង្គមជាតិ។ ដូច្នេះ កិរិយាប្រព្រឹត្តនូវព្រហ្មចរិយាធម៌ជាមង្គលដ៏ ឧត្តម។

**៣៣. អរិយសច្ចាន ទស្សនំ** កិរិយាឃើញនូវអរិយសច្ចធម៌ទាំងឡាយ។ អរិយសច្ច ធម៌បានដល់ធម៌ ពិតដ៏ខ្ពង់ខ្ពស់៤យ៉ាងគឺ ទុក្ខសច្ចៈ សេចក្តីទុក្ខ១ សមុទយសច្ចៈ ហេតុនៃសេចក្តីទុក្ខ១ និរោធសច្ចៈ ទីដែលក្តី ទុក្ខត្រូវបានរំលត់១ និងមគ្គសច្ចៈ វិធីរំលត់ទុក្ខ១។ សេចក្តីពិតនៃជីវិតមនុស្ស សត្វ ទេព្តា ក្នុងត្រៃភព គឺពោរ ពេញទៅដោយសេចក្តីទុក្ខប្រែប្រួលឥតខ្លឹមសារទាំងអស់។ មូលហេតុនៃសេចក្តីទុក្ខនេះ គឺបណ្តាលមកពីជីវិត ដែលពោរពេញដោយកិលេសតណ្ហាគ្រប់បែបយ៉ាង។ ដរាបណាកិលេសតណ្ហាត្រូវបានរំលត់អស់ហើយ ដរាប

នោះសេចក្តីទុក្ខក៏មិនមានទៀតឡើយ។ ព្រះអរិយបុគ្គលទាំងឡាយ មានព្រះពុទ្ធជាប្រធានសុទ្ធតែបានយល់ច្បាស់នូវអរិយសច្ចធម៌នេះ ហើយព្យាយាមប្រព្រឹត្ត ប្រតិបត្តិតាមមគ្គសច្ចៈដែលជាមាគ៌ា ដើម្បីរំលត់ទុក្ខប្រកបដោយអង្គ៨ គឺអដ្ឋង្គិកមគ្គ ទើបបានរំលត់កិលេសតណ្ហាឆ្លងផុតពីសេចក្តីទុក្ខគ្រប់យ៉ាង។ ដូច្នេះ កិរិយាឃើញនូវអរិយសច្ចធម៌ ជាមង្គលដ៏ឧត្តម។

**៣៤. និព្វាន សច្ឆិកិរិយា ច** កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានដោយបញ្ញាដ៏ខ្ពង់ខ្ពស់។ នេះបានដល់ការប្រព្រឹត្តប្រតិបត្តិនូវវិធីក្បួនច្បាប់សីលសមាធិបញ្ញា ឱ្យចេញជាលទ្ធផលច្បាស់លាស់។ ព្រះនិព្វាន គឺជាលទ្ធផលនៃការប្រព្រឹត្តប្រតិបត្តិសីល សមាធិ បញ្ញាតាមអរិយមគ្គប្រកបដោយអង្គ៨គឺ សម្មាទិដ្ឋិ គឺការយល់ឃើញត្រឹមត្រូវពិតប្រាកដ១សម្មាសង្កប្បៈគឺការត្រិះរិះត្រឹមត្រូវ គឺគិតនិងរម្លត់តណ្ហា១ សម្មាវាចា គឺការពោលតែពាក្យត្រឹមត្រូវ១ សម្មាកម្មន្តៈ គឺការប្រព្រឹត្ត ធ្វើការងារត្រឹមត្រូវតាមធម៌ និងច្បាប់រដ្ឋ១ សម្មាអាជីវៈ គឺការប្រកបមុខរបរត្រឹមត្រូវ ដោយចៀសវាងនូវអំពើបាប៥យ៉ាងមានការលក់មនុស្សជាដើម១ សម្មាវាយាមៈ គឺការព្យាយាមត្រឹមត្រូវ គឺព្យាយាមលះបង់អំពើអាក្រក់ដែលធ្លាប់ធ្វើឱ្យអស់ និងព្យាយាមចៀសវាងមិនធ្វើអំពើអាក្រក់ជាថ្មីទៀត ព្យាយាមរក្សាគុណធម៌ និងសេចក្តីដែលមានស្រាប់ឱ្យមានតាំងនៅ និងកាន់តែចម្រើនឡើង ព្យាយាមសាងគុណធម៌ និងក្តីល្អដែលមិនទាន់មានឱ្យមានជាប្រាកដ១ សម្មាសតិ គឺការរឭកដ៏ត្រឹមត្រូវមានការរឭកនូវវេទនាខាងក្នុងនិងវេទនាខាងក្រៅជាដើម១ និងសម្មាសមាធិ គឺការតម្កល់ចិត្តឱ្យខ្ជាប់ខ្ជួនក្នុងអារម្មណ៍តែមួយ១។ ដូច្នេះ ការប្រព្រឹត្តប្រតិបត្តិក្នុងមាគ៌ាប្រកបដោយអង្គ៨រហូតធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាគោលដៅចុងក្រោយនៃជីវិតក្នុងលោក ជាមង្គលដ៏ឧត្តម។

### ៤.១.១០. ហេតុដែលនាំឲ្យកើតមង្គលវគ្គទី១០ (មាន៤ហេតុ)

**៣៥. ផុដ្ឋស្ស លោកធម្មេហិចិត្តំ យស្ស ន កម្បតិ** ចិត្តនៃបុគ្គលដែលមិនញាប់ញ័រដោយលោកធម៌ លោកធម៌ គឺជាធម្មជាតិ ជាទីប្រាថ្នា និងជាទីស្អប់របស់មនុស្ស និងជាធម៌ដែលតែងកើតមាននៅក្នុងលោកដល់មនុស្សគ្រប់រូប មិនថាបុគ្គលនោះជាអ្នកចេះដឹងធម៌ ឬមិនចេះធម៌ឡើយ ហើយក៏មិនរើសមុខថា ជាពុទ្ធសាសនិក ឬជាសាសនិករបស់សាសនាណាមួយឡើយ។ លោកធម៌មាន៨ប្រការគឺ មានលាភ១ ឥតលាភ១ មានយស១ ឥតយស១ សរសើរ១ និន្ទា១ សុខ១ ទុក្ខ១។ អរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាប្រធានរមែងមិនញាប់ញ័រ គឺមិនសប្បាយភ្លើតភ្លើនទាំងមិនទោមនស្ស ដោយលោកធម៌ទាំង៨នេះឡើយ ទើបពួកលោករមែងរស់នៅជាក្សេមក្សាន្តជានិច្ច។ ដូច្នេះ ការព្យាយាមអប់រំចិត្តឱ្យបានទៅជាចិត្ត ដែលមិនញាប់ញ័រដោយលោកធម៌ទាំង៨នេះ ជាមង្គលដ៏ឧត្តម ។

**៣៦. អសោកំ** ចិត្តនៃបុគ្គលមិនសោយសោកចំពោះអារម្មណ៍។ មនុស្សគ្រប់រូបតែងតែជួបនូវអារម្មណ៍ គឺហេតុការណ៍គ្រប់យ៉ាងរាល់នាទីនៃជីវិតរបស់ខ្លួន។ ជាការពិតណាស់ តាំងពីភ្ញាក់ពីដំណេកដឹងខ្លួនឡើង ត្រចៀកជួបនឹងសំឡេង ភ្នែកជួបនឹងរូប ច្រមុះជួបនឹងក្លិន អណ្តាតជួបនឹងរសជាតិ កាយប៉ះនឹងវត្ថុគ្រប់យ៉ាង។ អារម្មណ៍ទាំងនេះ ខ្លះជាទីពេញចិត្តនាំឱ្យសប្បាយ ខ្លះជាទីស្អប់ខ្ពើមនាំឱ្យខឹងមួម៉ៅក្តៅក្រហាយ។ ប៉ុន្តែ ព្រះអរិយបុគ្គលដែលជាមនុស្សដ៏ប្រសើរមានចិត្តស្អាតបរិសុទ្ធ ចាកកិលេសតណ្ហា លោភៈ ទោសៈ មោហៈហើយនោះ លោកមិនសោយសោកក្តៅក្រហាយ នឹងអារម្មណ៍ទាំងឡាយនោះឡើយ។ ដូច្នេះការព្យាយាមអប់រំចិត្តរហូតបានជាចិត្តមិនសោកសៅ ជាមង្គលដ៏ឧត្តម។

**៣៧. វីរជំ** ចិត្តដ៏បរិសុទ្ធ ស្អាតចាកកិលេស។ នេះបានដល់ប្រភេទនៃចិត្តជាន់ខ្ពស់ដែលមិនប្រឡាក់ដោយកិលេសទាំងបី គឺលោភៈចិត្ត ស្អប់ជាប់នឹងសម្ភារៈគ្រប់យ៉ាង ដែលនាំឱ្យមានសេចក្តីលោភលន់គ្មានទីបំផុត១ ទោសៈចិត្ត ថ្នាំងថ្នាក់ស្អប់ខ្ពើម ក្រោធខឹង ទោមនស្ស ប្រទូស្តនឹងសម្ភារៈគ្រប់យ៉ាងដែលនាំឲ្យកើតជាអំពើហិង្សាជាដើម១ មោហៈចិត្ត វង្វេងក្នុងអារម្មណ៍ប្រកបដោយសេចក្តីសង្ស័យ និងរាយមាយឥតខ្មាសឥតខ្លាចអំពើទុច្ចរិត១។ ដូច្នេះ កិរិយាអប់រំចិត្តឱ្យបានទៅជាចិត្តបរិសុទ្ធស្អាតចាកកិលេស ជាមង្គលដ៏ឧត្តម។

**៣៨. ខេមំ** ចិត្តក្សេមក្សាន្ត។ នេះបានដល់សន្តានចិត្តរបស់ព្រះអរិយបុគ្គលទាំងឡាយ ដែលមានព្រះពុទ្ធជាប្រធាន ដែលបានឆ្លងផុតពីអន្លង់ទាំង៤គឺ ៖ អន្លង់គឺកាមតណ្ហា១ អន្លង់គឺភពទាំងបី១ អន្លង់គឺទិដ្ឋិយល់ខុស១ និងអន្លង់គឺអវិជ្ជា ការមិនយល់មិនដឹងនូវសច្ចធម៌១។ ចិត្តដែលបានឆ្លងផុតអន្លង់ទាំង៤ហើយ គឺជាចិត្តស្អាតបរិសុទ្ធ និងស្ងប់ក្សេមក្សាន្តក្រៃលែង។ ដូច្នេះ កិរិយាខំកសាងខ្លួន គឺអប់រំចិត្តឱ្យបានទៅជាចិត្តក្សេមក្សាន្តយ៉ាងនេះ ជាមង្គលដ៏ឧត្តម។

បុគ្គលទាំងឡាយណាបានខិតខំកសាងខ្លួន ដោយខិតខំប្រព្រឹត្តប្រតិបត្តិនូវមង្គលទាំង៣៨ប្រការនេះឱ្យបរិបូណ៌ហើយ រមែងមិនចាលចាញ់ក្នុងទីទាំងពួង រហូតសម្រេច មគ្គ ផល និព្វាន ជាទីអវសាន។

# ជំពូក៥

# ព្រះសម្មាសម្ពុទ្ធបង្ហាញពីតួនាទីបុគ្គលក្នុងសង្គម

## ៥.១. តួនាទីរបស់បុគ្គលដែលត្រូវប្រតិបត្តិបត្តិមាន៖

### ៥.១.១. តួនាទីមាតាបិតាចំពោះកូន

មាតាបិតាជាទិសខាងកើត ដែលកូនទម្រុកបម្រុងដោយស្ថានទាំងឡាយ៥ យ៉ានេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថាន៥ទាំងឡាយ៥យ៉ាងវិញដូច្នេះគឺ ៖

១ - ហាមឃាត់កូនចាកអំពើអាក្រក់

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានបង្រៀនដល់មាតាបិតាទាំងឡាយ ត្រូវមានស្មារតីជានិច្ចក្នុងការការការពារកូនប្រុសស្រីរបស់ខ្លួនឲ្យតាំងនៅក្នុងសេចក្ដីល្អ។ អ្វីជាអំពើអាក្រក់? អំពើអាក្រក់គឺជាអំពើ ឬសកម្មភាពទាំងឡាយណា ដែលធ្វើឲ្យប៉ះពាល់ដល់សេចក្ដីសុខ សេចក្ដីថ្លៃថ្នូរ និងផលប្រយោជន៍ខ្លួនឯង មនុស្សនៅជុំវិញខ្លួន និងប្រយោជន៍សាធារណៈ ដែលស្ដែងតាមកាយ វាចា និងចិត្ត អំពើទាំងនោះគឺជាអំពើអាក្រក់ អំពើទុច្ចរិត។ ម្យ៉ាងទៀតអំពើអាក្រក់គឺ ការមិនគោរពឪពុកម្ដាយ មិនគោរពបងប្អូន មិនគោរពសាច់ញាតិ មិនគោរពចាស់ទុំ មិនគោរពព្រះសង្ឃ មិនគោរពលោកគ្រូ អ្នកគ្រូ មិនគោរពមិត្រភក្តិ ខ្ជិលច្រអូស មិនប្រឹងប្រែងសិក្សារៀនសូត្រ មិនគោរពពេលវេលា មិនគោរពកន្លែងធ្វើការងារ មិនគោរពច្បាប់ប្រទេស មិនគោរពច្បាប់សាសនា មិនគោរពច្បាប់គ្រួសារ មិនគោរពច្បាប់សាលា សេពគប់តែមនុស្សអាក្រក់ ជក់បារី ជក់អាភៀន ជក់កញ្ឆា ជក់ម៉ា និងគ្រឿងញៀនផ្សេងៗទៀត សេពសុរា សេពមេរ័យ សេពបៀ លេងល្បែងស៊ីសង ស្រីក្រៅតម្រា ដើរលេងយប់ព្រលប់ខុសកាល ប្រជល់មាន់ និយាយកុហក និយាយញុះញង់ និយាយចាក់ដោត និយាយពាក្យឥតខ្លឹមសារ មានគំនិតសំឡឹងរំពៃទ្រព្យរបស់អ្នកដទៃ ចិត្តគំកួនព្យាបាទ ចងអាឃាត មានសេចក្ដីយល់ឃើញប្រាសចាកតម្រា មិច្ឆាទិដ្ឋិ មិនស្គាល់អាក្រក់ល្អ បាប បុណ្យ គុណ ទោស គ្មានចិត្តសន្ដោស គ្មានចិត្តមេត្តា ករុណា គ្មានការអភ័យ គ្មានការអធ្យាស្រ័យ ធ្វើការងារទុច្ចរិត កាប់សម្លាប់ លួច ឆក់ប្លន់ កេងប្រវ័ញ្ច លួចទ្រព្យគេ ប្រព្រឹត្តលួចប្រពន្ធ ប្ដីអ្នកដទៃ ឥរិយាបថខ្វះសីលធម៌ សុជីវធម៌ និងគុណធម៌ ជាដើម។ ឪពុកម្ដាយត្រូវតែព្យាយាមពន្យល់កូន បង្រៀនកូន អប់រំកូន ផ្ដល់ដំបូន្មានដល់កូនឲ្យបានគ្រប់គ្រាន់ គ្រប់កាលៈទេសៈ និងគ្រប់ពេលវេលាធ្វើឲ្យយ៉ាងណាឲ្យកូនមានការយល់ដឹងអំពីអំពើអាក្រក់ទាំងឡាយខាងលើនេះ ឲ្យជាក់ច្បាស់ដោយពុទ្ធិរបស់ខ្លួនថា អំពើអាក្រក់មានផលជាទុក្ខ វិនាសអន្តរាយ ខាតខូចប្រយោជន៍ ខូចកិត្តិយសកេរ្តិ៍ឈ្មោះ វិនាសទ្រព្យសម្បត្តិខ្ចាត់ខ្ចាយញាតិផងទាំងពួងបាត់បង់តម្លៃជាមនុស្ស រដ្ឋការត្រូវអនុវត្តច្បាប់ផាកពិន័យ ដាក់ទណ្ឌកម្ម ដាក់គុក ដាក់ច្រវ៉ាក់ ឬនាំឲ្យមានផលវិបាកយ៉ាងធ្ងន់ធ្ងរនោះគឺ ការខូចបង់អវយវៈ រហូតដល់ការបាត់បង់ជីវិត។ ដូច្នេះឪពុកម្ដាយត្រូវតែមានពេលវេលាគ្រប់គ្រាន់ និងសមរម្យបំផុតដើម្បីទេសនាឲ្យកូនបានស្ដាប់ បង្ហាញឲ្យកូនឃើញដោយសច្ចៈ ឲ្យកូនមើលឃើញវិបត្តិនោះដោយបញ្ញារបស់ខ្លួន ឲ្យចេះថ្មឹកក្នុងការគិត ឲ្យកូនព្យាយាមបណ្ដុះនិស្ស័យល្អៗនៅល្អុងសន្តាននេះជាការងារដ៏ឧត្តមដែលឪពុកម្ដាយត្រូវធ្វើ។

២ - ឲ្យកូនតម្កល់នៅក្នុងសេចក្ដីល្អ

ក្នុងនាមជាឪពុកម្ដាយ គឺជាមនុស្សសំខាន់នៅក្នុងគ្រួសារ ព្រោះអ្នកទាំងពីរជាអ្នកបង្កើតកូនមកឲ្យបានឃើញលោកនេះ។ ឪពុកម្ដាយបន្ទាប់ពីផ្ដល់កំណើតឲ្យកូន និងបង្កើតកូនមក ត្រូវទទួលភារៈយ៉ាងធ្ងន់ធ្ងរក្នុងការមើលថែចិញ្ចឹមបីបាច់រក្សា ទាំងចំណីអាហារ សំលៀកបំពាក់ ទីកន្លែងសម្រាក់សម្រាន គេង អង្គុយ ថ្នាំសម្រាប់ព្យាបាលពោគនៅពេលដែលមានបញ្ហាសុខភាពជាដើមដល់កូន ក្នុងចំណោមភារកិច្ចដ៏ធ្ងន់នោះ មានភារកិច្ចមួយទៀតដែលរឹតតែធ្ងន់ធ្ងរនោះគឺ ការបង្រៀនកូនឲ្យតាំងនៅក្នុងអំពីល្អ សេចក្ដីបរិសុទ្ធ យុត្តិធម៌ ភាពត្រឹមត្រូវ ការងារនេះមិនមែនងាយស្រួលនោះទេ ព្រោះមនុស្សម្នាក់ៗសុទ្ធតែមានគំនិត ការគិត ទិដ្ឋិ មានៈ

រឹងត្អឹង ពិបាកក្នុងការអប់រំ និងការបង្រៀន តែទោះជាយ៉ាងណា ឪពុកម្តាយ ឬអាណាព្យាបាល ត្រូវតែប្រតិបត្តិការងារនេះឲ្យបានខ្ជាប់ខ្ជួនបំផុត ក្នុងការអប់រំកូនរបស់ខ្លួន។ ត្រូវបង្ហាញកូនឲ្យច្បាស់លាស់ថា តើអំពើល្អគឺជាអ្វី?អំពើល្អឲ្យផលដូចម្តេចដល់អ្នកប្រព្រឹត្ត? ឪពុកម្តាយគឺជាអ្នកបង្រៀនប្រធានបទនេះដល់កូនមុនគេ ឪពុកម្តាយត្រូវឲ្យប្រាកដថា តើអំពើល្អគឺជាអ្វី អំពើល្អ គឺជាចលនាទាំងឡាយណាដែលកើតតាម កាយ វាចា និងចិត្ត ស្ថិតនៅក្នុងសេចក្តីបរិសុទ្ធ ប្រាសចាកទោស ត្រូវបង្រៀនកូនឲ្យចេះគោរពចាស់ទុំ លោកគ្រូ អ្នកគ្រូ អ្នកជិតខាង មិត្តភក្តិ ចេះចែករំលែកដល់អ្នកដទៃ ជួយសង្គ្រោះដល់មនុស្ស សត្វដែលនៅជុំវិញខ្លួន មិនត្រូវខ្ជិលច្រអូសត្រូវឧស្សាហ៍ប្រារព្ធនូវសេចក្តីព្យាយាម ធ្វើការងារ រៀនសូត្រ ចៀសឲ្យឆ្ងាយពីស្រីក្រៅតម្រា ស្រា គ្រឿងញៀន មិត្តអាក្រក់ សេពគប់តែមិត្តល្អ កល្យាណមិត្ត សប្បុរស ធ្វើបុណ្យទាន ជាមនុស្សគោរពពេលវេលា គោរពសិទ្ធិអ្នកដទៃ ឲ្យកូននេះគោរពច្បាប់ជាតិ ច្បាប់សាសនា ច្បាប់សីលធម៌ក្នុងគ្រួសារ វិន័យកន្លែងការងារ ជាមនុស្សទន់ភ្លន់ រុះរាយរាក់ទាក់ ចេះជួយអ្នកដទៃដោយចិត្តសប្បុរស មានចិត្តមេត្តា ករុណា ជាមនុស្សមានសីលធម៌ គុណធម៌ និងសុជីវធម៌ក្នុងជីវិតជាប្រចាំ។ ត្រូវតែបង្ហាញលទ្ធផលនៃអំពើល្អដល់កូនឲ្យបានច្បាស់លាស់តាំងពីតូចៗទៅ ធ្វើល្អនាំឲ្យយើងបានសេចក្តីសុខ សេចក្តីចម្រើន សេចក្តីគោរព ការរាប់អាន រស់នៅដោយមិនគ្មានការភ័យខ្លាចពីច្បាប់ជាតិ រស់នៅដោយសេចក្តីថ្លៃថ្នូរ មានសុភមង្គលក្នុងគ្រួសារ នាំមនុស្សនៅជុំវិញខ្លួនទទួលបានសេចក្តីសុខ និងគុណប្រយោជន៍ជាច្រើនទៀត។

៣ - ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ

**សារប្រយោជន៍នៃសិក្សា**

**ជីវិតគឺការសិក្សារ** ពំនោលនេះ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីសារៈសំខាន់នៃការសិក្សា។ ជីវិតដែលនឹងមានដំណើរប្រកបដោយសេចក្តីសុខ និងសម្រេចបានជោគជ័យត្រូវអាស្រ័យដោយ **ការសិក្សា**។

ការសិក្សា គឺជាផ្នែកមួយនៃជីវិត ដែលមិនអាចគេចវេះជៀសវាង។ បើពុំមានការសិក្សារទេ ជីវិតនឹងត្រូវគាំងស្ទៀមដូចគេចុចជីពចរ មិនអាចដើរឆ្ពោះទៅរកក្តីរុងរឿងបានឡើយ។

សេចក្តីសុខ និងជោគជ័យរបស់មនុស្ស ត្រូវចាប់ចេញដំណើរឡើង ពីការមើលឃើញតម្លៃនៃការសិក្សានោះឯង។

ការរៀនមានសារៈសំខាន់ចំពោះបុគ្គលម្នាក់ៗផង ហើយក៏មានសារៈសំខាន់ដល់លោកយើងព្រមទាំងមនុស្សជាតិលើលោកផងដែរ។ បើមនុស្សភាគច្រើននៅលើលោកនេះ សុទ្ធតែជាអ្នកដែលមិនបានរៀន ការអភិវឌ្ឍអ្វីៗផងទាំងពួងលើលោក ពិតជាកើតឡើងដោយពិបាកបំផុត ឬស្ទើរតែមិនអាចដើរទៅមុខបាន (ឬដើរថយក្រោយ?) រហូតដល់គេអាចនិយាយថា **លោកវិលទៅមុខដោយការរៀន** បើពុំមានការរៀនទេ **លោកប្រៀបដូចជានៅគាំង**។ ពេលនោះលោកនឹងត្រូវធ្លាក់ដុនដាប ហើយអាចនឹងឈានទៅដល់ទីអវសាននៃពិភពលោក និងបណ្តាមនុស្សជាតិរួមជាមួយផងដែរ។

**ការរៀន ជាកត្តាចាំបាច់ក្នុងសម័យបច្ចុប្បន្ន**

បច្ចុប្បន្ននេះ យើងរស់នៅលើលោកនៃបណ្តាញព័ត៌មានដែលអាចនិយាយថាពុំមានជីវិតណាមួយនៅលើលោកអាចជៀសគេចផុត ពីការប៉ះពាល់អំពីចន្លេបត់បែនដែលកើតមានលើលោកបានឡើយ។ ហេតុនេះបើបុគ្គលណាអាចសម្របសម្រួលឲ្យស៊ីសង្វាក់ ឬបត់ឲ្យទាន់តាមបត់ផ្លាស់ប្តូររបស់លោកយើងបានល្អ អ្នកនោះនឹងអាចសម្រេចជោគជ័យ ទទួលបាននូវសេចក្តីសុខ ហើយអាចរំដោះខ្លួនគេចផុតពីវិបត្តិផ្សេងៗបានយ៉ាងល្អបំផុត។

យើងអាចនិយាយថា លោកវិលទៅមុខក្នុងល្បឿនកាន់តែលឿនគ្រប់វិនាទី។ គ្រប់ជីវិតនៅលើលោកត្រូវព្យាយាមរត់ឲ្យទាន់ការធ្វើចលនារបស់លោក បើមិនដូច្នោះទេ អ្នកនឹងដើរពុំទាន់គេ ហើយត្រូវឈឺចាប់នឹងក្តីបរាជ័យដែលកើតមានចំពោះខ្លួនឯង។ សារៈសំខាន់ ឬការចាំបាច់នៃការរៀនអាចពិចារណាទៅតាមផ្លូវផ្សេងៗជាច្រើនដូចខាងក្រោមនេះ ៖

**- ការរៀនធ្វើឲ្យ បត់បែនទាន់សភាពការណ៍**

ពេលដែលអ្នកគ្រប់គ្រងមុខជំនួញ "បើកទ្វារ" យកចិត្តទុកដាក់អំពីបណ្តាញ អ៊ិនធើណេត គេនឹងបានសិក្សាពីចំណេះដឹងឬព័ត៌មានផ្សេងៗ រហូតដល់ស្វែងយល់បានថា មនុស្សទូទាំងពិភពលោក តែងនិយមប្រើអ៊ិនធើណេតយ៉ាងសុសសាយទូលំទូលាយ មានមនុស្សប្រើដល់ទៅ រាប់រយលាននាក់ និងកំពុងតែមានចំនួនច្រើនឡើងជាលំដាប់។ប្រសិនបើ គេយកទំនិញឬសេវារបស់ខ្លួនមកផ្សព្វផ្សាយតាម អ៊ិនធើណេត ទំនិញឬសេវាទាំងនោះមិនត្រឹមតែមានគេទទួលស្គាល់ក្នុងប្រទេសប៉ុណ្ណោះទេតែវានឹងត្រូវបានគេដឹងនៅទូទាំងពិភពលោកទៀតផង។ បើយើងគិតពីតម្លៃនៃការឃោសនា ការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ិនធើណេត មានតម្លៃថោកជាងតម្លៃឃោសនាតាមប្រព័ន្ធផ្សេងៗដទៃទៀត។ ការយល់ដឹងក្នុងរឿងនេះ ធ្វើឲ្យអ្នកជំនួននោះសម្រេចចិត្តទិញទំព័រឃោសនាតាមប្រព័ន្ធអ៊ិនធើណេត ហើយទីបំផុត គេក៏អាចទទួលកម្រៃតបស្នងយ៉ាងខ្ពស់បំផុតដោយសារតែការ **រៀនយល់ដឹង**របស់ខ្លួននេះឯង។

អ្វីទាំងនេះ ប្រសិនបើគេមិនបានស្វះស្វែងរៀនយល់ដឹង តែបែរជាគិតថា បច្ចេកវិទ្យាសម័យថ្មីវាមានភាពលំបាកស្មុគស្មាញមិនងាយនឹងរៀនឲ្យបានជ្រៅជ្រះឬគិតថាចាំមើលឲ្យអ្នកដទៃគេសាកល្បងមុនសិនខ្លួនឯងចាំធ្វើក្រោយគេចុះពេលនោះយើងប្រាកដជានឹងដើរទីផ្សារក្រោយគេ យឺតជាងគេ ហើយអាចពុំមានឱកាសប្រកួតនឹងគេទៀតផង។

ហេតុនេះការមិនព្រមរៀន អាចធ្វើឲ្យយើងបត់បែនមិនទាន់ពេលឯការស្វះស្វែងរៀន ធ្វើឲ្យយើងបោះជំហានបានមុនគេ។ សូមអ្នកកុំភ្លេចថាបើអ្នកប្រញាប់រូតរះទិញសំបុត្រឡានឲ្យបានមុនគេ អ្នកមានសិទ្ធិ និងជ្រើសរើសបានកៅអីល្អៗជាងគេ។

**- ការរៀន ធ្វើឲ្យ ដើរទាន់ព្រឹត្តិការណ៍លោក**

ការដើរឲ្យទាន់ព្រឹត្តិការណ៍លោក ក្នុងទីនេះ ពុំមែនមានន័យថា មនុស្សគ្រប់គ្នាទាំងអស់នៅលើលោកត្រូវខំដើរឲ្យទាន់ ឬតម្រូវខ្លួនឲ្យស្របតាមបត់របស់ពិភពលោកចំពោះគ្រប់ៗរឿង ពុំមែនជាការខំព្យាយាមរត់ទៅតាមសម័យម៉ូដ ឬរត់ទៅតាមឥទ្ធិពលផ្សេងៗ ទាំងគ្មានសតិសម្បជញ្ញៈនោះទេ ហើយវាក៏មិនមែនជាការអន្ទះសា ខំស្វះស្វែងតាមឲ្យទាន់ការត្រេកត្រអាលទៅលើសម្ភារៈនោះដែរ។ តែអ្វីៗត្រូវតែឆ្លងកាត់ការត្រិះរិះពិចារណាយ៉ាង ល្អិតល្អន់ផងថា តើសម្ភារៈទាំងនោះវាមានការចាំបាច់ពិតប្រាកដដែរឬទេ? តើវាស័ក្តិសមនឹងតម្លៃដែលយើងត្រូវចាយវាយដែរឬទេ?

ការដើរឲ្យទាន់ព្រឹត្តិការណ៍លោកក្នុងទីនេះមានន័យថា យើងត្រូវបត់បែនឲ្យទាន់ព្រឹត្តិការណ៍លោកក្នុងការតាមដាន សិក្សាស្រាវជ្រាវអំពីការរីកចម្រើនផ្នែកបច្ចេកវិទ្យាសុខាភិបាល ការអប់រំ វប្បធម៌ សេដ្ឋកិច្ច សង្គម និងផ្នែកនយោបាយជាដើម។

៤ - ដណ្ដឹងភរិយាស្វាមីសមគួរឲ្យ

ក្នុងឋានៈជាឪពុកម្ដាយមិនត្រឹមត្រូវចិញ្ចឹមកូនឲ្យរស់ ឲ្យសិក្សារៀនសូត្រ និងកិច្ចការជាច្រើនទៀតកាលពីនៅតូចនោះទេ គឺធំឡើងក៏ត្រូវសំឡឹងរំពៃរកគូស្រករឲ្យកូន ពេលណាកូនពេញវ័យការហើយ។ ក្នុងរឿងនេះមានរឿងស្មុគ្រស្មាញណាស់ ដោយកិច្ចនេះវាស្រ័យទៅតាមសម័យកាលនីមួយៗ និងអាស្រ័យទៅតាមគ្រួសារនីមួយៗ និងអាស្រ័យទៅតាមទំនោររបស់បុគ្គល ឬសិទ្ធិរបស់បុគ្គល យើងពិបាកនឹងកំណត់ថាខាងណាមួយត្រូវណាស់ ព្រោះឪពុកម្ដាយចង់ឲ្យកូនបានយ៉ាងនេះ តែកូនដែលជាសាមីខ្លួនគឺចង់អ្នកណាដែលស្រឡាញ់ តែមួយផ្នែកទៀតគេសំយោគគ្នារវាងសមាជិកនៅក្នុងគ្រួសារ។

**សិក្សាទស្សនៈខាងក្រោមមាន៖**

តើយុវជនគួរតែជ្រើសរើសគូស្រករដោយខ្លួនឯង ឬទុកឲ្យគ្រួសារជាអ្នករៀបទុកដាក់ឲ្យ?

ការរៀបអាពាហ៍ពិពាហ៍ គឺជាដំណាក់កាលមួយដែលកម្រ និងមានមនុស្សណាម្នាក់អាចជៀសផុតណាស់។ យ៉ាងណាមិញ ការជ្រើសរើសមិត្ត១០០ឆ្នាំ ពិតជាមានសារៈសំខាន់ណាស់នៅក្នុងជីវិតរបស់យុវវ័យគ្រប់គ្នា ព្រោះប្រសិនជាពួកគេជ្រើសរើសមនុស្សខុសមកធ្វើជាគូជីវិត ពួកគេអាចនឹងប្រឈមមុខនឹងការឈឺចាប់ ឬការស្ដាយក្រោយនៅពេលខាងមុខ។

ក៏ប៉ុន្តែ មនុស្សនឹងត្រូវធ្វើជាដៃគូរបស់អ្នកគួរតែជាមនុស្សដែលអ្នកស្រលាញ់ចេញពីបេះដូង ឬក៏ត្រូវជាមនុស្សដែលគ្រួសាររបស់អ្នកជ្រើសរើសសម្រាប់អ្នក?

ការសម្រេចចិត្តជ្រើសរើសគូស្រករ គួរតែត្រូវបានធ្វើឡើងដោយពឹងផ្អែក លើបេះដូងរបស់ខ្លួនឯងផង និងការពេញចិត្តរបស់ឪពុកម្ដាយផង ក៏ប៉ុន្តែឪពុកម្ដាយត្រូវតែមានអទិភាពធំជាងចិត្តខ្លួនឯង។

«បើសិនជាខ្ញុំស្រលាញ់គ្នា និងចង់រៀបការជាមួយនារីណាម្នាក់ ខ្ញុំនឹងណែនាំនារីនោះទៅកាន់គ្រួសាររបស់ខ្ញុំ ក៏ប៉ុន្តែប្រសិនជាឪពុកម្ដាយរបស់ខ្ញុំពុំពេញចិត្តជាមួយនឹងនារីម្នាក់នោះ ខ្ញុំនិងព្យាយាមកាត់ចិត្ត ហើយ

ឈប់ទាក់ទងជាមួយនិងនារីម្នាក់នោះ»។

«យើងពុំអាចមានៈដោយដើរតាមតែចិត្តខ្លួនឯងដោយពុំមានការព្រមព្រៀងពីគ្រួសារបាននោះទេ។ ម្យ៉ាងទៀត ឪពុកម្ដាយរបស់យើងមានបទពិសោធន៍ច្រើនជាងយើង ដែលជាក្មេងៗចំពោះបញ្ហានេះ ដូច្នេះ ហើយការសម្រេចចិត្តរបស់ពួកគាត់ប្រាកដជាមានហេតុផលត្រឹមត្រូវ»។

ការយល់ព្រមពីគ្រួសារ ចំពោះការជ្រើសរើសគូស្រករបស់យុវវ័យ ពិតជាមានសារៈសំខាន់ណាស់ ក៏ប៉ុន្តែពួកគេ ក៏ត្រូវតែចេះស្រលាញ់មនុស្សណា ដែលសាកសមនឹងឲ្យគ្រួសារមានការពេញចិត្តផងដែរ។

«បើសិនជាយើងចេះជ្រើសរើសមនុស្សដែលមានលក្ខខណ្ឌល្អសមជាមនុស្សដែលយើងអាចដើរជាមួយពេញមួយជីវិតបាន យើងប្រាកដជាពុំពិបាកនឹងទទួលការយល់ព្រមពីគ្រួសារនោះឡើយ»។

ក្នុងការជ្រើសរើសមនុស្សដែលសាកសមជាគូជីវិត យើងជាយុវវ័យគួរតែពិចារណាទៅលើចំណុចចំនួន ៣គឺ ការងារ អត្តចរិតនិងសេចក្ដីស្មោះសររបស់គេ។ ដោយឡែក យើងពុំគួរមើលលើកត្តាគ្រួសារ ឬវង្សត្រកូលរបស់គេខ្លាំងពេកនោះទេ ព្រោះកត្តាទាំង៣ខាងលើនេះ មិនមែនអាស្រ័យទៅលើកត្តាគ្រួសារទាំងស្រុងនោះឡើយ»។

យុវវ័យគួរតែជ្រើសរើសគូស្រករដោយពឹងផ្អែក ចិត្ត និងបេះដូងរបស់គេ ជាជាងការចាំឲ្យឪពុក ម្ដាយសម្រេចចិត្ត។

ឪពុកម្ដាយគឺជាអ្នកមានគុណ ក៏ប៉ុន្តែវាពុំមែនមានន័យថា យើងត្រូវតែធ្វើតាមពួកគាត់រហូតនោះទេ។ ខ្ញុំនិយាយបែបនេះក៏មិនមែនមានសេចក្ដីថាខ្ញុំជាកូនកត្តញ្ញូនោះទេ ក៏ប៉ុន្តែគូស្រករបស់យើង គឺជាអ្នកដែលនឹងរស់នៅជាមួយយើងពេញមួយជីវិត ពុំមែនឪពុកម្ដាយរបស់យើងឯណា»។

«បើសិនជាយើងត្រូវវេទនា ដោយសារតែយើងត្រូវរស់នៅជាមួយមនុស្សខុស តើនរណាដែលនឹងមកទទួលខុសត្រូវចំពោះរឿងក្រៅតែពីខ្លួនយើង? យើងត្រូវរកមនុស្សណា ដែលមានល្អគ្រប់គ្រាន់សម្រាប់រូបយើង និងស្រលាញ់រូបយើង ហើយធ្វើខ្លួនឲ្យល្អសម្រាប់គេ និងស្រលាញ់រូបគេវិញដែរ ហើយនៅ ពេលដែលយើងទាំងពីរមានសមត្ថភាពគ្រប់គ្រាន់ហើយ យើងអាចស្ម័គ្រចិត្តរៀបការ និងរស់នៅជាមួយគ្នាបាន។ ការបង្ខំ ឬហាមឃាត់នរណាក្នុងការជ្រើសរើសគូស្រករគឺជាអំពើរលោភលើសិទ្ធិមនុស្ស និងខុសនឹងច្បាប់ ទោះបុគ្គលនោះជានរណាក៏ដោយ»។

យុវជនឧត្តមក៏បានបន្ថែមដែរថា៖ «ប្រសិនជាឪពុកម្ដាយរបស់អ្នកណែនាំនរណាម្នាក់មកឲ្យអ្នកដែលពួកគាត់បានពេញចិត្តចង់បានជាកូនប្រសារ អ្នកក៏គួរតែឲ្យពួកគាត់ទុកពេលឲ្យអ្នកនឹងគេបានស្វែងយល់ចិត្តគ្នាជាមុនសិន។ អ្នកពុំអាចរៀបការជាមួយនរណាម្នាក់ដែលអ្នកពុំពេញចិត្ត ឬស្រលាញ់បាននោះឡើយ»។

សិក្សាអំពីរបៀបការជ្រើសរើសគូស្រករខ្មែរ

ក្រោយការភ្ជាប់ពាក្យ ការរៀបការត្រូវតែប្រារព្ធធ្វើឡើងតាមប្រពៃណីជាតិ បន្ទាប់ពីបានសុំការអនុញ្ញាតច្បាប់។ ពិធីរៀបមង្គលការ គឺជាពិធីមួយដែលរៀបចំឡើងសម្រាប់ផ្សំផ្គុំមនុស្សប្រុស ស្រីឲ្យក្លាយជាប្ដីប្រពន្ធ។ នៅក្នុងប្រទេសកម្ពុជាយើង គូស្វាមីភរិយាថ្មីតែបានទទួលដំបូន្មានពីអាចារ្យ មាតាបិតា និងចាស់ទុំញាតិមិត្តទាំងសងខាង។ ដំបូន្មានទាំងនោះទាក់ទងទៅនឹងជីវិតរស់នៅប្រចាំថ្ងៃ ដើម្បីលើកកំពស់ ទំនាក់ទំនងប្រកបដោយសុភមង្គលក្នុងជីវិតអាពាហ៍ពិពាហ៍របស់គេ។

មនុស្សត្រូវតែរៀបការព្រោះមូលហេតុដូចខាងក្រោម៖

☞ កសាងគ្រួសារមួយដោយមានការទទួលស្គាល់ ពីច្បាប់ ពីប្រពៃណី និងពីសង្គម

☞ បង្កើត និងចិញ្ចឹមបីបាច់ថែរក្សាកូន ដើម្បីបន្តពូជពង្សវង្សត្រកូល

☞ បំពេញតម្រូវការខាងជីវសាស្ត្រ មានមិត្តរួមជីវិត

☞ ធ្វើឲ្យអ្នកដែលយើងស្រឡាញ់មានចិត្តសប្បាយរីករាយ ធានាសុវត្ថិភាព សេចក្តីស្រឡាញ់ និងអារម្មណ៍

☞ រស់នៅដោយខ្លួនឯង មិនពឹងផ្អែកលើម្តាយឪពុក។

☞ ការរៀបអាពាហ៍ពិពាហ៍អាចមានហេតុផលផ្សេងៗទៀត ប៉ុន្តែចំណុចសំខាន់ដែលត្រូវចងចាំគឺការរួមរស់ស្របច្បាប់រវាងបុរស និងស្ត្រី។ ការរៀបការមានសារៈសំខាន់ណាស់ព្រោះវាជាសញ្ញានៃការចាប់ផ្តើមជីវិតគ្រួសារថ្មី។ គូស្វាមីភរិយាថ្មីមានទំនួលខុសត្រូវដូចខាងក្រោម៖

☞ រក្សាទំនាក់ទំនងក្នុងគ្រួសារឲ្យល្អប្រកបដោយសុភមង្គល

☞ រៀបចំ និងអនុវត្តផែនការគ្រួសារ

☞ មានមុខជំនាញដើម្បីងាយរកការងារធ្វើ

☞ ថែរក្សា និងរៀបចំគេហដ្ឋានឲ្យស្អាត មានអនាម័យ

☞ រក្សាទំនាក់ទំនងល្អ និងយោគយល់ចំពោះសាច់ថ្លៃ និងញាតិមិត្តជិតឆ្ងាយ

☞ លើកកម្ពស់សុខភាព និងសុខុមាលភាពគ្រួសារ

☞ គោរព ទទួលខុសត្រូវ យោគយល់ និងថែរក្សាគ្រួសារគ្រប់ពេលវេលា។

☞ ច្បាប់អាពាហ៍ពិពាហ៍នៅកម្ពុជា

**អាយុ**

អាយុរៀបការ គឺជាបញ្ហាដ៏សំខាន់ក្នុងការយកមកគិតពិចារណានៅមុនពេលរៀបការ។ នៅក្នុងមាត្រាទី៥នៃច្បាប់អាពាហ៍ពិពាហ៍ចែងថា បុរសអាចរៀបការនៅអាយុ២០ឆ្នាំ ហើយស្ត្រីត្រូវតែមានអាយុចាប់ ពី១៨ឆ្នាំឡើងទៅ។

មូលហេតុនៃការកំណត់អាយុនេះ គឺជាការយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់រដ្ឋាភិបាល លើសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ដែលមានបំណងកសាងគ្រួសារឲ្យបានរឹងមាំ មានសុភមង្គល និងធានាការចិញ្ចឹមបីបាច់ថែរក្សាអប់រំកូនរបស់គេបានល្អប្រសើរ។ ទោះជាយ៉ាងនេះក៏ដោយ ដើម្បីឲ្យមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការកសាងគ្រួសារមួយប្រកបដោយសុភមង្គល បុរសគួររៀបការក្នុងអាយុ ២៥ឆ្នាំ និងស្ត្រី ២១ឆ្នាំ។

ការជ្រើសរើសគូស្រករ

ប្រទេសកម្ពុជា ជាប្រទេសហត្ថលេខី នៃសន្ធិសញ្ញាអន្តរជាតិស្តីពីផែនការសកម្មភាពប្រជាករ និងអភិវឌ្ឍន៍ (ICPD ១៩៩៤)។ នៅក្នុងកិច្ចព្រមព្រៀងនោះ ប្រទេសកម្ពុជាបានយល់ព្រមទទួលយកមកអនុវត្តលើច្បាប់អាពាហ៍ពិពាហ៍នៅក្នុងប្រទេស តាមមាត្រាដូចខាងក្រោម៖

១. មាត្រាទី១៦ ការប្រកាសអំពីសិទ្ធិមនុស្ស

បុរសស្ត្រីដែលមានអាយុរៀបការមានសិទ្ធិរៀបការនិងបង្កើតគ្រួសារដោយមិនប្រកាន់សញ្ជាតិជនជាតិ

និងសាសនាឡើយ។ ពួកគេមានសិទ្ធិស្មើៗក្នុងការរៀបការ និងដំណោះស្រាយក្នុងជីវិតអាពាហ៍ពិពាហ៍។ ការរៀបអាពាហ៍ពិពាហ៍ត្រូវតែធ្វើឡើងដោយមានការព្រមព្រៀង រវាងសាមីខ្លួនទាំងពីរដោយគ្មានការគំរាមកំហែង និងបង្ខិតបង្ខំពីនរណាម្នាក់ឡើយ។ គ្រួសារជាកោសិកាសង្គមតាមបែបធម្មជាតិ មានសារៈសំខាន់ និងមានសិទ្ធិទទួលការការពារពីសង្គម និងពីរាជរដ្ឋាភិបាល។

២. មាត្រាទី២៣ ស្តីអំពីសន្ធិសញ្ញាអន្តរជាតិអំពីសិទ្ធិរបស់ប្រជាពលរដ្ឋ និងនយោបាយ

គ្មានការរៀបអាពាហ៍ពិពាហ៍ណាមួយ ដែលត្រូវធ្វើឡើងដោយគ្មានការព្រមព្រៀង និងដោយគ្មានការស្ម័គ្រចិត្តពីភាគីទាំងសងខាងទេ។ បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ទោះបីមានគ្រួសារមួយចំនួនជ្រើសរើសគូស្រករតាមរយៈម្តាយឪពុកក៏ដោយ ក៏សាមីខ្លួនភាគច្រើន បានធ្វើការសម្រេចចិត្តដោយខ្លួនគេផ្ទាល់ ក្នុងការជ្រើសរើសគូអនាគត។

ពិធីរៀបអាពាហ៍ពិពាហ៍ ៖ ពិធីរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា ត្រូវបានរៀបចំឡើងតាមលំដាប់លំដោយ ដូចខាងក្រោម៖

ស្វែងយល់ថា តើភាគីទាំងសងខាងអាចរស់នៅបានសេចក្តីសុខនឹងគ្នាឬទេ?

ដំណាក់ចែចូវ

ការកំណត់វេលាភ្ជាប់ពាក្យ

ពិធីរៀបមង្គលការ។

ពិធីដែលបានរៀបរាប់ខាងលើនេះ គេអាចធ្វើជាលក្ខណៈធំ ឬតូចទៅតាមលទ្ធភាពស្ថានភាពគ្រួសារ។ តែគេក៏មិនភ្លេចដែរថា អ្វីដែលសំខាន់ក្នុងជីវិតអាពាហ៍ពិពាហ៍ គឺសុភមង្គលក្នុងគ្រួសារ។ ការរៀបចំពិធីរៀបមង្គលការត្រូវបានធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម៖

ការរៀបចំមុន

ជាធម្មតា មុននឹងឈានចូលដល់ថ្ងៃរៀបមង្គលការ ប្រជាជនកម្ពុជា ត្រូវគោរពតាមទំនៀមទម្លាប់ប្រពៃណីជាតិ និងច្បាប់អាពាហ៍ពិពាហ៍។ មាតាបិតាទាំងសងខាង និងសាមីខ្លួនទាំងពីរត្រូវរៀបចំឯកសារមួយចំនួនដើម្បីសុំការអនុញ្ញាតពីរដ្ឋអំណាចមូលដ្ឋាន និងរៀបចំពិធីមង្គលការដូចខាងក្រោម៖

សំបុត្រកំណើតមួយច្បាប់

វិញ្ញាបនប័ត្របញ្ជាក់ទីលំនៅ និងនៅលីវ

សេចក្តីប្រកាសពីកន្លែងរៀបការ

លិខិតយល់ព្រមពីរដ្ឋអំណាច ដោយសុំសំបុត្រអាពាហ៍ពិពាហ៍ពីរដ្ឋអំណាច និងបិទប្រកាសជា សាធារណៈឲ្យបាន១០ថ្ងៃមុនថ្ងៃរៀបការចូលមកដល់។

រៀបចំសម្លៀកបំពាក់រៀបការ និងវត្ថុចាំបាច់ដទៃទៀត បើគូស្វាមីភរិយាថ្មីត្រូវទៅរស់នៅផ្ទះផ្សេង

រៀបចំបញ្ជីឈ្មោះភ្ញៀវ និងសំបុត្រអញ្ជើញ

រកអាចារ្យ និងនិមន្តព្រះសង្ឃ

រៀបចំកន្លែង និងអាហារសម្រាប់ទទួលភ្ញៀវ

រៀបចំអញ្ជើញភ្ញៀវឲ្យបានយ៉ាងតិច ៥ថ្ងៃមុនពេលរៀបការ

សម្អាត និងតុបតែងផ្ទះសម្បែងឲ្យបានមុនពេលរៀបការ ១ថ្ងៃ ឬ២ថ្ងៃ។

ពិធីរៀបអាពាហ៍ពិពាហ៍

តាមប្រពៃណីខ្មែរ ពិធីរៀបមង្គលការត្រូវធ្វើឡើងរយៈពេលបីថ្ងៃ តាមកម្មវិធីដូចខាងក្រោម៖

ថ្ងៃទី១

ជាថ្ងៃចូលរោង គឺថ្ងៃដែលគេដង្ហែកូនកម្លោះចូលទៅរោង ដែលគេសង់នៅក្បែរផ្ទះកូនក្រមុំមុននឹងនាំឡើងទៅផ្ទះខាងស្រី នៅពេលដង្ហែនោះមានភ្លេងលេងកំដរផង។

ថ្ងៃទី២ ជាថ្ងៃដែលគេប្រារព្ធពិធី៖

១. ពិធីលើកកំណត់៖ គេដង្ហែគ្រឿងភស្តុភារបណ្ណាការ(ជំនូន)ឡើងទៅលើផ្ទះខាងស្រី។

២. ពិធីសែនជំនាងផ្ទះ៖ គេដាក់ចំណីក្នុងកន្ទោង លើកដាក់ទៅក្នុងច្រម ជាកន្លែងសម្រាប់តង្វាយជូនដល់ជំនាងផ្ទះ។

៣. ពិធីសែនជូនតា៖ គេរៀបចំសែនជូនតាទាំងសងខាង។

៤. ពិធីស៊ីស្លា៖ គេលើកម្លូស្លាជូនមេបាចាស់ទុំពិសា។

៥. ពិធីកាត់សក់៖ ជាដំបូងអាចារ្យបួងសួងសុំរបស់ទិព្វពីទេវតា និងវត្ថុស័ក្តិសិទ្ធិ រួចឧទ្ទិសរំងាប់ចង្រៃហើយឧបកិច្ចកាត់សក់បីកន្រ្តៃដាក់ក្នុងកន្ទោង ដែលដាក់បណ្តែតក្នុងផ្តិល។ បន្ទាប់មកអ្នកច្រៀងកំប្លែងបានបួងសួងសុំកន្រ្តៃ ក្រាស កាំបិតកោរ កញ្ចក់.. រួចច្រៀងរៀបរាប់ពីព្រៃព្រឹក្សា និងការដើរលក់កន្រ្តៃ។

៥. ពិធីសូត្រមន្ត៖ គេនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត។

៦. ពិធីរៀបភោជនាហារជូនភ្ញៀវ៖ គេនិយមរៀបចំពិធីជប់លៀងភ្ញៀវនៅពេលយប់។

ថ្ងៃទី៣ ជាថ្ងៃផ្ទឹម ដែលគេមានរៀបចំពិធីដូចតទៅ៖

១. ពិធីលាងជើងឲ្យកូនប្រុស

២. ពិធីសំពះផ្កាស្លា៖ កូនប្រុសយកដៃកែផ្កាស្លាចំនួនបីដង

៣. ពិធីរាំបើកវាំងនន៖ គេច្រៀងអញ្ជើញកូនស្រីឲ្យចេញមកផ្ទឹម។

៤. ពិធីបង្វិលពពិល

៥. ពិធីសែនចងដៃ ឬ សែនកូចដៃ

៦. ពិធីធ្វើធ្មេញ ពិធីបុកលក្ខ ពិធីរៀបផ្លែឈើ

៧. ពិធីបាចផ្កាស្លា

៨. ពិធីតោងស្បៃចូលក្នុងបន្ទប់។

គឺថ្ងៃនេះហើយដែលគូស្វាមីភរិយាសន្មតថា ជាថ្ងៃជោគមង្គលសម្រាប់ការចាប់ផ្តើមដំណើរជីវិតរួមគ្នា។ ប៉ុន្តែសព្វថ្ងៃនេះ គេបានបំព្រួញពិធីរៀបអាពាហ៍ពិពាហ៍ឲ្យមកនៅត្រឹមតែមួយថ្ងៃប៉ុននោះ គឺចាប់ពីព្រលឹម គេហែកូនកម្លោះទៅផ្ទះកូនក្រមុំដោយនាំគ្រឿងភស្តុភារទៅជាមួយផង។ បន្ទាប់មកគេរៀបចំពិធីផ្សេងៗទៀតជាបន្តបន្ទាប់ ដូចបានរៀបរាប់ខាងលើ។ ដល់ពេលល្ងាចគេរៀបចំពិធីជប់លៀងនៅគេហដ្ឋានខាងស្រី ឬនៅភោជនីយដ្ឋានជាកិច្ចបញ្ចប់ពិធី។ ដោយមានគូស្វាមីភរិយាថ្មី អមដោយយុវជន យុវនារីកិត្តិយស(អ្នកកំដរ) ឈរនៅច្រកចូលរោងពិធីចាំទទួល និងជូនផ្កាថ្លែងអំណរគុណចំពោះភ្ញៀវ ដែលបានអញ្ជើញមកចូលរួម។ មាតាបិតាទាំងសងខាងត្រូវឈរទទួលភ្ញៀវដែលអញ្ជើញមកចូលរួមជិតកូនកម្លោះ កូនក្រមុំ។

៥ - ចែកទ្រព្យសម្បត្តិក្នុងសម័យគួរ

មាតាបិតាស្ទើគ្រប់រូបទាំងអស់នៅលើលោកនេះ បន្ទាប់ពីបានផ្តល់កំណើតឲ្យកូនមក ក្រៅពីការចិញ្ចឹមកូនឲ្យរស់រានមានជីវិត គឺមាតាបិតាទាំងឡាយ រៀបចំកូនឲ្យមានគូស្រករជាស្វាមីភរិយា ឲ្យបានសមរម្យសមឋានៈជាមនុស្សក្នុងសង្គម មាតាបិតាតែងតែចែករំលែកទ្រព្យសម្បត្តិដែលមាន តាមធនធានទាំងរបស់មានវិញ្ញាណ និងរបស់ឥតវិញ្ញាណ របស់មានវិញ្ញាណ មានដូចជា គោ ក្របី ជ្រូក មាន់ ទា ដំរី សេះ ជាដើម របស់ដែលគ្មានវិញ្ញាណ មានដូចជា ស្រែ ចម្ការ ច្បាដំណាំ មាស ពេជ្រ កែវកង ប្រាក់ តុ ទូ កៅអី គ្រែនិងរបស់មានតម្លៃផ្សេងៗទៀត ចែកដល់កូនប្រុសស្រីរបស់ខ្លួនដើម្បីប្រើប្រាស់ចិញ្ចឹមជីវិតតទៅ។

មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបំរុង ដោយស្ថាន៥យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថាន៥យ៉ាងនេះ ទិសខាងកើតនោះ ដែលកូនបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេមឥតមានភយន្តរាយយ៉ាងនេះ។

### ៥.១.២. តួនាទីកូនចំពោះមាតាបិតា

មាតាបិតានៅទិសខាងកើត កូនត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ៥យ៉ាងគឺ៖

១ - កូនត្រូវតាំងចិត្តថា អាត្មាអញមាតាបិតាបានចិញ្ចឹមរក្សាមកហើយ និងចិញ្ចឹមមាតាបិតាវិញ។

កូនត្រូវតាំងចិត្តថា៖ អាត្មាអញនេះ, មាតាបិតាបានចិញ្ចឹមបីបាច់ថែរក្សារហូតដល់ធំពេញរូបពេញរាងមកយ៉ាងនេះហើយ គឺត្រូវតែចិញ្ចឹមបីបាច់ថែរក្សាលោកទាំងពីរវិញទោះក្នុងលក្ខណ្ឌណាក៏ដោយ ឲ្យដូចដែលលោកបានចិញ្ចឹមបីបាច់ថែរក្សាយើង។ដូច្នេះចូរអ្នកកុំបីអៀនអន់ក្នុងការតប និងសងគុណលោកទាំងពីរដោយការបម្រើឱ្យបានខ្ជាប់ខ្ជួន ទៀងទាត់ និងជ្រះថ្លាផង។

២ - នឹងជួយធ្វើការងាររបស់មាតាបិតា

កូនត្រូវជួយធ្វើកិច្ចការងាររបស់មាតាបិតា ៖ ចូរកូនគ្រប់ៗរូប គប្បីធ្វើការងារប្រពៃលៃលកយកពេលវេលាធ្វើការងារជូនជួសឪពុកម្តាយកុំបីណាយក្លាយជាកូនខ្ជិលច្រអូសឡើយ។ កូនល្អត្រូវធ្វើកិច្ចការទាំងឡាយណាដែលធ្វើឱ្យឪពុកម្តាយរីករាយសប្បាយចិត្ត ត្បិតនេះក៏ជាកិត្តិយសរបស់យើងក្នុងនាមជាកូន ហើយយើងតែងទទួលបាននូវការកោតសរសើរពីនរជនគ្រប់ទិសទី។ ជាបុណ្យកុសល កូនៗនោះរមែងចម្រើនបានជួបតែសេចក្តីសុខ ឥតមានទុក្ខភ័យ គ្រោះចង្រៃណាហ៊ានមកកើតក្នុងជីវិតនៃបុគ្គលជាកូនល្អនោះឡើយ។

៣ - ទាំងតម្កល់វង្សត្រកូលឲ្យតាំងនៅល្អ

កូនត្រូវតម្កល់វង្សត្រកូលរបស់មាតាបិតាឱ្យបានល្អប្រសើរ ៖ បើឃើញអត្តភាពនៃជីវិតរបស់ខ្លួនឯងថាអាត្មាអញនេះ បានកើតមកក្នុងវង្សត្រកូលដែលល្អបវរដោយកេរ្តិ៍ឈ្មោះក្តី មាតាបិតាលោកប្រកបរបរសុច្ចរិតក្តីក្រុមគ្រួសារជាអ្នកប្រតិបត្តិក្នុងគន្លងធម៌ក្តី ជាអ្នកគោរពច្បាប់របស់នគរយ៉ាងម៉ឺងម៉ាត់ក្តី ពូជអម្បូរវង្សត្រកូលរបស់យើងសុទ្ធតែជាបុគ្គលសប្បុរស ដែលតែងតែទទួលបានការរាប់រក និងការសរសើរពីអ្នកផងក្នុងសង្គមចូរយើងជាកូន ចៅជំនាន់ក្រោយរបស់លោក គប្បីពិចារណាឲ្យបានល្អិតល្អន់ និងប្រតិបត្តិឲ្យស្របតាម ឬឲ្យបានល្អប្រសើរជាងតាមគន្លង នៃមរតកដ៏ថ្លៃថ្លាដែលអស់លោកបានកសាង និងបន្សល់ទុកដល់យើង។

ធ្វើយ៉ាងនេះ ឈ្មោះថា ៖ យើងបានតម្កល់ ឬលើកវង្សត្រកូលរបស់យើងហើយ។

៤ - ប្រតិបត្តិឲ្យជាអ្នកសមទទួលទ្រព្យសម្បត្តិមត៌កពីមាតាបិតាបាន

កូនត្រូវប្រតិបត្តិឲ្យសមជាអ្នកទទួលបាននូវមត៌កពីម្ដាយឪពុកៈ កូនប្រុសស្រីទាំងឡាយ គប្បីសិក្សាពិចារណាថាៈ ទោះបីម្ដាយឪពុកមានទ្រព្យតិចតួចសម្រាប់ចែកឱ្យកូនៗក៏ដោយក្ដី កូនៗគប្បីញ៉ាំងចិត្តរីករាយជ្រះថ្លាសមជាកូនល្អ ក្នុងការទទួលយកនូវមត៌កដ៏ប្រសើរទាំងនោះពីឪពុកម្ដាយ ជាពិសេសគឺព្រហ្មវិហារធម៌ ដែលជាទ្រព្យដ៏ប្រសើរក្រៃលែង ដែលលោកមានចិត្តមេត្តា ករុណា មុទិតា និងឧបេក្ខា ចំពោះកូនៗគ្រប់ៗរូប ចាប់តាំងពីចាប់បដិសន្ធិរហូតដល់ថ្ងៃ ដែលពួកគាត់ស្លាប់ចាកចោលរូបកាយទៅ គឺឥតមាននរណាមានចិត្តស្មោះត្រង់ ចំពោះកូនប្រុសស្រីស្មើនឹងលោកឪពុកអ្នកម្ដាយរបស់យើងឡើយ។

៥ - ធ្វើបុណ្យទក្ខិណាទាន ហើយឧទ្ទិសទក្ខិណាទានដល់មាតាបិតា ដែលធ្វើកាលកិរិយាទៅបរលោកហើយ។

កូនៗត្រូវធ្វើបុណ្យឧទ្ទិសទក្ខិណានុប្បទាន នៅពេលដែលលោកឪពុកអ្នកម្ដាយ ធ្វើកាលកិរិយាទៅបរលោកហើយៈ ការធ្វើបុណ្យទក្ខិណានុប្បទាន គឺជាផ្លូវនៃកុសលដែលកូនប្រុសស្រីគប្បីបំពេញដែលមិនអាចនឹងគេចវេះបានឡើយ ដើម្បីជាសេចក្ដីល្អរបស់យើងផង និងដើម្បីផ្ដល់នូវចំណែកនៃកុសលចំពោះលោកឪពុកអ្នកម្ដាយ ដែលធ្វើមរណកាលទៅកាន់លោកខាងមុខផង ការចេះធ្វើបុណ្យទក្ខិណានុប្បទាន គឺជាការប្រារព្ធនូវចិត្តជាកុសល ដែលធ្វើដើម្បីសង្គ្រោះដល់ជនដែលបានស្លាប់ទៅកាន់បរលោកនាយ។ ចូរកូនប្រុសស្រីកុំគប្បីប្រាសចាកមត៌កដែលលោកឪពុកអ្នកម្ដាយតែងតែធ្វើ គឺការកសាងនូវកុសល ធ្វើបុណ្យសុន្ទរ៍ទានរក្សាសីល។

### ៥.១.៣. តួនាទីភរិយាចំពោះស្វាមី

១ - ចាត់ចែងការងារដោយល្អ

☞ គោរពរាប់អានមាតាបិតា ញាតិមិត្តរបស់ស្វាមីឲ្យដូចញាតិមិត្តរបស់ខ្លួនឯង

☞ សង្គ្រោះមាតាបិតា ញាតិមិត្តរបស់ស្វាមីឲ្យសមទៅនឹងឋានៈតាមឱកាស

☞ សំដែងមេត្រី ចិត្តអាណិតអាសូរដល់ញាតិមិត្តរបស់ស្វាមីឲ្យដូចជារបស់ខ្លួនឯង

២ - សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ

☞ យកចិត្តទុកដាក់ ទទួលរាក់ទាក់ ឱកាសទៅលេង ឲ្យដំណឹង ឬសាកសួរព័តមាន សុខទុក្ខអ្នកជិតខាងរបស់ស្វាមីតាមកាលៈទេសៈ

☞ មិនប្រកាន់យករឿងឥតប្រយោជន៍ ឬពាក្យសំដីនិយាយមិនល្អ អ្នកដែលរាប់អានរបស់ស្វាមី

☞ ធ្វើចិត្តឲ្យធន់ ព្យាយាមអត់ឱនដល់មាតា បិតា ញាតិមិត្ត និងគោរពរាប់អានរបស់ស្វាមី

☞ មិនមាក់ងាយ មើលថោកមាតាបិតា ញាតិមិត្ត និងអ្នកជាទីគោរពរាប់អានរបស់ស្វាមី ទោះជាក្នុងប្រការណាក៏ដោយចរចាផ្អែមល្ហែមទន់ភ្លន់ យកចិត្តយកថ្លើមប្រតិបត្តិស្វាមីឲ្យសមជាភរិយាដ៏ល្អ។

៣ - មិនប្រព្រឹត្តក្បត់ចិត្តប្ដី

☞ មានសេចក្ដីស្មោះត្រង់ស្នេហា ស្វាមីភក្ដិចំពោះស្វាមីដោយសេចក្ដីគោរព

☞ មិនបែកចិត្តទៅនិយមប្រុសដទៃ មិនប្រព្រឹត្តស្និទ្ធស្នាល ឬដើរលេងជាមួយប្រុសដទៃលើសការគួរ

☞ ស្ទាប់ស្ទង់ ឲ្យស្គាល់និស្ស័យចិត្តថ្លើមរបស់ស្វាមី

☞ ប្រកាន់នាទីជាភរិយា ដែលត្រូវឧស្សាព្យាយាម កែខៃសេចក្ដីធ្វើប្រហែសធ្វេសប្រហែសផ្ទាំផ្ទងរបស់ស្វាមី ស្របតាមកាលៈទេសៈ

☞ មិននាំរឿងប្រុសដទៃមកនិយាយសំដែងការពេញចិត្តនឹងប្រុសដទៃជាហេតុនាំឲ្យស្វាមីរង្កៀសចិត្ត

☞ គិតដល់ជីវិត និងអនាគតកូនជាប់ជានិច្ច និងចាត់ទុកថាជាភារៈកិច្ចចំបងនៃគ្រួសារ

☞ រំលឹកជាប់ជានិច្ចថា នឹងធ្វើខ្លួនឲ្យទៅជាភរិយាដ៏ល្អបំផុតរបស់ស្វាមី និងមាតាដ៏ល្អរបស់បុត្រាបុត្រី☞ លាក់អាថ៌កំបាំងរបស់ស្វាមី និងគ្រួសារមិនឲ្យលេចលឺទៅក្រៅផ្ទះ

☞ គិតជានិច្ចថា កិច្ចធុរៈរបស់ស្វាមីក៏ជារបស់ខ្លួនឯងដែរ

☞ ពេលដឹងថាខ្លួនបានប្រព្រឹត្តខុសហើយ គួរតែទទួលសារភាព និងសុំទោស

☞ មិននាំយករឿងដែលមិនសមគួរមកនិយាយឲ្យស្វាមី ឬគ្រួសារទទួលសេចក្ដីក្ដៅក្រហាយ។

៤ - ថែទាំទ្រព្យដែលស្វាមីរកបានមកដោយល្អ

☞ រក្សាទ្រព្យសម្បត្តិដែលមានឲ្យនៅគង់វង្ស

☞ ហ្មត់ចត់ ចេះចាយក្នុងផ្លូវដែលញគួរចាយ មិនកំណាញ់ស្វិត ឬខ្ជះខ្ជាយជ្រុលហួស

☞ មិនលេងល្បែងស៊ីសង ឬសេពគ្រឿងស្រវឹង

☞ មិនលាក់ កិប ឬបិទបាំងស្វាមីក្នុងរឿងលុយកាក់

☞ សន្សែសន្សំទ្រព្យសម្បត្តិដែលរកបានដោយគន្លងធម៌ ឲ្យកើនទ្វេឡើងជាលំដាប់

☞ ព្យាយាមធ្វើខ្លួនជាអ្នកមានចិត្តថ្លើមធន់ និងទូលាយ។

៥ - ឈ្លាសវៃមិនខ្ជិលច្រអូសក្នុងកិច្ចការសព្វគ្រប់។

ភរិយាគប្បីពិចារណាខ្លួនឯងឲ្យបានរឿយៗថា កិច្ចការមេផ្ទះអញបានបំពេញល្អដែរទេ មានសេចក្ដីខ្ជិលមកច្របូកច្របល់ដែរឬអត់ទេ បើឃើញថា ខ្វះខាតគួរបំពេញ បើច្បាស់លាស់ពេញលេញល្អហើយក៏រក្សាឲ្យល្អតទៅ ការងារឆ្លាតវៃជាមង្គលដ៏ឧត្តម។

សម្ដីអាក្រក់លាមករបស់អ្នកដទៃគឺទុកត្រឹមអ្នកដទៃចុះកុំស្រវាប្រមូលមកឲ្យប្រឡាក់ដល់ខ្លួនឯង ទោះជាអំពើដោយកាយក៏ដោយ ត្រង់អ្នកដទៃធ្វើឬមិនធ្វើជាកិច្ចការងាររបស់គេ បើថាជាកូនចៅក៏អប់រំទូន្មានធ្វើជាកិច្ចការងាររបស់គេ បើថាជាកូនចៅក៏អប់រំទូន្មានប្រដៅទៅ ប៉ុន្តែចំពោះខ្លួនឯងវិញត្រូវតាំងស្មារតីកសាងស្នាដៃកុំភ័យក្រែងល្អលើសគេពេក នោះពេលរស់នៅមិនយូប៉ុន្មានឡើយ ឱកាសសាងល្អមានតិចតួចណាស់។ ឈ្នះសេចក្ដីល្ងង់របស់ខ្លួនឯងបាន ដោយការសិក្សាស្វែងយល់ ឈ្នះសេចក្ដីខ្ជិលបាន ដោយការព្យាយាម ឈ្នះសេចក្ដីក្រោធបាន ដោយការមិនក្រោធ ឈ្នះសេចក្ដីកំណាញ់ដោយការឲ្យទាន ឈ្នះការនិយាយឡេះឡោះដោយពាក្យបានការ។

**ភរិយា៧ប្រភេទ**

សម្តេចព្រះជិនស្រីសម្មាសម្ពុទ្ធ ទ្រង់សម្តែងនូវបុគ្គល៧ពួក សត្ត បុរិសស្ស ភរិយា ស្ត្រីជាភរិយានៃបុរសក្នុងលោកនេះមាន៧ពួកគឺ៖

១ - ប្រពន្ធគិតតែសម្លាប់ប្តី និមាតាបិតារបស់ប្តី (វធកា ភរិយា)

២ - ប្រពន្ធជាចោរ គិតតែលួចសម្បត្តិរបស់ប្តី (ចោរី ភរិយា)

៣ - ប្រពន្ធមានអាការស្មើរនឹងម្ចាស់នៃប្តី (អយ្យា ភរិយា)

៤ - ប្រពន្ធប្រព្រឹត្តក្នុងប្តីស្មើនឹងមាតា (មាតា ភរិយា)

៥ - ប្រពន្ធស្មើនឹងប្អូនស្រីរបស់ប្តី (ភគិនី ភរិយា)

៦ - ប្រពន្ធស្មើរនឹងសម្លាញ់របស់ប្តី (សខី ភរិយា)

៧ - ប្រពន្ធដូចជាខ្ញុំស្រីរបស់ប្តី (ទាសី ភរិយា)[25]។

ភរិយា៣ពួក គឺ វធកា ភរិយា១ ចោរី ភរិយា១ អយ្យា ភរិយា១ ជាភរិយាអាក្រក់ក បុរសមិនគួរយកធ្វើជាប្រពន្ធទេ គួរតែលះបង់ចោលទៅ ឯភរិយា៤ពួកខាងគឺ មាតា ភរិយា១ ភគិនី ភរិយា១ សខី ភរិយា១ ទាសី ភរិយា១ ជាភរិយាល្អ បុរសត្រូវយកធ្វើជាប្រពន្ធរហូតទៅ ហើយបុរសត្រូវទំនុកបម្រុងប្រពន្ធល្អនេះដោយកិច្ច៥យ៉ាងរហូតទៅ។

**៥.១.៤. តួនាទីស្វាមីចំពោះភរិយា**

ក្រោយពីរៀបអាពាហ៍ពិពាហ៍រួចមនុស្សពីរនាក់បានក្លាយជាគ្រួសារមួយ ជាភរិយាស្វាមីដែលត្រូវគោរពគ្នាទៅវិញទៅមក។ ការគោរពប្រតិបត្តិធ្វើឲ្យជីវិតគូស្នេហ៍មានសេចក្តីសុខទាំងកាយ ទាំងចិត្ត នេះជាទង្វើមួយដ៏សំខាន់ដែលស្វាមីភរិយាទាំងឡាយគួរតែសិក្សាស្រាវជ្រាវ។ ក្នុងគ្រួសារ ការមិនយោគយល់ចិត្តគ្នា ធ្វើឲ្យកើតមានការឈ្លោះប្រកែកបែកសំឡេងរហូតដល់ត្រូវលែងលះគ្នា។ ក្នុងគ្រួសារ គ្មានស្វាមីភរិយាណាប្រាថ្នាចង់ជួបការបែកបាក់ប្រេះឆានោះទេ។

១ - ការរាប់អានជាភរិយាពេញ ពេញសិទ្ធិពេញមុខពេញមាត់ក្នុងសង្គម។

☞ នាំទៅចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់រដ្ឋ

☞ លើតម្កើងភរិយាឲ្យពេញមុខ ដោយការណែនាំឲ្យទទួលភ្ញៀវ នាំទៅដើរលេង

☞ លើកតម្កើងការរស់នៅឲ្យស្មើភាពគ្នា ដូចជាបរិភោគរួមគ្នា អង្គុយស្មើគ្នា ដើរកៀកគ្នា

☞ មិនឲ្យភរិយាធ្វើការធ្ងន់ហួសកម្លាំង មានពេលរីករាយ និងឈប់សម្រាកខ្លះ ជួយភរិយាក្នុងកិច្ចការផ្ទះតាមសមគួរ។

☞ ជួយភរិយាពេលចេញក្រៅផ្ទះ ដូចជាជួយកាន់របស់ ពរកូន

[25] កម្ពុជសុរិយា ភាគ៣២/១ គ.ស១៩៦០ ទំព័រ ៥០១

☞ ប្រើពាក្យសំដីសរសើរ សាទរ និងអគុណានូវកិច្ចការដែលភរិយាធ្វើឲ្យ

☞ លើកតម្កើងសេចក្ដីល្អរបស់ភរិយាតាមកាលៈទេសៈ មិននិន្ទា ឬមាក់ងាយទោះជាប្រការណាក៏ដោយ។

☞ និយាយលួងលោមពេលភរិយាមានអាសន្ន

☞ ផ្ដល់ភាពកក់ក្ដៅ និងចែករំលែកភារកិច្ចស្រាលធ្ងន់ និងមិនធ្វើឲ្យមានវិបត្តិផ្លូវចិត្ត

☞ គោរពក្នុងឋានៈជាភរិយា និងជាមិត្តរួមជីវិត

☞ ព្យាយាមស្ដាប់ស្ទង់ ឲ្យស្គាល់និស្ស័យចិត្តថ្លើមភរិយា

☞ សន្ទនាប្រាស្រ័យ និងពោលពីកិច្ចការរបស់ខ្លួនឲ្យស្ដាប់តាមសមគួរ

☞ ប្រឹក្សាណែនាំ និងផ្ដល់យោបល់តាមសមគួរ

☞ លះបង់ថ្ងៃទំនេរឲ្យទៅថ្ងៃរបស់គ្រួសារតាមសមគួរ។

២ - មិនមើលងាយភរិយា[26]

☞ មិនវាយដំ ឬធ្វើទារុណកម្មភរិយា

☞ ប្រើពាក្យសំដីទន់ភ្លន់ជាមួយភរិយា

☞ ប្រសិនបើភរិយាខុស ភ្លាត់ភ្លាំងដោយប្រការណា គួរណែនាំដាស់តឿនដោយទន់ភ្លន់ មិនប្រើវាចាអាសអាភាស។

☞ កាលបើដឹងខ្លួនខុសត្រូវទទួលខុស

☞ រាល់លើកដែលខ្លួនទទួលគុណបំណាច់ក្នុងអំពើល្អ គប្បីនឹកជានិច្ចថា ភរិយាជាអ្នកមានចំណែកចូលរួមជាមួយផង

☞ មិនមាក់ងាយ មើលថោកមាតាបិតា ញាតិមិត្ត ឬអ្នករាប់អានរបស់ភរិយា

☞ មិនប្រៀបធៀបស្ត្រីដទៃ និងភរិយាខ្លួនក្នុងផ្លូវដែលនាំឲ្យកើតមានការអាក់អន់ចិត្ត

☞ មិនយកចំណុចខ្សោយរបស់ភរិយា មកនិយាយនាំឲ្យខ្មាស់អៀន និងឈឺចាប់ក្នុងចិត្ត

☞ ប្រកាន់នាទីជាស្វាមីដែលត្រូវដាស់តឿនសេចក្ដីធ្វេសប្រហែសរបស់ភរិយាតាមកាលៈទេសៈ

៣ - ដោយមិនប្រព្រឹត្តក្បត់ចិត្ត

☞ ស្មោះត្រង់នឹងគ្នាទៅវិញទៅមក

☞ ត្រូវចងចាំជានិច្ចថាទ្រព្យសម្បត្តិដែលមាន ឬរកមកបានក៏ជាការរួមចំណែករបស់ភរិយាផងដែរ

☞ គប្បីរំលឹកជាប់ជានិច្ចភរិយាជាភេទទន់ខ្សោយ ហើយទុករបស់ភរិយាក៏ជាទុករបស់ខ្លួនដែរ

☞ រក្សាព្យាបាលភរិយាដោយប្រពៃពេលភរិយាមានជំងឺឈឺថ្កាត់

☞ មិនប្រព្រឹត្តអាក្រក់ ដូចជាលេងល្បែងស៊ីសង ជក់កញ្ឆា ស្រា អាភៀន ។ល។

---

[26] សុត្តន្តបិដក ភាគ១៩ ព.ស ទំព័រ ៨៦

៤ - ដោយប្រគល់ការងារធំក្នុងផ្ទះឲ្យភរិយា

☞ ទុកភរិយាជាអណាព្យាបាល មើលថែទាំទ្រព្យសម្បត្តិ និងកិច្ចការក្នុងផ្ទះសម្បែង

☞ ធ្វើចិត្តត្រជាក់ឲ្យធន់ មិនឆេវឆាវ និងអត់ឱនចំពោះកំហុសភ្លាត់ភ្លាំងរបស់ភរិយា

☞ ជួយការពារភរិយាគ្រប់ផ្លូវ ដើម្បីឲ្យចាកផុតពីការមាក់ងាយ

☞ ធ្វើខ្លួនឲ្យសមជាមេគ្រួសារ។

៥ - ដោយការឲ្យគ្រឿងតែងខ្លួន (អលង្ការ)

ជាធម្មតាស្ត្រីរមែងត្រូវការអលង្ការ ទោះបីតិចច្រើនយ៉ាងណាក៏ទៅតាមកម្លាំងទ្រព្យ ដូច្នេះ ស្វាមីគប្បីបំពេញចិត្តភរិយាត្រង់ចំណុចនេះហាក់ដូចជាមិនចាំបាច់ប្រាប់សោះ ព្រោះថាបើបុរសស្រឡាញ់ស្ត្រីណាហើយក៏តែងប្រាថ្នាឲ្យអលង្ការដល់ស្ត្រីនោះ ណាមួយនាងជាភរិយាទៀតផង ពិតមែនតែភរិយាប្រដាប់អលង្ការប៉ុន្តែវាសង្ហាស្វាមីឯណោះទេតើ។

តាមពិត ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងអំពីវត្ថុសម្រាប់សង្គ្រោះគ្រប់យ៉ាង ដើម្បីបណ្តុះនូវពូជមេត្រីភាពឲ្យដល់សត្វលោក ដែលសត្វលោកកំពុងតែខ្វល់ខ្វាយ ក្នុងការស្រឡាញ់ស្អប់គាប់ទាស់ជារៀងរាល់ថ្ងៃមកនោះ។ អលង្ការនេះត្រូវបានជាតំណាងឲ្យមេត្តាចិត្តតំណាងឲ្យសេចក្តីថ្លៃថ្នូរ តំណាងឲ្យសេចក្តីស្មោះត្រង់។ បដិសេធការមើលងាយមើលថោក ការវាយដំទាត់ធាក់ និងអំពើអាក្រក់ផ្សេងៗទៀត ដែលជាលាមកមិនមែនអលង្ការ។

### ៥.១.៥. តួនាទីសិស្សចំពោះគ្រូ

អាចារ្យជាទិសខាងត្បូង សិស្សត្រូវប្រតិបត្តិដោយស្ថាន៥យ៉ាងគឺ

១ - ដោការក្រោកឡើងទទួល

២ - ដោយការគាល់បម្រើ

៣ - ដោយការជឿស្តាប់ឱវាទ

៤ - ដោយការបម្រើតូចៗមានទឹកលុបមុខនឹងស្ងួនជាដើម

៥ - ដោយការរៀនសិល្បសាស្ត្រ ដោយគោរព

### ៥.១.៦. តួនាទីគ្រូចំពោះសិស្ស

អាចារ្យជាទិសខាងត្បូង ដែលសិស្សប្រតិបត្តិហើយដោយស្ថាន៥យ៉ាងនេះឯងហើយ រមែងអនុគ្រោះសិស្សដោយស្ថាន៥យ៉ាងវិញគឺ

១ - ដឹកនាំសិស្សឲ្យល្អ

២ - ឲ្យសិស្សរៀនដោយល្អ

៣ - ប្រៀនប្រដៅសិស្សឲ្យចេះត្រឹមត្រូវក្នុងសិល្បសាស្ត្រសព្វគ្រប់

៤ - តែងលើកតម្កើងសិស្សក្នុងទីប្រជុំមិត្តអាមាត្យ

៥ - ធ្វើសេចក្តីការពារសិស្សក្នុងទិសទាំងឡាយ

### ៥.១.៧. តួនាទីចៅហ្វាយនាយចំពោះបុគ្គលិក

ទាសៈ និងកម្មករ ជាទិសខាងក្រោមចៅហ្វាយនាយត្រូវទំនុកបម្រុងដោយស្ថាន៥យ៉ាងគឺ ដោយការចាត់ចែងការងារសមគួរតាមកម្លាំង១ ដោយាការឲ្យនូវភត្តាហារនឹងថ្លៃឈ្នួល១ ដោយការព្យាបាលក្នុងវេលាឈឺថ្កាត់១ ដោយាការចែករំលែកនូវរបស់មានរសត្រកាលចំឡែក១ ដោយការឈប់សម្រាកក្នុងសម័យគួរ១។

### ៥.១.៨. តួនាទីបុគ្គលិកចំពោះចៅហ្វាយនាយ

ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ១ ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ១ កាន់យកតែរបស់ដែលចៅហ្វាយនាយឲ្យ១ ធ្វើការងាររបស់ចៅហ្វាយនាយដោយយកចិត្តទុកដាក់១ នាំកិត្តិគុណរបស់ចៅហ្វាយនាយទៅថ្លែងក្នុងទីនោះៗ១។ ទាសៈ និងកម្មករជាទិសខាងក្រោម ដែលចៅហ្វាយនាយទំនុកប្រុងហើយដោយស្ថាន៥យ៉ាងនេះឯងហើយ រមែងអនុគ្រោះចៅហ្វាយនាយដោយស្ថាន៥យ៉ាងនេះទិសខាងក្រោមនោះ ដែលចៅហ្វាយនាយបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ។

### ៥.១.៩. តួនាទីសមណៈព្រាហ្មណ៍ចំពោះបរិស័ទ៦ប្រការ

ហាមឃាត់កុលបុត្តចាកអំពើអាក្រក់១ ឲ្យតាំងនៅក្នុងអំពើល្អ១ អនុគ្រោះដោយចិត្តដ៏ល្អ១ ឲ្យបានស្តាប់ពាក្យដែលមិនធ្លាប់បានស្តាប់១ បំភ្លឺសេចក្តីដែលធ្លាប់ស្តាប់ហើយ១ ប្រាប់ផ្លូវសួគ៌១។

### ៥.១.១០. តួនាទីបរិស័ទចំពោះសមណៈព្រាហ្មណ៍៥ប្រការ

កាយកម្មប្រកបដោយមេត្តា១ វចីកម្មប្រកបដោយមេត្តា១ មនោកម្មប្រកបដោយមេត្តា១ ជាអ្នកមិនបិទទ្វារផ្ទះ១ ដោយកិរិយាឲ្យនូវអាមិសទាន១[27]។

### ៥.១.១១. កល្យាណមិត្ត

មនុស្ស៤ពួកនេះ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អគឺ មិត្តមានឧបការៈ អ្នកត្រូវដឹងថាជាមិត្តមានសន្តានចិត្តល្អ១ មិត្តរួមសុខទុក្ខ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ១ មិត្តប្រាប់ប្រយោជន៍ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ១ មិត្តមានសេចក្តីឈឺឆ្អាល អ្នកត្រូវដឹងថា ជាមិត្តមានសន្តានចិត្តល្អ១។

មិត្តមានឧបការៈ ជាមិត្តមានសន្តានល្អ ត្រូវដឹងដោយស្ថាន៤យ៉ាងគឺ រក្សាមិត្តដែលធ្វេសប្រហែស១ រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស១ ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្តីភិតភ័យ១ កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្តល់ភោគៈជាទ្វិគុណាជាងទ្រព្យដែលមិត្តត្រូវការនោះ១។

មិត្តរួមសុខទុក្ខ ជាមិត្តដែលមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន៤យ៉ាងគឺ ប្រាប់អាថ៌កំបាំងរបស់ខ្លួនដល់មិត្ត១ ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត១ មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ សូម្បីជីវិតក៏ហ៊ានលះបង់ដើម្បីប្រយោជន៍ដល់មិត្ត១ ។

[27] សុត្តន្តបិដក ទីឃនិកាយ ភាគ១៩ ព.ស២៥០៣ ទំព័រ៩០

មិត្តប្រាប់ប្រយោជន៍ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន៤យ៉ាងគឺ ហាមចិត្តឲ្យឃ្លាតចាក់អំពើអាក្រក់១ ដឹងនាំឲ្យមិត្តតម្កល់នៅតែក្នុងអំពើល្អ១ ឲ្យបានឮពាក្យដែលមិនធ្លាប់បានឮ១ ប្រាប់ផ្លូវសួគ៌១។

មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន៤យ៉ាងគឺ ជួយព្រួយចិត្តពីព្រោះមិត្តបានសេចក្តីវិនាស១ ជួយត្រេកអរព្រោះមិត្តបានសេចក្តីចម្រើន១ ទទឹងទាស់នឹងមនុស្សដែលពោលទោសមិត្ត១ សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត១។

### ៥.១.១២. បាបមិត្ត

បុគ្គលខ្លះ ជាមិត្តសម្លាញ់បានតែក្នុងរោងសុរាក៏មាន បុគ្គលខ្លះថា សម្លាញ់ៗបានតែនៅចំពោះមុខក៏មាន បុគ្គលណាកាលបើប្រយោជន៍ (ខ្លួន) កើតឡើងទើបធ្វើជាសម្លាញ់ បុគ្គលនោះមកជាសម្លាញ់នឹងខ្លួនក៏មាន។ ការដេកដល់ថ្ងៃ១ ធ្វើសេវនកិច្ចនឹងប្រពន្ធអ្នកដទៃ១ ភាវៈជាអ្នកមានពៀរច្រើន១ ភាវៈជាអ្នកធ្វើអំពើឥតប្រយោជន៍១ ភាវៈជាអ្នកកំណាញ់ស្វិតស្វាញ១។ នរជនដែលមានមិត្រអាក្រក់មានសម្លាញ់អាក្រក់ មានមារយាទនឹងគោចរអាក្រក់ យ៉ាងដូច្នេះគង់នឹងដល់នូវសេចក្តីវិនាសយ៉ាងពិតប្រាកដ។

អ្នកត្រូវស្គាល់ពួកមនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម៤ពួកនេះគឺ អ្នកត្រូវស្គាល់មនុស្សដែលគិតយកតែប្រយោជន៍ខ្លួនថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម១ អ្នកត្រូវស្គាល់មនុស្សល្អតែសំដីថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម១ អ្នកត្រូវស្គាល់មនុស្សដែលនិយាយចាក់បណ្តោយឲ្យគាប់ចិត្តថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម១ អ្នកត្រូវស្គាល់មនុស្សជាសម្លាញ់ ក្នុងការវិនាសគោគៈទាំងឡាយថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម១ សេពគប់មិត្តព្រោះហេតុតែប្រយោជន៍១ ទាំងនេះជាមិត្តប្លម។

មិត្តល្អតែសំដី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន៤យ៉ាងគឺ មិត្តទទួលរាក់ទាក់ដោយរបស់ដែលកន្លងហើយ១ ទទួលរាក់ទាក់ដោយរបស់ដែលមិនទាន់មានមក១ សង្គ្រោះដោយអំពើឥតប្រយោជន៍ កាលកិច្ចទាំងឡាយកើតភ្លាមៗ ក៏សម្តែងអាងរបស់ខូចខាត១។

មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន៤យ៉ាងគឺ បើមិត្តធ្វើអំពើអាក្រក់ ក៏យល់ព្រមតាម១ មិត្តធ្វើអំពើល្អក៏យល់ព្រមតាម១ ពណ៌នាគុណមិត្ត តែក្នុងទីចំពោះមុខ១ ពោលទោសមិត្ត ក្នុងទីកំបាំងមុខ១ ទាំងនេះមិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម។

មនុស្សគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្តគ្រាន់តែមិត្តប្លម (នោះ) អ្នកត្រូវស្គាល់ដោយស្ថាន៤យ៉ាង គឺមិត្តគិតយកតែប្រយោជន៍ខ្លួន១ មិត្តប្រាថ្នាយករបស់ច្រើនដោយ (ឱ្យ) របស់តិចតួច១ ទាល់តែមានភ័យទើបជួយធ្វើកិច្ចរបស់មិត្ត១។

មនុស្សជាសម្លាញ់ក្នុងផ្លូវវិនាស មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន៤យ៉ាងគឺសម្លាញ់ក្នុងកិរិយាប្រកបដោយរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ១ ជាសម្លាញ់ក្នុងការប្រកបរឿយៗនូវការត្រាច់ទៅតាមច្រកល្ហកខុសកាល១ ជាសម្លាញ់ក្នុងកិរិយាដើរមើលល្បែងមហោស្រព១ ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយៗ នូវល្បែងភ្នាល់ដែលជាហេតុជាទីតាំងនៃសេចក្តី

ប្រមាទ[28]១ ទាំងនេះគឺមនុស្សជាសម្លាញ់ក្នុងផ្លូវវិនាស។

**៥.១.១៣. អបាយមុខ ជាប្រធាននៃសេចក្តីវិនាសភោគៈ៦យ៉ាង**

១ - កិរិយាប្រកបរឿយៗនូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទ ជាប្រធាននៃសេចក្តីវិនាស។

ទោសក្នុងកិរិយាប្រកបរឿយៗនូវការផឹកទឹកស្រវឹងគឺសុរា និងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្តីវិនាសមាន៦យ៉ាងគឺ

គឺវិនាសទ្រព្យដែលឃើញជាក់ស្តែងខ្លួនឯង១ ការឲ្យកើតជម្លោះ១ ហេតុនាំឲ្យកើតរោគទាំងឡាយ១ ការនាំឲ្យខូចកេរ្តិ៍ឈ្មោះ១ ការបញ្ចាកេរ្តិ៍ខ្មាស១ ហេតុជាគម្រប់៦ គឺធ្វើបញ្ញាឲ្យមានកម្លាំងថយខ្សោយ១។

២ - បានប្រកបរឿងៗ នូវការត្រាច់ទៅតាមច្រកល្ហកខុសកាល ជាប្រធាននៃសេចក្តីវិនាសភោគៈ

ទោសក្នុងការប្រកបរឿយៗ នូវការដើរទៅតាមច្រកល្ហកខុសកាលនេះមាន៦យ៉ាងគឺ អ្នកនោះឈ្មោះថា មិនគ្រប់គ្រងមិនរក្សាខ្លួន១ អ្នកនោះឈ្មោះថា មិនគ្រប់គ្រងមិនរក្សាកូនប្រពន្ធ១ អ្នកនោះឈ្មោះថា មិនគ្រប់គ្រងមិនរក្សាទ្រព្យសម្បត្តិ១ សេចក្តីរង្កៀសតែងកើតមានក្នុងកន្លែង (ដែលខ្លួនទៅដល់)នោះៗ១ ពាក្យមិនពិតតែងធ្លាក់មកត្រូវលើបុគ្គលនោះ១ បុគ្គលនោះឈ្មោះថា បំពេញនូវធម៌ជាទុក្ខច្រើន១

៣ - ការដើរមើលមហោស្រព ជាប្រធាននៃសេចក្តីវិនាសភោគៈ

ទោសក្នុងការដើរមើលល្បែងមហោស្រពនេះមាន៦យ៉ាងគឺ របាំក្នុងទីណា ក៏ទៅក្នុងទីនោះ១ ចម្រៀងក្នុងទីណា ក៏ទៅក្នុងទីនោះ១ ការប្រគំក្នុងទីណា ក៏ទៅក្នុងទីនោះ១ គេប្រជុំនិយាយរឿងព្រេង ឥតប្រយោជន៍ក្នុងទីណា ក៏ទៅក្នុងទីនោះ១ ល្បែងវាយគងក្នុងទីណា ក៏ទៅក្នុងទីនោះ១ ល្បែងវាយនោតក្នុងទីណា ក៏ទៅក្នុងទីនោះ១។

៤ - ការប្រកបរឿយៗ នូវហេតុជាទីតាំង នៃសេចក្តីប្រមាទ គឺលេងល្បែងភ្នាល់ ជាប្រធាន នៃសេចក្តីវិនាសភោគៈ។

ទោសក្នុងការប្រកបរឿយៗនូវការលេងល្បែងភ្នាល់ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ នេះមាន៦យ៉ាងគឺ បុគ្គលនោះបើឈ្នះគេ តែងបានពៀរ១ បើចាញ់គេ តែងសោកស្តាយទ្រព្យសម្បត្តិ១ វិនាសទ្រព្យសម្បត្តិ ដែលឃើញជាក់ស្តែងទាន់ភ្នែក១ កាលបើទៅសាលាវិនិច្ឆ័យ គេមិនជឿស្តាប់ពាក្យ១ ពួកមិត្តអាមាត្យតែងបោះបង់ចោល១ ជាបុគ្គលដែលគេមិនត្រូវការដណ្តឹង ឬឲ្យកូនស្រី ព្រោះគេគិតថា បុរសបុគ្គលអ្នកលេងល្បែងភ្នាល់ មិនអាចចិញ្ចឹមប្រពន្ធបានទេ១។

៥ - ការសេពគប់នូវបាបមិត្ត ជាប្រធានៃសេចក្តីវិនាសភោគៈ។

ទោសក្នុងការសេពគប់នូវបាបមិត្តនេះមាន៦យ៉ាងគឺ ពួកជនដែលជាអ្នកលេងល្បែងភ្នាល់១ ជនដែល

[28] សុត្តន្តបិដក ភាគ១៩ ព.ស ២៥០៣ ទំព័រ ៨០

ជាអ្នកលេងស្រី១ ជនដែលជាអ្នកលេងផឹកសុរា១ ជនដែលជាអ្នកបោកប្រាសបញ្ឆោតអ្នកដទៃ ដោយរបស់ក្លែង១ ជនដែលជាអ្នកបំបាត់ប្រវ័ញ្ចអ្នកដទៃ ក្នុងទីចំពោះមុខ១ ជនដែលជាអ្នកឆក់ដណ្តើមទ្រព្យសម្បត្តិអ្នកដទៃ១ ជនទាំងនោះជាមិត្តសម្លាញ់របស់ជននោះ។

៦ - ការប្រកបរឿយៗនូវសេចក្តីខ្ជិល ជាប្រធាននៃសេចក្តីវិនាសភោគៈ។

ទោសក្នុងការប្រកបរឿយៗ នូវសេចក្តីខ្ជិលច្រអូសនេះមាន៦យ៉ាងគឺ មិនធ្វើការងារ ដោយអាងថា ត្រជាក់ណាស់១ មិនធ្វើការងារដោយអាងថា ក្តៅណាស់១ មិនធ្វើការងារដោយអាងថា ល្ងាចណាស់១ មិនធ្វើការងារដោយអាងថា ព្រឹកណាស់១ មិនធ្វើការងារ ដោយអាងថា ឃ្លានណាស់១ មិនធ្វើការងារដោយអាងថា ស្រេកណាស់១ កាលបើជនខ្ជិលច្រអូសនោះ ច្រើនដោយការពោលអាងកិច្ចយ៉ាងនេះ ភោគៈទាំងឡាយដែលមិនទាន់កើតក៏ខាន់កើតឡើងផងភោគៈទាំងឡាយដែលកើតឡើងហើយក៏ដល់នូវសេចក្តីរេចរឹលទៅវិញផង។

ភាពខ្ជិលច្រអូសនេះ បើមាននៅក្នុងខ្លួនអ្នកបួសរូបណាហើយ រមែងដឹកនាំអ្នកបួសរូបនោះឲ្យប្រព្រឹត្តក្នុងផ្លូវខុស ឲ្យមានសេចក្តីប្រមាទក្នុងកិច្ចប្រតិបត្តិទាំងពួងទាំងឡាយ បើជាគ្រហស្ថវិញភាពខ្ជិលច្រអូសនោះនឹងដឹកនាំឲ្យក្ររហាម ឲ្យល្ងង់ខ្លៅ ឲ្យថោកទាប ឲ្យវិនាសអន្តរាយចាកប្រយោជន៍គ្រប់យ៉ាង។

តាមសេចក្តីពិត ទ្រព្យសម្បត្តិមិនដែលរត់ចូលមកក្នុងដៃអ្នកខ្ជិលច្រអូសនោះឡើយ លុះណាតែបុគ្គលមានព្យាយាម គឺការក្រោកធ្វើការ ខំប្រឹងប្រែង ខ្មីឃ្មាត សង្វាតក្រោកឡើងធ្វើការផ្សេងៗ អត់ទ្រាំនឹងឧបសគ្គគ្រប់យ៉ាងទើបបានជោគជ័យក្នុងជីវិត។

ព្រោះហេតុនោះហើយ ទើបមានបុរាណភាសិតមួយកន្លែង បង្គាប់ឲ្យសម្លាប់មារយាទថោកទាបនេះ គឺឲ្យបោះបង់ការខ្ជិលច្រអូសចោល បើមិនដូច្នោះទេ រមែងទទួលនូវវិបត្តិគ្រប់យ៉ាងសម្រាប់ជីវិត។

មិនធ្វើការងារ ដោយអាងថា ត្រជាក់ណាស់ មិនធ្វើការងារ ដោយអាងថា ក្តៅណាស់ មិនធ្វើការងារ ដោយអាងថា ល្ងាចណាស់ មិនធ្វើការងារ ដោយអាងថា ព្រឹកណាស់ មិនធ្វើការងារ ដោយអាងថា ឃ្លានណាស់ មិនធ្វើការងារ ដោយអាងថា ស្រេកណាស់។

បុគ្គលដែលតាំងនៅក្នុងភាពទម្រន់នៃអំពើទាំងនេះ ជាមនុស្សបាននូវទ្រព្យសម្បត្តិផង មិនបាននូវវិជ្ជាផង មិបាននូវសេចក្តីស្រឡាញ់ផង មិនបានទទួលនូវការរាប់អានអំពីញាតិ និងអ្នកជុំវិញខ្លួនផង មិនទទួលបាននូវសេចក្តីទុកចិត្តផង មិនទទួលបាននូវកិត្តិសយ កេរ្តិ៍ឈ្មោះ យសសក្តិផង ជាដើម។

# ជំពូក៦

# ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញ

# អំពីលក្ខណៈសម្បត្តិអ្នកដឹកនាំ ទសពិធរាជធម៌

## ៦.១. ទសពិធរាជ១០ប្រការ

### ៦.១.១. និយមន័យទសពិធរាជ

ទសពិធរាជធម៌ (ទសៈ ពិធៈ រាជៈ ធ័រ) តាមទម្លាប់ថា ទស់សៈពិធរាជធម៌ (ទសវិធិ+រាជធម្ម) រាជធម៌១០យ៉ាងគឺធម៌១០ប្រការសម្រាប់ព្រះរាជា ទ្រង់ប្រព្រឹត្តព្រមទាំងណែនាំ ពួកសេនាបតី មន្ត្រីតូចធំ និងពួករាស្ត្រប្រជាឲ្យប្រព្រឹត្តផង។

ទសពិធរាជធម៌ ជាធម៌របស់ព្រះរាជាគ្រប់គ្រងនគរ ដែលនឹងអាចធ្វើឲ្យមហាជនស្រែកអបអរសាទរថា" ពេញចិត្ត ពេញចិត្ត ពេញចិត្ត " ទៅតាមអត្ថន័យរបស់ពាក្យ " រាជា " ដែលថា"ពេញចិត្ត" ដូចដែលបានអធិប្បាយរួចមកហើយ។ "ពេញចិត្តៗ" ជាឧទានស័ព្ទដែលសម្តែងឲ្យឃើញនូវទឹកចិត្តរីករាយ មានសេចក្តីសុខរបស់អ្នកដើរតាមចំពោះអ្នកដឹកនាំដែលបានបំពេញ "ធម្មៈ "ឬនាទីរបស់ខ្លួនបានដោយត្រឹមត្រូវ និងទៅតាមគោលបំណងរបស់មហាជន " រាជា " ឬអ្នកដឹកនាំណា ដែលបានធ្វើឲ្យមហាជនឧទានយ៉ាងដូច្នេះបាន យើងហៅថា"ធម្មរាជា"ឬ "ធម្មិករាជា " ធម្មរាជា ឬធម្មិករាជា ជាអ្នកដឹកនាំនៅក្នុងក្តីស្រមៃរបស់ខ្មែរដែលថា ថ្ងៃណាមួយលោកនឹងមកជួយដឹកនាំ គ្រប់គ្រងមហាជនខ្មែរ ដែលកំពុងរងទុក្ខវេទនា ឲ្យបានសេចក្តីសុខ និងអភិវឌ្ឍនភាពឲ្យក្លាយជាអារ្យប្រទេស។

ក្នុងរាជាណាចក្រខ្មែរ ព្រះរាជាដែលគ្រងរាជ្យក្រោយសម័យអង្គរ សុទ្ធតែជាពុទ្ធសាសនិកជន ដូច្នេះហើយបានជាយកទសពិធរាជធម៌នេះ ជាគោលធម៌ដែលព្រះរាជាគ្រប់ព្រះអង្គត្រូវគោរពប្រតិបត្តិ និងលើកកម្ពល់ទុកដូចជាមាត្រដ្ឋាន សម្រាប់ការគ្រប់គ្រងប្រទេស ។

ថ្វីត្បិតតែទសពិធរាជធម៌ ប្រែថាធម៌សម្រាប់ព្រះរាជាតាមកាលសម័យនៃរាជានិយមក្តី តែដូចដែលយើងបានឃើញហើយស្រាប់ថា រាជា សម្តៅដល់អ្នកដែលជាប្រមុខគេ ដឹកនាំគេ។

ដូច្នេះគោលធម៌នេះ មិនត្រឹមតែសំរាប់ព្រះរាជា១អង្គ ដែលជាអ្នកគ្រងរាជ្យប៉ុណ្ណោះទេ គឺបានដល់អ្នកណាដែលមាននាទីទទួលខុសត្រូវ ក្នុងកិច្ចការដឹកនាំគេជាប្រធានគេ ឬប្រមុខគេគ្រប់ជាន់ថ្នាក់ទាំងអស់ នៅក្នុងប្រទេសឥណ្ឌា ដែលជាប្រភពនៃពុទ្ធសាសនា ពាក្យថាក្សត្រ ឬវណ្ណៈក្សត្រពុំមែនសំដៅតែទៅលើក្សត្រដែលសោយរាជ្យនោះទេ។ ពាក្យថាក្សត្រមានន័យក្នុងឋានៈជាអ្នកដែលមានមុខនាទីក្នុងការគ្រប់គ្រងប្រទេស គ្រប់គ្រងខេត្តជាទ័ពចម្បាំងជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់។ បើនិយាយតាមភាសាបច្ចុប្បន្ន បានដល់រដ្ឋាភិបាល គណៈរដ្ឋមន្ត្រី និងមន្ត្រីរាជការទាំងពួង។

**ទសពិធរាជធម៌ មានទាំងអស់ ១០ ប្រការគឺៈ**

១. ទាន ការឲ្យ

២. សីល ការប្រព្រឹត្តល្អ

៣. បរិច្ចាគ ការបរិច្ចាគ

៤. អាជ្ជវៈ ការស្មោះត្រង់

៥. មទ្ទវៈ ការទន់ភ្លន់

៦. តបៈ ការដុតកិលេស

៧. អកោធៈ ការមិនក្រោធ

៨. អវិហឹង្សា ការមិនបៀតបៀន

៩. ខន្តី ការអត់ធន់

១០. អវិរោធនៈ ការមិនធ្វើខុស[29]

រាជធម៌ទាំង ១០ នេះ អាចចងចាំជាភាសាបាលីខ្លីៗថាៈ

ទានំ សីលំ បរិច្ចាគំ អាជ្ជវំ មទ្ទវំ តបំ

អកោធំ អវិហិង្សញ្ច ខន្តិញ្ច អវិរោធនំ ។

**៦.១.២. ទានៈ**

(ខ្វល់ខ្វាយក្នុងចែកអំណោយ ជាពិសេសគឺបង្កើតការងារឲ្យប្រជាជនធ្វើត្រឹមត្រូវ)

**ទាន** គឺការឲ្យជាប្រការទីមួយ ហើយក៏ជារឿងដំបូងបំផុតក្នុងចំណោមរឿងទាំងអស់ ដែលត្រូវនិយាយ គឺថាកំណើតរបស់មនុស្សយើង គ្រាន់តែកើតចេញមកអំពីផ្ទៃមាតាភ្លាម ក៏ចាប់ផ្តើមមានទានសម្រាប់ទទួលហើយ គឺរាប់ចាប់តាំងពីបោដោះរហូតដល់ចេះបរិភោគអាហារ និងបីថ្នាក់ថ្នមពផ្ងូតទឹក និងផ្តល់អ្វីសព្វយ៉ាងឲ្យយើងរៀនសូត្រចេះដឹងសម្រាប់អនាគត ។

" យើងទទួលទានពីគេ គេទទួលទានពីយើង " ប្រការនេះឯងដែលយើងធ្វើឲ្យជីវិតនេះ សង្គមនេះ និងពិភពលោកនេះ មានមនុស្សរស់នៅដោយការស្រលាញ់គ្នា នៅជាមួយគ្នាបាន។

ពាក្យថា ទាន ប្រើបរិបទ ២យ៉ាងគឺៈ

**១.ទាន** ការឲ្យដើម្បីជំរះកិលេស ដែលមាននៅក្នុងចិត្តរបស់អ្នកឲ្យ (មានគោលបំណងដើម្បីបដិបត្តិខាងផ្នែកផ្លូវចិត្តរបស់អ្នកឲ្យ)។

**២.ទាន** ការឲ្យដើម្បីជួយសង្គ្រោះ ដល់អ្នកទទួលទាន (មានគោលបំណងដើម្បីប្រណិប័តន៍យកចិត្តអ្នកទទួល)

អ្នកដឹកនាំគប្បីមានទានទាំង២បរិបទនេះ ព្រោះថាបរិបទនីមួយៗ មានគុណប្រយោជន៍ចំពោះអ្នកដឹកនាំទាំងអស់។ក្នុងបរិបទទីមួយមានប្រយោជន៍ក្នុងការកំចាត់នូវសេចក្តីលោភដែលជាអំពើអាក្រក់គ្រប់បែបគ្រប់យ៉ាង។ ការឲ្យទានបែបនេះ ស្របទៅតាមច្បាប់ធម្មជាតិ គឺថានៅពេលដែលយើងកើត ឥតមានយកអ្វីមកជាមួយទេ លុះដល់ពេលដែលយើងស្លាប់ទៅវិញក៏ឥតមានយកអ្វីទៅជាមួយដែរ។ ម្យ៉ាងទៀត ការឲ្យទានដើម្បីកម្ចាត់សេចក្តីលោភនេះចំពោះអ្នកដឹកនាំវិញគឺជាការកសាងបារមីឲ្យកើតមានដល់ខ្លួន និងឲ្យមហាជនទុកចិត្តលើភាពស្មោះត្រង់ចំពោះតួនាទីរបស់អ្នកដឹកនាំបាន។ ទានប្រភេទនេះអាចកំចតនូវពាក្យស្លោកខ្មែរថាៈ« មាន់នៅនិងស្រូវ លែងអីនឹងស៊ីស្រូវ »។

ចំពោះទានក្នុងបរិបទទី២ មានប្រយោជន៍ក្នុងគ្រប់គ្រងមហាជន។ ការឲ្យទាននេះមានន័យថា ការ

[29] ហេង មណីចិន្តា ព្រះបាទធម្មិក គ.ស ១៩៩៥ ទំព័រ ៨១

ជួយសង្គ្រោះទំនុកបម្រុងប្រជានុរាស្ត្រឲ្យបានសេចក្តីសុខនិងទិញទឹកចិត្តចងទឹកចិត្ត ឲ្យគេនឹកឲ្យគេស្រលាញ់ខ្លួន ដើម្បីឲ្យអ្នកស្រុកអួតថា "លោកហ្នឹងមនុស្សចិត្តល្អ" ដើម្បីបានផលប្រយោជន៍ត្រឡប់ពីអ្នកទទួលនោះមកវិញ។

ផលនៃការឲ្យទានបែបបរិបទទី២ នេះគឺៈ

ក. បានទទួលសេចក្តីស្រឡាញ់ពីអ្នកទទួល។

ខ. បានទទួលអាមិសតបត្រឡប់មកវិញ ដូចជាទ្រព្យរបស់ កិត្តិយស កេរ្តិ៍ឈ្មោះ។

ប្រភេទរបស់ទានមាន ៣គឺៈ

**១. វត្ថុទានៈ** គឺការឲ្យវត្ថុបច្ច័យឲ្យឧបករណ៍ធ្វើដើមទុន ឲ្យអ្វីៗជាបច្ច័យសម្រាប់ជីវិតដល់ប្រជារាស្ត្រ សាសនា អ្នករដ្ឋការ អ្នកដែលមានសេចក្តីត្រូវការ ។

**២. ធម្មទាន** គឺការឲ្យចំណេះវិជ្ជា និងឲ្យសមត្ថភាព ដែលអាចឲ្យអ្នកទទួលយកទៅជួយខ្លួនគេបាន ឲ្យការប្រៀបប្រដៅដូចជា ជួយដាស់តឿន ណែនាំ ការជួយពន្យល់ ឲ្យស្គាល់ពីការប្រព្រឹត្តល្អ ការលើកទឹកចិត្ត ឲ្យប្រឹងប្រែងតស៊ូជាដើម។

**៣. អភយទាន** គឺការឲ្យអភ័យទោសដល់ចំពោះមហាជន មានមេត្តា ករុណា មិនមែនជាមនុស្សចងពៀរ ចងអាឃាត ព្យាបាទ ដោយប្រកាន់ថាអញធំ អ្នកណាប៉ះមិនបាន។

### ៦.១.៣. សីលៈ

(ត្រូវឃុំគ្រងខ្លួនឯងឲ្យជាប់នៅក្នុងចំណែកនៃសេចក្តីល្អត្រឹមត្រូវតែម្យ៉ាង)

សីល គឺជាគោលទីពីរ ដែលធ្វើឲ្យព្រះរាជា ឬអ្នកដឹកនាំទាំងឡាយ ត្រូវមហាជនអបអរសាទរថា « ពេញចិត្តហើយ ពេញចិត្តហើយ, ជាខពីរដែលធ្វើឲ្យកើតសេចក្តីស្រឡាញ់ ភក្តីភាព ការទុកចិត្ត ការគោរពគ្នា ការសហប្រតិបត្តិការណ៍ដល់គ្នា និងគ្នាគ្រប់ៗផ្នែកទាំងអស់។

អ្នកដឹកនាំដែលមិនគោរពច្បាប់ គ្មានវិន័យ គ្មានសីល អ្នកដឹកនាំនោះនឹងក្លាយទៅជាអ្នកដឹកនាំ ផ្តាច់ការ ឃោរឃៅ រាស្ត្រមានតែសេចក្តីទុក្ខ។

**សីលប្រចាំលោករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ៥ ទៀតគឺៈ**

១. ការមិនបៀតបៀនប្រទូសរាយការកាប់សម្លាប់ជីវិតមនុស្ស សត្វទូទៅ។

២. ការមិនលួច ឬការកាន់យកទ្រព្យរបស់អ្នកដទៃ ដោយទុច្ចរិត។

៣. ការមិនប្រព្រឹត្តកន្លងកូនប្រពន្ធ ស្វាមីអ្នកដទៃគឺត្រេកអរតែ និងកម្មសិទ្ធិរបស់ខ្លួន។

៤. ការមិននិយាយកុហក ភូតភរ បោកបញ្ឆោត នាំឲ្យខូចប្រយោជន៍អ្នកដទៃ។

៥. ការមិនសេពនូវគ្រឿងស្រវឹង គ្រឿងញៀន ផ្សេងៗដែលបណ្តាលឲ្យប៉ះពាល់ដល់សុខភាព។

**ផលប្រយោជន៍របស់សីល**

. **សីល** នាំមកនូវស្ថានសួគ៌នាពេលបច្ចុប្បន្នឲ្យកើតឡើង។ ហើយសង្គមមនុស្ស នឹងក្លាយទៅជាសង្គមស្ថានសួគ៌ បើអ្នកដឹកនាំមានសីលជាគំរូឲ្យប្រជារាស្ត្រធ្វើតាម។

. **សីល** នាំឲ្យភោគសម្បត្តិកើនសម្បូរ ប្រើមិនចេះអស់។ ហើយសង្គមខ្មែរ នឹងក្លាយទៅជាសង្គម ដែលមានអភិវឌ្ឍន៍ក្លាយទៅជាអារ្យប្រទេសបើអ្នកដឹកនាំមានសីលជាគំរូឲ្យប្រជាជននាំគ្នាកាន់តាម។

. **សីល** នាំឲ្យសង្គមបាននូវសេចក្តីសុខ ត្រជាក់ត្រជុំ គ្មានភ្លើងសង្គ្រាម។ ក្នុងលោកនេះសីលគឺជារបស់ដ៏ប្រសើរបំផុត អ្នកមានប្រាជ្ញា ជាមនុស្សឧត្តមបំផុតអាស្រ័យដោយសារសីល និងបញ្ញា គេអាចយកជ័យជំនះលើមនុស្ស និងទេវតាបាន។

**៦.១.៤. បរិច្ចាគៈ**

(ត្រូវហ៊ានលះបង់ទាំងធនធាន និងកម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតី)

**បរិច្ចាគ គឺការលះបង់**

**ទាន** ក្នុងទសពិធរាជធម៌ ខទី១ បានដល់ការឲ្យទ្រព្យចំពោះអ្នកណាមួយ ឬក្រុមនីមួយៗដើម្បីទាក់ទាញចងរឹតទឹកចិត្តរបស់គេឲ្យស្មោះស្ម័គ្រ ឲ្យស្រលាញ់មកលើខ្លួន។ ឯបរិច្ចាគដែលជាគោលធម៌ទី ៣ នេះគឺបានដល់ការលះបង់ សេចក្តីសុខរបស់ខ្លួន ឬទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីប្រយោជន៍រួម មិនចំពោះអ្នកណា ឬក្រុមណាមួយឡើយដូចជាបរិច្ចាគកម្លាំង ដើម្បីកសាងថ្នល់ បរិច្ចាគដី ដើម្បីកសាងមន្ទីរពេទ្យ បរិច្ចាគលោហិត ដើម្បីព្យាបាលអ្នកជំងឺ,បរិច្ចាគទ្រព្យ ដើម្បីកសាងវត្តអារាម,បរិច្ចាគសេចក្តីសុខផ្ទាល់ខ្លួន ដើម្បីសេចក្តីសុខមហាជន។

ទាំងនេះគឺជាតួគោលបដិបត្តិដែលហៅថា បរិច្ចាគ ដែលនឹងអាចធ្វើឲ្យមហាជននាំគ្នាស្រែកថា "ពេញចិត្តៗ" ចំពោះអ្នកដឹកនាំ។

វិធីបដិបត្តិក្នុងការបរិច្ចាគៈ

បណ្ឌិតកាលណាឃើញថា បើលះបង់សេចក្តីសុខល្មមហើយ នឹងបាននូវសេចក្តីសុខដ៏ធំ ក៏គួរលះបង់នូវសេចក្តីសុខល្មមនោះចោល។

ព្រះពុទ្ធវចនៈបទនេះ ជាមេបទសម្រាប់អនុវត្តនូវការលះបង់។ សារសំខាន់ក្នុងពុទ្ធភាសិតនេះគឺថា មុននឹងលះបង់ ឬបរិច្ចាគអ្វីៗណានីមួយ គប្បីពិចារណាឲ្យបានច្បាស់លាស់។ បើឃើញច្បាស់ថា ការលះបង់នោះ នឹងទទួលបានប្រយោជន៍ច្រើនជាងខាតប្រយោជន៍ហើយ សឹមលះបង់។

ដូចខ្មែរយើងលោកបានប្រាប់ថា ឲ្យធ្វើខ្លួនដូចជាជង្គូវបាក់ខ្នង គឺបើចាប់ត្រង់ណាហើយ ត្រូវចាប់ឲ្យបានច្បាស់សិន ទើបលែងកន្ទុយទៅតាមក្រោយ។ នៅក្នុងការលះបង់នេះ ត្រូវស្ថិតនៅក្នុងគោលការណ៍ " លះតូចដើម្បីយកធំ "។ ដើម្បីងាយយល់ថារបស់ណាតូច មានប្រយោជន៍តិចរបស់ណាធំ មានប្រយោជន៍ច្រើន ព្រះសម្មាសម្ពុទ្ធបានសម្តែងអំពីលំដាប់នៃវត្ថុដែលត្រូវលះបង់ដូច្នេះ។

**ធនំ ចជេ អង្គវរស្ស ហេតុ អង្គំ ចជេ ជីវិតំ រក្ខមានោ**

**អង្គំ ធនំ ជីវិតញ្ចាបិ សព្វំ ចជេ នរោ ធម្មមនុស្សរន្តោ។**

គប្បីលះបង់ទ្រព្យសម្បត្តិ ដើម្បីរក្សាអវយវៈ គប្បីលះបង់អវយវៈ ដើម្បីរក្សាជីវិត គប្បីលះបង់ សូម្បីតែទ្រព្យ អវយវៈ និងជីវិត ដើម្បីថែរក្សាធម៌។

- **ទ្រព្យសម្បត្តិៈ** បានដល់មាសប្រាក់ របស់គ្រប់បែបយ៉ាងក្រៅពីខ្លួនប្រាណ សាច់ឈាមយើង រួមទាំងកម្មសិទ្ធិ និងផលប្រយោជន៍ ដែលនឹងអាចឲ្យកើតជាទ្រព្យដូចជាតំណែងអំណាច ជាដើម។
- **អវយវៈ** បានដល់រាងកាយ ដូចជាភ្នែក ត្រចៀក ច្រមុះ ដៃ ជើង ។ល។
- **ជីវិតៈ** បានដល់ជីវិតមានដង្ហើមចេញចូល ការរស់នៅ។

- **ធម៌:** បានដល់គុណធម៌ ដូចជាសន្តិធម៌ ការងារត្រឹមត្រូវ យុត្តិធម៌។

ទាំង ៤យ៉ាងនេះ គឺជាលំដាប់នៃតម្លៃ សម្រាប់វត្ថុដែលយើងនឹងត្រូវពិចារណាដើម្បីលះបង់។

**ក. លះបង់ទ្រព្យដើម្បីរក្សាអវយវៈ**

ទ្រព្យជារបស់ក្រៅខ្លួន មិនទៀងទាត់ ឧបមាដូចជាក្រមរឈើ ដែលរុំព័ទ្ធដើមសម្រាប់កាពារកម្តៅត្រឹមតែមួយ រយៈ ហើយក៏រុះពោយទៅ។ មាសប្រាក់ ក៏ដូចគ្នាដែរ បានហើយក៏អស់ទៅវិញដោយសារការចំណាយលើអ្វីៗសព្វបែបយ៉ាង។ ដូច្នេះបើប្រៀបធៀបជាមួយអវយវៈ ទ្រព្យត្រូវលះបង់ចោលមុនគេ។

**សម្រាប់អ្នកដឹកនាំ ការលះបង់ទ្រព្យមាន ២ យ៉ាងគឺ:**

▫ **រូបទ្រព្យ:** ការលះបង់នេះបានដល់ដីធ្លី ផ្ទះសម្បែង សត្វពាហនៈ យានជំនិះមាសប្រាក់។

▫ **នាមទ្រព្យ:**បានដល់អំណាច កេរ្តិ៍ឈ្មោះ តំណែង ការឃើញតែប្រយោជន៍ខ្លួន សេចក្តីសុខស្រួល សេចក្តីស្នេហា ការចងអាឃាត ព្យាបាទ កិលេស ឧបនិស្ស័យអាក្រក់ប្រចាំខ្លួនជាដើម។ នាមទ្រព្យទាំងនេះ របស់ណាអាក្រក់ របស់ណាដែលមិនជាប្រយោជន៍ច្រើនដល់មហាជន ក៏សុខចិត្តលះបង់ចេញ។

**ខ. លះបង់អាវៈយវៈ ដើម្បីរក្សាជីវិត**

អាវយវៈជារបស់ដែលជាប់និងខ្លួន មានស្នេហភាពជាងទ្រព្យសម្បត្តិ និងជារបស់ដែលសម្រាប់បង្កើតនូវទ្រព្យសម្បត្តិ ទើបត្រូវមានតម្លៃជាងទ្រព្យសម្បត្តិ។ ការលះបង់អវយវៈ បានដល់ការលះបង់ ចំណែករូបរាងកាយ ដែលមិនប៉ះពាល់ដល់ជីវិត ដូចជាលះបង់កម្លាំង លះបង់សេចក្តីសុខខាងរាងកាយ សុខចិត្តអត់ងងុយ ធន់នឿយហត់ ធន់ឈឺ ឃ្លាន សុខចិត្តបាត់បង់រូបឆោម ដើម្បីបំពេញប្រយោជន៍រួម។

**គ. លះបង់ជីវិតដើម្បីរក្សាធម៌**

ធម៌បានដល់សេចក្តីល្អ កិត្តិយស គុណធម៌ សីលធម៌ ដែលជាសម្បត្តិពិសេសរបស់មនុស្សយើង ជាខ្លឹមសាររបស់ជីវិត និងរាងកាយ ជាពិសេសគឺសម្រាប់អ្នកដឹកនាំ។ ជីវិតយើងតូចមួយត្រូវស្លាប់ត្រូវលះបង់មែនតែជីវិតរាប់រយម៉ឺនសែន ត្រូវរស់នោះយើងត្រូវលះបង់។

**ប្រយោជន៍របស់ការលះបង់**

សង្គមមនុស្ស ដែលនឹងអាចរស់រានមកដល់ពេលនេះបាន ក៏ព្រោះមានមនុស្សជាច្រើនលះបង់អ្វីៗគ្រប់បែបយ៉ាង តាំងពីទ្រព្យសម្បត្តិ អវយវៈ និងជីវិត ដែលជាទីស្រឡាញ់របស់ខ្លួន។ ការលះបង់នេះ ពុំមែនជាករណីយកិច្ចដោយបង្ខំទេ តែគឺជាច្បាប់ធម្មជាតិ ដែលចែងមកសម្រាប់ឲ្យយើងធ្វើ។ ព្រះពុទ្ធទ្រង់សម្តែងថា ជនមានប្រាជ្ញាតែជាអ្នកឃើញតែប្រយោជន៍ខ្លួន គឺអសោច។

ព្រោះហេតុនោះ បុគ្គលជាប្រមុខដឹកនាំ ត្រូវព្យាយាមលះបង់អំពីអាក្រក់ លះបង់ទ្រព្យសម្បត្តិដើម្បីអវយវៈ លះបង់អវយវៈ ដើម្បីជីវិត និងលះបង់ជីវិតដើម្បីធម្មៈ ហើយសន្តិភាព សន្តិសុខ យុត្តិធម៌ សុភមង្គល ឧត្តមសុខ ដ៏ប្រាកដជាកើតឡើងក្នុងសង្គម និងក្នុងលោកយ៉ាងពិត។

**៦.១.៥. អាជ្ជវៈ**

(ត្រូវធ្វើខ្លួនឲ្យត្រង់គឺត្រង់ដោយកាយ ត្រង់ដោយវាចា ត្រង់ដោយចិត្តជានិច្ច)

**អាជ្ជវៈ ការស្មោះត្រង់**

អាជ្ជវៈ ប្លែងមកពី **ឧជុ** ប្រែថា «ភាពត្រង់ មិនវៀចវេរ មិនបិទលាក់ » ជាស្តេចធម៌ ឬរាជធម៌ ជា

ចំណុចសំខាន់ទី៤ក្នុងចំណោមស្ដេចធម៌ទាំង១០ ដែលបុគ្គលជាប្រមុខណាមួយទ្រទ្រង់ឲ្យតាំងមាំនៅក្នុងសន្ដានហើយ នឹងបានជាប្រយោជន៍ដល់ជនច្រើន នឹងបានដល់នៅសេចក្ដីចម្រើនដល់ជនច្រើន នឹងបានដល់នូវសេចក្ដីសុខដល់ជនច្រើន នឹងញ៉ាំងមហាជនឲ្យរីករាយបាន។ (ភាពស្មោះត្រង់ គឺជាអាទិទេពដ៏មានឥទ្ធានុភាពរបស់បុគ្គលជាប្រមុខ (ថ្នាក់ដឹកនាំ) សម្រាប់ការស្រោចស្រង់ប្រទេសជាតិ និងជួយសង្គ្រោះដល់មហាជន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន)។ បញ្ញាក់ ថ្នាក់ដឹកនាំ ត្រូវស្មោះត្រង់ចំពោះខ្លួនឯង ស្មោះត្រង់ចំពោះក្រុម ស្មោះត្រង់ចំពោះការងារ ស្មោះត្រង់ចំពោះជាតិ ស្មោះត្រង់ចំពោះប្រជាពលរដ្ឋ គឺស្មោះត្រង់ទាំងក្នុងទីចំពោះមុខ និងស្មោះត្រង់ទាំងក្នុងទីកំបាំងមុខ គឺស្មោះត្រង់ជាសាធារណៈជនទូទៅ នឹងធ្វើទុកក្នុងចិត្តដោយឧបាយដ៏ត្រឹមត្រូវប្រកបដោយភាពប្រុងប្រយ័ត្នបំផុត។

**ប្រភេទរបស់ត្រង់**

គឺត្រង់ចំពោះតួនាទីគឺ នាទីរបស់ខ្លួន និងរបស់អ្នកតូច ត្រង់ចំពោះការងារ ត្រង់ចំពោះវាចា គឺនិយាយយ៉ាងណាធ្វើយ៉ាងហ្នឹង ត្រង់ចំពោះបុគ្គល គឺត្រង់ចំពោះខ្លួនឯង និងបុគ្គលដទៃ ត្រង់ចំពោះសេចក្ដីល្អ គឺកាយបរិសុទ្ធិ វាចាបរិសុទ្ធិ ចិត្តបរិសុទ្ធិ។

រួមសេចក្ដីថា នៅក្នុងការបំពេញតួនាទីរបស់ខ្លួនដែលជាអ្នកធំ ទោះបីជាមានអ្វីមករុញច្រាន ឬមកបង្ខំឲ្យខ្លួនងាកវេខុសផ្លូវធម៌យ៉ាងណាក៏ដោយ ក៏ខំពង្រឹងចិត្តរបស់ខ្លួន មិនព្រមចុះញ៉ម ឬលុះទៅតាមអំណាចទាំងនោះ ហើយហ៊ានតស៊ូពុះពារគ្រប់ឧបសគ្គដើម្បីរក្សាធម៌ឲ្យគង់វង្ស (ធម្មោ ហវេ រក្ខតិ ធម្មចារី អ្នករក្សាធម៌ៗតែងរក្សាបុគ្គលនោះវិញ)។

មនុស្សត្រង់គឺស្រឡាញ់ យុត្តិធម៌ ភាពត្រឹមត្រូវតាមធម៌ ដើរតាមគន្លងធម៌ ប្រកបដោយធម៌។

**ផលប្រយោជន៍របស់ភាពស្មោះត្រង់**

មនុស្សត្រង់ គឺមនុស្សមិនវៀច ពាក្យថា ត្រង់គឺជាតម្រូវការចំបាច់របស់មនុស្សទូទៅ ដោយហោចទៅសូម្បីតែវត្ថុក៏ដូចគ្នារួមទាំងការងារផងដែរ។ ជនដែលដើរតាមផ្លូវត្រង់ ផ្លូវកណ្ដាលគឺជាអរិយសាវ័ករបស់ព្រះសម្មាសម្ពុទ្ធដ៏ពិតៗ។ អ្នកដឹកនាំដែលត្រង់ គឺពិតជាអ្នកដឹកនាំដែលកំពុងនាំរាស្ត្រប្រជាដើរលើផ្លូវមជ្ឈិមប្បដិបទា ឆ្ពោះទៅរកការរួចផុតពីសេចក្ដីទុក្ខលំបាករបស់រាស្ត្រប្រជា នឹងឆ្ពោះទៅរកព្រះនិព្វានសម្រាប់ខ្លួនឯងផ្ទាល់ដ៏ពិតៗ។

**៦.១.៦. មទ្ទវៈ**

(ត្រូវធ្វើខ្លួនឲ្យជាមនុស្សទន់ភ្លន់ គឺទន់ភ្លន់ទាំងកាយ ទាំងវាចា ទាំងចិត្ត)

**មទ្ទវៈគឺភាពទន់ភ្លន់**

**មទ្ទវៈ** ប្រែថា ការទន់ភ្លន់ ប្រាស់ចាក់ការប្រងេងប្រងាង ប្រលើសបើស។

ក្នុងឋានៈជាអ្នកដឹកនាំ ជាប្រមុខរបស់ជនទាំងឡាយដ៏ច្រើន ក្រៅពីមាន ទាន សីល អាជ្ជវៈ អ្នកដឹកនាំត្រូវមានកិរិយាសុភាពទន់ភ្លន់រៀបរយ ចំពោះអ្នកក្រោមបង្គាប់ខ្លួន គួរឲ្យជាទីគោរពរាប់អាន និងចង់ឲ្យគេចូលចិត្តសន្ទនាប្រាស្រ័យជាមួយ និងមិនជាអ្នកក្រេប្រងេងប្រងាង មិនរឹងរូសចំពោះមហាជនដែលខ្លួនគ្រប់គ្រង។ ភាពទន់ភ្លន់នេះគឺជាមន្តដ៏សក្តិសិទ្ធ និងជាទឹកអម្រិតដ៏មានឥទ្ធានុភាព សម្រាប់ចាក់ស្រោច និងប្រស់ព្រំដល់អ្នកក្រោមបង្គាប់ មានន័យថា បុគ្គលជាប្រមុខត្រូវមានចិត្តទូលំទូលាយ មិនចង្អៀតចង្អល់ចំពោះអ្នកតូច គឺ

ទន់ភ្លន់ហើយមើងមាត់ប្រកបដោយគុណធម៌ និងវិចារណញ្ញាណដ៏ត្រឹមត្រូវ និងមានការទទួលខុសត្រូវខ្ពស់ចំពោះសិទ្ធិជាសាធារណៈ។

**គុណធម៌មទ្ទវៈនេះ** នឹងអាចបង្កើតផលដល់អ្នកបដិបត្តិបាន ជាដំបូងត្រូវធ្វើឲ្យកើតមាននៅក្នុងចិត្តជាមុនសិន បើចិត្តមិនទាន់មានភាពទន់ភ្លន់ កាយ វាចារបស់អ្នកនោះ ក៏មិនអាចមានភាពទន់ភ្លន់បានដែរ។ វិធីដែលនឹងឲ្យកើតមទ្ទវៈ នៅក្នុងចិត្តព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា ត្រូវធ្វើសមាធិជាពិសេស ការចម្រើនមេត្តា ករុណា មុទិតា និងឧបេក្ខា។

**ចិត្តដែលមានសមាធិ** ជាចិត្តដែលទន់ភ្លន់ និងជាចិត្តដែលអាចធ្វើការងារអ្វីៗក៏បានទាំងអស់ ដូចជាក្រមួនឃ្មុំ អាចយកទៅសូន្យធ្វើជារូបអ្វីក៏បាន។ ដូច្នេះ អ្នកដឹកនាំត្រូវរឹកហាត់សមាធិ អប់រំចិត្តឲ្យមានភាពនឹងនជាចិត្តមិនរវើរវាយ មានសតិនៅជាប់ជានិច្ច។ កាលណាចិត្តមានភាពហ្នឹងហើយ ការងារទាំងឡាយក៏នឹងកើនប្រសិទ្ធភាពជាមិនខាន (ចិត្តទន់ភ្លន់មិនខុសដៃយកដៃ មិនខុសជើងយកជើង)។

**សារសំខាន់របស់មទ្ទវៈ ឬភាពទន់ភ្លន់**

ក្នុងមួយថ្ងៃៗ យើងម្នាក់ៗត្រូវប្រឈមមុខនឹងនាទីរបស់ខ្លួនគ្រប់ពេលវេលា និងគ្រប់ទីកន្លែងទាំងអស់។ អ្នកគប្បីជ្រាបថា កាលណាយើងគោរពអ្នកដទៃ អ្នកដទៃនឹងគោរពយើងវិញ មានន័យថាអ្វីៗនៅក្នុងលោកមិនមែនសម្រេចអំពីអ្នកដទៃទាំងស្រុងទេ ពោលគឺវាមានចំណុចផ្តើមពីបុគ្គលម្នាក់ៗទើបវាមាន ប្រតិកម្មទៅវិញទៅមក យើងទន់ភ្លន់ទៅរកអ្នកដទៃ អ្នកដទៃនឹងទន់ភ្លន់មករកយើងវិញ។

ភាពទន់ភ្លន់នេះគឺនាំមកនូវសាមគ្គីធម៌ ឯកភាពគ្នា ភាពស្និទ្ធស្នាលរកគ្នា មិនចាប់កំហុសគ្នា មានអធ្យាស្រ័យល្អ មានភាពកក់ក្តៅក្នុងការងារ នាំមកនូវប្រយោជន៍ដ៏ច្រើន នាំមកនូវសេចក្តីសុខដ៏ច្រើនដល់គ្នានិងគ្នា មិនមានភាពច្របូកច្របល់ ភាពទន់ភ្លន់នាំមកនូវជោគជ័យក្នុងការងារ និងទំនាក់ទំនង។

**៦.១.៧. តបៈ**

(ត្រូវជាមនុស្សព្យាយាមជម្រុះចោលនូវអំពើអាក្រក់ ទម្លាប់អាក្រក់ចេញ)

**តបៈ គឺការកំចាត់អំពើអាក្រក់ ឬការដុតកម្តៅនូវកិលេស**

ពាក្យថា **តបៈ** ដែលមានន័យដុតកម្តៅនោះមិនមែនមានន័យថា ដុតធ្វើរដោយភ្លើង ឬដេកហាលថ្ងៃ ឬដេកលើផ្ទាំងថ្មឲ្យអស់កិលេសនោះឡើយ ការធ្វើបែបនេះគឺគ្រាន់តែធ្វើខ្លួនប្រាណឲ្យទុក្ខលំបាកប៉ុណ្ណោះ តែការដុតកម្តៅក្នុងទីនេះ គឺដៅដល់ការប្រតិបត្តិតាមធម៌ដ៏សមគួរដល់ធម៌ ដែលគួរប្រតិបត្តិឯណោះវិញទេ ពោលគឺត្រូវប្រព្រឹត្តទៅតាមគោលការណ៍សំខាន់ៗគឺ សីល សមាធិ និងបញ្ញា។

**តបៈ មានពីរប្រភេទគឺ:**

ក. តបៈ ព្រះរាជា

ខ. តបៈព្រះឥសី ឬតាបស

តបៈទាំងពីរប្រភេទនេះគឺដុតដូចគ្នា តបៈព្រះរាជា ប្រែថា ដុតអំពើអាក្រក់ ឯតបៈឥសី ឬតាបស ដុតសេចក្តីអាក្រក់។

តបៈព្រះរាជា គឺជាតបៈរបស់អ្នកដឹកនាំដែលជាប្រធានរបស់អ្នកដទៃ។ មានន័យថា បុគ្គលជាប្រមុខត្រូវតែប្រតិបត្តិខ្លួនឲ្យសមស្របទៅ និងឋានៈតួនាទី ការងា ដោយការសង្កេតរាល់អំពើរបស់ខ្លួន ដែលបាន

ប្រព្រឹត្តធ្វើក្នុងកំឡុងពេលនៃការគ្រប់គ្រងរបស់ខ្លួន ថាតើមានកំហុសឆ្គង អំពើអាក្រក់ដែលចេញមកតាមរយៈកាយ វាចា ចិត្ត មានលោភៈ ទោសៈ មោហៈ ដែរ ឬទេ? បើមានត្រូវព្យាយាមលះបង់គឺធ្វើតបៈនោះឯង។ នៅពេលដែលបុគ្គលជាប្រមុខបានប្រតិបត្តិដោយត្រឹមត្រូវល្អហើយ នោះប្រមុខដឹកនាំ នឹងឈានទៅដុតកម្ទេចអំពើអាក្រក់របស់អ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដោយការញាំញីនូវអំពើអាក្រក់ដោយការដាក់ទោស ព្យួរការងារ ដកមុខដំណែង ចំពោះអ្នកខុសដោយមិនគាំទ្រលើកទឹកចិត្ត ដល់មនុស្សអាក្រក់គឺមិនត្រូវចូលដៃជើង និងមនុស្សអាក្រក់ មិនជួយសង្គ្រោះជនអាក្រក់ ដែលប្រព្រឹត្តធ្វើអំពើអាក្រក់នាំឲ្យមានបញ្ហាដល់សង្គមជាតិ គឺមិនត្រូវស៊ីសំណូកស៊ីកប៉ាន់ចំពោះជនទុច្ចរិត ពោលគឺត្រូវដាក់ទោសទណ្ឌឲ្យសមទៅតាមទង្វើខិលខូចរបស់ជននោះ។

**តបៈព្រះឥសី៖** បានដល់ការបដិបត្តិធម៌ ដើម្បីដុតកម្ដៅនូវសេចក្ដីអាក្រក់ ដែលមាននៅក្នុងខ្លួនឲ្យអស់ទៅ។ ជាធម្មតា សេចក្ដីអាក្រក់មានបង្កប់នៅជាប់ជានិច្ចជាមួយនឹងតណ្ហា គឺសេចក្ដីប្រាថ្នា ចំណង់ ការចូលចិត្តរបស់មនុស្សម្នាក់ៗ ដូច្នេះហើយបានជាការធ្វើតបៈ គឺការខំប្រឹងអត់ធ្មត់ មិនធ្វើអ្វីទៅតាមចិត្តដែលខ្លួនចង់ ឬធ្វើអ្វីផ្ទុយនឹងទម្លាប់របស់ខ្លួន ដូចជាៈ

យើងចូលចិត្តដេក ធ្វើតបៈគឺមិនដេក
ចូលចិត្តតែងខ្លួន ធ្វើតបៈគឺមិនតែងខ្លួន
ជក់បារី ធ្វើតបៈគឺមិនជក់បារី
លេងល្បែង ធ្វើតបៈគឺមិនលេង
មើលងាយគេ ធ្វើតបៈគឺមិនមើលងាយគេ
ចូលចិត្តស៊ីសំណូក ធ្វើតបៈគឺមិនស៊ីសំណូក
ចូលចិត្តស៊ីផឹកខ្ជះខ្ជាយ ធ្វើតបៈគឺឈប់ស៊ីផឹកខ្ជះខ្ជាយ
ចូលចិត្តឃើញតែប្រយោជន៍ខ្លួន ធ្វើតបៈគឺឈប់ឃើញតែប្រយោជន៍ខ្លួននិងបក្សពួក

ដូច្នេះ តបៈព្រះឥសី គឺការដែលអ្នកដឹកនាំត្រូវព្យាយាមហ្វឹកហាត់ខ្លួន ទប់ចិត្ត លះបង់នូវអ្វីមិនល្អដែលអាក្រក់ ដែលជាទម្លាប់មិនសមគួរឲ្យអស់ចេញពីក្នុងខ្លួន។

នៅក្នុងព្រះពុទ្ធសាសនា មានការដុតបំផ្លាញនូវកិលេស ១៦យ៉ាងដែលត្រូវដុតឲ្យអស់ ឬឲ្យនៅសល់តិចតួចបំផុត ឈ្មោះថាជាការបំពេញតបៈព្រះឥសីយ៉ាងប្រសើរ។ សូម្បីតែអ្នកដឹកនាំ មិនមែនជាព្រះឥសី តែក៏គប្បីដុតកម្ទេចនូវកិលេស ទាំង១៦ នេះឲ្យអស់ ឬឲ្យធូរស្រាលពីសន្ដានចិត្តរបស់ខ្លួនគឺៈ

| **ឈ្មោះកិលេស** | **តបៈដែលត្រូវលះបង់** |
|---|---|
| ១. អភិជ្ឈាវិសមលោភៈ | ឈប់គិតប្រាថ្នាចង់តែលោភលន់មិនសមគួរ |
| ២. ព្យាបាទៈ | ឈប់គិតព្យាបាទគេ |
| ៣. ទោសៈ | ឈប់ប្រទូស្តរាយគេ |
| ៤.ឧបនាហៈ | ឈប់ចងគំនុំគេ |
| ៥. មក្ខៈ | ឈប់លុបគុណបុណ្យ មួលបង្កាច់អំពើល្អរបស់គេ |
| ៦. បលាសៈ | ឈប់អង្គុយលើចង្កេះលើកខ្លួនឯង |
| ៧. ឥស្សា | ឈប់ច្រណែនឈ្នានីស |

៨. មច្ឆរិយៈ ឈប់កំណាញ់ម៉ៅស្វិតឃើញតែប្រយោជន៍ខ្លួន
៩. មាយា ឈប់មាយាលាក់ពុតកំហូច
១០. សាថេយ្យៈ ឈប់កុហកគេដោយពាក្យអួត
១១. ថម្ភៈ ឈប់ក្បាលរឹង រឹងរូស
១២. សារម្ភៈ ឈប់ប្រគួតប្រជែងក្នុងន័យបំផ្លាញ គិតតែពីចង់ឈ្នះ
១៣. មានៈ ឈប់ប្រកាន់ខ្លួនឬកខ្ពស់
១៤. អតិមានៈ ឈប់គិតថាមានតែខ្លួនឯងខ្លាំង ហើយប្រមាថមើលងាយគេ
១៥. មទៈ ឈប់ស្រវឹងស្រី ស្រា ល្បែង យស អំណាច បុណ្យសក្តិ លាភ
១៦. បមាទៈ ឈប់ប្រមាទ ធ្វេសប្រហែសខ្ជីខ្ជា។

ជាសរុបអ្នកដឹកនាំទាំងឡាយ ត្រូវរៀនចម្រើនតបៈ គឺត្រូវដុតកម្តៅជនអាក្រក់ និងអំពើអាក្រក់ដែលមាននៅក្នុងសង្គមខ្លួនឲ្យអស់ នឹងមិនត្រូវភ្លេចទេថា យើងជាអ្នកដឹកនាំ ក៏ត្រូវដុតចោលនូវសេចក្តីអាក្រក់ និងអំពើអាក្រក់ដែលយើងមានឲ្យអស់ទៅដែរ។ កាលណាតបៈរបស់យើងកើតមានច្រើនហើយ ពេលនោះឯងដែលមហាជននឹងស្រែកអប់អរសាទរឲ្យពរថា **«ពេញចិត្ត ពេញចិត្តហើយជាមិនខាន»**។

**៦.១.៨. អក្កោធៈ**

(ត្រូវការពារខ្លួនឲ្យបានចំពោះព្រឹត្តិការណ៍ កុំឲ្យចិត្តក្រេវក្រោធខុសទំនង)

**អក្កោធៈ គឺការមិនក្រេវក្រោធ**

**១. ន ហិ សាធុ កោធោ** សេចក្តីក្រោធមិនល្អសោះឡើយ។
**២. កោធោ សត្ថមលំ លោកេ** សេចក្តីក្រោធទុកដូចជាច្រេះរបស់អាវុធក្នុងលោក។
**៣. អនត្ថជននោ កោធោ** សេចក្តីក្រោធនាំទៅរកសេចក្តីវិនាស។
**៤. កោធោ ចិត្តបកោបនោ** សេចក្តីក្រោធធ្វើឲ្យចិត្តមិនសម្រាក។
**៥. មកោធោ ទុម្មេធគោចរោ** សេចក្តីក្រោធជាលក្ខណៈរបស់មនុស្សពាល។
**៦. នត្ថិ ទោស សមោ គហោ** គ្មានការចាប់ចងឯណាស្មើនិងទោសៈទេ។
**៧. នត្ថិ ទោស សមោ កលិ** គ្មានកំហុសស្មើនិងទោសទេ។
**៨. ហន្តិកុទ្ធោ សមាតរំ** ជនដែលក្រោធ សូម្បីតែម្តាយខ្លួន ក៏ហ៊ានសម្លាប់ដែរ។
**៩. កុទ្ធោ អត្ថំ នជានាតិ** ជនដែលក្រោធរមែងមិនបាននូវផលទាំងឡាយ។
**១០. កុទ្ធោ ធម្មំ ន បស្សតិ** អ្នកក្រោធរមែងមិនឃើញនូវហេតុទាំងឡាយ។
**១១. ទុក្ខំ សយតិ កោធនោ** មនុស្សក្រោធតែងដេកកើតទុក្ខជានិច្ច។
**១២. អថោ អត្ថំ គហេត្វាន អនត្ថំ បដិបជ្ជតិ** អ្នកដែលមានសេចក្តីក្រោធចូលលុកលុយហើយ តែងបំផ្លាញនូវផលប្រយោជន៍ដែលខ្លួនមាន។

ទាំងអស់នេះ គឺជាពុទ្ធភាសិតខ្លះ ក្នុងចំណោមពុទ្ធភាសិតដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បានសម្តែង អំពីទោសនៃសេចក្តីក្រោធ។

**លក្ខណៈរបស់សេចក្តីក្រោធ**

មុននឹងមិនក្រោធ សូមធ្វើការស្គាល់នូវសេចក្តីក្រោធជាមុនសិន ថាតើមានលក្ខណៈយ៉ាងណា?

ក្រោធគឺជាអាការៈរបស់ចិត្តដែលក្តៅធ្លលឆេះ ក្រវល់ក្រវាយ អន្ទះអន្ទែង ពុះកញ្ជ្រោល ។

ការដែលក្តៅធ្លលឆេះមកពី ព្យាបាទៈ ការចងគំនុំសងសឹក ទោសៈ ការគិតប្រទូសរ៉ាយ កោធៈ ការក្តៅពុះកញ្ជ្រោល បដិឃៈ ការទាស់ចិត្ត ថ្នាំងថ្នាក់ចិត្ត អរតិ ការមិនពេញចិត្ត។

សេចក្តីក្រោធទាំងនេះបើកើតឡើងចំពោះមនុស្សធម្មតា មិនសូវជាបង្ករឿងប៉ុន្មានទេ តែបើកើតឡើងចំពោះអ្នកដឹកនាំប្រាកដជាមានគ្រោះអន្តរាយជាខ្លាំង។ ដូច្នេះការរម្ងាប់សេចក្តីក្រោធ ចាប់តាំងពីអរតិគឺការមិនពេញចិត្តមកទើបជាការសំខាន់សម្រាប់អ្នកប្រមុខដឹកនាំ។

**ការមិនក្រោធ**

អក្កោធៈ គឺការមិនក្រោធនូវក្នុងគោលធម៌ទី៧នេះ គឺអ្នកដឹកនាំ ត្រូវដឹងថា សេចក្តីក្រោធឆាប់ឆាបភ្លើងជាងអ្នកក្រោមអំណាច បើប្រៀបទៅនិងប្រេងឥន្ទនៈ សេចក្តីក្រោធរបស់អ្នកតូច គឺប្រៀបដូចជា ប្រេងកាត ឯសេចក្តីក្រោធរបស់អ្នកធំគឺដូចជាប្រេងសាំង ឬហ្គាសដែរ។ ដូច្នេះចូរប្រយ័ត្នកំដាក់នៅកៀនភ្លើងពេក ឬការពារកំឲ្យភ្លើងចូលមកជិត ឬបើជាចូលមកហើយ ត្រូវរកមធ្យោបាយពន្លត់ភ្លើងឲ្យបានមួយរំពេច កុំឲ្យឆាបរាលដាលទាន់។

ក្នុងការរំលត់ភ្លើងក្រោធ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា យោ វេ ឧបតិតំ កោធំ រថំ ភនតំ វធ យេតមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ អ្នកណាអាចរម្ងាប់សេចក្តីក្រោធដែលកើតឡើងបាន ភ្លាមមួយរំពេច ដូចអ្នកបើកបររថ បញ្ឈប់រថដែលកំពុងរត់ទៅមុខយ៉ាងលឿនបានភ្លាមមួយរំពេចនោះ អ្នកនោះតថាគតហៅថា ជានាយសារថី ឬអ្នកបើកបរ ចំណែកអ្នកក្រៅពីនោះ ឬអ្នកបញ្ឈប់មិនបានភ្លាម តថាគតហៅថា ត្រឹមតែជាអ្នកកាន់ខ្សែ ឬចង្កូតតែប៉ុណ្ណោះ។

ព្រះពុទ្ធវចនៈនេះ ព្រះពុទ្ធប្រៀបអ្នកដឹកនាំ ក្រុម សង្គម ប្រទេស រដ្ឋ ដូចជាអ្នកបររថ មានទីគ្រប់គ្រងរថដែលកំពុងធ្វើដំណើរពីកន្លែងមួយទៅមួយ ពីតំបន់មួយទៅតំបន់មួយប្រកបដោយសុវត្ថិភាព។ ចំណែកអ្នកតូច ដែលស្ថិតនៅក្រោមការគ្រប់គ្រង ដូចជាអ្នកដែលជិះដោយសារនៅក្នុងរថ។

**របៀបបញ្ឈប់សេចក្តីក្រោធ**

ការបញ្ឈប់សេចក្តីក្រោធ មិនមែនជារឿងងាយៗទេ តែក៏មិនពិបាករហូតដល់ទៅរម្ងាប់ភ្លើងក្រោធមិនបាននោះដែរ។ សំខាន់គឺនូវត្រង់ថា យើងឈប់ក្រោធ ឬកំណត់ដឹងនូវសេចក្តីក្រោធឲ្យបានច្បាស់លាស់នៅក្នុងចិត្ត ថា សេចក្តីក្រោធកើតឡើងហើយៗ ព្យាយាមលះសេចក្តីក្រោធចេញ និងកំណត់ឲ្យបានជាក់លាក់ថាសេចក្តីក្រោធវាកើតឡើងអំពីអ្វី ហើយវានាំយើងទៅណា ចម្លើយគឺទៅរកកន្លែងវិនាសតែម្យ៉ាងគត់ គ្មានទេសេចក្តីចម្រើន គ្មានទេភាពថ្កុំថ្កើង និងសន្តិភាព នៅពេលឃើញផលរបស់ក្រោធយ៉ាងនេះហើយក៏បញ្ឈប់វាភ្លាម ដូចជានាយសារថីកំពុងតែបររថយ៉ាងលឿនតែដល់មាត់ជ្រោះក៏បញ្ឈប់រថង៉ក់មួយរំពេច ការពាររថកុំឲ្យធ្លាក់ចូលទៅក្នុងជ្រោះ យ៉ាងណាមិញអ្នកដែលអាចទប់សេចក្តីក្រោធបាន គឺជៀសវាងផុតពីសេចក្តីវិនាសអន្តរាយដូច្នោះដែរ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា អក្កោធេន ជិនេកោធំ គប្បីឈ្នះមនុស្សក្រោធដោយការមិនក្រោធតប។ គប្បីជ្រាបថា (បុគ្គលក្រោធប្រៀបដូចជា មនុស្សឆ្កួត មនុស្សវង្វេង មនុស្សឡប់សតិ ឬឆ្កួតវង្វេងព្រោះសេចក្តីក្រោធ (កោធមត្តកោ)។

វិធីខ្លះសម្រាប់រម្ងាប់សេចក្តីក្រោធ ដែលអ្នកដឹកនាំអាចសាកល្បងបានដូចជា៖

- ត្រូវមានសម្មាទិដ្ឋិ ពិចារណាឲ្យឃើញទោសរបស់សេចក្តីក្រោធ រហូតដល់ថា សេចក្តីក្រោធមានទោសមែនពិចារណាឲ្យឃើញផលប្រយោជន៍ ដែលនឹងកើតមកអំពីការដែលមិនខឹងក្រេវក្រោធ។

ឧបាយ១២យ៉ាងសម្រាប់កំចាត់សេចក្តីក្រោធ

ឧបាយអ្វីខ្លះដែលនឹងអាចកំចាត់សេចក្តីក្រោធបានសម្រេច?

គប្បីចាំនូវឧបាយទាំងនេះទុកក្នុងចិត្តគឺ៖

១. បុគ្គលគប្បីចែករំលែកដើម្បីជាប្រយោជន៍ដល់ជនដទៃ (ដែលស្អប់ខ្លួន)។

២. បុគ្គលគប្បីគិតអំពីអំពើល្អ។

៣. បុគ្គលគប្បីគិតអំពីបំណងល្អ។

៤. បុគ្គលគប្បីគិតអំពីការដែលសត្វមានកម្មជារបស់ខ្លួន។

៥. បុគ្គលគប្បីគិតអំពីការលើកលែងចោលនូវបំណុលកម្ម។

៦. បុគ្គលគប្បីគិតអំពីការជាប់ជាសាច់ញាតិនឹងគ្នា។

៧. បុគ្គលគប្បីគិតអំពីកំហុសរបស់ខ្លួន។

៨. បុគ្គលមិនគប្បីគិតអំពីសេចក្តីទុក្ខដែលញាំញីដល់ខ្លួនឡើយ។

៩. បុគ្គលគប្បីពិនិត្យពិច័យអំពីធម្មជាតិរបស់ឥន្ទ្រីយ៍ទាំងឡាយ។

១០. បុគ្គលគប្បីពិនិត្យពិច័យអំពីការរលត់ទៅនៃសភាវៈទាំងឡាយតែមួយខណៈៗ។

១១. បុគ្គលគប្បីពិនិត្យពិច័យអំពីការរលត់ទៅនៃកងខន្ធតែមួយខណៈៗ។

១២. បុគ្គលគប្បីពិនិត្យពិច័យអំពីសុញ្ញតា។

១. បើទោះជាខឹងក្រោធយ៉ាងណាក្តី ក៏បុគ្គលគប្បីឲ្យនូវអ្វីដែលជនដទៃសុំ និងទទួលនូវអ្វីដែលជនដទៃឲ្យដោយសេចក្តីពេញចិត្ត ហើយក្នុងការនិយាយស្តីជាមួយជនដទៃនោះ បុគ្គលគប្បីប្រើពាក្យល្អៗជានិច្ចគប្បីធ្វើនូវអ្វីដែលអ្នកដទៃគេនាំគ្នាធ្វើចុះ ធ្វើដូច្នេះ សេចក្តីក្រោធរបស់បុគ្គលនឹងអ្នកដទៃនោះ នឹងវិនាសទៅជាមិនខាន។

២. បើបុគ្គលសំឡឹងនូវអំពើល្អរបស់អ្នកដទៃ គប្បីដូច្នេះថា នេះជាសេចក្តីល្អ នេះមិនមែនជាសេចក្តីអាក្រក់ទេ។

សេចក្តីឧបមាទៅនឹងស្រះទឹក៖មានស្រះមួយកន្លែងគ្របដណ្តប់ដោយស្មៅចំណីទា កាលបើបុគ្គលវែកស្មៅនោះចេញហើយក៏អាចដងទឹកនោះបាន។ បើជនដទៃនោះគ្មានសេចក្តីល្អទាល់តែសោះ បុគ្គលគប្បីផ្សាយមេត្តាឲ្យដល់ជននោះដូច្នេះ៖ " បុគ្គលនេះពុំមានសេចក្តីល្អសោះ ជននេះប្រាកដជាប្រព្រឹត្តទៅក្នុងសេចក្តីទុក្ខហើយ"។

៣. បុគ្គលគប្បីគិត (ក្នុងការទទួលបាន) នូវបំណងល្អរបស់អ្នកដទៃដូច្នេះ " បើបុគ្គលណាមួយមិនគោរពអ្នកដទៃសូមឲ្យបុគ្គលនោះកើតនូវបំណងល្អចុះ"បើជននោះមិនបានទទួលនូវសេចក្តីគោរពទេ ជននោះគប្បីធ្វើនូវអំពើល្អ ម្យ៉ាងទៀត ការរលត់ទៅនៃអកុសល គឺជាសេចក្តីសុខ។ គប្បីជ្រាបអំពីការប្តូរសេចក្តីក្រោធឲ្យទៅជាបំណងល្អយ៉ាងនេះចុះ។

៤. បុគ្គលគួរពិចារណាកម្មអាក្រក់ របស់ខ្លួនថា " អំពើអាក្រក់ដែលអាត្មាអញបានធ្វើ ប្រាកដជាធ្វើឲ្យ

សេចក្តីក្រោធកើតឡើងចំពោះអ្នកដទៃហើយ។

៥. បុគ្គលគប្បីគិតយ៉ាងនេះថា ៖ ព្រោះកម្មពីអតីត ទើបអ្នកដទៃមកតិះដៀលអាត្មាអញ ឥឡូវនេះ អាត្មាអញរួចពីបំណុលនេះហើយ បើនឹកដល់ការលើកលែងចោលនូវបំណុល បានយ៉ាងដូច្នេះ អាត្មាអញក៏មានចិត្តរីករាយ។

៧. បុគ្គលកើតឡើងនូវការគិតឃើញខ្លួនឯងថា " សេចក្តីក្រោធរបស់បុរសនោះកើតឡើងព្រោះតែអាត្មាអញ អាត្មាអញបានធ្វើបាបព្រោះតែបុរសនោះ កាលបើដាស់សតិរបស់ខ្លួនឯងយ៉ាងនេះហើយ បុគ្គលរមែងសម្លឹងឃើញនូវកំហុសរបស់ខ្លួន។

៨. បុគ្គលមិនគប្បីពិចារណាថា " សេចក្តីទុក្ខរបស់អញ ពុំមានទាក់ទងទៅនឹងសេចក្តីក្រោធនោះទេ បុគ្គលគប្បីពិចារណាទុក្ខដូច្នេះថា "ព្រោះតែសេចក្តីល្ងង់ខ្លៅ ទើបអាត្មាអញឃើញទុក្ខរបស់ខ្លួនថាជានីវរណៈ" បុគ្គលគួរពិចារណាយ៉ាងនេះការដែលបុគ្គលសោយទុក្ខដោយខ្លួនឯងព្រោះតែមានចិត្តមិនចិត្តមិនប្រកបដោយមេត្តា។ ការដែលប្រាកដឡើងដូច្នេះ (ឌ. ដែលជានីវរណធម៌) ក៏ព្រោះតែវាជាសេចក្តីទុក្ខខាងផ្លូវចិត្ត។ បុគ្គលគួរចៀសវាងកន្លែងណាដែលសត្រូវអាស្រ័យនៅ ហើយគួរអាស្រ័យនៅកន្លែងណាដែលនឹងមិនបានឮសំឡេងរបស់សត្រូវ ឬសម្លឹងឃើញនូវកំហុសនូវកំហុសរបស់ខ្លួន។

៩. បុគ្គលគប្បីពិនិត្យពិច័យយ៉ាងនេះថា ៖ " ការជួបប្រសប់ជាមួយនឹងវត្ថុដែលជាទីស្រឡាញ់និងវត្ថុដែលពុំមែនជាទីស្រឡាញ់នោះ គឺជាធម្មជាតិរបស់ឥន្ទ្រីយ៍ទាំងឡាយ" ព្រោះហេតុនេះហើយ ទើបបានជាអាត្មាអញស្អប់ព្រោះហេតុនេះហើយទើបអាត្មាអញរលត់សតិ។

១០. បុគ្គលគប្បីពិនិត្យពិច័យយ៉ាងនេះថា ៖ " បុរសនោះកើតទុក្ខព្រោះតែមានជាតិកំណើតសភាវៈទាំងអស់នេះ រលត់ទៅវិញតែក្នុងមួយខណៈចិត្តតែប៉ុណ្ណោះ" តើសភាវៈណាមួយក្នុងរបស់ជននោះ ដែលអាត្មាអញខឹងហ្នឹង?

១១. បុគ្គលគប្បីពិនិត្យពិច័យយ៉ាងនេះថា៖ " គឺខន្ធខាងក្នុង និងខន្ធខាងក្រៅនេះទេ ដែលធ្វើឲ្យកើតទុក្ខអាត្មាអញមិនអាចមានសេចក្តីក្រោធចំពោះចំណែកណា ឬកន្លែងណាមួយបានទេ"។

១២. បុគ្គលគប្បីពិនិត្យពិច័យយ៉ាងនេះថា ៖ " ក្នុងន័យដែលពិតមែនទែននោះ គេមិនអាចនិយាយបានថា " បុរសនេះបណ្តាលឲ្យសេចក្តីទុក្ខកើតឡើង " ឬ "បុរសនេះមានសេចក្តីទុក្ខ" ទេ។ កាយនេះជាផលនៃហេតុ និងបច្ច័យទាំងឡាយគឺពុំមានអត្តានៅក្នុងខន្ធទាំងឡាយទេ។

ព្រោះហេតុនេះទើបព្រះដ៏មានព្រះទ្រង់ត្រាស់នូវគាថានេះថា៖

" បុគ្គលរស់នៅក្នុងឱទ្យានជិតស្ថានភូមិស្រុក តែប្រសប់សុខនឹងទុក្ខគ្រប់វេលា បុគ្គលនោះមិនដែលក្តៅក្រហាយ ព្រោះដោយសារតែជនដទៃ ឬព្រោះតែអាត្មាខ្លួនទេ តែពីព្រោះតែចិត្តរបស់បុគ្គលនោះមានតណ្ហា បើចិត្តបុគ្គលនោះស្អាតល្អប្រាសចាកនូវមន្ទិលនៃតណ្ហាហើយ តើនឹងមានជនណាអាចទៅប៉ះជនដែលជាអ្នកពុំមានមន្ទិលនោះ?[30]។

ឥឡូវងាកមកឈ្វេងយល់អំពីបុគ្គលអ្នកដែលមាន សេចក្តីក្រោធ ចងអាឃាត ចង់ពៀរនឹងគ្នានោះម្តង

---

[30] ហេង មណីចិន្តា គម្ពីរវិមុត្តិមគ្គ ព.ស ២៥៥៤ ទំព័រ ១៩៩

បុគ្គលប្រភេទនេះ មានលក្ខណៈសម្គាល់៩យ៉ាង ដែលជាហេតុជាទីតាំងនៃអាឃាតគឺៈ

១ - អ្នកនេះ បានប្រព្រឹត្តសេចក្តីវិនាសឲ្យដល់អញហើយ

២ - អ្នកនេះ កំពុងតែប្រព្រឹត្តសេចក្តីវិនាសឲ្យដល់អញហើយ

៣ - អ្នកនេះ នឹងប្រព្រឹត្តសេចក្តីវិនាសឲ្យដល់អញ

៤ - អ្នកនេះ បានប្រព្រឹត្តសេចក្តីវិនាស ឲ្យដល់មនុស្សទីស្រឡាញ់ពេញចិត្តរបស់អញរួចហើយ

៥ - អ្នកនេះ កំពុងតែប្រព្រឹត្តសេចក្តីវិនាស ឲ្យដល់មនុស្សទីស្រឡាញ់ពេញចិត្តរបស់អញ

៦ - អ្នកនេះ នឹងប្រព្រឹត្តសេចក្តីវិនាស ឲ្យដល់មនុស្សជាទីស្រឡាញ់ជាទីពេញចិត្តរបស់អញ

៧ - អ្នកនេះ បានប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនជាទីស្រឡាញ់ពេញចិត្តរបស់អញរួចហើយ

៨ - អ្នកនេះ កំពុងប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនទីស្រឡាញ់ពេញចិត្តរបស់អញ

៩ - អ្នកនេះ នឹងប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនជាទីស្រឡាញ់ពេញចិត្តរបស់អញ។

បុគ្គលអ្នកចងអាឃាត ដោយអាឃាតវត្ថុ៩ប្រការនេះ នឹងជាបច្ច័យឲ្យវិនាសយ៉ាងជាក់ប្រាកដ។

បុគ្គលអ្នកចងអាឃាតគេនោះ ព្រោះអាស្រ័យវត្ថុ៩ប្រការ ដូចពណ៌មកខាងដើម ហេតុនោះ អ្នកប្រាជ្ញគួររកឧបាយដើម្បីហាមឃាត់ចិត្ត ដោយខន្តីបានតែម្តងបន្តិចៗ ក៏ប្រសើរណាស់ហើយ។ ម្យ៉ាងទៀត ឧបាយដែលនឹងបន្ទោបង់ចោលនូវអាឃាតព្យាបាទនោះ មាន៩ប្រការដូចគ្នាដែរៈ

១ - អ្នកនេះ បានប្រព្រឹត្តសេចក្តីវិនាសឲ្យដល់អញហើយ នឹងងគប្បីបានអំពីណា (គឺថាធ្វើឲ្យអញវិនាសមិនកើតទេ)។

២ - អ្នកនេះ កំពុងតែប្រព្រឹត្តសេចក្តីវិនាសឲ្យដល់អញហើយ នឹងគប្បីបានអំពីទីណា។

៣ - អ្នកនេះ នឹងប្រព្រឹត្តសេចក្តីវិនាសឲ្យដល់អញ នឹងគប្បីបានអំពីទីណា។

៤ - អ្នកនេះ បានប្រព្រឹត្តសេចក្តីវិនាស ឲ្យដល់មនុស្សទីស្រឡាញ់ពេញចិត្តរបស់អញរួចហើយ នឹងគប្បីបានអំពីទីណា។

៥ - អ្នកនេះ កំពុងតែប្រព្រឹត្តសេចក្តីវិនាស ឲ្យដល់មនុស្សទីស្រឡាញ់ពេញចិត្តរបស់អញ នឹងគប្បីបានអំពីទីណា។

៦ - អ្នកនេះ នឹងប្រព្រឹត្តសេចក្តីវិនាស ឲ្យដល់មនុស្សជាទីស្រឡាញ់ជាទីពេញចិត្តរបស់អញ នឹងគប្បីបានអំពីទីណា។

៧ - អ្នកនេះ បានប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនជាទីស្រឡាញ់ពេញចិត្តរបស់អញរួចហើយ នឹងគប្បីបានអំពីទីណា។

៨ - អ្នកនេះ កំពុងប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនទីស្រឡាញ់ពេញចិត្តរបស់អញ នឹងគប្បីបានអំពីអំពីទីណា។

៩ - អ្នកនេះ នឹងប្រព្រឹត្តប្រយោជន៍ ឲ្យដល់មនុស្សមិនជាទីស្រឡាញ់ពេញចិត្តរបស់អញ នឹងគប្បី

បានអំពីទីណា។

បន្ទាបង់អាឃាដបានហើយ ក៏នឹងលះបង់នូវពៀរវេរាព្យាបាទបាន[31]។

### ៦.១.៩. ខន្តិ

(ត្រូវតែបណ្ដុះចិត្តអំណត់ អត់ធ្មត់ ទប់ស្កាត់សេចក្ដីក្រោធ ធ្វើសេចក្ដីអភ័យ)

ខន្តី គឺការអត់ធន់

ខន្តី តាមតួអក្សរ នៃភាសាបាលី ប្រែថាការអត់ធន់ ឬការសមគួរនឹងទទួលផល។

ជាទូទៅ យើងប្រើពាក្យថា ខន្តី តែត្រឹមការអត់ធន់ទេ តែនៅក្នុងព្រះត្រៃបិដក លោកប្រែថា សមគួរនឹងទទួលផល ដូចដែលនៅក្នុងការប្រតិបត្តិធម៌ រៀបនឹងបានសម្រេចមគ្គផលនិព្វាននោះ ក៏លោកប្រើពាក្យខន្តីដែរគឺសមគួរនឹងសម្រេចក្រោយពីអត់ធន់ជាយូរមកហើយ។ ពាក្យខន្តីមានន័យរួមទាំងសកម្មភាពដែលត្រូវអត់ធន់ផង និងផលនៃការអត់ធន់ផង បន្ទាប់ពីអត់ធនដល់កម្រិតមួយហើយ ផលដែលបានមក ក៏សមគួរទៅនឹងសេចក្ដីព្យាយាមដែលបានអត់ធន់មកដែរ។

ហេតុដែលចំបាច់ត្រូវអត់ធន់ នៅក្នុងរាងកាយរបស់មនុស្សយើងនេះ ក្រៅពីមានផ្នែកត្រចៀក អវយវៈដែលយើងអាចមើលឃើញនេះ នៅមានរបស់សំខាន់ទៀតដែលយើងមើលមិនឃើញ គឺកម្លាំង។ កម្លាំងនេះយើងត្រូវអាស្រ័យពឹងពាក់តាំងពីនៅតូច ព្រោះបើគ្មានកម្លាំងយើងមិនអាចធ្វើអ្វីបានទេ យ៉ាងហោចណាស់ត្រូវមានកម្លាំងសម្រាប់ដកដង្ហើម និងទទួលទានអាហារដែរ (កម្លាំងកាយ)។

ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងសរសើរនូវខន្តីធម៌យ៉ាងទូលំទូលាយៈ

ខន្តី បរមំ តបោតីតិក្ខា សេចក្ដីអត់ធន់គឺជាតបៈធម៌ដ៏ឧត្តម។

សីលសមាធិគុណានំ ខន្តី បធានការណំ សេចក្ដីអត់ធន់ជាហេតុជាទីតាំងនៃគុណគឺសីល និងសមាធិទាំងឡាយ។

សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិតេ ធម៌ទាំងឡាយជាកុសល ទាំងអស់នោះតែងចម្រើនដោយសេចក្ដីអត់ធន់មែនពិត។

កេវលានំ បិ បាបាណំ ខន្តិ មូលំ និកន្តតិ សេចក្ដីអត់ធន់ តែងកាត់បង់នូវឫសនៃបាបទាំងឡាយ។

គរហកលហាទីនំ មូលំ ខណតិ ខន្តិកោ បុគ្គលអ្នកអត់ធន់ ឈ្មោះថាជីករំលើងនូវទោសទាំងឡាយមានពាក្យតិះដៀល និងការឈ្លោះប្រកែកជាដើម។

ខន្តិ ធីរស្ស លង្ការោ ខន្តិ តបោ តបស្សិនោ សេចក្ដីអត់ធន់ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្ដីអត់ធន់ជាគ្រឿងដុតបង់នូវបាបធម៌របស់អ្នកដែលមានតបៈធម៌។

ខន្តិ ពលំ វយតីនំ ខន្តិ ហិតសុខាវហោ សេចក្ដីអត់ធន់ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ ជាគុណជាតិ នាំមកនូវប្រយោជន៍ និងសេចក្ដីសុខ។

ខន្តិកោ មេតវា លាភី យសស្សី សុខ សីលវា អ្នកអត់ធន់ជាអ្នកមានមិត្តសម្លាញ់ មានលាភ មានយស មានសេចក្ដីសុខជាប្រក្រតី។

---

[31] កម្ពុជាសុរិយា ភាគ៣២/១ គ.ស ១៩៦០ ទំព័រ ៦១៨

អ្នកដែលអត់ធន់ នឹងបានមិត្តសម្លាញ់ អ្នកដែលអត់ធន់នឹងបានលាភ អ្នកដែលអត់ធន់នឹងបានយស អ្នកដែលអត់ធន់នឹងបានសេចក្តីសុខ មនុស្ស និងទេវតាតែងស្រឡាញ់អ្នកមានខន្តី។

អ្នកដែលអត់ធន់ ឈ្មោះថាជាអ្នកបានធ្វើប្រយោជន៍ឲ្យដល់ខ្លួនឯងផង ឲ្យដល់សង្គមផង អ្នកអត់ធន់ ឈ្មោះថា បានឡើងលើផ្លូវដែលធ្វើដំណើរទៅកាន់ស្ថានសួគ៌ ព្រះនិព្វាន។

អ្នកណាអត់ធន់ អ្នកនោះឈ្មោះថា បានធ្វើតាមឱវាទព្រះសម្មាសម្ពុទ្ធ។ បណ្តាការបូជាទាំងឡាយ ការបូជាដោយការអត់ធន់ ឈ្មោះថាជាការបូជាដ៏ឧត្តមបំផុត។

## ៦.១.១០. អវិហឹសា

(ត្រូវបណ្តុះចិត្តមេត្តា កុំបង្កជម្លោះ របួសស្នាម ឬហិង្សាផ្សេងៗក្នុងតំណែង)

អវិហិង្សា គឺការមិនបៀតបៀនអ្នកដទៃ

អវិហិង្សា ប្រែថា ការមិនបៀតបៀន គឺក្លែងធ្វើឲ្យគេក្តៅក្រហាយ រងទុក្ខរាល់ទង្វើទាំងឡាយ ដោយតាមរយៈផ្លូវកាយ ផ្លូវវាចា ផ្លូវចិត្តដែលជាសកម្មភាពប្រចាំថ្ងៃខ្លួនម្នាក់ៗ។

គោលបំណងរបស់រាជធម៌ ចំណុចនេះ គឺឲ្យអ្នកជាប្រមុខដឹកនាំទាំងឡាយ វៀរចាកប្រើអំណាចតួនាទីរបស់ខ្លួន ក្នុងផ្លូវដែលមិនត្រឹមត្រូវ ដូចជាជិះជាន់ ការគំរាមកំហែងអ្នកដែលនៅក្រោមអំណាចនាទីរបស់ខ្លួនពលរដ្ឋខ្លួន ឲ្យទុក្ខវេទនា ក្តៅក្រហាយ ព្រោះតែដើម្បីប្រយោជន៍ខ្លួន សេចក្តីសុខរបស់ខ្លួន ឬបក្សពួកខ្លួន។

មានពាក្យ ១ទៀតស្មើ និងពាក្យអវិហឹង្សាដែរ គឺពាក្យ អព្យាបជ្ឈា ដែលប្រែថា មិនបៀតបៀន មិនព្យាបាទដូចគ្នា។

ផលប្រយោជន៍របស់ការមិនបៀតបៀន ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា អព្យាបជ្ឈំ សុខំ លោកេ មានន័យថា ការមិនបៀតបៀនគ្នា គឺជាសេចក្តីសុខក្នុងពិភពលោក។ បើផ្ទុយនៃពុទ្ធភាសិតនេះមកមាន ន័យថា ការបៀតបៀនគ្នាគឺជាសេចក្តីទុក្ខរបស់ពិភពលោក។ គប្បីជ្រាបថា ការមិនបៀតបៀនគ្នា និងការបៀតបៀនគ្នា គឺជាកត្តាកំណត់នូវជោគវាសនារបស់ពិភពលោក ពិភពលោកនឹងមានភាពស្ងប់ស្ងាត់សន្តិភាព ឬក៏កើតសង្គ្រាមវិនាសហិនហោច ក៏ព្រោះអាស្រ័យការបៀតបៀនគ្នា និងការមិនបៀតបៀនគ្នានេះ ឯង។

ព្រះពុទ្ធទ្រង់សរសើរនូវការមិនបៀតបៀនគ្នាថាៈ

អបិ ចេ បត្តមាទាយ អនាគារំ បរិព្វចេ អញ្ញំ អហិង្សយំ លោកេ អបិ រជ្ជេន តំ វរំ។

ថ្វីត្បិតតែដៃកាន់អម្បែងដើរសុំទានគេថ្វីត្បិតតែគ្មានផ្ទះសម្បែង ដើរត្រាចគ្រប់ទីកន្លែងយ៉ាងណាក្តី តែមិនបៀតបៀនអ្នកណានៅក្នុងលោកឡើយប្រការនេះប្រសើជាងការនៅគ្រប់គ្រងរាជសម្បត្តិទៅទៀត។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ឲ្យតម្លៃទៅលើការមិនបៀតបៀនគ្នានេះថា មានតម្លៃប្រសើរជាងការនៅគ្រប់គ្រងរាជសម្បត្តិ ការគ្រប់គ្រងប្រទេសទៅទៀត ឬអាចនិយាយបានថា ក្នុងលោកនេះ ក្នុងប្រទេសនេះ មិនបាច់មានការគ្រប់គ្រងក៏បានដែរ បើសិនជាមិនមានការបៀតបៀនគ្នា មិនមានការជិះជាន់គ្នា មិនមានការគំរាមកំហែងគ្នា មិនមានការលួច ឆក់ ប្លន់ទេនោះ។ ពោលគឺអ្នកដឹកនាំ មិនបៀតបៀនរាស្ត្រ រាស្ត្រមិនបៀតបៀនអ្នកដឹកនាំមានសេចក្តីសន្តោសចំពោះគ្នាទៅវិញទៅមក នោះការគ្រប់គ្រង គឺពិតជាល្អប្រសើរបំផុតនៅក្នុងលោកនេះ។ តែបើការគ្រប់គ្រងណាដែលមានការបៀតបៀន អ្នកដឹកនាំណាដែលមានការបៀតបៀនក្នុងការគ្រប់គ្រង អ្នកដឹកនាំនោះមានតម្លៃមិនស្មើរ និងអ្នកសុំទានឡើយ (ដែលគ្មានផ្ទះសម្បែងទ្រព្យសម្បត្តិ តែមិនបានបៀតបៀន

នរណាឲ្យក្តៅក្រហាយឈឺចាប់ វិនាសកម្មណាមួយ ឡើយ។

ប្រភពនៃការបៀតបៀនមានវត្ថុ១០ប្រការគឺៈ

១. បាណាតិបាតៈ ការបៀតបៀន ការកាប់សម្លាប់ ការធ្វើទារុណកម្មអមនុស្សធម៌គ្មានគុណធម៌។

២. អទិន្នាទានៈ បៀតបៀន លួច រឹបអូសទ្រព្យសម្បត្តិអ្នកដ៏ទៃ ទាំងអចលនវត្ថុ និងចលនវត្ថុ។

៣. កាមេសុមិច្ឆារៈ ការបៀតបៀនក្រុមគ្រួសារដោយការលួចសាហាយស្មន់ ប្តី ប្រពន្ធអ្នកដទៃ។

៤. មុសាវាទៈ បៀតបៀនខាងផ្លូវចិត្ត បានដល់ពាក្យភូតភរកុហក នាំឲ្យខូចប្រយោជន៍អ្នកដទៃ។

៥. ផរុសវាទៈ បៀតបៀនសេចក្តីស្ងប់សុខកិត្តិយសអ្នកដទៃ ដោយការជេរប្រទេចពាក្យអាក្រក់។

៦. បិសុណាវាទៈ បៀតបៀនការសាមគ្គី ការស្រឡាញ់រាប់អាន ភាពសុខស្រួល ដោយសម្តីញុះញង់ ចាក់ដោត អុចអាល ផ្ទឹះផ្ទៀល ធ្វើឲ្យខូចការងារ ខូចមិត្តភាព ខូចសាមគ្គីភាពរបស់អ្នកដទៃ។

៧. សម្ផប្បលាបៈ បៀតបៀនសេចក្តីចម្រើន ដោយការធ្វើឲ្យខូចកិត្តិយស ដោយការមួលបង្កាច់នៃសម្តីណាមួយ ធ្វើឲ្យគេបាត់បង់តម្លៃ និងសេចក្តីថ្លៃថ្នូរក្នុងសង្គម។

៨. អភិជ្ឈាៈ បៀតបៀនផលប្រយោជន៍ គឺសម្តែងចិត្តឲ្យគេឃើញថា ជាមនុស្សច្រណែន ជាមនុស្សល្មោភ ជាមនុស្សមិនចេះឆ្អែត គិតតែចង់បានប្រយោជន៍សម្រាប់ខ្លួនឯង។

៩. ព្យាបាទៈ បៀតបៀនសន្តិសុខ ដោយចិត្តឃោរឃៅ ចងអាឃាតចង់ឲ្យអ្នកដទៃវិនាស។

១០. មិច្ឆាទិដ្ឋិៈ បៀតបៀនដោយសទ្ធា គឺពន្យល់ប្រាប់ផ្លូវឲ្យគេធ្វើខុសឲ្យគេយល់ខុស។ បុគ្គលជាប្រមុខដឹកនាំត្រូវវៀរបង់ឲ្យឆ្ងាយ នូវវត្ថុទាំងឡាយខាងលើនេះកុំឲ្យមានក្នុងសន្តានឡើយ។

### ៦.១.១១. អវិរោធនៈ

(ត្រូវគោរពច្បាប់ យកច្បាប់ជាធំ មិនត្រូវប្រើអំណាច ធ្វើខ្លួនជាគំរូ)

**អវិរោធនៈ គឺការធ្វើអ្វីមិនឲ្យខុស**

នេះគឺជាគុណធម៌ចុងក្រោយ នៅក្នុងទសពិធរាជធម៌របស់ព្រះរាជា អ្នកប្រមុខដឹកនាំ គឺអវិរោធនៈ ដែលមានន័យថា ការមិនមានកំហុស ការធ្វើអ្វីកុំឲ្យខុស ការធ្វើអ្វីប្រកបដោយសតិសម្បជញ្ញៈ។

ចំណុចស្វែងយល់ អ្នកធំ អ្នកដឹកនាំ ប្រមុខ ព្រះរាជា ប្រធាន នាយក មិនត្រូវធ្វើខុសឡើយ ព្រោះបើធ្វើខុស មហាជនដែលនៅពីក្រោយ នៅពីក្រោម ដែលផ្ញើវាសនាលើខ្លួនជាអ្នកកាច់ចង្កូត ប្រាកដជានឹងធ្វើខុសតាមនឹងប្រាកដជាទទួលផលអាក្រក់ ព្រោះការធ្វើខុសរបស់អ្នកដឹកនាំជាមិនខាន។

អវិរោធៈ ជាធម្មសមោធាន គឺរួមនូវទសពិធរាជធម៌ទាំងអស់ រួមនូវគុណសម្បត្តិ គុណភាព សុខភាព និងគុណធម៌របស់អ្នកដឹកនាំដែលគួរមាន។

ពាក្យថា អវិរោធៈ ស្មើនឹងពាក្យថា សម្មា ដែលជាក្បាលរបស់អរិយមគ្គទាំង៨ និងជាផ្លូវតែមួយគត់ឆ្ពោះទៅរកការរំលត់ទុក្ខ ការអស់បញ្ហាទាំងពួង។

បដិបត្តិគោលធម៌អវិរោធៈនេះបាន ឈ្មោះថាបដិបត្តិតាមពុទ្ធវចនៈទាំងអស់ៈ

១. យល់មិនឲ្យខុស

២. គិតមិនឲ្យខុស

៣. និយាយមិនឲ្យខុស

៤. ធ្វើការមិនឲ្យខុស

៥. ចិញ្ចឹមជីវិតមិនឲ្យខុស

៦. ព្យាយាមមិនឲ្យខុស

៧. រឭកឃើញមិនឲ្យខុស

៨. ការតម្កល់ចិត្តមិនឲ្យខុស

កាលណាធ្វើមិនឲ្យខុសទាំង៨យ៉ាងនេះហើយ ឈ្មោះថា មានសម្មាមគ្គ គឺបានដើរលើផ្លូវដែលត្រូវដែលនឹងនាំទៅរក សម្មត្តៈ = ភាវៈដែលត្រូវ២ប្រការ ជាផលដែលកើតពីការមិនធ្វើខុសគឺៈ

-សម្មាញាណៈ ដឹងត្រូវ

-សម្មាវិមុត្តិ ការរួចផុតពីទុក្ខពីបញ្ហាទាំងពួងដោយត្រូវសម្មាវិមុត្តិ គឺការរួចផុតពីសេចក្ដីទុក្ខការផុតបញ្ហា ភាវៈគ្មានបញ្ហា គ្មានអ្វីរុកគួន មានឥស្សរភាព មានសេចក្ដីសុខដ៏បរិបូណ៌ ទាំងអស់កើតឡើងដោយការធ្វើ មិនឲ្យខុសក្នុងមគ្គទាំង៨។

ផលប្រយោជន៍របស់អវិរោធៈ

រឿងដែលសំខាន់បំផុត ចំពោះគោលធម៌អវិរោធៈនេះគឺចង់ឲ្យអ្នកដឹកនាំទាំងឡាយ មានការយល់ត្រូវថា អវិរោធៈនេះមានការចំបាច់ណាស់សម្រាប់គ្រប់គ្រង ហើយត្រូវមានសតិ សម្បជញ្ញៈឲ្យជាប់និច្ច ដើម្បីនឹងធ្វើអវិរោធៈ ឲ្យបានច្រើនជាទីបំផុតតាមដែលអាចធ្វើទៅបាន។

បុគ្គលជាប្រមុខដឹកនាំទាំងអស់ត្រូវកំចាត់បង់ឲ្យបាននូវវិរោធៈការក្រេវក្រោធ ឬមិច្ឆាមគ្គ ការយល់ខុស ប្រាស់ចាកនូវសេចក្ដីពិតព្រមទាំងកំហុស និងផ្លូវអាក្រក់ ផ្លូវខុសទាំងឡាយចេញឲ្យអស់ពីដំណើរនយោបាយការគ្រប់គ្រងក្នុងឋានៈជាប្រមុខដឹកនាំ។

គប្បីស្វែងយល់នូវពុទ្ធភាសិតដែលព្រះបរមគ្រូបានណែនាំគឺៈ

យស្ស បាបំ កតំ កម្មំ កុសលេន បហីយតិ សោមំ លោកំ បភាសេតិ អព្ភា មុត្តោ វ ចន្ទិមា។

អ្នកណាធ្វើបាប (ធ្វើខុស ធ្វើមិនត្រូវ) ពីពេលមុនហើយឥឡូវនេះ បានលះបង់ចេញដោយការធ្វើល្អ ធ្វើត្រូវ ធ្វើមិនខុស អ្នកនោះរមែងបំភ្លឺលោកនេះឲ្យភ្លឺស្វាងបាន ដូចជាដួងព្រះចន្ទ្រា ដែលស្រឡះផុតចាកអំពីផ្ទៃពពកដូច្នោះដែរ។

ការធ្វើខុសគឺមិនជាអ្វីទេ សំខាន់គឺព្រមកែ ព្រមលះបង់កំហុសដែលខុសនោះទើបល្អប្រសើរ។

សរុបសេចក្ដីទសពិធរាជធម៌

យើងបានសិក្សារួចមកហើយ នូវអង្គទាំងឡាយរបស់ទសពិធរាជទាំង១០ ដែលជាធម៌សម្រាប់ទ្រទ្រង់នូវវិបុលភាពសង្គម និងសម្រាប់គុណភាពរបស់បុគ្គលជាប្រមុខដឹកនាំ សរុបរាជធម៌គឺៈ

១. ទានៈ បានដល់ការឲ្យ ៣ប្រការធំៗគឺ

- អាមិសទាន ការឲ្យវត្ថុមានបច្ច័យបួនជាដើម។

- ធម្មទាន ការឲ្យធម៌ ចំណេះដឹង

- អភយទាន ការអត់ឱនអធ្យាស្រ័យទោសដល់គ្នា និងគ្នា។

ទានមានសារប្រយោជន៍ណាស់ ក្នុងការបណ្ដុះនូវស្វាមីភក្តិ ភាតរភាព កតញ្ញូកតវេទី ធ្វើឲ្យអ្នកដែលបានទទួលទានអាចរហូតដល់ទៅហ៊ានលះបង់ជីវិតដើម្បីអ្នកដែលឲ្យខ្លួនធ្វើឲ្យចងមិត្តបានបានជាទីស្រឡាញ់

រាប់អានអំពីសំណាក់មហាជនទូទៅ បាននូវសេចក្ដីគោរព លែងមានសត្រូវនឹងគ្នា។

២. សីលៈ គឺការធ្វើឲ្យខ្លួនស្ថិតនៅក្នុងប្រក្រតីភាព មិនបង្កនូវសេចក្ដីក្ដៅក្រហាយដល់ខ្លួន និងអ្នកដទៃសុភាពរាបសាគោរពច្បាប់វិន័យចិញ្ចឹមជីវិតក្នុងអំពើសុចរិតរួមទាំងការប្រើប្រាស់ទ្រព្យសម្បត្តិប្រកបដោយភាពពិចារណាខ្ពស់ សីលនឹងធ្វើឲ្យចេះគោរពគ្នា ទុកចិត្តគ្នា ធ្វើឲ្យការងារស្អាតស្អំ។

៣. បរិច្ចាគៈ គឺការលះបង់ដោយពុំគិតទាមទារ ឬចង់បាននូវអ្វីមកវិញ ជាថ្នូរជាបច្ច័យឲ្យកើតនូវការគោរព ការកោតសរសើរអំពីអ្នកទទួលឡើយ។ លះបង់ទ្រព្យដើម្បីរក្សាអវយវៈ លះបង់អវយវៈដើម្បីជីវិត ជនជាបណ្ឌិតស៊ូលះបង់ទាំងទ្រព្យសម្បត្តិ ទាំងអវយវៈ ទាំងជីវិត ដើម្បីរក្សាធម៌។ សង្គមណាក៏ដោយនឹងអាចស្ថិតនៅបាន ព្រោះអាស្រ័យមនុស្សគ្រប់គ្នាចេះរំលែកបរិច្ចាគជួយគ្នាក្នុងគ្រាក្រ។

៤. អាជ្ជវៈគឺការត្រង់ការមិនវៀចក្រឡិកក្រឡុចមានមុខមានក្រោយ។ត្រង់ក្នុងមុខនាទីត្រង់ក្នុងការងារត្រង់ចំពោះវាចា ត្រង់ចំពោះបុគ្គល ចំពោះរាស្ត្រប្រជា និងត្រង់ចំពោះសេចក្ដីល្អ។ អាជ្ជវៈ ធ្វើឲ្យក្នុងរយៈពេលដែលត្រូវធ្វើដំណើរទៅរកគោលដៅខ្លីឆាប់ ព្រោះជាផ្លូវត្រង់ ព្រមទាំងអាចធ្វើឲ្យប្រជារាស្ត្រកើតការទុកចិត្តកើតការគោរព យកជាគំរូតាម មិនហ៊ានប្រព្រឹត្តផ្ដេសផ្ដាស។

៥. មទ្ទវៈ គឺការទន់ភ្លន់ មិនរឹងរូស មិនចចេស គោរពទៅតាមមតិរបស់រាស្ត្រ បត់បែនទៅតាមស្ថានការណ៍បាន ធ្វើឲ្យសង្គម ឬក្រុមសហការីកើតទស្សនៈគ្នាឯងធ្វើឲ្យមានសាមគ្គី។

៦. តបៈ គឺការដុតកម្ដៅអំពើអាក្រក់ ឬដុតកម្ដោចជនអាក្រក់ កុំឲ្យមានក្នុងខ្លួន និងសង្គម ធ្វើឲ្យជនអាក្រក់មិនហ៊ានធ្វើបាបតទៅទៀត ធ្វើឲ្យជនល្អមានចិត្តចង់ធ្វើល្អដើម្បីប្រយោជន៍រួម ធ្វើឲ្យប្រទេសជាតិមានការរួបរួមកម្លាំគ្នា មានអ្នកដឹកនាំសុទ្ធតែជាមនុស្សល្អ។

៧. អក្កោធៈ ការមិនក្រោធ មិនខឹង មិនទ្រង់ព្រះពិរោធ មិនឆេវឆាវ មិនមែនជាមនុស្សត្រចៀកសេចក្ដីក្រោធនេះជាសត្រូវរបស់អវិរោធៈ បើមិនចង់ខុសមិនត្រូវក្រោធឡើយ។ អ្នកដឹកនាំប្រទេសមិនត្រូវខឹងឡើយ ព្រោះខឹងខូច ខឹងខាត ខឹងខុស ខឹងខាន ដល់សេដ្ឋកិច្ច នយោបាយ សង្គមកិច្ច ទាហាន ព្រោះរឿងទាំងអស់នេះមិនអាចប្រើកំហឹងច្រឡោតតូងតាងបានឡើយ។ សាមគ្គី មិត្តភាព ការធ្វើឲ្យគេហ៊ានចូលជិត ការមិនស្អាយក្រោយ ជាប្រយោជន៍របស់អក្កោធៈ។

៨. អវិហឹង្សាៈ គឺការមិនបៀតបៀន ការគោរពសិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិស្ត្រី សិទ្ធិសត្វតិរច្ឆាន។ អវិហិង្សា ជាប្រភព នៃប្រជាធិបតេយ្យ ប្រភពនៃសិទ្ធិ សេរីភាព និងយុត្តិធម៌សង្គម។

៩. ខន្តីៈ គឺការអត់ធន់ អត់ធ្មត់ អត់ទ្រាំ ស៊ូទ្រាំ ទើបសមគួរធ្វើជាអ្នកដឹកនាំ សមគួរនឹងបាននូវប្រយោ-ជន៍ ដែលខ្លួនប្រាថ្នា ការអត់ធន់របស់អ្នកដឹកនាំគឺនាំមកនូវសន្តិភាពសម្រាប់ជាតិ។

១០. អវិរោធៈ ចម្រើនឲ្យជាប់ជានិច្ច គ្រប់ដង្ហើមចេញចូលថា អញនឹងមិនធ្វើខុស អញនឹងមិនធ្វើឲ្យខុសព្រោះមានតែមិនខុស ទើបត្រូវ ទើបសុខ ទើបមានសន្តិភាព ទើបចម្រើនលូតលាស់ ទើបមិនខាតខូចប្រយោជន៍ (មានតែការមិនខឹងទេ ទើបឈ្នះខឹងបាន)។

## ៦.២. ព្រហ្មវិហារធម៌៤

សុខ សន្តិភាព និងសុភមង្គល សេចក្ដីប្រាថ្នារបស់មនុស្សគ្រប់រូប ដើម្បីមានសន្តិភាព និងសុភមង្គលពេញលេញមនុស្សម្នាក់ៗត្រូវមានទំនាក់ទំនងល្អជាមួយមនុស្សជុំវិញខ្លួននិងសង្គម។ ប្រតិបត្តិបានល្អនូវ ព្រហ្ម

វិហារធម៌នាំមកនូវសន្តិភាព និងភាពសុខសាន្ត ភាពរីករាយ ការស្គាល់ខុស ស្គាល់ត្រូវ ស្គាល់គុណ ស្គាល់ទោស ចំពោះមនុស្សជុំវិញ និងការចេះកែខ្លួនឲ្យក្លាយជាមនុស្សល្អ ជាការរស់នៅចុះសម្រុងរបស់យើងជាមួយអ្នកដទៃ និងជាមូលដ្ឋាននៃការរីកចម្រើនរបស់បុគ្គល គ្រួសារ និងសង្គម។

ព្រហ្មវិហារធម៌ជាធម៌របស់ព្រះព្រហ្មដែលក្រាលចិត្ត សន្តោសប្រោសប្រណីចំពោះគ្រប់រូបមនុស្ស សត្វដោយគ្មានការរើសអើស ព្រហ្មវិហារធម៌ គឺធម៌ជាទីនៅរបស់ព្រហ្ម ឬជាធម៌ប្រតិបត្តិដើម្បីឲ្យមនុស្សរស់នៅបានល្អប្រសើរ ដែលប្រជាជនគ្រប់ស្រទាប់វណ្ណៈ និងត្រូវប្រតិបត្តិមានសាមគ្គីភាព និងភាពសុខសាន្តនៅក្នុងគ្រួសារ និងសង្គម។

**៦.២.១. មេត្តា**

(សេចក្តីរាប់អានស្រឡាញ់ពេញចិត្តដោយស្មើ និងស្មោះត្រង់)

ការមានចិត្តស្រឡាញ់រាប់អានញាតិមិត្ត និងសាធារណជនក្នុងសង្គម ដោយគ្មានការរើសអើង និងប្រកបដោយសន្តានចិត្តភក្តីទូលាយ ដូចជាមាតាបិតាចង់ឲ្យតែកូនបានសេចក្តីសុខ ចម្រើនជានិច្ច ចៀសផុតពីទុក្ខវេទនា ពៀរវេរា និងគ្រោះមហន្តរាយគ្រប់ប្រការ។

មេត្តាជាឋាមពលនៃធម៌ដែលមានអានុភាពបំផុត អាចផ្សព្វផ្សាយដោយគ្មានការរើសអើង ទៅកាន់បុគ្គលដែលជាទីស្រឡាញ់របស់យើង ឬទៅកាន់អ្នកដទៃដែលមិនមែនជាក្រុមញាតិមិត្ត ឬទៅកាន់បច្ចាមិត្តទៀតផង។

មេត្តា មានន័យថា ស្និទ្ធស្នាល ការប្រតិបត្តិប្រកបដោយមេត្តា គឺសត្រូវទាំងអស់នឹងប្រែត្រឡប់ជាមិត្តមិនអាចស្អប់ និងមិនចងពៀរវេរាចំពោះយើងបានយូរឡើយ។ អ្នកមានមេត្តាគ្មានការភ័យតក់ស្លុត អំពីហេតុការណ៍អាក្រក់កើតឡើងទេ គេអាចដោះស្រាយបានរាល់បញ្ហាទាំងអស់ ទោសៈជាបដិបក្ខ និងមេត្តា នៅពេលមានទោសៈចូលលុកលុយក្នុងចិត្ត យើងត្រូវយកមេត្តាធម៌មកលាងសំអាតចិត្តរបស់យើង។ ប្រសិនបើមនុស្សគ្រប់រូបសុទ្ធតែមានមេត្តាចិត្តដូចគ្នា មនុស្សនៅក្នុងលោកនឹងមិនមានជំលោះ អំពើហិង្សាជាមួយគ្នាឡើយ។

ធម៌ដែលផ្ទុយគ្នាពីសេចក្តីក្រោធ គឺមេត្តា សេចក្តីក្រោធមានទោស បង្កផលអាក្រក់ដ៏ក្រៃលែង យ៉ាងណាមេត្តាក៏មានគុណ បង្កផលល្អច្រើនក្រៃលែងដូច្នោះដែរ។ កាលបើដូច្នេះ ទើបគួររម្ងាប់សេចក្តីក្រោធ ហើយតាំងចិត្តមេត្តាមកជំនួសវិញ ឲ្យមេត្តានេះឯង ជួយកម្ចាត់កម្ចាយ និងការពាររារាំងសេចក្តីក្រោធ រហូតដល់បានឈ្នះដាំស្ពាព។

អ្នកមានមេត្តាធម៌អាចយកឈ្នះចិត្តអ្នកដទៃបាន ជាជ័យជំនះដ៏ប្រសើរ អ្នកដែលតាំងនៅក្នុងមេត្តាឈ្មោះថា ធ្វើនូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ខ្លួនឯង និងប្រយោជន៍អ្នកដទៃ។

មេត្តាបានធ្វើចិត្តឲ្យស្រស់ថ្លាស្អាតផូរផង់ មានសេចក្តីសុខ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងអានិសង្សរបស់មេត្តាមាន១១ប្រការគឺ៖

១. ដេកលក់ជាសុខ បើយើងក្រោធជាមួយអ្នកដទៃ យើងបីដូចជាត្រូវថ្នាំពិស មិនបានដេកនៅជាសុខ

ឡើយ ដូច្នេះទើបត្រូវចម្រើននូវមេត្តា រស់នៅជាមួយនឹងមេត្តាធម៌ ព្រមទាំងគុណធម៌ផ្សេងៗទៀតផង។

២. ភ្ញាក់ឡើងក៏ជាសុខ សុខសប្បាយក្នុងចិត្តដោយពីថ្ងៃមុនមិនបានធ្វើអាក្រក់ព្រោះក្រោធឡើយ និងដោយនឹកឃើញដោយអំពើល្អ ដែលខ្លួនបានធ្វើហើយ។

៣. មិនយល់សប្តិអាក្រក់ សូម្បីតែយល់សប្តិក៏ឃើញអារម្មណ៍ល្អៗ ដូចជា ថ្វាយបង្គំព្រះពោធិព្រឹក្ស ហែរកឋិន និងឃើញធ្វើបុណ្យផ្សេងៗទៀត និងមិនយល់សប្តិឃើញកាប់ចាក់ឈ្លោះប្រកែកគ្នាជាដើមឡើយ។

៤. ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ បើយើត្រូវការឲ្យមនុស្សទាំងឡាយស្រឡាញ់យើង គឺយើងត្រូវរៀនឲ្យចេះស្រឡាញ់អ្នកដទៃជាមុនសិន គឺរៀនឲ្យមានមេត្តា។

៥. ជាទីស្រឡាញ់នៃអមនុស្សទាំងឡាយ យើងត្រូវទុកអមនុស្សទាំងឡាយ ទេវតាទាំងឡាយជាមិត្ត រួមកើត រួមចាស់ រួមឈឺ រួមស្លាប់ជាមួយនឹងយើង។ នៅពេលដែលយើងធ្វើកុសលអ្វីមួយរួចហើយ យើងត្រូវឧទ្ទិសកុសលនោះឲ្យដល់មនុស្ស និងទេវតាទាំងឡាយផង។

៦. ទេវតាទាំងឡាយជួយថែរក្សា មនុស្សដែលមានគុណធម៌ថ្នាក់មេត្តានេះ ដោយល្អប្រពៃនៅក្នុងសន្តាន មេត្តាតាំងនៅមាំ មិនកម្រើកញាប់ញ័រ បានលាតត្រដាងចិត្តមេត្តាចំពោះមនុស្ស និងសត្វទាំងឡាយ មិនត្រឹមតែមនុស្សទេដែលមានស្រឡាញ់ និងការពារនោះ សូម្បីពួកទេវតាទាំងឡាយក៏តាមជួយការពារថែរក្សាបុគ្គលនោះមិនឲ្យមានអន្តរាយ ឲ្យមានភ័យ និងភាពញាប់ញ័រកើតឡើងដល់បុគ្គលអ្នកមានមេត្តាឡើយ។

៧. មិនត្រូវដោយសស្ត្រាវុធជាដើម ជាអន្តរាយខាងក្រៅឡើយ មេត្តាជាធម៌រម្ងាប់នូវពៀរ អ្នកចម្រើននូវមេត្តាជាអ្នកស្លូតបូង រហូតដល់បានសម្រេចនូវគុណធម៌ដ៏ប្រសើរ ដែលអាចការពារនូវអន្តរាយបាន។

៨. មានចិត្តតាំងមាំបានដោយឆាប់ មេត្តាធម៌ ជាធម៌មានឧបការៈដល់កុសលធម៌ដទៃទៀត ខ្លាំងក្លាណាស់ ទោះជាទានក្តី សីលក្តី ជាដើម។

៩. សម្បុរមុខស្រស់ថ្លា ព្រោះដោយអំណាចមេត្តា បានញ៉ាំងឲ្យរូបស្រស់បស់ ទឹកមុខគួរឲ្យរាប់អាន ទោះបីជាស្អាតពីកំណើតក៏ដោយ ក៏ព្រោះមកអំពីមានបុណ្យ ដែលបានធ្វើហើយនោះ ប្រកបដោយមេត្តាដែរ។

១០. មិនវង្វេងស្មារតីពេលជិតស្លាប់ មនុស្សដែលវង្វេងនៅពេលជិតស្លាប់ ព្រោះបាត់បង់ស្មារតី ឯមេត្តាជាគុណជាតញ៉ាំងស្មារតីឲ្យចម្រើន មិនសន្សំការខឹងក្រោធ ដែលជាបាបនាំឲ្យវង្វេងនោះឡើយ។

១១. កាលបើមិនទាន់ត្រាស់ដឹងនូវគុណធម៌ជាន់ខ្ពស់ គឺព្រះអរហត្តទេ រមែងចូលទៅកាន់ព្រហ្មលោក ដោយអំណាចមេត្តាចេតោវិមុត្ត។

បើជាអ្នកនៅច្រើនដោយសេចក្តីក្រោធឈ្មោះថា ជាអ្នកនៅឆ្ងាយអំពីការបានអានិសង្សទាំងនេះ ដូច្នេះ ទើបគួរចម្រើននូវមេត្តាធម៌ ឲ្យជាធម៌ប្រចាំចិត្ត ប្រចាំជីវិត ហ្វឹកហាត់អប់រំឲ្យមានមេត្តាជាប្រក្រតីរៀងរាល់ថ្ងៃ ព្រោះថា បើមេត្តាចិត្តនៅមានមិនទាន់បានមាំទាំទេ គឺមិនអាចយកឈ្នះសេចក្តីក្រោធបានឡើយ[32]។

[32] ប៊ុត សាវង្ស វិធីរម្ងាប់សេចក្តីក្រោធ ព.ស ២៥៤៧ ទំព័រ២៧

**៦.២.២. ករុណា**

(មានសេចក្តីអាណិតសន្តោសប្រោសប្រណី ជួយដោះទុក្ខអ្នកដទៃ)

ករុណា គឺការមានចិត្តអាណិតអាសូរ ដោយគ្មានច្រណែនឈ្នានីស យកត្រូវតែខ្លួនឯង ទិតៀនរិះគន់កំហុសអ្នកដទៃឡើយ ការអាណិតអាសូរចំពោះមនុស្សទាំងអស់នៅក្នុងសង្គម ដែលបានទទួលរងទុក្ខលំបាកផ្សេងៗទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ដោយចង់ឲ្យពួកគេរួចផុតពីទុក្ខលំបាក និងរស់នៅបានសុខស្រួលដូចខ្លួនដែរ មនុស្សត្រូវជួយសង្គ្រោះ និងធ្វើទានចំពោះមនុស្សដែលជួបប្រទះការជួបលំបាកវេទនា នៅក្នុងពិភពលោកនេះ គ្មានពេលណា និងកន្លែងណាដែលមនុស្សដែលមិនទទួលរងសេចក្តីទុក្ខ និងការឈឺចាប់នោះទេ គ្រាន់តែសេចក្តីទុក្ខ និងការឈឺចាប់នោះ មានប្រភពខុសៗគ្នាប៉ុណ្ណោះ។ បុព្វហេតុនៃសេចក្តី និងការឈឺចាប់ខ្លះបង្កើតឡើងដោយធម្មជាតិដូចជា ខ្យល់ព្យុះ ទឹកជំនន់ ការរាំងស្ងួត ជំងឺរាតត្បាតជាដើម មនុស្សខ្លះត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ដែលកើតឡើងជាយថាហេតុដូចជាភ្លើងឆេះផ្ទះ ចោរកម្មផ្សេងៗជាដើម។

មនុស្សដែលមានករុណា តែងតែស្តែងចេញមនោសញ្ចេតនា អាណិតអាសូរតាមរយៈការបរិច្ចាគទាន ករុណាដឹកនាំមនុស្សឲ្យដើរតាមផ្លូវសច្ចៈ យុត្តិធម៌ ចៀសវាងសកម្មភាពទាំងឡាយណា ដែលធ្វើឲ្យដទៃរងការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្តដូចជា ការកាប់សម្លាប់ ការធ្វើទារុណកម្ម មានប្រមាថមាក់ងាយ ការលួចបន្លំ ការកេងប្រវ័ញ្ច បោកប្រាស់ និងអំពើបាបកម្មផ្សេងៗទៀត ព្រោះមនុស្សទាំងអស់សុទ្ធតែស្រឡាញ់អាយុជីវិតរបស់ខ្លួន ចង់រស់នៅដោយសុខសន្តិភាព សុភមង្គល និងសេចក្តីថ្លៃថ្នូរ។

**៦.២.៣. មុទិតា**

(មានចិត្តទន់ភ្លន់ មិនគុំកួនចំពោះមនុស្សទូទៅ)

មុទិតា គឺមានចិត្តទន់ភ្លន់ មានចិត្តរីករាយអបអរសាទរ ចំពោះសេចក្តីសុខចម្រើនរបស់អ្នកដទៃមិនរើសមុខ និងចង់ឲ្យគេស្ថិតនៅក្នុងសេចក្តីសុខ សុវត្ថិភាពជានិច្ច ដោយគ្មានការច្រណែននិទ្ទាឈ្នានីស។

**៦.២.៤. ឧបេក្ខា**

(មានចិត្តត្រង់ស្រឡាញ់យុត្តិធម៌ ស្រឡាញ់ភាពត្រឹមត្រូវ មិនលំអៀង)

ឧបេក្ខា គឺការប្រកាន់ជាកណ្តាល មិនលំអៀងទៅខាងណា និងមានចិត្តជាអព្យាក្រឹត មិនមានចិត្តត្រេកអរហួសហេតុ និងមិនខឹងសំបារចំពោះអ្នកណាទាំងអស់ បំណងសំខាន់គឺចង់តែឲ្យពួកគេរស់នៅតាមលទ្ធភាព សមត្ថភាព និងសេរីភាពរបស់គេ។ មិនមានចិត្តលោភលន់ ឬព្រួយកង្វល់ ចំពោះអ្នកជិតខាងដែលមានទ្រព្យសម្បត្តិច្រើនជាងខ្លួន មនុស្សតែងតែជាប់ជំពាក់ទៅលើមនុស្សណាម្នាក់ ឬវត្ថុអ្វីមួយដែលជាទីស្រឡាញ់ពេញចិត្តរបស់ខ្លួន ហើយការជាប់ជំពាក់នេះនាំឲ្យមនុស្សមានចិត្តលំអៀង (អគតិ)។ ដូច្នេះមនុស្សម្នាក់ត្រូវប្រកាន់ខ្ជាប់ព្រហ្មវិហារធម៌ ព្រោះវាជាប្រភពនៃសន្តិភាព និងវឌ្ឍនភាពនៃសង្គម និងពិភពលោក។

**ព្រហ្មវិហារធម៌របស់អ្នកមានគុណ**

ព្រហ្មវិហារធម៌របស់អ្នកមានគុណ ជាព្រហ្មវិហាររបស់បុព្វការីជនដែលបានចិញ្ចឹមបីបាច់ថែរក្សា

អាណិតស្រឡាញ់ បានបង្រៀន និងជួយទំនុកបំរុងផ្គុងផ្តើមឲ្យបានសម្រេចប្រយោជន៍ផ្សេងៗក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតនាពេលបច្ចុប្បន្ន និងទៅអនាគត។

មាតាបិតា ឬអាណាព្យាបាល ជាបុព្វការីជនរបស់បុត្រធីតា

ព្រះមហាក្សត្រ និងមន្ត្រីរាជការគ្រប់ផ្នែក ជាបុព្វការីជនរបស់សាធារណជនក្នុងប្រទេស

គ្រូអាចារ្យជាបុព្វការីរបស់សិស្សានុសិស្ស

ព្រះសម្មាសម្ពុទ្ធជាបុព្វការីរបស់ពុទ្ធបរិស័ទ និងមនុស្សលោក

ព្រះសម្មាសម្ពុទ្ធបានចាត់ទុកមាតាបិតាជាព្រះ ជាអ្នកមានគុណ ព្រោះលោកទាំងពីរជាអ្នកមានព្រហ្មវិហារធម៌ចំពោះបុត្រធីតា ព្រហ្មវិហារធម៌របស់មាតាបិតា ជាធម៌ដ៏ប្រសើរខ្ពង់ខ្ពស់ព្រោះលោកទាំងពីរប្រកបទៅដោយៈ

មេត្តា ៖ ការស្រឡាញ់ ប្រាថ្នាឲ្យកូនបានសុខ ជាពិសេសគឺស្រឡាញ់តាំងពីដឹងថាខ្លួនមានផ្ទៃពោះ គឺធ្វើយ៉ាងណាមិនឲ្យខូចសុខភាពដល់កូនក្នុងផ្ទៃឡើយ ដូចជាមិនហ៊ានហូបអាហារដែលមានជាតិហឹរជាដើម។

ករុណា ៖ អាណិតអាសូរគិតចង់ឲ្យកូនបានរួចអំពីទុក្ខចាប់តាំងពីប្រសូត្រមក ប្រុសក្តី ស្រីក្តី ល្អ អាក្រក់យ៉ាងណាក៏ដោយ ក៏មាតាបិតាចិញ្ចឹមកូនឲ្យរស់រានដែរ។

មុទិតា ៖ សេចក្តិត្រេកអរក្នុងវេលាដែលកូនបានសុខ ត្រេកអរតាំងពីកូនរៀននិយាយ ចេះសើច ហើយតែងតែសរសើរកូនគ្រប់ពេល។

ឧបេក្ខា ៖ តាំងចិត្តជាកណ្តាល ព្រោះឪពុកម្តាយស្រឡាញ់កូនស្មើៗគ្នា មាតាបិតាតែងតែប្រស់ព្រំមកលើបុត្រជានិច្ចកាល។

ដោយអំណាចព្រហ្មវិហារធម៌នេះ លោកជាមាតាបិតាខំព្យាយាមស្វែងរកទ្រព្យសម្បត្តិ សម្រាប់ជួយឧបត្ថម្ភដល់បុត្រធីតា ទោះបីជាលោកបានជួបប្រទះ និងសេចក្តីលំបាកវេទនាយ៉ាងណាក៏ដោយ ក៏លោកនៅតែព្យាយាមប្រឹងប្រែងជួយឧបត្ថម្ភបុត្រធីតារបស់ខ្លួនតាមលទ្ធភាពដែរ មិនតែប៉ុណ្ណោះពេលបុត្រធីបានចម្រើនវ័យ ពេញរូបរាង មាតាបិតាទាំងឡាយតែងព្យាយាមរំពៃរកមើលជ្រើសរើសគូស្រករដ៏សមរម្យ ដើម្បីរៀបចំផ្សំផ្គុំជាភរិយាស្វាមី និងចែកទ្រព្យសម្បត្តិឲ្យបុត្រធីតាទុកប្រកបរបរចិញ្ចឹមជីវិតទៀតផង។

**កតញ្ញូតាធម៌ និងកតវេទីតាធម៌**

កតញ្ញូតាធម៌ និងកតវេទីតាធម៌ ជាធម៌ដែលបុគ្គលគ្រប់រូបត្រូវយល់ដឹង និងអនុវត្តជាប់ជានិច្ច ដើម្បីចៀសវាងការប្រមាថមាក់ងាយពីអ្នកដទៃ ដែលនាំឲ្យអាប់ឱនដល់សិរីសួស្តី។ ការយល់ដឹង និងការអនុវត្តបានល្អ នូវធម៌ទាំងពីរនេះ នឹងដឹកនាំឲ្យបុគ្គលនោះក្លាយជាមនុស្សមានភាពថ្លៃថ្នូរក្នុងសង្គម ប្រកបដោយសិរីសួស្តី និងសុភមង្គល។

ការដឹងគុណគឺការទទួលស្គាល់គុណបំណាច់ដ៏ធំធេងរបស់បុព្វការីជន មានមាតាបិតាជាដើម ដែលលោកបានធ្វើចំពោះយើង គេហៅថា កតញ្ញូតាធម៌ ឯការតបស្នងចំពោះលោកអ្នកមានគុណគេហៅថា

កតវេទីតាធម៌។

ពាក្យកតញ្ញូតាធម៌ និងកតវេទីតាធម៌មានន័យផ្សេងគ្នា តែគេច្រើនប្រើពាក្យនេះបញ្ចូលគ្នា គឺកតញ្ញូកតវេទី ដែលមានន័យថា គឺការដឹងគុណផង និងការតបគុណផង។ បុត្រធីតាគ្រប់រូបត្រូវអប់រំខ្លួនឲ្យក្លាយជាមនុស្សដឹងគុណមាតាបិតា និងការខិតខំតបគុណលោកទាំងពីរវិញ ដោយគោរព ស្ដាប់ដំបូន្មាន និងចិញ្ចឹមបីបាច់ថែរក្សាលោកជាប្រចាំ តាមលទ្ធភាព និងសមត្ថភាពរបស់ខ្លួន និងមានការទទួលខុសត្រូវចំពោះជីវភាព សុខភាព និងសុវត្ថិភាពរបស់លោកគ្រប់កាលៈទេសៈ មិនធុញទ្រាន់ ទោះជាពេលវេលាដែលជួបការលំបាកស្មុគស្មាញក្នុងជីវភាព ឬហេតុការអ្វីផ្សេងក៏ដោយ។ ទាំងអស់នេះមានឈ្មោះថាជា កូនកតញ្ញូកតវេទី ឬកូនប្រកបដោយកតញ្ញូកតវេទីតាធម៌។ ផ្ទុយមកវិញកូនចៅដែលមិនដឹងគុណ មិនបានតបគុណមាតាបិតា មិនស្ដាប់ដំបូន្មាន មិនប្រព្រឹត្តល្អ ធ្វើឲ្យវង្សត្រកូលខូចកិត្តិយស និងមិនយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សាមាតាបិតាតាមលទ្ធភាពរបស់ខ្លួន ទោះបីខ្លួនមានទ្រព្យសម្បត្តិគ្រប់គ្រាន់ ក៏មិនរវល់អើពើនឹងលោកទាំងពីរទាល់តែសោះ គិតតែពីជីវិតប្ដីប្រពន្ធកូនរបស់ខ្លួន ទុកបណ្ដោយឲ្យលោកទទួលរងទុក្ខលំបាកតាមយថាកម្ម ទាំងនេះមានឈ្មោះថា កូនអកតញ្ញូ អកតវេទី ឬកូនរមិលគុណ។

ចំពោះសិក្សានុសិស្សនៅពេលខ្លួនមានចំណេះដឹងច្រើន មានបុណ្យសក្ដិខ្ពស់ មានទ្រព្យសម្បត្តិគ្រប់គ្រាន់ ពេលឃើញគ្រូរបស់ខ្លួនចាស់ជរា ឬមានទុក្ខធុរៈផ្សេងៗ ត្រូវយកចិត្តទុកដាក់ជួយសង្គ្រោះលោកតាមកាលៈទេសៈ និងតាមលទ្ធភាព ទើបមានឈ្មោះថា សិស្សកតញ្ញូកតវេទី។

រីឯប្រជារាស្ត្រក៏ដូចគ្នាដែរ គឺមានភារៈជួយទំនុកបម្រុងប្រទេសជាតិរបស់ខ្លួនតាមលទ្ធភាព ដូចជាបង់ព័ន្ធជូនរដ្ឋតាមច្បាប់កំណត់មិនគេចវេះ ចង់មានចង់បានហួសហេតុ ភ្លេចគិតដល់ការអភិវឌ្ឍប្រទេសជាតិ និងគោរពច្បាប់សង្គម មិនពុករលួយ មិនបង្កឲ្យមានបញ្ហាផ្សេងៗ ដល់ការរក្សាសុខសន្តិភាព និងសុវត្ថិភាពសង្គម ទើបមានឈ្មោះថា ជាជនដែលមានកតញ្ញូកតវេទីចំពោះប្រទេសជាតិរបស់ខ្លួន។

ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះមហាករុណា ព្រះអង្គបានប្រោសប្រទានព្រះធម៌ ព្រះវិន័យ និងព្រះឱវាទទាំងឡាយដល់មនុស្សលោក ដើម្បីទុកជាផ្លូវសម្រាប់ប្រតិបត្តិប្រកបដោយផលល្អ សិរីមង្គលសម្រាប់កសាងជីវភាពរស់នៅទោះក្នុងបច្ចុប្បន្ន ឬបរលោក។ ពុទ្ធបរិស័ទគ្រប់ស្រទាប់វណ្ណៈ ទាំងបព្វជិត និងគ្រហស្ថ តែគោរពបូជាតាមធម៌របស់ព្រះអង្គដោយគ្រឿងសក្ការៈទាំងឡាយ មានម្ហូបអាហារនំចំណី និងផលានុផលជាដើមទៅតាមលទ្ធភាព និងកាលៈទេសៈ។

## ៦.៣. អគតិធម៌៤

និយមន័យ អគតិធម៌

អគតិធម៌ ការពុំគួរប្រព្រឹត្ត សេចក្ដីលម្អៀង។ អគតិធម៌ គឺជាដំណើរនៃការនាំទៅរកសេចក្ដីសាបសូន្យប្រយោជន៍គ្រប់យ៉ាង ព្រោះថា នៅក្នុងទីណាក៏ដោយ ឲ្យតែទីនោះពោរពេញទៅដោយសេចក្ដីលម្អៀង ទោះលម្អៀងនៅក្នុងចំណែកណាមួយក៏ដោយ ក្នុងចំណោមលម្អៀងទាំង៤ប្រភេទនេះ ក្រុមនោះ បក្សនោះ សង្គម

នោះ ជាតិនោះ គ្រួសារនោះ ក៏គង់នឹងដល់នូវសេចក្តីវិនាសសាបសូន្យយ៉ាងពិតប្រាកដ។ បើនិយាយពីជាតិវិញ នឹងបង្កើតឲ្យមានវប្បធម៌អយុត្តិធម៌សង្គម ការជិះជាន់ ការបំភ័ន្ត ការបំពានច្បាប់ ការព្យាបាទគ្នា ការធ្វើទុក្ខបុកម្នេញដល់គ្នានិងគ្នាមិនចេះចប់ ភាពលម្អៀងនេះ ជាការបំផ្លាញ់សេចក្តីស្មោះត្រង់ បំផ្លាញ់ការទឹកចិត្តគ្នា និងជាប្រភពនៃការរើសអើង និងហិង្សាក្នុងសង្គម។

លើលោកនេះទំនងជាគ្មានបុគ្គលណាម្នាក់អាចលះដាច់ស្រឡះនូវអគតិនោះទេ ប្រហែលជាគ្មានដាច់ខាត។ អគតិទាំងបួននេះបើណាមួយស្ថិតនៅក្នុងចិត្តបុគ្គលពិសេសអ្នកដឹកនាំអង្គភាព ឬស្ថាប័នប្រាកដហើយ បុគ្គលិកក្រោមឱវាទច្បាស់ជាខូចសាមគ្គីភាព ។ លើសពីនេះទៀតបើអគតិនេះកើតមាននៅក្នុងស្ថាប័នតុលាការវិញ វាកាន់តែធ្ងន់ធ្ងរបំផុតនឹងធ្វើឱ្យជញ្ជីងអង្គការមួយនេះគ្មានយុត្តិធម៌ជាដាច់ខាត

តើអគតិនោះមានសេចក្តីយ៉ាងណា? ហេតុអ្វីបានជាមានឥទ្ធិពលដល់ម្លឹង? ខាងក្រោមនេះជាការបង្ហាញពីលក្ខណៈរបស់អគតិ៤យ៉ាង ៖

**៦.៣.១. ឆន្ទាគតិ** (លំអៀងព្រោះស្រឡាញ់ ពេញចិត្តមិនប្រកបដោយសមធម៌)

**៦.៣.២. ភយាគតិ** (លំអៀងព្រោះការភ័យខ្លាច ខ្លាចអំណាចពីខាងក្រៅ និងផលប្រយោជន៍)

**៦.៣.៣. ទោសាគតិ** (លំអៀងដោយសេចក្តីក្រេវក្រោធ អន់ស្រពន់ចិត្ត ខឹងសម្បា)

**៦.៣.៤. មោហាគតិ** (លំអៀងការមើលមិនឃើញគុណតម្លៃ ព្រោះតែសេចក្តីល្ងង់ខ្លៅ)

អ្នកណាប្រព្រឹត្តកន្លងធម៌ ព្រោះសេចក្តីស្រឡាញ់ ព្រោះសេចក្តីស្អប់ ព្រោះសេចក្តីខ្លាច ព្រោះសេចក្តីវង្វេង យសរបស់បុគ្គលនោះរមែងសាបសូន្យទៅដូចព្រះចន្ទខាងរនោច។ អ្នកមិនប្រព្រឹត្តកន្លងធម៌ទាំង៤ខាងលើ យសរបស់បុគ្គលនោះ រមែងពេញបរិបូណ៌ដូចព្រះចន្ទខាងខ្នើត[33]។

១. ឆន្ទាគតិ មានន័យថា ការប្រព្រឹត្តនូវសេចក្តីលំអៀងព្រោះហេតុនៃសេចក្តីស្រឡាញ់។ ជាធម្មជាតិរបស់មនុស្សសេចក្តីស្រឡាញ់គឺមាននៅក្នុងសន្តានគ្រប់ៗគ្នា គ្មានសាមញ្ញជនណាដែលមិនមានសេចក្តីស្រឡាញ់នោះទេ សេចក្តីស្រឡាញ់នេះហើយដែលនាំឲ្យមនុស្សគ្រប់រូបទាំងអស់ ប្រើល្បិចកិចលក ចេះប្រើមធ្យោបាយ ចេះប្រើវិធី ដើម្បីការពារសាច់ញាតិរបស់ខ្លួន ឬជនណាម្នាក់ដែលមានប្រយោជន៍សម្រាប់ខ្លួន ពេលខ្លះបើទោះជាដឹងថា ជននោះមានកំហុសធ្ងន់ធ្ងរយ៉ាងណាក៏ដោយ រហូតអ្នកខ្លះការពារជនជាទីស្រឡាញ់ និងអ្នកដែលមានប្រយោជន៍សម្រាប់ខ្លួនរហូតដល់វិនាសខ្លួនឯងសព្វបែបយ៉ាងក៏មាន។ សម្រាប់ជនអ្នកកាត់ក្តី ក្តី សម្រាប់អ្នកចែករំលែកទ្រព្យសម្បត្តិក្តី បើស្ថិតជាប់នៅក្នុងសេចក្តីស្រឡាញ់ហើយ មិនអាចសម្រេចក្តីដោយយុត្តិធម៌បានទេ។

ដើម្បីសម្រេចក្តីដោយយុត្តិធម៌ទៅបាន អ្នកកាត់ក្តីត្រូវកំណត់សេចក្តីស្រឡាញ់ឲ្យបានច្បាស់លាស់ ពោលគឺសេចក្តីស្រឡាញ់ជាលក្ខណៈមនោសញ្ចេតនាផ្ទាល់ខ្លួន ជាមួយក្រុមគ្រួសារ និងសាច់ញាត់ជាដើម ច្បាប់គឺជាការកំណត់ទោស ខុស ត្រូវ ច្បាប់មិនមែនជាសេចក្តីស្រឡាញ់ឡើយ ទោះជននោះជានរណាក៏ដោយ ឲ្យតែខុសគឺត្រូវតែចាត់ការតាមច្បាប់ជាកំហិត ពេលនោះច្បាប់នឹងបង្ហាញថាអ្នកប្រព្រឹត្តខុសប៉ុណ្ណា ត្រូវមានទោសប៉ុណ្ណា អាស្រ័យទៅតាមទោសកំហុសដែលបានប្រព្រឹត្តខុសនឹងបទបញ្ញត្តិ។

២. ទោសគតិ ដំណើរនៃការខឹងក្រេវក្រោធ ប្រឡោមខាម (លំអៀងព្រោះកំហឹង) អ្នកកាត់សេចក្តីត្រូវជា

---

[33] សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ឆដ្ឋភាគ ១៩ ព.ស ២៥៥៣ ទំព័រ ៧១

មនុស្សដែលមានសេចក្តីអត់ធ្មត់ខ្លាំងណាស់ ព្រោះថា ពេលភាគីទៅប្រជុំគ្នាក្នុងការស្វែងរកយុត្តិធម៌ មនុស្សត្រូវដេជែក វែកញែក ដាក់គ្នាទៅវិញទៅមក ដោយសំដីតូចខ្លះ សំដីធំខ្លះ ជួនកាលអាចប៉ះពាល់ដល់អ្នកដែលកាត់ក្តីក៏មានដូច្នេះ អ្នកដែលមានភារកិច្ចក្នុងការកាត់ក្តី ត្រូវតែមានចិត្តធ្ងន់ក្នុងមុខតំណែងរបស់ខ្លួន។ បើមិនដូច្នោះទេ នឹងសម្រេចដោយចិត្តខឹងសម្បារ ក្រេវក្រោធ មិនអាចឈរលើគោលការណ៍ច្បាប់ និងគតិយុត្តិធម៌ឡើយ វាធ្វើឲ្យការ សេចក្តីនោះ តាមអំណាចនៃការខឹង វាធ្វើឲ្យយុត្តិធម៌ប្រែប្រួល។ ក្នុងនាមអ្នកកាត់ក្តី គប្បីប្រព្រឹត្តខ្លួននៅក្នុងគុណគឺខន្តិធម៌ឲ្យបានមាំទាំ ធ្វើចិត្តឲ្យត្រជាក់ ស្តាប់ហេតុផលដោយចិត្តមេត្តា មិនអាចបញ្ចេញកំហឹងរបស់ខ្លួនទៅគូភាគីណាមួយឡើយ ទោះភាគីនោះមានកំហុសធ្ងន់ធ្ងរប៉ុណ្ណាក៏ដោយ ព្រោះយើងដឹងហើយ តួនាទីជាអ្នកផ្តល់យុត្តិធម៌ ភាពស្អាតស្អំ ផ្តល់ភាពត្រឹមត្រូវទៅដល់គូភាគីស្មើៗគ្នា។

៣. ភយាគតិ ភាពភ័យខ្លាច (លំអៀងព្រោះសេចក្តីភ័យខ្លាច ញាប់ញ័ររន្ធត់ក្នុងចិត្ត) ក្នុងនាមជាអ្នកកាត់សេចក្តីឲ្យត្រឹមត្រូវតាមមាត្រាច្បាប់ ត្រូវតែរឹងមាំក្នុងមុខតំណែងរបស់ខ្លួន មិនត្រូវបញ្ចូលអារម្មណ៍ភ័យខ្លាចអំពីសំណាក់ឥទ្ធិពលខាងក្រៅឡើយ ត្រូវតែមុតមាំក្នុងតំណែង និងច្បាប់ឲ្យត្រឹមត្រូវ ត្រូវការពារខ្យល់ដែលចូលតាមត្រចៀកឲ្យបាន ត្រូវរក្សាភ្នែកឲ្យមុត ត្រូវរក្សាកាយវិការឲ្យទន់ភ្លន់ ត្រូវរក្សាសំដីនៅក្នុងច្បាប់ ត្រូវជាគុទូទៅអមជានិច្ច គឺសីលធម៌ គុណធម៌ សុជីវធម៌ ដើម្បីរក្សាតម្លៃខ្លួន និងច្បាប់សម្រាប់រក្សាយុត្តិធម៌។ មនុស្សកាលណាមានចិត្តភ័យញាប់ញ័ររន្ធត់ គឺវាធ្វើឲ្យចិត្តរវើរវាយ កាលណាចិត្តរវើរវាយសម្រេចចិត្តប្រាកដជាល្អៀង ការសម្រេចចិត្តប្រាកដជាប្រើអារម្មណ៍ កាលណាសម្រេចក្តីដោយប្រើអារម្មណ៍ គឺយុត្តិធម៌នឹងក្រឡាប់ចាក់។

៤. មោហាគតិ ដំណើរនៃសេចក្តីល្ងង់ខ្លៅ (លំអៀងព្រោះសេចក្តីល្ងង់ខ្លៅ) វាពិតជាគ្រោះថ្នាក់ខ្លាំងណាស់សម្រាប់ប្រជាជន ដែលរស់នៅក្នុងសង្គមដែលមានអ្នកកាត់ក្តីជាមនុស្សល្ងង់ខ្លៅ ជាមោហោ ជាមនុស្សឈ្លាស មនុស្សដែលត្រូវបិទបាំងដោយមោហោ គឺជាប្រភេទមនុស្សធ្វើតាមអារម្មណ៍ តាមគំនិត និងតាមទស្សនៈផ្ទាល់ខ្លួន ច្រើនជាងការប្រតិបត្តិច្បាប់ ច្រើនជាងការយល់ដឹងអំពីច្បាប់ យើងដឹងជាទូទៅហើយ មនុស្សល្ងង់ខ្លៅមិនអាចធ្វើរឿងល្អៗ រឿងចម្រើនៗ រឿងត្រូវៗ បានល្អនោះទេ ព្រោះហេតុដូច្នោះទើបសង្គមជាទូទៅគេខ្លាចណាស់ ខ្លាចមនុស្សល្ងង់ខ្លៅកាន់ការខាងសម្រេចសេចក្តី ក្តី ជាអ្នកដឹកនាំក្តី ព្រោះបុគ្គលប្រភេទនេះមិនអាចធ្វើអ្វីដែលសុចរិត យុត្តិធម៌ និងភាពស្មោះត្រង់បានទេ។

អគតិតាមស័ព្ទប្រែជា ការពុំគួរប្រព្រឹត្ត សេចក្តីលម្អៀង គឺប្រព្រឹត្តមិនទៀងត្រង់ចំពោះសេចក្តីពិត មានន័យថា នឹងធ្វើអ្វីចំពោះបុគ្គលណាក៏មិនសមហេតុសមផលសមដើមសមចុងឡើយ ប្រព្រឹត្តទៅដោយសេចក្តីស្រឡាញ់ខ្លះ ស្អប់ខ្លះ ល្ងង់ខ្លះ ខ្លាចចំពោះហេតុដែលមិនគួរខ្លាចខ្លះ។ បើបុគ្គលអ្នកប្រព្រឹត្តយកការស្រឡាញ់ ស្អប់ ល្ងង់ ខ្លាច មកជាត្រីមុខយ៉ាងនេះហើយ រមែងខូចយុត្តិធម៌ ជាការមិនល្អទាំងអស់ ហេតុនេះគួរលះបង់ចោលមិនគួរប្រព្រឹត្តទេ។

# ជំពូក៧

# ហេតុដែលនាំឲ្យសម្រេចប្រយោជន៍លោកិយ

## ៧.១. ហេតុដែលនាំឲ្យសម្រេចប្រយោជន៍លោកិយ៤ប្រការ

### ៧.១.១. ឧដ្ឋានសម្បទា ប្រឹងប្រែងឧស្សាហ៍ព្យាយាម បំពេញកិច្ចការទាំងឡាយ

មនុស្សម្នាក់ៗត្រូវមានសេចក្តីព្យាយាមប្រកបកិច្ចការជានិច្ចនិរន្តរ៍ កិច្ចការដែលត្រូវប្រែកបនោះ ត្រូវហ្វឹកហាត់ខ្លួនឲ្យបានស្ទាត់ជំនាញ ឲ្យទៅជាមនុស្សស្ទុះស្ទា សង្វាត ឱហាត ឧស្សាហ៍ធ្វើការអត់ធ្មត់នឹងការងារក្លាហាននឹងការងារ ហ៊ានពុះនឹងឧបសគ្គ និងសេចក្តីលំបាកគ្រប់យ៉ាង មិនធុញទ្រាន់ និងការងារធ្ងន់ឬស្រាលឡើយ មិនព្យាយាមធ្វើការងារណាដែលប្រកបដោយទុច្ចរិតផ្សេងៗ មានលេងល្បែងភ្នាល់ជាដើម។ សេចក្តីឧស្សាហ៍ក្នុងផ្លូវចិត្ត សំដៅយកលក្ខណៈនៃសេចក្តីធន់ទ្រាំរបស់ចិត្ត ដែលមិនចុះចាញ់ធម្មជាតិ មិនញ៉ំមរាថយក្រោយចំពោះសេចក្តីលំបាក ចំពោះការមិនសមតាមបំណង ចំពោះការមើលងាយចំអកឡកឡឺយ នៃជនដទៃចំពោះសេចកក្តីនឿយណាយធុញទ្រាន់ ដែលចូលមកជ្រៀតជ្រែកក្នុងសេចក្តីឧស្សាហ៍របស់ខ្លួន នេះជាលក្ខ-ណៈរបស់មនុស្សមានស្មារតី រឹងប៉ឹងក្លានហានអង់អាច យកជ័យជាច់ខាតទៅលើករណីយនោះ។ ឧទាហរណ៍ដូចជាយើងរៀនសូត្រវិជ្ជាផ្សេងៗ តាំងប្រឡងយកសញ្ញាបត្រ មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ជាដើម មិនមែនសម្រេចដោយសេចក្តីខ្ជិលច្រអូស មិនមានសេចក្តីព្យាយាមនោះទេ គឺកើតមកអំពីសេចក្តីប្រឹងប្រែងឧស្សាហ៍រៀនសូត្រពិត។

ព្រះសម្មាសម្ពុទ្ធទ្រង់សរសើរចំពោះសេចក្តីឧស្សាហ៍ព្យាយាមយ៉ាងដូច្នេះថា ៖

វិរិយេន ទុក្ខមច្ចេតិ គេឆ្លងសេចក្តីទុក្ខលំបាកបានដោយសាសេចក្តីព្យាយាម។ រាល់សេចក្តីទុក្ខលំបាកទាំងឡាយ ដែលតែងតែកើតមានចំពោះមនុស្សគ្រប់គ្នា ទោះសេចក្តីទុក្ខ លំបាកនោះមានរូបភាពបែបណាក៏ដោយ ដើម្បីចាកចេញពីសេចក្តីទុក្ខលំបាកនោះៗបាន គឺត្រូវមានសេចក្តីព្យាយាមជាអធិបតី និងប្រកបព្រមជាមួយចំណេះដឹង បញ្ញា ពុទ្ធិ ភាពឆ្លាតវៃ បទពិសោធ ដែលជាមធ្យោបាយសម្រាប់ទម្លាយនៅសេចក្តីទុក្ខលំបាកទាំងនោះ បុគ្គលគ្រប់រូបមិនអាចឆ្លងសេចក្តីទុក្ខលំបាកទាំងឡាយបាន ដោយការខ្ជិលច្រអូស ការដេកចាំពេលវេលា ការស្រមើលស្រមៃ ការបន់ស្រន់ បួងសួង ឬការជួយអំពីសំណាក់អ្នកណាម្នាក់ឡើង ការឆ្លងសេចក្តីទុក្ខបាកបានមិនមែនព្រោះហេតុនៃអ្នកដទៃឡើយ គឺលុះត្រាតែបុគ្គលម្នាក់ៗព្យាយាមឆ្លងដោយខ្លួនឯងមានឆន្ទៈក្នុងការឆ្លង មានសេចក្តីឆ្លាតវៃក្នុងការឆ្លងទើបអាចរើបម្រាស់ខ្លួនឲ្យចេញផុតអំពីសេចក្តីទុក្ខលំបាកទាំងឡាយនោះបាន។

ឧទាហរណ៍ ដើម្បីឆ្លងភក់ ឆ្លងស្ទឹង ឆ្លងទន្លេ ឆ្លងជ្រោះ ជាដើមបាន គេត្រូវព្យាយាមធ្វើស្ពាន ព្យាយាមធ្វើក្បូន ធ្វើទូក ធ្វើសំពៅជាដើម ដើម្បីឆ្លងទៅដល់ត្រើយនាយដោយសុវត្ថិភាពបាន។ យ៉ាងណាមិញ ដើម្បីឆ្លងពីក្របាន ត្រូវព្យាយាមធ្វើការងារឲ្យខ្លាំងក្លា និងត្រឹមត្រូវ ដើម្បីឆ្លងពីភាពល្ងង់ខ្លៅបាន ត្រូវព្យាយាមសិក្សា

រៀនសូត្រ ព្យាយាមស្វែងយល់ ឈ្វេងយល់ ស្រាវជ្រាវឲ្យបានច្រើន សេពគប់តែជាមួយជនអ្នកមានប្រាជ្ញា មានគតិបណ្ឌិត មានបទសោធល្អ មានចំណេះដឹងពិតប្រាកដ មានសន្ដានចិត្តសុចរិត ដើម្បីទទួលបាននូវចំណេះដឹង ទទួលបាននូវបច្ចេកទេស តិចនិក ភាពឆ្លាតវៃ ដើម្បីយកទៅដោះស្រាយបញ្ហាដែលបានកើតឡើង ឬនឹងកើតឡើងនាពេលអនាគត។

យើងចង់ឆ្លងអំពីអ្វីមួយ យើងត្រូវតែព្យាយាមសិក្សា ព្យាយាមឈ្វេង អំពីអ្វីនោះឲ្យបានជាក់ប្រាកដជាក់ច្បាស់ ជាមុនសិន ឧទាហរណ៍ បើអ្នកធ្វើស្រែមិនបានផលច្រើន អ្នកគួរតែរកមូលហេតុរបស់វាថាមកពីអ្វី រួចហើយអ្នកត្រូវរកមូលហេតុថាតើគួរធ្វើយ៉ាងណាដើម្បីឲ្យការធ្វើស្រែទទួលបានទិន្នផលច្រើន។

ដើម្បីឆ្លងអំពីសេចក្ដីទុក្ខបាន យើងត្រូវព្យាយាមសិក្សាឲ្យឃើញនូវហេតុដែលនាំឲ្យកើតទុក្ខ ថាវាបណ្ដាលមកពីអ្វី ពេលយើងសិក្សាឃើញដោយបញ្ញាហើយ ទើបយើងឈ្វេងសិក្សាហេតុ មាគ៌ា ឬវិធីសាស្ត្រដើម្បីលះបង់នូវហេតុនោះដើម្បីឲ្យបានសម្រេចនៅសេចក្ដីសុខ។

ឧដ្ឋាតា វិន្ទតេ ធនំ អ្នកណាដែលស្ទុះស្ទាព្យាយាមរក អ្នកនោះរមែងរកទ្រព្យបាន។

រាល់លទ្ធផលទាំងឡាយ ដែលមនុស្សលោកទទួលបាន ទោះជាទ្រព្យសម្បត្តិក្ដី យសសក្ដិក្ដី វិជ្ជាក្ដី សេចក្ដីសុខក្ដី និងរាល់ការសម្រេចនៃបំណងប្រាថ្នាទាំងឡាយក្ដី មិនដែលកើតឡើងដោយសេចក្ដីអាលស្យៈ គឺសេចក្ដីខ្ជិលច្រអូសឡើយ ជនអ្នកខ្ជិលច្រអូស មិនអាចសម្រេចបាននូវសម្បត្តិទាំងឡាយខាងលើនេះឡើយ សម្បត្តិខាងលើមិនដែលកើតមានដល់បុគ្គលអ្នកខ្ជិលច្រអូសឡើយ។

ទ្រព្យសម្បត្តិទាំងឡាយ វិជ្ជាទាំងឡាយ និងលទ្ធផលទូទៅដែលកើតមានឡើង គឺកើតមានចំពោះតែជនអ្នកមានសេចក្ដីព្យាយាម អ្នកមានការឧស្សាហ៍ក្នុងការបំពេញការងារប្រកបដោយប្រាជ្ញា និងការអំណត់អត់ធន់តែប៉ុណ្ណោះ បុគ្គលអ្នកមានសេចក្ដីព្យាយាមតឹងរឹងល្អ ចំពោះការងារ និងការតព្វកិច្ចរបស់ខ្លួន មិនត្រឹមតែទទួលបានទ្រព្យសម្បត្តិឡើយ គឺទទួលបានទាំងក្ដីស្រឡាញ់ សេចក្ដីទុកចិត្ត ភាពរីករាយ ភាពសាមគ្គី កិត្តិយស កេរ្តិ៍ឈ្មោះ បុណ្យសក្ដិ អំណាច ការលើកតម្កើង ការពោលសរសើរ ការលើកធ្វើជាបុគ្គលគម្រូ ឲ្យឡើងទីជាប្រមុខនៃការដឹកនាំ ប្រគល់ការងារជាធំឲ្យមើលការខុសត្រូវ ឲ្យគ្រប់គ្រងការងារ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានលើកឡើងអំពីសេចក្ដីព្យាយាមជាច្រើនទម្រង់ ទៅតាមកិច្ចប្រតិបត្តិដោយឡែកៗពីគ្នាមានដូចជា ៖

ក្នុងសម្មប្បធាន (សេចក្ដីព្យាយាម) ៤ ទ្រង់លើកឡើងថា

សំវរប្បធាន ព្យាយាមការពារបាបមិនកើតឡើងក្នុងសន្ដាន

បហានប្បធាន **ព្យាយាម**លះបង់បាបដែលកើតឡើងហើយ

ភាវនាបធាន ព្យាយាមចម្រើនកុសលឲ្យកើតឡើងក្នុងសន្ដាន

អនុរក្ខណាបធាន ព្យាយាមរក្សាកុសលសាបសូន្យទៅវិញ

ក្នុងឥទ្ធិបាទធម៌៤មានមួយគឺ

វិរិយ សេចក្តីព្យាយាមប្រកបកិច្ចការ ការផ្តោតចិត្តទៅលើការខិតខំប្រឹងប្រែង

ក្នុងឥន្ទ្រិយ៥ មានមួយគឺ

វិរិយិន្ទ្រិយ សេចក្តីព្យាយាមជាធំ

ក្នុងពលៈ៥ មានមួយគឺ

វិរិយពលៈ កម្លាំងនៃសេចក្តីព្យាយាម

ក្នុងពោជ្ឈង្គ៧ មានមួយគឺ

វិរិយៈ សេចក្តីព្យាយាម

ក្នុងអរិយអដ្ឋង្គិកមគ្គ៨ មានមួយគឺ

សម្មាវាយាម សេចក្តីព្យាយាមត្រូវ

បុគ្គលអ្នកប្រារព្ធនូវសេចក្តីព្យាយាមដោយឆន្ទៈ គង់នឹងសម្រេចក្តីប្រាថ្នាតាមចំណង់បាន សេចក្តីព្យាយាមដែលមាននៅក្នុងមនសិការរបស់មនុស្ស ទោះមនុស្សនោះមានអាវយវៈយ៉ាងណា មានការរាងកាយយ៉ាងឲ្យតែព្យាយាមជាប់មិនដាច់គង់នឹងបានជោគមិនខានប្រៀបដូចជាធម្មជាតិមួយចំនួនមានដូចជាៈ

ដំណក់ទឹកត្នោត ដែលស្រក់ចេញអំពីផ្កាត្នោតម្តងមួយដំណក់ៗ មួយយប់ទល់ភ្លឺ ឬពេញមួយថ្ងៃ អាចញុំាងបំពង់ឲ្យពេញដោយទឹកត្នោតបានដោយបរិបូណ៌។

ដំណក់ទឹកថ្មភ្នំ ដែលជ្រាបទម្លុះតាមសាច់ថ្មម្តងមួយដំណក់ៗ ហើយស្រក់ទៅលើថ្មដុំថ្ម ឬផ្ទាំងថ្មដទៃទៀត ធ្វើឲ្យផ្ទាំងថ្ម ឬដុំថ្មនោះធ្លុះធ្លាយ ឬក្លាយទៅជាមានក្រឡុកជ្រៅដក់ទឹកបាន។

ដំណក់ទឹកភ្លៀងស្រក់ម្តងមួយដំណក់ៗ ពីក្នុងលំហអាកាសមក គង់ធ្វើឲ្យពាំងពោរពេញដោយទឹក ធ្វើឲ្យប្រឡាយ ស្ទឹង បឹងបរិបូណ៌ដោយទឹកហូរហៀរហូតដល់ធ្វើឲ្យខ្នងប្រឡាយ ស្ទឹង បឹងបាក់ដាច់ដោយសាទឹកភ្លៀងបាន។

សត្វឃ្មុំមានខ្លួនប្រាណតូចៗ តែងអាចសាងស្រណុះ និងក្បាលទឹកធំ ឬតូចតាមលទ្ធភាពរបស់វា។

សត្វស្រមោចមានខ្លួនប្រាណតូចៗជាងសត្វឃ្មុំ ពាំដីម្នាក់បន្តិចៗ គង់ធ្វើឲ្យដីមានជម្រៅក្លាយជាកូនប្រឡាយតូចមួយ។

សត្វកណ្តៀរមានខ្លួនប្រាណតូចៗដែរ ពួកវាពាំអាចម៍ម្តងបន្តិចៗ បង្កើតបាននូវដំបូកមួយដ៏ធំ។

ជាងឈើប្រើកម្លាំងអារឈើដ៏ធំ ដោយទាញដែករណាទៅវិញទៅមក មុតម្តងបន្តិចៗ រហូតបំបែកឈើដ៏ធំនោះឲ្យទៅជាចម្រៀកៗតូចធំតាមតម្រូវការរបស់ខ្លួនបាន។

ជាងដំបាញប្រើអំបោះម្តងមួយសរសៃៗដ៏តូច បង្កើតបានជាផ្ទាំងក្រណាត់មួយដ៏ធំតាមតម្រូវការ។

កសិករស្ទូងស្រូវដោយដោតសំណាបម្តងមួយជង់ៗ គង់ធ្វើឲ្យស្រែពេញបរិបូណ៌ដោយសំណាប។

ទាំងនេះគឺជាការប្រៀបធៀប ឬឧទាហរណ៍ ដើម្បីដាស់តឿនសតិស្មារតីរបស់មនុស្សលោក ឲ្យប្រឹងប្រែងធ្វើការងារ ហើយធ្វើដោយភាពជឿជាក់ ធ្វើដោយស្គាល់ខ្លួនឯង ធ្វើដោយស្គាល់កាលៈទេសៈ ក្នុងន័យថា

ធ្វើអ្វីកុំហន់ប្រញាប់ប្រញាលចង់បានផលទាន់ហន់ ចង់បានច្រើន តែត្រូវធ្វើការដោយយកចិត្តទុកដាក់ យល់ពីការងារ ស្គាល់ពីកម្លាំងរបស់ខ្លួន ព្យាយាមជាប្រចាំដូចឧទាហរណ៍ខាងលើ គង់តែនឹងបានសម្រេចប្រយោជន៍ជាក់ជាមិនខាន។ សេចក្ដីព្យាយាមជាគុណតម្លៃដ៏ខ្ពស់បំផុតរបស់មនុស្ស ក្នុងចំណោមគុណតម្លៃជាច្រើនទៀតដែលមនុស្សគ្រប់រូបគប្បីបំពេញជាប្រចាំក្នុងជីវិត។ រឿងអ្វីក៏ដោយគឺសុទ្ធតែកើតឡើងដោយសេចក្ដីព្យាយាមទាំងអស់ សូម្បីតែយើងបរិភោគបាយ យើងមិនអាចបរិភោគតែមួយស្លាបព្រាឆ្អែតទេ គឺយើងត្រូវព្យាយាមបរិភោគម្ដងមួយស្លាបព្រាៗ រហូតតោងតែពេញក្រពះទើបយើងឆ្អែត។

ព្រោះហេតុដូច្នេះហើយ បានជាអ្នកប្រាជ្ញទាំងឡាយនៅលើផែនដីនេះ តែងតែពោលសរសើរនូវបុគ្គលអ្នកមានសេចក្ដីព្យាយាម អ្នកមានការឧស្សាហ៍ ការឱហាត ការស្មុះស្វា ព្រោះលោកបានមើលឃើញយ៉ាងច្បាស់ថា រាល់ប្រយោជន៍ទាំងឡាយនៅលើផែនដីនេះ គឺកើតចេញមកពីសេចក្ដីព្យាយាម។

ក្នុងដំណើរប្រព្រឹត្តទៅនៃសេចក្ដីព្យាយាមនោះ យើងក៏ត្រូវមានអ្វីៗជាច្រើនបន្ថែមទៀតដែរ មានដូចជាចំណេះដឹង ជំនាញ ភាសាជាតិ និងភាសាបរទេស កំព្យូទ័រ សីលធម៌ គុណធម៌ សុជីវធម៌ ដែលតម្រូវឲ្យមានប្រកបព្រមជាមួយនឹងសេចក្ដីព្យាយាមក្នុងកិច្ចការនោះៗ ដើម្បីបំពេញសេចក្ដីត្រូវការការងារ ដើម្បីឲ្យការប្រតិបត្តិការងារនោះ ប្រកបដោយគុណភាព ការជឿជាក់ ធ្វើឲ្យការងាររុងរឿងឡើងជាលំដាប់។

**៧.១.២. អារក្ខសម្បទា** (ត្រូវចេះរក្សាទុកដាក់ទ្រព្យសម្បត្តិដែលខំរកបានមកហើយដោយល្អ)

ការដល់ព្រមដោយការរក្សា គឺរក្សាផលប្រយោជន៍របស់ខ្លួនដែលរកបានមកហើយ មិនឲ្យបាត់បង់ខូចខាតទៅវិញ ចំណេះវិជ្ជាក្ដី ទ្រព្យសម្បត្តិក្ដី តំណែងការងារក្ដី បុណ្យស័ក្តក្ដី ដែលជាវត្ថុសម្រាប់ធ្វើឲ្យជាតិសាសនារបស់ខ្លួន ឲ្យស្ថិតស្ថេរ ព្រមទាំងមានការចម្រើនលូតលាស់តទៅទៀត។ ត្រូវរក្សាខ្លួនមិនឲ្យមានរោគភ័យ វិបត្តិអន្តរាយនានា រក្សាទឹកដី ដែលជាកេរតំណែលពីដូនតា មិនឲ្យពួកជនជាចោរទុច្ចរិតទាំងក្នុងប្រទេសទាំងក្រៅប្រទេសមករឹបជាន់ដណ្ដើមយកបានឡើយ បើពួកទមិឡអន្យតិរ្ថីយ៍មកវាយដណ្ដើមយកទឹកដីជាបុព្វសិទ្ធិនៃយើង យើងត្រូវមានសេចក្ដីក្លាហានវាយប្រហារតបត ឬច្បាំងប្រឆាំងនឹងពួកវាវិញ បានសេចក្ដីថា បើតស៊ូដើម្បីបណ្ដេញពួកខ្មាំងទាំងនេះឲ្យចេញផុតពីដែនដី ឈ្មោះថាយើងជាអ្នករក្សាសន្តិសុខឲ្យជាតិ សាសនា និងប្រទេសខ្មែរឲ្យគង់វង្ស ឈ្មោះថាជាជនមានការរក្សាថែទាំទ្រព្យសម្បត្តិ ត្រឹមត្រូវតាមក្បួនតម្រាផង របស់ណាដែលគេធ្វើឲ្យបាត់បង់ទៅ ត្រូវព្យាយាមរកឲ្យឃើញមកវិញ របស់ណាដែលទ្រុឌទ្រោមបាក់បែក ត្រូវព្យាយាមជួសជុលឲ្យបានល្អឡើងវិញ ហើយត្រូវស្គាល់ប្រមាណក្នុងការចាយវាយទ្រព្យសម្បត្តិ មិនព្រមឲ្យមនុស្សគ្មានសីលធម៌ដណ្ដើមយកបានឡើយ។

**៧.១.៣. លក្ខណមិត្តតា** (ក្នុងការរស់នៅគប្បីបង្កើតមិត្តភាពជាមួយមនុស្សល្អឲ្យបានច្រើន)

ភាពនៃជនជាអ្នកមានមិត្តល្អ មិត្តសប្បុរស ជាអ្នកមានគំនិតមារយាទល្អ គួររាប់រកនៃជនទូទៅ បុរសស្ត្រី អ្នកអាស្រ័យនៅក្នុងស្រុក ឬនិគមន៍ជនបទនីមួយៗ ដែលមានមនុស្សចាស់ក្ដី ជាក្មេងក្ដី តែជាអ្នកមានកិរិយាមារយាទសណ្ដាប់ធ្នាប់បែបចាស់ ឬមនុស្សចាស់ ដែលមានកិរិយាមារយាទជាមនុស្សចាស់មែនទែន គឺ

ជាមនុស្សមានការពិសោធច្រើន មានការត្រិះរិះច្រើន ជាមនុស្សបរិបូណ៌ដោយ សទ្ធា សីល ចាគ និងបញ្ញា ក៏បានទៅភព្វប្រសព្វរាប់រកយកជាមិត្ត ដើម្បីនិយាយចរចាសាកសួរ អំពីគតិលោក គតិធម៌ អំពីបញ្ហាជាតិ សាសនា និងរដ្ឋ មុខជំនួញ ការរកស៊ីទទួលទាន ឲ្យឃើញថាត្រឹមត្រូវតាមរបៀបមេដឹកនាំនៃប្រទេសកម្ពុជាយើងហើយ ត្រូវតែបុរស ស្ត្រីចូលទៅចម្លងយករបៀបបែបផែនរបស់ជនទាំងនេះ យ៉ាងនេះជាដើម ហៅថា កល្យាណមិត្តតា។

ពាក្យថា កល្យាណមិត្តនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងប្រាប់ថាមាន៤ពួកគឺ ៖

១- មិត្តមានឧបការៈមិត្តជួយឧបត្ថម្ភទំនុកបម្រុងយើងគេរាល់គ្នា ដោយមិនប្រកាន់ជាតិ ត្រកូល វណ្ណៈ ពណ៌សម្បុរ សាសនា នយោបាយ និងការងារជាដើម ( ឧបការោ)។

២ - មិត្តរួមសុខ រួមទុក្ខ គ្រប់កាលៈទេសៈ គឺថាបើមិត្តបានសុខបានចម្រើនមានភាពរុងរោចន៍ ក៏ត្រេកអរសាទរ ជួយការពារសេចក្តីចម្រើនរបស់មិត្ត និងជួយឲ្យរឹតតែរុងរឿងចម្រើនឡើងបន្ថែមទៀត បើមិត្តមានភ័យ ជួបវិបត្តិដោយបការៈណាមួយក៏ជួយឈឺឆ្អាល ជួយជ្រោមជ្រែងដោះស្រាយបញ្ហា ជួយរំដោះមិត្តឲ្យរួចផុតអំពីភ័យវិបត្តិនោះៗ ដោយទឹកចិត្តស្មោះស ដោយសេចក្តីអនុគ្រោះ រហូតដល់បញ្ហាវិបត្តិត្រូវបានដោះស្រាយដោយសន្តិវិធី និងចប់ចុងចប់ដើមដោយបរិបូណ៌ មិនបោះបង់មិត្តចោល មិត្តបែបនេះហៅថា មិត្តរួមសុខរួមទុក្ខជាមួយមិត្ត មិត្តរួមស្លាប់រស់ជាមួយមិត្ត ( សុខទុក្ខញ្ច យោ មិត្តោ)។

៣ - មិត្តប្រាប់ប្រយោជន៍ មិត្តប្រាប់ហេតុផល សេចក្តីសុខចម្រើនដល់គូសម្លាញ់ ដែលធ្លាប់បានរួមរស់នៅជាមួយគ្នា។ មិត្រប្រាប់ប្រយោជន៍ គឺមិត្តដែលជួយឈឺឆ្អាលដល់មិត្តអំពីមុខរបស់ អំពីសេដ្ឋកិច្ច អំពីជំនួញ អំពីការងារ គឺជួយប្រាប់ ឬបង្ហាត់បង្រៀនអំពីបច្ចេកទេស អាជីវកម្ម ពាណិជ្ជកម្ម គឺជួបប្រាប់តែរឿងណាដែលមានប្រយោជន៍ ជួយប្រាប់តែរឿងណាដែលនាំឲ្យមិត្តកើតគំនិត កើតប្រាជ្ញ កើតការច្នៃប្រឌិត កើតការប្រតិបត្តិការងារត្រឹមត្រូវ ពេលជួបមិត្តនិយាយតែអំពីរឿងការងារដែលត្រូវធ្វើ ស្របនឹងសីលធម៌ ស្របនឹងច្បាប់រដ្ឋ និយាយដាស់តឿនមិត្តឲ្យឧស្សាហ៍ប្រឹងប្រែងព្យាយាម ឲ្យមិត្តធ្វើតែរឿងដែលល្អៗ រឿងដែលនាំឲ្យមានការរីកចម្រើន រឿងដែលនាំឲ្យមានសុភមង្គលផ្ទាល់ខ្លួន និងគ្រួសារ ធ្វើតែការងារណាដែលមិនប៉ះពាល់ដល់សេចក្តីសុខអ្នកដទៃ មិនប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ជាដើម (អត្ថាក្ខាយី)។

៤ - មិត្តមានសេចក្តីអនុគ្រោះ គឺមិត្តដែលមានសេចក្តីសន្តោសប្រោសប្រាណ ឃើញមិត្តសម្លាញ់បានដើរលើផ្លូវខុស ក៏ជួយណែនាំបង្ហាញផ្លូវឲ្យដើរមករកផ្លូវត្រូវវិញ។ មិត្តដែលល្អ គឺមិត្តដែលតាមការពារមិត្ត បើឃើញមិត្តធ្វើអំពីអាក្រក់ ត្រូវជួយប្រាប់មិត្តភ្លាមឲ្យឃើញថានេះជាអំពីអាក្រក់ ត្រូវលះបង់ចោលជាប្រញាប់ ជួយបង្ហាញមិត្តឲ្យឃើញនូវផល នៃវិបត្តិដែលកើតអំពីអំពើអាក្រក់នោះៗដល់មិត្ត ត្រូវបង្ហាញអំពីផលប៉ះពាល់នៃអំពើនោះឲ្យទាន់ពេលវេលាត្រូវហាមឃាតទប់ស្កាត់នូវទង្វើនោះកុំឲ្យរីករាលដាល គឺជួយរហូតដល់មិត្តមានស្មារតី មានសតិសម្បជញ្ញៈ និងដឹងខ្លួនឡើងវិញ ហើយលះបង់នូវអំពើទាំងនោះចោលឲ្យដាច់ស្រឡះ។ មិត្តដែលបានជួយមិត្តឲ្យស្គាល់ហេតុនៃសេចក្តីចម្រើន និងសេចក្តីវិនាស បង្ហាញមិត្តឲ្យកាន់យកហេតុនៃសេចក្តី

ចម្រើន និងលះបង់ចោលនូវហេតុដែលនាំទៅរកសេចក្តីវិនាស ជួយជាស់តឿនមិត្តថានេះរឿងដែលត្រឹមត្រូវ ហើយត្រូវការពារ និងធ្វើឲ្យចម្រើនឡើងជាលំដាប់ ដាស់តឿនមិត្តថានេះ ជារឿងអាក្រក់ រឿងដែលសង្គមស្អប់ខ្ពើម រឿងដែលមិនជាប្រយោជន៍ដល់ជនច្រើនត្រូវលះបង់ ត្រូវបញ្ចៀសវាឲ្យផុត ព្យាយាមលះបង់លុបបំបាត់ចោលឲ្យស្រឡះពីជីវិត (មិត្តានុកម្បិកោ)។

មិត្តទាំង៤ប្រភេទនេះហើយ ដែលជាមិត្តល្អគួរអង្គុយជិត ដោយការគោរពបូជាដូចជាមាតានិងបុត្ត ព្រោះថាមិត្តទាំងនេះ ជាមិត្តមានសន្តានចិត្តស្មោះត្រង់ចំពោះយើងគ្រប់យើងរូប ដើម្បីដឹកនាំយើងទៅរកផ្លូវត្រូវ ផ្លូវសុខសួស្តី។

ប៉ុន្តែផ្ទុយទៅវិញ ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញឲ្យឃើញ នូវលក្ខណៈសម្បត្តិរបស់មិត្តមួយពួកទៀតមិនឲ្យយើងចូលទៅសេពគប់ដែលលោកហៅថា បាបមិត្ត មិត្តដែលមានលក្ខណៈចិត្តអាក្រក់មាន៤យ៉ាងគឺ

១ - មិត្តដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន គិតតែប្រយោជន៍គ្រួសារ បងប្អូនកូនចៅរបស់ខ្លួន បក្សពួករបស់ខ្លួន ក្រុមរបស់ខ្លួន (អញ្ញទត្ថុហរោ មិត្តោ)។

២ - មិត្តល្អតែសំដី ល្អតែមាត់ ឯចិត្តវិញថា ចិត្តជាទេវទត្ត មាត់ជាទេវតា (វចីបរមោ)។

៣ - មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្តមិត្ត គឺឃើញមិត្តធ្វើខុសក៏អ៊ើ ឃើញមិត្តធ្វើត្រូវក៏អ៊ើ (អនុប្បិយភាណី)។

៤ - មិត្តសម្លាញ់ដឹកនាំទៅក្នុងផ្លូវវិនាស (អបាយសហាយោ)។

មិត្តទាំង៤ប្រភេទនេះ ជាមិត្តដែលបុរស ស្ត្រីគួរចៀសវាង មិនត្រូវគប់រកឡើយ តែបើបុរសស្ត្រីណាចូលទៅគប់មិត្តទាំង៤ពួកនេះ រមែងធ្វើឲ្យខ្លួនយើងវិនាសអន្តរាយ ចាកសេចក្តីចម្រើន និងខូចកេរ្តិ៍ឈ្មោះអាប់យសដោយពិតប្រាកដ[34]។

**៧.១.៤. សមជីវិតា** (ការរស់នៅក្នុងសង្គមមិនត្រូវវាយឫកពារ ក្រអឺតក្រទម រស់នៅមានធម៌ល្អ)

ការរស់នៅក្នុងកំណើតជាមនុស្ស ត្រូវចិញ្ចឹមជីវិតត្រូវ ការចិញ្ចឹមជីវិតស្មើ គឺបើមានទ្រព្យសម្បត្តិច្រើនចាយវាយប្រើប្រាស់តិច បើមានទ្រព្យសម្បត្តិតិចចាយវាយតិចចុះមកទៀតឲ្យល្មមរស់បាន ដើម្បីធ្វើការបម្រើជីវិតខ្លួន ជីវិតគ្រួសារ ជីវិតប្រទេសជាតិឲ្យសុខដុមរមនា លូតលាស់ចម្រើន ជាបុគ្គលតាំងនៅក្នុងឧត្តមគិតថា " រស់នៅត្រឹមតែរស់ មិនរស់នៅហឺហាច្រងេងច្រងាងដែលចុះក្នុងតម្រាថា ជាអ្នកស៊ីចាយខ្ជះខ្ជាយ ស្វែងរកសេចក្តីសប្បាយឥតប្រយោជន៍ ឬចុះក្នុងតម្រាថា ជាអ្នកស៊ីចាយថាំ នាំឲ្យរូបកាយមានសុខភាពមិនល្អ " ជាអ្នកចេះចាយវាយទ្រព្យសម្បត្តិ ឲ្យមានប្រយោជន៍ដល់ខ្លួន និងប្រយោជន៍ដល់គ្រួសាររបស់ខ្លួន និងសង្គមជាតិ។

ដើម្បីភាពត្រឹមត្រូវនៃជីវិត យើងត្រូវសម្របការរស់នៅរបស់យើងឲ្យមានភាពសាមញ្ញ ក្នុងន័យថា ឲ្យការរស់នៅមិនជាសត្រូវ មិនជាឧបសគ្គរាំងស្ទះ មិនធ្វើឲ្យកើតមាននូវការភ័យខ្លាច មិននបង្កនូវសេចក្តីអន្តរាយ

[34] កម្ពុជសុរិយា ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ ពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥១៤ គ.ស ១៩៧០ទំព័រ៨២១

ដល់មនុស្សនៅជុំវិញខ្លួន និងក្នុងសង្គម។ ការរស់នៅស្មើគឺក្នុងន័យថា ជាការរស់នៅដោយឈរលើគោលការណ៍ធម្មជាតិ គឺមនុស្សមានជីវិតតែមួយ មនុស្សត្រូវការសេចក្ដីសុខ មនុស្សត្រូវការសេចក្ដីថ្លៃថ្នូរ មនុស្សត្រូវការសិទ្ធិក្នុងការរស់នៅ មនុស្សត្រូវការសេរីភាពក្នុងការរស់នៅ មនុស្សត្រូវការយុត្តិធម៌។ មនុស្សម្នាក់គឺមានជីវិតតែមួយដូចគ្នាទាំងអស់ ទោះបុគ្គលនោះកើតក្នុងត្រកូលណា សញ្ជាតិជាអ្វីក៏ដោយ គឺមនុស្សមានភាពស្មើគ្នាពីកំណើត កាលណាបុគ្គលមានការពិចារណាយ៉ាងនេះ នឹងនាំឲ្យបុគ្គលកើតមាននូវវិចារណញ្ញាណ សីលធម៌ គុណធម៌ និងសុជីវធម៌ក្នុងការរស់នៅបានយ៉ាងត្រឹមត្រូវ ទោះជននោះកើតនៅក្នុងត្រកូលណា សញ្ជាតិណាក៏ដោយ មានទ្រព្យសម្បត្តិ មានយសសក្តិ អំណាចយ៉ាងណាក៏ដោយ ក៏មិនប្រើប្រាស់ធនធានទាំងនោះទៅធ្វើឲ្យប៉ះពាល់ដល់សេចក្ដីសុខ សេចក្ដីថ្លៃថ្នូរ សេចក្ដីចម្រើនរបស់មនុស្សជាតិដូចគ្នាដែរ ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ។ មនុស្សដែលមានគុណតម្លៃនៃជីវិតរស់នៅស្មើល្អ មិនត្រឹមតែមិនបង្កបញ្ហាទុក្ខទោសដល់មនុស្សជាតិ ដូចគ្នាតែប៉ុណ្ណោះទេ ថែមទាំងលះបង់នូវធនធានផ្ទាល់ខ្លួន ដើម្បីជួយដល់មនុស្សជាតិដូចគ្នាទៀតផង ដោយមិនប្រកាន់ជាតិ ត្រកូល សាសនា ពូជសាសន៍ ពណ៌សម្បុរវណ្ណៈជាដើមឡើយ គឺកំណត់ដឹងតែម្យ៉ាងគត់គឺ ជាមនុស្សជាតិដូចគ្នាតែមួយ កាលណាកំណត់ច្បាស់លាស់យ៉ាងនេះហើយ គឺសេចក្ដីស្រឡាញ់ និងសេចក្ដីអនុគ្រោះ មេត្តាករុណា នឹងកើតមានចំពោះអ្នកដទៃ គឺស្មើនឹងខ្លួនឯង លែងមើលបំណាំ លែងចាប់កំហុស លែងចងគំនុំ លែងមានតណ្ហាក្នុងការធ្វើឲ្យអ្នកដទៃវិនាស គឺប្រាថ្នាត្រឹមតែចង់អ្នកទៃបានសុខស្រួលបានចម្រើនរុងរឿងដូចខ្លួនដែរ។

ផ្នែកសេដ្ឋកិច្ចដូចជាខាង ឧស្សាហកម្ម និងពាណិជ្ជកម្ម បើអ្នកកាន់ទាំងឡាយក្នុងពិភពលោក ខ្វះធម៌ទី១ គឺឧដ្ឋានសម្បទា កម្ជិលមិនប្រឹងប្រែងចំពោះករណីយកិច្ច រវល់តែប្រចាំគ្នា ច្រណែនគ្នា អំពីប្រយោជន៍ផ្ទាល់ខ្លួន មិនខំរវៃឧស្សាហកម្ម និងពាណិជ្ជកម្ម ឲ្យដើរទាន់សម័យទេ សេដ្ឋកិច្ចត្រូវធ្លាក់ចុះ។

បើមានឧដ្ឋានសម្បទាហើយ ខ្វះអារក្ខសម្បទា មានការខ្ជះខ្ជាយ មិនត្រួតពិនិត្យឲ្យដល់ទីកន្លែង ចេះតែប្រចាំ បណ្តាក់គ្នាម្នាក់អាងលើម្នាក់ នៅតែក្នុងការិយាល័យ រំពឹងតែលើក្រដាស លើបញ្ជីនោះ ផលនៃឧស្សាហកម្ម និងពាណិជ្ជកម្មត្រូវខូចខាត សេដ្ឋកិច្ចត្រូវធ្លាក់ចុះ។

បើមានធម៌ទាំងពីរនេះហើយ ប៉ុន្តែខ្វះធម៌ទី៣ គឺកល្យាណមិត្តតា មានការទំនាក់ទំនងជាមួយអ្នកលក់អ្នកទិញ ជាមនុស្សទុច្ចរិតមានការគៃបន្លំ និងនាំគៃបន្លំដោយហេតុណាមួយ ឬក៏មានសហការីរបស់ខ្លួនជាមនុស្សពុករលួយ ត្រូវជើងនឹងអ្នកទិញ ឬអ្នកលក់ ធ្វើឲ្យខូចខាតផលឧស្សាហកម្ម និងពាណិជ្ជកម្មនោះ សេដ្ឋកិច្ចត្រូវធ្លាក់ចុះ។

បើមានធម៌ទី១.២.៣. នេះគ្រប់គ្រាន់ហើយ នៅខ្វះធម៌ទី៤ គឺសមជីវតា មានការចំណាយច្រើនជាងចំណូល ដោយការខ្ជះខ្ជាយ ឬដោយការប្រើបុគ្គលិកច្រើនហួស ដែលបណ្ដាលមកពីមិនចេះប្រើ គឺអំពើដែលគេតែម្នាក់កើត យើងប្រើ ៤ ទៅ ៥ នាក់ ទើបកើតហើយមិនល្អទៀត ឬទិញរបស់មួយមុខៗចូលច្រើនហួសដើម្បីបានភាគរយអំពីអ្នកលក់ ឯរបស់ដទៃទៀតគ្មានលុយទិញឲ្យគ្រប់គ្រាន់ ដែលនាំឲ្យអាក់អួលដំណើរ

ឧស្សាហកម្មពាណិជ្ជកម្ម សេដ្ឋកិច្ចត្រូវធ្លាក់ចុះ។ កាលបើសេដ្ឋកិច្ចធ្លាក់ចុះព្រោះខ្លួនខ្វះសមត្ថភាព ឬព្រោះខ្លួនទុច្ចរិតហើយខំតម្លើងថ្លៃទំនិញដើម្បីទប់ទល់នោះ រឹតតែនាំឲ្យចង្រៃធំដល់សង្គមជាតិអ្នកប្រើប្រាស់ថែមទៀត។

ទិដ្ឋធម្មិកធម៌នេះ មានន័យទូលំទូលាយគ្រប់ករណីយកិច្ចទាំងអស់របស់អ្នកពិភពលោក។

**៧.២. ហេតុដែលនាំឲ្យសម្រេចប្រយោជន៍លោកិយ៤ប្រការ (ឥទ្ធិបាទធម៌)**

ក្នុងទ្រឹស្តីព្រះពុទ្ធសាសនា យើងមិនបានឃើញក្បួនវិទ្យាសាស្ត្រ ដូចជាក្បួនធ្វើរថយន្ត អាកាសយាន និងក្បួនធ្វើវិទ្យុ អគ្គិសនីជាដើមនោះមែន ប៉ុន្តែទ្រឹស្តីព្រះពុទ្ធសាសនានេះឯង ជាប្រភពនៃវិទ្យាសាស្ត្រ នៃវឌ្ឍនធម៌ សីលធម៌ អារ្យធម៌ និងវប្បធម៌ក្នុងពិភពលោកទាំងមូល ដូចជាមុខវិជ្ជា វត្ថុសិក្សាគ្រប់ផ្នែកទាំងអស់ក្នុងទ្រឹស្តីវិទ្យាសាស្ត្រ សុទ្ធតែកើតមកអំពីអធិបតិធម៌ គឺជាសភាវជាធំក្នុងកិច្ចការ ឬហៅថា ឥទ្ធិបាទធម៌ គុណធម៌ដូចជាជំហាននៃសេចក្តីសម្រេចមាន៤គឺ៖

**៧.២.១. ឆន្ទៈ** (ត្រូវមានសេចក្តីពេញចិត្តចំពោះកិច្ចការនុកិច្ច ដែលខ្លួនត្រូវបំពេញ និងបង្កើតថ្មី)

បំណងគឺការប៉ុនប៉ងប្រាថ្នា ចំពោះអ្វីមួយហើយតែមានការពិនិត្យសង្កេត ជាកិច្ចសិក្សា ឬកត់សម្គាល់ នេះជាមូលហេតុទី១ ដែលនាំឲ្យកើតវិទ្យាសាស្ត្រ។

បើមានការពិនិត្យ បែបនេះហើយ តែងសន្និតស្មានទៅលើអ្វីមួយ ដែលបានកំណត់ទុកមុនថា នឹងមាន នេះជាមូលហេតុទី២ ដែលនាំឲ្យកើតវិទ្យាសាស្ត្រទៀត។

**៧.២.២. វិរិយៈ** (ត្រូវមានសេចក្តីព្យាយាម ប្រឹងប្រែងឧស្សាហ៍ បំពេញកិច្ចការងារទាំងឡាយ)

សេចក្តីព្យាយាមមិនខ្ជិលច្រអូសកាយ និងចិត្ត ខំខ្វល់ខ្វាយពិសោធន៍សាកល្បង រកការពិតតាមគំនិត នេះជាមូលហេតុទី៣ ដែលនាំឲ្យកើតវិទ្យាសាស្ត្រ។

**៧.២.៣. ចិត្តៈ** (ត្រូវយកចិត្តទុកដាក់ មានចិត្តរឹងមាំចំពោះការងារ មិនធ្វេសប្រហែសនឹងការងារ)

គំនិត គឺការចេះគិត កត់ត្រា ចងក្រងជាទ្រឹស្តីក្បួនខ្នាតឡើង តាមដំណើរការណ៍ ដែលបានសាកល្បងហើយ នេះជាមូលហេតុទី៤ ដែលនាំឲ្យកើតវិទ្យាសាស្ត្រ។

**៧.២.៤. វិមំសា** (ត្រូវពិចារណា ត្រូវថ្លឹងថ្លែង ត្រូវជាក់ច្បាស់ចំពោះការងារដោយប្រាជ្ញា)

ការត្រិះរិះពិចារណាប្រកបដោយទេពកោសល្យ ការអនុវត្តលៃលក តាមវិធានដែលមាននៅក្នុងទ្រឹស្តី នេះជាហេតុទី៥ ដែលនាំឲ្យសម្រេចកើតជាវិទ្យាសាស្ត្រ។

អធិបតិធម៌ ឬឥទ្ធិបាទធម៌នេះ មិនមែនមានប្រយោជន៍តែខាងការបង្កើតវិទ្យាសាស្ត្រប៉ុណ្ណោះទេ ជាធម៌មានប្រយោជន៍ធំបំផុតក្នុងពិភពលោកអាចញ៉ាំងវត្ថុបំណងរបស់អ្នកពិភពលោកឲ្យបានសម្រេចគ្រប់យ៉ាង តាំងពីប្រយោជន៍តូចទាបដល់ប្រយោជន៍ខ្ពង់ខ្ពស់ជាអមតៈ[35]។

---

[35] សុង ស៊ីវ ពុទ្ធសាសនា និងវិទ្យាសាស្ត្រ ទស្សនវិជ្ជា តក្កវិជ្ជា វិទ្យាសាស្ត្រ ព.ស ២៥១៦ គ.ស ១៩៧២ ទំព័រ ១៦៦

## ៧.៣. គោលការដែលគួរធ្វើគ្រប់ពេលវេលា (សារាណីយធម៌)

មេត្តាជាគុណធម៌ក្នុងដួងចិត្តដែលល្អិតល្អន់និងស្រស់ស្អាតប្រាសចាកសេចក្តីក្តៅក្រហាយ ប៉ុន្តែចំពោះសេចក្តីស្រលាញ់វិញ មិនថាត្រជាក់ល្អកទៅប៉ុនណានោះឡើយ វារមែងបង្កប់នូវសេចក្តីក្តៅក្រហាយ ញាប់ញ័រ និងការភ័យខ្លាចដោយប្រការផ្សេងៗ។ មនុស្សដែលយើងស្រលាញ់ យើងរមែងជួយគេទាំងក្នុងពេលដែលគេបានសុខ និងទាំងក្នុងពេលដែលគេបានទុក្ខ តែចំពោះមនុស្សដែលយើងមានមេត្តាទៅវិញយើងនិងជួយគេក្នុងករណីដែលគេមានទុក្ខតែប៉ុណ្ណោះ។

**៧.៣.១. មេត្តាកាយកម្ម** (អំពើទាំងឡាយដែលស្តែងចេញតាមកាយគឺត្រូវប្រកបដោយមេត្តា)

មេត្តាគឺជាពាក្យកម្ចីពីភាសាបាលី។ ប្រជាជនកម្ពុជាភាគច្រើន យល់ច្រឡំអត្ថន័យពាក្យមេត្តាថាជាការអាណិតអាសូរ តែតាមការបកស្រាយរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យមេត្តានេះ មានអត្ថន័យថា ការរាប់អាន រាប់រកគ្នាដោយចិត្តបរិសុទ្ធ ដោយបំណងចង់ឲ្យអ្នកដទៃបាននូវសេចក្តីសុខតែម្យ៉ាង។ នៅក្នុងព្រះពុទ្ធសាសនាថេរវាទ មេត្តា គឺជាធម៌ដ៏សំខាន់មួយ នៅក្នុងចំណោមព្រហ្មវិហារធម៌ទាំង៤។

ធម៌មេត្តានេះ ត្រូវបានគេហ្វឹកហាត់ចម្រើន ដើម្បីឲ្យសត្វលោកទូទៅបានប្រកបដោយសេចក្តីស្ងប់សុខ មិនមានការព្យាបាទគ្នាទៅវិញទៅមក។

មានកាយកម្មប្រកបដោយមេត្តា គឺប្រាថ្នាល្អដល់ក្រុមរួមការងាររួមពួកជន ក្នុងសង្គមតូចធំ ដោយការជួយកិច្ចធុរៈផ្សេងៗសម្តែងសេចក្តីពេញចិត្តដោយអាកប្បកិរិយា សុភាពមិនតូងតាង និងគោរពរាប់អានគ្នាទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ។

**៧.៣.២. មេត្តាវចីកម្ម** (អំពើទាំងឡាយដែលស្តែងចេញតាមវាចាគឺត្រូវប្រកបដោយមេត្តា)

មានវចីកម្មប្រកបដោយមេត្តា គឺប្រាប់នូវអ្វីដែលជាប្រយោជន៍ ណែនាំឬដាស់តឿនដោយបំណងល្អ ពោលវាចាដោយសុភាពរាបសាមិនរមុំងរម៉ោក និងនិយាយដោយសេចក្តីគោរព ឬសេចក្តីរាប់អាន ទាំងទីចំពោះមុខ និងទីកំបាំងមុខ។

នៅក្នុងគម្ពីរព្រះពុទ្ធសាសនា ព្រះត្រៃបិដក គេឃើញមានពាក្យមេត្តានេះជាច្រើនអត្ថបទ ដូចជានៅក្នុងព្រះសូត្រឈ្មោះ កកចូបមសូត្រ និងករណីយមេត្តសូត្រ ជាដើម។ នៅក្នុងបដិសម្ភិទាមគ្គ ក៏មានអធិប្បាយជាច្រើនទាក់ទងនឹងមេត្តា។

គេអាចផ្សាយមេត្តាតាមបែបច្រើនយ៉ាង ដូចមានក្នុងព្រះសូត្រមួយចំនួន ដូចជាករណីយមេត្តសូត្រ ឬក៏លើកយកគាថាណាមួយជាភាសាបាលី ឬសំរាយជាភាសាខ្មែរក៏បាន។

នៅក្នុងករណីយមេត្តសូត្រ មានគាថាជាភាសាបាលីថា

កិច្ចណា (ដែលព្រះអរិយៈ) បានត្រាស់ដឹងនូវបទដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន (បានធ្វើហើយ) កិច្ចនោះ កុលបុត្រអ្នកឈ្លាសក្នុងប្រយោជន៍គួរធ្វើ (កុលបុត្រនោះ) ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយ និងវាចារផង ត្រង់ល្អដោយចិត្តផង គេប្រដៅងាយផង មានសុភាពទន់ភ្លន់ផង មិនមានមានៈដ៏ក្រៃលែងផង សន្តោសផង គេចិញ្ចឹមងាយផង មានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាលព្រម (មានបរិក្ខារតិច)ផង មានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង មិនឃ្នើសឃ្នងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង វិញ្ញូជនទាំងឡាយ គួរតិះដៀលជនទាំងឡាយដទៃ ដោយកម្មណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមក

សូម្បីតិចតួច (ហើយគួរផ្សាយមេត្តាចិត្ត ចំពោះពពួកសត្វថា) សត្វទាំងឡាយទាំងពួង សូមឲ្យមានសេចក្តីសុខ ឲ្យមានសេចក្តីក្សេម ឲ្យមានខ្លួនដល់នូវសេចក្តីសុខចុះ។

នៅក្នុងបដិសម្ភិទាមគ្គ មានគាថាជាភាសាបាលីថា

សព្វេ សត្តា អវេរិនោ ហោន្តុ, ខេមិនោ ហោន្តុ, សុខិនោ ហោន្តុ... សត្វទាំងឡាយទាំងពួង សូមកុំឲ្យមានពៀរ សូមឲ្យមានសេចក្តីក្សេម សូមឲ្យមានសេចក្តីសុខ ... ដូច្នេះជាដើម។

ផ្សាយមេត្តាទៅទិសទាំង១០

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ។

ពួកសត្វទាំងអស់ក្នុងទិសបូព៌ ទិសអាគ្នេយ៍ សូមឲ្យជាសត្វមិនមានពៀរនឹងគ្នា សូមឲ្យមានតែសេចក្តីសុខជានិច្ច។ល។

ឬក៏ គេអោយផ្សាយមេត្តាដោយគាថាខ្លីៗថា

ទុក្ខប្បត្តា ច និទ្ទុក្ខា, ភយប្បត្តា ច និព្ភយា, សោកប្បត្តា ច និស្សោកា, ហោន្តុ សព្វេបិ បាណិនោ។ សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ, ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ, ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅហោង។

**៧.៣.៣. មេត្តាមនោកម្ម** (អំពើទាំងឡាយដែលស្តែងចេញតាមចិត្តគឺត្រូវប្រកបដោយមេត្តា)

ចងចិត្តគិតល្អ គឺគិតអ្វីដែលជាប្រយោជន៍ដល់គ្នាទៅវិញទៅមក នឹកគិតរកគ្នាដោយសុទិដ្ឋិនិយម គិតក្នុងគោលបំណងល្អ។

ការហ្វឹកហាត់កាយចិត្តឲ្យមានសេចក្តីស្រឡាញ់ដោយចិត្តមេត្តាដល់សព្វសត្វ ដោយហោចទៅសូម្បីតែសត្រូវរបស់ខ្លួនក៏គួរផ្សាយមេត្តាឱ្យគេបានសុខ រួចចាកទុក្ខផងទាំងពួង នេះជាសន្តានពុទ្ធសាសនិក ។ ខាងក្រោមនេះជាកិច្ចដែលសាធុជនគួរផ្សាយមេត្តា ៖

១- ផ្សព្វផ្សាយមេត្តា

២- តាំងសេចក្តីប្រាថ្នាល្អចំពោះមនុស្សទូទៅ

៣- ខ្វល់ខ្វាយជួយសង្គ្រោះដល់អ្នកដទៃ

៤- ឧបត្ថម្ភបម្រុង និងចូលរួមក្នុងកិច្ចការសាធារណប្រយោជន៍

៥- មិនស្អប់ខ្ពើមអំពើរបស់អ្នកដទៃ

៦- សម្តែងការពេញចិត្តនៅពេលអ្នកដទៃមានជោគជ័យ

៧- តម្កល់ចិត្តជាកណ្តាល សម្លឹងមើលហេតុការណ៍ទាំងឡាយតាមសេចក្តីពិត ។

អ្នកឋិតនៅក្នុងគោលធម៌ទាំង៧នេះ រមែងជាមនុស្សប្រកបដោយចិត្តមេត្តា ករុណា និងជាអ្នករក្សាបានចិត្តល្អបរិសុទ្ធដល់សត្វសព្វទិសានុទិស ។

**គុណប្រយោជន៍នៃមេត្តាធម៌**

គុណប្រយោជន៍ ឬហៅម្យ៉ាងទៀតថា អានិសង្សនៃការចម្រើនមេត្តា មានសំដែងនៅក្នុងគម្ពីរបរិវារៈកឋាខន្ធ ឯកុត្តរិកៈ មានជាអាទិ៍ថា

មេត្តាចេតោវិមុត្តិ ដែលបុគ្គលធ្វើឲ្យថ្មើកហើយ ចំរើនហើយ ធ្វើឲ្យក្រាស់ក្រែលហើយ ធ្វើឲ្យដូចជាយានជំនិះ ហើយ ធ្វើឲ្យជាទីនៅហើយ ឲ្យតាំងនៅញឹកញយហើយ សន្សំទុកមិនឲ្យបាត់ ប្រារព្ធដោយល្អហើយ និងមាន អានិសង្ស១១ប្រការជាពិតប្រាកដ គឺ

១. បុគ្គលនោះដេកលក់ជាសុខ

២. ភ្ញាក់ឡើងជាសុខ

៣. មិនយល់សុបិ្តអាក្រក់

៤. ជាទីស្រឡាញ់របស់ពួកមនុស្ស

៥. ជាទីស្រឡាញ់របស់ពួកអមនុស្ស

៦. ពួកទេវតាតែងរក្សា

៧. ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី ក៏មិនប៉ះពាល់ដល់បុគ្គលនោះ

៨. ចិត្តបុគ្គលនោះ រមែងចូលកាន់សមាធិដោយរួសរាន់

៩. បុគ្គលនោះ មានពណ៌សម្បុរមុខស្រស់បស់

១០. បុគ្គលនោះមិនបានវង្វេង ធ្វើមរណកាល

១១. កាលបើមិនទាន់បានត្រាស់ដឹងនូវគុណធម៌ជាន់ខ្ពស់ទេ ជាអ្នកបានទៅកើតក្នុងព្រហ្មលោក។

**៧.៣.៤. សីលសាមញ្ញតា** ត្រូវមានជីវិតជាប្រក្រតីតាំងនៅក្នុងសេចក្តីល្អ បរិសុទ្ធ វៀរអំពើអាក្រក់ ប្រព្រឹត្តឲ្យល្អដូចអ្នកដទៃ គឺមានការប្រព្រឹត្តសុចរិតល្អប្រពៃរក្សារបៀបវិន័យក្នុងសង្គមមិនធ្វើខ្លួនឲ្យជាទីរង្កៀស ឬ អន្តរាយនូវកេរ្តិ៍ឈ្មោះរបស់ពួកក្រុមឡើយ។

**៧.៣.៥. សាធារណភោគី** (ការបែងចែកភាគលាភត្រឹមត្រូវ កុំល្មោភលន់តែម្នាក់ឯង ក្រុមឯង)

ជាអ្នកបរិភោគដោយការចែករំលែក គឺបែងចែកលាភដែលបានមកដោយធម៌ សូម្បីជារបស់បន្តិចបន្តួចក៏ធ្វើការចែកចាយឱ្យបានដល់អ្នកដទៃបរិភោគផង ឬប្រើប្រាស់ផងជាទូទៅ។

**៧.៣.៦. ទិដ្ឋិ (សម្មាទិដ្ឋិ)** (រាល់គំនិត គឺត្រូវសំយោគជារួម ដើម្បីសេចក្តីសុខក្នុងក្រុម)

គឺមានការឃើញដោយប្រពៃរួមគ្នា យល់ព្រមជាមួយគ្នាក្នុងគោលការណ៍សំខាន់ៗ កាន់យកនូវឧត្តមគតិ គោលគំនិតល្អៗរបស់ អ្នកដទៃមិនប្រកាន់នូវមានះដោយធ្វើអ្វីតាមតែគំនិតរបស់ខ្លួនមិនស្តាប់ពាក្យអ្នកដទៃនោះឡើយ ហើយម៉្យាងទៀត មាននូវសម្មាទិដ្ឋិដ៏ខ្ពង់ខ្ពស់ដែលជាទិសដៅដូចគ្នា ប្រព្រឹត្តទៅដើម្បីផ្តាច់បង់នូវការយល់ខុសឱ្យអស់ពីក្នុងចិត្ត។

**សារាណិយធម៌នេះ កន្លែងខ្លះព្រះសម្មាសម្ពុទ្ធជាម្ចាស់ជា អបរិហានិយធម៌ក៏មានៈ**

ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង អបរិហានិយធម៌ ៦ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសំដែងប្រាប់។ ពួកភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា

ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រុងដម្កល់ កាយកម្មប្រកបដោយមេត្តា ក្នុងសព្រហ្មចារីទាំងឡាយ ទាំងក្នុងទីចំពោះមុខ និងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ

ដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ)។

ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រុងតម្កល់ វចីកម្មប្រកបដោយមេត្តា ក្នុងសព្រហ្មចារីទាំងឡាយ ទាំងក្នុងទីចំពោះមុខ និងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ)។

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនឹងប្រុងដម្កល់ មនោកម្មប្រកបដោយមេត្តា ក្នុងសព្រហ្មចារីទាំងឡាយ ទាំងក្នុងទីចំពោះមុខ និងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ)។

ម្នាលភិក្ខុទាំងឡាយ បើលាភទាំងឡាយណាដែលប្រកបដោយធម៌ ដែលបានមកដោយធម៌ ហោច ទៅសូម្បីវត្ថុដែលគេដាក់ចុះក្នុងបាត្រពួកភិក្ខុមានការបរិភោគដោយមិនបាច់ចែករំលែកដោយលាភទាំងឡាយ មានសភាពយ៉ាងនោះ គឺជាអ្នកមានការបរិភោគ ជាសាធារណៈ ជាមួយនឹងសព្រហ្មចារីទាំងឡាយ ដែលមាន សីល អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ)។

ម្នាលភិក្ខុទាំងឡាយ សីលទាំងឡាយណាមិនដាច់ មិនធ្លុះ មិនពព្រុះ មិនពពាល ជាសីលរបស់មនុស្ស អ្នកជា (មិនជាខ្ញុំតណ្ហា) អ្នកប្រាជ្ញតែងសរសើរ ជាសីលមិនបានជ្រោកជ្រាកដោយតណ្ហា និងទិដ្ឋិ ជាសីល ញុំាងសមាធិឲ្យប្រព្រឹត្តទៅបាន ពួកភិក្ខុជាអ្នកមានសីលស្មើគ្នា ដោយសព្រហ្មចារីទាំងឡាយ ក្នុងសីល ទាំងឡាយ មានសភាពយ៉ាងនោះ ទាំងក្នុងទីចំពោះមុខ និងក្នុងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុ ទាំងឡាយ សេចក្តីចំរើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹម ណោះ)។

ម្នាលភិក្ខុទាំងឡាយ ទិដ្ឋិណាដែលឥតទោស ជាទីស្រោចស្រង់សត្វ ប្រព្រឹត្តទៅដើម្បីអស់សេចក្តីទុក្ខ ដោយប្រពៃ ដល់អ្នកធ្វើតាមទិដ្ឋិនោះ ពួកភិក្ខុជាអ្នកមានទិដ្ឋិស្មើគ្នា ដោយសព្រហ្មចារីទាំងឡាយ ក្នុងទិដ្ឋិមាន សភាពយ៉ាងនោះ ទាំងក្នុងទីចំពោះមុខ និងក្នុងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តី ចម្រើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ)។ ម្នាលភិក្ខុ ទាំងឡាយ បើអបរិហានិយធម៌ទាំង៦នេះ នឹងឋិតនៅក្នុងពួកភិក្ខុ ឬពួកភិក្ខុប្រតិបត្តិ ក្នុងអបរិហានិយធម៌ទាំង ៦នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដ ដល់ពួកភិក្ខុ សេចក្តីសាប សូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ)។ កាលដែលព្រះមានព្រះភាគ គង់លើភ្នំគិជ្ឈកូដ ទៀបក្រុងរាជ គ្រឹះនោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើន ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិ ដែលអប់រំដោយសីល រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិ រមែង មានផលច្រើន មានអានិសង្សច្រើន ចិត្ត ដែលអប់រំដោយបញ្ញា រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ដោយ ប្រពៃពិត គឺកាមាសវៈ (ធម៌ជាគ្រឿងត្រាំ គឺកាម) ភវាសវៈ (ធម៌ជាគ្រឿងត្រាំ គឺភព) អវិជ្ជាសវៈ (ធម៌ ជា

គ្រឿងត្រាំ គឺអវិជ្ជា)។

## ៧.៤. កល្យាណធម៌៥ប្រការ (ធម៌ល្អសម្រាប់ជីវិត)

ពិតណាស់ក្នុងព្រះពុទ្ធសាសនា មានមេរៀនជាច្រើនសម្រាប់ឱ្យមនុស្សសិក្សារៀនសូត្រ គោរពបដិបត្តិ ដើរទៅរកសុខសន្តិភាពពិតប្រាកដក្នុងលោក។ ក្នុងនោះដែរ មានគោលធម៌មួយជាមេរៀនដ៏សំខាន់ជួយជម្រុញធ្វើឱ្យមនុស្សទៅជាបុគ្គលស្អាតដោយកាយវាចា និងចិត្តដែលគេឱ្យឈ្មោះថា កល្យាណធម៌ យកមកអនុវត្តឲ្យបានល្អបរិបូណ៍ និងគ្រប់ពេលវេលាដោយស្មារតីយកចិត្តទុកដាក់។

ពាក្យថាកល្យាណធម៌ គឺជាធម៌ល្អជាធម៌បរិសុទ្ធិ និងជាធម៌ដែលធ្វើឱ្យមនុស្សស្អាតផូរផង់ក្នុងជីវិត ហើយពាក្យថា កល្យាណដូចដែលយើងបានដឹងមកហើយគ្រាន់តែបានស្តាប់ក៏ដឹងថាល្អដែរ រហូតដល់មានអ្នកខ្លះដាក់ឈ្មោះថាកល្យាណ ឬកល្យាណី វត្តកល្យាណអីជាដើម។

ពាក្យកល្យាណធម៌នេះ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់សំដែងមក គឺមិនមែនសំដៅទៅលើគ្រាន់តែជាការនិយាយការអាននោះឈ្មោះថាជាបុគ្គលបានបដិបត្តិកល្យាណធម៌ឬក៏ឈ្មោះថាជាអ្នកបាននូវកល្យាណធម៌ក៏ទេដែរ ហើយកល្យាណធម៌នេះមានដល់ទៅ៥ចំណុច ដែលជាមេរៀនដ៏សំខាន់សម្រាប់មនុស្សគ្រប់គ្នាដូចដែលបានពោលខាងដើម។

ព្រះពុទ្ធជាម្ចាស់ទ្រង់បានប្រកាសសំដែងនេះ មិនមែនមានន័យថា គ្រាន់តែមានកល្យាណធម៌ហើយមនុស្សគ្រប់គ្នាក្លាយទៅជាកល្យាណជនភ្លាមៗទាំងអស់គ្នាទេ ក៏ប៉ុន្តែនេះគ្រាន់តែជាមេរៀនមួយដែលព្រះពុទ្ធបានដាក់ចេញមកដើម្បីឱ្យទាំងអស់គ្នាស្គាល់ថា តើអ្វីទៅជាកល្យាណធម៌ ហើយត្រូវដើរតាមដោយរបៀបណាអ៊ីចឹងហើយបានជាចំណុចទីមួយលោកសំដែងថា មនុស្សគ្រប់រូបត្រូវបណ្តុះទឹកចិត្តមេត្តា កាលណាយើងមានមេត្តាហើយត្រូវពង្រឹង និងពង្រីកនូវមេត្តាឱ្យកើត ប្រសិនណាមេត្តាមិនទាន់កើតទេគ៏ឱ្យបណ្តុះឡើងក្នុងចិត្ត។

### ៧.៤.១. មេត្តា (សេចក្តីរាប់អានដោយស្មោះស្មគ្រ ទាំងក្នុងទីចំពោះមុខ និងទីកំបាំងមុខ)

មេត្តា គិតចង់ឲ្យអ្នកដទៃបានសុខ ទាំងចង់ឲ្យគេប្រាសចាកទុក្ខ។

### ៧.៤.២. សម្មាអាជីវៈ (ការរកប្រកបមុខរបរទទួលទាន និងស្វែងរកទ្រព្យក្នុងផ្លូវដែលត្រឹមត្រូវ)

ក្នុងកល្យាណធម៌ចំណុចទី២ គឺសម្មាអាជីវៈ ដែលជាការចិញ្ចឹមជីវិតត្រូវ ឬចិញ្ចឹមជីវិតដោយមិនមានទោសនោះ ព្រះអង្គមានថេរដីកាពន្យល់ថា អង្គទី២នេះជាធម៌សម្រាប់មនុស្សគ្រប់គ្នាក្នុងលោកយកទៅគោរពបដិបត្តិ ហើយសម្មាអាជីវៈនេះ គឺស្ថិតនៅក្នុងអដ្ឋង្គិកមគ្គទាំង៨ ដែលជាផ្លូវដ៏ប្រសើរសម្រាប់រុញច្រានបុគ្គលនោះឱ្យក្លាយទៅជាព្រះអរិយបុគ្គលចេញចាកទុក្ខបាន ក៏ប៉ុន្តែនៅក្នុងអត្ថន័យនេះ សំដៅដល់មនុស្សណាដែលបានអនុវត្ត ទៅលើការចិញ្ចឹមជីវិត ដែលប្រាស់ចាកទោសដោយមិនបៀតបៀន កាប់សម្លាប់គេងប្រវញ្ចដោយហេតុណាមួយនៅក្នុងជីវិតនៃការរស់នៅ ដូចនេះបុគ្គលនោះឈ្មោះថាមានសម្មាអាជីវៈ។

សម្មាអាជីវៈ មានន័យថា បុគ្គលដែលជាអ្នកបដិបត្តិសម្មាអាជីវា គួរតែជៀសវាងជំនួញ ឬប្រកបអាជីវកម្មណាមួយដែលបណ្តាលទុក្ខទោសដល់មនុស្សសត្វមានជីវិត។ ជំនួញ៥ប្រការ បើកាលណាគេប្រព្រឹត្តនូវទង្វើទាំងនេះ នឹងឱ្យនូវទុក្ខទោសគឺទី១ ជំនួញគ្រឿងអាវុធដែលបំផ្លាញនូវសេចក្តីសុខអ្នកដទៃ ទី២ ជំនួញ

ជួញដូរមនុស្ស ទី៣ ជំនួញសាច់សត្វ ទី៤ ជំនួញគ្រឿងញៀន និងទី៥ ជំនួញថ្នាំពុល។

**៧.៤.៣. សទារសន្តោសៈ** (ស្មោះត្រង់ ត្រេកអរតែនឹងប្រពន្ធរបស់ខ្លួន)

កល្យាណធម៌ចំណុចទី៣ គឺសទារសន្តោស ជាការត្រេកអរចំពោះតែភរិយារបស់ខ្លួនដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយមិនក្បត់ចិត្តគ្នាទៅមានក្រៅ មានក្នុងហើយត្រេកអរ ពេញចិត្តជាមួយនឹងអ្វី ដែលខ្លួនមាន និងចេះគោរពទៅតាមតួនាទីរៀងៗខ្លួន មានការផ្តល់ភាពកកក្តៅដល់ភរិយារបស់ខ្លួន មិនឃើញស្រីផ្សេងល្អជាងភរិយាខ្លួនលួចទៅមានពីរមានបីមិនឲ្យដឹង។ ចំណុចនេះមិនមែនសម្រាប់តែខាងប្រុសនោះទេ ខាងស្រីក៏ដូចគ្នាដែរ គឺត្រូវមានការបំពេញតាមតួនាទីជាភរិយាឲ្យបានល្អ ទើបមិនមានបញ្ហាក្នុងគ្រួសារ។

**៧.៤.៤. សច្ចៈ** (គ្រប់កាលៈទេសៈគឺមានសេចក្តីត្រង់ពិតប្រាកដជានិច្ច)

កល្យាណធម៌ចំណុចទី៤ សច្ចៈគឺជាសេចក្តីពិត ការនិយាយពិត ធ្វើពិត និយាយយ៉ាងណាធ្វើយ៉ាងនោះ ធ្វើយ៉ាងណានិយាយយ៉ាងនោះ កាលណាយើងមានភាពស្មោះត្រង់រវាងគ្នាទៅវិញទៅមកនោះ មនុស្សពិតជារស់នៅជាមួយគ្នាបានសេចក្តីសុខណាស់ ហើយសច្ចៈនេះមិនមែនជាខ្លឹមសារធម្មតាទេ សូម្បីតែព្រះពុទ្ធជាម្ចាស់ក៏ព្រះអង្គសន្សំសច្ចបារមីមួយដែរ ដើម្បីបានសម្រេចទៅជាព្រះពុទ្ធមួយព្រះអង្គ។ សច្ចៈ ការពោលពាក្យពិតប្រកបដោយប្រយោជន៍ និងត្រូវតាមកាលដែរ ហើយសច្ចៈនេះគឺសម្រាប់មនុស្សគ្រប់គ្នាអនុវត្តតាមដើម្បីឱ្យមាននូវសុខសន្តិភាពក្នុងជីវិត និងសង្គម។

**៧.៤.៥. សតិ** (គ្រប់ពេលវេលានៃសកម្មភាពការរស់នៅគឺត្រូវមានស្មារតី ភ្ញាក់រឭកជានិច្ច)

ចំណែកកល្យាណធម៌ចំណុចទី៥ ដែលជាចំណុចចុងក្រោយនោះ គឺសតិស្មារតីគ្រប់បរិបូរណ៍ មានការគិតពិចារណាបានត្រឹមត្រូវ សតិនេះសំខាន់ណាស់ កាលណាមនុស្សបាត់បង់សតិ គឺបាត់បង់អ្វីៗស្ទើរតែគ្រប់យ៉ាង។ ការរស់នៅប្រចាំថ្ងៃសតិនេះសំខាន់ខ្លាំងណាស់ ដែលជាការចាំគ្រប់គ្រងកាយ វាចា និងចិត្តឲ្យដើរត្រូវរកទិសដៅមួយដែលខ្លួនចង់បាន។

## ៧.៥. ហេតុដែលនាំឲ្យអាយុខ្លីមាន៥

តាមធម្មជាតិរបស់មនុស្ស និងសត្វ ដែលមានជីវិតរស់នៅលើលោកនេះ គឺគ្មានអ្វីជាក់លាក់នោះឡើយ តែងតែមានការប្រែប្រួលគ្រប់ដង្ហើមចេញចូល។ ការរស់នៅរបស់សត្វទាំងឡាយ គឺគ្មានអ្នកណាកំណត់បានឡើយ សុខក្តី ទុក្ខក្តី អាយុវែងក្តី អាយុខ្លីក្តី មានក្តី ក្រីជាដើម រឿងទាំងឡាយនេះសុទ្ធតែមានហេតុរបស់វា ហើយបណ្តាហេតុទាំងឡាយនោះ គ្មានអ្នកណាក្រៅពីខ្លួនឯងឡើយ ដែលជាអ្នកសាងឡើង។ រឿងកម្មពីអតីតកាលយើងមិនអាចមើលឃើញ និងដឹងបានឡើយ តែព្រះសម្មាសម្ពុទ្ធទ្រង់បានបង្ហាញហេតុផលជាក់ស្តែងដល់មនុស្សជាតិគ្រប់ជាតិសាសន៍ទាំងអស់នៅលើផែនដីនេះ ដោយមានដំណើរនៃហេតុដែលនាំឲ្យអាយុខ្លីមានដូចខាងក្រោមនេះ ៖

### ៧.៥.១. មិនចេះធ្វើខ្លួនឲ្យសប្បាយ

មនុស្សទាំងឡាយដែលកើតមកលើលោកនេះ តែងតែមានរឿងកើតឡើងផ្សេងៗគ្នា ដែលពិបាកនឹងកំណត់ថាជារឿងអ្វី រឿងតូច ឬរឿងធំ រឿងផ្ទាល់ខ្លួន ឬរឿងគ្រួសារ ឬរឿងប្រកបមុខរបរ ឬតួនាទីមុខដំណែង ឬក៏បញ្ហាដែលបណ្ដាលមកពីជំងឺ រឿងរ៉ាវស្នេហ៍គ្រស្នាញទាំងឡាយ ធ្វើឲ្យមនុស្សមានសភាពតានតឹងចិត្ត ក្ដៅក្រហាយក្នុងចិត្ត រវើរវាយចិត្ត ក្រហល់ក្រហាយក្នុងចិត្ត ព្រួយបារម្ភ ការភ័យខ្លាច ជាដើម។

ការដែលមនុស្សមិនចេះធ្វើខ្លួនឲ្យសប្បាយ គឺវានាំឲ្យមានបញ្ហាប៉ះពាល់ដល់សុខភាពជាច្រើន មានដូចជា អាចធ្វើឲ្យប្រព័ន្ធរំលាយអាហាររបស់យើងមានដំណើរការមិនល្អ ប៉ះពាល់ដល់ការគេង ព្រមទាំងអាចនាំឲ្យមានបញ្ហាបេះដូងថែមទៀតផង។

ពាក្យខ្មែរយើង តែងតែនិយាយដាស់តឿនស្មារតីដល់មនុស្សផងគ្នាថា ឈើបៀបទឹកឆាប់ពុក មនុស្សបៀបទុក្ខឆាប់ស្លាប់។ ឈើដែលបៀបទឹកនោះ ទោះជាឈើប្រភេទអ្វីក៏ដោយ ឲ្យតែបៀបទឹកគឺឆាប់ពុកផុយណាស់ មនុស្សក៏ដូចគ្នា ឲ្យតែមួយថ្ងៃៗនៅតែក្នុងសភាពក្រៀមក្រំ កើតទុក្ខមិនស្រាកស្រាន សុខភាពរបស់បុគ្គលនោះនឹងស្រុតចុះជាលំដាប់ រហូតដល់ធ្វើឲ្យធ្លាក់ខ្លួនឈឺ ឬមានជំងឺផ្សេងៗកើតឡើងជាច្រើន ធ្វើឲ្យរាងកាយមានសភាពទ្រុឌទ្រោម ធ្វើឲ្យជំងឺគ្របសង្កត់បានងាយ។ ពាក្យខ្មែរយើងមួយទៀតតែងតែនិយាយថា មនុស្សដែលកើតទុក្ខច្រើន គឺបាយក៏មិននឹក ទឹកក៏មិនស្រេក ទទួលដំណេកក៏មិនបាន, ខ្លួនប្រាណក៏មិនស្រណុកទ្រូងក្ដៅងំដោយកំហឹង ដោយភាពសោកសៅរ៍ ដោយភាពស្រងូតស្រងាត់ កន្ទក់កន្ទេញ ជាដើម មនុស្សដែលនៅក្នុងសភាពបែបនេះ និងប្រព្រឹត្តទៅនាំឲ្យមានអាយុខ្លី គឺឆាប់ស្លាប់។

### ៧.៥.២. មិនស្គាល់ប្រមាណក្នុងការសប្បាយ

ការសប្បាយរីករាយ គឺតម្រូវការដ៏ចាំបាច់បំផុតសម្រាប់មនុស្សគ្រប់រូប ភាពសប្បាយរីករាយគឺជាធម្មជាតិសាមញ្ញរបស់មនុស្សសាមញ្ញ មនុស្សសាមញ្ញត្រូវការភាពសប្បាយរីករាយ ដើម្បីញ៉ាំងជីវិតឲ្យស្រស់ស្រាយ ព្រោះហេតុនោះទើបមនុស្សសាមញ្ញជាទូទៅ នាំគ្នាស្វែងរកការសប្បាយ ស្វែងរកស្នាមញញឹម ស្វែងរកការរំភើបចិត្តដោយរូបភាពផ្សេងៗ ទៅតាមចំណង់ចំណូលចិត្តរបស់ខ្លួន។ ប៉ុន្តែក្នុងនោះផងដែរ មានមនុស្សជាច្រើន មិនថាបុរស ឬស្ត្រី នោះឡើយ តែងតែសប្បាយហួសហេតុ ឬខុសទំនង ការសប្បាយទាំងនោះមានដូចជា៖ សប្បាយនឹងស្រី សប្បាយនឹងបុរស សប្បាយនឹងស្រា សប្បាយនឹងចូលក្លឹប សប្បាយនឹងល្បែងស៊ីសង សប្បាយនឹងការដើរលេងយប់ សប្បាយនឹងការដើរមើលល្បែងមហោស្រព សប្បាយនឹងការសេពគប់មនុស្សអាក្រក់ សប្បាយនឹងសម្លាប់ជីវិតសត្វ សប្បាយនឹងគ្រឿងញៀន សប្បាយនឹងការដក់បារី ជាដើម ហេតុទាំងនេះនឹងនាំឲ្យមនុស្សមានអាយុខ្លីយ៉ាងពិតប្រាកដ។

### ៧.៥.៣. បរិភោគអាហារដែលមានធាតុខ្លាញ់ច្រើន (អាហារដែលមិនរលាយ)

ព្រះសម្មាសម្ពុទ្ធសម្ដែងថា ការបរិភោគល្មមប្រមាណសំដៅដល់ការចេះសន្តោសក្នុងការបរិភោគ មិនល្មោភតាមចំណង់នោះទេ ព្រោះយើងមិនមែនបរិភោគតែមួយពេលហើយឈប់ឯណា ត្រូវគិតទៅដល់ថ្ងៃ

ក្រោយផង ក្រែងលោកមិនបានដូចសព្វថ្ងៃ។ ការបរិភោគនេះសោតទៀត ក៏មិនមែនបរិភោគរហូតទាល់តែហល់តើចេញមកវិញនោះក៏ទេដែរគឺត្រូវស្គាល់ប្រមាណនៃការបរិភោគឲ្យត្រឹមត្រូវតែល្មម ដើម្បីញ៉ាំងឥរិយាបថទាំង៤ឲ្យប្រព្រឹត្តទៅស្រួល ពិសេសពោះវៀនក្រពះដំណើរការល្អទៅបានហើយ។ អ្នកខ្លះព្រោះតែមិនស្គាល់ប្រមាណនៃការបរិភោគហ្នឹងហើយ បានជាអ្នកខ្លះត្រូវវេទនាទុក្ខវេទនា ដេកក៏មិនស្រួល អង្គុយក៏មិនស្រួល ដកដង្ហើមចេះតែផុតៗ ធ្វើការមិនកើត ខ្ជិលច្រអូស នេះជាទោសនៃការមិនស្គាល់ប្រមាណនៃការបរិភោគ ដែលពាក្យចាស់តែពោលថា ស៊ីមិនស្គាល់ប្រមាណ។

ផលប៉ះពាល់នៃការទទួលទានច្រើនជ្រុលដោយមិនស្គាល់ប្រមាណ៖

មនុស្សភាគច្រើនក្នុងពេលបច្ចុប្បន្ន ភាគច្រើនមានទម្លាប់ទទួលទានអាហារច្រើន ដែលជាមូលហេតុបណ្តាលឲ្យកើតបញ្ហា និងជំងឺផ្សេងៗយ៉ាងហ័ស។ ពួកគេមួយចំនួនពុំបានយល់ដឹងពីផលប៉ះពាល់នៃការទទួលទានអាហារច្រើនពេកឡើយផ្ទុយទៅវិញទម្លាប់ទាំងនោះ បានធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់ពួកគេ។

ផលប៉ះពាល់ទាំងនោះរួមមាន៖

១. កើនជាតិខ្លាញ់៖ ដើម្បីទទួលបានតុល្យភាពនៃជាតិកាឡូរីនៅក្នុងរាងកាយ លោកអ្នកគួរធ្វើការបរិភោគជាតិកាឡូរីឲ្យបានសមស្របទៅនឹងតម្រូវការរបស់រាងកាយលោកអ្នក។ ប្រសិនបើអ្នកទទួលទានជាតិកាឡូរីច្រើនពេក អ្នកនឹងជួបប្រទះនឹងបញ្ហាលើសជាតិខ្លាញ់ ដោយសារតែសារជាតុកាឡូរីទាំងនោះ បម្លែងទៅជាខ្លាញ់។

២. ប៉ះពាល់ដល់ខួរក្បាល ការបរិភោគច្រើនអាចធ្វើឲ្យមានផលប៉ះពាល់ដល់ខួរក្បាល ដែលការសិក្សាមួយបានលើកឡើងថា ការទទួលទានច្រើនអាចបណ្តាលឲ្យមានបញ្ហាលើសទម្ងន់ ហើយអាចមានផលប៉ះពាល់ដល់ការចងចាំ បើធៀបទៅនឹងអ្នកដែលមានទម្ងន់សមស្រប ហើយបញ្ហាផ្លូវចិត្តក៏អាចបណ្តាលមកពីការលើសទម្ងន់នេះដែរ។

៣. អាចធ្វើឲ្យចង្អោរ ការញ៉ាំច្រើនក៏អាចបណ្តាលឲ្យអ្នកចង្អោរ ឬមានអារម្មណ៍មិនស្រួលក្នុងពោះដែរ ដោយសារតែក្រពះរបស់មនុស្សពេញវ័យ មានទំហំប្រហែលនឹងកណ្តាប់ដៃតែប៉ុណ្ណោះ ដែលអាចផ្ទុកបានចំណុះ ៧.៥ មីលីលីត្រ ហើយអាចរីកមាឌដែលអាចផ្ទុកបានចំណុះប្រមាណ ៩៥០ មីលីលីត្រ។ នៅពេលដែលអ្នកទទួលទានអាហារច្រើនជ្រុលហួសកំណត់ អ្នកនឹងចង្អោរ ឬអាចក្អួត។

៤. ធ្វើឲ្យអ្នកងងុយគេង បន្ទាប់ពីធ្វើការបរិភោគម្ហូបអាហារបានច្រើនរួចមក មនុស្សភាគច្រើនមានអារម្មណ៍ងងុយគេង ដោយសារតែកម្រិតជាតិស្ករនៅក្នុងរាងកាយធ្លាក់ចុះ ហើយការធ្លាក់ចុះនៃកម្រិតជាតិស្ករនេះ ក៏អាចបណ្តាលឲ្យអ្នកស្លឹក ចង្វាក់បេះដូងលោតញាប់ និងឈឺក្បាល។ ចំណុចទាំងនេះ គឺពិតជាប្រឈមខ្លាំងណាស់សម្រាប់ជីវិត ដូច្នេះការបរិភោគអាហារពិតជាតម្រូវការចាំបាច់របស់មនុស្សគ្រប់រូបក៏ពិតមែន ក៏ប៉ុន្តែបើយើងបរិភោគដោយមិនមានរបៀប មិនសម្រឹតសម្រាំង មិនអនាម័យ វានឹងធ្វើឲ្យមនុស្សមានអាយុខ្លី។

### ៧.៥.៤. ដើរលេងខុសកាល

ពាក្យថាការដើរលេងខុសកាល គឺដើរលេងក្នុងពេលយប់ ដែលជាពេលវេលាមិនសូវមានអ្នកដឹង អ្នកឃើញ មានអាថ៌កំបាំងច្រើន ជាពេលវេលារបស់មនុស្សពួកចោរ អ្នកដែលមិនស្មោះត្រង់ ក្នុងករណីនេះគឺ

សំដៅដល់ពួកមនុស្សដែលមានចរិតអាក្រក់ មិនមែនជាទម្លាប់របស់អ្នករកស៊ីត្រឹមត្រូវនោះទេ ដូចជាអ្នកផ្សារ អ្នកលក់ដូរដែលមាននិយាមជាប្រក្រតីក្នុងការប្រកបមុខរបរនោះឡើយ។

ជាមនុស្សមិនចេះស្រឡាញ់ខ្លួន ឬមិនចេះរក្សាខ្លួន ក្នុងន័យនេះ ការដើរលេងខុសកាល គឺវាមានបញ្ហាប្រឈមជាច្រើនដូចជា គេងមិនគ្រប់គ្រាន់ គ្មានកម្លាំងគ្រប់គ្រាន់សម្រាប់ធ្វើការងារ មានអារម្មណ៍រាយមាយងងុយគេង ងាយធ្វើឲ្យខ្លួនមានជំងឺ បាត់បង់ការចងចាំ ស្មារតីមិនប្រក្រតី សុខភាពភ្នែកមិនល្អ រាងកាយទ្រុឌទ្រោម សុខភាពស្បែកអាប់មិនស្រស់ស្រាយ បាត់បង់កម្លាំងសម្រាប់បំពេញការងារ។

មិនអាចមើលថែប្រពន្ធកូន ក្នុងន័យថា ក្នុងឋានៈជាប្តីគឺមានភារកិច្ចចាំបាច់បំផុត សម្រាប់ទំនុកបម្រុងថែទាំបីបាច់រក្សា មើលការខុសត្រូវចំពោះភរិយាខ្លួន និងកូនរបស់ខ្លួន ពីបុរសខិលខូច ពីចោរកម្ម សត្វសាហាវសត្វល្អិត ជំងឺឈឺជំកាត់ ពេលយប់ព្រលប់មិនបាន គ្រួសារគ្មានភាពកក់ក្តៅ រស់នៅដោយការភ័យខ្លាច បើពីរឿងផ្ទាល់ខ្លួនវិញគឺអំពើនោះឲ្យមានអាយុខ្លីយ៉ាងពិតប្រាកដ។

មិនអាចគ្រប់គ្រងទ្រព្យសម្បត្តិដែលខ្លួនមាន ព្រោះចោរតែងតែលួចនៅពេលដែលម្ចាស់មិននៅ ចោរជាមនុស្សឆក់ឱកាស ជាមនុស្សសម្លឹងទ្រព្យសម្បត្តិអ្នកដទៃ បើប៉ះចំមនុស្សដើរលេងយប់ មនុស្សចោរនោះនឹងលួចគោ ក្របី ជ្រូក មាន់ ទា មាស ប្រាក់ ជាដើម។

ជាន់ដានចោរ ក្នុងន័យថា យើងដើរលេងយប់មិនមែនជាចោរ លួច ឆក់ ប្លន់ របស់ទ្រព្យអ្នកដទៃទេប៉ុន្តែពួកចោរគឺតែងតែគោចរពេលយប់ស្ងាត់ ដើម្បីលួចទ្រព្យសម្បត្តិរបស់អ្នកភូមិ បើក្នុងករណីចោរលួចទៅបាត់ គឺអ្នកដែលដើរលេងយប់នោះនឹងប្រឈមចំពោះការចោទប្រកាន់ បើគេសង្កេតឃើញបុគ្គលនោះធ្វើដំណើរពេលយប់ព្រលប់មិនត្រឹមត្រូវ។ ក្រៅពីនេះ ការដើរលេងយប់ ត្រូវជនសង្គមងងឹតចាប់ធ្វើទារុណកម្ម ឬទារប្រាក់កាស ឬចោទទម្លាក់កំហុសផ្សេងៗ ហើយក៏គ្មាននរណាដឹងឮ ព្រោះត្រាច់ចរតែម្នាក់ឯង ហើយក៏អាចនឹងធ្វើឲ្យជននោះមានអាយុខ្លី ដោយសារការធ្វើទារុណកម្ម ឬធ្វើឃាតបំបាត់មាត់ជាដើម។

ទៅដល់ទីណាគេមិនទុកចិត្តនៅទីនោះ ឬជាបុគ្គលដែលគេរង្កៀស មិនអាចយកជាគ្នាបាន ត្រូវគេសង្ស័យច្រើន បាត់បង់ការជឿជាក់ បាត់បង់ទំនុកចិត្ត មិនអាចយកជាគ្នាបាន។

ជាមនុស្សមានការធ្វេសប្រហែស ទាំងជីវិតផ្ទាល់ សមាជិកគ្រួសារ ប្រពន្ធ កូន ទ្រព្យសម្បត្តិ បង្កទុក្ខទោសឲ្យខ្លួនឯងច្រើនយ៉ាង ដែលវានឹងកើតឡើងគ្រប់កាលៈទេសៈ។

**៧.៥.៥. ល្មោភកាម**

ល្មោភកាម ក្នុងន័យនេះ គឺសំដៅដល់ការត្រេកត្រអាលចំពោះបុរស ចំពោះស្រ្តី ដែលមិនដឹងប្រភពច្បាស់លាស់ មានស្រ្តីរកស៊ីផ្លូវភេទជាដើម គឺធ្វើឲ្យរាងកាយចុះខ្សោយ គាងបេះដូង ឆ្លងកាមរោគមានដូចជាៈ ជំងឺស្វាយ ជំងឺអេដស៍ និងកាមរោគជាច្រើនទៀត។ ក្រៅពីនេះ គឺមិនត្រេកត្រអាលនិងកាមដោយមិនស្គាល់ប្រពន្ធ កូនស្រី ប្តីរបស់អ្នកដទៃ ដែលជាអំពើមិនប្រពៃ នេះជាក៏ជាកត្តាដែលនាំឲ្យជននោះមានអាយុខ្លីដែរ។

## ៧.៦. ហេតុដែលនាំឲ្យមានអាយុវែងមាន៥

### ៧.៦.១.ចេះធ្វើខ្លួនឲ្យសប្បាយ (សប្បាយការី)

សប្បាយជាដំណើរនាំឲ្យបានសុខ មាន៤គឺះ

សប្បាយព្រោះប្រតិបត្តិធម៌ត្រូវ ប្រតិបត្តិត្រឹមត្រូវ ការងារមិនមានទោស (ធម្មសប្បាយ)

សប្បាយព្រោះសេពគប់មនុស្សត្រឹមត្រូវ សប្បុរស កល្យាណជន ជនសុចរិត (បុគ្គលសប្បាយ)

សប្បាយព្រោះជ្រើសរើសទីតាំងបានល្អត្រឹមត្រូវ ទីតាំងមិនប្រព្រឹត្តទៅជាទោស (អាវសសប្បាយ)

សប្បាយព្រោះមានភោជនាហារគ្រប់គ្រាន់ (អាហារសប្បាយ)

អាហារដើម្បីសុខភាព

បើអ្នកទទួលទានបានត្រឹមត្រូវ និងហាត់ប្រាណបានទៀងទាត់ អ្នកនិងមានសុខភាពល្អ មិនឈឺញឹកញាប់ព្រមទាំងស្វាហាប់ទៀតផង អាហារ៣ប្រភេទ ដែលអ្នកគួរទទួលទានគឺះ

អាហារថាមពល (អាហារថមពលមានះ បាយ នំប័ង ពោត ទឹកឃ្មុំ ស្ករអំពៅ ត្រាវ តៅហ៊ូ ដំឡូងផ្វា ស្ករត្នោត)។

អាហារសាងសង់ (អាហារសាងសង់មានះ កង្កែប សណ្តែកសៀង បង្កង សាច់ជ្រូក សួត ទា ស៊ុត អន្ទង់ សណ្តែក មាន់ ត្រីល្អិត តៅហ៊ូ ក្តាម មឹក សណ្តែកខៀវ ត្រី)។

អាហារការពារ (អាហារការពារមានះ ឪឡឹក ស្វាយទុំ ល្ហុង ក្រូចពោសាត់ ត្របែក ប៉េងប៉ោះ ក្រូចឆ្មា ល្ហុងទុំ ស្លឹកបាស់ ស្ពៃចង្កឹះ ស្ពៃតឿ ស្ពៃខ្មៅ ដូង ត្រឡាច ខ្នុរ អំពិល ល្ពៅ ត្រកួន ស្លឹកម្រុំ ស្លឹកងប់។ អាហារទាំងបីប្រភេទនេះ ខ្លួនប្រាណយើងត្រូវការជាចាំបាច់ដើម្បីមានសុខភាពល្អ។

ជារួមអាហារដែលបរិភោគអាហារគ្រប់គ្រាន់ និងអាហារដែលមានសារជាតុបំប៉ន ចម្រុះ គឺជាកត្តាសំខាន់ដើម្បីទទួលបាននូវសុខភាពល្អ អាហារផ្តល់ថាមពលដល់រាងកាយ ព្រមទាំងជួយយើងឲ្យសិក្សារៀនសូត្រ និងគិតបានល្អ។ អាហារការពារយើងពីជំងឺ និងបញ្ហាសុខភាពផ្សេងៗទៀត ធ្វើឲ្យសរីរាង្គក្នុងរាងកាយយើងដំណើរការបានត្រឹមត្រូវ ព្រមទាំងធ្វើឲ្យស្បែក សក់ និងធ្មេញរបស់យើងស្អាត នឹងរឹងមាំទៀតផង ប៉ុន្តែមិនមែនគ្រប់អាហារទាំងអស់ សុទ្ធតែធ្វើឲ្យយើងមានសុខភាពល្អនោះទេ អាហារដែលផលិតពីរោងចក្រ ដែលមនុស្សយើងជាច្រើនប្រើប្រាស់ពឹងផ្អែកទៅលើវា មានផ្ទុកដោយអំបិល ខ្លាញ់ និងស្ករយ៉ាងច្រើនលើសពីការចាំបាច់ អាហារកែច្នៃទាំងនេះ អាចបណ្តាលឲ្យមាន ឬបង្កើតនូវបញ្ហាសុខភាពជាច្រើន ដូចជាជំងឺគាំងបេះដូង និងទឹកនោមផ្អែមជាដើម។

### ៧.៦.២. ដឹងប្រមាណក្នុងការសប្បាយ (សប្បាយមត្តំ ជានាតិ)

ការដឹងប្រមាណក្នុងការសប្បាយ ឬស្គាល់ការដែលគួរសប្បាយ មនុស្សគ្រប់រូបត្រូវការសប្បាយ ប៉ុន្តែសប្បាយឲ្យត្រូវទំនង សប្បាយចំពោះរឿងដែលគួរសប្បាយ ដូចជាសប្បាយនឹងការជួបជុំគ្នាធ្វើសេចក្តីល្អ មាន

ធ្វើទាន (អំណោយ) លេងកីឡា បាត់ប្រាណ និយាយពីរឿងដែលមានប្រយោជន៍ វៀរស្រា វៀរបារី វៀរគ្រឿងញៀន វៀរកញ្ឆា វៀរល្បែងស៊ីសង ជជែកជាមួយសប្បុរស ស្ដីពាក្យពេចន៍សប្បុរស ធ្វើអ្វីដែលល្អៗ នាំឲ្យចិត្តស្រស់ថ្លា មិនប៉ះពាល់ដល់សុខភាព សប្បាយនឹងជួយអ្នកដទៃដោយសមត្ថភាពបញ្ញា និងធនធានរបស់ខ្លួន ធ្វើបុណ្យឲ្យបានច្រើន បណ្ដុះនិស្ស័យមេត្តា ករុណា សេចក្ដីសន្ដោស ការអធ្យាស្រ័យ ការឲ្យអភ័យដល់គ្នានិងគ្នា ការរួមសាមគ្គីគ្នា ជាដើមទាំងនេះនឹងធ្វើឲ្យបុគ្គលនោះមានអាយុវែងបាន។

**៧.៦.៣. បរិភោគអាហារឲ្យសមល្មម អាហារដែលឆាប់រលាយ (បរិណាតភោជី)**

បរិភោគអាហារឲ្យល្មមសមរម្យ និងអាហារដែលមានគុណភាព និងអនាម័យល្អ ក្នុងន័យថា គប្បីបរិភោគអាហារឲ្យឆ្អែតល្មមៗកុំឲ្យឆ្អែតហួសហេតុពេក វៀរការបរិភោគគ្រឿងស្រវឹងគ្រប់ប្រភេទ វៀរការបរិភោគសាច់ និងខ្លាញ់ ដែលជាហេតុបណ្ដាលឲ្យស្ទះដល់សរសៃឈាម និងបញ្ហាសុខភាពដទៃទៀត វៀរភេសជ្ជៈជាតិផ្អែមចូលទៅក្នុងខ្លួនច្រើនហួសប្រមាណ បរិភោគបន្លែធម្មជាតិ បន្លែបៃតង ដែលមិនប្រើប្រាស់ជាតិគីមី និងថ្នាំគីមីដទៃទៀត ដែលប៉ះពាល់ដល់សុខភាព ញុំាអាហារឲ្យទៀងទាត់ពេលវេលា។ មនុស្សរស់ដោយសារញុំា បើមិនញុំាស្លាប់ តែបើបរិភោគមិនត្រឹមត្រូវព្រោះតែសេចក្ដីស្រេកឃ្លាន ឬល្មោភ ក្នុងការបរិភោគក៏បណ្ដាលឲ្យយើងស្លាប់បានដូចគ្នាដែរ។

**៧.៦.៤. ដើរលេងក្នុងកាលគួរ (មិនដើរលេងខុសកាល) (កាលចារី)**

ដើរលេងក្នុងកាលគួរ គឺមិនដើរលេងក្នុងពេលយប់ ដែលជាពេលវេលាមិនសមស្រប ពេលយប់មានពេលវេលាសម្រាកសម្រានគ្រប់គ្រាន់ មិនប្រឈមនឹងបញ្ហាផ្សេងៗ ដូចអ្នកដែលដើរលេងយប់ខុសកាល ធ្វើឲ្យមានសុខភាពល្អ មានកម្លាំងពលំមាំមួន មានស្មារតីល្អ មានចិត្តស្វាហាប់ មានអារម្មណ៍នឹងនចំពោះការងារ មានសុវត្ថិភាពទាំងខ្លួនឯងផ្ទាល់ និងគ្រួសារជាដើម។

**៧.៦.៥. មិនល្មោភកាមគុណ ឬប្រព្រឹត្តធម៌ដ៏ប្រសើរ (ព្រហ្មចារី)**

ទោសនៃកាមគុណ មានច្រើនបែបច្រើនយ៉ាងណាស់ បើបុគ្គលមិនដឹងប្រមាណក្នុងការប្រើបរិភោគកាមទេនោះ បុគ្គលនោះនឹងវិនាសអន្តរាយទាន់ហន់ជាក់ជាមិនខាន។

បុគ្គលគួរត្រេកអរតែចំពោះភរិយារបស់ខ្លួន និងស្វាមីរបស់ខ្លួន ក្រៅពីនេះ គឺមិនគួរទៅត្រេកត្រអាលចំពោះបុរស ឬស្ត្រីដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួនឡើយ។

កាលគ្រាព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្នុងវត្តជេតពន ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ក្នុងក្រុងសាវត្ថី ទ្រង់សម្ដែងពីទង្វើរបស់នាងបុរាណ ទុតិយិកា (ភរិយាមុន) ដល់ភិក្ខុមួយអង្គ ដែលលះបង់កាលប្រព្រឹត្តធម៌ ទើបទ្រង់លើកជាតក មកតំណាល ដូចតទៅ៖

កាលកន្លងទៅ នៅក្នុងដែនដីមគធៈ មានប្រើសព្រៃជ្រៅមួយចេញមកពីរកស៊ី នៅតាមព្រៃជ្រៅក្នុងពេលនោះ បានប្រទះឃើញប្រើសញីមួយ អាស្រ័យនៅទីនោះ ក៏កើតមានចិត្តប្រតិពទ្ធចំពោះនាងប្រើសនោះជាខ្លាំង ទើបសម្រេចចិត្តបែកចេញពីហ្វូងរបស់ខ្លួនដើម្បីដើរតាមហ្វូងរបស់ប្រើសញីនោះវិញ។

ប្រើសញីដឹងថាប្រើសព្រៃឈ្មោលនេះ មិនសូវស្គាល់តំបន់ជាយព្រៃនេះទេ ទើបនាងជាប្រើសញីនោះបានដាស់តឿនឲ្យគេវិលត្រឡប់ទៅព្រៃជ្រៅរបស់ខ្លួនវិញ តែប្រើសឈ្មោលនោះនៅតែចចេស មិនព្រមស្តាប់ ហើយក៏ចេះតែដើរតាមនាងជាប្រើសញីរហូតដល់ជើងភ្នំមួយ។

រំពេចនោះប្រើសញី បានធំក្លិនចម្លែកដូចជាមានព្រានព្រៃនៅក្បែរនោះ ទើបនាងថយមកនៅពី ក្រោយប្រើសឈ្មោលព្រៃនោះវិញ ដើម្បីសម្លឹងមើលនាយ មើលអាយដែលនៅជុំវិញខ្លួន។ ព្រានដែលកំពុង តែលាក់ខ្លួននៅពេលឃើញប្រើសទាំងពីរនោះ ដើរចូលមកជិតដល់ហើយ គេក៏ងើបចេញពីកន្លែងពួន រួចទាញធ្នូបាញ់តម្រង់ទៅរកប្រើសព្រៃ ឈ្មោលនោះយ៉ាងលឿន។ ពេលនោះប្រើសព្រៃឈ្មោលនោះ មិនបានដឹងខ្លួនជាមុន ក៏ត្រូវព្រួញ ចាក់ទម្លុះដងខ្លួនដេកដួលដោយក្តីឈឺផ្សាជាខ្លាំង។

ចំណែកឯប្រើសញីនោះវិញ កាលបើឃើញប្រើសព្រៃឈ្មោលនោះ ត្រូវព្រួញដូច្នោះ នាងប្រើសញីនោះគិតតែពីបោលរត់គេចយករួចតែខ្លួន ដោយមិនបានខ្វល់ពីប្រើសឈ្មោលនោះឡើយ។ កាលគ្រានោះ ព្រះតថាគតបានកើតជាទេវតា ដែលអាស្រ័យនៅតាមជើងភ្នំនោះ ដោយបានឃើញហេតុការណ៍នោះទាំងអស់ ទើបព្រះអង្គតិះទៀន ដល់ប្រើសព្រៃឈ្មោលនោះថា ៖

« អ្នកគួរណាតែមានជីវិត រស់នៅដើម្បី តបស្នង គុណមាតា បិតា បែរជាមកត្រូវ បាត់បង់ជិវិត ព្រោះតែកាមគុណ និងក្លាយមកជា អាហាររបស់ ព្រានព្រៃទៅវិញ » ក្នុងកាលក្រោយមក ប្រើសព្រៃឈ្មោល និង ប្រើសញី នោះបានមក កើតជាប្តីប្រពន្ធនឹងគ្នា រីឯទេវតាអង្គនោះបានមកជាតថាគត។

## ៧.៧. ព្រះសម្មាសម្ពុទ្ធបង្ហាញពីសេរីភាព១០ប្រការ

**៧.៧.១. កុំប្រកាន់ជឿអ្វីដែលមិនមានហេតុផល ឬព្រោះសេចក្តីរាយការណ៍** (**មា អនុស្សវេន**[36]) (ត្រូវពិចារណា) ការប្រកាន់ជឿតាមពាក្យដែលឮតាមៗគ្នាមក ជឿដោយឮដំណឹងគេនិយាយតៗគ្នាមកមិនមានការពិនិត្យពិចារណាឲ្យបានល្អិតល្អន់ ចំពោះអ្នកប្រាជ្ញ ឬរៀនសូត្រឲ្យឃើញប្រាកដជាក់ច្បាស់ស្រាប់តែឮហើយ ក៏ជឿកាន់យកតែម្តងទៅ។

**៧.៧.២.កុំប្រកាន់ជឿព្រោះទំនៀមទម្លាប់**(**មា បរម្បរាយ**)ត្រូវពិចារណាប្រកាន់ជឿតាមពាក្យបរម្បរាគឺពាក្យជាលំដាប់គ្នាមក ប្រកាន់ជឿទំនៀមទម្លាប់ឯណាខុសៗ ដែលធ្លាប់ឃើញគេធ្វើដើមៗមក។

**៧.៧.៣. កុំប្រកាន់ជឿអ្វីដោយការឆ្ងាក់ឆ្អើល ឬពាក្យចចាមអារ៉ាម**(**មា ឥតិកិរាយ**) (ត្រូវពិចារណា) ប្រកាន់ជឿដោយចូលចិត្តថា បានឮមកថា ហេតុនេះយ៉ាងដូច្នេះ ប្រកាន់ជឿដោយអាងថា ខ្ញុំបានឮមកដូច្នេះប្រាកដយ៉ាងនេះ ពាក្យព្រេងដែលនិយាយលេងតៗគ្នាមក។

**៧.៧.៤. កុំប្រកាន់ជឿអ្វីដោយមើលឃើញសមតាមគម្ពីររបស់ខ្លួន** (**មា បិដកសម្បទានេន**) (ត្រូវពិចារណា) ប្រកាន់ជឿដោយអាងថាពាក្យនេះ សមមួយអន្លើដោយរបៀបបិដករបស់យើង ហើយ ឬក៏សមតាមគម្ពីររបស់យើងហើយ គឺអាងក្បួនតម្រាដែលមិនបានសិក្សាឲ្យបានត្រឹមត្រូវ។

**៧.៧.៥. កុំប្រកាន់ជឿអ្វីដោយនឹកដៅ ឬស្មានយក** (**មា តក្កហេតុ**) (ត្រូវពិចារណា)

[36] កម្ពុជសុរិយា ភាគ១/២៧ គ.ស ១៩២៦ ទំព័រ៨

ប្រកាន់ជឿដោយសេចក្តីប្រកាន់នូវហេតុ ដែលគិតស្មានប្រមាណយកដោយខ្លួនឯង គឺឃើញយ៉ាងណាក៏ជឿកាន់យកយ៉ាងនោះ ស្រេចតែនឹងនឹកឃើញ មិនរវល់ពីខុសឬត្រូវឡើយ។

**៧.៧.៦. កុំប្រកាន់ជឿអ្វីដោយអាងការត្រិះត្រិះគ្នាន់ ឬកាត់តម្រូវ (មា នយហេតុ)** (ត្រូវពិចារណា) ប្រកាន់ជឿដោយត្មោះគ្មាន់កាត់តម្រូវផ្សែផ្សំយក គឺសម្គាល់យកពាក្យឯណាមួយ ដែលមានទំនងប្រហែលៗគ្នា មកផ្សែផ្សំផ្គូផ្គង់ប្រកបគ្នាហើយក៏ឲ្យឈ្មោះតាមទំនងនោះទៅ។

**៧.៧.៧. កុំប្រកាន់ជឿអ្វីដោយអាងការត្រិះរិះតាមអាការៈ ឬតាមស្ថានភាព(មា អាការបរិវិតក្កេន)** (ត្រូវពិចារណា) ប្រកាន់ជឿដោយកិរិយាត្រិះរិះ ដោយហេតុថា ហេតុនេះល្អ គឺហេតុអ្វីៗដែលកើតឡើងហើយ តែមិនមែនជាធម៌ពិត ក៏ហេតុនោះមកត្រិះរិះផ្គូផ្គងមើល បើហេតុឯណាដែលពេញចិត្តខ្លួនក៏ពោលថាល្អ ថាត្រូវហើយ ៗ ក៏ប្រព្រឹត្តកាន់យកតាមសេចក្តីត្រិះរិះនោះទៅ។

**៧.៧.៨. កុំប្រកាន់ជឿអ្វីដោយអាងថាត្រូវនឹងទិដ្ឋិរបស់ខ្លួន (មា ទិដ្ឋិនិជ្ឈានក្ខន្តិយា)** (ត្រូវពិចារនា) ប្រកាន់ជឿដោយគិតថា ហេតុនេះសមនឹងយោបល់របស់យើង ដែលសំឡឹងមើលឃើញថា ដែលអ្នកគួរកាន់យក គឺហេតុអ្វីៗ មិនមែនជាធម៌ពិត កើតឡើងហើយត្រូវនឹងគំនិតខ្លួនដែលធ្លាប់គិតទុកមក ក៏ចូលចិត្តថា ហេតុនោះត្រូវហើយ ពិតហើយៗ ក៏ប្រតិបត្តិកាន់យកតាមហេតុដែលសមនឹងយោបល់គំនិតនោះឯងទៅ។

**៧.៧.៩. កុំប្រកាន់ជឿថាអ្នកនេះជាអ្នកប្រាជ្ញគួរជឿនតាម (មា ភព្វរូបតាយ)** (ត្រូវពិចារណា)ប្រកាន់ជឿដោយគិតថាលោកនេះជាអ្នកអង់អាចចេះដឹង គួរតែយើងជឿកាន់យកតាមពាក្យលោកនេះ គឺបើមានអ្នកណាមួយគេចេះប្រសប់ឆ្លាតក្នុងពាក្យសំដីថ្វីមាត់ ចេះនិយាយស្រួលពីរោះឥតអាក់ តែពាក្យសំដីនោះមិនមែនជាពាក្យពិតត្រឹមត្រូវទេ ស្តាប់ហើយក៏ប្រកាន់ជឿតាមពាក្យ ដែលគេនិយាយស្រួលនោះទៅ។

**៧.៧.១០. កុំប្រកាន់ជឿថា បុគ្គលរូបនេះជាគ្រូរបស់យើង (មា សមណោ នោ គរុតិ)** (ត្រូវពិចារណា) ប្រកាន់ជឿដោយគិតថា សមណៈនេះ ជាគ្រូរបស់យើង គួរយើងកាន់យកតាមពាក្យរបស់សមណៈនេះ ប្រកាន់ជឿតាមលទ្ធិរបស់ខ្លួន បើទុកជាគ្រូនោះនិយាយខុសក៏ដោយ ក៏ចេះតែជឿកាន់យកតាមទាំងអស់ ទោះមានអ្នកណាមួយក្រៅពីគ្រូរបស់ខ្លួន គេនិយាយត្រូវតាមធម៌វិន័យ ត្រឹមត្រូវតាមច្បាប់ទម្លាប់ប៉ុណ្ណាក៏មិនជឿយកតាមដែរ។

ហេតុដែលមិនគួរប្រកាន់យកតាមមាន១០ប្រការ

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ស្តេចទៅកាន់ចារិក ក្នុងកោសលជនបទជាមួយនឹងភិក្ខុសង្ឃច្រើន ក៏បានទៅដល់និគមឈ្មោះកេសបុត្ររបស់ពួកក្សត្រិយ៍ឈ្មោះ កាលាមៈ។ ពួកកាលាមក្សត្រិយ៍ នៅក្នុងកេសបុត្តនិគម បានឮដំណឹងហើយប្រកាសប្រាប់គ្នាថា ម្នាលគ្នាយើងដ៏ចម្រើន បានឮថា ព្រះសមណគោតមជាសក្យបុត្រ ចេញពីសក្យត្រកូលបួសហើយ បានមកដល់កេសបុត្តនិគម កិត្តិស័ព្ទសរសើរព្រះគោតមដ៏ចម្រើននោះឯង ពីរោះល្បីខ្ចរខ្ចាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្ត ទ្រង់ត្រាស់ដឹងនូវ

ធម៌ទាំងពួងដោយព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ប្រសើរជាងសត្វលោក ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយព្រះអង្គឯង នូវលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វព្រមទាំងពួកសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសហើយអាចប្រកាសបាន ព្រះអង្គទ្រង់សំដែងធម៌ ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញបានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពដូច្នោះ ជាការប្រពៃពេកណាស់។ លំដាប់នោះ ពួកកាលាមក្សត្រិយ៍ នៅក្នុងកេសបុត្តនិគម បានចូលទៅគាល់ព្រះដ៏មានព្រះភាគលុះចូលទៅដល់ហើយ ពួកខ្លះក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ពួកខ្លះក៏ធ្វើសេចក្តីរីករាយ ជាមួយព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយក៏អង្គុយក្នុងទីសមគួរ ពួកខ្លះប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគអង្គុយក្នុងទីសមគួរ ពួកខ្លះប្រកាសនាម និងគោត្ត អង្គុយក្នុងទីសមគួរ ពួកខ្លះអង្គុយស្ងៀមក្នុងទីសមគួរ។ លុះពួកកាលាមក្សត្រក្នុងកេសបុត្តនិគម អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះដ៏ព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍មួយពួកមកកាន់កេសបុត្តនិគម សមណព្រាហ្មណ៍ទាំងនោះ សំដែងប្រកាសនូវវាទៈគឺ លទ្ធិរបស់ខ្លួនឯង បៀតបៀន មើលងាយ បង្អាប់បង្អោនលើកទម្លាក់នូវវាទៈរបស់បុគ្គលដទៃ បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ដទៃមួយពួកទៀត មកកាន់កេសបុត្តនិគម សមណព្រាហ្មណ៍ទាំងនោះ ក៏សំដែងប្រកាសនូវវាទៈរបស់ខ្លួនឯង បៀតបៀនមើលងាយ បង្អាប់បង្អោនលើកទម្លាក់នូវវាទៈរបស់បុគ្គលដទៃដែរបពិត្រព្រះអង្គដ៏ចម្រើនយើងខ្ញុំទាំងនោះមានសេចក្តីងឿងឆ្ងល់សង្ស័យពេកណាស់ចុះបណ្តាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនេះអ្នកណានិយាយពិតអ្នកណានិយាយកុហក។ ម្នាលកាលាមក្សត្រិយ៍ គួរអ្នកទាំងឡាយ ងឿងឆ្ងល់ដែរ គួរសង្ស័យដែរ ព្រោះការងឿងឆ្ងល់និងការសង្ស័យកើតឡើងដល់អ្នកទាំងឡាយក្នុងទីនេះហើយ។

ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ (ហេតុដែលមិនគួរប្រកាន់យកតាម មាន១០ប្រការ)

១ - អ្នកចូរមកអ្នកកុំប្រកាន់ ដោយគ្រាន់តែឮតាមគ្នា

២- កុំប្រកាន់តាមពាក្យបរម្បរា (ដែលលេចឮដោយនិយាយតៗគ្នាពីមួយទៅមួយ រកចុងរកដើមិនឃើញ។

៣ - កុំប្រកាន់ដោយបានឮថាដូច្នេះ

៤ - កុំប្រកាន់ដោយអាងក្បួនតម្រា

៥ - កុំប្រកាន់តាមហេតុដែលត្រិះរិះ

៦ - កុំប្រកាន់ដោយកាត់ដំរុយផ្ទៃផ្សំ

៧ - កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ គ្រឿងសម្គាល់ លក្ខណៈជាគ្រឿងសម្គាល់ បែបបទ។

៨ - កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យសមនឹងសេចក្តីយល់ឃើញ

៩ - កុំប្រកាន់ដោយយល់ថាមានសភាពគួរ (ជឿ)

១០ - កុំប្រកាន់ដោយគិតថា សមណៈ (នេះ) ជាគ្រូរបស់យើង។

ម្នាលកាលាមក្សត្រិយ៍ កាលណាបើអ្នកទាំងឡាយ ដឹងដោយខ្លួនឯងថា ធម៌ទាំងនេះ ជាអកុសល ធម៌ទាំងនេះប្រកបដោយទោស ធម៌ទាំងនេះ អ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះ បុគ្គលបានសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ ក្នុងកាលនោះ អ្នកទាំងឡាយ ត្រូវលះបង់ចោលចេញ។ ម្នាលកាលាមក្សត្រិយ៍អ្នកសម្គាល់នូវហេតុនោះដូចម្តេច លោភៈកាលកើតឡើង ក៏កើតឡើងក្នុងសន្តានរបស់បុរស ដើម្បីជាប្រយោជន៍ ឬ ដើម្បីមិនជាប្រយោជន៍ទេ។ បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីមិនជាប្រយោជន៍ទេ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះជាអ្នកល្មោភ ត្រូវសេចក្តីលោភគ្របសង្កត់ មានចិត្តត្រូវសេចក្តីលោភរួបរឹត រមែងសម្លាប់នូវសត្វមានជីវិតខ្លះ កាន់យកនូវទ្រព្យដែលបុគ្គលដទៃមិនបានឲ្យខ្លះ គប់រកនូវភរិយាអ្នកដទៃខ្លះ និយាយកុហកខ្លះ ដឹកនាំបុគ្គលដទៃដើម្បីហេតុនោះខ្លះ ហេតុនេះប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខអស់កាលដ៏អង្វែងដល់បុគ្គលនោះឬទេ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះ ដូចម្តេច ទោសៈកាលកើតឡើង ក៏កើតឡើង ក្នុងសន្តាននៃបុរស ដើម្បីជាប្រយោជន៍ ឬដើម្បីមិនជាប្រយោជន៍ទេ។ បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីមិនជាប្រយោជន៍ទេ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះជាអ្នកប្រទូស្តត្រូវ ទោសៈគ្របសង្កត់ មានចិត្តត្រូវទោសៈរួបរឹត រមែងសម្លាប់នូវសត្វមានជីវិតខ្លះ រមែងកាន់យកទ្រព្យរបស់បុគ្គលដទៃ ដែលគេមិនបានឲ្យខ្លះ គប់រកនូវភរិយាអ្នកដទៃខ្លះនិយាយកុហកខ្លះដឹកនាំបុគ្គលដទៃដើម្បីហេតុនោះខ្លះ ហេតុនេះប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលជាអង្វែង ដល់បុគ្គលនោះឬទេ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសំគាល់ហេតុនោះ ដូចម្តេច មោហៈ កាលកើតឡើងក៏កើតឡើងក្នុងសន្តាននៃបុរសដើម្បីជាប្រយោជន៍ឬ ដើម្បីមិនជាប្រយោជន៍ទេ។ បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីមិនជាប្រយោជន៍ទេ។ ម្នាលកាលាមក្សត្រិយ៍ចុះបុរសបុគ្គលនេះ ជាអ្នកវង្វេងត្រូវមោហៈគ្របសង្កត់មានចិត្តត្រូវមោហៈរួបរឹត រមែងសម្លាប់សត្វមានជីវិតខ្លះ កាន់យកទ្រព្យរបស់បុគ្គលដទៃដែលគេមិនបានឲ្យខ្លះ គប់រកនូវភរិយាអ្នកដទៃខ្លះនិយាយកុហកខ្លះ បបួលបុគ្គលដទៃដើម្បីហេតុនោះខ្លះ ហេតុនេះប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដើម្បីសេចក្តីទុក្ខអស់កាលជាអង្វែងដល់បុគ្គលនោះឬទេបពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះ ដូចម្តេច ធម៌នេះជាកុសល ឬជាអកុសល។ ជាអកុសលព្រះអង្គ។ ជាធម៌ប្រកបដោយទោសឬមិនប្រកបដោយទោសទេ។ ជាធម៌ប្រកបដោយទោសព្រះអង្គ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀលព្រះអង្គ។ ធម៌ទាំងនេះ ដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ដើម្បីសេចក្តីទុក្ខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនោះដូចម្តេចទៅវិញ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទាន បរិបូណ៌ហើយរមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ យើងខ្ញុំក៏យល់ក្នុងដំណើរនោះដូច្នោះដែរ។ ម្នាលកាលាមក្សត្រិយ៍ តថាគតបានសំដែង នូវហេតុនោះដូច្នេះហើយថា ម្នាលកាលាមក្សត្រិយ៍ អ្នកចូរមកអ្នកកុំប្រកាន់ ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុ ដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរុយផ្សេងៗ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យថាសមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរ ជឿ កុំប្រកាន់ដោយគិតថា សមណៈ (នេះ) ជាគ្រូរបស់យើង ម្នាលកាលាមក្សត្រិយ៍ កាលណាបើអ្នកដឹងដោយខ្លួនឯងថា ធម៌ទាំងនេះ ជាអកុសល ធម៌ទាំងនេះប្រកបដោយទោស ធម៌ទាំងនេះ

ដែលអ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះ ដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ ក្នុងកាលនោះអ្នកត្រូវលះបង់ចោលចេញ ពាក្យណាដែលតថាគតសំដែងហើយពាក្យនោះតថាគតពោលហើយ ព្រោះអាស្រ័យ នូវហេតុនេះ ដោយប្រការដូច្នេះ ម្នាលកាលាមក្សត្រិយ៍ អ្នកចូរមក អ្នកកុំប្រកាន់ ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរុយផ្សេផ្សំ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្ត តាមការពិនិត្យថាសមនឹងសេចក្តីយល់ឃើញកុំប្រកាន់ដោយយល់ថា មានសភាពគួរ (ជឿ) កុំប្រកាន់ដោយគិតថា សមណៈ (នេះ) ជាគ្រូរបស់យើងម្នាលកាលាមក្សត្រិយ៍ កាលណាបើអ្នកដឹង ដោយខ្លួនឯងថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះ មិនមានទោស ធម៌ទាំងនេះ ដែលអ្នកប្រាជ្ញសរសើរ ធម៌ទាំងនេះ ដែលបុគ្គលសមាទានពេញលេញហើយ ប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ម្នាលកាលាមក្សត្រិយ៍ ក្នុងកាលនោះ អ្នកទាំងឡាយ ចូរដល់នូវធម៌ទាំងនោះហើយនៅ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសំគាល់ហេតុនោះ ដូចម្តេច អលោភៈ កាលកើតឡើង ក៏កើតក្នុងសន្តានរបស់បុរស ដើម្បីជាប្រយោជន៍ ឬមិនជាប្រយោជន៍ទេ។ ដើម្បីជាប្រយោជន៍ព្រះអង្គ។

ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកមិនល្មោភ មិនត្រូវសេចក្តីលោភគ្របសង្កត់ មានចិត្តមិនត្រូវសេចក្តីលោភរួបរឹត មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យមិនគប់រកភរិយាអ្នកដទៃ មិននិយាយកុហក ទាំងមិនបានដឹកនាំអ្នកដទៃ ដើម្បីហេតុនោះ តើហេតុនេះប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ដល់បុគ្គលនោះដែរឬ។ យ៉ាងហ្នឹងហើយព្រះអង្គ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសំគាល់ហេតុនោះ ដូចម្តេច អទោសៈ កាលកើតឡើង ក៏កើតឡើងក្នុងសន្តាន របស់បុរសដើម្បីជាប្រយោជន៍ ឬដើម្បីមិនជាប្រយោជន៍ទេ។ ដើម្បីជាប្រយោជន៍ព្រះអង្គ។

ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកមិនប្រទូស្ត មិនត្រូវទោសៈគ្របសង្កត់ មានចិត្តមិនត្រូវទោសៈរួបរឹត មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យមិនគប់រកភរិយាអ្នកដទៃ មិននិយាយកុហក ទាំងមិនបានដឹកនាំបុគ្គលដទៃ ដើម្បីហេតុនោះ តើហេតុនេះ ប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលជាអង្វែងដល់បុគ្គលនោះដែរឬ។ យ៉ាងហ្នឹងហើយព្រះអង្គ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសំគាល់ហេតុនោះ ដូចម្តេច អមោហៈ កាលកើតឡើងក៏កើតឡើងក្នុងសន្តាន របស់បុរសដើម្បីជាប្រយោជន៍ ឬដើម្បីមិនជាប្រយោជន៍ទេ។ដើម្បីជាប្រយោជន៍ព្រះអង្គ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះជាអ្នកមិនវង្វេង មិនត្រូវមោហៈគ្របសង្កត់ មានចិត្តមិនត្រូវមោហៈរួបរឹត មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ មិនគប់រកភរិយាអ្នកដទៃ មិននិយាយកុហក ទាំងមិនដឹកនាំបុគ្គលដទៃដើម្បីហេតុនោះ តើហេតុនេះប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលអង្វែងដល់បុគ្គលនោះដែរឬ។ យ៉ាងហ្នឹងហើយព្រះអង្គ ម្នាលកាលាមក្សត្រិយ៍ អ្នកសំគាល់ហេតុនោះ ដូចម្តេចធម៌នេះជាកុសល ឬអកុសល ជាកុសលព្រះអង្គ ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ។ មិនប្រកបដោយទោសទេព្រះអង្គ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ។ ជាធម៌ដែលអ្នកប្រាជ្ញសរសើរព្រះអង្គ។ ធម៌ដែលបុគ្គលសមាទានពេញលេញហើយ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនោះ ដូចម្តេចទៅវិញ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលបុគ្គលសមាទានពេញលេញហើយ ប្រព្រឹត្ត

ទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ យើងខ្ញុំក៏យល់ក្នុងដំណើរនោះដូច្នោះដែរ។

ម្នាលកាលាមក្សត្រិយ៍ តថាគត បានសំដែងនូវហេតុនោះ ដូច្នេះហើយថា ម្នាលកាលាមក្សត្រិយ៍អ្នកចូរមក អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា អ្នកកុំប្រកាន់តាមពាក្យបរម្បរា អ្នកកុំប្រកាន់ ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ជំរួយផ្សៀផ្សំ កុំប្រកាន់ដោយត្រិះរិះ តាមអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យថាសមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថាមានសភាពគួរ (ជឿ) កុំប្រកាន់ដោយគិតថាសមណៈ (នេះ) ជាគ្រូរបស់យើងម្នាលកាលាមក្សត្រិយ៍ កាលណាបើដឹងដោយខ្លួនឯងថាធម៌នេះជាកុសល ធម៌នេះ មិនប្រកបដោយទោស ធម៌នេះ ដែលអ្នកប្រាជ្ញសរសើរធម៌នេះ ដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ម្នាលកាលាមក្សត្រិយ៍ ក្នុងកាលនោះ អ្នកទាំងឡាយចូរដល់នូវធម៌ទាំងនោះហើយនៅ ហេតុនោះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ ពាក្យនោះ តថាគតបានពោលហើយ ព្រោះអាស្រ័យនូវហេតុនេះ។

ម្នាលកាលាមក្សត្រិយ៍អរិយសាវកនោះឯងមិនមានអភិជ្ឈាមិនមានព្យាបាទ មិនវង្វេង មានសម្បជញ្ញៈ មានសតិយ៉ាងនេះឯង មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី១ ទិសទី២ ទិសទី៣ ទិសទី៤ ក៏ដូចគ្នា ផ្សាយទៅទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូចៗ មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ដោយអាការទាំងពួង ក្នុងទីទាំងពួង មានចិត្តប្រកបដោយករុណា មានចិត្តប្រកបដោយមុទិតា មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី១ទិសទី២ ទិសទី៣ និងទិសទី៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូចៗ មានចិត្តប្រកបដោយឧបេក្ខាជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ដោយអាការទាំងពួងក្នុងទីទាំងពួង។

ម្នាលកាលាមក្សត្រិយ៍ អរិយសាវកនោះឯង មិនមានចិត្តចងពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះមិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តស្អាតយ៉ាងនេះហើយ ជាអ្នកបាននូវអានិសង្ស៤យ៉ាងក្នុងបច្ចុប្បន្ន បើបរលោកមាន ផលនិងវិបាកនៃអំពើទាំងឡាយ ដែលបុគ្គលធ្វើល្អ និងអាក្រក់ក៏មាន លុះអាត្មាអញ ទំលាយរាងកាយ ស្លាប់ទៅ នឹងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ដោយហេតុណា ហេតុនោះជាឋានៈ នេះជាអានិសង្សទី១ ដែលអរិយសាវកនោះបានហើយ។ បើបរលោកមិនមាន ផលនិងវិបាក នៃអំពើដែលបុគ្គលធ្វើល្អ និងធ្វើអាក្រក់ ក៏មិនមានអាត្មាអញរក្សានូវខ្លួន ឲ្យជាបុគ្គលមិនមានពៀរ មិនមានព្យាបាទ មិនមានទុក្ខ មានតែសេចក្តីសុខ ក្នុងបច្ចុប្បន្ននេះឯង នេះជាអានិសង្សទី២ ដែលអរិយសាវកនោះបានហើយ។ បើអំពើអាក្រក់ដែលបុគ្គលធ្វើហើយ ឈ្មោះថា បានធ្វើហើយ អញមិនដែលគិតនូវអំពើអាក្រក់ របស់បុគ្គលណាមួយ សេចក្តីទុក្ខនឹងពាល់ត្រូវនូវអាត្មាអញ ដែលមិនបានធ្វើ នូវអំពើអាក្រក់អំពីទីណាបាន នេះជាអានិសង្សទី៣ ដែលអរិយសាវកនោះបានហើយ។ បើអំពើអាក្រក់ ដែលបុគ្គលធ្វើហើយឈ្មោះថា មិនបានធ្វើ អាត្មាអញនឹងពិចារណាឃើញច្បាស់ នូវខ្លួនដ៏បរិសុទ្ធ ដោយហេតុទាំងពីរ ក្នុងលោកនេះ នេះជាអានិសង្សទី ៤ ដែលអរិយសាវកនោះ បានហើយ។ ម្នាលកាលាមក្សត្រិយ៍ អរិយសាវកនោះឯង មិនមានចិត្តប្រកបដោយពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តបរិសុទ្ធ យ៉ាងនេះ នេះជាអានិសង្ស ៤ យ៉ាង ដែលអរិយសាវកនោះបានក្នុងបច្ចុប្បន្ន។

បពិត្រព្រះដ៏មានព្រះភាគ ហេតុនោះយ៉ាងនេះឯង បពិត្រព្រះសុគត ហេតុនោះ យ៉ាងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវកនោះឯង មិនមានចិត្តប្រកបដោយពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តបរិសុទ្ធយ៉ាងនេះ ទើបអរិយសាវកនោះ បាននូវអានិសង្ស ៤ យ៉ាងក្នុងបច្ចុប្បន្ន បើបរលោកមានផល និងវិបាកនៃអំពើដែលបុគ្គលធ្វើល្អ និងធ្វើអាក្រក់ក៏មាន លុះអាត្មាអញទំលាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ដោយហេតុណា ហេតុនោះ ជាឋានៈនេះជាអានិសង្សទី១ ដែលអរិយសាវកនោះបានហើយ

បើបរលោកមិនមាន ផល និងវិបាកនៃអំពើដែលបុគ្គលធ្វើល្អ និងអាក្រក់ក៏មិនអាត្មាអញនឹងរក្សាខ្លួនឲ្យជាបុគ្គលមិនមានពៀរមិនមានព្យាបាទមិនមានទុក្ខ មានតែសេចក្តីសុខក្នុងបច្ចុប្បន្ននេះឯងនេះ ជាអានិសង្សទី២ ដែលអរិយសាវកនោះបានហើយ។

បើអំពើអាក្រក់ ដែលបុគ្គលធ្វើហើយ ឈ្មោះថាបានធ្វើ អាត្មាអញ មិនដែលគិត នូវអំពើអាក្រក់របស់បុគ្គលណាមួយឡើយ សេចក្តីទុក្ខនឹងពាល់ត្រូវនូវអាត្មាអញ ដែលមិនធ្វើអំពើអាក្រក់អំពីទីណាបាន នេះជាអានិសង្សទី ៣ ដែលអរិសាវកនោះបានហើយ[37]។

បើអំពើអាក្រក់ ដែលបុគ្គលធ្វើហើយ ឈ្មោះថាមិនបានធ្វើ អាត្មាអញនឹងពិចារណាឃើញច្បាស់នូវខ្លួនដ៏បរិសុទ្ធ ដោយហេតុទាំង២ក្នុងលោកនេះ នេះជាអានិសង្សទី៤ ដែលអរិយសាវកនោះបានហើយ។ បពិត្រព្រអង្គដ៏ចម្រើនអរិយសាវកនោះឯង មិនមានចិត្តប្រកបដោយពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តបរិសុទ្ធយ៉ាងនេះ នេះជាអានិសង្ស៤យ៉ាង ដែលអរិយសាវកនោះបានក្នុងបច្ចុប្បន្ន។ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ពេកណាស់ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ថាជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ចាំទុកនូវយើងខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរណៈ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមតទៅ។

[37] សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត កាលាមសូត្រ ភាគ ៤១ ទំព័រ ២១៦-២២៩

# ជំពូក៨
# សប្បុរិសធម៌៧ប្រការ

## ៨.១. ព្រះសម្មាពុទ្ធ ទ្រង់បង្ហាញលក្ខណៈសម្បត្តិរបស់បុគ្គលអ្នកជោគជ័យក្នុងជីវិត និការងារ

**៨.១.១. ធម្មញ្ញុតា** ជាមនុស្សស្គាល់ហេតុ ឬជាអ្នកដឹងធម៌[38]។

ធម្មញ្ញូ គួរដឹងកំណើតហេតុ គ្រប់ប្រភេទគឺហេតុបង្កើតផល ទាំងផែនភពសព្វសត្វសេពឥតសល់ ដឹងមិនដល់ដោយខ្លៅដៅតែស្មាន។ ហេតុនោះឬគឺកម្មដែលកសាង មានពីរយ៉ាងគួរយល់សមុដ្ឋាន កម្មអាក្រក់និងល្អប្រចាំប្រាណ ធ្វើប៉ុន្មានបានប៉ុណ្ណឹងកុំប្រឹងធ្ងល់។ ចិត្តខិលខូចផ្តួចផ្តើមថ្លើមថ្លោសកាច យ៉ាងនេះប្រាជ្ញប្រាប់ថាអកុសល អ្នកណាសាងអ្នកនោះឯងសោយផល ជាប់សកលកាយស្មើដូចស្លែកាន់។ ប្រព្រឹត្តត្រឹមត្រង់ត្រូវផ្លូវសុចរិត នោះបណ្ឌិតហៅថាកុសលក្ខន្ធ ត្រូវត្រង់ត្រាប់ត្រិះគិតឱ្យកើតឆន្ទ គង់ជួបសន្តិសុខសថាពរ។ យើងជាអ្នកស្វែងមគ្គឱ្យជាក់ហេតុ នឹងប្រភេទភូមិផលកុំខ្វល់វរ ឥឡូវនេះលើកកម្មឡើងឧទ្ទរណ៍ ផ្តើមសុន្ទរវាទតខសំណៅ។ សូមករីប្រើជាចេះចំណាន ជួយប្រោសប្រាណពន្យល់ដល់ជនខ្លៅ ក្នុងធម្មញ្ញុតាតាមសំណៅ ប្រោសប្រដៅផុសខាត់អធ្យាស្រ័យ។

**៨.១.២. អត្ថញ្ញុតា** ជាមនុស្សស្គាល់ប្រយោជន៍ ឬស្គាល់សេចក្តី។

អត្ថញ្ញុតា ថាដឹងផល គួរសម្គាល់វាទីវិនិច្ឆ័យ ព្រោះតួហេតុប្រភេទដើមនិស្ស័យ ជាបច្ច័យដូចឧស និងអគ្គី។ ប្រៀបដូចធ្វើអំពីកម្មអាក្រក់ ផលខ្វក់ល្អក់ក៏ដក់ក្នុងឥន្ទ្រិយ អំពល់ចិត្តឥតសុខទុក្ខពេញទី គ្មានវិធីណាថយឱ្យស្រាកស្រាន្ត។ បើធ្វើល្អផលល្អកំដរកាយ ឲ្យសប្បាយសមបែបសេពសុខសាន្ត ក្រក៏ខ្វាត់ខ្សត់ក៏ខ្វាយឆ្ងាយចាកប្រាណ សុខសម្រាន្តរាល់ទិនមិនស្រាកស្រន់។ កាលសុខទុក្ខមកដល់ចូរប្រុងចិត្ត រំឭកគិតរំពឹងដឹងឱ្យទាន់ទាំងគេយើងក្នុងភពរាប់ម៉ឺនពាន់ ទុកតែជាន់សុខតាមជួយតែរាល់គ្នា។ ត្រូវពិនិត្យសមុទ័យទោសទុច្ចរិតដែលបាំងបិទឥតភ្លឺគឺអវិជ្ជា បើជម្រះឱ្យជ្រះពីអង្គា វេទនាគង់ស្ងប់រម្ងាប់កាយ។ កាលចិត្តកាចកើតឡើងយើងលះចេញ ត្រូវបំពេញមេត្តាករុណាផ្សាយ ទើបបានសេពសន្តិសុខសប្បាយ អង្វែងឆ្ងាយតទៅហៅផលល្អ។ ស្គាល់ធម៌ពីរនេះពេញជាស្គាល់ត្រូវ ព្រោះដងផ្លូវត្រូវកើតទ្រព្យរកក្រ ធម្មញ្ញូគួរដឹងថាដើមខ អត្ថញ្ញូលោកសរប្រាប់ថាចុង។ ឯស្គាល់ដើមគឺស្គាល់ប្រធានហេតុ កំណត់ខេត្តខណ្ឌគ្នាជាក្រៅក្នុង ការស្គាល់ផលត្រូវយល់ដល់ស្គាល់ចុង តពីក្នុងតួហេតុប្រភេទចាស់។

**៨.១.៣. អត្តញ្ញុតា** ជាមនុស្សស្គាល់ខ្លួនឯង។

អត្តញ្ញុតាថាស្គាល់ខ្លួន ត្រូវចេះសួនស្ងប់ស្ងៀមចៀមកេរ្តិ៍ខ្មាស ប្រុងប្រយ័ត្នមារយាទជាតិពុទ្ធសាសន៍មើលឱ្យច្បាស់ច្បាប់ធម៌ប្រដៅកាយ។ ឱ្យដឹងខ្លួនដោយជាតិត្រកូលកើត ពូជកំណើតក្រុងស្រែសែស្រឡាយ សម្បូណ៌ទ្រព្យសម្បត្តិឬខ្សត់ចាយ កំណត់កាយឱ្យជាក់ជាធម្មតា។ លុះកំណត់ដឹងជាតិដឹងកំណើត ដែល

---

[38] សុត្តន្តបិដក ភាគ ១៩ ទំព័រ ២៩៩

យើងកើតនៅក្នុងពូជពង្សណា ហើយដាក់ទុកខ្លួនប្រាណប្រើកិរិយា ឱ្យសមតាមអត្តាជាការគួរ។ កុំធ្វើបែបទូកមាត់ចង្អៀតព្រែក វាកន្ទែកចុកចែវមិនត្រូវជួរ មួយគប្បីកំណត់វិជ្ជាគួរ ឱ្យស្គាល់ខួរក្បាលខ្លួនជាល្ងង់ឆ្លាត។ បើដឹងខ្លួនថាខ្លួនជាមនុស្សល្ងង់ កុំទ្រនង់ទ្រនើសទ្រើសហួសខ្នាត លើផែនដីក្រអ្វីប្រាជ្ញផ្ទៀវឆ្លាត ត្រូវសង្វាតយកជាគ្រូអាចារ្យ។ តែបន្ទំចិត្តខ្លួនខ្លាំងវាខ្លៅ អាចហ្មងសៅសូន្យសព្វទ្រព្យខ្លឹមសារ បើសម្បូណ៌សម្បត្តិបរិវារ កុំឱឡារិកព្រើលមើលងាយគេ។ បូរាណពោលថាបើឈើរលំ ដើរកន្លងទាំងគុម្ពពុំអីទេ បើមនុស្សដួលកុំអាលកន្លងគេ ត្រូវគ្នាន់គ្នេរគេមនុស្សដូចគ្នាដែរ។ បើវ័យខ្លួនមិនទាន់បរិបូណ៌ច្រើន កុំព្រហើនហួសមាឌជាតិកូនខ្មែរ ចំណែកអ្នកអាយុច្រើនក៏ដែរ ត្រូវបង្វែរសន្តានស្មានមើលមាឌ។ ឱ្យសមភូមិតាមភាពស្ទាបស្ទង់វ័យ ទើបប្រពៃពេញវង្សពូជពង្សជាតិ មានចំណេះត្រូវចេះប្រើមារយាទ កុំឃ្លេងឃ្លាតក្លាយខឹងស្រវឹងខ្លាំង។

**៨.១.៤. មត្តញ្ញុតា** ជាមនុស្សស្គាល់ប្រមាណក្នុងភោជននិងស្គាល់ប្រមាណរបស់ដែលខ្លួនមាន។

មួយគួរចេះប្រមាណមាត់បរិភោគ កុំកញ្ច្រោកស៊ីជ្រុលទ័លចាក់ច្រាស ល្ងឹងជាថ្នាំផ្អែមផ្អូមហើមពោះណាស់ ប្រាជ្ញប្រកាសប្រាប់ផ្លូវត្រូវប្រយត្ន។ គួរជ្រើសរើសចំណីកុំធីខុស ឱជារសពិសាវាឈឺថ្កាត់ យ៉ាងផ្អកផ្អូរខ្ទូរខ្មោះទាស់បញ្ញត្តិ ភ្លក់មួយមាត់ភ្លាត់ខុសវាចុះផ្ទៃ។ មួយឱ្យចេះប្រយត្នសម្បត្តិទ្រព្យ កុំទម្លាប់ចាយធំពុំប្រពៃ ប្រាក់រាប់សែនមែនបើមិនចេះលៃ គង់មានភ័យដល់កាយស្តាយកម្លាំង។ ឯការរកទ្រព្យធនធូន់គំនិត ត្រូវព្រួយគិតប្រើកាយនឿយហត់ខ្លាំង ឃ្លាតប្រពន្ធឃ្លាតកូនខ្លួនស្គមស្គាំង សែងសុរិយំចាំងក្បាលហាលទាំងកាយ។ មានស្រីខ្លះប្រុសខំរកគគ្រេង ខ្លួនលួចលេងតែល្បែងតាមសប្បាយ គ្មានអាណិតគិតប្តីនឿយព្រួយកាយ តែប្រុសខ្លះជះចាយទ្រព្យដូចគ្នា។ កាលបើមានឱកាសគួរល្មមទៅ ដើរសំដៅរកបនមិនវង់វា ចំពូកខ្លះស្រុះស្រួលបបួលគ្នា ព្រមទាំងបុត្តកិរិយាចរចូលវង់។ គួរសង្វេគពេកណាស់នឹកឡើងហើយ មិនសមឡើយពួកយើងវង្វេងល្ងង់ ប្រឹងបង្ហិនធនធានគ្មានឱ្យគង់ ហាក់បម្រុងចង់តែឱ្យអស់ទៅ។ ឈ្មោះថាទ្រព្យទ្រនាប់ដៃអ្នកចាយ ចិញ្ចឹមកាយកាលឃ្លានគ្មានខុសត្រូវ បើអ្នកមានគំនិតគិតរាក់ជ្រៅ រើសតែផ្លូវឱ្យគុណចាយធនធាន។ ដូចចេញទុនចូលហ៊ុនជួញលក់ដូរ គួរបង្ហូរចាយចុះព្រោះចង់មាន បួនយ៉ាងនេះហៅចេះប្រើធនធាន បើសល់មានទៀតទុកបង្ការកាយ។ មួយឯស្រាអាភៀនញៀនបង្ងៀរ គួរលះវៀរខំភៀសចៀសឱ្យឆ្ងាយ នឹងវិនាសសម្បត្តិទ្រព្យខ្ចាត់ខ្ចាយ ផ្លូវអបាយមុខទុកអាត្មា។ ទោះមានច្រើនបើភ្លើនភ្លេចលៃលក ទ្រព្យដែលរកមកនោះគង់កាលណាទ្រព្យមានតិចប្របិចចាយហួសមាត្រា មិនប្រមាណអាត្មាផ្ងារច្រេងាង។ សូមដាស់តឿនសតិជនប្រុសស្រីដោយសេចក្តីសុចរិតឥតអួតអាង ពន្យល់ផ្លូវប៉ុណ្ណោះជាបែបយ៉ាង នឹងសូមអាងឧប្រាំតាមបរិយាយ។

**៨.១.៥. កាលញ្ញុតា** ជាមនុស្សស្គាល់កាល ស្គាល់ពេលវេលា ស្គាល់កាលៈទេសៈ។

កាលញ្ញុតា ក្នុងអត្ថថាឱ្យស្គាល់កាលទាំងឡាយ មានសេចក្តីវៀងរាយទូលាយឆ្ងាយ អធិប្បាយពីកាលយូរនិងឆាប់។ បើកាលមានអាសន្នបន្ទាន់ចង់ កុំបង្អង់ឱ្យយូរគួរប្រញាប់ ទើបទាន់ចិត្តឥតទាស់ថ្លោះចំណាប់បូរាណប្រាប់ស្តាប់ចុះពីរោះពិត។ត្រូវលៃកាលមុនក្រោយឱ្យជាក់ច្បាស់កាលរហ័សគួររហន់ឱ្យទាន់គិត បើកាលយូរគួរយូរធូរគំនិតចូលប្រព្រឹត្តឱ្យត្រូវផ្លូវប្រើការ។មានភាសិតប្រតិដ្ឋជាអត្ថ ថាកាលានុរូបំជាខ្លឹមសារ អ្នកហាត់

ចិត្តគួរិះរិចារណ៍ ស្មានមើលការធូរតឹងដឹងឱ្យទាន់។ ឯកិរិយាកាលនោះមានពីរយ៉ាង ជាតឹកតាងតាំងទុកតាមលក្ខណ៍ខណ្ឌ គឺកាលចរកាលប្រចាំបម្រុងកាន់ ជាកំណាន់គ្រប់ទិនមិនខុសទេ។ កាលប្រចាំចាត់ជាកាលរំឭក គឺពេលព្រឹកថ្ងៃត្រង់សាយណ្ហេ ក្នុងរវាងចន្លោះនោះគឺវេលាចរវិញជេញរផ្ទេរសម័យ។ កិច្ចណាកូវត្រូវធ្វើប្រចាំកាល ដូចចម្អិនអាហារយើងអាស្រ័យ ត្រូវរករៀបរួសរាន់ឱ្យទាន់ថ្ងៃ ចាត់សំចៃភោក្តាតាមការគួរ។ លុះឆ្អែតឆ្អល់ស្កប់ស្កល់គិតកុំភ្លេច ត្រូវចាប់កិច្ចការធ្វើកុំខ្មោះខ្មួរ បើហត់ពេកសម្រាកឱ្យតែគួរ កុំផ្កាកផ្អែកភ្នាក់ស្លួតម្រង់ខ្នង។ លង់លុះទាល់ដល់កាលពេលថ្ងៃត្រង់ សឹមបង្អង់បង្អន់កិច្ចការផង រកអាហារបរិភោគតាមបំណង បំបាត់ស្រេកឃ្លានផងដែលនឿយហត់។ ដល់បរិភោគស្រេចស្រាប់ចាប់ការធ្វើ ចូរខំរើល្បើល្បឹងប្រឹងអំណត់ យកកម្លាំងច្បាំងការកុំគិតហត់ ស៊ូទ្រាំអត់ដល់បច្ចុសម័យ។ ហើយងូតទឹកដុះកាយដែលស្មោកគ្រោក រួចបរិភោគភោជនតាមវិស័យ យ៉ាងនេះហៅកិច្ចការប្រចាំថ្ងៃ ក្រៅពីនោះកែខៃជាការចរ។ ដូចជាផ្ទះផ្ទុកតែគ្រឿងក្រខ្វក់សម្រាមដក់កកក្តាំងទាំងគំនរ គួរបោសប្រាសដុសខាត់កុំទុកគរ ប្រើមិនប្រើកៃវរវល់រក។ ទ្រព្យមាសប្រាក់ទុកដាក់តាមវគ្គស្មើ ត្រូវការប្រើមានព្រមតាមចិត្តភ្នក ណាមិនប្រើទើតាំងដោយកៀនញក គន់មិនទាស់ខ្វះយើងរកយកបានងាយ។ ហើយមើលកាលហាត់កូនតាមក្បួនខ្នាត ឱ្យឆ្លៀវឆ្លាតវាងវៃមិនរាយមាយ ពន្យល់ផ្លូវត្រូវខុសឱ្យផ្គុះផ្លាយ ការវិនាសនិយាយឱ្យចូលចិត្ត។ ធម្មតាពត់ព្រឹក្សាលតាវល្លិ ត្រូវពត់ពាល់ពីខ្ចីទើបទន់ស្និទ្ធ ការហ្វឹកហាត់កូនចៅឱ្យត្រូវចិត្ត គួរប្រៀនប្រិតពីតូចទើបស្ទាត់ច្បាស់។

**៨.១.៦. បរិសញ្ញុតា** មនុស្សស្គាល់ក្រុមមនុស្ស ស្គាល់និស្ស័យ ស្គាល់ការចេះដឹងរបស់មនុស្ស (ស្គាល់បរិស័ទ)។

បរិសញ្ញុតាអនុសន្ធិ៍ ប្រែតាមយល់ថាស្គាល់ប្រជុំជន គប្បីគន់គិតមើលឱ្យមាំមួន។ មនុស្សល្អមែនគង់មានអធ្យាស្រ័យ ក្នុងហទ័យវត្ថុទុកជាក្បួន ចូលត្រង់ណាចូលចុះចេះចៀមខ្លួន មិនឱ្យស្អួនស្ទាត់ហួសជ្រលួសកាល។ ធម្មតាបង្កើតកំណើតមនុស្ស មានជាន់ខ្ពស់ជាន់ទាបជាន់កណ្តាល មានទាំងប្រាជ្ញទាំងព្រើលទាំងខ្លួរស្រាល ទាំងស្របាលៗគ្នាពេញជានី។ មនុស្សគ្រប់ជាន់គួរសម្ព័ន្ធមេត្រីចិត្ត ចងជាមិត្តជាភក្តិសាមគ្គី តែឱ្យស្គាល់កិរិយាប្រវេណី រើសវិថីណាល្អប្រព្រឹត្តតាម។ មារយាទអធ្យាស្រ័យកាយវាចា លោកនិយមយ៉ាងណាក្នុងទីស្នាម ត្រូវសម្រួលផ្គួលដោយកុំឱ្យជាម ទើបសមតាមឋានៈទុកដាក់អង្គ។ ទោះជាទាបក៏មិនទាបពីកំណើត ប្រើកិរិយាឱ្យឆើតកុំលះបង់ ត្រូវស្គាល់សព្វបញ្ញោរឬស្វរត្រង់ កណ្តាលវង្សចំណោមប្រជុំជន។ សំឡេងប្រាប់សម្រែកដូចក្អែកបូល មារយាទប្រាប់ត្រកូលចូរប្រុងគន់ អធ្យាស្រ័យសមគួរឬស្នេរជន ផ្សាយចេញឯងឲ្យគន់ឃើញសខ្មៅ។ ទោះរូបឆោមលោមពណ៌ល្អស្អាងស្អាត តែមារយាទខុសខ្នាតគេថាខ្លៅ ស្រឡាញ់ខ្លួនស្ងួនកាយកុំឱ្យសៅ អាក្រក់ល្អក៏នៅតែលើខ្លួន។

**៨.១.៧. បុគ្គលញ្ញុតា** ជាមនុស្សស្គាល់បុគ្គល គឺស្គាល់បុគ្គលដែលអាស្រ័យនៅជាមួយគ្នា ឬរួមការងារ ឬជាអ្នកនៅក្រោមបការគ្រប់គ្រង ឬជាមេដឹកនាំ។

បុគ្គលញ្ញូតា មានអត្ថាធិប្បាយដោយនិយម ប្រែថាស្គាល់ចរិតជនតូចធំ គួរសមាគមឬគេចមិនសេព គប់។ ឯមនុស្សនៅក្រុងកំលុងខេត្ត មានប្រភេទពីរយ៉ាងអាងប្រារព្ធ គឺពាលកាចនិងប្រាជ្ញប្រាប់ឱ្យគ្រប់ មិនទាន់គប់គាស់កាយផ្សាយចេញឯង។ ឯសញ្ញាតិជនពាលចណ្ឌាលទាប គ្មានសុភាពរៀបរយគួរឱ្យក្រែង មានវិស័យចិត្តស្មគ្រជាអ្នកល្បែង ច្រើនសម្ដែងអាការកាចតក់ម៉ក់។ ផ្លូវវិនាសរូបកាយអបាយមុខ ទទួលផ្ទុកគ្រប់យ៉ាងខាងអាក្រក់ អណ្តាតផ្ទាត់បទករធេកុហក វៀចកូក់មុខងប់គ្រប់ប្រការ។ តែទៅស្និទ្ធផ្ចិតអង្គបង់មារយាទ ថោកថយជាតិពូជពង្សវង្សាវតារ គួរតែចៀសកៀសកាយឆ្ងាយឱចារ ទើបជាឧបការគុណដល់កាយ។ ឯបណ្ឌិតត្រង់គិតមិនចេះខុស ជនស្រីប្រុសត្រេងត្រាប់គង់សប្បាយ នឹងថ្កុំថ្កើងកេរ្តិ៍ឈ្មោះខ្ពស់វែងឆ្ងាយ បានសុខចិត្តសុខកាយគ្រប់ប្រការ។ ពោលក៏ល្អធ្វើក៏ល្អិតគិតក៏ត្រូវ សំដៅផ្លូវសន្តិសុខសង្ខារ វាងវិបីកាឡីមិច្ឆាចារ សាងតែការបុណ្យទានគ្មានខ្មោះខ្មរ។ ត្រឹមប៉ុណ្ណេះណែនាំឱ្យឃើញហេតុ គ្រឿងសង្កេតជាតិមនុស្សជា ឬជួក្នុងលោកនេះនឹងគប់គប្បីសួរ ឃើញសមគួរល្អពិតសឹមផ្ចិតអង្គ។ ធម៌ខនេះជាច្បាប់សម្រាប់ប្រើ ឲ្យសប្បុរសរើកផ្លូវត្រង់ ក្នុងរឿងសន្ថវមិត្តចិត្តចំណង ឲ្យផូរផង់យឺនយូរអង្វែងកប្ប។ មុននឹងគប់គប្បីមើលមុខមិត្ត ឲ្យឃើញពិតតាមពុទ្ធដីកាប្រាប់ អាក្រក់ល្អសខ្មៅដៅបានធាប់ មិនខុសច្បាប់បណ្ឌិតដូចសម្ដែង។ បើមនុស្សពាលតែពោលយល់ប្រភេទឱ្យឃើញហេតុឧបាយដែលក្លាយក្លែង គួរជ្រាបអត្ថរសព្រះពុទ្ធថ្លែង កុំអែងសង្ស័យអាល័យធ្វល់។ គប់ជនល្អគង់ល្អប្រសើរធើត អាចឱ្យកើតសុភអត្ថពិភឮផល គប់ជនអាក្រក់ចិត្តល្អក់ក្រខ្វក់ខ្វល់ ទុក្ខដាបដល់សកលកាយរាល់គ្នា។ មនុស្សយើងនេះឧត្តមដោយកំណើត មិនមែនកើតមកភ្លាមក៏ខូចជា លុះប្រឞល់ចូលជាប់ជាតិពាលា ខូចនិងជាតោងស្និតចិត្តអស់ស្អាត ។ បុគ្គលាធិដ្ឋានមានក្នុងអត្ថ បោតកោកូនសត្វសេកជាអាទិ៍ កាលញាស់ឡើងដំបូងគ្មានខ្វះខាត ចិត្តក៏ស្អាតបរិសុទ្ធឥតឃោរឃៅ។ លុះខ្យល់បក់ធក់បាត់សាត់ចាកទី ក៏ព្រាត់ពីសម្បុកបែកគ្នាទៅ សេកមួយនោះជ្រុលធ្លាក់លើលំនៅ ព្រះតាបសរើសទៅថែរក្សា។ សេកមួយទៀតវាតផាត់សាត់ទៅដល់ ទីមណ្ឌលសម្នាក់ពួកចោរា ចោររើសទៅចិញ្ចឹមដោយមេត្តា ថ្នមរក្សាឥតល្ហែថៃទាំទុក។ សេកដែលនៅសម្នាក់ព្រះតាបស ចិត្តសប្បុរសរកផលខ្វល់ចង់សុខ សាងសន្សំសុចរិតបិទផ្លូវទុក្ខ ឆ្ពោះតាំងមុខតាមមគ្គលោកអ្នកប្រាជ្ញ។ សេកដែលនៅនឹងចោរចិត្តអាក្រក់ រៀនតែធក់នឹងលួចឬស្បាកាច ចេះខិលខូចឱ្យដូចចោរកំណាច ភ្លាឥតខ្លាចឥតគិតជីវិតក្ស័យ។ ចូរមើលចុះតែជាតិសត្វតិរច្ឆាន បើគប់ពាលមិនខានខូចនិស្ស័យ បើគប់ប្រាជ្ញៗប្រៀនព្រះធម៌ថ្លៃ អធ្យាស្រ័យប្រែតាមស្នាមនោះហោង។

## ៨.២. បុញ្ញកិរិយាវត្ថុ១០ប្រការ

វត្ថុដែលបុគ្គលគួរប្រតិបត្តិចំពោះមនុស្សជាតិដូចគ្នា និងចំពោះសត្វមានជីវិត

**៨.២.១. ទានមយៈ** ការលះបង់របស់ដែលខ្លួនមានជួយដល់អ្នកដទៃដោយការបូជា ឬជួយសង្គ្រោះ។ កិរិយាឲ្យនូវវត្ថុដ៏គួរដល់បុគ្គលដែលគួរឲ្យ ដោយសេចក្ដីសង្គ្រោះឬបូជាគុណ គឺឲ្យដល់មនុស្សកំសត់ ឬបូជាដល់លោកអ្នកដ៏មានសីល និងមាតាបិតាជាដើម ហៅថា ទាន។

**៨.២.២. សីលមយៈ** រក្សាខ្លួនឲ្យតាំងនៅតែក្នុងសេចក្តីល្អ សេចក្តីបរិសុទ្ធ។

កិរិយាវៀរចាកអំពើអាក្រក់ដែលកើតអំពីកាយឬវាចាមានវៀរចាកបញ្ចវេរាទាំង៥ជាដើមហៅថាសីល។

**៨.២.៣. ភាវនាមយៈ** ព្យាយាមចម្រើនសេចក្តីល្អ ចម្រើនសុចរិត ចម្រើនសីលធម៌ ចម្រើនគុណធម៌ ចម្រើនសុជីវធម៌ក្នុងចិត្តជាប្រក្រតី។

កិរិយាធ្វើចិត្តឲ្យស្ងប់រម្ងាប់ ដោយសមថវិធីត្រឹមឧបចារ វិបស្សនាវិធីត្រឹមអនុលោក ហៅថា ភាវនា។

**៨.២.៤. អបចាយនមយៈ** ជាមនុស្សមានសេចក្តីគោរព ឱនលំទោន ស្គាល់ខ្ពស់ស្គាល់ទាប ដឹងចាស់ទុំ។

កិរិយាបន្ទន់អស្មិមានះ ដែលមានក្នុងចិត្តដោយសេចក្តីកោតក្រែងដល់បុគ្គលដែលគួរកោតក្រែង គឺជនដែលចម្រើនដោយជាតិ ដោយវ័យ និងដោយគុណ ហៅថា អបចាយនៈ។

អបចាយនកម្មមានន័យថា ការឱនលំទោន មាន៥យ៉ាងគឺ ៖

| | |
|---|---|
| ១. អភិវាទនំ | ការក្រាបសំពះ |
| ២. បច្ចុដ្ឋានំ | ការក្រោកទទួល |
| ៣. អាសនទានំ | ការឲ្យកន្លែងទទួល |
| ៤. មគ្គទានំ | ការបៀសផ្លូវឲ្យ |
| ៥. សក្ការកុការាមានបូជា | ធ្វើសក្ការៈបូជា |

**៨.២.៥. វេយ្យាវច្ចមយៈ** ជាមនុស្សចេះជួយយកអាសារអ្នកដទៃចេះជួយខ្វល់ខ្វាយទុក្ខធុរៈគ្នា។

កិរិយាជួយខ្វល់ខ្វាយក្នុងកិច្ចរបស់អ្នកដទៃ ដែលគួរធ្វើដោយកាយ ឬវាចា ហៅថា វេយ្យាវច្ចៈ។

**៨.២.៦.បត្តិទានមយៈ**ជាមនុស្សចេះចែករំលែកនូវអំពើល្អព័ត៌មានល្អរឿងរ៉ាវដែលមានប្រយោជន៍ដល់គ្នា និងគ្នា។

កិរិយាឲ្យនូវចំណែកបុណ្យ ដែលខ្លួនបានធ្វើហើយដល់អ្នកដទៃដោយចិត្តមេត្រី ដើម្បីឲ្យគេប្រព្រឹត្តត្រេកអរតាម ហៅថា បត្តិទានៈ។

**៨.២.៧. បត្តានុមោទនាមយៈ** ជាមនុស្សដែលមានចេះទទួលយកអំពើល្អពីអ្នកដទៃ ទទួលយកព័ត៌មានល្អៗ រឿងរ៉ាវដែលមានប្រយោជន៍ពីអ្នកដទៃ។

កិរិយាអនុមោទនាត្រេកអរ តាមសេចក្តីល្អរបស់អ្នកដទៃ ដោយចិត្តដែលប្រាសចាកសេចក្តីឫស្យា ឈ្នានីស ហៅថា បត្តានុមោទនា។

**៨.២.៨. ធម្មទេសនាមយៈ** ជាមនុស្សចេះរំលែកចំណេះដឹង ដែលជាចេះណេះដឹងនាំមកសុខសន្តិភាព ចំណេះដឹងនាំមកនូវសេចក្តីសេចក្តីបរិសុទ្ធ ចេះដឹងនាំឲ្យកើតប្រយោជន៍ ឲ្យកើតសាមគ្គី។

កិរិយាណែនាំបង្រៀនប្រដៅអ្នកដទៃ ឲ្យចេះចំដែលឥតទោស ឬពន្យល់ក្នុងផ្លូវធម៌ឲ្យស្គាល់កិច្ចគួរធ្វើ និងមិនគួរធ្វើ ដែលប្រព្រឹត្តទៅដើម្បីសម្បត្តិសួគ៌និងព្រះនិព្វាន ហៅថា ធម្មទេសនា។

**៨.២.៩. ធម្មស្សវនមយៈ** ជាមនុស្សចេះទទួលយកព័ត៌មានចំណេះដឹងល្អៗ ចេះស្តាប់ពាក្យមានប្រយោជន៍ និងស្គាល់ពាក្យដែលគ្មានប្រយោជន៍ ដាក់ចុះនៅសេចក្តីប្រកាន់ហើយទទួលយកចំណេះដឹងពីក្រៅបន្ថែម។

កិរិយាតាំងចិត្តស្តាប់ធម៌ដោយប្រុង ឲ្យចេះចាំធម៌អាចំបាន ហៅថា ធម្មស្សវន។

**៨.២.១០. ទិដ្ឋុជុកម្មយមៈ** ជាមនុស្សចេះតម្រែតម្រង់នូវការយល់ឃើញរបស់ខ្លួន ចេះសម្របការយល់ឃើញរបស់ខ្លួនទៅនឹងអ្នកដទៃ ដោយមិនមានមានះរឹងត្អឹងប្រកាន់យកត្រូវតែម្នាក់ឯង តម្រង់ការយល់ឃើញរបស់ខ្លួនឲ្យបានត្រឹមត្រូវត្រង់។

កិរិយាធ្វើទិដ្ឋិ សេចក្តីយល់ឃើញរបស់ខ្លួនត្រង់តាមគន្លងធម៌ដែលពិតមែន ហៅថា ទិដ្ឋុជុកម្ម។

បណ្តាបុញ្ញកិរិយាវត្ថុទាំង១០ប្រការនេះ ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញអំពី បច្ចេកទេសនៃការជួយសង្គ្រោះអ្នកដទៃ និងសង្គមជាតិទាំងមូល។ មេរៀនទាំង១០ចំណុចនេះ ព្រះសម្មាសម្ពុទ្ធទ្រង់បានបង្រៀនអំពីវិធីងាយៗក្នុងបង្កើនពុទ្ធិមនុស្សលោក ឲ្យមានចិត្តសប្បុរស ដើម្បីជួយមនុស្សជាតិ ឬសង្គមទាំងមូលទៅបានមានគ្រប់ទម្រង់ដែលមនុស្សគ្រប់គ្នាមានលទ្ធភាពធ្វើបាន ព្រោះនៅក្នុងព្រះពុទ្ធដីកានេះ បង្ហាញយ៉ាងច្បាស់ថាការធ្វើបុណ្យ និងសេចក្តីល្អចំពោះមនុស្សជាតិដូចគ្នា និងសព្វសត្វទូទៅ មានរឿងខ្លះមិនមែនសុទ្ធតែត្រូវប្រើលុយ ប្រើបាយទឹកនំចំណីត្រីសាច់អ្វីឡើយ ឲ្យតែមនុស្សមានបញ្ញាឆ្លាតវៃ គឺអាចធ្វើសេចក្តីល្អបានយ៉ាងងាយស្រួល ហើយត្រឹមត្រូវតាមពុទ្ធឱវាទយ៉ាងច្បាស់ច្បងបំផុត។ មានប្រជាជនខ្មែរ ជាច្រើនដែលគំនិតដុះស្នឹម ពីមួយជំនាន់ទៅមួយជំនាន់ ឲ្យតែនិយាយអំពីការធ្វើបុណ្យ តែងតែគិតថាអស់លុយ រហូតគេបង្កើតជាពាក្យបែបអសីលធម៌ថា ធ្វើបុណ្យអស់លុយ ធ្វើបាបបានលុយ ព្រោះពួកគេយល់ថា តោងតែមានប្រាក់ទៅធ្វើបុណ្យទើបកើតបុណ្យ បើគ្មានប្រាក់ទៅធ្វើបុណ្យទេគ្មានអាចកើតទៅជាបុណ្យទេ មានជនអាប់ប្រាជ្ញាមួយចំនួនតែងតែពោលពាក្យបែបនេះនៅក្នុងសង្គមបច្ចុប្បន្ននេះ ព្រោះពួកគេមិនយល់ដឹងអំពីវិធីនៃការធ្វើសេចក្តីល្អ នៅក្នុងព្រះពុទ្ធសាសនាមានលក្ខណៈពិតយ៉ាងណានោះទេ។ នៅក្នុងមេរៀនទាំង១០ប្រការនេះព្រះពុទ្ធជាម្ចាស់បានប្រាប់ពីមធ្យោបាយគ្រប់យ៉ាង ក្នុងការធ្វើបុណ្យ មានទ្រព្យក៏ធ្វើបាន មិនមានទ្រព្យក៏ធ្វើបាន ទាំងមានទ្រព្យក្តីមិនមានទ្រព្យក្តី ដើម្បីកើតទៅជាបុណ្យ គឺអាស្រ័យទៅលើសមត្ថភាពបញ្ញារបស់ជនផ្ទាល់ខ្លួន ដែលប្រើបញ្ញារបស់ខ្លួនមើលឃើញច្បាស់អំពីដំណើរនៃសេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ និងសេចក្តីបរិសុទ្ធនៃចិត្តក្នុងចំណោមការធ្វើបុណ្យទាំងអស់នេះ មានចំណុចមួយគឺដែលពិសេសក្នុងការជួយអ្នកដទៃនោះគឺ ធម្មទេសនាមយបុណ្យ មានន័យថា ការដែលជួយអ្នកដទៃឲ្យមានបញ្ញា មានចំណេះដឹង ចេះពិចារណា ស្គាល់កម្មដែលគួរប្រព្រឹត្ត និងកម្មដែលមិនគួរប្រព្រឹត្ត រឹតតែពិសេសនោះគឺ បង្រៀនមនុស្សឲ្យយល់ដឹងអំពីដំណើរជីវិត ពោលគឺពិចារណារឿយៗនូវជីវិតមិនទៀង ជាទុក្ខ និងអនត្តា ដើម្បីបង្កើននូវគុណភាពរបស់ចិត្ត ក្នុងការរស់នៅត្រៀបទប់ទល់នឹងព្យសនៈ (សេចក្តីវិនាស) ដែលវានឹងកើតឡើងក្នុងដំណាក់កាលណាមួយ។

# ជំពូក៩
# ឱវាទបាតិមោក្ខ

## ៩.១. វិន័យនាំមកនៅសន្តិភាព

នៅក្នុងឱវាទបាតិមោក្ខនេះ គឺជាធម៌សម្រាប់រម្ងាប់បង់នូវអកុសលធម៌ទាំងខាងក្នុង និងខាងក្រៅ។ ខាងក្នុងបានដល់ចិត្ត ធម្មជាតិចិត្តនេះ ជាប្រធាននៃបាតុភូតទាំងឡាយ កុសលកើតឡើងក៏ដោយសារចិត្ត អកុសលកើតឡើងក៏ដោយសារចិត្ត ដើម្បីអាចអប់រំចិត្តបាន គឺត្រូវព្យាយាមហ្វឹកហាត់ លត់ដំ ដោយការប្រើបញ្ញា និងការត្រិះរិះពិចារណាដោយយោនិសោមនសិការ គឺពិចារណាដោយឧបាយនៃប្រាជ្ញា ព្រោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បង្ហាញថា គ្មានធម្មជាតិណាដែលពិបាកគ្រប់គ្រងដូចជាចិត្តនេះទេ ដូច្នេះចិត្តមិនមែនមនុស្សគ្រប់រូបសុទ្ធតែគ្រប់គ្រងបាននោះទេ ចាំបាច់ត្រូវសិក្សាមេរៀនព្រះធម៌ដែលស្តីអំពីចិត្ត សិក្សាអំពីការប្រព្រឹត្តទៅរបស់ធម្មជាតិ និងការប្រព្រឹត្តទៅនៃជីវិតរបស់មនុស្សលោក ឲ្យឃើញដោយប្រាជ្ញានោះទើបអាចទប់ស្កាត់ចិត្តអកុសលបានខ្លះ។ ធម្មជាតិខាងក្រៅ បានដល់កាយ វាចា ការគ្រប់គ្រងកាយវាចានេះក៏ជាភារៈដ៏ធ្ងន់ដែរព្រោះកាយនិងចាវាក៏ជាប្រភពនៃកុសល និងអកុសលដែរ ប៉ុន្តែអ្នកដែលបញ្ជាធម្មជាតិទាំងពីរនេះបានឲ្យទៅសម្រេចកិច្ចការអ្វីមួយទោះល្អ ឬអាក្រក់ក៏សុទ្ធតែត្រូវបានបញ្ជាដោយចិត្ត ក្នុងខណៈពេលអាយតនៈខាងក្នុង ប៉ះខ្ទប់គ្នាជាមួយនឹងអាយតនៈក្រៅ។

ជារួមការគ្រប់គ្រងបាននូវធម្មជាតិទាំងបីនេះ គឺនាំមកនូវសន្តិភាព និងសុភមង្គលក្នុងជីវិតយ៉ាងពិតប្រាកដ ព្រោះប្រភពនៃសុភមង្គលគឺស្ថិតនៅលើចិត្ត កាយ និងវាចានេះឯង។ ឱវាទបាតិមោក្ខនេះ គឺព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញអំពីវិធីសាស្ត្រក្នុងអប់រំចិត្ត កាយ និងវាចានេះឯង មិនមានដើម្បីអ្វីក្រៅពីនេះឡើយ។

**៩.១.១. សព្វបាបស្ស អករណំ** ការមិនធ្វើនូវអំពើបាបទាំងពួង។

ការមិនធ្វើអំពើបាបៈ គឺលោកចង់អប់រំមនុស្សទាំងឡាយ ឲ្យឈប់បន្តការប្រព្រឹត្តនូវអំពើបាបទាំងពួងដែលខ្លួនធ្លាប់មានពីអតីតកាល និងបច្ចុប្បន្ន ដែលបង្កផលប៉ះពាល់ និងការឈឺចាប់ដល់មនុស្សសត្វដទៃ និងនាំឲ្យខ្លួនឯងវិនាសអន្តរាយ។ អំពើបាបទាំងនោះ មានដូចជា ការកាប់សម្លាប់ជីវិតមនុស្សសត្វ ការឆក់យកទ្រព្យដោយមានម្ចាស់ហួងហែង ការប្រព្រឹត្តផ្តាំផ្តងលើកូនប្រពន្ធអ្នកដទៃ ការភូតកុហកបោកប្រាស់សាធារណជនដើម្បីកេងចំណេញផលប្រយោជន៍ផ្ទាល់ខ្លួន, ការជិះជាន់កេងប្រវ័ញ្ច ជញ្ជក់ឈាមជនស្លូតត្រង់ក្រោមស្លាកនៃអំពើល្អ ។ល។ ដូច្នោះ ក្នុងជីវិតរស់នៅ ដើម្បីទទួលបានសុភមង្គលក្នុងគ្រួសារ ក្នុងសង្គម ក្នុងពិភលោក គេត្រូវយកមាគ៌ាសន្តិភាពមកប្រតិបត្តិ ហើយដើម្បីទទួលបានសុខសន្តិភាព គឺតម្រូវឲ្យបុគ្គលគ្រប់រូបបញ្ឈប់អំពើដ៏លាមកទាំងអស់នោះ ដែលធ្លាប់មានក្នុងសន្តានរបស់ខ្លួនកន្លងមក។

**៩.១.២. កុសលស្សូបសម្បទា** ការបំពេញកុសលឲ្យបរិបូណ៌។

ការធ្វើអំពើល្អៈ គឺព្រះអង្គមានព្រះបំណងឲ្យយើងគ្រប់គ្នា ចាប់ផ្តើមធ្វើអំពើល្អទាំងពួង មិនមែនឈប់

ធ្វើអំពើអាក្រក់ហើយ ឈប់ធ្វើអ្វីៗ ហើយសំងំនៅស្ងៀមនោះទេ។ ការធ្វើអំពើល្អ ដូចជា ការមិនបៀតបៀនឈ្នានីសអ្នកដទៃ ការចេះជួយសង្គ្រោះអ្នកដទៃ ការចេះចែករំលែកសេចក្តីសុខ និងទ្រព្យសម្បត្តិដែលខ្លួនមានដល់អ្នកដទៃ ការចូលរួមជួយដោះស្រាយបញ្ហាសាច់ញាតិ ក្រុមគ្រួសារ បងប្អូនក្នុងសហគមន៍ និងការជួយគិតគូរដល់បញ្ហាសង្គមទាំងមូល ផងដែរ។ ការលះបង់ផលប្រយោជន៍ និងសេចក្តីសុខផ្ទាល់ខ្លួន ដើម្បីមនុស្សក្នុងលោក ជាពិសេសជនរួមឈាមនៃយើង គឺជាអំពើដ៏ប្រពៃមួយ ដែលព្រះជិនស្រីនៃយើង ទ្រង់កោតសរសើរ ហើយសូម្បីអ្នកប្រាជ្ញទស្សនវិទូក្នុងលោក ក៏ឲ្យតម្លៃដែរ។ លោកអ្នកប្រាជ្ញទាំងនោះតែងចាត់ទុកបុគ្គលប្រភេទនេះថា ជាអ្នកមានឧត្តមគតិខ្ពង់ខ្ពស់ ជាអ្នករស់នៅ ដែលនាំប្រយោជន៍យ៉ាងច្រើនក្រៃលែងដល់មនុស្សជាតិ។

**៩.១.៣. សចិត្តបរិយោទបនំ** ការញ៉ាំងចិត្តរបស់ខ្លួនឲ្យផូរផង។

ការធ្វើចិត្តឲ្យស្អាតផូរផង់៖ គឺលោកចង់ឲ្យយើងជម្រះចិត្តឲ្យស្អាតបរិសុទ្ធ ដោយកម្ចាត់ចោលនូវកិលេស ជាគ្រឿងសៅហ្មងទាំងឡាយឲ្យអស់ពីខន្ធសន្តានរបស់យើង។ គ្រឹះនៃកិលេសដែលធ្វើឲ្យចិត្តយើងសៅហ្មង កន្ទក់កន្ទេញនោះ គឺ លោភៈ ទោសៈ និងមោហៈ។ ទោសៈ គឺសេចក្តីចង់បាននូវអ្វីៗគ្រប់យ៉ាងគ្មានព្រំដែន។ ចំណោកឯ ទោសៈ គឺការក្រោធខឹងនឹងវត្ថុក្នុងលោក។ រីឯ មោហៈ គឺភាពវង្វេងក្នុងលោក ដោយយល់ខុសពីការពិតចំពោះធម្មជាតិ។

**៩.១.៤. ខន្តិ បរមំ តបោ តីតិក្ខា** សេចក្តីអត់ធន់ជាតបៈធម៌ដ៏ឧត្តម។

**ខន្តិ សេចក្តីអត់ធ្មត់**

**អត្តនោបិ បរេសញ្ច អត្ថាវហោវ ខន្តិកោ សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ។**

អ្នកមានខន្តីជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកមានខន្តីជាអ្នកឡើងទៅកាន់ផ្លូវជាទីទៅនៃឋានសួគ៌ និង ព្រះនិព្វាន។

**ខន្តិ** ប្រែថា «សេចក្តីអត់ធន់» ចំពោះសត្វនិងសង្ខារ។ សេចក្តីអត់ធន់ចំពោះហេតុដែលនាំឲ្យកើតលោភៈទោសៈ មោហៈ សេចក្តីអត់ធន់ចំពោះអក្កោសវត្ថុពាក្យជេរទាំង ១០ យ៉ាងគឺ: **ចោរោសិ** ឯងជាចោរ១ **ពាលោសិ** ឯងជាមនុស្សពាល ១ **មូឡ្ហោសិ** ឯងជាមនុស្សវង្វេង១ **ឱដ្ឋោសិ** ឯងជាសត្វអូដ្ឋ១ **គោណោសិ** ឯងជាសត្វគោ១ **គទ្រភោសិ** ឯងជាសត្វលា១ **នេរយិកោសិ** ឯងជាសត្វនរក១ **តិរច្ឆានគតោសិ** ឯងជាសត្វតិរច្ឆាន ១ **សុគតិ** មិនមានដល់ឯង ១ **ទុគ្គតិ** មានដល់ឯងជាប្រាកដ ១ ។ក្នុងលោកសន្និវាសនេះ គេនិយមរាប់យកនូវរតនវត្ថុគឺមាស ពេជ្រ ត្បូង និល ជាដើម ថាជាវត្ថុល្អប្រសើរបំផុតតាមលោកនិយម, ប៉ុន្តែក្នុងព្រះពុទ្ធសាសនាព្រះសម្មាសម្ពុទ្ធទ្រង់លើកយកធម៌ខន្តី សេចក្តីអត់ធន់នេះ ថាជាវត្ថុប្រសើរបំផុតជាងគ្រឿងអាភរណៈទាំងនោះទៅទៀត។ **ខន្តិ** ជាគូគ្នានឹង **សោរច្ចៈ**ដែលប្រែថា សេចក្តីស្ងប់ស្ងៀម ធម៌ទាំងពីរយ៉ាងនេះតែងតែអាស្រ័យគ្នា ឃ្លាតចេញពីគ្នាមិនបាន ដូចជាមនុស្សខ្វាក់និងខ្វិន ដូចជាមេសោរនិងកូនសោ តោងតែអាស្រ័យគ្នាទៅវិញទៅមក។ **ខន្តិ**សេចក្តីអត់ធន់ជាគុណធម៌ល្អបំផុត ដែលធ្វើឲ្យកល្យាណធម៌ដ៏ទៃកើតឡើងបាន ដូចជាសីល សមាធិ សមាធិ ធម៌ទាំងនេះដែលកើតឡើងក៏អាស្រ័យខន្តិជាមូលដ្ឋានឬជាប្រភពដែរ ពីព្រោះខន្តិជាមាតារបស់កល្យាណធម៌ទាំងពួង បើខ្វះខន្តិធម៌នេះ ធម៌ដទៃក៏ពុំអាចតាំងនៅបានឡើយ ។បុគ្គលណាមានខន្តិធម៌នេះនៅប្រចាំក្នុងខន្ធសន្តានហើយបុគ្គលនោះតែងបានជាទីស្រឡាញ់ពេញចិត្តនៃទេវតានិងមនុស្សទាំងឡាយ

ទោះបីបុគ្គលនោះទៅកាន់ទីណាៗក៏ដោយ តែងតែមិនមានគ្រោះថ្នាក់ឧបសគ្គអ្វីឡើយ។ លោកសរសើរខន្តិ សេចក្តីអត់ធន់មានន័យច្រើនយ៉ាង សូម្បីព្រះសម្មាសម្ពុទ្ធអង្គណាក៏ដោយ ដែលបានត្រាស់ដឹងឡើងក្នុងលោក ទ្រង់សំដែងសរសើរគុណរបស់ខន្តីថា **ខន្តិ បរមំ តបោតីតិក្ខា** ថាខន្តិជាតបៈដ៏ឧត្តមតែមួយបទប៉ុណ្ណេះ។ ពាក្យថា «**តបៈ**» ប្រែថា ការដុតកំដៅ ឬដុតបំផ្លាញ ពួកធម៌ណាដែលកើតឡើងហើយដុតបំផ្លាញបាបធម៌ជាសត្រូវដល់ខ្លួនបាន ធម៌អម្បាលនោះបានឈ្មោះថា តបៈធម៌ទាំងអស់, ដូចជាកុសលកម្មបថ ជាតបៈធម៌របស់អកុសលកម្មបថ ព្រោះកាលបើអកុសលកម្មបថកើតឡើង អាចកំចាត់អកុសលកម្មឲ្យអន្តរធានទៅបាន វីរិយៈ (សេចក្តីព្យាយាមប្រឹងប្រែង) កើតឡើងក៏អាចកំចាត់បង់សេចក្តីខ្ជិលច្រអូសឲ្យអន្តរធានទៅបាន ប៉ុណ្ណេះជាដើម។ ឯ**ខន្តិ** (សេចក្តីអត់ធន) នោះបានជាហៅថាតបៈធម៌ព្រោះដុតបាបធម៌ទាំងឡាយមានទោសៈ សេចក្តីប្រទូស កោធៈ សេចក្តីក្រោធព្យាបាទ សេចក្តីបំផ្លាញគេឲ្យវិនាស វិហឹសា សេចក្តីបៀតបៀនគេ អរតិ សេចក្តីមិនត្រេកអរ បដិឃៈ សេចក្តីថ្នាំងថ្នាក់ជាដើមដែលជាសាខារបស់ទោសឲ្យរីងស្ងួតទៅ ឯទោសៈដែលចម្រើនធំថ្លោសឡើងបានក៏អាស្រ័យសេចក្តីមិនអត់ធន់, ដូចអ្នកដែលទាស់ទែងខ្វែងគំនិតគ្នា ដូចភិក្ខុក្រុងកោសម្ពីដែលអាស្រ័យនឹងហេតុបន្តិចបន្តួច សព្វបើគ្រាន់តែទឹកសល់អំពីការជម្រះលាមកប៉ុណ្ណោះក៏មិនប្រឹងអត់ធន់ ផ្តួចផ្តើមឲ្យកើតជាវិវាទរោលរាលធំធាត់ឡើងដរាបដល់បែកសាមគ្គីអំពីគ្នា បើប្រសិនជាខាងណាអត់បាន រឿងរ៉ាវនោះក៏នឹងស្ងប់ម្ងាប់ទៅមិនខានឡើយ។ ខន្តិសេចក្តីអត់ធន់នេះមិនមែនមានគុណចំពោះតែខ្លួនឯងទេ រមែងមានគុណប្រយោជន៍ដល់អ្នកដទៃផង ហេតុដូច្នេះបានជាលោកសរសើរថា ជាតបធម៌ដ៏សំខាន់ក្រៃពេក។ មួយទៀត អ្នកមានខន្តីជាអ្នកអាចឡើងទៅកាន់ផ្លូវជាទីទៅកាន់ឋានសួគ៌និងព្រះនិព្វានបាន។

**អធិប្បាយ**

ពាក្យថា **ខន្តិ** បានដល់ អធិវាសនខន្តិ ដែលលោកពោលទុកយ៉ាងនេះថា "**តត្ថ កតមា ខន្តិ? យា ខន្តិ ខមនតា អធិវាសនតា អចណ្ឌិក្កំ អនសុរោបោ អត្តមនតា ចិត្តស្ស** បណ្តាធម៌ទាំងនោះ ខន្តិ តើដូចម្តេច? គឺ ភាពអត់ធ្មត់ ការអត់សង្កត់ ភាពមិនកាច មិនព្រហើន ភាពនៃចិត្តរីករាយ" ។

### ៩.១.៥. និព្វានំ បរមំ វទន្តិ ពុទ្ធា ព្រះនិព្វានជាធម៌ដ៏ឧត្តម

តើនិព្វានគឺជាអ្វីទៅ?

មានអស់លោកមួយចំនួនយល់ឃើញថា និព្វានគឺមានរូប មានរាង មានខន្ធទាំង៥គឺ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណក្ខន្ធនៅឡើយ ខ្លះទៀតយល់ថា និព្វានគឺជាភពមួយដទៃទៀតនៅក្រៅពីកាមភព រូបភព និងអរូបភពដែលយើងហៅថាសង្សារវដ្តនោះ។ នៅមានអ្នកប្រព្រឹត្តបដិបត្តិធម៌ខ្លះទៀតបានមានមតិថា និព្វានគឺជាភពមួយដែលមានតែសេចក្តីសុខមិនមានទុក្ខ តែនៅមានបញ្ចក្ខ័ន្ធនៅឡើយដែរ។

នៅមានមតិ និងយោបល់ច្រើនដទៃទៀតមានន័យផ្សេងៗគ្នាទាក់ទងនឹង ព្រះនិព្វាន។

និព្វានក្នុងអភិធម្មត្ថសង្គហ

និព្វានគុណ ឬគុណរបស់ព្រះនិព្វានក្នុងគម្ពីរអេភធម្មត្ថសង្គហៈ បានពណ៌នាជាដើមថា អជាតំ និព្វានមិនកើតទៀត អជរា និព្វានមិនចេះចាស់ទ្រុឌទ្រោមគ្រាំគ្រា អព្យាធឹ និព្វានចេះឈឺ ឬមិនមានរោគ (ជម្ងឺ) អមតំ និព្វានមិនមានសេចក្តីស្លាប់ (អម្រឹត្យ) អសង្ខតំ មិនមានបច្ច័យតាក់តែង សន្តិបទំ មានតែសេចក្តីស្ងប់ឯកន្តំ មានតែសេចក្តីសុខតែម្យ៉ាង ។ល។ រីឯព្រះនិព្វានក្នុងបដិច្ចសមុប្បាទបានអធិប្បាយថា ព្រះនិព្វានព្រោះ

ការរលត់ទៅនៃអវិជ្ជា។ សង្ខារទាំងឡាយរលត់ទៅព្រោះការរលត់ទៅរបស់អវិជ្ជា ។ល។ សេចក្តីគ្រាំគ្រា សេចក្តីឈឺចាប់គ្រប់បែបយ៉ាង ទុក្ខ សោក ខ្សឹកខ្សួលទាំងឡាយ ដោយសរុបបានដល់ទុក្ខវេទនាដែលកើតឡើងតាមផ្លូវកាយ ទោមនស្សវេទនាដែលកើតតាមផ្លូវចិត្តហ្នឹងឯង។

**និព្វានប្បភេទ**

មាននិព្វានពីរយ៉ាងទៀតគឺសឧបាទិសេសនិព្វានសេចក្តីរលត់កិលេសតណ្ហាអស់ដោយឧច្ឆេទប្បហាន (កាត់ផ្តាច់អស់ទាំងឫសគល់មិនមានសល់)១ អនុបាទិសេសនិព្វាន រលត់អស់ទាំងកិលេសតណ្ហា អស់ទាំងបញ្ចក្ខ័ន្ធ១។ ឈ្មោះថាបរិនិព្វាន ព្រោះការរលត់ទៅនៃនិព្វានទាំងពីរនេះឯង ហេតុដូច្នេះមិនមានការអធិប្បាយដទៃឲ្យផ្សេងពីនេះឡើយ។ មាននិព្វានបីយ៉ាងទៀតគឺ អនិមិត្តំ មិនមាននិមិត្ត (គន្លង ជាម ស្នាម លក្ខណៈ) អប្បណិហិតំ។ សុញ្ញតំ សូន្យមិនមានអ្វីសេសសល់មានន័យថាមិនមានកិលេស និងតណ្ហាសេសសល់។ សូមអស់លោកសាកល្បងគិតពិចារណាបន្តិចថា តើនិព្វាននុ៎ះ ដូចម្តេចហ្ន៎? យ៉ាងម៉េចបានជាក្នុងព្រះពុទ្ធសាសនានិយាយតែព្រះនិព្វានថា ជាសេចក្តីសុខកំពូល ហើយហ៊ានអះអាងថា មិនមានសេចក្តីណាដទៃក្រៅពីនិព្វានទៀតផង។ (យថាវាទី តថាការី) មានសេចក្តីថា ពោលយ៉ាងណា ត្រូវតែធ្វើយ៉ាងនោះ គឺយ៉ាងពោលហ្នឹងឯង។ សូមជម្រាបអស់លោកថា មានពុទ្ធសាសនិកភាគច្រើនដែលនិយាយស្ទាត់មាត់ថា និព្វានៗ ដូច្នេះ តែពួកគាត់នឹងបានយល់ថា និព្វានមានសេចក្តីថាយ៉ាងណាទេ ឬយល់ដែរ តែមិនមែនជាព្រះនិព្វានដែលព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់បានសម្តែង ឬចេះនិព្វានដែលជាមិច្ឆាទិដ្ឋិ (យល់ខុសពីព្រះពុទ្ធតម្រាស់)។

និព្វានក្នុងធម្មចក្កប្បវត្តនសូត្រ

ធម្មចក្កប្បវត្តនសូត្រ ឬបឋមទេសនានៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គបានលើកយកអរិយសច្ច៤យ៉ាងមកសម្តែងដល់ពួកតាបសបញ្ចវគ្គិយ៍មានកោណ្ឌញ្ញៈ ភទ្ទិយៈ វប្បៈ មហានាម និងអស្សជិ ឲ្យបានយល់ពីដំណើរនៃវាលវដ្តសង្សារនេះ ថាជាទុក្ខ (ទុក្ខសច្ច) សារហេតុនៃទុក្ខគឺតណ្ហា (ទុក្ខសមុទយសច្ច) ទីរលត់ទុក្ខគឺនិព្វាន (ទុក្ខនិរោធសច្ច) និងមគ្គសច្ចជាវិធីរំលត់ទុក្ខ (ទុក្ខនិរោធគាមិនី បដិបទា)។ យើងបានឃើញពាក្យថានិព្វានគឺទុក្ខនិរោធ( ទីរលត់ទុក្ខហ្នឹងឯង) មានអ្នកប្រាជ្ញមួយចំនួនបានមានប្រសាសន៍ថានិព្វានគឺ ការដែលគ្មានបញ្ហាក្នុងជីវិតបច្ចុប្បន្ន មិនថាការអស់ទៅនៃបញ្ហាក្នុងសង្គមគ្រួសារ ឬក្នុងសង្គមជាតិទាំងមូល។ បញ្ហានោះមានច្រើនអនេក ពុំអាចគណនាបាន តែយើងសង្កត់ធ្ងន់ចំពោះបញ្ហាណាដែលយើងបានជួបប្រទះ ឬកំពុងតែមាន ដូចជាករណីទំនាស់ក្នុងសង្គមគ្រួសារដែលគេចាត់ទុកថា ជាបញ្ហាធំបំផុតសម្រាប់សង្គមគ្រួសារក្រីក្រជាពិសេសនៅតាមជនបទចំកាត់មាត់ញក ភាគច្រើនពួកគាត់ពុំសូវបានយល់ដឹងពីអ្វីដែលហៅថាសេចក្តីសុខដ៏ពិតប្រាកដនៃជីវិតគូរស្រករនោះទេ ហេតុដូច្នេះក្នុងនាមយើងជាពុទ្ធសាសនិក គប្បីងាកមកគិតដល់បញ្ហា និងវិធីកែបញ្ហាទាំងនោះឲ្យជីវិតខ្លួនឯង និងអ្នកដែលយើងស្រឡាញ់គឺគ្រួសារយើង ជាតិយើង មនុស្សជាតិយើងម្តង ព្រោះកន្លងមកហាក់ដូចជាមិនមានអ្នកឲ្យតម្លៃរឿងសេចក្តីសុខនៃជីវិតប៉ុន្មានសោះ តែក៏នៅមានជនមួយក្រុមគិតដល់រឿងប្រាក់ និងសេចក្តីសុខ តើលុយអាចទិញសេចក្តីសុខបានឬទេ? ដូច្នេះជាដើម។

និព្វានធាតុមាន ២ យ៉ាងគឺៈ

សឧបាទិសេសនិព្វាន១ អនុបាទិសេសនិព្វាន១។

អធិប្បាយថា កិលេសទាំងឡាយរលត់អស់មិនមានសេសសល់ នៅសល់តែខន្ធដែលជាចំណែកបរិសុទ្ធហៅថា

"សឧបាទិសេសនិព្វាន " កិលេសព្រមទាំងកងទុក្ខរលត់អស់មិនមានសេសសល់ សូម្បីតែខន្ធដែលជាចំណែក បរិសុទ្ធក៏រលត់អស់ ហៅថា " អនុបាទិសេសនិព្វាន " ។ និព្វានស័ព្ទនេះប្រើបានច្រើនយ៉ាង តែក្នុងនេះ សូមប្រែតែត្រឹម ៣ យ៉ាងគឺះ

១. ប្រែថា " មិនមាន " គឺមិនមានតណ្ហា

២. ប្រែថា " អស់ទៅ " គឺអស់កិលេស

៣. ប្រែថា " រលត់មិនសល់ " គឺរលត់កិលេសនិងកងទុក្ខ។

ដែលប្រែថា " មិនមាន និងអស់ទៅ " សំដៅយកសឧបាទិសេសនិព្វានតែម្យ៉ាង។ ដែលហៅថា " រលត់មិនសល់ " សំដៅយកទាំងសឧបាទិសេសនិព្វាន ទាំងអនុបាទិសេសនិព្វាន។

**៩.១.៦. ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ** បុគ្គលដែលសម្លាប់សត្វដ៏ទៃ មិនឈ្មោះថាបព្វជិត បុគ្គលដែលបៀតសត្វដទៃមិនឈ្មោះថាសមណៈឡើយ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរហើយក្នុងធម៌ ពិចារណាធម៌ រឭកធម៌រឿយៗ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ។

ភិក្ខុមិនគប្បីមើលងាយលាភរបស់ខ្លួន ដែលកើតឡើងដោយធម៌ មិនគប្បីចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃ រមែងមិនបានសមាធិឡើយ។ បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួន ទេវតា និងមនុស្សទាំងឡាយ តែសរសើរភិក្ខុនោះឯង ដែលជាអ្នកមានព្យាយាមជាគ្រឿងអាស្រ័យរស់នៅ ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស។

ភិក្ខុណានៅដោយអំណាចមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងបានបទដ៏ស្ងប់ ជាទីរម្ងាប់ចាកសង្ខារ នាំមកនូវសេចក្ដីសុខ។

ម្នាលភិក្ខុ អ្នកចូរស្ដារទូកគឺអត្តភាពនេះ ទូកដែលអ្នកស្ដារហើយ នឹងដល់ត្រើយឆាប់ អ្នកកាត់រាគៈ និងទោសៈបានហើយ អំពីនោះនឹងអាចដល់នូវព្រះនិព្វាន។

ភិក្ខុគប្បីកាត់ ឱរម្ភាគិយសំយោជនៈ៥ផង គប្បីលះបង់ឧទ្ធម្ភាគិយសំយោជនៈ៥ផង គប្បីចម្រើនឥន្ទ្រីយ៍៥តទៅ ភិក្ខុអ្នកកន្លងកិលេស ជាគ្រឿងជំពាក់ ៥ មាន រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ បានហើយ ទើបតថាគតហៅថា អ្នកឆ្លងអន្លង់បាន។

ម្នាលភិក្ខុ ចូរអ្នកពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្តរបស់អ្នកចូរកុំវិលទៅរកកាមគុណឡើយ អ្នកចូរកុំប្រមាទទំពាស៊ីនូវដុំនៃលោហៈ កុំឲ្យជាអ្នកកាលភ្លើងឆេះហើយ កន្ទក់កន្ទេញថា នេះជាទុក្ខ ដូច្នេះឡើយ។ ការពិនិត្យមិនមានដល់បុគ្គលអ្នកមិនមានប្រាជ្ញា ប្រាជ្ញាមិនមានដល់បុគ្គលអ្នកមិនពិនិត្យ ការពិនិត្យនិងប្រាជ្ញាមានក្នុងបុគ្គលណា បុគ្គលនោះឯង ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន។

សេចក្ដីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ។

ភិក្ខុពិចារណាកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែង

បានបីតិ និងបាមោជ្ជៈ បីតិ និងបាមោជ្ជៈនោះ ឈ្មោះថា ជាអមតៈធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ។

គុណធម៌៣ប្រការគឺ ការរក្សាឥន្រ្ទីយ៍១ សេចក្តីសន្តោស១ ការសង្រួមក្នុងបាតិមោក្ខ១ ជាខាងដើមនៃព្រះនិព្វាននោះ តែងមានដល់ភិក្ខុអ្នកមានបញ្ញាក្នុងសាសនានេះ ម្នាលភិក្ខុ អ្នកចូរគប់រកកល្យាណមិត្តអ្នកមានព្យាយាមជាគ្រឿងរស់ដោយបរិសុទ្ធិ ជាអ្នកមិនខ្ជិលច្រអូស។

ភិក្ខុ គប្បីជាអ្នកប្រព្រឹត្តធ្វើបដិសណ្ឋារៈ គប្បីជាអ្នកឈ្លាសក្នុងអាចារៈ ព្រោះហេតុទាំងពីរនោះ អ្នកនឹងមានបាមោជ្ជៈច្រើន នឹងធ្វើទីបំផុតទុក្ខបាន។

ភិក្ខុអ្នកមានកាយរម្ងាប់ហើយ មានវាចារម្ងាប់ហើយ មានចិត្តរម្ងាប់ហើយ មានចិត្តតម្កល់មាំហើយ មានអាមិសក្នុងលោកខ្ជាក់ចោលហើយ ទើបតថាគតហៅថា ជាអ្នកស្ងប់រម្ងាប់។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជម្រុះរាគៈ និងទោសៈចេញ ដូចដើមម្លិះ ជម្រុះនូវផ្កាម្លិះទាំងឡាយ ដែលស្វិតហើយដូច្នោះ។

អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង ចូរពិនិត្យខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះបើមានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ។

ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនឯងជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូររវាំងខ្លួន ដូចពាណិជរវាំងសេះដ៏ល្អ។

ភិក្ខុអ្នកក្រាស់ដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់ជាទីរម្ងាប់នូវសង្ខារនាំមកនូវសេចក្តីសុខ។

ភិក្ខុណានៅកម្លោះ ប្រឹងប្រែងក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញុំាងលោកនេះឲ្យភ្លឺស្វាងបាន ដូចជាព្រះចន្ទដែលរះផុតពីពពក។

**៩.១.៧.អនូបវាទោ អនូបឃាតោ** ការមិនពោលតិះដៀលអ្នកដទៃ ការមិនបៀតបៀនអ្នកដទៃ

ការមិនបៀតបៀនគ្នា រមែងនាំមកនូវសេចក្តីសុខ។

ទុក្ខ អាចមានពីរប្រភេទ គឺទុក្ខពីកំណើត និងទុក្ខពីសង្គម។ ទុក្ខពីកំណើត តែងកើតមានចំពោះមនុស្សគ្រប់គ្នា ដោយជៀសមិនរួច។ ប៉ុន្តែ មនុស្ស អាចរងទុក្ខមួយបន្ថែមទៀត គឺទុក្ខ ដែលកើតចេញពីការធ្វើបាបគ្នាក្នុងសង្គម។

ចាប់តាំងពីកើតមក មនុស្សគ្រប់រូប មានទុក្ខតាមខ្លួនរួចជាស្រេចទៅហើយ ដែលហៅថាទុក្ខ ព្រោះមានកំណើត ឬទុក្ខពីធម្មជាតិ។ ទុក្ខប្រភេទនេះ នឹងនៅបន្តជារៀងរហូត ដោយមិនប្រែប្រួលឡើយ។ ឲ្យតែមានរូប គឺមានទុក្ខ ទោះស្ថិតក្នុងសម័យកាលណាក៏ដោយ។

ទុក្ខព្រោះអ្វី? ទុក្ខព្រោះខ្វះទ្រព្យ ទុក្ខព្រោះជំងឺ ទុក្ខព្រោះចាស់ជរា ទុក្ខព្រោះបែកបាក់សាច់ញាតិ ក្រុមគ្រួសារ និងមនុស្សដែលខ្លួនស្រឡាញ់ និងទុក្ខព្រោះសេចក្តីស្លាប់ ជាដើម។ ទុក្ខទាំងនេះ តែងតែកើតចំពោះមនុស្សរាល់គ្នា ដោយគ្មាននរណាម្នាក់អាចគេចផុតឡើយ ទោះជាអ្នកនោះ ក្រ ឬមាន រាស្ត្រ ឬមន្ត្រី សេដ្ឋី ឬស្តេច ក៏ដោយ។

ក្រៅពីជួបទុក្ខពីកំណើត ឬទុក្ខពីធម្មជាតិ មនុស្សអាចនឹងជួបទុក្ខមួយជាន់ទៀត គឺទុក្ខ ដែលកើតចេញពីសង្គម ប្រសិនបើសង្គមនោះមិនល្អ ដូចជា មនុស្សមិនចេះយោគយល់គ្នា ឈ្នានីសគ្នា កេងប្រវ័ញ្ចគ្នា បាញ់ស្លាប់ ធ្វើទុក្ខបុកម្នេញដាក់គ្នា អ្នកមានលុយ មានអំណាច ធ្វើបាបអ្នកក្រ ជិះជាន់ រឹបអូសដីធ្លីផ្ទះសម្បែង

ប្រជារាស្ត្រ មេដឹកនាំខ្វះគុណធម៌ គិតតែពីអំណាច គិតតែពីប្រយោជន៍ក្រុមគ្រួសារ បក្សពួក ដោយមិនខ្វល់ពីទុក្ខលំបាកប្រជារាស្ត្រ។

មនុស្សក្នុងប្រទេសឬសង្គមប្រភេទនេះ ប្រាកដជារស់នៅដោយការភ័យខ្លាច និងរងទុក្ខពីសង្គមដោយជៀសមិនរួច។ ដូច្នេះ មនុស្ស ត្រូវជួបទុក្ខពីរជង គឺទុក្ខពីធម្មជាតិផង និងទុក្ខពីសង្គមផង។

សេចក្តីទុក្ខពីកំណើត ប្រៀបដូចជាដំបៅ។ ឯ ការធ្វើបាបដាក់គ្នា ប្រៀបដូចជា ការយកបន្លាទៅចាក់ត្រង់កន្លែងដែលមានដំបៅ។ «ការយកបន្លា ទៅចាក់ដំបៅបែបនេះ នឹងបង្កើនការឈឺចាប់ទ្វេដង»។

មនុស្ស មានទុក្ខពីធម្មជាតិតាមជាប់ខ្លួន គឺវេទនា និងឈឺចាប់ណាស់ទៅហើយ។ ចុះហេតុអ្វី ត្រូវធ្វើបាបដាក់គ្នា ដែលនាំឲ្យមានទុក្ខបន្ថែម រហូតដល់ទៅពីរត្រួតនោះ?

មនុស្ស គប្បីជៀសវាងឲ្យបាននូវការធ្វើអំពើអាក្រក់ក្នុងសង្គម។ មនុស្សគ្រប់រូប គួររួមគ្នាកសាងសង្គមមួយដែលល្អ សម្រាប់ការរស់នៅជាមួយគ្នា ដោយគ្មានការភ័យខ្លាច ហើយធ្វើយ៉ាងណាកុំឲ្យសង្គមនោះ ក្លាយជាសង្គម ដែលផ្តល់ទុក្ខដល់មនុស្ស បន្ថែមពីលើកទុក្ខពីធម្មជាតិ។

ធ្វើជាមនុស្ស គួរតែមានក្តីសន្តោស និងការជួយគ្នាទៅវិញទៅមក ទើបអាចជួយគ្នាក្នុងការកាត់បន្ថយក្តីទុក្ខ និងការឈឺចាប់បាន។ មានរឿងសំខាន់ៗពីរយ៉ាង ដែលយើងត្រូវកាន់ខ្ជាប់ឲ្យបាន ដើម្បីកាត់បន្ថយសេចក្តីទុក្ខ ហើយក៏អាចនាំឲ្យមានសុខដុមរមនាក្នុងសង្គមផងដែរ។

ទីមួយ យើងត្រូវតាំងចិត្តឲ្យបានថា មិនត្រូវធ្វើអំពើអាក្រក់ណាមួយទៅលើអ្នកដទៃ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ហើយត្រូវព្យាយាមបណ្តុះចិត្តរបស់ខ្លួនឲ្យមានក្តីមេត្តាចំពោះអ្នកដទៃ។ និយាយឲ្យខ្លីគឺការមិនធ្វើបាបទាំងពួង។

ទីពីរ យើងត្រូវព្យាយាមជួយអ្នកដទៃ។ បើមានទ្រព្យ ជួយទ្រព្យ។ បើមានគំនិត ជួយគំនិត។ បើគេឈឺចាប់ គួរជួយរំសាយការឈឺចាប់នោះ។ យើង គួរជួយគ្នាទៅវិញទៅមក តាមមធ្យោបាយឬតាមលទ្ធភាពដែលអាចធ្វើទៅបាន។ មានតែធ្វើបែបនេះទេ ទើបជីវិតគ្រប់គ្នា អាចកាត់បន្ថយក្តីទុក្ខបានខ្លះ។

យើងនិងគេ មិនខុសគ្នាឡើយ គឺកើតមក មានទុក្ខ មានការឈឺចាប់ មានក្តីសោកសៅ ជាប់នឹងខ្លួនស្ទើរតែទ្រាំមិនបានទៅហើយ ដូច្នេះ វាគ្មានហេតុផលអ្វី ដែលត្រូវធ្វើបាបគ្នា ហើយផ្តល់ក្តីទុក្ខឬការឈឺចាប់ដល់គ្នាបន្ថែមទៀតនោះទេ។

**៩.១.៨. បាតិមោក្ខេ ច សំវរោ** ការសង្រួមក្នុងបាតិមោក្ខ

ការសង្រួមក្នុងបាតិមោក្ខនេះ បានដល់ច្បាប់ដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តិហើយ មានដល់ទៅ ២២៧មាត្រា ដែលមានត្រាទាំងនេះគឺសម្រាប់ឲ្យបុគ្គលជាភិក្ខុអនុវត្ត មានបរាជិក៤ សង្ឃាទិសេស១៣ អនិយត២ និស្សគ្គិយបាចិត្តិយ៣០ សុទ្ធិកបាចិត្តិយ ៩២ បដិទេសនិយ៤ សេក្ខិយវត្ត៧៥ បូកនិងអធិករណសមថ៧ត្រូវជា២២៧មាត្រា។

ការសង្រួចភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចចាកទុក្ខទាំងពួងបាន។

ជនណាសង្រួមដៃ សង្រួមជើង សង្រួមវាចា សង្រួមអត្តភាព ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋាន ដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ជាអ្នកនៅឯកឯង តែងមានចិត្តត្រេកអរក្នុងធម៌ បណ្ឌិតទាំងឡាយ ហៅជននោះថាជា ភិក្ខុ ។

មួយទៀត បុគ្គលណាមិនមានសេចក្ដីប្រកាន់ក្នុងនាម និងរូប ថាជារបស់អញ ដោយប្រការទាំងពួង បុគ្គលណាមិនសោកស្ដាយ ព្រោះនាមនិងរូបដែលមិនមាន បុគ្គលនោះឯងតថាគតហៅថា ជាភិក្ខុ។

ភិក្ខុណាសង្រួតមាត់ ជាអ្នកពោលដោយបញ្ញា មានចិត្តមិនរាយមាយ សម្ដែងអត្ថផង ធម៌ផងបាន ភាសិតរបស់ភិក្ខុនោះទើបឈ្មោះថាពីរោះ។

ឱវាទបាតិមោក្ខនេះ ជាសាសនធម៌ផ្លូវប្រតិបត្តិរបស់ពុទ្ធបរិស័ទគ្រប់ចំពូកទូទៅទាំងសាសនមណ្ឌល។ ព្រះបោរាណាចារ្យបានសម្ដែងទុកថា ធម្មតាព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលបានត្រាស់ដឹងក្នុងអតីតកាលកន្លងហើយ តាំងពីព្រះវិបស្សីសម្មាសម្ពុទ្ធជាដើមក្ដី ព្រះអរហន្តសម្មាសម្ពុទ្ធដែលនឹងបានត្រាស់ក្នុងអនាគតកាលខាងមុខក្ដី ព្រះអរហន្តសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើងទាំងឡាយ ដែលមានសាសនៅរាទរុងរឿងនៅសព្វថ្ងៃនេះក្ដី ព្រះសម្មាសម្ពុទ្ធក្នុងកាលទាំង ៣ តែងទ្រង់ធ្វើវិសុទ្ធិឧបោសថសម្ដែងឱវាទបាតិមោក្ខ ៣ គាថានេះក្នុងទីប្រជុំនៃព្រះសង្ឃសាវ័កដ៏ប្រសើរ ដែលហៅថា ចតុរង្គសន្និបាត (ការប្រជុំសាវ័កប្រកបដោយអង្គ ៤) ដូចគ្នាគ្រប់ៗ អង្គ ផ្សេងតែវារៈដែលទ្រង់សម្ដែង ព្រះអង្គខ្លះច្រើនដង ព្រះអង្គខ្លះតិចដង និងផ្សេងចំនួនភិក្ខុដែលមកប្រជុំ ច្រើនតិចជាងគ្នាតាមកាល ព្រះវិបស្សីសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ ដង គឺមានភិក្ខុ ៦ លាន ៨ សែនរូបម្ដង ១ សែនរូបម្ដង ៨ ហ្មឺនរូបម្ដង ព្រះសិខីសម្មាសម្ពុទ្ធ មានចតុរង្គសន្និបាត ៣ ដង គឺមានភិក្ខុ១សែនរូបម្ដង ៨ហ្មឺនរូបម្ដង ព្រះវេស្សភូសម្មាសម្ពុទ្ធមានចតុរង្គសន្និបាត ៣ ដង គឺមានភិក្ខុ ៨ ហ្មឺនរូបម្ដង ៧ ហ្មឺនរូបម្ដង ៦ ហ្មឺនរូបម្ដង ព្រះសម្មាសម្ពុទ្ធជាបរមសាស្ដារបស់យើងមានចតុរង្គសន្និបាតតែម្ដង ព្រះអរហន្តសាវ័ក ដែលមកប្រជុំគ្នាក្នុងគ្រានោះតែ ១ ២៥០ រូប តិចជាងព្រះសម្មាសម្ពុទ្ធពីបុរាណ។

ចតុរង្គសន្និបាតរបស់ព្រះសម្មាសម្ពុទ្ធពីបុរាណដូច្នេះគឺ

១- សព្វេ ឯហិភិក្ខូ ភិក្ខុទាំងអស់សុទ្ធតែជាឯហិភិក្ខុ

២- សព្វេ ឥទ្ធិយា និព្វត្តបត្តចីវរា ភិក្ខុទាំងអស់សុទ្ធតែមានបាត្រនិងចីវរកើតឡើងដោយឫទ្ធិ

៣- សព្វេ អនាមន្តិតាវ អាគតា ភិក្ខុទាំងអស់សុទ្ធតែមកឥតនរណានិមន្ត

៤- បណ្ណរសេ ឧបោសថទិវសេ មកក្នុងថ្ងៃឧបោសថ ១៥ កើត។

ចតុរង្គសន្និបាត របស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងនេះដូច្នេះគឺ

១- មាឃនក្ខត្តេន យុត្តោ បុណ្ណមីឧបោសថ ទិវសោ ថ្ងៃឧបោសថព្រះចន្ទពេញវង់ប្រកបដោយផ្កាយប្រចាំខែមាឃៈ គឺថ្ងៃ ១៥ កើតមាឃៈ

២- កេនចិ អនាមន្តិតានិ ហុត្វា អត្តនោយេវ ធម្មតាយ សន្និបតិតានិ អឌ្ឍតេរសានិ ភក្ខុសតានិ ភិក្ខុ ១២៥០ រូប ឥតមាននរណានិមន្តឡើយ ស្រាប់តែមកប្រជុំគ្នាតាមធម្មតារបស់លោក។

៣- តេសុ ឯកោ បុថុជ្ជនោ វា សោតាបន្ន សកទាគាមិអនាគាមិសុក្ខវិបស្សអរហន្តេសុ វា អញ្ញតរោ នត្ថិ សព្វេ ឆ អភិញ្ញាវ ភិក្ខុអម្បាលនោះជាបុថុជ្ជន ឬសោតាបន្ន សកទាគាមី អនាគាមី ឬព្រះអរហន្តសុក្ខវិបស្សកៈ សូម្បីតែ ១ រូបក៏មិនមាន សុទ្ធតែជាព្រះអរហន្ត បានអភិញ្ញាណ ៦ គ្រប់រូប។

៤- ឯកោបិ ចេត្ថ សត្ថកេន កេសេ ឆិន្ទិត្វា បព្វជិតោ នាម នត្ថិ សព្វេ ឯហិភិក្ខុយេវ សូម្បីតែ ១ រូបដែលកោរសក់ដោយកាំបិតហើយបួសក៏មិនមាន សុទ្ធតែជាឯហិភិក្ខុទាំងអស់។

ចតុរង្គសន្និបាតនេះ ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើងទ្រង់ធ្វើក្នុងវត្តវេឡុវ័ន។ មានដំណាលថា កាលដែលព្រះអង្គសាវ័កទាំងពីរបួសហើយ ព្រះមហាមោគ្គល្លានបានសម្រេចអរហត្តក្នុងថ្ងៃទី៧។ ព្រះធម្មសេនាបតីសារីបុត្ត បានសម្រេចសាវ័កបារមីញាណក្នុងថ្ងៃទី ១៥ នៅវេលាដែលបញ្ជូនញាណទៅតាមខ្សែធម្មទេសនា ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែង វេទនាបរិគ្គហសូត្រ ប្រោសទីឃនខបរិព្វាជកជាក្មួយរបស់លោក ក្នុងញកគុហាឈ្មោះ សូករខាតលេណៈ នាពាក់កណ្តាលភ្នំគិជ្ឈកូដ។ កាលដែលព្រះដ៏មានព្រះភាគទ្រង់ជ្រាបថាព្រះថេរៈបានសម្រេចអរហត្តហើយ ព្រះអង្គទ្រង់ហោះទៅតាមអាកាសប្រតិស្ឋានឯវត្តវេឡុវ័ន។ ព្រះថេរៈបានជ្រាបដូច្នោះ ក៏ហោះទៅតាមអាកាសប្រតិស្ឋានក្នុងវត្តវេឡុវ័នដែរ។ សម័យនោះជាវេលាជួបជុំប្រកបដោយអង្គ ៤ ដែលហៅថា ចតុរង្គសន្និបាត ព្រះដ៏មានព្រះភាគក៏ទ្រង់សម្តែងឱវាទបាតិមោក្ខ ក្នុងទីប្រជុំនោះ។

ហេតុដូច្នេះបានជាចតុរង្គសន្និបាតនេះ ជាទីនិយមរាប់អានរបស់អ្នកប្រាជ្ញថាជាមហាអស្ចារ្យ និងជាមហាមង្គលប្រសើរ កាលបើដល់ថ្ងៃពេញបូរមីខែមាឃ ដែលជាថ្ងៃអភិលក្ខិតកាលដូច្នេះ សប្បុរសក៏នាំគ្នាចាត់ចែងគ្រឿងសក្ការៈដ៏ផ្ចិតផ្ចង់ មានប្រទីបផ្កាលាធូបទាននិងកម្រងផ្កាជាដើម យកទៅបូជាចំពោះព្រះស្តូបជាទីបញ្ចុះព្រះសារីរិកធាតុ និងឧទ្ទេសិកចេតិយ គឺព្រះពុទ្ធប្បដិមា ដែលប្រតិស្ឋានទុកជាគ្រឿងសំគាល់ក្នុងអារាមផ្សេងៗ ឧទ្ទិសចំពោះព្រះសម្មាសម្ពុទ្ធ និងព្រះអរហន្តទាំងឡាយ ដែលបរិនិព្វានទៅជាយូរអង្វែងហើយ ប្រជុំគ្នាស្តាប់ព្រះសង្ឃសូត្រស្វាធ្យាយ និងស្តាប់ព្រះសទ្ធម្មទេសនាជាទីរលឹកដល់ថ្ងៃដែលព្រះសម្មាសម្ពុទ្ធពីបុរាណ និងព្រះសម្មាសម្ពុទ្ធបរមគ្រូរបស់យើងទ្រង់ធ្វើ ចតុរង្គសន្និបាត នោះឯងតាមសេចក្តីជឿនិងសេចក្តីជ្រះថ្លារបស់ខ្លួនៗ ជាប់ជាប្រវេណីតៗ មកដរាបដល់សព្វថ្ងៃនេះ។

### ៩.១.៩. **មត្តញ្ញុតា ច ភត្តស្មឹ** ភាវៈជាអ្នកដឹងប្រមាណក្នុងភត្ត

ភាវៈជាអ្នកដឹងប្រមាណក្នុងភត្តនោះ, ឲ្យមានសេចក្តីពិស្តារ ដើម្បីជាគ្រឿងប្រដាប់ សតិបញ្ញានិងជាវត្តប្រតិបត្តិរបស់សាធុជនពុទ្ធបរិស័ទ ដូចតទៅនេះ ៖

សភាពជាអ្នកដឹងការល្អការល្មម និងការសមគួរហៅថា ភាវៈជាអ្នកដឹងប្រមាណ ភាវៈអ្នកដឹងប្រមាណនោះ មានប្រការដែលនឹងត្រូវពណ៌នាជាច្រើន ដូចយ៉ាងដឹងប្រមាណក្នុងការប្រើឥរិយាបថទាំង៤គឺ ឈរ ដើរ អង្គុយ ដេក ឲ្យប្រព្រឹត្តទៅស្មើ មិនប្រើឲ្យជ្រុលមួយ ៗ ដឹងប្រមាណក្នុងការធ្វើ, ការនិយាយ និងការគិត ឲ្យមានរបៀបរៀបរយតាមគន្លងធម៌ ឬដឹងប្រមាណក្នុងការប្រើកម្លាំងកាយ, កម្លាំងគំនិត, កម្លាំងទ្រព្យ ឲ្យល្មមសម ឬដឹងប្រមាណក្នុងការសូម និងការឲ្យដោយស្រួល អម្បាលនេះជាដើម។ តែក្នុងទីនេះ នឹងពណ៌នាចំពោះតែការដឹងប្រមាណ ៣ យ៉ាង។

ការដឹងប្រមាណ ៣ យ៉ាង

ក. ដឹងប្រមាណក្នុងការស្វែងរក

ខ. ដឹងប្រមាណក្នុងការទទួល

គ. ដឹងប្រមាណក្នុងការបរិភោគ។

អធិប្បាយការដឹងប្រមាណ

ក. ដឹងប្រមាណក្នុងការស្វែងរកនោះ បើជាគ្រហស្ថស្វែងរកដោយផ្លូវដែលត្រូវតាមធម៌ វៀរចាកការស្វែងរកក្នុងផ្លូវខុសដូចវៀរចាកមិច្ឆាកម្មន្ត ៣ យ៉ាងគឺៈ

១. មិនសម្លាប់សត្វ

២. មិនលួចទ្រព្យគេ

៣. មិនប្រព្រឹត្តខុសក្នុងកាម

និងវៀរចាកមិច្ឆាជីវៈ ឬមិច្ឆាវាណិជ្ជ ៥ យ៉ាង គឺៈ

១. មិនរកស៊ីលក់ដូរគ្រឿងប្រដាប់សម្រាប់ប្រហារ

២. មិនលក់មនុស្ស

៣. មិនលក់ដូរសាច់ គឺមិនចិញ្ចឹមសត្វទាំងឡាយមានជ្រូកជាដើម ហើយសម្រាប់យកសាច់លក់ ឬក៏មិនទិញដូរមកសម្លាប់យកសាច់លក់

៤. មិនលក់ដូរទឹកស្រវឹង គឺសុរានិងមេរ័យ

៥. មិនលក់ដូរថ្នាំពិស ដែលជាគ្រឿងបំពុលមនុស្សនិងសត្វអម្បាលនេះជាដើម។

បើជាបព្វជិតស្វែងរកដោយផ្លូវដែលត្រូវតាមធម៌វិន័យវៀរចាកកុលទូសកៈ អនេសនៈ វេជ្ជកម្ម អម្បាលនេះជាដើម។

ខ. ដឹងប្រមាណក្នុងការទទួលនោះ, បើជាគហស្ថទទួលទិញទទួលបញ្ចាំតែរបស់ត្រជាក់ គឺរបស់ដែលកើតឡើងក្នុងផ្លូវបរិសុទ្ធ, មិនទទួលទិញទទួលបញ្ចាំរបស់ក្តៅ គឺរបស់ដែលកើតអំពីចោរកម្មខុសចាកព្រះរាជប្បញ្ញត្តិ អម្បាលនេះជាដើម។ បើជាបព្វជិត ទទួលតែវត្ថុណាដែលជាកប្បិយៈគួរតាមធម៌វិន័យវៀរចាកវត្ថុដែលជាអកប្បិយៈ មិនគួរតាមធម៌វិន័យ អម្បាលនេះជាដើម។

គ. ដឹងប្រមាណក្នុងការបរិភោគនោះ បើជាគ្រហស្ថផ្លាស់ប្តូរចាយវាយបរិភោគ ឲ្យគួរសមតាមកម្លាំងទ្រព្យ មិនរំពេកមិនខ្ជះខ្ជាយពេក ទាំងបរិភោគទៀតសោត ក៏ដឹងប្រមាណរបស់ ដឹងប្រមាណកាល ដឹងប្រមាណពោះ មិនបរិភោគរបស់ដែលស្អុយរបស់ដែលខូច អម្បាលនេះជាដើម។ បើជាបព្វជិតវិញសោត ក៏ដឹងប្រមាណរបស់ ប្រមាណកាល ប្រមាណផ្ទៃទាំង៣ប្រការនេះដូចគ្នា។ ព្រះពុទ្ធជាម្ចាស់ដែលទ្រង់បានត្រាស់ក្នុងអតីតកាលក្តី អនាគតកាលក្តី ឬព្រះបរមគ្រូរបស់យើងទាំងឡាយក្នុងបច្ចុប្បន្ននេះក្តី ដែលទ្រង់បានតែងតាំងធម៌វិន័យ ចំពោះរឿង គ្រប់គ្រាន់សម្រាប់ឲ្យពួកបព្វជិតប្រតិបត្តិតាម ដូចទ្រង់ហាមប្រាមមិនឲ្យបរិភោគរបស់ដែលកើតដោយអធម្មកម្ម និងរបស់ដែលកន្លងហួសវេលា ទ្រង់កំណត់កាលវេលាឲ្យបរិភោគដោយស្រួល និងទ្រង់សំដែងបច្ចវេក្ខណវិធី សម្រាប់ឲ្យពិចារណាក្នុងខណៈដែលទទួល, ដែលកំពុងបរិភោគ, ដែលបរិភោគរួចហើយ ឲ្យឃើញថាគ្រាន់តែជាធាតុឬបដិកូល ដូច្នេះជាដើមនោះ ក៏ដើម្បីឲ្យស្គាល់ប្រមាណនេះឯង។

ការដឹងប្រមាណនេះ បើសំដែងចំពោះតែការដឹងប្រមាណក្នុងភត្តាហារម្យ៉ាងប៉ុណ្ណោះ ក៏គប្បីជ្រាបតាមន័យដែលមានក្នុង អប្បណ្ណកសូត្រ ថាៈ

សេចក្តីថា ម្នាលភិក្ខុទាំងឡាយ! ភិក្ខុក្នុងសាសនានេះ ពិចារណាដោយយោបល់ហើយទើបឆាន់ចង្ហាន់ មិនឆាន់ដើម្បីនឹងលេងដូចក្មេងអ្នកស្រុក មិនឆាន់ដើម្បីឲ្យកើតបុរិសមានៈស្រវឹងដូចអ្នកចម្បាប់ប្រដាល់ មិនឆាន់ដើម្បីប្រកាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបុរី មិនឆាន់ដើម្បីធ្វើឲ្យផូរផង់ពណ៌សម្បុរដូចអ្នកលេងរបាំ ឆាន់

ចង្ហាន់នេះ គ្រាន់តែឲ្យតាំងនៅនៃរាងកាយប៉ុណ្ណោះ ដើម្បីញុំាងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់នូវសេចក្ដីលំបាកគឺសេចក្ដីស្រេកឃ្លាន ដើម្បីទំនុកបម្រុងនូវព្រហ្មចរិយៈធាន់ចង្ហាន់ដោយធ្វើទុកក្នុងចិត្តថា អាត្មាអញនឹងកំចាត់បង់នូវវេទនាចាស់ គឺសេចក្ដីស្រេកឃ្លានដែលមានហើយផង និងមិនញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណឲ្យកើតឡើងផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង៤ក្ដី សេចក្ដីមិនមានទោស គឺមិនប្រអូសកាយប្រអូសចិត្តជាដើមក្ដី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង៤ក្ដី នឹងមានដល់អាត្មាអញដោយបានបរិភោគអាហារនេះមិនខានឡើយ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ ភោជនេ មត្តញ្ញូ ហោតិ

ម្នាលភិក្ខុទាំងឡាយ! យ៉ាងនេះឯង ទើបឈ្មោះថា ភិក្ខុ ជាអ្នកដឹងប្រមាណក្នុងភោជន។

**៩.១.១០. បន្តញ្ច សយនាសនំ** ទីដេក ទីអង្គុយដ៏ស្ងាត់

ព្រៃភ្នំ ឬព្រៃឈើដែលផុតពីស្រុក និងឧបចារនៃស្រុក ដែលប្រកបដោយពួកឈើធំតូច ឬរុក្ខមូល (គល់ឈើ) និងសុញ្ញាគារដ្ឋាន (ផ្ទះទំនេរឥតមានមនុស្សនៅ) ដោយហោចទៅសូម្បីតែកុដិ (ខ្ទម) តូចៗ ដែលសង់ក្នុងទីស្ងាត់សម្រាប់ជាទីចម្រើនសមណធម៌ ទីអម្បាលនេះជាដើម ហៅថា ទីដេកអង្គុយដ៏ស្ងាត់។

ធម្មតាព្រៃភ្នំរមែងជាទីស្រួល គួរឲ្យសរសើរច្រើនយ៉ាង ទើបជាទីត្រេកអររបស់ពួកយោគី តែពួកយោគីដែលទៅនៅក្នុងព្រៃនោះ គួរបង្អោនចិត្តគិតប្រៀបធៀបព្រៃហើយ និងចិត្តរបស់ខ្លួន។

**៩.១.១១. អធិចិត្តេ ច អាយោគោ** ការបំពេញព្យាយាមក្នុងអធិចិត្ត

នៅពេលកើតទុក្ខផ្លូវចិត្ត យើងត្រូវគិតដល់ហេតុនៃសេចក្ដីទុក្ខនោះ គឺមកអំពីតណ្ហា ពោលគឺចំណង់ដែលចង់បានអ្វីពីអ្នកដទៃ ឬចង់បានអ្វីអំពីលោកនេះ គ្រាន់តែមិនបានតាមចំណង់ប៉ុណ្ណោះ ទើបកើតទុក្ខហ្នឹងឯង។ កាលណា បើយើងរកហេតុឃើញដូច្នេះហើយ យើងត្រូវគិតឲ្យច្បាស់លាស់តទៅថា សូម្បីបានអ្វីៗនោះតាមប្រាថ្នា ដូចបំណង តើយើងពិតជាគ្រប់គ្រាន់ទេ អស់ទុក្ខអស់ភ័យទេ ឈប់ធ្វើអ្វីខុសហើយឬ មានចិត្តត្រជាក់ក្សេមក្សាន្តពិតមែនឬ... យើងនឹងបានចម្លើយយ៉ាងច្បាស់លាស់មកថា អត់ទេ ព្រោះអ្វីនោះមិនមែនជាសោតាបត្តិមគ្គផងហ្នឹង។ កាលណាបានយល់ដឹង ដូច្នេះពិតប្រាកដក្នុងចិត្តហើយ អ្វីនោះៗ គឺមិនសូវជាសំខាន់ប៉ុន្មានឡើយ មិនបានទេក៏ហីទៅ អ្វីដែលសំខាន់ពិត គឺការឃើញសច្ចធម៌ ចូលកាន់ភូមិព្រះអរិយៈឯណោះទេតើ។

ការអប់រំចិត្តឲ្យស្ងប់ដោយវិធីសមាធិ ឬសមថភាវនានិងម្យ៉ាងទៀត អប់រំឲ្យស្ងប់ផង លះផ្ដាច់ផងដោយវិធីវិបស្សនាភាវនា ។

សមាធិឬសមថភាវនា ចំណុចនេះ សំដៅដល់ការចងចិត្តទុកជាមួយនឹងអារម្មណ៍សមាធិ យ៉ាងណាមួយ។ នៅពេលណាចិត្តចាប់នូវអារម្មណ៍បានល្អហើយ ពោលគឺមិនរវើរវាយងាករេទៅក្នុងរឿងដទៃ នៅពេលនោះ សេចក្ដីសុខក៏កើតឡើង។

ចិត្តបានទទួលនូវការសម្រាកជាសុខសម្រាន្តមិនស្វែងរក ឬ សម្លឹងរករបស់ដទៃទៀតឡើយ មានភាពជាខ្លួនឯង និងមានសេចក្ដីសុខនៅដោយខ្លួនឯង ពោលគឺមិនមានរវល់ដោយអំណាចកិលេសចូលមករំខាន និងចូលមកដឹកនាំទៅក្នុងអារម្មណ៍ផ្សេងៗនោះឯង។

ការដែលចិត្តរបស់មនុស្សរេរីរវាយ ត្រាច់ទៅនេះត្រាច់ទៅនោះ ព្រោះហេតុតែស្វែងរកនូវសេចក្តីសុខដោយអំណាចនៃកាមតណ្ហា។ លុះដល់ពេលចិត្តបានទទួលនូវសេចក្តីសុខដោយអារម្មណ៍របស់សមាធិហើយ មានការពេញចិត្តនៅក្នុងអារម្មណ៍របស់សមាធិនោះ ចិត្តក៏មាននូវសេចក្តីសុខសម្រាន្ត រាងកាយក៏រឹងប៉ឹងមាំមួន តាំងមាំមិនញាប់ញ័រមិនងេងងោងងោកងក់ បាត់បង់អស់នូវការហត់នឿយជាដើមទាំងនេះព្រោះមកអំពីសុខសម្រាន្តនៃចិត្ត បានផ្សព្វផ្សាយទៅគ្រប់សរសៃប្រសាទ និងគ្រប់ចំណែកនៃរាងកាយ។ នៅពេលចិត្តបានទទួលសេចក្តីស្ងប់យ៉ាងនេះហើយ ភាពជាសុខប្រកបដោយបីតិ បានជ្រួតជ្រាបពេញរាងកាយ អស់កាយកដ៏យូរ អាចតាំងនៅរហូតដល់មួយថ្ងៃមួយយប់ក៏បាន។

វិបសសនាភាវនា ជាបឋមគឺត្រូវស្តាប់ព្រះធម៌ឲ្យយល់ច្បាស់ដល់នូវព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាទីពឹងទីរលឹកសមាទានសីល មានសទ្ធាជឿថាសត្វទាំងឡាយប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន។

គោលសំខាន់ គឺការគ្រប់គ្រងចិត្តដោយសតិសម្បជញ្ញៈ ឲ្យចិត្តនៅជាមួយនឹងអារម្មណ៍បច្ចុប្បន្ន ក្នុងពេលដេក ដើរឈរ អង្គុយ ឬក្នុងពេលបរិភោគអាហារជាដើម។ វិបស្សនាភាវនាគឺជាការគ្រប់គ្រងនូវឥន្ទ្រិយ៦ បានដល់ការសង្រួមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មិនឲ្យអភិជ្ឈា (ស្រឡាញ់) ទោមនស្ស (ស្អប់) គ្របសង្កត់ចិត្តបាន នៅពេលឃើញរូប ឬ ឮសំឡេងជាដើម។

វិបស្សនាភាវនា មានភាពប្រណីតនិងខ្ពស់ជាងឥន្ទ្រិយសំវរៈថ្នាក់សីល ប៉ុន្តែចាំបាច់ត្រូវតែមានជំនួយអំពីឥន្ទ្រិយសំវរសីល ព្រោះតឥន្ទ្រិយសំវរសីល ជាអាហារនៃសុចរិត ៣ ជាអាហារនៃសតិប្បដ្ឋាន ៤ ឯការអប់រំចម្រើននូវសតិប្បដ្ឋាន ៤ ជាការចម្រើនវិបស្សនាភាវនា។

ឥន្ទ្រិយសំវរសីលមិនមែនជាការស្រាវជ្រាវរាវរកសេចក្តីពិតក្នុងអារម្មណ៍ជាបរមត្ថឡើយ គ្រាន់តែប្រៀបបីដូចជាអ្នកយាមទ្វារប៉ុណ្ណោះ។ ឯចំណែកការចម្រើនសតិប្បដ្ឋានវិញ គឺជាកម្រិតនៃសតិដែលមានការហ្វឹកហាត់ខ្ពស់ជាងកម្រិតសតិថ្នាក់សំវរសីល។ ជាសតិផ្នែកតាមដានស្រាវជ្រាវ និងនាំមកនូវបញ្ញាចែកខន្ធធាតុអាយតនៈ ដុសខាត់កម្ចាត់នូវមោហៈអវិជ្ជា ដែលមោហៈអវិជ្ជានេះនាំឲ្យវង្វេងប្រកាន់ខន្ធធាតុអាយតនៈថាជាសត្វបុគ្គលតួខ្លួន។

អរិយមគ្គអង្គ ៨ បើសង្គ្រោះជាសិក្ខា ៣ គឺសម្មាទិដ្ឋិនិងសម្មាសង្កប្បៈ ជាបញ្ញា សិក្ខា សម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ ជាសីលសិក្ខា ឯអង្គមគ្គ ៣ ទៀតគឺសម្មាវាយាមៈសម្មាសតិ និង សម្មាសមាធិ ជាសមធិសិក្ខា ឬ ចិត្តសិក្ខា។

បើសង្គ្រោះជាវិជ្ជា និងចរណៈ សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ជាវិជ្ជា ឯអង្គមគ្គផ្សេងៗទៀតជាចរណៈ។

បើសង្គ្រោះជាសមថៈ និងវិបស្សនាវិញ សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ជាវបស្សនា ក្រៅពីនេះជាសមថៈដូច្នេះសីលសិក្ខា ត្រូវចូលក្នុងក្រុមសមថៈ ឬក្រុមចរណៈ (ការសង្គ្រោះនេះមានក្នុងអដ្ឋកថាសច្ចវិភង្គ គម្ពីអភិធម្ម)។

ពិតមែនតែជាបឋម សតិប្បដ្ឋាន ៤ មានអារម្មណ៍ជាបច្ចុប្បន្ន តែលុះដល់បញ្ញាមានការចម្រើនខ្លាំងក្លាបញ្ញាក៏មានការពិចារណា ឃើញច្បាស់នូវអារម្មណ៍ជាបរមត្ថគ្រប់កាលទាំង៣ ឃើញបច្ច័យនៃបញ្ចក្ខន្ធ ឃើញបដិសមុប្បាទធម៌ដែលជាសង្ខារធម៌សុទ្ធ។

បញ្ញាឃើញសង្ខាធម៌ មានតែការអស់ទៅ សូន្យទៅត្រូវនាំមកនូវអានិសង្ស៨ ប្រការៈ

១- មានការលះបង់នូវភវទិដ្ឋិ (យល់ថាមានព្រលឹងតួខ្លួនត្រូវទៅកើតក្នុងភពថ្មី ក្រោយពីស្លាប់ ព្រោះ

មិនបានឃើញថា បដិសន្ធិជាផលវិបាករបស់កម្មនេះ ជាភវទិដ្ឋិ) ។

២- មានការលះបង់នូវសេចក្តីត្រេកអរ និងសេចក្តីត្រូវការប្រាថ្នាក្នុងជីវិត (នេះមិនមែនជាបែបទោមនស្ស របៀបដូចមនុស្សខ្លះមិនប្រាថ្នាការរស់នៅនោះឡើយ អានិសង្សទី២ នេះសំដៅត្រង់ប្រាសចាកតណ្ហាក្នុងជីវិត)។

៣- មានភាពស្មុះស្មាប្រឹងប្រែង ស្វែងរកបុណ្យកុសល គ្រប់ពេល និងគ្រប់ផ្នែកដែលបំពេញបាន។

៤- មានអាជីពបរិសុទ្ធ។

៥- មានការលះបង់នូវសេចក្តីខ្វល់ខ្វាយ ក្នុងការធ្វើបាប ។

៦- មានការប្រាសចាកនូវភ័យ ។

៧- បាននូវខន្តី និងសោរច្ចៈ ។

៨- កម្ចាត់បង់បាននូវការស្រឡាញ់ និងការស្អប់ មិនបង្កប់នូវគំនុំទុកក្នុងសន្តាន ។

វិបស្សនាភាវនា គឺជាភ្លើងដុតនូវបាបធម៌ និងកិលេសផ្សេងៗ ឲ្យរីងស្ងួត រហូតដាច់ជាសមុច្ឆេទ លែងត្រឡប់មកវិញព្រោះការបានសម្រេចនូវអរិយមគ្គជាលោកុត្តរនេះជាសេចក្តីស្ងប់ដោយអំណាចវិបស្សនាភាវនា។

រួមសេចក្តីថា ឧបសមៈ គឺសេចក្តីស្ងប់នេះ ជាគុណជាតិដែលចាំបាច់ដ៏ក្រៃលែង សម្រាប់ជីវិតប្រចាំថ្ងៃដោយចំពោះណាស់នោះគឺ ស្ងប់ចាកកិលេសដែលជាហេតុនៃសេចក្តីខ្វល់ខ្វាយ និងការជំពាក់វាក់វិន ទាំងឡាយ។ បើមនុស្សក្នុងលោកយើងនេះ ជួយនាំគ្នារម្ងាប់នូវកិលេសក្នុងសន្តាននៃខ្លួនឯងគ្រប់ៗគ្នា ពិភពលោកយើងនេះ នឹងបានសុខស្ងប់ត្រជាក់ជាងសព្វថ្ងៃ រាប់រយពាន់ដង ព្រោះកិលេសដែលមាននៅខាងក្នុង សន្តាននៃមនុស្សយើងម្នាក់ៗនោះឯង បានប្លែងឫទ្ធិចេញមកទម្លាយគ្នានឹងគ្នាឲ្យក្តៅក្រហាយ ក្រវល់ក្រវាយជានិច្ចរហូតមក។ ការជួយគ្នារក្សានូវសេចក្តីស្ងប់ក្នុងចិត្តរៀងៗខ្លួន គឺជាការជួយដល់ពិភពលោកជួយដល់សង្គមដ៏ធំឲ្យបានស្ងប់មាំមួន និងគង់វង្សឋិតថេរជាពិតប្រាកដ។

# ជំពូក១០

# ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញអំពីរឿងពិតនៃជីវិត អរិយសច្ចៈ

## ១០.១. អរិយសច្ចៈ៤ប្រការ

**១០.១.១. ទុក្ខសច្ចៈ** (សេចក្តីទុក្ខលំបាក់ការពិបាកទ្រាំ គឺជាសេចក្តីពិតរបស់មនុស្សលោក)

ទុក្ខអរិយសច្ចៈ សេចក្តី ពិត របស់ អរិយៈ គឺ ទុក្ខបានដល់ ធម្មជាតដែលសត្វ ជីកគាស់រំលើង បាន ដោយក្រ ធម្មជាតទទេធម្មជាតនាំឲ្យលំបាក ព្រួយ ពិបាក អត់ទ្រាំ ធម្មជាតដែលអរិយបុគ្គល ខ្ពើម ឆ្អើម ធុញទ្រាន់ នឿយណាយនោះគឺ ទុក្ខ១២កងគឺ ៖

ជាតិទុក្ខ កិរិយាកើត កើតព្រម កិរិយាចុះកាន់គភ៌ កិរិយាកើត កិរិយាកើតថ្មី កិរិយាមានប្រាកដ នៃ ខន្ធ កិរិយាបានចំពោះនូវអាយតនៈ ក្នុងសត្តនិកាយនោះៗនៃពួកសត្វនោះៗ។

ជរាទុក្ខ កិរិយា ទ្រុឌ ទ្រោម គ្រាំគ្រា ធ្មេញ បាក់ សក់ ស្កូវ ស្បែក ជ្រួញ ជ្រីវ កិរិយា សាប សូន្យ អាយុ កិរិយា ចាស់ ជុំវិញ នៃ ឥន្ទ្រិយ។

មរណទុក្ខ កិរិយាច្យុតិ ឃ្លាតចេញបែកធ្លាយ អន្តរធាន សេចក្តីស្លាប់ គឺមច្ចុ កាលកិរិយា កិរិយា បែកធ្លាយ នៃខន្ធកិរិយាដាក់ចោលនូវសាកសព កិរិយាផ្តាច់បង់ជីវិតិន្ទ្រិយ។ (អនិច្ចកម្ម អនិច្ចធម្ម សុគតទៅកាន់បរលោក។

សោកទុក្ខ សំណោក កិរិយាស្តាយ កិរិយាស្រណោះ ស្រងេះស្រងោច ខាងក្នុងសង្រេងសង្រៃ ខាងក្នុងនៃ បុគ្គល ប្រកប ដោយ សេចក្តីវិនាស អន្តរាយណាមួយ ដែលទុក្ខធម៌ ណាមួយមកប៉ះពាល់។

បរិទេវទុក្ខកិរិយាយំទួញរក យំទួញរៀបរាប់ អាការយំទួញរកអាការ យំទួញរៀបរាប់ ខ្សឹកខ្សួល អណ្តឺតអណ្តក។

ទុក្ខទុក្ខ សេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយ ប្រព្រឹត្តក្នុងកាយ កិរិយាទទួលសោយនូវសេចក្តី ទុក្ខ សេចក្តីមិនស្រស់ស្រាយកើតអំពីការប៉ះពាល់ដោយកាយ។

ទោមនស្សទុក្ខ សេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយ ប្រព្រឹត្តក្នុងចិត្ត កិរិយាទទួលសោយ នូវ សេចក្តីទុក្ខ សេចក្តីមិនស្រស់ស្រាយ កើតអំពីការប៉ះពាល់ដោយចិត្ត។

ឧបាយាសទុក្ខ សេចក្តី ចង្អៀត ចង្អល់ សេចក្តីតានតឹង ភាពចង្អៀតចង្អល់ ភាពតានតឹង នៃ បុគ្គល ប្រកបដោយវិនាសអន្តរាយណាមួយ ដែលទុក្ខធម៌ណាមួយមកប៉ះពាល់។

អប្បិយេហិ សម្បយោគទុក្ខ ការប្រកបព្រមដោយសត្វនឹងសង្ខារ មិនជាទីស្រឡាញ់ ជាទុក្ខ គឺការ សង្គម សមាគម ប្រជុំព្រម លាយឡំ ដោយរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ មិនជាទីប្រាថ្នាមិនជាទីត្រេក អរ មិនជាទីពេញចិត្ត ឬដោយពួកបុគ្គលមិនប្រាថ្នា ប្រយោជន៍មិនប្រាថ្នា សេចក្តីចំរើន មិនប្រាថ្នាការនៅ សប្បាយ មិនប្រាថ្នាធម៌ក្សេមចាកយោគៈ។

បយេហិ វិប្បយោគទុក្ខ ការព្រាត់ប្រាសចាកសង្ខារ នឹងសត្វជាទីស្រឡាញ់ ជាទុក្ខ គឺការមិនមូល មិត្ត មិនជួបជុំ មិនមូលត្រកូល មិននៅលាយឡំគ្នា ដោយរូប សម្លេង ក្លិន រសផោដ្ឋព្វៈ ជាទីប្រាថ្នា ជាទី ត្រេកអរ ជាទីពេញចិត្ត ឬដោយ មាតា បិតា បង ប្អូន ប្រុស បង ប្អូន ស្រី អាមាត្យ ញាតិ សា លោ ហិត ដែលប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីចំរើន ប្រាថ្នាធម៌ក្សេមចាកយោគ។

យម្បិច្ឆំ ន លភតី តម្បិ ទុក្ខំ ការដែលប្រាថ្នារបស់ណា មិនបានរបស់នោះ ជាទុក្ខ គឺពួកសត្វមានកំណើត ការគ្រាំគ្រា ជម្ងឺដម្កាត់ សេចក្តីស្លាប់ សេចក្តីសោក សេចក្តីខ្សឹក ខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់ជាធម្មតា មានសេចក្តីប្រាថ្នាថា "ឱ! ហ្ន៎ ធ្វើម្តេចយើងទាំងឡាយកុំគប្បីមានកំណើត ការគ្រាំគ្រា ជម្ងឺដម្កាត់ ។ល។ សេចក្តីចង្អៀតចង្អល់ ឱហ្ន៎ ធ្វើដូចម្តេចបានកំណើត ការគ្រាំគ្រាជម្ងឺដម្កាត់ ។ល។ សេចក្តីចង្អៀតចង្អល់ កុំមកកាន់យើងទាំងឡាយ " ប្រាថ្នានេះមិនសម្រេច[39]។

សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខាដោយបំព្រួញ ឧបាទានក្ខន្ធ៥ជាទុក្ខគឺ៖

រូបូបាទានក្ខន្ធ គំនរ នៃសេចក្តី ប្រកាន់មាំ គឺរូប។វេទនូបាទានក្ខន្ធគំនរនៃសេចក្តីប្រកាន់មាំ គឺវេទនា។ សញ្ញូបាទានក្ខន្ធ គំនរ នៃសេចក្តីប្រកាន់មាំគឺ សញ្ញា។ សង្ខារូបាទានក្ខន្ធ គំនរ នៃសេចក្តី ប្រកាន់មាំ គឺសង្ខារ។ វិញ្ញាណូបាទានក្ខន្ធ គំនរ នៃសេចក្តី ប្រកាន់មាំ គឺវិញ្ញាណ។

**១០.១.២. សមុទយសច្ចៈ** (ហេតុដែលបណ្តាលឲ្យមានសេចក្តីទុក្ខគ្រប់យ៉ាង)

ទុក្ខសមុទយអរិយសច្ច ការកើតឡើងនៃទុក្ខ អរិយសច្ចទីពីរនេះ គឺការកើតឡើង ឬកំណើតនៃទុក្ខ ជាសេចក្តីពិត (ទុក្ខសមុទយអរិយសច្ច) អត្ថន័យធម្មតាទូទៅនៃសច្ចៈ ទីពីរនេះ ជាអត្ថន័យដែលព្រះពុទ្ធអង្គបានពន្យល់ច្រើនអន្លើណាស់ នៅក្នុងគម្ពីរព្រះត្រៃបិដកព្រះពុទ្ធសាសនា ដូចមានសេចក្តីតទៅនេះ៖

ធម៌អ្វីដែលនាំឲ្យកើតទុក្ខ? តណ្ហា ការស្រេកឃ្លានអន្ទះសា សេចក្តីប្រាថ្នា ក្តៅក្រហាយ ជាធម៌នាំឲ្យមានភពថ្មី ប្រកបដោយសេចក្តីរីករាយ តណ្ហានេះប្រកបដោយសេចក្តីត្រេកត្រអាល ដោយការជាប់ជំពាក់វាក់វិនខ្លាំងខ្លា ហើយចេះតែនាំឲ្យស្វែងរកសេចក្តីរីករាយថ្មីៗ ឥតឈប់ឈរតទៅទៀត នៅត្រង់នេះ នៅត្រង់នោះ ដរាបទៅបានដល់តណ្ហាបីប្រការគឺ៖

១ - កាមតណ្ហា សេចក្តីប្រាថ្នាក្នុងភព

២ - ភវតណ្ហា សេចក្តីប្រាថ្នាឲ្យកើតក្នុងរូបភព

៣ - វិភវតណ្ហា សេចក្តីប្រាថ្នាឲ្យកើតក្នុងអរូបភព។

ការស្រេកឃ្លានខ្លាំង សេចក្តីប្រាថ្នាស្និតស្នាញ ការជាប់ជំពាក់វាក់វិន ការលោភលន់ពន់ប្រមាណ ទាំងអស់នេះហើយ កើតប្រាកដឡើងដោយអាការៈផ្សេងៗច្រើនអនេក ហើយនាំឲ្យកើតទុក្ខគ្រប់ប្រការនាំឲ្យមានកំណើតតទៅទៀត។ សេចក្តីនេះយើងមិនគួរគប្បីយល់ថា តណ្ហានេះជាដើមហេតុ តែមួយនេះទេ តាមពុទ្ធ

---

[39] ឈឹម ទូច អធិប្បាយប្រជុំកងធម៌ពិស្តារ ព.ស ១២៥១៦ គ.ស ១៩៧២ ទំព័រ៦៣

សាសនា ហេតុដើម មិនមែនមានតែមួយទេ អ្វីទាំងអស់សុទ្ធតែមានទាក់ទងគ្នាទៅវិញទៅមក ឯតណ្ហាដែលទុកថា ជាហេតុ ឬជាដើមកំណើតនៃទុក្ខ នេះ ក៏ព្រោះតែធម៌នេះនាំឲ្យកើត (សមុទយ) ធម៌អ្វីតទៅទៀតគឺតណ្ហា ជាហេតុនាំឲ្យកើតវេទនា ការកើតវេទនា ជាហេតុនាំឲ្យកើតផស្សៈ ហើយចេះតែនាំឲ្យកើតអ្វីៗបន្តទៀតវិលទៅវិលមកដូចកង់ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឲ្យឈ្មោះថា បដិច្ចសមុប្បាទ។

ម្យ៉ាងទៀត តណ្ហា នេះ មិនជាដើម ឬបុព្វហេតុតែមួយដែលនាំឲ្យកើតទុក្ខទេ គ្រាន់តែជាបុព្វហេតុចេញមុខមុនគេ រហ័សក្លាមមុនគេ គឺជាប្រធាន ជាធម៌នាំឲ្យកើតសព្វទាំងអស់ តណ្ហាជាមេខ្លោង តណ្ហានេះហើយជាមណ្ឌលឧត្តមគតិគិតខុស ដែលនាំឲ្យយល់ថា មានខ្លួនឯង កើតមកពីអវិជ្ជា។

សព្វថា តណ្ហា មិនមែនបានសេចក្តីត្រឹមតែសេចក្តីប្រាថ្នា ឧបាទាន ការប្រកាន់ជាប់ចំពោះកាមគុណទ្រព្យសម្បត្តិ អានុភាព ប៉ុណ្ណឹងទេ បានសេចក្តីហួតទៅដល់ឧបាទានធម៌ ជាគ្រឿងប្រកាន់ខ្ជាប់ដទៃទៀត ដូចការប្រកាន់គំនិត ឧត្តមគតិ មតិ ទ្រឹស្តី ទស្សនទាន និងជំនឿទៀតផង ព្រោះធម៌ទាំងនេះ សុទ្ធតែកើតពីតណ្ហាដែលហៅថា ធម្មតណ្ហា។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា អពមង្គលគ្រប់យ៉ាង ការចលាចល់ទាស់ទែងខ្វែងគំនិតគ្នាគ្រប់ប្រការ រាប់ពីការទាស់គ្នាតូចតាច ស្វាមីភរិយា ទាស់គ្នារៀងរហូតដល់ទៅមហាសង្គ្រាមរវាងប្រទេស សេចក្តីអន្តរាយទាំងអស់នេះ ឫសគល់របស់នៅត្រង់ តណ្ហានេះឯង រដ្ឋបុរសក្នុងលោក ដែលព្យាយាមរកការដោះស្រាយការខ្វែងគំនិតជាអន្តរជាតិ ឬដែលនិយាយពីសង្គ្រាម ឬពីសន្តិភាព គ្រាន់តែជាផ្លូវនយោបាយ ឬផ្លូវសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺនិយាយត្រឹមតែសំបកក្រៅ មិនចូលទៅដល់ក្នុងចំណោទដែលជាឫសគល់ឡើយ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ចំពោះរដ្ឋបាលកិក្ខុថា " លោកនេះចេះតែខ្វះខាត មិនចេះឆ្អែតទេព្រោះជាខ្ញុំតណ្ហា (តណ្ហាទាសោ)។

មនុស្សក្នុងលោកយល់គ្រប់គ្នាថា សេចក្តីទុក្ខគ្រប់ប្រការ សុទ្ធតែកើតចេញមកពីសេចក្តីប្រាថ្នា តណ្ហាជាហេតុដើមនាំឲ្យកើតភពថ្មីឬថានាំឲ្យមានកំណើតទៀតនោះជាចំណោមមួយដែលគេដោះស្រាយបានដោយលំបាកបំផុត ដើម្បីស្រាយប្រស្នាលំបាកនេះ គេត្រូវដោះស្រាយទៅតាមទស្សនវិជ្ជា បែបអរិយសច្ចៈ ទើបបានដើងសព្វមួយដ៏ប្រសើរបំផុត ពោលគឺវែកញែកឲ្យល្អិតជ្រាលជ្រៅតាមអរិយសច្ចទីមួយទុក្ខអរិយសច្ចទៀតផង ព្រោះប្រស្នាលំបាកនេះ ជាប់ទាក់ទង់គ្នាទៅដល់ទ្រឹស្តីកម្មៈ និងភពថ្មីទៀត[40]។

លោកពោលថា អាហារមាន៤ប្រការ អាហារនេះ លោកទុកជាបុព្វហេតុមួយដែលឲ្យមានភពថ្មី ហើយឲ្យកើតជាសត្វឡើងគឺៈ

១ - កវលិង្ការាហារ បានដល់អាហារគ្រោតគ្រាត

២ - ផស្សាហារ អាហារគឺវេទនា ៣ប្រការដែលកើតពីការប៉ះពាល់ឥន្ទ្រីយ៍ទាំង៦ប្រការ

៣ - មនោសញ្ចេតនាហារ បានដល់ចេតនាកម្ម៣ប្រការ ដែលនាំឲ្យមានបដិសន្ធិក្នុងត្រៃភព

---

[40] កម្ពុជសុរិយា ភាគ៤៤/១ គ.ស១៩៧២ ទំព័រ ២០៨

៤ - វិញ្ញាណាហារ បានដល់ចិត្តណាមួយ ដែលនាំទៅក្នុងខណៈបដិសន្ធិចិត្តក្នុងត្រៃភព។

បណ្តាអាហារទាំង៤ប្រការនេះមនោសញ្ចេតនាហារនេះជាធម៌ប្រមូលយកចេតនាចង់រស់នៅ ចង់កើត ចង់កើតថ្មីទៀត ចង់បន្តកំណើតទៅទៀត ត្រឡប់មកកើតជាថ្មីទៀត ចេតនានេះឯង ជាឫសគល់នៃការកើត និងជាធម៌បន្តឲ្យមានការកើតទៅទៀតមិនឈប់ ឯការកើតនេះ ត្រូវប្រព្រឹត្តទៅតាមច្បាប់ធម្មជាតិ គឺកម្មល្អ ឬអាក្រក់ (កុសលាកុសលកម្ម)។

ចេតនានេះជាតួ កម្ម សមដូចពុទ្ធភាសិតថា កាលបើបុគ្គលយល់ច្បាស់នូវមនោសញ្ចេតនាហារហើយ ក៏អាចយល់ដល់តណ្ហា៣ប្រការ បានដោយប្រពៃ ដូច្នេះ ពាក្យថា តណ្ហា ចេតនា មនោសញ្ចេតនាហារ និង កម្ម នេះជាពាក្យមានអត្ថន័យតែមួយដូចគ្នា បានសេចក្តីថា សេចក្តីប្រាថ្នា ចេតនា ចង់នៅជាមនុស្ស ចង់កើត ចង់កើតទៀត ចង់វិលមកកើតទៀត ចង់ចម្រុងចម្រើនឲ្យរឹងរិតតែច្រើនតទៅទៀត ចង់សន្សំឲ្យកើតមានឡើង ឥតឈប់ឈរ។

នេះហើយ ជាបុព្វហេតុដែលនាំឲ្យកើតទុក្ខ (ទុក្ខសមុទយៈ) ធម៌នេះហើយដែលយើងបានឃើញនៅក្នុងសង្ខារក្ខន្ធ ជាខន្ធមួយនៅក្នុងខន្ធបញ្ចកៈ ដែលនាំឲ្យកើតបានហៅថា មនុស្ស ឬ សត្វ ឡើង ធម៌នេះ ជាធម៌សំខាន់ក្រៃលែង ជាចំណុចសារវន្តនៅក្នុងពុទ្ធសាសនា។ យើងគប្បីកំណត់ចំណាំទុកឲ្យច្បាស់លាស់ដោយប្រពៃ ចងចាំឲ្យម៉ត់ចត់ថា បុព្វហេតុនេះហើយ មេនេះហើយ នាំឲ្យកើតទុក្ខនៅក្នុងទុក្ខ មិនមែននៅឯណាក្រៅពីបុព្វហេតុនេះឡើយ ហើយគួរកត់ចំណាំទុកតទៅទៀតថា បុព្វហេតុ ឬមេនៃការរំលត់ទុក្ខ ក៏នៅក្នុងការរំលត់ទុក្ខនោះឯង មិនមែននៅឯណាក្រៅពីបុព្វហេតុនេះឡើយ សមដូចពុទ្ធភាសិតថា យំ កិញ្ចិ សមុទយធម្មំ សព្វំ តំ និរោធធម្មំ អ្វីមួយជាធម៌ នាំឲ្យកើតអ្វីទាំងអស់នោះ ជាធម៌នាំឲ្យរលត់ទៅវិញ។

អ្វីនីមួយជាសត្វជាវត្ថុឬជាវិធី បើនៅក្នុងខ្លួនឯង មានធម៌ជាហេតុនាំឲ្យកើតឡើង ជាធម៌នាំឲ្យមកកើតជាមនុស្សវិញ ក៏តែងមានធម៌ ឬមានមេការរលត់ ឬក៏ការអន្តរាយ នៅក្នុងខ្លួនឯងវិញដែរ ដូចជាខន្ធបញ្ចកៈ ជាធម៌ដែលមានបុព្វហេតុនាំឲ្យកើតក្នុងខ្លួនឯង ក៏ត្រូវមានធម៌ជាបុព្វហេតុនាំឲ្យរលត់ទៅវិញក្នុងខ្លួនឯងដែរ។

មួយទៀត កម្ម ជាបាលី កម៌ ជាសំស្ក្រឹត មកពីរូបធាតុតែមួយថា ករ ប្រែថា អំពើ ការធ្វើ ប៉ុន្តែក្នុងទ្រឹស្តីពុទ្ធសាសនាពាក្យថាកម្មឬកម៌មានអត្ថន័យពិសេស គឺមានអត្ថន័យថា អំពើប្រកបដោយចេតនា មិនមែនមានត្រឹមតែអំពើត្រង់ៗប៉ុណ្ណោះទេ។ ពាក្យថា អំពើត្រង់ៗតាមធម្មតា មិនមានន័យថា ល្អ ឬអាក្រក់ទេ ឬមានន័យថា ជាលទ្ធផលនៃកម្មទេ។ ពាក្យថា កម្ម ឬកម៌ នេះក្នុងពុទ្ធសាសនា មិនមែនមានន័យថា ផល របស់កម្ម គឺកម្មផល ឬកម្មវិបាក។

ចំណែកពាក្យថា ចេតនា ទើបអាចទៅជា ល្អ ឬអាក្រក់បាន ដូចជា តណ្ហា នេះទៅជាល្អ ឬអាក្រក់បាន ឯ កម្ម ឬកម៌ ដែលទៅជាល្អ ឬអាក្រក់ ក៏ដោយអាស្រ័យចេតនានេះឯង បើថា គ្រាន់តែជា កម្ម ឬកម៌ ត្រង់ៗនោះ មិនទៅជាល្អ ឬអាក្រក់បានទេ។ ដូច្នេះ កម្ម ឬកម៌ ប្រកបដោយចេតនា ទើបហៅថា ល្អ ឬអាក្រក់បាន ដូច កុសលកម្ម ផលិតផលល្អ អកុសលកម្ម ផលិតផលអាក្រក់។ ធម៌គឺតណ្ហា ចេតនា កម្ម មានកម្លាំង

ឲ្យទៅជា ល្អ ឬអាក្រក់ ព្រោះធម៌ទាំងនេះមានពលៈ ឬថាមពលនៅក្នុងខ្លួនឯង ពលៈ ឬថាមពល នេះរុញច្រានឲ្យទៅជា ល្អ ឬអាក្រក់ តាមសភាពរបស់ខ្លួន ល្អ ឬអាក្រក់ កុសល អកុសល ជាសារបក្ខៈ ហើយឋិតនៅក្នុងរង្វង់តំណគឺសង្សារ (អន្ទោលទៅមក) ព្រះអរហន្ត លោកធ្វើអំពើដែរ តែអំពើរបស់លោកមិនកើតទៅជាកម្ម ឬកម៌ ទេ គឺគ្រាន់តែជា កិរិយា ព្រោះចិត្តលោករួចស្រឡះហើយពីទ្រឹស្តី ឬអន្ទាក់ ពោលគឺការយល់ឃើញខុស រួចស្រឡះហើយពីតណ្ហា ដែលចង់បន្តកំណើត ឬវិលមកកាន់កំណើតវិញ ព្រមទាំងរួចស្រឡះអំពីជាគ្រឿងសៅហ្មង ពោលគឺកិលេស អាសវៈ គ្រឿងត្រាំ ទាំងអស់ហើយ ដូច្នេះព្រះអរហន្តមិនមានពូជកំណើតទៀតទេ។

ទ្រឹស្តី កម្ម ឬ កម៌ នេះ មិនគួរយើងភាន់ច្រឡំថាដូចជាច្បាប់ដែលគេហៅថា ច្បាប់យុត្តិធម៌ កាត់ទោសខាងចរិយា និងសញ្ញាណថា ប្រទានរង្វាន់ ឬពិន័យទោស នោះទេ គំនិតដែលយល់ឃើញថា ច្បាប់យុត្តិធម៌កាត់ទោសខាងចរិយា ច្បាប់ប្រទានរង្វាន់ ច្បាប់ពិន័យទោស នេះ ជាគំនិតដែលកើតចេញពីទស្សនទាននៃអាទិទេព នៃព្រះយមរាជ ដែលជាអ្នកតែងច្បាប់ សម្រេចថា នេះល្អ នេះអាក្រក់។ ពាក្យថា ច្បាប់យុត្តិធម៌ ក្នុងនាមខ្លួនឯង មានន័យមិនច្បាស់លាស់ទេ ហើយប្រកបដោយគ្រោះថ្នាក់ច្រើន ព្រមទាំងប្រគល់អំពើអាក្រក់ច្រើនជាងអំពើល្អ ដល់មនុស្សជាតិទៀតផង។

ឯ កម្ម ឬកម៌ ដែលប្រើក្នុងព្រះពុទ្ធសាសនា ជាទ្រឹស្តី ហេតុ និងផល កម្ម និងប្រតិកម្ម ជាទ្រឹស្តីស្តីពីច្បាប់ធម្មជាតិសុទ្ធសាធ ឥតមានសេចក្តីដូចច្បាប់តុលាការ ដែលមានសេចក្តីជាច្បាប់ពិន័យទោសនោះទេ ច្បាប់ កម្ម ឬកម៌ បើប្រកបដោយចេតនា សុទ្ធតែផលិត ឬធ្វើឲ្យមាន ហេតុ និង ផល ឬ លទ្ធផល ជាដរាប គឺកម្មជាកុសល ឲ្យផលល្អ កម្មជាអកុសល ឲ្យផលអាក្រក់ មិនមែនច្បាប់តុការ ឬច្បាប់ប្រទានរង្វាន់ ឬក៏ច្បាប់ពិន័យទោសនោះឡើយ កម្ម ឬកម៌ ផលិតចេញពីធម្មជាតិរបស់ខ្លួនសុទ្ធសាធ ពោលគឺពីច្បាប់កម្មសុទ្ធសាធ។ ទ្រឹស្តីកម្ម ឬកម៌នេះ មិនមានអ្វីនឹងនាំឲ្យលំបាកចូលចិត្តពេកនោះទេ ការនាំឲ្យលំបាកយល់ក្នុងគំនិតនោះ គឺផលរបស់កម្ម ដែលប្រកបដោយចេតនានោះ អាចបន្តឲ្យផលរហូតទៅដល់អនាគត់ជាតិទៅទៀត។

អ្នកសិក្សាបានដឹងហើយថា បុគ្គល សត្វ មិនមានទេ មានតែការផ្សំគ្នានៃ ពលៈ ឬថាមពល ដែលជារបស់កាយ និងចិត្ត ការដែលយើងនិយាយថា ស្លាប់ បានសេចក្តីថា ការមិនកម្រើក មិនដើរទាំងអស់ នៃគ្រឿងចក្រគឺសព៌ាង្គកាយ ចុះពលៈ ឬថាមពល នេះផុតរលត់ឈឹងទាំងអស់តទៅ ព្រមមួយអន្លើដោយការឈប់ង៉ក់នៃការកម្រើក ឬការដើរនៃគ្រឿងចក្រគឺសព៌ាង្គកាយដូច្នេះឬ?

ពុទ្ធសាសនាមិនឆ្លើយដូច្នោះទេ ពុទ្ធសាសនានិយាយថា មានធម៌បន្តទៅទៀត គឺ ឆន្ទៈ ចេតនា តណ្ហា ចង់កើត ចង់បន្តកំណើត ចង់វិលមកកើត តទៅទៀត ជាធម៌ទាំងនេះជាកម្លាំងខ្លាំងសម្បើមអស្ចារ្យ ធ្វើឲ្យមានចលនា ធ្វើឲ្យជីវិតទាំងពួង ភពទាំងពួង ធ្វើឲ្យលោកទាំងមូលចេះតែប្រព្រឹត្តតទៅមិនមានទីបំផុត។ ពលៈ នេះធំណាស់ ថាមពលខ្លាំងណាស់នៅក្នុងលោកយើងនេះ តាមទ្រឹស្តីពុទ្ធសាសនាកម្លាំងទាំងអស់នេះ មិនមែនឈប់ដើរ ព្រមជាមួយនឹងការមិនដើរនៃគ្រឿងចក្រសព៌ាង្គកាយ ពោលគឺសេចក្តីស្លាប់ទេ កម្លាំងទាំងអស់

កម្លាំងទាំងអស់ចេះដើរទៅជានិច្ច បន្តការដើររបស់ខ្លួនទៅក្នុងរូបដទៃទៀត បង្កើតជាភពថ្មីៗ ដែលយើងហៅថា ជាតិ (កំណើត)។

មានទស្សនៈមួយបានលើកឡើងថា បើមិនមានអ្វីទៀតទាត់ មិនមានអង្គភាព ដែលមិនប្រែប្រួល មិនមានសារជាតិ ដូចជាខ្លួនឯង ឬព្រលឹងទេ ចុះអ្វីទៅដែលអាចបន្តកើតទៀត ឬឲ្យមានកំណើតទៀត ក្រោយពីការបែកធ្លាយសព៌ាង្គកាយទៅ? មុនយើងនិយាយអំពីជីវិត (ការរស់នៅ) បន្ទាប់ពីមរណៈកាលទៅ យើងសន្មតទុកថា មានជីវិតរស់នៅសិនទៅចុះ ចុះជីវិត ការរស់នៅ វាបន្តការរស់នៅរបស់វាបានដូចម្ដេច? អ្វីដែលយើងហៅថា ជីវិត (ការរស់នៅ) ? ជីវិត (ការរស់នៅ) នេះ ដូចជាយើងនិយាយដដែលៗ មិនមែនអ្វីដទៃទេ គឺការផ្សំខន្ធបញ្ចកៈនេះឯង ការផ្សំពលៈ ឬថាមពលនៃកាយ និងចិត្តនេះឯង។ ធម្មជាតិដែលផ្សំគ្នានេះ ជាធម្មជាតិប្រែប្រួលជានិច្ចតទៅ មិនមែននៅដដែលៗទេ សូម្បីតែក្នុងខណៈចិត្តពីរ ដែលតៗគ្នាក៏ដោយ គ្រប់តែខណៈចិត្ត សុទ្ធតែកើតឡើងតាំងនៅ ហើយរលត់ទៅវិញ ជាធម្មតា។ កាលបើខន្ធបញ្ចកៈកំពុងកើតមានឡើង សត្វ ឈ្មោះថាកំពុងទ្រុឌទ្រោមទៅផង ឈ្មោះថាកំពុងស្លាប់ទៅផង ដូចពុទ្ធភាសិតថា ម្នាលភិក្ខុ គ្រប់ខណៈចិត្ត អ្នក ឈ្មោះថាកំពុងកើតឡើងផង ឈ្មោះថាកំពុងទ្រុឌទ្រោមទៅផង ឈ្មោះថាកំពុងស្លាប់ទៅផង។ ក្នុងចិរវេលាដែលយើងមានជីវិតរស់នៅ យើងកើតផង យើងរស់ផង យើងស្លាប់ផង គ្រប់ខណៈចិត្ត ប៉ុន្តែ យើងចេះតែបន្តការរស់ទៅបាន ក៏ព្រោះគ្រឿងចក្រគឺសព៌ាង្គកាយឋិតនៅល្អ បើគ្រឿងចក្រគឺសព៌ាង្គកាយបែកធ្លាយហើយ ធម៌ទាំងឡាយគឺ ឆន្ទៈ ចេតនា តណ្ហា .. ជាពលៈ ឬថាមពលនិងរុញច្រានទៅឲ្យយើងកើតទៀត។ សេចក្ដីនេះយើងចេះយល់ថា ជីវិត ការរស់នៅ របស់យើងនេះ ចេះតែបន្តគ្នាទៅបានដោយមិនមានធម្មជាតិអ្វីមួយទៀងទាត់ មិនចេះប្រែប្រួល ដូចជា ខ្លួនឯង ឬអត្មា ព្រលឹង នេះម្ដេចក៏យើងមិនចេះយល់ថា ពលៈ ឬថាមពលដែលជារបស់កាយ និងចិត្តនោះ វាអាចបន្តការប្រព្រឹត្តទៅបានរបស់វា ដោយមិនមាន ខ្លួនឯង ឬអាត្មា ព្រលឹង នៅខាងក្រៅខ្លួនវា បន្ទាប់ពីការឈប់ង៉ក់នៃការដើរគ្រឿងចក្រ គឺសព៌ាង្គកាយនោះផង?

យើងគប្បីយល់ថា បើកាយបែកធ្លាយ គឺស្លាប់ទៅហើយ ខន្ធដទៃទៀត ដែលរួមគ្នាជាខន្ធបញ្ចកៈក៏រលត់ទៅដែរ តែធម៌ទាំងឡាយជាកម្លាំង ដូចពលៈ ឬថាមពល គឺ ឆន្ទៈ ចេតនា តណ្ហា មិនរលត់ទៅជាមួយគ្រឿងចក្រគឺសព៌ាង្គកាយនោះទេ វាបន្តការដើររបស់វា ទៅកាន់យករូបកាយមួយដទៃទៀត ដែលលោកហៅថា ជីវិតថ្មី ឬ ភពថ្មីមួយទៀត។ កាលយើងស្ថិតនៅក្នុងកុមារភាព រូបកាយចិត្តទាំងអស់នេះ នៅទន់ខ្សោយនៅខ្ចី ប៉ុន្តែវាមិនមានអ្វីមួយនៅក្នុងខ្លួនវាជាពលានុភាព ធម៌នេះ វាផលិតនូវការចម្រើនធ្វើឲ្យមានវឌ្ឍនាការចម្រើនឡើងទៅជាមនុស្សធំ ពលៈ ឬថាមពលនៃកាយ និងចិត្តនេះហើយ រួមផ្សំគ្នាកើតបានទៅជាសព៌ាង្គកាយមួយ ដែលយើងហៅថា តួ បុគ្គល សត្វ ឬអាត្មា អញ ឯង ហើយវាចេះតែបន្តនៅក្នុងខ្លួនវា នូវពលានុភាពឲ្យកើតជាជីវិតថ្មី គឺភពថ្មីៗ ហើយមានវឌ្ឍនាការចម្រើនធំឡើង មានកម្លាំងពេញបរិបូណ៌ទៀតតទៅ។

ធម៌ទាំងនេះ ទោះបីវាមិនមានសារជាតិ ទៀតទាត់ មិនចេះប្រែប្រួលក៏ដោយ ក៏មិនមានអ្វីឆ្លងពី ខណៈចិត្តមួយទៅខណៈចិត្តមួទៀតទេ សូម្បីមើលទៅឃើញរូបជ្រងោ ក៏មិនមានអ្វីទៀងទាត់ ក៏មិនមានអ្វីមិនចេះ

ប្រែប្រួល ហើយវាមិនអាចនឹងឆ្លង ឬធ្វើវដ្តប្រវេសន៍ ពីជីវិតមួយទៅជីវិតមួយទៀតបានទេ បើចង់និយាយការនេះ គឺជាគ្រឿងបន្តមួយជាប់តគ្នារជឹក បន្តពីមួយទៅមួយរជឹកតទៅ ដែលលោកហៅថា សន្តតិ (ការតគ្រឿងបន្ត) ហើយវាចេះតែប្រែប្រួលទៅក្នុងខ្លួនវាគ្រប់ខណៈចិត្ត។ សន្តតិ (គ្រឿងបន្ត)នេះ បើនិយាយឲ្យសមរម្យមិនគឺអ្វីដទៃទេ គឺជាធម្មជាតិទទេ តែវាមានចលនា។ បើនឹងប្រៀបធៀប គួរប្រៀបធៀបដូចអណ្តាតភ្លើងដែលឆេះរហូតពេញមួយយប់ អណ្តាតភ្លើងនេះ មិនមែនអណ្តាតភ្លើងដដែលៗទេ ឬនឹងថាអណ្តាតភ្លើងមួយផ្សេងទៀតក៏មិនបានដែរគឺភ្លើងដដែលនោះឯងឆេះរហូតតទៅ។សេចក្តីនេះ យើងគួរយល់ដូចម្តេច? ដូចកុមារម្នាក់តទៅចម្រើនធំឡើងបានជាមនុស្សមានអាយុ៥០ឆ្នាំនេះ ដោយពិតមិនមែនកុមារដដែលទេ តែនឹងថាមនុស្សដទៃទៀតក៏មិនមែនដែរ ឯមនុស្សដែលស្លាប់ក្នុងភពនេះ ហើយទៅកើតក្នុងភពដទៃទៀតក៏មិនមែនដែរ នេះជាសន្តតិ គ្រឿងបន្តតគ្នារជឹក នៃអនុក្រមតែមួយនេះឯង។

**១០.១.៣. និរោធសច្ចៈ** (លទ្ធផលទទួលបាននៃកិច្ចប្រតិបត្តិ គឺសុភមង្គល បរមសុខ ព្រះនិព្វាន)

សច្ចៈភាពទីបី គឺជាអ្វីដែលយើងហៅថា "ការបញ្ឈប់ពិត"។ ជាទូទៅត្រូវបានគេបកប្រែថា "ការរំលត់ពិត" គឺសំដៅលើលទ្ធភាពដើម្បីបញ្ឈប់នូវ សេចក្តីភាន់ច្រឡំ ដើម្បីកុំឱ្យវាកើតឡើងទៀតបាន។ បើសិន យើងលុបបំបាត់សេចក្តីភាន់ច្រឡំ ដែលវាជាមូលហេតុពិតនោះ យើងនឹងអាចលុបបំបាត់នូវប ញ្ហាពិត (មោហៈ) បាន ពោលគឺសុខ និងទុក្ខនៅក្នុងឆាកជីវិត និងជាតិកំណើតដែលជាឫសគល់របស់វា។ ប្រសិន បើយើងសម្រេចវាបានតាមរយៈការបដិបត្តិនេះ យើងទទួលបាននូវអ្វីដែលយើងនៅថា "ការរួចរំដោះ"។ ខ្ញុំប្រាកដនៅក្នុងចិត្តថា អ្នកទាំងអស់គ្នាច្បាស់ជាបានយល់ បានឃើញពាក្យសំស្ក្រឹះទាំងនេះហើយ គឺពាក្យថា "សង្សារវដ្ត" ការកើតម្តងហើយម្តងទៀតមិនអាចគ្រប់គ្រងបាន និងពាក្យថា "និព្វាន" ការរួចរំ ដោះទុក្ខ។

នៅក្នុងសម័យព្រះពុទ្ធ មានប្រព័ន្ធជំនឿឥណ្ឌាជាច្រើនដែលនិយាយអំពី ការរួចរំដោះចេញពីវាលវដ្តសង្សារ។ កាលសម័យនោះ នេះគឺជាប្រធានបទសាមញ្ញទូទៅនៅក្នុងប្រទេសឥណ្ឌា។ តែទោះបីជាបែបហ្នឹងក្តី ព្រះសម្មាសម្ពុទ្ធ ទ្រង់បានឈ្វេងយល់ឃើញថា ប្រព័ន្ធជំនឿទាំងអស់នោះ មិនបានយល់ឱ្យបានស៊ីជម្រៅដើម្បីរកភិនភាគបង្ហាញឱ្យច្បាស់នូវ មូលហេតុពិត នៃបញ្ហាទេ។ អ្នកគ្រាន់តែអាចដកឃ្លាមួយរយៈ បានពីបញ្ហាដែលកើតឡើងដដែលៗនេះតែប៉ុណ្ណោះ។ ឧទាហរណ៍៖ កើតនៅក្នុងភពសួគ៌ណាមួយដែល ចិត្តរបស់អ្នកមានលក្ខណៈទទេស្អាត មួយរយៈពេលយូរ តែវានឹងដល់ទីបញ្ចប់របស់វា។ គ្មានទេការរួចរំដោះពិតប្រាកដនៅក្នុងប្រព័ន្ធជំនឿទាំងនោះ។

**១០.១.៤. មគ្គសច្ចៈ** (ហេតុដែលបណ្តាលឲ្យសម្រេចជោគជ័យក្នុងជីវិត គឺផ្លូវត្រង់ផ្លូវ៨)

១-សម្មាទិដ្ឋិៈ ប្រាជ្ញាយល់ឃើញត្រូវ បានដល់ប្រាជ្ញាដឹងក្នុង អរិយសច្ចៈ ៤

- ទុក្ខៈ ធម្មជាតដែលនាំឲ្យលំបាកព្រួយមានជាតិ ជរា មរណៈជាដើម
- ទុក្ខសមុទយៈ ហេតុបណ្តាលឲ្យកើតទុក្ខបានដល់តណ្ហា
- ទុក្ខនិរោធៈ ព្រះនិព្វានរំលត់តណ្ហាបណ្តាលទុក្ខ

- ទុក្ខនិរោធគាមិនីបដិបទា មជ្ឈមមាគ៌ានាំឲ្យទៅកាន់ទីរំលត់ទុក្ខ ។

២-សម្មាសំង្កប្បៈ សេចក្តីត្រិះរិះត្រូវ បានដល់សេចក្តីត្រិះរិះត្រូវ ៣ យ៉ាងគឺ

- នេក្ខម្មសង្កប្បៈ សេចក្តីត្រិះរិះក្នុងការចេញចាកកាម

- អព្យាទសង្កប្បៈ សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ

- អវិហឹសាសង្កប្បៈ សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន។

៣-សម្មាវាចាៈ សំដីត្រូវ បានដល់ការវៀរចាក វចីទុច្ចរិត ៤ យ៉ាង គឺ

- មុសាវាទា វេរមណី ការវៀរចាកកិរិយាពោលកុហក

- បិសុណាយ វាចាយ វេរមណី ការវៀរចាកសំដីញុះញង់

- ផរុសាយ វាចាយ វេរមណី ការវៀរចាកសំដីទ្រគោះ

- សម្ផប្បលាបា វេរមណី ការវៀរចាកកិរិយាពោលរឿងឥតប្រយោជន៍។

៤-សម្មាកម្មន្តៈ ការងារត្រូវបានដល់ការវៀរចាក កាយទុច្ចរិត ៣ យ៉ាងគឺ

- បាណាតិបាតា វេរមណី ការវៀរចាកកិរិយាបំបាត់ប្រាណសត្វ

- អទិន្នាទានា វេរមណី ការវៀរចាកការកាន់យកវត្ថុដែលគេមិនឲ្យ

- កាមេសុមិច្ឆាចារា វេរមណី ការវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

-សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ សម្រាប់គ្រហស្ថ បានដល់ការវៀរចាកជំនួញខុស កិរិយាលះបង់ការបំបាត់ដោយជញ្ជីងជាដើម ការធ្វើជាសាក្សីកោង, ការល្មោភសំណូក ហើយប្រកបអាជីវកម្ម ដោយវណិជ្ជកម្មដែលនាំឲ្យសេដ្ឋកិច្ចជាតិចំរើន ដោយវិជ្ជាជីវៈ ដ៏យុត្តិធម៌ ដោយកសិកម្ម ជាឧត្តមកម្ម នឹងគោរក្ខកម្ម សម្រាប់បព្វជិត បានដល់ការលះបង់មិច្ឆាអាជីវៈដោយអនេសនៈបាបធម៌ មានទូតកម្ម វេជ្ជកម្មជាដើម ការត្រាច់ទៅកាន់អគោចរដ្ឋាន ហើយចិញ្ចឹមជីវិតដោយភិក្ខាចរិយធម៌ដ៏ស្មើ ឬបច្ច័យដែលកើតឡើងតាមធម៌។

៦-សម្មាវាយាមៈ ព្យាយាមត្រូវ បានដល់សម្មប្បធាន គឺការបង្កើតឆន្ទៈ ព្យាយាមប្រារព្ធ វិរិយៈ តាំងបធាន ផ្គងចិត្តៈ

-ដើម្បីមិនឲ្យអកុសលធម៌លាមក មិនទាន់កើតឡើង កើតឡើងបាន,

-ដើម្បីលះបង់នូវអកុសលធម៌លាមកកើតឡើងហើយ,

-ដើម្បីឲ្យកុសលធម៌មិនទាន់កើតឡើង កើតឡើង,

-ដើម្បីឲ្យកុសលធម៌កើតឡើងហើយ ឋិតនៅ មិនសាបសូន្យ ឲ្យចំរើនច្រើនឡើង ឲ្យចំរើនទូលំទូលាយ ឲ្យបរិបូណ៌ ។

៧-សម្មាសតិៈ ការរលឹកត្រូវ បានដល់ សតិប្បដ្ឋាន ៤ គឺ

១- កាយានុបស្សនាសតិប្បដ្ឋាន កិរិយាដំកល់សតិខ្ជាប់ខ្ជួនពិចារណារឿយ ៗ ក្នុងកាយ

២- វេទនានុបស្សនាសតិប្បដ្ឋាន កិរិយាដំកល់សតិ ខ្ជាប់ខ្ជួន ពិចារណារឿយ ៗ ក្នុងវេទនា

៣- ចិត្តានុបស្សនាសតិប្បដ្ឋាន កិរិយាដំកល់សតិ ខ្ជាប់ខ្ជួន ពិចារណារឿយ ៗ ក្នុងចិត្ត

៤- ធម្មានុបស្សនាសតិប្បដ្ឋាន កិរិយាដំកល់សតិ ខ្ជាប់ខ្ជួន ពិចារណារឿយ ៗ ក្នុងធម៌។

៨-សម្មាសមាធិៈ សមាធិត្រូវ បានដល់ឈាន៤ ដែលភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ចាកអកុសលធម៌ទាំងឡាយ ហើយបានសម្រេច គឺ ៖

១. បឋមជ្ឈាន ប្រកបដោយ វិតក្កៈ វិចារៈ មានបីតិ សុខៈ កើតអំពីវិវេគ,

២. ទុតិយជ្ឈាន រម្ងាប់វិតក្កៈ វិចារៈ ថ្លាល្អខាងក្នុង មានឯកោទិភាពចិត្ត មានបីតិសុខកើតអំពីវិវេគ

៣. តតិយជ្ឈាន ប្រាសចាកបីតិ មានសុខៈ នឹងឧបេក្ខា

៤. ចតុត្ថជ្ឈាន លះបង់សុខនឹងទុក្ខ មិនមានសោមនស្សទោមនស្ស ជាអទុក្ខមសុខៈ មានសតិប្រកបដោយឧបេក្ខាដ៏បរិសុទ្ធ។

បណ្ដាមគ្គទាំង ៨

- សម្មាទិដ្ឋិ ញ៉ាំងលោកឲ្យដឹងច្បាស់នូវ អនិច្ចតា ទុក្ខតា អនត្តតា នូវសមុទ័យនៃលោកប្បញ្ញា គឺតណ្ហា នូវឧបាយដោះនឹងកិរិយាដោះ។

- សម្មាសង្កប្បៈ ឲ្យស្គាល់សមុដ្ឋានអសន្តិភាព គឺកាមៈ ព្យាបាទៈ វិហឹសា ហើយឲ្យសាងសន្តិភាពដោយកាមវិរតិ ព្រហ្មវិហារធម៌៤ជាធម៌ស្ងួនលោក។

- សម្មាវាចា ឲ្យមានសច្ចៈ មានសន្តិភាពសាមគ្គីអរិយធម៌ដោយវាចានឹងវាចាប្រកបដោយប្រយោជន៍។

- សម្មាកម្មន្តៈ ឲ្យគោរពសិទ្ធិ សេរីភាព អធិបតេយ្យ ដែលមានសម្រាប់កាយិកសុខ ចេតសិកសុខជីវិតសវិញ្ញាណកាវិញ្ញាណកទ្រព្យ គ្រាមធម៌។

- សម្មាអាជីវៈ ឲ្យប្រកបអាជីវកម្មដោយធម៌។

- សម្មាវាយាមៈ ឲ្យលះបង់អាលស្យភាព (កំជិល) ដែលជាប្រធានអកុសលធម៌។

- សម្មាសតិ ឲ្យមានសតិសម្បជញ្ញៈជានិច្ចថា "លោកមានសមភាពទៅវិញទៅមក" ព្រោះលោកជាទឹកដី ភ្លើង ខ្យល់ បិតនៅក្នុងអាណា អនិច្ចតា ទុក្ខតា អនត្តតា ដូចគ្នា ជាប់ចោទលោកប្បញ្ញាដូចគ្នា។

- សម្មាសមាធិ ឲ្យមានចិត្តស្អាតផូរផង់ តាំងនៅមាំមួនចំពោះសត្វនឹងសង្ខារ។

មគ្គទាំង ៨ នេះចាត់ចូលក្នុងសិក្ខាទាំង ៣គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ ចូលក្នុង អធិប្បញ្ញា សិក្ខា សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ចូលក្នុង អធិសីលសិក្ខា សម្មាវិយាមៈ សម្មាសតិ សម្មាសមាធិ ចូលក្នុង អធិចិត្តសិក្ខា ។

ព្រះពុទ្ធសាសនា មានគោលធម៌ប៉ុណ្ណេះជាដើម ដែលជាពន្លឺបំភ្លឺលោក ឲ្យភ្លឺស្វាងចាកមហន្ធការគឺអវិជ្ជា ហើយឲ្យស្គាល់មធ្យោបាយសាងសន្តិភាពសម្រាប់សាកលលោក នឹងឯកន្តសន្តិភាព គឺសន្តិភាពសម្រាប់ខ្លួននាបច្ចុប្បន្ន អនាគត នឹងសន្តិភាព រួចចាកអណាលោករាជនឹងលោកប្បញ្ញានាអវសានជាតិ។

## ១០.២. បដិច្ចសមុប្បាទធម៌

### ១០.២.១. អវិជ្ជា

អវិជ្ជា តាមន័យរបស់ព្រះពុទ្ធសាសនាជាសភាវធម៌ សំដៅយកការមិនដឹងនូវអរិយសច្ច៤ គឺមិនដឹងនូវទុក្ខ មិនដឹងនូវហេតុដែលនាំឲ្យកើតទុក្ខ មិនដឹងនូវការរំលត់ទុក្ខ មិនដឹងនូវផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខ។ អវិជ្ជាជានាមធម៌ ពុំមិនមែនជារូបធម៌ ដូចជាដីទឹកភ្លើងខ្យល់ឡើយ គឺជាគំនិតយល់ខុស បើគំនិតយល់ត្រូវហៅថា មានវិជ្ជា គឺមានចំណេះយល់ច្បាស់ក្នុងអរិយសច្ច៤។ អវិជ្ជាផ្លូវធម៌ផ្សេងពីអវិជ្ជាផ្លូវលោក។ អវិជ្ជាផ្លូវលោកសំដៅយកការពុំចេះនូវវិជ្ជាទាំងឡាយដែលមនុស្សលោកបង្កើតឡើង ដូចជាពុំចេះអក្សរសាស្រ្ត ពុំចេះប្រវត្តិសាស្រ្តភូមិសាស្រ្ត ចរិយាសាស្រ្ត ទស្សនវិជ្ជា និងបច្ចេកវិទ្យាផ្សេងៗ ជាដើម។ ឯអវិជ្ជាផ្លូវធម៌ ពុំមែនល្ងង់ព្រោះ

មិនចេះនូវវិជ្ជាទាំងនេះទេ ព្រោះវិជ្ជាផ្លូវលោកទាំងនេះមានភាពពិតតាមលោកសច្ចៈ។ អ្នកមានវិជ្ជាផ្លូវលោកទាំងនេះពុំឈ្មោះថាអស់អវិជ្ជាឡើយ គឺនៅមានអវិជ្ជាដដែល អវិជ្ជាព្រោះពុំដឹងនូវអរិយសច្ចដែលធ្វើឲ្យទុក្ខអស់ទៅ មានជាតិទុក្ខជាដើម។ អវិជ្ជាពុំដឹងថាខ្លួន មនុស្សចែកជាខន្ធ៥ គឺ រូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណ ដែលប្រព្រឹត្តទៅដោយលក្ខណៈ៣យ៉ាងគឺ អនិច្ចំ មិនទៀងជាទុក្ខ និងជា អនត្តា ពុំមែនខ្លួនប្រាណ ។ ព្រះពុទ្ធសម្តែងថា សេចក្តីល្ងង់អ្វីពុំស្មើនឹងសេចក្តីល្ងង់ក្នុងខន្ធ៥ ឡើយ។ ការស្គាល់លក្ខណៈខន្ធ៥ ទើបធ្វើទុក្ខឲ្យអស់ទៅបាន។ វិជ្ជាផ្លូវលោកគ្រាន់តែសម្រួលឲ្យរស់នៅក្នុងសង្គម បានសុខស្រួលខ្លះប៉ុណ្ណោះ ប៉ុន្តែពុំអាចធ្វើទុក្ខមានជាតិទុក្ខជាដើម ឲ្យអស់ទៅបានឡើយ។ ចំណែកការមានវិជ្ជាក្នុងខន្ធ៥ ផ្នែកវិបស្សនាវិជ្ជា ទើបធ្វើទុក្ខឲ្យអស់ទៅបាន។ អវិជ្ជាកន្លែងខ្លះ វិគ្គហៈថា ធម្មជាតិបាននូវអំពើដែលគេមិនចង់បាន បានដល់ទុច្ចរិត៣យ៉ាងគឺ កាយទុច្ចរិត វចីទុច្ចរិត និង មនោទុច្ចរិត។ មួយទៀតថា ធម្មជាតិមិនបាននូវអំពើដែលគេត្រូវបាន បានដល់ កាយសុចរិត វចីសុចរិត និង មនោសុចរិត។ អវិជ្ជាពុំដឹងនូវខន្ធអនាគត ពុំដឹងនូវខន្ធទាំងអតីត និងអនាគត និងពុំដឹងនូវបដិច្ចសមុប្បាទធម៌ គឺធម៌កើតរលត់តគ្នា ដោយហេតុ ដោយបច្ច័យ ដូចជាអវិជ្ជាកើតមាននាំឲ្យមានសង្ខាររហូតជាតិកើតមាន នាំឲ្យមានជរា និងមរណៈជាដើម។ ព្រះពុទ្ធសម្តែងថាតថាគតរកពុំឃើញធម៌ណាមួយ ដែលមានទោសដូចអវិជ្ជានេះឡើយ អវិជ្ជាមានទោសធ្ងន់ជាងធម៌ដទៃដោយហេតុថា មនុស្សសត្វធ្វើខុសដោយសារអវិជ្ជា ការពុំដឹង នូវអរិយសច្ច៤ គឺពុំដឹងនូវទុក្ខ នូវហេតុដែលនាំឲ្យកើតទុក្ខជាដើមនេះឯង។ ប្រៀបដូចមនុស្សងងឹតភ្នែកពីកំណើត ហើយវង្វេងផ្លូវក្នុងព្រៃតែងតែដើរខុសផ្លូវជាធម្មតា។ អវិជ្ជា ប្រៀបដូចជាសត្វមមាចមមង់ ដែលឃើញអណ្តាតភ្លើងភ្លឺថ្លាក៏ស្មានខុសថាជាពន្លឺគួរជាទីរីករាយសប្បាយឥតបានដឹងថាភ្លើងនោះក្តៅក៏ហើរចូលទៅដល់នូវការក្សិណក្ស័យជីវិត។ ប្រៀបម្យ៉ាងទៀតដូចសត្វដង្កូវនាង ដែលរុំព័ទ្ធខ្លួននៅក្នុងសំបុក បានត្រូវគេយកទៅស្ងោរដើម្បីយកសរសៃសូត្រ ដែលរុំព័ទ្ធខ្លួនវាធ្វើជាសូត្រ ដើម្បីត្បាញធ្វើសំពត់ស្លៀកពាក់ក៏ក្ស័យជីវិតទៅ។

សេចក្តីទាំងអស់នេះ ប្រៀបដូចជាបុគ្គលប្រកបដោយ អវិជ្ជា បិទបាំងពុំឲ្យឃើញការពិត ហើយប្រព្រឹត្តតាមការយល់ខុសនោះ ក៏ដល់នូវសេចក្តីវិនាសទៅ។ អវិជ្ជា អាចកម្ចាត់បានដោយការសិក្សាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយប្រតិបត្តិតាមសមថវិបស្សនាឲ្យឃើញអរិយច្ចទាំង៤ ពន្លះមគ្គផលនិព្វានរហូតអរហត្តផល។ ពុទ្ធសាសនិកដែលបានសិក្សាយល់ច្បាស់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ទោះពុំអាចលះបង់អវិជ្ជានេះបានក្នុងពេលនេះ ក៏ឈ្មោះថាដើរត្រូវតាមផ្លូវដែលត្រូវលះហើយ។ អវិជ្ជាបិទបាំងមិនឲ្យឃើញការពិតនេះ មានទោសទាំងផ្លូវលោក និងផ្លូវធម៌។

នៅក្នុងគម្ពីរព្រះអភិធម្មបានពន្យល់ថា អវិជ្ជាគឺជាមេនាំអាទិ៍ឲ្យមានជាតិ កំណើត និងជាតួជីវិតនេះឯង។ អវិជ្ជានោះមាន៨យ៉ាងគឺ:

១- មិនដឹងក្នុងសេចក្តីសុខ គឺមិនដឹងក្នុងទុក្ខទាំង១២កង មានជាតិទុក្ខជាដើម។

២- មិនដឹងនូវធម៌ជាហេតុនាំឲ្យកើតទុក្ខ គឺមិនដឹងនូវតណ្ហា សេចក្តីប្រាថ្នាគ្រប់យ៉ាង។

៣- មិនដឹងនូវព្រះនិព្វានជាទីរំលត់នូវសេចក្តីទុក្ខទាំងអស់។

៤- មិនដឹងនូវផ្លូវជាទីចូលទៅរំលត់នូវសេចក្តីទុក្ខ។

៥- សេចក្តីមិនដឹងក្នុងខន្ធ គឺមិនដឹងនូវជាតិកំណើតដែលធ្លាប់កើតក្នុងជាតិមុនៗ។

៦- មិនដឹងនូវជាតិកំណើតដែលនឹងកើតតទៅជាតិខាងមុខៗទៀត។

៧- សេចក្តីមិនដឹងទាំងក្នុងអតីត ទាំងក្នុងអនាគត។

៨- សេចក្តីមិនដឹងក្នុងនាមរូប ដែលកើតឡើងដោយអាស្រ័យហេតុបច្ច័យ ។

អវិជ្ជាទាំង៨នេះ រមែងនាំបដិសន្ធិសត្វលោកឲ្យវិលកើតចាស់ឈឺស្លាប់នៅក្នុងវាលវដ្តសង្សារនេះ គ្មានទីបំផុតឡើយ។

### ១០.២.២. សង្ខារ

សង្ខារ ប្រែថា ការតាក់តែង គ្រឿងប្រកប គ្រឿងប្រុងផ្តុំ ប្រមូលផ្សំ ចែកចេញជា៣យ៉ាងគឺ

បុញ្ញាភិសង្ខារការតាក់តែងសត្វឲ្យកើតក្នុងកាមាវចរភូមិនិងរូបាវចរភូមិ១ អបុញ្ញាភិសង្ខារ ការតាក់តែងសត្វឲ្យកើតក្នុងអបាយភូមិទាំងបួនមាននរកជាដើម១ អនេញ្ជាភិសង្ខារ ការតាក់តែងសត្វឲ្យកើតក្នុងអរូបព្រហ្ម។ សង្ខារចែកជា៣យ៉ាងទៀតគឺ កាយសង្ខារ ការកម្រើកអវយវៈដូចជាលើកដៃ លើកជើង ឈានដើរជាដើម១ វចីសង្ខារ ការកម្រើកវាចាគឺនិយាយស្តី សើច យំ ជាដើម១ ចិត្តសង្ខារ ការត្រិះរិះនូវអារម្មណ៍ផ្សេងៗ សង្ខារនេះបើចែកទៅតាមជាតិមាន៣គឺ កុសលសង្ខារ១ អកុសលសង្ខារ១ អព្យាកតសង្ខារ១ ដូចគ្នានឹងវេទនាដែរ។ ការរួបរួមសង្ខារទាំងអស់ ដូចបានរៀបរាប់មកប៉ុណ្ណេះជាដើមនេះ ហៅថា សង្ខារក្ខន្ធ។

សង្ខារកើតមានបានជាបច្ច័យនាំឲ្យវិញ្ញាណមកតាំងនៅកុសលចេតនា និងអកុសលចេតនាជា ប្រភពជា ដែនកើតរបស់សង្ខារធម៌ ដែលតាំងនៅត្រង់ភពមានមហាភូតរូប៤

១. អាកាសធាតុៈក៏តាក់តែងឡើងបានជាបច្ច័យនាំឲ្យនាមរូបកើតឡើង។

២. នាមរូបៈកាលបើកើតមានរមែងជាបច្ច័យនាំឲ្យសឡាយតនៈកើតមាន។

៣. អាយតនៈ៦ ជាលំនៅរបស់អារម្មណ៍ជាទីដែលចិត្តតោងយកអារម្មណ៍កាលបើអាយតនៈ កើតមាន បានជាបច្ច័យនាំឲ្យផស្សៈរមែងកើតមាន។ ព្រោះអាយតនៈតាក់តែងកើតឡើងពីមហាភូតរូប៤ពីអាកាសធាតុ ដែលនៅជាមួយគ្នារមែងមានការប៉ះផ្ទប់ ហើយការប៉ះផ្ទប់នេះក៏ចាត់ទុកជាអារម្មណ៍មួយដែរ។ ដូច្នេះកាលបើមានផស្សៈនៅត្រង់អាយតនៈណា ជាបច្ច័យនាំឲ្យវេទនាកើតឡើងនៅត្រង់អាយតនៈនោះ។ វេទនាជាធម្មជាតិដឹង ឬសោយរសរបស់អារម្មណ៍កាលបើវេទនាកើតឡើង ជាបច្ច័យនាំឲ្យតណ្ហាកើតមាន គឺសេចក្តីប្រាថ្នាចំពោះរសរបស់អារម្មណ៍ កាលបើចិត្តប្រាថ្នាពោល គឺតណ្ហាកើតមានជាបច្ច័យនាំឲ្យឧបាទាន គឺចូលទៅ កាន់យកប្រកាន់មាំចំពោះអារម្មណ៍ក៏កើតមាន សេចក្តីលោភៈកើតឡើងរមែងញុំាងបុគ្គលឲ្យជាប់ជំពាក់ចំពោះអារម្មណ៍នោះ។ ឯការកាន់យកប្រកាន់មាំនោះគឺកាន់យកវត្ថុសត្វបុគ្គល ដែលមាននៅក្នុងភពនោះៗជាបច្ច័យ នាំឲ្យភពកើតមានឡើងបានដល់កម្មភព១ ឧប្បត្តិភព១ បានជាបច្ច័យនាំឲ្យជាតិកំណើត៤ក៏កើតមានឡើង។ ឯជរាមរណៈ កើតសេចក្តីក្រៀមស្ងួតចិត្ត សេចក្តីខ្សឹបខ្សួល សេចក្តីទោមនស្សតែងមានព្រមតែង កើតព្រម ព្រោះអាស្រ័យហេតុយ៉ាងនោះ។ ឃើញថា បដិច្ចសមុប្បាទធម៌ ក៏មិននៅក្រៅអំពីរូបធម៌នាមធម៌នេះដែរ

ទាំងនេះគឺជាពន្លឺសម្រាប់ការចំរើនវិបស្សនាភាវនា គោលដៅគឺ បង្កើតវិបស្សនាបញ្ញាដើម្បីរំលត់អវិជ្ជា ដែលជាឫសគល់នៃទុក្ខ។

### ១០.២.៣. វិញ្ញាណ

វិញ្ញាណ ប្រែថា ធម្មជាតិដឹងច្បាស់នូវអារម្មណ៍ទាំងពួង អារម្មណ៍ទាំង៦មានរូបារម្មណ៍ជាដើម តែងមកផ្ទប់ក្នុងទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម ធម្មជាតិដែលដឹងនូវអារម្មណ៍នោះ ជាក់ច្បាស់ជាងចេតសិកធម៌ទាំងពួង ហៅថា វិញ្ញាណ វិញ្ញាណនោះហៅថា ចិត្ត ក៏បាន ព្រោះជាធម្មជាតិតែងសន្សំនូវអារម្មណ៍ទាំងពួង ហៅថា មនោ ក៏បាន ព្រោះជាធម្មជាតតែងទន់ទោរទៅកាន់អារម្មណ៍។

វិញ្ញាណ (Consciences) បានដល់ការដឹងគឺការដឹងតាមភ្នែកហៅថាចក្ខុវិញ្ញាណ។

| | | |
|---|---|---|
| ការដឹងតាមត្រចៀក | ហៅថា | សោតវិញ្ញាណ |
| ការដឹងតាមច្រមុះ | ហៅថា | ឃានវិញ្ញាណ |
| ការដឹងតាមអណ្ដាត | ហៅថា | ជីវ្ហាវិញ្ញាណ |
| ការដឹងតាមផ្លូវកាយ | ហៅថា | កាយវិញ្ញាណ |
| ការដឹងតាមផ្លូវចិត្ត | ហៅថា | មនោវិញ្ញាណ។ |

កាលណាផលល្អកើតឡើង ការដឹងនោះរមែងប្រព្រឹត្តទៅជាសុខ ប៉ុន្តែប្រសិនបើផលអាក្រក់កើតឡើង ការដឹងនោះរមែងប្រព្រឹត្តទៅជាទុក្ខ។ ដូចជីវិតរស់នៅរបស់មនុស្ស កាលបើមនុស្សរស់នៅក្នុងសង្គមមានច្បាប់ទម្លាប់ល្អ មនុស្សគ្រប់គ្នាប្រតិបត្តិតាមច្បាប់ផល នៃសង្គមក៏កើតឡើងមានសណ្ដាប់ធ្នាប់ល្អ ចិត្តរបស់មនុស្សរមែងដឹងច្បាស់ថា ខ្លួនរស់នៅមានសេចក្ដីទុក្ខដូច្នេះឯង។

### ១០.២.៤. នាមរូប

នាមរូប(Mind and Matter) សំដៅដល់ជីវិតរបស់មនុស្ស ដែលអាស្រ័យដោយជីវៈ(Life) និងសរីរៈ (Body)។ សភាវៈនៃជីវៈគឺ ជានាមដែលទទួលនូវការដឹងមានន័យថាជាភាវៈដឹងចំណែក ឯសរីរៈ គឺជារូបដែលជាភាវៈពុំដឹង។ ធម្មជាតិពីរយ៉ាងនេះរស់នៅអាស្រ័យគ្នាសភាពទុកលំបាក ឬសុខសាន្តរបស់រូប ឬសរីរៈគឺនាមជាអ្នកទទួលដឹងនូវសភាពជាទុក្ខលំបាក និងសុខសាន្តនោះៗ ចំណែកសភាពទោមនស្សសោមនស្សកើតចេញពីនាមក៏អាស្រ័យ រូប ផងដែរ ទើបសភាពដូច្នេះ (ទោមនស្សសោមនស្ស) អាចប្រព្រឹត្តទៅបាន។

### ១០.២.៥. សឡាយតនៈ

សឡាយតនៈ(Matter six bases ) ជាវត្ថុទាំង៦ដែលកើតឡើង អាស្រ័យ នៃសរីរៈនេះហើយវាគឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្តប្រព្រឹត្តទៅគ្រប់ឥរិយាបថទាំងអស់របស់មនុស្ស។ ព្រោះហេតុនោះហើយទើបត្រូវមានច្បាប់ ដើម្បីបញ្ញត្តិតាំងឡើង ទុកសម្រាប់ប្រើប្រាស់វាឲ្យស្របតាមឆន្ទះ នៃមនុស្សគ្រប់គ្នាចង់បានគឺជាផលប្រយោជន៍នៃសេចក្ដីសុខសាន្តទាំងអស់គ្នា។

### ១០.២.៦. ផស្សៈ

ផស្សៈ (Contact) ជាផលទទួលពីធម្មជាតិក្នុងការទួលភ្ជាប់ពីសរីរៈមកជីវៈ ការកើតឡើងរបស់ផស្សអាស្រ័យដោយការប្រជុំនូវភាវៈ៣ទៀតគឺ សឡាយតនៈ វិញ្ញាណ និងវេទនា។

### ១០.២.៧. វេទនា

វេទនា ការទទួលអារម្មណ៍ ការសោយ ឬការរងអារម្មណ៍ ការដឹង អារម្មណ៍ ជា សុខ ឬជាទុក្ខ.។ ច្រើនសំដៅចំពោះការទទួលអារម្មណ៍ ជាទុក្ខៈ គួរឲ្យមានវេទនាណាស់!។ ពោលតាម គម្ពីរពុទ្ធសាសនា វេទនាមាន ៥ យ៉ាងគឺ ១-សុខ វេទនា : ការទទួលអារម្មណ៍ជាសុខ ២-ទុក្ខវេទនាជាទុក្ខ ៣-ឧបេក្ខាវេទនា ជា ឧបេក្ខា ៤-សោមនស្ស វេទនាជា សោមនស្ស ៥-ទោមនស្ស វេទនាជា ទោមនស្ស។ ខ្មែរប្រើក្លាយជា កិ. ក៏មាន សំដៅសេចក្ដីថា "រងទុក្ខ លំបាក": វេទនាណាស់ ! វេទនាអ្វីម្ល៉េះទេ!។

### ១០.២.៨. តណ្ហា

អ្វីទៅហៅថា តណ្ហា?

តណ្ហា ជាសេចក្ដីត្រូវការ ការចង់បានរបស់តួបុគ្គលមនុស្សម្នាក់ៗ។ ដោយសារតណ្ហា ជាចេតនានៃការចង់បានរបស់មនុស្ស ទើបតណ្ហាជាកំលាំងនាំឱ្យចិត្តមនុស្សមានសកម្មភាពខ្លាំង។ តណ្ហា ជាហេតុនាំអោយចិត្តបង្កើតជាគំនិតជាច្រើនឥតឈប់នៅក្នុងចិត្ត។ តណ្ហាជាហេតុនាំអោយមនុស្សធ្វើរឿងជាច្រើន ដើម្បីផ្លាស់ប្ដូរបាននូវរបស់អ្វីមួយដែលខ្លួនចង់បាន។ ដោយសារកំលាំងនៃតណ្ហា បានជំរុញឱ្យមនុស្សយើង ភ្ញាក់ពីគេង ត្រូវគិតពីរឿងនេះ ទៅគិតពីរឿងនោះ ធ្វើសកម្មភាពនេះ ធ្វើសកម្មភាព ដើម្បីដេញតាមរបស់ដែលខ្លួនចង់បាននោះ។ តណ្ហាគឺជាថាមពលផ្ដល់អោយចិត្ត បញ្ជាចុះមកក្នុងរាងកាយមនុស្សឱ្យធ្វើសកម្មភាព។ជាទូទៅ រាល់សកម្មភាព កាយវិការរបស់បុគ្គលមនុស្សម្នាក់ៗ សុទ្ធតែបំរើអោយគោលបំណងអ្វីមួយទាំងអស់ ហើយគោលបំណងទាំងនោះ ភាគច្រើន សុទ្ធតែកើតចេញពីកម្លាំងនៃសេចក្ដីត្រូវការ កម្លាំងនៃតណ្ហារបស់មនុស្សនេះឯង។ តណ្ហារបស់មនុស្សយើងម្នាក់ៗ ដែលកើតមានពីពេលមួយខណៈពេល ទៅមួយខណៈពេល វាមិនបាត់ទៅណាឡើយ គឺវានៅលាក់ពួននៅជាគ្រាប់ពូជកម្មនៅក្នុងខ្លួនមនុស្សម្នាក់ៗ ហើយវាចង់ចាំពេលវេលាល្អ វាចេញមកទៀត ជំរុញឱ្យការចង់បាននោះមានក្នុងចិត្តម្ដងទៀត។ ក្នុងខ្លួនមនុស្សយើងម្នាក់ៗសព្វថ្ងៃមានផ្ទុកនូវគ្រាប់ពូជតណ្ហាជាច្រើនពេញខ្លួន ហើយវាមានលលក្ខណៈជាប្រៀបដូចដែកឆក់ ដែលចាំទាក់ឆក់យកតណ្ហាថ្មីទៀតមកនៅជាមួយគ្នាទៀតឱ្យបានច្រើន ដូច្នេះហើយ បានជាមនុស្សពីមួយថ្ងៃទៅមួយ ពីតូចទៅធំ ចេះតែមានសេចក្ដីត្រូវការ ឬតណ្ហាកាន់តែច្រើនទៅៗ ព្រោះកាលណាយើងមានតណ្ហាកាន់តែយើង កំលាំងឆក់យកតណ្ហាថ្មីក៏កាន់តែខ្លាំងដែរ ដូច្នេះ ជីវិតមនុស្សរស់នៅមិនដែលបានទំនេរ ឬបានសំរាកម្ដងឡើយ គឺរស់នៅសំរាប់តែដេញតាមតណ្ហានេះរហូត មិនចេះអស់។

### ១០.២.៩. ឧបាទាន

ឧបាទាន, ខន្ធ និង ឧបាទានក្ខន្ធ

១. ឧបាទាន (សេចក្ដីប្រកាន់មាំ)

ពាក្យថា ឧបាទាន កាលញែកបទហើយបាន ២ បទ គឺ ឧប + អាទាន = ឧបាទាន។

ឧប ប្រែថា មាំ អាទាន ប្រែថា កាន់យក ឬប្រកាន់ កាលរួមទាំង ២ បទ ចូលគ្នាហើយ ប្រែថា ការប្រកាន់មាំ

ក្នុងអារម្មណ៍ ធម៌ដែលប្រកាន់មាំក្នុង អារម្មណ៍។ ដែលហៅថា ឧបាទាននេះ ប្រៀបដូចពស់ដែលចាប់កង្កែប តែងខាំកង្កែបនោះទុកយ៉ាងមាំ មិនលែង យ៉ាងណា លោភៈ ទិដ្ឋិ ទាំង២នេះ ដែលមាន សភាពប្រកាន់មាំក្នុងអារម្មណ៍របស់ខ្លួនៗ មិនលែង ក៏យ៉ាងនោះដែរ ដូចមាន វចនត្ថៈថា ឧបាទីយន្តីតិ ឧបាទានានិ ធម៌ពួកណារមែងប្រកាន់មាំក្នុងអារម្មណ៍ ព្រោះហេតុនោះ ធម៌ពួកនោះ ឈ្មោះថា ឧបាទាន។

ឧបាទានមាន៤គឺ ៖

១. កាមុបាទាន ធម្មជាតជាគ្រឿងប្រកាន់មាំក្នុងកាមារម្មណ៍ អង្គធម៌ បានដល់ លោភចេតសិកក្នុងលោភមូលចិត្ត៨ដួង។

២. ទិដ្ឋុបាទាន ធម្មជាតិជាគ្រឿងប្រកាន់មាំក្នុងការយល់ខុស ដែលក្រៅពីសីលព្វតបរាមាសទិដ្ឋិ និងអត្តវាទទិដ្ឋិ អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុង ទិដ្ឋិ-គតសម្បយុត្តចិត្ត៤ដួង។

៣. សីលព្វតុបាទាន ធម្មជាតិជាគ្រឿងប្រកាន់មាំក្នុងការបដិបត្តិខុស អង្គបានដល់ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត៤ដួង។

៤. អត្តវាទុបាទាន ធម្មជាតិជាគ្រឿងប្រកាន់មាំក្នុងនាមរូប ខន្ធ ៥ ថាជាតួខ្លួន អង្គធម៌បានដល់ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង ។

### ១០.២.១០. ភព

ភពក្នុងព្រះពុទ្ធសាសនាមាន៣ ចែកជាឋាន៣១ជាន់គឺ (រាប់ពីឋានក្រោមឡើងទៅលើ)

១. **កាមភព**១១ជាន់ ចែកចេញជាអបាយភូមិ៤ មនុស្ស១ និងសួគ៌៦ជាន់គឺ៖

- អបាយភូមិ៤៖ នរក ប្រេត តិរច្ឆាន និង អសុរកាយ។
- ឋានមនុស្ស១៖ ឋានមនុស្សលោកយើង។
- ឋាន៦ជាន់៖ ចាតុម្មហារាជិកា តាវតឹង្សាយាមា តុសិតា និម្មានរតី បរនិម្មិតវសវតី។

២. **រូបភព**១៦ជាន់ ស្ថិតនៅលើឋានទេវតា៦ជាន់ ជាកន្លែងមានរូប ប៉ុន្តែមិនមានកាម មិនមានតណ្ហា មិនមានភេទប្រុសស្រី មាន១៦ជាន់គឺ ព្រហ្មបារសជ្ជា ព្រហ្មបុរោហិតា មហាព្រហ្ម បរិត្តាភាព្រហ្ម អប្បមាណាតាព្រហ្ម អាភស្សរាព្រហ្ម បរិត្តាសុភាព្រហ្ម អប្បមាណសុភាព្រហ្ម សុភកិណ្ណកាព្រហ្ម វាហប្ផលាព្រហ្ម អសញ្ញីសត្តាព្រហ្ម អវេហាព្រហ្ម អតប្បាព្រហ្ម សុទស្សាព្រហ្ម សុទស្សីព្រហ្ម អកនិដ្ឋកព្រហ្ម។

៣. **អរូបភព**៤ជាន់ ស្ថិតនៅលើព្រហ្ម១៦ជាន់ ជាឋានដែលមិនមានរូប មិនមានតណ្ហា មិនមានកាមកិលេស មិនមានប្រុសស្រី មាន៤ជាន់គឺ អាកាសនញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ នេវសញ្ញានាសញ្ញាយតនៈ។

### ១០.២.១១. ជាតិ

ជាតិ កិរិយាកើត កើតព្រម កិរិយាចុះកាន់គភ៌ កិរិយាកើត កិរិយាកើតថ្មី កិរិយាកើតមានប្រាកដនៃខន្ធធម្មជាតិដែលអរិយបុគ្គលខ្ពើមធុញទ្រាន់ នឿយណាយ នោះគឺទុក្ខទាំង១២កង។

**១០.២.១២. ជរាទុក្ខ** (ចាស់ទ្រុឌទ្រោម) មរណទុក្ខ (សេចក្ដីស្លាប់) សោកទុក្ខ (សេចក្ដីសោកសៅ ការស្ដាយស្រណោះ) បរិទេវទុក្ខ (សេចក្ដីខ្សឹកខ្សួល ព្រួយញ៉ាំញី រីងរៃ) ទុក្ខទុក្ខ (ទុក្ខជាន់ទុក្ខ) ទោមនស្សទុក្ខ (សេចក្ដីក្រេវក្រោធ ថ្នាំងថ្នាក់ចិត្ត ទើសចិត្ត) ឧបាយាសទុក្ខ (ទុក្ខព្រោះព្រាត់ប្រាសគ្នា បែក

បាក់គ្នា) អប្បិយេហិ សម្បយោគទុក្ខ (ទុក្ខព្រោះជួបរឿងដែលមិនពេញចិត្ត) បិយេហិ វិប្បយោគគទុក្ខ (ទុក្ខព្រោះបាត់បង់របស់ដែលជាទីស្រឡាញ់ ពេញចិត្ត) យម្បិច្ឆំ ន លភតិ តម្បិទុក្ខ (ទុក្ខព្រោះ សេចក្តីប្រាថ្នារបស់ដែលមិនបានដូចចិត្ត)។

**បំណកស្រាយជារួម**

មុននឹងពោលថា អវិជ្ជា មានន័យថាដូចម្តេច? ជាកត្តានាំឲ្យកើតអ្វី? សូមពណ៌នានូវភពសិន។

ភពគឺអ្វី?

ភពជាទីសំណាក់របស់សត្វ ក្នុងដំណើរត្រាច់រង្គាត់ក្នុងវដ្តសង្សារ ភពមាន៣គឺ កាមភព១ រូបភព១ អរូបភព។

ដូចម្តេចបានជាហៅថាកាមភព?

បានជាហៅថាដូច្នេះព្រោះភពនេះ ពោរពេញដោយកាម (សេចក្តីតម្រេក ចំណង់) ឬដោយកាមគុណទាំង៥ គឺ រូប សំឡេង ក្លិន រស សម្ផស្ស។ សត្វក្នុងកាមភពរមែងក្រេបជញ្ជក់ ទោះបីតិច ឬច្រើននូវកាមគុណទាំង៥នេះ មិនដែលអាក់ខានមួយវេលាណាឡើយ។

ឯកាមភពមាន១១ភូមិ ដោយរាប់ស្ថានមនុស្សបញ្ចូលជាមួយផង។

ដូចម្តេចបានជាហៅថារូបភព?

បានជាហៅថាដូច្នេះព្រោះភពនេះ ប្រាសចាកកាមគុណទាំង៥ គឺថា បើសត្វណាមានបំណងនឹងទៅកើតក្នុងទីនោះ ត្រូវឲ្យប្រាសចាកកាមគុណទាំង៥ពីខន្ធសន្តាន បើពុំដូច្នោះទេ ខ្លួននឹងពុំអាចទៅអាស្រ័យនៅក្នុងភពនោះបានឡើយ។

សូមបញ្ជាក់ថា នៅក្នុងរូបភព សត្វនៅត្រូវប្រើប្រាស់រូបជាប្រយោជន៍ចិត្ត តែមិនមានការប្រកាន់មាំ និងការតម្រេកក្នុងរូបដូចជាសត្វក្នុងកាមភពឡើយ។

ដូចម្តេចហៅថា អរូបភព ?

បានជាហៅដូច្នេះព្រោះភពនេះ មិនត្រឹមតែប្រាសចាកកាមគុណទាំង៥ប៉ុណ្ណោះទេ គឺថែមទាំងមិនត្រូវការប្រើរូបទៀតផង។ យ៉ាងនេះបានជាមានសត្វខ្លះដោយយល់ភាន់ស្មានថា ភពនេះជាព្រះនិព្វាន។ ភពទាំងបីនេះរួមគ្នា ហៅថាសង្សារវដ្ត ឬសង្សារចក្រ។

តើមនោគតិនៃសត្វក្នុងត្រៃភព មានសភាពដូចម្តេច?

សត្វក្នុងត្រៃភពតែមានមនោគតិរបស់ខ្លួន មិននឹងនឡើយ មនោគតិនេះ លោតឆ្លោតទៅឆ្លងមកក្នុងភពទាំងបី តាមទំហំនឹងកម្លាំងផលកម្មរបស់ខ្លួន។ វិញ្ញាណសត្វប្រៀបដូចសត្វស្វាដែលមានខ្សែជាប់ក ហើយដែលគេចងទុកពេងមួយមានបោះបង្គោលបី ប្រកបដោយឈើខ្វែងខាងចុង សម្រាប់ឲ្យសត្វនេះលោកផ្លោះទៅមកបាន ស្វាមិនអាចលោតផុតពីបង្គោលបីបានយ៉ាងណា វិញ្ញាណសត្វក៏មិនអាចនឹងស្ទុះផុតចេញពីភពបីបានយ៉ាងនោះ វៀរលែងតែវិញ្ញាណនៃព្រះខីណាស្រពចេញ។

មានបញ្ហាចោទឡើងថា ចុះសុគតិស្ថាននោះដូចម្ដេច? ទុគ្គតិស្ថាននោះដូចម្ដេច?

សុគតិស្ថានប្រែថា ស្ថានមានដំណើរស្រួល ទុគ្គតិស្ថាន ប្រែថា ស្ថានមានដំណើរតឹងពិបាក ដោយអំណាចការផ្សេងគ្នានៃផលកម្ម តែជាយ៉ាងណា ក៏សត្វមិនអាចស្ទុះរួចពីភពបីបានឡើយ ប្រៀបដូចជាខ្លែងដែលបុគ្គលបង្ហើរ ឰអាកាស ខ្លែងនោះនឹងត្រូវធ្លាក់មកលើផែនដីវិញជាប្រាកដ កាលណាអស់មានខ្យល់ទ្រហើយត្រូវតែហោះឡើងទៅវិញទៀត កាលណាត្រឡប់មានខ្យល់មកវិញ។

ព្រះពុទ្ធទេសនាថា តែមានជាតិ ត្រូវមានជរាៗ ត្រូវមានព្យាធិៗ ត្រូវមានមរណៈ វត្ថុទាំងបួននេះ មានជាធម្មតាក្នុងភពបី។

គេឧបមាទុកភពទាំងបី ដូចជាផ្ទះបីខ្នង មានសភាពផ្សេងពីគ្នាគឺ ផ្ទះទី១ ធ្វើអំពីស្លឹក ផ្ទះទី២ ធ្វើអំពីឈើប្រក់ក្បឿង ផ្ទះទី៣ ធ្វើអំពីថ្ម ប៉េតុងអារម៉េ ហើយក្នុងផ្ទះនីមួយៗ សឹងមានមនុស្សម្នាក់អាស្រ័យនៅ។

គេសួរថា តើមនុស្សទាំងបីនាក់ខាងលើនេះ មានការថ្លៃថ្នូរវិសេសជាងគ្នាបែបណាខ្លះ? បើម្នាក់ៗសុទ្ធតែមានជារយ៉ាងមុតព្យួរនៅនឹងជញ្ជាំង រងចាំឲ្យដល់ពេលនឹងកាត់កម្ចាត់ផ្ទះរៀងខ្លួនៗ ត្រង់ចំណុចនេះ ព្រះពុទ្ធពោលថា មានដំណើរស្រួល និងដំណើរពិបាកប្លែកគ្នាខ្លះ ក៏ពិតមែន តែទោះបីខ្លួនបានសុខស្រួលមួយគ្រាក៏គង់គ្រាក្រោយខ្លួននឹងត្រូវទៅជួបនឹងទុក្ខវិញជាមិនខាន ព្រោះវិញ្ញាណសត្វមិនមែនតាំងនៅ ជាស្ថាពរក្នុងភពនីមួយៗឡើយ គឺថាសត្វដែលទៅសំចតនៅអរូបភពក្ដី រូបភពក្ដី កាមភពក្ដី តែងតែត្រូវមរណៈសង្គ្រាមមកផ្ដាច់ជីវតិន្ទ្រីយ៍ដូចៗគ្នាជាធម្មតា។

ដូច្នេះសម្រេចសេចក្ដីថា ភពទាំងបីឬសង្សារវដ្ដ ជាកន្លែងទុក្ខព្រោះមានធម៌បីគឺ អនិច្ចំ ទុក្ខំ អនត្តា ស្ថិតនៅជានិច្ច។

## ១០.៣. សាមញ្ញលក្ខណៈធម៌៣ប្រភេទ

### ១០.៣.១. អនិច្ចំ (សភាពមិនទៀងទាត់)

ពួកសត្វទាំងឡាយកើតលើផ្ទៃផែនដី សុទ្ធតែជាសត្វខ្លៅល្ងង់ លុះនូវអំណាចនៃលោភ និងទោសសម្គាល់ខ្លួនថាជាល្អ ថាសុខ ដោយចិត្តកំឡៅអស់កាលទាំងពួង។ ឯរាងកាយរបស់គេយើងរាល់គ្នានេះ ជាទីអាស្រ័យនូវរោគផ្សេងៗ បីដូចជាក្អមពេញទៅដោយថ្នាំពិសពុល ពុំនោះសោតបីដូចជានគរបិសាច ព្រោះរាងកាយជារបស់ធ្វើនូវសេចក្ដីភ័យមានប្រមាណច្រើន រាងកាយតែងរលត់ទៅក្នុងវ័យ បីដូចជាពពុះទឹក គឺសេចក្ដីសោកតែងបៀតបៀនហើយ បីដូចជាដំបៅដែលកូនសរវាមុត រាងកាយនេះគឺជរា និងសេចក្ដីសោកគ្របសង្កត់ហើយ បីដូចជាផ្កាឈូកដែលបុគ្គលច្របាច់ដោយដៃ រាងកាយគឺបុគ្គលចិញ្ចឹមរក្សាហើយ ប្រកបដោយទុក្ខច្រើន បីដូចជាកូនកំណាចដែលមាតាបិតាចិញ្ចឹមរក្សា។

ជនទាំងឡាយឯណាសេពគប់នូវរាងកាយ ក្នុងលោកនេះ ឧបមាដោយកិរិយាសេពគប់ដោយសត្វអាសិរពឹសពស់ ជនទាំងឡាយឯណាដេកច្រើន សេចក្ដីទុក្ខទាំងឡាយនឹងកើតដល់បុគ្គលទាំងឡាយនោះច្រើន

ដែរ បីដូចជាសត្រូវគឺខ្លួនចិញ្ចឹមរក្សា។

រាងកាយគឺជរាបៀតបៀនហើយ បីដូចជាគប់ភ្លើងឆេះស្មៅ ដែលស្ថិតនៅក្នុងទីប្រាសខ្យល់ ជនទាំងឡាយណាសេពគប់រាប់អានរាងកាយហើយជនទាំងឡាយនោះប្រកបដោយសេចក្ដីលំបាកពេកណាស់ បីដូចជាដុំដែកក្ដៅ គឺបុគ្គលញុំាញីហើយ មុខជាក្ដៅរលាក់មិនខាន រាងកាយមានសេចក្ដីសុខតិចណាស់ បីដូចជាដំណក់ទឹកសន្សើម មានទុក្ខច្រើនដូចជាទឹកសមុទ្រតែងហូរទៅក្នុងលោកអស់កាលទាំងពួង រាងកាយមានទុក្ខពេកណាស់ ដល់សត្វមានអាយុវែងក្ដី[41] សត្វដែលអាយុតិចក្ដី សេចក្ដីទុក្ខ និងស្លាប់ក៏សឹងមានដូចគ្នា ជនពាលទាំងឡាយជាបុគ្គលប្រមាទ មានសភាពជាអ្នកសម្គាល់នូវខ្លួនថាជាសុខ តែងប្រាថ្នានូវរាងកាយ គឺទុក្ខអំពីសេចក្ដីស្លាប់បៀតបៀនហើយ មានប្រការផ្សេងៗយើងនេះឯង ជនទាំងឡាយប្រកបដោយជាតិជាបណ្ឌិតឃើញនូវរាងកាយមានទុក្ខពន់ពេកដូច្នេះហើយ តែងរិះគិតរកនូវឧបាយដើម្បីដោះខ្លួនឲ្យរួចផុតចាក់ទុក្ខពិតប្រាកដ។

ជនទាំងឡាយជាបុគ្គលខ្លៅ តែងសម្គាល់ដឹងនូវខន្ធបញ្ចក គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជារបស់មិនទៀង ព្រោះខន្ធបញ្ចកមានសភាពកើតឡើង និងវិនាសទៅវិញ ថាជារបស់ល្អ ថាជារបស់ទៀងកក្នុងកាលទាំងពួង ម្យ៉ាងទៀងជរាតែងកំចាត់បង់នូវរូបជាទីស្រឡាញ់របស់សត្វទាំងឡាយ រោគទាំងពួងតែងកំចាត់បង់នូវកម្លាំង ឯស្ដេចមច្ចុតែងកំចាត់បង់នូវជីវិត ភោគសម្បត្តិទាំងឡាយក្ដី កូនប្រុសស្រីទាំងឡាយក្ដី បុរសជាផៅពង្ស ឬជាមិត្តសម្លាញ់ទាំងឡាយក្ដី យានជំនិះទាំងឡាយក្ដី ស្រែចម្ការច្បារដំណាំងទាំងឡាយក្ដី របស់អ្វីនីមួយគួរគប្បីទៅតាមខ្លួនបាន សូម្បីស្ថិតនៅក្នុងស្ថានកាមាវចរទាំងឡាយ តែងត្រេកអរហើយនៅក្នុងកាមគុណដ៏ជាទិព្វក៏គង់តែលះបង់នូវរាំងកាយជារបស់ខ្លួន ដោយកិរិយាអស់បុណ្យ និងអស់អាយុពុំលែងឡើយ ទោះរូបព្រហ្មទាំងឡាយក្ដី អរូបព្រហ្មទាំងឡាយក្ដី មានប្រក្រតីចម្រើននូវឈាន មានឫទ្ធិអានុភាពច្រើន កាលញុំាងទិសទាំងឡាយឲ្យភ្លឺស្វាងរុងរឿងបាន ព្រហ្មទាំងឡាយនេះ ក៏តែងតែលះបង់នូវអត្តភាពជារបស់ខ្លួនពុំខាន ទោះព្រះពុទ្ធទាំងឡាយក្ដី ព្រះបច្ចេកពុទ្ធទាំងឡាយក្ដី សាវកទាំងឡាយក្ដី ប្រកបដោយឫទ្ធិច្រើន ដែលជាទីលំនៅនៃគុណមានសីលគុណជាដើម មានមន្ទិលគឺកិលេស មានរាគជាដើមប្រាសចេញអំពីសន្ដានចិត្តហើយ ព្រះអរិយបុគ្គលទាំងឡាយទាំងពួង មានព្រះពុទ្ធជាដើម លោកក៏ដល់នូវអំណាចនៃបច្ចុរាជមិនលែង ទោះសមុទ្រ គឺបុគ្គលមិនគប្បីប្រមាណទាំងឡាយជាអណ្ដូងជាទីកើតនៃកែវទាំងឡាយ មានត្រើយច្រាំងគឺបុគ្គលឃើញមិនបានមានជម្រៅដ៏ជ្រាលជ្រៅ សមុទ្រទាំងឡាយអម្បាលនោះ ក៏គង់ដល់នូវអំណាចនៃអនិច្ចតាធម៌ដូចគ្នា ទោះភ្នំសិនេរុ និងផែនដីទាំងមូល ទាំងសមុទ្រ ព្រមទាំងភ្នំដ៏ទៃក្ដី សត្វទាំងឡាយដែលត្រេចទៅលើផែនដីក្ដី ក៏គង់ដល់នូវសេចក្ដីវិនាសសោះសូន្យ ទៅក្នុងកាលទីបំផុតនៃយុត្តកាលពុំខានឡើយ ទោះទាំងភូមិភពទាំងឡាយ អំពីខាងក្រោមស្ថានអកស្សរាក៏គង់ដល់នូវភាវជាអាកាសទទេពុំបាននឹងនៅ បីដូចជាគ្រាប់ស្ពៃ

[41] កម្ពុជាសុរិយា ភាគ៦/២ ខែ្ស ១០ ១១ ១២ រួមគ្នា ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស ២៤៧៧ គ.ស ១៩៣៤ ទំព័រ៥៦

ស្ថិតនៅចុងដែកស្រួច និងបាច់ពោលទៅថ្មីក្នុងសរីរកាយរបស់សត្វទាំងឡាយ។

ជនទាំងឡាយឯណាជាអ្នកប្រាជ្ញ អាចដឹងហើយនូវរាងកាយ ថាជារបស់មានសភាពទៀតយ៉ាងនេះហើយ តែងប្រព្រឹត្តបុណ្យ ឱ្យទានមានប្រការផ្សេងៗ ដើម្បីឱ្យរួចចេញចាកភពទាំងប្រការគឺ កាមភព រូបភព អរូបភពនេះឯង។

ព្រះពុទ្ធជាម្ចាស់រមែអប្រដៅថា ចូរអ្នកមើលវត្ថុទៅតាមរូបភាពពិតរបស់វា នៅពេលដែលយើងមើលអ្វីៗទាំងអស់ក្នុងលោកនេះ តាមរបៀបនេះ ពោលនោះយើងឃើញថា ៖

» អ្វីៗទាំងអស់សុទ្ធតែមិនទៀង »

» អ្វីកើតមក សុទ្ធតែគ្មានសារសំខាន់ »

» អ្វីៗទាំអស់សុទ្ធតែជាទុក្ខវេទនា »

នៅពេលព្រះពុទ្ធជាម្ចាស់ចូល " និព្វាន " នៅក្រោមម្លប់ដើមសាលព្រឹក្សទាំងគូ នៅដែនកុសិណារា ដោយផ្ទុំព្រះសីសបែរទៅទិសខាងជើង ព្រះភក្រ្តបែរទៅទិសខាងលិច ព្រះអង្គទ្រង់ត្រាស់ថា "អ្វីៗទាំងអស់សុទ្ធតែអនិច្ចៈ អ្វីៗទាំងអស់សុទ្ធតែប្រែប្រួលឥតឈប់ឈរ ដូច្នេះ សូមកុំប្រមាទក្នុងការប្រតិបត្តិ " វត្ថុទាំងឡាយសុទ្ធតែស្ថិតនៅក្នុងស្ថានភាពប្រែប្រួលឥតមានទីបញ្ចប់ ហើយវត្ថុទាំងអស់នោះ ប្រែប្រួលពីមួយរូបទៅមួយរូបទៀត ក្នុងវដ្តសង្សារ "។

ផ្កាយបញ្ចេញពន្លឺនៅលើមេឃ រួចដើមឈើ និងរុក្ខជាតិនានានៅលើភ្នំកំពុងប្រែប្រួលឥតឈប់ឈររៀងរាល់ថ្ងៃ មួយឆ្នាំ ពេញមួយឆ្នាំ ដើមឈើ និងរុក្ខជាតិនានាដុះឫស ចេញពន្លក ចេញផ្កា រួចចេញផ្លែ នៅគ្រប់ពេលអ្វីៗទាំងអស់សុទ្ធប្រែប្រួលនៅក្នុងធម្មជាតិក៏ដូចជានៅក្នុងមរណភពនៅក្នុងនាម និងនៅក្នុងរូប។

គ្មានអ្វីដែលស្ថិតស្ថេរជានិរន្តរ៍ ឬមិនប្រែប្រួលដាច់ខាតនោះទេ នៅក្នុងលោកនេះ ប៉ុន្តែមនុស្សខំព្យាយាមចាត់ទុករបស់ខ្លឹមសារនោះថា ជារបស់មានសារៈ និងពិត រួចក៏ធ្លាក់ទៅក្នុងកាមទោស ដោយសារការប៉ុនប៉ងយករបស់ពិតឥតសារៈ ធ្វើជាកម្មសិទ្ធិរបស់ខ្លួន នោះហើយជាដើមហេតុនៃសេចក្តីទុក្ខវេទនាទាំងឡាយ នៅពេលដែលវត្ថុទាំងឡាយកំពុងប្រែប្រួលឥតឈប់ឈរ មនុស្សក្បាលរឹង ចចេសប៉ុនប៉ងឃាត់វត្ថុទាំងឡាយនោះ កុំឱ្យប្រែប្រួលទៅវិញ នោះហើយជាប្រភពនៃសេចក្តីទុក្ខ។

### ១០.៣.២. ទុក្ខំ (សភាពជាទុក្ខ ពិបាកទ្រាំ)

" អ្វីៗទាំងអស់សុទ្ធតែទុក្ខវេទនា " នោះជាហេតុផលមូលដ្ឋាន ដែលធ្វើឲ្យព្រះពុទ្ធជាម្ចាស់ បោះបង់ចោលលោកិយនេះ ជីវិតជាហេតុនាំមកនូវការឈឺចាប់ និងសេចក្តីទុក្ខសោក សម្រាប់អ្នកមានជីវិតរស់នៅទាំងអស់គ្នា ពេលនេះពុទ្ធកាលកន្លងទៅបាន២៥៦៤ហើយ ប៉ុន្តែសច្ចធម៌នេះនៅតែស្ថិតស្ថេរឥតប្រែប្រួលឡើយ។

ទុក្ខវេទនាទាំងឡាយ កើតមកពី " តណ្ហាលោកិយ " មូលហេតុនៃតណ្ហារបស់មនុស្សនេះ មានប្រភពចេញមកពីការស្រឡាញ់ខ្លួនឯងហួសហេតុពេកដែលនាំមនុស្សទៅរកការប្រកាន់យកវត្ថុ ដែលឥតសារៈ ថាជាវត្ថុមានសារៈរួចនាំទៅរកការយល់ច្រឡំដោយប៉ុនប៉ងបង្កើតភាពមិនប្រែប្រួលចេញពីអ្វីដែលកំពូងប្រែប្រួល។

ដើម្បីបើកផ្លូវឆ្ពោះទៅរកការពិត យើងត្រូវដណ្តើរជ័យជំនះពីលើតណ្ហាលោកិយ ដែលមាននៅក្នុងចិត្តរបស់យើង ព្រោះវាជាប្រភពនៃសេចក្តីទុក្ខវេទនាគ្រប់យ៉ាង មានតែនៅក្នុងឱកាសនោះទេ ទើបយើងសម្រេចបាននូវសេចក្តីស្ងប់ខាងផ្លូវចិត្ត សេចក្តីស្ងប់ដ៏វិសុទ្ធនោះ គឺជាសេចក្តីប្រាថ្នាដ៏កំពូលរបស់ព្រះពុទ្ធសាសនាដែលគេហៅថា " សេចក្តីស្ងប់នៃព្រះនិព្វាន " ការសម្រេចបាននូវស្ថានភាពនៃសេចក្តីស្ងប់ដ៏កំពូលនោះ គឺជាវត្ថុបំណងនៃព្រះពុទ្ធសាសនា[42]។

ព្រះពុទ្ធទ្រង់វែកញែកអំពីទុក្ខ ៣ប្រការគឺៈ

១- ទុក្ខទុក្ខ សេចក្តីឈឺចាប់ព្រោះទុក្ខៈ ការឈឺចាប់ ព្យាធិ ជរា មរណៈ មរណៈទុក្ខ

២- វិបរិនាមទុក្ខ សេចក្តីឈឺចាប់ព្រោះការប្រែប្រួលៈ អ្វីដែលផ្ទុយនឹងបំណង សេចក្តីសុខដែលបាត់បង់ទៅ។

៣- សង្ខារទុក្ខ សេចក្តីទុក្ខយ៉ាងសុខុម ដែលជាការប្រតិកម្មទៅលើ គុណភាពនៃធម្មជាតិ ដែលតាក់តែងដោយបច្ច័យ រួមទាំងខន្ធ កត្តាបង្កើតចិត្តរបស់មនុស្ស។

សម័យមួយព្រះមានព្រះភាគ ទ្រង់គង់លើប្រាសាទរបស់មិគារមាតា ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី សម័យនោះឯង ចៅស្រីជាទីស្រឡាញ់ពេញចិត្ត របស់នាងវិសាខាមិគារមាតា បានធ្វើមរណភាព គ្រានោះវិសាខាមិគារមាតា មានសំពត់សើម សក់សើម ចូលទៅគាល់ព្រះមានព្រះភាគទាំងថ្ងៃត្រង់ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ។ លុះវិសាខាមិគារមាតាអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនាងវិសាខាចុះនាងមកពីណា មានសំពត់សើម សក់សើម ចូលមកក្នុងទីនេះទាំងថ្ងៃត្រង់ បពិត្រព្រះអង្គដ៏ចម្រើន ចៅជាទីស្រឡាញ់ពេញចិត្តរបស់ខ្ញុំព្រះអង្គធ្វើមរណភាព ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គ មានសំពត់សើម សក់សើម ចូលមកក្នុងទីនេះទាំងថ្ងៃត្រង់។ ម្នាលវិសាខា មនុស្សក្នុងក្រុងសាវត្ថី មានចំនួនប៉ុន្មាន នាងចង់បានកូន និងចៅចំនួនប៉ុណ្ណោះឬ បពិត្រព្រះមានព្រះភាគដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថីមានចំនួនប៉ុន្មាន ខ្ញុំព្រះអង្គចង់បានកូននិងចៅចំនួនប៉ុណ្ណោះ ម្នាលវិសាខា ចុះមនុស្សទាំងឡាយក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណភាពរាល់ៗថ្ងៃប៉ុន្មាននាក់ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្រុងសាវត្ថីធ្វើមរណភាពរាល់ៗថ្ងៃ ១០នាក់ខ្លះ ៩នាក់ខ្លះ ៨នាក់ខ្លះ ៧នាក់ខ្លះ ៦នាក់ខ្លះ ៥ នាក់ខ្លះ ៤នាក់ខ្លះ ៣នាក់ខ្លះ ២នាក់ខ្លះ ១នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សក្នុងក្រុងសាវត្ថី ចេះតែធ្វើមរណភាពមិនដែលស្ងាត់ទេ។ ម្នាលវិសាខា នាងសម្គាល់នូវហេតុនោះដូចម្តេច ចុះនាងជាអ្នកមានសំពត់សើម សក់សើម ក្នុងកាលណាម្តងៗទេឬ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គល្មមត្រឹមតែកូននឹងចៅច្រើនប៉ុណ្ណោះ។

ម្នាលវិសាខា បុគ្គលណា ៖

| | | | | |
|---|---|---|---|---|
| មានវត្ថុជាទីស្រឡាញ់ | ១០០ | បុគ្គលនោះមានសេចក្តីទុក្ខ | ១០០ | បុគ្គលណា |
| មានវត្ថុជាទីស្រឡាញ់ | ៩០ | បុគ្គលនោះមានសេចក្តីទុក្ខ | ៩០ | បុគ្គលណា |
| មានវត្ថុជាទីស្រឡាញ់ | ៨០ | បុគ្គលនោះមានសេចក្តីទុក្ខ | ៨០ | បុគ្គលណា |
| មានវត្ថុជាទីស្រឡាញ់ | ៧០ | បុគ្គលនោះមានសេចក្តីទុក្ខ | ៧០ | បុគ្គលណា |

[42] កម្ពុជសុរិយា ភាគ៥២ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស ២៥៤១ គ.ស ១៩៩៨ ទំព័រ ៨០

មានវត្ថុជាទីស្រឡាញ់ ៦០ បុគ្គលនោះមានសេចក្តីទុក្ខ ៦០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៥០ បុគ្គលនោះមានសេចក្តីទុក្ខ ៥០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៤០ បុគ្គលនោះមានសេចក្តីទុក្ខ ៤០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៣០ បុគ្គលនោះមានសេចក្តីទុក្ខ ៣០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ២០ បុគ្គលនោះមានសេចក្តីទុក្ខ ២០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ១០ បុគ្គលនោះមានសេចក្តីទុក្ខ ១០ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៩ បុគ្គលនោះមានសេចក្តីទុក្ខ ៩ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៨ បុគ្គលនោះមានសេចក្តីទុក្ខ ៨ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៧ បុគ្គលនោះមានសេចក្តីទុក្ខ ៧ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៦ បុគ្គលនោះមានសេចក្តីទុក្ខ ៦ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៥ បុគ្គលនោះមានសេចក្តីទុក្ខ ៥ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៤ បុគ្គលនោះមានសេចក្តីទុក្ខ ៤ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ៣ បុគ្គលនោះមានសេចក្តីទុក្ខ ៣ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ២ បុគ្គលនោះមានសេចក្តីទុក្ខ ២ បុគ្គលណា
មានវត្ថុជាទីស្រឡាញ់ ១ បុគ្គលនោះមានសេចក្តីទុក្ខ ១ បុគ្គលណា

មិនមានវត្ថុជាទីស្រឡាញ់ បុគ្គលនោះ ក៏មិនមានសេចក្តីទុក្ខសោះដែរ តថាគតទើបពោលថា បុគ្គលទាំងនោះជាអ្នកមិនមានសោក ជាអ្នកប្រាសចាកធូលីគឺកិលេស ជាអ្នកមិនមានសេចក្តីចង្អៀតចង្អល់។ សេចក្តីសោកក្តី សេចក្តីខ្សឹកខ្សួលក្តី ណាមួយ ឬសេចក្តីទុក្ខ ជាច្រើនយ៉ាងក្នុងលោក ធម៌ទាំងនោះ រមែងកើតឡើងព្រោះអាស្រ័យសត្វនិងសង្ខារ ជាទីស្រឡាញ់ កាលបើមានសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្ត ធម៌ទាំងនោះ ក៏រមែងមាន។ ព្រោះហេតុនោះឯង បុគ្គលណាមិនមានសត្វ និងសង្ខារ ជាទីស្រឡាញ់ ជាទីពេញចិត្ត ក្នុងលោកណាមួយទេ បុគ្គលនោះទើបមានសេចក្តីសុខ ប្រាសចាកសេចក្តីសោក ព្រោះថាបុគ្គលមិនមានសោក គឺការប្រាសចាកធូលីគឺកិលេស មិនគប្បីធ្វើសត្វ និងសង្ខារ ឲ្យជាទីស្រឡាញ់ ក្នុងលោកណាមួយឡើយ[43]។

ទុក្ខរាប់បញ្ចូលទៅក្នុងត្រៃលក្ខណៈ គឺភាពមិនទៀង (អនិច្ចំ) ភាពឈឺចាប់ (ទុក្ខំ) ភាពមិនមែនខ្លួន (អនត្តា)។ ទុក្ខបង្ហាញការពិសោធន៍ថា សង្ខារជារបស់មិនទៀង (អនិច្ចំ) ដូច្នេះវាពន្យល់អំពីសភាពការណ៍ដែលធ្វើឲ្យចិត្ត ទៅជាធម្មជាតិប្រែប្រួល មិនទៀង។ ព្រោះហេតុនោះ វាក៏ជាច្រកចូលទៅក្នុងអនត្តា មិនមែនខ្លួន។ ហេតុតែវាមានកម្លាំង តែងប្រែប្រួលជានិច្ច មិនអាចគ្រប់គ្រងវាបាន ហើយមិនមែនជាសេចក្តីពេញចិត្តនៅទីបំផុត ជីវិតដែលខ្វះ ការត្រួតពិនិត្យ គឺជាទុក្ខដោយពិត។ សំនួរចំពោះការស្វែងរករបស់ព្រះពុទ្ធ ថាតើខ្ញុំដាក់ភាពទាក់ទង ដែលស្ថិតស្ថេរទៅក្នុងអ្វី? ព្រះអង្គមិនបានប្រកែកថា មានសេចក្តីពេញចិត្តក្នុងការពិសោធន៍ទេ ការចម្រើនវិបស្សនា សន្មត់ថា យោគីឃើញតាមកាលវេលា នូវសុខៈយ៉ាងច្បាស់។ សេចក្តីឈឺចាប់ ត្រូវឃើញជាសេចក្តីឈឺចាប់ សេចក្តីរីករាយត្រូវឃើញ ជាសេចក្តីរីករាយ ការមិនយល់ស្របនោះគឺ សុខៈដែលអាស្រ័យ

---

[43] សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ ធម្មបទគាថា ឧទាន ៥២ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស ២៥០០ ទំព័រ៣៤៧

នឹងបច្ច័យ ថាជារបស់គង់វង់ហើយតាំងនៅបានយូរ។ ក្នុងគម្ពីរជំនាន់ដើម ខន្ធៈពន្យល់ថាទុក្ខៈជាអ្វី។ បើតាម Noa Ronkin អ្វីដែលបង្ហាញក្នុងគម្ពីរនោះ អត្ថរបស់ខន្ធៈទូលំទូលាយជាង ត្រឹមតែពាក្យថាអាយតនៈ ដែលបង្កើតរូបកាយរបស់មនុស្ស។ Sue Hamilton បានផ្តល់ការសិក្សា ក្បោះក្បាយអំពីខន្ធៈ។ យោបល់របស់លោកស្រីគឺ ការភពប្រសប់រវាងខន្ធ៥ រួមជាមួយនឹងទុក្ខៈ បញ្ជាក់ឲ្យឃើញថា ការពិសោធគឺជាសភាពរួមគ្នានៃការដឹងត្រង់ៗ ជាមួយនឹងទិស របស់ចិត្ត ដែលដាក់ពណ៌ឲ្យវា ក្នុងន័យនៃការមិនពេញចិត្ត។ ដូច្នេះការពិសោធន៍ ទទួលការដឹងផង និងអារម្មណ៍ផងទាំង២ផ្នែក ហើយមិនអាចបំបែកចេញ អំពីសញ្ញាខន្ធ (ការចាំ) បានឡើយ ទៅតាមការប្រែប្រួលនៃសញ្ញា ការពិសោធន៍របស់គេ ក៏ផ្លាស់ប្តូរដែរ យើងម្នាក់ៗផ្ទាល់ខ្លួនមានសកម្មភាព នៃវិញ្ញាណ សញ្ញា និងចេតនា តាមបែបនិងកំរឹតផ្សេងៗគ្នា ហើយប្រតិកម្ម និងការបកស្រាយ អំពីការពិសោធន៍របស់យើង គឺជាការពិសោធន៍ របស់យើងតែប៉ុណ្ណោះ ក្នុងការព្រមព្រៀងចំពោះ ខ្សែគំនិតនេះ Gethin ពិនិត្យឃើញថា ចំពោះទស្សនៈនៃការពិសោធន៍នេះ ខន្ធៈបង្ហាញរូបរាងជា ទិដ្ឋភាព៥នៃធម្មជាតិដែលតាក់តែងដោយបច្ច័យ ទិដ្ឋភាព៥នៃការពិសោធន៍របស់គេ។ ដូច្នេះហើយ ខន្ធៈនិមួយៗជាតំណាង នៃប្រភេទមួយរបស់បាតុភូត ដ៏ស្មុគស្មាញ ដែលកើតហើយរលត់ បន្តគ្នា ក្នុងការឆ្លើយតប ទៅនឹងដំណើរនៃចិត្តដែលមានមូលដ្ឋានលើ អាយតនៈ៦។ ខន្ធៈទាំងនោះក៏ក្លាយទៅជា ឧបាទានក្ខន្ធ៥ ដែលបញ្ចូលសេចក្តីលោភលន់ និងអ្វីដែលគេជាប់ជំពាក់ចិត្ត។

### ១០.១.៣. អនត្តា (សភាពមិនមែនជាកម្មសិទ្ធិរបស់ខ្លួន)

សំឡេងពោលថា រថដូច្នេះ ព្រោះប្រជុំអវយវៈ ដោយប្រការឯណា សម្មតិដូច្នេះ ថាខ្លួនព្រោះប្រជុំនាម និងរូបដោយប្រការដូច្នោះ សំឡេងហៅថា រថដូច្នេះ បើនាំយកនូវអវយវៈចេញហើយ ក៏ពុំមានយ៉ាងណាមិញ សម្មតិដូច្នេះ ថាខ្លួនបើនាំយកនូវនាម និងរូបចេញហើយក៏ពុំមានយ៉ាងដូច្នោះឯង រាងកាយមិនមែនខ្លួនយ៉ាងនេះ បីដូចជាភូត មារយា ព្រោះជារបស់បញ្ឆោតសត្វ បីដូចជាថ្ងៃបណ្តើរកូន ព្រោះជារបស់ប្រឡោមល្បួងសត្វ បុគ្គលពាលគប្បីពោលដូច្នេះថា កូនរបស់ស្រីអារ គប្បីទ្រទ្រង់នូវប្រវេណី ដោយប្រការដូច្នោះហើយ ប្រាថ្នានូវខ្លួនក្នុងកាលទាំងពួង បុគ្គលពាលគប្បីពោលថា អញផឹកនូវទឹក ថ្ងៃបណ្តើរកូនដោយប្រការយ៉ាងណា បុគ្គលពាលនោះថាពោលដូច្នេះថា អញប្រជាប់ស្ថិតស្ថាងនូវខ្លួនដោយប្រការដូច្នោះ ហើយរាប់អានស្រឡាញ់នូវខ្លួន បុគ្គលឯណាគប្បីពោលដូច្នេះថា អញធ្វើនូវផ្លូវដោយស្នែងនៃសត្វទន្សាយហើយគប្បីទ្រទ្រង់ បុគ្គលពាលពោលដូច្នេះថា ខ្លួនធ្វើនូវឫទ្ធិក្នុងកាលទាំងពួង បុគ្គលអ្នកស្វែងរកនូវខ្លឹមសារចេកពុំឃើញមានយ៉ាងណា បុគ្គលកាលស្វែងរកនូវខ្លួនក្នុងខន្ធទាំងឡាយ ក៏ពុំឃើញមានយ៉ាងនោះបុគ្គលពាលឃើញនូវថ្ងៃបណ្តើរកូនអំពីចម្ងាយសម្គាល់ថាជាទឹក ហើយស្ទុះចូលទៅជិតយ៉ាងណាមិញ បុគ្គលពាលសម្គាល់នូវខ្លួនថាជាសុខ ហើយស្រឡាញ់រាប់អាននូវខ្លួនយ៉ាងដូច្នេះឯង បុគ្គលជាបុថុជ្ជនរាប់អានស្រឡាញ់នូវរបស់គ្មានថាខ្លួនដូច្នេះ យើងប្រព្រឹត្តធ្វើនូវអំពើលាមកក្នុងលោកនេះ ហើយរមែងសោយក្នុងកាលជាខាងក្រោយអស់កាលទាំងពួង បុរសជាអ្នកប្រាជ្ញដឹងច្បាស់នូវខ្លួនថាជារបស់ប្រឡោមល្បួងសត្វយ៉ាងនេះ បីដូចជាថ្ងៃបណ្តើរអំពីចម្ងាយ ហើយក៏មិនបានស្រឡាញ់រាប់អាននូវខ្លួនក្នុងកាលទាំងពួង។

រាយកាយនេះដ៏ពោរពេញដោយរបស់របមិនស្អាត មានខ្ទុះនិងមូតលាមកជាដើម ជារបស់មិនល្អជាទីខ្ពើមរអើមផង ក្នុងកាលទាំងពួងមែនពិត បីដូចជាក្អមដ៏ពេញដោយលាមក សេចក្តីពិតថា រាងកាយជាប្រទេសជាទីកើតរបស់សត្វដង្កូវទាំងឡាយ ជាផ្ទះមានជំងឺជាដើម ជាព្រៃស្មសាន ជាកន្លែងសម្រាប់សម្រាលកូន ជាសត្វដង្កូវទាំងឡាយក្នុងកាលទាំងពួង បីដូចជាក្អមដ៏ពេញដោយសត្វដង្កូវ រាងកាយសូម្បីគឺបុគ្គលចិញ្ចឹមរក្សាដោយវត្ថុមានសំពត់ និងគ្រឿងក្រអូបជាដើមសព្វថ្ងៃ ក៏នៅតែជារបស់មិនស្អាតដដែល បីដូចជាក្អមលាមក គឺបុគ្គលចោលក្នុងវត្ថុមានគ្រឿងក្រអូបជាដើម រាងកាយជាផ្ទះសម្រាប់ពពួកគឺ សក់ទាំងឡាយ គឺរោមទាំងឡាយជាទីលំនៅរបស់ទឹកភ្នែក ខ្លាញ់ខាប់ ខ្លាញ់រាវ ញុំាងវត្ថុមិនស្អាតមានស្លេស្មជាដើមឱ្យហូរទៅកាន់ទ្វារទាំង៩ក្នុងកាលទាំងពួង រាងកាយនេះសូម្បីតែបុគ្គលកាន់យកនូវទឹកក្នុងសមុទ្រទាំងអស់ យកនូវគ្រឿងក្រអូបប្រមាណប៉ុនភ្នំព្រះសុមេរុមកលាងមកងូតមកអប់ជានិច្ចកាល ក៏នៅតែពុំល្អមានប្រការដូច្នោះឯង។ ជនពាលទាំងឡាយពុំឃើញនូវរាងកាយជាទីលំនៅនៃរោគប្រកបដោយសោក ប្រកបដោយភ័យ ដោយសេចក្តីអន្តរាយហើយ តែងរាប់អាននូវរាងកាយក្នុងកាលទាំងពួង ប្រសិនណាបើ អាការមានសាច់ជាដើម ទាំងអស់ដែលតម្កល់នៅខាងក្នុងហើយប្រាកដខាងក្រៅវិញ បុគ្គលគប្បីកាន់យកនូវដំបងព្រនង់ ដុំដីហើយដេញក្អែកត្មាតទាំងឡាយពុំលែង ប្រសិនណាបើ មាតាបិតាព្រមទាំងភរិយា ឃើញនូវរបស់ខាងក្នុងទាំងអស់ ប្រាកដខាងក្រៅវិញ មុខជាគ្មានស្តាយស្រណោះអាឡោះអាល័យ ហើយដើរចោលបោះបង់ហើយ ប្រាកដជាសត្វក្អែកត្មាតទាំងឡាយ ទំពារស៊ីនូវរាងកាយដែលប្រឡាក់ដោយសាច់ និងឈាម គឺបុគ្គលចោលបង់នៅក្នុងព្រៃស្មសានមែនពិតណាស់ ញាតិសាលោហិតមិត្រសម្លាញ់ទាំងឡាយនឹងមានអំពីទីឯណា ជនទាំងឡាយប្រកបដោយជាតិជាបណ្ឌិត ដឹងច្បាស់ហើយនូវរាងកាយដោយអសុភយ៉ាងនេះ គប្បីធ្វើនូវព្រះធម៌ជាទីគោរព ស៊ូលះបង់នូវអង្គ លះបង់នូវជីវិត។

ដុំដីដែលបុគ្គលចោលទៅក្នុងអាកាស ហើយធ្លាក់ចុះមកលើផែនដីវិញយ៉ាងណាមិញ សត្វដែលកើតមកហើយ តែងដល់នូវសេចក្តីស្លាប់ពិតដោយប្រការយ៉ាងនោះ វីរបៀបរលកទាំងឡាយពុំដែលប្រព្រឹត្តកន្លងឲ្យហួសអំពីច្រាំងក្នុងកាលទាំងពួង យ៉ាងណាមិញ បណ្តាពពួកជនក្នុងលោកនេះពុំដែលប្រព្រឹត្តកន្លងនូវសេចក្តីស្លាប់ ដោយប្រការដូច្នោះឯង ជារទឹកភ្លៀងទាំងឡាយ តែងធ្លាក់លើផែនដីក្នុងទិសទាំងឡាយ ទៀងក្នុងទិសទាំងឡាយយ៉ាងណា បណ្តាពពួកជនទាំងឡាយក៏ទៀងតែដល់នូវអំណាចនៃមច្ចុរាជដូច្នោះឯង សត្វតិរច្ឆានទាំងឡាយទាំងពួងក្តី ប្រេត គន្ធព អារក្ខទឹក សមនុស្ស អសុរ យក្ខទាំងឡាយក្តី សត្វទាំងឡាយមានតិរច្ឆានជាដើមនោះ តែងដល់នូវសេចក្តីស្លាប់ទាំងអស់ដូចគ្នា សូម្បីទេវតាក្នុងស្ថានកាមាវចរទាំងឡាយក្តី រូបព្រហ្មក្តី អរូបព្រហ្មក្តី ដែលមានអាយុវែងមានតេជះច្រើន ទេវតាទាំងឡាយទាំងពួងនោះ ក៏ដល់នូវសេចក្តីស្លាប់ពុំលែងឡើយ ភាជនដីគឺនាយស្មូនឆ្នាំងធ្វើហើយ មានកិរិយាដល់ព្រមនូវសភាពបែកធ្លាយទៅមែន មានឧបមាយ៉ាងឯប្រជុំជនទាំងអស់មានកិរិយាដល់នូវសភាពបែកធ្លាយទៅ មានឧបមាយ៉ាងដូច្នោះ ឯសេចក្តីមរណៈជាធម៌ទៀង សូម្បីតែ១ក៏អាចដើម្បីសម្លាប់នូវសត្វក្នុងភពទាំងបីបានឥតមានសេសសល់ លោកអ្នកប្រាជ្ញតែងធ្វើនូវកូនប្រពន្ធផង នូវជីវិតផង ឱ្យអណ្តែតនៅក្នុងទីជិត ដោយអំណាចទាន បុគ្គលពាលទាំងឡាយ ឃើញនូវ

សេចក្តីស្លាប់ដូច្នេះហើយ បុគ្គលពាលទាំងឡាយនោះពោលថា អញនឹងធ្វើនូវបុណ្យក្នុងថ្ងៃស្អែកៗហើយ តែនៅតែធ្វើនូវបាបពុំលែងឡើយ លោកអ្នកប្រាជ្ញទាំងឡាយ គិតនូវសេចក្តីស្លាប់ពិតណាស់ហើយ លោកអ្នកប្រាជ្ញទាំងឡាយនោះ តែងលះបង់នូវជីវិត ព្រមទាំងទ្រព្យផងនូវអង្គផង នូវកូន និងប្រពន្ធផង ឲ្យទៅជាទានពុំបានយឺតយូរមែនពិត។

បុគ្គលណាពិចារណាឃើញដោយបញ្ញាថា ធម៌ទាំងឡាយទាំងពួង (ខន្ធ) ជាអនត្តា ក្នុងកាលណា ក្នុងកាលណោះ បុគ្គលនោះតែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ។

ពាក្យថាធម៌ទាំងឡាយទាំងពួងក្នុងទីនេះ បានដល់ខន្ធ៥ ព្រោះខន្ធទាំង៥នេះ សុទ្ធតែជារបស់មិនទៀង ជាទុក្ខ មិនមែនជារបស់ខ្លួន។

ពាក្យថា អនត្តា អ្នកណាមួយមិនអាចឱ្យប្រព្រឹត្តទៅក្នុងអំណាចថា ចូរកុំចាស់ ចូរកុំស្លាប់ ដូច្នេះបានឡើយ គឺជាសភាពសោះសូន្យ មិនមានម្ចាស់ ឥតមានអ្នកណាត្រួតត្រាបាន ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាចនៃជាតិណាមួយឡើយ។

អនត្តា បានដល់ធម្មជាតិណា ឈប់ទំពារស៊ីនូវសុខ និងទុក្ខ ធម្មជាតិនោះឈ្មោះថា អនត្តា (មិនមែនខ្លួន)។ អនត្តា សព្ទនេះ លោកសំដៅយកធម្មជាតិមិនមែនជាចិត្ត មិនមែនខ្លួន គឺជារបស់ឥតម្ចាស់ត្រួតត្រាឡើយ។ ពាក្យថា អនត្តា ជាគូបដិបក្ខ និងពាក្យថា អត្តា។ អត្តា នេះ បានដល់សភាវៈណា ទំពាស៊ីនូវសុខ និងទុក្ខ សភាវៈនោះឈ្មោះថា អត្តា ឬ អាត្ម័ន។ អត្តា ឬ អាត្ម័ន សព្ទនេះ លោកសំដៅយកចិត្ត និងខ្លួន។

ក្នុងពិភពលោកនេះ អ្វីៗទាំងអស់ដែលបច្ច័យ ឬសង្ខតធាតុប្រមូលផ្តុំឡើងបានជារូបរាងកាយនោះ ទោះបីមានវិញ្ញាណក្តី ឥតវិញ្ញាណក្តី សុទ្ធតែជារបស់អនិត្យៈ ឬទ្រវ្យៈទាំងអស់ គឺពុំស្ថិតស្ថេរនៅទៀងទាត់ ឬនឹងថ្កល់ឥតប្រែប្រួលកម្រើករញ្ជួយនោះទេ ទាំងតួធាតុឯងសោតទៀត ក៏ត្រូវមានចលនា តែងតែផ្លាស់ប្តូរប្រែប្រួលជាធម្មតាដែរ។ ដូច្នេះ វត្ថុទាំងអស់ក្នុងលោក ជាតុអនិត្យៈបែបនោះក៏ត្រូវតែផ្លាស់ប្តូរ ពីផ្នែកមួយទៅផ្នែកមួយទៀត ហើយការផ្លាស់ប្តូរនេះ ក៏ចេះតែវិវឌ្ឍន៍ជាដរាប ដោយសារកម្លាំងវិទ្យាសាស្ត្រ ដែលមនុស្សលោកខំប្រឹងស្រាវជ្រាវ ហើយបង្កើតឡើងតៗគ្នាមក។ យើងអាចសង្កេតឃើញមនុស្សសត្វចេះកម្រើកដៃជើង ចេះទទះស្ទាបត្រាចចរលើលា ពីទីមួយទៅទីមួយទៀត ឬពីភូមិមួយទៅភូមិមួយទៀតបាន ចេះស្រេកទឹក ចេះឃ្លានអាហារ ចំណី។ ការប្រាថ្នាវត្ថុបែបនោះមក ដើម្បីបំប៉នរាងកាយ ឲ្យមានដំណើរប្រព្រឹត្តទៅបានស្រួល ហើយជាគ្រឿងបន្តពូជជារតឹកូនចៅ មនុស្សលោកកាលបើប្រសូត្រចាកទ្វារមាសនៃមាតាពេលណា ពេលនោះត្រូវមានរាងកាយប្រកបដោយអាការៈ៣២ប្រការមានសក់ជាដើម។ រូបរាងកាយនេះ គេអាចបានកំណត់បានថាជាភេទប្រុស ភេទស្រីដោយគំហើញយ៉ាងជាក់ច្បាស់ ហើយអាចចាប់កាន់ប៉ះពាល់ដោយដៃបានថែមទៀត។ រូបរាងកាយរបស់មនុស្សប្រុសស្រី សុទ្ធតែប្រកបដោយគ្រឿងផ្សំជាច្រើនយ៉ាង ដែលលោកកំណត់ទៅតាមគ្រឿងផ្សំទាំងនោះថា រូបរាងកាយរបស់មនុស្សសត្វ សុទ្ធតែប្រកបផ្សំដោយធាតុ៤ ឯធាតុ៤នោះគឺ វត្ថុណាមានលក្ខណៈរឹងៗ វត្ថុនោះឈ្មោះថា បឋវីធាតុ បានដល់ធាតុដី វត្ថុណាមានលក្ខណៈរាវៗ វត្ថុនោះមានឈ្មោះ

ថា អាបោធាតុ បានដល់ធាតុទឹក វត្ថុណាមានលក្ខណៈក្តៅៗ វត្ថុនោះមានឈ្មោះថា តេជោធាតុ បានដល់ធាតុភ្លើង វត្ថុណាមានលក្ខណៈបក់ទៅមក វត្ថុនោះឈ្មោះថា វាយោធាតុ បានដល់ធាតុខ្យល់។

ធាតុទាំង៤នេះហើយដែលសម្រាប់ញ៉ាំងអត្តា ឬអាត្ម័ន ឲ្យប្រព្រឹត្តទៅរាល់ថ្ងៃ មិនឲ្យវិនាសដោយបការណាមួយ (សម្រាប់ការរស់នៅ) អាស្រ័យដោយធាតុទាំង៤នោះ ជាដើមចម បើធាតុទាំង៤នោះ ធាតុណាមួយ ពុំមានចលនាទេ រូបរាងកាយរបស់មនុស្សសត្វ តែមានដំណើរប្រព្រឹត្តទៅពុំបានស្រួល ព្រោះគ្រឿងផ្សំទាំងនោះមានអាការៈពុំស្របគ្នា នេះជាទ្រឹស្តីនៃផ្នែកពុទ្ធសាស្ត្រ។

អ្នកវិទ្យាសាស្ត្របានខំប្រឹងគិត និងស្រាវជ្រាវរករកនូវគ្រឿងការពាររូបនោះ ព្រោះរូបនេះ សុទ្ធតែប្រកបដោយគ្រឿងផ្សំឡើង ហើយវាបាត់បង់ទៅវិញបាន ម្លោះហើយម្ចាស់ខ្លួន ឬម្ចាស់រូបនោះ ក៏ខំប្រឹងស្ងួនគ្រងរក្សាថ្នាក់ថ្នម ដើម្បីកុំឲ្យគ្រឿងផ្សំទាំងនោះបែកខ្ញែកគ្នា ព្រោះខ្លួនមនុស្សនេះ ប្រកបឡើងដោយគ្រឿងផ្សំជាច្រើនផ្នែក ទើបកើតបានជាតួខ្លួន ឬតួរូប។ ខ្លួនមនុស្សនេះ មានគ្រឿងការពារ ដោយស្បែកមួយស្តើង ហើយឃឹតមានសាច់ដុំ និងឆ្អឹងនៅជាបន្ទាប់ ខ្លួនមនុស្សមានក្បាល ដងខ្លួន និងអវយវៈ។ មនុស្សមានសមភាពជាគូនឹងគ្នាដូចជាដៃ និងជើង ត្រចៀក ភ្នែក ច្រមុះ ដូចគ្នា មួយគូៗ នៅនឹងក្បាល គេឃើញមុខ និងលលាដ៏ក្បាលដែលមានខួរនៅខាងក្នុង ដងខ្លួនមានរាងប្រហោងខណ្ឌជាច់ពីគ្នា ដោយឆ្អឹងបង្កោងទ្រូង។ នៅផ្នែកខាងលើឬទ្រូង មានសួត និងបេះដូង នៅផ្នែកខាងក្រោមមានពោះ ថ្លើម ក្រពះលំពែង ពោះវៀន ដែលចែកជាពោះវៀនធំ មានប្រវែង ១ម ៣០ និងពោះវៀនតូចមានប្រវែង ៨ម តម្រងនោមហៅថា វក្កំ និងថ្លោកនោម។ អវយវៈលើ ឬ ដៃភ្ជាប់នឹងដងខ្លួនដោយសារឆ្អឹងស្លាបប្រចៀវ និងឆ្អឹងដងកាំបិត ហើយចែកជាដើមដៃ កំភួនដៃដែលភ្ជាប់គ្នាដោយសន្លាក់គួយ ហើយបាត់ដៃដែលភ្ជាប់មកជាមួយនឹងកំភួនដៃ ដោយសារ កដៃ អវយវៈក្រោម ឬ ជើងភ្ជាប់មកនឹងដងខ្លួនដោយសារត្រគាក ឬឆ្អឹងផាល ហើយចែកជាភ្លៅ ស្មងជើង ដែលភ្ជាប់គ្នាដោយសន្លាក់ជង្គង់ ហើយបាទជើងភ្ជាប់មកនឹងស្មងជើង ដោយសារ កជើង សរីរាង្គទាំងឡាយនៃខ្លួនមនុស្សនេះផ្គុំគ្នាជាគ្រឿង ឬបរិធាន ដែលនីមួយៗរ៉ាប់រងនូវមុខងារផ្ទាល់របស់ជីវិតមនុស្ស សរីរាង្គនេះ ត្រូវប្រកបដោយស្បែកជាគ្រឿងឧបត្ថម្ភ ស្បែកជាស្រោមនៃរាងកាយ មានស្រទាប់សើមួយ គឺស្បែកសើ ហៅថា អធិតចៈស្បែកសើនេះ ចែកជាផ្នែកស្លាប់នៅខាងលើ និងផ្នែករស់នៅជាបន្ទាប់ ហើយនឹងមានស្រទាប់ជ្រៅមួយ គឺស្បែកក្នុងហៅថា តចៈ ដែលមានសរសៃឆ្មារៗ ហៅថា នហារូលោហិត និងខ្លាញ់នៅខាងក្នុងនោះ ស្បែកនេះមានមុខងារសំខាន់ការពារសរីរាង្គ ដែលធ្វើឲ្យដឹងនូវសម្ផស្ស គឺរលីង ឬគគ្រើម ស្អាត ឬពុំស្អាត ឲ្យដឹងនូវសីតុណ្ហភាព ដូចជាក្តៅ ឬត្រជាក់ ទាំងដឹងនូវសណ្ឋានរាងផ្សេងៗផង។ រូបរាងកាយនេះ មានលក្ខណៈមួយទៀតហៅថា បរិធាន នៃចលនា អាស្រ័យដោយអដ្ឋិសណ្ឋាន អដ្ឋិសណ្ឋាននេះ ជាគ្រឿងទ្រទ្រង់នូវរាងកាយ ដែលបង្កើតបានជាឆ្អឹងវែង ខ្លី សំប៉ែត ឆ្អឹងនីមួយៗ មានតួឆ្អឹង ឬខ្លួន និងក្បាលពីរ មួយនៅខាងលើ និងមួយនៅខាងក្រោម ឆ្អឹងនេះកើតឡើងដោយរូបធាតុនៃឆ្អឹង ឬឆ្អឹងទន់ និងរូបធាតុនៃរ៉ែ ហៅថា រូបធាតុខនិជ ដូចជាកំបោរហៅថា កាបូណាតដីស្ករ និងហ្វូស្វាតដីស្ករ ឆ្អឹងនេះបង្ខាំជាប់គ្នានៅនឹងលលាដ៍ក្បាល ឆ្អឹងខ្លះភ្ជាប់គ្នា

ដោយសន្លាក់ ដូចជាឆ្អឹងដៃ និងឆ្អឹងជើង មិនត្រឹមតែប៉ុណ្ណោះរូបរាងកាយនេះ ទាក់ទងដោយសរសៃប្រាសាទ ដែលគ្រឿងដឹងហេតុការណ៍ ផ្សេងៗ សរសៃប្រាសាទនេះ ចែកចេញជាមណ្ឌលសរសៃប្រាសាទ និងសរសៃប្រាសាទ មជ្ឈមណ្ឌលសរសៃប្រាសាទចែកចេញជាប្រអប់លលាដ៍ក្បាល ចែកចេញជាកន្សោមខួរ ខួរតូច និងមើមខួរ ឬខួរកញ្ចឹងក ខួរទាំងបីនេះស្ថិតនៅក្នុងលលាដ៍ក្បាល ខួរមិញ្ជាឆ្អឹងខ្នង ដែលជាសរសៃខួរពណ៌សមានប្រវែង៤០សង់ទីម៉ែត្រ ឋិតនៅក្នុងប្រហោងឆ្អឹងខ្នង កន្សោមខួរ គឺជាមន្ទីរនៃស្មារតី នៃសតិ បញ្ញា និងនៃការដឹងវេទនារម្មណ៍ ដែលវាបញ្ជានៅចលនាដ៏មានឆន្ទៈ ហៅថា ចលនាសចិត្តកៈ គឺជាចលនាដែលធ្វើដោយគំនិតជាមុនដោយឆន្ទៈចង់ធ្វើ។ ខួរតូចរ៉ាប់រងនូវតុល្យភាព នៃរាងកាយ គឺធ្វើរាងកាយឲ្យមានជំហរសភាពហ្នឹងហ្ន មើមខួរពិនិត្យត្រួតត្រា នូវចលនានៃការដកដង្ហើម ចេញចូល និងចលនានៃឈាមក្នុងបេះដូង មិញ្ជាឆ្អឹងខ្នងកំណត់ចលនាឥតឆន្ទៈ ឬចលនាអចិត្តកៈ ដែលធ្វើការឆាប់ប្រញាប់ដោយឥតគិត ដូចជាការវាយមូសខាំ ឬការកន្ត្រាក់ដោយគេចាក់។ ចំពោះសរសៃប្រាសាទ នេះដែលចេញពីមជ្ឈមណ្ឌលវិញ សរសៃប្រាសាទនោះ ចូលទៅគ្រប់សព៌ាង្គកាយ ដែលចែកជាពីរយ៉ាងគឺ សរសៃប្រាសាទវេទយិត ដែលសម្រាប់ធ្វើឲ្យយើងដឹងនូវវិញ្ញាណទាំងឡាយ មកប៉ះពាល់រាងកាយយើង។ សរសៃប្រាសាទចលនា ដែលនាំការបញ្ជាអំពីមជ្ឈមណ្ឌលខួរក្បាលទៅឲ្យសាច់ដុំបណ្ដាលឲ្យមានការកម្រើកកន្ត្រាក់។

សរុបសេចក្ដីទៅ នៅក្នុងខ្លួនរបស់មនុស្សលោកនេះ សុទ្ធតែប្រកបដោយរាងកាយជាគ្រឿងផ្សំឡើងទាំងអស់ កាលបើគ្រឿងផ្សំទាំងនោះ ពុំស្របគ្នា ឬពុំមានចលនាស្មើគ្នាទេ រូបនោះក៏មិនអាចសភាពរឹងប៉ឹងបានដែរ បើរូបរាងកាយមានអាការពុំបរិបូណ៌ដូច្នេះហើយ បានជាពិភពលោកសព្វថ្ងៃនេះ ខំប្រឹងបង្កើតអង្គការមួយឈ្មោះ អង្គការសុខភាព។ កំណើតនៃអង្គការនេះគេយល់ឃើញថា រូបរាងកាយមនុស្សប្រកបដោយគ្រឿងផ្សំឡើង បើបែកបាក់គ្រឿងផ្សំណាមួយ គេត្រូវការពារ ឬជួសជុលប្រដាប់នោះ ឲ្យមានដំណើរស្រួល ដូចជារថយន្ត ដែលប្រកបដោយគ្រឿងផ្សំនោះ កាលបើម៉ាស៊ីមានដំណើរមិនស្រួល គេត្រូវរកយន្តការី មកត្រួតពិនិត្យគ្រឿងនោះយ៉ាងណា រូបរាងកាយក៏ប្រកាន់តាមហេតុនោះដែរ តាមន័យនេះ ខ្លួនគឺរូបកាយរបស់មនុស្សក្នុងលោកនេះ ខាងផ្នែកពុទ្ធសាស្ត្រ និងវិទ្យាសាស្ត្រស្របគ្នាថា ខ្លួននេះប្រកបដោយគ្រឿងផ្សំដូចគ្នាមែន ប៉ុន្តែមានការខុសគ្នាដោយអន្លើៗ។ បើទុកជាដូច្នោះក៏ដោយ អ្នកវិទ្យាសាស្ត្រនៅតែយល់ថា អត្តា ឬអាត្ម័ន នៅពាសពេញលើផ្ទៃពសុធា ហើយជារបស់មិនប្រែប្រួល ទៅណាបាន បានជាគេខំប្រឹងការពារខ្លួននោះមិនឲ្យវិនាសឆាប់ឡើយ និមិត្តហេតុដូច្នេះហើយ បានជាព្រះលោកនាថទ្រង់ត្រាសថា រូបកាយ ឬរបស់គ្រប់យ៉ាងនៅលើលោកនេះ សុទ្ធតែជាអនត្តា គឺមកមិនមែនខ្លួន មិនស្គាល់ខ្លួន ឥតមានម្ចាស់ត្រួតត្រាឡើយ បើរបស់យើងពិតមែន យើងអាចឃាត់បាន នៅពេលដែលមានវិបត្តិ ក្នុងកាលៈ ទេសៈណាមួយ ខ្លួនគឺរាងកាយរបស់មនុស្សនេះ ដែលអ្នកវិទ្យាសាស្ត្រថា ប្រកបឡើងដោយគ្រោងឆ្អឹង ពុទ្ធសាស្ត្រយល់ពិតមែនហើយ ប៉ុន្តែគ្រោងឆ្អឹងនោះ មិនអាចមានការទៀងទាត់ ស្ថិតស្ថេរនៅបានឡើយ។

**ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាសថា៖**

អត្តភាពណាមួយ ដែលមានការមិនទៀងទាត់ស្ថិតស្ថេរអ្នកចូលមើលអត្តភាពនោះ ដែលគេធ្វើវិចិត្តហើយ ជាកាយពេញពាសដោយដំបៅ ដែលកុសល និងអកុសលកម្មផ្គុំឡើងដោយឆ្អឹង៣០០កំណាត់ជាអត្តភាពក្តៅក្រហាយជានិច្ច ជាកាយដែលមហាជនរំពឹងត្រិះរិះដោយប្រការជាច្រើន។

ម្យ៉ាងទៀតកាលព្រះគតតែ ពុំទាន់បានត្រាស់ដឹង គឺនៅជាព្រះពោធិសត្វនៅឡើយ ទ្រង់មាន ទស្សនៈថាក្នុងលោកនេះ របស់ទាំងអស់គ្រប់យ៉ាងមានជីវិត ដែលគេពុំអាចទម្លាយបាន ជីវិតនេះ ជាតួអនត្តា ឬអាត្ម័ន គឺរូបរាយកាយរបស់មនុស្ស ពេលដែលព្រះអង្គបានត្រាស់ដឹង ទ្រង់បានយល់ច្បាស់នូវពាក្យថា អនត្តា ដូច្នេះ ហើយក៏ដោយ ព្រះមហាបុរសនៅតែពោលពាក្យថា អនត្តា ឬអាត្ម័នដដែល ព្រោះពុំចោលពាក្យដែលគេធ្លាប់សន្ទនាអស់រយៈកាលដ៏យូរលង់ណាស់មកហើយ ទៅជាពាក្យងាយស្តាប់ ឬជាឧបាយដ៏វិសេសមួយ អាចទាក់ទាញចិត្តគំនិតរបស់មនុស្ស ឲ្យចុះស៊ប់ក្នុងអំណាចនៃទ្រឹស្តីថា អនត្តា នេះវិញ។ មួយទៀត ព្រះមានព្រះភាគទ្រង់ត្រាស់ថា អរិយសាវ័កក្នុងសាសនានេះ កាលបើដឹងច្បាស់នូវហេតុការណ៍ នៃអនត្តា ចិត្តរមែងរួចផុតចាកកំណាន់ ប៉ុន្តែអរិយសាវ័កនោះឯងរមែងមិនវិវាទនឹងអ្នកឯណា សំដីណាដែលគេសន្មតនិយាយក្នុងអរិយសាវ័ករមែងពោលពាក្យតាមនោះ គឺមិនមានឧបាទាន (មិនសេចក្តីប្រកាន់)ឡើយ។ ដូច្នេះពាក្យថា អនត្តា ឬអាត្ម័ននេះ ព្រះពុទ្ធបរមគ្រូទ្រង់សំដែងទុកមកគ្រាន់តែជាសំនួនលោកវោហារងាយទូន្មានវេយ្យសត្វ ដែលមានកំណាន់ថា ជាខ្លួនរបស់អញ ហើយឲ្យខំតាំងចិត្តប្រតិបត្តិធម៌តែប៉ុណ្ណោះ ព្រោះព្រះអង្គគ្មានជាប់ជំពាក់ក្នុងរឿងអនត្តា ឬអាត្ម័នឡើយ។ ជាទូទៅព្រះពិជិតមារ ទ្រង់បដិសេធនូវពាក្យថា អនត្តា ឬអាត្ម័នហើយទ្រង់សម្តែងដោយបរមត្ថវោហារថាវត្ថុទាំងអស់ដែលមាននៅក្នុងលោកកាលបើមានកាយរាងសណ្ឋានទ្រង់ទ្រាយតូចធំ ល្អអាក្រក់ លក្ខណៈបែបណាក៏ដោយ សុទ្ធតែជារបស់មិនទៀង ជាទុក្ខ មិនមែនជារបស់ខ្លួន (អនត្តា) ទៅវិញ។ ឧទាហរណ៍ ដូចជាទឹកនៅក្នុងសមុទ្រ ទន្លេ ស្ទឹងបឹង មានលក្ខណៈមិនទៀង ទ្រាំមិនបាន ឥតមាននរណាមួយជាម្ចាស់ត្រួតត្រាវាត្រូវផ្លាស់ប្តូរជាដរាប ទឹកនោះកាលបើមានកំដៅត្រូវយ៉ាងខ្លាំង តែប្រែប្រួលទៅជាចំហាយហើយហុយឡើងទៅកាន់អាកាសវេហាស៍ ចំហាយនោះប៉ះនឹងធាតុត្រជាក់ ក៏ផ្តុំគ្នាក្លាយទៅជាទឹកភ្លៀងធ្លាក់ចុះមកលើផ្ទៃពសុធា និងសំងំនៅក្នុងសមុទ្រ ទន្លេ ស្ទឹង បឹង ដូចមុនទៀត វិលចុះ វិលឡើងយ៉ាងនេះ បានជាព្រះលោកវិទូទ្រង់ត្រាស់ថា វត្ថុទាំងអស់សុទ្ធតែជាអនត្តា។

តាមទ្រឹស្តីពុទ្ធសាសនា យើងបានដឹងហើយថា មនុស្សម្នាក់ៗមានខន្ធ៥ គឺ រូប វេទនា សញ្ញា សង្ខារទាំងឡាយ និងវិញ្ញាណ ខន្ធទាំង៥នេះ ដែលលោកមិនបានកំណត់រាប់យកជីវិត មកនិយាយផងទេ ព្រោះខន្ធទាំង៥នេះ លោកចែកចេញជា២ប្រការគឺ រូប១ នាម១ ធម្មជាតិណាដែលវិនាសទៅដោយក្តៅ និងត្រជាក់ ធម្មជាតិនោះលោកឲ្យឈ្មោះថា រូប ដោយមានតួមើលឃើញផង ចាប់ពាល់បានផង ធម្មជាតិណាដែលឱនចូលទៅតាមអារម្មណ៍ គឺ វេទនា សញ្ញា សង្ខារទាំងឡាយ និងវិញ្ញាណ ធម្មជាតិនោះលោកឲ្យឈ្មោះថា នាមធម៌ដោយគ្រាន់តែមានឈ្មោះប៉ុណ្ណោះ គឺជាធម្មជាតិផ្លាស់ប្តូរប្រែប្រួល មិនបានទទួលអារម្មណ៍ល្អ អាក្រក់ មិន

មែនជាបុណ្យ បាប ជាអព្យាក្រឹត្យ កាលបើរូបកើតឡើង រូបនោះក៏រមែងបែកធ្លាយ ឬរលត់ទៅវិញជាធម្មតា។

ព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញ និងប្រៀបធៀបចំពោះខន្ធទាំង៥យ៉ាងដូច្នេះថា៖

រូបមានសេចក្តីប្រៀបធៀបដូចជាដុំនៃពពុះទឹក វេទនាមានសេចក្តីប្រៀបធៀបដូចជាក្រពេញទឹកដែលប៉ោងឡើងព្រួចៗ សញ្ញាមានសេចក្តីប្រៀបធៀបដូចជាថ្ងៃបណ្តើរកូន សង្ខារទាំងឡាយមានសេចក្តីប្រៀបធៀបដូចជាដើមចេក វិញ្ញាណមានសេចក្តីប្រៀបធៀបដូចជាកលមាយា សេចក្តីប្រៀបនៃខន្ធទាំង៥នេះ គឺព្រះសម្ពុទ្ធមានផៅពង្សដូចជាព្រះអាទិត្យទ្រង់សំដែងហើយ។

សេចក្តីប្រៀបធៀបនៃព្រះពុទ្ធដីកាខាងលើនេះ ព្រះអណាវណាញ្ញាណទ្រង់បំភ្លឺថា ខន្ធទាំង៥នេះមានរូបជាដើម មិនអាចឋិតថេរចីរកាលបានទេ ព្រោះរូបនេះជាទីជម្រកនៅនៃជរា ព្យាធិ និងមរណៈ រូបនេះលោកប្រៀបដូចជាចង្កៀង ធម្មតាចង្កៀងដែលមានពន្លឺទៅបានដោយអាស្រ័យឧបករណ៍បរិបូណ៌ គឺមាន តួចង្កៀង ប្រេង ប្រឆេះ អាកាស និងមានមនុស្សអុចទើបមានចំហេះ យ៉ាងណា ឯរូបរាងកាយ ដែលមានជីវិតរស់នៅកើតមានឡើងបាន ដោយអំណាចនៃការប្រជុំនៃហេតុបច្ច័យទាំងនោះដែរ។ រូបដែលកើតឡើងតៗគ្នានោះ ក៏គ្រាន់ជា ឧប្បាទធម៌ ឬក៏មានចលនានៃរាងកាយដែលប្រកបដោយធាតុ៤ប៉ុណ្ណោះ ការប្រព្រឹត្តទៅនៃរូបនេះជាឧប្បាទធម៌មួយ ដែលកើតឡើង ឋិតនៅ រលត់ទៅវិញ របស់នាមធម៌ជាបន្តបន្ទាប់គ្នា ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជាក់អំពីលក្ខណៈរបស់រូបថា របស់ណាមួយ មានកិរិយាកើតឡើងជាធម្មតា របស់នោះ មានកិរិយារលត់ទៅវិញជាធម្មតាដែរ ព្រោះហេតុដូច្នោះ បានព្រះសយម្ភូញាណទ្រង់ត្រាស់ថា អនត្តា។

ព្រះពុទ្ធបរមគ្រូទ្រង់សំដែងបញ្ជាក់ថា អាយតនៈទាំង១២សុទ្ធតែជា អនត្តា មានសេចក្តីដូចខាងក្រោម៖

ម្នាលអានន្ទ អនត្តាសញ្ញា នោះដូចម្តេច? ម្នាលអានន្ទភិក្ខុសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា ភ្នែក រូបទាំងឡាយ ត្រចៀក សម្លេងទាំងឡាយ ច្រមុះ ក្លិនទាំងឡាយ អណ្តាត រសទាំងឡាយ កាយ សម្ផស្សទាំងឡាយ ចិត្ត ធម៌ទាំងឡាយ មិនមែនជារបស់ខ្លួនទេ ភិក្ខុពិចារណាឃើញរឿយៗថា មិនមែនជារបស់ខ្លួនក្នុងអាយតនៈខាងក្នុង៦ និងអាយតនៈខាងក្រៅ៦នេះ ដោយប្រការដូច្នេះ ម្នាក់អានន្ទ នេះហើយដែលតថាគតហៅថា អនត្តសញ្ញា។ ដូច្នេះពាក្យថា អនត្តា ជាពុទ្ធទស្សនៈមួយ ដែលព្រះសម្ពុទ្ធជាម្ចាស់ទ្រង់សំដែងមកនេះ ដើម្បីជាគ្រឿងពិចារណានៃប្រជាពលលោក ព្រោះអនត្តាធម៌នេះ ជាឧប្បាទធម៌មួយ ដែលអាចបង្ខិល មនុស្ស ទេវា មារ ព្រហ្មទាំងនោះ ឲ្យចុះស៊ប់ក្នុងអំណាចនៃទ្រឹស្តីថា នោះមិនមែនជារបស់អញ នោះមិនមែនអញ នោះមិនមែនជារបស់អញឡើយ គឺជាសភាពមិនប្រព្រឹត្តទៅក្នុងអំណាចនៃហេតុណាមួយ សភាពមិនមានម្ចាស់ត្រួតត្រា ហួងហែងរក្សាការពារ សភាពសោះសូន្យទទេ សភាពជាគូបដិបក្ខ និងអត្តា (ខ្លួនប្រាណ)។ ក្នុងលោកនេះមនុស្សគ្រប់សញ្ជាតិ ឬគ្រប់សាសន៍ ទោះបីមានវ័យបែបណា និងឋានៈបែបណាក៏ដោយ ត្រូវមានធម៌នេះប្រព្រឹត្តតាម ឬឋិតនៅជាប់ជាដរាប បើទុកជាជនណាមួយ ដែលមានបំណងគេចវេះឲ្យផុតពីធម៌នោះពុំបាន សូម្បីជននោះបានចូលទៅសំងំក្នុង

អាកាសក្តី ក្នុងសមុទ្រក្តី ក្នុងល្អាងភ្នំ ឬចន្លោះនៃភ្នំក្តី ឬក៏ជ្រោះជ្រលងដងអូក្តី ក៏នៅតែគេចមិនរួចពីអនត្តាធម៌ដដែល។

ជាទូទៅ ប្រទេសលើផែនដី ដែលមនុស្សលោកឋិតនៅ ឬរស់នៅ ក៏ត្រូវមានធម៌នេះគ្របសង្កត់ជាធម្មតា គម្របនៃអនត្តាធម៌នេះ ចំពោះមនុស្ស សត្វ ឬវត្ថុគ្រប់បែបយ៉ាងក្នុងលោកនេះ ពុំរើសវណ្ណៈទេ ទោះបីស្តេចនាម៉ឺន មន្ត្រី គហបតី ប្រជារាស្ត្រ អ្នកមាន អ្នកក្រ ល្អ អាក្រក់ ក្មេង ចាស់ កម្លោះ ក្រមុំ ប្រុស ស្រី មានវ័យ ឬចំណាស់បែបណាក៏ដោយ ឲ្យតែមានរូបរាងកាយ សុទ្ធតែឋិតនៅក្នុងអំណាចនៃធម៌នោះទាំងអស់ ធម៌នេះ ពុំមែនជាធម៌សម្រាប់អ្នកស្រុក  ពុំមែនជាធម៌សម្រាប់អ្នកនិគម ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយៗក៏ពុំមែនទេ ធម៌នេះ គឺជាធម៌សម្រាប់មនុស្ស សត្វ ទេព្តា មារ ព្រហ្ម គ្រប់ៗរូបទាំងអស់ និមិត្តហេតុប៉ុណ្ណោះហើយ បានជាព្រះសម្មាសម្ពុទ្ធ ជាមហាទស្សនវិទូមួយយ៉ាងឯក ទ្រង់ត្រាស់ថា ក្នុងពិភពលោកនេះ អ្វីទាំងអស់ដែលបច្ច័យប្រជុំតាក់តែងប្រមូលផ្តុំឡើងជារូបរាងកាយនោះ ទោះបីមានវិញ្ញាណក្តី ឥតវិញ្ញាណក្តី សុទ្ធតែជារបស់មិនស្តាប់បង្គាប់ឥតមានម្ចាស់ត្រួតត្រាឡើយ[44]។

អនត្តា សភាពមិនមែនជារបស់ខ្លួន មានអាការៈ៥គឺ

បរតោ ខន្ធ៥ មិនលុះក្នុងអំណាចនៃបុគ្គលដទៃ មិនចេះស្តាប់បង្គាប់អ្នកណាឡើយ១ បរិត្តតោ ខន្ធ៥ ប្រកបដោយសេចក្តីសុខចម្រើនទៀងទាត់ស្ថិតស្ថេរតិចពេកណាស់ រកសង្ឃឹមមិនបាន១ តុច្ឆតោ ខន្ធ៥ ឥតមានអ្វីសោះជារបស់ទទេ១ សុញ្ញតោ ខន្ធ៥ មិនស្ថាពរឡើយ ជារបស់សោះសូន្យ១ អនត្តតោ ខន្ធ៥ មិនមែនជារបស់ចិត្ត របស់ខ្លួន មិនលុះក្នុងអំណាចចិត្ត អំណាចខ្លួនសោះឡើយ១។ អាការៈរបស់អនត្តា៥នេះ បុគ្គលត្រូវពិចារណា ឲ្យគ្រប់ខន្ធទាំង៥ ក្នុងខន្ធមួយៗមានអាការៈ៥ ប្រាំៗដងត្រូវជា២៥។ គុណនៃការពិចារណានូវអនត្តធម៌នេះ អាចលះបង់នូវនិកន្តិ សេចក្តីត្រេកត្រអាលចំពោះខន្ធទាំង៥។

រួមអាការៈរបស់ត្រៃលក្ខណៈទាំង៣ត្រូវជា២០០គត់ ឬ ថាត្រូវជាសាមញ្ញលក្ខណៈ២០០គត់។

ការពិចារណានូវត្រៃលក្ខណ៍នេះ មិនមែនលះអកុសលធម៌បានត្រឹមតែធម៌៣គឺ ទិដ្ឋិ មានៈ និកន្តនោះទេ អាចលះបង់បាននូវអកុសលធម៌ដាច់ដាច់ ដរាបដល់ចិត្តផុតស្រឡះចាកអាសវធម៌ទាំងពួង រំលត់នូវខន្ធទាំង៥បានដល់នូវព្រះនិព្វានជាទីបំផុត។

ការមិនទៀងទាត់ជាដើមនេះឯងហើយជាលក្ខណៈប្រចាំពិភពលោក ប្រចាំជីវិតរបស់អ្នក ពិភពលោកនេះត្រូវបានញាំញីដោយធម៌ទាំងបីនេះព្រោះហេតុដូច្នោះទើបព្រះសម្មាសម្ពុទ្ធ បន្ទាប់ពីទ្រង់បានត្រាស់ដឹងមកស្តេចយាងទៅប្រោសបញ្ចវគ្គិយភិក្ខុ នាព្រៃឥសិបតនមិគទាយវ័ន ព្រះអង្គសម្តែងអំពីអត្តលក្ខណសូត្រ គឺប្រកាសអំពីអនិច្ចំ ទុក្ខំ អនត្តតា ដែលជាលក្ខណៈប្រចាំពិភពលោកនេះ ឲ្យបញ្ចវគ្គិយភិក្ខុ ស្តាប់ ដើម្បីធ្វើខ្លួនឲ្យផុតពីសេចក្តីព្រួយលំបាក វិនាសអន្តរាយគ្រប់យ៉ាង ឲ្យបានក្របដណ្តប់នូវសេចក្តីសុខក្សេមក្សាន្តក្នុងព្រះនិព្វាន។

ដើម្បីពិចារណានូវត្រៃលក្ខណ៍ ទាំង៣នោះឲ្យច្បាស់លាស់ មុនដំបូងត្រូវស្គាល់នូវខន្ធ៥ ដែលមាននៅក្នុងខ្លួនរបស់យើងគេ ទាំងអស់គ្នាសិន។ ខន្ធ៥នោះមាន រូបក្ខន្ធ គំនរគឺរូប១ វេទនាខន្ធ គំនរគឺវេទនា១ សញ្ញា

[44] កម្ពុជសុរិយា ទស្សនវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ ព.ស ២៥១៤ គ.ស ១៩៧០ ទំព័រ ៦០៥

ខន្ធ គំនរគឺសញ្ញា១ សង្ខារក្ខន្ធ គំនរគឺសង្ខារ១ វិញ្ញាណក្ខន្ធ គំនរគឺវិញ្ញា១។

រូបក្ខន្ធ

ពាក្យថា រូបប្រែថា ធម្មជាតិដែលប្រែប្រួល ឬវិនាសដោយហេតុផ្សេងៗ មានវិនាសដោយក្តៅ និងត្រជាក់ជាដើម ចែកចេញជា២គឺយ៉ាងគឺ មហាភូតរូប១ ឧបាទាយរូប១។

មហាភូតរូបមាន៤គឺ

បឋវិជាតុរូប រូបធាតុដីមាន ២០គឺ កេសា សក់ លោមា រោម នខា ក្រចក ទន្តា ធ្មេញ តចោ ស្បែក មំសំ សាច់ ន្ហារូ សរសៃ អដ្ឋិ ឆ្អឹង អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង វក្កំ ទាច ហទយំ បេះដូង យកនំ ថ្លើម កិលោមកំ វាវ បិហកំ សាច់ស្ទៀត បប្ផាសំ សួត អន្តំ ពោះវៀនធំ អន្តគុណំ ពោះវៀនតូច ឧទរីយំ អាហារថ្មី ករីសំ អាហារចាស់ មត្ថលុង្គំ ខួរក្នុងក្បាល (១)។

អបោធាតុរូប រូបធាតុទឹកមាន ១២គឺ

បិត្តំ ទឹកប្រមាត់ សេម្ហំ ទឹកស្លេស្ម៍ បុព្វោ ទឹកខ្ទុះ លោហិតំ ទឹកឈាម សេទោ ទឹកញើស មេទោ ខ្លាញ់ខាប់ អស្សុ ទឹកភ្នែក វសា ខ្លាញរាវ ខេឡោ ទឹកមាត់ សិង្ឃានិកា ទឹកសម្បោរ លសិកា ទឹករំអិល មុត្តំ ទឹកនោម (២)។

តេជោធាតុរូប រូបធាតុភ្លើងមាន៤គឺ

សន្តប្បត្តិ ភ្លើងអប់រំកាយ ផ្សាយទៅក្នុងសរីរៈ ឲ្យក្តៅសព្វជាប្រក្រតី បរិទយ្ហត្តិ ភ្លើងក្តៅរោលរាលផ្សាយទៅក្នុងកាយ បរិណាមត្តិ ភ្លើងដុតរំលាយអាហារឲ្យទ្រុឌទ្រោមផ្សាយឱជារសឲ្យជ្រួតជ្រាបទៅក្នុងកាយ ជីរណត្តិ ភ្លើងដុតរាងកាយឲ្យចាស់គ្រាំជរាទុព្វលភាព (៣)។

វាយោធាតុរូប រូបធាតុខ្យល់មាន៦គឺ

ឧទ្ធង្គមា វាតា ខ្យល់បក់ពីខាងក្រោមផ្សាយទៅខាងលើ អធោគមា វាតា ខ្យល់បក់ពីខាងលើផ្សាយចុះទៅខាងក្រោម កុច្ឆិសយា វាតា ខ្យល់បក់វិលវល់ផ្សាយទៅក្នុងផ្ទៃពោះ កោដ្ឋាសយា វាតា ខ្យល់បក់ផ្សាយទៅសព្វអវយវៈធំតូច អស្សាសបស្សាសា ខ្យល់សម្រាប់ដកដង្ហើមចេញចូល (៤)។

ឧបាទាយរូបមាន២៤គឺ

បសាទរូប៥គឺ (ចក្ខុរូប រូបគឺភ្នែក១ សោតរូប រូបគឺត្រចៀក១ ឃានរូប រូបគឺច្រមុះ១ ជីវ្ហារូប រូបគឺអណ្តាត១ កាយរូប រូបគឺកាយ១)។ វិសយរូប៤គឺ (រូបារម្មណរូប រូបគឺ រូបារម្មណ៍១ សទ្ទារម្មណរូប រូបគឺសទ្ទារម្មណ៍១ គន្ធារម្មណរូប រូបគឺ គន្ធារម្មណ៍១ រសារម្មណរូប រូបគឺ រសារម្មណ៍១។ ភាវរូប២គឺ ឥត្ថីភាវរូប រូបភាពគឺស្ត្រី១ បុរិសភាវរូប រូបភាពគឺបុរស១។ ហទយរូប១ ឯហទយរូប១នោះ គឺរូបហឫទ័យជាទីអាស្រ័យនៃមនោធាតុ។អាហាររូប១ រូបអាហារដែលបុគ្គលធ្វើឲ្យជាពំនូតហើយ បរិភោគសម្រាប់ទំនុកបម្រុងនូវរាងកាយ។ ជីវិតរូប១ រូបជីវិត គឺការរស់នៅ។ បរិច្ឆេទរូប១ បរិច្ឆេទរូប រូបដែលមានក្នុងចន្លោះៗនៃរូប គឺធម្មតាកាត់តែងកំណត់មិនឲ្យច្រឡំ នូវបាច់នៃរូបមួយៗ។ វិញ្ញត្តិរូប២ គឺ កាយវិញ្ញត្តិរូប រូបដែលញ៉ាំងកាយឲ្យកម្រើក១ វចីវិញ្ញត្តិរូប រូបដែលញ៉ាំងវាចាឲ្យកម្រើក១។ វិការរូប៣ គឺ រូបស្ស លហុតា រូបភាពនៃការប្រព្រឹត្តទៅ ឆាប់រហ័ស មិនយឺតយូរ១ រូបស្ស មុទុតា រូបគឺភាវទន់ភ្លន់ ងាកបែរទៅមកបាន មិនគាំង មិនរឹង១ រូបស្ស កម្មញ្ញតា រូបភាពនៃការប្រព្រឹត្តទៅ គួរដល់ការងារទាំងពួង១។ លក្ខណរូប៤ គឺ រូបស្ស ឧបចយោ កិរិយាសន្សំនៃរូបជាដំបូង តាំងតែពីបដិសន្ធិមក ដរាបដល់កើតចក្ខុទសកៈ សោតទសកៈ១ រូបស្ស សន្តតិ ដំណនៃរូបដែលកើតអំពីនោះទៀត

តែនៅមិនទាន់ដល់ការគ្រាំគ្រា១ រូបស្ស ជរតា ភាវៈនៃសេចក្តីចាស់គ្រាំគ្រា នៃរូបទាំងពីរនោះ១ រូបស្ស អនិច្ចតា ភាពនៃការមិនទៀងទាត់មិនស្ថាពរ នៃរូបទាំង៣នោះ រួចជា២៤។ ការរួបរួមគំនររូបទាំងអស់ ដូចបានរៀបរាប់មកប៉ុណ្ណេះជាដើមហៅថា រូបក្ខន្ធ។

២ វេទនាខន្ធ

វេទនាខន្ធ ប្រែថា ធម្មជាតិទទួលនូវរសនៃអារម្មណ៍ ដូចពាក្យដែលព្រះសារីបុត្តត្ថេរសម្តែងថា វេទយតីតិ ខោ អាវុសោ តស្មា វេទនាតិ វុច្ចតិ ធម្មជាតិណាទទួលសោយនូវអារម្មណ៍ ធម្មជាតិនោះ ព្រះមានព្រះភាគត្រាស់ហៅថា វេទនា។ វេទនានេះជាចេតសិកធម៌មួយសម្រាប់ទទួលដឹងនូវរសនៃអារម្មណ៍ បើអារម្មណ៍ មានរសជាសុខ ជាទុក្ខ ឬ ជាឧបេក្ខាមកដល់ហើយ ចេតសិកធម៌ គឺវេទនានោះ ក៏ទទួលដឹងនូវរសនៃអារម្មណ៍នោះៗ បានទាំងអស់ ព្រោះវេទនានេះ ជាសព្វចិត្តសាធារណចេតសិក ដូចគ្នានឹងផស្សៈដែរ ចែកទៅតាមទីកន្លែងដែលកើត មាន៦ប្រការគឺ

ចក្ខុសម្ផស្សជាវេទនា វេទនាកើតដោយចក្ខុសម្ផស្ស១ សោតសម្ផស្សជាវេទនា វេទនាកើតដោយសោតសម្ផស្ស១ ឃានសម្ផស្សជាវេទនា វេទនាកើតដោយឃានសម្ផស្ស១ ជិវ្ហាសម្ផស្សជាវេទនា វេទនាកើតដោយជិវ្ហាសម្ផស្ស១ កាយសម្ផស្សជាវេទនា វេទនាកើតដោយកាយសម្ផស្ស១ មនោសម្ផស្សជាវេទនា កើតដោយមនោសម្ផស្ស១។ ម្យ៉ាងទៀត វេទនានេះបើនិយាយដោយជាតិវិញ មាន៣យ៉ាងគឺ កុសលវេទនា១ អកុសលវេទនា១ អព្យាកតវេទនា១។ រួមវេទនាទាំងអស់ ដូចបានរៀបរាប់មកប៉ុណ្ណេះជាដើមហៅថា វេទនាខន្ធ។

៣ សញ្ញាខន្ធ

សញ្ញា ប្រែថា ធម្មជាតិដឹង ឬស្គាល់ដោយប្រពៃនូវអារម្មណ៍ មានពណ៌ខៀវជាដើម ឬថា ធម្មជាតិចំណាំនូវអារម្មណ៍ ដូចពាក្យដែលព្រះសារីបុត្តត្ថេរសម្តែងថា សញ្ជានាតីតិ ខោ អាវុសោ តស្មា សញ្ញាតិ វុច្ចតិ ម្នាលអាវុសោ ធម្មជាតិណា ចំណាំនូវអារម្មណ៍ធម្មជាតិនោះព្រះមានព្រះភាគត្រាស់ហៅថា សញ្ញា។

សញ្ញានេះបែងចែកទៅតាមប្រភេទនៃអារម្មណ៍មាន៦គឺ រូបសញ្ញា សេចក្តីសម្គាល់ក្នុងរូបារម្មណ៍១ សទ្ទសញ្ញា សេចក្តីសម្គាល់ក្នុងសទ្ទារម្មណ៍១ គន្ធសញ្ញា សេចក្តីសម្គាល់ក្នុងគន្ធារម្មណ៍១ រសសញ្ញា សេចក្តីសម្គាល់ក្នុងរសារម្មណ៍១ ផោដ្ឋព្វសញ្ញា សេចក្តីសម្គាល់ក្នុងផោដ្ឋព្វារម្មណ៍១ ធម្មសញ្ញា សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍១។ ម្យ៉ាងទៀត សញ្ញានេះបើនិយាយដោយជាតិវិញមាន៣យ៉ាងគឺ កុសលសញ្ញា១ អកុសលសញ្ញា១ អព្យាកតសញ្ញា១ ដូចគ្នានិងវេទនាដែរ។ រួបរួមសញ្ញាទាំងអស់ដូចបានរៀបរាបមកប៉ុណ្ណេះ ជាដើមនេះហៅថា សញ្ញាខន្ធ។

៤ សង្ខារខន្ធ

សង្ខារ ប្រែថា ការតាក់តែង គ្រឿងប្រកប គ្រឿងប្រុង ផ្គុំ ប្រមូលផ្សំ ចែកចេញជា៣យ៉ាងគឺ

បុញ្ញាភិសង្ខារ ការតាក់តែងសត្វឲ្យកើតក្នុងកាមាវចរភូមិ និងរូបាវចរភូមិ១ អបុញ្ញាភិសង្ខារ ការតាក់តែងសត្វឲ្យកើតក្នុងអបាយភូមិទាំងបួនមាននរកជាដើម១ អនេញ្ជាភិសង្ខារ ការតាក់តែងសត្វឲ្យកើតក្នុងអរូបព្រហ្ម។ សង្ខារចែកជា៣យ៉ាងទៀតគឺ កាយសង្ខារ ការកម្រើកអវយវៈដូចជាលើកដៃ លើកជើង ឈានដើរជាដើម១វចីសង្ខារ ការកម្រើកវាចាគឺនិយាយស្តី សើច យំ ជាដើម១ ចិត្តសង្ខារ ការត្រិះរិះនូវអារម្មណ៍ផ្សេងៗ។ សង្ខារនេះបើចែកទៅតាមជាតិមាន៣គឺ កុសលសង្ខារ១ អកុសលសង្ខារ១ អព្យាកតសង្ខារ១ ដូចគ្នានឹងវេទនាដែរ។ ការរួបរួមសង្ខារទាំងអស់ ដូចបានរៀបរាប់មកប៉ុណ្ណេះជាដើមនេះ ហៅថា សង្ខារក្ខន្ធ។

៥ វិញ្ញាណក្ខន្ធ

វិញ្ញាណ ប្រែថា ធម្មជាតិដឹងច្បាស់នូវអារម្មណ៍ទាំងពួង អារម្មណ៍ទាំង៦មានរូបារម្មណ៍ជាដើម តែងមកផ្ទប់ក្នុងទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម ធម្មជាតិដែលដឹងនូវអារម្មណ៍នោះ ជាក់ច្បាស់ជាងចេតសិកធម៌ទាំងពួង ហៅថា វិញ្ញាណ វិញ្ញាណនោះហៅថា ចិត្ត ក៏បាន ព្រោះជាធម្មជាតិតែងសន្សំនូវអារម្មណ៍ទាំងពួង ហៅថា មនោ ក៏បាន ព្រោះជាធម្មជាតិតែងទន់ទោរទៅកាន់អារម្មណ៍។

វិញ្ញាណនោះបើចែកទៅតាមទ្វារមាន៦គឺ

ចក្ខុវិញ្ញាណសេចក្ដីដឹងច្បាស់នូវអារម្មណ៍ក្នុងចក្ខុទ្វារ១សោតវិញ្ញាណ សេចក្ដីដឹងច្បាស់នូវសទ្ទារម្មណ៍ក្នុងសោតទ្វារ១ ឃានវិញ្ញាណ សេចក្ដីដឹងច្បាស់នូវគន្ធារម្មណ៍ក្នុងឃានទ្វារ១ ជីវ្ហាវិញ្ញាណ សេចក្ដីដឹងច្បាស់នូវអារម្មណ៍ ក្នុងជីវ្ហាទ្វារ១ កាយវិញ្ញាណ សេចក្ដីដឹងច្បាស់នូវផោដ្ឋព្វារម្មណ៍ក្នុងកាយទ្វារ១ មនោវិញ្ញាណ សេចក្ដីដឹងច្បាស់នូវធម្មារម្មណ៍ក្នុងនមោទ្វារ១។ ម្យ៉ាងទៀត វិញ្ញាណ នេះបើចែកទៅតាមជាតិមាន៣គឺ កុសលវិញ្ញាណ១ អកុសលវិញ្ញាណ១ អព្យាកតវិញ្ញាណ១។ រួបរួមវិញ្ញាណទាំងអស់ ដូចបានរៀបរាប់មកប៉ុណ្ណេះជាដើមនេះ ហៅថា វិញ្ញាណក្ខន្ធ។

ខន្ធទាំង៥នេះ មានគ្រប់រូបសត្តនិករទាំងអស់ ជាមេនាំបណ្ដាលសត្តនិករឲ្យកើតទុក្ខព្រួយក្រៀមក្រំខ្សឹកខ្សួលអាឡោះអាល័យជាអនេក រកទីបំផុតរកចុងដើមមិនឃើញ ព្រោះក្នុងខន្ធមួយៗមានលក្ខណៈប្រចាំនៅ៣ៗគ្រប់ខន្ធទាំង៥[45]។

ការយល់ច្បាស់សព្វគ្រប់អំពីលក្ខណៈទាំង៣នេះ អាចជួយមនុស្សបញ្ចប់សេចក្ដីទុក្ខបាន (Dukkha nirodha)។ ព្រះពុទ្ធបានបង្រៀនថា អ្វីៗទាំងអស់ដែលតាក់តែងឡើងដោយបច្ច័យ (សង្ខារ) ជារបស់មិនទៀង និង ជាទុក្ខ។ ព្រះអង្គក៏មានព្រះបន្ទូលថា អនត្តា ជាធម៌ពន្យល់ថា គ្មានអញ ឬ របស់អញ ក្នុងអ្វីៗដែលមានបច្ច័យតាក់តែង និង អ្វីៗដែលគ្មានបច្ច័យតាក់តែង (ដូចជានិព្វាន)។

ព្រះសិទ្ធត្ថបានសម្រេចព្រះនិព្វាន និង សម្មាសម្ពោធិញ្ញាណ បន្ទាប់ពីបានធ្វើសមាធិយ៉ាងបរិបូណ៌ ហេតុនេះទើប ព្រះអង្គត្រូវបានហៅថាព្រះពុទ្ធសក្យមុនី (មនុស្សនៃត្រកូលសក្យដែលប្រកបដោយបញ្ញា និងបានជាព្រះពុទ្ធ)។ ដោយសារបញ្ញិន្ទ្រិយ (ឥន្ទ្រិយ គឺ បញ្ញា) ព្រះពុទ្ធទ្រង់ដឹងដោយផ្ទាល់ថា អ្វីៗនីមួយៗក្នុងរូបលោកនេះ (និងអ្វីៗក្នុងបាតុភូតវិទ្យា និងចិត្តវិទ្យា) សំគាល់បានដោយលក្ខណៈ ៣ នេះ។

**១ អនិច្ចំ** ជាពាក្យក្នុងភាសាបាលី ដែលភាសាសំស្ក្រឹតហៅថា អនិត្យា ប្រែថា មិនទៀង ឬមិនស្ថិតស្ថេរ ពាក្យនេះតម្រង់ទៅលើការពិតដែលថា ធម៌ទាំងអស់ ដែលតាក់តែងដោយបច្ច័យ (សង្ខារ) មានដំណើរប្រែប្រួលជានិច្ច។ តាមពិតគ្មានធម៌ឯណា ដែលសាបសូន្យក្នុងទីបំផុតទេ អាការៈខាងក្រៅរបស់វាប៉ុណ្ណោះ ដែលសាបសូន្យ ព្រោះវាផ្លាស់ប្ដូរពីធម្មជាតិមួយ ទៅធម្មជាតិមួយផ្សេងទៀត។ ឧបមាដូចជាស្លឹកឈើ ដែលធ្លាក់ចុះលើដី ហើយរលាយបាត់ទៅ។ នៅពេលដែលរូបរាង និងវត្តមានរបស់ស្លឹកឈើបានសាបសូន្យទៅ គ្រឿងដែលបង្កើតស្លឹកឈើ បានក្លាយទៅជាលំអងល្អិតៗ ដែលអាចបន្តឲ្យដើមឈើថ្មី កើតឡើង។ ពុទ្ធសាសនាបង្រៀនមនុស្សឲ្យប្រកាន់យកមាគ៌ាកណ្ដាល (ឧបេក្ខា) ដោយជៀសវាងនូវទស្សនៈហួសហេតុ គឺសស្សតទិដ្ឋិនិយម

[45] សុង ស៊ីវ ត្រៃលក្ខណប្រទីប ការផ្សាយរបស់បណ្ណាគារ ត្រៃរតន៍ លេខ១៣៦អី០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ ព.ស ២៤៩៨ គ.ស ១៩៥៥ ទំព័រ ១-២៨

(eternalism) និង ឧច្ឆេទទិដ្ឋិនិយម (nihilism)។

## ១០.៤. សមាធិ និងបស្សនា

### ១០.៤.១. និយមន័យសមាធិ

**និយមន័យ សមាធិ សមាធិ** ដំណើរតាំងស៊ប់មាំនៃចិត្ត ការចុះស៊ប់ឬស្លុងចិត្តក្នុងអារម្មណ៍ដែលរំពឹង ការនឹករំពឹងស្លុងចិត្ត ដំណើរស្លុងចិត្តស៊ប់ក្នុងអង្គឈាន។ ។(វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត)

**សមាធិ** គឺជាការតាំងចិត្តមាំក្នុងអារម្មណ៍តែមួយ ឬការដឹងច្បាស់នូវអារម្មណ៍នោះៗ ដោយសច្ចភាព។

### ១០.៤.២. របៀបចម្រើនសមាធិ

វិធីរំងាប់ការបែកអារម្មណ៍

ពង្រឹងស្មារតី

អារម្មណ៍មូល និងល្អ ពិចារណាអ្វីក៏បានល្អ

ពិតណាស់ ទាំងគេទាំងយើង តែដល់វ័យដែលគេនិយមហៅថាពេញវ័យនោះ ចាប់ផ្ដើមមានអារម្មណ៍មិនស្រួលរវើរវាយគិតច្រើន នាំឲ្យមានអារម្មណ៍មិនសូវមូល ប៉ះពាល់ខ្លាំងជាងគេគឺទៅលើការសិក្សា និងការងារតែម្ដង។

១ - វិធីអនុវត្តលម្អិតក្នុងការធ្វើសមាធិនេះគឺធ្វើដូចខាងក្រោម

១ - អង្គុយពែនភ្នែនដោយដាក់ជើងស្ដាំលើជើងឆ្វេង

២ - ដៃស្ដាំដាក់លើដៃឆ្វេង

៣ - បិទភ្នែក

៤ - ដកដង្ហើមចូលនិងដកដង្ហើមចេញឲ្យវែងៗ

៥ - ប្រមូលអារម្មណ៍គិតតែពីការដកដង្ហើមចូលនិងចេញប៉ុណ្ណោះរយៈពេល១៥ទៅ៣០នាទីរាល់ៗថ្ងៃ ឧទាហរណ៍ គិតថាអារម្មណ៍ខ្ញុំចូលហើយអារម្មណ៍ខ្ញុំចេញហើយ អានាបាណស្សតិ យស្ស អបរិបុណ្ណា អភាវិតា កាយោបិ ឥញ្ជិតោ ហោតិ ចិត្តម្បិ ហោតិ ឥញ្ជិតំ។ អាណាបាណស្សតិ ដែល អ្នកណាមិនបានអប់រំឲ្យបរិបូណ៌ កាយក្ដី ចិត្តក្ដី របស់អ្នកនោះតែងញាប់ញ័រ។ អានាបាណស្សតិ គឺការចម្រើននូវ អានាបាណស្សតិកម្មដ្ឋាន ប្រែថា កម្មដ្ឋានដែលលើកខ្យល់ចេញចូលជាអារម្មណ៍។ បុរសស្ត្រីណាមិនបានអប់រំ បានសេចក្ដីថា មិនបានចម្រើនឲ្យកើតមានឡើងក្នុងសន្ដានចិត្តទេ កាយក្ដី ចិត្តក្ដី របស់បុរសស្ត្រីនោះរមែងញាប់ញ័រតក់ស្លុតរន្ធត់ខ្លាចនឹង សេចក្ដីស្លាប់ជាធម្មតា មកពីមិនបានចម្រើនអាណាបាណស្សតិកម្មដ្ឋាននោះឯង។ (ដកស្រង់ចេញពី ខុទ្ទកនិកាយ បដិ សម្ភិទាមគ្គ និងធ្វើអត្ថាធិប្បាយដោយ មហា សោម សុវណ្ណ) ពន្យល់ន័យ " អានាបាណស្សតិ" តាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត អានាបាណ ខ្យល់ដង្ហើមចេញ" + អាបាណ "ខ្យល់ដង្ហើមចូល" ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល។ ក្នុងគម្ពីរកែសព្ទពន្យល់សេចក្ដីថា លោកអ្នកប្រាជ្ញពួកខ្លះយល់ថា អាន អស្សាស "ខ្យល់ដង្ហើមចូល" អាបាណ បស្សាស "ខ្យល់ដង្ហើមចេញ" ដូច្នេះវិញ, ក៏គង់បានសេចក្ដីថា "ខ្យល់ដង្ហើមចូលចេញឬចេញចូលដូចគ្នា គឺប្រើការបានដូចគ្នា (ហៅ អានាប្រាណ ក៏បាន ឬហៅត្រឹមតែ

អានាបា ក៏បាន។ ឈ្មោះកម្មដ្ឋានមួយយ៉ាង (ក្នុងពួកអនុស្សតិកម្មដ្ឋាន១០) ប្រើវិធីរាប់ខ្យល់ដង្ហើមចេញចូលចម្រើនអានាបា ឬ អានាប្រាណ។ ខ្មែរប្រើពាក្យនេះជាឈ្មោះវិធីស្មិង ស្មាធិ៍មួយយ៉ាង (ខាងផ្លូវធ្វេងក្រៅពីបែបកម្មដ្ឋាន) ប្រើវិធីភាវនារាប់ខ្យល់ដង្ហើមដែរ ចេះអានា ប្រាណ បែកអានាប្រាណទៅជាខូចស្មារតី ។

### ១០.៤.៣. បុគ្គលដែលអាចធ្វើសមាធិបាន

**តើអ្នកណាខ្លះអាចធ្វើការសមាធិបាន?**

មនុស្សគ្រប់វ័យសុទ្ធតែអាចធ្វើសមាធិបាននៅគ្រប់ពេល និងកាលៈទេសៈ ប៉ុន្តែចំពោះអ្នកដែលកំពុងតានតឹងខ្លាំង ឬស្ត្រេសខ្លាំង យកល្អគួរតែកុំធ្វើ ការសមាធិ លុះត្រាតែមានគ្រូបង្ហាត់នៅជាមួយ ចៀសវាងការនៅម្នាក់ឯង ដែលអាចបង្កជាទុក្ខទោសទៅវិញ។

ដើម្បីធ្វើការសមាធិបានល្អ លក្ខខណ្ឌដំបូងគេគឺទីតាំងស្ងប់ស្ងាត់ល្មម និងចៀសវាងការស្លៀកពាក់តឹងពេកដែលពិបាកដល់ការធ្វើឥរិយាបថសមរម្យ ឬអ្នកអាចអង្គុយលើកៅអីជំនួសឲ្យការបត់ជើងពែនភ្នែន។ រយៈពេលដែលល្អ គួរតែមួយថ្ងៃ ១០នាទី មុនពេលចូលគេង៥នាទី និងមុនពេលចេញ ទៅធ្វើការ ឬទៅរៀន៥នាទី ឬអាចចាប់ផ្តើមជាមួយការសមាធិត្រឹម ២ ទៅ ៣នាទីក្នុងពេលម្តងៗសិន តែត្រូវប្រាកដផងថាអ្នកបានរៀបចំខ្លួនទាំងកាយ និងចិត្តឲ្យបានរួចរាល់ និងមានពេលគ្រប់គ្រាន់មុនពេលសមាធិ។

### ១០.៤.៤. ខ្លឹមសារសមាធិ និងបស្សនា

សមាធិមានពីរយ៉ាងគឺ សកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន

សមថកម្មដ្ឋាន គឺជាការគ្រៀកចិត្ត ឬចងចិត្តឲ្យជាប់ក្នុងអារម្មណ៍តែមួយមិនបណ្តោយឲ្យចិត្តត្រាច់ចរទៅរកអារម្មណ៍ផ្សេងៗ។

សមថសមាធិមាន៣កំរិតតាមកម្លាំងនៃការប្រតិបត្តិៈ

**១ - ខណិកសមាធិ** គឺសមាធិដែលចិត្តមានអារម្មណ៍តែមួយ ឬចិត្តស្ងប់កើតឡើងមួយជួរខណៈ តែមិនបានយូរប៉ុន្មានក៏រលត់ទៅ។

**២ - ឧបចារសមាធិ** គឺសមាធិដែលចិត្តស្ងប់រំងាប់ប្រាសចាកនិវរណៈទាំង៥តែមិនជាអារម្មណ៍របស់អង្គឈានមានបឋមជ្ឈានជាដើមនោះទេ ប៉ុន្តែអារម្មណ៍របស់ឧបចារសមាធិនេះគឺជាអារ ម្មណ៍សមាធិដែលចិត្តស្ថិតក្នុងសភាពជិតបានឈានសមាបត្តិហ្នឹងឯង។

**៣ - អប្បនាសមាធិ** គឺសមាធិចិត្តដែលគង់ស៊ុបក្នុងអារម្មណ៍នៃឈានសមាបត្តិមានរូបជ្ឈានជាដើមដែលចិត្តខណៈនោះកំពុងសោយអារម្មណ៍ដែលជាអង្គនៃឈានមាន វិតក្ក វិចារ បីតិ សុខ ចិត្តឯកគតារួមជាអង្គ៥។ ចុះអ្វីទៅជាអារម្មណ៍របស់សមថសមាធិ? ពាក្យថាសមាធិប្រែថាចិត្តស្ងប់នេះមិនមែនសុទ្ធតែត្រឹមត្រូវជាសម្មាសមាធិទាំងអស់ទេ ឯមិច្ឆាសមាធិគឺសមាធិខុសចាកគន្លងធម៌ ឬសមាធិចិត្តដែលប្រកាន់ខ្ជាប់នូវវិបស្សនូបក្កិលេសថាជាលោកុត្តរៈមានមគ្គផលនិព្វានហើយលះបង់ការប្រតិបត្តិចម្រើនភាវនាចោលព្រោះហេតុដូច្នេះសមាធិចិត្តជាសម្មាសមាធិទៅបានកេចិអាចារ្យឬអដ្ឋកថាចារ្យទាំងឡាយពោលថាត្រូវផ្តោតចិត្តទៅលើអារម្មណ៍ណាមួយនៃអារម្មណ៍កម្មដ្ឋានទាំង៤០យ៉ាងតាមអធ្យាស្រ័យឬចរិតរៀងៗខ្លួននៃបុគ្គលម្នាក់ៗ។

សមាធិ ៣

តយោ សមាធី សមាធិ ៣ យ៉ាង គឺៈ

១. សវិតក្កវិចារោ សមាធិ សមាធិប្រកបដោយវិតក្ក វិចារ បានដល់ បឋមជ្ឈាន។

២. អវិតក្កវិចារមត្តោ សមាធិ សមាធិមិនមានវិតក្កមានត្រឹមតែវិចារបានដល់ទុតិយជ្ឈាន។

៣. អវិតក្កោ អវិចារោ សមាធិ សមាធិមិនមានវិតក្ក មានត្រឹមតែវិចារ បានដល់តតិយ ជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈាន[46]។

**១.៤ អធិប្បាយ**

គប្បីជ្រាបវិនិច្ឆ័យក្នុង**សមាធិ** តទៅះ

សមាធិ ក្នុងបឋមជ្ឈាន មានទាំងវិតក្ក ទាំងវិចារ ។ដោយបញ្ចកន័យ សមាធិក្នុងទុតិយជ្ឈាន មិនមានវិតក្ក មានតែវិចារ ។ សមាធិដ៏សេស ( អំពីសមាធិក្នុងទុតិយជ្ឈាន ) មិនមានទាំងវិតក្ក ទាំងវិចារ ។

**១៧ អានាបាណស្សតិ. ឬ អានាបាណស្សតិកម្មដ្ឋាន**

(–ប៉ាណ័សសៈ–) កម្មដ្ឋានមានវិធីតាំងស្មារតីរាប់ខ្យល់ដង្ហើមចេញចូលជាអារម្មណ៍ (ហៅកាត់ខ្លីត្រឹមតែ អានាបា ក៏បានដែរ ។(រៀនអានាបា :

**១៨ វិធីសាស្រ្តដំបូងនៃការធ្វើសមាធិ ឬអានាបាណស្សតិ កម្មដ្ឋាន.**

**សមាធិភាវនា ការធ្វើសមាធិឲ្យដុះដាលឡើង មាន ៤ យ៉ាង គឺះ**

១. **អត្ថាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា ទិដ្ឋធម្មសុខវិហារាយ សំវត្តតិ** ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនាដែលបុគ្គលចម្រើន ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន

២. **អត្ថាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា ញាណទស្សនប្បដិលាភាយ សំវត្តតិ** ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈបានដល់មគ្គញ្ញាណ ផលញ្ញាណ សព្វញ្ញុតញ្ញាណ បច្ចវេក្ខ ណញ្ញាណ និងវិបស្សនាញាណ។

៣. **អត្ថាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា សតិសម្បជញ្ញាយ សំវត្តតិ** ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីសតិ និងសម្បជញ្ញៈ

៤. **អត្ថាវុសោ សមាធិភាវនា ភាវិតា ពហុលីកតា អាសវានំ ខយាយ សំវត្តតិ** ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ។

ម្នាល អាវុសោទាំងឡាយ ចុះសមាធិភាវនា ដូចម្តេច ដែលបុគ្គលចម្រើនហើយធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីជាសុខក្នុងបច្ចុប្បន្ន។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងលាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ។ បានដល់នូវចតុត្ថជ្ឈាន ម្នាលអាវុសោទាំងឡាយ នេះជាសមាធិភាវនាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន។

ម្នាលអាវុសោទាំងឡាយចុះសមាធិភាវនាដូចម្តេចដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា សេចក្តីសម្គាល់ក្នុងពន្លឺ អធិដ្ឋាននូវទិវាសញ្ញា សេចក្តីសម្គាល់ថាថ្ងៃ ថា ថ្ងៃយ៉ាងណា យប់យ៉ាងនោះ

[46] សុត្តន្តបិដកលេខ ភាគ ១៩ ទំព័រ ១៤៣

យប់យ៉ាងណា ថ្ងៃយ៉ាងនោះ មានចិត្តបើកចេញស្រឡះ ឥតមានអ្វីរួបរឹតបិទបាំង ចម្រើនចិត្តដែលប្រកបដោយពន្លឺ ម្នាលអាវុសោទាំងឡាយ នេះជាសមា ធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ។

ម្នាល អាវុសោទាំងឡាយ ចុះសមាធិភាវនាដូចម្ដេច? ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីសតិ និងសម្បជញ្ញៈ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ វេទនាកើតឡើងក៏ដឹង តាំងនៅក៏ដឹង អស់ទៅក៏ដឹង សញ្ញាកើតឡើងក៏ដឹង តាំងនៅក៏ដឹង អស់ទៅក៏ដឹង វិតក្កកើតឡើងក៏ដឹង តាំងនៅក៏ដឹង អស់ទៅក៏ដឹង ម្នាលអាវុសោទាំងឡាយ នេះជាសមា ធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយតែងប្រព្រឹត្តទៅ ដើម្បីសតិនិងសម្បជញ្ញៈ។

ម្នាល អាវុសោទាំងឡាយ ចុះសមាធិភាវនាដូចម្ដេច ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណារឿយៗ នូវសេចក្ដីកើតឡើង និងសូន្យទៅក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ ការរលត់ទៅនៃរូបដូច្នេះ។ វេទនាដូច្នេះ។ សញ្ញាដូច្នេះ។ សង្ខារដូច្នេះ។ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ ការរលត់ទៅនៃវិញ្ញាណដូច្នេះ ម្នាលអាវុសោទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ[47]។

១.៩ អធិប្បាយ

ពាក្យថា ទិដ្ឋធម្មសុខវិហារាយ សេចក្ដីថា ដើម្បីប្រយោជន៍ដល់ការនៅជាសុខក្នុងអត្តភាពនេះ។ ផលសមាបត្តិ ឈាន ព្រមទាំងឈានដែលព្រះខីណាស្រពឲ្យកើតឡើងហើយ ក្នុងវេលាតមក លោកពោលទុកក្នុងទីនេះ។ ពាក្យថា អាលោកសញ្ញំ មនសិករោតិ (ធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា) សេចក្ដីថា ធ្វើទុកក្នុងចិត្តនូវពន្លឺមានពន្លឺនៃព្រះអាទិត្យ ព្រះចន្ទ និងកែវមណីជាដើម ទាំងវេលាថ្ងៃ ទាំងវេលាយប់ថា អាលោកោ (ពន្លឺ) ដូច្នេះ។ ពាក្យថា ទិវាសញ្ញំ អធិដ្ឋាតិ ( អធិដ្ឋាននូវទិវាសញ្ញា ) សេចក្ដីថា កាលធ្វើទុកក្នុងចិត្តយ៉ាងនេះហើយ ក៏តាំងសញ្ញាទុកថា វេលាថ្ងៃ ដូច្នេះ។ ពាក្យថា យថា ទិវា តថា រត្តឹ ( ថ្ងៃយ៉ាងណា យប់យ៉ាងនោះ ) សេចក្ដីថា ឃើញពន្លឺក្នុងវេលាថ្ងៃយ៉ាងណា ក្នុងវេលាយប់ក៏គប្បីធ្វើទុកក្នុងចិត្តដូចគ្នាយ៉ាងនោះ។ ពាក្យថា យថា រត្តឹ តថា ទិវា (យប់យ៉ាងណា ថ្ងៃយ៉ាងនោះ) សេចក្ដីថា ឃើញពន្លឺក្នុងវេលាយប់យ៉ាងណា ក្នុងវេលាថ្ងៃក៏គប្បីធ្វើទុកក្នុងចិត្តយ៉ាងនោះដូចគ្នា។ ពាក្យថា ឥតិ វិវដេន ចេតសា ( មានចិត្តបើកចេញស្រឡះ ) សេចក្ដីថា មានចិត្តដែលបើកហើយយ៉ាងនេះ។ ពាក្យថា អបរិយោនទ្ធេន (ឥតមានអ្វីរួបរឹតបិទបាំង) សេចក្ដីថា មិនត្រូវរួបរឹតដោយជុំវិញ។ ពាក្យថា សប្បភាសំ (ចម្រើនចិត្តដែលប្រកបដោយពន្លឺ) សេចក្ដីថា ប្រព្រឹត្តទៅជាមួយនឹងពន្លឺ។ ពាក្យថា ញាណទស្សនប្បដិលាភាយ (ដើម្បីបាននូវញាណទស្សនៈ) សេចក្ដីថា ដើម្បីប្រយោជន៍ដល់ការបាននូវញាណទស្សនៈ។ លោកពោលអ្វីទុកដោយពាក្យនេះ។ លោកពោលដល់ពន្លឺដែលជាគ្រឿងបន្ទោបង់ថីនមិទ្ធៈ ឬពន្លឺក្នុងការបរិកម្ម។ សូម្បីដោយពាក្យនេះជាការដែលលោកពោលដល់អ្វី? ជាការដែលលោកពោលដល់ទិព្វចក្ខុញាណ របស់ព្រះខីណាស្រព។ កាលទិព្វចក្ខុញាណនោះ មកហើយក៏ដោយ នៅមិនទាន់

[47] សុត្តន្តបិដក ភាគ ១៩ ព.ស ២៥០៣ ទំព័រ ១៤៩-១៥១

មកក៏ដោយ លោកពោលសំដៅដល់សមាបត្តិដែលមានឈានជាបាទនុ៎ះឯង ទើបពោលពាក្យថា សប្បភាសំ ចិត្តំ ភាវេតិ (ចម្រើនចិត្តដែលប្រកបដោយពន្លឺ)។

ពាក្យថា សតិសម្បជញ្ញាយ (ដើម្បីសតិ និងសម្បជញ្ញៈ) សេចក្ដីថា ដើម្បីប្រយោជន៍ដល់សតិ និងសម្បជញ្ញៈដែលមានសត្វជាទីតាំង។ ក្នុងពាក្យថា វិទិតា វេទនា ឧប្បជ្ជន្តិ (វេទនាដែលកើតឡើងក៏ដឹង) ជាដើម សេចក្ដីថា វត្ថុដែលព្រះខីណាស្រពដឹងហើយ អារម្មណ៍ក៏ជាការដឹងហើយ វេទនាទាំងឡាយរមែងកើតឡើងយ៉ាងនេះ រមែងតាំងនៅយ៉ាងនេះ រមែងរលត់ទៅយ៉ាងនេះ ព្រោះដឹងទាំងវត្ថុ ទាំងអារម្មណ៍។ មិនចំពោះតែវេទនាតែម្យ៉ាងប៉ុណ្ណោះទេ លោកពោលទុកក្នុងទីនេះ សូម្បីសញ្ញាជាដើមក៏ជាការដែលដឹងច្បាស់ហើយ រមែងកើតឡើងរមែងតាំងនៅរមែងរលត់ទៅ។ម្យ៉ាងទៀតការកើតឡើងនៃវេទនាក៏ជាការដែលលោកដឹងហើយ ការតាំងនៅក៏ជាការដែលលោកដឹងហើយ។ ភិក្ខុសូម្បីឃើញលក្ខណៈនៃការកើតឡើងថា ព្រោះអវិជ្ជាកើត វេទនាទើបកើត ព្រោះតណ្ហាកើត ព្រោះកម្មកើត ព្រោះផស្សៈកើត ទើបកើតវេទនា ឈ្មោះថា រមែងឃើញការកើតឡើងនៃវេទនាខន្ធ។ ការកើតឡើងនៃវេទនា រមែងជាការដែលលោកដឹងហើយយ៉ាងនេះ។ លោកដឹងនូវការតាំងនៅនៃវេទនាយ៉ាងដូចម្ដេច។ កាលលោកមនសិការដោយភាពជារបស់មិនទៀង ក៏រមែងជាការដែលលោកដឹងដល់ការតាំងនៅដោយការអស់ទៅ។ កាលមនសិការដោយភាពជាទុក្ខ រមែងជាការដែលលោកដឹងដល់ការតាំងនៅដោយភាពជារបស់គួរខ្លាច។ កាលមនសិការដោយភាពជាអនត្តា ក៏រមែងដឹងដល់ការតាំងនៅដោយភាពជារបស់សូន្យ។ការតាំងនៅនៃវេទនាជាការដែលលោកដឹងហើយយ៉ាងនេះ។ លោករមែងដឹងដោយភាពជារបស់អស់ទៅ ដោយភាពជារបស់គួរខ្លាច ដោយភាពជារបស់សូន្យ។ ការតាំងនៅមិនបាននៃវេទនា ជាការដែលលោកដឹងហើយដូចម្ដេច? ការតាំងនៅមិនបាននៃវេទនា រមែងមានយ៉ាងនេះគឺ ព្រោះអវិជ្ជារលត់ វេទនាទើបរលត់។ល។ ដូច្នេះ ក្នុងពាក្យនេះ បណ្ឌិតគប្បីជ្រាបសេចក្ដីតាមន័យដូចគ្នានេះ។

ពាក្យថារូបំជាដើម មានន័យដូចពោលមកហើយនោះឯង ដោយប្រការដូច្នេះ។ ពាក្យថា អយំ អាវុសោ សមាធិភាវនា ( ម្នាលអាវុសោទាំងឡាយ នេះជាសមាធិភាវនា ) សេចក្ដីថា សមាធិភាវនាដែលមានឈានជាបាទនេះ រមែងមានដល់ញាណជាគ្រឿងដឹងដល់ការអស់ទៅនៃអាសវៈ។

កម្មដ្ឋាន

ពាក្យថា កម្មដ្ឋាន មានន័យថា អារម្មណ៍ដែលគួរចំរើនឲ្យកើតសតិសម្បជញ្ញៈ និងគុណវិសេសផ្សេងៗ មានសមាធិជាដើមលោកហៅថា កម្មដ្ឋាន។ បានសេចក្ដីថាហេតុជាទីតាំងនៃភាវនាកម្ម គឺជាអារម្មណ៍សម្រាប់បរិកម្មភាវនា ម្យ៉ាងទៀតថា ហេតុជា ទីតាំងនៃអំពើព្យាយាមដើម្បីនឹងចំរើនសមាធិភាវនា ហៅថា កម្មដ្ឋាន។ កម្មដ្ឋានមាន២យ៉ាងគឺៈ សមថកម្មដ្ឋាន១ វិបស្សនាកម្មដ្ឋាន១។ សមថកម្មដ្ឋាន ជាឧបាយសម្រាប់ទូន្មានចិត្តឲ្យស្ងប់ចាកកិលេស មានកាមច្ឆន្ទៈជាដើម ឯវិបស្សនាកម្ម ដ្ឋានជាឧបាយសម្រាប់ធ្វើបញ្ញាឲ្យត្រចះឡើង ដើម្បីលះបង់នូវកិលេសមានឧបាទាន គឺសេចក្ដីប្រកាន់ក្នុងខន្ធជាដើម។ យោគាវចរជាអ្នកព្យាយាមដំបូង គប្បីសិក្សាប្រតិបត្តិក្នុងសមថកម្មដ្ឋានជាមុនសិន ទើបគួរប្រតិបត្តិក្នុងវិបស្សនាកម្មដ្ឋានជាខាងក្រោយ។

កម្មដ្ឋានទាំងអស់មាន៤០

គឺៈកសិណ១០ អសុភ១០ អនុស្សតិ១០ ព្រហ្មវិហារ៤ អារុប្បជ្ឈាន៤ អាហារេបដិកូលសញ្ញា១ និងចតុធាតុវវដ្ឋាន១។

អនុស្សតិ១០មានដូចតទៅនេះៈ

១ - ពុទ្ធានុស្សតិ រលឹករឿយៗនូវគុណព្រះពុទ្ធជាអារម្មណ៍។

២ - ធម្មានុស្សតិ រលឹករឿយៗនូវគុណព្រះធម៌ជាអារម្មណ។

៣ - សង្ឃានុស្សតិ រលឹករឿយៗនូវគុណព្រះសង្ឃជាអារម្មណ៍។

៤ - សីលានុស្សតិ រលឹករឿយៗនូវសីលជាអារម្មណ។

៥ -ចាគានុស្សតិ រលឹករឿយៗនូវចាគគុណជាអារម្មណ៍។

៦ - ទេវានុស្សតិ រលឹករឿយៗនូវសទ្ធាទិគុណរបស់ទេវតាជាអារម្មណ៍។

៧ - មរណានុស្សតិ រលឹករឿយៗនូវសេចក្តីស្លាប់ជាអារម្មណ៍។

៨ - កាយគតាសតិ រលឹករឿយៗតាំងចុះក្នុងកាយមានអាការៈ៣២ជាអារម្មណ៍។

៩ - អានាបានស្សតិ រលឹករឿយៗនូវអស្សាសបស្សាសជាអារម្មណ៍។

១០ - ឧបសមានុស្សតិ រលឹករឿយៗនូវគុណរបស់ព្រះនិព្វានជាអារម្មណ៍ ។

២.២ កាយគតាសតិៈអាការៈ៣

យោគាវចរ ជាអ្នកព្យាយាមចម្រើនកាយគតាសតិ គប្បីទន្ទេញឲ្យចាំរត់មាត់នូវ អាការៈ៣២ដូចតទៅៈ

ជាអនុលោម (រាប់បណ្តោយ) សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ខួរក្នុងក្បាល ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹក ភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ។

ជាបដិលោម (រាប់បញ្ច្រាស) ទឹកមូត្រ ទឹករំអិល ទឹកសំបោរ ទឹកមាត់ ខ្លាញ់ រាវ ទឹកភ្នែក ខ្លាញ់ខាប់ ញើស ឈាម ខ្ទុះ ស្លេស្ម ប្រមាត់ ខួរក្នុងក្បាល អាហារ ចាស់ អាហារថ្មី ពោះវៀនតូច ពោះវៀនធំ សួត ក្រពះ វាវ ថ្លើម បេះដូង តម្រង បស្សាវៈ ខួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់។

ចតុធាតុវវដ្ឋានៈធាតុ៤

កិរិយាកំណត់នូវលក្ខណៈរបស់ធាតុទាំង៤ ហៅថា ចតុធាតុវវដ្ឋានកម្មដ្ឋាន។

ធាតុទាំង៤នោះគឺ បឋវីធាតុ (ធាតុដី) អាបោធាតុ (ធាតុទឹក) តេជោធាតុ (ធាតុភ្លើង) និង វាយោធាតុ (ធាតុខ្យល់)។ ធាតុទាំង៤នោះ បើសម្តែងឲ្យពិស្តា មានអាការៈ៤២យ៉ាងគឺៈ បឋវីធាតុមានអា ការៈ២០ អាបោធាតុមានអាការៈ១២, តេជាធាតុមានអាការៈ៤ និងវាយោធាតុមានអា ការៈ៦។

បឋវីធាតុ២០អាការៈគឺៈ

កេសា សក់១ លោមា រោម១ នខា ក្រចក១ ទន្តា ធ្មេញ១ តចោ ស្បែក១ មំ សំ សាច់១ នហារូ សរសៃ១ អដ្ឋិ ឆ្អឹង១ អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង១ វក្កំ តម្រងបស្សាវៈ១ ហទយំ បេះដូង១ យកនំ ថ្លើម១ កិលោមកំ វាវ១ បិហកំ ក្រពះ១ បុប្ផាសំ សួត១ អន្តំ ពោះវៀនធំ១ អន្តគុណំ ពោះវៀនតូច១ ឧទរិយំ អាហារថ្មី១ ករីសំ អាហារចាស់១ មត្ថលុង្គំ ខួរក្នុងក្បាល១។

អាបោធាតុ១២គឺៈ

បិត្តំ ប្រមាត់១ សេម្ហំ ស្លេស្ម១ បុព្វោ ខ្ទុះ១ លោហិតំ ឈាម១ សេទោ ញើស១ មេទោ ខ្លាញ់ខាប់១ អស្សុ ទឹកភ្នែក១ វសា ខ្លាញ់រាវ១ ខេឡោ ទឹកមាត់១ សង្ឃាណិកា ទឹកសំបោរ១ លសិកា ទឹករំអិល១ មុត្តំ ទឹកមូត្រ១។

តេជោធាតុ៤គឺៈ

១ - សន្តប្បតិ ភ្លើងញ៉ាំងកាយឲ្យក្តៅសព្វ។

២ - ជរិយតិ ភ្លើងញ៉ាំងកាយឲ្យចាស់គ្រាំគ្រា។

៣ - បរិឌយ្ហតិ ភ្លើងញ៉ាំងកាយឲ្យក្តៅរោលរាលឈឺចាប់។

៤ - សម្មាបរិណាមំគច្ឆតិ ភ្លើងដែលញ៉ាំងអាហារឲ្យរលាយ។

វាយោធាតុ៦គឺៈ

១ - ឧទ្ធង្គមាវាតា ខ្យល់ដែលផាត់ឡើងទៅលើ។

២ - អធោគមាវាតា ខ្យល់ដែលផាត់ទៅខាងក្រោម។

៣ - កុច្ឆិសយាវាតា ខ្យល់ដែលផាត់នៅខាងក្រៅពោះវៀន។

៤ - កោដ្ឋាសយាវាតា ខ្យល់ដែលផាត់នៅខាងក្នុងពោះវៀន។

៥ - អង្គមង្គានុសារិនោវាតា ខ្យល់ដែលផាត់ផ្សាយទៅសព្វសព៌ាង្គកាយ។

៦ - អស្សាសបស្សាសាវាតា ខ្យល់ដែលដកដង្ហើមចេញ ចូល។

សេចក្តីគួរចងចាំៈ

យោគាវចរអ្នកធ្វើការព្យាយាម អាចជ្រើសរើសយកកម្មដ្ឋាននានា ក្នុងកម្មដ្ឋាន៤០ដែលបានរៀបរាប់មកខាងលើ តាមសេចក្តីប្រាថ្នា។ យោគាវចរអ្នកធ្វើការព្យាយាម គប្បីចំរើនរឿយៗ នូវអនាបនស្សតិ ព្រមទាំងកាយគតាសតិ (អាការៈ៣២) ជាការចាំ បាច់ ទោះបីជាព្យាយាមចំរើនកសិណក្តី អសុភក្តី អនុស្សតិក្តី អាហារបដិកូលសញ្ញាក្តី ឬក៏ចតុធាតុវវដ្ឋានក្តី។ ឯយោគាវចរអ្នកធ្វើការព្យាយាម ដែលកំពង់ចំរើនវិបស្សនាក្តី ក៏នៅតែត្រឡប់ធ្វើអនាបនស្សតិជារឿយៗដែរ ព្រោះអនាបនស្សតិកម្មដ្ឋានជាវិធីប្រសើរ ជាងគេក្នុងការធ្វើអារម្មណ៍ឲ្យស្ងប់ល្អ។ កម្មដ្ឋាន៤០សម្រាប់ចំរើនឈាន ឲ្យបានសម្រេចឈានចាប់តាំងពីបឋមជ្ឈាន រហូតដល់បញ្ចមជ្ឈាន ផលនៃការសម្រេចឈានអំពីកម្មដ្ឋាន៤០ ជាលោកិយ គឺថា សម្រេចនូវស្ថានសួគ៌ ស្ថានព្រហ្ម។ ដើម្បីសម្រេចនូវព្រះនិព្វានយោគាវចរអ្នកធ្វើការ ព្យាយាម ត្រូវតែចំរើននូវវិបស្សនាកម្ម។ វិបស្សនា មិនមែនកម្មដ្ឋាន៤០ខាងលើនេះទេ ប៉ុន្តែយោគាវចរគប្បីធ្វើព្យាយាមឲ្យបានហោចណាស់ក៏ត្រឹមបឋមជ្ឈានសិនដែរ ទើប ចូលទៅកាន់វិបស្សនាជាក្រោយ។ ការចំរើនអំពីវាយោធាតុ ពិនិត្យមើលការដឹងល្ហើយៗលើកាយ និងក្នុងកាយតាម វាយោធាតុ ដែលសញ្ចរត់ឡើង-ចុះ នេះជាការចំរើនចតុធាតុវវដ្ឋាន ក្នុងកម្មដ្ឋាន៤០ មិនមែនជា វិបស្សនាឡើយ។ វិបស្សនា គឺ វិសុទ្ធិ៧ ដែលនឹងអធិប្បាយពន្យល់ជាខាង ក្រោយទៀត។

ការដឹងគ្រប់គ្រាន់នៃវិធីដកដង្ហើម១៦យ៉ាង

ថ្ងៃពេញបូណ៌មីខែកត្តិកចូលមកដល់ ផ្កាកុមុតឬផ្កាឈូកសរីកៈរហង់ គ្រប់ទីកន្លែង។ ដោយផ្កាកុមុតតែងចាប់រីកជារៀងរាល់ឆ្នាំ ចំថ្ងៃពេញបូណ៌មីខែកត្តិកដូច្នោះហើយ បានជាគេហៅថា ថ្ងៃកុមុត។ នៅពេលល្ងាចថ្ងៃកុមុតនោះ នៅវត្តបុព្វារាម មានសាវ័ក៣ពាន់រូបគង់ចាំស្តាប់ ព្រះដ៏មានព្រះភាគបង្រៀនអំពី វិធីដកដង្ហើម យ៉ាងស្ងៀមស្ងាត់ ក្រោមពន្លឺព្រះចន្ទថ្លាទៀបមាត់បឹងមួយ ដែលមានផ្កាឈូករីកស្គុះស្គាយ និងចោលសុគន្ធពិដោរក្រអូបឈ្ងុយឈ្ងប់។ នេះជាលើកទីមួយហើយ ដែលព្រះពុទ្ធទ្រង់សំដែងយ៉ាងក្បោះក្បាយបំផុតនូវសូត្រមួយស្តីអំពីការដឹងគ្រប់ គ្រាន់នៃការដកដង្ហើម ទៅកាន់ភិក្ខុ ភិក្ខុនី ដែលជាសាវ័ករបស់ព្រះអង្គ។ ភិក្ខុនីមួយចំនួន ដូចជា ភិក្ខុនីយសោធរា ភិក្ខុនីរូបនន្ទា ភិក្ខុនីសីលា ភិក្ខុនីវិមល ភិក្ខុនីសោមា ភិក្ខុនីមុត្តា ភិក្ខុនីឧត្តរា

ក៏មានវត្តមានក្នុងទីនោះដែរ។

ព្រះពុទ្ធទ្រង់សំដែងសូត្រនោះថា ម្នាលភិក្ខុ ភិក្ខុនីទាំងឡាយ វិធីនៃការដកដង្ហើម បើយើងខំប្រឹងសិក្សាឲ្យបានហ្មត់ចត់និងខ្ជាប់ខ្ជួន នឹងអាចនាំមកនូវលទ្ធផលល្អ និងសារប្រយោជន៍សំខាន់បំផុត វានាំឲ្យទទួលជោគជ័យនៅក្នុងការសិក្សា នូវសតិប្បដ្ឋាន៤និងពោជ្ឈង្គ៧ ដែលបណ្តាលឲ្យមានការយល់ដឹង និងរួចចាកអំពីទុក្ខ។

បុគ្គលម្នាក់ៗត្រូវតែអនុវត្ត ការដកដង្ហើមដូចតទៅនេះ ៖

ដង្ហើមទី១- ដកដង្ហើមចូលវែង អ្នកដឹងថា អ្នកកំពុងដកដង្ហើមចូលវែង ដកដង្ហើមចេញវែងអ្នកដឹង ថាអ្នកកំពុងដកដង្ហើមចេញវែង។

ដង្ហើមទី២- ដកដង្ហើមចូលខ្លី អ្នកដឹងថា អ្នកកំពុងដកដង្ហើមចូលខ្លី ដកដង្ហើមចេញខ្លីអ្នក ដឹងថាអ្នកកំពុងដកដង្ហើមចេញខ្លី។ ការដកដង្ហើមទាំងពីរបែបខាងលើនេះ អាចឲ្យអ្នកកាត់ផ្តាច់នូវការភ្លេចភ្លាំង និងសេចក្តីកង្វល់ឥតប្រយោជន៍។ ជាមួយគ្នានេះដែរ អាចបណ្តាលឲ្យអ្នកមានការគិតគូរត្រឹមត្រូវ និងជួបប្រទះនូវជីវិតបច្ចុប្បន្ន។ ការភ្លេចភ្លាំងគឺការបាត់បង់គំនិតត្រឹមត្រូវ ការ ដកដង្ហើមដោយការយល់ដឹង អាចនាំឲ្យយើងត្រឡប់មកគិតអំពីជីវិតវិញ ។

ដង្ហើមទី៣. ដកដង្ហើមចូលគឺអ្នកដឹងនូវរូបកាយទាំងមូលរបស់អ្នក ដកដង្ហើមចេញ អ្នកដឹងនូវរូបកាយទាំងមូលរបស់អ្នក។ដង្ហើមនេះ អាចឲ្យអ្នកចំរើនភាវនាលើរូបកាយ និងទាក់ទងផ្ទាល់ជា មួយនឹងរូបកាយរបស់អ្នក។ ការដឹងអំពីរូបកាយទាំងមូល និងអំពីផ្នែកនិមួយៗនៃរូបកាយ អាចធ្វើឲ្យអ្នកមើលឃើញនូវវត្តមានដ៏អស្ចារ្យ នៃរូបកាយរបស់អ្នក និងដំណើរនៃការកើតនិងស្លាប់ ដែលមិនឱបជាប់នៅក្នុងរូបកាយរបស់អ្នកផង។

ដង្ហើមទី៤. អ្នកកំពុងដកដង្ហើមចូល ហើយធ្វើឲ្យខ្លួនអ្នកទាំងមូលនៅហ្នឹងហ្ន និងសុខស្រួល។ អ្នកកំពុងដកដង្ហើមចេញ ហើយធ្វើឲ្យខ្លួនអ្នកទាំងមូលនៅហ្នឹងហ្ននិងសុខស្រួល។ ដង្ហើមទី៤នេះ អាចជួយអ្នកឲ្យយល់ដឹងនូវសភាពហ្នឹងហ្ននិងសុខស្រួលនៃកាយ គឺពេលនេះហើយដែលកាយនិងចិត្ត និងដង្ហើមស្រុះស្រួលគ្នាជាធ្លុងមួយ។

ដង្ហើមទី៥. អ្នកកំពុងដកដង្ហើមចូល នឹងមានអារម្មណ៍រីករាយ អ្នកកំពុងដកដង្ហើមចេញ នឹងមានអារម្មណ៍រីករាយ។

ដង្ហើមទី៦. អ្នកកំពុងដកដង្ហើមចូល នឹងមានអារម្មណ៍សប្បាយ អ្នកកំពុងដកដង្ហើមចេញ នឹងមានអារម្មណ៍សប្បាយ។ ជាមួយនឹងដង្ហើមទាំងពីរនេះ អ្នកអាចឆ្លងកាត់វិស័យនៃអារម្មណ៍។ ដង្ហើមទាំងពីរនេះបង្កើតឲ្យមានសភាពស្ងប់ស្ងៀម និងរីករាយ ដែលអាចចិញ្ចឹមទុកក្នុងកាយនិងចិត្ត ដោយសារការបញ្ឈប់នូវគំនិតរប៉ាត់រប៉ាយ និងភ្លេចភ្លាំង ហើយអ្នកនឹងដឹងខ្លួនឯងវិញ នាពេលបច្ចុប្បន្ននេះ។ សុភមង្គលនិងសេចក្តីរីករាយ ក៏កើតឡើងនៅក្នុងខ្លួនរបស់អ្នក អ្នករស់នៅក្នុងសភាពអស្ចារ្យនៃជីវិត ដែលអាចក្រេបរស់ជាតិនៃសេចក្តីស្ងប់ស្ងាត់ និងរីករាយ ដែលកើតមាននៅក្នុងអារម្មណ៍។ តាមការជួបប្រទះក្នុងជីវិតដ៏អស្ចារ្យនេះហើយទើបអ្នកដូរអារម្មណ៍ បណ្តាលឲ្យទៅជាអារម្មណ៍រីករាយបាន។ ដូច្នេះអារម្មណ៍ទាំងពីរនេះ ពិតជាធ្វើឲ្យអ្នកសប្បាយរីករាយ។

ដង្ហើមទី៧. អ្នកកំពុងដកដង្ហើមចូល អ្នកដឹងនូវសកម្មភាពនៃគំនិត ឬអារម្មណ៍ទាំងឡាយនៅក្នុងខ្លួនរបស់អ្នកអ្នកកំពុងដកដង្ហើមចេញ អ្នកដឹងនូវសកម្មភាពនៃគំនិត ឬអារម្មណ៍ទាំងឡាយនៅក្នុងខ្លួនរបស់អ្នក។

ដង្ហើមទី៨. អ្នកកំពុងដកដង្ហើមចូល អ្នកធ្វើឲ្យសកម្មភាពនៃគំនិតនិងអារម្មណ៍ទាំងឡាយ ក្នុងខ្លួនរបស់អ្នកស្ងប់និងសុខស្រួល អ្នកកំពុងដកដង្ហើមចេញ អ្នកធ្វើឲ្យសកម្មភាពនៃគំនិតនិងអារម្មណ៍ ទាំងឡាយក្នុងខ្លួនរបស់អ្នកស្ងប់និងសុខស្រួល។ជាមួយនឹងដង្ហើមទាំងពីរ អាចធ្វើឲ្យអ្នកមើលឃើញវែងឆ្ងាយនូវអារម្មណ៍ទាំងឡាយ ដែលកើតឡើងនៅក្នុងខ្លួនរបស់អ្នក ទោះបីជាអារម្មណ៍ នោះសប្បាយក្តី មិនសប្បាយក្តី ឬនៅកណ្តាលធម្មតាក្តី និងអាចឲ្យអ្នកធ្វើនូវអារម្មណ៍ស្ងប់ និងសុខស្រួលបាន បើអ្នកដឹងអំពីអារម្មណ៍ផ្ទាល់ខ្លួនអ្នកហើយអាចមើលជ្រៅទៅដល់ឫសគល់និងធម្មជាតិរបស់វា អ្នកពិតជាអាចទប់ និងធ្វើឲ្យអារម្មណ៍ទាំងនោះស្ងប់និងសុខស្រួលបាន ទោះបីជាអារម្មណ៍នោះជាគំនិតអាក្រក់ កើតឡើងអំពីលោភៈ ទោសៈ មោហៈ ក៏ដោយ។

ដង្ហើមទី៩. អ្នកកំពុងដកដង្ហើមចូល អ្នកដឹងនូវទឹកចិត្តរបស់អ្នក អ្នកកំពុងដកដង្ហើមចេញ អ្នកដឹងនូវទឹកចិត្តរបស់អ្នក។

ដង្ហើមទី១០. អ្នកកំពុងដកដង្ហើមចូល នឹងធ្វើចិត្តរបស់អ្នកសប្បាយ និងសុខស្រួល អ្នកកំពុងដកដង្ហើមចេញ នឹងធ្វើឲ្យចិត្តរបស់អ្នកសប្បាយនិងសុខស្រួល។

ដង្ហើមទី១១. អ្នកកំពុងដកដង្ហើមចូល និងកំពុងផ្ចង់ចិត្តរបស់អ្នក អ្នកកំពុងដកដង្ហើមចេញ និងកំពុងផ្ចង់ចិត្តរបស់អ្នក។

ដង្ហើមទី១២. អ្នកកំពុងដកដង្ហើមចូល នឹងកំពុងដកចិត្តរបស់អ្នក អ្នកកំពុងដកដង្ហើមចេញនឹងកំពុងដកចិត្តរបស់អ្នក ។ជាមួយនឹងដង្ហើមទាំង៤នេះ អ្នកអាចឆ្លងកាត់វិស័យទី៣ដែលជាចិត្ត ។ដង្ហើមទី៩អាច នាំឲ្យអ្នកស្គាល់នូវសភាវៈទាំងអស់នៃចិត្តដូចជាសញ្ញាខន្ធ គឺការពិចារណា ការប្រកាន់ ការសប្បាយ ការកើតទុក្ខនិងការមន្ទិលសង្ស័យ។ អ្នកសង្កេតពិនិត្យនិងស្គាល់នូវសភាវៈទាំងនេះ ដើម្បីមើលឃើញជ្រៅ ទៅក្នុងសកម្មភាពនៃចិត្តឬអារម្មណ៍ ពេលសកម្មភាពនៃចិត្តឬអារម្មណ៍ ត្រូវបានសង្កេតពិនិត្យនិងទទួលស្គាល់រួចហើយ អ្នកអាចប្រមូលចិត្តរបស់អ្នក និងធ្វើចិត្តនោះ ឲ្យស្ងប់និងសុខស្រួលបាន។ ចិត្តនេះកើតឡើងដោយអារម្មណ៍ទី១០ និងទី១១។ ដង្ហើមទី១២ អាចធ្វើឲ្យអ្នករួចចាកផុតពីឧបសគ្គទាំងអស់នៃចិត្ត ដោយសារការភ្លឺស្វាងនៃចិត្តរបស់អ្នក ទើបអ្នកអាចមើលឃើញនូវឫសគល់នៃសង្ខារ វិញ្ញាណ និងអាចឈ្នះនូវឧបស័គ្គទាំងអស់បាន។

ដង្ហើមទី១៣ - អ្នកកំពុងដកដង្ហើមចូល អ្នកកំពុងពិនិត្យ នូវធម្មជាតិមិនទៀងទាត់ អនិច្ចំ នៃធម៌ទាំងអស់ ។ អ្នកកំពុងដកដង្ហើមចេញ នឹងកំពុងពិនិត្យនូវធម្មជាតិ មិនទៀងទាត់ នៃធម៌ទាំងអស់។

ដង្ហើមទី១៤ - អ្នកកំពុងដកដង្ហើមចូល នឹងកំពុងតែពិនិត្យនូវការវិនាស អនត្តា នៃធម៌ទាំងអស់ អ្នកកំពុងតែដកដង្ហើមចេញ នឹងកំពុងតែពិនិត្យនូវការវិនាស ឬសាបរលាបនៃធម៌ទាំងអស់។

ដង្ហើមទី១៥ - អ្នកកំពុងដកដង្ហើមចូល នឹងកំពុងចំរើនភាវនានូវវិមុត្តិ ការរំដោះទុក្ខ អ្នកកំពុងដកដង្ហើមចេញ នឹងកំពុងចំរើនភាវនានូវវិមុត្តិ។

ដង្ហើមទី១៦ - អ្នកកំពុងដកដង្ហើមចូល នឹងកំពុងចំរើនភាវនាឧបេក្ខា អ្នកកំពុងដកដង្ហើមចេញ នឹងកំពុងចំរើនភាវនានូវឧបេក្ខា ជាមួយនឹងដង្ហើមទាំង៤នេះ អ្នកអាចឆ្លងកាត់វិស័យនៃធម្មារម្មណ៍ នឹងសមាធិចិត្តដើម្បីពិនិត្យមើលនូវធម្មជាតិពិតនៃធម៌ទាំងអស់ ជាដំបូងគឺការសង្កេតពិនិត្យ ទៅលើធម្មជាតិមិនទៀងនៃធម៌ទាំងអស់ ព្រោះតែធម៌ទាំងអស់មិនទៀងទាត់ហើយ បានជាធម៌ ទាំងអស់នោះត្រូវតែវិនាសសាបសូន្យ។ នៅពេលដែលអ្នក បានយល់ច្បាស់នូវធម្មជាតិមិនទៀងទាត់ និងការវិនាសសាបសូន្យនៃធម៌ទាំងអស់ អ្នកពិតជាមិនប្រតោងជាប់ ដោយការវិល កើតវិលស្លាប់ នៅក្នុងវដ្តសង្សារ ពុំចេះចប់នោះឡើយ ដោយសារហេតុនេះ

ហើយ អ្នកអាចរួចខ្លួន និងសម្រេចនូវវិមុត្តិ ការផុតទុក្ខ ការរួចខ្លួនមិនមែនមានន័យថា គេចវេះឬរត់ចេញពីជីវិតនោះទេ រួចខ្លួនក្នុងទីនេះ មានន័យថា រួចខ្លួនអំពីចំណងតណ្ហានិងការវិលវល់ នៅក្នុងវដ្តសង្សារដែលមានធម៌ជាប្រធាន។ នៅពេលដែលអ្នកមានឧបេក្ខា និងសម្រេចនូវវិមុត្តិ អ្នកពិតជាអាច រស់នៅបានយ៉ាងសុខស្រួល និងសប្បាយរីករាយ នៅក្នុងជីវិតនេះ មិនមានអ្វីអាចនឹងចងអ្នកបានទៀតទេ។ នេះហើយជាការប្រៀនប្រដៅ របស់ព្រះសាស្តា ដូចម្តេចដែលហៅថាការពិនិត្យជ្រៅទៅក្នុង កាយចិត្តនិងធម្មារម្មណ៍តាមវិធីដកដង្ហើមទាំង១៦យ៉ាង។

ព្រះសមណគោតមបរមសាស្តា ទ្រង់បានដាក់វិធីដកដង្ហើមទាំង១៦នេះ ឲ្យអនុវត្តនៅក្នុងការហាត់រៀនពោជ្ឈង្គ៧ផងដែរ គឺ សតិ១ ធម្មវិជយៈ១ វិរិយៈ១ បីតិ១ បស្សធិ១ សមាធិ១ និង ឧបេក្ខា១។ ភិក្ខុនិងភិក្ខុនីទាំង៣ពាន់អង្គ បានស្តាប់ការប្រៀនប្រដៅរបស់ព្រះពុទ្ធ ដោយសេចក្តីរីករាយ និងកក់ក្តៅជាទីបំផុត នៅក្នុងរាត្រីពេញបូណ៌មី ខែកត្តិក ក្រោមពន្លឺព្រះចន្ទថ្លា។

ពុទ្ធានុស្សតិ កម្មដ្ឋាន

មុននឹងពោលនូវកម្មដ្ឋានដទៃ សូមពោលអំពីពុទ្ធានុស្សតិកម្មដ្ឋានមុនសិន កាលបើយោគាវចរកុលបុត្តមានប្រាថ្នា ដើម្បីចំរើននូវពុទ្ធានុស្សតិកម្មដ្ឋាន គប្បីឲ្យមានចិត្តជ្រះថ្លាក្នុងគុណរបស់ព្រះពុទ្ធ មិនឲ្យមានកំរើកហើយចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីឮកដល់គុណ របស់ព្រះពុទ្ធថា ៖

ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវា។ បន្ទាប់មកត្រូវស្រង់យក ព្រះពុទ្ធគុណមួយៗ មករំពឹងពិចារណាបន្តទៅទៀត រីឯគុណរបស់ព្រះពុទ្ធនោះ មានដល់ទៅ១០ព្រះនាមដូច្នេះគឺៈ

១- សោ ភគវា ឥតិបិ អរហំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថាអរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវគឺកិលេសទាំងពួងផង ព្រោះព្រះអង្គបំបាក់បង់នូវកាំ របស់សំសារចក្របានផងព្រោះព្រះអង្គមិនសម្ងំធ្វើបាបក្នុងទីស្ងាត់ផង។

២- សោ ភគវា ឥតិបិ សម្មាសម្ពុទ្ធោ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងដោយប្រពៃ ចំពោះព្រះអង្គឯង។

៣-សោ ភគវា ឥតិបិ វិជ្ជាចរណសម្បន្នោ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះ នាមថា វិជ្ជាចរណសម្បន្នោព្រោះព្រះអង្គបរិបូរដោយវិជ្ជានិងចរណៈ។

៤- សោ ភគវា ឥតិបិ សុគតោ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អផងព្រោះព្រះអង្គមានព្រះបន្ទូលពីរោះផង។

៥- សោ ភគវា ឥតិបិ លោកវិទូ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវលោក។

៦- សោភគវា ឥតិបិ អនុត្តរោ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរវិសេសរកបុគ្គលណាប្រសើរជាងគ្មាន។

៧- សោ ភគវា ឥតិបិ បុរិសទម្មសារថិ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាម ថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន។

៨- សោ ភគវា ឥតិបិ សត្ថាទេវមនុស្សានំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះ នាមថា សត្ថាទេវ

មនុស្សានំព្រោះព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ។

៩- សោ ភគវា ឥតិបិ ពុទ្ធោ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គជាអ្នកភ្ញាក់រលឹកផង ជាបុគ្គលរីកផង ជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង។

១០- សោ ភគវា ឥតិបិ ភគវា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា ភគវា ព្រោះ ព្រះអង្គមានព្រះភាគផង ព្រះអង្គជាអ្នកចែកផង ព្រះអង្គមានជោគផង ព្រះអង្គជាអ្នកបំបាក់បង់ផង ព្រះអង្គមានដំណើរទៅកាន់ត្រៃភព ខ្ជាក់ចោលហើយ ។

ក្នុងការពិចារណារលឹកគុណព្រះពុទ្ធ ត្រូវឲ្យដឹងសេចក្តីអធិប្បាយក្នុងគុណនោះៗ ឲ្យបានសព្វគ្រប់ផង ដោយអំណាចដែលយោគីនឹករលឹករឿយ ៗ នូវគុណនៃព្រះដ៏មានព្រះភាគ តាមន័យដែលពោលមកហើយនេះ សម័យនោះចិត្តរបស់ព្រះយោគីសោត ក៏ប្រាសចាកកិ លេសគឺ រាគៈ ទោសៈ មោហៈ តម្កល់នៅត្រង់ចំពោះទៅរកព្រះតថាគត ព្រមទាំងនីវរណធម៌ក៏ទ្រោមចុះផង លំដាប់នោះវិតក្កៈ និងវិចារៈ ក៏កើតឡើង ត្រិះរិះពិចារណារឿយៗ នូវពុទ្ធគុណមានអរហំជាដើម ហើយបីតិក៏កើតឡើងជាបទដ្ឋានយ៉ាងនេះ កាយបស្សទ្ធិ និងចិត្តបស្សទ្ធិ គឺសេចក្តីស្ងប់កាយ និងសេចក្តីស្ងប់ចិត្តក៏កើតឡើង បណ្តាលឲ្យព្រះ យោគីប្រាសចាកសេចក្តីក្រវល់ក្រវាយ ស្ងប់ម្ងាប់យ៉ាងនេះហើយ សុខៈប្រព្រឹត្តទៅក្នុងកាយនិងចិត្តក៏កើតឡើងទៀត ពេលនោះ ចិត្តរបស់ព្រះយោគីក៏តម្កល់មាំក្នុងពុទ្ធគុណ ជាអារម្មណ៍ អង្គឈានក៏កើតឡើងក្នុងខណៈជាមួយគ្នា តាមលំដាប់ដូច្នេះ តែក្នុងពុទ្ធានុស្សតិ កម្មដ្ឋាននេះមានអំណាចកើតឡើងត្រឹមតែ ឧបចារជ្ឈានប៉ុណ្ណោះ មិនអាចឲ្យកើតបានដល់ អប្បនាឈាន ឡើយ ព្រោះគុណរបស់ព្រះពុទ្ធជាគម្ពីរភាពក្រៃពេក ព្រះយោ គីមិនអាចរលឹកឲ្យសព្វគ្រប់ទៅបាន។ កម្មដ្ឋាននេះដល់នូវកិរិយារាប់ថា ពុទ្ធានុស្សតិដូច្នេះ ព្រោះកើតឡើងដោយអំណាចរលឹកនូវពុទ្ធគុណ។

ធម្មានុស្សតិ កម្មដ្ឋាន

កាលបើព្រះយោគាវចរកុលបុត្តមានប្រាថ្នា ដើម្បីចំរើននូវធម្មានុស្សតិកម្មដ្ឋាន គប្បីឲ្យមានចិត្តជ្រះថ្លាក្នុងគុណរបស់ព្រះធម៌ កុំឲ្យមានកំរើក ហើយចូលទៅរកទីស្ងាត់ ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរលឹកដល់គុណរបស់ព្រះបរិយត្តិធម៌ និងព្រះនព្វ លោកុត្តរធម៌ ចាប់ពី ស្វាក្ខាតោ ភគវតាធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិ បស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោវិញ្ញូហិ ជាទីបំផុត ។ បន្ទាប់មកត្រូវស្រង់យកគុណមួយ ៗ មករំពឹងពិចារណាឲ្យដឹងសេចក្តីច្បាស់ លាស់គ្រប់គុណនោះៗ។ រីឯធម្មគុណនោះមាន៦បទគឺ ៖

១- ស្វាក្ខាតោ ភគវតាធម្មោ ប្រែថាព្រះបរិយត្តិធម៌និងព្រះនព្វលោកុត្តរធម៌ គឺព្រះ ដ៏មានព្រះភាគទ្រង់សម្តែងទុកដ៏ពិរោះឬដោយប្រពៃ។

២- សន្ទិដ្ឋិកោ ប្រែថា ធម៌ដែលព្រះអរិយបុគ្គលឃើញច្បាស់ដោយខ្លួនឯង (បាន ដល់អរិយមគ្គ និងលោកុត្តរធម៌)។

៣- អកាលិកោ ប្រែថា ធម៌មិនមានកាលវេលា (កាលបើព្រះអរិយមគ្គកើតឡើង ហើយ ព្រះអរិយផលក៏កើតឡើងក្នុងលំដាប់គ្នាពុំឃឺតយូរឡើយ)។

៤- ឯហិបស្សិកោ ប្រែថា គួរដល់ឯហិបស្សវិធី ព្រះអរិយបុគ្គលដែលបានសម្រេច មគ្គនិងផលហើយ គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន។

៥-ឱបនយិកោប្រែថាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមក ទុកក្នុងខ្លួន ដោយអំណាចនៃភាវនា។

៦- បច្ចត្តំ វេទិតព្វោវិញ្ញូហិ ប្រែថា ធម៌គឺវិញ្ញូជនទាំងឡាយមានឧគ្ឃដិតញ្ញូជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន។ ដោយអំណាចដែលព្រះយោគី នឹករលឹករឿយៗ នូវគុណព្រះធម៌ តាមន័យ ដែលបានពោលមកនេះ គុណទាំងឡាយមានចិត្តដែលស្ងប់ចាកកិលេស គឺរាគៈ ទោសៈ មោហៈ រហូតដល់បានសម្រេចឧបចារជ្ឈាន កើតឡើងតាមលំដាប់មានសភាព ដូចក្នុងពុទ្ធានុស្សតិកម្មដ្ឋានដែរសូមព្រះយោគីគប្បីដឹងចុះ។ កម្មដ្ឋាននេះមានអនុភាពឲ្យសម្រេចដល់ត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាចនឹង ឲ្យបានដល់អបនាឈានឡើយ ព្រោះគុណរបស់ព្រះធម៌ ជាគម្ពីរភាពក្រៃពេក ព្រះយោ គីមិនអាចនឹងរលឹកឲ្យសព្វគ្រប់បាន។

សង្ឃានុស្សតិ កម្មដ្ឋាន

កាលបើព្រះយោគាវចរកុលបុត្តមានប្រាថ្នាដើម្បីចម្រើននូវ សង្ឃានុស្សតិកម្ម ដ្ឋាន គប្បីឲ្យមានចិត្តជ្រះថ្លាក្នុងគុណ របស់ព្រះសង្ឃកុំឲ្យកម្រើក ហើយចូលទៅរកទី ដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរលឹកដល់គុណរបស់ព្រះអរិយសង្ឃ ចាប់ពី សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយ បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលានិ ឯស ភគវតោ សាវកសង្ឃោ អាហុណេយ្យោ បាហុ ណេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ជាទីបំផុត ហើយត្រូវស្រង់យកគុណមួយៗ មករំពឹងពិចារណាឲ្យដឹងសេចក្តី ច្បាស់លាស់ គ្រប់គុណនោះៗ។ រីឯគុណព្រះសង្ឃមាន៩បទ គឺ ៖

១-សុបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថា ពួកសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយប្រពៃប្រតិបត្តិតាមគន្លងនៃព្រះនព្វលោកុត្តរធម៌។

២- ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថា ពួកសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ ប្រតិបត្តិជាមជ្ឈិមាបដិបទាតាមផ្លូវប្រកបដោយអង្គ៨ មាន សមាទិដ្ឋិជាដើម។

៣- ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថា ពួកសាវកនៃព្រះដ៏មានព្រះ ភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន(ជាស្ថានក្សេមចាកទុក្ខទាំងពួង)។

៤- សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ប្រែថា ពួកសាវកនៃព្រះដ៏មាន ព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម (ប្រតិបត្តិគួរដល់សីល សមាធិ និងបញ្ញា)។

យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា បានសេចក្តីថា ព្រះសង្ឃដែលរាប់ ជាគូនៃបុរសមាន៤ គឺលោកអ្នកដែលបានសម្រេចនូវ សោតាបដិមគ្គ និងសោតាបដិ ផលជាគូ១ សកិទាគាមិមគ្គ និងសកិទាគាមិផលជាគូ១ អនាគាមិមគ្គ និងអនាគាមិផល ជាគូ១ អរហត្តមគ្គនិងអរហត្តផលជាគូ១។ បើរាប់រៀងជាបុរសបុគ្គលមាន៨គឺ លោក ដែលបានសម្រេចនូវសោតាបដិមគ្គ១ សោតាបដិផល១ សកិទាគាមិមគ្គ១ សកិទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១និងអរហត្តផល១។

ឯស ភគវតោ សាវកសង្ឃោ បានសេចក្តីថា ព្រះសង្ឃដែលបានពណ៌នាមកទាំងអម្បាលនេះនុះជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ។

៥- អាហុណេយ្យោ ប្រែថា លោកគួរទទួលនូវបច្ច័យ៤ ដែលបុគ្គលនាំមកបូជា។

៦- បាហុនេយ្យោ ប្រែថា លោកគួរទទួលនូវអាគន្តុកទាន (ទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្រដែលមកអំពីទិសផ្សេងៗបង្អោនចូលមកបូជា)។

៧- ទក្ខិណេយ្យោ ប្រែថា លោកគួរទទួលនូវទក្ខិណាទាន (ទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម

បង្អោនមកបូជា)។

៨- អញ្ជលិករណីយោ ប្រែថា លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ។

៩-អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ប្រែថា លោកជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្ត ដទៃក្រៃលែងជាងគ្មាន

ដោយអំណាចដែលព្រះយោគី នឹករលឹករឿយៗ នូវគុណព្រះសង្ឃ តាមន័យ ដែលពោលមកនេះ គុណទាំងឡាយមានចិត្តដែលស្ងប់ចាកកិលេស គឺរាគៈ ទោសៈ មោហៈ រហូតដល់បានសម្រេចឧបចារជ្ឈាន កើតឡើងតាមលំដាប់មានសភាពដូចក្នុងពុទ្ធានុស្សតិកម្មដ្ឋានដែរ សូមព្រះយោគីគប្បីដឹងចុះ។ កម្មដ្ឋាននេះ មានអនុភាពឲ្យសម្រេចដល់ត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាចនឹង ឲ្យបានដល់អបនាឈានឡើយ ព្រោះ គុណរបស់ព្រះសង្ឃ ជាគម្ភីរភាពក្រៃពេក ព្រះយោគីមិនអាចនឹងរលឹកឲ្យសព្វគ្រប់បាន។

ព្រះអភិធម្ម - សម្មតិសច្ចៈ និង បរមត្ថសច្ចៈ

ក្នុងព្រះអភិធម្មសង្ខេប មានការពន្យល់ថា សច្ចៈ ឬសេចក្តីពិតមាន២គឺៈ

១- សម្មតិសច្ចៈ សម្មតិសច្ចៈ មានន័យថា សេចក្តីពិតដែលមនុស្សជាទូទៅសម្គាល់ ទៅតាមការ មើលឃើញ តាមរូបរាង ពណ៌សម្បុរខាងក្រៅ មិនគិតដល់វត្ថុជាតុខាងក្នុង ឬធម្មជាតិដើមឡើយ។ ផ្ទះរទេះ គោ ក្របី ពូម៉ៅ តាមួន ព្រះអាទិត្យ ព្រះចន្ទ ។ ល ។ ជាសម្មតិសច្ចៈ គឺរូបរាងដូច្នេះ ពណ៌ដូច្នេះ ទំហំយ៉ាងនេះ គេសម្គាល់ថាជារបស់នេះ ជា សត្វនេះ ជាមនុស្សនេះ។ ដើម្បីចំណាំវត្ថុ សត្វ មនុស្ស គេក៏ដាក់ឈ្មោះឲ្យដើម្បី ហៅ កុំឲ្យច្រឡូកច្រឡំគ្នា។ ការតែងតាំងនាមនេះហៅថាបញ្ញត្តិ។

២- បរមត្ថសច្ចៈបរមត្ថសច្ចៈ មានន័យថា សេចក្តីពិតតាមធម្មជាតិខាងក្នុង ដែលស្ថិតនៅក្នុង ភាព កំបាំង មិនអាចមើលឃើញដោយងាយ ជាសេចក្តីពិតដែលមិនផ្លាស់ប្តូរដូចជា បរមត្ថសច្ចៈរបស់ផ្ទះនិងរទេះ នៅតែជា ឈើ ដដែល គឺជាធម្មជាតិពិតៗ របស់វា មិនប្តូរ ទៅតាមសភាពខាងក្រៅឡើយ។

បញ្ញត្តិ និងបរមត្ថអ្វីទាំងឡាយទោះបីជាសម្មុតិក្តី ឬជាបរមត្ថក្តី តែងមានឈ្មោះសម្រាប់ហៅដែលហៅ ថា បញ្ញត្តិ នោះឯង។ ធម្មជាតិ ដែលបញ្ញត្តិ ធ្វើការតែងតាំងនាមទៅឲ្យ គឺ ៖

១- វត្ថុ គឺរបស់ផ្សេងៗ ដូចជា ផ្ទះ កុដិ វិហារ សាលា មេឃ ផ្កាយ ជាដើម។

២-សត្វ គឺអ្វីៗ ដែលមានជីវិតជាប់ជំពាក់ក្នុងបំណងដូចជា គោ ក្របី ជ្រូក ពូសុខ យាយសៅជាដើម។

៣- សង្ខារ មាន២គឺ ឧបាទិន្នកសង្ខារ១ និង អនុបាទិន្នកសង្ខារ១។ ឧបាទិន្នក សង្ខារ គឺសង្ខារដែល មានវិញ្ញាណគ្រប់គ្រង មានពាក្យថាបុគ្គល មនុស្ស ទេវតា ព្រហ្មជាដើម។ ឯអនុបាទិន្នកសង្ខារ គឺសង្ខារដែល គ្មានវិញ្ញាណគ្រប់គ្រង មានពាក្យថា ដើមដូង ដើមចេក ដើមត្នោត ឈូក ស្មៅជាដើម។ បរមត្ថធម៌ មានសេចក្តី ដ៏ល្អិតក្រៃលែង ដូចជា រូប នាម ខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ។ ដែលជាអារម្មណ៍ របស់វិបស្សនា។ បញ្ញត្តិធម៌ ដែលជាឈ្មោះ មិនមែន ជាអារម្មណ៍របស់វិបស្សនាទេ។

នាម និងរូបនាម ជាធម្មជាតិឱនទៅកាន់អារម្មណ៍ មានកិរិយាឱនទៅកាន់អារម្មណ៍ជា លក្ខណៈ បាន ដល់អរូបក្ខន្ធ៤។ អរូបក្ខន្ធ មានន័យថា ក្រុមអរូប៤យ៉ាងគឺៈ វេទនាខន្ធ១ សញ្ញាខន្ធ១ សង្ខារក្ខន្ធ១ និង វិញ្ញាណក្ខន្ធ១។ វេទនាខន្ធៈ ក្រុមសោយអារម្មណ៍ បានដល់វេទនាដែលកើតជាមួយចិត្ត ៨៩ ឬ១២១ដួង។ សញ្ញាខន្ធៈ ក្រុមចាំអារម្មណ៍ បានដល់សញ្ញាដែលកើតឡើងជាមួយចិត្ត៨៩ ឬ១២១ដួង។ សង្ខារក្ខន្ធៈ ក្រុម តាក់តែងនូវអារម្មណ៍ បានដល់ចេតសិក៥០ គឺចេតសិក ទាំង៥២ ដកយកវេទនាចេតសិក១និងសញ្ញាចេ សិក១ចេញ នៅសល់៥០។ វិញ្ញាណក្ខន្ធៈ ក្រុមដឹងច្បាស់នូវអារម្មណ៍ បានដល់ចិត្ត៨៩ ឬ១២១ដួង។ វេទនា

សញ្ញា សង្ខារ វិញ្ញាណ លោកហៅថា នាមធម៌ ព្រោះជាធម្មជាតិតែង ឱនទៅទេជ្រទៅ រទៅកាន់អារម្មណ៍ តាមទ្វារ៦ នៅពេលដែលអារម្មណ៍មកប្រាកដ ដល់ទ្វារទាំងនោះ។ រូប មានន័យ ធម្មជាតិដែលបែកធ្លាយ មាន កិរិយាបែកធ្លាយជាលក្ខណៈ បាន ដល់រូបក្ខន្ធ។ រូបក្ខន្ធ មានន័យថា ក្រុមរូប២៨ គឺៈ មហាភូតរូប៤ ឧបាទាយ រូប២៤។ បណ្តារូបទាំង២៨នេះ តែងមានលក្ខណៈផ្សេងៗ គ្នា មានលក្ខណៈរឹង រាវ ក្តៅ ល្ហើយ ជាដើមតាម រូបមួយៗ។ តែបើពោលពីលក្ខណៈរួមវិញ មានត្រឹមតែមួយ គឺកិរិយាបែកធ្លាយជាលក្ខណៈ ព្រោះថារូបទាំង ២៨នោះ បើទុកជាមានលក្ខណៈ ផ្សេងគ្នាយ៉ាងណា ក៏ដោយក៏គង់ត្រូវវិនាស ឬបែកធ្លាយដូចគ្នាទាំងអស់ដែរ ទើបពោលថា រូបក្ខន្ធនេះ ជារូបធម៌។

ទ្វារ ៦ទ្វារ មានន័យថា វត្ថុ ឬសន្ទះ ជាគ្រឿងបិទ គឺថាសង្រួមដោយវត្ថុនោះ (បសាទ រូប) ដូច្នេះវត្ថុ នោះហៅថា ទ្វារ។

ទ្វារនោះមាន៦ គឺៈ

១- ចក្ខុទ្វារ ទ្វារភ្នែក សំដៅយកបសាទរូប ដែលសម្រាប់សម្រេចកិច្ចក្នុងការ ឃើញនូវរូប នៅពេល ដែលរូបមកប្រាកដដល់ទ្វារភ្នែក។

២- សោតទ្វារ ទ្វារត្រចៀក សំដៅយកបសាទរូប ដែលសម្រាប់សម្រេចកិច្ចក្នុងការស្តាប់ នៅពេល ដែលសម្លេងមកប្រាកដដល់ទ្វារត្រចៀក ។

៣- ឃានទ្វារ ទ្វារច្រមុះ សំដៅយកបសាទរូប ដែលសម្រាប់សម្រេចកិច្ចក្នុងការ ធុំក្លិន នៅពេលដែល ក្លិនមកប្រាកដដល់ទ្វារច្រមុះ។

៤- ជិវ្ហាទ្វារ ទ្វារអណ្តាត សំដៅយកបសាទរូប ដែលសម្រាប់សម្រេចកិច្ចក្នុងការ ដឹងរសជាតិ នៅពេល ដែលរសជាតិមកប្រាកដ ដល់ទ្វារអណ្តាត ។

៥- កាយទ្វារ ទ្វារកាយ សំដៅយកបសាទរូប ដែលសម្រាប់សម្រេចកិច្ចក្នុងការដឹងនូវវត្ថុ នៅពេល ដែលវត្ថុមកប៉ះផ្ទប់នឹងទ្វារកាយ។

៦- មនោទ្វារ ទ្វារចិត្ត សំដៅយកភវង្គ មានបាលីថាៈ មនោទ្វារំ បន ភវង្គន្តិ វុច្ចតិ មានន័យថា ភវង្គ ហ្នឹងឯងគឺលោកហៅថា មនោទ្វារ។

អារម្មណ៍ ៦អារម្មណៈ មានន័យថា ធម្មជាតិដែលចូលមក ហើយធ្វើចិត្តនិងចេត សិកឲ្យ តោងជាប់ ឬ ធ្វើចិត្ត និងចេតសិកឲ្យត្រេកអរ ក្នុងធម្មជាតិនោះ ហៅថាអារម្មណ៍។

អារម្មណ៍មាន៦គឺៈ

១- រូបារម្មណ៍ អារម្មណ៍គឺរូប មានកិរិយាប៉ះខ្ទប់នឹងចក្ខុបសាទជាលក្ខណៈ បានដល់វណ្ណរូប មាន ពណ៌ខៀវ លឿង ក្រហម ស ជាដើម។

២- សទ្ទារម្មណ៍ អារម្មណ៍គឺសម្លេង មានកិរិយាប៉ះខ្ទប់នឹងសោតបសាទជា លក្ខណៈ បានដល់សម្លេង ស្គរ ពិណ ប៉ី ជាដើម។

៣- គន្ធារម្មណ៍ អារម្មណ៍គឺក្លិន មានកិរិយាប៉ះខ្ទប់នឹងឃានបសាទជាលក្ខណៈ បានដល់ក្លិនផ្កាឧប្បល ផ្កាម្លិះ ជាដើម។

៤- រសារម្មណ៍ អារម្មណ៍គឺរសជាតិ មានកិរិយាប៉ះខ្ទប់នឹងជិវ្ហាបសាទជាលក្ខណៈ បានដល់រសជាតិនៃ ដើម ផ្លែ មើមឈើជាដើម។

៥- ផោដ្ឋព្វារម្មណ៍ អារម្មណ៍គឺវត្ថុ ដែលប៉ះខ្ទប់នឹងកាយ បានដល់ធាតុ៣ គឺៈ-បថវីធាតុ ធាតុដីមានលក្ខណៈរឹង តេជោធាតុ ធាតុភ្លើង មានលក្ខណៈក្តៅ វាយោធាតុ ធាតុខ្យល់ មាន លក្ខណៈល្ហើយៗ។

៦- ធម្មារម្មណ៍ អារម្មណ៍គឺធម៌ មានលក្ខណៈផ្សេងៗ គ្នាតាមសភាពធម៌នោះ បានដល់ ធម៌៦គឺ បសាទរូប១ សុខុមរូប១ ចិត្ត១ ចេតសិក១ និញ្វាន១ វិញ្ញត្តិ១ ។

រូប នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមទ្វារ២ គឺចក្ខុទ្វារ១, មនោទ្វារ១។

សម្លេងនឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិកដែលកើតតាមទ្វារ២គឺសោតទ្វារ១ មនោទ្វារ១។

ក្លិន នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមទ្វារ២ គឺឃានទ្វារ១ មនោទ្វារ១

រស នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមទ្វារ២ គឺជីវ្ហាទ្វារ១ មនោទ្វារ១ ។

រឹង ក្តៅ ល្ហើយ នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាម ទ្វារ២ គឺ កាយទ្វារ១ មនោទ្វារ១។

ធម្មា គឺក្រុមធម៌ មានបសាទរូប និងសុខុមរូប ជាដើម នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារតែម៉្យាង។

សេចក្តីអធិប្បាយថាៈ

កាលដែលរូបារម្មណ៍មកប្រាកដដល់ចក្ខុទ្វារហើយ រូបនោះក៏បានមកជាអារម្មណ៍របស់ចិត្ត និងចេតសិក ដែលកើតតាមចក្ខុទ្វារ ហើយក៏រលត់ទៅ។ បន្ទាប់មកក៏ បានមកជាអារម្មណ៍ដល់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារថែមទៀត ព្រោះហេតុដូច្នេះទើបពោលថា រូបនឹងបានមកជាអារម្មណ៍ របស់ចិត្តនិងចេតសិក ដែលកើត តាមទ្វារ២ គឺ ចក្ខុទ្វារ១, មនោទ្វារ១។ កាលដែលសទ្ទារម្មណ៍ មកប្រាកដដល់សោតទ្វារហើយ រូបនោះក៏បានមកជាអា រម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមសោតទ្វារ ហើយក៏រលត់ទៅ។ បន្ទាប់មកក៏ បានមកជាអារម្មណ៍ដល់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារថែមទៀត ព្រោះហេតុដូច្នេះទើបពោលថា សម្លេងនឹងបានមក ជាអារម្មណ៍ របស់ចិត្តនិងចេតសិក ដែលកើតតាមទ្វារ២ គឺ សោតទ្វារ១ មនោទ្វារ១។ កាលដែលគន្ធារម្មណ៍ មកប្រាកដដល់ឃានទ្វារហើយ រូបនោះក៏បានមកជាអា រម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមឃានទ្វារ ហើយក៏រលត់ទៅ។ បន្ទាប់មកក៏ បានមកជាអារម្មណ៍ដល់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារថែមទៀត ព្រោះ ហេតុដូច្នេះទើបពោលថា ក្លិននឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើត តាមទ្វារ២ គឺ ឃានទ្វារ១ មនោទ្វារ១។ កាលដែលរសារម្មណ៍ មកប្រាកដដល់ជីវ្ហាទ្វារហើយ រូបនោះក៏បានមកជាអា រម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមជីវ្ហាទ្វារ ហើយក៏រលត់ទៅ។ បន្ទាប់មកក៏ បានមកជាអារម្មណ៍ដល់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារថែមទៀត ព្រោះ ហេតុដូច្នេះទើបពោលថា រសជាតិនឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើត តាមទ្វារ២ គឺ ជីវ្ហាទ្វារ១ មនោទ្វារ១។ កាលដែលផោដ្ឋព្វារម្មណ៍ មកប្រាកដដល់កាយទ្វារហើយ ផោដ្ឋព្វៈនោះក៏បាន មកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមកាយទ្វារ ហើយក៏រលត់ទៅ។ បន្ទាប់មកក៏ បានមកជាអារម្មណ៍ដល់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារ ថែមទៀត ព្រោះហេតុដូច្នេះទើបពោលថា ផោដ្ឋព្វៈនឹងបានមកជាអារម្មណ៍របស់ចិត្ត និង ចេតសិក ដែលកើតតាមទ្វារ២ គឺ កាយទ្វារ១ មនោទ្វារ១។ រីឯធម៌ មានបសាទរូប និងសុខុមរូបជាដើម កាលដែលប្រាកដដល់មនោទ្វារហើយ ក៏បានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមមនោទ្វារតែម៉្យាង ហើយក៏រលត់ទៅព្រោះ ហេតុដូច្នេះទើបពោលថា ធម៌នឹងមកជាអារម្មណ៍របស់ចិត្ត

និងចេតសិក ដែលកើតតាមមនោទ្វារតែម៉្យាង។ ចិត្ត និងចេតសិក ដែលកើតតាមបញ្ចទ្វារ អាចទទួលកាន់យកអារម្មណ៍ជាបច្ចុប្បន្នមួយៗ តាមទ្វាររៀងៗខ្លួន មិនអាចកាន់យកនូវអារម្មណ៍ក្នុងអតីតៈនិងអនាគតបានឡើយ។ ឯចិត្ត និង ចេតសិក ដែលកើតតាមមនោទ្វារ អាចកាន់យកនូវអារម្មណ៍៦ ក្នុងអតីតៈ បច្ចុប្បន្ន និងអនាគតបានទាំងអស់។

កំណត់ដឹងនូវនាម និងរូប

ក្នុងការចម្រើនវិបស្សនាថ្នាក់ដំបូង ដើម្បីបំពេញនូវសេចក្ដីត្រូវការនៃព្រះយោគាវចរ ដែលជាអាទិកម្មិកបុគ្គល សូមលើកយករូបបរមត្ថ និងនាមបរមត្ថ ខ្លះៗ មកបកស្រាយ រៀបរៀង ទុកជាក្បួនប្រតិបត្តិក្នុងការហាត់ពត់ អប់រំចិត្តក្នុងព្រះពុទ្ធសាសនា នេះ។ រូបធម៌ទាំងអស់ មានចំនួន២៨ គឺមហាភូតរូប៤ និង ឧបាទាយរូប២៤ តែក្នុងទី នេះសូមលើកយកតែរូបចំនួន៩ មកតាំងទុកជាអារម្មណ៍ របស់បញ្ញានៃព្រះយោគាវចរដែលជាអាទិកម្មិកបុគ្គលដូចតទៅ៖ រូប៩នោះគឺៈ បឋវីធាតុ១ អាបោធាតុ១ តេជាធាតុ១ វាយោធាតុ១ វណ្ណៈ១ គន្ធៈ១ រសៈ១ ឱជៈ១ (រូប៨នេះហៅថា សុទ្ធដ្ឋករូប) និងសទ្ទៈ១។

- បឋវីធាតុ ធាតុដីមានលក្ខណៈរឹង
- អាបោធាតុ ធាតុទឹកមានលក្ខណៈជ្រាបសើម
- តេជោធាតុ ធាតុភ្លើងមានលក្ខណៈក្ដៅ
- វាយោធាតុ ធាតុខ្យល់មានលក្ខណៈល្ហើយៗ
- វណ្ណៈ គឺរូបពណ៌មានកិរិយាប៉ះខ្ទប់នឹងចក្ខុបសាទជាលក្ខណៈ
- សទ្ទៈ គឺសម្លេងមានកិរិយាប៉ះខ្ទប់នឹងសោតបសាទជាលក្ខណៈ
- គន្ធៈ គឺក្លិនមានកិរិយាប៉ះខ្ទប់នឹងឃានបសាទជាលក្ខណ
- រសៈ គឺរសជាតិមានកិរិយាប៉ះខ្ទប់នឹងជិវ្ហាបសាទជាលក្ខណៈ។
- ឱជៈ គឺឱជា សំដៅយកឱជារសដែលសម្រាប់ចិញ្ចឹមសរីរៈរាងកាយ សត្វឲ្យមានជីវិតប្រព្រឹត្តទៅក្នុងលោកឱជៈនេះផ្សព្វផ្សាយទៅពេញរាងកាយសត្វទាំងមូល មានឱជៈជាលក្ខណៈ។

វណ្ណរូប នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមចក្ខុទ្វារនិងមនោទ្វារ។ សទ្ទរូប នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមសោតទ្វារនិងមនោទ្វារ។

គន្ធរូប នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមឃានទ្វារ និងមនោទ្វារ។

រសរូប នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើតតាមជិវ្ហាទ្វារ និងមនោទ្វារ។ បឋវីធាតុ តេជោធាតុ វាយោធាតុ នឹងបានមកជាអារម្មណ៍របស់ចិត្ត និងចេត សិក ដែលកើតតាមកាយទ្វារ និងមនោទ្វារ អាបោធាតុ ឱជរូប នឹងបានមកជាអារម្មណ៍របស់ចិត្តនិងចេតសិក ដែលកើត តាមមនោទ្វារតែម៉្យាង ព្រោះរូបទាំងនេះជារូបល្អិត ចិត្តនិងចេតសិកតាមបញ្ចទ្វារ មិនអាចឃើញបាន។

នាមធម៌ មានច្រើនបែបយ៉ាង តែសូមលើកតែត្រឹម៥ មកទុកជាអារម្មណ៍របស់វិបស្សនា។ នាមធម៌៥ នោះគឺ ផស្សៈ១ វេទនា១ សញ្ញា១ ចេតនា១ ចិត្ត១។

- ផស្សៈធម្មជាតិប៉ះនូវអារម្មណ៍មានកិរិយាប៉ះនូវអារម្មណ៍ជាលក្ខណៈ
- វេទនាធម្មជាតិសោយនូវអារម្មណ៍មានកិរិយាសោយនូវអារម្មណ៍ជាលក្ខណៈ
- សញ្ញាធម្មជាតិចាំនូវអារម្មណ៍មានកិរិយាចាំនូវអារម្មណ៍ជាលក្ខណៈ

- ចេតនា ធម្មជាតិគិតនូវអារម្មណ៍ មានភាពគិត ឬចាត់ចែង ឬភាពសន្សំជា លក្ខណៈ

- ចិត្ត គឺវិញ្ញាណ គឺធម្មជាតិដឹងច្បាស់នូវអារម្មណ៍ មានកិរិយាដឹងច្បាស់ជាលក្ខណៈ

ក្រុមធម៌ទាំង៥នេះ លោកហៅថា នាមធម៌ តែងកើតឡើងតាមទ្វារទាំង៦ មានចក្ខុទ្វារជាដើម កាន់យកអារម្មណ៍៦ មានរូបារម្មណ៍ជាដើម ក្នុងសម័យដែលប្រាជ្ញារបស់ព្រះយោគី បានកំណត់ដឹងនូវលក្ខណៈនៃសភាវៈធម៌ មានរូបជាដើម ដែលមក ប្រាកដដល់ទ្វារ មានចក្ខុទ្វារជាដើម ។

កំណត់ដឹងនូវបច្ច័យរបស់នាមរូប

ពេទ្យអ្នកឈ្លាសវៃ ឃើញនូវរោគអ្នកជម្ងឺ ក៏ស្វែងរកនូវសមុដ្ឋាននៃរោគនោះ យ៉ាងណា បុរសអ្នកប្រកបដោយសេចក្តីករុណា ឃើញទារកដ៏ក្មេងខ្ចី កំពុងដេកផ្ងារក្នុងព្រៃស្មសាន ហើយក៏ធ្វើការពិចារណាថាតើមាតាបិតារបស់ ទារកនេះមួយណាហ្ន៎ យ៉ាងណា ព្រះយោគីកាលបើកំណត់ដឹងនូវនាមរូបហើយក៏ពិចារណារកហេតុបច្ច័យ របស់នាមរូបនោះ ក៏យ៉ាងនោះដូចគ្នា។ ការពិចារណារកនូវហេតុបច្ច័យរបស់នាមរូបក្នុងវិបស្សនានេះ ព្រះយោគីត្រូវពិចារណា រកហេតុបច្ច័យរបស់រូបកាយជាមុនសិន ទើប ពិចារណារកហេតុបច្ច័យ របស់នាមកាយជាខាងក្រោយ។ ហេតុបច្ច័យរបស់រូបកាយមាន៥គឺ អវិជ្ជា១ តណ្ហា១ ឧបាទាន១ កម្ម១ អាហារ១។

- អវិជ្ជាសេចក្តីល្ងង់ខ្លៅ

- តណ្ហាសេចក្តីប្រាថ្នាសេចក្តីតក់ស្លុតក្នុងអារម្មណ៍

- ឧបាទានសេចក្តីប្រកាន់មាំក្នុងអារម្មណ៍

- កម្មអំពើល្អនិងអំពើអាក្រក់

- អាហារ កវឡឹង្ការាហារ បានដល់ដុំបាយ ទឹក នំ ចំណី ជាដើម ដែលបុគ្គលបរិភោគលេបចូលទៅកន្លងបំពង់ក។

**សេចក្តីកត់ចំណាំ:** បុគ្គលម្នាក់ៗ កើតឡើងមានៈខន្ធ៥ ខន្ធ៥នោះគឺ រូប១ វេទនា១ សញ្ញា១ សង្ខារ១ វិញ្ញាណ១។ អាយតនៈ១២ វិញ្ញាណ៦ អាយតនៈក្នុង និងអារម្មណ៍៦ អាយតនៈក្រៅ។

## ១០.៤.២. វិបស្សនា

**និយមន័យវិបស្សនា** ការពិចារណាឃើញច្បាស់តាមពិត ប្រាជ្ញាពិចារណាឃើញច្បាស់នូវ ដំណើរសង្ខារធម៌តាមការណ៍ពិត។

### ពន្លឺនាវាត្រៃលោក និងនាវាត្រៃលក្ខណ៍

សេចក្តីអធិប្បាយក្នុងខាងដើម នៃវិបស្សនាកម្មដ្ឋាននេះ គួរពួកពុទ្ធសាសនិកជនទូទៅ ជ្រាបថាកាលដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើងបានត្រាស់ដឹងឡើងជាសាស្តាចារ្យឯកក្នុង លោក ទ្រង់មានព្រះហឫទ័យ ប្រកបដោយព្រះមហាករុណាដ៏ធំ ទ្រង់ប្រោសប្រទានព្រះសទ្ធម្ម ទេសនាចំពោះសត្តនិករក្នុងលោកអស់រយៈចំនួន៤៥ព្រះវស្សា។ ដោយទ្រង់មានព្រះពុទ្ធបំណង ចង់ឲ្យពួកសត្តនិករទាំងនោះ បានសម្រេច មគ្គផល ក្នុងពេលបានស្តាប់ ឬស្តាប់រួចហើយ និងបានប្រតិបត្តិតាម ដើម្បីឆ្ពោះត្រង់ទៅកាន់ ព្រះនិព្វានតែម៉្យាង។ មិនមែនមានពុទ្ធបំណង ត្រឹមតែដឹកនាំសត្វឲ្យបានសុគតិ គឺសម្បត្តិមនុស្សលោក ទេវលោក ឬព្រហ្មលោកប៉ុណ្ណោះទេ។ ព្រោះព្រះអង្គទ្រង់បានជ្រាប ជាក់ច្បាស់នូវភពទាំងពួង ដែលទ្រង់បានធ្លាប់កើតស្លាប់ៗ ដោយផ្ទាល់ព្រះអង្គឯងមក អស់រយៈកាលជាអនេកជាតិ ទាំងទ្រង់ឃ្វេងយល់ច្បាស់ ដោយព្រះបញ្ញាញាណផង

ទៀតថា ភពទាំង៣នេះ សឹងពេញទៅដោយគំនរភ្លើងទុក្ខ និងភ្លើងកិលេស ដែលកំពុងតែឆេះ រោលរាលកំដៅពួកសត្វ ឲ្យក្ដៅក្រហល់ក្រហាយ អន្ទះអន្ទែងជានិច្ច ដោយភ្លើងទុក្ខ ភ្លើងកិលេស ដុតកំដៅឲ្យឆេះរាលដាលវិលវល់ កើតស្លាប់ក្នុងវដ្តសង្សារ សោយទុក្ខវេទនារកទីបំផុតគ្មាន។ ពួកសត្វដែលត្រូវអវិជ្ជាដឹកមុខ បិទបាំងបញ្ញា មិនឲ្យឃើញច្បាស់នូវកងទុក្ខ ត្រឡប់ជាសម្គាល់ថា ការកើតក្នុងភព ជាការសុខសប្បាយទៅវិញ ឧបមាដូចសត្វល្អិតៗ តូចៗ មានសត្វ មមាចជាដើម ក្រឡេកឃើញពន្លឺ ភ្លើងភ្លឺប្រាលក្នុងរាត្រីកាល ក៏នឹកស្មានថាជារបស់ត្រជាក់ សុខសប្បាយ ឥតបានដឹងថា ភ្លើងនេះជារបស់ក្ដៅក្រហាយឡើយ ក៏នាំគ្នាហើរត្រសុករុលត្បុលចូលចោមរោមលេងប្រឡែង ព័ទ្ធក្រឡឹងនាយអាយ ដោយសេចក្ដីសំគាល់ខុស (មោហៈ) មិន បានមួយនាទីនាឡិកាផង ក៏ដល់នូវសេចក្ដីវិនាសអន្តរាយ ស្លាប់ខ្លួននៅទីនោះ ត្រៀបត្រាកកកុញ ហួសវិស័យនឹងរាប់ថាប៉ុណ្ណេះប៉ុណ្ណោះបាន ដោយសារតែភ្លើងនេះឯង យ៉ាងណាមិញ។ បុគ្គលដែលត្រូវអវិជ្ជាបិទបាំងហើយសំគាល់ឃើញសម្បត្តិមនុស្ស សម្បត្តិទេវតា ក៏នឹកស្មានថា សម្បត្តិទាំងនោះជារបស់វិសេស ត្រជាក់ត្រជុំថ្លៃថ្លាប្រកបដោយសេចក្ដីសុខស្រួល ថាជារបស់ទៀងទាត់ មិនវិបល្លាសប្រែប្រួល ម្ល៉ោះហើយក៏នាំគ្នា បំពេញការកុសលផ្សេងៗ ចំពោះតែខាង វដ្ដគាមិនីកុសល គឺកុសលដែលធ្វើដំណើរ ឲ្យវិលវល់ក្នុងភព ព្រោះតែប្រាថ្នានូវសម្បត្តិទាំងនោះ ឯសម្បត្តិទាំងនោះឯង រមែងចងក្រៀកនូវបុគ្គលជាម្ចាស់នោះ ឲ្យចាប់នៅក្នុងភព ហើយឆេះរោលរាល ដោយគំនរភ្លើងទុក្ខ និងភ្លើងកិលេស ធ្វើឲ្យវិលវល់ស្លាប់កើត ទទួលរងនូវសេចក្ដីទុក្ខ វេទនាក្នុងវដ្តសង្សាររឿយៗ រកទីបំផុតគ្មានយ៉ាងនោះដែរ។

**ព្រះពុទ្ធភាសិតទ្រង់ត្រាស់ថាៈ**

យថាបិ នាម ជច្ចន្ធោ នរោ អបរិនាយកោ
ឯកទា យាតិ មគ្គេន ឧម្មគ្គេនាបិ ឯកទា
សំសារេ សំសរំ ពាលោ តថា អបរិនាយកោ
ករោតិ ឯកទា បុញ្ញំ អបុញ្ញម្បិ ឯកទា
យទា ច ញត្វា សោធម្មំ សច្ចានិ អភិ សមេស្សតិ
តទា អវិជ្ជូ ប សមា ឧបសន្តោ ចរិស្សតិ ។

សេចក្ដីថា មនុស្សខ្វាក់អំពីកំណើត (ត្រាច់ចរលើផែនដី) បើឥតគេដឹកដៃនាំមុខទេ ដួនដើរទៅត្រង់ផ្លូវក៏មាន ដួនដើរទៅខុសផ្លូវក៏មាន យ៉ាងណាមិញ បុគ្គលពាលល្ងង់ខ្លៅ ដែលប្រ កបដោយអវិជ្ជាបិទបាំង មិនឲ្យដឹងច្បាស់នូវកងទុក្ខ ព្រោះការអន្ទោលទៅមកក្នុងវដ្តៈ កាលត្រាច់រង្គាត់ទៅ ក្នុងវាលវដ្តសង្សារ បើមិនមានអ្នកប្រាជ្ញដឹកនាំមុខទេ រមែងប្រារព្ធធ្វើនូវបុញ្ញាភិសង្ខារ គឺចំណែកជាបុណ្យខ្លះក៏មាន ប្រារព្ធធ្វើនូវអបុញ្ញាភិសង្ខារ គឺចំណែកជាបាបខ្លះក៏មាន ប្រារព្ធធ្វើនូវអនេញ្ជាភិសង្ខារ គឺជាចំណែកឈានដែលមាន ចិត្តវិបល្លាសដោយទិដ្ឋិមានសស្សតទិដ្ឋិជាដើម ក៏មានយ៉ាងនោះដែរ។ លុះណាតែបុគ្គលពាលនោះ យល់ច្បាស់លាស់ បានត្រាស់ដឹងនូវអរិយសច្ចៈ៤ប្រការ ពេលណា និងជាបុគ្គលប្រព្រឹត្តធម្មបតិបត្តិ ឆ្ពោះទៅរកសន្តិសុខ ស្ងប់ស្ងាត់ក្នុងពេលនោះ ព្រោះ បានស្ងប់អវិជ្ជា។ តែថាបើបុគ្គលពាលនោះ មិនបានត្រាស់ដឹងនូវអរិយសច្ចៈ ដោយ ច្បាស់លាស់ទេ ទុកណាជាបុគ្គលនោះ ប្រារព្ធធ្វើនូវបុញ្ញាភិសង្ខារ គឺការតាក់តែងបុណ្យណាមួយ ដោយកាយ វាចា ចិត្តបុណ្យនោះឯងរមែងច្រឡំទៅដោយ ទោសទុក្ខជាច្រើនប្រការ មានជាតិ និងជរាជាដើម ព្រោះហេតុអ្វី? ព្រោះតែប្រាថ្នានូវសម្បត្តិ ក្នុងលោកទាំង៣ គឺមនុស្សលោក ទេវលោក ព្រហ្មលោក ដោយសំគាល់ថា សម្បត្តិទាំង

នេះឯង ជាសម្បត្តិប្រសើរ ប្រកបដោយសេចក្តីសុខ យ៉ាងទៀងទាត់។ ប៉ុន្តែព្រះសព្វញ្ញុពុទ្ធ ពុំដែលទ្រង់សំដែងសរសើរ ចំពោះកំណើតនៃសត្វ ដែលអន្ទោលទៅកើតជាមនុស្សក្តី ជាទេវតាក្តី ជាព្រហ្មក្តី ថាជាកំណើតប្រកបដោយគុណផុត ចាកសេចក្តីទុក្ខទាំងពួងនោះឡើយ។ ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ថា បើជាតិកំណើតរបស់សត្វទាំងឡាយមាននៅដរាបណា សេចក្តីទុក្ខទាំងឡាយ មានជាតិទុក្ខជាដើម ក៏មាននៅដរាបនោះដែរ។ ព្រោះហេតុនោះ បានជាព្រះអង្គទ្រង់ត្រាស់សរសើរចំពោះតែ ព្រះនិព្វានមួយ ថាជា ធម្មជាតិអាចធ្វើសត្វទាំងឡាយ ឲ្យរលត់ផុតចាកទុក្ខគ្រប់ប្រការ។ ចំណែកបុគ្គលដែល ប្រកប ដោយវិជ្ជា រមែងមានការយល់ឃើញថា ការកើតជាមនុស្សក្តី កើតជាទេវតាក្តី កើតជាព្រហ្មក្តី ដោយអំណាចកាមាវចរកុសល ឬរូបាវចរកុសលណាមួយ ក៏គង់មិនរួចចាកទុក្ខទាំងពួងបាន ឡើយ ទាំងមានការយល់ឃើញថា បើជាតិកំណើតមិនទាន់អស់ទេ ទុក្ខក៏នៅមិនទាន់អស់ដែរ ព្រោះកំណើតរបស់សត្វទាំងឡាយ ដែលកើតក្នុងភពថោកទាប និងភពដ៏ឧត្តមនោះៗ ដោយ អំណាចកុសលាកុសលកម្ម សុទ្ធតែជាកំណើត នៅមានការប្រែប្រួលមិនទៀងទាត់ កាលបើអស់អំណាច នៃកុសលាកុសលកម្មនោះហើយ សត្វទាំងឡាយនោះឯង ត្រូវតែវិលត្រឡប់ចុះឡើងនៅក្នុងវដ្តៈ ដោយអំណាចនៃផលបុណ្យ និងផលបាបដឹកនាំដូច្នេះ តើទីបំផុតនៃទុក្ខរបស់សត្វ នៅត្រឹមណា? បុគ្គលដែលប្រកបដោយវិជ្ជា កាលបើយល់ឃើញយ៉ាងនេះហើយ រមែងមាន សេចក្តី នឿយណាយធុញទ្រាន់ចំពោះកំណើតដែលកើតរឿយៗ ក្នុងវដ្តៈនេះតែងត្រេះរិះរក ឧបាយ ដើម្បីនឹងដោះខ្លួន គេចចេញឲ្យរួចផុតចាកភពទាំង៣ ដោយការខំប្រឹងប្រែង បំពេញកុសលផ្សេងៗ ចំពោះតែខាងវិវដ្តគាមិនីកុសល គឺកុសលដែលធ្វើដំណើរ ត្រង់ឆ្ពោះទៅកាន់ព្រះនិព្វានជាទីប្រាសចាកវដ្តៈ។ បុគ្គលនោះ កាលបើធ្វើនូវកុសលណាមួយ ដោយកាយ វាចា ចិត្ត មានការឲ្យទានជាដើម រមែងតាំងចិត្តដើម្បីធ្វើពួកកិលេសទាំងឡាយ មានលោភៈជាដើម ឲ្យរីងស្ងួតអស់ពីខន្ធសន្តាន សំដៅទៅព្រះនិព្វាន តែម៉្យាងប៉ុណ្ណោះ។ កុសលរបស់បុគ្គលនោះហៅថា វិវដ្តគាមិនីកុសល គឺកុសលរបស់បុគ្គល អ្នកដល់ត្រើយ នៃច្រាំង គឺព្រះនិព្វាន រួចផុត ស្រឡះ ចាក ការវិលកើតវិលស្លាប់។

ធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់លើកឡើងសំដែង សម្រាប់ឲ្យសត្វប្រតិបត្តិតាម ដើម្បីឆ្ពោះតម្រង់ទៅកាន់ព្រះនិព្វាននោះ មានច្រើនជា អនេកណាស់ ក្នុងទីនេះ ទ្រង់សំដែងសំដៅ យកវិបស្សនាតែម៉្យាង ទីខ្លះសំដៅយកសមថៈផង ទាំងវិបស្សនាផង ទីខ្លះសំដៅយក អដ្ឋង្គិមគ្គ គឺមគ្គដែលប្រកបដោយ អង្គ៨ប្រការ មានសមាទិដ្ឋិជាដើម ទីខ្លះសំដៅយក ត្រ័យសិក្ខាទាំង៣ គឺ សីល សមាធិ បញ្ញា ទីខ្លះសំដៅយក ពោធិ៍បក្ខិយធម៌ទាំង៣៧ប្រការ មានសតិបដ្ឋាន៤ សម្មប្ប ធាន៤ ជាដើម។ ក្នុងទីនេះសំដៅយក វិបស្សនា កម្មដ្ឋានតែម៉្យាងប៉ុណ្ណោះ ដូចតទៅ ៖

ពន្លឺនាវាត្រៃលោក និងនាវាត្រៃលក្ខណ៍ទី១

សេចក្តីអធិប្បាយក្នុងខាងដើម នៃវិបស្សនាកម្មដ្ឋាននេះ គួរពួកពុទ្ធសាសនិកជនទូរទៅ ជ្រាបថា កាលដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង បានត្រាស់ដឹងឡើងជាសាស្តាចារ្យឯកក្នុងលោក ទ្រង់មានព្រះហឫទ័យ ប្រកបដោយព្រះមហាករុណាដ៏ធំ ទ្រង់ប្រោសប្រទានព្រះសទ្ធម្ម ទេសនាចំពោះសត្តនិករក្នុងលោក អស់រយៈចំនួន៤៥ព្រះវស្សា។ ដោយទ្រង់មានព្រះពុទ្ធបំណង ចង់ឲ្យពួកសត្តនិករទាំងនោះ បានសម្រេច មគ្គផល ក្នុងពេលបានស្តាប់ ឬស្តាប់រួចហើយ និងបានប្រតិបត្តិតាម ដើម្បីឆ្ពោះត្រង់ទៅកាន់ ព្រះនិព្វានតែម៉្យាង។ មិនមែនមានពុទ្ធបំណង ត្រឹមតែដឹកនាំសត្វឲ្យបានសុគតិ គឺសម្បត្តិមនុស្សលោក ទេវលោក ឬព្រហ្មលោក

ប៉ុណ្ណោះទេ ។ ព្រោះព្រះអង្គទ្រង់បានជ្រាប ជាក់ច្បាស់នូវភពទាំងពួង ដែលទ្រង់បានធ្លាប់កើតស្លាប់ៗ ដោយផ្ទាល់ព្រះអង្គឯងមក អស់រយៈកាលជាអនេកជាតិ ទាំងទ្រង់ឈ្វេងយល់ច្បាស់ ដោយព្រះបញ្ញាញាណផងទៀតថា ភពទាំង៣នេះ សឹងពេញទៅដោយគំនរភ្លើងទុក្ខ និងភ្លើងកិលេស ដែលកំពុងតែឆេះ រោលរាលកំដៅពួកសត្វឲ្យក្តៅក្រហល់ក្រហាយអន្ទះអន្ទែងជានិច្ចដោយភ្លើងទុក្ខភ្លើងកិលេស ដុតកំដៅឲ្យឆេះ រោលជាលវិលវល់ កើតស្លាប់ក្នុងវដ្តសង្សារ សោយទុក្ខវេទនារក ទីបំផុតគ្មាន។

ពួកសត្វដែលត្រូវអវិជ្ជាដឹកមុខ បិទបាំងបញ្ញា មិនឲ្យឃើញច្បាស់នូវកងទុក្ខ ត្រឡប់ជាសម្គាល់ថា ការកើតក្នុងភព ជាការសុខសប្បាយទៅវិញ ឧបមាដូចសត្វល្អិតៗ តូចៗ មានសត្វ មមាចជាដើម ក្រឡេកឃើញពន្លឺ ភ្លើងភ្លឺប្រាលក្នុងរាត្រីកាល ក៏នឹកស្មានថាជារបស់ត្រជាក់ សុខសប្បាយ ឥតបានដឹងថា ភ្លើងនេះជារបស់ក្តៅក្រហាយឡើយ ក៏នាំគ្នាហើរត្រសុករុលត្បុល ចូលចោមរោមលេងប្រឡែង ព័ទ្ធក្រឡឹងនាយអាយ ដោយសេចក្តីសំគាល់ខុស (មោហៈ) មិន បានមួយនាទីនាឡិកាផង ក៏ដល់នូវសេចក្តីវិនាសអន្តរាយ ស្លាប់ខ្លួននៅទីនោះ ត្រៀបត្រាកកកុញ ហួសវិស័យនឹងរាប់ថា ប៉ុណ្ណោះប៉ុណ្ណោះបាន ដោយសារតែភ្លើងនេះឯង យ៉ាងណាមិញ។ បុគ្គលដែលត្រូវអវិជ្ជាបិទបាំងហើយ សំគាល់ឃើញសម្បត្តិមនុស្ស សម្បត្តិទេវតា ក៏នឹកស្មានថា សម្បត្តិទាំងនោះជារបស់វិសេស ត្រជាក់ត្រជុំថ្លៃថ្លា ប្រកបដោយសេចក្តីសុខស្រួល ថាជារបស់ទៀងទាត់ មិនវិបល្លាសប្រែប្រួល ម្ល៉ោះហើយក៏នាំគ្នា បំពេញការកុសលផ្សេងៗ ចំពោះតែខាង វដ្តគាមិនីកុសល គឺកុសលដែលធ្វើដំណើរ ឲ្យវិលវល់ក្នុងភព ព្រោះតែប្រាថ្នានូវសម្បត្តិទាំងនោះ ឯសម្បត្តិទាំងនោះឯង រមែងចងក្រៀកនូវបុគ្គលជាម្ចាស់នោះ ឲ្យចាប់នៅក្នុងភព ហើយឆេះរោលរាល ដោយគំនរភ្លើងទុក្ខ និងភ្លើងកិលេស ធ្វើឲ្យវិលវល់ស្លាប់កើត ទទួលរងនូវសេចក្តីទុក្ខ វេទនាក្នុងវដ្តសង្សាររឿយៗ រកទីបំផុតគ្មានយ៉ាងនោះដែរ។

**ព្រះពុទ្ធភាសិតទ្រង់ត្រាស់ថា៖**

យថាបិនាមជច្ចន្ធោនរោអបរិនាកោឯកទា យាតិ មគ្គេន ឧម្មគ្គេនាបិ ឯកទាសំសារេ សំសរំ ពាលោ តថា អបរិនាយកោករោតិ ឯកទា បុញ្ញំ អបុញ្ញម្បិ ឯកទាយទា ច ញត្វា សោធម្មំ សច្ចានិអភិសមេស្សតិតទា អវិជ្ជូ បសមា ឧបសន្តោ វិស្សតិ។

សេចក្តីថា មនុស្សខ្វាក់អំពីកំណើត (ត្រាច់ចរលើផែនដី) បើឥតគេដឹកដៃនាំមុខទេ ជួន ដើរទៅត្រង់ផ្លូវក៏មាន ជួនដើរទៅខុសផ្លូវក៏មាន យ៉ាងណាមិញ បុគ្គលពាលល្ងង់ខ្លៅ ដែលប្រ កបដោយអវិជ្ជាបិទបាំង មិនឲ្យដឹងច្បាស់នូវកងទុក្ខ ព្រោះការអន្ទោលទៅមកក្នុងវដ្តៈ កាលត្រាច់រង្គាត់ទៅ ក្នុងវាលវដ្តសង្សារ បើមិនមានអ្នកប្រាជ្ញដឹកនាំមុខទេ រមែងប្រារព្ធធ្វើនូវបុញ្ញាភិសង្ខារ គឺចំណែកជាបុណ្យខ្លះក៏មាន ប្រារព្ធធ្វើនូវអបុញ្ញាភិសង្ខារ គឺចំណែកជាបាបខ្លះក៏មាន ប្រារព្ធធ្វើនូវអនេញ្ជាភិសង្ខារ គឺជាចំណែកឈានដែលមាន ចិត្តវិបល្លាសដោយទិដ្ឋិ មានសស្សតទិដ្ឋិជាដើមក៏មាន យ៉ាងនោះដែរ។ លុះណាតែបុគ្គលពាលនោះ យល់ច្បាស់លាស់បានត្រាស់ដឹងនូវអរិយសច្ចៈ៤ប្រការ ពេលណា និងជាបុគ្គលប្រព្រឹត្តធម្មបតិបត្តិ ឆ្ពោះទៅរកសន្តិសុខ ស្ងប់ស្ងាត់ក្នុងពេលនោះ ព្រោះបានស្ងប់អវិជ្ជា។ តែថាបើបុគ្គលពាលនោះ មិនបានត្រាស់ដឹងនូវអរិយសច្ចៈ ដោយច្បាស់លាស់ទេ ទុកណាជាបុគ្គលនោះ ប្រារព្ធធ្វើនូវបុញ្ញាភិសង្ខារ គឺការតាក់តែងបុណ្យណាមួយ ដោយកាយវាចា ចិត្ត បុណ្យនោះឯងរមែងច្រឡំទៅដោយ ទោសទុក្ខជាច្រើនប្រការ មានជាតិនិងជរាជាដើម ព្រោះហេតុអ្វី? ព្រោះតែប្រាថ្នានូវសម្បត្តិ ក្នុងលោកទាំង៣ គឺមនុស្សលោក ទេវលោក ព្រហ្មលោក ដោយសំគាល់ថាសម្បត្តិទាំងនេះឯង ជាសម្បត្តិប្រសើរ ប្រកបដោយសេចក្តីសុខ យ៉ាងទៀងទាត់។ ប៉ុន្តែព្រះសព្វញ្ញូពុទ្ធ ពុំដែល

ទ្រង់សំដែងសរសើរ ចំពោះកំណើតនៃសត្វ ដែលអន្ទោលទៅកើតជាមនុស្សក្តី ជាទេវតាក្តី ជាព្រហ្មក្តី ថាជាកំណើត ប្រកបដោយគុណ ផុតចាក សេចក្តីទុក្ខទាំងពួងនោះឡើយ ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ថា បើជាតិកំណើតរបស់សត្វ ទាំងឡាយមាននៅដរាបណា សេចក្តីទុក្ខទាំងឡាយ មានជាតិទុក្ខជាដើម ក៏មាននៅដរាបនោះដែរ។ ព្រោះហេតុនោះ បានជាព្រះអង្គទ្រង់ត្រាស់សរសើរចំពោះតែ ព្រះនិព្វានមួយ ថាជាធម្មជាតិអាចធ្វើសត្វទាំងឡាយ ឲ្យរលត់ផុតចាកទុក្ខគ្រប់ប្រការ។ ចំណែកបុគ្គលដែលប្រកបដោយវិជ្ជា រមែងមានការយល់ឃើញថា ការកើតជាមនុស្សក្តី កើតជាទេវតាក្តី កើតជាព្រហ្មក្តី ដោយអំណាចកាមាវចរកុសល ឬរូបាវចរកុសលណាមួយ ក៏គង់មិនរួចចាកទុក្ខទាំងពួងបានឡើយ ទាំងមានការយល់ឃើញថា បើជាតិកំណើតមិនទាន់អស់ទេ ទុក្ខក៏នៅមិនទាន់អស់ដែរ ព្រោះកំណើតរបស់សត្វទាំងឡាយ ដែលកើតក្នុងភពថោកទាប និងភពដ៏ឧត្តមនោះៗ ដោយអំណាចកុសលាកុសលកម្ម សុទ្ធតែជាកំណើត នៅមានការប្រែប្រួលមិនទៀងទាត់ កាលបើអស់អំណាច នៃកុសលាកុសលកម្មនោះហើយ សត្វទាំងឡាយនោះឯង ត្រូវតែវិលត្រឡប់ចុះឡើងនៅក្នុងវដ្តៈ ដោយអំណាចនៃផលបុណ្យ និងផលបាបដឹកនាំដូច្នេះ តើទីបំផុតនៃទុក្ខរបស់សត្វនៅត្រឹមណា? បុគ្គលដែលប្រកបដោយវិជ្ជា កាលបើយល់ឃើញយ៉ាងនេះហើយ រមែងមានសេចក្តី នឿយណាយធុញទ្រាន់ ចំពោះកំណើតដែលកើតរឿយៗក្នុងវដ្តៈនេះ តែងត្រេះរិះរកឧបាយ ដើម្បីនឹងដោះខ្លួនគេចចេញ ឲ្យរួចផុតចាកភពទាំង៣ ដោយការខំប្រឹងប្រែង បំពេញកុសលផ្សេងៗ ចំពោះតែខាងវិវដ្តគាមិនីកុសល គឺកុសលដែលធ្វើដំណើរ ត្រង់ឆ្ពោះទៅកាន់ព្រះនិព្វាន ជាទីប្រាសចាកវដ្តៈ។ បុគ្គលនោះ កាលបើធ្វើនូវកុសលណាមួយ ដោយកាយ វាចា ចិត្ត មានការឲ្យទានជាដើម រមែងតាំងចិត្តដើម្បីធ្វើពួកកិលេសទាំងឡាយ មានលោភៈជាដើម ឲ្យរីងស្ងួតអស់ពីខន្ធ សន្តាន សំដៅទៅព្រះនិព្វាន តែម្យ៉ាងប៉ុណ្ណោះ។ កុសលរបស់បុគ្គលនោះហៅថា វិវដ្តគាមិនីកុសល គឺកុសលរបស់បុគ្គល អ្នកដល់ត្រើយ នៃច្រាំង គឺព្រះនិព្វាន រួចផុតស្រឡះចាកការវិលកើតវិលស្លាប់។

ធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់លើកឡើងសំដែង សម្រាប់ឲ្យសត្វប្រតិបត្តិតាម ដើម្បីឆ្ពោះតម្រង់ទៅកាន់ព្រះនិព្វាននោះ មានច្រើនជា អនេកណាស់ ក្នុងទីនេះ ទ្រង់សំដែងសំដៅ យកវិបស្សនាតែម្យ៉ាង ទីខ្លះសំដៅយកសមថៈផង ទាំងវិបស្សនាផង ទីខ្លះសំដៅយកអដ្ឋង្គិមគ្គ គឺមគ្គដែលប្រកបដោយអង្គ៨ប្រការ មានសមាទិដ្ឋិជាដើម ទីខ្លះសំដៅយក ត្រ័យសិក្ខាទាំង៣ គឺ សីល សមាធិ បញ្ញា ទីខ្លះសំដៅយក ពោធិ៏បក្ខិយធម៌ទាំង៣៧ប្រការ មានសតិបដ្ឋាន៤ សម្មប្ប ធាន៤ ជាដើម។ក្នុងទីនេះសំដៅយកវិបស្សនាកម្មដ្ឋានតែម្យ៉ាងប៉ុណ្ណោះដូចតទៅៈ

ពន្លឺនាវាត្រៃលោក និងនាវាត្រៃលក្ខណ៍ វគ្គទី២

**កម្មវិធីចំរើន វិបស្សនាកម្មដ្ឋាន**កាលបើព្រះយោគាវចរមានបំណងនឹងចំរើននូវ វិបស្សនានោះគប្បីឲ្យដឹងអត្ថនៃវិបស្សនាភាវនាដូច្នេះថាៈ

បុគ្គលអ្នកធ្វើវិបស្សនាបញ្ញាដែលខ្លួនឃើញក្នុងអារម្មណ៍ហើយ មានក្នុងចិត្តដោយចេតនាណា ចេតនានោះឈ្មោះថា វិបស្សនាភាវនា។ ក៏ឯវិបស្សនាភាវនានេះ ព្រះយោគាវចរនឹងចំរើន គប្បីសិក្សាឲ្យដឹងច្បាស់ នូវធម៌៣ប្រការជាមុនសិនគឺៈ

១-ធម៌ជាភូមិជាអារម្មណ៍របស់វិបស្សនា

២-ធម៌ជាឫសគល់ជាហេតុឲ្យកើតឡើងហើយតាំងនៅរបស់វិបស្សនា

៣- អ្វីជាតួវិបស្សនា។

**១.៤ អ្វីជាភូមិជាអារម្មណ៍របស់វិបស្សនានោះ ?**

សង្ខារធម៌ដែលបច្ច័យប្រជុំតាក់តែងឡើងគឺឧបាទិន្នកៈ ដែលនាមធម៌អាស្រ័យ និងអនុបាទិន្នកៈ ដែលនាមធម៌មិនអាស្រ័យ ឬថា នាម និងរូប ដែលចែកចេញទៅដោយប្រការផ្សេងៗ មានខន្ធ៥ អាយតនៈ១២ ធាតុ១៨ ឥន្ទ្រិយ២២ ជាដើម ទាំងអស់នេះគឺ**ជាភូមិ ជាអារម្មណ៍របស់វិបស្សនា**។ អ្នកដែលចំរើនវិបស្សនានោះ ត្រូវរៀនធម៌ដែលជាភូមិ ជាអារម្មណ៍ របស់វិបស្សនានោះ ឲ្យដឹងច្បាស់លាស់ជាមុន ហើយគប្បីសាកសួរលោក អ្នកចេះដឹងនូវអត្ថនិងធម៌ ឲ្យដឹងសេចក្តីពិតប្រាកដ ចំណានល្អ ទើបគួរនឹងចំរើនវិបស្សនាបាន។

**អ្វីជាឫសគល់ ជាហេតុកើតឡើង តាំងនៅរបស់វិបស្សនានោះ ?**

សីលវិសុទ្ធិ សេចក្តីបរិសុទ្ធនៃសីល១ ចិត្តវិសុទ្ធិ សេចក្តីបរិសុទ្ធនៃចិត្តគឺ ឧបចារសមាធិ និងអប្បនាសមាធិ១ វិសុទ្ធិទាំង២នេះឯង ជា**ឫសគល់ ជាហេតុកើតឡើង តាំងនៅរបស់វិបស្សនា**។ អ្នកដែលនឹងចម្រើននោះ ត្រូវប្រតិបត្តិឲ្យជាអ្នក មានសីលបរិសុទ្ធ និងចិត្តបរិសុទ្ធ ដោយសមាធិជាមុន ទើបគួរនឹងចម្រើនវិបស្សនាបាន។ បើជាអ្នកមានសីលមិនបរិសុទ្ធ មិនមានសមាធិ ចិត្តរាយមាយហើយ ក៏ជាអ្នកអភ័ព្វមិនគួរនឹងចម្រើនវិបស្សនានោះបានឡើយ។ ព្រោះ ថាសីល និងសមាធិជាកម្លាំងឲ្យកើតវិបស្សនា។

**អ្វីជាតួវិបស្សនា ?**

**វិសុទ្ធិទាំង៥យ៉ាងគឺៈ**

១-**ទិដ្ឋិវិសុទ្ធិ** សេចក្តីបរិសុទ្ធនៃការឃើញ។

២- **កង្ខាវិតរណវិសុទ្ធិ** សេចក្តីបរិសុទ្ធ នៃឃើញច្បាស់ កន្លងបង់សេចក្តីសង្ស័យបាន។

៣- **មគ្គាមគ្គញាណទស្សនវិសុទ្ធិ** សេចក្តីបរិសុទ្ធនៃការដឹងពិតឃើញពិត នេះជាផ្លូវ នេះមិនមែនជាផ្លូវ

៤- **បដិបទាញាណទស្សនវិសុទ្ធិ** សេចក្តីដឹងច្បាស់ឃើញច្បាស់ នូវផ្លូវប្រតិបត្តិ ដែលជាហេតុឲ្យអរិយមគ្គកើតឡើង។

៥- **ញាណទស្សនវិសុទ្ធិ** សេចក្តីបរិសុទ្ធនៃការដឹងការឃើញ នូវករណីយកិច្ចដែលជាចំណែកនៃលោកុត្តរៈ គឺឃើញក្នុងមគ្គ៤ ដោយជាក់ច្បាស់តាម លក្ខណៈនិងសភាវៈ មិនវង្វេងទៅតាមសម្មតិ លោកវោហារថា ជាសត្វ ខ្លួន ប្រាណ យើង គេឡើយ ដែលជាតួទិដ្ឋិវិសុទ្ធិ។ ទាំងជាហេតុនិងជាបច្ច័យ កន្លងកង្ខាក្នុងកាលទាំង៣ ចេញបាន គឺមិនសង្ស័យថាយើងច្យុតមកពីទីណា? យើងជាអ្វី? យើងនឹងទៅ កើតក្នុងទីណា? ទេវបុត្រ ទេវតា មានឬមិនមាន? ដែលជាតួកង្ខាវិតរណវិសុទ្ធិ។ វិបស្សនាញាណទាំង៩ មានឧទយព្វយញាណជាដើម មានអនុលោមញាណ ជាទីបំផុត ឈ្មោះថាបដិបទាញាណទស្សនវិសុទ្ធិ។ អរិយមគ្គទាំង៤នេះឈ្មោះថា ញាណទស្សនវិសុទ្ធិ។ វិសុទ្ធិទាំង៥ប្រការនេះឯង ជាតួវិបស្សនា។ ម្យ៉ាងទៀត បញ្ញាដែលយើងដឹងពិតឃើញពិត ក្នុងសភាវៈ ការកើតឯងរបស់សង្ខារ គឺឃើញថា ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ឃើញច្បាស់ថា របស់ឯណាមិនទៀងតែកាល ណាកើតឡើងហើយ រលត់បាត់បង់ទៅវិញ របស់នោះជាទុក្ខពិត បើរបស់ឯណាជាទុក្ខ របស់ នោះជាអនត្តា មិនមែនជាខ្លួនជាប្រាណ របស់នោះមិនគួរបើនឹងប្រកាន់ប្រកៀក ថាជារបស់យើង ដោយអំណាចតណ្ហា ឧបាទាន មានៈ និងទិដ្ឋិឡើយ។ ព្រោះថាខ្លួនប្រាណយើងគេមិន មានទេ បញ្ញាដែលពិចារណាឃើញជាក់ច្បាស់យ៉ាងនេះ ដរាបដល់កើតនិព្វិទា (នឿយណាយ)ស្អប់ខ្ពើមសង្ខារ កើតវិរាគៈ ប្រាសចាកសេចក្តីតម្រេក ត្រេកអរក្នុងសង្ខារ វិមុត្តិរួចផុតចាក កិលេសាសវៈទាំងអស់ នេះជាតួវិបស្សនាទាំងអស់ដូចគ្នា។

សាធុជនអ្នកបំពេញសេចក្ដីព្យាយាម បដិបត្តិក្នុងវិបស្សនាដូចបានពោលមកនេះ ធ្វើឲ្យបរិបូណ៌ហើយ ក៏បានឈ្មោះថាចំរើន វិបស្សនាដោយល្អ នេះជាសេចក្ដីអធិប្បាយ ដោយសង្ខេបក្នុងវិបស្សនានេះ។ឯសេចក្ដីពិស្ដារដូចមានតទៅនេះ៖

អ្នកដែលចម្រើនវិបស្សនា គប្បីឲ្យជាអ្នកបរិសុទ្ធដោយសីល បរិសុទ្ធដោយទិដ្ឋិ ហើយគប្បីដឹងលក្ខណៈ កិច្ច ហេតុ ផល របស់វិបស្សនានោះឯង។

**អ្វីហ្ន៎ជាលក្ខណៈរបស់វិបស្សនា?**

សភាវៈការកើតឯងរបស់សង្ខារ គឺជារបស់មិនទៀង ជាទុក្ខ ជាអនត្តាពិត។ សេចក្ដីឃើញថា សង្ខារជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ជាក់ច្បាស់យ៉ាងនេះឯង ជាលក្ខណៈគ្រឿងសំគាល់ របស់វិបស្សនា បើការដឹងឃើញ យ៉ាងដទៃទៅ មិនត្រូវតាមន័យដូចពោល មកខាងលើនេះ ក៏មិនមែន ជាវិបស្សនាឡើយ។

**អ្វីហ្ន៎ជាកិច្ច និងជាគុណរបស់វិបស្សនា?**

សេចក្ដីងងឹតគឺមោហៈ ការភ័ន្តច្រឡំក្នុងសង្ខារ ថាជារបស់ទៀង ថាសុខ ថាខ្លួនប្រាណឯណា បិទបាំងបញ្ញាមិនឲ្យឃើញច្បាស់ នូវរបស់ពិតនៃសង្ខារ សេចក្ដីកំចាត់បង់ងងឹតចេញបានអស់ មិនវង្វេងក្នុងសង្ខារថាជារបស់ទៀងទាត់ ជារបស់សុខ ជាខ្លួន ប្រាណ ជារបស់ល្អ នេះឯងជាកិច្ច ជាគុណវិបស្សនា។

**អ្វីហ្ន៎ជាផលរបស់វិបស្សនា?**

សេចក្ដីឃើញពិតទូទៅក្នុងសង្ខារទាំងពួង ថាជារបស់មិនទៀង ជាទុក្ខ ជាអនត្តា សេចក្ដីងងឹតគឺមោហៈ ការវង្វេងចូលមក តាំងនៅមិនបាន ព្រោះមានពន្លឺភ្លឺស្វាងកើតឡើង នេះឯងជា ផលរបស់វិបស្សនាក្នុងបទនេះ។ អ្វីជាហេតុកើតឡើង ហើយតាំងនៅរបស់វិបស្សនា? ចិត្តដែលមិនរាយមាយតាំងនៅ ខ្ជាប់ខ្ជួនឯណានិមួយ ដោយអំណាចសមាធិនេះឯងជា ហេតុកើតឡើង តាំងនៅរបស់វិបស្សនា។ វិបស្សនានោះ រមែងអាស្រ័យសមាធិ ទើបកើតឡើងតាំងនៅបាន បើមិនបានចំរើនសមាធិ ឲ្យកើតមុនហើយក៏មិនអាចចម្រើនវិបស្សនា ឲ្យកើតឡើងបាន ព្រោះថា សមាធិជាហេតុឲ្យកើត វិបស្សនាដោយន័យនេះ អ្នកដែលមានសីលមិនបរិសុទ្ធ មិនបានសមាធិ នឹងមកពោលអួតថា ខ្លួនបានសម្រេចវិបស្សនាភាវនាយ៉ាងនេះ មិនគួរជឿឡើយ។ ព្រោះសីលបរិសុទ្ធ ជាហេតុឲ្យកើតសមាធិ សមាធិជាហេតុ ឲ្យកើតវិបស្សនា វិបស្សនា ជាហេតុឲ្យកើតអរិយមគ្គ អរិយមគ្គជាហេតុ ឲ្យកើតអរិយផល ជាធម៌តាមនិយម មានយ៉ាងនេះ មិនប្រែប្រួល ទៅជាយ៉ាងដទៃឡើយ។ អ្នកដែលចំរើនវិបស្សនាគប្បីឲ្យដឹង លក្ខណៈកិច្ចហេតុ ផល របស់វិបស្សនាដោយប្រការដូច្នេះ។

**ពន្លឺនាវាត្រៃលោក និងនាវាត្រៃលក្ខណ៍ វគ្គទី៣**

**វិភាគការចែកជា៦ចំណែកគឺ:**

អនិច្ចំ របស់មិនទៀង១ អនិច្ចលក្ខណំ គ្រឿងសំគាល់ដែលឲ្យកំណត់ដឹង ថាជារបស់ មិនទៀង១ ទុក្ខំ របស់ដែលសត្វអត់ទ្រាំ បានដោយកម្រ១ ទុក្ខលក្ខណំ គ្រឿងសំគាល់ដែល ឲ្យកំណត់ដឹង ថាជាទុក្ខ១ អនត្តា សភាវៈមិនមែនជាខ្លួនប្រាណ១អនត្តលក្ខណំគ្រឿងសំ គាល់ដែលឲ្យកំណត់ដឹង ថាមិនមែនជាខ្លួនប្រាណ១។ ក្នុងវិភាគទាំង៦នេះ សង្ខារដែលប្រជុំតាក់តែង ឡើងជាឧបាទិន្នកៈ១ និងអនុបាទិន្នកៈ១ ឬថានាម និងរូបដែលចែកចេញទៅដោយប្រការផ្សេងៗ មានខន្ធ ធាតុ អាយតនៈជាដើម ដែលជាភូមិ ជាអារម្មណ៍របស់វិបស្សនានោះទាំងអស់ ជាតួអនិច្ចំ ជារបស់មិនទៀង ព្រោះថាកើតឡើងហើយ រលត់សាបសូន្យទៅវិញជាធម្មតា តែងតែប្រែប្រួលទៅយ៉ាងដទៃ មិនតាំងនៅដូចដើមឡើយ។ ក៏ឯការកើតឡើងហើយ សាបសូន្យទៅ នឹង

ប្រែប្រួលទៅ ជាយ៉ាងដទៃនេះឯង ជាតួអនិច្ចលក្ខណៈ ជាគ្រឿងសំគាល់ដែលឲ្យដឹងថា ជារបស់មិនទៀងពិត។ សង្ខារនិងនាម រូបដែលជារបស់មិនទៀង នោះជាតួទុក្ខំ ព្រោះជារបស់ប្រែប្រួល ទៅជាយ៉ាងដទៃៗដោយភ្លើងគឺ ជរា ព្យាធិ និងមរណៈ បៀតបៀនដុតបំផ្លាញជានិច្ច។ រីឯការកើតរលត់ និងប្រែប្រួលជាយ៉ាងដទៃៗ ទៅដោយ ជរា ព្យាធិ និងមរណៈ បៀតបៀនដុតបំផ្លាញនោះឯង ជាទុក្ខលក្ខណៈ ជាគ្រឿងសំគាល់ឲ្យដឹងថា ជាតួទុក្ខពិត។ ធម៌ទាំងអស់ ដែលជាសង្ខារនិងវិសង្ខារ និងព្រះនិព្វានសុទ្ធតែជា អនត្តា ព្រោះជាធម៌សូន្យ ចាកខ្លួនប្រាណ សត្វ បុគ្គល មិនមានអ្នកឯណាមួយ ជាម្ចាស់របស់គ្រាន់តែជាសភាវៈធម៌មួយៗ ផ្សេងៗទៅប៉ុណ្ណោះ។ ក៏ភាពជារបស់សូន្យចាកខ្លួន ប្រាណ សត្វ បុគ្គល មិនមានម្ចាស់របស់គ្រាន់តែជាសភាវៈម៉្យាងប៉ុណ្ណោះ នេះហៅថា អនត្តលក្ខណៈ គ្រឿងសំគាល់ដឹងថា ជាអនត្តាពិត។

អ្នកដែលចំរើនវិបស្សនា គប្បីដឹងស្គាល់វិភាគធម៌៦យ៉ាង ដូចពោលមកនេះ អ្នកបំពេញព្យាយាមចម្រើនវិបស្សនា ជាអ្នកបរិបូណ៌ដោយគុណសម្បត្តិ មានសីល និងទិដ្ឋិជាដើម ដូចបានពោលមកនេះ ទើបគួរជាអ្នក ចំរើនវិបស្សនាដ៏ល្អ ជាអ្នកអាចញ៉ាំងវិបស្សនានោះ ឲ្យបរិបូណ៌បាន ដោយប្រការទាំងពួង។

លំដាប់នេះ នឹងសំដែងធម៌ដែលជា អារម្មណ៍របស់វិបស្សនា និងវិធីចម្រើនវិបស្សនា តាមបាលី និងអដ្ឋកថាដូចតទៅនេះ៖

សេចក្ដីថា សង្ខារដែលជាបច្ច័យប្រជុំតាក់តែងឡើង ជាឧបាទិន្នកៈ និងអនុបាទិន្នកៈ ទាំងអស់នោះឯង ជាអារម្មណ៍របស់វិបស្សនា។ វិបស្សនាដែលមានសង្ខារ ជាអារម្មណ៍នោះ បានខាងអនិច្ចលក្ខណៈ និងទុក្ខលក្ខណៈ ទាំងពីរដែលមានមកហើយ ក្នុងបាលីថា៖

**សព្វេ សង្ខារា អនិច្ចា** សង្ខារធម៌ទាំងអស់ជារបស់មិនទៀង រមែងកើតឡើងហើយរលត់ បាត់បង់ទៅវិញជាធម្មតា។

**សព្វេ សង្ខារា ទុក្ខា** សង្ខារទាំងអស់ជាទុក្ខដូច្នេះ។ ម៉្យាងទៀត ធម៌ទាំងអស់ដែលជាសង្ខារ និងវិសង្ខារ (ព្រះនិព្វាន) ក៏ជាអារម្មណ៍របស់វិបស្សនា។ វិបស្សនាដែលមានធម៌ ទាំងអស់ជាអារម្មណ៍នោះបានតែក្នុងអនត្តលក្ខណៈម៉្យាង ដែលមានក្នុងបាលីថា សព្វេ ធម្មា អនត្តា ធម៌ទាំងអស់មិនមែនខ្លួន ប្រាណ។

ព្រះនិព្វានដែលមានសង្ខារទៅប្រោសហើយ មិនមានមកក្នុងសង្ខារ ទាំងពីរខាងដើមនោះទេ ព្រោះព្រះនិព្វាន ជាធម៌ទៀង ពេញពោរដោយ បរមសុខយ៉ាងមាំមួន ប៉ុន្តែព្រះនិព្វាននោះ ជាអនត្តាធម៌ មិនមែនជាខ្លួនប្រាណ សត្វបុគ្គលឡើយ គ្រាន់តែជា អសង្ខតធាតុ ប៉ុណ្ណោះ ទើបបានមានមកក្នុងពាក្យថា សព្វេ ធម្មា អនត្តា ដូច្នេះ។

សាធុជនកាលនឹងចំរើនវិបស្សនាដែលមានសង្ខារ និងធម៌ជាអារម្មណ៍នោះ គប្បីចំរើនតាមន័យដែលមានមកក្នុងបាលីដូច្នេះថាៈ សព្វេ សង្ខារា អនិច្ចា សព្វេ សង្ខារា ទុក្ខា សព្វេ ធម្មា អនត្តា។ ម៉្យាងទៀតពួក៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ បណ្ដាខន្ធទាំង៥នោះ គឺរូបក្ខន្ធ មានកិរិយាចាស់ទ្រុឌទ្រោម ទៅជាខាងដើម មានកិរិយាបែកធ្លាយទៅ ជាខាងចុង ព្រោះបច្ច័យ ជាសត្រូវដល់ខ្លួន មានត្រជាក់និងក្ដៅ ជាដើមជាលក្ខណៈ បាននឹងមហាភូតរូប៤គឺ ដី ទឹក ភ្លើងខ្យល់ និងរូបដែលអាស្រ័យ នូវមហាភូតរូប៤នោះទាំងអស់ នេះជាពួករូប។ វេទនាមានការទទួលរង ឬសោយនូវអារម្មណ៍ ជាលក្ខណៈ គឺជាសុខ ទុក្ខ ឧបេក្ខា កើតអំពីសម្ផស្ស ការពាល់ត្រូវ។ ការសោយនូវអារម្មណ៍ ទាំងអស់នេះ ជាពួកវេទនា។ សញ្ញា មានសេចក្ដីសំគាល់នូវអារម្មណ៍ ឬចំណាំនូវអារម្មណ៍ ជាលក្ខណៈ គឺសំគាល់រូប ហើយចំណាំរូបបាន សំគាល់សម្លេង ហើយចំណាំសម្លេងបាន

សំគាល់ក្លិន ហើយចំណាំក្លិនបាន សំគាល់រស ហើយចំណាំរសបាន សំគាល់សម្ផស្ស ហើយចំណាំសម្ផស្សបាន សំគាល់ធម្មារម្មណ៍ ហើយចំណាំធម្មារម្មណ៍បាន សេចក្តីសំគាល់ ហើយចាំបានទាំងអស់នេះ ជាពួកសញ្ញា។ សង្ខារមានការតាក់តែងចិត្ត ឬប្រុងចិត្តជាលក្ខណៈ គឺមនោសញ្ចេតនា សេចក្តីត្រិះរិះក្នុងចិត្ត ក្នុងអារម្មណ៍មានរូបារម្មណ៍ជាដើម គឺចេតសិកធម៌ ដែលកើតក្នុងចិត្តទាំងអស់ លើកលែងតែ វេទនានិងសញ្ញាចេញ ទាំងអស់នេះ ជាពួកនៃសង្ខារ។ វិញ្ញាណមានការដឹងច្បាស់ នូវអារម្មណ៍ជាលក្ខណៈ គឺចិត្ត ដែលអាស្រ័យចក្ខុ សោតៈ ឃានៈ ជីវ្ហា កាយ ចិត្តកើតឡើងជាកុសលខ្លះ, អកុសលខ្លះ, ជាវិបាកខ្លះ, ជាកិរិយាខ្លះ ចិត្តទាំងនេះជាពួកវិញ្ញាណ។

ខន្ធទាំង៥ដែលពោលមកនេះ ជាភូមិ ជាអារម្មណ៍របស់វិបស្សនា។ ដែលមានខន្ធ៥ជាជាអារម្មណ៍នោះ មានក្នុងអនិច្ចលក្ខណៈ និងអនត្តលក្ខណៈទាំងពីរ ដូចបាលីថា រូបំអនិច្ចំ រូបមិនទៀង វេទនាអនិច្ចា វេទនាមិនទៀង សញ្ញាអនិច្ចា សេចក្តីចាំបានមិនទៀង សង្ខារា អនិច្ចា ធម៌ដែលតាក់តែងចិត្ត ប្រុងចិត្តមិនទៀង វិញ្ញាណំអនិច្ចំ ចិត្តដែលដឹងច្បាស់ នូវអារម្មណ៍មិនទៀង។ រូបំអនត្តា រូបមិនមែនជាខ្លួនប្រាណ វេទនាអនត្តា ការសោយនូវអារម្មណ៍ មិនមែនជាខ្លួនប្រាណ សញ្ញាអនត្តា សេចក្តីចាំបានមិនមែនខ្លួនប្រាណ សង្ខារអនត្តា ធម៌ដែលតាក់តែងចិត្ត ប្រុងចិត្តមិនមែនខ្លួនប្រាណ វិញ្ញាណំអនត្តា ចិត្តដែលដឹងច្បាស់ នូវអារម្មណ៍មិនមែន ខ្លួនប្រាណ។ សព្វេ សង្ខារា អនិច្ចា សង្ខារធម៌ទាំងឡាយទាំងពួងមិនទៀង សព្វេ ធម្មា អនត្តា ធម៌ទាំងឡាយទាំងពួង ជាសង្ខារនិងវិសង្ខារ មិនមែនជាខ្លួនប្រាណដូច្នេះ។

បាលីដែលលើកយកមកសំដែងនេះ សំដែងតែចំពោះអនិច្ចលក្ខណៈ និងអនត្តលក្ខណៈ ទាំងពីរយ៉ាងប៉ុណ្ណោះ មិនបានសំដែង ទុក្ខលក្ខណៈផងទេ ព្រោះទុក្ខលក្ខណៈរាប់បញ្ចូលក្នុង អនិច្ចលក្ខណៈស្រាប់ហើយ ដោយហេតុថា របស់ណាមិនទៀង របស់នោះជាទុក្ខ កាលបើឃើញអនិច្ចលក្ខណៈហើយ ទុក្ខលក្ខណៈក៏នឹងប្រាកដផង ។ ព្រោះហេតុនោះបាលីនេះ ទើបសំដែងត្រឹមតែអនិច្ចលក្ខណៈ និងអនត្តលក្ខណៈប៉ុណ្ណោះ។

សាធុជនអ្នកបំពេញសេចក្តីព្យាយាម គប្បីចំរើនវិបស្សនា ដែលមានខន្ធ៥ជាអារម្មណ៍ តាមបាលីដូចបានពោលមកមកនេះចុះ ។ ម៉្យាងទៀតវិបស្សនា ដែលមានខន្ធ៥ជាអារម្មណ៍ មានក្នុងលក្ខណៈទាំង៣គឺ **អនិច្ចលក្ខណៈ១ ទុក្ខលក្ខណៈ១ អនត្តលក្ខណៈ១** ដែលមានក្នុង បាលីថា **រូបំ អនិច្ចំ** រូបមិនទៀង **យទ និច្ចំ តំ ទុក្ខំ** រូបឯណាជារបស់មិនទៀង រូបនោះជាទុក្ខ **យំ ទុក្ខំ តំ អនត្តា** រូបឯណាដែលជាទុក្ខ រូបនោះមិនមែនជារបស់ខ្លួនទេ។ **យទនត្តា តំ នេតំ មម នេសោ ហមស្មិ នមេសោ អត្តា** រូបឯណាមិនមែនខ្លួន រូបនោះមិនមែនជារបស់យើងទេ រូបនោះមិនមែនជាខ្លួន ប្រាណនៃយើងទេ អ្នកទាំងឡាយគប្បីឃើញ ដោយបញ្ញាដ៏ប្រពៃ តាមពិតរបស់រូប ដូច្នេះឯង។ **វេទនា អនិច្ចា** ការសោយអារម្មណ៍ ជារបស់មិនទៀង **យទនិច្ចំ តំ ទុក្ខំ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ **យំ ទុក្ខំ តំ អនត្តា** របស់ឯណាដែលជាទុក្ខ របស់នោះមិនមែន ជាខ្លួនប្រាណ **យទនត្តា តំ នេតំ មម នេសោហមស្មិ នមេសោ អត្តា** របស់ឯណាមិនមែនជាខ្លួន ជាប្រាណ របស់នោះមិនមែនជារបស់យើង របស់នោះមិនមែន ជាខ្លួនប្រាណយើងទេ អ្នកទាំងឡាយគប្បីឃើញ ដោយបញ្ញាដ៏ប្រពៃចុះ។ **សញ្ញាអនិច្ចា** ការចាំបានជារបស់មិនទៀង **យទ និច្ចំ តំ ទុក្ខំ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ **យំ ទុក្ខំ តំ អនត្តា** របស់ឯណាដែល ជាទុក្ខ របស់នោះមិនមែនជាខ្លួនប្រាណ **យទនត្តា តំ នេតំ មម នេសោហមស្មិ នមេសោ អត្តា** របស់ឯណាមិនមែនជាខ្លួន ជាប្រាណរបស់នោះមិនមែន ជារបស់យើងទេ អ្នកទាំងឡាយគប្បី ឃើញដោយបញ្ញាដ៏ប្រពៃចុះ។ **សង្ខារា អនិច្ចា** ធម៌ដែលតាក់តែងចិត្ត ប្រុងចិត្តទាំងឡាយមិនទៀង **យទ**

**និច្ចំ តំ ទុក្ខំ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ **យំ ទុក្ខំ តំ អនត្តា** របស់ឯណាដែលជាទុក្ខ របស់នោះមិនមែនជាខ្លួនប្រាណ **យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តា** របស់ឯណាមិនមែនជាខ្លួន ជាប្រាណ របស់នោះមិនមែនជា របស់យើងទេ អ្នក ទាំងឡាយគប្បីឃើញ ដោយបញ្ញាដ៏ប្រពៃចុះ។ **វិញ្ញាណំ អនិច្ចំ** ចិត្តដែលដឹងច្បាស់នូវអារម្មណ៍ ជារបស់មិនទៀង **យទ និច្ចំ តំ ទុក្ខំ** របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ **យំ ទុក្ខំ តំ អនត្តា** របស់ឯណាដែលជាទុក្ខ របស់នោះមិនមែនជាខ្លួនប្រាណ **យទនត្តា តំ នេតំ មម នេសោ ហមស្មិ នមេសោ អត្តា** របស់ឯណាមិនមែនជាខ្លួន ជាប្រាណ របស់នោះមិនមែនជារបស់យើងទេ អ្នកទាំងឡាយគប្បីឃើញ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះចុះ។

ម្យ៉ាងទៀត វិបស្សនាដែលមានខន្ធ៥ ទាំងហេតុនិងបច្ច័យ បាននឹងលក្ខណៈទាំង៣ ដែលមានមកហើយក្នុងបាលីថា **រូបំអនិច្ចំ** រូបមិនទៀង ធម៌ឯណាជាហេតុ ជាបច្ច័យឲ្យរូបកើតឡើង សូម្បីធម៌នោះក៏មិនទៀងដូចគ្នា រូបដែលកើតឡើង ព្រមដោយហេតុ ដែលមិនទៀងហើយ នឹងបានរបស់ទៀងមកពីណា។ **វេទនា អនិច្ចា** ការសោយអារម្មណ៍ជារបស់មិនទៀង ធម៌ឯណាជាហេតុជាបច្ច័យ ឲ្យវេទនាកើតឡើង សូម្បីធម៌នោះក៏មិនទៀងដូចគ្នា វេទនាដែលកើត ឡើងព្រមដោយហេតុ ដែលមិនទៀងយ៉ាងនេះហើយ នឹងបានរបស់ទៀងមកពីណា។ **សញ្ញាអនិច្ចា** ការចាំបានជារបស់មិនទៀង ធម៌ឯណាជាហេតុជាបច្ច័យ ឲ្យសញ្ញាកើតឡើង សូម្បីធម៌នោះក៏មិនទៀងដូចគ្នា សញ្ញាដែលកើតឡើង ព្រមដោយហេតុ និងបច្ច័យដែលមិនទៀងហើយ នឹងបានជារបស់ទៀងមកអំពីណា។ **សង្ខារាអនិច្ចា** ធម៌ទាំងឡាយដែលតាក់តែងចិត្ត ប្រុងចិត្តមិនទៀង ធម៌ឯណាជាហេតុជាបច្ច័យ ឲ្យសង្ខារកើតឡើង សូម្បីធម៌នោះ ក៏មិនទៀងដូចគ្នា សង្ខារដែលកើតឡើង ព្រមដោយហេតុបច្ច័យ ដែលមិនទៀងហើយ នឹងបានរបស់ទៀងមកពីណា។ វិញ្ញាណំអនិច្ចំ ចិត្តដែលដឹងច្បាស់ នូវអារម្មណ៍មិនទៀង ធម៌ឯណាជាហេតុជាបច្ច័យ ឲ្យវិញ្ញាណកើតឡើង សូម្បីធម៌នោះ ក៏មិនទៀងដូចគ្នា វិញ្ញាណដែលកើត ព្រមដោយហេតុ បច្ច័យ មិនទៀងហើយ នឹងបានជារបស់ទៀង ស្ថិតស្ថេរមកអំពីណា។

**រូបជាទុក្ខ** ធម៌ឯណាដែលជាហេតុ ជាបច្ច័យឲ្យរូបកើតឡើង សូម្បីធម៌នោះក៏ជាទុក្ខដូចគ្នា។ រូបដែលកើតឡើង ព្រមដោយហេតុបច្ច័យ ជាទុក្ខហើយ នឹងបានជារបស់សុខមកពីណា។ វេទនាជាទុក្ខ ធម៌ឯណាដែលជាហេតុជាបច្ច័យ ឲ្យវេទនាកើតឡើង សូម្បីធម៌នោះ ក៏ជាទុក្ខដូចគ្នា។ វេទនាដែលកើតឡើង ព្រមដោយហេតុបច្ច័យ ជាទុក្ខហើយ នឹងបានជារបស់សុខ មកអំពីណា។ សញ្ញាជាទុក្ខ ធម៌ឯណាដែលជាហេតុជាបច្ច័យឲ្យសញ្ញាកើតឡើង សូម្បីធម៌នោះក៏ជា ទុក្ខដូចគ្នា។ សញ្ញាដែលកើតឡើងព្រមដោយ ហេតុបច្ច័យជាទុក្ខហើយ នឹងបានជារបស់សុខមកអំពីណា។ សង្ខារជាទុក្ខ ធម៌ឯណាដែលជាហេតុជាបច្ច័យ ឲ្យសង្ខារកើតឡើង សូម្បីធម៌នោះក៏ជាទុក្ខដូចគ្នា។ សង្ខារដែលកើតឡើង ព្រមដោយហេតុបច្ច័យ ជាទុក្ខហើយ នឹងបានជារបស់សុខមកពីណា។ វិញ្ញាណជាទុក្ខ ធម៌ឯណាដែលជាហេតុជាបច្ច័យ ឲ្យវិញ្ញាណកើតឡើង សូម្បីធម៌នោះក៏ជាទុក្ខដូចគ្នា។ វិញ្ញាណដែលកើតឡើង ព្រមដោយហេតុបច្ច័យជាទុក្ខហើយ នឹងបានជារបស់សុខមកពីណា។

**រូបជាអនត្តា** រូបមិនមែនជាខ្លួនប្រាណ ធម៌ឯណាជាហេតុបច្ច័យឲ្យរូបកើតឡើង សូម្បីធម៌នោះក៏ជាអនត្តា មិនមែនជាខ្លួនប្រាណដូចគ្នា។ រូបដែលកើតឡើង ព្រមដោយហេតុបច្ច័យ ជាអនត្តាហើយ នឹងបានជាខ្លួនប្រាណមកអំពីណា។ វេទនាជាអនត្តា មិនមែនជាខ្លួនប្រាណ ធម៌ឯណាជាហេតុបច្ច័យឲ្យវេទនាកើតឡើង សូម្បីធម៌នោះក៏ជាអនត្តា មិនមែនជាខ្លួន ប្រាណដូចគ្នា។ វេទនាដែលកើតឡើង ព្រមដោយហេតុបច្ច័យ ជាអនត្តាហើយ នឹងបានជាខ្លួន ប្រាណមកអំពីណា។ សញ្ញាជាអនត្តា មិនមែនជាខ្លួនប្រាណ ធម៌ឯណាជាហេតុ

បច្ច័យ ឲ្យសញ្ញាកើតឡើង សូម្បីធម៌នោះក៏ជាអនត្តា មិនមែនជាខ្លួនប្រាណដូចគ្នា។ សញ្ញាដែលកើតឡើង ព្រមដោយហេតុបច្ច័យជាអនត្តាហើយ នឹងបានជាខ្លួនប្រាណមកអំពីណា។ សង្ខារជាអនត្តា មិនមែនជាខ្លួនប្រាណធម៌ឯណាជាហេតុបច្ច័យឲ្យសង្ខារកើតឡើង សូម្បីធម៌នោះក៏ជាអនត្តា មិនមែនជាខ្លួនប្រាណ ដូចគ្នា។ សង្ខារដែលកើតឡើង ព្រមដោយហេតុបច្ច័យ ជាអនត្តាហើយ នឹង បានជាខ្លួនប្រាណមកអំពីណា។ វិញ្ញាណជាអនត្តា មិនមែនជាខ្លួនប្រាណ ធម៌ឯណាជាហេតុ បច្ច័យឲ្យវិញ្ញាណកើតឡើង សូម្បីធម៌នោះក៏ជាអនត្តា មិនមែនជាខ្លួនប្រាណដូចគ្នា។ វិញ្ញាណ ដែលកើតឡើង ព្រមដោយហេតុបច្ច័យជាអនត្តាហើយ នឹងបានជាខ្លួនប្រាណមកអំពីណា។ វិបស្សនាដែលមានខន្ធ៥ ព្រមទាំងហេតុបច្ច័យជាអារម្មណ៍ មានក្នុងលក្ខណៈទាំង ៣ ដូចមានមកហើយក្នុងបាលីដូច្នេះ។

ព្រះយោគាវចរកុលបុត្តអ្នកចម្រើនវិបស្សនា ដែលមានខន្ធ៥សុទ្ធជាអារម្មណ៍ក្តី ដែលមានខន្ធ៥ ទាំងហេតុបច្ច័យជាអារម្មណ៍ក្តី ដូចន័យដែលមានមកហើយក្នុងបាលី ដូចពោលមកនេះក៏បាន។ រីឯវិធីចម្រើនវិបស្សនា ដែលមានមក ក្នុងអដ្ឋកថានោះដូច្នេះ គឺអ្នកបំពេញព្យាយាម បើបានឈានជា សមថយានិកៈហើយ រមែងធ្វើឈានដោយខ្លួនឯង បានឲ្យជាបាទនៃវិបស្សនាហើយ គឺចេញចាកឈាន ហើយកំណត់ឈានទាំង៥ បាននឹងវិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ទាំងសម្បយុត្តធម៌ ដែលកើតឡើងព្រម ដោយអង្គឈាននោះ តាមន័យចូលចិត្តឲ្យជាក់ច្បាស់ ប្រាកដថា អង្គឈាននិងសម្បយុត្តធម៌ ទាំងអម្បាលនេះ ជានាមធម៌ ព្រោះជាធម៌បង្អោនទៅ កាន់អារម្មណ៍ ហើយស្វែងរកទីអាស្រ័យ របស់នាមធម៌នោះ ទើបឃើញថា ហទយរូបនេះជាទីអាស្រ័យរបស់នាមធម៌នោះ មហាភូតរូប និងឧបាទាយរូប ជាទីអាស្រ័យរបស់ ហទយរូបនេះ ទើបសន្និដ្ឋានចូលចិត្តច្បាស់ថា ហទយរូប មហាភូតរូប និងឧបាទាយរូប ទាំងអម្បាលនេះជា រូបធម៌ ព្រោះជារបស់តែងទ្រុឌទ្រោម គ្រាំគ្រាទៅជាបច្ច័យ ជាសត្រូវដល់ខ្លួន មានត្រជាក់ និងក្តៅជា ដើម។ អ្នកបំពេញព្យាយាម កាលបើបានឈាន សមថយានិកៈហើយ រមែងកំណត់ដឹងនូវនាម និងរូបជាក់ច្បាស់យ៉ាងនេះដូច្នេះឯង។

ចំណែកខាងវិបស្សនាយានិកៈ អ្នកមានញាណ គឺវិបស្សនា មិនបានឈានសមាបត្តិឯណា កាលដែលចំរើនវិបស្សនា មកកំណត់សង្ខារ មាននាមនិងរូបជាដើម។ ម្យ៉ាងទៀតមកកំណត់កាយ និងចិត្តចេតសិកដោយប្រភេទនៃពួកទាំង៥ គឺពួករូប ជារបស់ទ្រុឌទ្រោមទៅ១ ពួកវេទនា ការសោយនូវអារម្មណ៍១ ពួកសញ្ញា ការចាំបាននូវអារម្មណ៍១ ពួកសង្ខារ ជាអ្នកតាក់តែងនូវចិត្ត១ ពួកវិញ្ញាណ ជាអ្នកដឹងច្បាស់នូវអារម្មណ៍១ រួមត្រូវជា៥ពួក។ ការដែលកំណត់កាយ និងចិត្តចេតសិកនេះ ចែកចេញជា៥ពួក ដូចពោលមកហើយ។ អ្នកបំពេញព្យាយាម នឹងពិចារណា ខន្ធទាំង៥ឲ្យជាក់ច្បាស់ តាមលក្ខណៈ ចំពោះខណ្ឌដូច្នេះហើយ គប្បីបំប្រួញខន្ធទាំង៥នោះ រួមចូលមកជា២ គឺនាម១ រូប១។ រូបខន្ធ ពួករូបជារូបដដែល ព្រោះជារបស់ទ្រុឌទ្រោមទៅជាធម្មតា តែវេទនា សញ្ញា សង្ខារ វិញ្ញាណ អរូបខន្ធទាំង៤នេះជានាម ព្រោះជាធម៌បង្អោនទៅកាន់អារម្មណ៍ ការកំណត់សង្ខារដែលប្រព្រឹត្តទៅក្នុងភពទាំង៣ បំប្រួញចុះជានាមជារូបដូច្នេះហើយ ក៏បានសន្និដ្ឋានជា សត្វបុគ្គល ខ្លួនប្រាណ ទេវតា មារ ព្រហ្មដទៃៗ ក្រៅចាកនាមនិងរូប ទៅហើយមិនមាន។ មានតែនាមរូបប៉ុណ្ណោះប្រព្រឹត្តទៅក្នុងភពទាំង៣ ។ ក៏ពាក្យថា សត្វបុគ្គល ខ្លួនប្រាណ ជាដើមនោះ មិនមានដោយបរមត្ថ មកបញ្ញត្តិសម្មតិនាមរូបនោះឯង ថាជាសត្វបុគ្គល ខ្លួនប្រាណជាដើម បីដូចជាសម្មតិឈើ ថាជាក្របទូកដូច្នោះ ក៏នាមរូបទាំង២នេះ អាស្រ័យគ្នានឹងគ្នា ហើយក៏លឿនទៅក្នុងសង្សារ បីដូចជា មនុស្សយើងហើយនឹងទូក ទាំងពីរអាស្រ័យគ្នានឹងគ្នា ហើយលឿនទៅ ក្នុងសមុទ្ទសាគរដូច្នោះ។ ការកំណត់នាមនិងរូប បានដឹងច្បាស់តាមពិត

លះសត្តូបលទ្ធិសត្តញាណចេញ បានតាំងនៅ ក្នុងភាពជាអ្នកមិនវង្វេងក្នុងបញ្ញត្តិ ថាសត្វបុគ្គល ខ្លួនប្រាណ ជាដើមដូច្នេះហើយ ទិដ្ឋិសេចក្ដីឃើញរបស់អ្នកបំពេញ ព្យាយាមនោះ ក៏បរិសុទ្ធដោយល្អ ឈ្មោះថាទិដ្ឋិវិសុទ្ធិ ជាគួវិបស្សនាទី១។

សាធុជនអ្នកបំពេញព្យាយាម ធ្វើឲ្យទិដ្ឋិបរិសុទ្ធ បរិបូណ៌ឡើងហើយ គួរចំរើនវិបស្សនាតទៅ ស្វែងរកហេតុបច្ច័យរបស់នាមរូបនោះ បីដូចជាពេទ្យអ្នកឆ្លាតក្នុង ការរក្សារោគ កាលបើឃើញរោគហើយ ក៏រមែងស្វែងរកសមុដ្ឋាននៃរោគនោះ យ៉ាងណាមិញ អ្នកបំពេញព្យាយាម កាលបើដឹងនាម-រូបច្បាស់ហើយ គួរស្វែងរកហេតុបច្ច័យ របស់នាមរូបនោះដែរ កាលបើដឹងហេតុបច្ច័យ របស់នាមរូបនោះច្បាស់ហើយ ក៏រមែងឆ្លងផុតចាកកង្ខា គឺសេចក្ដីសង្ស័យក្នុងកាលទាំង៣បាន។

អ្វីជាហេតុបច្ច័យរបស់នាមរូបនោះ? ហើយនាមរូបនោះ អាស្រ័យរបស់អ្វីទើបកើតឡើង? កម្មជាហេតុ-បច្ច័យ របស់នាមរូបនោះ នាមរូបនោះជាគួវិបាក ផលសុខវិសេសរបស់កម្ម អាស្រ័យកម្មទើបកើតឡើងបាន។ កម្មនោះមាន២យ៉ាងគឺ កុសលកម្ម១ អកុសលកម្ម១។ នាមរូបឯណាកើតឡើង ដោយអកុសលកម្ម នាមរូបនោះ ជារបស់ទុព្វលភាព ថោកទាប។ នាមរូបឯណាដែលកើតឡើង ដោយអាស្រ័យកុសលកម្ម នាមរូបនោះជារបស់សុខុមល្អិត ដោយហេតុដូច្នេះទើបបានថា កម្មជាហេតុជាបច្ច័យរបស់នាមរូបនោះ។ តែបើគ្រាន់តែកម្មម៉្យាង ក៏មិនជាហេតុឲ្យកើតនាមរូប ក៏ត្រូវអាស្រ័យឧបាទាន គ្រឿងប្រកាន់ខ្ជាប់ និងឆន្ទៈរាគៈ សេចក្ដីគាប់ចិត្តត្រេកអរ ឧបាទានត្រូវអាស្រ័យនឹងតណ្ហា សេចក្ដីចំណង់ជាហេតុ ឲ្យអន្ទះអន្ទែងទៅ តណ្ហាក៏ត្រូវអាស្រ័យនឹងអវិជ្ជា សេចក្ដីមិនដឹងច្បាស់ មិនដឹងតាមសេចក្ដីពិត ព្រោះហេតុនោះ អវិជ្ជាទើបជាបច្ច័យរបស់តណ្ហា តណ្ហាជាបច្ច័យរបស់ឧបាទាន ឧបាទានជាបច្ច័យរបស់កម្ម(គឺភព) ភពជាបច្ច័យរបស់ជាតិ គឺនាមរូប ដោយន័យនេះទើបបាន ការសន្និដ្ឋានឃើញ ច្បាស់ថា ធម៌ទាំង៤យ៉ាងគឺ អវិជ្ជា តណ្ហា ឧបាទាន កម្ម ជាហេតុបច្ច័យ របស់នាមរូបនោះ។ នាមរូបនោះត្រូវអាស្រ័យ ធម៌៤យ៉ាងនេះ ទើបកើតឡើងហើយប្រព្រឹត្តទៅ មហាភូតរូប៤គឺ ដីទឹកភ្លើងខ្យល់ និងអាហារ ជាបច្ច័យរបស់រូបធម៌ ដោយឧបត្ថម្ភរូបនោះទុក។ ផស្សៈជាបច្ច័យរបស់នាមធម៌គឺ វេទនា សញ្ញា សង្ខារ នាមធម៌ទាំង៣នេះ អាស្រ័យបច្ច័យគឺផស្សៈ កើតឡើងហើយទើបប្រព្រឹត្តទៅបាន។ នាមរូបជាបច្ច័យ របស់នាមធម៌ គឺវិញ្ញាណ ព្រោះវិញ្ញាណនោះអាស្រ័យចក និងរូបទាំងពីរហើយកើតឡើង ទើបបានឈ្មោះថា ចក្ខុវិញ្ញាណ បើអាស្រ័យសោតៈ និងសម្លេងទាំងពីរនេះ កើតឡើងហើយ ទើបបានឈ្មោះថា សោតវិញ្ញាណ បើអាស្រ័យ ឃានៈនិងខ្លិនទាំងពីរនេះ កើតឡើងហើយ ទើបបានឈ្មោះថា ឃានវិញ្ញាណ បើអាស្រ័យជីវ្ហានិងរសទាំងពីរនេះ កើតឡើងហើយ ទើបបានឈ្មោះថា ជិវ្ហាវិញ្ញាណ បើអាស្រ័យកាយនិងសម្ផស្ស ទាំងពីរនេះកើតឡើងហើយ ទើបបានឈ្មោះថា កាយវិញ្ញាណ បើអាស្រ័យចិត្ត និងធម្មា ទាំងពីរនេះកើតឡើងហើយ ទើបបានឈ្មោះថា មនោវិញ្ញាណ។ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ទាំង៥នេះមានរូបតែម៉្យាងជាបច្ច័យ អាស្រ័យរូបហើយប្រព្រឹត្តទៅ។ ឯមនោវិញ្ញាណ មាននាមរូបទាំងពីរជាបច្ច័យ អាស្រ័យនាមរូបទាំងពីរ នេះហើយកើតឡើងប្រព្រឹត្តទៅ។ ដោយហេតុនេះ នាមនិងរូបទើបជាបច្ច័យរបស់នាមធម៌ គឺវិញ្ញាណ វិញ្ញាណអាស្រ័យនាមនិងរូប ទាំងពីរនេះកើតឡើងហើយប្រព្រឹត្តទៅ។ បានសេចក្ដីសន្និដ្ឋាន ឃើញច្បាស់ថា អវិជ្ជា តណ្ហា ឧបាទាន កម្ម អាហារ ជាហេតុបច្ច័យរបស់រូបធម៌។ រូបធម៌អាស្រ័យនូវបច្ច័យ ទាំង៥យ៉ាងនេះកើតឡើង ហើយប្រព្រឹត្តទៅ។ អវិជ្ជា តណ្ហា ឧបា ទាន កម្ម ផស្សៈ ជាបច្ច័យរបស់នាមធម៌គឺ វេទនា សញ្ញា សង្ខារ អាស្រ័យនូវបច្ច័យទាំង៥ យ៉ាង

នេះកើតឡើង ហើយប្រព្រឹត្តទៅ។ អវិជ្ជា តណ្ហា ឧបាទាន កម្ម នាមនិងរូប ជាហេតុបច្ច័យ របស់នាមធម៌ គឺវិញ្ញាណ អាស្រ័យនូវបច្ច័យទាំង៥ យ៉ាងនេះកើតឡើង ហើយប្រព្រឹត្តទៅ។

កាលបើអ្នកខំបំពេញព្យាយាម មកកំណត់ហេតុបច្ច័យ របស់នាម-រូប ជាក់ច្បាស់ដោយប្រការ ដូច្នេះហើយ គប្បីចូលចិត្តច្បាស់ថា នាមរូបដែលជាបច្ច័យនោះ អាស្រ័យហេតុបច្ច័យ ហើយប្រព្រឹត្តទៅយ៉ាងណា សូម្បីនាម-រូបដែលជាអតីត អនាគតក្តី រមែងអាស្រ័យហេតុបច្ច័យ កើតឡើងហើយប្រព្រឹត្តទៅដូច្នេះឯង។

កាលបើអ្នកបំពេញព្យាយាម កំណត់ហេតុបច្ច័យរបស់នាមរូប ជាក់ច្បាស់ដូច្នេះហើយ រមែងកន្លងកង្ខា គឺសេចក្តីសង្ស័យក្នុងកាលទាំង៣ កង្ខាក្នុងកាលទាំង៣នោះគឺ កង្ខាប្រារព្ធចំណែកខាង អតីតកន្លងហើយនោះ ៥ កង្ខាចំណែកខាង អនាគតខាងមុខ ដែលមិនទាន់មកដល់៥ កង្ខាក្នុងបច្ចុប្បន្ននេះ៦រួមត្រូវជាកង្ខា១៦យ៉ាងក្នុងកាលទាំង៣។

២.១ ពន្លឺនាវាត្រៃលោក និងនាវាត្រៃលក្ខណ៍ វគ្គទី៤

២.២ សង្ស័យក្នុងអតីត៥យ៉ាងនោះគឺៈ

១- សង្ស័យថា ដូចជាអញរំពឹងទៅ ក្នុងកាលដែលកន្លងទៅហើយ អាត្មាអញកើតជាអ្វីអេះ

២- សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ អាត្មអញមិនបានកើតជាអ្វីទេ ឬអេះ!

៣- សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ អាត្មាអញជាខត្តិយជាតិ ឬព្រាហ្មណ ជាតិ ឬក៏ជាអ្នកស្រែអ្នកឈ្នួញទេអេះ!

៤- សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ អាត្មាអញមានសណ្ឋាន ទ្រង់ទ្រាយធំ ឬតូច ខ្មៅ ឬស ល្អឬអាក្រក់អេះ!

៥- សង្ស័យថា ក្នុងកាលដែលកន្លងទៅហើយ អាត្មាអញដើមដំបូងកើតជាអ្វី ដល់មកខាងក្រោយអាត្មអញកើតជាអ្វីអេះ?។ រួមមកត្រូវជា សង្ស័យក្នុងអតីត៥ប្រការ។

២.៣ សង្ស័យក្នុងអនាគត៥គឺៈ

១- សង្ស័យថា ក្នុងកាលខាងមុខ អាត្មាអញនឹងកើតជាអ្វីហ្ន៎!

២- សង្ស័យថា ក្នុងកាលខាងមុខ អាត្មាអញនឹងកើតទៀតដែរឬហ្ន៎!

៣- សង្ស័យថា ក្នុងកាលខាងមុខ អាត្មាអញនឹងបានកើតជាខត្តិយជាតិ ឬព្រាហ្មណ ជាតិ ឬក៏ជាអ្នកស្រែ អ្នកឈ្នួញ ក្រីក្ររហេមរហាម យ៉ាងណាទៅអេះ!

៤-សង្ស័យថា ក្នុងកាលខាងមុខ អាត្មាអញនឹងកើត ជាអ្នកមានសណ្ឋាន ទ្រង់ទ្រាយធំ តូច ខ្ពស់ ទាប ខ្មៅ ស ដូចម្តេចទៅហ្ន៎!

៥- សង្ស័យថា ក្នុងកាលខាងមុខ អាត្មាអញនឹងកើតជាអ្វីតពីនោះទៅនឹងទៅកើតជាអ្វី ទៀតអេះ! រួមមកត្រូវជាសង្ស័យក្នុងអនាគត៥ប្រការ។

២.៤ សង្ស័យក្នុងបច្ចុប្បន្ន៦នោះគឺៈ

១- សង្ស័យថា ដូចជាអញរំពឹងទៅ សព្វថ្ងៃនេះមានឈ្មោះថាខ្លួនអញមែន ឬមិនមែន ខ្លួនអញទេ។

២- សង្ស័យថា ដូចជាអញគិតទៅ សព្វថ្ងៃនេះមិនមានឈ្មោះថាខ្លួនអញទេ ឬដូចម្តេច!

៣- សង្ស័យថា សព្វថ្ងៃនេះបានឈ្មោះថា អាត្មាអញកើតក្នុងខត្តិយជាតិ ឬព្រាហ្មណ ជាតិ ឬក៏ជាអ្នកស្រែ អ្នកឈ្នួញ អ្នកគ្រូ ឬជាដូចម្តេច!

៤- សង្ស័យថា សព្វថ្ងៃនេះបានឈ្មោះថា អាត្មាអញកើតបានជារូបរាង ពណ៌សម្បុរសណ្ឋានទ្រង់ទ្រាយធំ តូច ខ្ពស់ ទាប ខ្មៅ ស ល្អ អាក្រក់ ដូចម្តេចទៅ!

៥- សង្ស័យថា សត្វនេះមកអំពីណា មកកើតក្នុងទីនេះអេះ!

៦- សង្ស័យថា សត្វនេះមកកើតក្នុងទីនេះហើយ នឹងទៅកើតក្នុងទីណាទៀតអេះ! រួមត្រូវជាសង្ស័យក្នុងបច្ចុប្បន្ន៦ប្រការ។ រួមកង្ខាទាំង អតីត៥ អនាគត៥ បច្ចុប្បន្ន៦ ត្រូវជា១៦យ៉ាងដូច្នេះ។

ការកំណត់នាមរូបឃើញ ជាក់ច្បាស់យ៉ាងនេះហើយ រមែងឆ្លងចាកកង្ខាទាំង១៦យ៉ាងបាន ជាអ្នកមិនមានសង្ស័យក្នុងចំណែកអតីត អនាគត បច្ចុប្បន្ន ហើយបញ្ញារបស់ អ្នកបំពេញព្យាយាមនោះ នឹងមានកម្លាំងក្លៀវក្លា ទើបឈ្មោះថា កង្ខាវិតរណវិសុទ្ធិ ជាតួវិបស្សនាទី២។ ព្រះយោគាវចរបុគ្គល កាលប់កំណត់ដឹងហេតុបច្ច័យ របស់នាមរូបជាក់ច្បាស់ ដរាបកន្លងចាកកង្ខា ក្នុងកាលទាំង៣បានហើយ គួរខំចំរើនវិបស្សនាបញ្ញាតទៅ គឺពិចារណានាម-រូប ដែលជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្រៅឬខាងក្នុង ឬជ្រោកជ្រាក ឬសុខុមថោកទាប ឬឧត្តម ឆ្ងាយឬជិត ឲ្យឃើញនាមរូបទាំងអស់ ជារបស់មិនទៀងពិត បានសេចក្តីថាសង្ខារទាំងឡាយ កើតឡើងហើយ ក៏រលត់អស់ទៅក្នុងកាលនោះៗ។ ក៏នាមរូបឯណាជាអតីត នាមរូបនោះក៏រលត់ទៅក្នុងអតីត មិនមានមកដល់បច្ចុប្បន្ននេះទេ ។ នាមរូបឯណា ដែលជាអនាគត នាមរូបនោះ ក៏រលត់ទៅក្នុងអនាគត មិនមានទៅដល់អនាគត ខាងមុខទៀតឡើយ។ នាមរូប ឯណាដែលជាបច្ចុប្បន្ន នាម-រូបនោះក៏រលត់ទៅក្នុងបច្ចុប្បន្ន មិនមានទៅដល់ អនាគតខាងមុខទៀតឡើយ ។ នាម-រូបឯណាដែលជាខាងក្នុង នាម-រូបនោះក៏រលត់ទៅ ខាងក្នុង មិនមែនមករលត់ ខាងក្រៅឡើយ។ នាមរូបឯណាដែលជាខាងក្រៅ នាមរូបនោះក៏រលត់ទៅខាងក្រៅ មិនមែនមករលត់ខាងក្នុងឡើយ។ នាមរូបឯណាដែលជាជ្រោកជ្រាក នាមរូបនោះក៏រលត់ទៅ តាមសភាពជ្រោកជ្រាកទៅ មិនមែនរលត់តាម សភាពល្អិតឡើយ។ នាមរូបឯណាដែលល្អិត នាមរូបនោះក៏រលត់ទៅ តាមសភាពល្អិត មិនមែនរលត់ទៅដោយសភាព ជានាមរូបជ្រោកជ្រាកឡើយ។ នាមរូបឯណាដែលថោកទាប នាមរូបនោះក៏រលត់ទៅ ក្នុងសភាពជានាមរូបថោកទាប មិនដល់សភាព ជានាមរូបឧត្តមឡើយ។ នាមរូបឯណាដែលឧត្តម នាមរូបនោះក៏រលត់ទៅ ក្នុងសេចក្តីជានាមរូបឧត្តម មិនមែនដល់នូវសភាពជានាមរូបថោកទាបឡើយ នាមរូបឯណាដែលឆ្ងាយ នាមរូបនោះក៏រលត់ទៅ ក្នុងទីឆ្ងាយទៅ មិនមែនដល់នូវសភាពជា នាមរូបជិតបានឡើយ។ នាមរូបឯណាដែលជិត នាមរូបនោះក៏រលត់ទៅ ក្នុងទីជិត មិនដល់នូវសភាពជា នាមរូបឆ្ងាយបានឡើយ។ ព្រោះហេតុនោះ នាមរូបទាំងអស់ជារបស់មិនទៀងពិត ព្រោះកើតឡើងហើយរលត់អស់ទៅក្នុងកាលនោះៗ មិនកន្លងកាលនោះៗ បានឡើយ។ នាមរូបឯណាដែលជា របស់មិនទៀង នាមរូបនោះជាទុក្ខ ព្រោះការកើតឡើងហើយ រលត់អស់ទៅជានិច្ចឥតឈប់ឡើយ។ នាមរូបឯណាជារបស់ទុក្ខ នាមរូបនោះជារបស់អនត្តា មិនមែនជាខ្លួនប្រាណ មិនមានពិត គឺគ្រាន់តែជា នាមរូបប៉ុណ្ណោះឯង។ ក៏នាមរូបនោះមិនមែន ជារបស់យើងមិនមែនជាខ្លួនប្រាណរបស់យើងមិនមែនជាយើងឡើយ។

**កាលព្រះយោគាវចរ មកប្រារព្ធវិបស្សនា ដោយល្អដូច្នេះ ធម៌១០យ៉ាងក៏កើតឡើងគឺះ**

១- **ឧភាសៈ** ពន្លឺភ្លឺស្វាងកើតអំពីវិបស្សនាចិត្ត ផ្សាយចេញចាកសរីរវយវៈ។

២- **បីតិ** ផ្សាយចេញទៅសព្វសព៌ាង្គកាយ ធ្វើកាយនិងចិត្តឲ្យឆ្អែត កើតឡើងដោយវិបស្សនាចិត្ត។

៣- **វិបស្សនាញាណ** ចាស់ក្លាឃើញនាម-រូបជាក់ច្បាស់ដោយល្អកើតឡើង។

៤- **បស្សទ្ធិ** សេចក្តីស្ងប់កាយស្ងប់ចិត្ត រម្ងាប់ក្រវល់ក្រវាយចេញបានដោយល្អ កើតឡើងដោយ

វិបស្សនាចិត្ត។

៥- **សុខៈ** ប្រព្រឹត្តទៅក្នុងកាយនឹងចិត្តដ៏ឧត្តម កើតឡើងដោយវិបស្សនាចិត្ត។

៦- **អធិមោក្ខៈ** សេចក្ដីជឿខ្ជាប់ មានកម្លាំងខ្លាំងក្លា ជាទីផូរផង់របស់ចិត្តនិងចេតសិក កើតឡើងដោយវិបស្សនា។

៧- **បគ្គាហៈ** សេចក្ដីព្យាយាម មិនតឹងមិនធូរ ផ្គងចិត្តទុកដោយល្អក្នុងអារម្មណ៍ ធ្វើឲ្យចិត្តប្រព្រឹត្តទៅស្មើបាន កើតឡើងដោយវិបស្សនា។

៨- **ឧបដ្ឋានៈ** សតិតាំងភ្ជាប់ រក្សានូវអារម្មណ៍ទុក ធ្វើឲ្យប្រាកដដោយល្អ ដូចជាបរលោកប្រាកដមានដល់ អ្នកមានទិព្វចក្ខុដូច្នោះ។

៩- **ឧបេក្ខា** សេចក្ដីឃើញធម៌ជាកណ្ដាលក្នុងសង្ខារទាំងអស់ មានកម្លាំងខ្លាំងក្លាកើតឡើង។

១០- **និកន្តិ** សេចក្ដីស្រឡាញ់មានអាការៈសុខុម ធ្វើឲ្យអាល័យក្នុងវិបស្សនាកើតឡើង។

ធម៌ទាំង១០យ៉ាងនេះ ជាឧបធិកិលេសគ្រឿងសៅហ្មងរបស់វិបស្សនា ព្រោះកើតឡើងហើយ ធ្វើអ្នកចម្រើនវិបស្សនាឲ្យវង្វេង ទៅសំគាល់ថា មគ្គ-ផលកើតឡើងដល់ខ្លួន។ ខ្លួនថាមគ្គ ផលហើយ ក៏បញ្ឈប់សេចក្ដីព្យាយាម មិនចម្រើនវិបស្សនាតទៅទៀត ក៏កើតតណ្ហា មានៈ ទិដ្ឋិ ថារបស់គេ របស់យើង ខ្លួនប្រាណយើងឡើងទៀត។ ព្រោះហេតុដូច្នោះ ធម៌ទាំង១០យ៉ាងនេះ ទើបបានថា ជាឧបធិកិលេស គ្រឿងសៅហ្មងរបស់វិបស្សនា។ ព្រះយោគាវចរមកប្រារព្ធ វិបស្សនាដោយល្អ កាលបើឧបធិកិលេសទាំង១០យ៉ាងឯណានិមួយៗកើតឡើងហើយ មិនត្រេកអរ មិនវង្វេងក្នុងធម៌ឧបធិកិលេស ដែលកើតឡើងនោះ មិនបញ្ឈប់សេចក្ដីព្យាយាមរបស់ខ្លួនចេញ ដោយចូលចិត្តជឿច្បាស់ថា មិនមែនជាមគ្គផល មិនមែនជាផ្លូវវិបស្សនា ផ្លូវវិបស្សនាផ្សេងៗដែលយើងគប្បីដំណើរទៅ។ វិបស្សនាបញ្ញា របស់អ្នកបំពេញ ព្យាយាមចាស់ក្លា ដឹងឃើញជាក់ច្បាស់ថា នេះជាផ្លូវមគ្គផល នេះមិនមែនជាផ្លូវមគ្គផល បានដោយល្អយ៉ាងនេះ ឈ្មោះថា មគ្គាមគ្គញាណទស្សនវិសុទ្ធិជាតួវិបស្សនាទី៣។

អ្នកចំរើនវិបស្សនា កាលបើមានបញ្ញាចាស់ក្លា ធ្វើមគ្គាមគ្គញាណទស្សនវិសុទ្ធិ ឲ្យបរិបូណ៌ហើយវិនិច្ឆ័យបានឃើញច្បាស់ថា នេះជាតួអរិយមគ្គ នេះជាតួឧបធិកិលេស មិនមែនជាតួអរិយមគ្គ ដូច្នេះហើយ គួរចម្រើនវិបស្សនាញាណ ទាំង៩ប្រការដ៏បរិសុទ្ធផុតចាកឧបធិកិលេសហើយដើម្បីនឹងឲ្យបាន អរិយមគ្គខាងលើតទៅ។

វិបស្សនាញាណទាំង៩នោះគឺៈ

១-ឧទយព្វយញ្ញាណ

២-ភង្គញ្ញាណ

៣-ភយតូបដ្ឋានញ្ញាណ

៤-អាទីនវញ្ញាណ

៥-និព្វិទាញ្ញាណ

៦-មុញ្ចិតុកាម្យតាញ្ញាណ

៧-បដិសង្ខាញ្ញាណ

៨-សង្ខារុបេក្ខាញ្ញាណ

៩- សច្ចានុលោមញ្ញាណ

**១- ឧទយព្វយញ្ញាណ** ក្នុងញាណទាំង៩នេះ បញ្ញាដែលដឹងច្បាស់ នូវសេចក្តីកើតឡើងផង សេចក្តីរលត់អស់ទៅផង របស់នាមរូបនោះឈ្មោះថា ឧទយព្វយញ្ញាណ នេះពោលដោយសេចក្តីសង្ខេប។ បើពោលជានិប្បរិយាយវិញថា អ្នកបំពេញសេចក្តីព្យាយាម គប្បីពិចារណាជា និព្វទ្ធលក្ខណៈ គឺសេចក្តីកើតឡើង៥ និងវិបរិណាមលក្ខណៈ គឺសេចក្តីរលត់ទៅ៥ របស់ខន្ធ៥ ដោយន័យនេះ ក្នុងខមួយៗ មានលក្ខណៈ១០ៗ ទាំងកើតទាំងរលត់ខន្ធទាំង៥នេះ រួមទាំងកើតទាំងរលត់ ៥ដប់ដងត្រូវជា៥០គត់។ ក្នុងរូបខន្ធនោះ ឲ្យបំពេញព្យាយាម គប្បីពិចារណា ជានិព្វទ្ធលក្ខណៈ គឺកើតឡើង៥យ៉ាង រូបកើតក៏ព្រោះអវិជ្ជា សេចក្តីមិនច្បាស់កើតឡើង១ តណ្ហា១ ព្រោះកម្មជា កុសល-អកុសលកើតឡើង១ ព្រោះអាហារជា គ្រឿងឧបត្ថម្ភកើតឡើង១ គឺសេចក្តីកើតឡើង របស់សត្វតែម៉្យាង មិនអាស្រ័យហេតុ-បច្ច័យ១ រួមជានិព្វទ្ធលក្ខណៈសេចក្តីកើតរបស់រូបក្ខន្ធ ៥យ៉ាងដូច្នេះ។ គប្បីឃើញ វិបរិណាមលក្ខណៈក្នុងរូបក្ខន្ធទាំង៥យ៉ាងដូច្នេះ គឺរូបដែលរលត់ទៅ ព្រោះអវិជ្ជារលត់១ ព្រោះតណ្ហារលត់ទៅ១ ព្រោះកម្មរលត់អស់ទៅ១ ព្រោះអាហាររលត់អស់ទៅ១ ព្រោះរលត់អស់ទៅនៃរូបតែម៉្យាង មិនមានហេតុ-បច្ច័យ១ រួមជាវិបរិណាមលក្ខណៈ ៥យ៉ាងដូច្នេះ។ អ្នកបំពេញ សេចក្តីព្យាយាម ពិចារណា និព្វទ្ធលក្ខណៈ៥ និងវិបរិណាមលក្ខណៈ៥ ជា១០ផងគ្នារបស់រូបក្ខន្ធដូច្នេះ។ រួចហើយត្រូវពិចារណា និព្វទ្ធលក្ខណៈ៥ វិបរិណាមលក្ខណៈ៥ របស់វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធផង ឲ្យដូចជាពិចារណាក្នុង រូបក្ខន្ធដូច្នោះ ផ្សេងគ្នាតែក្នុង វេទនាសញ្ញា សង្ខារ និងវិញ្ញាណ ត្រង់អាហារឲ្យផ្លាស់យកផស្សៈ ដាក់ជំនួសដូច្នេះថា វេទនាកើតឡើងព្រោះ ផស្សៈកើតឡើងដែរ វេទនារលត់ទៅក៏ព្រោះផស្សៈរលត់ទៅ។ (សញ្ញាក្តី សង្ខារក្តី មានន័យដូចគ្នានឹងវេទនា)។ រីឯវិញ្ញាណ ត្រង់អាហារ ឲ្យយកនាមរូបជំនួសដូចតទៅនេះថា វិញ្ញាណកើតមានព្រោះ នាមរូបកើតឡើង វិញ្ញាណនោះរលត់ទៅក៏ ព្រោះនាមរូបរលត់។ និព្វទ្ធលក្ខណៈ និងវិបរិណាមលក្ខណៈ របស់វេទនា សញ្ញា សង្ខារ និងវិញ្ញាណប្លែកគ្នា មិនដូចលក្ខណៈ របស់រូបតែប៉ុណ្ណោះ។ បញ្ញាដែលដឹងនិព្វទ្ធលក្ខណៈ និងវិបរិណាមលក្ខណៈក៏កើតឡើងហើយរលត់ទៅ របស់ខន្ធ៥ដូច្នេះ ឈ្មោះថាឧទយព្វយញ្ញាណ ដែលបង្ហាញឲ្យចម្រើន ឃើញច្បាស់ថានាមរូប ជារបស់មិនទៀងពិត។

**២- ភង្គញ្ញាណ** បញ្ញាដែលពិចារណា តាមសេចក្តីរលត់ របស់សង្ខារតែម៉្យាង មិនពិចារណាហេតុ គឺសេចក្តីកើតឡើង ពិចារណាតែត្រឹមផល គឺសេចក្តីបែកធ្លាយទៅ នៃសង្ខារតែម៉្យាងប៉ុណ្ណោះ ជារបស់ពិតដូច្នេះថា សង្ខារទាំងអស់រមែងបែកធ្លាយទៅជាធម្មតា សេចក្តីដែលមិនបែកធ្លាយទៅ នៃសង្ខារនោះមិនមានឡើយ ឧបមាដូចជាពពុះទឹក មានដុំធំ តូចយ៉ាងណាៗក្តី មានកិរិយាបែកធ្លាយ ទៅវិញជាធម្មតា។ ក៏ចិត្តឯណា មានរូបជាអារម្មណ៍ កើតឡើងហើយ រមែងបែកធ្លាយទៅ អ្នកបំពេញព្យាយាម គប្បីពិចារណាឲ្យឃើញ ការបែកធ្លាយទៅ នៃចិត្តនោះជាអារម្មណ៍។ ម៉្យាងទៀត ចិត្តឯណាដែលមានវេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអារម្មណ៍ក្តី គប្បីពិចារណា ឲ្យឃើញការបែកធ្លាយទៅ នៃចិត្តនោះៗជាអារម្មណ៍ដូច្នេះ នេះជាកិច្ចរបស់ភង្គញ្ញាណ។

**៣- ភយតូបដ្ឋានញ្ញាណ** បញ្ញារបស់អ្នក បំពេញព្យាយាម ដឹងនូវសេចក្តីកើតឡើង និងសេចក្តីរលត់ទៅនៃសង្ខារ ចាស់ក្លាដរាបណា សង្ខារទាំងអម្បាលនេះ ប្រាកដជាភ័យគួរឲ្យខ្លាច ដូចជាគេឃើញភ្លើងឆេះផ្ទះនេះឈ្មោះថា ភយតូបដ្ឋានញ្ញាណ។

**៤- អាទីនវញ្ញាណ** កាលឃើញ ភយតូបដ្ឋានញ្ញាណ គឺឃើញថា សង្ខារជាភ័យធំគួរឲ្យ ខ្លាចប្រាកដជាក់ច្បាស់ ដូច្នោះហើយ ទើបមិនមាន សេចក្តីត្រេកអរក្នុង សង្ខារទាំងអម្បាលនោះឡើយ ដូចជាបុគ្គលស្រឡាញ់ជីវិត ដឹងថាភោជនាហារ រលាយទៅដោយថ្នាំពិសហើយ ក៏មិនហ៊ានបរិភោគដូច្នោះ ឬដឹងថា ស្ទឹង

មានក្រពើធំកាច គួរខ្លាចមិនហ៊ានចុះ ទៅងូតទឹកឡើយ។ បញ្ញាឃើញទោស របស់សង្ខារសព្វយ៉ាងនេះ ដរាបតែមិនត្រេកអរក្នុងសង្ខារ ដូចបានពោលមកហើយ នេះឈ្មោះថា អាទីនវញ្ញាណ។

**៥- និព្វិទាញាណ** បុគ្គលបានចំរើន អាទីនវញ្ញាណ ឲ្យមានកម្លាំងចាស់ក្លា ល្អិតណាដែល មាននិព្វិទា គឺសេចក្តីនឿយណាយ ស្អប់ខ្ពើមក្នុងសង្ខារ ទាំងអម្បាលនោះ មិនត្រេកអររីករាយ ឧបមាដូចបុគ្គល ឃើញទោសរបស់ភរិយា ហើយនឿយណាយ ស្អប់ខ្ពើមភរិយា ដូច្នោះឯង ឈ្មោះថា និព្វិទាញាណ។

**៦- មុញ្ចិតុកាម្យតាញាណ** ចិត្តរបស់អ្នកចំរើននោះ មិនជាប់ជំពាក់ក្នុង សង្ខារឯណានិមួយឡើយ មានបំណងតែនឹងដោះខ្លួន ចេញចាកអំពីសង្ខារ ទាំងឡាយនោះ ព្រោះសេចក្តីនឿយ ណាយចំពោះសង្ខារ បីដូចជាសត្វនៅក្នុងទ្រុង ចង់តែរួចចាកទៅខាងក្រៅដូច្នោះ ឈ្មោះថា មុញ្ចិតុកាម្យតាញាណ។

**៧- បដិសង្ខាញាណ** កាលបើព្យាយាម ធ្វើមុញ្ចិតុកាម្យតាញាណ ឲ្យបរិបូណ៌ហើយ ប្រាថ្នាឲ្យរួចចាកសង្ខារ ទាំងអម្បាលនោះ ហើយលើកសង្ខារទាំងនោះ ឡើងកាន់ព្រះត្រៃលក្ខណ៍ កំណត់ពិចារណា ដោយបដិសង្ខានុបស្សនាញាណ ដើម្បីធ្វើឧបាយឲ្យផុតចេញចាក សង្ខារទាំងនោះឡើង ទើបពិចារណាឃើញថា សង្ខារទាំងអស់ ជារបស់មិនទៀងពិត ព្រោះកើតឡើង ហើយរលត់សូន្យទៅវិញ ឲ្យពិចារណាក្នុងលក្ខណៈទាំង៣ ដើម្បីឲ្យសម្រេចឧបាយដោះចេញ ចាកសង្ខារទាំងអម្បាលនោះ ប្រៀបដូចបុរសអ្នកនេសាទ ចាប់មច្ឆាជាតិ យកអង្រុតទៅរុតត្រី ក្នុងទឹក ហើយលូកដៃចុះ ទៅតាមមាត់អង្រុត គិតនឹងចាប់ត្រី ដោយសេចក្តីត្រេកអរ តែថាជាសត្វ អាសិរពិសសោះ កាលបើចាប់លើកឡើងមក ស្រាប់តែឃើញសត្វអាសិរពិស ទើបខ្លាចតក់ស្លុតរន្ធត់ ឃើញទោសក្នុងការចាប់កាន់នោះ ក៏ប្រាថ្នានឹងលែងចោល សត្វអាសិរពិសនោះទៅវិញ ទើបចាប់ត្រង់កន្ទុយ លាតផ្ទត់ចេញចាកដើមដៃ ហើយលើកឡើង គ្រវីលើក្បាលជាច្រើនជុំ ធ្វើឲ្យសត្វអាសិរពិសនោះទុព្វលភាពថយកម្លាំង មិនអាចនឹងខាំបាន ក៏រលាស់បោះចោលទៅអំពីដៃ ហើយប្រញាប់ប្រញាល់ រត់ឡើងមកលើគោក សម្លឹងមើលផ្លូវ ដែលសត្វអាសិរពិស វារលូនមក សម្លឹងមើលទៅហើយមិនឃើញ ក៏ត្រេកអរ នឹកថាផុតហើយៗចាកភ័យធំ ព្រោះតែសត្វអាសិរពិសនោះ មានឧបមាដូចម្តេចមិញ ឧបមេយ្យថា ដូចជាអ្នកព្យាយាម បានអត្តភាពគឺបញ្ចក្ខន្ធនេះ ក៏ត្រេកអរ ប្រកាន់ខ្ជាប់ថា យើងរបស់យើង ដូចជាបុរសចាប់សត្វអាសិរពិសក្នុងទឹកបាន ហើយត្រេកអរចាប់ទុកជាប់ដោយសំគាល់ថា ជាមច្ឆាជាតិដូច្នោះ។ អ្នកបំពេញព្យាយាម កាលបើឃើញអត្តភាព គឺបញ្ចក្ខន្ធនេះ ថាមិនទៀង ជាទុក្ខ ជាអនត្តាពិតហើយ ក៏មានសេចក្តីភ័យតក់ស្លុតរន្ធត់ខ្លាចបញ្ចក្ខន្ធនោះ ដោយភយតូបដ្ឋានញ្ញាណ ដូចជាបុរសលើកដៃឡើង ចាប់មាត់អង្រុត ហើយឃើញក្បាល សត្វអាសិរពិស ខ្លាចដូច្នោះឯង។ វាយមបុគ្គល កាលបើឃើញទោសរបស់បញ្ចក្ខន្ធនេះ ដោយអាទីនវញ្ញាណហើយ នឿយណាយចំពោះ បញ្ចក្ខន្ធនេះដោយនិព្វិទានោះ នោះបញ្ញារបស់បុគ្គល អ្នកបំពេញព្យាយាម ស្វែងរកឧបាយ ដើម្បីដោះចេញចាកសង្ខារ ដូចពណ៌នាមកដូច្នេះ ឈ្មោះថាបដិសង្ខាញាណ។

**៨- សង្ខារូបេក្ខាញាណ** កាលកំណត់ពិចារណាសង្ខារទាំងអស់ ថាជារបស់សូន្យ ចាកខ្លួនប្រាណសត្វបុគ្គល សូន្យចាកអាការ ជារបស់មិនទៀង ខ្លួនប្រាណជារបស់ល្អ អាការទាំងអម្បាលនោះ មានក្នុងសព្វសង្ខារដូចជាដុំនៃពពុះទឹក និងព្រេញថ្ងៃដូច្នោះ។ កាលបើអ្នកបំពេញ ព្យាយាមបានកំណត់សង្ខារ ទាំងអស់ឲ្យឃើញថា សុទ្ធសឹងអនុវត្តន៍ ដោយបដិសង្ខានុបស្សនា ដូច្នេះហើយ ទើបកំណត់សង្ខារជារបស់សូន្យ មានពីរយ៉ាងគឺ យើងសូន្យចាកសព្វវត្ថុ១ សព្វវត្ថុ សូន្យចាកយើង១។ រួចកំណត់ការសូន្យ ចាក៤យ៉ាងទៀតថា ខ្លួនមិនមានរបស់១ របស់មិនមានខ្លួន១ អ្នកដទៃមិនមានរបស់១ របស់អ្នកដទៃមិនមាន១ មានតែសង្ខារប៉ុណ្ណោះ ទូទៅ

ទាំងអស់ ហើយទើបកំណត់ សង្ខារទាំងអស់ដោយលក្ខណៈ ទាំង៣ថែមទៀត ចិត្តរបស់អ្នក បំពេញព្យាយាមនោះ ក៏អស់តក់ស្លុត អស់ខ្លាច អស់ភ័យ អស់ស្អប់ អស់ស្រឡាញ់ ជាចិត្តព្រងើយៗ ក្នុងសង្ខារ ទាំងអម្បាលនោះ មិនប្រកាន់ថា យើង របស់យើងទៀតឡើយ ដូចជាបុគ្គលមានភរិយា លែងលះគ្នាហើយ លុះទៅជួបគ្នាទៀត ក៏ព្រងើយកន្តើយដោយ សំគាល់ថា មិនមែនជាភរិយារបស់ខ្លួនដូច្នេះ។ បញ្ញារបស់អ្នក បំពេញព្យាយាមបានពិចារណាឃើញ ដូចពោលមកនេះ ហៅថា សង្ខារុបេក្ខាញាណ។ បណ្តាញាណទាំង៣គឺ សង្ខារុបេក្ខាញាណ១ មុញ្ចិតុកាម្យតាញាណ១ និងបដិសង្ខាញាណ១ទាំង៣នេះ បើពោលដោយអត្ថដូចគ្នា តែបើពោលទៅតាមព្យញ្ជនៈវិញ ឃើញថាផ្សេងគ្នា។ ឯសង្ខារុបេក្ខាញាណនេះ ជាកំពូលនៃ វិបស្សនាញាណទាំងអស់។

**៩-អនុលោមញ្ញាណ** អ្នកបំពេញព្យាយាម កាលបើចំរើន សង្ខារុបេក្ខាញាណ លុះគ្រាតែកើតសទ្ធា វិរិយ សតិ សមាធិ និងសង្ខារុបេក្ខាញាណ ចាស់ក្លាហើយ គួរនឹងពោលបានថា អរិយមគ្គកើតឡើងក្នុងកាលឥឡូវនេះ ខណៈនោះសង្ខារុបេក្ខាញាណ កើតឡើងហើយ ក៏ពិចារណាសង្ខារទាំង៣ ដោយលក្ខណៈទាំង៣ឯណានិមួយជា អារម្មណ៍ ទើបយាងចុះកាន់ភវង្គ ក្នុងលំដាប់នៃភវង្គនោះ មនោទ្វារាវជ្ជនៈកើតឡើង ធ្វើលក្ខណៈទាំង៣ឯណានីមួយឲ្យជាអារម្មណ៍ហើយធ្លាក់ចុះកាន់ភវង្គ។ ក្នុងលំដាប់នៃភវង្គនោះ ជវនចិត្តទី១ ធ្វើលក្ខណៈទាំង៣ ឯណានិមួយ ឲ្យជាអារម្មណ៍យ៉ាងនោះ កើតឡើងហើយ បានឈ្មោះថា បរិកម្ម។ ក្នុងលំដាប់នៃបរិកម្មនោះ ជវនចិត្តទី២ ធ្វើលក្ខណៈទាំង៣ ឯណានីមួយ ឲ្យជាអារម្មណ៍ កើតឡើងហើយ ទើបបានឈ្មោះថា ឧបចារៈ។ ក្នុងលំដាប់នៃឧបចារៈនោះ ជវនចិត្តទី៣ ធ្វើលក្ខណៈទាំង៣ ឯណានីមួយ ឲ្យកើតឡើងហើយ ទើបឈ្មោះថា អនុលោម។ ក៏អនុលោមនោះ គឺជាអនុលោមញ្ញាណ នោះឯង ព្រោះញាណនេះ អនុលោមទៅតាម វិបស្សនាទាំង៨ខាងដើម ដោយកិច្ចត្រូវធ្វើ យ៉ាងនេះដូចគ្នា អនុលោមទៅតាម ពោធិបក្ខិយធម៌ ទាំង៣៧ខាងលើដោយផ្លូវប្រតិបត្តិនោះព្រោះហេតុនោះ អនុលោមនេះ ទើបលោកពោលថាជា អនុលោមញ្ញាណ។

ក៏វិបស្សនាញាណទាំង៩ មានឧទយព្វយញ្ញាណជាដើម មានសច្ចានុលោមញ្ញាណ ជាទីបំផុត ឈ្មោះថា បដិបទាញាណទស្សនវិសុទ្ធិ ជាតួវិបស្សនាទី៤។ ក្នុងលំដាប់នៃ អនុលោមញ្ញាណនោះ គោត្រភូចិត្តទាញយក ព្រះនិព្វាននោះ មកជាអារម្មណ៍ កន្លងបថុជ្ជនគោត្រ យាងចុះកាន់អរិយគោត្រ។ គោត្រភូញាណ មិនបានរាប់បញ្ចូលក្នុងបដិបទាញាណទស្សនវិសុទ្ធិឡើយ គឺរាប់បញ្ចូលទៅក្នុងពួក ញាណទស្សនវិសុទ្ធិ ព្រោះតាំងនៅក្នុងទី ជាអាវជ្ជនៈរបស់មគ្គញាណ តាំងនៅក្នុងចន្លោះកណ្តាល គួររាប់ថាជា វិបស្សនាបាន ព្រោះធ្លាក់ចុះទៅនៅ ក្នុងក្រសែរបស់ វិបស្សនា។

**កិរិយាតម្កល់ចិត្តក្នុងសីល**

កិច្ចប្រតិបត្តិក្នុងព្រះពុទ្ធសាសនាដែលជាគោលសំខាន់បំផុតមាន៣យ៉ាងគឺៈ

សីល១ សមាធិ១ បញ្ញា១។ គុណជាតិទាំង៣នេះ គឺសីលជាគុណជាតិដែលយោ គាវចរត្រូវរក្សាមុនជាងគុណជាតិដទៃទាំងអស់ក្នុងកិច្ចប្រតិបត្តិ ដើម្បីប្រព្រឹត្តទៅធ្វើ ឲ្យជាក់ច្បាស់នូវផ្លូវព្រះនិព្វានដែលជាទីរលត់បង់នូវសេចក្តីទុក្ខទាំងពួង។

**-ព្រោះហេតុអ្វី ?**

-ព្រោះថា កាលបើសីលមិនមានក្នុងសន្តានចិត្តនៃយោគាវចរហើយ សមាធិ ការ តម្កល់ចិត្តនឹង ក៏មិនមាន និងមិនអាចញ៉ាំងវិបស្សនាបញ្ញាឲ្យកើតឡើងបានដោយពិត។ មានសេចក្តីនៅក្នុងគម្ពីរវិសុទ្ធិមគ្គភាគ១ ថាៈ បុរសឈរស៊ប់នៅលើផែនដី លើកនូវកាំបិតដែលបានសំលៀងយ៉ាងមុត ហើយកាប់នូវគុម្ពឫស្សីយ៉ាងធំ

បាន មាន សេចក្តីឧបមាយ៉ាងណា យោគាវចរដែលស្ថិតនៅលើផែនដី គឺសីលលើកឡើងនូវ កាំបិត គឺវិបស្សនាបញ្ញា ដែលបានសំលៀងយ៉ាងមុតល្អ ដោយថ្មសំលៀងគឺសមាធិ ដោយដៃគឺ បរិហារិកប្បញ្ញា ដែលផ្គងលើងដោយកម្លាំង នៃសេចក្តីព្យាយាម កាត់ ផ្តាច់នូវបណ្តាញគឺតណ្ហា ដែលធ្លាក់ចុះក្នុងសន្តាននៃខ្លួននោះទាំងអស់បាន ក៏មាន សេចក្តីឧបមេយ្យយ៉ាងនេះដែរ។

**ព្រះពុទ្ធដីកាថា:**

សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដំ នរៈប្រកបដោយបញ្ញា ស្ថិតនៅស៊ប់ក្នុងសីល កាលចម្រើននូវចិត្តផង បញ្ញាផង ជាអ្នកមានសេចក្តីព្យាយាម ជាគ្រឿងដុតកំដៅនូវកិលេសជាប្រក្រតី មានប្រាជ្ញាជា គ្រឿងរក្សាខ្លួន ឃើញភ័យក្នុងសង្សារ នរៈនោះគប្បីកាត់ផ្តាច់នូវបណ្តាញនេះបាន។ បណ្តាធម៌ទាំង៣នេះ សូមលើកយកត្រង់ពាក្យថា សីលដែលជាកិច្ចប្រតិបត្តិដំបូងរបស់ពុទ្ធបរិស័ទក្នុងសាសនានេះ មកបកស្រាយមុនដូចតទៅៈ

**អ្វីជាតួសីល?**

ធម៌៤យ៉ាងគឺ ចេតនា១ ចេតសិក១ សំវរៈ១ អវិតិក្កមៈ១ របស់បុគ្គលវៀរចាកអំ ពើ មានបាណាតិបាតជាដើម ឬថារបស់បុគ្គលកាលបំពេញនូវវត្តិប្រតិបត្តិ ហៅថា សីល ន័យក្នុងបដិសម្ភិទា មានពោលថាៈ

**ចេតនា សីលំ ចេតសិកំ សីលំ សំវរោ សីលំ អវិតិក្កមោ សីលំ** ប្រែថា ចេតនាជាតួសីល ចេតសិកជាតួសីល សេចក្តីសង្រួមជាតួសីល ការមិនប្រព្រឹត្តកន្លងជាតួសីល ។

១- **ចេតនា សីលំ** ចេតនាជាតួសីល ព្រះពុទ្ធដីកាថាៈ ចេតនាហំ ភិក្ខវេ សីលំ វទាមិ ម្នាលភិក្ខុទាំងឡាយ តថាគតហៅថា ចេតនាជាតួសីល។ ចេតនាមានន័យថា ធម្មជាតិអ្នកគិត អ្នកចាត់ចែង អ្នកសន្សំវិគ្គហថាៈ អភិសន្ទហតីតិចេតនា ធម្មជាតិចាត់ចែងហៅថា ចេតនា បានសេចក្តីថាធម្មជាតិដែលញ៉ាំងសម្បយុត្តធម៌ គឺចិត្តនិងចេតសិកដែលប្រ កបជាមួយ ឲ្យហូរចុះទៅក្នុងសីល។ ការគិត គំនិត ការចាត់ចែងរបស់បុគ្គលវៀរចាកបញ្ចវេរា គឺសម្លាប់សត្វ១, ការ កាន់យកទ្រព្យសម្បត្តិដែលគេមិនបានឲ្យ១ ការប្រព្រឹត្តខុសក្នុងកាម១ ការពោល ពាក្យកុហក១ ការផឹកទឹកស្រវឹងមានសុរានិងមេរ័យ១ តាមផ្លូវកាយ ឬផ្លូវវាចា ហៅថាសីល។ ម៉្យាងទៀត ចេតនាក្នុងកម្មបថ៧យ៉ាង គឺកាយកម្ម៣ និងវចីកម្ម៤ របស់បុគ្គល កាលលះបង់នូវអំពើមានកិរិយាញ៉ាំង សត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វជាដើមក៏ហៅថាសីល។

**២- ចេតសិកំ សីលំ** -ចេតសិកជាតួសីល ចេតសិកមានន័យថា ធម្មជាតិមានសេចក្តីកើត សេចក្តីរលត់ អារម្មណ៍និងវត្ថុ ជាមួយគ្នាដោយចិត្ត ហៅថាចេតសិក តែនៅក្នុងទីនេះបានដល់ធម៌៣យ៉ាងគឺៈ

១- **អនភិជ្ឈា** ការមិនសម្លឹងរំពៃចង់បានទ្រព្យរបស់គេ មកធ្វើជាទ្រព្យរបស់ខ្លួន ដែលជាអលោភចេតសិក។

២-**អព្យាបាទោ**ការមិនចងគំនុំចង់ឲ្យសត្វដទៃវិនាសដែលជាអទោសចេតសិក។

៣- **សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ ដែលជាអមោហចេតសិកហៅថាសីល។

ដូចមានព្រះពុទ្ធដីកាជាដើមថាៈ ចេតសិក សីលំ នាម អភិជ្ឈំ បហាយ វិគតាភិជ្ឈេន ចេតសោ វិហរតិបុគ្គលលះបង់នូវអភិជ្ឈា មានចេតនាដែលមាន អភិជ្ឈាទៅប្រោសហើយ គង់នៅ ឈ្មោះថាចេតសិកសីល។

៣- **សំវរោ សីលំ**

សេចក្តីសង្រួមជាតួសីល សេចក្តី**សង្រួម៥**យ៉ាងគឺៈ

១- **បាតិមោក្ខសំវរោ** សេចក្តីសង្រួមនូវកាយ វាចា ទៅតាមសិក្ខាបទដែលមាន នៅក្នុងបាដិមោក្ខ បាន ដល់បរាជិក៤ សង្ឃាទិសេស១៣ អនិយត២ និស្សគ្គិយបាចិត្តយ៣០ សុទ្ធិកបាចិត្តយ៩២ បាដិទេសនិយ៤ សេក្ខិយវត្ត៧៥ អធិករណ សមថ៧ រួមជា២២៧ (សិក្ខាបទសម្រាប់ភិក្ខុសង្ឃ) និងសេចក្តីសង្រួមកាយ វាចា មិន ប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ខាងក្រៅបាតិ មោក្ខបានដល់ពួក សិក្ខាបទ ដែលជាពួកថុល្លច្ចយាបត្តិ ទុក្កដាបត្តិ,ទុព្ភាសិតាបត្តិសីលនេះជាបាតិមោក្ខសំវរសីល។

២- **សតិសំវរោ** សេចក្តីសង្រួមសតិ បានដល់ការសង្រួមឥន្ទ្រិយទាំង៦ គឺៈ ចក្ខុន្ទ្រិយ១ សោតិន្ទ្រិយ១ ឃានិន្ទ្រិយ១ ជីវ្ហិន្ទ្រិយ១ កាយិន្ទ្រិយ១ មនិន្ទ្រិយ១ គឺជាការសង្រួមស្មារតីតាមផ្លូវភ្នែក ត្រចៀក ច្រមុះអណ្តាត កាយ និងចិត្ត ហាមឃាត់ មិនឲ្យអកុសលធម៌ គឺអភិជ្ឈា និងទោមនស្ស និងបាបធម៌ កើតឡើងគ្របសង្កត់ចិត្ត បាន ក្នុងខណៈដែលមានអារម្មណ៍ មានរូបារម្មណ៍ជាដើម មកប៉ះខ្ទប់នឹងទ្វារ មាន ចក្ខុទ្វារជាដើម។ សីលនេះ ជា ឥន្ទ្រិយសំវរសីល។

៣- **ញាណសំវរោ** សេចក្តីសង្រួមញាណ (ការដឹង) បានដល់ប្រាជ្ញាដែលតម្កល់ ដោយប្រពៃ ពិចារណាក្នុងការប្រើប្រាស់នូវបច្ច័យ៤ គឺ ចីវរប្បច្ច័យ១ បិណ្ឌបាត បច្ច័យ១ សេនាសនបច្ច័យ១ គិលាន ភេសជ្ជបច្ច័យ១ តាមសមគួរដល់ធម៌នៃការ ប្រើប្រាស់បច្ច័យ របស់អ្នកបួសមានធាតុបច្ចវេក្ខណៈជាដើម។ សីលនេះជាបច្ចយសន្និស្សិតសីល។

៤- **ខន្តិសំវរោ** សេចក្តីសង្រួមក្នុងការអត់ទ្រាំគ្រប់យ៉ាង ចំពោះត្រជាក់និងក្តៅ លោកធម៌៨គឺ លាភ១ យស១ អយស១ និន្ទា១ សរសើរ១ សុខ១ ទុក្ខ១ ជាដើម ដែលកើតឡើងដល់ខ្លួន។

៥- **វិរិយសំវរោ** សេចក្តីសង្រួមនូវការព្យាយាម បានដល់នូវការព្យាយាមអត់ សង្កត់ កម្ចាត់បង់នូវ អកុសលវិតក្កៈ៣គឺ កាមវិតក្កៈ សេចក្តីត្រិះរិះពីកាម១ ព្យាបាទ វិតក្កៈ សេចក្តីត្រិះរិះពីព្យាបាទ១ វិហិង្សាវិតក្កៈ សេចក្តីត្រិះរិះបៀតបៀនសត្វ១ ដែលកើតឡើងគ្របសង្កត់ចិត្ត។

សេចក្តីសង្រួម៥យ៉ាង និងចេតនាវៀរចាកចំពោះវត្ថុដែលដល់ព្រមរបស់កុលបុត្ត ដែលជាអ្នកភ័យ ខ្លាចក្នុងបាប ក៏ហៅថា សំវរសីលទាំងអស់។

**៤- អវិតិក្កមោសីលំ** ការមិនប្រព្រឹត្តកន្លងជាតួសីល បានដល់ការមិនប្រព្រឹត្តកន្លង ដែលប្រកបដោយ កាយ វាចា របស់បុគ្គលដែលបានសមាទានសីល មានសីល៥ជាដើម។ ឧបាសក ឧបាសិកាដែលបាន សមាទានសីលពីបុគ្គល ឬព្រះសង្ឃហើយ ក៏ប្រឹងសង្រួមកាយ វាចា ដោយប្រពៃតាមសិក្ខាបទដែលខ្លួនបាន សមាទានហើយ គឺមិនប្រព្រឹត្តកន្លងនូវ សិក្ខាបទណាមួយឡើយ។ សីលរបស់ឧបាសក ឧបាសិកា ដែលកើត ឡើងនេះឯង ហៅថា អវិតិក្កមសីល។

**ពួកអរិយសច្ចៈ**

អរិយសច្ចៈគឺជាសេចក្តីពិតដ៏ប្រសើរមាន៤យ៉ាងគឺៈ

១ **ទុក្ខសច្ចៈ** សភាវៈពិតគឺទុក្ខ។

២ **សមុទយសច្ចៈ** សភាវៈពិតគឺហេតុដែលនាំឱ្យកើតទុក្ខ។

៣ **និរោធសច្ចៈ** សភាវៈពិតគឺ ការរំលត់ទុក្ខ។

៤ **មគ្គសច្ចៈ** សភាវៈពិតគឺ ផ្លូវរំលត់ទុក្ខ។

**ទុក្ខសច្ចៈ**គឺសេចក្តីទុក្ខដែលមិនគួរប្រាថ្នា មិនគួរពេញចិត្ត បែងចែកជាបីប្រភេទគឺៈ

-**ជាតិទុក្ខ** ទុក្ខគឺការកើតដែលជាការឧបត្តិរបស់រូបនាមក្នុងភពមួយៗ។

-ជរាទុក្ខ ទុក្ខគឺការចាស់នៃរូបនាម ដែលកើតឡើងយ៉ាងបន្តបន្ទាប់។

- **មរណទុក្ខ** ទុក្ខគឺសេចក្តីគឺស្លាប់ ជាការរលត់សូន្យរបស់រូបនាម ដោយមិនកើតឡើងទៀតក្នុងភព នោះៗ។

**ក្រៅពីនេះទុក្ខនៅមាន៧ប្រភេទទៀតគឺ:**

-**ទុក្ខទុក្ខ** ទុក្ខដែលអត់ទ្រាំបានដោយលំបាក គឺសេចក្តីទុក្ខតាមផ្លូវកាយដែលមានការឈឺចុកចាប់ ឬ សេចក្តីទុក្ខផ្លូវចិត្តដែល បានការមិនសប្បាយចិត្ត សេចក្តីសោកសង្រេងចិត្ត។

-**វិបរិណាមទុក្ខ** ទុក្ខព្រោះការប្រែប្រួល គឺសេចក្តីទុក្ខតាមផ្លូវកាយនិងចិត្ត ដែលមិនបានគង់វង្សរហូតទៅ ការប្រែប្រួលទៅ ធ្វើឱ្យអ្នកដែលបានទទួលនូវសេចក្តីសុខបែរជាកើតទុក្ខវិញ។

-**សង្ខារទុក្ខ** ទុក្ខប្រចាំសង្ខារគឺរូបនាម ទាំងអស់ដែលជាលោកិយធម៌ ព្រមទាំងឧបេក្ខាវេទនា វៀរលែងតណ្ហាចេញ សង្ខារទុក្ខនេះគ្របដណ្តប់សេចក្តីទុក្ខក្នុងទុក្ខសច្ចៈទាំងអស់សូម្បី សុខវេទនា និងទុក្ខវេទនាក៏រាប់ថាជាសង្ខារទុក្ខដូចគ្នា។ ដូចសេចក្តីក្នុងសឡាយតនវគ្គវេទនាសំ យុត្តថាៈ តំ ខោ បនេតំ ភិក្ខុ មាយា សង្ខារនំ អនិច្ចតំ សន្ធាយ ភាសិតំ យំកិញ្ចិ វាទយិតំ តំទុក្ខស្មិន្តិ ម្នាលភិក្ខុទាំងឡាយវេទនាយ៉ាងណានីមួយ មាននៅវេទនានោះជាទុក្ខតថាគតពោលដល់ ការមិនទៀងរបស់សង្ខារទាំងឡាយ។

សូម្បីសុខវេទនានិងទុក្ខវេទនា នឹងរាប់ថាជាសង្ខារទុក្ខដូចគ្នា តែសុខវេទនាជាហេតុនាំ ឲ្យកើតទុក្ខការប្រែប្រួលអំពីដើមទើបមានទើបឈ្មោះថាវិបរិណាមទុក្ខនិងទុក្ខវេទនាក៏ជាទុក្ខ ដែលអត់ទ្រាំបានដោយលំបាកយ៉ាងពិតប្រាកដ ទើបឈ្មោះថាទុក្ខទុក្ខ។

-**បដិច្ឆន្នទុក្ខ** ទុក្ខបិតបាំង គឺទុក្ខដែលអ្នកដទៃទទួលដឹងមិនបាន ដូចជាឈឺក្បាល ឈឺធ្មេញ ក្តៅខ្លួន សេចក្តីលំបាកកាយលំបាកចិត្ត សេចក្តីទោសមនស្សខូចចិត្ត កន្លែងខ្លះហៅថា អនាដកទុក្ខ គឺទុក្ខមិនប្រាកដច្បាស់។

-**អបដិច្ឆន្នទុក្ខ** ទុក្ខមិនបិទបាំង ដូចជាសេចក្តីទុក្ខផ្លូវកាយ ដូចកើតអំពីកាំបិតមុត លំពែង មុត បន្លាមុត បូស ខ្លះហៅថា បាដកទុក្ខ គឺទុក្ខប្រាកដច្បាស់។

-**និប្បរិយាយទុក្ខ** ទុក្ខដោយត្រង់គឺទុក្ខវេទនា

-**បរិយាយទុក្ខ** ទុក្ខដោយអម គឺជាតិទុក្ខជាដើម ក្រៅអំពីទុក្ខវេទនា សូម្បីទុក្ខទាំងនេះនឹង មិនមែនសភាពដែលអត់ធន់ដោយលំបាក ក៏ជាហេតុកើតរបស់សេចក្តីទុក្ខតាមផ្លូវកាយ និងផ្លូវ ចិត្តក្នុងឱកាសតទៅ។

-**ជាតិទុក្ខ** ជរាទុក្ខ និមរណទុក្ខ ចាត់ជាទុក្ខសច្ចៈព្រោះជាទុក្ខដោយអម សូម្បីសេចក្តីសោយសោក សេចក្តីខ្ទួញយំ សេចក្តីទុក្ខកាយ សេចក្តីទុក្ខចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តក៏ ចាត់ជាទុក្ខសច្ចៈដូចគ្នា ព្រោះជាទុក្ខដោយត្រង់ ពិតមែនហើយជាតិជាដើមកើតអំពីឧបាទានក្ខន្ធ៥ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ បើមិនមានឧបាទានក្ខន្ធហើយ ការកើតជាដើមក៏មិនមានបាន ដូច្នោះការពោលដោយសង្ខេបឧបាទានក្ខន្ធ៥ ដែលប្រាកដក្នុងខណៈឃើញ បានលឺជា ដើមទើបឈ្មោះថាទុក្ខព្រោះជាទុក្ខប្រចាំសង្ខារ ដែលប្រែប្រួល និងជាទីតាំងនៃជាតិទុក្ខជាដើម។

**សមដូចព្រះពុទ្ធវចនថា:**

កតមញ្ច ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។ ជាតិបិទុក្ខា ជរាបិទុក្ខា មរណម្បិទុក្ខំ សោកបរិទេវទុក្ខ ទោមនស្សុបា

យាសាបិទុក្ខា អប្បិយេហិសម្បយោគោទុក្ខោ បិយេហិ វិប្បយោគោទុក្ខោ យម្បិច្ឆំនលភតិតម្បិទុក្ខំ សង្ខិត្តេន បញ្ចុប្បាទានក្ខន្ធាទុក្ខា។

ម្នាលភិក្ខុទាំងឡាយចុះទុក្ខអរិយសច្ចៈនោះតើដូចម្តេច? ជាតិកំណើតការកើតដំបូងក៏ជាទុក្ខ ជរាគឺការចាស់គ្រាំក៏ជាទុក្ខមរណៈគឺសេចក្តីស្លាប់ក៏ជាទុក្ខសោកៈគឺសេចក្តីសោកស្រណោះក៏ជាទុក្ខ បរិទេវៈ សេចក្តីក្សឹកក្សួល ទុក្ខសេចក្តីលំបាកកាយ ទោមនស្ស គឺសេចក្តីអាក់អន់តូចចិត្ត ឧបាយាស គឺសេចក្តីចង្អៀតចង្អល់ចិត្តក៏សុទ្ធតែជាទុក្ខ។ អប្បិយេហិសម្បយោគោ គឺដំណើរជួបប្រសព្វសត្វ និងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ក៏ជាទុក្ខ បិយេហិវិប្បយោគោគឺសេចក្តីព្រាត់ប្រាស់សត្វ និងសង្ខារទាំងឡាយក៏ជាទុក្ខ យម្បិច្ឆំ នលភតិតម្បិ គឺបុគ្គលកាល ចង់បាននូវរបស់ណាមិនបាន ឯការមិនបានរបស់នោះក៏ជាទុក្ខ។ បើដោយសេចក្តីបំព្រួញឧបាទានក្ខន្ធ៥មានរូបាទានក្ខន្ធជាដើមគឺជាសេចក្តីទុក្ខ។

**សមុទយសច្ចៈ** គឺតណ្ហាដែលភ្លើតភ្លើនត្រេកអរ ឧបាទានក្ខន្ធ៥ថាជាវត្ថុល្អស្អាត ជាទីពេញចិត្ត អ្នកដែលមានតណ្ហារមែងធ្វើនូវកម្មល្អ ឬកម្មអាក្រក់ដោយសេចក្តីត្រូវការ និងជាសុខឱ្យខ្លួនក្នុងបច្ចុប្បន្ន ឬអនាគតកម្មដែលបុគ្គលបានធ្វើទុកក្នុងមួយភព១ ទើបមានច្រើនសន្ធឹកសន្ធាប់រាប់មិនអស់គ្រប់យ៉ាង កម្មដែលនឹងឲ្យផលក្នុងបដិសន្ធិនោះ ជាកម្មយ៉ាងណានីមួយដែលមានកម្លាំង ធ្វើពេលជិតស្លាប់ ឬសន្សំទុកជានិច្ច រមែងប្រាកដឱ្យមកជាអារម្មណ៍ក្នុងពេលជិតស្លាប់ ឬអារម្មណ៍ដែលជាឧបករណ៍របស់កម្មនោះៗ ជាផ្កាឈើបូជាព្រះ ឬអារម្មណ៍ជាទីតាំង របស់ភពថ្មី ដូចវិមានរមែងមកប្រាកដដូចសុបិនឃើញអ្នកតោងយកអារម្មណ៍ទាំងបីគឺកម្ម កម្មនិមិត្ត ឬគតិនិមិត្តយ៉ាងណានីមួយទុកហើយរមែងទៅកើតក្នុងភពនោះៗក្រោយអំពីអស់ជីវិត ហើយដោយមានឧបាទានក្ខន្ធ៥ឧប្បត្តិឡើងក្នុងភពនោះ។

**និរោធសច្ចៈមានព្រះពុទ្ធភាសិតថាៈ**

កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ យោតស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិអនាលយោ។

ម្នាលភិក្ខុទាំងឡាយចុះដូចម្តេចដែលហៅថាទុក្ខនិរោធអរិយសច្ចៈ? ការអស់ទៅនិងការ រលត់ទៅដោយមិនមានសេសសល់ ការលះបង់ ការរលាស់ចោល ការដម្រុះចោល ការមិនមានអាល័យចំពោះតណ្ហានោះឯង ហៅថា ទុក្ខនិរោធអរិយសច្ចៈ។

**៣.២ មគ្គសច្ចៈ គឺអរិយមគ្គប្រកបដោយអង្គទាំង៨ដែលមានព្រះពុទ្ធដីការថាៈ**

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមនី បដិទាអរិយសច្ចំ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថិទំ សម្មាទិដ្ឋិសម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ។

ម្នាលភិក្ខុទាំងឡាយ អរិយសច្ចៈ គឺមគ្គដែលជាផ្លូវទៅទុក្ខ បានដល់អរិយមគ្គប្រកបដោយ អង្គ៨ប្រការនោះឯងពោលគឺ ការយល់ត្រូវ១ ការត្រិះរិះត្រូវ១ វាចាត្រូវ១ ការងារត្រូវ១ ការចិញ្ចឹមជីវិតត្រូវ១ ការព្យាយាមត្រូវ១ ការរឭកត្រូវ១ ការដំកល់ចិត្តឱ្យនឹងត្រូវ១។ទាំងនេះឯង ហៅថាអរិយមគ្គប្រកបដោយអង្គ៨។

**អានិសង្សនៃការចម្រើនសតិប្បដ្ឋាន ឬវិបស្សនាភាវនា**

អ្នកដែលចម្រើនសតិបដ្ឋាន តាមសតិបដ្ឋានទេសនានេះ រមែងសម្រេចមគ្គផលនិងនិព្វាន ជាអ្នកលះកិលេសបានដោយមិនមានសេសសល់ អាចរម្ងាប់ការសោយសោក និងការរួញរា រលត់ទុក្ខផ្លូវកាយ និងទោមនស្សផ្លូវចិត្តក្នុងភពនេះ បានទទួលទុក្ខ និងទោមនស្សទៀត លោកជាអ្នកសម្រេចមគ្គញ្ញាណ៤ សោតា

បត្តិមគ្គញ្ញាណ សកទាមិមគ្គញ្ញាណ អនាគាមិមគ្គញ្ញាណ អរហត្តមគ្គញ្ញាណ ព្រមទាំងដឹងច្បាស់ព្រះនិព្វាន ដែលជាសភាពរំលត់ទុក្ខទាំងពួង សមពិតដូចព្រះពុទ្ធវចនៈក្នុងមហាសតិប្បដ្ឋានសូត្រថាៈ ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ នព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោសតិប្បដ្ឋានា។

ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវតែមួយ ដែលនឹងធ្វើឱ្យពួកសត្វបរិសុទ្ធបាន កន្លងផុតពីសេចក្ដីសោក និងសេចក្ដីយំសោករៀបរាប់បាន រលត់ទុក្ខនិងទោសមនស្សបាន សម្រេចអរិយមគ្គនិងឃើញច្បាស់ព្រះនិព្វាន បានផ្លូវនេះគឺសតិប្បដ្ឋាន៤ប្រការ។

ការចម្រើនសតិប្បដ្ឋាននេះគឺជាផ្លូវមួយ ដើម្បីលះកិលេសដឹងច្បាស់ព្រះនិព្វាន ដូច្នោះអ្នកដែលចម្រើនសតិប្បដ្ឋាន ដោយការកំណត់ដឹងកងរូប វេទនាចិត្តនិងសភាវធម៌ ដែលជាបរមត្ថសុទ្ធៗ ទើបអាចសម្រេចចំណុចប្រាថ្នា ក្នុងការបដិបត្តិធម៌គឺ ការរួចផុតអំពីវដ្ដសង្សារបាន ម្យ៉ាងទៀត ការចម្រើនសតិប្បដ្ឋាន ហៅថា វិបស្សនាភាវនា ការចម្រើនវិបស្សនាក៏បាន។

### ១០.៤.៣. សារប្រយោជន៍សមាធិ

ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថ-បិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូល ព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកសីលជាកុសល មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស? ម្នាលអានន្ទ ពួកសីលជាកុសល មានអវិប្បដិសារៈ (សេចក្តីមិនក្តៅក្រហាយ) ជាប្រយោជន៍ មានអវិប្បដិសារៈ ជាអានិសង្ស។ បពិត្រព្រះអង្គដ៏ចម្រើន ចុះអវិប្បដិសារៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស? ម្នាលអានន្ទ អវិប្បដិសារៈ មានបាមុជ្ជៈ (សេចក្តីរីករាយ) ជាប្រយោជន៍ មានបាមុជ្ជៈជាអានិសង្ស។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបាមុជ្ជៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស? ម្នាលអានន្ទ បាមុជ្ជៈ មានបីតិ (សេចក្តីឆ្អែតចិត្ត) ជាប្រយោជន៍ មានបីតិជាអានិសង្ស។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបីតិ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស? ម្នាលអានន្ទ បីតិ មានបស្សទ្ធិ (សេចក្តីស្ងប់) ជាប្រយោជន៍ មានបស្សទ្ធិ ជាអានិសង្ស។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបស្សទ្ធិ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស? ម្នាលអានន្ទ បស្សទ្ធិ មានសុខៈជាប្រយោជន៍ មានសុខៈជាអានិសង្ស។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសុខៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស? ម្នាលអានន្ទ សុខៈ មានសមាធិ ជាប្រយោជន៍ មានសមាធិ ជាអានិសង្ស។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសមាធិ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស? ម្នាលអានន្ទ សមាធិ មាន**យថាភូតញ្ញាណទស្សនៈ** (វិបស្សនាញាណទន់ខ្ចី) ជាប្រយោជន៍ មាន**យថាភូតញ្ញាណទស្សនៈ** ជាអានិសង្ស។ បពិត្រព្រះអង្គដ៏ចម្រើន ចុះ**យថាភូតញ្ញាណទស្សនៈ** មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស? ម្នាលអានន្ទ **យថាភូតញ្ញាណទស្សនៈ** មាននិព្វិទា និងវិរាគៈ (វិបស្សនាញាណដ៏មានកម្លាំង និងមគ្គ) ជាប្រយោជន៍ មាននិព្វិទា និងវិរាគៈ ជាអានិសង្ស។ បពិត្រព្រះអង្គដ៏ចម្រើន ចុះនិព្វិទា និងវិរាគៈ មានអ្វីជាប្រយោជន៍ មានអ្វីជាអានិសង្ស? ម្នាលអានន្ទ និព្វិទា និងវិរាគៈ មានវិមុត្តិញ្ញាណទស្សនៈ (អរហត្តផល និងបច្ចវេក្ខណញ្ញាណ) ជាប្រយោជន៍ មានវិមុត្តិញ្ញាណទស្សនៈ ជាអានិសង្ស។ ម្នាលអានន្ទ ពួកសីលជាកុសល មានអវិប្បដិសារៈ ជាប្រយោជន៍ មានអវិប្បដិសារៈ ជាអានិសង្ស អវិប្បដិសារៈ មានបាមុជ្ជៈ ជា

ប្រយោជន៍មានបាមុជ្ជៈ ជាអានិសង្ស បាមុជ្ជៈ មាន បីតិ ជាប្រយោជន៍ មានបីតិ ជាអានិសង្ស បីតិ មានបស្សទ្ធិ ជាប្រយោជន៍ មានបស្សទ្ធិ ជាអានិសង្ស បស្សទ្ធិ មានសុខៈ ជាប្រយោជន៍ មានសុខៈ ជាអានិសង្ស សុខៈ មានសមាធិជាប្រយោជន៍ មានសមាធិ ជាអានិសង្ស សមាធិ មាន**យថាភូតញ្ញាណទស្សនៈ**ជាប្រយោជន៍ មាន**យថាភូតញ្ញាណទស្សនៈ** ជាអានិសង្ស **យថាភូតញ្ញាណទស្សនៈ**មាននិព្វិទា និងវិរាគៈ ជាប្រយោជន៍ មាននិព្វិទា និងវិរាគៈជាអានិសង្ស និព្វិទា និងវិរាគៈ មានវិមុត្តិញ្ញាណៈទស្សនៈ ជាប្រយោជន៍ មានវិមុត្តិញ្ញាណទស្សនៈ ជាអានិសង្ស ដោយប្រការដូច្នេះឯង។ ម្នាលអានន្ទ ពួកសីលជាកុសល រមែងញ៉ាំងធម៌ទាំងនោះ ឲ្យពេញតាមលំដាប់ ដើម្បីព្រះអរហត្តដោយប្រការដូច្នេះ[48]។

**គុណប្រយោជន៍នៃការធ្វើសមាធិ (សម្រាប់ភាពសាមញ្ញៗនៃជីវិត)**

ធ្វើសមាធិអាចទប់ស្កាត់ភាពចាស់ជរា

សមាធិ ជាការអនុវត្ត ដ៏ចំណាស់មួយ ក្នុងពុទ្ធសាសនា។ នៅពេលឮពាក្យថាសមាធិភ្លាម នោះគេនឹកគិតភ្លែតដល់ធម៌ ដល់សាសនា។ ប៉ុន្តែចាប់ពីជាង២០ឆ្នាំចុងក្រោយនេះមក សមាធិ បានទទួលការស្វាគមន៍ពីសំណាក់ពិភពវេជ្ជសាស្ត្រនិងវិទ្យាសាស្ត្រ។ សមាធិ មានគុណប្រយោជន៍ច្រើនណាស់សម្រាប់សុខភាព ប្រសិនយើងអនុវត្តធ្វើជាប្រចាំ រៀងរាល់ថ្ងៃពី១០ទៅ៣០នាទីម្តង និងក្នុងរយៈពេលជាច្រើនឆ្នាំ។ ធ្វើសមាធិអាចពន្យឺតភាពចាស់ទ្រុឌទ្រោមនៃខួរក្បាល និងជួយឱ្យខួរក្បាលមានសមត្ថភាពប្រសើរឡើង ព្រមទាំងអាចជួយគ្រប់គ្រងអារម្មណ៍បានទៀត កាត់បន្ថយអារម្មណ៍ឡើងស្ត្រេស និងសម្រួលដំណេក។

នៅពេលឮពាក្យថា សមាធិ យើងនឹងនឹកគិតដល់ភ្លាម ដល់ការប្រារព្ធសាសនា ប៉ុន្តែតាំងពីឆ្នាំ១៩៧០មក គ្រូពេទ្យឯកទេសផ្នែកចិត្តសាស្ត្រជាតិអាមេរិក បានប្រែក្លាយសមាធិជាវិធីសាស្ត្រព្យាបាលសម្រួលផ្លូវចិត្តអារម្មណ៍ ដែលលែងមានលក្ខណៈសាសនា។ នៅឆ្នាំ១៩៧៩ សាស្ត្រាចារ្យវេជ្ជសាស្ត្រ Jon Kabat-Zinn បានសម្រេចរៀបចំជាកម្មវិធីសិក្សាសមាធិរយៈពេល៨សប្តាហ៍មានឈ្មោះថា MBSR "Mindfulness based stress reduction" ដែលប្រែតាមពាក្យមួយបានថា កាត់បន្ថយស្ត្រេសទាំងនៅមានស្មារតីពេញ។

តាំងពីនោះមក ការធ្វើសមាធិបានក្លាយជាជម្រើសកាន់តែច្រើនឡើងៗ របស់ពិភពវេជ្ជសាស្ត្រ! ក្រុមគ្រូពេទ្យអាមេរិក បានចាប់ផ្តើមមុនគេ បន្ទាប់មកគឺបារាំង។ សមាធិទំនងជាផ្តល់ប្រយោជន៍ច្រើនដល់សុខភាព និងផ្តល់ឥទ្ធិពលល្អដល់ខួរក្បាល ដូចជា លើកទឹកចិត្ត កាត់បន្ថយស្ត្រេស បង្កើនការផ្តុំអារម្មណ៍ បំភ្លេចការឈឺចុកចាប់រ៉ាំរ៉ៃ និងជួយសម្រួលដំណេក។

**សមាធិបច្ចេកទេសប្រឆាំងនឹងស្ត្រេស**

ជាច្រើនឆ្នាំចុងក្រោយមកនេះ សមាធិលែងមានរូបភាពជាសាសនាទៀតហើយ! សមាធិត្រូវបានគេរាប់ជាបច្ចេកវិទ្យាប្រយុទ្ធប្រឆាំងនឹងការឡើងស្ត្រេស និងជំងឺគេងមិនលក់ទៅវិញ ដ៏ពេញនិយម។ នៅអឺរ៉ុបជាក់ស្តែងនៅបារាំង គេអាចរករៀនធ្វើសមាធិ នៅតាមមជ្ឈមណ្ឌលសម្រាកលំហែ មិនមែននៅតែតាមទីវត្តអារាម ឬទីសាសនាទេ។ សមាធិ គឺជាការផ្តល់ពេលវេលាឱ្យខ្លួនឯង អង្គុយនិងអង្កេតមើលស្ថានភាពអារម្មណ៍ ស្វែងរក ភាពស្ងប់ និងភាពធូរស្បើយ ឆ្ងាយពីភាពពុះកញ្ជ្រោល សំឡេង សម្ពាធ ពីថ្ងៃ។ នៅពេលអារម្មណ៍បានស្ងប់ មូលល្អ នោះស្ត្រេសក៏ធ្លាក់ចុះ ហើយការងោគងងុយនឹងលេចឡើង ដំណេកក៏បានស្ងប់ល្អដែរ។

[48] សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត ឯកាទសមភាគ អានិសង្សវគ្គភាគ៥០ ទំព័រទី ១ ដល់ ៣

បង្កើតឱកាសស្ងប់ល្អ ចេះស្តាប់អារម្មណ៍និងសរីរាង្គខ្លួនប្រាណ ផ្តោតឬផ្ចង់អារម្មណ៍ទៅលើចលនាដង្ហើម ទៅលើពេលវេលាជាក់ស្តែង នេះហើយជាកម្មវត្ថុនៃហាត់រៀនធ្វើសមាធិ ដែលតែងអាចប្រព្រឹត្តជាក្រុម (១ម្តងមួយម៉ោង) ដោយម្នាក់ឯង។ ស្តាប់ទៅងាយទេ តែជាលំហាត់ដ៏លំបាក។

ក្រៅអំពីជាលំហាត់សម្រាកលំហែអារម្មណ៍ ការធ្វើសមាធិ ពិភពវេជ្ជសាស្ត្របានងាកមកជ្រើសរើសប្រើជាវិធីសាស្ត្រព្យាបាលទប់ស្កាត់ការលាប់ជំងឺធ្លាក់ទឹកចិត្ត ឬហៅថាវិធីសាស្ត្រព្យាបាលអារម្មណ៍ទាំងនៅមានស្មារតីពេញលេញ។ ដើម្បីប្រឈមរស់ជាមួយនឹងជំងឺមហារីក គ្រូពេទ្យឯកទេសនៅប្រទេសលោកខាងលិចក៏បានស្នើឱ្យ អ្នកមានផ្ទុកជំងឺមហារីក អ្នកកំពុងទទួលការព្យាបាល ឬអ្នកទើបងើបពីឈឺ ប្រតិបត្តិការធ្វើសមាធិជាប្រចាំ។

**សមាធិកាត់បន្ថយភាពចាស់ជរា**

ស្រទាប់ប្រព័ន្ធប្រសាទដ៏ក្រាស់ក្នុងលលាដក្បាលមនុស្ស មាននិន្នាការស្រុតចុះទៅតាមភាពចាស់ជរារបស់យើង។ ការធ្វើសមាធិ ពន្យឺតការស្រុតស្រទាប់ប្រព័ន្ធប្រសាទផង និងទន្ទឹមពេលជាមួយគ្នានោះ វាក៏អាចបន្ថយល្បឿននៃភាពចាស់ទ្រុឌទ្រោមរបស់ខួរក្បាលផង។ ការសិក្សាលើខួរក្បាលអ្នកធ្វើសមាធិ ជាច្រើនឆ្នាំ និងជាច្រើន ម៉ោង (ចាប់ពី ១៥០០០ ទៅ៣ម៉ឺនម៉ោង) សមាធិ ចាប់មានឥទ្ធិពល និងចាប់មានប្រសិទ្ធភាពលើខួរក្បាល មិនឱ្យចាស់ជរាទៅតាមអាយុ ពេលគឺបើតាមរូបភាពអ្នកធ្វើសមាធិ រក្សាម៉ាសមាឌខួរក្បាលបានល្អជាង និងស្រុតចុះតិចជាង អ្នកមិនធ្វើសមាធិ ដែលមានវ័យស្របាលគ្នា។

ជាធម្មតា ខ្លួនប្រាណមនុស្សយើងមានអារម្មណ៍ មានញាណទទួលដឹងអ្វីៗសព្វយ៉ាង គឺដោយសារតែការផ្តល់សញ្ញា ផ្តល់ព័ត៌មាន ប្រទាក់គ្នាឆ្លងពីប្រព័ន្ធប្រសាទមួយទៅប្រព័ន្ធប្រសាទមួយទៀត។ ហើយការធ្វើសមាធិនឹងសម្រួល ឱ្យប្រព័ន្ធប្រសាទមានចំណងប្រទាក់ភ្ជាប់គ្នាថ្មីៗបន្ថែមទៀត។ មានន័យថា បុគ្គលណាបានធ្វើសមាធិ ងាយនឹងចងចាំ ទទួលយក និងឆាប់ចេះ នូវអ្វីដែលថ្មី ព្រោះខួរក្បាលមានដំណើរការល្អ។ម្យ៉ាងវិញ ការធ្វើសមាធិទំនងជាបានមនុស្សយើងឱ្យងាយសម្របខ្លួននៅនឹងស្ថានការណ៍ ព្រមទាំងមានទឹកចិត្តស្រស់ថ្លាប្រសើរឡើង។

ការសិក្សា ថ្មីបន្ថែម នឹងអាចវាយតម្លៃអំពីឥទ្ធិពលនៃការធ្វើសមាធិចំពោះការវិវឌ្ឍ នៃទំហំខួរក្បាលដែលចេះតែរួញទៅ ទៅតាមវ័យចំណាស់របស់មនុស្ស និងដែលធ្វើមនុស្សចាស់បាត់បង់បន្តិចម្តងការយល់ដឹងនិងការចងចាំ។ គ្រូពេទ្យឯកទេសមនុស្សចាស់ ចាប់អារម្មណ៍ខ្លាំងណាស់ នឹងវិធីសាស្ត្រធ្វើសមាធិ ទាំងនៅមានស្មារតីពេញលេញ។ ស្ត្រេស មានកង្វល់ និងធ្លាក់ទឹកចិត្ត សុទ្ធសឹងជាកត្តាដែលនាំឆាប់កើត ឆាប់មានការវិវត្តជំងឺវង្វេងវង្វាន់ ហើយអ្នកស្រាវជ្រាវលើកឃើញសមាធិ ជាវិធីសាស្ត្រមួយសម្រាប់ទប់ស្កាត់ ឬកំរិតផលវិបាកនៃសង្គមព្រោះជំងឺវង្វេងវង្វាន់។ អ្នកស្រាវជាវ ជាតិបារាំង បែលហ្សិក អង់គ្លេស អាល្លឺម៉ង់ ស្វីស អេស្ប៉ាញ កំពុងសិក្សារួមគ្នាលើមនុស្សចាស់ចាប់អាយុ៦៥ឆ្នាំឡើងទៅ អំពីឥទ្ធិពលនៃការធ្វើសមាធិ និងការសិក្សាភាសាបរទេស ចំពោះភាពចាស់នៃខួរក្បាល ដែលនឹងអាចផ្តល់លទ្ធផលនៅក្នុងពេលឆាប់ៗខាងមុខ។

**សមាធិសម្រួលការគ្រប់គ្រងអារម្មណ៍**

ឥទ្ធិពលមួយទៀតរបស់សមាធិ គឺឥទ្ធិពលទៅលើអារម្មណ៍! ខួរក្បាលមនុស្សមានពីរភាគ អារម្មណ៍វិជ្ជមាននៅភាគខាងឆ្វេង និងអារម្មណ៍អវិជ្ជមាននៅខួរក្បាលផ្នែកខាងស្តាំ។ចំពោះអ្នកធ្វើសមាធិ ដែនអារម្មណ៍វិជ្ជមាននឹងរីករាលឆ្លងទៅស៊ីខ្វេងចូលដល់ក្នុងដែនអារម្មណ៍អវិជ្ជមាន។ ដោយសារតែមូលហេតុនេះហើយ ទើប

នៅប្រទេសលោកខាងលិច មានអ្នកចូលចិត្តធ្វើសមាធិកាន់តែច្រើនឡើងៗ។ ថ្វីបើការធ្វើសមាធិ បាននាំឱ្យយើងមានភាពធូរស្បើយក្នុងអារម្មណ៍មែន ប៉ុន្តែ សមាធិគ្មានលទ្ធិពលលើអាកប្បកិរិយារបស់យើងទេ។ នេះបើគេជឿតាមការសិក្សាវិទ្យាសាស្ត្រចំនួន២០ដែលបានវិភាគឃើញថាការធ្វើសមាធិ បាននាំឲ្យបុគ្គលអ្នកធ្វើនោះស្រស់ស្រាយ ចេះយោគយល់ចិត្ត អារម្មណ៍ល្អ បាត់ទុក្ខកង្វល់ ធ្លាក់ស្ត្រេសមែន តែមានកម្រឹតបំផុតចំពោះអត្តចរិក អាកប្បកិរិយាពីកំណើត។

ប៉ុន្តែសូមចងចាំថា ទោះធ្វើសមាធិជាវិធីសាស្ត្រព្យាបាលជំងឺ ឬដើម្បីបន្ធូរអារម្មណ៍ក្តី ក៏សមាធិអាចមានប្រសិទ្ធភាពល្អិកណាតែអ្នកអនុវត្តធ្វើជាប្រចាំ ដោយញឹកញាប់ ឬប្រសើរបំផុតត្រូវធ្វើជារៀងរាល់ថ្ងៃ។ ប៉ុន្តែមិនមែនដាច់ខាតត្រូវទៅធ្វើនៅមជ្ឈមណ្ឌល ឬមណ្ឌលសាសនាទេ មានវិធីរៀនធ្វើសមាធិច្រើនបែបច្រើនយ៉ាងណាស់ និងធ្វើនៅតែផ្ទះ តែម្នាក់ឯងក៏បាន។ អ្វីដែលចាំបាច់ម្យ៉ាង គឺភាពស្ងប់ស្ងាត់ ! ហើយបើអ្នកគ្មានពេលទំនេរទេ ១០នាទីក្នុងមួយថ្ងៃ គឺគ្រប់គ្រាន់ហើយសម្រាប់ធ្វើសមាធិ[49]។

ជ្រើសរើសទីស្ងប់ស្ងាត់ គ្មានទូរទស្សន៍ គ្មានទូរស័ព្ទ សូមស្តាប់ និងនៅជាមួយខ្លួនអ្នក អង្គុយក៏បាន ទម្រេតខ្លួនក៏បាន តែកុំគេង ដកដង្ហើមមួយៗ ស្រូបខ្យល់ចូល ដកដង្ហើមចេញ ផ្តោតអារម្មណ៍តែទៅលើចលនាដង្ហើម ស្តាប់សភាពរាងកាយ ហើយបន្ធូរអារម្មណ៍ បន្តដកដង្ហើមវែងៗមួយៗ ហើយរាប់ដង្ហើមចេញរាប់ដង្ហើមចូលរបស់អ្នក តាមដានដំណើរខ្យល់ដងដង្ហើមរបស់អ្នកដែលចូលតាមរន្ធច្រមុះ រួចធ្លាក់ចុះទៅក្នុងពោះ ប្រសិនបើអ្នកបែកអារម្មណ៍ គិតដល់រឿងអ្វីផ្សេងសូមមើលបញ្ហានោះ រួចងាកមកគិតអំពី ចលនាដង្ហើមរបស់អ្នកវិញ បន្តស្រូបចូល និងដកដង្ហើមចេញវែងៗ សូមកុំចុះចាញ់នៅពេលបែកអារម្មណ៍ ដាស់ស្មារតីត្រលប់ស្តាប់ដង្ហើមវិញ។

[49] https://www.rfi.fr/km/cambodia/20180214-គុណប្រយោជន៍-នៃការធ្វើ-សមាធិ

# ជំពូក ១១

# ឈ្វេងយល់អំពីបុណ្យសំខាន់ៗក្នុងព្រះពុទ្ធសាសនា

## ១១.១. ឈ្វេងយល់អំពីបុណ្យមាឃបូជា

ពិធីបុណ្យមាឃបូជា

មាឃបូជា ជាពីធីបុណ្យមួយដែលមានសារៈសំខាន់នៅក្នុងពុទ្ធសាសនា ដែលរួមមាន ៖

មាឃបូជា ពិសាខបូជា អាសាឡបូជា និងបុណ្យបវារណា (ចេញវស្សា)។ បុណ្យមាឃបូជាប្រារព្ធឡើង ដើម្បីរំលឹកដល់ថ្ងៃដែល ព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសបង្កើត ព្រះពុទ្ធសាសនាឡើងក្នុងលោកនាប្រទេសឥណ្ឌាកាលពី ៥៨៨ ឆ្នាំ មុនគ្រិស្តសករាជ នាថ្ងៃទី ១៥កើត ខែមាឃ ក្រោយពីការត្រាស់ដឹងរបស់ព្រះអង្គចំនួន ៩ ខែគត់។ ការបង្កើតព្រះពុទ្ធសាសនា ក្នុងឋានៈជាអង្គការសាសនាមួយនេះ ធ្វើឡើងនៅ ក្នុងចំណោមព្រះសង្ឃចំនួន ១២៥០ អង្គ ជាសមាជិក ក្នុងអង្គមហាសន្និបាតមួយ ដែលបាននិមន្តមកពីគ្រប់ស្រទាប់វណ្ណៈទាំងអស់។ នៅក្នុងមហាសន្និបាតនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រកាសនៅគោលការណ៍ ចំនួន១១ ប្រការសម្រាប់ឲ្យសមាជិកមហាសន្និបាត ទាំងអស់កាន់យកជាវិថីជីវិត និងសម្រាប់យកទៅ ផ្សព្វផ្សាយ ដល់ជនដទៃទៀត ឲ្យបានយល់ពី ពុទ្ធសាសនា។ គោលការណ៍ ទាំង១១ប្រការនេះ មានឈ្មោះជាភាសាបាលីថា "ឱវាទបាដិមោក្ខ" ដែលពុទ្ធសាសនិកជនម្នាក់ៗ ត្រូវយកមក សិក្សាឲ្យយល់ដឹង និងអនុវត្តដូចតទៅ ៖

១- គោលបំណងៈ គោលបំណងរបស់ ព្រះពុទ្ធសាសនា ឬក៏ដូចជា គោលបំណងរបស់ ពុទ្ធសាសនិកម្នាក់ៗ គឺ ស្វែងរកនិព្វានដែលប្រែថា សភាវប្រាសចាក ទុក្ខមិនមាន សេចក្តីទុក្ខ មិនមានបញ្ហា នៅក្នុងដួងចិត្តរបស់ខ្លួន ពាក្យនិព្វាននេះ មានន័យស្មើនិង ពាក្យថា "សន្តិ "ដែលប្រែថា" សេចក្តីស្ងប់ "។ យើងអាចនិយាយថា គោលបំណង របស់ព្រះពុទ្ធសាសនា គឺការបង្កើតឡើងនូវ សន្តិភាព ក្នុងដួងចិត្តនេះដែរ ក៏ជាមូលដ្ឋានគ្រឹះនៃ សន្តិភាពក្នុងសង្គម ដែលខ្លួនរស់នៅផង។ ការកាន់ព្រះពុទ្ធសាសនា គឺជាការប្រឹងប្រែង ដើម្បីបង្កើតសន្តិភាពដល់ខ្លួន និងចូលរួមចំណែកដល់ សន្តិភាពសង្គម និងពិភពលោក នេះជាកាតព្វកិច្ច ដែលពុទ្ធសាសនិកម្នាក់ៗ ត្រូវប្រឹងប្រែង ធ្វើអោយសម្រេច ។

២ - គោលដៅ :សន្តិភាព ឫនិព្វាន មិនមែនកើតឡើងដោយការសុំបន់ស្រន់បួងសួងទេ និងក៏មិនអាចកើតឡើងដោយសារផ្តល់ ឬប្រទានឲ្យ ដោយចិត្តស្រឡាញ់ មេត្តារបស់ អាទិទេព ឬព្រះជាម្ចាស់ អង្គណាមួយឡើយ សន្តិភាពនេះ កើតដោយសារការសន្សំ របស់សកម្មភាព៣យ៉ាងគឺ:

១ - ការមិនធ្វើអាក្រក់ ការកម្ចាត់អំពើអាក្រក់ ការកម្ចាត់អំពើអាក្រក់ និងការពារអំពើអាក្រក់គ្រប់ប្រភេទ មិនឲ្យកើតក្នុងជីវិតរស់នៅទាំងផ្លូវកាយនិងផ្លូវសម្តី។

២ - ការធ្វើអំពើល្អ បង្កើតអំពើល្អ និងរក្សាអំពើល្អឲ្យ ស្ថិតស្ថេរគង់វង្សក្នុង ជីវិតរស់នៅប្រចាំថ្ងៃ ទាំងអំពើល្អខាងផ្លូវកាយនិងផ្លូវសម្តី។

៣ - ពង្រឹងចិត្តដែលជាមូលដ្ឋាននៃអំពើ ដោយកម្ចាត់កិលេស ឬមេរោគដែលគោង ចិត្តឲ្យអស់ទៅរហូតដល់ចិត្តស្អាតបរិសុទ្ធ មិនមានសភាវៈអាក្រក់ស្ថិតនៅ។

**លក្ខណៈរបស់ព្រះពុទ្ធសាសនិកជន ៖**

លក្ខខណ្ឌទី១៖ មានការអត់ធ្មត់ក្នុងការធ្វើអំពើល្អ និង កម្ចាត់អំពើអាក្រក់។

លក្ខខណ្ឌទី២៖ មិនប្រើអំពើហិង្សាក្នុងការរស់នៅ។

លក្ខខណ្ឌទី៣៖ មិនប្រើពាក្យបៀតបៀននិងតិៈដៀលអ្នកដទៃ។

លក្ខខណ្ឌទី៤៖ រក្សាសីល រស់នៅក្នុងច្បាប់ យកច្បាប់ជាធំ។

លក្ខខណ្ឌទី៥៖ បរិភោគ ប្រើប្រាស់វត្ថុទាំងឡាយដោយសន្សំសំចៃ និងស្គាល់ប្រមាណ។

លក្ខខណ្ឌទី៦៖ ចូលចិត្តភាពស្ងប់ស្ងាត់ និងបង្កើតបរិយាកាសស្ងប់ស្ងាត់។

លក្ខខណ្ឌទី៧៖ មានសេចក្តីព្យាយាមក្នុងការសម្អាតចិត្ត ធ្វើឲ្យចិត្តមានសមាធិ។

មេរៀនពីបុណ្យមាឃបូជា ៖ ថ្ងៃនេះជាថ្ងៃដែល ព្រះពុទ្ធអង្គទ្រង់ប្រកាសគោលការណ៍ទាំង១១ ប្រការនេះ សម្រាប់ជាប្រយោជន៍ដល់បរិស័ទយកទៅប្រើប្រាស់ ៖

ចំណុច១ ៖ ក្នុងឋានៈជាបរិស័ទ ការអនុវត្តន៍តាមប្រការទាំង១១នេះ នឹងនាំទៅរកសន្តិភាពផ្លូវចិត្តជាពិតប្រាកដ

ចំណុច២ ៖ ក្នុងឋានៈជាពលរដ្ឋ ក្នុងសង្គមការមាន គោលបំណង រួមមានគោលដៅដូចគ្នា និងការប្រព្រឹត្តប្រហាក់ប្រហែលគ្នានេះ នឹងអាចនាំមកនូវ សន្តិភាព និង ការអភិវឌ្ឍដែលប្រកបដោយនិរន្តភាព។

ចំណុច៣ ៖ ក្នុងឋានៈជាក្រុមបក្សនៅ ក្នុងសង្គម ឬប្រទេសជាតិមួយ ដែលព្យាយាម ស្វែងរកនូវឱកាស ដើម្បីរក្សាសន្តិភាព និងជំរុញដល់ ការអភិវឌ្ឍដល់ ប្រទេសជាតិតែឯងនោះ ការគោពតាមគោលការណ៍ទាំង១១ប្រការនេះ នឹងកាត់បន្ថយបាននូវអស្ថិរភាព ជម្លោះ និងអំពើហិង្សា ដែលកើតមកពីការ ប្រកួតប្រជែងគ្នាបាន។

ចំណុច៤៖ ក្នុងឋានៈជាអ្នកផ្សាយសាសនា ការប្រព្រឹត្តទៅតាមគោលការណ៍នេះ នឹងនាំឲ្យមានការយោគយល់ការផ្តល់កិត្តិយស ដល់គ្នានិងគ្នា និងការរស់នៅជុំគ្នា ក្នុងឋានៈជាមនុស្សជាតិបាន បើទោះជាមាន សាសនាខុសគ្នាៗក៏ដោយ។ ចំណុច៥ ក្នុងឋានៈជាអន្តរជាតិ ការគោរពតាមគោលការណ៍នេះ នឹងនាំមកនូវនិរន្តភាព របស់មនុស្សជាតិ បរិស្ថានធម្មជាតិ ពិភពសត្វ និងអាកាសធាតុដ៏យូរអង្វែងបាន ដោយមិនបាច់ ព្រួយបារម្ភក្នុងការដណ្តើមគ្នាដើម្បីរស់ឡើយ ។

សង្ឃឹមថាយើងម្នាក់ៗអាចទាញយកប្រយោជន៍បានខ្លះពីថ្ងៃមាឃបូជានេះ នឹងអញ្ជើញនាំគ្នាធ្វើបុណ្យទានរក្សាសីល និងសមាធិសម្អាតចិត្តរបស់ខ្លួនក្នុងថ្ងៃនេះ ដើម្បីបូជា និងរំលឹកចំពោះគុណព្រះសម្មាសម្ពុទ្ធដែលព្រះអង្គ បានបង្កើត ព្រះពុទ្ធសាសនាសម្រាប់ជាមាគ៌ាជីវិតដល់ពួកយើងទាំងអស់គ្នា។

មាឃបូជា ជាពីធីបុណ្យមួយដែលមានសារៈសំខាន់នៅក្នុងពុទ្ធសាសនា ដែលរួមមាន៖ មាឃបូជា ពិសាខបូជា អាសាឍបូជា និងបុណ្យបវារណា (ចេញវស្សា)។ បុណ្យមាឃបូជាប្រារព្ធឡើង ដើម្បីរំលឹកដល់ថ្ងៃដែល ព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសបង្កើត ព្រះពុទ្ធសាសនាឡើងក្នុងលោកនាប្រទេសឥណ្ឌាកាលពី ៥៨៨ ឆ្នាំ មុនគ្រិស្តសករាជ នាថ្ងៃទី ១៥កើត ខែមាឃ ក្រោយពីការត្រាស់ដឹងរបស់ព្រះអង្គចំនួន ៩ ខែគត់។ ការបង្កើតព្រះពុទ្ធសាសនាក្នុងឋានៈជាអង្គការសាសនាមួយនេះធ្វើឡើងនៅក្នុងចំណោមព្រះសង្ឃចំនួន ១២៥០ អង្គ ជាសមាជិក ក្នុងអង្គមហាសន្និបាតមួយ ដែលបាននិមន្តមកពីគ្រប់ស្រទាប់វណ្ណៈទាំងអស់។ នៅក្នុងមហាសន្និបាតនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រកាសនៅគោលការណ៍ ចំនួន១១ប្រការ សម្រាប់ឲ្យសមាជិកមហា

សន្និបាត ទាំងអស់កាន់យកជាវិថីជីវិត និងសម្រាប់យកទៅ ផ្សព្វផ្សាយ ដល់ជនដទៃទៀត ឲ្យបានយល់ពី ពុទ្ធសាសនា។ គោលការណ៍ ទាំង១១ប្រការនេះ មានឈ្មោះជាភាសាបាលីថា "ឱវាទបាដិមោក្ខ" ដែលពុទ្ធសាសនិកជនម្នាក់ៗ ត្រូវយកមក សិក្សាឲ្យយល់ដឹង និងអនុវត្តដូចតទៅ ៖

គោលបំណងៈ គោលបំណងរបស់ ព្រះពុទ្ធសាសនា ឬក៏ដូចជា គោលបំណងរបស់ ពុទ្ធសាសនិកម្នាក់ៗ គឺ ស្វែងរកនិព្វានដែលប្រែថា សភាវប្រាសចាក ទុក្ខមិនមាន សេចក្ដីទុក្ខ មិនមានបញ្ហា នៅក្នុងដួងចិត្តរបស់ខ្លួន ពាក្យនិព្វាននេះ មានន័យស្មើនិង ពាក្យថា " សន្តិ " ដែលប្រែថា" សេចក្ដីស្ងប់ "។ យើងអាចនិយាយថា គោលបំណាង របស់ព្រះពុទ្ធសាសនា គឺការបង្កើតឡើងនូវ សន្តិភាព ក្នុងដួងចិត្តនេះដែរ ក៏ជាមូលដ្ឋានគ្រឹះនៃ សន្តិភាពក្នុងសង្គម ដែលខ្លួនរស់នៅផង។ ការកាន់ព្រះពុទ្ធសាសនា គឺជាការប្រឹងប្រែង ដើម្បីបង្កើតសន្តិភាពដល់ខ្លួន និងចូលរួមចំណែកដល់ សន្តិភាពសង្គម និងពិភពលោក នេះជាកាតព្វកិច្ច ដែលពុទ្ធសាសនិកម្នាក់ៗ ត្រូវប្រឹងប្រែងធ្វើឲ្យ សម្រេច។

គោលដៅ ៖ សន្តិភាព ឬនិព្វាន មិនមែនកើតឡើងដោយការសុំបន់ស្រន់បួងសួងទេ និងក៏មិនអាចកើត ឡើងដោយសារផ្ដល់ ឬប្រទានឲ្យ ដោយចិត្តស្រឡាញ់ មេត្តារបស់ អាទិទេព ឬព្រះជាម្ចាស់ អង្គណាមួយឡើយ សន្តិភាពនេះ កើតដោយសារការសន្សំ របស់សកម្មភាព៣យ៉ាងគឺៈ

ការមិនធ្វើអាក្រក់ ការកម្ចាត់អំពើអាក្រក់ ការកម្ចាត់អំពើអាក្រក់ និងការពារអំពើអាក្រក់គ្រប់ប្រភេទមិនឲ្យកើតក្នុងជីវិតរស់នៅទាំងផ្លូវកាយនិងផ្លូវសម្ដី។

ការធ្វើអំពើល្អ បង្កើតអំពើល្អ និងរក្សាអំពើល្អឲ្យ ស្ថិតស្ថេរគង់វង្សក្នុង ជីវិតរស់នៅប្រចាំថ្ងៃ ទាំងអំពើល្អខាងផ្លូវកាយនិងផ្លូវសម្ដី។

ពង្រឹងចិត្តដែលជាមូលដ្ឋាននៃអំពើ ដោយកម្ចាត់កិលេស ឬមេរោគដែលគោង ចិត្តឲ្យអស់ទៅ រហូតដល់ចិត្តស្អាតបរិសុទ្ធ មិនមានសភាវៈអាក្រក់ស្ថិតនៅ។

លក្ខណៈរបស់ព្រះពុទ្ធសាសនិកជន ៖

លក្ខខណ្ឌទី១៖ មានការអត់ធ្មត់ក្នុងការធ្វើអំពើល្អ និងកម្ចាត់អំពើអាក្រក់។

លក្ខខណ្ឌទី២៖ មិនប្រើអំពើហិង្សាក្នុងការរស់នៅ។

លក្ខខណ្ឌទី៣៖ មិនប្រើពាក្យបៀតបៀននិងតិះដៀលអ្នកដទៃ។

លក្ខខណ្ឌទី៤៖ រក្សាសីល រស់នៅក្នុងច្បាប់ យកច្បាប់ជាធំ។

លក្ខខណ្ឌទី៥៖ បរិភោគ ប្រើប្រាស់វត្ថុទាំងឡាយដោយសន្សំសំចៃនិងស្គាល់ប្រមាណ។

លក្ខខណ្ឌទី៦៖ ចូលចិត្តភាពស្ងប់ស្ងាត់ និង បង្កើតបរិយាកាសស្ងប់ស្ងាត់។

លក្ខខណ្ឌទី៧៖ មានសេចក្ដីព្យាយាមក្នុងការសម្អាតចិត្ត ធ្វើឲ្យចិត្តមានសមាធិ។

មេរៀនពីបុណ្យមាឃបូជា ៖ថ្ងៃនេះជាថ្ងៃដែល ព្រះពុទ្ធអង្គទ្រង់ប្រកាសគោលការណ៍ទាំង១១ ប្រការនេះ សម្រាប់ជាប្រយោជន៍ដល់បរិស័ទយកទៅប្រើប្រាស់ៈ

ចំណុច១៖ ក្នុងឋានៈជាបរិស័ទ ការអនុវត្តន៍តាមប្រការទាំង១១នេះ នឹងនាំទៅរកសន្តិភាពផ្លូវចិត្តជាពិតប្រាកដ[50]។

[50] https://km.wikipedia.org/wiki wiki/ពិធីបុណ្យមាឃបូជា

ចំណុច២៖ ក្នុងឋានៈជាពលរដ្ឋ ក្នុងសង្គមការមាន គោលបំណង រួមមានគោលដៅដូចគ្នា និងការប្រព្រឹត្តប្រហាក់ប្រហែលគ្នានេះនឹងអាចនាំមកនូវ សន្តិភាព និងការអភិវឌ្ឍដែលប្រកបដោយនិរន្តភាព។

ចំណុច៣៖ ក្នុងឋានៈជាក្រុមបក្សនៅ ក្នុងសង្គម ឬប្រទេសជាតិមួយ ដែលព្យាយាម ស្វែងរកនូវឱកាស ដើម្បីរក្សាសន្តិភាព និងជំរុញដល់ ការអភិវឌ្ឍន៍ដល់ ប្រទេសជាតិតែឯងនោះ ការគោពតាមគោលការណ៍ទាំង១១ប្រការនេះ នឹងកាត់បន្ថយបាននូវអស្ថិរភាព ជម្លោះ និងអំពើ ហិង្សា ដែលកើតមកពីការប្រកួតប្រជែងគ្នាបាន។

ចំណុច៤៖ ក្នុងឋានៈជាអ្នកផ្សាយសាសនា ការប្រព្រឹត្តទៅតាមគោលការណ៍នេះ នឹងនាំឲ្យមានការយោគយល់ការផ្តល់កិត្តិយស ដល់គ្នានិងគ្នា និងការរស់នៅជុំគ្នា ក្នុងឋានៈជាមនុស្សជាតិ។

## ១១.២. មេរៀនអំពីបុណ្យវិសាខបូជា

អត្ថន័យនៃបុណ្យវិសាខបូជា

បុណ្យវិសាខបូជា គឺជាពិធីបុណ្យមួយយ៉ាងធំ ក្នុងព្រះពុទ្ធសាសនារាប់ថា ជាពុទ្ធស្សរណកិច្ចដ៏សំខាន់សម្រាប់រំឭកដល់ដល់ព្រះពុទ្ធសមណគោត្តមបរមគ្រូ នាថ្ងៃពេញបូណ៌មី (គឺថ្ងៃ១៥កើត) ខែពិសាខដែលពុទ្ធសាសនិកទាំងឡាយ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ តែងធ្វើសក្ការបូជាប្រកបដោយបសាទសទ្ធាជ្រះថ្លាចំពោះគុណរបស់ព្រះសម្មាសម្ពុទ្ធ។ ការដែលប្រារព្ធធ្វើពិធីបូជានាថ្ងៃ១៥កើត ពេញបូណ៌មី ខែពិសាខនេះ អាស្រ័យដោយលោកអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនា បានកំណត់ទុកក្នុងគម្ពីរបឋមសម្ពោធិថា ជាមហាមង្គលអភិលក្ខិតកាល គឺជាថ្ងៃមហាមង្គល ត្រូវនឹងថ្ងៃដែលព្រះសម្ពុទ្ធបរមគ្រូ៖

១ - ទ្រង់ប្រសូតចាកឧទរមាតា ថ្ងៃសុក្រ ពេញបូណ៌មី ខែ ពិសាខ ឆ្នាំ ច មុន ព.ស ៨០ឆ្នាំ។

២ - ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ថ្ងៃពុធ ពេញបូណ៌មី ខែ ពិសាខ ឆ្នាំរកា មុន ព.ស ៤៥ឆ្នាំ។

៣ - ទ្រង់រលត់ខន្ធចូលព្រះបរមនិព្វាន ថ្ងៃអង្គារ ពេញបូណ៌មី ខែ ពិសាខ ឆ្នាំម្សាញ់ ជាការចាប់ផ្តើមពុទ្ធសករាជ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តាចារ្យ ទ្រង់ប្រសូត ត្រាស់ដឹង និងបរិព្វាន សុទ្ធតែក្នុងថ្ងៃពេញបូណ៌មី ខែពិសាខទាំងអស់ប្លែកតែឆ្នាំប៉ុណ្ណោះ ព្រោះហេតុនោះហើយ បានជាអ្នកប្រាជ្ញចងក្រង ជាគាថាទុកដូច្នេះថា អាសាឡ្ហ បុណ្ណ មោក្កន្តោ វិសាខ យេវ និក្ខមិ វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិព្វុតោ សេចក្តីថា ៖ ព្រះពុទ្ធយាងចុះកាន់គភ៌នៃព្រះវរមាតា ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ទ្រង់ប្រសូតក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ បានត្រាស់ដឹងជាព្រះពុទ្ធ ក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ និងទ្រង់បរិនិព្វានក៏ក្នុងថ្ងៃពេញបូណ៌មី ខែពិសាខដែរ ផ្សេងតែឆ្នាំប៉ុណ្ណោះ។ ជាប្រពៃណី ពិធីពិសាខបូជា គេតែងនាំគ្នាធ្វើនៅក្នុងវេលារាត្រី ព្រោះតម្រូវទៅតាមពាក្យថា បុណ្ណមី មានសេចក្តីថា ខែពេញបូណ៌មី ឬ ព្រះចន្ទពេញវង់។

ម្យ៉ាងទៀត ការប្រារព្ធក្នុងពេលរាត្រី អាស្រ័យដោយលក្ខណៈងាយស្រួល២យ៉ាងគឺ ម្យ៉ាងដើម្បីនឹងបានឱកាសអុជប្រទីប ផ្កាលា បូជាភ្លើងអគ្គិសនីឲ្យភ្លឺរុងរឿងរន្ទាល បានជាទីជ្រះថ្លារបស់អ្នកមានសទ្ធា និងម្យ៉ាងទៀត ឲ្យពុទ្ធបរិស័ទបានជួបជុំគ្នាដ៏ច្រើនកុះករទាំងប្រុសទាំងស្រី អាចបំពេញកុសលកម្មនេះ ដោយសប្បាយរីករាយព្រោះវេលាយប់ទំនេរផង។

វិសាខបូជាចាត់ទុកថា ជាបុណ្យដ៏ធំ ដោយមានមហាជនចាស់ ក្មេង ប្រុសស្រី នៅជុំគ្នាច្រើនកុះករ ដោយនាំគ្នាកាន់គ្រឿងសក្ការទៅជាមួយ សម្រាប់បូជាមានៈ ទៀន ធូប ផ្កា និងប្រទីបផ្ទាលាតូចធំអុជបំភ្លឺព្រោងព្រាត នៅក្នុងវត្ត អារាម។ និយាយជារួម ធ្វើបុណ្យវិសាខបូជា គឺដើម្បីរំឭកដល់ថ្ងៃ ដែលជាមហាអភិលក្ខិតកាលទាំងបីដូចបានពោលរៀបរាប់ខាងលើរួចមកហើយ ឯពិធីដែលធ្វើកំណត់ថា ត្រឹមត្រូវ គឺត្រូវមានការសំដែងរឿងពុទ្ធប្បវត្តិ តាំងអំពីដើមរហូតដល់ចប់ ដើម្បីញុំាងសេចក្តីជ្រះថ្លា ឲ្យកើតមានក្នុងគុណព្រះពុទ្ធ គុណព្រះធម៌ គុណព្រះសង្ឃ ឲ្យខ្លាំងក្លាឡើង។

បុណ្យវិសាខបូជានេះត្រូវបានអង្គការសហប្រជាជាតិ ទទួលស្គាល់ចំពោះបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនា លើសាកលលោក ក្នុងនោះមានប្រទេសកម្ពុជាផងដែរ តាំងពីឆ្នាំ២០០០មកម្លេះ។ ចំណែកប្រទេសកម្ពុជា ដែលមានព្រះពុទ្ធសាសនា បានមកប្រតិស្ឋានតាំងពីដំបូង ហើយស្ថិតនៅជាប្រទេសមានឥស្សរភាពជាយូរណាស់មកហើយ តែបើតាមការស្រាវជ្រាវ ពិនិត្យមើលក្នុងព្រះរាជពង្សាវតារ ឬក្នុងសេចក្តីកំណត់ហេតុផ្សេងៗតាំងពីសម័យនគរភ្នំ «ហ្វូ
ណន) រហូតដល់សម័យលង្វែកមិនប្រាកដថា មានទំនៀមធ្វើវិសាខបូជាឡើយ។

## ១១.៣. ឈ្វេងយល់អំពីបុណ្យកឋិន

បុណ្យកឋិន

កឋិនទានបវេណីព្រះពុទ្ធសាសនាគឺជាឧត្តមបុណ្យរបស់ពុទ្ធបរិស័ទ។ ពាក្យថា"កឋិន"ជាភាសាបាលីសំដៅយកក្របក្តារ ដែលភិក្ខុសង្ឃសម័យបុរាណឥណ្ឌាប្រើសម្រាប់ដេរសំពត់ធ្វើជាស្បង់ចីវរ។ សំពត់ដែលបានរៀបចំតាក់តែងឡើងនោះមានឈ្មោះថា"សំពត់កឋិន"។ បុណ្យកឋិន ជាពិធីបុណ្យមួយចាប់ផ្តើមធ្វើបន្ទាប់ពីបុណ្យចេញវស្សា បុណ្យកឋិនតែងត្រូវបានដង្ហែចូលគ្រប់ទីអារាមទាំងអស់ ពុំមានទំនេរវត្តណាមួយ ត្រូវបានឧកខានឡើយ។ ដូច្នេះគេតែងតែឃើញ ក្បួនកឋិនទានតែងបានដង្ហែទៅកាន់ទីអារាមរៀងៗខ្លួន ចាប់ពីថ្ងៃ១រោច ខែអស្សុជដល់ថ្ងៃទី១៥កើត ខែកត្តិកហើយបើទីអារាមណាមួយ មិនមានកឋិនណាមួយហែចូលទេ។ ទីអារាមនោះក៏ត្រូវតែរៀបចំជាកឋិនជើងវត្តដែរ។ ពិធីហែអង្គកឋិនទៅកាន់ទីអារាមនីមួយៗ គេរៀបចំធ្វើឡើងយ៉ាងអធិកអធម្ម សប្បាយរីករាយយ៉ាងក្រៃលែង អ្នកផ្តើមបុណ្យបានរៀបចំបរិក្ខាកឋិនមានត្រៃចីវរ ចិវរ សង្ឃាដិ ស្បង់ ព្រមដោយ ទេយ្យទាន ផ្សេងៗទៀតដូចជា បាត ចានស្រាក់ កាំបិតចេស ម្ជុល ថង់យាម ឆ័ត្រជាដើមសព្វគ្រប់អស់ហើយ គេនាំគ្នាហែទៅទីអារាម ដែលបានកំណត់ទុក។ បើកឋិននោះដង្ហែទៅវត្តឆ្ងាយ គេជួបជុំគ្នាពីព្រលឹមរួចនាំគ្នាឡើងរថយន្តសំដៅទៅវត្តនោះ ។ បើវត្តនៅតាមដងទន្លេ គេជិះទូករឺ កប៉ាល់។ កាលខ្ញុំនៅកុមារភាពស្រុកយើង ពុំទាន់មាន ការរីកចំរើនខាងផ្លូវគមនាគមន៍នៅឡើយ យានយន្តទៀតសោតក៏ពុំសូវមានខ្ញុំច្រើនឃើញពុទ្ធបរិសទ្ធហែអង្គកឋិនទៅកាន់ទីវត្តឆ្ងាយៗ ដោយប្រើដំរីជាយានជំនិះ ក្នុងពិធីហែអង្គកឋិនដោយដំរីនេះ មើលទៅគួរឱ្យសប្បាយរីករាយខ្លាំងណាស់ មានដំរីជាច្រើន រហូតដល់ ២០ ទៅ ៣០ដំរី ដើរដង្ហែជាជួរ ដំរីនិមួយៗគេ តុបតែងរចនាដូចជាដំរីព្រះអិន្ទ្រច្យុតពីស្ថានសួគ៌ នៅលើខ្នងដំរី គេចងរយាង រំលេចដោយភ្ញីផ្កា ក្បាច់ក្បូររចនា ភ្លឺចិញ្ចាំងចញ្ចែង មនុស្សម្នាប្រុសស្រី ក្មេងចាស់ តែងខ្លួន លាបម្សៅ សិតសក់ស្លៀកសំពត់អាវថ្មីៗ បាំងក្លស់ចំរុះពណ៌គួរជាទីត្រេកត្រអាលក្រៃពេក ក្នុងការហែនេះ គេមានប្រគំភ្លេង តូរ្យត

ន្ត្រីយ៉ាងពិរោះ ហើយជាពិសេស គឺជាក្រុមភ្លេងឆៃយ៉ាំ ដែលធ្វើអោយបរិយាកាស រិតតែគគ្រឹកគគ្រេង រស់រវើក សប្បាយក្រៃលែង។ លុះទៅដល់វត្ត គេមិនទាន់យកអង្គកឋិននេះចូលទៅក្នុងព្រះវិហារភ្លាមទេ គេតំកល់អង្គកឋិនទុកនៅក្នុងសាលាបុណ្យមួយ ដែលគេបានរៀបចំទុកជាស្រេច។ គេនិមន្តព្រះសង្ឃឆាន់ពេលថ្ងៃត្រង់ បន្ទាប់ពីនោះ ពុទ្ធបរិសទ្ធ ដើងវត្តមានតួនាទីរៀបចំទទួលភោជនាហារលៀងដល់ភ្ញៀវ ដែលនាំអង្គកឋិនចូលមកកាន់វត្តរបស់ខ្លួនយ៉ាងអឺកអធឹក កក់ក្តៅរាក់ទាក់រីករាយជាពន់ពេក លុះរសៀលជ្រេរទាបបន្តិច គេនាំគ្នាហែអង្គកឋិនព័ទ្ធជុំវិញព្រះវិហារចំនួនបីជុំ ទើបនាំគ្នាចូលក្នុងវិហារ។ ចៅអធិការវត្ត បានចាត់អោយភិក្ខុមួយអង្គជាអ្នកគ្រងអង្គកឋិននោះ។ ពុទ្ធបរិសទ្ធចាប់ផ្តើមនម្សការថ្វាយបង្គំព្រះ ហើយវេរអង្គកឋិនប្រគេនព្រះសង្ឃជាកិច្ចឆ្លងបង្ហើយបុណ្យ។ អត្ថន័យនៃបុណ្យកឋិន តាមអដ្ឋកថាសំដៅយកព្រះពុទ្ធដីកា ដែលព្រះពុទ្ធទ្រង់បានបញ្ញត្តិទុកមកថាកឋិនគឺការប្រជុំរួមនូវរូបធម៌ និងនាមធម៌ ដែលប្រព្រឹត្តទៅក្នុងអត្ថន័យពីរយ៉ាងគឺៈ

១. រស់បានដោយកម្រសមដូចវិគ្គហៈថា "កឋតិ កិច្ឆេន ជីវតីតិ កឋិនោ"។ ប្រែថា "សភាវៈឯណារស់បានដោយកម្រ សភាវៈនោះហៅថាកឋិនព្រោះលោកប្រៀបប្រដូចជាឈើស្នឹង ដែលបុគ្គលកាត់ចាកចេញពីដើម ហើយយកទៅបោះភ្ជាប់នឹងដីរមែងដុះលូតលាស់ឬរស់នៅបានដោយកម្រយ៉ាងណាឯកិច្ច ដែលនឹងកើតឡើង ឬតាំងឡើងជាកឋិនពេញទី គឺបានដោយកម្រពន់ពេកណាស់ក៏យ៉ាងនោះដែរ"។

២. ពោលសរសើរព្រោះចីវរទាន ដែលយើងកសាងជាកឋិននោះ ជាទានវិសេសជាងទានដទៃ ដែលព្រះអរិយទាំងឡាយមានព្រះសម្ពុទ្ធ ជាប្រធានតែងពោលសរសើរថាជាទានដ៏វិសេសអាចរួបរួម ឬក៏សង្គ្រោះនូវអានិសង្ស៥យ៉ាងរបស់ភិក្ខុអ្នកក្រាលគ្រងមិនឱ្យទៅគ្រងនៅទីដទៃបាន។ សមដូចវិគ្គហៈថា "បញ្ច អានិសំសេ អញ្ញត្ថ គន្តុំ អទត្វា កឋិតិ សង្គណ្ហាតីតិ"។ ប្រែថា"ធម្មជាតិឯណាក្រៀកទុកឬសង្គ្រោះនូវអានិសង្សទាំង៥យ៉ាងមិនឱ្យទៅក្នុងទីដទៃបាន ធម្មជាតិនោះឈ្មោះថាកឋិន"។

កឋិននេះអាចឱ្យសម្រេចដល់បុគ្គលទាំងពីរផ្នែកគឺៈ

☞ ទាយក ឬទាយិកា គឺជាអ្នកឱ្យ។ ជននោះរមែងទទួលអានិសង្សច្រើន ទទួលផលច្រើន ក្នុងអនាគតកាល មានការទទួលនូវសម្បត្តិក្នុងឋានទេវលោកជាដើម។

☞ បដិគ្គាហកៈ ភិក្ខុ ឬ បុគ្គល ឬ សង្ឃ ជាអ្នកទទួលក្រាលគ្រង និងអនុមោទនាកឋិនត្រូវបានសម្រេចនូវអានិសង្ស ៥យ៉ាងពេញលេញ គ្រប់គ្រាន់ ដរាបដល់រយៈកាលនៃកឋិនខេត្ត។

ពិធីដែលទាយក-ទាយិកា នាំយកសំពត់កឋិនទៅប្រគេនចំពោះភិក្ខុសង្ឃ ដែលបានគង់ចាំវស្សា អស់មួយត្រីមាស (៣ខែ) ក្នុងអាវាស (វត្ត) ណាមួយ និងនៅពេលណាមួយក្នុងកំណាត់ ២៩ថ្ងៃ (ចាប់ពីថ្ងៃ ១រោច ខែអស្សុជរហូតដល់ថ្ងៃ១៥កើតពេញបូណ៌មីខែកត្តិក) ឱ្យលោកក្រាលគ្រងមានឈ្មោះថា"បុណ្យកឋិន" ឬ "កឋិនទាន"។

បុព្វហេតុកឋិន

វិន័យបិដក ភាគ៨ កឋិនក្ខន្ធកៈ បានចែងអំពីបុព្វហេតុនៃបុណ្យកឋិនថា"ក្នុងសម័យពុទ្ធកាល ព្រះសម្ពុទ្ធ ទ្រង់ពុទ្ធានុញ្ញាតឲ្យភិក្ខុប្រើប្រាស់ តែបង្សុកូលចីវរ ព្រះអង្គពុំទាន់បានពុទ្ធានុញ្ញាតឱ្យប្រើគហបតីចីវរ-

ចីវរនៅឡើយ"។

នាសម័យមួយនោះនៅក្នុងរវាងមជ្ឈិមពោធិកាល ព្រះសម្ពុទ្ធទ្រង់កំពុងតែចាំព្រះវស្សាក្នុងវត្តជេតពន ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី សាងថ្វាយនៅទៀបក្រុងសាវត្ថី។ គ្រានោះមានភិក្ខុ៣០អង្គ "ភទ្ទវគ្គិយត្ថេរ" ក្នុងដែនបាឋេយ្យ ជាអ្នកប្រព្រឹត្តធម៌ធុតង្គរុក្ខមូលនៅក្នុងព្រៃបាននាំគ្នានិមន្តចេញពីទីនោះមកកាន់ក្រុងសាវត្ថី ដើម្បីនឹងចូលក្រាបបង្គំគាល់ព្រះសម្ពុទ្ធ។ ប៉ុន្តែពេលភិក្ខុទាំងអស់បានមកដល់តែត្រឹមសាកេត (ភូមិមួយនៅជាប់នឹងក្រុងសាវត្ថី) ស្រាប់តែថ្ងៃចូលវស្សាក៏មកដល់នឹងស្រូតមកទៀតមិនទាន់ក៏នាំគ្នាផ្អាកធ្វើដំណើរស្វែងរកទីសេនាសនៈនៅចាំវស្សា៣ខែ នាទីនោះតែម្តងទៅ។

ភិក្ខុសង្ឃទាំង៣០អង្គនោះមានសេចក្តីអផ្សុកកើតទុក្ខតូចព្រះទ័យយ៉ាងខ្លាំង ដោយគិតឃើញថាព្រះសម្ពុទ្ធទ្រង់គង់នៅទីនោះចម្ងាយត្រឹមតែ៦យោជន៍ (៩៦គីឡូម៉ែត្រ) ទៀតសោះ មិនសមយើងទាំងឡាយស្ទុនដំណើរមិនបានចូលគាល់បម្រើព្រះអង្គដូចបំណង។

លុះដល់ថ្ងៃចេញវស្សា បវារណាស្រេចហើយ ភិក្ខុទាំងអស់ក៏នាំគ្នាប្រញាប់ប្រញាល់ចូលកាន់ក្រុងសាវត្ថី។ លុះដល់ហើយ ភិក្ខុទាំង៣០អង្គ ក៏បានចូលទៅក្រាបថ្វាយបង្គំគាល់ព្រះសម្មាសម្ពុទ្ធ ដោយមានស្បង់ចីវរទទឹកជោក។ ព្រះសម្ពុទ្ធ ក៏មានព្រះភាគទ្រង់មានព្រះបន្ទូលរួសរាយរាក់ទាក់ និងត្រាស់សួរសុខទុក្ខភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ! តើសរីយន្តរបស់អ្នកទាំងឡាយ ល្មមអត់សង្កត់បានឬទេ? ល្មមប្រព្រឹត្តទៅបានឬទេ? តើអ្នកទាំងឡាយមានសេចក្តីព្រមព្រៀងស្មោះស្មើឥតមានវិវាទទាស់ទែងគ្នាទេឬ?"។

ភិក្ខុទាំងឡាយនោះ ក៏ក្រាបបង្គំទូលនូវសេចក្តីលំបាកខ្លាំងរបស់ខ្លួនក្នុងការធ្វើដំណើរ ដែលមានមកតាមផ្លូវ ដោយសព្វគ្រប់ប្រការ។

លំដាប់នោះ ព្រះសម្មាសម្ពុទ្ធសម្តែងនូវធម្មកថា ប្រារព្ធអំពីសង្សារវដ្តមិនមានទីបំផុតប្រោសប្រទានដល់ភិក្ខុទាំងនោះ។ លុះចប់ធម៌ហើយ ភិក្ខុទាំងឡាយនោះបានសម្រេចព្រះអរហត្តផលគ្រប់ៗអង្គរួចហើយក៏នាំគ្នាក្រាបថ្វាយបង្គំលាព្រះសម្ពុទ្ធចៀសចេញទៅ។

លំដាប់តអំពីនោះមកព្រះសម្ពុទ្ធទ្រង់ព្រះពុទ្ធចិន្តាថា ប្រសិនបើតថាគតបានអនុញ្ញាតនូវកឋិនត្ថារកិច្ចដល់ភិក្ខុទាំងឡាយទុករួចពីគ្រាមុនមកម្ល៉េះសមភិក្ខុទាំង៣០អង្គនេះបានលះចីវរមួយទុកនៅកន្លែងហើយយកជាប់មកជាមួយខ្លួន តែស្បង់មួយប៉ុណ្ណោះមានអត្ថិភាពស្រាលមិនលំបាកតាមផ្លូវយ៉ាងនេះសោះឡើយ។ រីឯកឋិនត្ថារកិច្ចនេះសោត ព្រះពុទ្ធទាំងឡាយ ក៏ធ្លាប់បានអនុញ្ញាតទុកដល់សាវកពុំដែលលះបង់ផង។

លុះព្រះសម្ពុទ្ធទ្រង់ព្រះតម្រិះយ៉ាងដូច្នេះហើយ ទើបទ្រង់ត្រាស់ឱ្យប្រជុំភិក្ខុទាំងឡាយរួចហើយ ទ្រង់អនុញ្ញាតនូវកឋិនត្ថារកិច្ចដល់ភិក្ខុទាំងឡាយថា "អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ"។ ប្រែថា "ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយ ដែលនៅចាំវស្សារួចហើយទទួលក្រាលគ្រងកឋិនបាន។ ម្នាលភិក្ខុទាំងឡាយ! អានិសង្ស៥ប្រការនឹងសម្រេចដល់ភិក្ខុទាំងឡាយ ដែលជាអ្នកបានក្រាលគ្រង និងបានអនុមោទនាកឋិនរួចហើយនោះ"។

កឋិនកាល (កាលទាន) ចីវរកឋិនមិនខុសប្លែកគ្នាអំពីចីវរទានដទៃទៀតទេ គ្រាន់តែការធ្វើបុណ្យ

កឋិនចីវរមានកំណត់កាលបរិច្ឆេទច្បាស់លាស់ និងមានប្រជាប្រិយភាពច្រើន ដែលហៅថា "កឋិនកាល ឬកាលទាន"។

ព្រះសម្ពុទ្ធទ្រង់ពុទ្ធានុញ្ញាតឱ្យភិក្ខុសង្ឃទទួលស្បង់ចីវរអំពីពុទ្ធបរិស័ទ និងគហបតីទាំងឡាយ ក្នុងពេលមួយខែ កំណត់ពីថ្ងៃ១រោច ខែអស្សុជដល់ថ្ងៃ១៥កើតពេញបូណ៌មីខែកត្តិក (ការរវាងពាក់កណ្ដាលខែតុលាដល់ពាក់កណ្ដាលខែវិច្ឆិកា)។ ព្រះសម្ពុទ្ធទ្រង់ព្រះមេត្តាប្រោសអនុញ្ញាត ដល់ភិក្ខុសង្ឃ ជាអ្នកក្រាលគ្រង និងអនុមោទនាកឋិននោះបានទទួលអានិសង្ស៥ប្រការ។

ជនមានសទ្ធា ដែលបានធ្វើកឋិនទានឈ្មោះថា ជាអ្នកបានគោរពនូវព្រះពុទ្ធដីកា ដែលទ្រង់បានពុទ្ធានុញ្ញាតឱ្យភិក្ខុសង្ឃ បានទទួលអានិសង្ស៥ប្រការផង ជាអ្នកមានចិត្តអាណិតអាសូរ ចំពោះភិក្ខុសង្ឃ ដែលបានគង់ចាំវស្សាអស់ត្រីមាសនោះផង និងជាអ្នកតអាយុព្រះពុទ្ធសាសនា អស់កាលជាយូរអង្វែងទៅផង។

ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងជាគាថាយ៉ាងនេះថា "សុខស្ស ទាតា មេធាវី សុខំ សោអធិគច្ឆតិ"។ ប្រែថា "ជនដ៏មានប្រាជ្ញា (ណាមួយ) បានធ្វើនូវសេចក្ដីសុខស្រួល (ដល់អ្នកដទៃ) ជននោះឯងរមែងបានជួបប្រទះនឹងសេចក្ដីសុខស្រួល (ជាពិតប្រាកដពុំដែលខានឡើយ)"។

សេចក្ដីអធិប្បាយជាយ៉ាងនេះថា ជនណាបានធ្វើកឋិនទាន ដែលនាំឱ្យភិក្ខុសង្ឃបានទទួលនូវអានិសង្ស៥យ៉ាងក្នុងរវាង៥ខែបានឈ្មោះថា ជាអ្នកឱ្យសេចក្ដីសុខស្រួលដល់អ្នកដទៃក្នុងបច្ចុប្បន្នជាតិ ជននោះឯងតែងបានសុខក្នុងមនុស្សលោក និងទេវលោកក្នុងអនាគត។

ដោយអំណាចផលានិសង្សនៃកឋិននោះក្នុងអនាគតកាល ជននោះនឹងបានជាឯហិភិក្ខុ មានត្រៃចីវរកើតឡើងឯកឯងដោយឫទ្ធិ នៅពេលបព្វជ្ជាជាបព្វជិតនៅក្នុងសាសនា ព្រះពុទ្ធអង្គណាមួយហើយក៏នឹងបានសម្រេចមគ្គផលនិព្វានក្នុងពេលបព្វជ្ជានោះពុំខានឡើយ"។

តាំងពីពេលនោះតរៀងមក បុណ្យកឋិនបានក្លាយជាបុណ្យទំនៀមមួយរបស់ពួកពុទ្ធបរិស័ទ ដើម្បីបំពេញនូវសេចក្ដីត្រូវការស្បង់ចីវរដ៏វិសេសនេះ។

## ១១.៤. ឈ្វេងយល់អំពីបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌ

ក្នុងប្រទេសកម្ពុជាយើង មានសាស្ត្រា ឬគម្ពីរ៣បែបចែងពីប្រភពគឺដើមកំណើតនៃបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ដូចមានសេចក្ដីបរិយាយនៅខាងក្រោមនេះ ៖

១ - សាស្ត្រាវិជ្ជាធរចែងថា ៖

កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ មានព្រះមហាថេរ ១ រូបឈ្មោះព្រះឧបគុត្តត្ថេរ បានហោះហៅថាទៅកាន់ឋាននរក ពេលនោះដោយឫទ្ធិរបស់លោក ពួកសត្វនរកបានដកដង្ហើមស្រួល១ស្របក ក៏នាំគ្នាផ្ដាំលោកថា សូមប្រាប់ម្ដាយឪពុកបងប្អូនកូនចៅញាតិផៅរបស់យើងខ្ញុំផង មានឈ្មោះដូច្នោះៗ នៅស្រុកឈ្មោះដូច្នោះៗ សូមឲ្យអាសូរករុណាដល់យើងខ្ញុំ ធ្វើបុណ្យឲ្យទានឧទ្ទិសផលមកឲ្យយើងខ្ញុំផង កុំខានបើដល់រនោចខែភទ្របទហើយ ញាតិសន្ដានបានធ្វើបុណ្យឲ្យទាន ឧទ្ទិសផលមកឲ្យយើង យើងខ្ញុំគ្រប់គ្នានឹង

ឲ្យសព្វសាធុការដល់ពួកញាតិទាំងនោះឲ្យបានសេចក្តីសុខសប្បាយ។

កាលនោះព្រះឧបគុត្តត្ថេរ ត្រឡប់មកពីឋាននរកមកវិញ លោកបានថ្វាយព្រះពរព្រះរាជា១អង្គ ព្រះរាជាអង្គនោះទ្រង់បានទទួលសួរព្រះសម្មាសម្ពុទ្ធថា បើមាតា បិតា យើងខ្ញុំត្រូវការធ្វើបុណ្យឧទ្ទិសផលជូនទៅលោកតើត្រូវធ្វើបុណ្យអ្វី?

ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា ត្រូវធ្វើបាយបិណ្ឌបាយបត្តបូរ រាល់ថ្ងៃចាប់តាំងពីថ្ងៃ១រោចខែភទ្របទដល់ថ្ងៃ១៥រោចខែភទ្របទ ត្រូវសមាទានសីល៥ និងឧបោសថសីល ត្រូវនិមន្តព្រះសង្ឃសូត្រធម៌ទេសនា ដារឆាន់រាល់ព្រឹក ហើយត្រូវឧទ្ទិសផលជូនទៅដល់ពួកញាតិសន្តាន ដែលទៅកើតក្នុងទុគ្គតិភព ញាតិទាំងនោះនឹងចូររួចរំដោះចាកទុក្ខ បានសុខក្នុងសុគតិភព ដូចសេចក្តីប្រាថ្នា។

២ - សាស្ត្រាអានិសង្សបិណ្ឌចែងថា ៖

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ចំពោះអនាថបិណ្ឌិកសេដ្ឋីថា តែដល់រនោចខែភទ្របទ ដែលគេរៀបកាន់បិណ្ឌនោះ ម្តាយឪពុក និងញាតិសន្តាន ដែលស្លាប់ទៅៗកើតទុគ្គតិភពទាំងប៉ុន្មាន សុទ្ធតែបានមកជួបជុំចាំទទួលផង ដែលកូនចៅបានធ្វើបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌឧទ្ទិសជូនទៅ ដោយអំណាចអានិសង្សប្រគេនបានបិណ្ឌបាយបត្តបូរដល់ព្រះសង្ឃនៅរនោចខែភទ្របទដែលកូនចៅឧទ្ទិសជូនទៅនោះ ពួកញាតិទាំងប៉ុន្មានក៏បានរួចរំដោះចាកទុគ្គតិភពទៅកើតក្នុងឋានសួគ៌ទេវលោកដូចសេចក្តីប្រាថ្នា។

៣ - គម្ពីរបេតវត្ថុចែងថា ៖

កាលព្រះសម្មាសម្ពុទ្ធទ្រង់គង់ធរមាននៅឡើយ មានព្រាណម្នាក់នៅក្រុងពារាណសី តែងទៅបាញ់សត្វក្នុងព្រៃ កាលព្រានត្រឡប់ពីព្រៃមកវិញ ពួកកូនក្មេងតែងចោមរោមសុំសាច់រាល់ថ្ងៃ ថ្ងៃមួយព្រានទៅបាញ់សត្វ ព្រានក៏បេះផ្កាត្របែក ឬផ្កាព្រឹកចងជុំវិញខ្លួនខ្លួន រែកខ្លះយកមកផ្ទះ លុះក្មេងៗសុំសាច់ ព្រានក៏ឲ្យផ្កានោះ ១ស្មែងម្នាក់ ដោយទោសនេះ ដល់ព្រាននោះស្លាប់ទៅ ទៅកើតជាប្រេតអាក្រាត មានផ្កាត្របែក ឬផ្ការាជព្រឹក្សជាប់នៅនឹងក្បាលដើរក្នុងទឹក ដើម្បីទៅសុំអាហារអំពីពួកញាតិបរិភោគ វេលានោះកាលិយអាមាត្យនៃព្រះបាទពិម្ពិសារ ជិះទូកទៅបង្ក្រាបស្រុកបច្ចន្តគ្រាមបានឃើញប្រេត ហើយមានសេចក្តីអាសូរហើយក៏សួរប្រេតថា យើងមានសត្វជុំ បើយើត្រូវការឲ្យអ្នក តើធ្វើដូចម្តេចអ្នកនឹងទទួលបរិភោគបាន? ប្រេតឆ្លើយថា បើក្នុងទូកនេះមានឧបាសកណា ជាអ្នកមានត្រៃសរណគមន៍ មានសីល សូមលោកឲ្យសត្វដល់ឧបាសកនោះហើយឧទ្ទិសផលឲ្យមកខ្ញុំចុះ លោលិយអាមាត្យ ធ្វើតាមប្រេតប្រាប់ ប្រេតក៏បានរួចចាកប្រេតភូមិនោះ ហើយប្រេតនោះផ្តាំថា សូមលោកមេត្តា បើលោកធ្វើបុណ្យទានឯណានីមួយ ហើយសូមឧទ្ទិសផលដល់ប្រេតឯទៀតៗផង លុះកោលិយអាមាត្យ ត្រឡប់មកស្រុកវិញ បានថ្វាយទានចំពោះព្រះពុទ្ធជាម្ចាស់ហើយ ក្រាបបង្គំទូលរឿងប្រេតនោះ ព្រះអង្គទ្រង់សំដែងបេតនិកាយឲ្យប្រាកដឡើង ដល់បរិស័ទក្នុងគ្រានោះ។

បណ្តាសាស្ត្រា និងគម្ពីរទាំង៣គឺ សាស្ត្រាវិជ្ជាធរ និងសាស្ត្រាអានិសង្សបិណ្ឌជាសាស្ត្រាសម្រាយ គ្មានឈ្មោះអ្នកតែងគ្មានប្រាប់ថា តែងក្នុងសម័យណាទេឯគម្ពីរ១គឺបេតវត្ថុជាអដ្ឋកថាព្រះសុត្តន្តបិដកខុទ្ទកនិកាយ

ព្រះធម្មបាលាចារ្យតែងក្នុងសម័យក្រោយ ព្រះសម្មាសម្ពុទ្ធបរិនិព្វាន តំណាលគ្នាអដ្ឋកថាព្រះសុត្តន្តបិដកទាំងពួង។

ការពិចារណាតាមរូបរឿងក្នុងសាស្ត្រា និងគម្ពីរដែលពោលមកហើយនេះ ឃើញថារបៀបបុណ្យកាន់បិណ្ឌក្នុងកម្ពុជរដ្ឋយើងនេះ ត្រូវតាមសេចក្ដីក្នុងសាស្ត្រាវិជ្ជាធរខ្លះ សាស្ត្រាអានិសង្សបិណ្ឌខ្លះ និងគម្ពីរបេតវត្ថុខ្លះ គឺកំណត់ថ្ងៃខែធ្វើ ត្រូវតាមសាស្ត្រាវិជ្ជាធរ និងសាស្ត្រាអានិសង្សបិណ្ឌ ឯរបៀបធ្វើផ្កាបិណ្ឌ និងកិច្ចឧទ្ទិសផលទៅប្រេតត្រូវតាមគម្ពីរបេតវត្ថុ គឺបាយបិណ្ឌដែលគេធ្វើដើម្បីឧទ្ទិសដល់ប្រេតនោះ គេប្រដាប់ដោយផ្កាធ្វើពីស្លាន់ក្រាប ឬក្រដាសពណ៌ និងផ្កាឈើផ្សេងៗ មានទំនងប្រហែលគ្នា និងអាការរបស់ប្រេតដែលមានចែងក្នុងគម្ពីរបេតវត្ថុនោះថា ប្រេតមានផ្កាត្របែកប្រដាប់ក្បាលដើរមករកអាហារ ឯផ្នុះញាតិរបស់ខ្លួនគឺថា ទំនៀមដែលគេធ្វើបាយបិណ្ឌបាយបត្តបូរប្រគេនព្រះសង្ឃ ដោយមានក្បូរក្បាច់ភ្ញីផ្កា ជាអម្បូរប្លែកពីបិណ្ឌបាតទានឯទៀត ប្រហែលជាបុរាណបណ្ឌិតប្រឌិតធ្វើតាមរឿងប្រេងក្នុងគម្ពីរបេតវត្ថុនោះឯង។

កាលដែលពុទ្ធបរិស័ទជាតិខ្មែរ តែដល់ថ្ងៃ១រោចខែភទ្របទ តែងនាំគ្នាទៅកាន់បិណ្ឌក្នុងទីអារាមរាល់ថ្ងៃ ដរាបដល់ថ្ងៃ១៥រោចខែភទ្របទ តែងនាំគ្នាទៅកាន់បិណ្ឌគេភ្ជុំគ្នាធ្វើបង្ហើយហៅថា ភ្ជុំបិណ្ឌ ទោះបីអ្នកទាល់ក្រលំបាកយ៉ាងណា ក៏ធ្វើឲ្យបានយ៉ាងតិចណាស់ត្រឹមថ្ងៃភ្ជុំ ជាថ្ងៃបង្ហើយពុំហ៊ានខាននោះ ក៏ដោយហេតុជឿតាមសាស្ត្រាវិជ្ជាធរ សាស្ត្រាអានិសង្សបិណ្ឌ គម្ពីរបេតវត្ថុ ហើយនឹងជឿតាមដំណើរចាស់ៗ ដែលធ្លាប់ធ្វើឲ្យឃើញរឿយៗ ដោយមានចិត្តអាណិតដល់មាតាបិតា ជីដូន ជីតា និងញាតិសន្តា សាលោហិតដែលចែកឋានទៅហើយ។

## ១១.៥. ឈ្វេងយល់អំពីការបំបួសនាគ

ប្រវត្តិ និងអត្ថន័យនៃការបំបួសនាគ ដែលកូនខ្មែរមួយចំនួនបានបំភ្លេចចោល លែងអនុវត្តដូចពីជំនាន់មុន!

សង្គមខ្មែរពីសម័យបុរាណនៅមុនពេលកម្លោះចូលស្ដីដណ្ដឹងកូនក្រមុំ រៀបមង្គលការជាភរិយា គឺឪពុកម្ដាយតែងតម្រូវឲ្យកូនប្រុសចូលទៅបួសរៀន យកចំណេះចេះដឹង និងដុសខាត់គំនិតមារយាទ នៅវត្តអារាមព្រោះសម័យនោះ ខ្មែរយើងមិនទាន់មាន សាលារៀន ឬមហាវិទ្យាល័យ ដូចសព្វថ្ងៃនេះទេ។ ក្រោយពីចាកសិក្ខាបទមកវិញ អ្នកស្រុកច្រើនហៅកូនកម្លោះនោះថា អ្នកបណ្ឌិត។ ចំណេរកាលក្រោយមក ពាក្យហៅនោះក៏ក្លាយជា"អន្ទិតៗ"គឺសំដៅទៅរកប្រុសកម្លោះដែលបានបួសរៀន មានការចេះដឹងទាំងផ្លូវលោក និងផ្លូវ ធម៌។

ការចូលទៅបួសរៀននោះ ត្រូវបានគេហៅថា "**បំបួសនាគ**"។ នៅបច្ចុប្បន្ននេះ ពលរដ្ឋយើងមិនសូវដឹងជ្រៅ ជ្រួតជ្រាប អំពីពិធីនេះទេ។ ចំពោះអត្ថន័យនៃពាក្យថា "**នាគ**" នៅទីនេះ មិនមែនសំដៅទៅលើសត្វនាគនោះទេ តែមានន័យថា ល្អប្រសើរ ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម។

ដូច្នេះ ការ"**បំបួសនាគ**" ផ្ដោតអត្ថន័យសំខាន់ ទៅលើអ្នកដែលមានឋានៈខ្ពង់ខ្ពស់ អ្នកប្រសើរ ដែលបានលះបង់ នូវអំពើបាបគ្រប់យ៉ាង។ ព្រះពុទ្ធជាម្ចាស់បានប្រទានព្រះនាមនេះដល់នរជនណា ដែលសុខចិត្តលះបង់ចោល នូវអំពើមិនល្អ ហើយងាកមករកការកសាងធម៌វិញ។

ការបំបួសនាគចែកចេញជាពីរបែបគឺ បំបួសភិក្ខុ និងបំបួសនេន។ បួសភិក្ខុ គឺសម្រាប់បុរសពេញវ័យ ចាប់ពី ២០ឆ្នាំឡើង រីឯបំបួសនេនគឺការបំបួសតាំងពីអាយុ៧ឆ្នាំឡើងទៅ។

កាលពីសម័យដើម ប្រទេសខ្មែរយើងក៏ធ្លាប់មាននារីៗវ័យក្មេង ស្ម័គ្រចិត្តទៅបួស ជាភិក្ខុនីដូចបុរសដែរ ប៉ុន្តែក្រោយមក សង្គមបានហាមឃាត់វិញ ដោយសារគេយល់ឃើញថា នារីៗមានចិត្តចង់មាន ចង់បានជាងបុរសៗ ដែលនាំឲ្យចិត្តមិនស្ងប់។ ម្យ៉ាងវិញទៀត នារីអាចមានផលវិបាក ប្រសិនបើជួបប្រទះនូវឧបសគ្គអ្វីមួយ ដូចជាត្រូវប្រឈមមុខ នឹងសត្វសាហាវ នៅពេលដើរក្នុងព្រៃ ម្នាក់ឯងជាដើម ដូច្នេះហើយ សង្គមក៏ផ្លាស់ប្តូរ ការបង្រៀនអប់រំនារី ដោយពិធីចូលម្លប់វិញ។

## រឿងព្រេងនៃពិធីបំបួសនាគ

ទំនៀមបំបួសនាគនេះ មានរឿងព្រេងពីបុរាណមួយនិទានថា កាលដែលព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្នុងវត្តជេតពន់ នាគរាជមួយមានមហិទ្ធិរិទ្ធិមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាចង់បួសជាភិក្ខុ ក៏កាឡាខ្លួនជាមាណពចូលទៅថ្វាយ បង្គំព្រះមហាតិស្សត្ថេរ ហើយទូលថា "ខ្ញុំព្រះករុណាសូមបួសជាព្រះមហាថេរផង"។ ព្រះមហាតិស្សត្ថេរ ក៏បំបួស ស្តេចនាគកាឡានោះជាភិក្ខុទៅ។

ថ្ងៃមួយនៅពេលដែលភិក្ខុស្តេចនាគនោះសិងពេលថ្ងៃ យ៉ាងស្កប់ស្កល់ខ្លួនលោក ក៏ក្លាយជានាគធ្វាយវង្វេលពេនពេញបន្ទប់។ ស្បង់ចីវរខ្ទាត់ខ្ទាយអស់លើងអំពីកាយ។ ពេលនោះសាមណេរមួយ អង្គផ្ទង់ចង្ហាន់រួចចូលទៅនិមន្តឆាន់ លុះបើកទ្វារទៅស្រាប់តែឃើញពស់ពេនពេញបន្ទប់ ភ័យរន្ធត់ស្ទុះរត់ស្រែក ឆោឡោផ្អើលពេញទាំងវត្ត។ លុះជ្រាបទៅដល់ព្រះដ៏មានបុណ្យ ទើបព្រះអង្គទ្រង់ព្រះត្រាស់ថា "ចាប់ពីថ្ងៃនេះទៅ ភិក្ខុឯក្រោយកុំបីបំបួសសត្វតិរច្ឆាននូវខ្មោច បិសាច រាជកូត យក្សាឡើយ"។ អាស្រ័យដំណើរដែលព្រះអង្គទ្រង់ត្រាស់ដូច្នេះ ទើបភិក្ខុនាគក្រាបទូលព្រះដ៏មានបុណ្យថា "ខ្ញុំព្រះអង្គនេះមានចិត្តស្មោះចំពោះសាសនាព្រះអង្គពិតណាស់ ឥតមានក្លែងបន្លំទេ បើខ្ញុំព្រះអង្គមានភេទជា សត្វ មិនអាចបួសក្នុងសំណាក់ព្រះអង្គបាន ដូច្នេះខ្ញុំព្រះអង្គសូមពរឱ្យមានព្រះត្រាស់ថា បើភិក្ខុនឹងបំបួសកុលបុត្រ សូមឱ្យហៅអ្នកសុំផ្នួសនោះថា "នាគ" ដូច្នេះតទៅ ដើម្បីឱ្យគេនឹកឃើញដល់ឈ្មោះខ្ញុំព្រះអង្គ ដែលជាអ្នកស្មោះចំពោះសាសនាព្រះអង្គ តែពុំមាននិស្ស័យនឹងបានបួស ជាភិក្ខុដូចមនុស្សផងទាំងពួង។ ព្រះពុទ្ធអង្គ ទើបបញ្ញត្តិពាក្យឱ្យហៅបព្វជ្ជាបេក្ខៈនិងឧបសម្បទាបេក្ខៈថា"នាគ" តាមសំណូមពរដែលស្តេចនាគសុំ។ អាស្រ័យរឿងនេះឯង ទើបមានឈ្មោះ ហៅថា "នាគ នាគ"រហូតមក។

## ប្រវត្តិនៃពិធីបំបួសនាគ

នៅពេលដែលព្រះពុទ្ធ នៅជាឧបាសក ព្រះជន្ម ២៩ឆ្នាំ ព្រះអង្គបានរៀបអភិសេក ជាមួយព្រះនាងពិម្ពា។ មានថ្ងៃមួយ ព្រះអង្គអផ្សុកកាយពេក ក៏ត្រាស់ហៅអាអាមាត្យ ឲ្យជូនទៅក្រសាល នៅសួនច្បារក្នុងព្រះបរមរាជវាំង។ ខណៈដែល ព្រះអង្គកំពុងទតផ្កាចំរុះពណ៌គ្នា ក៏ស្រាប់តែប្រទះ ឃើញមនុស្សវ័យចំណាស់ម្នាក់កោងខ្នងដើរកាន់ឈើច្រត់ កាត់ព្រះភ័ក្ត្រព្រះអង្គ ពេលនោះព្រះអង្គក៏សួរទៅអាអាមាត្យថា នោះជាអ្វី? អាមាត្យក៏ទូលព្រះអង្គថា "គឺជាមនុស្សចាស់" ពេលនោះ ព្រះអង្គគិតក្នុងព្រះទ័យថា "តាមពិតមនុស្សចាស់ទៅ គឺបែបហ្នឹងទេតើ"។

នៅថ្ងៃទី២ ព្រះអង្គក៏បានទត ឃើញមនុស្សចាស់ម្នាក់កាន់បំពង់ឫស្សី ហើយក៏កើតមានចម្ងល់ទៀត។ ព្រះអង្គសួរទៅអាអាមាត្យ អាមាត្យទូលថា "គឺជាមនុស្សឈឺ" ។ ពេលនោះ ព្រះអង្គមានព្រះរាជបន្ទូល ខ្សឹបៗ

តែម្នាក់ឯងថា "មនុស្សចាស់ហើយ ត្រូវតែឈឺ"។ នៅថ្ងៃបន្តទៀត ស្រាប់តែមានមនុស្សដង្ហែសព កាត់ព្រះភ័ក្ត្រព្រះអង្គ ព្រះអង្គក៏ឆ្ងល់ទៀតថា ហេតុអ្វីម្នាក់នេះហើមខ្លួនប្រាណ ហើយត្រូវគេសែងទៀត។ អាអាមាត្យក៏ទូលថា "នេះគឺមនុស្សស្លាប់"។

ប៉ុន្មានថ្ងៃ ក្រោយមកទៀត ភិលៀងបានមកទូលព្រះអង្គថា ព្រះនាងពិម្ពាប្រសូត្របានបុត្រា។ ព្រះអង្គសប្បាយ ព្រះទ័យយ៉ាងខ្លាំង ប៉ុន្តែមួយសន្ទុះក្រោយមក ព្រះអង្គស្វែងយល់ឃើញថា មនុស្សម្នាក់ៗ មិនអាចគេចផុតពី កើត ចាស់ ឈឺ ស្លាប់ នោះបានឡើយ។

ស្របពេលជាមួយគ្នានោះ ព្រះអង្គក៏បានប្រទះឃើញអ្នកបួស ដែលលែងគិតពី រឿងស្មុគស្មាញ អ្វីទាំងអស់ ហើយគិតគួររៀនតែធម៌វិន័យ ដែលធ្វើឲ្យអារម្មណ៍ស្ងប់។ ពេលនោះ ព្រះអង្គក៏សម្រេចចិត្ត បោះបង់ចោលរាជបល្ល័ង ទ្រព្យសម្បត្តិ មាសពេជ្រ កែវកង រួមទាំងភរិយា និងបុត្រាផង ដើម្បីទៅបួសជាភិក្ខុ។ ដោយមូលហេតុនេះ ទើបពិធីបំបួសនាគនេះ បានត្រូវចាប់បដិសន្ធិឡើង ជាទំនៀមទម្លាប់រៀងរហូតមក។

**តើប្រារព្ធពិធីបំបួសនាគយ៉ាងដូចម្ដេចខ្លះ?**

ថ្ងៃទី១៖ ឪពុកម្ដាយ រួមទាំងសាមីខ្លួន ដែលស្ម័គ្រចិត្តបួសនោះ ត្រូវធ្វើដំណើរមកកាន់វត្តអារាម។ លុះដល់ថ្ងៃត្រង់ វេលាម៉ោង ១រសៀល ទើបចាប់ផ្ដើមពិធីកោរសក់ រួចទៅងូតទឹកជម្រះកាយ លាបប្រេងម្សៅតាមការគួរ (សាច់ញាត្តិតុបតែងខ្លួនឱ្យនាគ អាចលាបម្សៅលាបក្រេមបាញ់ទឹកអប់ពាក់គ្រឿងមាសខ្សែរករខ្សែរដៃកងជើងជាដើម បន្ទាប់ពីបួសហើយគឺគេលែង៩ប៉ះពាល់របស់អស់នេះទៀតហើយ)ហើយបំពាក់ចីពរស ទៅបុរសនោះ ដែលគេច្រើនហៅថា ជា «នាគ ឬកូននាគ »។ នៅម៉ោង៦ល្ងាច គេមានពិធីសូត្រមន្ត។

ថ្ងៃទី២៖ បន្ទាប់ពីស្រស់ស្រូវអាហារពេលព្រឹករួច សាច់ញាតិជិតខាង និងបងប្អូនដែលរស់នៅក្បែរវត្តនាំគ្នាហែហមដង្ហែកូននាគ ចំនួន ៣ជុំ ព្រះវិហារ វត្ត ដែលជាភស្តុតាង តំណាងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។

បន្ទាប់មក អ្នកបួសត្រូវចាប់ផ្ដើមរៀនធម៌ រំងាប់អារម្មណ៍កិលេសទាំងឡាយ ដើម្បីលាងបាបកម្ម ដែលបានធ្វើកន្លងមក។ កាលពីសម័យបុរាណ អ្នកចូលទៅបួសរៀន នៅក្នុងទីវត្តអារាម ត្រូវចំណាយពេលវេលាយ៉ាងតិចគឺមួយព្រះវស្សា(មួយឆ្នាំ) ទើបអាចសឹកមកកសាងជីវិតជាមនុស្សសាមញ្ញវិញ។

**ពិធីបំបួសនាគលម្អិត**

ទំនៀមបួសនាគ ក៏មានលំនាំផ្សេងៗ ខុសគ្នាបន្តិចៗ ដូចជាទំនៀមធំៗ ដទៃទៀតដែរ មានទំនៀមខ្លះដែលគេយល់ឃើញថា មិនត្រឹមត្រូវតាមច្បាប់ព្រះពុទ្ធសាសនា គេក៏កាត់ចោលទៅ ទំនៀមខ្លះដែលកើតឡើងតាមកាលៈទេសៈ ក៏ត្រូវបញ្ចូលមកវិញ។ ហេតុនេះយើងសូមជម្រាបថា សេចក្ដីអធិប្បាយអំពីពិធីបំបួសនាគដែលយើងនឹងអធិប្បាយជូនក្នុងទីនេះ ពុំមែនជារបៀបតួយ៉ាង ដែលគេត្រូវតែធ្វើតាមនោះទេ គឺជារបៀបទំនៀមយ៉ាងសង្ខេបមួយ ដែលគេធ្លាប់បានឃើញធ្វើមកហើយ។

មុនថ្ងៃបំបួសចំនួន ៤-៥ ថ្ងៃ អ្នកដែលត្រូវចេញទៅបួស ត្រូវកាន់ទៀនធូបទៅជម្រាបលាបងប្អូន និងញាតិមិត្តរបស់ខ្លួន ដើម្បីឲ្យគេបានដឹងផងថា : ខ្លួននឹងចូលទៅបម្រើព្រះពុទ្ធសាសនាហើយ។

ទំនៀមដែលយើងអធិប្បាយដូចតទៅនេះ ជាទំនៀមដែគេធ្វើនៅគេហដ្ឋានសាមីខ្លួនក៏បាន ឬធ្វើនៅទីអារាមក៏បាន ប៉ុន្តែពិធីខ្លះគេលះបង់អស់ទៅហើយ។

បើបំបួសសាមណេរ ត្រូវមានរៀបចំត្រៃចីវរ បាត្រ កន្ទេល ខ្នើយ។ បើបំបួសជាភិក្ខុវិញ ត្រូវមានកាំបិតកោ ថ្មសំលៀង បំពង់ម្ជុលថែមលើបរិក្ខារខាងលើនេះទៀតទើបគ្រប់។ ក្រៅអំពីបរិក្ខារទាំងនេះ មានដបទឹក

អប់ បាយសីធំមួយ ធ្វើដោយដើមចេកមួយដើម ដែលមានកំពស់ត្រឹមចិញ្ចើមមនុស្សឈរ។ បាយសីនោះមាន ១៩ ថ្នាក់ ដែលជាតំណាងព្រលឹងមនុស្សទាំង ១៩ ប៉ុន្តែមានអ្នកខ្លះ ធ្វើសង្ខេបត្រឹមតែ ៩ថ្នាក់។ នៅលើកំពូលបាយសីមានកន្ទោងស្លឹកចេកមួយ ដាក់បាយព្រលឹង ១៩ (ឬ ៩) ពំនូត មានសាជីធ្វើដោយស្លឹកចេកគ្របពីលើ ហើយនៅលើកំពូលសាជីមានដោតទៀនរាយមួយផង។ គេយកស្លឹកចេក ៣ ជាងមករុំព័ទ្ធបាយសីនោះ ១ ជាន់ រួចទើបយកសំពត់ហូលរុំ ១ ជាន់ពីក្រៅទៀត។

លុះរៀបគ្រឿងបរិក្ខារដូចបានពោលមកនេះ ជាជួរតាមលំដាប់ស្រេចហើយ នាគត្រូវចូលទៅអង្គុយជិតបាយសីធំ ដើម្បីស្តាប់ព្រះសង្ឃចម្រើនព្រះបរិត្ត ដោយមានឪពុកម្តាយបងប្អូននឹងក្រុមញាតិមិត្រអង្គុយអមផង។ បន្ទាប់មកគេរៀបធ្វើពិធី "ហៅព្រលឹងនាគ" គ្រានោះអាចារ្យកាន់អំពៅខ្មៅ ១ ដើមដែលគេទុកឲ្យមានសន្លឹកពីរឬបីនៅចុង ហើយចងឲ្យមានទំនងដូចចំពុះបក្សី។ អាចារ្យកាន់ដើមបង្វៃចំពុះនោះនៅគ្រប់ទិសបោយហៅព្រលឹងឲ្យនាគ2 បន្ទាប់មកគេរៀប "ធ្វើធ្មេញ" ឲ្យនាគទៀត។

កាលជំនាន់ដើម នៅពេលបំបួសនាគក្តី នៅពេលរៀបអាពាហ៍ពិពាហ៍ក្តី គេនិយមយកម្រ័ក្សបុកលាយជាមួយរុក្ខជាតិខ្លះទៀត ដើម្បីយកទៅលាបធ្មេញសាមីខ្លួនឲ្យមានសម្បុរខ្មៅស្រិលមែនៗ។ សព្វថ្ងៃនេះ អាចារ្យគ្រាន់តែរៀប "ធ្វើធ្មេញ" "បំពេញកិច្ចទេ តមកទៀតអាចារ្យរៀបចំបញ្ចុកបាយនាគ" គឺគេយកបាយព្រលឹងទៅដាក់ក្នុងទឹកដូងហើយបញ្ចុកមាត់នាគទៅ រួចហើយទើបគេយកអំបោះជ្រលក់ទឹកមន្ត ចងដៃនាគ។ បន្ទាប់មកទៀត ពួកក្រុមញាតិសាច់សាលោហិតនាំគ្នាអង្គុយជាវង់ជុំវិញនាគ ហើយរៀបបង្វិលពពិល ដើម្បីចម្រើនសិរីសួស្តីជ័យមង្គលដល់នាគនោះ។ ជាធម្មតា គេត្រូវបង្វិលពពិល ១៩ ជុំ ហើយបក់ផ្សែងសំដៅទៅរកនាគផង។ លុះគ្រប់កំណត់ជុំហើយ អាចារ្យពន្លត់ទៀន រួចយកកំញម លាយជាមួយនឹងទឹកអប់បន្តិចយកទៅលាបចិញ្ចើមនិងថ្ពាសនាគ។

ថ្ងៃបន្ទាប់មក គេរៀបក្បួនហែនាគទៅកាន់វត្តព្រះកែវមក៌ត បើប្រសិនជានាគនោះជាវង្សក្សត្រ ឬជាកូននាម៉ឺនជាន់ខ្ពស់ ការហែនាគមានសភាពគគ្រឹកគ្រេងណាស់ ស្ទើរតែប្រហាក់ប្រហែលនឹងការរៀបចំហែស្តេច១ព្រះអង្គដែរ ព្រោះកាលដែលព្រះបរមសាស្តាយើង ទ្រង់ចេញទៅសាងព្រះផ្នួស ព្រះអង្គជារាជបុត្រាក្សត្រគ្រងរាជ្យដែរ។ គេឃើញមានភ្លេងឆៃយ៉ាំ១ ក្រុមចេញដើរមុខក្បួនមានមនុស្ស ទ្រពានប្រាក់តំកល់ត្រៃចីវរ ទ្របាត្រនិងគ្រឿងសក្ការៈបូជា ដើរមុខនាគ។ បន្ទាប់មកទៀត នាគដែលមានសំលៀកបំពាក់ដូចស្តេចសម័យបុរាណជិះសេះមាន មនុស្សបាំងក្លស់ឲ្យផង។

នៅមុខវត្ត មានមនុស្សកំប្លែងម្នាក់ធ្វើជាមារាធិរាជ ដែលចាំរារាំងព្រះពោធិសត្វ មិនឲ្យចេញទៅបួសស្ទុះទៅចាប់មុខសេះដែលនាគជិះ ហើយធ្វើហាក់ដូចជាឃាត់មិនឲ្យនាគចូលទៅបួស។ ប៉ុន្តែនាគមិនព្រមលោតចុះពីលើខ្នងសេះ ហើយដើរចូលទៅក្នុងទីវត្ត ដោយមានក្រុមញាតិសាលោហិតហែតាមពីក្រោយផង។ ដល់ហើយក្បួនហែនាគដើរប្រទក្សិណព្រះវិហារ៣ជុំ អាចារ្យស្រែកអនុមោទនា ហើយទទួលយកភេទជាបព្វជិត។ នៅពេលដែលអាចារ្យស្រែកថា ៖ "អនុមោទនា លោអើយ ! " អ្នកដើរហែទាំងប៉ុន្មានក៏ទទួលព្រមគ្នាថា សាធុ ! ប្រែថា ប្រពៃហើយ ប្រសើរហើយ។

លុះហែប្រទក្សិណគ្រប់៣ជុំហើយ នាគចូលទៅក្នុងព្រះវិហារ អុជធូបទៀនដោតនៅមុខពុទ្ធាសនៈ រួចថ្វាយបង្គំព្រះពុទ្ធរូប៣ដង ទើបថយទៅអង្គុយពីមុខត្រៃចីវរ និងបាត្រ។ បើមាននាគច្រើនរូប នាគត្រូវអង្គុយជាជួរ តាមលំដាប់អាយុចាស់ក្មេង។ បើបួសជាសាមណេរមានតែលោកជាឧបជ្ឈាយ១ អង្គជាការស្រេច តែបើ

បួសជាភិក្ខុវិញ ច្បាប់វិន័យពុទ្ធសាសនាថា ត្រូវមានព្រះសង្ឃយ៉ាងតិចត្រឹម៥អង្គ។

តពីនេះ នាគកាន់ទ្រសំពត់កាសាវៈគឺ ស្បង់ចីពរចូលទៅដាក់ចំពោះមុខព្រះឧបជ្ឈាយ៍ហើយថ្វាយបង្គំ ៣ដង សូត្រធម៌វន្ទាសូមខមាទោសរួចហើយសូត្រពាក្យសុំផ្នួសជាគម្រប់៣ដង ព្រមទាំងប្រគេនសំពត់កាសាវៈ ទៅព្រះឧបជ្ឈាយ៍ៗ ទទួលហើយ នាគសូត្រសុំសំពត់កាសាវៈនោះមកវិញ។ ព្រះឧបជ្ឈាយ៍ក៏ប្រគល់ឲ្យតាមសុំ "នាគអង្គុយច្រហោងប្រណម្យអញ្ជលី កាន់ទ្រសំពត់កាសាវៈនៅមុខព្រះឧបជ្ឈាយ៍ៗ ចាប់ចុងម្រាមដៃហើយ ប្រាប់ធម៌កម្មដ្ឋាន ៥ យ៉ាងហៅថា តចបញ្ចកកម្មដ្ឋាន ដែលហៅតាមទម្លាប់ថាឲ្យធម៌ "កេសា" ឲ្យនាគថាតាម ដោយមានបាលីថា កេសា លោមា នខា ទន្តា តចោ ប្រែថា "សក់ រោម ក្រចក ធ្មេញ ស្បែក"។ ហើយប្រាប់ ប្រាសមកវិញទៀតថា តចោ ទន្តា នខា លោមា កេសា ប្រាប់ពន្យល់នាគឲ្យយល់ច្បាស់ថា របស់ទាំង៥យ៉ាង នេះ ជាវត្ថុបដិកូលស្មោគគ្រោក គួរខ្ពើមរអើម។ រួចកិច្ចនេះហើយ ព្រះឧបជ្ឈាយ៍យកអង្សកពាក់កនាគជា សញ្ញាថា នឹងបានទៅជាសាមណេរហើយ។ នាគងាកខ្លួនទៅផ្លាស់សំលៀកបំពាក់គ្រហស្ថចេញក្នុងទីដ៏សម គួរ ហើយទើបស្លៀកស្បង់ចីពរ ត្រឹមត្រូវតាមច្បាប់វិន័យ។ បន្ទាប់ពីនេះនាគកាន់គ្រឿងសក្ការៈបូជា មានទៀន ធូបជាដើមចូល ទៅថ្វាយបង្គំព្រះឧបជ្ឈាយ៍ សូត្រពាក្យសុំត្រៃសរណគមន៍និងសីលព្រះឧបជ្ឈាយ៍ឲ្យត្រៃ សរណគមន៍និងសីល១០តាមសុំ រួចហើយទើបសាមណេរសូត្រសុំនិស្ស័យ (ទីនៅអាស្រ័យ) ចំពោះព្រះ ឧបជ្ឈាយ៍ បើបួសជាសាមណេរ ពិធីបំបួសត្រូវចប់អស់តែត្រឹមប៉ុណ្ណេះឯង។

បើត្រូវការបំពេញឧបសម្បទាជាភិក្ខុ ត្រូវមានកិច្ចបន្តទៅទៀតគឺសាមណេរនោះ ត្រូវស្ពាយបាត្រក្រោក ឈរឡើង ចូលទៅកណ្តាលជំនុំសង្ឃ ចំពោះមុខព្រះឧបជ្ឈាយ៍ ទើបឧបសម្បទាចារ្យ (គ្រូសូត្រ) សូត្រតាំង នាមឧបសម្បទាបេក្ខៈ និងព្រះឧបជ្ឈាយ៍ប្រាប់បង្ហាញដល់នាគនូវបាត្រ សង្ឃាដី ចីពរ និងស្បង់ ឲ្យនាគទទួល ស្គាល់យល់ដឹងថា "នេះបាត្ររបស់អ្នក" ជាដើម ហើយឲ្យនាគថយទៅឈរឆ្ងាយបន្តិច ផុតពីទីប្រជុំសង្ឃ ទើប សូត្រប្រកាសប្រាប់សង្ឃសុំឱកាសប្រៀនប្រដៅនាគព្រមទាំងសាកសួរនូវកិច្ចផ្សេងៗ មានរោគពាធក្នុងខ្លួនជា ដើម ដើម្បីឲ្យដឹងថា សាមីខ្លួននោះបរិសុទ្ធស្អាត អាចនឹងទទួលឧបសម្បទាពេញលក្ខណៈជាភិក្ខុបានឬទេ។ លុះប្រៀនប្រដៅសាកសួររួចហើយ ទើបលោកគ្រូសូត្រនោះ ត្រឡប់ចូលមកក្នុងកណ្តាលជំនុំសង្ឃវិញសូត្រ ប្រកាសប្រាប់សង្ឃ និងហៅនាគឲ្យចូលមកអង្គុយកណ្តាលជំនុំសង្ឃថ្វាយបង្គំព្រះឧបជ្ឈាយ៍ និងព្រះសង្ឃរួច ហើយ ឲ្យអង្គុយច្រហោងប្រណម្យអញ្ជលីសូត្រសូមឧបសម្បទា ចំពោះសង្ឃ៣ដងគឺ សូមឲ្យសង្ឃអនុគ្រោះ លើកខ្លួនឲ្យផុតពីភេទជាសាមណេរ ហើយតំកល់តំកើងឲ្យឡើងពេញលក្ខណៈជាភិក្ខុ។ ពេលនោះជំនុំសង្ឃ ត្រូវអង្គុយព័ទ្ធចូលឲ្យជាប់ហត្ថបាសគ្នា ទើបលោកគ្រូសូត្រសួរបញ្ជាក់នាគ នូវអន្តរាយិកធម៌ គឺរោគាពាធ ផ្សេងៗជាដើម ដែលបានសួរខាងក្រៅជំនុំសង្ឃហើយនោះថែមមួយលើកទៀត។ លុះបានសាកសួរកិច្ចនេះ ចប់សព្វគ្រប់ហើយឧបសម្បទាចារ្យ (លោកគ្រូសូត្រ) សូត្រញត្តិចតុក្កកម្មវាចា៣។ ចប់ញត្តិចតុក្កកម្មវាចា ខណៈណា ឧបសម្បទាបេក្ខ គឺសាមណេរនោះ ក៏បានឋិតនៅក្នុងភេទជាភិក្ខុពេញបរិបូណ៌ក្នុងខណៈនោះ។ បន្ទាប់ពីនេះព្រះឧបជ្ឈាយ៍ ឬលោកគ្រូសូត្រប្រៀនប្រដៅប្រាប់នូវវិន័យសង្ឃករណីកិច្ចចំពោះភិក្ខុថ្មីនោះ (ហៅ តាមទម្លាប់ថា "ផ្តាំនាគ" តាមប្រពៃណីពីបុរាណ ផ្តាំនាគនេះលោកសូត្រជាបទយ៉ាងគ្រលួច គួរជាទីចាប់ អារម្មណ៍ពីរោះណាស់ នាំឲ្យមាតាបិតា និងបងប្អូនរបស់ភិក្ខុថ្មី យំស្រក់ទឹកភ្នែកស្រណោះអាឡោះអាល័យ យ៉ាងក្រលែង។

## ១១.៦. ឈ្វេងយល់ការចូលវស្សា និងការចេញវស្សា

ការចាំវស្សា

មូលហេតុនៃការចូលវស្សា

សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវន នាក្រុងរាជគ្រឹះ គ្រានោះឯង ការចាំវស្សាព្រះមានព្រះភាគមិនទាន់បានអនុញ្ញាតដល់ភិក្ខុទាំងឡាយនៅឡើយទេ។ភិក្ខុទាំងនោះក៏ចេញដើរទៅកាន់ចារិកផ្សេងៗ អស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណសក្យបុត្ត មិនសមបើនឹងដើរខុសរដូវកាល ជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀននូវវត្ថុដែលមានជីវិតមានឥន្ទ្រិយតែមួយ ជាន់សត្វល្អិតៗឲ្យវិនាសសោះ។ សូម្បីពួកបរិព្វាជកាមានលទ្ធិដទៃ ជាអ្នកពោលធម៌អាក្រក់ ម្ដេចគង់នឹងសំងំឈប់សម្រាក់ចាំវស្សា ឬសូម្បីសត្វស្លាបបក្សាបក្សីទៀតសោត ក៏គង់តែធ្វើសម្បុកលើចុងឈើហើយសំងំឈប់សម្រាកចាំវស្សាដែរ។ ពេលមនុស្សទាំងឡាយកំពុងលើកទោសបែបនេះ ពួកភិក្ខុទាំងឡាយក៏បានឮច្បាស់នឹងត្រចៀកផ្ទាល់ហើយក៏នាំសេចក្ដីនោះ ទៅក្រាបទូលព្រះសម្ពុទ្ធ ព្រះសាស្ដាទ្រង់ធ្វើធម្មិកថា ត្រាសហៅភិក្ខុទាំងឡាយមកអនុញ្ញាតថា **អនុជានាមិ ភិក្ខវេ វស្សំ ឧបគន្តុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយចូលវស្សា។

ទំនៀមទម្លាប់ព្រះពុទ្ធសាសនា តែដល់វស្សានរដូវហើយ គឺចាប់តាំងពីថ្ងៃ ១ រោច ខែ អាសាឍ រហូតទល់នឹងថ្ងៃ ១៥ កើត ខែ កត្តិក រយៈកាល៤ខែនេះភិក្ខុសាមណេរ ពុំត្រូវត្រាចចររហេតរហូតទេ ត្រូវរកទីលំឈប់សម្រាកមួយកន្លែងអស់ចិរវេលា ៣ ខែ ដែលលោកហៅថា ចាំវស្សា ។

**ការចាំវស្សាមាន ២ យ៉ាងគឺ**

១ លើកដំបូងភិក្ខុ សាមណេរត្រូវចូលវស្សាពីថ្ងៃ ១ រោច ខែ អាសាឍ ឬ ទុតិយាសាឍ រហូតទល់នឹងថ្ងៃ ១៥ ខែ អស្សុជ ចូលរបៀបនេះហៅថា បរិមិកាវស្សា។

បើឆ្នាំណាមានអធិកមាស ត្រូវវស្សានៅថ្ងៃ ១ រោច ខែ ទុតិយាសាឍ ព្រោះមានពុទ្ធានុញ្ញាតថា **អនុជានាមិ ភិក្ខវេ រាជូនំ អនុវត្តិតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតឲ្យចូលវស្សាទៅតាមការអនុវត្តលើកខែរបស់ព្រះរាជាចុះ (ព្រះបាទមាគធសេនិយពិម្ពិសារ)។

២ លើកក្រោយ ចូលវស្សាពីថ្ងៃ ១ រោច ខែ ស្រាពណ៍ រហូតទល់ថ្ងៃ ១៥កើត ខែកត្តិក ចូរវស្សារបៀបនេះ ហៅថា បច្ឆិមិកាវស្សា។

អដ្ឋកថា ថា ទ្រង់មានសេចក្ដីប្រាថ្នានឹងលើកខែ ជាដំបូងនៃវស្សានរដូវ គឺប្រាថ្នានឹងធ្វើខែស្រាពណ៍ឲ្យទៅជាខែអាសាឍវិញ (ខែអាសាឍខាងដើម ហៅថា បឋមាសាឍ ខែដែលលើកខាងក្រោយ ហៅថា ទុតិយាសាឍ[51]។

---

[51] វិន័យបិដក មហាវគ្គ ទុតិយភាគ ៧ វស្សូបនាយិកក្ខន្ធកៈ ព.ស ២៥៥៣ ទំព័រ ៥

នៅថ្ងៃចូលវស្សា សាមណេរទាំងឡាយមិនត្រូវដើរចេញពីអាវាសឡើយ គប្បីជួយរៀបចំអាវាស បរិវេណ ព្រះវិហារ តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ប្រគេនភិក្ខុសង្ឃ បន្ទាប់ពីភិក្ខុសង្ឃចូលវស្សារួចហើយ សាមណេរគប្បីប្រជុំគ្នាក្នុងវិហារ អធិដ្ឋានចូលវស្សាព្រមគ្នាថា៖

**ឥមស្មឹ អាវាសេ ឥមំ តេ មាសំ វស្សំ ឧបេម** ប្រែថា យើងទាំងឡាយនៅចាំវស្សាអស់បីខែនេះ ក្នុងអាវាសនេះ។ ថាតែត្រឹមបាលី ៣ ដង ប្រែមិនបាច់ថាទេ។

ប្រសិនបើភិក្ខុណាមួយមានធុរៈ មិនបានប្ដេជ្ញាអធិដ្ឋានបាលីចូលបុរិមិកាវស្សាទេ ភិក្ខុនោះអាចប្ដេជ្ញាអធិដ្ឋានបាលីចូលវស្សាបច្ឆិមិកាវស្សាបានដែរ ប៉ុន្តែភិក្ខុពុំអាចគេចវេះមិនចូលវស្សាណាមួយជាដាច់ខាត ដូចមានពុទ្ធប្បញ្ញត្តិថា **ន ភិក្ខវេ វស្សំ ន ឧបគន្តព្វំ យោ ន ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស** ម្នាលភិក្ខុទាំងឡាយភិក្ខុកុំមិនចូលវស្សាឡើយ គឺត្រូវតែចូលវស្សា ភិក្ខុណាមិនចូលវស្សា ភិក្ខុនោះត្រូវអាបត្តិទុក្កដ។

**សត្តាហករណីយៈ**

ភិក្ខុកាលបើបានប្ដេជ្ញាអធិដ្ឋានចូលវស្សាក្នុងអាវាសណាមួយហើយ ត្រូវស្ថិតនៅក្នុងបរិវេណអាវាសនោះគ្រប់បីខែ គឺមិនត្រូវចេញទៅក្រៅអាវាសនោះឲ្យកន្លងរាត្រីណាមួយឡើយ ដូចមានពុទ្ធប្បញ្ញត្តិថា **ន ភិក្ខវេ វស្ស ឧបគន្ត្វា បុរិមំ វា តេ មាសំ បច្ឆិមំ វា តេ មាសំ អវសិត្វា ចារិកា បក្កមិតព្វា យោ បក្កមេយ្យ អាបត្តិ ទុក្កដស្ស** ម្នាលភិក្ខុទាំងឡាយភិក្ខុណាចូលវស្សាហើយ មិននៅចាំបុរិមិកាវស្សាអស់បីខែ ឬបច្ឆិមិកាវស្សាអស់បីខែទេ មិនត្រូវចៀសចេញទៅកាន់ចារិកឡើយ ភិក្ខុណាចៀសចេញទៅត្រូវអាបត្តិទុក្កដ។ បើភិក្ខុមានធុរៈចាំបាច់ អាចលើកសត្តាហៈ ជាមុនហើយទើបចេញបាន តែត្រូវត្រឡប់មកអាវាសវិញឲ្យទាន់មុនអរុណរះចន្លោះថ្ងៃទី៧យ៉ាងយូរបំផុត។

ឯធុរៈដែលចាំបាច់ភិក្ខុត្រូវលើកមកធ្វើជាមូលហេតុដើម្បីលើកសត្តាហៈនោះគឺ

១/ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ទុកជាពួកជនទាំង ៧ គឺ ភិក្ខុ ១ ភិក្ខុនី ១ សិក្ខមានា ១ សាមណេរ ១ សាមណេរី ១ មាតា ១ បិ តា ១ មិនបានបញ្ជូនបម្រើមកក៏តថាគតអនុញ្ញាតឲ្យភិក្ខុទៅដោយសត្តាហៈករណីយ៍បាន តែភិក្ខុត្រូវត្រឡប់មកវិញ ក្នុងរវាង ៧ ថ្ងៃគឺមុនអរុណរះថ្ងៃទី៧[52]។

## ១១.៧. ឈ្វេងយល់អំពីតួនាទីវត្តអារាមព្រះពុទ្ធសាសនា

ខេមរជននៅក្នុងប្រទេសកម្ពុជា បានទទួលផល អំពីវត្តអារាមព្រះពុទ្ធសាសនាជាច្រើនយ៉ាង ដូចមានសេចក្ដីរៀបរាប់នៅខាងក្រោមនេះ ៖

១ - វត្តអារាមព្រះពុទ្ធសាសនា ទុកដូចជាគ្រឹះស្ថាន ឬមហាមន្ទីរជាទីកើតនៃសិល្បៈ ទស្សនវិជ្ជា វិទ្យាសាស្ត្រ និងសីលធម៌ គឺប្រពៃណីដ៏ល្អ ព្រះពុទ្ធសាសនាមានអត្ថបទល្អៗ ច្រើនណាស់សម្រាប់ប្រតិបត្តិដើម្បីរំលត់ទុក្ខ នាំមកនូវសេចក្ដីសុខ ជាសាសនាបំភ្លឺប្រយោជន៍ តាំងអំពីបច្ចុប្បន្នដល់បរលោក ជាសាសនាឲ្យសិទ្ធិ

[52] វិន័យបិដក មហាវគ្គ ទុតិយភាគ ៧ វស្សូបនាយិកក្ខន្ធកៈ ព.ស ២៥៥៣ ទំព័រ ៣៣

បរិបូណ៌ដល់សត្វលោក ព្រះពុទ្ធសាសនាទុកដូចជាដួងប្រទីបមួយសម្រាប់បំភ្លឺលោក ឲ្យមនុស្សលោកឃើញសិល្បៈ ឃើញផ្លូវប្រតិបត្តិ ដើរកាត់តម្រង់ទិសទៅរកសេចក្តីសុខចម្រើន ទាំងបច្ចុប្បន្ននឹងទៅបរលោក ជាសាសនាមួយរាវរកឃើញមគ្គផលនិព្វានបាន។ ព្រះពុទ្ធសាសនាមានគុណភាពប្រកបដោយប្រយោជន៍ ជាច្រើនយ៉ាង ដូចជាសេចក្តីចម្រើន ឈានលឿនទៅមុខរបស់មនុស្សលោក ក៏ច្រើនតែកើតមកពីអំពីព្រះពុទ្ធសាសនាជាដំបូង សូម្បីវេជ្ជសាស្ត្រ និងវិទ្យា ដែលរាប់ថាជាវិជ្ជាសម័យថ្មី ក៏កើតមកអំពីអ្នកប្រាជ្ញ ដែលចម្លងផ្ចិតយកអំពីព្រះពុទ្ធសាសនាខ្លះមិនខាន បើមិនច្រើនក៏តិច។

គ្រប់ប្រទេសទាំងអស់ច្រើនតែទទួលដឹងថា សេចក្តីចម្រើនក្នុងសិល្បៈវិទ្យាសាស្ត្រ បានទទួលកំណើតអំពីសាសនា អ្នកប្រាជ្ញវិទ្យាសាស្ត្រប្រទេសជប៉ុន បានសរសេរទុក្ខក្នុងប្រវត្តិសាស្ត្រថា ព្រះពុទ្ធសាសនាជាសាសនានាំសេចក្តីចម្រើនមកឲ្យប្រទេសជប៉ុន ព្រះពុទ្ធសាសនាបានបើទ្វារប្រទេសជប៉ុន ដោយទ្រឹស្តីមុនដំបូងបង្អស់ឲ្យប្រទេសជប៉ុនឈមមុខទៅរកសេចក្តីចម្រើន ព្រោះហេតុនោះ យើងជាជាតិជប៉ុន នៅចុងប៉ូចបូព៌ាប្រទេស គួរណាស់តែសើររើ សិក្សាអនុវត្តព្រះពុទ្ធសាសនាដោយគោរពមិនត្រូវធ្វេសប្រហែសឡើយ។

២ - វត្តអារាមព្រះពុទ្ធសាសនា ជាអណ្តូងសម្រាប់កើតនៃការសិក្សា បើទោះការសិក្សានោះពុំបានទូលំទូលាយ ដោយមិនទាន់បានអនុវត្ត ក៏អាចចិញ្ចឹមសិល្បៈក្នុងផ្លូវវប្បធម៌របស់ជាតិខ្មែរ ឲ្យមានជីវិតជាប់ពូជជារមិនដាច់ ប្រទេសកម្ពុជារបស់យើង ដែលមានការចេះដឹងក្នុងលទ្ធិសាសនាក្តី ក្នុងសិល្បៈណាមួយក្តី ផ្លូវអក្សរសាស្ត្រក្តី សុទ្ធតែកើតអំពីវត្តអារាមព្រះពុទ្ធសាសនាជាដំបូង សូម្បីវិជ្ជាពេទ្យ ក៏ច្រើនតែកកើតមកអំពីបព្វជិតពុទ្ធសាសនិក ទោះបីមានវិន័យ ហាមមិនឲ្យបព្វជិតធ្វើពេទ្យមើលជំងឺ ក៏ហាមបានដោយក្រណាស់ ដោយហេតុបព្វជិតមើលជំងឺឲ្យទទេមិនបាច់យកថ្លៃ។

៣ - វត្តអារាម ជាកន្លែងប្រជុំប្រជាជន ដើម្បីសន្ទនាពីធម៌អាថ៌ ឬព្រឹត្តិការណ៍នានាតាមសេចក្តីចេះដឹងក្នុងសម័យនិយមនោះៗ វត្តអារាម ទុកជារោងរៀនហត្ថកម្មមួយ ក្នុងផ្លូវសិល្បៈ មានរៀនជាងឈើការកសាងវិហារ សាលាជាដើម។ ពូជជារនៃសេចក្តីចម្រើនរបស់យើង ដែលមានឈ្មោះជាប់មក ជាប្រទេសមានអក្សរសាស្ត្រ មានបុរាណវត្ថុជាគ្រឿងបង្ហាញសិល្បៈ ឲ្យឃើញជាកេរដំណែល មានប្រជាជាតិជាម្ចាស់ប្រទេស មានមហាក្សត្រសោយរាជ្យ ក៏ដោយអំណាចគុណនៃព្រះពុទ្ធសាសនាជួយទ្រទ្រង់ ឬថាព្រះពុទ្ធសាសនា ជាឃ្លាំងទុកដាក់នូវសិល្បៈ ព្រមទាំងអក្សរសាស្ត្ររបស់ជាតិ ឲ្យមានជីវិតរស់នៅរហូតមក រួមសេចក្តីថា " ព្រះពុទ្ធសាសនា នាំមកនូវប្រយោជន៍យ៉ាងធំ ឲ្យប្រទេសកម្ពុជាយើង។

៤ - ប្រទេសកម្ពុជាយើង ក៏យើងអាចបានឃើញជាក់ច្បាស់ហើយគឺថា កាលដែលប្រទេសយើងមិនទាន់សាលារៀនអក្សរសាស្ត្រក្នុងផ្លូវការនៅឡើយ មានតែវត្តអារាមហ្នឹងឯង ជាសាលារៀន កាលដែលផ្លូវការមិនទាន់មានមន្ទីរពេទ្យ ព្យាបាលរោគនៅឡើយ មានតែវត្តអារាមជាមន្ទីរពេទ្យស សម្រាប់មើលជំងឺនៃប្រជាជន មិនត្រឹមតែមើលជំងឺកាយប៉ុណ្ណោះទេ អាចពិនិត្យមើលជំងឺចិត្តទៀតផង ព្រោះថាការកើតទុក្ខព្រួយបារម្ភ

ក្នុងផ្លូវចិត្តនេះ ចាត់ជារោគមួយយ៉ាងធំណាស់ វត្តអារាមនៃព្រះពុទ្ធសាសនា ឈ្មោះថាជាកន្លែងសម្រាប់រម្ងាប់រោគកាយ រោគចិត្ត ដែលមានទុក្ខឲ្យធូរស្រាលក៏មាន ឲ្យជាសះស្បើយទៅក៏មាន។

៥ - ក្រុងភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជាយើង មានវត្តអារាមធំៗ គឺវត្តឧណ្ណាលោម វត្តលង្កា វត្តសារាវ៉ន វត្តបទុមវតី ជាដើម ជាវត្តទទួលបន្ទុកនៃភិក្ខុសាមណេរ និងកុមារតូចធំបានច្រើនណាស់ វត្តនីមួយៗមានភិក្ខុសាមណេរ និងកុមារ ដែលស្នះចេញពីស្រុកខេត្តផ្សេងៗ មកនៅបញ្ចុះជ្រំជាមួយគ្នា ដើម្បីសិក្សារៀនសូត្រយកចំណេះវិជ្ជា ព្រោះថានៅភ្នំពេញ ជាទីប្រជុំជាធំសម្បូរដោយការសិក្សាជាងទីឯទៀតៗ។ ពួកភិក្ខុដែលមកនូវក្នុងវត្តទាំងនោះ បានយូរឆ្នាំ ទាំងមានសមត្ថភាពគ្រាន់បើ ហើយបានធ្វើជាមេកុដិ អាចទទួលចិញ្ចឹមភិក្ខុសាមណេរ និងកុមារឲ្យរៀនសូត្រផងទាល់តែសម្រេចការសិក្សា ពួកកុមារដែលមកនូវអាស្រ័យជ្រកកោន ក្នុងវត្តជាមួយនឹងព្រះសង្ឃនោះ សុទ្ធតែជាកូនអ្នកស្រែចម្ការ ដែលក្រទ័លទ្រព្យសម្បត្តិ គួរឲ្យអណោចអធម្ម អាណិតអាសូរពួកកុមារកំសត់ទាំងនោះពន់ពេក បើកុំតែមានវត្តអារាមព្រះពុទ្ធសាសនាប្រហែលជាពុំបានទទួលស្មើការសិក្សា ដូចកូនអ្នកមានទ្រព្យទេ ប្រែសេចក្ដីថា កូនអ្នកក្រីក្រធនជានរស់នៅដោយសារបាយវត្ត ខំទ្រាំទ្រនៅបំពេញការសិក្សាទាំងរហេមរហាម ទាល់តែសម្រេចផលនៃការសិក្សា បានឡើងឋានៈទៅជាអ្នកមានជីវភាពខ្ពង់ខ្ពស់តាមសមគួរ ដល់សមត្ថភាពរបស់ខ្លួន ចំណែកឯកូនអស់លោកឥស្សរជន ឬកូនគហបតី មិនត្រូវបានមកជ្រកកោននៅអាស្រ័យក្នុងវត្តឡើយ។

កូនចៅរបស់អ្នកក្រីក្រ បានទទួលសេចក្ដីសង្គ្រោះ អំពីបព្វជិតព្រះពុទ្ធសាសនិកក្នុងឆ្នាំនីមួយៗ បានច្រើននាក់ណាស់ ដូចយ៉ាងវត្តធំៗ សិស្សនិស្សិត ៣០០ ទៅ៤០០នាក់ ចំនួនពួកកុមារទាំងប៉ុណ្ណោះ បើរាជរដ្ឋាភិបាលយកទៅចិញ្ចឹមវិញ អស់ប្រាក់ថវិកាជាតិមិនមែនតិចទេ។ កុមារទាំងនេះឈ្មោះថា រស់នៅដោយអាស្រ័យនឹងម្លប់ព្រះពុទ្ធសាសនា នៅជ្រកកោនក្រោមម្លប់ព្រះពុទ្ធសាសនា ខំប្រឹងប្រែងសិក្សារៀនសូត្រទាល់តែបានទទួលលទ្ធផល នៃការសិក្សារបស់ខ្លួន ករណីយនេះឃើញថាព្រះពុទ្ធសាសនា ទុកដូចជាកន្លែងឧបត្ថម្ភអាហារូបករណ៍មួយដ៏ប្រសើរដល់អ្នកក្រីក្រ អាចចិញ្ចឹមមនុស្សក្រទ័ល ដែលមិនមានលំនៅជ្រកកោន និងអាហារបរិភោគ វត្តរបស់ព្រះពុទ្ធសាសនា ឈ្មោះថាបានជួយសម្រាលភារៈនៃរាជរដ្ឋាភិបាលឲ្យធូរស្រាលបានច្រើនណាស់។

៦ - បព្វជិតពុទ្ធសាសនិក នៅវត្តអារាមគ្រប់ស្រុកមានលោកចៅអធិការ គ្រូសូត្រស្ដាំ ឆ្វេង ជាដើម ពេលភ្ជាក់ខ្លួនក្នុងការសិក្សាធម្មវិន័យហើយ បានចុះស្នាមក្នុងផ្លូវសិក្សាតាមសម័យនិយម។ ការសិក្សាច្បាប់ព្រះពុទ្ធសាសនា របស់បព្វជិតក្នុងពុទ្ធសាសនិកនោះ ជាកម្លាំងមួយដែលនាំឲ្យមានប្រាជ្ញាស្មារតីបរិបូណ៌ នាំឲ្យភ្លឺក្នុងផ្លូវធម៌ផង ផ្លូវលោកផង គឺថាការសិក្សាជួយឲ្យបព្វជិតនោះមានឧត្តមគតិ និងសមត្ថភាព ទាំងឧបាសក ឧបាសិកាជើងវត្តក៏អាចដឹកនាំចិត្ត ឲ្យមានសទ្ធាជ្រះថ្លាក្នុងការកសាងសេនាសនៈសម្រាប់បម្រើព្រះពុទ្ធសាសនាផង បម្រើប្រទេសជាតិផង។

ដំណើរនេះសឲ្យឃើញថា ព្រះពុទ្ធសាសនា កាលបើបុគ្គលណាបានសិក្សាអប់រំល្អហើយ អាចនាំឲ្យ

ឆ្លុះបំភ្លឺឃើញសារប្រយោជន៍ ក្នុងផ្លូវធម៌បានផង ក្នុងផ្លូវលោកបានផង ព្រះពុទ្ធសាសនាឈ្មោះថា ជាសាសនាជួយពលរដ្ឋប្រទេសកម្ពុជា ឲ្យចេះស្រឡាញ់ប្រទេសជាតិរបស់ខ្លួនបានដោយបរិបូណ៌ ជាសសានាមានទ្រឹស្តីល្អៗអាចជួយសាងវឌ្ឍនធម៌ និងសាមគ្គីធម៌របស់ជាតិ ឲ្យកើតមានឡើង។

៧ - អក្សរសាស្ត្រខ្មែរ សម្រាប់ប្រទេសយើង បើកុំតែមានវត្តអារាមពុទ្ធសាសនិក ប្រហែលជាសាបសូន្យអស់ទៅហើយ ព្រោះហេតុនោះ វត្តអារាមឈ្មោះថាជាកន្លែងសម្រាប់រក្សាទុកនូវសិល្បសាស្ត្រ ចិញ្ចឹមអក្សរសាស្ត្ររបស់ជាតិទុកឲ្យរស់នៅ អក្សរសាស្ត្រនេះទុកជាពន្លឺរស្មីរបស់ជាតិ កាលបើបាត់អក្សរសាស្ត្រហើយជាតិក៏អាប់ឱន សាបសូន្យទៅជាលំដាប់ ដោយហេតុនេះពុទ្ធសាសនានៅប្រទេសកម្ពុជាយើងឈ្មោះថាជាសាសនាជួយជ្រោងជ្រែងរក្សាទុកនូវអក្សរសាស្ត្រជាតិ។

បព្វជិតពុទ្ធសាសនិក ដែលបានរៀនក្នុងផ្លូវគន្ថធុរៈ គឺរៀនគម្ពីរព្រះត្រៃបិដក ចេះចាំយល់សព្វភាសាបាលីអាចប្រែពីបាលីមកភាសាខ្មែរបានដោយងាយ បានបោះពុម្ពផ្សាយចេញជាសៀវភៅធំ តូច គរគោកយើងអាចមើលបានក្នុងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ព្រមបណ្ណាគារឯទៀតៗ និងឃើញសៀវភៅខ្មែរដេរដាសផ្សេងទៀត។ សៀវភៅអក្សរសាស្ត្រខ្មែរផ្នែកពុទ្ធសាសនា ចេញព្រោងព្រាតទាំងនេះច្រើនតែកើតអំពីស្នាដៃព្រះសង្ឃដែលបានរៀនសូត្រក្នុងព្រះពុទ្ធសាសនា។ប្រទេសកម្ពុជាដែលមានវឌ្ឍនធម៌ខាងផ្លូវសិល្បសាស្ត្រអក្សរសាស្ត្រកំពុងរើបទៅរកផ្លូវផ្លូវរីកចម្រើនរុងរឿងមកនេះ ដោយកម្លាំងរស្មីនៃព្រះពុទ្ធសាសនាជាប្រាជក[53]។

## ១១.៨. ឈ្វេងយល់អំពីកិច្ចដើម្បីបានងារជាឧបាសក និងឧបាសិកាក្នុងព្រះពុទ្ធសាសនា

### និយមន័យឧបាសក ឧបាសិកា

ឧបាសក អ្នកអង្គុយជិតឲ្យប្រើប្រាស់ អ្នកបម្រើ អ្នកប្រជិតប្រជីបម្រើបម្រាស់ សិស្សសាសនា។ អ្នកដល់ព្រះរតនត្រ័យជាទីពឹងឬជាទីរឭក គឺគ្រហស្ថដែលចូលកាន់ពុទ្ធសាសនាស៊ប់ ហើយកាន់សីលធម៌ខ្ជាប់ខ្ជួនតាមច្បាប់សម្រាប់ពុទ្ធសាសនិកជនជាគ្រហស្ថ បើស្ត្រីជា ឧបាសិកា "គ្រហស្ថស្រី" បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ ដូចជា ឧបាសកគុណ គុណធម៌សម្រាប់ឧបាសកឬរបស់ឧបាសក។ ឧបាសកប្បដិបត្តិ ឬប្រតិបត្តិប្រតិបត្តិរបស់ឧបាសក។ ឧបាសកភាព ភាពជាឧបាសក។ ឧបាសកសម្បត្តិ ឬសម្បទា ការបរិបូណ៌ដោយឧបាសកគុណ។ ឧបាសកសីល សីលសម្រាប់ឧបាសក គឺនិច្ចសីល ឧបោសថសីលឬអតិរេកសីល (សីល៥ សីល៨ ឬសីល១០) ឧបាសកផ្ទុយគ្នាពីទាយក ដែលគ្រាន់តែដក់ចិត្តឲ្យទាន ប៉ុន្តែគេអាចហៅរួមបាន បាសកទាយក ទាយិកា។ ព្រោះសុទ្ធតែពួកសប្បុរស មានចិត្តស្រស់បស់ឆ្ពោះសាសនាកាន់សីលឲ្យទានរួបរួមគ្នាសាមគ្គីសមគ្គាបង្កើតសុខ។

វិធីថ្វាយខ្លួនជា ឧបាសក ឧបាសិកា

[53] ពុទ្ធសាសនា ២៥០០ ការផ្សាយរបស់វិទ្យាស្ថានរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥៤៥ ទំព័រ ១៣៨

បុរស ឬស្ត្រី ដែលមានសទ្ធាជ្រះថ្លា ក្នុងព្រះរតនត្រ័យគឺ គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយមានប្រាថ្នាប្ដេជ្ញាខ្លួនជា ឧបាសក ឬឧបាសិកា គប្បីបដិបត្តិគឺ សេចក្ដីប្រតិបត្តិជាចំណែកខាងដើម ឲ្យពេញស៊ប់ជាអ្នកកាន់ព្រះពុទ្ធសាសនា ឬជាអ្នកតម្កល់នៅក្នុងព្រះពុទ្ធសាសនា នោះត្រូវធ្វើដោយកិច្ច២យ៉ាងគឺះ

១. មុនដំបូង នមស្ការចំពោះព្រះរតនត្រ័យ។

២.បន្ទាប់មកត្រូវបញ្ចេញវចីភេទ សូមខមាទោសនឹងព្រះរតនត្រ័យក្នុងទីចំពោះមុខ នៃព្រះធម្មាចារ្យ។

ពាក្យសូមខមាទោស

បុរសច្រើននាក់ ( ២នាក់ឡើងទៅ ) ព្រះសង្ឃមួយអង្គ

អច្ចយោ នោ ភន្តេ អច្ចគមា យថា ពាលេ

យថា មុឡ្ហេ យថា អកុសលេ យេ មយំ

ភន្តេ កាយេន វា វាចាយ វា មនសា

វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស

វា អគារវំ អករិម្ហា តេសំ នោ ភន្តេ

អយ្យោ អច្ចយំ អច្ចយតោ បដិគណ្ហាតុ អាយតឹ សំវរាយ

ប្រែថា បពិត្រព្រះករុណាដ៏ចម្រើន ទោសកំហុស ដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះករុណាដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាទាំងឡាយ បានធ្វើហើយនូវសេចក្ដីល្មើស មិនគោរពដល់ព្រះពុទ្ធក្ដី ដល់ព្រះធម៌ក្ដី ដល់ព្រះសង្ឃក្ដី ដោយកាយក្ដី ដោយវាចាក្ដី ដោយចិត្តក្ដី បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាអត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះ ជាសេចក្ដីខុសពិត ដើម្បីនឹងបានសង្រួមគឺថា នឹងប្រព្រឹត្តឲ្យល្អ តទៅក្នុងខាងមុខនោះហោង។

ព្រះធម្មាចារ្យត្រូវទទួលថា ( សាធុម្ដង )

សិស្សថា ( សាធុ ៣ ដង )

ពាក្យប្ដេជ្ញាខ្លួន

បុរសច្រើននាក់ ( ២នាក់ឡើងទៅ ) ព្រះសង្ឃ មួយអង្គ

ឯតេ មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ

សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ

នោ អយ្យោ ធារេតុ អជ្ជតគ្គេ បាណុបេ តេ សរណំ គតេ។

ប្រែថា បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅអស់កាល យូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹង ទីរឭកសូមព្រះករុណាជ្រាបនូវខ្ញុំព្រះករុណាទាំងឡាយ ថាជាឧបាសក បានដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹងទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះ ជាដើមរៀងទៅ។

ពាក្យសូមខមាទោស

ស្ត្រីច្រើននាក់ ( ២ នាក់ឡើងទៅ ) ព្រះសង្ឃ មួយអង្គ

អច្ចយោ នោ ភន្តេ អច្ចគមា យថា ពាលា

យថា មុទ្ធា យថា អកុសលា យា មយំ
ភន្តេ កាយេន វា វាចាយ វា មនសា
វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស
វា អគារវំ អករិម្ហា តាសំ នោ ភន្តេ
អយ្យោ អច្ចយំ អច្ចយតោ បដិគណ្ហាតុ
អាយតឹ សំវរាយ។

ប្រែថា បពិត្រព្រះករុណាដ៏ចម្រើន ទោសកំហុស ដែលប្រព្រឹត្តកន្លងគ្របសង្កត់ហើយនូវ ខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះករុណាដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាទាំងឡាយ បានធ្វើហើយនូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាអត់នូវ ទោសកំហុសនោះ ដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឲ្យល្អ តទៅក្នុងខាងមុខ នោះហោង

ព្រះធម្មាចារ្យត្រូវទទួលថា ( សាធុម្តង )

សិស្សថា ( សាធុ ៣ ដង )

ពាក្យប្តេជ្ញាខ្លួន

ឯតា មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ
សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកោយោ
នោ អយ្យោ ធារេតុ អជ្ជតគ្គេ បាណុបេតា សរណំ គតា។

ប្រែថា បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅ អស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹង ទីរឭក សូមព្រះករុណាជ្រាប នូវខ្ញុំព្រះករុណាទាំងឡាយថា ជាឧបាសិកា បានដល់ហើយ នូវព្រះរតនត្រ័យ ជាទីពឹង ទីរឭក ស្មើដោយជីវិតតាំងអំពីថ្ងៃនេះ ជាដើមរៀងទៅ។

ព្រះធម្មាចារ្យត្រូវទទួលថា ( សាធុម្តង )

សិស្សថា ( សាធុ ៣ ដង )

ខ. វិធីសមាទានសីល

ក្នុងកិច្ចសមាទានសីលនេះ ឧបាសក ឧបាសិកា ដែលមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា គប្បីសមាទានសីលនឹងអាចារ្យ ឬភិក្ខុ សាមណេរជាបុគ្គល ឬគណៈ ឬសង្ឃដែលគង់នៅក្នុងទីនោះ រីឯសីលនោះមាន សីល៥ សីល៨ និងសីល១០។

## ១១.៩. ឈ្វេងយល់អំពីគម្ពីរព្រះត្រៃបិដក

### គម្ពីរព្រះត្រៃបិដក

ព្រះពុទ្ធសាសនា ដែលជាតិកម្ពុជា ឬខេមរ គឺខ្មែរកាន់រៀងមក បច្ចុប្បន្ននេះ គឺព្រះពុទ្ធព្រះនាម ជាព្រះសមណគោតម ឬព្រះសក្យមុនី ដែលចូលបរិនិព្វាន តាំងពីព្រះពុទ្ធសករាជមួយឆ្នាំរៀងមក ពុទ្ធសករាជបាន

២៥៦៤ឆ្នាំ គ្រិស្តសករាជ២០២០។

ក្នុងរាជព្រះករុណាព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ ចមចក្រពង្ស ព្រះចៅក្រុងកម្ពុជាធិបតី ជាម្ចាស់ជីវិតលើត្បូង ច្បាប់បន្ទាត់សព្វគ្រប់ ពីព្រះពុទ្ធសាសនាដ៏វិសេស ដូចមានក្នុងព្រះត្រៃបិដក គឺកញ្ជើទាំង៣ សម្តែងព្រះទិព្វវាចា ជាតម្រាប់តម្រាមានប្រាំបីម៉ឺនបួនពាន់ព្រះធម្មក្ខន្ធ។

ត្រៃ ប្រែថា បី បិដក ប្រែថា កញ្ជើ ឬភាជន៍ "កញ្ជើ ឬភាជន៍៣ " តម្កល់ ព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ចែកចេញជា១៧គម្ពីរគឺ វិន័យបិដក៥គម្ពីរ សុត្តន្តបិដក៥គម្ពីរ អភិធម្មបិដក៧គម្ពីរ រួមជា១៧គម្ពីរ។

ព្រះវិន័យបិដក កញ្ជើ ឬភាជន៍ ជាទីតម្កល់នូវព្រះវិន័យគឺច្បាប់សម្រាប់ទូន្មាននូវកាយ និងវាចា ឲ្យរៀបរយបានដល់ឧបញ្ញត្តិ ដែលជាចាត់ជាសិក្ខាបទ និងអភិសមាចារ គឺប្រព្រឹត្តល្អ ជាគ្រឿងរក្សាគណៈសង្ឃក្នុងព្រះពុទ្ធសាសនា។

**ព្រះវិន័យបិដកនេះចេញជា៥គម្ពីរគឺ៖**

១ - អាទិកម្ម អំពើខាងដើម សម្តែងពី មូលប្បញ្ញត្តិ នៃសិក្ខាបទធំតូច មានចំនួន១៩សិក្ខាបទ មានបារាជិក៤ជាដើមគម្ពីរនេះមាន ៤២០០ព្រះធម្មក្ខន្ធ។

២ - បាចិត្តិយ អំពើល្មើសញ៉ាំងកុសលឲ្យធ្លាក់ចុះ សំដែងពីសិក្ខាបទមានចំនួន២០៨សិក្ខាបទ មាននិស្សគ្គិយ គឺកងអាបត្តិ៣០ជាដើម គម្ពីរនេះមាន៥០០០ព្រះធម្មក្ខន្ធ។

៣ - មហាវគ្គ ពួកធំ សម្តែងអំពីកម្មរបស់សង្ឃធំៗ មានចំនួន១០ខន្ធ មានបញ្ជាខន្ធកៈ គឺរឿងបំបួសជាដើម គម្ពីរនេះមាន ៥០០០ព្រះធម្មក្ខន្ធ។

៤ - ចុល្លវគ្គ ពួកតូច ពីកិច្ចានុកិច្ចរបស់សង្ឃតូចៗ ចំនួន១២ខន្ធកៈ មានកម្មក្ខន្ធកៈជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ៣២០០ព្រះធម្មក្ខន្ធ។

៥ - បរិវារ រាយរង សំដែងអំពីសេចក្តីរួបរួមខវិនយប្បញ្ញត្តិបញ្ចូលជាពួក ដើម្បីឲ្យជាក់ច្បាស់ឡើង មានសំដែងអំពីមហាវារ ១៦ជាដើម គម្ពីរនេះមាន ព្រះធម្មក្ខន្ធ៣៥០០ព្រះធម្មក្ខន្ធ។

រួមព្រះធម្មក្ខន្ធក្នុងវិន័យបិដកទាំង៥គម្ពីរត្រូវជា២១០០០ព្រះធម្មក្ខន្ធ។

ព្រះសុត្តន្តបិដក គឺព្រះសូត្រ កញ្ជើ ឬភាជន៍ ជាទីតម្កល់នូវព្រះសូត្រ សម្រាប់ប្រតិបត្តិរបស់ពុទ្ធបរិស័ទដោយសង្ខេបខ្លះពិស្តារខ្លះ។

**សុត្តន្តបិដកនេះចែកជា៥គម្ពីរគឺ៖**

១ - ទីឃនិកាយ ប្រជុំនៃសូត្រវែងៗ សម្តែងពីព្រះសូត្រមានសេចក្តីពិស្តារចំនួន៣២សូត្រមានព្រហ្មជាលសុត្រជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ ៣០០០។

២.មជ្ឈិមនិកាយប្រជុំនៃសូត្រយ៉ាងកណ្តាល សំដែងព្រះសូត្រមានសេចក្តីមិនវែងមិនខ្លីយ៉ាងកណ្តាល មានចំនួន១៤២សូត្រ មានមូលបរិយាយសូត្រជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ៣០០០។

៣ - សំយុត្តនិកាយ ប្រជុំនៃសូត្រដែលរួបរួម សំដែងពីព្រះសូត្រដែលភ្ជាប់ដោយប្រភេទនៃបុគ្គល និង

ធម៌មានចំនួន ៧៧២៦ សូត្រ មានឱឃតរណសូត្រជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ៤០០០។

៤ - អង្គុត្តរនិកាយ ប្រជុំធម៌មានអង្គដ៏ក្រៃលែង សំដែងធម៌ជាពួកៗ តាំងពីធម៌មានពួក១ ដរាប់ដល់ធម៌មានពួក១១ មានចំនួន៩៥៥៧ សូត្រ មានចិត្តបរិយាយទានសូត្រជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ ៥០០០។

៥ - ខុទ្ទកនិកាយ ប្រជុំនៃធម៌តូចៗ សំដែងរួបរួមពីប្រភេទធម៌តូចៗ មានចំនួន១៥គម្ពីរ ឈ្មោះខុទ្ទកបាទ និងធម្មបទជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ ៦០០០។

រួមព្រះធម្មក្ខន្ធក្នុងព្រះសុត្តន្តបិដក ទាំង៥គម្ពីរត្រូវ២១០០០ព្រះធម្មក្ខន្ធ។

ព្រះអភិធម្មបិដក កញ្ជើ ឬភាជន៍ ជាទីតម្កល់នូវព្រះអភិធម្ម គឺធម្មអត្ថដ៏ជ្រាលជ្រៅបានដល់ចិត្ត ចេតសិក និងនិព្វាន។

**អភិធម្មបិដកនេះចែកចេញជា៧គម្ពីរគឺះ**

១ - ធម្មសង្គណី កិរិយាពោលរួបរួមនូវធម៌ សំដែងអំពីធម៌ដែលរួបរួមបញ្ចូលគ្នាជា៤កណ្ឌ មានចិត្តុប្បាទកណ្ឌ ជាដើមគម្ពីរនេះមានព្រះធម្មក្ខន្ធ ២៣០០។

២ - វិភង្គ កិរិយាចែក សំដែងពីចំណែកនូវធម៌ ១៨កង មានខន្ធ៥ និងអាយតនៈ១២ជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ៦៥០០។

៣ - ធាតុកថា កិរិយាពោលនូវធាតុ សំដែងបរមត្ថធម៌ ដែលសំដែងសង្គ្រោះរួបរួមជាមួយគ្នាបាន និងសង្គ្រោះរួបរួមជាមួយគ្នាមិនបានជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ៧០០០។

៤ - បុគ្គលប្បញ្ញត្តិ កិរិយាបញ្ញត្តិតែងតាំងនូវបុគ្គលគឺសត្វទាំងពួង សម្តែងពីបញ្ញត្តិ៦យ៉ាងមាន ខន្ធប្បញ្ញត្តិជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ៥៦០០។

៥ - កថាវត្ថុ ហេតុនៃពាក្យពោលប្រស្នា សំដែងពីពាក្យពោលចំពោះបុគ្គល ប្រុស ស្រីជាដើម គម្ពីរនេះព្រះធម្មក្ខន្ធ៧១០០។

៦ - យមក ធម៌ជាគូៗ មានមូលយមកជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ៥១០០។

៧ - បដ្ឋាន ហេតុ គតិ សំដែងពីធម៌ដែលជាមេ ជាទីអាស្រ័យនៅនៃធម៌ទាំងពួង ហេតុប្បច្ច័យជាដើម គម្ពីរនេះមានព្រះធម្មក្ខន្ធ៨៥០០។

បូកបញ្ចូលគ្នាទាំង៣នៃគម្ពីរព្រះត្រៃបិដកត្រូវជាប្រាំបីម៉ឺនបួនពាន់ (៨៤០០០) ព្រះធម្មក្ខន្ធ[54]។

## ១១.១០. ឈ្វេងយល់អំពីព្រះពុទ្ធបដិមា នៅប្រទេសកម្ពុជា

ព្រះពុទ្ធរូប បើតាមអ្នកប្រាជ្ញប្រវត្តិសាស្ត្រ ត្រាចរង្គាត់ស្រាវជ្រាវរក បុរាណវត្ថុក្នុងប្រទេសផ្សេងៗ មានប្រទេសឥណ្ឌាជាដើម គេឃើញព្រះពុទ្ធច្រើនបែប ប៉ុន្តែបើទុកជាយ៉ាងណា ក៏ព្រះពុទ្ធរូបនោះៗ ប្លែកពីរូប

[54] កម្ពុជសុរិយា ភាគ១/២៧ គ.ស១៩២៦ ទំព័រ ៧២

មនុស្សធម្មតា ដែលអាចឲ្យអ្នកផងឃើញហើយ គួរឲ្យស្គាល់បានភ្លាមថា ជារូបព្រះពុទ្ធ។ ម្យ៉ាងទៀតព្រះពុទ្ធរូបដែលគេឆ្លាក់ថ្មក្ដី ខ្លឹមឈើក្ដី គេតែងតម្រូវចិត្តនៃពុទ្ធសាសនិកផងដែរ ឬត្រូវតាមមហាបុរិសលក្ខណៈនៃព្រះសម្មាសម្ពុទ្ធផងដែរ។ ប៉ុន្តែពួកសិប្បវន្ត ដែលកសាងព្រះពុទ្ធរូបនោះ ទោះបីអំពីថ្មក្ដី ខ្លឹមឈើក្ដី ឬគំនូរក្ដី ច្រើនតែធ្វើទៅតាមបែបភាពទ្រង់ទ្រាយមុខមាត់ របស់ជាតិខ្លួនឯងជាដរាប មិនសូវខុសអំពីមុខមាត់ របស់ជាតិខ្លួនបានឡើយ ដែលនាំឲ្យយើងស្គាល់ថា ជាការរចនារបស់ជាតិនេះ ជាតិនោះជាប្រាកដ។

បើតាមសេចក្ដីរាយការណ៍របស់អ្នកប្រាជ្ញ ដែលស្វែងរកបុរាណវត្ថុឃើញថា ព្រះពុទ្ធរូបទើបតែនឹងកើតមានឡើងក្នុងកាលខាងក្រោយ ដែលពុទ្ធសករាជកន្លងទៅបានជាង៤០០ឆ្នាំ ហើយពុំមែនកើតឡើងក្នុងកាលព្រះអង្គគង់ព្រះជន្មនៅឡើយនោះទេ។ព្រះពុទ្ធរូបដែលកើតមុនគេបង្អស់នៅក្នុងប្រទេសគន្ធារៈ ដោយព្រះបាទកនិស្កៈ ជាក្សត្រមួយព្រះអង្គជាជាតិក្រិក ជាប់រាជវង្សតមកពីព្រះបាទអាឡេកសង់ដ្រ៍ ដែលមានឥទ្ធិពលពង្រីកអាណាចក្រចូលមកក្នុងប្រទេសឥណ្ឌា ក្នុងកាលពុទ្ធសករាជទី៤ បន្ទាប់មកពួកសិប្បវន្តជាតិក្រិកខ្លះជាតិឥណ្ឌាខ្លះ ចេះតែកសាងព្រះពុទ្ធរូប ដោយការឆ្លាក់ថ្មក៏មាន ខ្លឹមឈើក៏មាន តៗគ្នាតាំងពីកាលនោះមក។

**ប្រទេសកម្ពុជាមានព្រះពុទ្ធរូប៨បែប**

១ - ព្រះពុទ្ធរូបសមាធិ គង់ពត់ព្រះភ្នែនមានព្រះហស្តស្តាំផ្ងារលើ ព្រះហស្តឆ្វេងតម្រួតលើព្រះភ្នែន ហៅថា វិតក៌មុទ្រ។

២ - ព្រះពុទ្ធរូបមារវិជ័យ (កាលផ្ចាញ់មារ) គង់ពត់ព្រះភ្នែនដូចព្រះពុទ្ធរូបសមាធិដែរ ប៉ុន្តែព្រះហស្តស្តោះផ្កាប់លើព្រះឧរូ (ភ្លៅ) ចង្អុលចុះទៅផែនដី ព្រះហសត្តឆ្វេងផ្ងារដាក់លើព្រះឧរូ ហៅថា ភូមិស្បស៌មុទ្រ។ ព្រះពុទ្ធរូបបែបនេះ កាលបើគេគូរនៅលើជញ្ជាំងព្រះវិហារ ឬលើផ្ទាំងសំពត់ ឃើញសុទ្ធតែមានរូបពួកពលមារាធិរាជ កាន់អាវុធរាល់ដៃ។

៣ - ព្រះពុទ្ធរូបសំដែងធម្មចក្រ គង់ពត់ព្រះភ្នែនមានព្រះហស្តស្តាំក្ដោបម្រាម ធ្វើជាមូលដូចរូបកង់រទេះព្រះហស្តឆ្វេងធ្វើអាការៈដូចព្រះហស្តស្តាំក៏មាន ដាក់លើព្រះឧរូក៏មាន ហៅថាធម្មចក្រមុទ្រា។ ព្រះពុទ្ធរូបបែបនេះ កាលបើគេគូរ តែងតែមានរូបបញ្ចវគ្គិយភិក្ខុ កំពុងអង្គុយគោរព ស្ដាប់ធម្មចក្រកប្បវត្តនសូត្រ ដែលជាបឋមទេសនា។

៤ - ព្រះពុទ្ធរូបប្រទានអភ័យ ជាតំណាងកាលដែលព្រះអង្គសំដែងធម៌ប្រោសត្វក្នុងទីណាមួយ មានព្រះកាយឈរក៏មាន គង់ពត់ព្រះភ្នែនក៏មាន ព្រះហស្តស្តាំរាទៅមុខ ព្រះហស្តឆ្វេងសំយុងចុះ ហៅថា អភយមុទ្រា។

៥ - ព្រះពុទ្ធរូបប្រទានពរ មានព្រះហស្តទាំងពីរសំយុងចុះ បែរបាទព្រះហស្តទៅខាងមុខ ទ្រង់គង់ពត់ព្រះភ្នែនក៏មាន ទ្រង់ឈរក៏មាន ជាតំណាងកាលបរិស័ទណាមួយចូលមកថ្វាយបង្គំដោយត្រូវការចង់ជួប ចង់ឃើញក្ដី ក្រាបទូលសួរធម៌អាថ៌ចំពោះព្រះអង្គក្ដី ហៅថា វរមុទ្រា។

៦ - ព្រះពុទ្ធរូបទ្រង់ឈរឱបបាត ជាតំណាងកាលដែលព្រះអង្គទ្រង់និមន្តបិណ្ឌបាត ហៅថា បាត្រាទានមុទ្រា។

៧ - ព្រះពុទ្ធរូបទ្រង់ផ្ទុំ ជាតំណាងកាលដែលព្រះអង្គ ផ្ទុំផ្អៀងកាយទៅខាងស្តាំ ព្រះបាទឆ្វេងត្រួតលើព្រះបាទស្តាំ ដោយទ្រង់ផ្ទុំធម្មតាក្តី ផ្ទុំលើមញ្ចាសនៈ ជាអនុដ្ឋានសញ្ញាទ្រង់បរិនិព្វានក្តី ហៅថា សយនមុទ្រា។

៨. ព្រះពុទ្ធរូបនាគប្រក់ ជាតំណាងកាលព្រះអង្គ គង់នៅក្លឹស្រះមុចលិន្ទ ដែលក្នុងកាលនោះមានភ្លៀងបង្អុរខ្លាំង មាននាគរាជមកពេនព័ទ្ធព្រះអង្គបើកពពារគ្រប់បាំងលើព្រះអង្គដើម្បីការពារភ្លៀង។

ព្រះពុទ្ធរូបនាគប្រក់ នៅប្រទេសឥណ្ឌា មិនដែលឃើញមានទេ មានតែក្នុងប្រទេសខ្មែរ ដែលកើតឡើងដោយសិល្បៈខ្មែរ ក្នុងសម័យក្រោយកសាងតាមរឿងពុទ្ធប្បវត្តិ។

ពាក្យថា មុទ្រា នេះជាភាសាសំស្រ្កឹត បាលីថា មុទ្ទា ប្រែជាខ្មែរថា គ្រឿងសម្គាល់ បែបយ៉ាង អាការកាយវិការ ត្រា សញ្ញា។

## ១១.១១. ឈ្វេងយល់អំពីពិធីបុណ្យចូលឆ្នាំខ្មែរ

ក្នុងមួយឆ្នាំៗមានពាក្យថា សង្ក្រាន្ត គ្រប់ឆ្នាំទាំងអស់ ឯពាក្យថា សង្ក្រាន្ត ក្លាយមកពីពាក្យសំស្រ្កឹតថា សំក្រាន្តិ ការដែលព្រះអាទិត្យចូលកាន់រាសីវេលាចូលក្នុងឆ្នាំថ្មី គឺត្រង់ពេលចែកឆ្នាំ។ ដើម្បីឲ្យប្រជាជនខ្មែរទាំងឡាយបានយល់ដឹងពាក្យថាប្រវេណី សង្ក្រាន្ត។

ក្នុងកាលដើមនៃភទ្រកប្បនេះ មានសេដ្ឋីម្នាក់មានទ្រព្យសម្បត្តិច្រើនស្តុកស្តម្ភ តែមិនមានកូន មានផ្ទះនៅជិតអ្នកប្រមឹកម្នាក់ អ្នកប្រមឹកនោះមានកូនប្រុសពីរនាក់ មានរូបឆោមសម្បុរល្អ មានពណ៌សម្បុរដូចមាសគួរជាទីពិតពិលរមិលមើល នៃមនុស្សទាំងពួង ថ្ងៃមួយអ្នកប្រមឹកស្រានោះ ចូលទៅនិយាយពាក្យអាក្រក់ទ្រគោះបោះបោកនឹងសេដ្ឋីៗ ទើបសួរថា ឯងហេតុអ្វីបានជាហ៊ានមកពោលពាក្យប្រមាថមើលងាយយើងជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភច្រើនដល់ម្ល៉េះ អ្នកប្រមឹកឆ្លើយតបវិញថា លោកសេដ្ឋី លោកគ្រាន់តែមានទ្រព្យសម្បត្តិច្រើននោះក៏មែន តែលោកគ្មានកូន កាលបើលោកស្លាប់ទៅហើយ សម្បត្តិទាំងនោះនឹងវិនាសខ្ចាត់ខ្ចាយសូន្យទៅទទេមិនខាន យើងខ្សត់ទ្រព្យ តែមានកូនឃើញថា ប្រសើរជាងលោក ហេតុដូច្នេះបានយើងមើលងាយ លោកសេដ្ឋីឈរទ្រឹងគិតមួយស្របក់ ទៅឃើញមែន សមតាមពាក្យប្រមឹកថា ក៏មានសេចក្តីអៀនខ្មាស់តូចចិត្តនឹងគ្មានកូន ទើបខំបួងសួងបន់ស្រន់ព្រះអាទិត្យព្រះចន្ទ តាំងអធិដ្ឋានសេចក្តីប្រាថ្នា សូមឲ្យបានកូនរហូតដល់៣ឆ្នាំ ក៏មិនបានកូនមួយសោះ លុះយូរដល់ថ្ងៃនក្ខត្តឫក្ស ជាឈ្មោះផ្កាយមួយពួកមាន៧ដែលក្លាយមកពីកូនទាំង៧ ដែលខ្មែរធ្លាប់ហៅថា នក្ខត្តឫក្ស ល្អ ឬអាក្រក់ចំពោះត្រង់ផ្កាយនោះឯង ព្រះអាទិត្យឡើងកាន់រាសី សេដ្ឋីទើបនាំបរិវារទៅកាន់ដើមជ្រៃធំ មានមែកត្រសុំត្រសាយដែលជាទីនៅនៃហ្វូងសត្វបក្សី បក្សាទាំងពួង នៅទៀបឆ្នេរសមុទ្រ លុះទៅដល់ហើយយកអង្ករមកលាងទឹក ៧ដងឲ្យស្អាតហើយ ទើបចំអិនបូជាដល់អារក្សព្រះជ្រៃ ប្រគំភ្លេងតាំងអធិដ្ឋានសុំកូន អារក្សព្រះជ្រៃមានសេចក្តីករុណា ទើបហោះទៅ

គាល់ព្រះឥន្ទ្រាធិរាជក្រាបបង្គំទូលសូមបុត្រឲ្យលោកសេដ្ឋី ព្រះឥន្ទចាត់ឲ្យធម្មបាលទេវបុត្រ ច្យុតមកចាប់បដិសន្ធិក្នុងគភ៌នៃភរិយាសេដ្ឋីនោះ លុះគ្រប់ដប់ខែហើយទើបប្រសូត្របុត្រនោះមក សេដ្ឋីមានសេចក្តីត្រេកអរពន់ពេក ដោយបានសមតាមបំណង ទើបឲ្យឈ្មោះបុត្រនោះថា ធម្មបាល សេដ្ឋីបានសាងប្រាសាទ៧ជាន់ ឲ្យធម្មបាលកុមារនៅជិតដើមជ្រៃធំក្បែរឆ្នេរសមុទ្រនោះ កុមារបានស្តាប់បក្សី នៅលើដើមជ្រៃនោះនិយាយគ្នារាល់ថ្ងៃតាំងពីតូចមក លុះចម្រើនធំឡើងចេះស្តាប់ភាសាសត្វបាន តមកបានរៀនត្រៃវេទ ចេះចាំចប់សព្វគ្រប់ជាកុមារឆ្លៀវឆ្លាត ក្នុងវិទ្យាសាស្រ្តតាំងពីអាយុ៧ខួប ទើបបានឡើងជានាទីអាចារ្យបង្ហាត់បង្រៀនមង្គលការផ្សេងៗ ដល់មនុស្សទាំងពួង។ ក្នុងខណៈនោះមនុស្សទាំងឡាយ ប្រកាន់ជឿកបិលមហាព្រហ្ម ថាជាអ្នកសំដែងមង្គលដល់ពួកមនុស្ស កាលបើកបិលមហាព្រហ្មជាបហេតុនោះហើយ ទើបហោះចុះមកសួរប្រស្នានឹងធម្មបាលកុមារ៣យ៉ាង សន្យាគ្នាថា បើធម្មបាលកុមារដោះស្រាយប្រស្នាបាន នឹងកាត់ក្បាលខ្លួនបូជា បើដោះមិនបាននឹងកាត់ក្បាលធម្មបាលកុមារវិញ ធម្មបាលកុមារសូមថយគិតចំនួន៧ថ្ងៃ គ្រាកន្លង៦ថ្ងៃហើយ ក៏គិតមិនយល់តិចតួចសោះ ទើបនឹកថា ព្រឹកនេះអញនឹងត្រូវស្លាប់ដោយអាជ្ញាស្តេចកបិលមហាព្រហ្មមិនខានអាត្មាអញមិនគួរស្លាប់ដោយហេតុនេះឡើយ នឹងរត់ចេញទៅលាក់ខ្លួនពួនអាត្មាឲ្យស្លាប់នឹងហេតុដទៃល្អជាងទើបចុះចាក់ចេញពីប្រាសាទទាំងកណ្តាលអាធ្រាត្រ ទៅពួកដេកនៅទីចន្លោះគល់ត្នោតលៃពីរដើម ដែលមានសត្វឥន្ទ្រីយ៍ មួយគូញីឈ្មោលវាធ្វើសំបុកអាស្រ័យនៅលើចុងត្នោតនោះ ចួនជាវេលានោះ សត្វឥន្ទ្រីយ៍ញីសួរស្វាមីថា ព្រឹកនេះយើងនឹងបានអាហារមកពីណា ឥន្ទ្រីយ៍ឈ្មោលប្រាប់ថា ឯងកុំថប់បារម្ភអ្វីនឹងអាហារមកពីទីណា យើងនឹងបានស៊ីសព (ខ្មោចស្រស់) ធម្មបាលកុមារដែលស្តេចកបិលមហាព្រហ្មនឹងសម្លាប់ព្រោះដោះស្រាយប្រស្នាមិនរួចឥន្ទ្រីយ៍នោះសួរថាប្រស្នានោះពិបាកដោះស្រាយយ៉ាងណាទៅបានជាឆ្លើយមិនរួច ឥន្ទ្រីយ៍ឈ្មោលបានប្រាប់ថា ស្តេចកបិលមហាព្រហ្មសួរពីសិរី៣យ៉ាងរបស់ពួកមនុស្ស តើនៅត្រង់ណាខ្លះ? ឥន្ទ្រីយ៍ញីសួរថា បើប្រស្នាបែបនេះនឹងដោះស្រាយបែបណាទើបត្រូវ ឥន្ទ្រីយ៍ឈ្មោលប្រាប់ថា ឱ! ឯងមិនយល់ប្រស្នានេះទេ បើដូច្នោះចាំស្តាប់អញចុះ ពេលព្រឹកសិរីស្ថិតនៅត្រង់មុខ ពួកមនុស្សទើបយកទឹកលុបលាងមុខ នេះជាពាក្យឆ្លើយប្រស្នាទី១ ពេលថ្ងៃត្រង់សិរីស្ថិតនៅត្រង់ទ្រូង ពួកមនុស្សទើបយកគ្រឿងសាបមកប្រស់ព្រំទ្រូង នេះជាពាក្យឆ្លើយប្រស្នាទី២ ពេលអស្តង្គត សិរីស្ថិតនៅជើង ពួកមនុស្សទើបយកទឹកលាងជើង នេះជាពាក្យឆ្លើយប្រស្នាទី៣ ធម្មបាលកុមារខំផ្ទៀងស្តាប់បានឮដូច្នោះហើយ ក៏មានសេចក្តីត្រេកអរគិតថា អញនឹងរួចផុតពីសេចក្តីស្លាប់ហើយម្តងនេះ ទើបត្រឡប់មកប្រាសាទខ្លួនវិញ លុះព្រឹកឡើង ស្តេចកបិលមហាព្រហ្មមកសួរប្រស្នាដដែលនោះទៀត ធម្មបាលក៏ដោះតាមពាក្យឥន្ទ្រីយ៍ ស្តេចកបិលមហាព្រហ្ម អើត្រូវហើយៗ បើដូច្នោះខ្ញុំត្រូវកាត់ក្បាលខ្ញុំបូជាអ្នកហើយ ក៏ហៅថានាងទេពធីទាំង៧នាក់ ដែលជាបរិចារិការបស់ព្រះឥន្ទមកជួបជុំហើយ ទើបប្រាប់ថា យើងនឹងកាត់ក្បាលបូជាធម្មបាលកុមារ តែក្បាលយើងនេះបើនឹងតាំងទុកនៅលើផែនដីភ្លើងនឹងឆេះទួទៅទាំងលោកធាតុ បើនឹងបោះបណ្តែតទៅលើអាកាស ភ្លៀងក៏នឹងរាំង បើនឹងបោះទៅក្នុងមហាសមុទ្រក៏នឹងរីងស្ងួត បើដូច្នោះត្រូវឲ្យកូនទាំង៧នាក់នេះយកពានមាសមកទទួលព្រះសិរ (ក្បាល) អញ

ហើយក៏កបិលមហាព្រហ្មកាត់សិរប្រគល់ឲ្យទៅនាធុង្សជាបុត្រីច្បង នាងធុង្សយកពានមាសមកទទួលព្រះសិរបិតា ហើយហោះទៅប្រទក្សិណភ្នំសុមេរុ ៦០នាទី ទើបយកទៅប្រតិស្ឋានទុកនៅមណ្ឌប នៅនាទីគុហាគន្ធមូលី ភ្នំកៃលាស បូជាដោយគ្រឿងទិព្វផ្សេងៗ ព្រះវិស្សុកម្មទេវបុត្របាននិម្មិតរោងកែងទាំង៧ប្រការ ឈ្មោះភគវតី ឲ្យជាទីប្រជុំទេវតាទាំងឡាយ ទេវតាទាំងនោះក៏នាំគ្នាយកព្រះសិរស្តេចកបិលមហាព្រហ្មមកលាងទឹកក្នុងស្រះអនោតត្ត៧ដង ហើយចែកគ្នាបួងសួងគ្រប់ៗគ្នា រាប់តាំងពីថ្ងៃនោះមករហូតដល់គ្រប់កំណត់៣៦៥ថ្ងៃ លោកសន្មតថាមួយឆ្នាំ ហៅថា សង្ក្រាន្ត នាងទេពធីតាទាំង៧អង្គ ត្រូវវេនផ្លាស់ប្តូរគ្នារាល់ឆ្នាំ ក្នុងមួយឆ្នាំត្រូវនាងទេពធីតាម្នាក់ អញ្ជើញព្រះសិរស្តេចកបិលមហាព្រហ្មចេញហែរប្រទក្សិណជុំវិញភ្នំព្រះសុមេរុ ហើយត្រឡប់ទៅទេវលោកវិញដូច្នេះឯង។

នាងសង្ក្រាន្តទាំង៧នោះ មានតាមតម្រាហោរាសាស្ត្រថា ៖

១. ថ្ងៃអាទិត្យឈ្មោះ ធុង្ស សៀតផ្កាទទឹម (ផ្កាក្រទឹម) ប្រដាប់ដោយគ្រឿងបទុមរាគ សោយផ្លែល្វាជាអាហារ ព្រះហស្តស្តាំទ្រង់ចក្រ ព្រះហស្តឆ្វេងទ្រង់ស័ង្ខ គ្រុឌជាពាហនៈ។

២. ថ្ងៃចន្ទឈ្មោះ គោរាគ ទ្រង់ផ្កាមន្ទារបុស្ស (សៀតផ្កាត្រកៀត) ប្រកបដោយកែវមុក្តា សោយប្រេងល្ងជាអាហារ ព្រះហស្តស្តាំទ្រង់ព្រះខ័ន (ក្បួនខ្លះថា ឈើច្រត់) ព្រះហស្តឆ្វេងទ្រង់ចាប់មុខព្រះខ័ន ព្យគ្ឃរាជជាពាហនៈ។

៣. ថ្ងៃអង្គារ៍ ឈ្មោះ រាក្សស សៀតផ្កាឈូកក្រហម ប្រដាប់ដោយគ្រឿងមោរ៉ា សោយលោហិតជាអាហារ ព្រះហស្តស្តាំទ្រង់ត្រៃសូល៍ ព្រះហស្តឆ្វេងទ្រង់ធ្នូ សូករជាពាហនៈ។

៤. ថ្ងៃពុធ ឈ្មោះ មណ្ឌា សៀតផ្កាចម្ប៉ា ប្រដាប់គ្រឿងពិទូរ្យ សោយទឹកដោះជាអាហារ ព្រះហស្តស្តាំទ្រង់ដែកស្រួច (ម្ជុល) ព្រះហស្តឆ្វេងទ្រង់ឈើច្រត់ លាជាពាហនៈ។

៥. ថ្ងៃព្រហស្បតិ៍ ឈ្មោះ កិរិណី សៀតផ្កាមណ្ឌា ប្រដាប់ដោយកែវមរកត សោយសណ្តែកល្ងជាអាហារ ព្រះស្តាំទ្រង់កង្វេរ ព្រះហស្តឆ្វេងទ្រង់អាវុធ (កាំភ្លើង) ហត្ថីជាពាហនៈ។

៦. ថ្ងៃសុក្រ ឈ្មោះ កិមិទា សៀតផ្កាចង្កុលណី ប្រដាប់ដោយគ្រឿងបុស៉ាខាំ សោយចេកទឹកជាអាហារ ព្រះហស្តស្តាំទ្រង់ព្រះខ័ន ព្រះហស្តឆ្វេងទ្រង់ពិណ ក្របីជាពាហនៈ។

៧. ថ្ងៃសៅរ៍ ឈ្មោះ មហោធរា សៀតផ្កាត្រកៀត (ក្បួនខ្លះថាផ្កាក្រូច) ប្រដាប់ដោយគ្រឿងកែវនិលរត្នសោយសាច់ទ្រាយជាអាហារ ព្រះហស្តស្តាំទ្រង់ចក្រ ព្រះហស្តឆ្វេងទ្រង់ត្រីសូល៍ មយូរាជាពាហនៈ[55]។

ការធ្វើពិធីបុណ្យចូលឆ្នាំខ្មែរ

បុណ្យចូលឆ្នាំខ្មែរ ជាបុណ្យប្រពៃណីជាតិ ដែលប្រជាជននៅក្នុងប្រទេសកម្ពុជាតែងតែប្រារព្ធធ្វើជារៀងរាល់ឆ្នាំ នៅក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ មានការរៀបចំដូចតទៅ ៖ ពិធីបុណ្យចូលឆ្នាំ ប្រព្រឹត្តទៅ៣ថ្ងៃ គឺនៅ

[55] កម្ពុជសុរិយា ភាគ ១០/១ ពុទ្ធសាសនបណ្ឌិត្យ គ.ស ១៩៣៨ ទំព័រ២១២

ថ្ងៃទី ១៣, ១៤, ឬ ១៥ ខែ មេសា ព្រោះជារដូវកាលដែលប្រជាជនខ្មែរមានពេលទំនេរពីការប្រមូលផលស្រូវ និងដំណាំកសិកម្មផ្សេងៗ។ មុនពេលប្រារព្ធ ពិធីបុណ្យចូលឆ្នាំ ១ ឬ២ថ្ងៃ ប្រជាជនខ្មែរតែងតែនាំគ្នា សំអាត តុបតែងផ្ទះសម្បែង និងរៀបចំគ្រឿងសម្ភារៈផ្សេងៗ ដើម្បីត្រៀមទទួលទេវតាឆ្នាំថ្មី។

ថ្ងៃទី ១ ៖ ថ្ងៃមហាសង្ក្រាន្ត

នៅពេលចូលដល់ថ្ងៃទី១ នៃថ្ងៃបុណ្យចូល ឆ្នាំខ្មែរ ដែលក្នុងប្រពៃណីខ្មែរតែងហៅថ្ងៃនោះថាជា ថ្ងៃមហាសង្ក្រាន្ត (sankranti)។ នៅពេលនោះប្រជាពលរដ្ឋខ្មែរដែលកាន់ជំនឿតាមព្រះពុទ្ធសាសនា បានរៀបចំកន្លែងទទួលទេវតាឆ្នាំថ្មី ដែលមានគ្រឿងរណ្តាប់ផ្សេងៗ និងមានតុបតែងលម្អដោយភ្លើងចម្រុះពណ៌តាមផ្ទះរបស់ពួកគេ។ គ្រឿងរណ្តាប់ មានដូចជា ៖ ទឹកផ្តិលអប់ដោយផ្កា ទៀន ៥ ធូប ៥ ផ្កាភ្ញី ភេសជ្ជៈ និងនំចំណី, ផ្លែឈើជាច្រើន។ បន្ទាប់មក ពួកគេនឹងធ្វើការសែនព្រេន ដោយមានអុជធូប និងទៀន តាមគេហដ្ឋានរបស់ខ្លួន។ នៅពេលដល់កំណត់ថាទេវតាឆ្នាំថ្មី យាងចុះមកប្រសិទ្ធិពរជ័យ សិរីសួស្តី ដើម្បីឲ្យពួកគេទទួលបានសេចក្តីសុខពេញមួយឆ្នាំ។

ក្នុងថ្ងៃនេះដែរ គេក៏យកចង្ហាន់ទៅប្រគេនភិក្ខុទាំងឡាយនៅតាមវត្តអារាម ពេលល្ងាចគេនាំគ្នាជញ្ជូនខ្សាច់សាង វាលុកចេតិយ នៅជុំវិញព្រះវិហារ ឬនៅជុំវិញដើមពោធិណាមួយនៅក្នុងវត្តនោះ។ នៅពេលព្រលប់គេប្រគេនភេសជ្ជៈដល់ភិក្ខុទាំងឡាយ និមន្តភិក្ខុសូត្រចម្រើនព្រះបរិត្ត និង សំដែងធម្មទេសនា។

ថ្ងៃទី ២ ៖ ថ្ងៃ វនបត

នៅពេលចូលថ្ងៃទី២ នៃបុណ្យចូលឆ្នាំខ្មែរ គេហៅថ្ងៃនោះ ថាជា វារៈវ័នបត ប្រជាជននាំគ្នាទៅវត្តអារាមដើម្បីយក ចង្ហាន់ នំចំណី ផ្លែឈើ ទៅប្រគេនព្រះសង្ឃ។ លើសពីនេះទៅទៀត ក៏មានការរៀបចំលេងល្បែងប្រជាប្រិយ ដូចជា៖ ចោលឈូង បោះអង្គញ់ លាក់កន្សែង និងមានការច្រៀងរាំបទចម្រៀងប្រពៃណីផងដែរ នៅតាមវត្តអារាម និង តាមបណ្តាតំបន់នានានៅក្នុងប្រទេសកម្ពុជា។

ក្នុងថ្ងៃនេះដែរ កូនចៅជូនសំលៀកបំពាក់ នំចំណី លុយកាក់ ដល់អ្នកមានគុណ មានឪពុកម្តាយ ជីដូនជីតា ជាដើម។ ជួនកាលគេធ្វើទាន ដល់មនុស្សបម្រើ ឬអ្នកក្រីក្រទៀតផង ។ ពេលរសៀល គេនាំគ្នាទៅពូនភ្នំខ្សាច់ទៀត ហើយសូត្រធម៌អធិដ្ឋានភ្នំខ្សាច់ដែលគេសន្មត់ទុកដូចចូឡាមនីចេតិយ ហើយនិមន្តភិក្ខុទាំងឡាយបង្សុកូលចេតិយបញ្ជូនមគ្គផលដល់វិញ្ញាណក្ខន្ធបងប្អូន ដែលបានស្លាប់ទៅ។

ថ្ងៃទី ៣ ៖ ថ្ងៃឡើងស័ក

នៅពេលចូលថ្ងៃទី ៣ ជាថ្ងៃបញ្ចប់ពិធីបុណ្យចូលឆ្នាំ គេហៅថា វារៈឡើងស័ក ឬថ្ងៃឆ្លង នៅថ្ងៃនោះ គេតែងប្រារព្ធធ្វើពិធី ស្រង់ទឹករូបបដិមារបស់ព្រះពុទ្ធ នៅតាមវត្តអារាម ដើម្បីសុំសេចក្តីសុខ ហើយក៏ជាថ្ងៃបញ្ចប់នៃការប្រារព្ធធ្វើពីធីបុណ្យចូលឆ្នាំខ្មែរដែរ។

ក្នុងថ្ងៃនេះដែរ ពេលព្រឹកនិមន្តភិក្ខុទាំងឡាយសូត្រឆ្លងភ្នំខ្សាច់ ។ ពេលល្ងាច និមន្តភិក្ខុស្រង់ទឹក និងស្រង់ព្រះពុទ្ធរូប (តាមការនិយមនៃស្រុកខ្លះ)។ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ គេនាំគ្នាលេងល្បែងប្រជាប្រិយកំសាន្តសប្បាយជាច្រើន ដូចជាលេង បោះអង្គញ់ ចោលឈូង ទាញព្រ័ត្រ លាក់កន្សែង ចាប់កូនខ្លែងជាដើម និងមានរបាំត្រុដិ (ច្រើនមាននៅខេត្តបាត់ដំបង សៀមរាប) ជាពិសេសទៀតគឺរាំវង់ តែអាស្រ័យទៅតាមការនិយមចូលចិត្តរបស់មនុស្សម្នាក់ៗ អ្នកខ្លះនិយមនាំគ្នាដើរកំសាន្តបន្ត អ្នកខ្លះនិយមធ្វើបុណ្យទានតាមវត្តអារាម។

អត្ថន័យនៃពិធីបុណ្យចូលឆ្នាំខ្មែរ

ខ្មែរកំណត់យកពេលបុណ្យ ចូលឆ្នាំថ្មី ខែមេសា (ខែចេត្រ) ពីព្រោះខែចេត្រ ជាដើមឆ្នាំដែលព្រះអាទិត្យចូលកាន់មេសរាសី គឺព្រះអាទិត្យ ដើរចំពីក្បាលជាសង្រ្កាន្ត ។ ខ្មែរមានជំនឿថា ក្នុងអំឡុងពេលមួយឆ្នាំនៃការរស់នៅ គេតែងជួបប្រទះអពមង្គល ឧបទ្រពចង្រៃ ផ្សេងៗ ជួនកាលមានទុក្ខសោក ជួនកាលមានគ្រោះអាសន្នអន្តរាយ ជួនកាលមានគ្រោះជំងឺរួបរឹតរាងកាយ ជួនកាលទៀតបានប្រព្រឹត្តអំពើសៅហ្មង មិនគប្បី ។ លុះផុតឆ្នាំចាស់ទៅ គេនាំគ្នាធ្វើបុណ្យ គេស្លៀកពាក់ ថ្មីៗ គេនាំគ្នាដើរលេងកម្សាន្ត ដើម្បីឱ្យអស់កង្វល់ ហើយឲ្យមានសិរីសួស្តី មានសុភមង្គលនៅក្នុងឆ្នាំថ្មី ។

ម្យ៉ាងទៀតរយៈពេលមួយឆ្នាំ ដែលគេបានបែកចេញពីគ្រួសារ និងញាតិមិត្ត ដែលទៅប្រកបរបរចិញ្ចឹមជីវិតនៅឆ្ងាយៗ លុះដល់ឆ្នាំថ្មី គេបានវិលទៅជួបជុំគ្នា សួរសុខទុក្ខគ្នា ដើម្បីបន្ធូរបន្ថយការនឹករលឹក និងបំបាត់ការនឿយហត់ពីការងារផង រួចទើបបន្តជីវភាពថ្មីនៅក្នុងឆ្នាំថ្មី ប្រកបរបរដោយជោគជ័យ និងអាយុយឺនយូរ។

អត្ថន័យម្យ៉ាងទៀត ស្ថិតនៅត្រង់ពិធីបុណ្យចូលឆ្នាំថ្មី គឺជាប្រពៃណីមួយ អាចបណ្តុះស្មារតី ស្រឡាញ់រាប់អានគ្នារវាងអ្នកស្រុកព្រៀងលាន ជាកត្តាបង្កើតសាមគ្គីភាពជាតិ។ ហេតុនេះហើយ ទើបនៅពេលនោះ គេមិនត្រឹមតែជួបជុំគ្នាក្នុងគ្រួសារប៉ុណ្ណោះទេ តែគេនាំគ្នាទៅធ្វើបុណ្យនៅវត្តអារាមទៀត ដែលជាមជ្ឈមណ្ឌលបង្កើតសាមគ្គីភាព។

ដោយសារពិធីបុណ្យចូលឆ្នាំថ្មី មានអត្ថន័យធំធេងយ៉ាងនេះហើយ ទើបខ្មែរយើងនិយមរាប់អានទុកជាប្រពៃណីជាតិមួយ តាំងពីដើមរហូតមក។

# សន្និដ្ឋាន

ខ្លឹមសារនៅក្នុងសៀវភៅ ទស្សនវិជ្ជាព្រះពុទ្ធសាសនានេះ ត្រូវបានចងក្រងឡើងដោយផ្ចិតផ្ចង់បំផុត ដោយទាញយកខ្លឹមសារសំខាន់ៗ ដែលជាមេរៀនដ៏ល្អឧត្តមរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលព្រះអង្គបានបង្រៀនហើយដោយល្អ ដល់សាវ័កទាំងឡាយកាលពីអតីតកាល ខ្លឹមសារទាំងនោះ គឺពិតជាមានឥទ្ធិពល និងវិសាលភាពបំផុតសម្រាប់សង្គមមនុស្សលោក ព្រោះមេរៀនទាំងនោះ គឺសុទ្ធតែចង្អុលបង្ហាញអំពីមធ្យោបាយដើម្បីនាំមកនូវសន្តិភាពផ្ទាល់ខ្លួន និងបរិស្ថានជុំវិញ មានបរិស្ថានសង្គមមនុស្សជាដើម។ យោងតាមខ្លឹមសារនៃមេរៀនទាំងនេះ ពិតជាបានចូលរួមចំណែកដ៏សំខាន់បំផុតក្នុងការបណ្តុះនិស្ស័យល្អដល់មនុស្សក្នុងសង្គម ជាពិសេស នៅក្នុងសៀវភៅ ទស្សនវិជ្ជាព្រះពុទ្ធសាសនានេះ នឹងជួយឲ្យនិស្សិតទាំងឡាយដែលកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ បានទទួលចំណេះដឹងពិតប្រាកដរបស់ព្រះពុទ្ធសាសនា ហើយមើលឃើញពីឧត្តមភាពនៃព្រះពុទ្ធសាសនាដែលពួកគេធ្លាប់បានគោរពតាំងពីដើម ដោយបន្តវេនពីដូនតា ម៉ែឪ ដែលពួកគេបានប្រតិបត្តិតៗគ្នា ដោយពេលខ្លះមិនស្គាល់ថា ត្រង់កន្លែងណាជាព្រះពុទ្ធសាសនា កន្លែងណាជាជំនឿ តើបេះដូងរបស់ព្រះពុទ្ធសាសនានៅត្រង់ណា តើព្រះពុទ្ធសាសនាបានបង្រៀនមនុស្សឲ្យប្រតិបត្តិដូចម្តេច គោលដៅរបស់ព្រះពុទ្ធសាសនាបង្រៀនឲ្យមនុស្សរស់នៅដូចម្តេច និងបង្រៀនមនុស្សឲ្យធ្វើដំណើរទៅណា។

ដើម្បីឲ្យសង្គមមនុស្សមានសីលធម៌ល្អក្នុងការរស់នៅ បើមនុស្សគ្រប់រូបបានសិក្សាដោយយកចិត្តដាក់ទៅលើពាក្យពេចន៍របស់ព្រះពុទ្ធជាម្ចាស់ ហើយប្រតិបត្តិតាមដោយប្រពៃនោះ ជីវិតឯកជនក៏បានសេចក្តីសុខ មនុស្សនៅជុំវិញខ្លួនក៏បានសេចក្តីសុខ សង្គមជាតិទាំងមូលក៏បានសេចក្តីសុខ បើសង្គមមនុស្សរស់ដោយល្អប្រពៃហើយ សេចក្តីសុខសុភមង្គល និងសេចក្តីចម្រើនក៏នឹងកើតមានឡើងយ៉ាងប្រាកដ។

តែផ្ទុយទៅវិញ បើមនុស្សនៅក្នុងសង្គម មិនបានសិក្សាដោយល្អ និងប្រព្រឹត្តផ្ទុយពីការបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធ យើងនឹងបានឃើញលទ្ធផលដែលកើតចេញពីការអំពើនោះៗ ជាច្រើនរូបភាព មានដូចជាការបៀតបៀនគ្នា ការប្រើហិង្សា ការឈ្លោះទាស់ទែងគ្នា ការប្រទុស្តរាយដល់គ្នា និងគ្នា ការកាប់សម្លាប់គ្នា ការជិះជាន់គ្នា ការរស់នៅរបស់មនុស្សមានភាពច្របូកច្របល់ បាត់បង់សេចក្តីថ្លៃថ្នូរភាពជាមនុស្សជាតិ។

ការចេះដឹងរបស់មនុស្សគឺជាពិតជាមានសារសំខាន់ជាទីបំផុត មានតែការចេះដឹងពិតប្រាកដទេ ទើបអាចជួយរំដោះជីវិតឲ្យរស់នៅដោយភាពរុងរោចន៍បាន ការចេះដឹងគឺជាមធ្យោបាយតែមួយគាត់សម្រាប់ដោះស្រាយរាល់វិបត្តិនានា ដោយភាពត្រឹមត្រូវបាន ការចេះដឹងនាំឲ្យមនុស្សចេះគិតពិចារណាប្រកបដោយសុចរិតយុត្តិធម៌ និងមានចិត្តប្រកបដោយមេត្តា ករុណា សេចក្តីសន្តោស ចំពោះមនុស្សជាតិ និងសត្វដែលមានជីវិតនានានៅលើផែនដីនេះ។

ការចេះដឹងមិនត្រឹមតែធ្វើឲ្យមនុស្សមានភាពស្អាតស្អំខ្លួនឯងតែប៉ុណ្ណោះទេ និងធ្វើឲ្យមនុស្សក្លាយទៅជាមេដឹកនាំល្អ ប្រជានល្អ ប្រមុខល្អ ជាដើម។ ដូច្នេះមេរៀននៅក្នុងសៀវភៅ ទស្សនវិជ្ជាព្រះពុទ្ធសាសនានេះ និងបានជួយបង្កើនការចេះដឹង នូវចំណេះដឹងថ្មីៗបន្ថែមទៀតដល់អ្នកសិក្សាទាំងឡាយ ឲ្យយល់កាន់តែច្បាស់ពីការបង្រៀនរបស់ព្រះពុទ្ធ ហើយឈប់ទទួលយកនូវអ្វីដែលជាមធ្យោបាយប្លម មិនប្រកបដោយសច្ចធម៌។

រាល់ការបង្រៀនទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធ ដែលមានធម្មៈរហូតទៅដល់៨៤០០០ធម្មក្ខន្ធ ដែលធម្មៈទាំងនេះ គឺជាការបង្រៀនអំពីគោលវិធីសម្រាប់ការប្រតិបត្តិ សុទ្ធសាធសម្រាប់មនុស្សជាតិទូទៅ ក្នុង

វិធីសម្រាប់ប្រតិបត្តិទាំងនោះ គឺមានលក្ខណៈតាមលំដាប់លំដោយ និងតាមអធ្យាស្រ័យនិស្ស័យចិត្តរបស់មនុស្សលោក ចំណុចនៃចាប់ផ្ដើមបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធ គឺតាមរយៈការបង្ហាញអំពីកន្សោមធម៌ទៅតាមលំដាប់ តាំងពីវិធីប្រតិបត្តិសម្រាប់សាមញ្ញជន រហូតដល់ធម៌ដែលមានលក្ខណៈស៊ីជម្រៅ ដែលញ៉ាំងសាមញ្ញជនឲ្យជាក់ច្បាស់ក្នុងរឿងជីវិត រហូតមានជនសាមញ្ញជាច្រើនបានក្លាយខ្លួនទៅជាអរិយជន។ ព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើការប្រៀបធៀបប្រដូចព្រះធម៌ ដែលត្រូវបង្រៀនដល់មនុស្សលោក ទៅនឹងមហាសមុទ្រថាធម្មជាតិសមុទ្រ គឺមានលក្ខណៈចាប់ពីចំណុចសាមញ្ញ គឺមានជម្រេលតាមលំដាប់ពីរាករហូតដល់ជម្រៅខ្លាំងមិនដូចអណ្ដូង ឬស្រះទឹកឡើយ គឺមានលក្ខណៈជាចំណោទច្រាំងជ្រៅតែម្ដង។ ព្រោះហេតុនេះហើយ យើងសង្កេតមើលទៅលើការបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធ ជាក់ស្ដែងព្រះធម៌ទាំងនោះ គឺមាននៅក្នុងសៀវភៅទស្សនៈវិជ្ជាព្រះពុទ្ធសាសនានេះស្រាប់ មានដូចជា ការប្រតិបត្តិតួនាទី ទសពិធរាជ ទាន សីល ក្នុងនោះមានសីល៥ សីល៨ សីល១០ និងសីល៤ កម្មបថ បានដល់កុសលកម្ម និងអកុសលកម្ម ភាវនា បានសមាធិ និងវិបស្សនា ជាដើម រហូតដល់អរិយសច្ចធម៌ ដែលជាគ្រឹះមេរៀនដ៏សែនជ្រៅ ពាក់ព័ន្ធដល់ចិត្ត ចេតសិក រូបនិព្វាន គោលការណ៍នៃការបង្រៀនទាំងនេះ គឺដើម្បីអនុគ្រោះដល់មនុស្សលោក ដើម្បីធ្វើខ្លួនឲ្យបានសុខ សុភមង្គលនៅក្នុងលោកិយនេះ តាមរយៈការសិក្សា ការបដិបត្តិដោយបញ្ញា ដើម្បីឈានទៅដល់ឧត្តមភាពនៃជីវិត ព្រះសម្មាសម្ពុទ្ធបានបើកបង្ហាញហេតុផល ដែលជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំង អំពីការកើតឡើងនៃសេចក្ដីទុក្ខ ហេតុនៃសេចក្ដីទុក្ខ ទីរំលត់បង់នៃទុក្ខ និងធម្មោបាយដើម្បីកម្ចាត់បង់នូវសេចក្ដីទុក្ខ។

យោងតាមការសិក្សារៀនសូត្រ អំពីពុទ្ធដីការបស់សម្មាសម្ពុទ្ធ ដែលលោកបានបែងចែកជាពួក ជាក្រុមដ៏ច្រើនរួចមក យើងអាចទាញសេចក្ដីសន្និដ្ឋានបានថា បើមនុស្សលោកគ្រប់ជាតិសាសន៍ គ្រប់វណ្ណៈ បានសិក្សាដោយល្អ ប្រតិបត្តិដោយល្អ ប្រកបដោយយោនិសោមនសិការ តាមការបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធ រាល់បញ្ហាទាំងឡាយនឹងត្រូវបញ្ចប់ បញ្ហាទាំងនោះមានអកុសលធម៌ជាដើម ដែលកើតចេញអំពីអវិជ្ជា និងតណ្ហា ព្រោះធម៌ទាំងនេះជាស្ថាបនិកបង្កើតឡើងនូវអំពើអកុសលគ្រប់យ៉ាងក្នុងជីវិតរបស់មនុស្ស។ បើមនុស្សគ្រប់រូបបានសិក្សាឲ្យយល់ច្បាស់ដោយបញ្ញា នូវហេតុបច្ច័យទាំងនេះហើយ មនុស្សទាំងឡាយនោះនឹងបញ្ឈប់បាននូវរាល់បញ្ហាអកុសលដែលកើតឡើងបាន ហើយធ្វើខ្លួនឲ្យទទួលបាននូវឧត្តមភាពនៃជីវិត ធ្វើឲ្យជីវិតបរិសុទ្ធ ការរស់នៅប្រកបដោយសេចក្ដីសុខ និងភាពស្ងប់ស្ងៀមនៃចិត្ត បញ្ចៀសបាននូវអកុសលធម៌ទាំងឡាយ ដែលមិនទាន់កើតក្ដី ដែលកើតហើយក្ដី បំរុងនឹងកើតក្ដី អាចទុបស្កាត់ ឬអាចកម្ចាត់ចោលបាន។ និងម្យ៉ាងទៀត មានលទ្ធភាពញ៉ាំងកុសលដែលមិនទាន់កើតឲ្យកើតឡើងបាន បើកើតឡើងហើយពង្រឹង និងពង្រីកឲ្យរឹតតែចម្រើនខ្លាំងឡើង ធ្វើខ្លួនឲ្យតាំងនៅក្នុងសីល ធ្វើកិច្ចការប្រកបដោយសុចរិត ប្រតិបត្តិតួនាទីប្រកបដោយព្រហ្មវិហារធម៌ និងទសពិធរាជធម៌ រស់នៅជាមួយគុណធម៌ មានសេចក្ដីសន្ដោស ស្រឡាញ់យុត្តិធម៌ ធ្វើឲ្យជីវិតរស់នៅដោយគ្មានការភ័យខ្លាច នាំមកនូវសន្តិភាពដល់មនុស្ស និងសត្វ។

**អនុសាសន៍**

ក្នុងនាមអ្នកចងក្រង និងនិពន្ធ សៀវភៅមុខវិជ្ជា **ទស្សនវិជ្ជាព្រះពុទ្ធសាសនា** សម្រាប់បម្រើការបង្រៀន និងរៀននៅថ្នាក់ឧត្តមសិក្សា ព្រោះការបង្រៀន និងរៀនគ្រប់មុខវិជ្ជាទាំងអស់ សម្រាប់សិក្សារៀងរាល់ឆមាសនីមួយៗ ចាំបាច់គ្រូបង្រៀនទាំងអស់ ត្រូវតែមានសៀវភៅគោលយ៉ាងតិចបំផុត១ក្បាល ដើម្បីផ្តល់ចំណេះដឹងដល់និស្សិត ព្រោះយើងដឹងហើយថា ការបង្រៀនដែលគ្មានឯកសារគោលសម្រាប់បង្រៀន ប្រាកដណាស់ការបង្រៀននោះនឹងចាប់ច្បិចត្រង់នេះបន្តិច ត្រង់នោះបន្តិច បង្រៀនតាមនឹកឃើញ ការដែលបង្រៀនដោយគ្មានសៀវភៅគោលជាមូលដ្ឋានដូច្នេះ វានាំឲ្យមានបញ្ហាជាច្រើន ទាំងការបង្រៀន និងការសិក្សារបស់និស្សិត គុណវិបត្តិដែលបង្រៀនដោយគ្មានសៀវភៅគោលមុខវិជ្ជាត្រឹមត្រូវ តាមជាក់ស្តែង ៖

១. ការបង្រៀនមិនត្រឹមត្រូវតាមមុខវិជ្ជា ដែលតម្រូវឲ្យបង្រៀន និងរៀនសម្រាប់ឆមាសនីមួយៗ។

២. បង្រៀនតាមអារម្មណ៍ តាមការនឹកឃើញ ដោយមិនត្រឹមត្រូវតាមលំដាប់លំដោយ ការបង្រៀនមានការស្មុគស្មាញ មិនច្បាស់លាស់ មានចេតនាបង្រៀនដើម្បីឲ្យតែគ្រប់ម៉ោងដែលរដ្ឋបានកំណត់។

៣. ធ្វើឲ្យនិស្សិតមិនជឿជាក់ នឿយណាយធុញទ្រាន់ក្នុងការសិក្សា បង្កការលំបាកដល់និស្សិតចំពោះមុខវិជ្ជាដែលត្រូវសិក្សា បង្កឲ្យនិស្សិតគ្មានភាពស្និទ្ធស្នាលជាគ្រូបង្រៀន ធ្វើឲ្យនិស្សិតរាយមាយ មិនចង់សិក្សាព្រោះតែការបង្រៀនគ្មានការយកចិត្តទុកដាក់ បង្រៀនដោយគ្មានលំដាប់លំដោយតាមខ្លឹមសារមេរៀន។

៤. ធ្វើឲ្យប៉ះពាល់ដល់ការបណ្តុះបណ្តាលធនធានមនុស្ស មិនមានចំណេះដឹងពិតប្រាកដ មិនមានជំនាញជាក់លាក់ មានចំណេះដឹងខ្សោយ កាលណាធនធាននិស្សិតមានចំណេះដឹងខ្សោយ ក៏វាបណ្តាលឲ្យប៉ះពាល់ដល់ការអភិវឌ្ឍជាតិ ព្រោះនិស្សិតគ្រប់រូបសុទ្ធតែមានកាតព្វកិច្ចយ៉ាងសំខាន់សម្រាប់ជាតិ។

ចំពោះការបង្រៀន និងរៀន ដែលមានសៀវភៅគោលសម្រាប់មុខវិជ្ជាចងក្រង និងនិពន្ធត្រឹមត្រូវ តាមនិយាមនៃការបង្រៀន គឺនាំមកនូវគុណសម្បត្តិជាច្រើនទាំងការបង្រៀន និងការរៀនមាន ៖

១. ធ្វើឲ្យការបង្រៀន និងរៀន ប្រព្រឹត្តទៅបានតាមលំដាប់ដោយ មិនសាំញ៉ាំ

២. គ្រប់គ្រងពេលវេលាបានយ៉ាងល្អ ទាំងការបង្រៀន និងរៀន

៣. ការបង្រៀនដែលមានសៀវភៅគោលត្រឹមត្រូវ ធ្វើឲ្យនិស្សិតមានភាពងាយស្រួលក្នុងការសិក្សា

៤. ធ្វើឲ្យការបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយសក្តានុពល ពោលគឺនិស្សិតនឹងទទួលបាននូវចំណេះដឹងពិតប្រាកដ ជំនាញពិតប្រាកដ កាលណាបណ្តុះបណ្តាលនិស្សិតដោយល្អប្រកបដោយគុណភាព គឺជាការបណ្តុះបណ្តាលប្រកបដោយគុណតម្លៃ សម្រាប់ចូលរួមអភិវឌ្ឍន៍ជាតិនាពេលអនាគត។

ដើម្បីឲ្យការសិក្សារបស់និស្សិតប្រកបដោយគុណភាព ក្នុងនាមលោក លោកស្រីសាស្ត្រាចារ្យគ្រប់រូបគួរតែចូលរួមក្នុងការចងក្រង និងនិពន្ធសៀវភៅ ដែលជាមុខវិជ្ជាត្រូវបង្រៀននៅថ្នាក់មហាវិទ្យាល័យឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ព្រោះថា កាលណាមានសៀវភៅដែលសមស្របទៅតាមជំនាញ ដែលនិស្សិតសិក្សានីមួយៗច្រើបបែប គឺជាកត្តាដ៏សំខាន់សម្រាប់ពង្រីកចំណេះដឹងរបស់និស្សិត រឹតតែមានវិសាលភាព។

ព្រោះកម្រិតនៃការសិក្សាថ្នាក់មហាវិទ្យាល័យ គឺជាកម្រិតនៃការសិក្សាស្រាវជ្រាវ ស្វែងរកអ្វីដែលថ្មី ទំនើប ទាន់សម័យ បានដល់ការសិក្សាអំពីអ្វីដែលថ្មី ដូច្នេះការចងក្រង និងនិពន្ធគឺជាការងារដ៏សំខាន់បំផុត ដែលត្រូវតែចាប់អារម្មណ៍ និងចូលរួមបំពេញការងារនេះដោយសកម្មបំផុត ដើម្បីលើកកម្ពស់វិស័យនៃការអប់រំ ឲ្យមានឥទ្ធិពលចំណេះដឹងចំពោះយុវជនប្រុសស្រីទាំងឡាយ ឲ្យពួកគេរឹងមាំ និងជាធនធានដ៏ល្អឯក សម្រាប់ជីវិតរបស់ពួកគេផ្ទាល់ គ្រួសារ សង្គម និងប្រទេសជាតិទាំងមូល។

ការចងក្រង និងនិពន្ធ គឺពោរពេញទៅដោយគុណតម្លៃដ៏ឧត្តមបំផុត ព្រោះនេះការជាអំពីសប្បុរស និងជាការធ្វើបុណ្យដ៏ថ្លៃថ្លាបំផុតសម្រាប់មនុស្សជាតិ ការផ្ដល់ឲ្យនូវវត្ថុអ្វីៗគ្រប់យ៉ាងដល់មនុស្សជាតិ ក៏ឈ្មោះថាជាការផ្ដល់ឲ្យមែនហើយ តែការផ្ដល់ឲ្យនោះមិនឈ្មោះថា ផ្ដល់ឲ្យសព្វយ៉ាងឡើយ តែចំពោះការផ្ដល់ឲ្យនូវចំណេះដឹងពិតប្រាកដ គឺជាការផ្ដល់ឲ្យនូវសម្បត្តិគ្រប់យ៉ាង ព្រោះមនុស្សដែលមានចំណេះដឹងហើយ អ្វីក៏អាចសម្រេចទៅជាប្រយោជន៍ដ៏ទូលាយបាន ដូចមានពាក្យកាព្យមួយបានលើកឡើងថា " មនុស្សល្ងង់ធំបានតែក្នុងផ្ទះខ្លួន អ្នកមានមាំមួនតែក្នុងភូមិអាត្មា គេបូជាស្ដេចតែក្នុងរដ្ឋា អ្នកមានវិជ្ជាគេបូជាសព្វទីកន្លែង"។

គុណតម្លៃនៃការចងក្រង និងនិពន្ធមានគុណតម្លៃធំធេងសម្រាប់មនុស្ស អ្នកនិពន្ធ និងចងក្រង អ្នកសិក្សា អ្នកអានទូទៅ និងស្រាវជ្រាវ ដើម្បីបន្តទៅចាប់យកចំណេះដឹងថ្មីទៀតៈ

១. ឈ្មោះថាបាន រក្សាទុកនូវចំណេះដឹងរបស់បុព្វបុរស និងអ្នកសិក្សាមុនៗឲ្យឋិតនៅសម្រាប់អ្នកជំនាន់ក្រោយសិក្សារៀនសូត្រ ដើម្បីបានជាគោលគំនិតក្នុងការអភិវឌ្ឍចំណេះបន្ថែមទៀត។

២. ឈ្មោះថា ជាអ្នកមានចិត្តសប្បុរសក្នុងការចែករំលែកនូវចំណេះដឹង ធម្មទាន ដល់មនុស្សជាតិ ព្រោះការផ្ដល់ឲ្យនូវចំណេះដឹងនេះ មិនមែនគ្រាន់តែដើម្បីសម្រាប់យកទៅធ្វើអាជីព សម្រាប់ចិញ្ចឹមជីវិតតែប៉ុណ្ណោះទេ តែជាការផ្ដល់នូវមូលដ្ឋានគ្រឹះនៃការពិចារណា ការវិភាគ ការវិនិច្ឆ័យប្រកបដោយភាពត្រឹមត្រូវ ជួយឲ្យមនុស្សមានសេចក្ដីព្យាយាម សេចក្ដីអំណត់អត់ធន់ យល់ពីហេតុផល ប្រតិបត្តិការងារដោយសុចរិតយុត្តិធម៌។ ការផ្ដល់ឲ្យនូវចំណេះដឹង គឺជាការផ្ដល់នូវកូនសោសម្រាប់ដាក់ដោះស្រាយ នូវបញ្ហាស្មុគស្មាញក្នុងជីវិត មានដូចជា បញ្ហាជីវិត បញ្ហាគ្រួសារ បញ្ហាការងារ បញ្ហាសង្គម បញ្ហាការដឹកនាំ បញ្ហាសេដ្ឋកិច្ច និងបញ្ហាជាច្រើនទៀតដែលតែងតែកើតមាននៅក្នុងជីវិត។

៣. ឈ្មោះថា ជាអ្នកបានផ្សព្វផ្សាយនូវវប្បធម៌ អរិយធម៌ ប្រពៃណីទំនៀមទម្លាប់ ដែលជាអត្តសញ្ញាណជាតិរបស់ខ្លួន ឲ្យមានការរីកចម្រើន សម្រាប់មនុស្សជំនាន់ក្រោយបន្តទៀត។

៤. ឈ្មោះថាជាអ្នកបានចូលរួមអភិរក្សអក្សរសាស្ត្រ អក្សរសិល្ប៍ ជាដើមឲ្យគង់វង្សជានិរន្តរ៍តទៅ។

៥. ក្នុងនាមជាគ្រូបង្រៀន ដែលឋិតនៅក្នុងឋានៈជាបញ្ញវន្ត គួរតែចូលរួមចងក្រង និងនិពន្ធអត្ថបទល្អៗដើម្បីចែករំលែកដល់សិស្ស និស្សិត និងអ្នកសិក្សារៀនសូត្រដទៃទៀត ជាសម្បត្តិដ៏ប្រពៃ ជាស្នាដៃដ៏ឧត្តម ព្រោះការចងក្រង និងនិពន្ធនេះគឺជាជំនាញ និងការងាររបស់គ្រូបង្រៀន ដែលត្រូវបំពេញជាចាំបាច់។

## គន្ថនិទ្ទេស


១. កម្ពុជសុរិយា ភាគ១/២៧ គ.ស១៩២៦

២. កម្ពុជាសុរិយា ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ ពុទ្ធសាសនបណ្ឌិត្យ ភាគ ២៧/២ គ.ស១៩៥៥

៣. កម្ពុជសុរិយា ភាគ៥៧ ២០០៣ គ.ស

៤. កម្ពុជសុរិយា ភាគ ៣២/១ គ.ស១៩៦០

៥. កម្ពុជសុរិយា ៤៣/១/ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ គ.ស ១៩៧១

៦. កម្ពុជសុរិយា ភាគ៣១/១ គ.ស១៩៥៩

៧. កម្ពុជសុរិយា ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ ពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥១៤ គ.ស ១៩៧០

៨. កម្ពុជសុរិយា ភាគ៤៤/១ គ.ស១៩៧២

៩. កម្ពុជាសុរិយា ភាគ៦/២ ខ្សែ ១០ ១១ ១២ រួមគ្នា ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស ២៤៧៧ គ.ស ១៩៣៤

១០. កម្ពុជសុរិយា ភាគ៥២ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស ២៥៤១ គ.ស ១៩៩៨

១១. កម្ពុជសុរិយា ទស្សនវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ ព.ស ២៥១៤ គ.ស ១៩៧០

១២. កម្ពុជសុរិយា ភាគ ១០/១ ពុទ្ធសាសនបណ្ឌិត្យ គ.ស ១៩៣៨

១៣. កម្ពុជាសុរិយា ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ ពុទ្ធសាសនបណ្ឌិត្យ ភាគ ៤២/១ គ.ស១៩៧០

១៤. ជួន ណាត វចនានុក្រមខ្មែរ ភាគទី១ ភាគទី២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យព.ស២៥១២ គ.ស១៩៦៨

១៥. ឈឹម ទូច ប្រស្នាត្រៃគុណ ពុទ្ធសាសនបណ្ឌិត្យ គ.ស១៩៩៩

១៦. ឈឹម ទូច ប្រស្នាត្រៃគុណ ពុទ្ធសាសនបណ្ឌិត្យ គ.ស១៩៩៩

១៧. ឈឹម ទូច អធិប្បាយប្រជុំកងធម៌ពិស្ដារ ព.ស ១២៥១៦ គ.ស ១៩៧២

១៨. ប៊ុឹង ប៉ម ការបណ្ដុះនិស្ស័យ ព.ស ២៥៥៤ គ.ស ២០១០ ទំព័រ ១១១-១៣៩

១៩. ប៊ុត សាវង្ស វិធីម្ងាប់សេចក្ដីក្រោធ ព.ស ២៥៤៧

២០. ពុទ្ធសាសនា ២៥០០ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៤៥

២១. ពុទ្ធសាសនា ២៥០០ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ព.ស២៥៤៥

២២. ពុទ្ធសាសនា ២៥០០ ការផ្សាយរបស់វិទ្យាស្ថានរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥៤៥

២៣. វិន័យបិដក មហាវគ្គ ទុតិយភាគ ៧ វស្សូបនាយិកក្ខន្ធកៈ ព.ស ២៥៥៣

២៤. សុង ស៊ីវ ពុទ្ធសាសនា និងវិទ្យាសាស្ត្រ ទស្សនវិជ្ជា តក្កវិជ្ជា វិទ្យាសាស្ត្រ ព.ស ២៥១៦ គ.ស ១៩៧២

២៥. សុង ស៊ីវ ត្រៃលក្ខណប្រទីប ការផ្សាយរបស់បណ្ណាគារ ត្រៃរតន៍ លេខ១៣៦អ៊ី០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ ព.ស ២៤៩៨ គ.ស ១៩៥៥

២៦. សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ភាគ១៩ ព.ស ២៥០៣

២៧. សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត តតិយភាគ ភាគ៥៤

២៨. សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត តតិយភាគ ៤២ ព.ស ២៥៥៣

២៩. សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត កាលាមសូត្រ ភាគ ៤១ ទំព័រ ២១៦-២២៩

៣០. សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋ ធម្មបទគាថា ឧទាន បឋមភាគ ៥២ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស ២៥០០

៣១. ហេង មណីចិន្តា គម្ពីរវិមុត្តិមគ្គ ព.ស ២៥៥៤

៣២. ហ៊ាត ណាហំ សីលត្ថទីបនី ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា ព.ស ២៥៥៧ គ.ស ២០១៣

៣៣. ហេង មណីចិន្តា ព្រះបាទធម្មិក គ.ស ១៩៩៥

៣៤. សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត ឯកាទសមភាគ អានិសង្សវគ្គភាគ៥០ ទំព័រទី ១ ដល់ ៣

៣៥. http://5000-years.org/kh/read/2286

៣៦. https://thmeythmey.com/?page=detail&id=41409

៣៧. https://thmeythmey.com/?page=detail&id=41409

៣៨. https://www.rfi.fr/km/cambodia/20180214-គុណប្រយោជន៍-នៃការធ្វើ-សមាធិ